**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ កែប្រែនៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៧

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្រ្តីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

**សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២)**

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្តីលោក ខៀវ សំផន៖**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ូរ ឧត្តរា

ចៅក្រម Claudia FENZ

ចៅក្រម យ៉ា សុខន

| | |
|---|---|
| កញ្ញា Soumeya MEDJEBEUR | **សហព្រះរាជអាជ្ញា៖** |
| លោក Clément BOSSIS | លោកស្រី ជា លាង |
| កញ្ញា Cécile ROUBEIX | លោក Nicholas KOUMJIAN |
| កញ្ញា អ៊ុច ស្រីផាត | |
| លោក តាន់ ឆាយរ័ត្ន | **មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| | **មេធាវីការពារក្តីលោក នួន ជា** |

# មាតិកា

មាតិកា ....................................... 3

សេចក្តីផ្តើម ....................................... 27

មាតិកាទី ១. ឧត្តមភាពនៃច្បាប់ ....................................... 28

ភាគទី ១. គ្មានវិធានយុត្តិសាស្ត្រ ....................................... 29

ជំពូកទី ១. ច្បាប់ជាតិ ....................................... 29

ជំពូកទី ២. ច្បាប់អន្តរជាតិ ....................................... 31

ផ្នែកទី ១. តុលាការយុត្តិធម៌អន្តរជាតិ ....................................... 31

ផ្នែកទី ២. តុលាការសិទ្ធិមនុស្សអឺរ៉ុប ....................................... 32

ផ្នែកទី ៣ .តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ....................................... 33

ផ្នែកទី ៤. តុលាការព្រហ្មទណ្ឌអន្តរជាតិ ....................................... 35

ជំពូកទី ៣. ច្បាប់របស់ អ.វ.ត.ក ....................................... 35

ភាគទី ២. យុត្តាធិការ ....................................... 38

ជំពូកទី ១. យុត្តាធិការពេលវេលា ....................................... 38

ផ្នែកទី ១. វិសាលភាព ....................................... 38

ផ្នែកទី ២. "សាលក្រម" សំណុំរឿង ០០២/០១ ....................................... 38

១. សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូល ....................................... 39

២. វិនិច្ឆ័យកិច្ចមិនត្រឹមត្រូវរបស់អង្គជំនុំជម្រះតុលាការកំពូល ....................................... 41

ផ្នែកទី ៣. សេចក្តីសន្និដ្ឋានលើសំណុំរឿង ០០២/០២ ....................................... 46

ជំពូកទី ២. យុត្តាធិការលើរឿងក្តី ....................................... 47

ផ្នែកទី ១. បណ្តឹងមកកាន់អង្គជំនុំជម្រះ នៅក្នុងដីកាដំណោះស្រាយស្ថាពរ ....................................... 47

១. នីតិវិធីនាំទៅរកដីកាដំណោះស្រាយ ....................................... 47

២. ដីកាដំណោះស្រាយ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ....................................... 50

ផ្នែកទី ២. ពាក្យបណ្តឹងកម្រិតមកត្រឹមអង្គហេតុមួយចំនួននៅក្នុងដីកាដំណោះស្រាយ ....................................... 53

១. បុព្វហេតុរបស់ដីកាដំណោះស្រាយ៖ ផ្តល់ព័ត៌មានអំពីបទចោទទាំងឡាយ ....................................... 54

២. ការកំណត់យកតែអង្គហេតុដែលជនជាប់ចោទត្រូវបានបញ្ជូនទៅជំនុំជម្រះ ....................................... 57

៣. បណ្តឹងដែលមិនអាចពង្រីកបាន ....................................... 59

ក. ច្បាប់ common law ....................................... 60

1. ការស៊ើបសួរ ....................................... 61

2. សាលក្រម ....62

2.ក.អង្គហេតុនៅក្រៅបណ្តឹងមកចៅក្រមស៊ើបអង្កេត ....64

2.ខ. អង្គហេតុមិននៅក្នុងពាក្យបណ្តឹង....65

i. បម្រាមពន្លាតដែនបណ្តឹងដោយឯកឯង ....65

ii. រួមទាំងករណីនៃការកែប្រែបទចោទ....67

iii. គ្រប់បទចោទទាំងអស់ ត្រូវតែលើកឡើងតែពីបទចោទ....69

3. បណ្តឹងឧទ្ធរណ៍ ....70

ខ. ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ....71

1. តុលាការព្រហ្មទណ្ឌអន្តរជាតិ ....71

2. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា និងតុលាការអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី....73

ផ្នែកទី ៣. វិសាលភាពនៃបណ្តឹងកាន់តែបង្រួមតូច ដោយដីកាបំបែកការចោទប្រកាន់ ....77

ផ្នែកទី ៤. ធាតុផ្សំដែលត្រូវដកចេញពីការពិភាក្សាសម្រេចក្នុងសំណុំរឿង ០០២/០២....79

១. ធាតុផ្សំនៃអង្គហេតុដែលមិនធ្លាប់បានប្តឹងមកអង្គជំនុំជម្រះទាល់តែសោះ ....79

ក. ខ្មែរក្រោម ....79

1. ការស៊ើបអង្កេត....80

2. ការជំនុំជម្រះ....81

ខ. ការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍....86

1. ការស៊ើបអង្កេត....86

2. ការជំនុំជម្រះសេចក្តី ....88

2.ក. គំនិតពុតត្បុតរបស់សហព្រះរាជអាជ្ញា....92

2.ខ. អសង្គតភាពរបស់អង្គជំនុំជម្រះ ....95

២. ធាតុផ្សំនៃអង្គហេតុដែលអង្គជំនុំជម្រះបានជម្រុះចោល ....97

៣. ធាតុផ្សំនៃអង្គហេតុដែលអង្គជំនុំជម្រះមិនបានទទួលត្រឹមត្រូវតាមនីតិវិធី ....100

ក. អង្គហេតុនៅក្រៅវិសាលភាពនៃបណ្តឹងមកកាន់សហចៅក្រមស៊ើបអង្កេត ....101

1. អង្គហេតុស្តីពីការជម្លៀស ....102

1.ក. ការកំណត់វិសាលភាពនៃបណ្តឹងដោយចិត្តឯងរបស់ចៅក្រមស៊ើបអង្កេត ....107

1.ខ. ការបដិសេធរបស់អង្គបុរេជំនុំជម្រះក្នុងការអារកាត់ឱ្យអស់សេចក្តី ....110

1.គ. ការបដិសេធមិនព្រមអារកាត់ឱ្យអស់សេចក្តីរបស់អង្គជំនុំជម្រះ....114

i. យុត្តិនិសេធ....115

ii. ការបង្ហាញអំពីភាពអគតិ ..........116

1.ឃ. សេចក្តីសន្និដ្ឋាន ..........120

2. អង្គហេតុ នៃ "ការបោសសម្អាត" ..........121

ខ. អង្គហេតុដែលពុំមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជូនទៅជំនុំជម្រះ ..........125

ភាគទី ៣. គោលការណ៍នីត្យានុកូលភាព (គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង) ..........127

ជំពូកទី ១. ទំនាក់ទំនងនៃគោលការណ៍ប្រឆាំងនឹងការផ្តន្ទាទោសតាមទំនើងចិត្ត..........127

ផ្នែកទី ១. គោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ..........130

ផ្នែកទី ២. គោលការណ៍ដឹងឮ និងអាចគ្រោងទុកបាន ..........131

១. ការដឹងឮ ..........132

២. ការអាចគ្រោងទុកមុនបាន ..........133

ផ្នែកទី ៣. គោលការណ៍បកស្រាយចង្អៀត និងជាប្រយោជន៍ដល់ជនជាប់ចោទ..........135

ជំពូកទី ២. ការកម្ទេចខ្លឹមសារនៃគោលការណ៍នានាដោយអង្គជំនុំជម្រះតុលាការកំពូល ..........138

ផ្នែកទី ១. ភាពឈានមុខនិយមនៃតុលាការ ..........141

១. វិនិច្ឆ័យកិច្ចដ៏មានកំហុស និងអគតិ..........141

២. គោលនយោបាយឧក្រិដ្ឋ៖ ការតស៊ូប្រឆាំងនឹងនិទណ្ឌភាពដែលបង្កផលប៉ះពាល់ដល់ការតស៊ូប្រឆាំងនឹងការផ្តន្ទាទោសតាមទំនើងចិត្ត..........146

ផ្នែកទី ២. លក្ខណៈពិសេសរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ..........156

១. ការលំបាកក្នុងការកំណត់វិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ..........156

២. ការអនុវត្តទូទៅ ..........159

៣. ទស្សនៈច្បាប់ដែលត្រូវបានទទួលយកជាច្បាប់ (OPINIO JURIS) ..........160

ផ្នែកទី ៣. ធាតុផ្សំចេតនានៃមនុស្សឃាតដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ..........161

១. អវត្តមាននៃចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មដោយប្រយោលនៅក្នុងរឿងក្តីគ្រូពេទ្យ ..........162

ក. អវត្តមាននៃការកំណត់និយមន័យនៃធាតុផ្សំអត្តនោម័ត ..........164

ខ. អវត្តមាននៃចេតនាប្រយោលនៅក្នុងអង្គហេតុ ..........165

២. ការមិនអាចអនុវត្តបាននៃច្បាប់ជាតិឆ្នាំ ១៩៧៥..........170

ក. ការយោងមិនត្រឹមត្រូវទៅលើច្បាប់កម្ពុជា ..........171

ខ. ការយោងទៅច្បាប់ដែលតាក់តែងឡើងក្រោយអង្គហេតុ..........172

គ. ការយោងទៅច្បាប់ដែលត្រូវបានតាក់តែងឡើងមុនអង្គហេតុដែលមិនអាចបង្កើតបានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ..........172

ផ្នែកទី ៤. ការបង្កើតសញ្ញាណសហឧក្រិដ្ឋកម្មរួមមួយតាមការកាត់តម្រឹម..........173

១. អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ និងនត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅសម័យអង្គហេតុ ......174

២. ការបង្កើតសហឧក្រិដ្ឋកម្មរួមកូនកាត់៖ "សហឧក្រិដ្ឋកម្មរួម ទម្រង់ទីបួន" របស់អង្គជំនុំជម្រះតុលាការកំពូល ......179

៣. នត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមកូនកាត់ ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ......183

ក. សាលដីកា Tadic និងយុត្តិសាស្ត្រក្រោយពេលសង្គ្រាម ......183

ខ. រឿងក្តីទាក់ទងនឹងគោលបំណងមិនឧក្រិដ្ឋ......190

1. រឿងក្តី Brima......190

2. រឿងក្តី *Martic* ......192

3. រឿងក្តី *KRAJISNIK*......194

4. រឿងក្តី *Prlic* ......195

គ. សេចក្តីសន្និដ្ឋាន ......197

៤. លក្ខណៈតែមួយគត់មិនធ្លាប់មាននៃការបូកបញ្ចូលគ្នាអោយខាងតែបានរវាងសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ និងសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី......199

៥. ការបង្កើតដោយកាត់តម្រឹមដើម្បីផ្តន្ទាទោសជនជាប់ចោទនៅ អ.វ.ត.ក ......202

ភាគទី ៤. វិធានច្បាប់ស្តីអំពីការពិនិត្យភ័ស្តុតាង ......207

ជំពូកទី ១. ចម្លើយជាលាយលក្ខណ៍អក្សរ ......210

ផ្នែកទី ១. ច្បាប់ដែលអាចអនុវត្តបានចំពោះការពិនិត្យពិចារណាលើចម្លើយជាលាយលក្ខណ៍អក្សរ ......210

១. តម្លៃជាភ័ស្តុតាងតិចបំផុត ......210

២. ការហាមឃាត់ប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរមួយចំនួន......212

ក. ការប្រាសចាករបស់អង្គជំនុំជម្រះ និងតុលាការកំពូលក្នុងសំណុំរឿង ០០២/០១......214

ខ. ការខ្វាចក្រែងមានការប្រាសចាកពីច្បាប់នៅក្នុងសំណុំរឿង ០០២/០២......217

ផ្នែកទី ២. ប្រតិចារឹកសវនាការនៃសំណុំរឿង ០១/០០២......220

ផ្នែកទី ៣. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី......222

ផ្នែកទី ៤. ចម្លើយរបស់ ស សារិន ......224

ជំពូកទី ២. ពាក្យចរចាមអារាម ......224

ជំពូកទី ៣. អ្នកជំនាញ ......225

ផ្នែកទី ១. ច្បាប់ដែលអាចអនុវត្តបានចំពោះការពិនិត្យពិចារណាលើសក្ខីកម្មរបស់អ្នកជំនាញ ......226

ផ្នែកទី ២. អវត្តមាននៃភាពគួរឱ្យទុកចិត្តបាន និងតម្លៃជាភ័ស្តុតាងនៃសក្ខីកម្មរបស់អ្នកជំនាញមួយចំនួន 228

១. អ៊ីសា ឧស្មាន ......229

២. អ្នកជំនាញ Alexander HINTON.......................................................230

៣. Henri LOCARD .......................................................231

ក. ភាពអគតិយ៉ាងខ្លាំង .......................................................233

ខ. “អ្នកជំនាញ” ត្រូវបានផ្តល់ដោយប្រភពរបស់ខ្លួនផ្ទាល់.......................................................244

1. អវត្តមានទំនាក់ទំនងរវាង ប៉ុល ពត និង ខៀវ សំផនក្នុងទសវត្សឆ្នាំ៩០ .......................................................246

2. ការសន្និដ្ឋានព្រាវអំពីតួនាទីនិងអំណាចរបស់ ខៀវ សំផន .......................................................247

គ. សេចក្តីសន្និដ្ឋាន .......................................................249

ជំពូកទី ៤. ធាតុផ្សំដែលទទួលបានពីការធ្វើទារុណកម្ម.......................................................249

ជំពូកទី ៥. វិមតិសង្ស័យ .......................................................250

ភាគទី ៥. សមធម៌ .......................................................257

ជំពូកទី ១. ការសន្និដ្ឋានទុកជាមុនក្នុងសំណុំរឿង ០០២/០១ .......................................................257

ជំពូកទី ២. ការបង្ហាញអំពីភាពអគតិក្នុងសំណុំរឿង ០០២០២/.......................................................259

ផ្នែកទី ១. រឿងក្តីក្នុងដំណាក់កាលស៊ើបអង្កេតដាក់បន្ទុក .......................................................259

ផ្នែកទី ២. ការសន្មតទុកជាមុនអំពីសុឆន្ទៈរបស់សហព្រះរាជអាជ្ញា និងអសុឆន្ទៈរបស់ក្រុមមេធាវីការពារក្តី .......................................................262

មាតិកាទី ២. ជម្លោះប្រដាប់អាវុធ៖ បរិបទសំខាន់.......................................................265

ភាគទី ១. ដើមហេតុ និងការចាប់ផ្តើមជម្លោះ.......................................................266

ជំពូកទី ១. សត្រូវបងប្អូនឯង.......................................................268

ផ្នែកទី ១. ចំណុចប៉ះទង្គិចគ្នា មុនឆ្នាំ ១៩៧៥ .......................................................268

១. កិច្ចព្រមព្រៀងទីក្រុងបញ្ជីណែរ និងការដាក់ជនកុម្មុយនីស្តកម្ពុជាឱ្យនៅក្រៅវាក .......................................................269

២. ការមិនទុកចិត្តគ្នា ទោះបីជាធ្លាប់តស៊ូរួមគ្នាក៏ដោយ.......................................................270

៣. កិច្ចព្រមព្រៀងទីក្រុងប៉ារីស ឬការបញ្ចប់អាណាព្យាបាលភាពរបស់ “បងធំ”.......................................................272

ផ្នែកទី ២. ជម្លោះព្រំដែន ចាប់ពីឆ្នាំ ១៩៧៥.......................................................273

១. ព្រំដែនដែលបន្សល់ទុកពីរដ្ឋបាលអាណានិគម.......................................................274

២. ប្រភពនៃការផ្ទុះជម្លោះ .......................................................275

ជំពូកទី ២. ឆ្នាំ ១៩៧៥-ឆ្នាំ ១៩៧៦៖ តុល្យភាពដ៏លំបាក រវាងសម្ព័ន្ធភាព និងអធិបតេយ្យជាតិ .......................................................276

ផ្នែកទី ១. ការប៉ុនប៉ងចរចា នៅពេលចាប់ផ្តើមជម្លោះ.......................................................276

១. ការចរចាដើម្បីប៉ុនប៉ងបន្ធូរបន្ថយភាពតានតឹង.......................................................277

២. ការបដិសេធរាល់ការប៉ះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជាប្រជាធិបតេយ្យ .......................................................278

ផ្នែកទី ២. បរិបទភូមិសាស្ត្រនយោបាយស្មុគស្មាញ.......................................................280

១. ចលនានៃប្រទេសមិនចូលបក្សសម្ព័ន្ធ និងបញ្ហាប្រឈមខាងការទូត ....................................281
២. ចិន និងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតនៅពីក្រោយឆាក ....................................282
ភាគទី ២. ការប្រព្រឹត្តិទៅនៃជម្លោះ ផ្អែកតាមភ័ស្តុតាងនៅក្នុងសំណុំរឿង ....................................283
ជំពូកទី ១. ការបកស្រាយជម្លោះជាឯកតោភាគី ដែលសហព្រះរាជអាជ្ញាបានជ្រើសយក ....................................283
ផ្នែកទី ១. ការប្រើប្រាស់តិចតួចនូវឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យ ....................................284
ផ្នែកទី ២. ការប្រើប្រាស់ចាំបាច់នូវបណ្ណសាររបស់កម្ពុជាប្រជាធិបតេយ្យ សម្រាប់ការបកស្រាយបញ្ហាស ពីនេះ ....................................288
១. ទេវកថាអំពីឆន្ទៈចូលចិត្តប្រើកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យ ....................................288
២. ការយល់ដឹងពីវិសមភាពកម្លាំងយោធារវាងកងទ័ពទាំងពីរ ....................................291
៣. ភាពខុសគ្នាខាងយោធា និងអវត្តមានឆន្ទៈប្រើកម្លាំង តាមការសង្កេតរបស់សាក្សីទាំងអស់ ....................................293
ក. ភាពខុសគ្នាខាងយោធា និងការការពារដែនដីគោក ....................................293
ខ. ការការពារដែនទឹក ....................................298
1. សក្ខីកម្មខុសគេរបស់សាក្សី 2-TCW-1000 ស្តីពីបញ្ហាយោធាឱ្យធ្វើបាបជនស៊ីវិលវៀតណាម ....................................300
1.ក. មុខងារជាកូនទាហានឈរជើងការពារដែនទឹកកម្ពុជា ....................................301
1.ខ. បញ្ហាដែលសន្មតថាទទួលបានពីមេបញ្ជាការកងវរសេនាតូច ....................................303
2. សក្ខីកម្មស៊ីសង្វាក់គ្នារបស់អតីតយោធានៃកងទ័ពបដិវត្តន៍កម្ពុជា ....................................305
ជំពូកទី ២. កាលប្បវត្តិសង្ខេបនៃការប៉ះទង្គិចដោយអាវុធ ....................................315
ផ្នែកទី ១. ការកើនឡើងនូវជម្លោះព្រំដែន ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦ ....................................315
១. ការប៉ះទង្គិចគ្នាដំបូងៗ និងការបន្តការចរចា ....................................315
២. ការប្រយុទ្ធកាន់តែមានសភាពខ្លាំងឡើង ....................................320
ផ្នែកទី ២. ជម្លោះឡើងកម្តៅខ្លាំង ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨ ....................................324
១. ការលុកលុយកាន់តែញឹកញាប់ និងចំណុចរបត់ នៅឆ្នាំ ១៩៧៧ ....................................324
២. សារទូរលេខបញ្ជាក់អំពីសង្គ្រាមចំហ ....................................327
ផ្នែកទី ៣. ការប្រកាសបរាជ័យរបស់កម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ ១៩៧៨ ដល់ឆ្នាំ ១៩៧៩ ....................................330
១. កងទ័ពអន់ថយរបស់កម្ពុជាប្រជាធិបតេយ្យ ....................................330
២. យុទ្ធសាស្ត្រមានប្រសិទ្ធភាពរបស់វៀតណាម ....................................332
ក. សម្ព័ន្ធភាពជាមួយអ្នកផ្តាច់ខ្លួនចេញពីបក្សកុម្មុយនីស្តកម្ពុជា ....................................333
ខ. ការរៀបចំសមរភូមិការទូត ....................................335
1. ការគ្រប់គ្រងល្បែងការទូតដោយវៀតណាម ....................................335

2. សេចក្តីថ្លែងការណ៍គ្មានប្រសិទ្ធភាពរបស់កម្ពុជាប្រជាធិបតេយ្យ ....................337
ភាគទី ៣. ផលវិបាកនៃជម្លោះប្រដាប់អាវុធក្នុងវិធីសាស្ត្រនៃសំណុំរឿង ០០២/០២ ....................339
ផ្នែកទី ១. ផលវិបាកនៃជម្លោះទៅលើការពិនិត្យលើអង្គហេតុ ....................339
ផ្នែកទី ២. ផលវិបាកទៅលើការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ....................341
មាតិកាទី ៣. ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ....................343
ភាគទី ១. សហករណ៍ និងការដ្ឋានការងារ ....................343
ជំពូកទី ១. សហករណ៍ត្រាំកក់ ....................343
ផ្នែកទី ១. បទចោទ ....................343
១. ការកម្រិតផ្នែកភូមិសាស្ត្រនៃបទចោទ ....................344
២. ការកម្រិតជាក់ស្តែងនៃបទចោទ ....................345
ក. ការសម្លាប់រង្គាល ....................345
1. ការស្លាប់ដោយសារអត់អាហារ ....................346
2. ការស្លាប់ដោយសារបញ្ហាសុខភាព ....................347
3. ការសម្លាប់ជនជាតិវៀតណាម ....................348
ខ. ការធ្វើឱ្យទៅជាទាសករ ....................349
គ. ការដាក់ក្នុងមន្ទីរឃុំឃាំង ....................350
ឃ. ការធ្វើទារុណកម្ម ....................351
ង. ការធ្វើទុកបុកម្នេញដោយមូលហេតុពូជសាសន៍ ....................352
ច. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ....................353
ឆ. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស) ......360
ជ. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ) ....................360
ផ្នែកទី ២. ភស្តុតាងគាំទ្រដល់សេចក្តីសន្និដ្ឋាននៃដីកាដំណោះស្រាយ ....................361
១. អំពីសមាសភាពស្រុកត្រាំកក់ ....................361
២. ការស្លាប់ ដោយការស្រេកឃ្លាន នៅតាមឃុំនៃស្រុកត្រាំកក់ ....................364
៣. អំពីអង្គហេតុដែលត្រូវបានកំណត់ថាជាការដាក់ក្នុងមន្ទីរឃុំឃាំង ....................366
៤. អំពីអង្គហេតុដែលត្រូវបានកំណត់ថាជាការធ្វើទារុណកម្ម ....................368
៥. អំពីការចោទប្រកាន់អំពីការលុបបំបាត់ "សិទ្ធិនយោបាយ" របស់ប្រជាជនថ្មី ....................369
ផ្នែកទី ៣. ការបង្ហាញភស្តុតាង ....................371
១. បញ្ជីភស្តុតាង ....................371
២. ភស្តុតាងក្រៅវិសាលភាព ....................373

ក. ឧទាហរណ៍អំពីអង្គហេតុកើតឡើងនៅតាមឃុំក្រៅវិសាលភាព ....373
ខ. ឧទាហរណ៍នៃអង្គហេតុពាក់ព័ន្ធនឹងជនជាតិភាគតិចវៀតណាម ....376
៣. ភ័ស្តុតាងអំពីឧក្រិដ្ឋកម្មមួយចំនួន ....378
ផ្នែកទី ៤. ការពិនិត្យមើលភ័ស្តុតាងពាក់ព័ន្ធ....379
១. គ្មានមនុស្សស្លាប់ដោយអត់បាយ នៅតាមឃុំក្នុងវិសាលភាពនៃបណ្តឹង ....379
ក. ឃុំសំរោង ....380
1. រី ពៅ ....380
2. ភ្នៅ យ៉ាវ ....382
3. ផាន់ ឆេន....383
ខ. ឃុំតាភេម....383
ផ្នែកទី ៥. ការកំណត់ប្រភេទបទល្មើស ....384
១. និយមន័យនៃការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ....385
២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ....385
ជំពូកទី ២. ទំនប់ត្រពាំងថ្ម....385
ផ្នែកទី ១. ការចោទប្រកាន់ ....385
១. អំពើមនុស្សឃាត....386
២. ការសម្លាប់រង្គាល ....387
៣. ការធ្វើឱ្យទៅជាទាសករ ....388
៤. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ....388
៥. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស)....390
៦. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ)....390
ផ្នែកទី ២. ភ័ស្តុតាងគាំទ្រដល់សេចក្តីសន្និដ្ឋាននៃដីកាដំណោះស្រាយ ....391
ផ្នែកទី ៣. ការបង្ហាញភ័ស្តុតាង ....392
១. បញ្ជីភ័ស្តុតាង ....393
២. ភ័ស្តុតាងក្រៅវិសាលភាព ....393
៣. ភ័ស្តុតាងអំពីឧក្រិដ្ឋកម្មមួយចំនួន ....394
ផ្នែកទី ៤. ការពិនិត្យមើលភ័ស្តុតាងពាក់ព័ន្ធ....395
ផ្នែកទី ៥. ការកំណត់ប្រភេទបទល្មើស ....397
១. និយមន័យនៃការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ....397
២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ....397

ជំពូកទី ៣. ទំនប់ ១ មករា ....................397
ផ្នែកទី ១. បទចោទ....................397
១. អំពើមនុស្សឃាត ....................398
២. ការសម្លាប់រង្គាល ....................400
៣. ការធ្វើឱ្យទៅជាទាសករ ....................401
៤. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ....................401
៥. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ....................403
៦. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស)....................403
៧. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ) ....................403
ផ្នែកទី ២. ការបង្ហាញភ័ស្តុតាង ....................404
១. បញ្ជីភ័ស្តុតាង ....................404
២. ភ័ស្តុតាងក្រៅវិសាលភាព ....................405
៣. ភ័ស្តុតាងអំពីឧក្រិដ្ឋកម្មមួយចំនួន ....................406
ផ្នែកទី ៤. ការពិនិត្យមើលភ័ស្តុតាងពាក់ព័ន្ធ....................407
ផ្នែកទី ៤. ការកំណត់ប្រភេទបទល្មើស ....................408
១. និយមន័យនៃការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ....................408
២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ....................408
ជំពូកទី ៤. ព្រលានយន្តហោះកំពង់ឆ្នាំង ....................408
ផ្នែកទី ១. បទចោទ....................408
១. អំពើមនុស្សឃាត....................409
២. ការសម្លាប់រង្គាល ....................413
៣. ការធ្វើឱ្យទៅជាទាសករ ....................415
៤. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ....................416
៥. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស)....................416
៦. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ)....................417
ផ្នែកទី ២. ការបង្ហាញភ័ស្តុតាង ....................418
១. បញ្ជីភ័ស្តុតាង ....................418
២. ភ័ស្តុតាងក្រៅវិសាលភាព ....................418
៣. ភ័ស្តុតាងអំពីឧក្រិដ្ឋកម្មមួយចំនួន ....................419
ផ្នែកទី ៣. ការពិនិត្យមើលភ័ស្តុតាងពាក់ព័ន្ធ ....................420

ផ្នែកទី ៤. ការកំណត់ប្រភេទបទល្មើស ....................................................................421
១. និយមន័យនៃការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ....................................421
២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ..............................................................422
ជំពូកទី ៤. គោលនយោបាយស្តីពីសហករណ៍ និងការដ្ឋានការងារ ...........................................422
ផ្នែកទី ១. សេដ្ឋកិច្ចសង្គ្រាម ..........................................................................423
១. ទំនើបកម្មជាចាំបាច់នូវប្រព័ន្ធចាស់ និងហួសសម័យ ..................................................423
២. ការប្រយុទ្ធខាងសេដ្ឋកិច្ច ដែលបំផ្លាញដោយការប្រយុទ្ធនៅសមរភូមិ ...............................425
ផ្នែកទី ២. ការកំណត់គោលដៅកែលម្អជីវភាពប្រជាជនឱ្យប្រសើរឡើង ...................................428
១. គោលដៅនៃដំណើរការសហករណ៍ និងការដ្ឋានការងារ..................................................428
២. កសិកម្មជាប្រភពដើមទុនតែមួយគត់......................................................................431
ភាគទី ២. មន្ទីរសន្តិសុខ...........................................................................................434
ជំពូកទី ១. ស-២១ ...............................................................................................434
ផ្នែកទី ១. បទចោទ.............................................................................................434
ផ្នែកទី ២. ការបង្ហាញភ័ស្តុតាង ..............................................................................435
១. ភ័ស្តុតាងបានមកពីសក្ខីកម្ម..................................................................................435
២. ភ័ស្តុតាងឯកសារ ..............................................................................................436
ក. បញ្ជីអ្នកទោសធ្វើឡើងដោយសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត ..436
ខ. សៀវភៅបញ្ជី E3/10770 ....................................................................................438
៣. អង្គហេតុក្រៅវិសាលភាពនៃការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ ...............................441
ផ្នែកទី ៣. ការពិនិត្យមើលភ័ស្តុតាងពាក់ព័ន្ធ ...............................................................442
១. វត្តមាន និងការចាប់ជនជាតិវៀតណាម នៅ ស-២១.....................................................443
ក. វត្តមានជនបរទេសនៅ ស-២១ ...........................................................................443
ខ. គ្មានព័ត៌មានអំពីចំនួនជនជាតិវៀតណាម នៅ ស-២១ ...................................................444
គ. គ្មានភាពច្បាស់លាស់ពាក់ព័ន្ធនឹងថ្ងៃដំបូងនៃការដឹកជនជាតិវៀតណាមចូល ស-២១ ...........444
២. លក្ខខណ្ឌនៃការឃុំខ្លួន និងសួរចម្លើយ ...................................................................445
ក. ឌុច តទល់នឹងចម្លើយរបស់ ផន ថនចាន់ ស្តីពីការសួរចម្លើយយោធាវៀតណាម ................446
ខ. អលទ្ធភាពក្នុងការសន្និដ្ឋានថាមានការប្រព្រឹត្តិខុសគ្នាទៅលើអ្នកទោសវៀតណាម .............447
គ. ការចាប់ទាហានវៀតណាម ភាគច្រើន នៅតាមព្រំដែន.................................................448
ឃ. ខ្សែភាពយន្តឃោសនា និងទាហានវៀតណាម .........................................................449
ង. ជនស៊ីវិលវៀតណាម នៅ ស-២១ ជាតិញដូចអ្នកផ្សេងដែរ ...........................................450

ផ្នែកទី ៤. ការកំណត់ប្រភេទបទល្មើស ....451
១. និយមន័យនៃការធ្វើទុក្ខបុកម្នេញ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)....451
២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ....452
ជំពូកទី ២. ក្រាំងតាចាន់....454
ផ្នែកទី ១. បទចោទ....454
១. អំពើមនុស្សឃាត....455
២. ការសម្លាប់រង្គាល....458
៣. ការធ្វើឱ្យទៅជាទាសករ ....460
៤. ការដាក់ក្នុងមន្ទីរឃុំឃាំង....461
៥. ការធ្វើទារុណកម្ម ....461
៦. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ....463
៧. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ....466
៨. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស)....467
៩. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ)....468
ផ្នែកទី ២. ការបង្ហាញភស្តុតាង ....469
១. បញ្ជីភស្តុតាង ....469
២. ភស្តុតាងក្រៅវិសាលភាព ....471
៣. ភស្តុតាងដែលមិនអាចយកមកធ្វើជាមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានអំពីឧក្រិដ្ឋកម្ម....472
ក. ភាពគ្មានយថាភាពនៃឯកសារ E3/2107....472
ខ. ភាពមិនអាចជឿជាក់បាននៃសក្ខីកម្មរបស់សាក្សី សយ សែន....474
៤. ភស្តុតាងអំពីឧក្រិដ្ឋកម្មមួយចំនួន ....475
ជំពូកទី ៣. អូរកន្សែង ....475
ផ្នែកទី ១. បទចោទ....475
១. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ....476
ក. អំពើមនុស្សឃាត ....476
ខ. ការសម្លាប់រង្គាល....478
គ. ការធ្វើឱ្យទៅជាទាសករ ....479
ឃ. ការដាក់ក្នុងមន្ទីរឃុំឃាំង ....479
ង. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ....480
ច. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍....480

ឆ. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស) ......481
២. ការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ.................................482
ក. អំពើមនុស្សឃាតដោយចេតនា .................................................................482
ខ. ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ និងទៀងទាត់..................................................................482
ផ្នែកទី ២. ការបង្ហាញភ័ស្តុតាង ..............................................................483
១. បញ្ជីភ័ស្តុតាង ......................................................................484
២. ភ័ស្តុតាងក្រៅវិសាលភាព ..........................................................484
៣. ភ័ស្តុតាងអំពីឧក្រិដ្ឋកម្មមួយចំនួន ...............................................485
ជំពូកទី ៤. ភ្នំក្រោល ...........................................................................486
ផ្នែកទី ១. បទចោទ..........................................................................486
១. ការកម្រិតផ្នែកភូមិសាស្ត្រនៃបទចោទ ...............................................487
២. ការកម្រិតជាក់ស្តែងនៃបទចោទ.....................................................489
ក. អំពើមនុស្សឃាត ...............................................................489
ខ. ការសម្លាប់រង្គាល ...............................................................490
គ. ការធ្វើឱ្យទៅជាទាសករ .........................................................490
ឃ. ការដាក់ក្នុងមន្ទីរឃុំឃាំង .......................................................492
ង. ការធ្វើទារុណកម្ម..............................................................492
ច. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ .................................493
ឆ. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស) ......494
ជ. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ)...........................495
ផ្នែកទី ២. ភ័ស្តុតាងគាំទ្រដល់សេចក្តីសន្និដ្ឋាននៃដីកាដំណោះស្រាយ.................................496
១. អំពីអង្គហេតុនៃការធ្វើការដោយបង្ខំ...................................................497
៤. អំពីអង្គហេតុនៃការបាត់ខ្លួនដោយបង្ខំ...................................................498
ផ្នែកទី ៣. ការបង្ហាញភ័ស្តុតាង ..............................................................498
១. បញ្ជីភ័ស្តុតាង ......................................................................499
២. ភ័ស្តុតាងក្រៅវិសាលភាព..........................................................500
ក. ការក្រឡេកមើលត្រួសៗទៅលើភ័ស្តុតាងក្រៅវិសាលភាព ....................................500
ខ. សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុន រុត ........................................501
1. ការរំឭកនីតិវិធី.................................................................501

2. ចម្លើយក្រៅវិសាលភាពនៃការជំនុំជម្រះក្តី ....................................504

3. ភស្តុតាងអំពីឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស) ....................................506

ផ្នែកទី ៤. ការពិនិត្យមើលភស្តុតាងពាក់ព័ន្ធ....................................507

១. ចម្លើយរបស់ ចាន់ ទូយ ....................................508

២. ចម្លើយរបស់ ណេត សារ៉ាត ....................................508

៣. ចម្លើយរបស់ ប៊ុន ឡឹងចូយ ....................................509

៤. ភស្តុតាងផ្សេងទៀត....................................510

ផ្នែកទី ៥. ការកំណត់ប្រភេទបទល្មើស ....................................511

១. អំពើមនុស្សឃាត (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)....................................511

ក. និយមន័យ ....................................511

ខ. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ....................................511

២. ការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)....................................512

ក. និយមន័យ ....................................512

ខ. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ....................................512

ជំពូកទី ៥. ការចោទប្រកាន់ចំពោះគោលនយោបាយទាក់ទងនឹងមន្ទីរសន្តិសុខ....................................512

ផ្នែកទី ១. ពីរដ្ឋមានសន្តិសុខមួយ ក្លាយជារដ្ឋអសន្តិសុខ ....................................514

ផ្នែកទី ២. ផ្នែកសន្តិសុខក្រោមការគ្រប់គ្រងរបស់កងទ័ព ....................................518

ផ្នែកទី ៣. មន្ទីរសន្តិសុខក្រាំងតាចាន់ ក្រោមការគ្រប់គ្រងរបស់ស្រុក....................................519

ភាគទី ៣. ការប្រព្រឹត្តលើក្រុមជាក់លាក់....................................520

ជំពូកទី ១. ពុទ្ធសាសនិក....................................520

ផ្នែកទី ១. ការចោទប្រកាន់ក្នុងដីកាដំណោះស្រាយ....................................521

ផ្នែកទី ២. វិសាលភាពបណ្តឹងដាក់ជូនសហចៅក្រមស៊ើបអង្កេត ត្រូវបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា....................................522

១. បណ្តឹងទាក់ទងនឹងអង្គហេតុពាក់ព័ន្ធនឹង “ពុទ្ធសាសនិក” ....................................523

២. បណ្តឹងទាក់ទងនឹងអង្គហេតុពាក់ព័ន្ធនឹង “ព្រះសង្ឃពុទ្ធសាសនា”....................................524

ផ្នែកទី ៣. កំហុសនីតិវិធី....................................529

ផ្នែកទី ៤. អង្គជំនុំជម្រះគ្មានយុត្តាធិការជំនុំជម្រះ ....................................530

ជំពូកទី ២. ការចោទប្រកាន់ស្តីពីគោលនយោបាយពាក់ព័ន្ធនឹងវិធានការជាក់លាក់ប្រឆាំងនឹងពុទ្ធសាសនិក.531

ជំពូកទី ៣. ជនជាតិចាម ....................................532

ផ្នែកទី ១. ការចោទប្រកាន់ ....................532
១. វិសាលភាពនៃការចោទប្រកាន់ យោងតាមដីកាដំណោះស្រាយ ....................533
ក. បទប្រល័យពូជសាសន៍ដោយអំពើមនុស្សឃាត ....................533
1. ការចោទប្រកាន់ក្នុងដីកាដំណោះស្រាយ ....................533
1.ក. វិសាលភាពភូមិសាស្ត្រ....................534
1.ខ. វិសាលភាពពេលវេលា ....................534
2. បណ្តឹងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទាំងអស់របស់សហព្រះរាជអាជ្ញា ..........535
ខអំពើមនុស្សឃាត . ....................536
1 .វិសាលភាពភូមិសាស្ត្រ....................536
2. វិសាលភាពពេលវេលា....................537
គ. ការសម្លាប់រង្គាល ....................537
ឃ. ការដាក់ក្នុងមន្ទីរឃុំឃាំង ....................538
ង. ការធ្វើទារុណកម្ម....................539
ច. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ....................540
២. វិសាលភាពនៃការចោទប្រកាន់ពីបទផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី ២ ក្រោយពីមានសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី....................542
ផ្នែកទី ២. ភ័ស្តុតាងដែលត្រូវបានបង្ហាញ ....................543
១. បញ្ជីភ័ស្តុតាង ....................544
២. ភ័ស្តុតាងស្ថិតនៅក្រៅវិសាលភាពសំណុំរឿង ....................545
៣. ភ័ស្តុតាងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដាក់ក្នុងមន្ទីរឃុំឃាំង ....................547
ផ្នែកទី ៣. ការពិនិត្យលើភ័ស្តុតាងពាក់ព័ន្ធ....................547
១. ការកត់សម្គាល់បឋម ....................547
ក. ការងារលម្អៀងរបស់លោក អ៊ីសា ឧស្មាន....................548
1. “អ្នកជំនាញ” ជាជនរងគ្រោះផង និងជាអ្នកស៊ើបអង្កេតផង....................548
2. “អ្នកជំនាញ” គ្មានការបណ្តុះបណ្តាលច្បាស់លាស់ ....................551
3. តាមន័យវិទ្យាសាស្ត្រ ការងារទាក់ទងនឹងស្ថិតិ គឺគ្មានមូលដ្ឋាន និងលម្អៀង ....................554
ខ. កំណត់ហេតុស្តាប់ចម្លើយច្រើនសម្បើម ....................557
២. ការពិនិត្យភ័ស្តុតាងទាក់ទងនឹងអង្គហេតុ....................558
ក. ការផ្លាស់ទីលំនៅប្រជាជនចាម ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២......559

1. គ្មានការរើសអើងលើប្រជាជនចាម ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ ....559

1.ក. ឯកសារឆ្នាំ ១៩៧៥ ដែលបង្ហាញពីការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ ....559

1.ខ. ការរំឭកអំពីសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូល ....560

1.គ. សារទូរលេខ ១៥ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥....562

1.ឃ. ប្រភេទផ្សេងៗនៃការផ្លាស់ទីលំនៅប្រជាជន....564

2. ការបះបោររបស់ជនជាតិចាមនៅក្នុងភូមិភាគបូព៌ា ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ ....567

2.ក. ការបះបោរនៅស្វាយឃ្លាំង ....567

2.ខ. ការបះបោរនៅកោះផល ....570

2.គ. ស្ថានភាពនៅជំនីក ....572

ខ. គ្មានការរើសអើងប្រឆាំងជនជាតិចាម ....573

1. ស្ថានភាពរស់នៅរបស់ប្រជាជនជាតិចាមនៅក្នុងភូមិភាគបូព៌ា និងភូមិភាគកណ្ដាល....574

1.ក. ស្ថានភាពរស់នៅក្នុងភូមិភាគបូព៌ា ក្រោយការបះបោរ ....574

1.ខ. ស្ថានភាពរស់នៅក្នុងភូមិភាគកណ្ដាល ....575

2. ការហាមឃាត់ជាទូទៅមិនឱ្យមានការប្រតិបត្តិសាសនា និងប្រពៃណី....576

2.ក. ស្ថានភាពនៅភូមិភាគបូព៌ា ....577

2.ខ. ស្ថានភាពនៅក្នុងភូមិភាគកណ្ដាល ....579

i. ស្រុកកងមាស ....579

ii. ស្រុកកំពង់សៀម ....581

iii. ស្រុកផ្សេងទៀតក្នុងភូមិភាគកណ្ដាល ....584

2.គ. ស្ថានភាពក្នុងភូមិភាគពាយ័ព្យ ....585

គ. គ្មានផែនការកម្ទេចក្រុមជនជាតិចាម ....585

1. ការរៀបអាពាហ៍ពិពាហ៍ជនជាតិចាម....586

2. ភ័ស្ដុតាងទាក់ទងនឹងព្រឹត្តិការណ៍កើតឡើងនៅក្រូចឆ្មារ និងកងមាស....589

2.ក. ករណីស្រុកក្រូចឆ្មារ....590

2.ខ. ករណីស្រុកកងមាស ....597

i. បញ្ជាឱ្យចាប់ខ្លួន ....597

ii. មូលហេតុនៃការចាប់ខ្លួន ....601

3. ការចោទប្រកាន់ពីការសម្លាប់មនុស្សនៅស្រុកក្រូចឆ្មារ និងស្រុកកងមាស ....603

3.ក. ស្រុកក្រូចឆ្មារ ....................................................................................603

i. ការបាត់ខ្លួនពាក់ព័ន្ធជាមួយនឹងការបោសសម្អាតភូមិភាគបូព៌ា ..........................603

ii. ករណីជាក់លាក់របស់ភូមិទ្រា ..........................................................603

iii. រណ្ដៅរកឃើញនៅទ្រា ក្រោយឆ្នាំ ១៩៧៩...............................................609

3.ខ. ស្រុកកងមាស......................................................................................610

i. ការចាប់ខ្លួនមនុស្សនៅក្នុងស្រុកកងមាស ...............................................610

ii. ព័ត៌មានអំពីរណ្ដៅដែលបានរកឃើញក្រោយឆ្នាំ១៩៧៩...................................613

ផ្នែកទី ៤. ការកំណត់បទចោទប្រកាន់.........................................................................615

១. អំពើមនុស្សឃាត (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)...................................................615

ក. និយមន័យ .............................................................................................615

ខ. ការកំណត់បទចោទប្រកាន់លើអង្គហេតុ ...................................................615

២. ការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)...................................................616

ក. និយមន័យ .............................................................................................616

ខ. ការកំណត់បទចោទប្រកាន់លើអង្គហេតុ ...................................................617

.1គ្មានភ័ស្តុតាងបង្ហាញពីស្ថានភាពរស់នៅដែលត្រូវបានរៀបចំឡើងដើម្បីបង្កឱ្យមានការស្លាប់ .........................................................................................................617

2. ភ័ស្តុតាងមិនគ្រប់គ្រាន់សម្រាប់សន្និដ្ឋានបានថាមានការសម្លាប់មនុស្សក្នុងចំនួនច្រើន .......618

3. ភ័ស្តុតាងពុំគ្រប់គ្រាន់សម្រាប់សន្និដ្ឋានបានថាមានផែនការកម្ទេចក្រុមជនជាតិចាម .........619

៣. ការធ្វើទារុណកម្ម (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)...................................................620

ក. និយមន័យ .............................................................................................620

ខ. ការកំណត់បទចោទលើអង្គហេតុ..............................................................622

៤. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) .....................623

ក. និយមន័យ .............................................................................................623

ខ. ការកំណត់បទចោទលើអង្គហេតុ..............................................................623

៥. អំពើមនុស្សឃាត (អំពើប្រល័យពូជសាសន៍) .........................................................624

ក. និយមន័យអំពើប្រល័យពូជសាសន៍ តាមរយៈអំពើមនុស្សឃាត .................................624

1. សេចក្ដីផ្ដើម .........................................................................................624

2. ធាតុផ្សំឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ...................................................627

2.ក. ធាតុផ្សំសត្យានុម័តិ .......................................................................627

2.ខ. ធាតុផ្សំអត្តនោម័តិ ........................................................................628

i. គោលបំណងបំផ្លិចបំផ្លាញក្រុមណាមួយ ....................................................629
ii. ទាំងស្រុង ឬមួយផ្នែក...................................................................632
iii. ជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា .......................................................633
iv. ការទាញសេចក្តីសន្និដ្ឋានពីចេតនា..........................................................636
ខ. ការកំណត់បទចោទប្រកាន់លើអង្គហេតុ ........................................................639
ជំពូកទី ៤. ការចោទប្រកាន់ស្តីពីគោលនយោបាយពាក់ព័ន្ធនឹងវិធានការដាក់លាក់ប្រឆាំងនឹងជនជាតិចាម .641
ផ្នែកទី ១. នត្ថិភាពនៃគោលនយោបាយប្រឆាំងជនជាតិចាម ដោយផ្អែកលើឯកសារសម័យខ្មែរក្រហម .641
១. ឯកសារលើកឡើងពីជនជាតិចាម ថាជាសមាជិកសំខាន់មួយនៃរបបកម្ពុជាប្រជាធិបតេយ្យ......642
២. ការទាក់ទងគ្នារវាង កែ ពក និង មជ្ឈិម ........................................................643
ក. សារទូរលេខ ខែ មេសា ឆ្នាំ ១៩៧៦ ផ្ញើទៅ ប៉ុល ពត.............................................643
ខ. ការទាក់ទងគ្នាផ្សេងទៀត ..............................................................644
ផ្នែកទី ២. នត្ថិភាពនៃគោលនយោបាយ ផ្អែកលើសក្ខីកម្ម ..........................................645
១. ភាពមិនទំនង និងភាពផ្ទុយគ្នា នៃសក្ខីកម្មរបស់ សុះ កំរី............................................645
ក. ជីវភាពរស់នៅរបស់ជនជាតិចាមនៅចម្ការលើ .................................................646
ខ. ការប្រជុំថ្នាក់ភូមិ នៅបុសខ្នុរ ............................................................647
គ. “ឯកសារព័ណ៌លឿង” ដ៏អាថ៌កំបាំង ស្តីពីការសម្លាប់រង្គាលជនជាតិចាម តាមការសន្មត ......648
២. អនិត្ថិភាពនៃគោលនយោបាយ បើតាមសាក្សីផ្សេងទៀត .........................................650
ក. កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា .......................................................650
ខ. សាក្សីផ្សេងទៀត ......................................................................653
ជំពូកទី ៥. អំពីជនជាតិវៀតណាម...........................................................655
ផ្នែកទី ១. ការចោទប្រកាន់ .............................................................655
១. ឧក្រិដ្ឋកម្មដែលចោទប្រកាន់.............................................................655
២. ដែនបណ្តឹងមកកាន់អង្គជំនុំជម្រះ........................................................656
ក. ការធ្វើមនុស្សឃាត ..................................................................656
ខ. ការសម្លាប់រង្គាល ....................................................................658
គ. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍.................................................659
ឃ. បទប្រល័យពូជសាសន៍ដោយឃាតកម្ម .........................................................660
ផ្នែកទី ២. ភ័ស្តុតាងដែលបានបង្ហាញ........................................................661
១. ភ័ស្តុតាងជាសក្ខីកម្ម....................................................................661
២. ភ័ស្តុតាងជាឯកសារ ...................................................................662

ក. ភស្តុតាងអំពីទិន្នន័យប្រជាសាស្ត្រ ....................................................................663

1. របាយការណ៍របស់ Ewa TABEAU....................................................................663

2. គ្មានទិន្នន័យប្រជាសាស្ត្រដែលអាចទុកចិត្តបានផ្សេងទៀត ....................................668

ខ. សារណារបស់សាកលវិទ្យាល័យ....................................................................671

៣. អង្គហេតុនៅក្រៅវិសាលភាព ....................................................................672

ក. អង្គហេតុនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមរូបភាពនៃការបាត់ខ្លួនដោយបង្ខំ) ............673

ខ. អង្គហេតុនៅក្រៅខេត្តព្រៃវែង និងស្វាយរៀង ....................................................673

គ. អង្គហេតុពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពសាធារណរដ្ឋខ្មែរលើទឹកដីវៀតណាម ....676

ផ្នែកទី ៣. ការពិនិត្យលើភស្តុតាងពាក់ព័ន្ធ....................................................................676

១. ការប្រព្រឹត្តលើជនជាតិវៀតណាមក្នុងខេត្តព្រៃវែង ....................................................677

ក. ស្រុកពាមរក៍ ....................................................................677

1. ការចោទប្រកាន់ពីបទមនុស្សឃាតលើជនជាតិវៀតណាម.............................................677

1.ក. ឃុំព្រែកជ្រៃ ....................................................................677

i. ករណីម្តាយរបស់ សៅ សាក់ ....................................................................678

ii. ករណីម្តាយរបស់ នាង ណាត (ឈ្មោះ យ៉ឺន)....................................................680

iii. ករណីគ្រួសាររបស់ វ៉ាន់ ម៉ៅ ....................................................................683

iv. ករណី ថាវ និងក្រុមគ្រួសាររបស់គាត់....................................................................685

v. ករណីឈ្មោះ កែម នៅ ប្រពន្ធរបស់ ឡុង ហ៊ែល....................................................687

vi. ករណីយាយ ឌឹក....................................................................688

1.ខ. ឃុំអង្គរយស ....................................................................689

1.គ. ករណីលើកឡើងនៅតាមកន្លែងមួយចំនួនដែលមិនត្រូវបានកំណត់ឱ្យបានច្បាស់ ......690

2. បទបញ្ជា និងនីតិវិធីនៃការចាប់ខ្លួនជនជាតិវៀតណាម ............................................691

3. ការប្រជុំស្តីពីជនជាតិវៀតណាម....................................................................693

4. ការប្រព្រឹត្តលើជនជាតិកម្ពុជាដែលមានសហព័ទ្ធជាជនជាតិវៀតណាម និងលើកូនៗដែលមានម្តាយ ឬ ឪពុក ជាជនជាតិវៀតណាម ....................................................................693

4.ក. ការប្រព្រឹត្តលើជនជាតិខ្មែរដែលមានសហព័ទ្ធជាជនជាតិវៀតណាម..........................693

4.ខ. ទ្រឹស្តីទាក់ទងនឹងខ្សែស្រឡាយខាងម្តាយ ....................................................694

ខ. ស្រុកព្រៃវែង (ភូមិពោធិ៍ចិន្តាំ និងភូមិស្វាយអន្ទរ)....................................................698

1. ការចោទប្រកាន់ពីបទមនុស្សឃាតលើជនជាតិវៀតណាម.............................................699

1.ក. ភូមិពោធិ៍ចិន្តាំ....................................................................699

i. ករណី ង៉ាង (ប្ដីរបស់ ឡេង សាម៉េត ហៅ តិច)......................................699

ii. ករណី ជុយ (ប្ដីរបស់ ដួង អឿន)..........................................................704

iii. ករណី សាន (ប្រពន្ធ ឡាច នី) ..........................................................707

1.ខ. ស្វាយអន្ទរ (ករណី សេង ហួរ និងក្រុមគ្រួសាររបស់គាត់)...............................710

2. បទបញ្ជា និងនីតិវិធីចាប់ខ្លួន និងសម្លាប់ជនជាតិវៀតណាម ..................................713

3. ការប្រជុំទាក់ទងនឹងជនជាតិវៀតណាម និងមូលហេតុនៃការចាប់ខ្លួន.............................715

4. កន្លែងសម្លាប់មនុស្សនៅវាលតូច..............................................................717

5. ការប្រព្រឹត្តមកលើជនជាតិខ្មែរដែលមានសហព័ទ្ធជាជនជាតិវៀតណាម និងមកលើកូនៗដែលមានម្ដាយ ឬ ឪពុកជាជនជាតិវៀតណាម ..............................................................720

5.ក. ការប្រព្រឹត្តមកលើជនជាតិខ្មែរដែលមានសហព័ទ្ធជាជនជាតិវៀតណាម .............720

5.ខ. ទ្រឹស្ដីទាក់ទងនឹងខ្សែស្រឡាយខាងម្ដាយ ..................................................722

គ. ស្រុកពារាំង.........................................................................................725

២. ការប្រព្រឹត្តលើជនជាតិវៀតណាមនៅខេត្តស្វាយរៀង ............................................726

ក. ការចោទប្រកាន់ពីបទសម្លាប់រង្គាលជនស៊ីវិលវៀតណាមនៅក្នុងខេត្តស្វាយរៀង..............726

1. រឿងរ៉ាវរបស់ អ៊ុង សំអ៊ាន.......................................................................727

1.ក. វត្តមានគ្រួសារចម្រុះខ្មែរ-វៀតណាម ......................................................727

1.ខ. ការចាប់ខ្លួនសមាជិកមួយចំនួនរបស់គ្រួសារទាំងនេះ .........................................728

2. រឿងរ៉ាវរបស់ ស៊ិន ឆែម.........................................................................730

2.ក. វត្តមានគ្រួសារចម្រុះជាតិសាសន៍ខ្មែរ-វៀតណាម..............................................730

2.ខ. ការចាប់ខ្លួនសមាជិកមួយចំនួនក្នុងគ្រួសារទាំងនេះ .........................................732

3. រឿងរ៉ាវរបស់ អ៊ិន យឿង........................................................................734

4. រឿងរ៉ាវរបស់ សៀង ចាន់ចី......................................................................736

4.ក. វត្តមានជនជាតិវៀតណាម....................................................................737

4.ខ. ការប្រព្រឹត្តលើជនជាតិវៀតណាម ...........................................................738

4.គ. ការចោទប្រកាន់ពីបទមនុស្សឃាតលើជនជាតិវៀតណាម ...................................739

i. ការចោទប្រកាន់ពីការសម្លាប់បងប្រុសទាំងពីររបស់គាត់ ....................................740

ii. ការចោទប្រកាន់ពីបទមនុស្សឃាតលើសមាជិកក្រុមគ្រួសារវៀតណាមពីរផ្សេងទៀត ..............................................................................................743

iii. ការធ្វើអត្តឃាតរបស់ឪពុកដើមបណ្ដឹងរដ្ឋប្បវេណី ..........................................745

5. ចម្លើយផ្សេងទៀត.................................................................................745

ខ. ទ្រឹស្តីខ្សែស្រឡាយខាងម្តាយ ....................................................747
ផ្នែកទី ៤. ការកំណត់ប្រភេទបទល្មើស ....................................................748
១. អំពើមនុស្សឃាត (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)....................................................749
ក. និយមន័យ ....................................................749
ខ. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ....................................................749
1. ការបង្ហាញនូវអំពើមនុស្សឃាតឱ្យហួសពីវិមតិសង្ស័យ ....................................................750
2. សេចក្តីសន្និដ្ឋានស្តីពីអំពើមនុស្សឃាតលើជនជាតិវៀតណាម....................................................752
2.ក. អំពើមនុស្សឃាតនៅខេត្តព្រៃវែង....................................................752
i. អន្លង់ទ្រា ....................................................752
ii. ពោធិ៍ចិនដាំ....................................................754
iii. ស្វាយអន្ទរ....................................................755
2.ខ. អំពើមនុស្សឃាតនៅខេត្តស្វាយរៀង....................................................756
២. ការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)....................................................757
ក. និយមន័យ ....................................................757
ខ. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ....................................................757
៣. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)....................................................758
ក. និយមន័យ ....................................................758
ខ. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ....................................................759
៤. អំពើមនុស្សឃាត (អំពើប្រល័យពូជសាសន៍)....................................................762
កនិយមន័យ ....................................................762
ខ. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ....................................................763
ជំពូកទី ៦. គោលនយោបាយស្តីពីការកំណត់គោលដៅជាក់លាក់ទៅលើជនជាតិវៀតណាម....................................................765
ផ្នែកទី ១. ការកត់សម្គាល់បឋម....................................................765
ផ្នែកទី ២. ការត្រឡប់មកនិយាយអំពីការបកស្រាយពាក្យ “យួន”....................................................768
១. ការប្រើប្រាស់ពាក្យ “យួន” នៅប្រទេសកម្ពុជា....................................................768
២. ដែនកំណត់នៃសក្ខីកម្មរបស់លោក Alexander HINTON....................................................771
ផ្នែកទី ៣. សង្គ្រាមប្រឆាំងនឹងរដ្ឋមួយ គឺមិនមែនប្រឆាំងនឹងប្រជាជនស៊ីវិលនោះទេ ....................................................775
១. សុន្ទរកថាក្នុងពេលសង្គ្រាម ....................................................775
ក. សុន្ទរកថារបស់លោក ខៀវ សំផន នៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧....................................................777

ខ. សេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន ក្នុងពេលផ្តាច់ទំនាក់ទំនងជាមួយវៀតណាមនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ......778
គ. សុន្ទរកថារបស់ ប៉ុល ពត នៅខែ មេសា ឆ្នាំ ១៩៧៨ ......779
ឃ. សុន្ទរកថារបស់លោក ខៀវ សំផន នៅថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨......780
ង. សេចក្តីថ្លែងការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៧៩......782
២. ឯកសារពីសម័យនោះផ្សេងទៀត ដែលលើកឡើងអំពីវៀតណាម ......783
៣. អវត្តមាននៃភ័ស្តុតាងអំពីការសម្លាប់រង្គាលជនស៊ីវិលវៀតណាម ......785
ជំពូកទី ៧. អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ......785
ផ្នែកទី ១. បទចោទ......785
១. សហករណ៍ត្រាំកក់......787
២. ទំនប់ ១ មករា......788
៣. ស-២១ ......789
៤. ក្រាំងតាចាន់ ......790
ផ្នែកទី ២. ភ័ស្តុតាងគាំទ្រដល់សេចក្តីសន្និដ្ឋាននៃដីកាដំណោះស្រាយ ......791
១. អំពីការតាមដានអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ដែលត្រូវបានចោទប្រកាន់ នៅកថាខណ្ឌ ៣១៩......791
២. អំពីការបាត់ខ្លួនអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ដែលត្រូវបានចោទប្រកាន់ នៅកថាខណ្ឌ ៣៩៨......792
ផ្នែកទី ៣. ភ័ស្តុតាងបង្ហាញជូនក្នុងពេលជំនុំជម្រះក្តី ......795
១. បញ្ជីភ័ស្តុតាង ......795
២. ភ័ស្តុតាងក្រៅវិសាលភាព ......796
៣. ភ័ស្តុតាងអំពីឧក្រិដ្ឋកម្មនៃការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយនៅត្រាំកក់......796
ជំពូកទី ៨. ការចោទប្រកាន់អំពីគោលនយោបាយស្តីពីការចាត់វិធានការជាក់លាក់ប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ......797
ភាគទី ៤. ការដាក់បទបញ្ញាលើការរៀបអាពាហ៍ពិពាហ៍......801
ជំពូកទី ១. ការរៀបអាពាហ៍ពិពាហ៍ ......801
ផ្នែកទី ១. បទចោទ......801
ផ្នែកទី ២. ការបង្ហាញភ័ស្តុតាង ......801
១. កំណត់សម្គាល់បឋម......801
ក. លក្ខណៈពិសេសនៃភ័ស្តុតាងជាសក្ខីកម្ម......802

1. ភ័ស្តុតាងជាសក្ខីកម្មយ៉ាងច្រើន ....................802
2. លក្ខណៈពិសេសនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ....................802
3. សារៈសំខាន់នៃសក្ខីកម្មរបស់អ្នកជំនាញ ....................804
ខ. កំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានដាក់បញ្ចូលយ៉ាងច្រើនសន្ធឹកសន្ធាប់ ....................805
២. ភ័ស្តុតាងក្រៅវិសាលភាព ....................805
៣. ភ័ស្តុតាងដែលមិនត្រូវបានជំទាស់តវ៉ា ....................806
ផ្នែកទី ៣. ការពិនិត្យមើលភ័ស្តុតាងពាក់ព័ន្ធ ....................807
១. ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ....................807
ក. ការសម្រេចចិត្តមិនអាស្រ័យនឹងឆន្ទៈរបស់អនាគតគូស្វាមី-ភរិយា ....................807
1. សញ្ញាណនៃមនោសញ្ចេតនាស្នេហា ក្នុងអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ....................808
2. ប្រភេទនៃការព្រមព្រៀងក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ....................810
3. ភាពមិនអាចប្រកែកបានចំពោះការផ្សំផ្គុំពីឪពុកម្តាយ ....................812
4. ឋានៈរបស់ស្ត្រី និងទំនាក់ទំនងរវាងបុរស និងស្រី មុនរបបកម្ពុជាប្រជាធិបតេយ្យ ....................813
ខ. ករណីយកិច្ចជាប្តី-ប្រពន្ធ និងការរំលោភសេពសន្ថវៈ ....................815
២. ការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ....................817
ក. វិធានស្តីពីការរៀបអាពាហ៍ពិពាហ៍ ....................817
1. គោលការណ៍គ្រប់គ្រងការផ្សំផ្គុំ ....................817
1.ក. ល័ក្ខខ័ណ្ឌ “តាមផ្លូវច្បាប់”៖ សីលធម៌ ១២ ប្រការ ....................817
1.ខ. ការសម្តែងការយល់ព្រម ....................819
1.គ. អាយុរៀបការ ....................823
2. តួនាទីរបស់អាជ្ញាធរក្នុងការជ្រើសរើសគូស្រករ ....................826
2.ក. ភាពស្រដៀងគ្នា និងភាពខុសគ្នានៃដំណើរការ ....................826
2.ខ. ភាពខុសគ្នានៃសក្ខីកម្មអំពីការចូលរួមរបស់ឪពុកម្តាយ ....................827
2.គ. ចំណងទាក់ទង និងមនោសញ្ចេតនា កើតក្រោយការរៀបអាពាហ៍ពិពាហ៍ ....................829
3. ការរៀបអាពាហ៍ពិពាហ៍ និងអវត្តមាននៃពិធីផ្សេងៗ ....................831
ខ. ស្ថានភាពក្រោយការរៀបអាពាហ៍ពិពាហ៍ ....................832
1. កាលៈទេសៈបង្ខំដែលត្រូវបានចោទប្រកាន់ ....................832
2. ការរួមដំណេក ....................834
2.ក. ការណែនាំឱ្យរួមដំណេក ....................834
2.ខ. សក្ខីកម្មអំពីការឃ្លាំមើល ....................836

2.គ. សក្ខីកម្មអំពីអវត្តមាននៃការឃ្លាំមើល ឬអវត្តមាននៃការណែនាំឱ្យឃ្លាំមើល...........837
3. ដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងអំពីការរំលោភសេពសន្ថវៈក្នុងចំណង
អាពាហ៍ពិពាហ៍ ......................................................................................................839
3.ក. រឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-274 ...........................................839
3.ខ. រឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ..........................................................840
3.គ. រឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន...............................................841
ផ្នែកទី ៤. ការកំណត់ប្រភេទបទល្មើស ...................................................................841
១. "និយមន័យ" នៃអំពើអមនុស្សធម៌ផ្សេងទៀត (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ....................841
២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ..................................................................844
ក. លក្ខណៈ និងកម្រិតធ្ងន់ធ្ងរ .....................................................................................845
1. អវត្តមាននូវទំនាក់ទំនងពិតប្រាកដរវាងសិទ្ធិ និងការហាមឃាត់ ដែលមានចែងនៅក្នុងអត្ថបទ
ច្បាប់ជាធរមាននៅសម័យនោះ ...................................................................................846
2. ការចាប់ផ្តើមលេចឡើងនូវបទដ្ឋានជាក់លាក់ជាងមុននៅពេលក្រោយ ...........................847
ខ. ផលប៉ះពាល់..........................................................................................................849
គ. ចេតនា ................................................................................................................851
ជំពូកទី ២. គោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដែលចោទប្រកាន់ .........................852
ផ្នែកទី ១. ការពិភាក្សាដេញដោលចោទប្រធានអំពីការបង្កើនចំនួនប្រជាជន.............................853
១. សុន្ទរកថាផ្លូវការ...................................................................................................853
២. សក្ខីកម្មផ្ទុយគ្នាក្នុងសវនាការ ..................................................................................855
ផ្នែកទី ២. ភាពជាតំណាងនៃរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី ....................................857
១. ទិដ្ឋភាពទូទៅនៃសក្ខីកម្មក្នុងសវនាការនៃសំណុំរឿង ០០២/០២ ...................................857
២. សេចក្តីសន្និដ្ឋាន ...................................................................................................859
មាតិកាទី ៤. ទំនួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល...................................................862
ភាគទី ១. ការចោទប្រកាន់........................................................................................862
ភាគទី ២. និយមន័យនៃទម្រង់នៃការទទួលខុសត្រូវ..........................................................864
ជំពូកទី ១. សហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ...................................................................864
ផ្នែកទី ១. ធាតុផ្សំសត្យានុម័តិ ..................................................................................864
ផ្នែកទី ២. ធាតុផ្សំអត្តនោម័ត ...................................................................................867
ផ្នែកទី ៣. សហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយដែលមានគោលបំណងផ្ទាល់មិនឧក្រិដ្ឋ .......................869
ជំពូកទី ២. ទម្រង់ទំនួលខុសត្រូវផ្សេងទៀតក្រៅពីសហឧក្រិដ្ឋកម្មរួម ...................................871

ភាគទី ៣. សុន្ទរកថាបញ្ឆេះកំហឹង និងការឃោសនាសង្គ្រាម....................................................872

ជំពូកទី ១. ការសង្ខេបស្ថានភាពនៃច្បាប់អន្តរជាតិស្តីពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការញុះញង់ឱ្យប្រព្រឹត្ត អំពើរើសអើង និងការឃោសនា .................................................................................................873

ជំពូកទី ២. យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ .......................................................875

ផ្នែកទី ១. រឿងក្តី Streicher..........................................................................................875

ផ្នែកទី ២. រឿងក្តី Fritzsche .........................................................................................877

ផ្នែកទី ១. រឿងក្តី Nahimmana (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា)...............879

ផ្នែកទី ២. រឿងក្តី BIKINDI (តុលាការព្រហ្មទណ្ឌសម្រាប់ប្រទេសរវ៉ាន់ដា) .............................881

ផ្នែកទី ៣. រឿងក្តី NZABONIMANA (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ..........882

ផ្នែកទី ៤. រឿងក្តី SESELJ (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី).........883

សេចក្តីសន្និដ្ឋាន .......................................................................................................887

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## សេចក្តីផ្តើម

១. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ បន្ទាប់ពីបើកកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញា កាលពីថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧[1] សហចៅក្រមស៊ើបអង្កេតបានបញ្ជូនខ្លួន លោក ខៀវ សំផន និងជនត្រូវចោទឯទៀត ទៅជំនុំជម្រះ[2]។ ក្រោយទទួលបានពាក្យបណ្តឹង អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានសម្រេចពិនិត្យមើលបទចោទ នៅក្នុងអំឡុងពេលនៃការជំនុំជម្រះដាច់ដោយឡែកពីគ្នា ដោយសារវ័យជរារបស់ជនជាប់ចោទ[3]។

២. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ បន្ទាប់ពីការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០១[4] អង្គជំនុំជម្រះបានផ្តន្ទាទោសលោក ខៀវ សំផន ឱ្យជាប់ពន្ធនាគារមួយជីវិត និងបានចាប់ផ្តើមសវនាការលើអង្គសេចក្តី នៅក្នុងសំណុំរឿង ០០២/០២ នៅខែ មករា ឆ្នាំ ២០១៥។

៣. នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ នៅចុងបញ្ចប់នៃសវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីសេចក្តីវិនិច្ឆ័យលើសំណុំរឿង ០០២/០១ បើទោះបីជាមានការលុបចោលនូវការផ្តន្ទាទោសមួយចំនួនក៏ដោយ[5]។

---

[1] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ឯកសារ D3។

[2] ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ **ឯកសារ D427** (« ដីកាដំណោះស្រាយ »)។

[3] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ **ឯកសារ E124**៖ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ **ឯកសារ E284**៖ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1**។ ឯកសារយោងពេញលេញនៃសេចក្តីសម្រេច សំណេរ និងឯកសារដទៃទៀតត្រូវបានដាក់នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។ ម៉្យាងទៀត ឯកសារយោងនៃប្រតិចារឹកសវនាការអាចមានកំហុស ដោយសារតែ បច្ចុប្បន្ន កំណែកំពុងដំណើរការ តែទោះជាបានកែឡើងវិញ ឬមិនបានក៏ដោយ យ៉ាងហោចណាស់ក៏មានការយោងទៅពេលវេលាដែលប្រែប្រួលទៅតាមភាសាដែលបានប្រតិចារឹករួច។

[4] សាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ **ឯកសារ E313** (« សាលក្រម ០០២/០១ »)។

[5] សាលដីកា ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ F36** (« សាលដីកា ០០២/០១ »)។

៤. នាពេលនោះ របបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្តន្ទាទោស រីឯម្ចាស់ជំនួយរបស់តុលាការមានការសប្បាយចិត្ត ដោយសារបេសកកម្មតាមផ្លូវនយោបាយ និងជាប្រវត្តិសាស្ត្រ របស់ អ.វ.ត.ក ត្រូវបានបញ្ចប់។

៥. នាពេលបច្ចុប្បន្ន អង្គជំនុំជម្រះអាចផ្តោតទៅលើបេសកកម្មស្វែងរកយុត្តិធម៌ ដូចតុលាការដទៃទៀតដែរ។

៦. ស្របតាមដំណើរការនៃការជំនុំជម្រះក្តី ក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ ដែលវិនិច្ឆ័យដោយចៅក្រមដដែល ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ("ក្រុមមេធាវីការពារក្តី") ហាក់ដូចជាឆោតល្ងង់បន្តិច ដោយត្រូវរង់ចាំករណីមួយនេះ។ ទោះជាយ៉ាងនេះក្តី ក្រុមមេធាវីការពារក្តីមានភារកិច្ចរំឭកថា ក្នុងការជំនុំជម្រះក្តីលើរូប ខៀវ សំផន អង្គជំនុំជម្រះមានកាតព្វកិច្ចអនុវត្តវិធានច្បាប់ និងនីតិវិធី ដែលកំណត់នៅក្នុងគ្រប់រឿងក្តីព្រហ្មទណ្ឌ។

៧. ដោយហេតុថាអង្គជំនុំជម្រះមិនបានត្រៀមជឿលើសំដីទាំងឡាយរបស់លោក ខៀវ សំផន ដូចជាថារូបលោកមិនជាប់ពាក់ព័ន្ធនឹងរាល់សេក្តីសម្រេចនានារបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងមិនមានចេតនាឧក្រិដ្ឋណាមួយទាល់តែសោះ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង ០០២/០២ នេះ ផ្តោតតែទៅលើសារតានៃឧត្តមភាពច្បាប់ (មាតិកាទី ១) ទៅលើការពិនិត្យបរិបទនៃជម្លោះប្រដាប់អាវុធ (មាតិកាទី ២) និងឧក្រិដ្ឋកម្មរងការចោទប្រកាន់ (មាតិកាទី ៣) ព្រមទាំងទៅលើប្រវត្តិនៃវិធានច្បាប់ស្តីពីទំនួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល (មាតិកាទី ៤)។ បើសិនជាមាការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ដោយគ្មានលម្អៀង លោក ខៀវ សំផន នឹងត្រូវរួចទោស។

**មាតិកាទី ១. <u>ឧត្តមភាពនៃច្បាប់</u>**

៨. បើទោះបីជាអង្គជំនុំជម្រះមិនត្រូវបានចងដោយវិធានយុត្តិសាស្ត្រក៏ដោយ (ផ្នែកទី ១) ក៏អង្គជំនុំជម្រះត្រូវតែគោរពវិធានដែលកំណត់យុត្តាធិការរបស់ខ្លួន (ផ្នែកទី ២) គោរពគោលការណ៍នីត្យានុកូលភាព (ផ្នែកទី ៣) គោរពរបបគតិយុត្តក្នុងការការពិនិត្យភ័ស្តុតាង (ផ្នែកទី ៤) និងសមភាព (ផ្នែកទី ៥)។

**ភាគទី ១. គ្មានវិធានយុត្តិសាស្ត្រ**

**ជំពូកទី ១. ច្បាប់ជាតិ**

៩. វិធានយុត្តិសាស្ត្រ គឺជាសាលក្រមគតិយុត្តដែលសម្រេចលើចំណុចច្បាប់ណាមួយ និងមានយុត្តាធិការ នៅពេលដែលតុលាការអ្នកចេញសាលក្រមនោះ ឬតុលាការជាន់ទាបណាមួយផ្សេងទៀត ត្រូវបានស្នើសុំឱ្យចេញសេចក្តីសម្រេច ដោយផ្អែកលើចំណុចច្បាប់ដូចគ្នា។ វិសាលភាព នៃ "យុត្តាធិការ" នេះ មានលក្ខណៈខុសគ្នា ទៅតាមប្រព័ន្ធច្បាប់។

១០. នៅក្នុងយុត្តាធិការនៃប្រព័ន្ធច្បាប់ *common law* ដែលមួយផ្នែកធំនៃប្រព័ន្ធច្បាប់នេះ ចេញមកពីច្បាប់ទំនៀមទម្លាប់ តែមិនមែនចេញមកពីវិធានសំណេរ ចៅក្រមត្រូវអនុវត្តវិធានយុត្តិសាស្ត្រ ដែលចៅក្រមទាំងនោះត្រូវបានចងភ្ជាប់ដោយសេចក្តីសម្រេចរបស់ខ្លួនកន្លងមក អនុលោមតាមវិធានយុត្តិសាស្ត្រ (*stare decisis*)[6]។

១១. ក្នុងយុត្តាធិការនៃប្រព័ន្ធច្បាប់ *civil law* ច្បាប់ត្រូវបានចងក្រង រីឯវិធានយុត្តិសាស្ត្រមិនមានតួនាទីរបស់ខ្លួនទេ ដោយសារចៅក្រមត្រូវបានចងភ្ជាប់ដោយច្បាប់។ ដូច្នេះ យុត្តិសាស្ត្រមិនសូវមានលក្ខណៈដាច់ខាតនោះឡើយ។ យុត្តិសាស្ត្រមិន "បញ្ជា" ទេ ប៉ុន្តែ "សំណូមពរ" ឱ្យគេអនុវត្តតាម។

១២. ដើម្បីជៀសវាងការអនុវត្តវិធានយុត្តិសាស្ត្រ ដោយស្វ័យប្រវត្តិ និងខ្វះការពិចារណា ដែលរារាំងដល់ការកែប្រែនូវការបកស្រាយមិនត្រឹមត្រូវ ឬទាត់ចោលយុត្តិសាស្ត្រមិនសមស្រប ឬអយុត្តិធម៌យ៉ាង

[6] វចនានុក្រម *Black's Law Dictionary* បោះពុម្ពលើកទី៧ "stare decisis" ឯកសារ **D381.1.1**។

ជាក់ច្បាស់ តុលាការកំពូលៗបំផុតរបស់ប្រទេសអនុវត្តប្រព័ន្ធច្បាប់ *common law* រក្សាសិទ្ធិមិនគោរពតាម នៅក្នុងកាលៈទេសៈមួយចំនួន។

១៣. នៅសហរដ្ឋអាមេរិច តុលាការកំពូលបានប្រកាសជាអាទិ៍ថា៖

> "កាតព្វកិច្ចគោរពតាមយុត្តិសាស្ត្រ ប្រសូត្រចេញពីភាពចាំបាច់ និងប៉ះទង្គិចនឹងភាពចាំបាច់ផ្ទុយគ្នា នៅផ្នែកម្ខាងទៀត។ [...] យើងទទួលស្គាល់ថា គ្មានប្រព័ន្ធច្បាប់ណាមួយនឹងអាចផ្តល់ប្រយោជន៍ដល់សង្គមឡើយ បើសិនជាប្រព័ន្ធនោះត្រូវពិនិត្យមើលបញ្ហានីមួយៗជាថ្មីឡើងវិញ នៅពេលដែលរឿងក្តីនីមួយៗលើកឡើងពីបញ្ហាមួយនោះ។ អាស្រ័យហេតុនេះ សូម្បីតែសញ្ញាណនៃនីតិរដ្ឋដែលជាមូលដ្ឋាននៃរដ្ឋធម្មនុញ្ញរបស់យើង តម្រូវជានិច្ចថា ការគោរពយុត្តិសាស្ត្រ គឺមិនអាចខ្វះបានឡើយ បើផ្អែកតាមនិយមន័យ។ ករណីផ្ទុយពីនេះ ភាពចាំបាច់មួយផ្សេងទៀតអាចកើតមាន នៅពេលដែលសាលក្រមតុលាការកន្លងទៅណាមួយ បែរជាត្រូវបានចាត់ទុកថាមានកំហុសជាក់ស្តែង រហូតធ្វើឱ្យការអនុវត្តរបស់វាអាចមានផលប៉ះពាល់"[7]។

១៤. នៅប្រទេសអង់គ្លេស តុលាការជាន់ខ្ពស់បានប្រកាសនៅឆ្នាំ ១៩៦៦ ថា៖

> "តុលាការជាន់ខ្ពស់ទទួលស្គាល់ [...] ថា ការចងភ្ជាប់តឹងរ៉ឹងទៅនឹងវិធានយុត្តិសាស្ត្រ អាចបណ្តាលឱ្យមានភាពអយុត្តិធម៌ នៅក្នុងករណីកំណត់ណាមួយ ព្រមទាំងរាំងស្ទះធំធេងដល់ដំណើរវិវត្តជាប្រចាំរបស់ច្បាប់។ អាស្រ័យហេតុនេះ តុលាការជាន់ខ្ពស់ស្នើសុំកែតម្រូវការអនុវត្តបច្ចុប្បន្នរបស់ខ្លួន ដោយរក្សាទុកសេចក្តីសម្រេចកន្លងមករបស់តុលាការ ដោយហេតុផលយុត្តិសាស្ត្រតម្រូវ និងមិនគោរពតាមសេចក្តីសម្រេចកន្លមក នៅពេលដែលតុលាការគិតថាមានកាតព្វកិច្ចត្រូវធ្វើ"[8]។

---

[7] *Planned Parenthood of Southeastern Pennsylvania v. Robert P. Casey*, 505 U.S. 833, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩២។ សម្រង់ជាភាសាបារាំងត្រូវបានទាញយកពីសាលដីកា Aleksovski (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ៩២។

[8] សេចក្តីប្រកាសធ្វើឡើងដោយ Lord Chancellor មុននឹងប្រកាសសាលដីកា ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៦៦។ សូមមើល ៖ ការសម្រាលទ្រឹស្តី Stare Decisis នៅក្នុងសភាជាន់ខ្ពស់នៃចក្រភពអង់គ្លេស ដោយលោក Gerald DWORKIN ទស្សនាវដ្តីអន្តរជាតិស្តីពីច្បាប់ប្រៀបធៀប ឆ្នាំ ១៩៦៧ ភាគទី ១៩ លេខ ១ ទំព័រ ១៩០ (លើគេហទំព័រ : http://www.persee.fr/doc/ridc_0035-3337_1967_num_19_1_14761)។

### ជំពូកទី ២. ច្បាប់អន្តរជាតិ

១៥. មិនមានវិធានយុត្តិសាស្ត្រទេ នៅក្នុងច្បាប់អន្តរជាតិ ដូចការលើកឡើងរបស់ Michael WOOD នៅឆ្នាំ ២០១៥ នៅក្នុងអង្គសន្និបាតលើកទី ៦៧ របស់គណៈកម្មាធិការច្បាប់អន្តរជាតិ ថា៖

> "គេអាចនិយាយបានថា សេចក្តីសម្រេចរបស់តុលាការ និងអង្គជំនុំជម្រះអន្តរជាតិ គឺមិនអាចប្រកែកបាន សម្រាប់កំណត់វិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ទម្ងន់របស់វា ប្រែប្រួលទៅតាមគុណភាពនៃការពិចារណា សមាសភាពរបស់តុលាការ ឬអង្គជំនុំជម្រះ និងទំហំនៃមតិភាគច្រើនដែលអនុម័តសេចក្តីសម្រេចទាំងនោះ"[9]។

១៦. តុលាការអន្តរជាតិ ដូចជា តុលាការយុត្តិធម៌អន្តរជាតិ តុលាការសិទ្ធិមនុស្សអឺរ៉ុប និងតុលាការព្រហ្មទណ្ឌអន្តរជាតិ បានច្រានចោលវិធានយុត្តិសាស្ត្រយ៉ាងជាក់ស្តែង ចំណែងសាលាឧទ្ធរណ៍នៃតុលាការចំពោះកិច្ច បានទទួលយកវិធាននេះ តាមរបៀបដោយឡែកមួយ។

### ផ្នែកទី ១. តុលាការយុត្តិធម៌អន្តរជាតិ

១៧. យោងតាមមាត្រា ៣៨(១) នៃលក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការយុត្តិធម៌អន្តរជាតិ អង្គជំនុំជម្រះអនុវត្ត *"សេចក្តីសម្រេចរបស់តុលាការ និងលទ្ធិ [...] ជា<u>មធ្យោបាយជំនួយ</u> ក្នុងការកំណត់វិធានច្បាប់ស្របតាមបទបញ្ញត្តិនៃមាត្រា ៥៩"* (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។ ផ្អែកលើមាត្រា ៥៩ របស់លក្ខន្តិកៈក្រុងរ៉ូម "សាលក្រមរបស់តុលាការ មានលក្ខណៈកំហិត សម្រាប់តែភាគីវិវាទ និងនៅក្នុងករណីដែលបានសម្រេចរួចហើយ តែប៉ុណ្ណោះ"។

១៨. តាមរយៈអានុភាពផ្សំគ្នានៃបទបញ្ញត្តិទាំងពីរ តុលាការយុត្តិធម៌អន្តរជាតិ ច្រានចោលគោលការណ៍វិធានយុត្តិសាស្ត្រ។ ទោះជាបែបនេះក្តី ចៅក្រមនៃតុលាការយុត្តិធម៌អន្តរជាតិបានយោងយ៉ាងងាយ

---

[9] របាយការណ៍ទី ៣ ស្តីពីការប្តេជ្ញាចិត្តនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ធ្វើបទបង្ហាញដោយលោក Michael WOOD (អ្នករាយការណ៍ពិសេស) នៅក្នុងសម័យប្រជុំលើកទី ៦៧ នៃគណៈកម្មការនៃច្បាប់អន្តរជាតិ, A/CN.4/682 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ** F30/12.1.54 កថាខណ្ឌ ៦០។

ស្រួលទៅលើការអនុវត្តកន្លងមក ដើម្បីធានានិរន្តភាពនៃយុត្តិសាស្ត្ររបស់របស់ពួកគេ។ ដូចអ្វីដែលចៅក្រម Tanaka បានលើកឡើងកាលពីឆ្នាំ ១៩៦៤ ថា គេត្រូវស្វែងរកតុល្យភាពដ៏ត្រឹមត្រូវមួយរវាងសច្ចភាពគតិយុត្ត និងយុត្តិធម៌៖

> "ខ្ញុំដឹងច្បាស់ណាស់ថា ការអនុវត្តយុត្តិសាស្ត្រកន្លងមក ត្រូវតែយកមកពិចារណាសម្រាប់រឿងក្តីទាំងអស់ដែលតុលាការត្រូវធ្វើការវិនិច្ឆ័យ។ វាមិនមានមន្ទិលសង្ស័យទាល់តែសោះថា ការគោរពតាមការអនុវត្តកន្លងមក និងការបន្តរក្សានិរន្តរភាពនៃយុត្តិសាស្ត្រ ជាបំណងប្រាថ្នាដ៏ខ្លាំងក្លា ដើម្បីជាប្រយោជន៍ដល់សច្ចភាពផ្លូវច្បាប់ ហើយក៏មិនអាចខ្វះបាន ទាំងនៅក្នុងច្បាប់ជាតិ ទាំងក្នុងច្បាប់អន្តរជាតិ។ រឿងក្តីប្រភេទដូចគ្នានេះ ត្រូវតែសម្រេចតាមរបៀបដូចគ្នា និងតាមវិនិច្ឆ័យកិច្ចដូចគ្នា បើអាចធ្វើបាន។ ការដាក់កំហិតនេះ ជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសកម្មភាពរបស់តុលាការ ដែលមានលក្ខណៈផ្ទុយគ្នាពីសកម្មភាពតាមបែបទ្រឹស្តីសុទ្ធសាធ។
>
> ទន្ទឹមនឹងនេះដែរ ឯកសណ្ឋានភាពនៃយុត្តិសាស្ត្រ មិនដែលមានលក្ខណៈដាច់ខាតសោះឡើយ។ គេអាចធានាឯកសណ្ឋានភាពរបស់វាបាន អាស្រ័យលើភាពចាំបាច់នៃយុត្តិធម៌ និងសំអាងហេតុ។ តុលាការមិនត្រូវស្ទាក់ស្ទើរក្នុងការធ្វើមោឃភាពយុត្តិសាស្ត្រ ឬបង្ហាញពីក្តីកង្វល់ហួសហេតុពីអំណាចសាលក្រមរបស់ខ្លួនកន្លងមកនោះទេ។ អំណាចផ្លូវការនៃសាលក្រមមួយរបស់តុលាការ មិនត្រូវបន្តប្រកាន់យក ដោយបង្កព្យសនកម្មដល់អំណាចជាសារវ័ន្តរបស់ខ្លួនឡើយ។ ដូច្នេះ វាជារឿងមួយដែលពិតជាមិនអាចជៀសផុតបាន ត្រង់ថា ដោយផ្អែកលើសេចក្តីសន្និដ្ឋាន ឬលើសំអាងហេតុ ចៅក្រមដែលស្ថិតនៅក្នុងចង្កោមភាគតិច នៅក្នុងរឿងក្តីមួយ នៅពេលបន្តិចក្រោយមក បែរមកស្ថិតនៅក្នុងចង្កោមភាគច្រើន សម្រាប់រឿងក្តីប្រភេទដូចគ្នាមួយផ្សេងទៀត"[10]។

## ផ្នែកទី ២. <u>តុលាការសិទ្ធិមនុស្សអឺរ៉ុប</u>

១៩. បើទោះបីជាតុលាការសិទ្ធិមនុស្សអឺរ៉ុប មានទម្លាប់គោរពយុត្តិសាស្ត្រ *"ដើម្បីជាប្រយោជន៍ដល់សច្ចភាពគតិយុត្ត និងការអភិវឌ្ឍដ៏ស៊ីសង្វាក់គ្នានៃយុត្តិសាស្ត្រពាក់ព័ន្ធនឹងអនុសញ្ញា"* ក៏ដោយ តុលាការ

---

[10] រឿងក្តី *Barcelona Traction, Light and Power Company, Limited* (ប្រទេសបែលហ្ស៊ិកតទល់នឹង ប្រទេសអេស្ប៉ាញ) - អញ្ញត្រកម្មសាលដីកា ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៦៤ មតិផ្ទាល់ខ្លួនរបស់លោក TANAKA ទំព័រ ៦៣។

នេះ *"មិនត្រូវបានចងភ្ជាប់ដោយសាលក្រមកន្លងមករបស់ខ្លួន"* នោះទេ និងអាចទាត់ចោលសាលក្រមនោះបាន *"បើសិនជាហេតុផលតម្រូវ"*[11]។

២០. ម្យ៉ាងវិញទៀត តុលាការសិទ្ធិមនុស្សអឺរ៉ុបចាត់ទុក *"ភាពចាំបាច់នៃសច្ចភាពគតិយុត្ត និងការការពារទំនុកចិត្តតាមផ្លូវច្បាប់របស់អ្នកទាមទារយុត្តិធម៌ មិនបោះបង់ច្បាប់ដែលមានតាំងពីយូរមកហើយ រួចងាកទៅចាប់យកយុត្តិសាស្ត្រអចិន្ត្រៃយ៍ឡើយ"*[12]។

## ផ្នែកទី ៣. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី

២១. បើទោះបីជាគ្មានបទបញ្ញត្តិណាមួយនៃលក្ខន្តិកៈរបស់តុលាការចំពោះកិច្ចបញ្ជាក់ថា យុត្តិសាស្ត្រមានអំណាចចាប់បង្ខំនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក៏ដោយក្តី សាលាឧទ្ធរណ៍បានវាយតម្លៃ ចាប់តាំងពីរឿងក្តីរបស់ *Aleksovski* មក ថា៖

> "ដើម្បីជាប្រយោជន៍ដល់សច្ចភាពគតិយុត្ត និងភាពអាចប្រមាណបានតាមផ្លូវច្បាប់ សាលាឧទ្ធរណ៍ត្រូវគោរពតាមសាលក្រមកន្លងមករបស់ខ្លួន ក៏ប៉ុន្តែ មានសិទ្ធិច្រានចោលសាលក្រមទាំងនោះ បើសិនជាហេតុផលតម្រូវ ដើម្បីជាប្រយោជន៍ដល់យុត្តិធម៌។
>
> ពាក់ព័ន្ធនឹងស្ថានភាពទាំងឡាយ ដែលហេតុផលតម្រូវឱ្យច្រានចោលសាលក្រមកន្លងទៅណាមួយ ដើម្បីប្រយោជន៍យុត្តិធម៌ យើងសូមលើកយកឧទាហរណ៍មួយស្តីពីសាលក្រមមួយ ដែលចេញដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍គតិយុត្តមានកំហុស ឬសាលក្រមដែលចេញដោយមិនយោងទៅលើបទបញ្ញត្តិច្បាប់ ឬសាលក្រមពាក់ព័ន្ធកន្លងមក (per incuriam) មានន័យថា "សម្រេចដោយមិនត្រឹមត្រូវ ពីព្រោះថា ជាទូទៅចៅក្រមម្នាក់ ឬច្រើន មិនបានជ្រួតជ្រាបច្បាស់លាស់ពីច្បាប់ជាធរមាន"។

---

[11] រឿងក្តី Cossey តទល់នឹង ចក្រភពអង់គ្លេស (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩០ កថាខណ្ឌ ៣៥។

[12] រឿងក្តី Unedic តទល់នឹង ប្រទេសបារាំង (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៧៤។

យើងគួរគូសបញ្ជាក់ថា វិធានតម្រូវឱ្យគោរពតាមសាលក្រមកន្លងមក ហើយការមិនគោរពតាម គឺជាករណីពិសេស។ សាលាឧទ្ធរណ៍នឹងទាត់ចោលសាលក្រមណាមួយដែលបានសម្រេចកន្លងមក ទាល់តែបានពិនិត្យដោយយកហ្មត់ចត់បំផុត ទាំងទិដ្ឋភាពច្បាប់ ជាពិសេស ប្រភពដែលបានដកស្រង់យកមកគាំទ្រ និងទាំងទិដ្ឋភាពនៃអង្គហេតុ។

អ្វីដែលបានទទួលយកនៅក្នុងសាលក្រមកន្លងមក គឺជាគោលការណ៍គតិយុត្តដែលជាសំអាងហេតុនៃសាលក្រមទាំងនោះ (ratio decidendi)”[13]។

២២. សាលាឧទ្ធរណ៍ វាយតម្លៃផងដែរថា អង្គជំនុំជម្រះសាលាដំបូងនៃតុលាការចំពោះកិច្ច “ត្រូវតែ” ពិនិត្យសំអាងហេតុនៃសាលក្រម[14]។

២៣. ទោះជាយ៉ាងនេះក្តី សាលាឧទ្ធរណ៍មិនស្ទាក់ស្ទើរក្នុងការយោងទៅលើសាលក្រមកន្លងមករបស់ខ្លួននោះទេ នៅពេលដែលយល់ឃើញថាចាំបាច់។ ឧទាហរណ៍ នៅក្នុងរឿងក្តី *Semanza* (៣១ ឧសភា ២០០០) សាលាឧទ្ធរណ៍បានអនុវត្តករណីនេះ ពាក់ព័ន្ធនឹងការបកស្រាយមាត្រា ៤០ ស្ទួន នៃវិធានដែលខ្លួនធ្លាប់បានធ្វើ នៅក្នុងរឿងក្តី *Barayagwiza* (០៣ វិច្ឆិកា ១៩៩៩) ក្រោយពីបានពិចារណាលើសារបានច្បាប់នៃមាត្រានេះ (នៅឆ្នាំ ១៩៩៦ !)[15]។ រឿងរ៉ាវដែលថ្មីបំផុត និងល្បីល្បាញបំផុត ពាក់ព័ន្ធនឹងការបដិសេធចោលនូវនិយមន័យនៃពាក្រ “ជួយ និងលើកទឹកចិត្ត” នៃសេចក្តីសម្រេចក្នុងរឿងក្តី *Perišić* ដែលត្រូវបានយកមកអនុវត្តមួយឆ្នាំក្រោយមក នៅក្នុងរឿងក្តី *Šainović*[16] ហើយដែលពិបាកនឹងទទួលយកជាឯកច្ឆ័ន្ទ នៅក្នុងចំណោមចៅក្រមនៃសាលាឧទ្ធរណ៍[17] ផ្ទុះបញ្ហាំងជាថ្មីម្តងទៀតពី “ភាពមិនទៀតទាត់” នៃយុត្តិសាស្ត្រ។

---

[13] សាលដីកា Aleksovski (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ១០៧-១១០។

[14] សាលដីកា Aleksovski (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ១១៣។

[15] Semanza តទល់នឹង រដ្ឋអាជ្ញា ICTR-97-20-A, សេចក្តីសម្រេច ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០០ កថាខណ្ឌ ៩១-៩៧។

[16] សាលដីកា Šainović *(តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី)* ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៤ កថាខណ្ឌ ១៦៥០។

[17] សាលដីកា Stanišić et Simatović *(តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី)* ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ

## ផ្នែកទី ៤. តុលាការព្រហ្មទណ្ឌអន្តរជាតិ

២៤. មាត្រា ២១ នៃលក្ខន្តិកៈទីក្រុងរ៉ូម របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក្រោមចំណងជើងថា "ច្បាប់ជាធរមាន" បានចែងនៅក្នុងកថាខណ្ឌទី២ ថា *"អង្គជំនុំជម្រះ __អាច__ អនុវត្តគោលការណ៍ និងវិធានច្បាប់ ដូចដែលអង្គជំនុំជម្រះធ្លាប់បានបកស្រាយរួចមកហើយ នៅក្នុងសាលសក្រមកន្លងមក"* (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។ ដូច្នេះ តុលាការព្រហ្មទណ្ឌអន្តរជាតិមិនមានកាតព្វកិច្ចគោរពតាមសាលក្រមកន្លងមកនោះទេ ហើយអាចប្រើប្រាស់សាលក្រមកន្លងមក ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

## ជំពូកទី ៣. ច្បាប់របស់ អ.វ.ត.ក

២៥. មិនមានអត្ថបទច្បាប់ណាមួយរបស់ អ.វ.ត.ក បានចែងថា ចៅក្រមត្រូវបានចងភ្ជាប់ដោយវិធានយុត្តិសាស្ត្រនោះទេ។ ករណីនេះ វិធានយុត្តិសាស្ត្រមិនមានអត្ថិភាពនៅក្នុងតុលាការអន្តរជាតិមួយនេះ ដែលប្រកាន់យកប្រព័ន្ធច្បាប់ civil law។

២៦. នៅក្នុងសំណុំរឿង ០០៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ BOHLANDER បានប្រកាសថា៖

> "អ.ប.ជ គឺជាសភាស៊ើបសួរនៅក្នុងដំណាក់កាលនីតិវិធីនៃការស៊ើបអង្កេតនៅ អ.វ.ត.ក។ នៅក្នុងប្រព័ន្ធច្បាប់ civil law ចៅក្រមមានកាតព្វកិច្ចត្រូវគោរពតាមច្បាប់តែប៉ុណ្ណោះ ហើយគោលការណ៍នៅក្នុងប្រព័ន្ធច្បាប់ common law ស្តីពីទ្រឹស្តីយុត្តិសាស្ត្រ មិនអាចយកមកអនុវត្តបានឡើយ។ ទោះបីជា អ.ប.ជ អាចចេញសាលដីកា និងសេចក្តីសម្រេចដែលចងកាតព្វកិច្ចដល់ ស.ច.ស ក៏ដោយ ក៏គោលការណ៍នីត្យានុកូលភាពដែលបានបង្កើតឡើងដោយ អ.ប.ជ យោងតាមវិធាន ពុំចងកាតព្វកិច្ចឱ្យ ស.ច.ស គោរពតាមនៅក្នុងការបកស្រាយច្បាប់នោះទេ"[18]។

២០១៥ កថាខណ្ឌ ១០៤-១០៦, *Separate and Partially Dissenting Opinion of Judge Carmel AGIUS* កថាខណ្ឌ ៦។ *Dissenting Opinion of Judge Koffi Kumelio A. AFANDE* កថាខណ្ឌ ២២-៣១។

[18] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦, សំណុំរឿង ០០៣-ឯកសារ **D87/2/1.7/1** កថាខណ្ឌ ១៣ (និងកថាខណ្ឌ ១៧)។

២៧. ក្រោយពីបានប្រកាសថា ការគោរពតាមសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង អាចនាំឱ្យមានការអនុវត្តច្បាប់តាមរបៀបដូចគ្នា នៅក្នុងសំណុំរឿងស្រដៀងគ្នា និងដើម្បីជាប្រយោជន៍ដល់សច្ចភាពគតិយុត្ត[19] សហចៅក្រមអន្តរជាតិ នៅចុងបញ្ចប់ បានផ្តល់ការបកស្រាយមួយផ្ទុយពីការបកស្រាយលើកមុនរបស់អង្គជំនុំបុរេជំនុំជម្រះ ទៅលើចំណុចច្បាប់ដូចគ្នា[20]។

២៨. ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានច្រានចោលសេចក្តីសម្រេចខ្លះរបស់អង្គជំនុំជម្រះតុលាការកំពូល។ ឧទាហរណ៍ អង្គជំនុំជម្រះបានវិនិច្ឆ័យ "គ្មានន័យអ្វីសោះ" ចំពោះលក្ខខណៈវិនិច្ឆ័យ "ភាពតំណាងសមស្រប" នៃដីកាដំណោះស្រាយមួយ ដែលបានដកស្រង់ដោយអង្គជំនុំជម្រះតុលាការកំពូល ហើយអង្គជំនុំជម្រះមិនបានអនុវត្តលក្ខខណៈវិនិច្ឆ័យនេះទេ[21]។ម្យ៉ាងវិញទៀត បន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញពីភាព "ចាំបាច់" ក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយទៀត ដែលមានសមាសភាពចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដោយមិនមានអ្វីប្រឆាំងទៅនឹងការចាត់តាំងនេះទេ "នៅពេលមានប្រយោជន៍ដល់យុត្តិធម៌" និងក្រោយពីអង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា បញ្ហានេះជាការទទួលខុសត្រូវរបស់ប្រធានអង្គជំនុំជម្រះ[22] នៅពេលនោះ ប្រធានអង្គជំនុំជម្រះបានបញ្ចេញនូវក្តីមន្ទិលសង្ស័យយ៉ាងខ្លាំងចំពោះយុត្តាធិការរបស់អង្គជំនុំជម្រះលើបញ្ហានេះ។ ប្រធានអង្គជំនុំជម្រះបានសម្រេចថា ទោះជាយ៉ាងណាក្តី ការចាត់តាំងបែបនេះ មិន "ផ្តល់ប្រយោជន៍ដល់ការគ្រប់គ្រងតុលាការបានល្អ"[23] នោះទេ។

---

[19] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦, សំណុំរឿង ០០៣-**ឯកសារ D87/2/1.7/1** កថាខណ្ឌ ១៩។

[20] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦, សំណុំរឿង ០០៣-**ឯកសារ D87/2/1.7/1** កថាខណ្ឌ ៧៨។

[21] សេចក្តីសម្រេច ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ **ឯកសារ E284** កថាខណ្ឌ ៩៦-៩៩។ ដោយសារសេចក្តីសម្រេចនេះបានប្តឹងដល់ឧទ្ធរណ៍ ហើយដោយតុលាការកំពូលបានប្រើអំណាចរបស់ខ្លួនក្នុងការកែប្រែសេចក្តីសម្រេច អង្គជំនុំជម្រះសាលាដំបូងបានបង្ខំចិត្តអនុវត្តតាម។

[22] សេចក្តីសម្រេច ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ **ឯកសារ E284/4/8** កថាខណ្ឌ ៧៥។

[23] អនុស្សរណៈ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣ **ឯកសារ E301/4** កថាខណ្ឌ ១០។

២៩. វាប្រាកដណាស់ថា យុត្តិសាស្ត្រអចិន្ត្រៃយ៍មួយ ផ្តល់អំណោយផលដល់សច្ចភាពគតិយុត្ត។ មានន័យថា ចៅក្រមមិនត្រូវគោរពតាម និងដាច់ខាត មិនត្រូវអនុវត្តតាមសាលក្រមចាស់ណាមួយនោះទេ បើសិនជាសាលក្រមនោះមានកំហុស។

៣០. ជាក់ស្តែង ដូចចៅក្រម GUILLAUME បានលើកឡើងរួចមកហើយ នៅតុលាការយុត្តិធម៌អន្តរជាតិថា *"តួនាទីរបស់ចៅក្រម មិនមែនគ្រាន់តែមកជំនួសអ្នកតាក់តែងច្បាប់"* និង *"គ្រាន់តែសង្កេតមើលនីតិរដ្ឋ"*[24] ប៉ុណ្ណោះទេ។ ដូច្នេះ វាពិតជាមានប្រយោជន៍ដល់យុត្តិធម៌ ក្នុងការច្រានចោលសាលក្រមចាស់មួយ ដែលនៅក្នុងនោះ មានការបកស្រាយច្បាប់មិនត្រឹមត្រូវ។

៣១. ដូច្នេះ នៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះមិនត្រូវគោរពតាមវិនិច្ឆ័យកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង ០០២/០១ ដោយស្វ័យប្រវត្តិ និងទាំងងងឹតងងល់ នោះទេ។ អង្គជំនុំជម្រះមិនត្រឹមតែមិនត្រូវធ្វើបែបនេះប៉ុណ្ណោះទេ តែថែមទាំងមានកាតព្វកិច្ចដាច់ខាត ក្នុងការច្រានចោល នៅពេលដែលវិនិច្ឆ័យកិច្ចនោះមិនត្រឹមត្រូវ។

៣២. ដូចអ្វីដែលក្រុមមេធាវីការពារក្តីធ្លាប់បានអះអាងរួចមកហើយថា ស្ថិរភាព និងភាពស៊ីសង្វាក់គ្នាផ្នែកយុត្តិសាស្ត្រ មានសារៈសំខាន់សម្រាប់ជំនឿទុកចិត្ត និងមរតកគតិយុត្តនៅគ្រប់តុលាការទាំងអស់។ ដូច្នេះ ការអនុវត្តម្តងហើយម្តងទៀត នូវសាលក្រមមិនត្រឹមត្រូវ ប៉ះពាល់ធ្ងន់ធ្ងរដល់ជំនឿទុកចិត្ត និងមរតកគតិយុត្ត[25]។

៣៣. ជាឧទាហរណ៍ មហាត្មៈ គន្ធី បានសរសេរថា *"កំហុសឆ្គងមិនអាចក្លាយជាសច្ចភាពបានទេ ដោយសារវារីករាលដាល និងបំប៉ែកខ្លួន"*[26]។

---

[24] *ភាពស្របច្បាប់នៃការប្រើប្រាស់អាវុធនុយក្លេអ៊ែរដោយរដ្ឋមួយក្នុងជម្លោះប្រដាប់អាវុធ* ការផ្តល់យោបល់ប្រឹក្សា ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦ មតិផ្ទាល់ខ្លួនរបស់លោក GUILLAUME ទំព័រ ៧១។

[25] ចម្លើយតបរបស់ ខៀវ សំផន ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ** F11/1 កថាខណ្ឌ ៥៤។

[26] ឯកសារ *La Jeune Inde*, Mohandas Karamchand GHANDI, ឆ្នាំ១៩២៥។

## ភាគទី ២. យុត្តាធិការ

### ជំពូកទី ១. យុត្តាធិការពេលវេលា

#### ផ្នែកទី ១ .វិសាលភាព

៣៤. អនុលោមតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក យុត្តាធិការពេលវេលារបស់ អ.វ.ត.ក លាតសន្ធឹងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩[27]។

#### ផ្នែកទី ២. "សាលក្រម" សំណុំរឿង ០០២/០១

៣៥. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានប្រកាសពិរុទ្ធភាពរបស់ ខៀវ សំផន ពីបទប្រព្រឹត្តបទឧក្រិដ្ឋមួយចំនួន តាមរយៈសហឧក្រិដ្ឋកម្មរួម និងពីបទរៀបចំផែនការ ញុះញង់ ជួយ និងលើកទឹកចិត្តឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងទៀត[28]។

៣៦. ក្រុមមេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ជំទាស់នឹងការប្រកាសពិរុទ្ធភាពមួយចំនួន ពាក់ព័ន្ធនឹងការរៀបចំផែនការ និងការញុះញង់ ដោយហេតុផលថា អង្គជំនុំជម្រះបានទាញយកទឡ្ហីករណ៍ ដោយផ្អែកលើអង្គហេតុ និងអត្តចរិតដែលបានកើតឡើងនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[29]។

៣៧. អង្គជំនុំជម្រះតុលាការកំពូល បានឆ្លើយថា អង្គជំនុំជម្រះអាចធ្វើបែបនេះបាន ដើម្បីប្រកាសពិរុទ្ធភាព ដោយសារ... សហឧក្រិដ្ឋកម្មរួម (sic)[30]។ ជាក់ស្តែង ក្រៅពីបានទាត់ចោលទឡ្ហីករណ៍មួយ

---

[27] ច្បាប់ស្តីពីការបង្កើតឱ្យមានអ.វ.ត.ក មាត្រា ២ ថ្មី។ ការកម្រិតពេលវេលានេះក៏មានផងដែរនៅក្នុងកិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងនៅក្នុងលំនាំមុខនៃវិធានផ្ទៃក្នុង។

[28] សាលក្រម ០០២/០១ កថាខណ្ឌ ១០៥៣-១០៥៤។

[29] សារណាបណ្តឹងសាទុក្ខ ០០២/០១ កថាខណ្ឌ ៩។

[30] សាលដីកា ០០២/០១ កថាខណ្ឌ ២១១ -២២១។

ដែលក្រុមមេធាវីការពារក្ដីមិនបានលើកឡើង[31] អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់ហេតុផលដោយអះអាងផ្ទុយពីចំណុចនេះទៅវិញ។

## ១. សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូល

៣៨. ក្រោយពីបានពិភាក្សាអស់ពេលយ៉ាងយូរអំពីសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្ដីសន្និដ្ឋានបញ្ចប់ថា៖

> "សរុបសេចក្ដី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា យោងតាមមាត្រា ២ ថ្មី នៃច្បាប់ អ.វ.ត.ក ធាតុផ្សំសត្យានុម័តិនៃបទឧក្រិដ្ឋដែលជាកម្មវត្ថុនៃបទចោទ ត្រូវស្ថិតក្នុងអំឡុងពេលនៃចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៧ ចំណែកអំពើប្រព្រឹត្តដែលបង្កើតឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលដោយផ្អែកលើការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម អាចមានអត្ថិភាពនៅមុននេះ ប្រសិនបើអំពើប្រព្រឹត្តនេះ គឺជាផ្នែកនៃការរួមចំណែកយ៉ាងទូលំទូលាយនៅក្នុងការអនុវត្តគោលបំណងរួមដែលបានបន្តនៅក្រោយថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥។ ទាក់ទងទៅនឹងរឿងក្ដីចំពោះមុខ គួរកត់សម្គាល់ថា នេះពុំមែនជារឿងក្ដីដែលមានអំពើតែមួយ (ដូចជា ការរៀបចំផែនការ ឬការញុះញង់) ដែលបានប្រព្រឹត្តឡើងក្រៅវិសាលភាពពេលវេលានៃយុត្តាធិការរបស់ អ.វ.ត.ក ដែលចុងក្រោយក្លាយជាបទល្មើសនៅក្នុងយុត្តាធិការពេលវេលានេះឡើយ។ ផ្ទុយទៅវិញ អំពើប្រព្រឹត្តដែលចោទជាបញ្ហានោះ គឺជាផ្នែកនៃការរួមចំណែកយ៉ាងទូលំទូលាយនៅក្នុងការអនុវត្តគោលបំណងរួមដែលបានបន្តនៅក្នុងអំឡុងពេលក្រោយថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៥។ ជាពិសេស ជនជាប់ចោទបានចូលរួមនៅក្នុងការត្រួតពិនិត្យទីក្រុងភ្នំពេញបន្ទាប់ពីការបណ្ដេញប្រជាជនចេញពីទីក្រុង និងបានបន្តរួមចំណែកនៅក្នុងការអនុវត្តគោលបំណងរួម។ ដូច្នេះ ពុំមានការបង្ហាញថា ជនជាប់ចោទបានដកខ្លួនចេញពីគោលបំណងរួមនៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ឬ

---

[31] ក្រុមមេធាវីការពារក្ដីបានលើកឡើងពីបញ្ហាយុត្តាធិការពេលវេលាប៉ុណ្ណោះ នៅក្នុងកថាខណ្ឌ ៩ នៃសារណាបណ្ដឹងសាទុក្ខ ០០២/០១។ ក្នុងកំណត់សម្គាល់ជើងទំព័រ ៥១២ នៃសាលដីកានៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានយោងទៅកថាខណ្ឌ ៩ ហើយបន្ថែម « សូមមើលកថាខណ្ឌ ២៣១ ផងដែរ »។ ប៉ុន្តែ នៅក្នុងកថាខណ្ឌ ២៣១ ក្រុមមេធាវីគ្រាន់តែលើកឡើងថា ដោយយោងតាមអង្គហេតុទាំងអស់ដែលអង្គជំនុំជម្រះបានពិនិត្យ ពីឆ្នាំ១៩៥៨ ដល់ឆ្នាំ១៩៧៩ អង្គជំនុំជម្រះមិនធ្លាប់បញ្ជាក់ឱ្យបានច្បាស់ទាល់តែ សោះថា តើអង្គជំនុំជម្រះទាញលោក ខៀវ សំផន ឱ្យជាប់ពាក់ព័ន្ធទៅនឹងផែនការឧក្រិដ្ឋរួម ឬទិដ្ឋភាពឧក្រិដ្ឋនៃ គោលបំណងរួម នៅពេលណា និងដោយរបៀបណា។ វាខុសពីពីចំណុចដែលរងការចោទប្រកាន់ នៅក្នុង កថាខណ្ឌ ៩។ ម្យ៉ាងទៀត ក្រុមមេធាវីរបស់លោក នួន ជា ក៏មិនបានលើកបញ្ហាពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមឡើយ តែលើកតែពីរបៀបនៃការចូលរួមដទៃទៀតប៉ុណ្ណោះ ៖ សាលដីកា ០០២/០១ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កំណត់សម្គាល់ជើងទំព័រ ៥១២ ដែលយោងទៅ កថាខណ្ឌ ៦២៧-៦៣៥ និង ៦៦៣ នៃសារណាបណ្ដឹងសាទុក្ខរបស់លោក នួន ជា។

ពេលណាមួយក្រោយមកទៀតនោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងបញ្ហានៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក”[32]។

៣៩. ដោយថែមទាំងមិនបាននិយាយពីប្រភពនៃការអះអាងគ្មានមូលដ្ឋាន ដែលថា ខៀវ សំផន ទំនងជាបានចូលរួមក្នុងកិច្ចការអធិការកិច្ចនៅក្រុងភ្នំពេញ បន្ទាប់ពីការជម្លៀសប្រជាជនរួច (ទោះបីជាចំណុចនេះមិនមានការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ឬនៅក្នុងសេចក្តីសន្និដ្ឋាននៃសាលក្រម 00២/0១ ហើយគ្មានធាតុផ្សំនៃភ័ស្តុតាងណាមួយ នៅក្នុងសំណុំរឿងដ៏សែនក្រាស់ឃ្មឹក លើកឡើងពីចំណុចនេះ ក៏ដោយ) អង្គជំនុំជម្រះតុលាការកំពូល ធ្វេសប្រហែសទាំងស្រុង ចំពោះសំណុំរឿងដែលប្តឹងមកខ្លួន ដោយសារសំណុំរឿងមានដាក់បញ្ចូលទម្រង់នៃការចូលរួមផ្សេងទៀត ក្រៅពីសហឧក្រិដ្ឋកម្មរួម ដូចជា ការរៀបចំផែនការ ឬការញុះញង់។

៤0. ទោះជាយ៉ាងណាក្តី ដើម្បីគាំទ្រវិនិច្ឆ័យកិច្ចរបស់ខ្លួនស្តីពីសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះតុលាការកំពូល “ត្រូវកត់សម្គាល់” ថា គេត្រូវតែបែងចែកសហឧក្រិដ្ឋកម្មរួមឱ្យដាច់ចេញពីទម្រង់នៃការចូលរួមផ្សេងៗទៀត ដែលតាមរយៈទម្រង់ទាំងនេះ អំពើតែមួយគត់ ដែលត្រូវបានប្រព្រឹត្តនៅក្រៅយុត្តាធិការពេលវេលារបស់តុលាការ អាចនឹងបណ្តាលឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋមួយ នៅក្នុងយុត្តាធិការពេលវេលា។

៤១. ជាក់ស្តែង នេះជាអ្វីដែលមេធាវីការពារក្តីបានស្តីបន្ទោសដល់អង្គជំនុំជម្រះ ដែលបានប្រកាសផ្តន្ទាទោសមួយចំនួន ពីបទរៀបចំផែនការ និងបទញុះញង់ ដោយផ្អែកតែទៅលើអំពើដែលបានប្រព្រឹត្តនៅក្រៅយុត្តាធិការរបស់តុលាការ។

៤២. បើទោះបីជាក្រុមមេធាវីការពារក្តីមិនធ្លាប់ដែលបានជំទាស់ថា អង្គជំនុំជម្រះអាចធ្វើសំអាងហេតុដោយផ្អែកលើធាតុផ្សំមួយចំនួន នៅក្រៅយុត្តាធិការពេលវេលារបស់ខ្លួនពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ក៏ដោយ តែក្រុមមេធាវីការពារក្តីត្រូវតែលើកឡើងថា វិនិច្ឆ័យកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូលចំពោះបញ្ហានេះ ពិតជាមានកំហុស និងមិនអាចក្លាយជាយុត្តិសាស្ត្រដែលគេអាចអនុវត្តតាមបានឡើយ។

---

[32] សាលដីកា 00២/0១ កថាខណ្ឌ ២២១។

## ២. វិនិច្ឆ័យកិច្ចមិនត្រឹមត្រូវរបស់អង្គជំនុំជម្រះតុលាការកំពូល

៤៣. អង្គជំនុំជម្រះតុលាការកំពូលបានចាប់ផ្ដើមដោយបញ្ចេញទស្សនៈរបស់ខ្លួនស្ដីពីសហឧក្រិដ្ឋកម្មរួម មុននឹងប្រកាសថា បញ្ហានេះទំនងជាមិនដែលធ្លាប់បានលើកឡើងទេ នៅក្នុងច្បាប់អន្តរជាតិ[33]។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលបានវាយតម្លៃថា គោលជំហររបស់ខ្លួនឆ្លុះបញ្ចាំងនៅក្នុង យុត្តិសាស្ត្រអង់គ្លេស និងយុត្តិសាស្ត្រអាមេរិច ជាពិសេស ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៃបទផ្សំគំនិត *"conspiracy"*[34]។ នៅចុងបញ្ចប់ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា យុត្តិសាស្ត្រ *Nahimana* ដែលអះអាងដោយក្រុមមេធាវីការពារក្តី គឺមានភាពពាក់ព័ន្ធតិចតួច[35]។

៤៤. នៅក្នុងរឿងក្តី *Nahimana* សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានចោទជាសំណួរថា នៅក្នុងករណីដែលជនជាប់ចោទម្នាក់ មិនបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយខ្លួនឯង តើអំពើជាទទំនួលខុសត្រូវរបស់ជននោះចំពោះបទឧក្រិដ្ឋបែបនេះ នៅក្រោមទម្រង់ (មួយ ឬច្រើន) នៃការទទួលខុសត្រូវ ដែលចែងដោយលក្ខន្តិកៈតុលាការ ត្រូវកើតមាននៅក្នុងយុត្តាធិការពេលវេលារបស់តុលាការដែរឬទេ មានន័យថា នៅចន្លោះថ្ងៃទី ០១ ខែ មករា និងថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤។ សាលាឧទ្ធរណ៍បានប្រកាសថា យុត្តិសាស្ត្រមិនបានផ្តល់ចម្លើយច្បាស់លាស់ចំពោះសំណួរនេះទេ[36]។ អាស្រ័យហេតុនេះ សាលាឧទ្ធរណ៍បានពិនិត្យមើលចេតនារបស់អ្នកសរសេរលក្ខន្តិកៈ និងបានកត់សម្គាល់ថា យុត្តាធិការពេលវេលា ត្រូវបានលើកពេល ពីខែ មេសា ឆ្នាំ ១៩៩៤ (កាលបរិច្ឆេទ ដែលបានស្នើឡើងតាំងពីដំបូង) ទៅខែ មករា ឆ្នាំ ១៩៩៤ ដើម្បីដាក់បញ្ចូលបទរៀបចំផែនការប្រល័យពូជសាសន៍[37]។ បន្ទាប់មក សាលាឧទ្ធរណ៍បានសន្និដ្ឋានថា៖

[33] សាលដីកា ០០២/០១ កថាខណ្ឌ ២១៥-២១៦។

[34] សាលដីកា ០០២/០១ កថាខណ្ឌ ២១៦។

[35] សាលដីកា ០០២/០១ កថាខណ្ឌ ២១៨-២២០។

[36] សាលដីកា Nahimana (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៣១០។

[37] សាលដីកា Nahimana (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៣១១-៣១២។

"បើតាមមតិរបស់សាលាឧទ្ធរណ៍ វាបានចង្អុលបង្ហាញយ៉ាងច្បាស់ថា អ្នកតាក់តែងលក្ខន្តិកៈចង់ឱ្យតុលាការមានយុត្តាធិការផ្តន្ទាទោសជនជាប់ចោទណាម្នាក់បាន ដរាបណាធាតុផ្សំទាំងអស់ដែលត្រូវបង្ហាញ ដើម្បីសន្និដ្ឋានពីទំនួលខុសត្រូវរបស់ជននោះ មានអត្ថិភាពនៅឆ្នាំ ១៩៩៤។ ម៉្យាងវិញទៀត ការបកស្រាយបែបនេះស្របគ្នាជាមួយគោលការណ៍បកស្រាយតឹងរ៉ឹងពីបទបញ្ញត្តិដែលផ្តល់យុត្តាធិការទៅដល់តុលាការអន្តរជាតិ និងជាមួយគោលការណ៍បកស្រាយតឹងរ៉ឹង ក្នុងច្បាប់ព្រហ្មទណ្ឌ។ ដូច្នេះ សាលាឧទ្ធរណ៍វិនិច្ឆ័យថា គេត្រូវតែបង្ហាញថា៖

១) ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ពីទំនួលខុសត្រូវរបស់ជនជាប់ចោទ ត្រូវបានប្រព្រឹត្តនៅឆ្នាំ ១៩៩៤។

២) អំពើ ឬការប្រព្រឹត្តិរបស់ជនជាប់ចោទ ដែលជាឫសគល់នៃទំនួលខុសត្រូវរបស់ជននោះ ស្របតាមទម្រង់នៃការទទួលខុសត្រូវ ដូចមានចែងនៅក្នុងមាត្រា ៦(១) ឬ ៦(៣) នៃលក្ខន្តិកៈ បានកើតឡើងនៅឆ្នាំ ១៩៩៤ ហើយនៅអំឡុងពេលនៃអំពើ ឬការប្រព្រឹត្តិទាំងនោះ ជនជាប់ចោទមានចេតនាឧក្រិដ្ឋ (mens rea) ដើម្បីដាក់ឱ្យទទួលខុសត្រូវ ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវនោះ" [38] ។

៤៥. អង្គជំនុំជម្រះតុលាការកំពូលយល់ថា ការបកស្រាយបែបនេះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាពីលក្ខន្តិកៈរបស់ខ្លួន "កើតចេញពីការពិចារណាលើប្រវត្តិនៃការធ្វើសេចក្តីព្រាងដាក់លាក់នៃបទប្បញ្ញត្តិនោះ និងការទទួលស្គាល់របស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR នូវបំណងរបស់អ្នកធ្វើសេចក្តីព្រាងលក្ខន្តិកៈនេះ។ ដូច្នេះទាំងអស់នេះពុំអាចយកមកធ្វើជាមូលដ្ឋានដើម្បីបកស្រាយមាត្រា ២ ថ្មី នៃច្បាប់ អ.វ.ត.ក បានឡើយ"[39]។

៤៦. វាច្បាស់ណាស់ថា ប្រវត្តិនៃការតាក់តែងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ខុសគ្នាពីប្រវត្តិនៃការតាក់តែងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ក៏ប៉ុន្តែ ថ្វីត្បិតតែគេមិនអាចនាំយកប្រវត្តិនៃការតាក់តែងនេះមកអនុវត្តបាន តែគេអាចនាំយកនីតិវិធីបកស្រាយមកអនុវត្តបានទាំងស្រុង។ ម៉្យាងវិញទៀត អង្គជំនុំជម្រះតុលាការកំពូល បានរំឭកដោយខ្លួនឯងផ្ទាល់ នាពេលក្រោយមក នៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០១ (ដោយពិនិត្យមើលបទបញ្ញត្តិមួយនៃ

[38] សាលដីកា Nahimana (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៣១៣។

[39] សាលដីកា ០០២/០១ កថាខណ្ឌ ២១៩។

លក្ខន្តិកៈរបស់តុលាការយោធាអន្តរជាតិ) ពីអត្ថបទច្បាប់ដ៏សំខាន់មួយពាក់ព័ន្ធនឹងបញ្ហានេះ ពោល គឺ អនុសញ្ញាក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាឆ្នាំ ១៩៦៩[40]។

៤៧. គេគួរកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលពិតជាបានជៀសវាងធ្វើការបកស្រាយមាត្រា ២ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងធ្វើការពិភាក្សាពីចេតនារបស់អ្នកតាក់តែងច្បាប់នេះ។

៤៨. បើសិនជាអង្គជំនុំជម្រះតុលាការកំពូលបានអនុវត្តវិញ អង្គជំនុំជម្រះតុលាការកំពូលគួរតែត្រូវពិនិត្យរបាយការណ៍ឆ្នាំ ១៩៩៩ របស់ក្រុមអ្នកជំនាញដែលទទួលអាណត្តិពីអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីសិក្សាពីលទ្ធភាពផ្សេងៗក្នុងការជំនុំជម្រះមេដឹកនាំខ្មែរក្រហម។ ក្រុមអ្នកជំនាញបានផ្តល់អនុសាសន៍ "យ៉ាងម៉ឺងម៉ាត់" ឱ្យបង្កើតតុលាការអន្តរជាតិពិសេសមួយ ដូចតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា[41] ដោយមានដែនយុត្តាធិការចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩៖

> "ស្ថាប័នទទួលបន្ទុកបង្កើតតុលាការមួយរបស់អង្គការសហប្រជាជាតិ គួរត្រូវសម្រេចកំណត់ដែនពេលវេលានៃយុត្តាធិការរបស់ខ្លួន។ ក្រុមអ្នកជំនាញបានវាយតម្លៃយ៉ាងម៉ឺងម៉ាត់ថា យុត្តាធិការ ក៏ដូចជាអាណត្តិរបស់តុលាការនេះដែរ ត្រូវតែកំណត់ត្រឹមរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩។ បើសិនជាយើងផ្តល់យុត្តាធិការដល់តុលាការនេះ ដើម្បីស្វែងយល់ពីការរំលោភសិទ្ធិមនុស្ស <u>តាមផ្នែកណាមួយ មុន ឬក្រោយអំឡុងពេលនោះ</u> យើងអាចនឹង

[40] សាលដីកា ០០២/០១ កថាខណ្ឌ ៣៩៣ និង កំណត់សម្គាល់ជើងទំព័រ ៩៧៣ អង្គជំនុំជម្រះតុលាការកំពូលបានយោងទៅមាត្រា ៣៣-៤ នៃអនុសញ្ញាទីក្រុង Vienna ស្តីពីច្បាប់សន្ធិសញ្ញាដែលស្ថិតនៅក្នុងផ្នែកទី៣ ក្រោមចំណងជើងថា « ការបកស្រាយអំពីសន្ធិសញ្ញា »។ មាត្រាពីរមុននោះដែលដាក់បញ្ចូលក្នុងផ្នែកនេះ បានចែងថាសន្ធិសញ្ញាមួយ « ត្រូវបកស្រាយដោយស្មោះត្រង់ទៅតាមន័យធម្មតាដែលមានក្នុងសន្ធិសញ្ញា តាមបរិបទរបស់វា និងដោយគិតដល់កម្មវត្ថុ និងគោលដៅរបស់វា (មាត្រា ៣១) ហើយចែងថា « សន្ធិសញ្ញាក៏អាចប្រើមធ្យោបាយបន្ថែមក្នុងការបកស្រាយ ជាពិសេសអាចប្រើការស្រាវជ្រាវដែលកំពុងធ្វើ ព្រមទាំងកាលៈទេសៈដែលនៅក្នុងអំឡុងពេលនោះ កតិកាសញ្ញាត្រូវបានអនុម័ត » (មាត្រា ៣២)។

[41] របាយការណ៍នៃក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា បង្កើតឡើងតាមសេចក្តីសម្រេចលេខ 52/135 នៃមហាសន្និបាត ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ (A/53/580 ; S/1999/231) **ឯកសារ D366/7.1.556** (« របាយការណ៍នៃក្រុមអ្នកជំនាញ **ឯកសារ D366/7.1.556** ») កថាខណ្ឌ ១៣៩-១៤០។

លែងមើលឃើញសារជាតិតែមួយគត់ និងវិសាមញ្ញ នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[42]។

៤៩. អ្នកតាក់តែងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានស្គាល់របាយការណ៍មួយនេះច្បាស់ណាស់ រួមទាំងល័ក្ខខ័ណ្ឌនៃការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា។ បើសិនអ្នកតាក់តែងច្បាប់ទាំងនោះមានចេតនាពន្លាតយុត្តាធិការពេលវេលារហូតដល់អំឡុងពេលមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដើម្បីដាក់បញ្ចូលបទរៀបចំផែនការ ពួកគេពិតជាបានធ្វើរួចបាត់ទៅហើយ។ ផ្ទុយទៅវិញ ពួកគេថែមទាំងបានសម្រេចមិនពន្លាតយុត្តាធិការនេះ ឱ្យទៅហួសថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ពោលគឺមិនដល់ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩ ទៅតាមអនុសាសន៍ដែលបានផ្តល់ ដោយមិនគិតថ្ងៃផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យដោយវៀតណាម។ ដូច្នេះ អ្នកតាក់តែងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានកំណត់ម៉ឺងម៉ាត់ពីយុត្តាធិការពេលវេលា ដើម្បីដករាល់អំពើទាំងឡាយដែលបានប្រព្រឹត្តដោយភាគីផ្សេងទៀតនៃជម្លោះ និងដោយអតីតសមាជិកបក្សកុម្មុយនីស្តកម្ពុជា ដែលកំពុងកាន់អំណាចបច្ចុប្បន្ន ចេញពីដែនពិនិត្យអង្គហេតុរបស់តុលាការ ពោលគឺមិនគិតអំពើកើតមានមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងក្រោយថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។

៥០. ម៉្យាងវិញទៀត ការបកស្រាយដ៏គ្មានមន្ទិលមួយនេះ ស្របតាមគោលការណ៍នៃការបកស្រាយតឹងរ៉ឹងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ដែលបានរំឭកឡើងវិញដោយយុត្តិសាស្ត្រ *Nahimana* ក៏ប៉ុន្តែបែរជាត្រូវបានបំភ្លេចទាំងស្រុងដោយអង្គជំនុំជម្រះតុលាការកំពូល (មិនមែនតែនៅត្រង់ចំណុចនេះប៉ុណ្ណោះទេ តែនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទាំងមូលតែម្តងផងដែរ)[43]។

៥១. ជំនួសឱ្យការជ្រើសរើសយកនីតិវិធីបកស្រាយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អង្គជំនុំជម្រះអង្គជំនុំជម្រះតុលាការកំពូលបែរជាចូលរួមក្នុងអំពើពុតត្បុតដ៏រាតត្បាតរបស់តុលាការមួយនេះ។ អង្គជំនុំជម្រះតុលាការកំពូលបានបន្តវិនិច្ឆ័យកិច្ចរបស់ខ្លួន ដោយសំអាងថាគ្មានភាពពាក់ព័ន្ធនៃយុត្តិសាស្ត្រ *Nahimana* ដោយអះអាងថា នៅក្នុងសំណុំរឿងនេះ វាជាបញ្ហាឧក្រិដ្ឋកម្មបន្តបន្ទាប់ពាក់ព័ន្ធនឹងការញុះញង់ដោយផ្ទាល់និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងសហការប្រព្រឹត្តបទ

---

[42] របាយការណ៍នៃក្រុមអ្នកជំនាញ **ឯកសារ D366/7.1.556** កថាខណ្ឌ ១៤៩ (មានជាភាសាបារាំងនៅក្នុងអ៊ិនធឺណិត)។

[43] សូមមើលខាងក្រោម កថាខណ្ឌ ៣០០-៥១៦។

ប្រល័យពូជសាសន៍ (ដែលមិនត្រូវបានយកមកពិនិត្យនៅក្នុងសំណុំរឿង ០០២/០១)[44]។ ក៏ប៉ុន្តែ ឧក្រិដ្ឋកម្មបន្តបន្ទាប់ទាំងនេះ មិនមានភាពពាក់ព័ន្ធ តិចឬច្រើនក្តី ជាងឧក្រិដ្ឋកម្មបន្តបន្ទាប់ពាក់ព័ន្ធនឹងការផ្សំគំនិត (ហើយក៏មិនបានយកពិនិត្យក្នុងសំណុំរឿង ០០២/០១ ដែរ) នៅក្នុងយុត្តិសាស្ត្រអង់គ្លេស ឬអាមេរិច ដែលអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញ កាលពីមុនពេលនោះបន្តិច ថា យុត្តិសាស្ត្រទាំងនេះ "ផ្តល់ជាព័ត៌មាន"[45]។ ជាក់ស្តែង គ្មានឧក្រិដ្ឋកម្មណាមួយ បន្តបន្ទាប់ ឬមិនបន្តបន្ទាប់ក៏ដោយ មានភាពពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមឡើយ ព្រោះវាជាទម្រង់នៃការទទួលខុសត្រូវ។

៥២. អង្គជំនុំជម្រះតុលាការកំពូលបានគេចវេសមិនទទួលស្គាល់ថា នេះជាគោលការណ៍ទូទៅទាញចេញពីយុត្តិសាស្ត្រ *Nahimana*។ គោលការណ៍នេះ មានភ្ជាប់អញ្ញត្តិកម្មតែមួយដែលគេស្គាល់ច្បាស់ និងអនុវត្តយ៉ាងទូលំទូលាយ រួមទាំងនៅ អ.វ.ត.ក៖

> "បទបញ្ញត្តិនៃលក្ខន្តិកៈស្តីពីយុត្តាធិការពេលវេលារបស់តុលាការ មិនបានហាមឃាត់ការទទួលយកធាតុផ្សំនៃភ័ស្តុតាង ដែលពាក់ព័ន្ធនឹងអង្គហេតុមុនឆ្នាំ ១៩៩៤ ឡើយ [...]។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងមួយនឹងអាចទទួលយកដោយត្រឹមត្រូវ និងផ្អែកលើធាតុផ្សំនៃភ័ស្តុតាងពាក់ព័ន្ធនឹងអង្គហេតុកើតមុនឆ្នាំ ១៩៩៤ បើសិនធាតុផ្សំទាំងនេះ មានគោលដៅ៖
>
> - បំភ្លឺបរិបទណាមួយ។
> - បង្ហាញដោយការពិចារណា ពីធាតុផ្សំ (ជាពិសេស ចេតនាឧក្រិដ្ឋ) នៃចរិតឧក្រិដ្ឋ ដែលបានកើតឡើង នៅឆ្នាំ ១៩៩៤។
> - បង្ហាញពីមាគ៌ាដឹកនាំដោយចេតនា" [46]។

៥៣. អង្គជំនុំជម្រះមិនមានការលំបាកទាល់តែសោះ ក្នុងការនាំយកយកអញ្ញត្តិកម្មនេះមកកាន់ អ.វ.ត.ក និងថែមទាំងបានអនុវត្តនៅក្នុងសាលក្រម ០០២/០១ ទៀតផង[47]។ ក៏ប៉ុន្តែ បើអញ្ញត្តិកម្មនេះអាចយកមកអនុវត្តបាន គោលការណ៍នេះកាន់តែអាចយកមកអនុវត្តបានដូចគ្នា។

---

[44] សាលដីកា ០០២/០១ កថាខណ្ឌ ២២០។

[45] សាលដីកា ០០២/០១ កថាខណ្ឌ ២១៦។

[46] សាលដីកា Nahimana (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា) ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៣១៣។

[47] សាលក្រម ០០២/០១ កំណត់សម្គាល់ជើងទំព័រ ១៩៥។

៥៤. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់វិនិច្ឆ័យកិច្ចរបស់ខ្លួន ដោយសំអាងថាខ្វះភាពពាក់ព័ន្ធនៃយុត្តិសាស្ត្រ *Nahimana* ដោយប្រកាសថា សាលាឧទ្ធរណ៍ "ពុំបានពិភាក្សាលើបណ្តុំនៃការអនុវត្តផែនការដូចនៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ ដូចជា ករណីដែលជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវដោយផ្អែកលើការរួមចំណែករបស់ខ្លួន លាតសន្ធឹងអស់រយៈពេលយ៉ាងយូរនៅក្នុងការអនុវត្តគោលបំណងរួម ទោះបីជាយ៉ាងណាក្តី ពុំបានប្រព្រឹត្តអំពើ*សត្យានុម័ត*ដោយផ្ទាល់នៃបទឧក្រិដ្ឋដែលបានចោទប្រកាន់នោះក៏ដោយ"[48]។

៥៥. ថ្វីបើវាមិនមែនជាបញ្ហាសហឧក្រិដ្ឋកម្មរួម នៅក្នុងរឿងក្តី *Nahimana* ក៏ដោយ សាលាឧទ្ធរណ៍នៃតុលាការចំពោះកិច្ច បានពិនិត្យមើលរឿងក្តីផ្សេងទៀតដែលមានជាប់ពាក់ព័ន្ធបញ្ហាសហឧក្រិដ្ឋកម្មរួម និងធាតុផ្សំដែលស្ថិតនៅក្រៅយុត្តាធិការពេលវេលាដែលគ្របដណ្តប់លើបទចោទ។ អាស្រ័យហេតុនេះ សាលាឧទ្ធរណ៍បានវាយតម្លៃថា គេអាចទទួលយកធាតុផ្សំនៃភស្តុតាងពាក់ព័ន្ធនឹងអំឡុងពេលមុនអង្គហេតុ ដើម្បីបង្ហាញគោលបំណងរួមបន្តន្ទាប់នៅក្នុងអំឡុងពេលដែលគ្របដណ្តប់បទចោទ រួមទាំងតួនាទីរបស់ជនជាប់ចោទក្នុងរយៈពេលនោះ[49]។ ទោះបីជាជនជាប់ចោទមិនអាចត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ទាំងនៅក្រៅយុត្តាធិការពេលវេលារបស់តុលាការ ទាំងនៅក្រៅបទឧក្រិដ្ឋកម្មរងការចោទប្រកាន់ នៅក្នុងបទចោទមួយ យុត្តិសាស្ត្រនេះពិតជាមានភាពពាក់ព័ន្ធក្នុងករណីនេះ ជាងនៅក្នុងយុត្តិសាស្ត្រអង់គ្លេស ឬអាមេរិច ដែលអង្គជំនុំជម្រះតុលាការកំពូលបានសំអាងលើ ដើម្បីគាំទ្រវិនិច្ឆ័យកិច្ចរបស់ខ្លួន ដែលជាការឆ្លើយតបទៅនឹងសំណួរដែលគ្មានអ្នកចោទសួរ។

## ផ្នែកទី ៣. <u>សេចក្តីសន្និដ្ឋានលើសំណុំរឿង ០០២/០២</u>

៥៦. នៅក្នុងសំណុំរឿងបច្ចុប្បន្ន ដូចក្នុងសំណុំរឿង ០០២/០១ ដែរ ខៀវ សំផន មិនត្រូវបានចោទប្រកាន់តែពីបទប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរយៈសហឧក្រិដ្ឋកម្មរួមមួយមុខ នោះទេ។

---

[48] សាលដីកា ០០២/០១ កថាខណ្ឌ ២២០។

[49] សាលដីកា Đorđević (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៤ កថាខណ្ឌ ២៩៥។

៥៧. ដូច្នេះ អង្គជំនុំជម្រះត្រូវចងចាំថា ខ្លួនមិនអាចប្រកាសពិរុទ្ធភាពណាមួយ ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត ក្រៅពីសហឧក្រិដ្ឋរួម ដោយសំអាងលើអង្គហេតុ និងអត្តចរិតនៅក្រៅយុត្តាធិការពេលវេលារបស់ខ្លួន។

៥៨. ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះអាចពិចារណាលើធាតុផ្សំនៅមុនយុត្តាធិការពេលវេលារបស់ខ្លួន សម្រាប់តែបង្ហាញពីគោលបំណងរួមបន្តបន្ទាប់នៅក្នុងអំឡុងពេលគ្របដណ្តប់ដោយដីកាដំណោះស្រាយប៉ុណ្ណោះ (ដែលដូចគ្នានឹងយុត្តាធិការពេលវេលារបស់តុលាការ) និងតួនាទីរបស់ ខៀវ សំផន នៅក្នុងអំឡុងពេលនោះ។

## ជំពូកទី ២. យុត្តាធិការលើរឿងក្តី

៥៩. យុត្តាធិការរបស់អង្គជំនុំជម្រះ នៅក្នុងដីកាដំណោះស្រាយដែលបានក្លាយជាស្ថាពរ (វគ្គទី ១) កម្រិតត្រឹមតែអង្គហេតុមួយចំនួននៃដីកាដំណោះស្រាយ (វគ្គទី ២) ដែលអង្គហេតុទាំងនេះផ្ទាល់ត្រូវបានកំណត់ដោយដីកាបំបែកសំណុំរឿង (វគ្គទី ៣)។ ទោះជាមានការកំណត់បែបនេះក្តី ធាតុផ្សំជាច្រើនទៀតនៅមុនពេលធ្វើការចោទប្រកាន់ ត្រូវបានបង្ហាញក្នុងអំឡុងពេលសវនាការ និងនៅទីបញ្ចប់ ត្រូវតែដកចេញពីកិច្ចពិភាក្សា (វគ្គទី ៤)។

### ផ្នែកទី ១. បណ្តឹងមកកាន់អង្គជំនុំជម្រះ នៅក្នុងដីកាដំណោះស្រាយស្ថាពរ

### ១. នីតិវិធីនាំទៅរកដីកាដំណោះស្រាយ

៦០. នៅ អ.វ.ត.ក ការចោទប្រកាន់រឿងក្តីព្រហ្មទណ្ឌមួយ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ អាចធ្វើឡើងបានដោយសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ ទោះបីជាការសម្រេចចិត្តដោយឯកឯង ឬដោយផ្អែកតាមពាក្យបណ្តឹង (វិធាន ៤៩(១) នៃវិធានផ្ទៃក្នុង) ដែលសហព្រះរាជអាជ្ញាអាចបើកការស៊ើបសួរបឋម ដើម្បីកំណត់ពីអត្ថិភាពនៃតម្រុយឧក្រិដ្ឋកម្មនៅក្នុងដែនយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ និងដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យ និងសាក្សីសំខាន់ៗ (វិធាន ៥០(១) នៃវិធានផ្ទៃក្នុង)។

៦១. បើសហព្រះរាជអាជ្ញាមានហេតុផលជឿថា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក បានកើតមានពិត សហព្រះរាជអាជ្ញាត្រូវបើកការស៊ើបសួរ ដោយបញ្ជូនដីកាបញ្ជូនរឿងឱ្យស៊ើបសួរទៅស៊ើបសួរ ប្រឆាំងនឹងបុគ្គលមួយ ឬច្រើនរូប ឬប្រឆាំងនឹងអញ្ញាតជន (វិធាន ៥៣(១) នៃវិធានផ្ទៃក្នុង)។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវចាត់ទុកជាមោឃៈ (វិធាន ៥៣(៣) នៃវិធានផ្ទៃក្នុង) បើគ្មានព័ត៌មានដូចតទៅ៖ ក) សេចក្តីសង្ខេបអំពីអង្គហេតុ ខ) ប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់ គ) បទបញ្ញត្តិច្បាប់ដែលកំណត់ និងបង្ក្រាបបទឧក្រិដ្ឋនេះ ឃ) ឈ្មោះបុគ្គលដែលត្រូវធ្វើការស៊ើបអង្កេត ប្រសិនបើមាន ង) កាលបរិច្ឆេទ និងហត្ថលេខារបស់សហព្រះរាជអាជ្ញាទាំងពីរ (វិធាន ៥៣(១) នៃវិធានផ្ទៃក្នុង)[50]។

៦២. ការស៊ើបសួរត្រូវតែធ្វើដាច់ខាតចំពោះឧក្រិដ្ឋកម្ម[51] ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក (វិធាន ៥៥(១) នៃវិធានផ្ទៃក្នុង)[52]។ នៅក្នុងដំណាក់កាលនេះ សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការ

---

[50] បទបញ្ញត្តិនៃវិធានផ្ទៃក្នុងទាំងនេះយកតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលក្រមនេះក៏យកតាមលំនាំក្រមនីតិវិធីព្រហ្មទណ្ឌបារាំងដែរ។ សូមមើល ៖ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៤៤ (ការបើកការស៊ើបសួរ) ៖ « ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ។ ការស៊ើបសួរត្រូវ បានបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញត្រជន។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន ៖ - សេចក្តីសង្ខេបនៃអង្គហេតុ, - ការកំណត់ឈ្មោះបទល្មើស, -ការបង្ហាញអត្ថបទច្បាប់ដែលកំណត់និងបង្ក្រាបបទល្មើសនិងឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ»។

[51] សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១២៤ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) វាក្យខណ្ឌ ១ ៖ « ការស៊ើបសួរ ត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាដោយអនុលោមតាមមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនេះ »។

[52] សូមអានផងដែរ <u>ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា</u> មាត្រា ១២២ (ការបើកការស៊ើបសួរ) ៖ « ការស៊ើបសួរត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន។»។ <u>ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង</u> មាត្រា ៧៩ ៖ « ការស៊ើបសួរសម្រាប់ការរៀបចំត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន លើកលែងតែមានបទបញ្ញត្តិពិសេស។ ការស៊ើបសួរ ក៏អាចធ្វើបានចំពោះបទលហុ ប្រសិនបើរដ្ឋអាជ្ញានៃសាធារណរដ្ឋយល់ស្រប [...] »។

ស៊ើបសួរតែលើអង្គហេតុណា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម (វិធាន ៥៥(២) នៃវិធានផ្ទៃក្នុង)[53]។

៦៣. ក្នុងអំឡុងពេលស៊ើបសួរ ប្រសិនបើមានលេចចេញអង្គហេតុថ្មី សហចៅក្រមស៊ើបអង្កេតត្រូវជូនព័ត៌មានដល់សហព្រះរាជអាជ្ញា លើកលែងតែអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសនៃអង្គហេតុដែលមានកំណត់ក្នុងដីកាសន្និដ្ឋានដែលមានស្រាប់។ កាលណាអង្គហេតុថ្មីនេះ ត្រូវបានបញ្ជូនទៅឱ្យសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតគ្មានអំណាចធ្វើការស៊ើបសួរលើអង្គហេតុថ្មីនោះបានឡើយ លុះត្រាតែទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញា (វិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង)[54]។

៦៤. ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេតត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភ័ស្តុតាងដាក់បន្ទុក ឬភ័ស្តុតាងដោះបន្ទុកក៏ដោយ (វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង)[55]។

---

[53] សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១២៥ (វិសាលភាពនៃការប្តឹង) វាក្យខណ្ឌ ១ : « ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ »។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា 80 I. វាក្យខណ្ឌ ១ : « ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរតាមដីកាបញ្ជូនរឿងនៃរដ្ឋអាជ្ញានៃសាធារណរដ្ឋតែប៉ុណ្ណោះ »។

[54] សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១២៥ (វិសាលភាពនៃការប្តឹង) វាក្យខណ្ឌ ២ និង ៣ ៖ « ប្រសិនបើមានលេចអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។ ប៉ុន្តែ ចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង »។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា 80 I. វាក្យខណ្ឌ ៣ ៖ « នៅពេលដែលអង្គហេតុដែលមិនមានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានជូនដំណឹងទៅកាន់ចៅក្រមស៊ើបសួរចៅក្រមនេះត្រូវផ្ញើជាបន្ទាន់ នូវពាក្យប្តឹង ឬកំណត់ហេតុដែលបានកត់ត្រា ទៅរដ្ឋអាជ្ញានៃសាធារណរដ្ឋ។ រដ្ឋអាជ្ញានៃសាធារណរដ្ឋអាចស្នើសុំចៅក្រមស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមថានឹងធ្វើការស៊ើបសួរលើអង្គហេតុថ្មី ឬក៏អាចស្នើសុំបើកការស៊ើបសួរដាក់លាក់ណាមួយ [...] »។

[55] សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១២៧ (ការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុក) ៖ « ចៅក្រមស៊ើបសួរបំ

៦៥. សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ (វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង)[56]។

## ២. ដីកាដំណោះស្រាយ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ

៦៦. ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ ត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយមានកំហុសនីតិវិធី (វិធាន ៦៧(២) នៃវិធានផ្ទៃក្នុង)[57]។

៦៧. សហចៅក្រមស៊ើបអង្កេត ត្រូវចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចតទៅ៖ ក) អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ។ ខ) ជនប្រព្រឹត្តបទឧក្រិដ្ឋនោះមិនទាន់កំណត់អត្តសញ្ញាណនៅឡើយ ឬ គ) ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ (វិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង)[58]។

---

ពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថាមាន ប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់។ ចៅក្រមស៊ើបសួរមានករណីយកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក »។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ៨១ វាក្យខណ្ឌ ១ ៖ « ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថាមាន ប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់។ ចៅក្រមស៊ើបសួរមានករណីយកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក »។

[56] សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៧ (ដីកាដំណោះស្រាយ) វាក្យខណ្ឌ ១ ៖ « ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់ »។

[57] សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៧ (ដីកាដំណោះស្រាយ) វាក្យខណ្ឌ ២ ៖ « ប្រសិនបើយល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទ ទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវ រៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ »។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៨១ វាក្យខណ្ឌ ៣ ៖ « ដីកាដីកាដំណោះស្រាយដីកាត្រូវមានសេចក្តីសង្ខេបនៃអង្គហេតុ ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងការកំណត់ឈ្មោះបទល្មើស បើពុំដូច្នេះទេត្រូវទុកជាមោឃៈ»។

[58] សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៧ (ដីកាដំណោះស្រាយ) វាក្យខណ្ឌ ៣ ៖ « ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅ ៖ ១-អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។ ២-ជនដែល

៦៨. ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ។ ដីកានេះអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះចំពោះអំពើមួយចំនួន ឬ ប្រឆាំងនឹងបុគ្គលមួយចំនួន និងអាចជាដីកាលើកលែងចោទប្រកាន់ចំពោះករណីដទៃទៀត (វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង)[59]។

៦៩. សហព្រះរាជអាជ្ញា ជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានជូនដំណឹងជាបន្ទាន់អំពីការចេញដីកាដំណោះស្រាយនេះ[60] ហើយដីកាដំណោះស្រាយនេះបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងករណីមួយចំនួន (វិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង)។ នៅពេលមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត សំណុំរឿងត្រូវបញ្ជូនទៅអង្គបុរេជំនុំជម្រះ (វិធាន ៦៩(១) នៃវិធានផ្ទៃក្នុង)[61]។

៧០. បើសហព្រះរាជអាជ្ញាអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដោយគ្មានល័ក្ខខ័ណ្ឌ ជនត្រូវចោទគ្រាន់តែចង់បញ្ជាក់ប្រាប់អំពីបទបញ្ញត្តិនៃដីកាដំណោះស្រាយ ដែល “ទទួលស្គាល់

---

ប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់។ ៣-គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ »។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៧៧ វាក្យខណ្ឌ ១ ៖ « ប្រសិនចៅក្រមស៊ើបសួរយល់ឃើញថាអង្គហេតុមិនមែនជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ ឬប្រសិនបើជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ឬគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ប្រសិនចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់»។

[59] សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៧ (ដីកាដំណោះស្រាយ) វាក្យខណ្ឌ ៤ ៖ « ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ច គោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះ ចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត »។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៨៤ : « ដីកាដែលចេញដោយចៅក្រមស៊ើបសួរដោយអនុលោមតាមផ្នែកទី២នេះ ត្រូវមាននាម គោត្តនាម កាលបរិច្ឆេទ ទីកន្លែងកំណើត លំនៅដ្ឋាន មុខរបររបស់ជនត្រូវចោទ។ ដីកានេះត្រូវបង្ហាញពីអត្ថបទច្បាប់ដែលកំណត់ចំពោះជននោះ និងភស្តុតាងបញ្ជាក់ថាមានបន្ទុក ឬគ្មានបន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ »។

[60] សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៧ (ដីកាដំណោះស្រាយ) វាក្យខណ្ឌ ៥ ៖ « ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុត ដល់ព្រះរាជអាជ្ញា ជនត្រូវចោទនិង ដើមបណ្តឹងរដ្ឋប្បវេណី »។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៨៣ វាក្យខណ្ឌ ១ ៖ « ត្រូវជូនដំណឹងអំពីដីកាដំណោះស្រាយដល់ជនត្រូវចោទ និងសាក្សីតំណាងដោយមេធាវី ហើយត្រូវជូនដំណឹងអំពីដីកាបញ្ជូនរឿងទៅជម្រះ ឬដីកាដំណោះស្រាយដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ការជូនដំណឹងត្រូវធ្វើឡើងក្នុងថិរវេលាដ៏ឆាប់បំផុត »។

[61] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ២៧១ (សមត្ថកិច្ចរបស់សភាស៊ើបសួរ) ៖ « បណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍»។ មាត្រា ២៧៣ (ការបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរ)។

យុត្តាធិការរបស់ អ.វ.ត.ក” និង/ឬ ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្ដោះអាសន្ន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ (វិធាន ៧៤(១) និង ៧៤(៣) នៃវិធានផ្ទៃក្នុង)[62]។

៧១. លើកលែងតែជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ (វិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង)[63]។

៧២. អង្គជំនុំជម្រះសាលាដំបូងទទួលបណ្ដឹង តាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ (វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង)[64]។

---

[62] នៅក្នុងទីនេះ មានខ្លឹមសារខុសគ្នារវាងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និង ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ៖ សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៥៣ (ការប្ដឹងទៅសភាស៊ើបសួរ) វាក្យខណ្ឌ ៣ និង ៤ ៖ « ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា លិខិតណាមួយនៃនីតិវិធីមានមោឃភាព ព្រះរាជអាជ្ញាធ្វើពាក្យសុំដោយមានសំអាងហេតុ បញ្ជូនទៅសភាស៊ើបសួរ និងជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ »។ មាត្រា ២៥២ (មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ) ៖ « វិធាននិងទម្រង់ការដែលចែងដោយមាត្រាខាងក្រោម ស្ដីអំពីបទប្បញ្ញត្តិទូទៅនៃនីតិវិធីស៊ើបសួរ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នោះទេនាំឱ្យមានមោឃភាពនៃនីតិវិធី ៖ មាត្រា ១២២ (ការបើកការស៊ើបសួរ), មាត្រា ១២៣ (សមត្ថកិច្ចដែនដី), កថាខណ្ឌទី ៣ នៃមាត្រា ១២៤ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ), កថាខណ្ឌទី ១ និងទី ២ នៃមាត្រា ១២៥ (វិសាលភាពនៃការប្ដឹង) និងមាត្រា ១២៨ (ជំនួយរបស់ក្រឡាបញ្ជី) នៃក្រមនេះ។ នាំឱ្យមានមោឃភាពផងដែរ កាលណាការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនេះ ឬបទប្បញ្ញត្តិទាំងឡាយស្ដីពីនីតិវិធីព្រហ្មទណ្ឌ ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលទទួលរងការបំពាននេះ។ វិធាន និងទម្រង់ការដែលមានលក្ខណៈសំខាន់នោះមានជាអាទិ៍គឺ វិធាន ទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួន»។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៨៦ ៖ « ជនត្រូវចោទមានសិទ្ធិប្ដឹងសាទុក្ខប្រឆាំងដីកា និងសេចក្ដីសម្រេចដែលមានចែងនៅក្នុងមាត្រា [...] 181 » (ដីកាដំណោះស្រាយ), មាត្រា ២១១ ៖ « [សភាស៊ើបសួរ] ពិនិត្យមើលថាតើមានបន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទដែរឬទេ »។

[63] សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៥៦ (ការលុបលាងមោឃភាពដោយដីកាដំណោះស្រាយ) ៖ « ដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបលាងមោឃភាពនៃនីតិវិធីមុន ប្រសិនបើមាន។ គ្មានមោឃភាពណាមួយនៃនីតិវិធីមុនអាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ »។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៧៩ វាក្យខណ្ឌ ៦ ៖ « នៅពេលចូលជាស្ថាពរ ដីកាដែលបានកំណត់នៅក្នុងវាក្យខណ្ឌ១ [ដីកាបញ្ជូនរឿងទៅជម្រះចំពោះមុខសាលាមជ្ឈិម] ត្រូវលុបលាងវិការៈចំពោះការមិនគោរពនីតិវិធី ប្រសិនបើមាន », មាត្រា ១៨១ វាក្យខណ្ឌ ៤ ៖ « នៅពេលចូលជាស្ថាពរ ដីកាដំណោះស្រាយត្រូវលុបលាងបញ្ចូលវិការៈចំពោះការមិនគោរពនីតិវិធី ប្រសិនបើមាន »។

[64] សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៩១ (របៀបប្ដឹងទៅតុលាការ) ៖ « ក្នុងរឿងព្រហ្មទណ្ឌសាលាដំបូងត្រូវបានទទួលបណ្ដឹងដោយ ៖ ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ [...] »។

៧៣. សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ (វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង)[65]។

៧៤. អង្គជំនុំជម្រះអាចផ្លាស់ប្តូរបទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចដាក់បញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ (វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង)[66]។

៧៥. អង្គជំនុំជម្រះត្រូវពិនិត្យថា តើអំពើនោះជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងថា តើជនជាប់ចោទបានប្រព្រឹត្តអំពើនោះដែរឬទេ (វិធាន ៩៨(៣) នៃវិធានផ្ទៃក្នុង)។

៧៦. អាស្រ័យហេតុនេះ ដូចសហចៅក្រមស៊ើបអង្កេតដែលនៅចំពោះមុខខ្លួនដែរ អង្គជំនុំជម្រះត្រូវចាត់ការតែបណ្តឹងលើរឿងក្តី (*in rem*) តែប៉ុណ្ណោះ។ ពាក្យបណ្តឹងនេះកម្រិតមកត្រឹមអង្គហេតុមួយចំនួននៅក្នុងដីកាដំណោះស្រាយដែលបានក្លាយជាស្ថាពរ។

## ផ្នែកទី ២. ពាក្យបណ្តឹងកម្រិតមកត្រឹមអង្គហេតុមួយចំនួននៅក្នុងដីកាដំណោះស្រាយ

៧៧. យើងគួររំឭកថា ដីកាដំណោះស្រាយមានបុព្វហេតុផ្តល់ព័ត៌មានអំពីបទចោទផ្សេងៗ (១) ដើម្បីស្វែងយល់ឱ្យបានកាន់តែច្បាស់ថា ហេតុអ្វីបានជាពាក្យបណ្តឹងមកអង្គជំនុំជម្រះ កំណត់ត្រឹមតែអង្គ

[65] សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៤៨ (ដែនកំណត់នៃការប្តឹងទៅតុលាការចំពោះអង្គហេតុ) វាក្យខណ្ឌ ១ ៖ « តុលាការអាចសម្រេចសេចក្តីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន [ឬ] ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ »។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ២៣១ ៖ « សាលាឧក្រិដ្ឋមានដែនសមត្ថកិច្ចពេញលេញក្នុងការវិនិច្ឆ័យក្តី [...] ចំពោះជនដែលត្រូវបានបញ្ជូនទៅចំពោះមុខស្ថាប័ននេះ តាមរយៈសេចក្តីសម្រេចចោទប្រកាន់។ តុលាការកំពូលមិនអាចដឹងឮចំពោះការចោទប្រកាន់ផ្សេងទៀតឡើយ »។ មាត្រា ៣៨៨ ៖ « សាលាមជ្ឈិមទទួលបណ្តឹងពីបទល្មើសទៅតាមសមត្ថកិច្ចរបស់ខ្លួន [...] តាមរយៈដីកាបញ្ជូនរឿងទៅជម្រះដែលសម្រេចដោយសមត្ថកិច្ចផ្នែកស៊ើបសួរ »។

[66] 66 សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៥០ (ការប្រកាសពីពិរុទ្ធភាព) វាក្យខណ្ឌ ១ ៖ « តុលាការពិនិត្យមើលថា ៖ - តើអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុឬទេ, - តើជនជាប់ចោទបានប្រព្រឹត្តអំពើដែលចោទប្រកាន់លើខ្លួនឬទេ។

ហេតុដែលជនជាប់ចោទត្រូវបានបញ្ជូនមកជំនុំជម្រះ (២) និងហេតុអ្វីបានជាអង្គជំនុំជម្រះត្រូវបានហាមឃាត់មិនឱ្យពង្រីកពាក្យបណ្ដឹងនោះ (៣)។

## ១. បុព្វហេតុរបស់ដីកាដំណោះស្រាយ÷ ផ្ដល់ព័ត៌មានអំពីបទចោទនាំមុខ

៧៨. ថ្វីបើដីកាដំណោះស្រាយដែលបានក្លាយជាស្ថាពរ គឺជាមូលដ្ឋាននៃការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ដីកានេះ ក៏ដូចជាបទចោទនានាដែរ មានគោលបំណងចម្បងផ្ដល់ព័ត៌មានដល់ជនជាប់ចោទ ពីអង្គហេតុដែលចោទប្រកាន់ពួកគេ ដែលជាការគោរពដល់សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌។

៧៩. ជាក់ស្ដែង វិធាន ២១(១) នៃវិធានផ្ទៃក្នុង ចែងថា ជនសង្ស័យ ឬជនត្រូវចោទគ្រប់រូប "មានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន" ។

៨០. មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិស៊ីវិលនិងនយោបាយ ដែលយោងដោយមាត្រា ៣៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក បញ្ញត្តថា៖

> "ជនជាប់ចោទពីបទព្រហ្មទណ្ឌគ្រប់រូប មានសិទ្ធិ ដោយស្មើភាពគ្នា យ៉ាងហោចណាស់ [...] ទទួលបានការជូនដំណឹង នៅក្នុងរយៈពេលយ៉ាងឆាប់រហ័សបំផុត ជាភាសាដែលខ្លួនចេះ និងដោយលម្អិត អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងរូបខ្លួន"។

៨១. នៅក្នុងពាក្យពេជន៍ស្រដៀងគ្នានេះដែរ មាត្រា ៦(៣)(ក) នៃអនុសញ្ញាការពារសិទ្ធិមនុស្សអឺរ៉ុប (CESDH) ចែងថា៖

> "ជនជាប់ចោទគ្រប់រូប មានសិទ្ធិ ជាអាទិ៍ [...] ទទួលបានការជូនដំណឹង ក្នុងរយៈពេលយ៉ាងឆាប់បំផុត ជាភាសាដែលខ្លួនចេះ និងដោយលម្អិត អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងរូបខ្លួន"។

៨២. ដូច្នេះ ដូចការលើកឡើងនៅក្នុងអនុសញ្ញាការពារសិទ្ធិមនុស្សអឺរ៉ុបដែរ បទបញ្ញត្តិទាំងនេះ៖

"បង្ហាញពីភាពចាំបាច់ក្នុងការយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការជូនដំណឹងពី "បទចោទ" ដល់សាមីជន។ បទចោទដើរតួនាទីកំណត់ក្នុងការការចោទប្រកាន់ព្រហ្មទណ្ឌ៖ ដោយគិតចាប់ពីអត្ថន័យរបស់វា ជនត្រូវចោទត្រូវទទួលបានការជូនដំណឹងជាផ្លូវការ ពីមូលដ្ឋានច្បាប់ និងអង្គហេតុ នៃការចោទប្រកាន់ប្រឆាំងនឹងរូបគាត់។ មាត្រា ៦ កថាខណ្ឌ ៣ (ក) នៃអនុសញ្ញា ទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជូនដំណឹង មិនត្រឹមតែពីមូលហេតុនៃការចោទប្រកាន់ មានន័យថា អង្គហេតុជាក់ស្តែងដែលដាក់បន្ទុកលើខ្លួន និងជាមូលដ្ឋាននៃការចោទប្រកាន់ ប៉ុណ្ណោះទេ តែថែមទាំង ពីការបែងចែកប្រភេទអង្គហេតុតាមផ្លូវច្បាប់ និងស្របតាមអ្វីដែលគណៈកម្មាធិការបានលើកឡើងពិតប្រាកដ និងដោយលម្អិត។

[...] តុលាការយល់ឃើញថា នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ព័ត៌មានលម្អិតនិងពេញលេញអំពីការដាក់បន្ទុកលើរូបជនជាប់ចោទណាម្នាក់ រួមទាំងប្រភេទបទល្មើស និងយុត្តាធិការ ប្រឆាំងនឹងរូបគាត់ គឺជាល័ក្ខខ័ណ្ឌសំខាន់សម្រាប់សមធម៌នៃនីតិវិធី។

[...] សិទ្ធិទទួលបានការជូនដំណឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ត្រូវតែពិចារណាទុកជាមុនដោយគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការរៀបចំការពារខ្លួន"[67]។

៨៣. នៅចំពោះមុខខ្លួន គណៈកម្មាធិការសិទ្ធិមនុស្សអឺរ៉ុប បានបញ្ជាក់ថា ជនជាប់ចោទមានសិទ្ធិទទួលបានការជូនដំណឹង៖

"ពី**មូលហេតុ**នៃបទចោទ មានន័យថា អង្គហេតុជាក់ស្តែងដែលដាក់បន្ទុកលើខ្លួន និងជាដើមចមនៃពិរុទ្ធភាពរបស់ខ្លួន និងពី**ប្រភេទ**នៃបទចោទ មានន័យថា ប្រភេទបទល្មើសនៃអង្គហេតុជាក់ស្តែង។ ព័ត៌មានដែលចែងដោយមាត្រា ៦(៣)(ក) ត្រូវមានផ្ទុកធាតុផ្សំដែលអាចឱ្យជនជាប់ចោទរៀបចំការការពារខ្លួនបាន ដោយមិនចាំបាច់បញ្ជាក់ពីធាតុផ្សំនៃភ័ស្តុតាង ដែលរដ្ឋអាជ្ញាសំអាងលើ" (យើងជាអ្នកដាក់អក្សរពណ៌ខ្មៅ)[68]។

៨៤. ដូច្នេះ យុត្តិសាស្ត្រស្តីពីសិទ្ធិមនុស្សបង្ហាញឱ្យឃើញថា នៅក្នុងបទចោទមួយ ជនជាប់ចោទទទួលបានព័ត៌មានពីការដាក់បន្ទុកប្រឆាំងនឹងខ្លួន គឺតាមរយៈអង្គហេតុជាក់ស្តែង រួមជាមួយប្រភេទបទល្មើសនៃអង្គហេតុទាំងនេះ តែមិនមែនតាមរយៈធាតុផ្សំនៃភ័ស្តុតាងដែលគាំទ្រនោះទេ។ ព័ត៌មានសំ

---

[67] រឿងក្តី Pélissier និងSassi តទល់នឹង ប្រទេសបារាំង (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥១-៥៤ (គ្មានឯកសារយោង)។

[68] រឿងក្តី X. តទល់នឹង ប្រទេសបែលហ្ស៊ិក (គណៈកម្មការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) សេចក្តីសម្រេចលើការទទួលយកពាក្យបណ្តឹង (លេខ 7628/76) ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ១៩៧៧ កថាខណ្ឌ ១ (គ្មានឯកសារយោង)។ សូមមើលផងដែរ ៖ រឿងក្តី Colozza និង Rubinat តទល់នឹង ប្រទេសអ៊ីតាលី (គណៈកម្មការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) របាយការណ៍នៃគណៈកម្មការនេះ (ពាក្យបណ្តឹងលេខ 9024/80 និង9317/81) ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៨៣ កថាខណ្ឌ ១១៥។

ខាន់ៗទាំងនេះ ត្រូវតែមានភាពលម្អិត ជាក់លាក់ និងពេញលេញ ដើម្បីអាចឱ្យជនជាប់ចោទអាចរៀបចំការពារខ្លួនបាន។

៨៥. គោលការណ៍ជាសារវ័ន្តទាំងនេះ មានជាអាទិ៍នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលនៅទីនោះ ដោយអនុលោមតាមច្បាប់ជាធរមាន រដ្ឋអាជ្ញាតាក់តែងបទចោទមួយ *"ដែលបង្ហាញយ៉ាងលម្អិតពីអង្គហេតុ និងឧក្រិដ្ឋកម្មមួយ ឬច្រើន ដែលត្រូវចោទប្រកាន់"*[69]។ បទចោទត្រូវបង្ហាញ *"ទំនាក់ទំនងសង្ខេបមួយរវាងអង្គហេតុនៃសំណុំរឿង និងប្រភេទបទល្មើសនៃអង្គហេតុ"*[70]។ សាលាឧទ្ធរណ៍ (ដែលនៅចំពោះមុខតុលាការនេះ គេអាចអះអាងជាលើកទីមួយ ពីកំហុសនៃបទចោទ)[71] រំឭកថា រដ្ឋអាជ្ញាដាច់ខាតត្រូវតែ៖

> "បង្ហាញអង្គហេតុសំខាន់ៗដែលគាំទ្រការចោទប្រកាន់ផ្សេងៗនៅក្នុងបទចោទ តែមិនត្រូវបង្ហាញធាតុផ្សំភ័ស្តុតាង នៃអង្គហេតុទាំងនេះទេ។ អំណឺះតទៅ ដើម្បីអាចឱ្យបទចោទមួយមានភាពច្បាស់លាស់គ្រប់គ្រាន់ គេត្រូវបង្ហាញឱ្យបានលម្អិតគ្រប់គ្រាន់ ពីអង្គហេតុសំខាន់ៗដែលត្រូវចោទប្រកាន់ ដើម្បីផ្តល់ព័ត៌មានច្បាស់លាស់ដល់ជនជាប់ចោទពីបទចោទប្រឆាំងនឹងខ្លួន ដើម្បីអាចឱ្យគាត់អាចរៀបចំការពារខ្លួនបាន"[72]។

---

[69] មាត្រា ១៨-៤ នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, មាត្រា ១៧-៤ នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា, មាត្រា ១៦-៤ នៃលក្ខន្តិកៈនៃយន្តការដើម្បីតុលាការព្រហ្មទណ្ឌអន្តរជាតិ។

[70] មាត្រា ៤៧-គ នៃវិធាននីតិវិធីនិងភ័ស្តុតាងតុលាការនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ហើយនិងវិធាននីតិវិធីនិងភ័ស្តុតាងតុលាការនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា មាត្រា ៤៨-គ យន្តការដើម្បីតុលាការព្រហ្មទណ្ឌអន្តរជាតិ។ សូមមើលផងដែរ បទដ្ឋាន ៥២ នៃបទបញ្ជាផ្ទៃក្នុងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលឯកសារបានបង្ហាញបន្ទុកមាន ៖ « ខ) សេចក្តីសង្ខេបនៃអង្គហេតុ ដែលបញ្ជាក់ថាតើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តនៅពេលណា និងនៅកន្លែងណា ដែលផ្តល់មូលដ្ឋានគ្រប់គ្រាន់ផ្លូវច្បាប់ និង អង្គហេតុ ដើម្បីនាំជននោះ ឬជនទាំងនោះទៅកាត់ទោស ហើយមានអង្គហេតុពាក់ព័ន្ធ ស្របទៅតាមយុត្តាធិការរបស់តុលាការ, គ) ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ចំពោះអង្គហេតុដែលត្រូវស្របគ្នានឹងបទឧក្រិដ្ឋ [...] ហើយក៏ស្របជាមួយទម្រង់ច្បាស់លាស់នៃការចូលរួមប្រព្រឹត្តបទឧក្រិដ្ឋនោះ [...] »។

[71] ជាឧទាហរណ៍ សូមមើល សាលដីកា Nahimana (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៣២៧, សាលដីកា Ntagerura (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ៣១, សាលដីកា Kvočka (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ៣៥។

[72] សាលដីកា Kupreškić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០១ កថាខណ្ឌ ៨៨។

៨៦. គោលការណ៍ដូចគ្នានេះ ដែលបង្កប់នៅក្នុងវិធាន ៦៧(២) និង ៦៧(៤) នៃវិធានផ្ទៃក្នុង ដូចបានរំឭកពីខាងលើ (វគ្គទី ១ និង ២) ចែងថា៖

> "- ដីកាដំណោះស្រាយត្រូវបញ្ជាក់អំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បើពុំនោះសោត ដីកានេះត្រូវចាត់ទុកជាមោឃៈដោយមានកំហុសនីតិវិធី។
>
> - ដីកាដំណោះស្រាយត្រូវមានសំអាងហេតុ"។

## ២. ការកំណត់យកតែអង្គហេតុដែលជនជាប់ចោទត្រូវបានបញ្ជូនទៅជំនុំជម្រះ

៨៧. យោងតាមការលើកឡើងពីខាងលើ វាច្បាស់ណាស់ថា វិសាលភាពនៃការចោទប្រកាន់លាតសន្ធឹងដល់អង្គហេតុជាក់ស្តែង ដែលទទួលបានការកំណត់ប្រភេទបទល្មើស ដើម្បីអាចទម្លាក់ការទទួលខុសត្រូវលើជនជាប់ចោទ។

៨៨. គឺអង្គហេតុទាំងនេះហើយ (ជាអង្គហេតុសម្រាប់ជំនុំជំម្រះជនជាប់ចោទ និងសម្រាប់សម្រេចសេចក្តី) ដែលកំណត់ដែនបណ្តឹងមកកាន់អង្គជំនុំជម្រះ។

៨៩. អាស្រ័យហេតុនេះ បើអង្គជំនុំជម្រះត្រូវចាត់ការតែពីអង្គហេតុលើរឿងក្តី អង្គជំនុំជម្រះមិនត្រូវចាត់ការលើអង្គហេតុទាំងអស់នៅក្នុងដីកាដំណោះស្រាយនោះទេ តែត្រូវចាត់ការតែលើអង្គហេតុជាក់ស្តែង ដែលទទួលបានការកំណត់ប្រភេទបទល្មើសដាក់បន្ទុកលើជនជាប់ចោទ។

៩០. ដូច្នេះ ដើម្បីកំណត់វិសាលភាពពិតប្រាកដនៃការចោទប្រកាន់ និងពាក្យបណ្តឹងមកកាន់អង្គជំនុំជម្រះ គេត្រូវពិនិត្យផ្នែកស្តីពីការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ (ផ្នែកទី ៣) នៅក្នុងដីកាដំណោះស្រាយ និងលើកឡើងពីអង្គហេតុដែលត្រូវបានកំណត់យកដោយសហចៅក្រមស៊ើបអង្កេត ដែលអាចដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌលើជនជាប់ចោទ។

៩១. អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនត្រូវបានប្តឹង៖

- ទាំងពីអង្គហេតុផ្សេងទៀតនៅក្នុងដីកាដំណោះស្រាយ
- ទាំងពីការកំណត់ប្រភេទបទល្មើសដែលគ្មានចំណងទាក់ទងជាមួយអង្គហេតុនៃបទល្មើស។

៩២. អាចនិយាយម៉្យាងទៀតថា ការគ្មានចំណងទាក់ទងរវាងអង្គហេតុ និងការកំណត់ប្រភេទបទល្មើសនៃអង្គហេតុដាក់បន្ទុកលើជនជាប់ចោទ នាំឱ្យគ្មានបណ្ដឹង។

៩៣. អង្គជំនុំជម្រះបានពិចារណាពីបញ្ហានេះរួចមកហើយ។ ទោះបីជាដីកាដំណោះស្រាយត្រូវតែកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ អង្គជំនុំជម្រះបានប្រកាសថា ខ្លួនមិនទទួលបានបណ្ដឹងត្រឹមត្រូវតាមនីតិវិធី ពីការចោទប្រកាន់ចំពោះការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ទេ[73]។ អង្គជំនុំជម្រះបានលើកឡើងថា ដោយគ្មានការយោងទៅអង្គហេតុសំខាន់ៗសម្រាប់គាំទ្រដល់ការចោទប្រកាន់ គ្រប់ផ្នែកទាំងអស់នៃដីកាដំណោះស្រាយនេះ មិនបានបំពេញល័ក្ខខ័ណ្ឌសុពលភាពដែលចែងដោយវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង និងប៉ះពាល់ដល់សិទ្ធិជនជាប់ចោទក្នុងការរៀបចំការពារខ្លួនប្រកបដោយប្រសិទ្ធភាព[74]។

៩៤. នៅក្នុងករណីផ្ទុយពីនេះ ជាក់ស្ដែង ពាក់ព័ន្ធនឹងអង្គហេតុដែលកំណត់នៅក្នុងដីកាដំណោះស្រាយ តែមិនបានកំណត់ប្រភេទបទល្មើសដាក់បន្ទុកលើជនជាប់ចោទ អង្គជំនុំជម្រះបានសង្កេតឃើញជាថ្មីទៀត ថាគ្មានបណ្ដឹងទេ (អង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ - សូមមើលវគ្គទី ៤ ខាងលើ)[75]។ ជាក់ស្ដែង ស្របតាមវិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយ សម្រាប់អង្គហេតុខ្លះ និងដីកាលើកលែងការចោទប្រកាន់សម្រាប់អង្គហេតុផ្សេងទៀត។

៩៥. គេគួរទទួលស្គាល់ថា វាពិតជាងាយស្រួលណាស់ក្នុងការវង្វេងនៅក្នុងរបត់ក្រវិចក្រវៀននៃដីកាដំណោះស្រាយ ដែលមានកម្រាស់ ៧៩០ ទំព័រ (៣៣៩ ទំព័រ និយាយពីអង្គហេតុ និង ៣៣៥ ទំព័រ

---

[73] សេចក្ដីសម្រេច ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ **ឯកសារ E122**។

[74] សេចក្ដីសម្រេច ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E122 កថាខណ្ឌ ១៦, ២១-២២។

[75] អនុស្សរណៈ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ E306 កថាខណ្ឌ ៣៖ សេចក្ដីសម្រេច ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ E348/4 កថាខណ្ឌ ១៥ ; សេចក្ដីសម្រេច ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E306/7/3**។

ពាក់ព័ន្ធនឹងកំណត់នៅខាងចុងដីកា ដែលមានយោងធាតុផ្សំនៃភ័ស្តុតាងជាច្រើនក្រាស់ក្រែល )។ ដូច ការលើកឡើងរបស់សហចៅក្រមស៊ើបអង្កេតមួយរូបដែលទទួលបន្ទុកតាក់តែងដីកា ដីកាដំណោះស្រាយគ្របដណ្តប់ដទៅដោយការអត្ថាធិប្បាយដែល៖

> "មិនចាំបាច់ទាល់តែសោះ ក៏ប៉ុន្តែ ទំនងជាសំខាន់សម្រាប់ [ពួកគេ] ក្នុងករណីដែល [ដីកាដំណោះស្រាយ] ស្ថិតនៅជាស្នាមដានតែមួយគត់ដែលបន្សល់ទុកដោយតុលាការនេះ ពាក់ព័ន្ធនឹងអ្វីៗដែលបានកើតឡើងនៅប្រទេសកម្ពុជា នៅរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩" [76]។

៩៦. ក៏ប៉ុន្តែ អង្គហេតុដែលត្រូវពិចារណានៅក្នុងដីកាដំណោះស្រាយ ដែលបង្កើតការជំនុំជម្រះក្តីព្រហ្មទណ្ឌ (តែមិនមែនជាការជំនុំជម្រះក្តីប្រវត្តិសាស្ត្រ) សុទ្ធសឹងជាអង្គហេតុជាក់ស្តែងដែលកំណត់យកនៅក្នុងការកំណត់ប្រភេទបទល្មើស ដែលអាចដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌលើជនជាប់ចោទ។ ដោយសារផ្នែកស្តីពីការកំណត់ប្រភេទបទល្មើសនៃដីកាដំណោះស្រាយ ដែលជួនកាល មានសភាពសង្ខេបជ្រុល និងឃ្លាតចាកឆ្ងាយពីផ្នែកអង្គហេតុនៃដីកា ករណីនេះតម្រូវឱ្យធ្វើការពិនិត្យបទបញ្ញត្តិច្បាប់ពាក់ព័ន្ធ នៃផ្នែកអង្គហេតុនៃដីកាដំណោះស្រាយ។ ជួនកាល យើងចាំបាច់ត្រូវយោងផងដែរលើដីកាបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញា។ ជាក់ស្តែង នៅក្នុងនីតិវិធីច្បាប់ និងប្រវត្តិសាស្ត្ររបស់ខ្លួន សហចៅក្រមស៊ើបអង្កេតបានបើកការស៊ើបសួរលើអង្គហេតុ ដែលមិនបានប្តឹងមកខ្លួន និងផ្អែកលើអង្គហេតុនោះ អង្គជំនុំជម្រះដែលមិនទទួលបានបណ្តឹងត្រឹមត្រូវតាមនីតិវិធីដែរនោះ មិនអាចចេញសេចក្តីសម្រេចបាន។

៩៧. ទោះជាយ៉ាងណាក្តី យោងតាមយុត្តិសាស្ត្រដ៏ចំណាស់របស់បារាំង អង្គជំនុំជម្រះ *"អាចសម្រេចតែលើអង្គហេតុដែលត្រូវបញ្ជូនទៅជំនុំជម្រះ និងលើជនត្រូវចោទដែលមានសិទ្ធិពិតប្រាកដក្នុងការជំនុំជម្រះក្តីតែលើអង្គហេតុទាំងនោះតែប៉ុណ្ណោះ"* [77]។

## ៣. <u>បណ្តឹងដែលមិនអាចពង្រីកបាន</u>

---

[76] សម្រង់អត្ថបទពីក្នុងសៀវភៅរបស់លោក Marcel LEMONDE *ចៅក្រមមួយរូបតទល់នឹងខ្មែរក្រហម* ខែមករា ឆ្នាំ២០១៣ ទំព័រ ២០២ **ឯកសារ E280.12**។

[77] សាលាឧទ្ធរណ៍នៃទីក្រុង Nîmes ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៦២, JCP 1963. II. 13069។

៩៨. ច្បាប់ common law ក៏ដូចជាច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហាមឃាត់ដាច់ខាតតុលាការជំនុំជម្រះពង្រីកការចោទប្រកាន់ឱ្យទៅហួសពីអង្គហេតុដែលមិនបានប្ដឹងមកខ្លួនត្រឹមត្រូវតាមនីតិវិធី។

**ក. ច្បាប់ common law**

៩៩. ស្របតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ក្នុងករណីដែលអង្គជំនុំជម្រះអាចធ្វើការផ្លាស់ប្ដូរការកំណត់បទចោទ ដែលបានអនុម័តរួចមកហើយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គជំនុំជម្រះអាចសម្រេចបានតែលើអង្គហេតុដែលត្រូវបានបញ្ជាក់នៅក្នុងដីកានោះ។ ក្នុងសំណុំរឿង **ឌុច** អង្គជំនុំជម្រះបានទទួលស្គាល់៖

> "ការកំណត់អំណាចក្នុងការកែប្រែបទចោទ ដែលបានចែងច្បាស់លាស់នៅក្នុងច្បាប់ មិនចង់ឱ្យមានការផ្លាស់ប្ដូរ ឬបន្ថែមអង្គហេតុ ដែលបានកំណត់យកនៅក្នុងបណ្ដឹងនោះទេ"[78]។

១០០. អង្គជំនុំជម្រះបានប្រកាសទៀតថា វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង បង្ហាញថា៖

> "អង្គជំនុំជម្រះសាលាដំបូងអាចកែប្រែបទចោទ សម្រាប់តែតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ។ វិធាននេះតម្រូវឱ្យអនុវត្តផងដែរចំពោះអង្គជំនុំជម្រះសាលាដំបូងទាំងឡាយ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ក៏ដូចជាក្នុងប្រព័ន្ធច្បាប់បារាំង ដែលច្បាប់កម្ពុជាបានចម្លងតាមតាំងពីដំបូងមក" [79]។

១០១. ជាក់ស្ដែង ច្បាប់បារាំងបានកំណត់តាំងពីយូរលង់មកហើយថា គ្មានយុត្តាធិការណាមួយ (សភាស៊ើបសួរ សាលាដំបូង សាលាឧទ្ធរណ៍) អាចសម្រេចលើអង្គហេតុ ដែលខ្លួនមិនទទួលបានបណ្ដឹងត្រឹមត្រូវតាមនីតិវិធីនោះទេ បើទោះជាមានការកែប្រែការកំណត់បទចោទ ឬគ្មានក៏ដោយ។

[78] សាលក្រម ឌុច ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៩៤។

[79] សាលក្រម ឌុច ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៩៤។

1. **ការស៊ើបសួរ**

១០២. សភាព្រហ្មទណ្ឌនៃតុលាការកំពូល រំឭកថា តាំពីច្រើនឆ្នាំមកហើយ បណ្ដឹងមកកាន់ចៅក្រមស៊ើបអង្កេត ត្រូវបានកំណត់ត្រឹមតែអង្គហេតុ ដែលបានប្ដឹងមកចៅក្រមនោះជាទៀងទាត់ប៉ុណ្ណោះ៖

> “អំណាចផ្ដល់ឱ្យចៅក្រមស៊ើបអង្កេត ដោយមាត្រា ៨១ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែលអនុញ្ញាតឱ្យចៅក្រមស៊ើបអង្កេតបើករាល់កិច្ចស៊ើបសួរតាមផ្លូវច្បាប់ ដែលខ្លួនយល់ថាមានសារៈសំខាន់ដល់ការស្វែងរកការពិត ត្រូវកំណត់ត្រឹមតែអង្គហេតុដែលបានប្ដឹងមកខ្លួនត្រឹមត្រូវតាមនីតិវិធី ស្របតាមមាត្រា ៨០ និង ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ” [80]។

១០៣. ស្ថាប័នស៊ើបសួរ ដែលទទួលបណ្ដឹងពីអង្គហេតុ តែមិនមែនពីការចោទប្រកាន់ មិនជាប់ទាក់ទងនឹងការកំណត់បទចោទដែលបានកំណត់យកនៅក្នុងបទចោទនោះទេ៖

> “ចៅក្រមស៊ើបអង្កេតទទួលបានបណ្ដឹងអំពីអង្គហេតុ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយមិនជាប់ទាក់ទងនឹងការកំណត់បទចោទបណ្ដោះអាសន្ននៃអង្គហេតុទាំងនេះដោយស្ថាប័នអយ្យការទេ”[81]។

> “ចៅក្រមស៊ើបអង្កេត និងសភាចោទប្រកាន់ផ្ទាល់តែម្ដង ទទួលបណ្ដឹងអំពីអង្គហេតុដែលចែងនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដោយមិនជាប់ទាក់ទងនឹងការកំណត់បទចោទបណ្ដោះអាសន្ននៃអង្គហេតុទាំងនេះដោយស្ថាប័នអយ្យការទេ” [82]។

១០៤. ទោះជាយ៉ាងនេះក្ដី បើទោះបីជាចៅក្រម “មិនជាប់ទាក់ទងនឹងការកំណត់បទចោទបណ្ដោះអាសន្នចំពោះអង្គហេតុដែលធ្វើឡើងដោយរដ្ឋអាជ្ញា[83] សេរីភាពនៃការកែប្រែបទចោទ ដែលចៅក្រមមានលែងមានភាពស្របច្បាប់ទៀតហើយ ខណៈដែលសេរីភាពនោះប៉ះពាល់ជាក់ស្ដែងដល់បណ្ដឹងមក

---

[80] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ លេខ 95-84041។

[81] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧២ លេខ 71-93622។

[82] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៨៥ លេខ 84-95197។

[83] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩២ លេខ 91-86066។

កាន់ខ្លួន"។ អ្វីៗប្រព្រឹត្តទៅតាមរបៀបនេះ នៅពេលដែលចៅក្រមត្រូវបានប្តឹងពីអង្គហេតុដែលមិនបានចែងនៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរ ក្រោមរូបភាពនៃការកែប្រែការកំណត់បទចោទ[84]។

១០៥. ទោះជាយ៉ាងណាក្តី ចៅក្រមស៊ើបអង្កេតត្រូវបានហាមពង្រីកការស៊ើបសួរ ដោយចិត្តឯង រហូតដល់អង្គហេតុនៅក្រៅដែនបណ្តឹង[85]។ ទន្ទឹមនឹងនេះដែរ ស្ថាប័នស៊ើបសួរ ថ្នាក់ទីពីរ មិនសម្រេចលើអង្គហេតុដែលស្ថិតនៅក្រៅដែនបណ្តឹងរបស់ចៅក្រមស៊ើបអង្កេតបានឡើយ[86]។

## 2. <u>សាលក្រម</u>

[84] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៣ លេខ 73-90372 ៖ « ដោយហេតុថាតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចៅក្រមស៊ើបសួរទទួលបានពាក្យបណ្តឹងប្រឆាំងនឹងឈ្មោះ X... និងភរិយារបស់គាត់ មិនមែនពីបទមនុស្សឃាតដោយចេតនាទៅលើបុគ្គលដែលមានឈ្មោះ Béatrice X ឡើយ... ប៉ុន្តែពីបទខកខានមិនបានជួយមនុស្សកំពុងមានគ្រោះថ្នាក់។ [...] គឺចាប់ពីពេលនោះ ទើបសាលាឧទ្ធរណ៍ដែលទទួលបន្ទុកបើកការចោទប្រកាន់បានប្រកាសយ៉ាងយុត្តិធម៌ថាគ្មានសមត្ថកិច្ចទទួលស្គាល់អង្គហេតុរងការចោទប្រកាន់ពីម្ចាស់បណ្តឹងនៅក្នុងសារណារបស់ខ្លួន។ គឺជាអង្គហេតុដែលសមត្ថកិច្ចផ្នែកស៊ើបសួរមិនបានទទួលបណ្តឹងពីអយ្យការ »។

[85] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៤ លេខ 83-94199 ៖ « មាត្រា ៨០ ក្រមនីតិវិធីព្រហ្មទណ្ឌហាមប្រាមដល់ចៅក្រមស៊ើបសួរមិនឱ្យបើកការស៊ើបសួរលើអង្គហេតុណាដែលចៅក្រមមិនទាន់ទទួលបានពាក្យបណ្តឹងស្របតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់រដ្ឋអាជ្ញានៃសាធារណរដ្ឋបារាំង"។ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៨ លេខ 97-84372 ៖ « អំណាចដែលប្រគល់ជូនចៅក្រមស៊ើបសួរ នៅក្នុងមាត្រា ៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្រិតត្រឹមអង្គហេតុណាដែលបានទទួលពាក្យបណ្តឹងទៀងទាត់ ដោយអនុលោមតាមមាត្រា ៨០ និង ៨៦ នៃក្រមនេះ » (បណ្តឹងសាទុក្ខសុំបដិសេធសាលដីកានៃក្រុមដើមចោទដែលបានប្រកាសថាមានសម្អាងហេតុដោយដីកាចាត់ឱ្យស៊ើបសួរដេញដោលនិងតាមរយៈការឃាត់ខ្លួននគរបាលយុត្តិធម៌ នៅក្នុងពេលសង្កេតអង្គហេតុថ្មីៗដែលមិនមានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ)។

[86] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៦៩ លេខ 67-93533 (បណ្តឹងសាទុក្ខសុំបដិសេធសាលដីកានៃក្រុមដើមចោទ ចំពោះអង្គហេតុណាដែលកើតឡើងក្រោយកាលបរិច្ឆេទនៃបណ្តឹងអាជ្ញាដែលត្រូវបានចាត់ការ ដោយមិនមែនជាកម្មវត្ថុនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយគេចផុតពីបណ្តឹង ទោះបីវាជាបទល្មើសបន្តក៏ដោយ)។ ក្នុងន័យដូចគ្នានេះ សូមមើល ៖ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧០ លេខ 68-93382។ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៧៩ លេខ 78-92189។

១០៦. នៅពេលដែលចៅក្រមស៊ើបអង្កេតវាយតម្លៃថាមានបន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ហើយអង្គហេតុបង្កជាបទល្មើសមជ្ឈិម ចៅក្រមចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅចំពោះមុខសាលាមជ្ឈិម[87]។ នៅពេលដែលចៅក្រមស៊ើបអង្កេតវាយតម្លៃថាមានការដាក់បន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ហើយអង្គហេតុបង្កជាបទឧក្រិដ្ឋ ចៅក្រមចេញដីកាចោទប្រកាន់នៅចំពោះមុខសាលាឧក្រិដ្ឋ (មាន ឬ គ្មាន ក្រុមប្រឹក្សាតុលាការ អាស្រ័យទៅតាមបទឧក្រិដ្ឋនោះ)[88]។

១០៧. ផ្ទុយពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកាចោទប្រកាន់បើកផ្លូវប្តឹងឧទ្ធរណ៍ដល់ជនត្រូវចោទ[89] ចំណែកឯរដ្ឋអាជ្ញាមានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់ចៅក្រមស៊ើបអង្កេត[90]។

១០៨. នៅពេលដែលដីកាចោទប្រកាន់ក្លាយជាស្ថាពរ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយ ដូចដីកាចោទប្រកាន់ដែរ កែប្រែកំហុសនីតិវិធីលើកមុន ក្នុងករណីដែលមាន[91]។

---

[87] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៧៧ វាក្យខណ្ឌ ១ និង ១៧៩ វាក្យខណ្ឌ ១។

[88] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៧៧ វាក្យខណ្ឌ ១ និង ១៨១ វាក្យខណ្ឌ ១។ សាលាឧក្រិដ្ឋពិសេស ដែលមានសមាសភាពតែចៅក្រមមានវិជ្ជាជីវៈប៉ុណ្ណោះ មានសមត្ថកិច្ចសម្រាប់បទឧក្រិដ្ឋខ្លះក្នុងវិស័យយោធា (មាត្រា ៦៩៧ និង ៦៩៨-៦) ក្នុងផ្នែកភេរវកម្ម (មាត្រា ៧០៦-២៥) ឬការជួញដូរគ្រឿងញៀន (មាត្រា ៧០៦-២៧)។

[89] តាមមាត្រា ១៨៦ វាក្យខណ្ឌ ១ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង សិទ្ធិប្តឹងសាទុក្ខសម្រាប់ជនត្រូវចោទ តទល់នឹងដីកា និងសេចក្តីសម្រេចដែលមានចែងនៅក្នុងមាត្រា ៨០-១-១ (សេចក្តីសម្រេចពាក់ព័ន្ធនឹងការប្តូរពីស្ថានភាពជាជនត្រូវចោទ មកជាសាក្សីដែលមានជំនួយពីមេធាវី) មាត្រា ៨៧ (ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី) មាត្រា ១៣៩ និង ១៤០ (សេចក្តីសម្រេចពាក់ព័ន្ធនឹងការត្រួតពិនិត្យតុលាការ) មាត្រា ១៤២-៦ និង ១៤២-៧ (សេចក្តីសម្រេចពាក់ព័ន្ធនឹងការបង្ខាំងក្នុងលំនៅដ្ឋានដោយមានការត្រួតពិនិត្យតាមប្រព័ន្ធអេឡិកត្រូនិក) មាត្រា ១៣៧-៣, ១៤៥-១ និង មាត្រា ១៤៥-២, ១៤៨ (សេចក្តីសម្រេចរបស់ចៅក្រមក្នុងការដោះលែង និងឃុំខ្លួន ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន និងសេចក្តីស្នើសុំដោះលែងឲ្យនៅក្រៅឃុំ), មាត្រា ១៦៧, វាក្យខណ្ឌ ៤ (សេចក្តីសម្រេចដែលបដិសេធប្រតិកោសលវិច័យ ឬបដិសេធកោសលវិច័យបន្ថែម) មាត្រា ១៧៩, វាក្យខណ្ឌ ៣ (ដីការបស់ចៅក្រមស៊ើបសួរដែលបង្គាប់ឲ្យដាក់ឃុំបណ្តោះអាសន្ននៅក្នុងពេលដំណោះស្រាយក្នុងការស៊ើបសួរ) និងមាត្រា ១៨១ (ដីកាដំណោះស្រាយ)។ ម៉្យាងវិញទៀត តាមមាត្រា ១៨៦-៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វាក្យខណ្ឌ ១ ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិប្តឹងសាទុក្ខប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជម្រះចំពោះមុខសាលាមជ្ឈិម (ចែងក្នុងមាត្រា ១៧៩ វាក្យខណ្ឌ ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) "ក្នុងករណីដែលសេចក្តីសម្រេចយល់ថាអង្គហេតុដែលបញ្ជូនទៅសាលាមជ្ឈិមជាបទឧក្រិដ្ឋដែលគួរតែជាកម្មវត្ថុនៃដីកាដំណោះស្រាយចំពោះមុខសាលាឧក្រិដ្ឋ"។

[90] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៨៥។

[91] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៧៩ វាក្យខណ្ឌ ៦ (ដីកាបញ្ជូនរឿងទៅជម្រះ) និង មាត្រា ១៨១ វាក្យខណ្ឌ ៤ (ដីកាដំណោះស្រាយ)។

១០៩. ក្នុងបទល្មើសមជ្ឈិម ក៏ដូចជាបទល្មើសព្រហ្មទណ្ឌដែរ តុលាការជំនុំជម្រះដែលត្រូវបានប្ដឹងដោយដីកាស្ពានព មិនអាចសម្រេចលើអង្គហេតុដែលមិនបានប្ដឹងត្រឹមត្រូវតាមនីតិវិធីមកខ្លួននោះទេ ទោះបីជាអង្គហេតុនៅក្រៅដែនបណ្ដឹងរបស់ចៅក្រមស៊ើបអង្កេត ឬ ជាអង្គហេតុនៅក្រៅដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាចោទប្រកាន់ក៏ដោយ។

## 2.ក.អង្គហេតុនៅក្រៅបណ្ដឹងមកចៅក្រមស៊ើបអង្កេត

១១០. វាពិតជាសមហេតុផលខ្លាំងណាស់ដែលថា បណ្ដឹងមកកាន់ស្ថាប័នស៊ើបអង្កេត មិនអាចពន្លាតរហូតដល់អង្គហេតុដែលស្ថាប័ននេះមិនបានប្ដឹងមកតាំងតែពីដំបូង។

១១១. ហានិភ័យនៃការពន្លាតដែនបណ្ដឹងរបស់សាលាឧក្រិដ្ឋ រហូតដល់អង្គហេតុដែលចៅក្រមស៊ើបអង្កេតចាត់ការខុសច្បាប់ដោយចិត្តឯង ត្រូវបានកំណត់ដោយសិទ្ធិប្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាចោទប្រកាន់។

១១២. ដោយសារផ្លូវឧបាស្រ័យនេះមិនត្រូវបានអនុញ្ញាតឱ្យជនត្រូវចោទ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅចំពោះមុខសាលាមជ្ឈិម សភាព្រហ្មទណ្ឌនៃតុលាការកំពូល បានសម្រេច និងធ្វើមោឃភាពសាលដីការបស់សាលាឧទ្ធរណ៍មួយ តាំងតែពីឆ្នាំ ១៩៦៧ ដោយប្រកាសថា៖

> "ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនបានប្ដឹងចៅក្រមសាលាមជ្ឈិម ពីអង្គហេតុកើតមុនបណ្ដឹងមកកាន់ចៅក្រមស៊ើបអង្កេតនោះទេ ហើយចៅក្រមទៀតសោត ដោយគ្មានដីកាបញ្ជូនរឿងថ្មីរបស់អង្គអយ្យការ នឹងមិនអាចទទួលបណ្ដឹងឡើយ" [92]។

១១៣. កាលពីឆ្នាំ ២០១២ កន្លងទៅថ្មីៗនេះ សាលាដំបូងបានធ្វើការពន្យល់ជាលក្ខណៈទូទៅជាង និងច្បាស់ៗ ថា៖

---

[92] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៦៧ លេខ 66-93733។

> "ម្យ៉ាង បើផ្អែកលើមាត្រា ១៧៩ វាក្យខណ្ឌ ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដីកាបញ្ជូនរឿងទៅស៊ើបសួរ នាំទៅរកការកែប្រែកំហុសនីតិវិធី តែដីកានេះនឹងមិនអាចកម្ចាត់កំហុសផ្ទាល់ខ្លួន ឬអសុក្រឹតភាពបានឡើយ។ [...] ម្យ៉ាងវិញទៀត ចៅក្រមស៊ើបអង្កេតអាចសម្រេចបញ្ជូនជនត្រូវចោទណាម្នាក់ ដោយផ្អែកតែលើអង្គហេតុដែលបានប្ដឹងមកខ្លួនប៉ុណ្ណោះ ហើយ [...] ជាលទ្ធផល ជនត្រូវចោទនោះ ដែលត្រូវបានបញ្ជូនមកចំពោះមុខសាលាមជ្ឈិម ជាមួយអង្គហេតុនៅក្រៅដែនបណ្ដឹងមកចៅក្រម អាចអាចទទួលការជំនុំជម្រះពីតុលាការបាន បើសិនជាការចោទប្រកាន់មានសំអាងហេតុត្រឹមត្រូវ ទោះជាត្រូវប្រកាសមោឃភាពដីកាជូនដំណឹងក៏ដោយ ពោលគឺធ្វើយ៉ាងណាដើម្បីធានាសិទ្ធិជនជាប់ចោទក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ដោយប្រសិទ្ធភាព (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[93]។

### 2.ខ. អង្គហេតុមិននៅក្នុងពាក្យបណ្ដឹង

១១៤. តុលាការជំនុំជម្រះមិនអាចទទួលបណ្ដឹងពីអង្គហេតុដែលមិនបានដាក់បញ្ចូលនៅក្នុងបណ្ដឹងមកកាន់ខ្លួនកាលពីដំបូងនោះទេ រួមទាំងការកែប្រែការកំណត់បទល្មើសផង។ គោលការណ៍នេះទទួលរងផលប៉ះពាល់ពីអាញ្ញត្តិកម្មតែមួយគត់ នៅក្នុងផ្នែកបទល្មើសមជ្ឈិម តែមិននៅក្នុងផ្នែកបទល្មើសព្រហ្មទណ្ឌទេ។

### i. បម្រាមពន្លាតដែនបណ្ដឹងដោយឯកឯង

១១៥. បម្រាមពន្លាតដែនបណ្ដឹងដោយឯកឯងរហូតដល់អង្គហេតុនៅក្រៅបទចោទ ឬ ការចោទប្រកាន់ត្រូវបានរំឭកជាប្រចាំដោយសភាព្រហ្មទណ្ឌនៃតុលាការកំពូល។

១១៦. ក្នុងបទល្មើសមជ្ឈិម តុលាការកំពូលរំឭកថា៖

> "សាលាមជ្ឈិមអាចសម្រេចដោយស្របច្បាប់តែលើអង្គហេតុដែលលើកឡើងនៅក្នុងដីកា ឬសម្រង់ ដែលបានប្ដឹងមកប៉ុណ្ណោះ" [94]។

---

[93] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ លេខ 12-86306។

[94] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៧៨ លេខ 77-92490។ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៨០ លេខ 79-92527។ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៨៦ លេខ

១១៧. ជាឧទាហរណ៍ តុលាការកំពូលបានបន្ទោសសាលដីការបស់សាលាឧទ្ធរណ៍មួយ ដែលបានប្រកាសពិរុទ្ធភាពរបស់ជនត្រូវចោទម្នាក់ ពីបទល្មើសមជ្ឈិមមួយចំនួន រួមទាំងពីបទចូលរួមជាមួយជនល្មើស *"ដែលមិនបានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"* ដោយជនត្រូវចោទទទួលបានការលើកលែងការចោទប្រកាន់ពីបទចូលរួមនេះ[95]។

១១៨. នៅក្នុងរឿងក្តីមួយផ្សេងទៀត តុលាការកំពូលមិនបានបន្ទោសសាលដីការបស់សាលាឧទ្ធរណ៍ ដែលបានទទួលយកអង្គហេតុដែលមិនចែងនៅក្នុងបទចោទ តែក្នុងឋានៈជា "ធាតុផ្សំនៃសីលធម៌"[96] តែប៉ុណ្ណោះ។

១១៩. ក្នុងវិស័យឧក្រិដ្ឋកម្ម តុលាការកំពូលរំឭកថា៖

> "សាលាឧក្រិដ្ឋមិនអាចស្គាល់បទចោទណាមួយផ្សេងទៀតក្រៅពីបទចោទដែលចេញមកពីដីកាចោទប្រកាន់ ដែលដីកានេះ ក្រោយពីក្លាយជាស្ថាពរ កំណត់យុត្តាធិការរបស់តុលាការ" [97]។

១២០. តុលាការកំពូលបានបន្ទោសសាលដីកាមួយ ដែលនៅក្នុងដីកានេះ ជនជាប់ចោទត្រូវបានប្រកាសថាមានពិរុទ្ធចំពោះអង្គហេតុ ដែលបានប្រពឹត្តនៅថ្ងៃខុសគ្នាពីថ្ងៃដែលកំណត់ដោយសាលដីកាចោទប្រកាន់[98]។ ករណីដូចគ្នានេះដែរ កើតមាននៅក្នុងរឿងក្តីមួយផ្សេងទៀត ដែលជនជាប់ចោទត្រូវបានប្រកាសថាមានពិរុទ្ធ ដោយសារបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈជាច្រើន ខណៈដែលដីកា

---

95-83265។

[95] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ លេខ 14-85307។

[96] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៧៩ លេខ 79-90931 ៖ « នៅក្នុងស្ថានភាពនេះ ក្រៅពីសម្អាងហេតុខុសឆ្គង សាលាឧទ្ធរណ៍ដែលខកខានមិនបានទទួលពាក្យបណ្តឹងដោយបានយោងទៅអង្គហេតុដែលមិនមានក្នុងការបង្គារទុកមុន តែត្រូវបានដកស្រង់ដោយសារតែមានធាតុផ្សំខាងសីលធម៌ បង្ហាញនូវធាតុផ្សំនៃបទល្មើសឆបោក »។

[97] តុលាការកំពូល-អង្គជំនុំជម្រះសាលាឧក្រិដ្ឋ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ លេខ 95-82085។ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ លេខ 99-82597។

[98] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ លេខ 95-82085។

ចោទប្រកាន់ កំណត់យកឧក្រិដ្ឋកម្មតែមួយគត់ក្នុងចំណោមឧក្រិដ្ឋកម្មទាំងនេះ ដោយតុលាការបាន *"កែតម្រូវខ្លឹមសារនៃបទចោទ"*[99]។

**ii. រួមទាំងករណីនៃការកែប្រែបទចោទ**

១២១. បម្រាមពន្លាតដែនបណ្ដឹងដោយតុលាការជំនុំជម្រះ នៅតែមានសុពលភាព រួមទាំងក្នុងករណីនៃការកែប្រែការកំណត់បទចោទនៃអង្គហេតុ។ ជាក់ស្ដែង សេរីភាពនៃការកែប្រែបទចោទ ដែលតុលាការជំនុំជម្រះមានពេញលេញ ត្រូវកំណត់ដោយល័ក្ខខ័ណ្ឌទ្វេ។

១២២. ទីមួយ ក្នុងករណីដែលតុលាការព្រហ្មទណ្ឌមានសិទ្ធិកែប្រែបទចោទនៃអង្គហេតុ៖

> "គឺក្នុងល័ក្ខខ័ណ្ឌដែលមិនត្រូវផ្លាស់ប្ដូរ និងបន្ថែមអ្វីទាំងអស់ទៅលើអង្គហេតុនៃបទល្មើស ហើយអង្គហេតុទាំងនេះ ស្ថិតនៅដដែលដូចបានកំណត់យកនៅក្នុងបណ្ដឹង" [100]។

១២៣. នៅក្នុងវិស័យព្រហ្មទណ្ឌ គេអាចនិយាយម៉្យាងទៀតថា៖

> "ដោយមិនរំលោភអំណាច តុលាការ និងក្រុមប្រឹក្សាជំនុំជម្រះ មិនអាចត្រូវបានចោទសួរ ដោយសំណួរជំនួស ឬបន្ថែមអង្គហេតុសំខាន់ថ្មីមួយទៅក្នុងអង្គហេតុដែលបានណត់យករួចហើយ ដោយដីកាចោទប្រកាន់" [101]។

១២៤. ដូច្នេះ តុលាការកំពូលបានបន្ទោសសាលដីការបស់តុលាការជាន់ទាប ដែលបានបន្ថែមបទចោទថ្មីទៅក្នុងបទចោទដែលបានប្ដឹងមកតុលាការជាន់ទាប ដោយថ្កោលទោសចំពោះការចាប់ខ្លួនតាម

---

[99] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ លេខ 99-82597។

[100] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៨៦ លេខ 84-95759 (មានសម្រង់នៅក្នុងសាលក្រម ឌុច ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៩៤ កំណត់សម្គាល់ជើងទំព័រ ៨៦៩)។ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ លេខ 77-91635 ៖ « លុះត្រាតែក្រុមប្រឹក្សាជំនុំជម្រះមិនជំនួសអង្គហេតុថ្មីដោយអង្គហេតុក្នុងបណ្ដឹងដែលខ្លួនទទួលបាន »។

[101] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៣ លេខ 83-91982។

ទំនើងចិត្ត និងការឃុំខ្លួនជនជាប់ចោទដែលបានបញ្ជូនខ្លួនដោយសារតែបទចោទតែមួយគត់ពាក់ព័ន្ធនឹងការឃុំខ្លួន[102]។

១២៥. ទីពីរ ការកែប្រែបទចោទថែមទាំងត្រូវស្របទៅនឹងការគោរពសិទ្ធិជាសារវ័ន្តរបស់ជនត្រូវចោទ។ ក្នុងការអនុវត្ត ការកែប្រែបទចោទត្រូវតែអនុលោមតាមសិទ្ធិរបស់ជនត្រូវចោទ ឬជនជាប់ចោទ ក្នុងការទទួលបានការជូនដំណឹងពីការដាក់បន្ទុកប្រឆាំងនឹងខ្លួន សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ និងសម្ភារៈចាំបាច់សម្រាប់រៀបចំការពារខ្លួន ដូចដែលតុលាការសិទ្ធិមនុស្សអឺរ៉ុប បានលើកឡើងនៅក្នុងរឿងក្ដីជាច្រើនប្រឆាំនឹងប្រទេសបារាំង៖

> "នៅពេលដែលច្បាប់បែបនេះត្រូវបានទទួលស្គាល់ដោយសាលាវិនិច្ឆ័យនៅក្នុងច្បាប់ជាតិ ក្នុងករណីដែលតុលាការនេះមានលទ្ធភាពកែប្រែបទចោទនៃអង្គហេតុដែលបានប្ដឹងមកខ្លួនត្រឹមត្រូវតាមនីតិវិធី តុលាការនេះត្រូវតែធានាថា ជនជាប់ចោទមានឱកាសអនុវត្តសិទ្ធិការពារខ្លួនលើចំណុចនេះ ដោយជាក់ស្ដែង និងមានប្រសិទ្ធភាព ដោយទទួលព័ត៌មានពីមូលហេតុនៃការចោទប្រកាន់ ក្នុងពេលវេលាសមស្រប មានន័យថា ភ័ស្តុតាងដែលយកមកដាក់បន្ទុកលើជនជាប់ចោទ និងជាសំអាងហេតុនៃការចោទប្រកាន់ ព្រមទាំងព័ត៌មានពីការកំណត់បទចោទចំពោះអង្គហេតុ ឱ្យបានលម្អិត" [103]។

១២៦. នៅក្នុងរឿងក្ដីមួយ ដែលសាលាឧក្រិដ្ឋបានផ្ដន្ទាទោសជនជាប់ចោទពីបទរំលោភសេពសន្ថវៈ ខណៈដែលជននោះត្រូវបានបញ្ជូនខ្លួនមកនជំនុំជម្រះនៅចំពោះមុខតុលាការនេះ ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ និងការរំលោភផ្លូវភេទ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានកត់សម្គាល់ពីការរំលោភសិទ្ធិរបស់ជនជាប់ចោទ ព្រោះថាបញ្ហាការកែប្រែបទចោទ ត្រូវបានលើកឡើងតែនៅក្រោយពេលការពិភាក្សាតែប៉ុណ្ណោះ។ តុលាការសិទ្ធិមនុស្សបានប្រកាសជាអាទិ៍ថា៖

---

[102] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៣ លេខ 83-91982 : « ថាក្នុងរឿងក្ដីនេះ សាលដីកាបញ្ជូនរឿងទៅជម្រះសំដៅតែទៅលើការដែលបានបង្ខាំងអ្នកស្រី Y… , ថា បែបនោះ តាមរយៈការរំលោភអំណាច និងរំលោភលើដែនកំណត់នៃបណ្ដឹងដែលអង្គជំនុំជម្រះបានប្រកាសទៅលើអង្គហេតុច្បាស់លាស់នៃការចាប់ចងមិនស្របច្បាប់ ដែលមិនមានចែងក្នុងបទចោទប្រកាន់ »។ សូមមើលផងដែរ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៦៦ លេខ 95-81210។

[103] រឿងក្ដី Mattei តទល់នឹង ប្រទេសបារាំង (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ ៣៦។ សូមមើលផងដែរ រឿងក្ដី Pélisser និង Sassi តទល់នឹង ប្រទេសបារាំង (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប តុលាការជាន់ខ្ពស់) ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥១-៥៤, ៦២-៦៣។ រឿងក្ដី Miraux តទល់នឹង ប្រទេសបារាំង (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៣១-៣២, ៣៤, ៣៧។

"ដោយប្រើសិទ្ធិមិនអាចដំទាស់បានរបស់ខ្លួនក្នុងការកែប្រែបទចោទ តុលាការជាតិមានកាតព្វកិច្ចផ្តល់លទ្ធភាពដល់អ្នកស្នើសុំសិទ្ធិការពារខ្លួន ដោយជាក់ស្តែង និងមានប្រសិទ្ធិភាព ជាអាទិ៍ ក្នុងពេលវេលាសមស្រប ដោយធ្វើការបញ្ជូនសំណុំរឿងដើម្បីបើកការពិភាក្សា ឬដោយស្នើសុំសេចក្តីសង្កេតរបស់អ្នកស្នើសុំ"[104]។

### iii. គ្រប់បទចោទទាំងអស់ ត្រូវតែលើកឡើងតែពីបទចោទ

១២៧. នៅក្នុងបទល្មើសមជ្ឈិម តុលាការវិនិច្ឆ័យអាចស្ថិតក្នុងស្ថានភាពពិសេសមួយ ក្នុងការទទួលដោយត្រឹមត្រូវ នូវបណ្តឹងពីអង្គហេតុ ដែលមិនបានចែងនៅក្នុងបទចោទ។ ក៏ប៉ុន្តែ ករណីនេះមិនអាចទៅរួចឡើយ នៅក្នុងបទល្មើសព្រហ្មទណ្ឌ។

១២៨. ជនចាប់ចោទអាចត្រូវបានជំនុំជម្រះលើបទចោទណាមួយ ដែលមិនបានប្តឹងមកសាលាមជ្ឈិម បើជនជាប់ចោទយល់ព្រម "ដោយច្បាស់លាស់" ទទួលយកការជំនុំជម្រះ លើអង្គហេតុទាំងនេះ។ ក្នុងករណីផ្ទុយពីនេះ សភាព្រហ្មទណ្ឌនៃតុលាការកំពូលសន្និដ្ឋានថា តុលាការទៅហួសដែននៃបណ្តឹងមកកាន់ខ្លួន[105] រួមទាំងនៅក្រោមរូបភាពនៃការកែប្រែបទចោទ[106]។

១២៩. ផ្ទុយទៅវិញ នៅគ្រប់ករណីទាំងអស់ សាលាឧក្រិដ្ឋមិនអាចកែប្រែបទចោទ ទោះជាមានការព្រមព្រៀងពីជនជាប់ចោទក៏ដោយ[107]។

---

[104] រឿងក្តី Miraux តទល់នឹង ប្រទេសបារាំង (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៣៤។

[105] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៥ លេខ 04-83879។

[106] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ លេខ 94-80387 ៖ « ចៅក្រមមានភារកិច្ចកំណត់ឈ្មោះបទល្មើសឱ្យបានត្រឹមត្រូវតាមច្បាប់ ចំពោះអង្គហេតុដែលរងពាក្យបណ្តឹង តែត្រូវគោរពតាមលក្ខខណ្ឌ គឺលុះត្រាតែមិនមានបន្ថែមបន្ថយ លើកលែងតែជនជាប់ចោទព្រមព្រៀងឱ្យមានការកាត់សេចក្តីទៅលើអង្គហេតុ ឬលើស្ថានទម្ងន់ទោសដែលមិនមាននៅក្នុងការចោទប្រកាន់ »។ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០១ លេខ 00-80600។

[107] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ លេខ 95-82085 ៖ « សាលាឧក្រិដ្ឋមិនអាចដឹងបទចោទណាមួយផ្សេងទៀត ក្រៅពីបទចោទប្រកាន់ដែលចេញពីសាលដីកាចោទប្រកាន់ ដែលនៅពេលណាស្ថាពរហើយកំណត់នូវយុត្តាធិការរបស់ខ្លួន។ [...] ប៉ុន្តែដោយហេតុថាពុំមានសេចក្តីចែងណាមួយពីសាលដីកានៃអយ្យការដែលថា លោក Benjamin X... បានប្រព្រឹត្តអំពើដែលជាធាតុផ្សំបទល្មើសសេពសន្ថវៈ មុនថ្ងៃទី១ ខែមករា ឆ្នាំ ១៩៩២ ហើយទោះបីជាជនជាប់ចោទព្រមធ្វើការ

3. **បណ្ដឹងឧទ្ធរណ៍**

១៣០. ដូចសភាស៊ើបសួរ និងសាលាវិនិច្ឆ័យដែរ សាលាឧទ្ធរណ៍មិនអាចពន្លាតដែនបណ្ដឹងដោយឯកឯងបានទេ។

១៣១. សភាព្រហ្មទណ្ឌនៃតុលាការកំពូល ធ្លាប់បានរំឭករួចមកហើយថា *"សាលាឧទ្ធរណ៍គ្មានសមត្ថកិច្ចសម្រេចលើអង្គហេតុនៅក្រៅបទចោទដែលបានដាក់ជូនចៅក្រមសាលាដំបូង"*។ ក្នុងករណីនេះ សាលាវិនិច្ឆ័យបានសន្និដ្ឋានថា សាលាឧទ្ធរណ៍មួយ៖

> "មិនស្គាល់វិធានស្ដីពីសមត្ថកិច្ចរបស់ខ្លួន នៅក្នុងវិស័យសណ្ដាប់ធ្នាប់សាធារណៈ ក្នុងករណីដែលសាលាឧទ្ធរណ៍មិនអាចសម្រេចបាន និងជំនួសចៅក្រមសាលាដំបូង ខណៈដែលចៅក្រមសាលាដំបូងមិនទទួលបានបណ្ដឹងត្រឹមត្រូវតាមនីតិវិធីនោះ" [108]។

១៣២. សាលាឧទ្ធរណ៍អាចកែប្រែអង្គហេតុបាន តែជានិច្ចជាកាល នៅក្នុងករណី *"មិនជំនួសអង្គហេតុថ្មីមួយដោយអង្គហេតុដែលបានប្ដឹងមកខ្លួន"*[109]។

១៣៣. ម្យ៉ាងវិញទៀត គឺនៅក្នុងតែករណីដែលដើមបណ្ដឹងឧទ្ធរណ៍ *"ត្រូវបានដាក់ទៅក្នុងស្ថានភាពមួយដែលអាចធ្វើការការពារខ្លួនបាន ពាក់ព័ន្ធនឹងការកំណត់បទចោទថ្មីតាមការគ្រោងទុក"*[110]។ ដោយ

---

កែតម្រូវ ដូចមានក្នុងកំណត់ហេតុពិភាក្សាដេញដោលបង្ហាញយ៉ាងណាក្ដី។ ដូច្នេះ បណ្ដឹងសាទុក្ខត្រូវរងការស៊ុំបដិសេធជាថ្មីម្ដងទៀត។ »។

[108] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២១ ខែមីនា ១៩៧៩ លេខ 78-92998។

[109] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ លេខ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨។

[110] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០១ លេខ 00-85066 (បណ្ដឹងបដិសេធ ដោយមូលហេតុថា « ចៅក្រមលំដាប់ទី២ បានវាយតម្លៃអង្គហេតុឡើងវិញដោយខ្លួនឯង [...] ដោយពុំបានអញ្ជើញជនជាប់ចោទឱ្យផ្ដល់សេចក្ដីពន្យល់លើការកែប្រែនោះឡើយ »)។ ដូចគ្នាដែរ ៖ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៤ លេខ 03-84388។ សូមមើលផងដែរ ៖ តុលាការកំពូល-សភាព្រហ្មទណ្ឌ ថ្ងៃទី១៧ ខែ តុលា ២០០១ លេខ 01-81988 (បណ្ដឹងបដិសេធ ដោយមូលហេតុថា ពុំមាន « ការកត់សម្គាល់ណាមួយនៃការបដិសេធសាលដីកាដែលគេតវ៉ា ហើយក៏ពុំមានវត្តតាងនៃកិច្ចដំណើរ

ឡែក តុលាការសិទ្ធិមនុស្សអឺរ៉ុបបានកត់សម្គាល់ថា លក្ខខណ្ឌនេះមិនត្រូវបានគោរពដោយសាលាឧទ្ធរណ៍បារាំងនោះទេ៖

> "ដោយប្រើប្រាស់សិទ្ធិមិនអាចជំទាស់បានរបស់ខ្លួនក្នុងការកែប្រែអង្គហេតុដែលបានប្ដឹងមកខ្លួនត្រឹមត្រូវតាមនីតិវិធី សាលាឧទ្ធរណ៍ត្រូវផ្តល់ឱកាសដល់អ្នកស្នើសុំអនុវត្តសិទ្ធិការពារខ្លួនលើចំណុចនេះ ដោយពិតប្រាកដ និងមានប្រសិទ្ធភាព ជាពិសេស ជាមួយពេលវេលាសមស្រប"[111]។

## ខ. ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

១៣៤. ថ្វីបើនីតិវិធីមានភាពខុសគ្នានៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ តែគោលការណ៍ស្ថិតនៅដដែល៖ គឺរដ្ឋអាជ្ញាជាអ្នកផ្តើមកំណត់វិសាលភាពនៃបទចោទ និងខណៈដែលរដ្ឋអាជ្ញាបានប្តឹងត្រឹមត្រូវតាមនីតិវិធីពីបទចោទនោះ សាលាវិនិច្ឆ័យមិនអាចពង្រីកវិសាលភាពនៃបទចោទដោយឯកឯងបានទេ។ ករណីនេះកើតមាន ជាអាទិ៍ នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការចំពោះកិច្ច។

### 1. តុលាការព្រហ្មទណ្ឌអន្តរជាតិ

១៣៥. នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ បើរដ្ឋអាជ្ញាវាយតម្លៃថាមានមូលដ្ឋានសមស្របសម្រាប់បើកកិច្ចស៊ើបសួរមួយ រដ្ឋអាជ្ញាដាក់សំណើសុំការអនុញ្ញាតិមួយទៅកាន់អង្គបុរេជំនុំជម្រះ ដោយមានបញ្ចូលឯកសារយោងពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត យោងតាមការសន្និដ្ឋានរបស់រដ្ឋអាជ្ញា ព្រមទាំងការបង្ហាញអង្គហេតុ ដែលរដ្ឋអាជ្ញាអះអាងថា មានមូលដ្ឋានសមស្របដែលអាចនាំទៅរកការសន្និដ្ឋានថា ឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តមែន[112]។

---

ការនីតិវិធី ដែលថាលោក Hakim X អាចការពារខ្លួនចំពោះការកំណត់បទចោទថ្មីនេះឡើយ ខណៈដែលធាតុផ្សំភស្តុតាងនៃបទល្មើសទទួលផលចោរកម្ម ដែលខុសពីភស្តុតាងសមគំនិតលួច មានមាននៅក្នុងបទចោទប្រកាន់ »)។

[111] រឿងក្តី Pélisser និង Sassi តទល់នឹង ប្រទេសបារាំង (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប តុលាការជាន់ខ្ពស់) ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៦២-៦៣។ សូមមើលផងដែរ រឿងក្តី Mattei តទល់នឹង ប្រទេសបារាំង (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ ៣៩, ៤១, ៤៣។

[112] មាត្រា ១៥-៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម និង បទដ្ឋាន ៤៩ វិធានផ្ទៃក្នុងរបស់តុលាការ។

១៣៦. ក្រោយពេលចាប់ផ្តើមបើកកិច្ចស៊ើបសួរ និងមុនពេលជំនុំជម្រះ អង្គបុរេជំនុំជម្រះបើកសវនាការមួយ ដើម្បីបញ្ជាក់ពីការដាក់បន្ទុក ដែលរដ្ឋអាជ្ញាចង់យកមកសំអាង សម្រាប់ស្នើសុំបញ្ជូនទៅជំនុំជម្រះ។ នៅមុនពេលសវនាការ រដ្ឋអាជ្ញាបង្ហាញដល់អង្គបុរេជំនុំជម្រះ និងដល់បុគ្គលពាក់ព័ន្ធ នូវ "ស្ថានភាពលម្អិតនៃការដាក់បន្ទុក" និង បញ្ជីភ័ស្តុតាង ដែលខ្លួនចង់បង្ហាញនៅសវនាការ។ ក្នុងអំឡុងពេលនៃសវនាការ រដ្ឋអាជ្ញាបង្ហាញលម្អិតនូវការដាក់បន្ទុកនីមួយៗ ជាមួយធាតុផ្សំនៃភ័ស្តុតាងចាំបាច់សម្រាប់បង្ហាញថា មានមូលហេតុសំខាន់ៗ ដែលនាំឱ្យគេជឿថា ជនជាប់ចោទបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលចោទប្រកាន់។ ដោយឡែក ជនជាប់ចោទអាចជំទាស់នឹងការដាក់បន្ទុក និងធាតុផ្សំនៃភ័ស្តុតាងដែលបង្ហាញដោយរដ្ឋអាជ្ញា ព្រមទាំងអាចបង្ហាញធាតុផ្សំនៃភ័ស្តុតាង។ នៅក្រោយសវនាការ អង្គបុរេជំនុំជម្រះបញ្ជាក់ពីការដាក់បន្ទុក ទាំងស្រុង ឬដោយផ្នែក បន្ទាប់ពីបានសន្និដ្ឋានថាមានភ័ស្តុតាងគ្រប់គ្រាន់ និងបញ្ជូនខ្លួនជនជាប់ចោទទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង *"ដើម្បីជំនុំជម្រះ ដោយសំអាងលើមូលដ្ឋាននៃការដាក់បន្ទុកដែលបានបញ្ជាក់រួចហើយ"*។ ក្រោយពីបានបញ្ជាក់ពីការដាក់បន្ទុក និងមុនពេលការចាប់ផ្តើមសវនាការ រដ្ឋអាជ្ញាអាចកែប្រែការដាក់បន្ទុកដោយមានការអនុញ្ញាត្តិពីអង្គបុរេ និងបន្ទាប់ពីបានជូនដំណឹងរួចហើយដល់ជនជាប់ចោទពីការដាក់បន្ទុក។ បើរដ្ឋអាជ្ញាមានបំណងដាក់បញ្ចូលការដាក់បន្ទុកបន្ថែម ឬជំនួសការដាក់បន្ទុកមានស្រាប់ដោយការដាក់បន្ទុកកាន់តែធ្ងន់ សវនាការថ្មីមួយត្រូវតែរៀបចំឡើង នៅចំពោះមុខអង្គបុរេ ដើម្បីបញ្ជាក់ពីការដាក់បន្ទុកថ្មីៗ[113]។

១៣៧. ក្រោយពីបានទទួលបណ្តឹង និងនៅក្រោយពេលសវនាការ អង្គបុរេផ្តល់សំអាងហេតុលើការសម្រេចរបស់ខ្លួន ដោយផ្អែកលើការវាតយតម្លៃលើភ័ស្តុតាង និងផ្អែកលើដំណើរការនីតិវិធីទាំងមូល។ លើសពីនេះទៀត៖

> "សេចក្តីសម្រេចរបស់អង្គបុរេមិនអាចទៅហួសពីអង្គហេតុ និងកាលៈទេសៈ ដែលបានពិពណ៌នានៅក្នុងការដាក់បន្ទុក និងការកែប្រែការដាក់បន្ទុកទាំងនោះឡើយ"[114]។

---

[113] មាត្រា ៦១ នៃលក្ខន្តិកៈទីក្រុងរ៉ូម បទដ្ឋាន ៥២-៥៣ នៃវិធានផ្ទៃក្នុងនៃតុលាការ និង វិធាន ១២១ ដល់ ១៣០ នៃ វិធាននីតិវិធី និងភ័ស្តុតាងតុលាការនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។

[114] មាត្រា ៧៤-២ នៃលក្ខន្តិកៈទីក្រុងរ៉ូម។

១៣៨. នៅពេលណាមួយនៃសវនាការ បើអង្គបុរេយល់ឃើញថា ការកំណត់បទចោទនៃអង្គហេតុ អាចកែប្រែបាន អង្គបុរេជូនដំណឹងដល់អ្នកចូលរួមក្នុងដំណើរការនីតិវិធី អំពីលទ្ធភាពនៃការកែប្រែនេះ ព្រមទាំផ្តល់ឱកាសធ្វើសេចក្តីសង្កេតដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដល់អ្នកចូលរួមទាំងអស់។ អង្គបុរេអាចព្យួរការពិភាក្សា ដើម្បីធានាថា អ្នកចូលរួមទាំងអស់មានពេលវេលា និងសម្ភារៈចាំបាច់ សម្រាប់ត្រៀមការពារខ្លួន ប្រកបដោយប្រសិទ្ធភាព។ នៅក្នុងសាលក្រមរបស់ខ្លួន អង្គបុរេអាចកែប្រែបទចោទនៃអង្គហេតុ៖

> "ដោយមិនទៅហួសក្របខណ្ឌនៃអង្គហេតុ និងកាលៈទេសៈ ដែលបានពិពណ៌នានៅក្នុងការដាក់បន្ទុក និងនៅក្នុងការកែប្រែទាំងអស់ដែលបានដាក់បញ្ចូលរួច" [115]។

១៣៩. ជនដែលត្រូវបានប្រកាសថាមានពិរុទ្ធ អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រម ដោយមូលហេតុកំហុសនីតិវិធី កំហុសអង្គហេតុ កំហុសអង្គច្បាប់ និង/ឬ ដោយមូលហេតុផ្សេងទៀតដែលប៉ះពាល់ដល់សមធម៌ ឬប្រក្រតីភាពនៃដំណើរការនីតិវិធី ឬសាលក្រម[116]។ សាលាឧទ្ធរណ៍ ដែលមានអំណាចទាំងអស់ដែលអង្គបុរេមាន និងធ្វើការសម្រេចលើនីតិវិធី សាលក្រម ឬការផ្តន្ទាទោស *"ដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍"*[117]។

## 2. <u>តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី</u>

១៤០. នៅក្នុងតុលាការចំពោះកិច្ច រដ្ឋអាជ្ញាទទួលបន្ទុកលើកិច្ចស៊ើបសួរនៃសំណុំរឿង និងអនុវត្តការចោទប្រកាន់[118]។ ដោយផ្អែកលើការសន្មត បើរដ្ឋអាជ្ញាសម្រេចថាអាចចោទប្រកាន់បាន រដ្ឋអាជ្ញាកសាង

---

[115] បទដ្ឋាន ៥៥ នៃ វិធានផ្ទៃក្នុង នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។

[116] មាត្រា ៨១-១-ខ នៃលក្ខន្តិកៈទីក្រុងរ៉ូម។

[117] មាត្រា ៨៣-១ និង ៨៣-២ នៃលក្ខន្តិកៈក្រុងរ៉ូម៕

[118] មាត្រា ១៦-១ នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មាត្រា ១៥-១ នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា មាត្រា ១៤-១ នៃលក្ខន្តិកៈនៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

បទចោទ ដោយបង្ហាញយ៉ាងសង្ខេបពីអង្គហេតុ និងឧក្រិដ្ឋកម្មមួយ ឬច្រើន ដែលបានចោទប្រកាន់ និងដែលបានបញ្ជូនទៅកាន់ចៅក្រមនៃអង្គបុរេ[119]។

១៤១. ចៅក្រមទទួលបន្ទុកពិនិត្យ អាចស្នើសុំទៅរដ្ឋអាជ្ញាឱ្យបង្ហាញធាតុផ្សំបន្ថែម បញ្ជាក់ ឬបដិសេធរាល់បទចោទ ឬពន្យារពេលពិនិត្យ ដើម្បីឱ្យរដ្ឋអាជ្ញាអាចធ្វើការកែប្រែបទចោទ[120]។

១៤២. ដោយមិនចាំមានការអនុញ្ញាត្តិជាមុន រដ្ឋអាជ្ញាអាចកែប្រែបទចោទ គ្រប់ពេលវេលា នៅមុនពេលការយល់ព្រមលើការកែប្រែនោះ។ ក្រោយមកទៀត និងរហូតដល់ពេលដែលជនជាប់ចោទចូលមកបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង រដ្ឋអាជ្ញាអាចធ្វើបែបនេះបានដរាបណាមានការអនុញ្ញាត្តិពីចៅក្រម ដែលបានយល់ព្រមរួចហើយ។ នៅពេលចូលមកបង្ហាញខ្លួនជាលើកដំបូង ឬនៅពេលបន្ទាប់មកទៀត បទចោទអាចកែប្រែបាន ទាល់តែមានការអនុញ្ញាត្តិពីអង្គជំនុំជម្រះសាលាដំបូង ដែលបានសម្រេចដោយការពិភាក្សាតទល់គ្នា[121]។

១៤៣. ក្រោយការបង្ហាញខ្លួនជាលើកដំបូងរបស់ជនជាប់ចោទ រដ្ឋអាជ្ញាបញ្ជូនទៅកាន់ក្រុមប្រឹក្សាការពារក្តីនូវឯកសារគាំទ្រភ្ជាប់ជាមួយបទចោទ នៅពេលស្នើសុំបញ្ជាក់[122]។ ចាំពីពេលនេះតទៅ ក្រុមប្រឹក្សា

---

[119] មាត្រា ១៨-៤ នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មាត្រា ១៧-៤ នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា មាត្រា ១៦-៤ នៃលក្ខន្តិកៈនៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[120] មាត្រា ១៩-១ នៃលក្ខន្តិកៈនៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មាត្រា ១៨-១ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា មាត្រា ១៧-១ នៃលក្ខន្តិកៈនៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ និង មាត្រា ៤៧-ឆ នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេស
យូហ្គោស្លាវី និង វិធាននីតិវិធី និងភ័ស្តុតាងតុលាការ តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសរ្វ៉ាន់ដា មាត្រា ៤៨-ឆ នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[121] មាត្រា ៥០ នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា មាត្រា ៥០ នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[122] មាត្រា ៦៦-ក-ឈ នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង វិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា មាត្រា ៧១-ក-ឈ នៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

ការពារក្តីអាចលើកឡើងពីអាញ្ញត្តិកម្មដែលត្រូវលើកយកមកពិភាក្សាមុន ជាពិសេស ពាក់ព័ន្ធនឹងអសមត្ថកិច្ច ឬការសំអាងហេតុដោយផ្អែកលើកំហុសទម្រង់នៃបទចោទ[123]។

១៤៤. ការជំនុំជម្រះចាប់ផ្តើមដោយការបង្ហាញភ័ស្តុតាងពីសំណាក់រដ្ឋអាជ្ញា[124]។ នៅក្រោយការបង្ហាញនេះ និងក្រោយពីបានស្តាប់ឡើករណ៍របស់ភាគីទាំងអស់ អង្គជំនុំជម្រះសាលាដំបូងត្រូវប្រកាសបដិសេធរាល់បទចោទ ដែលគ្មានធាតុផ្សំនៃភ័ស្តុតាងសម្រាប់គាំទ្រដល់ការផ្តន្ទាទោស[125]។

១៤៥. នៅក្រោយការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងត្រូវដកខ្លួន ដើម្បីពិភាក្សា និង *"ធ្វើការបោះឆ្នោតដាច់ដោយឡែកពីគ្នា លើបទចោទនីមួយៗ ដែលចែងនៅក្នុងបទចោទ"*[126]។ ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមទាំងមូល ឬផ្នែកណាមួយនៃសាលក្រម សាលាឧទ្ធរណ៍ *"ចេញសាលដីកា ដោយសំអាងលើសំណុំរឿងនៃបណ្តឹងឧទ្ធរណ៍"*[127]។

១៤៦. នៅក្នុងសាលក្រម **ឌុច** អង្គជំនុំជម្រះបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក បានដាក់កំហិតថា សហព្រះរាជអាជ្ញាត្រូវកែប្រែបទចោទជាផ្លូវការ នៅពេលដែលការពិនិត្យអង្គ

---

[123] មាត្រា ៧២-ក នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង វិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា មាត្រា ៧៩-ក នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[124] មាត្រា ៨៥-ក នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង វិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា មាត្រា ១០២-ក នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[125] មាត្រា ៩៨ ស្ទួន នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា មាត្រា ១២១ នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[126] មាត្រា ៨៧ នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង នៃ វិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា មាត្រា ១០៤ នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[127] មាត្រា ១១៧ នៃលក្ខន្តិកៈនៃ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, មាត្រា ១១៨ នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា, មាត្រា ១៤៤ នៃវិធាននីតិវិធី និងភ័ស្តុតាងតុលាការ នៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

ហេតុបង្ហាញថា អង្គហេតុទាំងនេះផ្សំឡើងដោយបទល្មើសខុសគ្នាពីបទល្មើសដែលបានចោទប្រកាន់ជនជាប់ចោទកាលពីលើកដំបូង[128]។ ដោយឡែក នៅក្នុងការសម្រេចមួយផ្សេងទៀត អង្គជំនុំជម្រះបានលើកឡើងថា អង្គជំនុំជម្រះនៃតុលាការចំពោះកិច្ចអនុម័តវិធីតឹងរ៉ឹងមួយ ពាក់ព័ន្ធនឹងកម្រិតនៃភាពច្បាស់លាស់នៃបទចោទ ដោយបន្ថែមថា៖

> "នៅពេលអង្គជំនុំជម្រះនៃតុលាការចំពោះកិច្ចបានយល់ឃើញថា បទចោទមួយមិនបង្ហាញឱ្យបានច្បាស់លាស់ពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ជាក់លាក់ប្រឆាំងនឹងជនជាប់ចោទ" [129]។

១៤៧. ជាក់ស្តែង សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ រំឭកពីច្បាប់ជាធរមានស្តីពីបទចោទដោយថ្លែងថា៖

> "បទចោទដែលបានកំណត់ និងអង្គហេតុសំខាន់ៗសម្រាប់គាំទ្រ ត្រូវតែបង្ហាញឱ្យបានជាក់លាក់គ្រប់គ្រាន់នៅក្នុងបទចោទ ដើម្បីជូនដំណឹងដល់ជនជាប់ចោទ។ រដ្ឋអាជ្ញាត្រូវស្គាល់សំណុំរឿងរបស់ខ្លួន មុននឹងចូលមកបង្ហាញខ្លួននៅក្នុងការជំនុំជម្រះ និងគ្មានសិទ្ធិរចនានិក្ខេបបទរបស់ខ្លួន ក្នុងអំឡុងពេលពិភាក្សា ស្របតាមដំណើរការនៃការបង្ហាញធាតុផ្សំនៃភស្តុតាង។ កំហុសបទចោទ អាចបង្ហាញក្នុងអំឡុងពេលជំនុំជម្រះ ដោយហេតុថា ការបង្ហាញធាតុផ្សំនៃភស្តុតាងមិនប្រព្រឹត្តទៅតាមការគ្រោងទុកនោះទេ។ នៅក្នុងកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះសាលាដំបូង ត្រូវព្យាយាមពិចារណា ថាតើត្រូវកែប្រែបទចោទ លើកពេលពិភាក្សា ឬដកចេញធាតុផ្សំនៃភស្តុតាង ដែលមិនស្ថិតនៅក្នុងក្របខណ្ឌនៃបទចោទ ដើម្បីធានាសមភាពនៃការជំនុំជម្រះ។ ក្នុងការចេញសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងមួយ អាចប្រកាសថាជនជាប់មានពិរុទ្ធបានដោយផ្អែកតែលើឧក្រិដ្ឋកម្មដែលបានបង្ហាញនៅក្នុងបទចោទតែប៉ុណ្ណោះ" [130]។

---

[128] សាលក្រម ឌុច ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៩៥ ដែលយោងទៅកំណត់សម្គាល់ជើងទំព័រ ៧៨១ ក្នុងសាលក្រម Kupreškić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៧៤៨ (« ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសន្និដ្ឋាននៅក្នុងពេលកាត់សេចក្តីដែលចាត់ទុកថាពុំមានសម្អាងហេតុថាជាបទល្មើសផ្សេងពីបទល្មើសរងការស្តីបន្ទោសដល់ជនជាប់ចោទដូចខាងដើម អង្គជំនុំជម្រះគួរតែស្នើសុំទៅរដ្ឋអាជ្ញាឱ្យកែប្រែបទចោទប្រកាន់។ ប្រសិនបើ រដ្ឋអាជ្ញាមិនធ្វើតាមបង្គាប់ អង្គជំនុំជម្រះមិនមានជម្រើសអ្វីក្រៅពីបដិសេធការដាក់បន្ទុកនោះឡើយ »)។

[129] សេចក្តីសម្រេច ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០១ **ឯកសារ E122** កថាខណ្ឌ ២០ និង កំណត់សម្គាល់ជើងទំព័រ ៤៤។

[130] សាលដីកា Muvunyi (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ ១៨។ សូមមើលផងដែរ ៖ សាលដីកា Ntagerura (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ២២, ២៧-២៨, សាលដីកា Kupreškić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី

១៤៨. ម៉្យាងវិញទៀត ពិតជាមានការបង្ហាញថា ពិរុទ្ធជនម្នាក់អាចលើកឡើងជាលើកដំបូង ក្នុងបណ្តឹងឧទ្ធរណ៍ ពីអត្ថិភាពនៃកំហុសបទចោទ៖

> "ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីកំហុសបទចោទ ជាលើកដំបូង នៅក្នុងបណ្តឹងឧទ្ធរណ៍ ជាអ្នកទទួលបន្ទុកបង្ហាញថា សមត្ថភាពត្រៀមការពារខ្លួន រងផលប៉ះពាល់ធ្ងន់ធ្ងរ។ ផ្ទុយទៅវិញ ក្នុងករណីដែលជនជាប់ចោទបានប្តឹងរួចមកហើយ នៅសាលាដំបូង ពីបទមិនបានទទួលព័ត៌មានចាំបាច់ រដ្ឋអាជ្ញាជាអ្នកទទួលបន្ទុកក្នុងការបង្ហាញក្នុងបណ្តឹងឧទ្ធរណ៍ថា សមត្ថភាពរបស់ជនជាប់ចោទក្នុងការត្រៀមការពារខ្លួន មិនទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរនោះទេ"។ ដូច្នេះ បញ្ហានេះអាស្រ័យទៅលើឆន្ទានុសិទ្ធិផ្ទាល់របស់សាលាឧទ្ធរណ៍ ក្នុងការផ្តល់យុត្តិធម៌នៅក្នុងរឿងក្តីនេះ"[131]។

## ផ្នែកទី ៣. វិសាលភាពនៃបណ្តឹងកាន់តែបង្រួមតូច ដោយដីកាបំបែកការចោទប្រកាន់

១៤៩. នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ មុនពេលបើកការជំនុំជម្រះក្តី និងទោះបីជាមានការជំទាស់ពីមេធាវីការពារក្តីក៏ដោយ[132] អង្គជំនុំជម្រះបានសម្រេចបំបែកការចោទប្រកាន់ជាថ្មីម្តងទៀត នៅក្នុងសំណុំរឿង ០០២[133]។ អង្គជំនុំជម្រះក៏បានកំណត់នៅក្នុងឧបសម្ព័ន្ធនៃដីការបស់ខ្លួន នូវកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយ ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២ ("ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២")[134]។

---

) ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០១ កថាខណ្ឌ ៨៨ និង ៩២។ សាលដីកា Kvoćka (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេស
យូហ្គោស្លាវី) ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ២៨, ៣១-៣៣។

[131] សាលដីកា Nahimana (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៣២៧។ សាលដីកា Ntagerura (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ៣១។ សូមមើលផងដែរ ៖ សាលដីកា Kvoćka (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ៣៥។

[132] សេចក្តីសន្និដ្ឋានរបស់លោក ខៀវ សំផន ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤**ឯកសារ E301/5/2**។

[133] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤**ឯកសារ E301/9/1**។

[134] ឧបសម្ព័ន្ធ ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះ សំណុំរឿងលេខ០០២/០២ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤**ឯកសារ E301/9/1.1**។

១៥០. ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ ពោលគឺរយៈពេលជាងមួយខែក្រោយពេលបញ្ចប់សវនាការលើអង្គសេចក្តីលើសំណុំរឿង ០០២/០២ និងស្របតាមសំណើរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានសម្រេច "បង្រួមវិសាលភាពនៃការចោទប្រកាន់ ក្នុងក្របខណ្ឌនៃសំណុំរឿង ០០២[135]"[136]។ ដូច្នេះ អង្គជំនុំជម្រះបានជម្រុះចេញពីបណ្តឹងមកកាន់ខ្លួននូវការចោទប្រកាន់នានាដែលមិនស្ថិតក្នុងវិសាលភាព នៃសំណុំរឿង ០០២/០១ និង ០០២/០២។

១៥១. ក្នុងសេចក្តីសម្រេចចុងក្រោយនេះ អង្គជំនុំជម្រះបានរំឭកជាអាទិ៍ថា៖

> "នៅក្នុងឧបសម្ព័ន្ធនៃដីកាបំបែកការចោទប្រកាន់ថ្មី អង្គជំនុំជម្រះបានបញ្ជាក់ថា ដោយអង្គជំនុំជម្រះទទួលសំណើមានសំអាងហេតុក្នុងគោលបំណងនេះ អង្គជំនុំជម្រះអាចពង្រីកវិសាលភាពនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២ ក្នុងករណីដែលមាន ដើម្បីបញ្ចូលអង្គហេតុបន្ថែមទាក់ទងនឹងការបោសសម្អាតនៅក្នុងភូមិភាគឧត្តរ និងបូព៌ា។ ពុំមានសំណើណាមួយក្នុងគោលបំណងនេះ ត្រូវបានដាក់ជូនអង្គជំនុំជម្រះទេ[137]"។

១៥២. អាស្រ័យហេតុនេះ រាល់ការចោទប្រកាន់ដែលអង្គជំនុំជម្រះបានដកចេញពីវិសាលភាពនៃការជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០២ ត្រូវបានជម្រុះចោល និងមិនត្រូវយកមកជំនុំជម្រះទេ។ ដូច្នេះ ការប៉ុនប៉ងទាំងឡាយរបស់សហព្រះរាជអាជ្ញា និងការព្យាយាមរបស់អង្គជំនុំជម្រះ ក្នុងការពិចារណាលើការចោទប្រកាន់ទាំងនេះដោយប្រយោល នៅក្នុងសំណុំរឿង ០០២/០២ តាមនីតិវិធីប្រវត្តិសាស្ត្រច្រើនជាងនីតិវិធីច្បាប់ ត្រូវតែបដិសេធចោល។

១៥៣. ក្នុងសំណុំរឿងនេះ ការចោទប្រកាន់ផ្សេងៗដែល ខៀវ សំផន ត្រូវឆ្លើយតប គឺមានតែការចោទប្រកាន់ដែលបានប្តឹងមកអង្គជំនុំជម្រះត្រឹមត្រូវតាមនីតិវិធី ដូចដែលអង្គជំនុំជម្រះបានសម្រេចកំណត់ នៅពេលបំបែកការចោទប្រកាន់។ ក្រៅពីនេះ អ្វីដែលទៅហួសវិសាលនៃបណ្តឹងដែលមិនអាចពង្រីកបាន ត្រូវតែដកចេញពីការពិភាក្សាសម្រេច។

---

[135] ការឆ្លើយតបទៅព្រះរាជអាជ្ញា ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E439/3**។

[136] សេចក្តីសម្រេច ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ **ឯកសារ E439/5**។

[137] សេចក្តីសម្រេច ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ **ឯកសារ E439/5** កថាខណ្ឌ ១២។

## ផ្នែកទី ៤. ធាតុផ្សំដែលត្រូវដកចេញពីការពិភាក្សាសម្រេចក្នុងសំណុំរឿង ០០២/០២

១៥៤. ក្នុងដំណើការជំនុំជម្រះសេចក្ដីនៃសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានទទួលយក និងស្ដាប់ធាតុផ្សំភ័ស្ដុតាងជាច្រើន នៃអង្គហេតុដែលស្ថិតនៅក្រៅវិសាលភាពនៃការចោទប្រកាន់។ វាជា ១) អង្គហេតុដែលមិនធ្លាប់បានប្ដឹងមកអង្គជំនុំជម្រះទាល់តែសោះ ២) អង្គហេតុដែលអង្គជំនុំជម្រះបានជម្រុះចោល ៣) អង្គហេតុដែលអង្គជំនុំជម្រះមិនបានទទួលត្រឹមត្រូវតាមនីតិវិធី។

១៥៥. ចំណុចទាំងនេះដែលអង្គជំនុំជម្រះត្រូវដកចេញពីការពិក្សាសម្រេចរបស់ខ្លួន ហើយដែលបានអូសបន្លាយការជំនុំជម្រះដោយឥតប្រយោជន៍ មានសរសេររៀបរាប់នៅក្នុងផ្នែកពាក់ព័ន្ធនៃសារណាសន្និដ្ឋានបញ្ចប់ការដេញដោលយើងនេះ។ ក៏ប៉ុន្ដែ នៅពេលនេះ យើងគប្បីពិនិត្យចំណុចដែលមានលក្ខណ:អន្ដរផ្នែក និង/ឬ ច្រំដែល។

### ១ .ធាតុផ្សំនៃអង្គហេតុដែលមិនធ្លាប់បានប្ដឹងមកអង្គជំនុំជម្រះទាល់តែសោះ

១៥៦. ចាប់តាំងពីដំបូងនៃការជំនុំជម្រះលើសំណុំរឿង ០០២/០២ សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី ព្យាយាមធ្វើយ៉ាងណាឱ្យអង្គជំនុំជម្រះសម្រេចលើអង្គហេតុដែលមិនធ្លាប់បានប្ដឹងមកអង្គជំនុំជម្រះ។ ក) សហព្រះរាជអាជ្ញាព្យាយាមពង្រីកវិសាលភាពទៅដល់អង្គហេតុពាក់ព័ន្ធនឹងខ្មែរក្រោម។ ខ) រីឯដើមបណ្ដឹងរដ្ឋប្បវេណីព្យាយាមពង្រីវិសាលភាពទៅដល់អង្គហេតុស្ដីពីការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍។

#### ក. ខ្មែរក្រោម

១៥៧. ដូចសហចៅក្រមស៊ើបអង្កេតដែរ អង្គជំនុំជម្រះមិនដែលបានទទួលបណ្ដឹងអំពីអង្គហេតុទាក់ទងនឹងខ្មែរក្រោមក្នុង ឋាន:ជាក្រុមជាក់លាក់នោះទេ។

1. **ការស៊ើបអង្កេត**

១៥៨. សហព្រះរាជអាជ្ញាមិនដែលបានបញ្ជូនអង្គហេតុពាក់ព័ន្ធនឹងការប្រព្រឹត្តិលើខ្មែរក្រោមទៅសហចៅក្រមស៊ើបអង្កេតនោះទេ។ សហចៅក្រមស៊ើបអង្កេតធ្លាប់បានរំឭកពីការប្រព្រឹត្តិនេះ ក្នុងចម្លើយតបរបស់ខ្លួនទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរលើខ្មែរក្រោម ដែលធ្វើឡើងដោយព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។

១៥៩. ជាក់ស្តែង នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត ថែមទាំងបានរំឭកថា "ខ្លួនបានទទួលបណ្តឹងពីការប្រព្រឹត្តិលើជនជាតិវៀតណាមរស់នៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង និងលើជនជាតិវៀតណាមក្នុងពេលវាយចូលលុកលុយប្រទេសវៀតណាម តែមិនបានទទួលបណ្តឹងពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តលើខ្មែរក្រោមរស់នៅក្នុងខេត្តពោធិសាត់ទេ។" សហចៅក្រមស៊ើបអង្កេតបដិសេធរាល់សំណើ ដោយផ្តល់សំអាងហេតុថា សំណើទាំងនេះ "មានកម្មវត្ថុឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមលើអង្គហេតុដែលមិនមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[138]"។

១៦០. នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះ បានបញ្ជាក់ថាសហចៅក្រមស៊ើបអង្កេតពិតជាពុំបានទទួលបណ្តឹងពីអង្គហេតុទាំងនេះមែន។ អង្គបុរេជំនុំជម្រះបានរំឭកយ៉ាងច្បាស់លាស់អំពីការកំណត់វិសាលភាពនៃការស៊ើបអង្កេត ដោយយោងទៅផ្នែកពាក់ព័ន្ធនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ៖ បុគ្គលដែលត្រូវបានចាត់ទុកថាជាជនជាតិវៀតណាម ឬត្រូវបានចាត់ទុកថាមានជាប់ទាក់ទង តាមរូបភាពណាមួយ ជាមួយប្រទេសវៀតណាម មិនស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេតទេ[139]។ អង្គបុរេថែមទាំងប្រកាសទៀតថា៖

[138] ដីកាតែមួយគត់ពាក់ព័ន្ធនឹងសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនពីរ ដាក់ដោយសហព្រះរាជអាជ្ញាទាក់ទងនឹងខ្មែរកម្ពុជាក្រោម និងការសម្លាប់រង្គាលដែលបានធ្វើឡើងនៅក្នុងស្រុកបាកាន (ខេត្តពោធិសាត់) ព្រមទាំងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យស៊ើបសួរបន្ថែមលើអំពើប្រល័យពូជសាសន៍ខ្មែរកម្ពុជាក្រោម និងជនជាតិវៀតណាម ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ **ឯកសារ D250/3/3** កថាខណ្ឌ ៧-៩។

[139] សេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ **ឯកសារ D250/3/2/1/5** កថាខណ្ឌ ៤១។

> “អង្គបុរេជំនុំជម្រះដឹងថា វិសាលភាពនៃការស៊ើបអង្កេតបច្ចុប្បន្ន ដូចដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម អាចមិនឆ្លុះបញ្ចាំងពីទំហំឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយខ្មែរក្រហមទៅលើអ្នកមានដើមកំណើតវៀតណាម ក្នុងរយៈកាលពាក់ព័ន្ធ” ។ ដូចបានលើកឡើងខាងលើ ស្របតាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក មានតែសហព្រះរាជអាជ្ញាតែប៉ុណ្ណោះដែលមានកាតព្វកិច្ចកំណត់វិសាលភាពនៃការស៊ើបសួរ។ ដោយឡែក អង្គបុរេជំនុំជម្រះពុំមានអ្វីត្រូវធ្វើការអត្ថាធិប្បាយវែងឆ្ងាយអំពីការចង់ដឹងថា តើសេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញាត្រង់ប្រការនេះ អាចមានផលប៉ះពាល់ដល់សមត្ថភាពរបស់ខ្លួនក្នុងការបង្ហាញភ័ស្តុតាងពាក់ព័ន្ធនឹងការចោទប្រកាន់លើជនត្រូវចោទ អំពីបទប្រល័យពូជសាសន៍លើក្រុមជនជាតិវៀតណាម ដែរឬទេ។[140]

១៦១. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ និងបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ តែចំពោះអង្គហេតុពាក់ព័ន្ធនឹងជនជាតិវៀតណាមតែប៉ុណ្ណោះ[141] ។

## 2. <u>**ការជំនុំជម្រះ**</u>

១៦២. នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ក្នុងឱកាសនៃការប្រកាសបើកការចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ សហព្រះរាជអាជ្ញា លោកស្រី ជា លាង មិនរារែកក្នុងការអះអាងថា សហព្រះរាជអាជ្ញានឹងបង្ហាញឱ្យឃើញថាមានការកំណត់មុខសញ្ញាចំពោះខ្មែរក្រោម៖

> “យើងនឹងឃើញថា [...] ការធ្វើទុក្ខបុកម្នេញលើក្រុមជាមុខសញ្ញា ដូចជាអតីតទាហានលន់នល់ ខ្មែរក្រោម និងប្រជាជនថ្មី បានបន្តពេញមួយរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ”[142]។
>
> “ក្រុមទាំងនេះត្រូវបានតាមដានយ៉ាងដិតដល់ ហើយត្រូវបានកំណត់ជាមុខសញ្ញាសម្រាប់ចាប់ខ្លួននិងសម្លាប់ចោល នៅពេលណាមានកំហុស ទោះជាកំហុសតិចតួចក្តី”[143]។

---

[140] សេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០**ឯកសារ D250/3/2/1/5** កថាខណ្ឌ ៦០។

[141] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៣៥-១៥២០ (មានការលើកឡើងពីជនភាគតិចខ្មែរកម្ពុជាក្រោម ប៉ុន្តែមានតែនៅក្នុងកថាខណ្ឌ ១៤៦៨ ប៉ុណ្ណោះ ដែលពាក់ព័ន្ធនឹងអង្គហេតុដែលចាត់ទុកថាជាការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីពីរ ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ ប៉ុន្តែមិនមែនជាជាកម្មវត្ថុនៃសំណុំរឿង ០០២/០២ ឡើយ លើកលែងតែករណីពាក់ព័ន្ធនឹងជនជាតិចាម)។

[142] ប្រតិចារឹក ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤**ឯកសារ E1/242.1** ទំព័រ ១២ ប.២៣-២៥ បន្ទាប់ពីម៉ោង 09.36.19។

"ខ្មែរក្រោមដែលបានបញ្ជូនមកត្រាំកក់ ត្រូវបានធ្វើឱ្យទៅជាទាសករ និងបង្ខំឱ្យធ្វើការនៅក្នុងសហករណ៍ និងការដ្ឋាននានានៅក្នុងស្រុក។ ក្រោយមក ជនជាតិវៀតណាមដែលទៅមិនទាន់អស់ ត្រូវបានប្រមូលយកទៅសម្លាប់ចោលរហូតទាល់តែគ្មាននៅសល់ជនជាតិវៀតណាមណាម្នាក់នៅក្នុងស្រុកត្រាំកក់។ ស្រដៀងគ្នានេះដែរ ខ្មែរក្រោមទាំងនោះត្រូវបានគេចាត់ទុកថាជាមុខសញ្ញា និងចោទថាមាន "ក្បាលយួនខ្លួនខ្មែរ"[144]។

១៦៣. នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ នៅពេលចាប់ផ្ដើមសវនាការលើអង្គសេចក្ដី ក្រុមមេធាវីការពារក្ដីទាំងអស់បានជំទាស់មិនឱ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីចោទសួរដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់អំពីការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោមនៅត្រាំកក់[145]។ ចៅក្រម Lavergne បានប្រកាសសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើការជំទាស់ខាងដើម៖

"ដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធការជំទាស់ដែលបានលើកឡើងដោយមេធាវីការពារក្ដី ដោយហេតុផលជាច្រើន។ ជាដំបូង អង្គហេតុដែលដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់សក្ខីកម្មថ្ងៃនេះ ជាអង្គហេតុដែលទាក់ទងនឹងល័ក្ខខ័ណ្ឌជីវភាពនៅក្នុងសហករណ៍ត្រាំកក់។ ត្រង់ប្រការនេះ យើងយល់ថា អង្គហេតុនេះមានភាពពាក់ព័ន្ធបាត់ទៅហើយ។ មូលហេតុទីពីរ គឺដោយហេតុថាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យជំនុំជម្រះរៀបរាប់អំពីអង្គហេតុមួយចំនួនពាក់ព័ន្ធនឹងខ្មែរក្រោម។ ដូច្នេះ ចំពោះយើង វាហាក់ដូចជាបញ្ហាដែលលើកឡើងនេះ ស្ថិតក្នុងវិសាលភាពនៃសំណុំរឿងនេះ។ មូលហេតុចុងក្រោយ អង្គជំនុំជម្រះរំឭកថា ខ្លួននឹងប្រាកដជាត្រូវសម្រេចថា អ្នកណាដែលត្រូវចាត់ទុកថាជាសមាជិកនៃក្រុមជនជាតិវៀតណាម ឧទាហរណ៍ វៀតណាមដែលមានសញ្ជាតិវៀតណាម ឬអ្នកដែលគេយល់ឃើញថាជាជនជាតិវៀតណាម។ ដូច្នេះ បញ្ហាពាក់ព័ន្ធនឹងការលំបាកមួយនេះ ស្ថិតនៅក្នុងវិសាលភាពនៃរឿងក្ដីទាំងស្រុង ហើយត្រូវតែយកមកពិភាក្សាដេញដោល"[146]។

១៦៤. នៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ក្រុមមេធាវីការពារក្ដី នួន ជា បានរំឭកថា សហព្រះរាជអាជ្ញាមិនបានកំណត់ថាខ្មែរក្រោមជាក្រុមជាក់លាក់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬនៅក្នុងដីកាសន្និដ្ឋានឱ្យស៊ើបសួរបន្ថែមឡើយ ហើយថាខ្មែរក្រោមនេះមិនមានរៀបរាប់នៅក្នុងដីកាដំណោះស្រាយក្នុងឋានៈជាក្រុមជាក់លាក់នោះទេ។ ក្រុមមេធាវីការពារក្ដី នួន ជា បានស្នើសុំអង្គ

[143] ប្រតិចារឹក ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ **ឯកសារ E1/242.1** ទំព័រ ១៤ ប.១៣-១៩ ម៉ោង 09.44.33។

[144] ប្រតិចារឹក ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ **ឯកសារ E1/242.1** ទំព័រ ១៤ ប.១២-២៣ បន្ទាប់ពីម៉ោង 09.44.33។

[145] ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/262.1** ទំព័រ ១៣-១៦ ពីម៉ោង 09.48.31 ដល់ម៉ោង 09.57.04។

[146] ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/262.1** ទំព័រ ១៦ ពីម៉ោង 09.57.04 ដល់ម៉ោង 09.58.50។

ជំនុំជម្រះឱ្យធានាដល់ភាគីថា ខ្មែរក្រោមនឹងមិនត្រូវបានចាត់ទុកថាជាឧបក្រុមដែលទំនងជាត្រូវកំណត់ជាគោលដៅជាក់លាក់[147]។

១៦៥. នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ បន្ទាប់ពីបានប្រើពេលជិតបីខែ ដើម្បីពិចារណាលើបញ្ហានេះ និងទុកឱ្យភាគីចោទសួរពាក់ព័ន្ធនឹងខ្មែរក្រោមក្នុងសវនាការ[148] អង្គជំនុំជម្រះបានចេញចាកឆ្ងាយពីសេចក្ដីសម្រេចលើការជំទាស់ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ របស់ខ្លួន ដែលត្រូវបានប្រកាសយ៉ាងប្រចុចញ៉ុចដោយចៅក្រម Lavergne ក្នុងនាមអង្គជំនុំជម្រះ។ អាស្រ័យហេតុនេះ ជាការឆ្លើយតបនឹងសំណើសុំការបំភ្លឺរបស់ នួន ជា ប្រធានអង្គជំនុំជម្រះបានប្រកាសថា៖

> “អង្គជំនុំជម្រះមិនបញ្ចូលការចោទប្រកាន់ទាក់ទងនឹងការកំណត់គោលដៅទៅលើខ្មែរក្រោមថាជាក្រុមជាក់លាក់មួយនោះទេ។ មានន័យថា ជាការធ្វើទុក្ខបុកម្នេញដែលជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬអំពើប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម”[149]។
>
> “ជាគោលការណ៍ ក្នុងករណីដែលភស្តុតាងដែលបានស្នើឡើង ឬដែលបានពិភាក្សានៅចំពោះមុខអង្គជំនុំជម្រះជាប់ពាក់ព័ន្ធតែទៅនឹងការកំណត់គោលដៅទៅលើខ្មែរក្រោម ហើយដែលពាក់ព័ន្ធតែជាមួយនឹងការបង្កើតធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬអំពើប្រល័យពូជសាសន៍លើខ្មែរក្រោមទេនោះ អង្គជំនុំជម្រះយល់ថាវាមិនពាក់ព័ន្ធ ហើយនិងមិនអនុញ្ញាតឱ្យធ្វើការដេញដោលឡើយ។ [...] ទោះជាយ៉ាងនេះក្តី ភស្តុតាងដែលទាក់ទងនឹងខ្មែរក្រោម អាចជាប់ពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀតនៅក្នុងសំណុំរឿង ០០២/០២ ដូចជាបរិបទប្រវត្តិសាស្ត្រ និងគោលនយោបាយនៃសំណុំរឿងនេះ ឬបទល្មើសដទៃទៀតដែលត្រូវបានចោទប្រកាន់ ហើយជនរងគ្រោះមួយចំនួន គឺជាខ្មែរក្រោម។ ក្នុងករណីនេះ អង្គជំនុំជម្រះអាចអនុញ្ញាតឱ្យធ្វើការដេញដោលបាន ក៏ប៉ុន្តែអង្គជំនុំជម្រះស្នើឱ្យភាគីផ្តោតជាចម្បងទៅលើការដេញដោលភស្តុតាងដែលជាប់ពាក់ព័ន្ធខ្លាំងបំផុត ទៅលើការចោទប្រកាន់ចំពោះអង្គហេតុនានាក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះនឹងមិនបដិសេធសក្ខីកម្មរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលបានថ្លែងថាបុគ្គលម្នាក់ជាខ្មែរក្រោមនោះទេ ពីព្រោះវាទាក់ទងនឹងបញ្ហាដទៃទៀត នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ ប៉ុន្តែ

---

[147] សារណារបស់ នួន ជា ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ E319/16** កថាខណ្ឌ ៩-១០ និង ១៩-ង។

[148] ប្រតិចារឹក ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ E1/293.1** មុនម៉ោង 09.44.51 ទំព័រ ១១ (ចៅក្រម FENZ៖ *“បញ្ហាទី២ទាក់ទងទៅនឹងសេចក្តីសម្រេច យើងនឹងចេញនៅក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន ហើយវាជាអាទិភាពទី១របស់យើង។ ហើយនៅពេលនេះ និងដំបូងបង្អស់ការសម្រេចរបស់យើង គឺទាក់ទងទៅនឹងបញ្ហាខ្មែរក្រោមដូចដែលយើងនិយាយរួចមកហើយ អាចដោះស្រាយបានដោយមិនមានការសម្រេចផ្ទុយពីនេះទេ”*)។

[149] ប្រតិចារឹក ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/304.1** ទំព័រ ៤៦-៤៧ ប.១១-២៥ បន្ទាប់ពីម៉ោង 13.35.39។

ចំណុចនេះ ពុំគួរជាចំណុចដែលត្រូវផ្តោតការយកចិត្តទុកដាក់នៃការតាំងសំណួររបស់មេធាវីការពារក្តីឡើយ ដោយហេតុថា ការកំណត់គោលដៅលើខ្មែរក្រោមមិនត្រូវបានចោទប្រកាន់ក្នុងសំណុំរឿងក្តីនេះឡើយ”[150]។

១៦៦. បន្ទាប់មកទៀត អង្គជំនុំជម្រះបានរំឭកជាប្រចាំអំពីសេចក្តីសម្រេចចុងក្រោយនេះ នៅពេលប្រកាសសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារចេញមកពីការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង០០៤[151] ដែលក្រុមមេធាវីការពារក្តីបានជំទាស់ ជាពិសេស ដោយមូលហេតុថាឯកសារខ្លះទាក់ទងនឹងខ្មែរក្រោម[152]។

១៦៧. ទោះជាយ៉ាងនេះក្តី ឆន្ទៈរបស់សហព្រះរាជអាជ្ញាដែលចង់ពង្រីកការចោទប្រកាន់រហូតដល់អង្គហេតុពាក់ព័ន្ធនឹងខ្មែរក្រោមក្នុងឋានៈជាក្រុមជាក់លាក់ ដែលបានបង្ហាញឱ្យឃើញតាំងពីសវនាការបើកការចោទប្រកាន់ មិនបានងាករេទាល់តែសោះ។ ជាក់ស្តែង នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ នៅចុងបញ្ចប់នៃសវនាការលើអង្គសេចក្តី សហព្រះរាជអាជ្ញារង De Wilde បានចោទសួរដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ (ដែលត្រូវបានកោះហៅមកថ្លែងអំពីទុក្ខសោករបស់គាត់ ដោយសារទទួលរងនូវព្យសនកម្ម បណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ថាតើខ្មែរក្រោមនៅស្រុកបាកាន ចាត់ទុកខ្លួនឯងជាវៀតណាម ឬខ្មែរ[153]។ ក្នុងពេលបន្តសួរពាក់ព័ន្ធនឹងចំណុចនេះ ប៉ុន្តែមេធាវីការពារក្តីបានកាត់ផ្តាច់ និងជំទាស់ គាត់បានឆ្លើយថាខ្សែសំណួររបស់គាត់៖

---

[150] ប្រតិចារឹក ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/304.1** ទំព័រ ៤៦ ប្រហែលម៉ោង 13.35.39។

[151] សេចក្តីសម្រេច ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E319/36/2** កថាខណ្ឌ ២២, សេចក្តីសម្រេច ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E319/47/3** កថាខណ្ឌ ២៥, សេចក្តីសម្រេច ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E319/52/4** កថាខណ្ឌ ១៧-១៨។

[152] ចម្លើយតបរបស់ ខៀវ សំផន ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/319/36/1** កថាខណ្ឌ ២០, ចម្លើយផ្ទាល់មាត់របស់លោក ខៀវ សំផន ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦, ប្រតិចារឹក ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E1/429.1** ទំព័រ ៤០-៤១ ពីម៉ោង 10.28.48 ដល់ម៉ោង 10.31.03, ចម្លើយតបរបស់ ខៀវ សំផន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E319/52/3** កថាខណ្ឌ ៣៤-៣៦, ចម្លើយតបរបស់ ខៀវ សំផន ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E319/56/2** កថាខណ្ឌ ៣៧-៣៩។

[153] ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៥ **ឯកសារ E1/489.1** ទំព័រ ១១-១២ ប្រហែលម៉ោង 09.34.07 (នៅពេលដើមបណ្តឹង ង៉ែត ចាត ផ្តល់សក្ខីកម្មស្តីពីផលប៉ះពាល់នៃអំពើឧក្រិដ្ឋកម្ម)។

"គឺចង់ដឹងថា (sic) តើខ្មែរក្រហមមានទស្សនៈយ៉ាងម៉េចចំពោះក្រុមខ្មែរក្រោមនេះ ដូចជាចង់ដឹងថាតើពួកខ្មែរក្រោមជាក្រុមមនុស្សដែលត្រូវបានចោទប្រកាន់ ក្រោមទ្រង់ទ្រាយណាមួយ ថាជាអ្នកជិតស្និទ្ធនឹងវៀតណាម ឬជាវៀតណាម។ ខ្ញុំគិតថាសំណួរនេះសំខាន់ និងមានភាពពាក់ព័ន្ធ"[154]។

១៦៨. ក៏ប៉ុន្តែ ខ្សែសំណួរនេះប្រហែលជាអាចមានភាពពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៤[155] ប៉ុន្តែវាមិនមានភាពពាក់ព័ន្ធទេនៅក្នុងសំណុំរឿង ០០២/០២។ ទោះបីជានៅចុងបញ្ចប់ សហព្រះរាជអាជ្ញារងបានបញ្ចប់សំណួរដោយខ្វះពេលវេលា[156] វាមិនមែនអត់ប្រយោជន៍ទេ ក្នុងការលើកឡើងថាស្ថានភាពខ្មែរក្រោមនៅស្រុកបាកាន គឺជាកម្មវត្ថុជាក់លាក់នៃសំណើមួយក្នុងចំណោមសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញា ដែលចៅក្រមស៊ើបអង្កេតបានបដិសេធចោល នៅឆ្នាំ ២០១០ ដោយមូលហេតុហួសវិសាលភាពនៃបណ្តឹងដែលខ្លួនបានទទួល ដូចបានលើកឡើងខាងលើ[157]។

១៦៩. ក្នុងសំណុំរឿងនេះ សហចៅក្រមស៊ើបអង្កេត និងជាចុងក្រោយ អង្គជំនុំជម្រះផ្ទាល់ មិនបានទទួលបណ្តឹងពីការចោទប្រកាន់ពាក់ព័ន្ធនឹងខ្មែរក្រោមក្នុងឋានៈជាក្រុមជាក់លាក់ ទោះបីពួកគេត្រូវបានចាត់ទុក ឬមិនត្រូវបានចាត់ទុកជាជនជាតិវៀតណាមក្តី។

១៧០. អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនត្រូវបណ្តោយទៅតាមការប៉ុនប៉ងជាប្រចាំរបស់សហព្រះរាជអាជ្ញា សំដៅធ្វើយ៉ាងណាឱ្យអង្គជំនុំជម្រះចេញពីវិសាលភាពនៃបណ្តឹង នៅពេលសម្រេចលើអង្គហេតុទាំងនេះ (ការប៉ុនប៉ងទាំងនេះ ប្រាកដជានឹងធ្វើឡើងជាថ្មី នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល)។ តួនាទីរបស់អង្គជំនុំជម្រះមិនមែនបំពេញចន្លោះប្រហោងរបស់សហព្រះរាជ

[154] ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៥ **ឯកសារ E1/489.1** ទំព័រ ១១ ប្រហែលម៉ោង 09.34.07។

[155] សូមមើលបញ្ជីឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃការស៊ើបសួរនៃសំណុំរឿង ០០៤ នៅតាមវែបសាយនៃ អ.វ.ត.ក : https://www.eccc.gov.kh/fr/case/topic/655។

[156] ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៥ **ឯកសារ E1/489.1** ទំព័រ ១៥ ប្រហែលម៉ោង 09.42.40 និង ទំព័រ ១៦ ប្រហែលម៉ោង 09.44.07។

[157] ដីកាតែមួយគត់ពាក់ព័ន្ធនឹងសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនពីរ ដាក់ដោយសហព្រះរាជអាជ្ញាទាក់ទងនឹងខ្មែរកម្ពុជាក្រោម និងការសម្លាប់រង្គាលដែលបានធ្វើឡើងនៅក្នុងស្រុកបាកាន (ខេត្តពោធិសាត់) ព្រមទាំងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យស៊ើបសួរបន្ថែមលើអំពើប្រល័យពូជសាសន៍ខ្មែរកម្ពុជាក្រោម និងជនជាតិវៀតណាម ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ **ឯកសារ D250/3/3** កថាខណ្ឌ ៧-៩។ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ **ឯកសារ D250/3/3**។

អាជ្ញា ក្នុងដំណាក់កាលស៊ើបអង្កេតនៃសំណុំរឿង ០០២ ឬក៏ជួយពង្រឹងបុព្វហេតុរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០៣ និង ០០៤ នោះដែរ។

## ខ. ការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍

១៧១. ដោយសហចៅក្រមស៊ើបអង្កេតមិនបានបញ្ជូនជនជាប់ចោទទៅជំនុំជម្រះចំពោះអង្គហេតុនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ដូច្នេះ អង្គជំនុំជម្រះមិនបានទទួលបណ្ដឹងពីអង្គហេតុនេះទេ។

### 1. ការស៊ើបអង្កេត

១៧២. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅក្នុងដីកាដំណោះស្រាយ ថាការរំលោភសេពសន្ថវៈត្រូវបានប្រព្រឹត្ត ក្នុងកាលៈទេសៈផ្សេងៗ (ជាពិសេសនៅ ក្រាំងតាចាន់ ស.២១ និងនៅតាមបណ្ដាសហករណ៍ត្រាំកក់) មុននឹងប្រកាសថាខ្លួនចាត់ទុកថា៖

> “គោលនយោបាយផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ គឺដើម្បីបង្ការបទឧក្រិដ្ឋនេះ និងដាក់ទណ្ឌកម្មដល់ចារី។ ពិតណាស់ ទោះបីជាគោលនយោបាយនេះមិនអាចឈានទៅដល់ការរារាំងការរំលោភសេពសន្ថវៈក៏ដោយ ក៏គេមិនអាចចាត់ទុកថា ការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រើប្រាស់ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីដាក់ឱ្យអនុវត្តផែនការរួមឡើយ។ ក៏ប៉ុន្តែ ករណីនេះខុសពីបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដូចរៀបរាប់ខាងក្រោម”[158]។

[158] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២៦-១៤២៩។

១៧៣. អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតបានសម្រេចមិនបញ្ជូនជនជាប់ចោទទៅជំនុំជម្រះចំពោះអង្គហេតុទាំងអស់នេះ គឺខុសពីអង្គហេតុនៃការរំលោភសេពសន្ថវៈ ដែលទំនងជាកើតឡើងក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍[159]។

១៧៤. ដោយហេតុថាសហព្រះរាជអាជ្ញាមិនបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដើម្បីជំទាស់នឹងដីកាលើកលែងការចោទប្រកាន់ដោយផ្នែក[160] ដីកានេះបានក្លាយជាអាជ្ញាអស់ជំនុំ ចាប់ពីថ្ងៃផុតកាលកំណត់អនុញ្ញាតឱ្យប្ដឹងឧទ្ធរណ៍។ ជាក់ស្ដែង ខុសពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនមានអំណាចជាអាជ្ញាអស់ជំនុំទៅលើអង្គសេចក្ដី (ដោយហេតុថាដីកាបញ្ជូនរឿងទៅជំនុំជម្រះមានតួនាទីត្រឹមតែសង្កេតមើល ថាតើមានបន្ទុកគ្រប់គ្រាន់ដែលគាំទ្រដល់ការបញ្ជូនទៅជំនុំជម្រះ[161]) ដីកាលើកលែងការចោទប្រកាន់ដែលមានសំអាងហេតុ មានអំណាចជាអាជ្ញាអស់ជំនុំ។ លើកលែងតែមានការបើកកិច្ចការស៊ើបសួរថ្មីលើអង្គហេតុថ្មី អំណាចនៃអាជ្ញាអស់ជំនុំមិនអនុញ្ញាតឱ្យមានការចោទប្រកាន់ជាថ្មី[162] ចំពោះអង្គហេតុដដែល ទោះបីជាស្ថិតក្នុងប្រភេទបទល្មើសណាក៏ដោយ។ ការ

---

[159] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៤, ១៥៤៥, ១៥៤៨, ១៥៥១, ១៥៥៤, ១៥៥៩ (សូមមើលផងដែរ កថាខណ្ឌ ៩២៦-៩២៧ និង ១១៨១)។

[160] ចៅក្រមស៊ើបសួរបានប្រកាសយ៉ាងច្បាស់លាស់ពីការលើកលែងការចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយ ដោយបង្ហាញពីសម្អាងហេតុ នៃសេចក្ដីសម្រេចរបស់ខ្លួន ហើយថែមទាំងចាត់ទុកថា ជាសេចក្ដីសម្រេចលើកលែងការចោទប្រកាន់ដោយមិនបាច់ចែង។ សេចក្ដីសម្រេចនេះអាចប្ដឹងឧទ្ធរណ៍បាន។ សូមមើលឧទាហរណ៍ ៖ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៤ លេខ 93-82613 **ឯកសារ E306/7/3/1/2.1.1**, តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០២ លេខ 01-86956 **ឯកសារ E306/7/2.1.2**។

[161] ជាឧទាហរណ៍ ៖ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ លេខ 96-82087 និង 96-83708 **ឯកសារ E306/7/3/1/2.1.2**។

[162] វិធាន ៧០ នៃ វិធានផ្ទៃក្នុង (« នៅពេលដែលមានបន្ទុកថ្មីលេចឡើង បន្ទាប់ពីដីកាលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើប-អង្កេតបានចូលជាស្ថាពរ ការស៊ើបសួរអាចនឹងត្រូវចាប់ផ្ដើមឡើងវិញដោយសហចៅក្រមស៊ើបអង្កេត តាមគំនិតផ្ដួចផ្ដើមរបស់សហព្រះរាជអាជ្ញា។»)។ មាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (« ក្រោយពេលដែលដីកាលើកលែងចោទប្រកានរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាលើកលែងចោទប្រកាន់របស់សភាស៊ើបសួរបានចូលជាស្ថាពរ ប្រសិនមានលេចឡើងបន្ទុកថ្មី ការស៊ើបសួរអាចបើកឡើងវិញ តាមការផ្ដើមគំនិតរបស់ព្រះរាជអាជ្ញា។»), មាត្រា ១៨៨ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង (« ជនត្រូវចោទ ដែលត្រូវសភាស៊ើបសួរបានសម្រេចថាលើកលែងការចោទប្រកាន់មិនអាចត្រូវចោទប្រកាន់ចំពោះអង្គហេតុដដែលនោះទេ វៀរលែងតែមានការដាក់បន្ទុកថ្មី ») និង មាត្រា ១៩០ ក្រមនីតិវិធីព្រហ្មទណ្ឌដដែលនេះ (« មានតែអយ្យការតែមួយគត់ដែលអាចសម្រេចថាតើត្រូវបើកការស៊ើបសួរជាថ្មីចំពោះការដាក់បន្ទុកថ្មី »)។ សូមមើលផងដែរ ៖ តុលាការកំពូល-សភាព្រហ្មទណ្ឌ

បើកកិច្ចស៊ើបសួរថ្មីដែលបិទបញ្ចប់ដោយដីកាលើកលែងការចោទប្រកាន់ ជាមធ្យោបាយតែមួយគត់ដែលធ្វើឱ្យដីកានេះក្លាយជាអាជ្ញាអស់ជំនុំ។ ដូច្នេះ ប្រការនេះដកការចោទប្រកាន់ថ្មីតាមរយៈការទទួលបណ្តឹងដោយផ្ទាល់របស់អង្គជំនុំជម្រះ[163]។

១៧៥. ក្នុងករណីនេះ ដីកាលើកលែងការចោទប្រកាន់ដោយផ្នែក ចំពោះអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ត្រូវបានចូលជាស្ថាពរមុនពេលដែលអង្គជំនុំជម្រះបានទទួលបណ្តឹងពីអង្គហេតុនេះនៅក្នុងដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ។ ដោយហេតុថាសហព្រះរាជអាជ្ញាមិនបានសុំបើកការស៊ើបអង្កេតជាថ្មីលើអង្គហេតុថ្មី នីតិវិធីទាក់ទងនឹងអង្គហេតុរំលោភសេពសន្ថវៈក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ បានបិទបញ្ចប់ជាច្រើនសប្តាហ៍មុនពេលបញ្ជូនជនជាប់ចោទនៅជំនុំជម្រះ។

## 2. <u>ការជំនុំជម្រះសេចក្តី</u>

១៧៦. ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១ ជាការឆ្លើយតបនឹងសារណាសហព្រះរាជអាជ្ញា និង "ដោយយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានហេតុផលមិនគ្រប់គ្រាន់ ក្នុងការ<u>មិនចោទប្រកាន់លើជនជាប់ចោទ</u>ពីបទរំលោភសេពសន្ថវៈ ក្នុងបរិបទផ្សេងក្រៅពីបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[164]" ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឱ្យអង្គជំនុំជម្រះ "កំណត់ប្រភេទបទល្មើស" លើអង្គហេតុទាំងអស់នេះឡើងវិញ ទោះបីជាខ្លួនទទួលស្គាល់ថា "សហចៅក្រមស៊ើបអង្កេតមិនបានបញ្ជូនអង្គហេតុទាំងនេះទៅ<u>អង្គជំនុំជម្រះក៏ដោយ</u>" [165]។

ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩ លេខ 08-84321 **ឯកសារ E306/7/3/1/2.1.3**។ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០១ លេខ 00-84408 **ឯកសារ E306/7/3/1/2.1.4**.

[163] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៨០ លេខ 79-94326 **ឯកសារ E306/7/3/1/2.1.5**។ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៩៧ លេខ 96-81.375 **ឯកសារ E306/7/3/1/2.1.6**។

[164] ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១ **ឯកសារ E99/1** កថាខណ្ឌ ៤០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[165] ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១ **ឯកសារ E99/1** កថាខណ្ឌ ៣២ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

១៧៧. នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ គឺរយៈពេលបីសប្តាហ៍ក្រោយការកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២[166] អង្គជំនុំជម្រះបានបដិសេធសំណើនេះ ដោយចាត់ទុកថាវាជាសំណើសុំពង្រីកវិសាលភាពនៃការចោទប្រកាន់ និងគ្មានមូលដ្ឋានច្បាប់[167]។

១៧៨. នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះមិនត្រឹមតែបានរំឭកពីសេចក្តីសម្រេចឆ្នាំ ២០១៤ របស់ខ្លួនប៉ុណ្ណោះទេ គឺថែមទាំងបានបញ្ជាក់ជាថ្មីទៀតថា ទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ មិនជាប់ពាក់ព័ន្ធនឹងអង្គហេតុរំលោភសេពសន្ថវៈ ដែលបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ចំតែម្តងទេ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានកត់សម្គាល់ថា "ការណ៍ដែលអំពើរំលោភសេពសន្ថវៈអាចកើតមានឡើងបាន អាចមានភាពពាក់ព័ន្ធ ដើម្បីបង្ហាញអំពីល័ក្ខខ័ណ្ឌនៅមន្ទីរក្រាំងតាចាន់"[168]។

១៧៩. នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើសុំឱ្យ "បញ្ជាក់អំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ស្តីអំពីការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ ដែលត្រូវបានប្រព្រឹត្តក្នុងបរិបទផ្សេងក្រៅពីបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"។ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា អង្គជំនុំជម្រះបានទទួលបណ្តឹងពីអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍ ហើយមានកាតព្វកិច្ចសម្រេចលើអង្គហេតុនេះ ដោយមិនចងភ្ជាប់ដោយការកំណត់ប្រភេទបទចោទរបស់ចៅក្រមស៊ើបអង្កេតនោះទេ[169]។

១៨០. នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ ក្រុមមេធាវីការពារក្តីបានឆ្លើយតបថា អង្គជំនុំជម្រះត្រូវបដិសេធសំណើក្លែងរូបឱ្យពិនិត្យឡើងវិញនូវសេចក្តីសម្រេចចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ពីព្រោះអង្គ

---

[166] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1** និង ឧបសម្ព័ន្ធ ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះ សំណុំរឿងលេខ០០២/០២ ចុះ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1.1**។

[167] អនុស្សរណៈ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E306** កថាខណ្ឌ ៣។

[168] សេចក្តីសម្រេច ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E348/4** កថាខណ្ឌ ១១។

[169] សារណារបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E306/7**។

ជំនុំជម្រះមិនដែលទទួលបានបណ្តឹងពីអង្គហេតុទាំងនេះទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសម្រេចលើអង្គហេតុទាំងនេះឡើយ[170]។

១៨១. នៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានអះអាងបញ្ជាក់ថា ខ្លួនមិនបានទទួលបណ្តឹងពីអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅការរៀបអាពាហ៍ពិពាហ៍ ហើយថាខ្លួនពុំមានសិទ្ធិពង្រីកការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទទេ[171]។ អង្គជំនុំជម្រះក៏កត់សម្គាល់ថា នៅក្នុងដីកាដំណោះស្រាយ "ពុំមានឧក្រិដ្ឋកម្មណាមួយដែលចោទប្រកាន់លើជនជាប់ចោទ ដោយផ្អែកលើអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ។ ការបកស្រាយនេះមានមូលដ្ឋានរឹងមាំ តាមរយៈទម្រង់នៃការចូលរួមដែលកំណត់យកនៅក្នុងដីកាដំណោះស្រាយ ដែលពាក់ព័ន្ធតែឧក្រិដ្ឋកម្មប្រព្រឹត្តក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំប៉ុណ្ណោះ"[172]។

១៨២. នៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៦ ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចចុងក្រោយនេះរបស់អង្គជំនុំជម្រះ ដោយផ្តល់សំអាងហេតុថាសេចក្តីសម្រេចនេះមានអានុភាពបញ្ចប់ការចោទប្រកាន់ទាក់ទងនឹងអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍[173]។ ដើមបណ្តឹងរដ្ឋប្បវេណីបានកត់សម្គាល់ពីអសង្គតភាពរបស់អង្គជំនុំជម្រះដែលយល់ឃើញថាអង្គហេតុដែលមិនបានប្តឹងមកខ្លួនមានភាពពាក់ព័ន្ធ[174]។ ដើមបណ្តឹងរដ្ឋប្បវេណីផ្តោតសំខាន់ទៅលើព្យសនកម្មដែលខ្លួនបានទទួលរង ដោយលើកឡើងច្រើនជាងគេអំពីសំណួរដែលខ្លួនបានសួរក្នុងសវនាការ ទាក់ទងនឹងការរំលោភសេពសន្ថវៈ និងការប្រព្រឹត្តិខុសសីលធម៌នៅមន្ទីរ

---

[170] ចម្លើយតបរបស់ ខៀវ សំផន ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៦ **ឯកសារ E306/7/1**។

[171] សេចក្តីសម្រេច ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E306/7/3**។

[172] សេចក្តីសម្រេច ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E306/7/3** កថាខណ្ឌ ១៥។

[173] បណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/1** ជូនដំណឹងនៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦។

[174] បណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/1** កថាខណ្ឌ ៦៦ និង ៧៧។

ស.២១[175] ដោយភ្ជាប់ព័ត៌មានលម្អិតនៃសំណួរទាំងនេះ និងពេលវេលាដែលខ្លួនបានចំណាយ នៅក្នុងឧបសម្ព័ន្ធនៃបណ្តឹងសាទុក្ខរបស់ខ្លួន[176]។

១៨៣. នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ក្រុមមេធាវីការពារក្តីបានឆ្លើយតបថា បណ្តឹងសាទុក្ខភ្លាមៗមិនអាចទទួលយកបានទេ ដោយមូលហេតុថាសេចក្តីសម្រេចដែលរងបណ្តឹងនេះមិនមានអានុភាពបញ្ចប់នីតិវិធីទាក់ទងនឹងអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ដោយហេតុថា អង្គជំនុំជម្រះគ្រាន់តែកត់សម្គាល់ជាថ្មីម្តងទៀតថា នីតិវិធីនេះបានចប់សព្វគ្រប់ នៅដំណាក់កាលស៊ើបអង្កេត ហើយថាអាស្រ័យហេតុនេះ ខ្លួនមិនដែលធ្លាប់បានទទួលបណ្តឹងពីអង្គហេតុនេះទាល់តែសោះ[177]។ ទោះយ៉ាងណាក្តី អង្គជំនុំជម្រះបានយល់ស្របជាមួយដើមបណ្តឹងរដ្ឋប្បវេណីថា វាមានបញ្ហានៅពេលខ្លួនពិចារណាថាអង្គហេតុដែលមិនបានប្តឹងមក អាចមានភាពពាក់ព័ន្ធ មុននឹងប្រកាសថា ជាអកុសល បញ្ហានេះមិនអាចលើកឡើងក្នុងក្របខណ្ឌនៃបណ្តឹងសាទុក្ខភ្លាមៗ។ ក៏ប៉ុន្តែ ក្រុមមេធាវីការពារក្តីបានកត់សម្គាល់ថា បញ្ហាដដែលៗនេះ ដែលកើតមានចំពោះមុខអង្គជំនុំជម្រះ មិនដែលចោទជាបញ្ហាម្តងណាសោះសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងអង្គហេតុផ្សេងទៀត[178] ។

១៨៤. នៅថ្ងៃដដែល សហព្រះរាជអាជ្ញាបានឆ្លើយតបថា បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចទទួលយកបាន ក្រោមមូលហេតុពីរ៖ ១) ដោយសារអង្គជំនុំជម្រះមិនដែលបានទទួលបណ្តឹងពីអង្គហេតុទាំងនេះ ដូច្នេះ មិនមាននីតិវិធីណាអាចនឹងត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចនេះឡើយ។ ២) បណ្តឹងសាទុក្ខនេះធ្វើឡើងយឺតពេល បើយោងទៅវិធាន ១០៧ (១) នៃវិធានផ្ទៃក្នុង

[175] បណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/1** កថាខណ្ឌ ៩៣។

[176] ឧបសម្ព័ន្ធ ខ ពេលវេលាដែលសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានចំណាយលើការពិនិត្យ ពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ នៅមន្ទីរសន្តិសុខ ស--២១ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/1.1.2**។

[177] ចម្លើយតបរបស់ ខៀវ សំផន ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/2**។

[178] ចម្លើយតបរបស់ ខៀវ សំផន ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/2** កថាខណ្ឌ ៣៩។

ពីព្រោះអង្គជំនុំជម្រះបានសម្រេចពីរដងរួចមកហើយលើបញ្ហាដដែលនេះ មុននឹងចេញសេចក្តីសម្រេចដែលរងបណ្តឹងសាទុក្ខនេះ[179]។

១៨៥. នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧ អង្គជំនុំជម្រះតុលាការកំពូលបានវិនិច្ឆ័យថា បណ្តឹងសាទុក្ខនេះមិនអាចទទួលយកបាន អនុលោមតាមវិធាន ១០៧ (១) នៃវិធានផ្ទៃក្នុង ដោយសារតែបណ្តឹងសាទុក្ខបានធ្វើឡើងយឺតពេល[180]។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ដើមបណ្តឹងរដ្ឋប្បវេណីគួរតែដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះសាលាដំបូងលើប្រធានបទដដែលនេះ ពោលគឺសេចក្តីសម្រេចចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ និងបានវាយតម្លៃថាវាគ្មានប្រយោជន៍អ្វីក្នុងការពិចារណាលើបញ្ហាដទៃទៀតនោះទេ[181]។

១៨៦. ការណ៍ដែលតុលាការកំពូលមិនបានសម្រេចលើបញ្ហាដែលលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីមិនផ្លាស់ប្តូរអ្វីទាល់តែសោះ ព្រោះថា ក្រុមមេធាវីការពារក្តី សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះប្រាកដច្បាស់ណាស់ថា អង្គជំនុំជម្រះមិនដែលទទួលបានបណ្តឹងពីអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍នោះទេ។ ក៏ប៉ុន្តែ យើងគួរគប្បីបង្អង់ពេលបន្តិចទៅលើការពិចារណារបស់ព្រះរាជអាជ្ញា ក្នុងការជំទាស់នឹងបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលការពិចារណានេះបង្ហាញអំពី ក) គំនិតពុតត្បុតរបស់ខ្លួន និង ខ) អសង្គតភាពរបស់អង្គជំនុំជម្រះដែលយល់ថាអង្គហេតុដែលខ្លួនទទួលស្គាល់ថាមិនបានប្តឹងមកខ្លួន មានភាពពាក់ព័ន្ធ។

## 2.ក. **គំនិតពុតត្បុតរបស់សហព្រះរាជអាជ្ញា**

១៨៧. ក្នុងការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញាផ្តល់មេរៀនច្បាប់ដ៏ពិតប្រាកដមួយ ដែលអង្គជំនុំជម្រះខ្លួនឯងគួរត្រូវចងចាំ និងអនុវត្ត។ ជាក់ស្តែង ដោយយក

---

[179] ចម្លើយតបរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/3**។

[180] ចម្លើយតបរបស់ព្រះរាជអាជ្ញាតុលាការកំពូល ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧ **ឯកសារ E306/7/3/1/4**។

[181] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧ **ឯកសារ E306/7/3/1/4** កថាខណ្ឌ ២៩-៣០។

តាមខ្សែគំនិតរបស់ក្រុមមេធាវីការពារក្ដីនៅក្នុងការឆ្លើយតបទៅដើមបណ្ដឹងរដ្ឋប្បវេណី[182] និងនៅក្នុងផ្នែកមុនៗនៃសាលក្រមសេចក្ដីសន្និដ្ឋានបញ្ចប់ការជំនុំជម្រះ[183] សហព្រះរាជអាជ្ញាបាននិយាយលម្អិតអំពីហេតុផលច្បាប់ដែលត្រូវយកមកអនុវត្តចំពោះការប៉ុនប៉ងពង្រីកវិសាលភាពនៃការចោទប្រកាន់របស់ខ្លួនផ្ទាល់។

១៨៨. សហព្រះរាជអាជ្ញាបានបង្ហាញថា ស្របតាមច្បាប់ជាធរមាន អង្គជំនុំជម្រះ "មិនដែលបានទទួលបណ្ដឹង[184]" អំពីអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ទេ។ សហព្រះរាជអាជ្ញាបានពន្យល់ថា សហចៅក្រមស៊ើបអង្កេតបានចេញដីកាលើកលែងការចោទប្រកាន់ចំពោះអង្គហេតុទាំងនេះ ដោយសារយល់ឃើញថា ជនជាប់ចោទមិនអាចចាប់ឱ្យទទួលខុសត្រូវចំពោះអង្គហេតុទាំងនេះ ដោយសារពុំមានទម្រង់នៃការចូលរួមណាមួយ[185]។ សហព្រះរាជអាជ្ញាបានអះអាងថាខ្លួន "តែងតែយល់ដីកាដំណោះស្រាយ" តាមរបៀបនេះ[186]។

១៨៩. ការអះអាងចុងក្រោយនេះ មិនត្រឹមត្រូវទាំងស្រុងនោះទេ។ ជាក់ស្ដែង ទោះបីជាសហព្រះរាជអាជ្ញាយល់បែបនេះតាំងពីពេលបើកសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២/០២ ក៏ដោយ ក៏នៅឆ្នាំ ២០១១ និងឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានអះអាងថា អង្គហេតុនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ "ជាផលវិបាកដែលអាចគ្រោងទុកបាននៃសហឧក្រិដ្ឋកម្មរួម"[187]។

---

[182] ចម្លើយរបស់មេធាវីការពារក្ដី លោក ខៀវ សំផន ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E306/7/1** និង ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/2**។

[183] សូមមើលខាងលើ កថាខណ្ឌ ៦០-១៤៨។

[184] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/3** កថាខណ្ឌ ១៧។

[185] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/3** កថាខណ្ឌ ២២ (និង ២៣-២៤)។

[186] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/3** កថាខណ្ឌ ២៥។

[187] សំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ **ឯកសារ E99** កថាខណ្ឌ ៣២ («អង្គហេតុជាក់ស្ដែងនានាដូចបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ក៏កំណត់ឱ្យឃើញផងដែរអំពីការរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងកាលៈទេសៈខុសគ្នាជាច្រើន ដែលស្ថិតនៅខាងក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ ជាការគួរឱ្យកត់សម្គាល់នៅតាមមន្ទីរសន្តិសុខ និងសហករណ៍នានា។ មិនដូចការរំលោភសេពសន្ថវៈ ក្នុងបរិបទចំណងអាពាហ៍ពិពាហ៍ដោយបង្ខំទេ បទឧក្រិដ្ឋជាក់លាក់មួយនេះ ត្រូវបានប្រព្រឹត្តឡើងដោយមិនមានការដាក់ទណ្ឌកម្មជាក់ស្ដែងដោយ បកក

១៩០. ទោះយ៉ាងណាក្តី ចាប់តាំងពីពេលនោះមក សហព្រះរាជអាជ្ញាបានយល់យ៉ាងច្បាស់ថា អង្គជំនុំជម្រះមិនអាចសម្រេចលើអង្គហេតុទាំងអស់ដែលមិនបានប្ដឹងមកខ្លួន ទោះបីជាសហព្រះរាជអាជ្ញាមានការប៉ុនប៉ងក្នុងគោលបំណងនេះក៏ដោយ។

១៩១. ជាក់ស្តែង សហព្រះរាជអាជ្ញាបានពន្យល់ថា ការបកស្រាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលថា អង្គជំនុំជម្រះបានទទួលបណ្តឹងលើរឿងក្តីអំពីអង្គហេតុទាំងអស់ដែលមានរៀបរាប់ក្នុងដីកាដំណោះស្រាយ កើតចេញពី "ការយល់ច្រឡំ[188]" ព្រោះថា ស្របតាមវិធានផ្ទៃក្នុង អង្គជំនុំជម្រះបាន "ទទួលបណ្តឹងតែពីអង្គហេតុ*កំណត់យក*ប្រឆាំងនឹង*ជនជាប់ចោទ* នៅក្នុងដីកាដំណោះស្រាយប៉ុណ្ណោះ" (គូសបន្ទាត់ពីក្រោមនៅក្នុងច្បាប់ដើម)[189]។

១៩២. សហព្រះរាជអាជ្ញាបានបន្ថែមទៀតថា ដីកាដំណោះស្រាយត្រូវតែបញ្ជាក់ជាចាំបាច់អំពីអង្គហេតុចោទប្រកាន់ និងការកំណត់ប្រភេទបទល្មើស ដែលកំណត់យកដោយសហចៅក្រមស៊ើបអង្កេត ដើម្បីធានាសិទ្ធរបស់ជនជាប់ចោទក្នុងការទទួលបានព័ត៌មានជាក់លាក់ និងគ្រប់ជ្រុងជ្រោយ អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ឱ្យស្របតាមសិទ្ធត្រៀមលក្ខណៈការពារខ្លួន[190]។

---

ទេ (*sic*)។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ឧក្រិដ្ឋកម្មបែបនេះ គឺជាផលវិបាកដែលគេអាចទាយទុកជាមុនបានអំពីសហឧក្រិដ្ឋកម្មរួម ដោយហេតុថា វាមានការពាក់ព័ន្ធនឹងការបាត់បង់ភាពជាមនុស្ស ការធ្វើទារុណកម្ម និងការបន្ទាបបន្ថោកដោយគិតទុកជាមុនចំពោះមនុស្សដែលគេហៅថា "ពួកសមាសភាពមិនល្អ"។»)។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ **ឯកសារ E1/240.1** ទំព័រ ២៤ ជាភាសាខ្មែរ (ពីព្រោះមិនត្រឹមត្រូវជាភាសាបារាំង) បន្ទាប់ពីម៉ោង 10.12.17 (នៅក្នុងសវនាការបឋម ព្រះរាជអាជ្ញាបានអះអាងថា សហឧក្រិដ្ឋកម្មរួម ប្រភេទទី៣ មានសារៈសំខាន់ណាស់ ហើយអាចជាផលប៉ះពាល់ទៅលើសំណុំរឿង ០០២/០២ ដោយផ្តល់ជាឧទាហរណ៍អំពីការរំលោភសេពសន្ថវៈដូចតទៅ ៖ « *បទរំលោភសេពសន្ថវៈនៅក្នុងរឿងក្តី០០២/០២ នោះក៏ត្រូវបានចាត់ទុកថាគឺជាផលវិបាកធម្មតា ហើយអាចប្រមើលមើលបាននៃផែនការនៃការធ្វើទុក្ខបុកម្នេញនៃការសម្លាប់នៃការធ្វើទារុណកម្ម ហើយនិងការបង្ខិតបង្ខំស្រករឱ្យរៀបការនោះ។* »)។

[188] ចម្លើយតបរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/3** កថាខណ្ឌ ២៦។

[189] ចម្លើយតបរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/3** កថាខណ្ឌ ២៧។

[190] ចម្លើយតបរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/3** កថាខណ្ឌ ២៧-២៨។

១៩៣. សហព្រះរាជអាជ្ញាបានរំឭកទៀតថា អង្គជំនុំជម្រះពុំមានសិទ្ធិអំណាចកំណត់ប្រភេទបទល្មើស ចំពោះអង្គហេតុណាដែលសហចៅក្រមស៊ើបអង្កេតមិនបានកំណត់នៅក្នុងដីកាដំណោះស្រាយនោះទេ[191] ហើយសហព្រះរាជអាជ្ញាយល់ស្របជាមួយដើមបណ្តឹងរដ្ឋប្បវេណីថា អង្គជំនុំជម្រះ"មិនមានសិទ្ធិសេរីភាពក្នុងការកំណត់ប្រភេទបទល្មើសឡើងវិញ ចំពោះអង្គហេតុណាដែលមិនបានប្តឹងមកត្រឹមត្រូវតាមនីតិវិធីតាំងពីដំបូង"[192]។

១៩៤. នៅទីបញ្ចប់ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា អង្គជំនុំជម្រះ"មិនមានសមត្ថកិច្ចបន្ថែមអង្គហេតុថ្មីទៅលើវិសាលភាពនៃសំណុំរឿង ០០២/០២ ឡើយ"[193]។

១៩៥. សេចក្តីប្រកាសរបស់សហព្រះរាជអាជ្ញាមិនគ្រាន់តែត្រឹមត្រូវប៉ុណ្ណោះទេ តែថែមទាំងអាចអនុវត្តបានដោយល្អឥតខ្ចោះចំពោះអង្គហេតុស្តីពីខ្មែរក្រោម ក្នុងឋានៈជាក្រុមជាក់លាក់ ក៏ដូចជាចំពោះអង្គហេតុដទៃទៀតទាំងអស់ដែលខ្លួនចង់ឱ្យអង្គជំនុំជម្រះសម្រេច ដោយទៅហួសពីវិសាលភាពនៃបណ្តឹង។

## 2.៦. អសង្គតភាពរបស់អង្គជំនុំជម្រះ

១៩៦. ដោយឥតសង្ស័យ ការភន្តច្រឡំរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅបរិបទអាពាហ៍ពិពាហ៍ កាន់តែមានសភាពខ្លាំងឡើង ដោយសារអសង្គតភាពរបស់អង្គជំនុំជម្រះដែលចាត់ទុកថាអង្គហេតុនៅក្រៅវិសាលភាពនៃរឿងក្តី អាចមានភាពពាក់ព័ន្ធ ហើយបានបណ្តោយឱ្យដើមបណ្តឹងរដ្ឋប្បវេណីចំណាយពេលច្រើនឥតប្រយោជន៍ទៅលើបញ្ហាទាំងនេះ ក្នុងពេលសវនាការ ។

---

[191] ចម្លើយតបរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/3** កថាខណ្ឌ ៣០។

[192] ចម្លើយតបរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/3** កថាខណ្ឌ ៣១ (ដោយស្រង់កថាខណ្ឌ ៧៦ នៃបណ្តឹងសាទុក្ខនៃដើមបណ្តឹងរដ្ឋប្បវេណី)។

[193] ចម្លើយតបរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E306/7/3/1/3** កថាខណ្ឌ ៣៤។

១៩៧. អសង្គតភាពដដែលៗនេះរបស់អង្គជំនុំជម្រះ ស្តែងចេញកាន់តែច្បាស់ចំពោះអង្គហេតុនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទអាពាហ៍ពិពាហ៍ ដោយហេតុថាអង្គជំនុំជម្រះបានទទួលស្គាល់ដោយច្បាស់លាស់ជាច្រើនលើកច្រើនសាថាខ្លួនមិនបានទទួលបណ្តឹងពីអង្គហេតុនេះទេ។

១៩៨. ដូច្នេះ វាគ្មានន័យអ្វីទាំងអស់ ក្នុងការលើកឡើងថា "ប្រការដែលអង្គហេតុនៃការរំលោភសេពសន្ថវៈបានកើតឡើង អាចមានភាពពាក់ព័ន្ធ ដើម្បីបង្ហាញអំពីល័ក្ខខ័ណ្ឌជីវិតនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់"[194] និងលើកឡើងថា "ពុំមានឧក្រិដ្ឋកម្មចោទប្រកាន់ណាមួយលើជនជាប់ចោទ ដែលផ្អែកលើអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"[195]។

១៩៩. ដោយហេតុថាពុំមានឧក្រិដ្ឋកម្មចោទប្រកាន់ណាមួយផ្អែកលើអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ អង្គហេតុទាំងនេះមិនអាចមានភាពពាក់ព័ន្ធ ដើម្បីបង្ហាញអំពីឧក្រិដ្ឋកម្មណាមួយប្រឆាំងនឹងជនជាប់ចោទ ហើយវាមិនមានភាពពាក់ព័ន្ធទាល់តែសោះ។

២០០. ការសម្រេចលើអង្គហេតុទាំងនេះ ដើម្បីបង្ហាញអំពីឧក្រិដ្ឋកម្មណាមួយប្រឆាំងនឹងជនជាប់ចោទ គឺវាស្មើនឹងការកំណត់ប្រភេទបទល្មើសឡើងវិញចំពោះអង្គហេតុដែលមិនបានប្តឹងមកអង្គជំនុំជម្រះ ពោលគឺជាការកែប្រែបទចោទ តាមរយៈការដាក់បញ្ចូលអង្គហេតុថ្មី ដែលអង្គជំនុំជម្រះត្រូវបានហាមឃាត់មិនឱ្យធ្វើជាដាច់ខាត។

២០១. ការសម្រេចលើអង្គហេតុទាំងនេះ "ជាលក្ខណៈបន្ទាប់បន្សំ" ដើម្បីទុកដានប្រវត្តិសាស្ត្រ មិនមែនជាសមត្ថកិច្ចរបស់ចៅក្រមក្នុងរឿងក្តីព្រហ្មទណ្ឌទេ ហើយក៏គ្មានប្រយោជន៍ថែមទៀត ពីព្រោះដានប្រវត្តិសាស្ត្រនេះមាននៅក្នុងដីកាដំណោះស្រាយរួចស្រេចទៅហើយ។

២០២. វិនិច្ឆ័យកិច្ចរបស់យើងនេះ អាចយកជាការបានសម្រាប់គ្រប់អង្គហេតុផ្សេងទៀត ដែលមិនបានប្តឹងមកអង្គជំនុំជម្រះ ហើយដែលអង្គជំនុំជម្រះតែងតែបានយល់ព្រមស្តាប់ "បន្តិចបន្តួច" ឬ "ត្រួសៗ" ឬ "ជាលក្ខណៈទូទៅ" ដោយមិននិយាយពិស្តារ ក្នុងអំឡុងពេលសវនាការ ។ ជាក់ស្តែង

[194] សេចក្តីសម្រេច ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E348/4** កថាខណ្ឌ ១១។

[195] សេចក្តីសម្រេច ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E306/7/3** កថាខណ្ឌ ១៥។

អង្គជំនុំជម្រះមិនអាចសម្រេចលើអង្គហេតុដែលមិនបានប្ដឹងមកខ្លួន តាមរបៀប "បន្តិចបន្តួច" ឬ "ត្រួសៗ" ឬ "ជាលក្ខណៈទូទៅ" ដោយមិនបញ្ជាក់ពិស្ដារ នោះឡើយ។ អង្គជំនុំជម្រះមិនអាចធ្វើបែបនេះបានទាល់តែសោះ។

២០៣. អស្រ័យហេតុនេះ នៅពេលពិភាក្សាសម្រេច អង្គជំនុំជម្រះត្រូវដកធាតុផ្សំទាំងអស់ដែលខ្លួនព្រមទទួលយក និងស្ដាប់ (តិចក្ដី ឬច្រើនក្ដី) ទាក់ទងនឹងអង្គហេតុនៅក្រៅដែនបណ្ដឹងដែលខ្លួនបានទទួល។

## ២. ធាតុផ្សំនៃអង្គហេតុដែលអង្គជំនុំជម្រះបានជម្រុះចោល

២០៤. ពេលសម្រេចបំបែកការចោទប្រកាន់ និងកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានជម្រុះចោលរាល់បទចោទ ដែលខ្លួនបានផាត់ចេញ និងបានជម្រុះចោលជាស្ថាពរកាលពីពេលថ្មីនេះ ក្នុងការសម្រេច "បង្រួម" វិសាលភាពនៃការចោទប្រកាន់នៅក្នុងសំណុំរឿង ០០២។

២០៥. ក្នុងចំណោមការចោទប្រកាន់ទាំងនេះ មានអង្គហេតុដែលសហចៅក្រមស៊ើបអង្កេតបានកំណត់ថាជាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជា នៅលើទឹកដីវៀតណាម។

២០៦. អង្គហេតុទាំងនេះមិនត្រូវបានបញ្ចូលក្នុងសំណុំរឿង ០០២/០២ តាមសំណើរបស់សហព្រះរាជអាជ្ញាទេ។ ស្របតាមហេតុផលនៃ "ភាពជាតំណាង" នៃដីកាដំណោះស្រាយ និងដើម្បីផ្ដល់ជាអនុសាសន៍លើវិសាលភាពនៃសំណុំរឿងដែលបន្តពីសំណុំរឿង ០០២/០១ សហព្រះរាជអាជ្ញាបាន៖

> "ស្នើសុំឱ្យបំបែក និងដកចេញពីវិសាលភាពនៃការពិចារណាក្នុងសំណុំរឿង ០០២ នូវរាល់ការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ពីបទ "ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើទឹកដីវៀតណាម (កថាខណ្ឌ ៨៣២ ដល់ ៨៤០)" ដោយហេតុថាការចោទប្រកាន់ទាំងនេះ ទាក់ទងនឹងអង្គហេតុដោយ

ខ្មែរ ឬមិនពាក់ព័ន្ធ ដែលមិនជាប់ទាក់ទងខ្លាំងនឹងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម ដែលរស់នៅលើទឹកដីកម្ពុជាប្រជាធិបតេយ្យ”[196]។

២០៧. ក្នុងដីកាបំបែកការចោទប្រកាន់របស់ខ្លួន អង្គជំនុំជម្រះបានផ្តល់សុពលភាពដល់សំណើរបស់សហព្រះរាជអាជ្ញាទាំងស្រុង[197]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះក៏បញ្ជាក់ក្នុងឧបសម្ព័ន្ធដែលកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២ ថា ការពិនិត្យអង្គហេតុស្តីពីជនជាតិវៀតណាម “នឹងមិនផ្តោតលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើទឹកដីវៀតណាមទេ”[198]។

២០៨. ទោះបីជាខ្លួនជាអ្នកផ្តួចផ្តើមគំនិតក្នុងការកំណត់វិសាលភាពក៏ដោយ ក៏សហព្រះរាជអាជ្ញាបានចោទសួរបុគ្គលមួយចំនួន នៅក្នុងសាលសវនាការ អំពីអង្គហេតុដែលទំនងជាបានកើតឡើងនៅលើទឹកដីវៀតណាម។ ទោះបីក្រុមមេធាវីការពារក្តីបានជំទាស់ក៏ដោយ ក៏អង្គជំនុំជម្រះបានទុកឱ្យសហព្រះរាជអាជ្ញាចោទសួរ ដោយឥតខ្វល់[199]។

---

[196] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣ **ឯកសារ E301/2** កថាខណ្ឌ ១១។ សូមមើលផងដែរ ៖ សេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ **ឯកសារ E301/5/1** កថាខណ្ឌ ២ ៖ « ដូចបានរៀបរាប់លម្អិតនៅក្នុងឯកសារ ដែលដាក់កាលពីថ្ងៃទី ៥ ខែធ្នូ ២០១៣ ទីតាំងឧក្រិដ្ឋកម្មឬព្រឹត្តិការណ៍ជាក់លាក់ទាំងឡាយដែលសហព្រះរាជអាជ្ញាបានស្នើសុំឱ្យដាក់បញ្ចូលក្នុងសំណុំរឿងលេខ០០២/០២ នោះគឺមាន ៖ [...] (២) ការប្រព្រឹត្តិមកលើជនជាតិវៀតណាម ដោយមិនរាប់បញ្ចូលនូវឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជានៅលើទឹកដីវៀតណាម [...] »។

[197] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1** កថាខណ្ឌ ៣២ និងសេចក្តីប្រកាសអនុម័ត។

[198] ឧបសម្ព័ន្ធទាក់ទងនឹងសំណុំរឿងលេខ ០០២/០២ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1.1** ទំព័រ ២ (២-iv-ខ) និង ទំព័រ ៣ (៣-xii)។

[199] សូមមើលឧទាហរណ៍ ៖ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៥៥-៥៦ ពីម៉ោង 13.51.28 ដល់ម៉ោង 13.55.56 ទំព័រ ៧០-៧១ ពីម៉ោង 14.36.57 ដល់ម៉ោង 14.40.52 (ផ្តល់សក្ខីកម្មរបស់លោក Stephen MORRIS)។ ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ៣៦-៣៨, ពីម៉ោង 11.14.44 ដល់ម៉ោង 11.20.43 (ផ្តល់សក្ខីកម្មរបស់លោក ជួន ធី)។ សូមមើលផងដែរ ៖ ប្រតិចារឹក ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/478.1** ទំព័រ ១៦-១៨ ពីម៉ោង 09.53.08 ដល់ម៉ោង 09.57.09 (បន្ទាប់លោក សែម អំ ផ្តល់ចម្លើយ)។

២០៩. ជាឧទាហរណ៍[200] អង្គជំនុំជម្រះបានបណ្ដោយឱ្យសហព្រះរាជអាជ្ញាប្រើពេលយ៉ាងយូរលើអង្គហេតុទាំងនេះ ក្នុងពេលចោទសួរ Stephen MORRIS[201] ដែលអនុញ្ញាតឱ្យសហព្រះរាជអាជ្ញា KOUMJIAN ថ្លែងបែបចំអកថា៖

> "ខ្ញុំសូមកោតសរសើរពួកខ្មែរក្រហមដែលបានបើកការវាយប្រហារដ៏សម្បើមដល់ម្ល៉ឹងនៅប្រទេសវៀតណាមរហូតដល់គេអាចវង្វេងវង្វាន់នៅក្នុងនោះ[202]"។

២១០. រួចមក ក្នុងការឆ្លើយតបទៅនឹងការជំទាស់ជាថ្មីរបស់ក្រុមមេធាវីការពារក្ដី សហព្រះរាជអាជ្ញាបានថ្លែងថា៖

> "ប្រាកដហើយ ទាំងនេះមិននៅក្នុងសំណុំរឿងនោះទេ ប៉ុន្តែវាពាក់ព័ន្ធចំពោះករណីនេះ និងចំពោះសក្ខីកម្មរបស់អ្នកជំនាញ"[203]។

២១១. ក៏ប៉ុន្តែ ប្រសិនបើវាមិនមែនជាផ្នែកមួយនៃសំណុំរឿង គឺវាគ្មានភាពពាក់ព័ន្ធទេ។ វាមានតែប៉ុណ្ណឹង។ វាជាការគួរឱ្យសោកស្ដាយ ដែលសហព្រះរាជអាជ្ញាមិនបានយល់ពីវិធានមូលដ្ឋាននៃនីតិវិធីព្រហ្មទណ្ឌ... រួមទាំងចៅក្រម LAVERGNE ផងដែរ ដែលបានបង្ហែបង្អង់អស់ពេលយ៉ាងច្រើនលើអង្គហេតុទាំងនេះ[204]។

---

[200] ចំពោះឧទាហរណ៍ផ្សេងទៀត សូមមើលចម្លើយរបស់លោក អៀង ផាន ទៅនឹងសំណួររបស់ព្រះរាជអាជ្ញា (ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ២៦ បន្ទាប់ពីម៉ោង 10.48.31) និងបទបង្ហាញពីឯកសារគន្លឹះស្ដីពីជម្លោះប្រដាប់អាវុធ (ប្រតិចារឹក ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារព្រាង ទំព័រ ១២-១៣ ពីម៉ោង 09.48.11 ដល់ម៉ោង 09.52.05 ទំព័រ ១៦-២៩, ពីម៉ោង 10.04.11 ដល់ម៉ោង 10.57.22 និង ទំព័រ ៣១-៤៥ ប្រហែលម៉ោង 11.06.28 ដល់ម៉ោង 11.20.46)។

[201] ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៥៧ និង ទំព័របន្តបន្ទាប់ ចាប់ពីម៉ោង 13.55.52។

[202] ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៦០ ប.៤-៧ មុនម៉ោង 14.03.20 បន្តិច។

[203] ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៧០ ប.១៥-២០ ក្រោយម៉ោង 14.38.42 បន្តិច។

[204] ការតាំងសំណួរចំពោះ 2-TCW-1065 ដោយលោកចៅក្រម LAVERGNE : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ១០ និង ទំព័របន្តបន្ទាប់ បន្ទាប់ពីម៉ោង 09.29.59. សូមមើលខាងក្រោម កថាខណ្ឌ ៧៩៣-៨០០។

២១២. អង្គជំនុំជម្រះមិនមានកាតព្វកិច្ចបំពេញចន្លោះប្រហោងរបស់សហព្រះរាជអាជ្ញា ដែលប្រហែលជាមិនបានគិតគូរឱ្យគ្រប់ជ្រុងជ្រោយមុននឹងធ្វើសំណើស្តីអំពីវិសាលភាពនៃសំណុំរឿង ០០២/០២[205]។ ទោះជាក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះមិនអាចសម្រេចលើអង្គហេតុដែលទំនងជាបានកើតឡើងនៅលើទឹកដីវៀតណាម និងដែលមិនបានប្តឹងមកខ្លួន ហើយអាស្រ័យហេតុនេះ ជនជាប់ចោទក៏មិនត្រូវទទួលខុសត្រូវដែរ។ ដូច្នេះ អង្គជំនុំជម្រះត្រូវដកចេញពីការពិភាក្សាសម្រេច នូវរាល់ធាតុផ្សំភស្តុតាង ដែលខ្លួនមិនគួរគប្បីស្តាប់ពីអង្គហេតុទាំងនេះ។

## ៣. ធាតុផ្សំនៃអង្គហេតុដែលអង្គជំនុំជម្រះមិនបានទទួលត្រឹមត្រូវតាមនីតិវិធី

២១៣. អង្គជំនុំជម្រះត្រូវដកចេញពីការពិភាក្សាសម្រេច នូវរាល់ធាតុផ្សំពាក់ព័ន្ធនឹងអង្គហេតុ ដែលមិនបានប្តឹងមកខ្លួនត្រឹមត្រូវតាមនីតិវិធី ហើយត្រូវធ្វើមោឃភាពរាល់ការចោទប្រកាន់មានវិការៈនៃដីកាដំណោះស្រាយ ដែលជនត្រូវចោទមិនមានលទ្ធភាពប្តឹងសាទុក្ខចំពោះមុខអង្គបុរេជំនុំជម្រះ។

២១៤. ជាក់ស្តែង បើតាមយុត្តិសាស្ត្ររបស់សភាព្រហ្មទណ្ឌនៃតុលាការកំពូលបារាំង ទោះបីជាដីកាដំណោះស្រាយដែលបានចូលជាស្ថាពរហើយ មានអានុភាពលុបបំបាត់កំហុសនីតិវិធីពីមុនៗមកក៏ដោយ ក៏ប៉ុន្តែ “ដីកានេះនឹងមិនអាចលុបបំបាត់កំហុស ឬអសុក្រឹតភាពរបស់ខ្លួនបានទេ”[206]។ ដូច្នេះ អង្គជំនុំជម្រះមានកាតព្វកិច្ចពិនិត្យ និងធ្វើមោឃភាពកំហុសនៃដីកាដំណោះស្រាយដែលបានលើកឡើងចំពោះមុខខ្លួន ដោយជនត្រូវចោទដែលបានក្លាយជាជនជាប់ចោទ “ធ្វើយ៉ាងណាធានាសិទ្ធិទទួលបានឧបាស្រ័យប្រកបដោយប្រសិទ្ធភាព”[207]។

២១៥. ដូច្នេះ អង្គជំនុំជម្រះត្រូវដើរតាមមាគ៌ាដែលខ្លួនបានជ្រើសយក ពេលដែលខ្លួនបានប្រកាសថា ខ្លួនមិនទទួលបានបណ្តឹងត្រឹមត្រូវតាមនីតិវិធី ពីការចោទប្រកាន់ពីបទរំលោភបំពានលើក្រុមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហើយខ្លួនក៏បានធ្វើមោឃភាពបទបញ្ញត្តិមានវិការៈនៃដីកាដំណោះស្រាយ ទាក់ទងនឹងការ

---

[205] សូមមើលខាងក្រោម អំពីសំណើនៃព្រះរាជអាជ្ញាពាក់ព័ន្ធនឹងពុទ្ធសាសនិក កថាខណ្ឌ ១៤៨៧-១៥២១។

[206] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ លេខ 12-86306។

[207] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ លេខ 12-86306។

ចោទប្រកាន់ទាំងនេះ ដែលមិនបំពេញល័ក្ខខ័ណ្ឌសុពលភាពនៃវិធាន ៦៧-២ នៃវិធានផ្ទៃក្នុង ទោះបីជាកំហុសនីតិវិធីពីមុនៗមកត្រូវបានចាត់ទុកជាមោឃៈរួចហើយក៏ដោយ[208]។

២១៦. ករណីនេះ អង្គជំនុំជម្រះត្រូវធ្វើមោឃភាពរាល់ការចោទប្រកាន់ ដែលមិនបានប្ដឹងមកខ្លួន ឱ្យបានត្រឹមត្រូវតាមនីតិវិធី ដោយហេតុថា **ក)** អង្គហេតុទាំងនេះស្ថិតក្រៅវិសាលភាពនៃបណ្ដឹងមកកាន់សហចៅក្រមស៊ើបអង្កេត ឬដោយហេតុថា **ខ)** ពុំមានបន្ទុកគ្រប់គ្រាន់ដើម្បីបញ្ជូនទៅជំនុំជម្រះ។ ក្នុងករណីខកខានមិនបានធ្វើបែបនេះ មានន័យថាអង្គជំនុំជម្រះដកហូតពីជនជាប់ចោទនូវសិទ្ធិទទួលបានឧបាស្រ័យ និងសិទ្ធិនិយាយការពារបុព្វហេតុរបស់ខ្លួន។ បើខកខានមិនធ្វើបែបនេះ មានន័យថាអង្គជំនុំជម្រះផ្ដល់សុពលភាពដល់នីតិវិធីមួយដ៏សែនអយុត្តិធម៌ ហើយដកហូតធម្មានុរូប និងភាពគួរឱ្យជឿជាក់បានពី អ.វ.ត.ក។

## **ក. អង្គហេតុនៅក្រៅវិសាលភាពនៃបណ្ដឹងមកកាន់សហចៅក្រមស៊ើបអង្កេត**

២១៧. ប្រសិនបើមានវិស័យណាមួយដែលសហចៅក្រមស៊ើបអង្កេតធ្វើហួសដែនកំណត់ គឺជាការបំពេញកិច្ចហួសពីដែនបណ្ដឹងមកកាន់ខ្លួនដែលកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ហើយសហព្រះរាជអាជ្ញាគេចវេសមិនព្រមប្ដឹងឧទ្ធរណ៍ ក្នុងខណៈដែលមានតែខ្លួនម្នាក់តែប៉ុណ្ណោះដែលអាចប្ដឹងបាន។

២១៨. ឧបនិស្ស័យជាចៅក្រមខាងប្រវត្តិសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេត និងការងប់ងុលតែលើការស៊ើបអង្កេតដាក់បន្ទុកច្រើនជាងការស៊ើបអង្កេតដោះបន្ទុក នឹងលើកយកមកបង្ហាញ នៅក្នុងផ្នែកពាក់ព័ន្ធនៃសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនេះ។ ក៏ប៉ុន្តែ យើងគួរត្រឡប់មកនិយាយអំពីការចោទប្រកាន់មានវិការៈ ដែលធ្លាប់ជាកម្មវត្ថុនៃសារណាដាក់ជូនអង្គជំនុំជម្រះ និងដែលអង្គជំនុំជម្រះមិនបានថ្លឹងថ្លែងភាពធ្ងន់ធ្ងរនៃបញ្ហានេះ ជាអាទិ៍ អង្គហេតុអំពីការជម្លៀស និងអង្គហេតុអំពីការ "បោសសម្អាតផ្ទៃក្នុង" ជាដើម។

[208] សេចក្ដីសម្រេច ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១**ឯកសារ E122**។ សូមមើលខាងលើ កថាខណ្ឌ ៩៣។

## 1. អង្គហេតុស្តីពីការជម្លៀស

២១៩. នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញាបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលមិនមានរៀបរាប់អង្គហេតុណាមួយទាក់ទងនឹងការបញ្ជូនខ្លួនជនជាតិវៀតណាមដែលរស់នៅប្រទេសកម្ពុជាទេ[209]។ បន្ទាប់មកទៀត សហព្រះរាជអាជ្ញាបានបញ្ជូនដីកាសន្និដ្ឋានឱ្យស៊ើបសួរបន្ថែម ដែលនៅក្នុងដីកាទាំងនោះ ក៏មិនមានរៀបរាប់អំពីអង្គហេតុប្រភេទនេះដែរ[210]។

២២០. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានជាអាទិ៍ថា "មានធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគ្រប់គ្រាន់ ក្រោមទម្រង់នៃការជម្លៀស នៅខេត្តព្រៃវែង និងស្វាយរៀង និងនៅសហករណ៍ត្រាំកក់"[211]។ បើតាមសហចៅក្រមស៊ើបអង្កេត ឧក្រិដ្ឋកម្មទាំងនេះអាចត្រូវបានប្រព្រឹត្តក្នុងព្រឹត្តិការណ៍នៃការប្រឆាំងនឹងជនជាតិវៀតណាមរស់នៅប្រទេសកម្ពុជា [...] ដែលត្រូវបានបង្ខំក្រោមទ្រង់ទ្រាយធំឱ្យចាកចេញពីកន្លែងដែលពួកគេស្នាក់នៅ និងឱ្យឆ្លងព្រំដែនទៅវៀតណាមវិញ"[212]។

---

[209] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ **ឯកសារ D3** (« ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា »)។

[210] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៨ (ស្តីពីមន្ទីរសន្តិសុខនៃភូមិភាគឧត្តរ) **ឯកសារ D83**។ ចម្លើយតបរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ (មានតម្លៃស្មើនឹងបណ្តឹងលើអង្គហេតុស្តីពីការរៀបការដោយបង្ខំ) **ឯកសារ D146/3**។ សេចក្តីអនុញ្ញាតបន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ (មានតម្លៃស្មើនឹងបណ្តឹងបន្ថែម ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការរៀបការដោយបង្ខំ) **ឯកសារ D146/4**។ សេចក្តីអនុញ្ញាតបន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ (ស្តីពីការរៀបការ) **ឯកសារ D146/5**។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ (ទាក់ទិននឹងអំពើប្រល័យពូជសាសន៍លើចាម) **ឯកសារ D196**។ សេចក្តីបញ្ជាក់របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ (មានតម្លៃស្មើនឹងបណ្តឹងលើអង្គហេតុស្តីពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស) **ឯកសារ D202**។

[211] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៧។

[212] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៨។

២២១. នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ អៀង ធីរិទ្ធ និង នួន ជា បានប្ដឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ[213]។ ពួកគាត់មិនបានលើកឡើងអំពីមធ្យោបាយនៃបណ្ដឹងសាទុក្ខ ពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានកំណត់ថាជាការជម្លៀសទេ។

២២២. នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ អៀង សារី ក៏ដាក់បណ្ដឹងសាទុក្ខប្រឆាំងដីកាដំណោះស្រាយដែរ។ គាត់បានផ្ដល់អំណះអំណាងជាពិសេសថា សហចៅក្រមស៊ើបអង្កេតមិនបានទទួលបណ្ដឹងទេ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា អំពីអង្គហេតុដែលក្រោយមកត្រូវបានកំណត់ថាជាការជម្លៀសនៅក្នុងដីកាដំណោះស្រាយ។ ដោយហេតុថាសហចៅក្រមស៊ើបអង្កេតពុំមានសមត្ថកិច្ចស៊ើបអង្កេតលើអង្គហេតុទាំងនេះ អៀង សារី បានស្នើសុំឱ្យធ្វើមោឃភាព ("ឆ្វូតចោល" នៅក្នុងសំណៅដើមជាភាសាអង់គ្លេសដែលមិនមានការបកប្រែ[214]) លើកថាខណ្ឌពាក់ព័ន្ធនៃដីកាដំណោះស្រាយ គឺកថាខណ្ឌ ១៣៩៧ ដល់ ១៤០១។

២២៣. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញផ្នែកសម្រេចសេចក្ដីនៃសេចក្ដីសម្រេចរបស់ខ្លួនទៅលើបណ្ដឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ[215]។ អំឡុងពេលនោះ ដីកាដំណោះស្រាយបានចូលជាស្ថាពរ។

២២៤. នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសំអាងហេតុនៃសេចក្ដីសម្រេចរបស់ខ្លួនលើបណ្ដឹងសាទុក្ខរបស់ អៀង ធីរិទ្ធ និង នួន ជា។ អង្គបុរេជំនុំជម្រះបញ្ជាក់ជាពិសេសថា៖

---

[213] បណ្ដឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្ដី របស់លោកស្រី អៀងធីរិទ្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ **ឯកសារ D427/2/1**។ បណ្ដឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្ដីរបស់លោក នួន ជា ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ **ឯកសារ D427/3/1**។

[214] បណ្ដឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្ដីរបស់លោក អៀង សារី ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ **ឯកសារ D427/1/6** កថាខណ្ឌ ២០៤។

[215] សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ **ឯកសារ D427/2/12** (លើបណ្ដឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ និង លោក នួន ជា) **ឯកសារ D427/1/26** (លើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី) និង **ឯកសារ D427/4/14** (លើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន)។

"ជាចុងក្រោយ ទាក់ទិននឹងការជំទាស់ដែលលើកឡើងពីវិការៈនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការជំទាស់ទាំងនេះ មិនមានលក្ខណៈយុត្តាធិការនោះទេ ហេតុដូច្នេះហើយ មិនអាចទទួលយកបានទេ នៅដំណាក់កាលបុរេជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីស្របជាមួយនឹងអត្ថន័យ ទាំងមូលនៃវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង និងជំពូកទី ២ នៃច្បាប់ អ.វ.ត.ក ដែលគូសបញ្ជាក់អំពីយុត្តាធិការលើរូបបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក។ ពុំមានបញ្ញត្តិណាមួយ ក្នុងច្បាប់ អ.វ.ត.ក ឬវិធានផ្ទៃក្នុងចែងថា វិការៈដែលបានលើកឡើងនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើការពិចារណាលើអង្គសេចក្តីនានាពេលសវនាការ។ ទោះបីជាយ៉ាងណាក៏ដោយ ទទ្ធីករណ៍ទាំងនេះមិនបង្ហាញពីកង្វះយុត្តាធិការរបស់ អ.វ.ត.ក ឡើយ"[216]។

២២៥. នៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១ អៀង សារី បានគិតទុកជាមុនថាអង្គបុរេជំនុំជម្រះនឹងចេញសេចក្តីសម្រេចស្រដៀងគ្នាលើបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ ចំពោះអង្គហេតុដែលកំណត់ថាជាការជម្លៀស។ ឈរលើមូលដ្ឋាននៃសម្រង់ខាងលើ គាត់សុំឱ្យអង្គបុរេជំនុំជម្រះដក កថាខណ្ឌ ១៣៩៧ ដល់ ១៤០១ នៃដីកាដំណោះស្រាយរងបណ្តឹងសាទុក្ខ មុនពេលចាប់ផ្តើមនៃការជំនុំជម្រះ។ គាត់បញ្ជាក់ឡើងវិញទៀតថា "សហចៅក្រមស៊ើបអង្កេតមិនត្រូវបានអនុញ្ញាតឱ្យស៊ើបអង្កេតលើការជម្លៀសជនជាតិវៀតណាមនៅព្រៃវែង ស្វាយរៀង និងនៅសហករណ៍ត្រាំកក់នោះទេ"[217]។

២២៦. នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសំអាងហេតុនៃសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខរបស់ អៀង សារី[218]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការរិះគន់របស់ អៀង សារី លើចន្លោះប្រហោងនៃវិសាលភាពនៃបណ្តឹងដែលសហចៅក្រមស៊ើបអង្កេតបានទទួលចំពោះអង្គហេតុដែលត្រូវបានកំណត់ថាជាការជម្លៀស គឺជា "ការស្តីបន្ទោសដល់សហចៅក្រមស៊ើបអង្កេត [...] ថាបានកំណត់និយមន័យឧក្រិដ្ឋកម្ម ឬធាតុផ្សំឧក្រិដ្ឋកម្ម ដោយភ័ន្តច្រឡំ"។ អាស្រ័យហេតុដូចនេះ អង្គបុរេជំនុំជម្រះបានពិចារណាថា "បណ្តឹងនេះទាក់ទងនឹងការបង្ហាញ

[216] សេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ **ឯកសារ D427/3/15** កថាខណ្ឌ ៦៣។

[217] ញត្តិរបស់លោក អៀង សារី ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១ **ឯកសារ E58** កថាខណ្ឌ ១ និង ១១។

[218] សេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ **ឯកសារ D427/1/30**។

សំណុំរឿងរបស់ភាគីទាំងអស់ ហើយថាវាមិនអាចទទួលយកបាន ក្នុងឋានៈជាអញ្ញត្រកម្មអំពីយុត្តាធិការ”[219]។

២២៧. នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ អៀង សារី ទទួលមរណភាព[220]។ បណ្តឹងអាជ្ញាប្រឆាំងនឹងរូបគាត់ក៏ត្រូវរលត់[221]។

២២៨. នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានចេញដីកាបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ នៅក្នុងសំណុំរឿង ០០២។ អង្គជំនុំជម្រះក៏បានកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២[222]។ តាមរយៈការសម្រេចនេះ អង្គជំនុំជម្រះបានបញ្ជូនឱ្យភាគីនូវបញ្ជីនៃកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២។ ចំពោះអង្គហេតុដែលជាធាតុផ្សំនៃការជម្លៀស ក្រោមទម្រង់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អង្គជំនុំជម្រះបានបញ្ជាក់ថា “ការពិនិត្យនឹងផ្តោតតែលើការចាត់វិធានការលើជនជាតិវៀតណាមនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង[223]។ ដោយមិនបានពន្យល់ឱ្យបានច្បាស់លាស់អំពីមូលហេតុនៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះក៏បានពិចារណាថា អង្គហេតុដែលកំណត់ដោយសហចៅក្រមស៊ើបអង្កេតថាជាការជម្លៀស នៅសហករណ៍ត្រាំកក់ ក្រោមទម្រង់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនស្ថិតនៅក្នុងការជំនុំជម្រះក្តី ក្នុងសំណុំរឿង ០០២/០២ ទេ[224]។

២២៩. នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានរំឭកថា “ខ្លួនមិនទាន់បានសម្រេចលើអញ្ញត្រកម្មទេ” ជាពិសេសអញ្ញត្រកម្មដែលលើកឡើងដោយ អៀង សារី ពាក់ព័ន្ធនឹង “យុត្តាធិការរបស់អង្គជំនុំជម្រះ ក្នុងការចាត់ទុកអង្គហេតុនៃការជម្លៀសថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានបង្គាប់ឱ្យភាគី “បញ្ជាក់ថាតើភាគីគាំទ្រអញ្ញត្រកម្មដែលលើក

---

[219] សេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ **ឯកសារ D427/1/30** កថាខណ្ឌ ៨៣ (៩) កំណត់សម្គាល់ជើងទំព័រ ១៩៩ និង កថាខណ្ឌ ៨៥។

[220] លិខិតបញ្ជាក់មរណភាព ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ **ឯកសារ E270**។

[221] សេចក្តីសម្រេច ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ **ឯកសារ E270/1**។

[222] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1**។

[223] ឧបសម្ព័ន្ធទាក់ទងនឹងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1.1** ទំព័រ ៥។

[224] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៧។

ឡើងដោយ អៀង សារី ដែរឬយ៉ាងណា។ ប្រសិនបើគាំទ្រ សូមឱ្យបញ្ជាក់ពីគោលជំហររៀងៗខ្លួនទាក់ទងនឹងប្រធានបទនេះ”[225]។

២៣០. នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ ខៀវ សំផន បានគាំទ្រអញ្ញត្រកម្មដែលលើកឡើងដោយ អៀង សារី។ អាស្រ័យហេតុនេះ គាត់បានសុំឱ្យអង្គជំនុំជម្រះ “ប្រកាស និងវិនិច្ឆ័យថាខ្លួនមិនមានយុត្តាធិការក្នុងការជំនុំជម្រះសេចក្ដីលើអង្គហេតុជម្លៀស ក្រោមទម្រង់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនេះទេ”[226]។

២៣១. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានបដិសេធសំណើរបស់ ខៀវ សំផន ដោយមានសំអាងហេតុដូចតទៅនេះ៖

> “ទោះបីជាវិសាលភាពនៃការស៊ើបអង្កេតគួរតែជាបញ្ហាដែលត្រូវជជែកវែកញែកឱ្យដឹងខុសត្រូវក៏ដោយ ក៏បញ្ហានេះគួរតែត្រូវបានលើកឡើងមុនការបើកសវនាការ។ ក្នុងក្របខណ្ឌនៃសំណុំរឿង ០០២ អង្គជំនុំជម្រះបានទទួលដីកាបញ្ជូនរឿងឱ្យជំនុំជម្រះដែលបានចូលជាស្ថាពរ និងដែល “លុបបំបាត់មោឃភាពនៃនីតិវិធីកន្លងមក ប្រសិនបើមាន ដោយស្របតាមបទប្បញ្ញត្តិនៃវិធាន ៧៦-៧ នៃវិធានផ្ទៃក្នុង” [227]។

២៣២. ការរំឭកអំពីនីតិវិធីនេះបង្ហាញថា បញ្ហាដែលលើកឡើងដោយ អៀង សារី និងបន្ទាប់មកដោយ ខៀវ សំផន អំពីការកំណត់វិសាលភាពនៃការស៊ើបអង្កេតដោយចិត្តឯងចំពោះអង្គហេតុដែលត្រូវបានកំណត់ថាជាការជម្លៀសនៅក្នុងដីកាដំណោះស្រាយ មិនដែលត្រូវបានសម្រេចអោយអស់សេចក្ដីទាល់តែសោះ។

២៣៣. ក) ទន្ទឹមនឹងនេះ ការរំលោភបំពានលើវិធាននីតិវិធីដោយសហចៅក្រមស៊ើបអង្កេត ត្រូវបានរកឃើញយ៉ាងច្បាស់ក្រឡែត។ នៅពេលប្រកាសថាសំណើរបស់ អៀង សារី និង ខៀវ សំផន មិនអាចទទួលយកបាន នៅពេលលើកសំណើនេះ ខ) អង្គបុរេជំនុំជម្រះ បន្ទាប់មក គ) អង្គជំនុំជម្រះបានដកហូតពីជនជាប់ចោទនូវសិទ្ធិទទួលបានឧបាស្រ័យប្រឆាំងនឹងសេចក្ដីសម្រេចខុសច្បាប់ ដែល

---

[225] អនុស្សរណៈ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E306** កថាខណ្ឌ ៥។

[226] សេចក្ដីសន្និដ្ឋានមេធាវីការពារក្ដីលោក ខៀវ សំផន ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E306/2**។

[227] អនុស្សរណៈ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ **ឯកសារ E306** កថាខណ្ឌ ៩។

ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួលបានព័ត៌មានអំពីការចោទប្រកាន់ប្រឆាំងនឹងខ្លួន[228]។ ឃ) នៅដំណាក់កាលនីតិវិធីនេះ អង្គជំនុំជម្រះមិនមានជម្រើសអ្វីក្រៅពីប្រកាសថា ខ្លួនមិនមានយុត្តាធិការក្នុងការកាត់សេចក្តីលើអង្គហេតុជម្លៀស ក្រោមទម្រង់ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ។

## 1.ក. ការកំណត់វិសាលភាពនៃបណ្តឹងដោយចិត្តឯងរបស់ចៅក្រមស៊ើបអង្កេត

២៣៤. វិធាន៥៥-២ នៃវិធានផ្ទៃក្នុង ចែងថា៖

> "សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចស៊ើបអង្កេតតែលើអង្គហេតុទាំងឡាយណាដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមប៉ុណ្ណោះ។"

២៣៥. ក៏ប៉ុន្តែមិនមានផ្នែកណាមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាស្តីពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅខេត្តព្រៃវែង ខេត្តស្វាយរៀង និងសហករណ៍ត្រាំកក់[229] និងផ្នែកណាមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើអង្គហេតុដទៃទៀត[230]របស់ព្រះរាជអាជ្ញាបង្ហាញពីអង្គហេតុទាក់ទងនឹង"ជនជាតិវៀតណាមរស់នៅប្រទេសកម្ពុជា[...] ដែលមួយចំនួនធំត្រូវបានបង្ខំអោយចាកចេញពីកន្លែងដែលពួកគេរស់នៅ និងឆ្លងព្រំដែនទៅកាន់ប្រទេសវៀតណាមវិញនោះទេ"[231]។

២៣៦. ដូច្នេះ វិធាន ៥៥-២ នៃវិធានផ្ទៃក្នុង មិនត្រូវបានគោរពឡើយ៖ ចៅក្រមស៊ើបអង្កេតមិនដែលទទួលបានបណ្តឹងអំពីអង្គហេតុដែលកំណត់ថាជាការជម្លៀស ក្រោមរូបភាពជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងដីកាដំណោះស្រាយ នោះទេ។

---

[228] វិធាន ២១-១-ឃ នៃវិធានផ្ទៃក្នុង, មាត្រា ៣៣ នៃច្បាប់បង្កើត អ.វ.ត.ក។ មាត្រា ១៤ នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ៦ និង ១៣ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

[229] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤២, ៤៣ និង ៦៩-៧០។

[230] សូមមើលខាងលើ កំណត់សម្គាល់ជើងទំព័រ ២១០។

[231] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៨។

២៣៧. នៅចំពោះមុខទឡ្ហីករណ៍ដែលលើកឡើងដោយ អៀង សារី នៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១[232] សហព្រះរាជអាជ្ញាបានបរាជ័យក្នុងការខំប្រឹងព្យាយាមរើខ្លួនចេញពីស្ថានភាពលំបាក ដោយព្យាយាមអះអាងថា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មាន"មូលដ្ឋានសមស្រប" ដែលអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបសួរលើអង្គហេតុទាំងនេះបាន[233]។ សហព្រះរាជអាជ្ញាបានលើកអំណះអំណាងដូចតទៅ៖

> "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរអនុញ្ញាតជាពិសេសឱ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបសួរទៅលើការនិរទេសខ្លួន។ គេក៏មានកំណត់ផងដែរអំពីអង្គហេតុនានាដែលថា "... ប្រជាជនរាប់ម៉ឺននាក់ដែលកំពុងរស់នៅភូមិភាគបូព៌ា..." ត្រូវបាន "បង្ខំឱ្យផ្លាស់ទីលំនៅ" និងថាប្រជាជនទាំងនេះគឺរាប់បញ្ចូលទាំងប្រជាជនមកពីព្រៃវែង និងស្វាយរៀង។ ជាងនេះទៀត សហព្រះរាជអាជ្ញាបានចោទយ៉ាងជាក់លាក់លើគោលនយោបាយនៃការដាក់គោលដៅទៅលើជនជាតិវៀតណាម"[234]។

២៣៨. ដូច្នេះ ការបង្ហាញទាំងនេះផ្អែកទៅលើគោលគំនិតបី ដែលសុទ្ធតែគ្មានប្រសិទ្ធភាពទាំងអស់។

២៣៩. ដំបូង សហព្រះរាជអាជ្ញាអះអាងថា សហចៅក្រមស៊ើបអង្កេតត្រូវបានអនុញ្ញាតឱ្យស៊ើបអង្កេត "ជាពិសេស" លើអង្គហេតុជម្លៀស។ ត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាផ្អែកលើកថាខណ្ឌ ១២២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ នេះជាការប៉ុនប៉ងទាំងងងើលអំពីសំណាក់សហព្រះរាជអាជ្ញា ក្នុងការបិទបាំងសុញ្ញភាពនៃវិនិច្ឆ័យកិច្ចរបស់ខ្លួន។ ម្យ៉ាងទៀត កថាខណ្ឌ ១២២ ចែងថា ការស៊ើបអង្កេតត្រូវបានបើកឡើងតែចំពោះអង្គហេតុដែលចោទប្រកាន់នៅក្នុងកថាខណ្ឌ ៣៧ ដល់ ៧២ នៃដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ដែលពុំមានលើកឡើងអំពីអង្គហេតុជម្លៀសទាល់តែសោះ។ ដូច្នេះ គេពុំអាចប្រើកថាខណ្ឌនេះដើម្បីបញ្ជាក់បំភ្លឺអំពីវិសាលភាពនៃការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតបានទេ។ ដោយឡែក ដូចដែលសហព្រះរាជអាជ្ញាមិនអាចធ្វើមិនដឹងមិនឮ សហចៅក្រមស៊ើបអង្កេតទទួលបានបណ្តឹងតែពីអង្គហេតុប៉ុណ្ណោះ តែមិនមែនពីការកំណត់ប្រភេទបទល្មើសដែលធ្វើឡើងដោយព្រះរាជអាជ្ញាសោះ

[232] សូមមើលខាងលើកថាខណ្ឌ ២២៥។

[233] ចម្លើយរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ **ឯកសារ E58/1** កថាខណ្ឌ ២៩។

[234] ចម្លើយតបរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ **ឯកសារ E58/1** កថាខណ្ឌ ២៩ ដែលយោងជាលំដាប់លំដោយទៅនឹង កថាខណ្ឌ ១២២, ៤២ និង ៦៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា។

ឡើយ[235]។ គោលជំហរបែបនេះរបស់សហព្រះរាជអាជ្ញា គឺជាការធ្វើមិនដឹងមិនឮអំពីបុគ្គលិកលក្ខណៈជាមូលដ្ឋាននៃការស៊ើបអង្កេតដែលត្រូវស៊ើបសួរតែលើអង្គហេតុ ព្រោះថា អ្នកស៊ើបអង្កេតមានកាតព្វកិច្ច "ស៊ើបអង្កេតទាំងលើភស្តុតាងដាក់បន្ទុក និងទាំងលើភស្តុតាងដោះបន្ទុក"[236]។

២៤០. បន្ទាប់មកទៀត សហព្រះរាជអាជ្ញានិយាយអំពីការជម្លៀសដំណាក់កាលទី៣ គឺសំដៅទៅលើការជម្លៀសមនុស្សនៅភូមិភាគបូព៌ា។ ក៏ប៉ុន្តែ កថាខណ្ឌ ៤២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលសហព្រះរាជអាជ្ញាយោង បញ្ជាក់យ៉ាងច្បាស់លាស់អំពីអង្គហេតុដែលជាធាតុផ្សំនៃការជម្លៀសដំណាក់កាលទី៣។ វាគឺជាអង្គហេតុដែលក្តោបលើប្រជាជនទាំងអស់ ហើយមិនមែនតែចំពោះជនជាតិវៀតណាមជាពិសេសនោះទេ ពីព្រោះថាអង្គហេតុទាំងនេះមិនទាក់ទងទាល់តែសោះទៅនឹងការបញ្ជូនជនជាតិវៀតណាមទៅប្រទេសវៀតណាមវិញ។

២៤១. នៅទីបញ្ចប់ សហព្រះរាជអាជ្ញាបានលើកឡើងអំពីកថាខណ្ឌ ៦៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលមានបញ្ជាក់អំពីអត្ថិភាពនៃគោលនយោបាយដែលកំណត់យកជនជាតិវៀតណាមជាគោលដៅជាក់លាក់។ ក៏ប៉ុន្តែ អង្គហេតុដែលលើកឡើងទាំងនេះទាក់ទងទៅនឹងអត្ថិភាពនៃគោលនយោបាយដែលមានគោលបំណងសម្លាប់រង្គាលជនជាតិវៀតណាមទាំងនេះ ជាពិសេសគឺតាមរយៈការប្រហារជីវិត។ មិនមានលើកឡើងអំពីការជម្លៀសប្រជាជននៅត្រង់ចំណុចណាមួយនោះទេ។

២៤២. ជាក់ស្តែង សហព្រះរាជអាជ្ញាមិនបានឆ្លើយតបទៅនឹង អៀង សារី ទាក់ទងនឹងសហករណ៍ក្នុងស្រុកត្រាំកក់ទេ ដោយគ្រាន់តែទទួលស្គាល់ដោយតណ្ហីភាពនូវភាពសមហេតុសមផលនៃការអះអាងរបស់ អៀង សារី។

---

[235] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧២ លេខ 71-93622 (« ចៅក្រមស៊ើបសួរទទួលបណ្តឹងស្តីពីអង្គហេតុដែលរងការចោទប្រកាន់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយឥតជាប់ពាក់ព័ន្ធទៅនឹងការកំណត់បទចោទប្រកាន់របស់អយ្យការទៅលើអង្គហេតុទាំងនោះឡើយ។ »)៖ តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩២ លេខ 91-86066 (ចៅក្រមស៊ើបសួរ « មិនត្រូវជាប់កាតព្វកិច្ចគោរពតាមការកំណត់ទោសបណ្តោះអាសន្នទៅលើអង្គហេតុដែលធ្វើឡើងដោយរដ្ឋអាជ្ញាឡើយ »)។ សូមមើលខាងលើ កថាខណ្ឌ ១០៣-១០៤។

[236] វិធាន ៥៥-៥ នៃ វិធានផ្ទៃក្នុង។

២៤៣. ខៀវ សំផន បានលើកឡើងអំពីចំណុចទាំងអស់នេះរួចហើយ នៅក្នុងសារណារបស់គាត់ដាក់ជូនអង្គជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤[237]។ វាមានសារៈសំខាន់ក្នុងការរំឭកអំពីចំណុចទាំងអស់នេះឡើងវិញ ពីព្រោះវាបង្ហាញឱ្យឃើញថាសហចៅក្រមស៊ើបអង្កេតមិនដែលទទួលបានបណ្តឹងពីអង្គហេតុដែលក្រោយមកត្រូវបានកំណត់ថាជាការជម្លៀសនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួននោះទេ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតបែរជាចាត់ការលើអង្គហេតុទាំងនេះដោយចិត្តឯង ដោយគិតថាយ៉ាងច្រើនប្រព្រឹត្តិកំហុសនីតិវិធីជាក់ស្តែងប៉ុណ្ណោះ ប៉ុន្តែអ្វីដែលជារូបភាពពិតនោះ គឺជាការរំលោភបំពានជាក់ស្តែងទៅលើការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីតែបម្រើប្រយោជន៍សហព្រះរាជអាជ្ញា ហើយមានទំនោរស៊ើបអង្កេតរកតែភ័ស្តុតាងដាក់បន្ទុកទៅវិញ។

## 1.២. ការបដិសេធរបស់អង្គបុរេជំនុំជម្រះក្នុងការអារកាត់ឱ្យអស់សេចក្តី

២៤៤. អង្គបុរេជំនុំជម្រះបានពិចារណាថា មធ្យោបាយនៃបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយអំពីបទរំលោភបំពានអំពីសំណាក់សហចៅក្រមស៊ើបអង្កេតលើវិសាលភាពនៃបណ្តឹងដែលខ្លួនបានទទួល មិនបំពេញលក្ខខ័ណ្ឌតម្រូវនៃវិធាន ៧៤-៣-ក នៃវិធានផ្ទៃក្នុង ដែលចែងថា "ជនជាប់ចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា[...] របស់សហចៅក្រមស៊ើបអង្កេត[...]បានតែពាក់ព័ន្ធនឹងការសុំបញ្ជាក់អំពីយុត្តាធិការតែប៉ុណ្ណោះ" (ផ្លូវឧបាស្រ័យតែមួយគត់ដែលអនុញ្ញាតឱ្យជនជាប់ចោទប្តឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយ គឺផ្លូវដែលស្របតាមវិធាន ៧៤-៣-ច ដែលចែងអំពីដីកា "ស្តីអំពីការឃុំខ្លួនបណ្តោះអាសន្ន ឬការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការ")។

២៤៥. អង្គបុរេជំនុំជម្រះបានរំឭកថា នៅពេល "បកស្រាយ" វិធាន ៧៤-៣-ក" អង្គជំនុំជម្រះបាន៖

> "សន្និដ្ឋានថា នៅក្នុងការបកស្រាយវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះបានលើកឡើងកាលពីមុនថា មានតែបណ្តឹងជំទាស់យុត្តាធិការប៉ុណ្ណោះដែលអាចលើកឡើងបានក្រោមវិធាននោះ។ នៅក្នុងការសម្រេចថាអ្វីខ្លះដែលបង្កើតបានជាបណ្តឹងជំទាស់យុត្តាធិការត្រឹមត្រូវមួយ អង្គបុរេជំនុំជម្រះបានពិចារណា

[237] សូមមើលខាងលើ កថាខណ្ឌ ២៣០។

ឃើញថា អង្គជំនុំជម្រះវិសាមញ្ញ មិនដូចគ្នានឹងប្រព័ន្ធនៃច្បាប់ *civil law* ទាំងស្រុងទេ ប៉ុន្តែ "មានស្ថានភាពអាចប្រៀបធៀបបានទៅនឹងតុលាការ មិនអចិន្ត្រៃយ៍នានា"[238]។

២៤៦. ដូច្នេះ អង្គបុរេជំនុំជម្រះបានរំឭកថា បើតាមខ្លួនយល់ ឧបាស្រ័យបែបនេះអាចទទួលយកបានតែក្នុងករណីដែលម្ចាស់បណ្ដឹងឧទ្ធរណ៍លើកឡើងថា ការអនុវត្តទម្រង់ឧក្រិដ្ឋកម្ម ឬទម្រង់នៃការចូលរួម រំលោភបំពានលើគោលការណ៍នីត្យានុកូលភាព[239]។ អង្គបុរេជំនុំជម្រះបានរំឭកផងដែរថា បណ្ដឹងឧទ្ធរណ៍អំពីវិការទម្រង់នៃដីកាដំណោះស្រាយមិនអាចទទួលយកបានទេ៖

> "ពុំមានបញ្ញត្តិណាមួយនៅក្នុងច្បាប់ អ.វ.ត.ក ឬនៅក្នុងវិធានផ្ទៃក្នុងលើកឡើងថា វិការៈទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានលើកឡើងបង្ហាញពីបញ្ហាយុត្តាធិការនានានោះទេ។ ដូចនេះ ទឡ្ហីករណ៍ទាំងអស់នេះអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើការពិចារណាលើអង្គសេចក្ដីនៅពេលសវនាការ ហើយចំណុចនេះមិនបង្ហាញពីកង្វះយុត្តាធិការរបស់ អ.វ.ត.ក នោះឡើយ"[240]។

២៤៧. អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថាលើបញ្ហានេះថា មធ្យោបាយនៃបណ្ដឹងសាទុក្ខរបស់ អៀង សារី លើអង្គហេតុជម្លៀស "ពាក់ព័ន្ធទៅនឹងការបង្ហាញសំណុំរឿងរបស់ភាគី ហើយវាមិនអាចទទួលយកបានទេ ក្នុងឋានៈជាបណ្ដឹងជំទាស់នឹងយុត្តាធិការ[241]"។ បើនិយាយតាមមួយបែបទៀត គឺថា អង្គបុរេជំនុំជម្រះយល់ឃើញថាបញ្ហានេះត្រូវលើកឡើងនៅក្នុងដំណាក់កាលជំនុំជម្រះចំពោះមុខខ្លួន។

២៤៨. ការវិភាគរបស់អង្គបុរេជំនុំជម្រះនេះ ផ្អែកលើការពិចារណារបស់ខ្លួនដែលថា អ.វ.ត.ក ស្ថិតនៅក្នុងស្ថានភាពមួយស្រដៀងគ្នានឹងស្ថានភាពតុលាការចំពោះកិច្ច ជាជាងប្រព័ន្ធផ្ទៃក្នុងនៃច្បាប់ស៊ីវិល។

---

[238] សេចក្ដីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ **ឯកសារ D427/1/30** កថាខណ្ឌ ៤៥ (ដែលយោងទៅសេចក្ដីសម្រេចលើកមុនរបស់ខ្លួន ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ **ឯកសារ D97/14/15** កថាខណ្ឌ ២១ និង ២៣-២៤)។

[239] សេចក្ដីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ **ឯកសារ D427/1/30** កថាខណ្ឌ ៤៥-៤៦។

[240] សេចក្ដីសម្រេចនៃអង្គបុរេជំនុំជម្រះចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ **ឯកសារ D427/1/30** កថាខណ្ឌ ៤៧។

[241] សេចក្ដីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ **ឯកសារ D427/1/30** កថាខណ្ឌ ៨៥។

២៤៩. អង្គបុរេជំនុំជម្រះគួរតែបកស្រាយវិធាន ៧៤-៣ នៃវិធានផ្ទៃក្នុង ដោយអនុលោមតាមមាត្រា ២៥២ និង ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងថា ក្រុមប្រឹក្សាស៊ើបអង្កេតមានសមត្ថកិច្ចក្នុងការសម្រេចលើមោឃភាពដែលបានលើកឡើងដោយជនត្រូវចោទ ក្នុងករណីមិនគោរពតាមវិធាន និងទម្រង់ការដែលមានចែងជាពិសេសនៅក្នុងមាត្រា ១២៤ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) វាក្យខណ្ឌ ៣ និង ១២៥ (វិសាលភាពនៃបណ្ដឹង) វាក្យខណ្ឌ ១ និង ២ ពីព្រោះថាមាត្រា ២៥២ ចែងថា៖

> "នាំឱ្យមានមោឃភាពផងដែរ កាលណា ការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនេះ ឬបទប្បញ្ញត្តិទាំងឡាយស្ដីពីនីតិវិធីព្រហ្មទណ្ឌ ធ្វើឱ្យប៉ះពាល់ដល់ភាគីដែលទទួលរងការបំពាននេះ។ វិធាន និងទម្រង់ការដែលមានលក្ខណៈសំខាន់នោះមាន ជាអាទិ៍ គឺវិធានទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួន"។

២៥០. ជាថ្មីម្ដងទៀត អង្គបុរេជំនុំជម្រះគួរតែប្រៀបប្រដូចដីកាដំណោះស្រាយទៅនឹងដីកាសម្រេចចោទប្រកាន់នៅក្នុងច្បាប់បារាំង ដែលជនជាប់ចោទពីបទឧក្រិដ្ឋអាចប្ដឹងឧទ្ធរណ៍ចំពោះមុខក្រុមប្រឹក្សាស៊ើបអង្កេត[242]។

២៥១. ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះបែរជាប្រៀបប្រដូចដីកាដំណោះស្រាយនេះទៅនឹងបទចោទប្រកាន់នៅចំពោះមុខតុលាការចំពោះកិច្ចដែលអាចកែប្រែបាននៅដំណាក់កាលជំនុំជម្រះ ហើយដែលជនជាប់ចោទអាចលើកឡើងអំពីវិការៈនៃដីកាដំណោះស្រាយនេះរហូតដល់ដំណាក់កាលបណ្ដឹងសាទុក្ខប្រឆាំងនឹងការផ្ដន្ទាទោស[243]។

២៥២. អង្គបុរេជំនុំជម្រះបានធ្វើយុត្តិកម្មការពារខ្លួនដោយលើកឡើងថា ខ្លួនធ្វើការបកស្រាយ "ទូលាយ" នៃវិធាន ៧៤ នៃវិធានផ្ទៃក្នុងតែក្នុងករណីពិសេសបំផុតប៉ុណ្ណោះ៖

> "នៅពេលដែលបណ្ដឹងឧទ្ធរណ៍ដែលបានប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមវិធាន ៧៤ នៃវិធានផ្ទៃក្នុង លើកឡើងអំពីបញ្ហាដែលមិនអាចឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកែតម្រូវបាន និងមិនអនុញ្ញាតឱ្យ

---

[242] សូមមើលខាងលើ កំណត់សម្គាល់ជើងទំព័រ ៦២ និង កថាខណ្ឌ ១០៦-១០៧។

[243] សូមមើលខាងលើ កថាខណ្ឌ ១៤០-១៤៨។

មានលទ្ធភាពប្ដឹងឧទ្ធរណ៍នៅដំណាក់កាលនេះបាន និងបង្កការខូចខាតដែលមិនអាចជួសជុលបានដល់សិទ្ធរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌[244]”។

២៥៣. អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា បន្ទាប់ពីមាន “ការស៊ើបអង្កេតទ្រង់ទ្រាយធំ អស់រយៈពេល ៣ ឆ្នាំ” “ការបង្កើនល្បឿននីតិវិធី” មានសារៈសំខាន់ជាងការពិនិត្យមធ្យោបាយផ្សេងទៀតនៃបណ្ដឹងឧទ្ធរណ៍ ក្រៅពីមធ្យោបាយបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងយុត្តាធិការ “ក្នុងខណៈដែល[ជនជាប់ចោទ] អាចលើកអំពីបញ្ហាវិការៈចោទប្រកាន់នៃដីកាដំណោះស្រាយនៅដំណាក់កាលជំនុំជម្រះ[245]”។

២៥៤. ទោះបីជាដំណោះស្រាយដែលជ្រើសរើសយកដោយអង្គបុរេជំនុំជម្រះ មិនអាច “ពន្លឿន” នីតិវិធីដោយហេតុថា ដំណោះស្រាយនេះគ្រាន់តែពន្យារពេលដោះស្រាយបញ្ហាទាំងនេះទៅដំណាក់កាលជំនុំជម្រះក៏ដោយ ក៏យ៉ាងហោចណាស់អង្គបុរេជំនុំជម្រះមានហេតុផល តាមរយៈការផ្ដល់លទ្ធភាពទៅដល់ជនជាប់ចោទដូចនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងការជំទាស់នឹងបទចោទប្រកាន់ និងតាមរយៈយុត្តិសាស្ត្របារាំងដែលអនុញ្ញាតឱ្យជនជាប់ចោទអាចចោទប្រកាន់លើវិការៈនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលខ្លួនមិនមានលទ្ធភាពប្ដឹងឧទ្ធរណ៍ “ដើម្បីឱ្យក្រុមប្រឹក្សាជំនុំជម្រះធ្វើមោឃភាពលើដីកាដំណោះស្រាយ ធ្វើយ៉ាងណាធានាសិទ្ធិទទួលបានឧបាស្រ័យប្រកបដោយប្រសិទ្ធភាព[246] ប្រសិនបើការចោទប្រកាន់របស់ជនជាប់ចោទមានសំអាងហេតុគ្រប់គ្រាន់”។

២៥៥. ផ្ទុយទៅវិញ ដំណោះស្រាយនេះលែងមាននិរន្តភាពទៀតហើយ កាលណាក្រុមប្រឹក្សាជំនុំជម្រះដែលមានទំនួលខុសត្រូវក្នុងការសម្រេចលើបញ្ហានេះ បដិសេធមិនបំពេញភារកិច្ចរបស់ខ្លួន ដែលប្រការនេះធ្វើឱ្យខូចខាតមិនអាចជួសជុលបានដល់សិទ្ធិរបស់ជនជាប់ចោទក្នុងទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌។

---

[244] សេចក្ដីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ **ឯកសារ D427/1/30** កថាខណ្ឌ ៤៨។

[245] សេចក្ដីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ **ឯកសារ D427/1/30** កថាខណ្ឌ ៥១។

[246] តុលាការកំពូល-សភាព្រហ្មទណ្ឌ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ លេខ 12-86306 (សេចក្ដីសម្រេចដែលបានចេញ នៅក្នុងរឿងក្ដីមួយដែលនិយាយពីការផុតពេលកំណត់នៃការទទួលបណ្ដឹងរបស់ចៅក្រមស៊ើបសួរ)។ សូមមើលខាងលើ កថាខណ្ឌ ១១៣។

1.គ. ការបដិសេធមិនព្រមអារកាត់ឱ្យអស់សេចក្ដីរបស់អង្គជំនុំជម្រះ

២៥៦. ដូចដែលបានរំឭកខាងដើម នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ អៀង សារី បានស្នើសុំឱ្យអង្គជំនុំជម្រះដកកថាខណ្ឌរងការរិះគន់ចេញពីដីកាដំណោះស្រាយ ឱ្យបានមុនពេលការចាប់ផ្ដើមជំនុំជម្រះ។ ក្រោយមរណភាពរបស់គាត់ នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានផ្ដល់លទ្ធភាពដល់ ខៀវ សំផន ក្នុងការគាំទ្រអញ្ញត្រកម្មដែលលើកឡើងដោយ អៀង សារី ហើយ ខៀវ សំផន បានបំពេញកិច្ចនេះ នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។ នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានបដិសេធសំណើរបស់ ខៀវ សំផន នៅក្នុងដីកាសម្រេចលេខ E306/5។

២៥៧. ដើម្បីឈានដល់ការបដិសេធនេះ អង្គជំនុំជម្រះបានចាប់ផ្ដើមដោយរំឭកវិធាន ៧៦-៧ នៃវិធានផ្ទៃក្នុង ដែលចែងថា ដីកាដំណោះស្រាយដែលបានចូលជាស្ថាពរមានអនុភាពលុបបំបាត់មោឃភាពនៃនីតិវិធីពីមុនៗ ហើយអង្គជំនុំជម្រះបានលើកឡើងថា អញ្ញត្រកម្មដែលលើកឡើងចំពោះមុខខ្លួននេះ "គួរតែត្រូវលើកឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេត" (ឯកសារ E306/5 កថាខណ្ឌទី ៥)។ អង្គជំនុំជម្រះក៏បានរំឭកផងដែរថា ពេលខ្លះខ្លួនយល់ព្រមពិនិត្យសំណើពាក់ព័ន្ធនឹងភាពមិនប្រក្រតីផ្សេងៗដែលកើតមានឡើងក្នុងដំណាក់កាលស៊ើបអង្កេត "កាលណាការពិនិត្យនេះមានភាពចាំបាច់ដើម្បីធានាសមធម៌នៅក្នុងការជំនុំជម្រះសេចក្ដី" (ឯកសារ E306/5 កថាខណ្ឌទី ៦)។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានលើកឡើងពីធាតុផ្សំមួយចំនួនដែលធ្វើឱ្យខ្លួនជឿងជាក់ថា ជនជាប់ចោទត្រូវបាន "ជូនដំណឹងអំពីវិសាលភាពនៃការស៊ើបអង្កេត ដោយត្រឹមត្រូវតាមនីតិវិធីច្បាប់" (ឯកសារ E306/5 កថាខណ្ឌទី ៧-៨)។ នៅទីបញ្ចប់ អង្គជំនុំជម្រះបានប្រកាសថា (ឯកសារ E306/5 កថាខណ្ឌ ៩-១០)៖

> "ហេតុដូច្នេះ ខៀវ សំផន មានឱកាសអាចរកឃើញភាពមិនប្រក្រតីដែលជាបញ្ហានៅពេលនេះ។ ប្រសិនបើវិសាលភាពនៃកិច្ចស៊ើបសួរ គឺជាបញ្ហានៃភាពចម្រូងចម្រាស បញ្ហានេះគួរតែត្រូវបានលើកឡើងនៅមុនពេលបើកសវនាការ។ យោងតាមវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានទទួលដីកាដំណោះស្រាយដែលត្រូវបានកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។

១០. មេធាវីការពារក្តី ខៀវ សំផន មិនបានបង្ហាញពីបញ្ហាចំពោះការជំនុំជម្រះប្រកបដោយយុត្តិធម៌បន្ថែមទៀត ដែលតម្រូវឱ្យមានការអន្តរាគមន៍ពីអង្គជំនុំជម្រះទេ នៅដំណាក់កាលនេះ”។ (យើងជាអ្នកជាគូសបន្ទាត់ពីក្រោម)

២៥៨. ដោយបដិសេធមិនអន្តរាគមន៍ និងមិនអារកាត់បញ្ហាឱ្យអស់សេចក្តី អង្គជំនុំជម្រះបានប្រព្រឹត្ត (i) យុត្តិនីសេធ និង (ii) បានបង្ហាញអំពីភាពអគតិរបស់ខ្លួន។

### i. យុត្តិនិសេធ

២៥៩. នៅពេលសួរទៅកាន់ក្រុមមេធាវីការពារក្តីទាំងអស់ មុនពេលបើកការជំនុំជម្រះសំណុំរឿង០០២/០២ ថាតើក្រុមមេធាវីចង់គាំទ្រសំណើរបស់ អៀង សារី ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ដែរឬទេ បើទោះបីជាបណ្តឹងអាជ្ញាប្រឆាំងនឹងគាត់បានរលត់ ក្រោយមរណភាពរបស់គាត់ អង្គជំនុំជម្រះបានយល់រួចស្រេចទៅហើយ ថាបញ្ហាសមធម៌កំពុងចោទឡើង។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានវាស់វែងអំពីទំហំនៃបញ្ហានេះទេ តែបែរជាជ្រើសរើសការបែរខ្នងដាក់បញ្ហា និងពាក់ក្បាំងភ្នែកដូចសេះទៅវិញ។

២៦០. អាស្រ័យហេតុដូចនេះ អង្គជំនុំជម្រះយល់ឃើញថា បញ្ហានេះ“គួរតែលើកឡើងនៅដំណាក់កាលស៊ើបអង្កេត” (ឯកសារ E305/5 កថាខណ្ឌទី ៥) ឬ “មុនពេលបើកការជំនុំជម្រះ” (ឯកសារ E306/5 កថាខណ្ឌទី ៩)។ ការសន្និដ្ឋាននេះមានលក្ខណៈពិបាកយល់ ដោយហេតុថាវាធ្វើឱ្យសំណួររបស់អង្គជំនុំជម្រះលែងបានការ នៅពេលសួរទៅកាន់ក្រុមមេធាវីការពារក្តី ថាតើចង់បន្តលើកអញ្ញត្រកម្មទៀតដែរឬទេ ក្រោយមរណភាពរបស់ អៀង សារី។ ក្នុងពេលបង្គាប់ឱ្យក្រុមមេធាវីការពារក្តីលើកអញ្ញត្រកម្ម អង្គជំនុំជម្រះបានធ្វើផ្ទុយពីការលើកឡើងរបស់ខ្លួនដែលថាបញ្ហានេះត្រូវបានលើកឡើង “ក្នុងពេលវេលាសមស្រប ដោយក្រុមមេធាវីការពារក្តីលោក អៀង សារី”[247]។

២៦១. លើសពីនេះទៅទៀត ការសន្និដ្ឋាននេះខុស ដោយហេតុថាបញ្ហានេះ មិនត្រឹមតែត្រូវបានលើកឡើងដោយ អៀង សារី មុនពេលបើកការជំនុំជម្រះប៉ុណ្ណោះទេ (ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១) តែវា

---

[247] អនុស្សរណៈ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E306** កថាខណ្ឌ ៥។

ថែមទាំងត្រូវបានលើកឡើងតាំងពីដំណាក់កាលស៊ើបអង្កេតមកម្ល៉េះ នៅចំពោះមុខអង្គបុរេជំនុំជម្រះ (ក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ)។

២៦២. ជាក់ស្តែង បញ្ហានេះពិតជាត្រូវបានលើកឡើងនៅដំណាក់កាលស៊ើបអង្កេតប្រាកដមែន ប៉ុន្តែមិនត្រូវបានអារកាត់ឱ្យអស់សេចក្តីនោះទេ។ កំហុសនៃកថាខណ្ឌ ១៣៩៧ ដល់ ១៤០១ នៃដីកាដំណោះស្រាយ មិនត្រូវបានសំអាតដោយអង្គបុរេជំនុំជម្រះទេ។

២៦៣. រីឯអង្គជំនុំជម្រះវិញ ដល់ពេលខ្លួនទទួលរឿងនេះ បែរជាបដិសេធមិនព្រមដោះស្រាយ "ក្នុងដំណាក់កាលនេះនៃនីតិវិធី"។

២៦៤. និយាយមួយបែបទៀត អង្គបុរេជំនុំជម្រះទុកឱ្យអង្គជំនុំជម្រះអារកាត់ឱ្យអសសេចក្តីលើបញ្ហានេះ។ ដល់ពេលទទួលបញ្ហានេះ អង្គជំនុំជម្រះឆ្លើយថាមិនមែនខ្លួននោះទេដែលត្រូវអារកាត់លើបញ្ហានេះ ពីព្រោះបញ្ហានេះគួរតែត្រូវបានលើកឡើងចំពោះមុខអង្គបុរជំនុំជម្រះ។

២៦៥. ទោះជាយ៉ាងណាក្តី ការដែលបញ្ហានេះពិតជាត្រូវបានលើកឡើងពីមុនមកដោយ អៀង សារី មិនមានសារៈសំខាន់អ្វីទេ។ តាមពិត ដោយហេតុថាការសម្អាតកំហុសនៃដីកាដំណោះស្រាយមិនអាចធ្វើទៅបានចំពោះមុខអង្គបុរេ អង្គជំនុំជម្រះមិនអាចបែរខ្នងដាក់បញ្ហា ដោយមិនប្រព្រឹត្តយុត្តិនីសេធ និងរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានឧបាស្រ័យប្រកបដោយប្រសិទ្ធិភាព និងសិទ្ធិការពារបុព្វហេតុរបស់ខ្លួន នោះឡើយ។

ii. <u>**ការបង្ហាញអំពីភាពអគតិ**</u>

- <u>**អន្តរាគមន៍ក្នុងករណីដែលសំណើរបស់សហព្រះរាជអាជ្ញាមិនអាចទទួលយកបាន**</u>

២៦៦. ការបដិសេធមិនអន្តរាគមរបស់អង្គជំនុំជម្រះ ក្នុងសេចក្តីសម្រេចរបស់ខ្លួន (E306/5) កាន់តែពិបាកយល់ទៅទៀត ក្នុងខណៈដែលខ្លួនបង្ហាញភាពតឹងរ៉ឹងចំពោះជនជាប់ចោទ ប៉ុន្តែបែរជាធូរលុងចំពោះសំណើរបស់សហព្រះរាជអាជ្ញាទៅវិញ។

២៦៧. អាស្រ័យហេតុដូច្នេះហើយបានជាអង្គជំនុំជម្រះប្រកាសថាអាចទទួលយកបាន និងបានអារកាត់ឱ្យអស់សេចក្ដីចំពោះសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ជាទម្រង់នៃទំនួលខុសត្រូវដែលអាចអនុវត្តបានចំពោះជនជាប់ចោទ និងចំពោះសំណើសុំដកចំណោទទាក់ទងជាមួយជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[248]។ ក៏ប៉ុន្តែ ក្នុងករណីទាំងពីរ ដីកាដំណោះស្រាយបានចូលជាស្ថាពរ ហើយពេលវេលាសម្រាប់លើកអញ្ញត្រកម្មបឋមក៏ហួសផុតទៅហើយដែរ។ ស្របតាមលក្ខខ័ណ្ឌតម្រូវនៃវិធាន ៨៩ កត្តាទាំងពីរនេះគួរតែជំរុញឱ្យអង្គជំនុំជម្រះប្រកាសថាសំណើរបស់ព្រះសហរាជអាជ្ញាមិនអាចទទួលយកបាន [249]។ ផ្ទុយទៅវិញ ដោយផ្អែកលើការបកស្រាយនៃវិធាន ៩៨-២ នៃវិធានផ្ទៃក្នុង ដែលទាក់ទងតែនឹងដំណាក់កាលជំនុំជម្រះតែប៉ុណ្ណោះនោះ[250] អង្គជំនុំជម្រះបានពិចារណាថា សំណើទាំងពីរនេះអាចទទួលយកបាន ថែមទាំងបន្ថែមទៀត ដោយមិនមានផ្ដល់យុត្តិកម្មតាមបញ្ញត្តិច្បាប់ ឬបទបញ្ជាណាមួយ ថាខ្លួនមានសិទ្ធិអំណាច “គ្រប់ពេលវេលា [...] កែប្រែការកំណត់ប្រភេទបទល្មើសលើអង្គហេតុដែលមានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ”[251] និង “ប្រកាសអំពីច្បាប់ដែលអាចអនុវត្តបានចំពោះករណីនេះ”[252]។

---

[248] សេចក្ដីសម្រេច ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ **ឯកសារ** E100/6។ សេចក្ដីសម្រេច ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ **ឯកសារ** E95/8។ ទោះបីជាអង្គជំនុំជម្រះមិនបានប្រកាសទទួលយកការស្នើសុំនោះជាផ្លូវការក៏ដោយ តែអង្គជំនុំជម្រះក៏បានសម្រេចលើអង្គសេចក្ដីទៅលើការស្នើសុំលើកទីបីរបៀបដូចគ្នានេះរបស់ព្រះរាជអាជ្ញា សំដៅ “កំណត់ទោសសាជាថ្មី” ពីបទរំលោភសេពសន្ថវៈដោយដាក់បញ្ចូលទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាក់លាក់ (សំណើ ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១១ **ឯកសារ** E99) នៅក្នុង អនុស្សរណៈ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ** E306 កថាខណ្ឌ ៤។ អង្គជំនុំជម្រះបានច្រានចោលសំណើនោះ ដោយសម្អាងលើសេចក្ដីសម្រេចរបស់តុលាការកំពូលទៅលើប្រធានបទនេះ។

[249] វិធាន ៨៩ នៃ វិធានផ្ទៃក្នុង។

[250] វិធាន ៨៩ នៃ វិធានផ្ទៃក្នុង « សវនាការលើអង្គសេចក្ដី»។ ចម្លើយតបរបស់ ខៀវ សំផន ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ **ឯកសារ** E99/3 កថាខណ្ឌ ៦-២០។

[251] សេចក្ដីសម្រេច ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ **ឯកសារ** E100/6 កថាខណ្ឌ ២៥។

[252] សេចក្ដីសម្រេច ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ **ឯកសារ** E95/8 កថាខណ្ឌ ៩។

២៦៨. ក្នុងករណីទាំងពីរដដែល អង្គជំនុំជម្រះបានកត់សម្គាល់ផងដែរថា សំណើទាំងអស់នេះបានធ្វើឡើង មុនពេលបើកសវនាការលើអង្គសេចក្តី។ ដូច្នេះ វាមិនប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទទេ[253]។

២៦៩. ពុំមានអំណះអំណាងជាធម្មានុរូបណាមួយអាចពន្យល់អំពីការប្រព្រឹត្តខុសគ្នាបែបនេះលើសំណើរបស់ ខៀវ សំផន និងលើសំណើរបស់សហព្រះរាជអាជ្ញា ហើយជាពិសេសទៀត ចំពោះករណី ខៀវ សំផន នេះ ហានិភ័យនៃការរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់គាត់មានយ៉ាងពិតប្រាកដ។ នៅថ្ងៃនេះ ការរំលោភបំពាននេះពិតជាកើតឡើងមែន។

- **<u>ទស្សនៈអគតិលើនីតិវិធីព្រហ្មទណ្ឌ</u>**

២៧០. ដើម្បីគាំទ្រដល់ការបដិសេធមិនព្រមអន្តរាគមលើបញ្ហាជម្លៀស អង្គជំនុំជម្រះបានប៉ាន់ប្រមាណថាជនជាប់ចោទ "ត្រូវបានជូនដំណឹងអំពីវិសាលភាពនៃការស៊ើបអង្កេត ដោយត្រឹមត្រូវតាមនីតិវិធី" (ឯកសារ E305/6 កថាខណ្ឌទី ៨)។ ដើម្បីគាំទ្រសេចក្តីសន្និដ្ឋាននេះ អង្គជំនុំជម្រះបានប្រថុយប្រថានក្នុងកម្រិតណាមួយទៅលើអង្គសេចក្តី។

២៧១. បើតាមអង្គជំនុំជម្រះ "ចាប់តាំងពីការចាប់ផ្តើមនីតិវិធី [...] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានប្រគល់សិទ្ធអំណាចទៅដល់សហចៅក្រមស៊ើបអង្កេតឱ្យស៊ើបអង្កេតលើឧក្រិដ្ឋកម្មជម្លៀស ដែលជាបទល្មើសបង្កើតបានជា [ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ]" (ឯកសារ E305/6 កថាខណ្ឌទី ៧)។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដ៏ធំដូចគ្នានឹងព្រះរាជអាជ្ញាដែលបានប្រព្រឹត្តកំហុសនេះមុនខ្លួន[254]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនអាចធ្វើមិនដឹងមិនឮថា សហចៅក្រមស៊ើបអង្កេតបានទទួលតែបណ្តឹងពីអង្គហេតុតែប៉ុណ្ណោះ គឺមិនមែនបណ្តឹងពីការកំណត់ប្រភេទបទល្មើសដែលជ្រើសរើសដោយសហព្រះរាជអាជ្ញានោះឡើយ។ ជាក់ស្តែង ពាក្យពេចន៍នៅក្នុងវិធានផ្ទៃក្នុង មិនបណ្តោយឱ្យមានការមន្ទិលសង្ស័យណាមួយទៅលើវិសាលភាពនៃបណ្តឹងដែលសហចៅក្រមស៊ើប

---

[253] សេចក្តីសម្រេច ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ **ឯកសារ E100/6** កថាខណ្ឌ ២៥។ សេចក្តីសម្រេច ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ **ឯកសារ E95/8** កថាខណ្ឌ ៩។

[254] សូមមើលខាងលើ កថាខណ្ឌ ២៣៩។

អង្គេតបានទទួលនោះឡើយ ដែលសហចៅក្រមស៊ើបអង្កេត "មានកាតព្វកិច្ចស៊ើបអង្កេតតែលើអង្គហេតុដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះ"[255]។ ច្បាប់បារាំង ក៏ដូចច្បាប់កម្ពុជាដែរមានលក្ខណៈដូចគ្នា ត្រង់ចំណុចនេះ[256]។ យុត្តិសាស្ត្របារាំងថែមទាំងបានបញ្ជាក់អំពីភាពតឹងរ៉ឹងនៃវិធាននេះជាច្រើនដងទៀតផង[257]។

២៧២. សេចក្តីសន្និដ្ឋានមានកំហុសរបស់អង្គជំនុំជម្រះ ផ្ទុះបញ្ចាំងឱ្យឃើញទស្សនៈដ៏គួរឱ្យព្រួយបារម្ភមួយលើនីតិវិធីព្រហ្មទណ្ឌ។ ជាក់ស្តែង អង្គជំនុំជម្រះយល់ឃើញថា នៅដំណាក់កាលនៃការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧក្រិដ្ឋកម្មត្រូវបានរកឃើញថាមានធាតុផ្សំរួចរាល់បាត់ទៅហើយ រីឯភារកិច្ចរបស់ចៅក្រមស៊ើបអង្កេត គឺត្រូវរកភ័ស្តុតាងដាក់បន្ទុកដើម្បីគាំទ្រដីកានេះ ក្នុងខណៈដែលខ្លួនត្រូវស៊ើបអង្កេតដាក់បន្ទុកផង និងដោះបន្ទុកផង។ បន្ទាប់មក អង្គជំនុំជម្រះគ្រាន់តែឡើងលើឆាកនៅនាទីចុងក្រោយ ដើម្បីកំណត់ទម្ងន់ទោសតែប៉ុណ្ណោះ។

២៧៣. ជាថ្មីម្តងទៀត ដើម្បីគាំទ្រដល់ការបដិសេធមិនព្រមធ្វើអន្តរាគមរបស់ខ្លួន ដោយមូលហេតុថាជនជាប់ចោទត្រូវបានជូនដំណឹងអំពីវិសាលភាពនៃការស៊ើបអង្កេតដោយត្រឹមត្រូវតាមនីតិវិធី អង្គជំនុំជម្រះបានអះអាងថែមទៀតថា ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាមាន "បញ្ជាក់យ៉ាងច្បាស់ [...] អំពីការជម្លៀសជនជាតិវៀតណាម"(ឯកសារ E305/6 កថាខណ្ឌទី ៨)។ ការអះអាងបែបនេះមិនទទួលបានការគោរពស្ញើចសរសើរទាល់តែសោះ ដោយមូលហេតុថាអង្គជំនុំជំម្រះស្គាល់មិនច្បាស់អំពីមុខងារនៃដីកាសន្និដ្ឋានស្ថាពរដែលមិនដើរតួនាទីជំនួសឱ្យបណ្តឹងមកកាន់សហ

---

[255] វិធានផ្ទៃក្នុង វិធាន ៥៥-២។

[256] ក្រមនីតិព្រហ្មទណ្ឌកម្ពុជា មាត្រា ១២៥ (វិសាលភាពនៃការប្តឹង) វាក្យខណ្ឌ ១ ៖ «ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពី អង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ។» (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ក្រមនីតិព្រហ្មទណ្ឌបារាំង មាត្រា ៨០ I. វាក្យខណ្ឌ ១។

[257] សូមមើលខាងលើ កថាខណ្ឌ ១០២-១០៥។

ចៅក្រមស៊ើបអង្កេត ឬមានតួនាទីជូនដំណឹងដល់ជនជាប់ចោទអំពីការចោទប្រកាន់ប្រឆាំងនឹងពួកគាត់ឡើយ[258]។

២៧៤. ដូចគ្នានឹងការដែលដីកាសន្និដ្ឋានស្ថាពរមិនអាចបំពេញចន្លោះប្រហោងនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម អង្គជំនុំជម្រះមិនអាចបំពេញចន្លោះប្រហោងរបស់សហព្រះរាជអាជ្ញា និងធ្វើយុត្តិកម្មលើការរកភ័ស្តុតាងដាក់បន្ទុកហួសដែនសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេតដោយគេចវេសមិនព្រមអារកាត់ឱ្យអស់សេចក្តីលើសុពលភាពនៃមាត្រា ១៣៩៧ ដល់ ១៤០១ នៃដីកាដំណោះស្រាយ។

## 1.ឃ. សេចក្តីសន្និដ្ឋាន

២៧៥. នៅដំណាក់កាលនេះនៃនីតិវិធី អង្គជំនុំជម្រះមានកាតព្វកិច្ចធ្វើមោឃភាពលើបទបញ្ញត្តិដែលមានកំហុសនៃដីកាដំណោះស្រាយ។ អង្គជំនុំជម្រះគ្មានជម្រើសអ្វីក្រៅពីកត់សម្គាល់ថាខ្លួនមិនបានទទួលបណ្តឹងពីអង្គហេតុជម្លៀសដែលមានរៀបរាប់នៅក្នុងកថាខណ្ឌ ១៣៩៧ ដល់ ១៤០១ នៃដីកាដំណោះស្រាយ ដោយត្រឹមត្រូវតាមនីតិវិធី។ ដូច្នេះ អង្គជំនុំជម្រះត្រូវប្រកាសថាខ្លួនពុំមានសមត្ថកិច្ចក្នុងការសម្រេចលើអង្គហេតុទាំងនេះដែលជនជាប់ចោទពុំមានទំនួលខុសត្រូវនោះទេ។

២៧៦. បើពុំដូចនោះទេ វាស្មើនឹងអង្គជំនុំជម្រះផ្តល់សុពលភាពទៅដល់នីតិវិធីមួយដែលមិនអនុញ្ញាតឱ្យជនត្រូវចោទ ឬជនជាប់ចោទ មានលទ្ធភាពជំទាស់នឹងការរំលោភបំពានពីសំណាក់សហចៅក្រមស៊ើបអង្កេតទៅលើបណ្តឹងមកកាន់ខ្លួន។ ប្រការនេះដឹកកប់សេចក្តីសង្ឃឹមចុងក្រោយចំពោះនីតិវិធីប្រកបដោយសមធម៌ និងភាពគួរឱ្យជឿជាក់បានរបស់ អ.វ.ត.ក តែម្តង។

---

[258] វិធានផ្ទៃក្នុង វិធាន ៥៥-២, ៦៦ និង ៦៧-១ នៃវិធានផ្ទៃក្នុង។ ក្រមនីតិព្រហ្មទណ្ឌកម្ពុជា មាត្រា ១២៥ (វិសាលភាពនៃការប្តឹង) វាក្យខណ្ឌ ១, ២៤៦ (ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា) និង ២៤៧ (ដីកាដំណោះស្រាយ) វាក្យខណ្ឌ ៤ («ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ច គោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ»)។

## 2. អង្គហេតុ នៃ "ការបោសសម្អាត"

២៧៧. នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦ ក្រុមមេធាវីការពារក្តីបានដាក់សំណើបន្ទាន់មួយទៅអង្គជំនុំជម្រះ ដើម្បីសុំការបំភ្លឺអំពីវិសាលភាពនៃបណ្តឹងមកកាន់អង្គជំនុំជម្រះពាក់ព័ន្ធនឹង"ការបោសសម្អាតផ្ទៃក្នុង"[259]។ ព្រឹត្តិការណ៍មួយចំនួនដែលបានកើតឡើងប៉ុន្មានសប្តាហ៍កន្លងមកនេះ ធ្វើឱ្យក្រុមមេធាវីការពារក្តីមានមន្ទិលសង្ស័យអំពីការពង្រីកវិសាលភាពនៃបណ្តឹងដោយអង្គជំនុំជម្រះ៖

- អង្គជំនុំជម្រះបានបង្កើតវគ្គតូចមួយនៃសវនាការ សម្រាប់ស្តាប់ជាពិសេសសក្ខីកម្មពាក់ព័ន្ធនឹង "ការបោសសម្អាតផ្ទៃក្នុង"[260]។
- អង្គជំនុំជម្រះបានសម្រេចកោះហៅសាក្សីថ្មីម្នាក់ តាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលជាសាក្សីក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយសំអាងហេតុថា សក្ខីកម្មរបស់គាត់អាចមានភាពពាក់ព័ន្ធនឹង"ការបោសសម្អាតកម្មាភិបាលនៅតំបន់ក្រចេះ"[261]។

២៧៨. នៅក្នុងសំណើនេះ យើងគប្បីគ្រាន់តែសង្ខេប ដោយយោងទាំងស្រុងទៅលើខ្លឹមសារលម្អិតដែលបានរៀបរាប់យ៉ាងវែងអន្លាយរួចមកហើយ ក្រុមមេធាវីការពារក្តីបានរំឭកថា "ការបោសសម្អាតផ្ទៃក្នុង" មិនមែនជាឧក្រិដ្ឋកម្មផ្ទាល់នោះទេ។ ជាក់ស្តែង "ការបោសសម្អាត" មិនមាននៅក្នុងការកំណត់ប្រភេទបទល្មើសនៃដីកាដំណោះស្រាយក្នុងឋានៈជាឧក្រិដ្ឋកម្មជាមូលដ្ឋាន ហើយការបោសសម្អាតនេះត្រូវតែមានទំនាក់ទំនងចាំបាច់ជាមួយនឹងទីតាំងមួយក្នុងចំណោមទីតាំងក្រោមការស៊ើបអង្កេតទាំងអស់ដែលជាកម្មវត្ថុនៃសំណុំរឿងនេះ ដូចដែលបានកំណត់ដោយដីកាបំបែកកិច្ចដំណើរការនីតិវិធី។

២៧៩. ក្រុមមេធាវីការពារក្តីបានគូសបញ្ជាក់ថា ស្របតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតបានទទួលតែអង្គហេតុ "បោសសម្អាត" ដែលទំនងជាកើត

---

[259] សំណើបន្ទាន់របស់លោក ខៀវ សំផន ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E420**។

[260] សំណើបន្ទាន់របស់លោក ខៀវ សំផន ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E420** កថាខណ្ឌ ៣-៧។

[261] សេចក្តីសម្រេច ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E319/36/2** កថាខណ្ឌ ១២។ សំណើបន្ទាន់របស់លោក ខៀវ សំផន ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E420** កថាខណ្ឌ ៨-៩។

ឡើងនៅភូមិភាគឧត្តរចាស់ក្នុងឆ្នាំ១៩៧៦ និងនៅភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៨ តែប៉ុណ្ណោះ។ ក្រុមមេធាវីការពារក្ដីបានបង្ហាញថា តាមរយៈសក្ខីកម្មមួយចំនួននៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានពង្រីកដោយចិត្តឯងនូវវិសាលភាពនៃការស៊ើបអង្កេតទៅដល់អង្គហេតុ "បោសសម្អាត"ផ្សេងទៀត ក្រៅពីអង្គហេតុដែលមានបញ្ជាក់នៅក្នុងដីកាបញ្ជូនទៅពួកគាត់។ បន្ទាប់មក ក្រុមមេធាវីការពារក្ដីបានរំឭកថា អង្គជំនុំជម្រះអាចសម្រេចលើអង្គហេតុ "បោសសម្អាត" ដែលបានប្ដឹងដោយត្រឹមត្រូវតាមនីតិវិធីទៅកាន់សហចៅក្រមស៊ើបអង្កេត តែក្នុងករណីដែលអង្គហេតុទាំងនេះមានចំណងទាក់ទងជាមួយទីតាំងមួយចំនួនដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២។

២៨០. នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានឆ្លើយតបនឹងសំណើរបស់ក្រុមមេធាវីការពារក្ដី តាមរយៈអនុស្សរណៈដ៏ខ្លីមួយ (ឯកសារ E420/1)[262]។ ក្នុងចម្លើយតបនោះ អង្គជំនុំជម្រះយល់ស្របថា "ការបោសសម្អាតផ្ទៃក្នុងមិនមែនជាបទល្មើសជាមូលដ្ឋាននោះទេ"(ឯកសារ E៤២០/១ កថាខណ្ឌទី ៥) មុននឹងថ្លែងថាខ្លួនបានទទួល៖

> "បណ្ដឹងពីអង្គហេតុផ្សេងៗពាក់ព័ន្ធនឹងគោលនយោបាយទាំងប្រាំដែលត្រូវបានចោទប្រកាន់ថាត្រូវបានគាក់តែងឡើង និងអនុវត្តដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ គោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំងនេះ ត្រូវបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយដូចតទៅ៖ *"ការអប់រំសមាសភាពមិនល្អ និងការកម្ទេចខ្មាំង ទាំងនៅក្នុង និងក្រៅបក្ស"* (ឯកសារ E420/1 កថាខណ្ឌទី ៦ មានគូសបន្ទាត់ពីក្រោមនៅក្នុងច្បាប់ដើម)។

២៨១. បន្ទាប់មកទៀត អង្គជំនុំជម្រះបានពិចារណាថា វិសាលភាពនៃសំណុំរឿងដូចដែលក្រុមមេធាវីការពារក្ដីបានកំណត់នៅទីតាំងខ្លះ និងអំឡុងពេលខ្លះ មិនត្រឹមត្រូវទេ៖

> "ការកំណត់ដ៏ចង្អៀតចំពោះដីកាដំណោះស្រាយបែបនេះ មិនស្របទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ដែលបានកំណត់នៅក្នុងសេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីសវនាការនេះទេ។ ដីកាដំណោះស្រាយបានកំណត់យ៉ាងច្បាស់អំពីទីតាំង និង អង្គភាពមួយចំនួនដែលស្ថិតនៅក្រៅភូមិភាគឧត្តរចាស់ និង ឧត្តរថ្មី និង/ឬ ភូមិភាគបូព៌ា ថាស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ ដីកាដំណោះស្រាយ

[262] អនុស្សរណៈ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E420/1**។

មិនបានកំណត់អំពីវិសាលភាពពេលវេលាដូចដែលបានអះអាងដោយមេធាវីការពារក្តី ខៀវ សំផន ឡើយ”។ (ឯកសារ E420/1 កថាខណ្ឌទី៦ មានគូសបន្ទាត់ពីក្រោមនៅក្នុងច្បាប់ដើម)។

២៨២. អង្គជំនុំជម្រះមិនមាននិយាយមួយម៉ាត់ណាសោះលើការដែលមេធាវីការពារក្តីលើកឡើងជាពិសេសនូវកថាខណ្ឌនៃដីកាដំណោះស្រាយ ដើម្បីបង្ហាញថា សហចៅក្រមស៊ើបអង្កេតបានពង្រីកវិសាលភាពនៃបណ្តឹងដែលខ្លួនបានទទួល ដែលវិសាលភាពនៃបណ្តឹងនេះត្រូវបានកំណត់មកត្រឹមទីតាំងមួយចំនួន និងមកត្រឹមអំឡុងពេលមួយចំនួន...។

២៨៣. បន្ទាប់ពីបានលាក់បាំងរឿងរកាំរកូសរបស់ខ្លួន អង្គជំនុំជម្រះបានសន្និដ្ឋានដោយកត់សម្គាល់ថា៖

> “ទំនាក់ទំនងរវាងគោលនយោបាយពាក់ព័ន្ធដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ និង បទល្មើសជាក់លាក់ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ គឺជាបញ្ហាដែលត្រូវដោះស្រាយនៅពេលរៀបចំធ្វើសាលក្រម។ នេះជាអ្វីដែលអង្គជំនុំជម្រះសាលាដំបូងលើកឡើងទៅលើបញ្ហានេះនៅពេលនេះ ហើយអង្គជំនុំជម្រះកត់សម្គាល់ថា ជាការគួរឱ្យសោកស្តាយដែលបញ្ហានេះត្រូវបានលើកឡើងនៅដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធី”។ (ឯកសារ E420/1 កថាខណ្ឌទី១០)

២៨៤. អាស្រ័យហេតុនេះ អង្គជំនុំជំម្រះមិនដែលបានឆ្លើយនឹងបញ្ហាដែលលើកឡើយដោយ ខៀវ សំផន ដែលមិនមែនជាបញ្ហានៃទំនាក់ទំនងរវាងគោលនយោបាយរងការចោទប្រកាន់ និងឧក្រិដ្ឋកម្មជាមូលដ្ឋាននោះទេ តែគឺជាបញ្ហាពាក់ព័ន្ធនឹងបណ្តឹងមកកាន់អង្គជំនុំជម្រះ ដែលត្រូវបានដោះស្រាយក្រោយបណ្តឹងមកកាន់សហចៅក្រមស៊ើបអង្កេត ខណៈបណ្តឹងមកកាន់សហចៅក្រមអង្កេតនេះមានភាពមិនប្រក្រតីមួយផ្នែកធំ។

២៨៥. ភាពស្ងៀមស្ងាត់របស់អង្គជំនុំជម្រះចំពោះការពង្រីកវិសាលភាពនៃបណ្តឹងដោយសហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងអង្គហេតុ “បោសសម្អាត” ពុំមានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេ បើយោងលើដីកាសេចក្តីសម្រេចកន្លងមករបស់អង្គជំនុំជម្រះដែលបដិសេធមិនពិនិត្យការពង្រីកវិសាលភាពនៃបណ្តឹងដែលខ្លួនបានទទួលទៅដល់អង្គហេតុជម្លៀស។

២៨៦. ទោះជាយ៉ាងណាក្តី នៅក្នុងដំណាក់កាលនេះនៃនីតិវិធី ក៏ដូចជាករណីអង្គហេតុជម្លោស អង្គជំនុំជម្រះពុំមានជម្រើសអ្វីក្រៅពីខ្វល់ខ្វាយក្នុងការលាក់បាំងរឿងរកាំរកូសរបស់ខ្លួននោះទេ។ អង្គជំនុំជំម្រះមានកាតព្វកិច្ចកត់សម្គាល់ថា ខ្លួនមិនបានទទួលដោយត្រឹមត្រូវតាមនីតិវិធីនូវអង្គហេតុ "បោសសម្អាត" ទាំងអស់ ដែលមានរៀបរាប់នៅក្នុងដីកាដំណោះស្រាយនោះទេ ដូច្នេះខ្លួនត្រូវតែធ្វើមោឃភាពលើបទបញ្ញត្តិមានកំហុសនៃដីកាដំណោះស្រាយដែលមិនអាចកែខៃបាននៅក្នុងដំណាក់កាលស៊ើបអង្កេត។

២៨៧. យើងគួរគប្បីបញ្ជាក់ថា ទោះក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះមិនអាចចាត់ទុកថាខ្លួនបានទទួលបណ្តឹងលើអង្គហេតុទាំងនេះ ដោយហេតុផលថាខ្លួនទំនងជាទទួលអង្គហេតុពាក់ព័ន្ធជាមួយនឹងគោលនយោបាយរងការចោទប្រកាន់បានឡើយ ពីព្រោះថា ប្រសិនបើយើងគិតដូចនេះ វាប្រៀបប្រដូចបានទៅនឹងការយល់ឃើញថា ម្ខាងមានអង្គហេតុទាក់ទងជាមួយគោលនយោបាយ និង ម្ខាងទៀតមានអង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលទំនាក់ទំនងនៃផ្នែកទាំងពីរនេះគួរតែយកមកពិភាក្សានៅដំណាក់កាលជំនុំជម្រះ។

២៨៨. ជាក់ស្តែង ទោះបីជាអង្គជំនុំជំម្រះទទួលអង្គហេតុទាក់ទងនឹងគោលនយោបាយក៏ដោយ ក៏វាទាល់តែអង្គហេតុទាំងនេះមានទំនាក់ទំនងជាមួយនឹងឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់ ថាវាជាគោលនយោបាយណាមួយជាក់លាក់។

២៨៩. និយាយមួយបែបទៀត គោលនយោបាយមិនមែនជាឧក្រិដ្ឋកម្មដោយឯកឯងនោះទេ។ វាគ្រាន់តែជាប្រភេទមួយដែលសហចៅក្រមស៊ើបអង្កេតបានចាត់ចំណាក់ថ្នាក់ឧក្រិដ្ឋកម្ម ហើយដោយសំអាងលើឧក្រិដ្ឋកម្មទាំងនេះ សហចៅក្រមសម្រេចបញ្ជូនជនជាប់ចោទទៅកាត់សេចក្តី ដោយយល់ឃើញថាពួកគាត់មានទំនួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងអស់នេះ តាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។

២៩០. ដូច្នេះ គោលនយោបាយទាំងប្រាំដែលរងការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ មិនអាចជា "ប្រអប់សម្រាប់ញាត់អ្វីៗទាំងអស់ចូល" ដើម្បីអនុញ្ញាតឱ្យអង្គជំនុំជម្រះពិនិត្យ និង សម្រេចលើអង្គហេតុដែលនៅក្រៅវិសាលភាពនៃបណ្តឹងដែលខ្លួនបានទទួលនោះទេ។

២៩១. លើសពីនេះទៅទៀត បន្ទាប់ពីបានរំឭកថា អង្គជំនុំជម្រះ "នៅគ្រប់កាលៈទេសៈទាំងអស់ ត្រូវបានហាមឃាត់មិនឱ្យសម្រេចលើការដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋ ដែលស្ថិតនៅក្រៅវិសាលភាពនៃបទចោទ" អង្គជំនុំជម្រះតុលាការកំពូលបានកំណត់គោលនយោបាយទាំងប្រាំដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយ ថាជា"មធ្យោបាយសម្រាប់ធ្វើការវិភាគអំពីការកសាងបដិវត្តន៍សង្គមនិយមនៅកម្ពុជា"[263]។

២៩២. ទំនាក់ទំនងតែមួយគត់ដែលត្រូវបង្ហាញនៅដំណាក់កាលជំនុំជម្រះ គឺទំនាក់ទំនងរវាងអង្គហេតុដែលអង្គជំនុំជម្រះបានទទួល ហើយដែលមុនអ្វីៗទាំងអស់ អង្គជំនុំជម្រះត្រូវបង្ហាញថាអង្គហេតុទាំងនេះជាធាតុផ្សំនៃឧក្រិដ្ឋកម្ម និងជនជាប់ចោទ ដើម្បីពិនិត្យមើលការចូលរួមរបស់គាត់ក្នុងឧក្រិដ្ឋកម្មទាំងនេះ ក្រោយពេលដែលឧក្រិដ្ឋកម្មទាំងនេះត្រូវបានរកឃើញថាពិតជាមានមែន។

២៩៣. ដូចអង្គហេតុជម្លៀស និងអង្គហេតុផ្សេងៗទៀត ដែលចេញផុតពីវិសាលភាពនៃបណ្តឹងដែលចៅក្រមស៊ើបអង្កេតបានទទួល អង្គហេតុ "បោសសម្អាត" ដែលអង្គជំនុំជម្រះមិនបានទទួលត្រឹមត្រូវតាមនីតិវិធី ក៏ទៅហួសវិសាលភាពនៃបណ្តឹងដូចគ្នា។

## ខ. អង្គហេតុដែលពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជូនទៅជំនុំជម្រះ

២៩៤. ជានិច្ចជាកាល ដើម្បីធានាសិទ្ធជនជាប់ចោទក្នុងការទទួលបានឧបាស្រ័យ និងសិទ្ធការពារបុព្វហេតុរបស់ខ្លួន អង្គជំនុំជម្រះត្រូវតែធ្វើមោឃភាពលើបទបញ្ញត្តិនៃដីកាដំណោះស្រាយ ដែលផ្អែកលើបទបញ្ញត្តិទាំងនេះ ជនជាប់ចោទត្រូវបានបញ្ជូនទៅជំនុំជម្រះ ក្នុងខណៈដែលពុំមានធាតុផ្សំដាក់បន្ទុកគ្រប់គ្រាន់។

២៩៥. ដូចដែលបានបង្ហាញខាងលើ ជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក មិនទទួលបានឧបាស្រ័យផ្សេងណាមួយប្រឆាំងនឹងបទបញ្ញត្តិនៃដីកាដំណោះស្រាយ ក្រៅពីបណ្តឹងទាក់ទងទៅនឹងយុត្តាធិការរបស់

---

[263] សាលដីកា ០០២/០១ កថាខណ្ឌ ២២៧។

តុលាការ និងការឃុំខ្លួនបណ្តោះអាសន្នតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ នៅចំពោះមុខតុលាការជាតិ ឬអន្តរជាតិដទៃទៀត ជនជាប់ចោទមានលទ្ធភាពជំទាស់នឹងកំហុសនៃបទចោទលើរូបគាត់ ជាអាទិ៍ កំហុសទាក់ទងនឹងភាពគ្រប់គ្រាន់នៃភស្តុតាងដាក់បន្ទុក យ៉ាងហោចណាស់ក៏នៅក្នុងដំណាក់កាលណាមួយនៃនីតិវិធីដែលប្រឆាំងនឹងពួកគាត់ដែរ។

២៩៦. អាស្រ័យហេតុនេះ ជនជាប់ចោទនៅចំពោះមុខតុលាការកម្ពុជា មានសិទ្ធិលើកពីកំហុសទាំងនេះនៅចំពោះមុខក្រុមប្រឹក្សាស៊ើបអង្កេត[264]។ ជនជាប់ចោទនៅចំពោះមុខតុលាការព្រហ្មទណ្ឌបារាំង អាចលើកឡើងអំពីកំហុសទាំងនេះ នៅចំពោះមុខក្រុមប្រឹក្សាស៊ើបអង្កេត[265]។ ជនជាប់ចោទនៅចំពោះមុខសាលាមជ្ឈិមបារាំង អាចលើកឡើងអំពីកំហុសនេះចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះ[266]។ ចំណែកជនជាប់ចោទនៅចំពោះមុខតុលាការចំពោះកិច្ច មានសិទ្ធិលើកឡើងអំពីកំហុសទាំងនេះ យ៉ាងហោចណាស់ក៏នៅក្នុងដំណាក់កាលជំនុំជម្រះសេចក្តីដែរ[267]។ ជនជាប់ចោទនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ អាចលើកឡើងអំពីកំហុសទាំងនេះនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងនៅដំណាក់កាលជំនុំជម្រះសេចក្តី[268]។

២៩៧. ដោយផ្អែកលើហេតុផលស្រដៀងគ្នាទៅនឹងហេតុផលនៃច្បាប់របស់តុលាការចំពោះកិច្ច និងច្បាប់បារាំងពាក់ព័ន្ធនឹងបទមជ្ឈិម អង្គបុរេជំនុំជម្រះ នៃ អ.វ.ត.ក បានបកស្រាយច្បាប់របស់ អ.វ.ត.ក ថាអាចអនុញ្ញាតឱ្យជនជាប់ចោទលើកអំពីបញ្ហាទាំងនេះ ក៏ប៉ុន្តែមិនមែននៅចំពោះមុខខ្លួនទេ គឺនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[269]។

[264] ក្រមនីតិព្រហ្មទណ្ឌកម្ពុជា មាត្រា ២៥៣ (ការប្តឹងទៅសភាស៊ើបសួរ) វាក្យខណ្ឌ ៣ និង ៤, មាត្រា ២៥២ (មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ)។

[265] ក្រមនីតិព្រហ្មទណ្ឌបារាំង មាត្រា ១៨៦ ៖ «សិទ្ធិប្តឹងឧទ្ធរណ៍គឺជាសិទ្ធិនៃជនត្រូវចោទប្រឆាំងនឹងដីកា និងសេចក្តីសម្រេចដែលមានចែងក្នុងមាត្រា […] ១៨១» (ដីកាចោទប្រកាន់), មាត្រា ២១១ ៖ «[សភាស៊ើបសួរ] ពិនិត្យមើលថាតើមានការដាក់បន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទដែរឬទេ »។

[266] សូមមើលខាងលើ កថាខណ្ឌ ១១០-១១៣។

[267] សូមមើលខាងលើ កថាខណ្ឌ ១៤០-១៤៨។

[268] សូមមើលខាងលើកថាខណ្ឌ ១៣៥-១៣៩។

[269] សូមមើលខាងលើកថាខណ្ឌ ២៤៤-២៥៥។

២៩៨. អាស្រ័យហេតុនេះ អង្គជំនុំជម្រះមានកាតព្វកិច្ចពិនិត្យលើការជំទាស់ពីភាពគ្រប់គ្រាន់នៃភ័ស្តុតាងដាក់បន្ទុកដែលនឹងលើកឡើងខាងក្រោម និងមានកាតព្វកិច្ចធ្វើមោឃភាពលើបទបញ្ញត្តិដែលមានកំហុសទាំងនេះនៃដីកាដំណោះស្រាយ ហើយដែលជនជាប់ចោទមិនអាចប្ដឹងឧទ្ធរណ៍នៅក្នុងដំណាក់កាលបឋម ហើយដែលអង្គជំនុំជម្រះមិនបានទទួលដោយត្រឹមត្រូវស្របតាមនីតិវិធី[270]។

២៩៩. បើខកខានពុំបានធ្វើដូច្នោះទេ អង្គជំនុំជម្រះនឹងផ្ដល់សុពលភាពទៅដល់នីតិវិធីមួយ ដែលជនជាប់ចោទនៃ អ.វ.ត.ក មិនអាចជំទាស់នឹងកំហុសនៃបទចោទលើខ្លួន។ ប្រការនេះធ្វើឱ្យប៉ះពាល់ដោយមិនអាចជួសជុលបានទៅដល់សិទ្ធិទទួលបានការជំនុំជម្រះសេចក្ដីមួយប្រកបដោយយុត្តិធម៌ និងធម្មានុរូបរបស់ អ.វ.ត.ក។

## ភាគទី ៣. គោលការណ៍នីត្យានុកូលភាព (គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង)

### ជំពូកទី ១ .ទំនាក់ទំនងនៃគោលការណ៍ប្រឆាំងនឹងការផ្ដន្ទាទោសតាមទំនើងចិត្ត

៣០០. គោលការណ៍នីត្យានុកូលភាព គឺជាគោលការណ៍ដ៏សំខាន់បំផុតនៃច្បាប់ព្រហ្មទណ្ឌ។ "គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង"*( Nullum crimen, nulla poena sine lege)*។ គោលការណ៍នេះ គឺជាការការពារដ៏ចាំបាច់ប្រឆាំងនឹងការធ្វើតាមទំនើងចិត្ត និងជាការធានាជាមូលដ្ឋាននៃសិទ្ធិសេរីភាពរបស់បុគ្គលនៅក្នុងសង្គមប្រជាធិបតេយ្យ។

៣០១. បុគ្គលត្រូវមានលទ្ធភាពសម្របសម្រួលអាកប្បកិរិយារបស់ខ្លួនទៅនឹងនិយាមដែលមានស្រាប់នៅពេលដែលគេកំពុងធ្វើអ្វីមួយ។ គេត្រូវមានលទ្ធភាពសម្រេចនៅពេលណាមួយ ថាតើត្រូវជ្រើសរើសយកការគោរពតាម ឬរំលោភគោលការណ៍ច្បាប់ ដោយដឹងថាទណ្ឌកម្មផ្សារភ្ជាប់ទៅនឹងការរំលោភបំពានរបស់គាត់។

៣០២. គោលការណ៍នីត្យានុកូលភាពត្រូវបានអភិវឌ្ឍនៅ "សករាជពន្លឺ" ជាពិសេសដោយ Cesare BECCARIA នៅក្នុងស្នាដៃដ៏ល្បីល្បាញរបស់គាត់ ក្រោមចំណងជើងថា "សន្ធិសញ្ញាស្ដីអំពីបទ

---

[270] សូមមើលខាងលើ ជាពិសេស កថាខណ្ឌ ៩៤២-៩៤៨, ១០២២-១០២៨, ១២៥៤-១២៧១។

ល្មើសមជ្ឈិម និងទោសទណ្ឌ" ដែលបោះពុម្ពផ្សាយនៅឆ្នាំ១៧៦៤។ សព្វថ្ងៃនេះ គោលការណ៍នេះមាននៅក្នុងអត្ថបទស្តីអំពីការការពារសិទ្ធិមនុស្ស គឺសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ (មាត្រ ៥ និងមាត្រា ៨) សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (មាត្រា ១១-២) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធពលរដ្ឋ និងនយោបាយ (មាត្រា ១៥) អនុសញ្ញាអ៊ឺរ៉ុបស្តីអំពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (មាត្រា ៧)។ គោលការណ៍នេះក៏មាននៅក្នុងក្រមព្រហ្មទណ្ឌជាច្រើន រួមទាំងក្រមព្រហ្មទណ្ឌកម្ពុជាផងដែរ។

៣០៣. ដូច្នេះ មាត្រា ១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថា៖

> "ច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនេះ"។

៣០៤. មាត្រា ៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា ក្រោមចំណងជើងថា "គោលការណ៍នីត្យានុកូលភាព" ចែងថា៖

> "មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន"[271]។

៣០៥. ទោះបីជាខុសពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធពលរដ្ឋ និងនយោបាយ[272] ក៏អនុសញ្ញាអ៊ឺរ៉ុបស្តីអំពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន មិនអាចយកមកអនុវត្តដោយផ្ទាល់នៅចំពោះមុខ អ.វ.ត.ក បានដែរ ពីព្រោះបទបញ្ញត្តិទាក់ទងនឹងគោលការណ៍នីត្យានុកូលភាពនៃកតិកាសញ្ញា និងអនុសញ្ញានេះ ស្ទើរតែដូចគ្នាទាំងស្រុង។ យុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបដែលមានលក្ខ

---

[271] នៅឆ្នាំ ១៩៥៦ មាត្រា ៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាចែងថា ៖ « ច្បាប់ព្រហ្មទណ្ឌគ្មានអានុភាពប្រតិសកម្មទេ គឺថាបទល្មើសណាបានប្រព្រឹត្ត មុនបទបញ្ញត្តិរបស់ច្បាប់ បទល្មើសនោះ មិនអាចត្រូវនិគ្រោះដោយទោសរបស់ច្បាប់ ដែលទើបនឹងបញ្ញត្តិថ្មីនេះបានទេ »។ ចំណែកឯមាត្រា ១១១-៣ នៃក្រមព្រហ្មទណ្ឌបារាំងវិញ ចែងថា ៖ « គ្មាននរណាម្នាក់ត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយធាតុផ្សំភស្តុតាងមិនត្រូវបានកំណត់ដោយច្បាប់ ឬពីបទលហុដែលធាតុផ្សំភស្តុតាងមិនត្រូវបានកំណត់ដោយបទបញ្ញត្តិនោះឡើយ។ គ្មាននរណាម្នាក់ត្រូវទទួលទោសដែលមិនមានចែងក្នុងច្បាប់នោះឡើយ ប្រសិនបើបទល្មើសជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬតាមបទបញ្ញត្តិ ប្រសិនបើបទល្មើសជាបទលហុ »។

[272] ច្បាប់បង្កើត អ.វ.ត.ក មាត្រា ៣៣ (ថ្មី)។

ណៈលម្អិតជាងយុត្តិសាស្ត្រនៃគណៈកម្មាធិការសិទ្ធិមនុស្ស ជាយុត្តិសាស្ត្រគោល ផ្នែកគោលការណ៍នីត្យានុកូលភាព។

៣០៦. នៅពេលពិចារណាលើការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព ដែលមានចែងនៅមាត្រា ៧ នៃអនុសញ្ញាអ៊ឺរ៉ុបស្តីអំពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបចាប់ផ្តើមដោយរំឭកថា៖

> "ការធានា នៃមាត្រា ៧ ដែលជាធាតុផ្សំជាមូលដ្ឋាននៃធម្មានុរូបនៃច្បាប់ មានសារៈសំខាន់បំផុតនៅក្នុងប្រព័ន្ធការពារអនុសញ្ញានេះ ដូចមាត្រា ១៥ បញ្ជាក់ថា មិនអនុញ្ញាតឱ្យមានករណីលើកលែងណាមួយទេ ទោះបីជាក្នុងកាលៈទេសៈសង្គ្រាម ឬកាលៈទេសៈគ្រោះថ្នាក់ជាសាធារណៈផ្សេងទៀតក៏ដោយ។ យោងទៅតាមកម្មវត្ថុ និងគោលបំណងរបស់មាត្រានេះ យើងត្រូវបកស្រាយ និងអនុវត្តវាយ៉ាងណា សំដៅធានាការការពារប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងការចោទប្រកាន់ ការផ្តន្ទាទោស និងការដាក់ទណ្ឌកម្មតាមទំនើងចិត្ត"[273]។

៣០៧. តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបក៏ប្រកាសផងដែរថា មាត្រា៧ នៃអនុសញ្ញាអ៊ឺរ៉ុបស្តីអំពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន៖

> "មិនកម្រិតមកត្រឹមតែការហាមឃាត់មិនឱ្យអនុវត្តដោយប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដោយបង្កការប៉ះពាល់ដល់ជនជាប់ចោទប៉ុណ្ណោះទេ។ នៅក្នុងមាត្រានេះ មានចែងជាលក្ខណៈទូទៅផងដែរអំពីគោលការណ៍នីត្យានុកូលភាពស្តីអំពីបទល្មើស និងទោសទណ្ឌ *(គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង)* និងអំពីគោលការណ៍ដែលតម្រូវមិនឱ្យអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលក្ខណៈពង្រីក ដែលបង្កព្យសនកម្មដល់ជនជាប់ចោទជាពិសេសតាមវិធីសាស្ត្រសទិសភាព។ គោលការណ៍ទាំងនេះបង្ហាញឱ្យឃើញថា បទល្មើសត្រូវតែកំណត់ឱ្យបានច្បាស់លាស់ដោយច្បាប់"[274]។

---

[273] រឿងក្តី Vasiliauskas តទល់នឹង ប្រទេសលីទុយអានី (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៥៣។

[274] រឿងក្តី Kokkinakis តទល់នឹង ប្រទេសក្រិច (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៥២, រឿងក្តី Vasiliauskas តទល់នឹង ប្រទេសលីទុយអានី (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៥៤។

៣០៨. គោលការណ៍នីត្យានុកូលភាពចែកចេញជាគោលការណ៍អនុសាធ្យន៍បី ដែលផ្អែកលើគោលការណ៍ទាំងបីនេះ វិធានព្រហ្មទណ្ឌមិនត្រូវអនុវត្តដោយប្រតិសកម្ម ត្រូវតែកំណត់ឱ្យច្បាស់លាស់ដោយច្បាប់ (លក្ខខ័ណ្ឌច្បាស់លាស់ស្តីអំពីការដឹងឮ និងការអាចគ្រោងទុកបាន) និងត្រូវតែបកស្រាយចង្អៀត។

## ផ្នែកទី ១ .គោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

៣០៩. ការអនុវត្តដោយប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌត្រូវបានហាមឃាត់ នៅពេលដែលការអនុវត្តនេះបង្កព្យសនកម្មដល់សាមីជន។ គោលការណ៍នេះអនុវត្តចំពោះបទបញ្ញត្តិដែលកំណត់និយមន័យបទល្មើស និងចំពោះបទបញ្ញត្តិដែលកំណត់ទោស។

៣១០. ទាក់ទងនឹងការកំណត់ទោស តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបបានកត់សម្គាល់ជាអាទិ៍ អំពីការអនុវត្តដោយប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ក្នុងករណីម្ចាស់បណ្តឹងឧទ្ធរណ៍មួយរូប។ នៅអំឡុងពេលនៃអង្គហេតុដែលគាត់ត្រូវបានផ្តន្ទាទោស ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានបង្ខាំងខ្លួនរយៈពេលបួនខែយ៉ាងយូរបំផុត ខណៈដែលសាលាឧទ្ធរណ៍បានអនុវត្តច្បាប់ថ្មីចំពោះគាត់ ដែលច្បាប់ថ្មីនេះបានបង្កើនរយៈពេលជាប់ឃុំរហូតដល់ពីរឆ្នាំ[275]។

៣១១. ចំពោះបទបញ្ញត្តិដែលកំណត់បទល្មើស ក្នុងរឿងក្តី Valisiauskas ទល់នឹង Lituanie តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបបានពនិត្យករណីម្ចាស់បណ្តឹងឧទ្ធរណ៍ជនជាតិលីទុយអានីម្នាក់ ដែលត្រូវបានផ្តន្ទាទោសពីបទប្រល័យពូជសាសន៍នៅឆ្នាំ ២០០៤ ចំពោះអង្គហេតុដែលត្រូវបានប្រព្រឹត្តក្នុងឆ្នាំ ១៩៥៣ ដោយអនុលោមតាមបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មីរបស់ប្រទេសលីទុយអានី ដែលបានចូលជាធរមាននៅឆ្នាំ ២០០៣។ តុលាការនេះបានប្រកាសថា៖

> "ក្នុងល័ក្ខខ័ណ្ឌនេះ តុលាការច្បាស់ណាស់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានផ្តន្ទាទោសស្របតាមបទបញ្ញត្តិច្បាប់ដែលមិនចូលជាធរមាននៅក្នុងឆ្នាំ ១៩៥៣ ហើយដូច្នេះ ច្បាស់ណាស់ថាបទបញ្ញត្តិទាំងនេះជាកម្មវត្ថុនៃ

[275] រឿងក្តី Jamil តទល់នឹង ប្រទេសបារាំង (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៣៤-៣៦។

ការអនុវត្តដោយប្រតិសកម្ម។ ការអនុវត្តនេះត្រូវបានវិភាគថាជាការរំលោភបំពានលើមាត្រា ៧ នៃអនុសញ្ញា វាលើកលែងតែមានការបង្ហាញថាការផ្តន្ទាទោសសាមីជន ផ្អែកលើច្បាប់អន្តរជាតិដែលអាចអនុវត្តបាននៅសម័យពាក់ព័ន្ធ”[276]។

៣១២. បន្ទាប់មកទៀត តុលាការសិទ្ធិមនុស្សអឺរ៉ុបបានវិភាគនិយមន័យនៃធាតុផ្សំឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅឆ្នាំ ១៩៥៣ ហើយបានកត់សម្គាល់ថានិយមន័យនេះមិនទូលាយស្មើនិយមន័យដែលត្រូវបានអនុវត្តចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍ដោយអាជ្ញាធរលីទុយអានីទេ។ ប្រការនេះនាំឱ្យតុលាការសិទ្ធិមនុស្សអឺរ៉ុបប្រកាសថា៖

“តុលាការយល់ស្របថា អាជ្ញាធរជាតិមានសិទ្ធិក្នុងការជ្រើសរើសយកនិយមន័យនៃអំពើប្រល័យពូជសាសន៍ទូលាយជាងនិយមន័យដែលមានចែងនៅមាត្រា ២ នៃអនុសញ្ញាឆ្នាំ ១៩៤៨ ស្តីអំពីអំពើប្រល័យពូជសាសន៍។ ក៏ប៉ុន្តែ ភាពបត់បែនរបស់ខ្លួនចំពោះប្រធានបទនេះ មិនអនុញ្ញាតឱ្យតុលាការជាតិប្រកាសការផ្តន្ទាទោសបែបប្រតិសកម្មដោយឈរលើមូលដ្ឋាននៃនិយមន័យទូលាយនៃបទល្មើសនេះទេ”[277]។

៣១៣. អាស្រ័យហេតុនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសន្និដ្ឋានថាមានការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព[278]។

## ផ្នែកទី ២ .គោលការណ៍ដឹងឮ និងអាចគ្រោងទុកបាន

៣១៤. គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោសតម្រូវថាបទល្មើស និងទោសដែលបង្ក្រាបបទល្មើសនេះត្រូវតែកំណត់ឱ្យបានច្បាស់លាស់ដោយច្បាប់។ ប្រការនេះតម្រូវឱ្យមានលក្ខខណ្ឌគុណភាពច្បាស់លាស់ជាពិសេសលក្ខខណ្ឌនៃការដឹងឮ និងនៃការអាចគ្រោងទុកមុនបាន។ ជាក់ស្តែង គឺ

---

[276] រឿងក្តី Vasiliauskas តទល់នឹង Lituanie (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៦៦។

[277] រឿងក្តី Vasiliauskas តទល់នឹង Lituanie (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៨១។

[278] រឿងក្តី Vasiliauskas តទល់នឹង Lituanie (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៨៥-១៨៦, ១៩១។

អ្នកទទួលខុសត្រូវចំពោះមុខច្បាប់ត្រូវមានលទ្ធភាពដឹងឮជាមុនអំពីអ្វីដែលជាបទល្មើស និងអ្វីដែលជាទោសដែលខ្លួនអាចប្រឈមមុខពេលខ្លួនប្រព្រឹត្តអំពើអ្វីមួយ។

៣១៥. ពាក់ព័ន្ធនឹងការកំណត់និយមន័យនៃបទល្មើស ក៏ដូចជាទោសដែលអាចអនុវត្តបាន លក្ខខណ្ឌតម្រូវដ៏តឹងរ៉ឹង នៃ"គុណភាពច្បាប់" ត្រូវបាននិយាយយ៉ាងលម្អិតនៅក្នុងយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប។

## ១. ការដឹងឮ

៣១៦. នៅពេលប្រឈមមុខនឹងការរំលោភបំពានជាសក្តានុពលលើគោលការណ៍នីត្យានុកូលភាព តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបចាប់ផ្តើមដោយពិនិត្យថាតើ "ច្បាប់" ព្រហ្មទណ្ឌដែលជាមូលដ្ឋាននៃការផ្តន្ទាទោសរងបណ្តឹងឧទ្ធរណ៍ ត្រូវបានដឹងឮគ្រប់គ្រាន់ល្មមដោយម្ចាស់បណ្តឹងឧទ្ធរណ៍ដែរឬទេ ឬអាចនិយាយថាតើច្បាប់នេះមានបោះពុម្ពផ្សាយដែរឬទេ?[279]។

៣១៧. តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបក៏អនុវត្តដូចគ្នាចំពោះឧក្រិដ្ឋកម្មអន្តរជាតិដែរ។ ក្នុងរឿងក្តី Korbely ទល់នឹង ប្រទេសហុងគ្រី ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានផ្តន្ទាទោសក្នុងឆ្នាំ២០០១ ចំពោះអង្គហេតុដែលបានកើតឡើងនៅខែ តុលា ឆ្នាំ ១៩៥៦។ នៅពេលនោះ គាត់ជានាយទាហានជាន់ខ្ពស់ អនុសេនីយឯក បំពេញមុខងារជានាយទាហានហ្វឹកហ្វឺន។ តុលាការជាន់ខ្ពស់នៃតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបបានកត់សម្គាល់ថា អនុសញ្ញាទីក្រុងហ្សឺណែវត្រូវបានបញ្ចូលទៅក្នុងច្បាប់ហុងគ្រីតាមរយៈក្រឹត្យឆ្នាំ១៩៥៤ និងត្រូវបានបោះពុម្ពផ្សាយជាកូនសៀវភៅស្តើងមួយ។ លើសពីនេះទៅទៀត ការណែនាំមួយរបស់នាយអគ្គសេនាធិការទាក់ទងនឹងការបង្រៀនអនុសញ្ញានេះ ដោយមានសេចក្តីសង្ខេបអមផង ត្រូវបានចុះផ្សាយក្នុងកាសែតកងទ័ពក្នុងខែ កញ្ញា ឆ្នាំ ១៩៥៦។ អាស្រ័យហេតុនេះ តុលាការ

---

[279] Par exemple ៖ រឿងក្តី Kokkinakis តទល់នឹង ប្រទេសក្រិច (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៥០។

សិទ្ធិមនុស្សអ៊ឺរ៉ុបបានយល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ដឹងឮគ្រប់គ្រាន់អំពីលិខិតតុបករណ៍ទាំងនេះ[280]។

៣១៨. ក្នុងរឿងក្តី Vasiliauskas ទល់នឹង ប្រទេសលីទុយអានី ដែលបានដកស្រង់ខាងលើ តុលាការជាន់ខ្ពស់បានយល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ដឹងឮគ្រប់គ្រាន់ នៅឆ្នាំ១៩៥៣ អំពីលិខិតតុបករណ៍ច្បាប់អន្តរជាតិដែលហាមឃាត់អំពើប្រល័យពូជសាសន៍។ ដោយឡែក តុលាការនេះបានកត់សម្គាល់ថា សហភាពសូវៀតជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងឡុងឆ្នាំ១៩៤៥ ដែលបង្កើតបានជាលក្ខន្តិកៈនៃតុលាការយោធាអន្តរជាតិនៃទីក្រុង Nuremberg និងបានចុះហត្ថលេខា ក្នុងខែធ្នូ ឆ្នាំ ១៩៤៩ លើអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨។ អនុសញ្ញានេះបានចូលជាធរមាននៅឆ្នាំ១៩៥១ បន្ទាប់ពីមានការដាក់លិខិតតុបករណ៍ចំនួនម្ភៃ ស្តីពីការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក[281]។

## ២ .ការអាចគ្រោងទុកមុនបាន

៣១៩. យោងតាមតុលាការជាន់ខ្ពស់នៃតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប៖

---

[280] រឿងក្តី Korbely តទល់នឹង ប្រទេសហុងគ្រី (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ កថាខណ្ឌ ៧៤-៧៥។ នៅក្នុងរឿងក្តីមួយទៀត សភាជាន់ខ្ពស់បានពិនិត្យរួមគ្នានូវការអាចទទួលយក និងការអាចកំណត់ទុកមុនបាននូវការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាមដោយសម្អាងលើច្បាប់ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិស្តីពីសង្គ្រាម ដោយពុំធ្លាប់ជាកម្មវត្ថុនៃការបោះពុម្ពផ្សាយជាផ្លូវការនៅសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ឬនៅសាធារណរដ្ឋសង្គមនិយមសូវៀតនៃឡេតូនី នៅក្នុងករណីពិសេសនៃនាយទាហានមេបញ្ជាការដឹកនាំកងទ័ពមួយក្រុម បន្ទាប់ពីបានកត់សម្គាល់ថា « ច្បាប់ទាំងនេះគឺជាច្បាប់ស្តីពីប្រធានបទជាក់លាក់ល្អិតល្អន់មួយ ដែលកំណត់នូវលក្ខណៈសម្បត្តិនៃការប្រព្រឹត្តបទល្មើស ក្នុងពេលសង្គ្រាម ដែលពាក់ព័ន្ធជាពិសេសដល់កម្លាំងយោធា និងជាពិសេសមេបញ្ជាការ » ៖ រឿងក្តី Kononov តទល់នឹង Lettonie ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១០ (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ២៣៥-២៣៩ និង ២៤៤។

[281] រឿងក្តី Vasiliauskas តទល់នឹង Lituanie (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៦៧-១៦៨។

"សញ្ញាណនៃ "ច្បាប់" តម្រូវឱ្យមានល័ក្ខខ័ណ្ឌគុណភាព បន្ថែមពីលើលក្ខខ័ណ្ឌនៃការដឹងឮ និងដែលអាចគ្រោងទុកមុនបាន។ ល័ក្ខខ័ណ្ឌគុណភាពទាំងនេះត្រូវតែបានបំពេញ ទាំងចំពោះការកំណត់និយមន័យបទល្មើស ទាំងចំពោះទោសដែលបទល្មើសនេះអាចទទួលរងការផ្តន្ទាទោស។ ចាប់តាំងពីពាក្យពេចន៍នៃបទបញ្ញត្តិពាក់ព័ន្ធ ហើយបើចាំបាច់ ដោយមានការបកស្រាយពីតុលាការ អ្នកទទួលខុសត្រូវចំពោះមុខច្បាប់ត្រូវមានលទ្ធភាពដឹង ថាតើអំពើសកម្មនិងអំពើអកម្មណា ដែលបង្កើតទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងថាតើទោសកម្រិតណា ដែលនឹងត្រូវប្រកាសចំពោះអំពើសកម្ម និង/ឬ អំពើអកម្ម។ ជាងនេះទៅទៀត ការអាចគ្រោងទុកមុននៃច្បាប់មិនផ្ទុយនឹងការដែលជនពាក់ព័ន្ធត្រូវការប្រឹក្សាច្បាស់លាស់ដើម្បីវាយតម្លៃអំពីផលវិបាកដែលអាចកើតចេញពីអំពើដែលត្រូវបានកំណត់[282] ក្នុងកម្រិតសមហេតុផលមួយនៅក្នុងកាលៈទេសៈនៃបុព្វហេតុ។"

៣២០. ដូចដែលតុលាការជាន់ខ្ពស់បានរំឭកថ្មីៗនេះនៅក្នុងរឿងក្តី Valiliauskas ទល់នឹង ប្រទេសលីទុយអានី គោលការណ៍ទាំងនេះក៏មានសុពលភាពដែរនៅក្នុងច្បាប់អន្តរជាតិ៖

"បទល្មើសត្រូវតែកំណត់ឱ្យបានច្បាស់លាស់ដោយច្បាប់ ទោះនៅក្នុងច្បាប់ជាតិក្តី ឬក្នុងច្បាប់អន្តរជាតិក្តី។ ល័ក្ខខ័ណ្ឌនេះត្រូវបានបំពេញកាលណាជនទទួលខុសត្រូវចំពោះមុខច្បាប់អាចដឹង ចាប់តាំងពីពាក្យពេជន៍នៃបទបញ្ញត្តិពាក់ព័ន្ធ ហើយបើចាំបាច់ ដោយមានការបកស្រាយពីតុលាការ ឬប្រឹក្សាច្បាប់ច្បាស់លាស់ ថាតើអំពើសកម្មនិងអកម្មណា ដែលបង្កើតទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ"[283]។

៣២១. នៅក្នុងរឿងក្តីនេះ តុលាការជាន់ខ្ពស់បានកត់សម្គាល់ថា តុលាការលីទុយអានីបានអនុវត្តចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍ នូវនិយមន័យនៃអំពើប្រល័យពូជសាសន៍ទូលាយជាងនិយមន័យដែលអាចអនុវត្តបាននៅសម័យអង្គហេតុ ហើយបានសន្និដ្ឋានថា ម្ចាស់បណ្តឹងឧទ្ធរណ៍ ទោះបីជាខ្លួនបានប្រឹក្សាជាមួយនឹងអ្នកច្បាប់ហើយក៏ដោយ ក៏ខ្លួនមិនអាចដឹងថា កាលពីសម័យពាក់ព័ន្ធ អំពើមនុស្សឃាតដែលគាត់ត្រូវបានផ្តន្ទាទោសនោះ អាចវិភាគចេញទៅជាអំពើប្រល័យពូជសាសន៍នោះទេ។

---

282 រឿងក្តី Kafkaris តទល់នឹង Chypre (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ១៤០ (មិនមានឯកសារយោងទៅនឹងសេចក្តីសម្រេចមុនៗនោះឡើយ)។

283 រឿងក្តី Vasiliauskas តទល់នឹង ប្រទេសលីទុយអានី (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៥៤។

អាស្រ័យហេតុដូចនេះ តុលាការជាន់ខ្ពស់បានសន្និដ្ឋានថា មានការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព[284]។

៣២២. ទាក់ទងនឹងទោស តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបបានពិនិត្យជាអាទិ៍ករណីរបស់ដើមបណ្ដឹងឧទ្ធរណ៍ជនជាតិហ្ស៊ីព្រម្នាក់ ដែលត្រូវបានផ្ដន្ទាទោសពីបទមនុស្សឃាតឱ្យជាប់ពន្ធនាគារអស់មួយជីវិត ដែលទោសនេះ កាលពីសម័យអង្គហេតុ ត្រូវជាប់ពន្ធនាគារ២០ឆ្នាំ នៅថ្នាក់អាជ្ញាធរប្រតិបត្ត និងរដ្ឋបាល[285]។ តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុបបានសន្និដ្ឋានថា៖

> "នៅសម័យដែលម្ចាស់បណ្ដឹងឧទ្ធរណ៍បានប្រព្រឹត្តបទល្មើស ច្បាប់ពាក់ព័ន្ធរបស់ប្រទេសហ្ស៊ីព្រក្នុងទិដ្ឋភាពរួម មិនត្រូវបានតាក់តែងឱ្យបានច្បាស់លាស់គ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យម្ចាស់បណ្ដឹងឧទ្ធរណ៍អាចយល់អំពីវិសាលភាពនៃទោសជាប់ពន្ធនាគារមួយជីវិត និងអំពីទម្រង់នៃការអនុវត្តទោស ក្នុងកម្រិតសមស្របណាមួយក្នុងកាលៈទេសៈនោះ ដោយមានក្រុមប្រឹក្សាច្បាស់លាស់សម្រាប់ជួយគាត់។ ដូច្នេះ មានការរំលោភបំពានលើមាត្រា៧ នៃអនុសញ្ញា ពាក់ព័ន្ធនឹងបញ្ហានេះ"[286]។

៣២៣. យោងតាមគោលការណ៍ និងឧទាហរណ៍ទាំងនេះ វាច្បាស់ណាស់ថា ការអាចគ្រោងទុកមុនបានមិនកម្រិតមកត្រឹមតែការគ្រោងទុកជាមុនបានបែបសាមញ្ញនៃការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌតែប៉ុណ្ណោះទេ គឺវាលាតសន្ធឹងរហូតដល់ខ្លឹមសារ និងលទ្ធភាពនៃការយល់ពីទំហំ និងវិសាលភាពនៃការចោទប្រកាន់នេះ។

## ផ្នែកទី ៣ .គោលការណ៍បកស្រាយចង្អៀត និងជាប្រយោជន៍ដល់ជនជាប់ចោទ

៣២៤. គោលការណ៍នីត្យានុកូលភាពស្ដីអំពីបទល្មើស និងទោសកំណត់ថា ចៅក្រមមិនត្រូវបកស្រាយច្បាប់ដោយសេរី ដោយប្រថុយប្រថានដាក់ទណ្ឌកម្មដោយគ្មានមូលដ្ឋានច្បាប់ជាក់ស្ដែងនោះទេ។

---

[284] រឿងក្ដី Vasiliauskas តទល់នឹង ប្រទេសលីទុយអានី (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៧៨, ១៨១, ១៨៥, ១៨៦ និង ១៩១។

[285] រឿងក្ដី Kafkaris តទល់នឹង ប្រទេសស៊ីប (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ១៤៣-១៤៨។

[286] រឿងក្ដី Kafkaris តទល់នឹង ប្រទេសស៊ីប (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ១៥០។

៣២៥. យោងតាមយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប "ជាអនុសាឮនៃគោលការណ៍នីត្យានុកូលភាពស្តីអំពីការផ្តន្ទាទោស បទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌត្រូវតែគោរពតាមគោលការណ៍បកស្រាយចង្អៀត"[287] និងតាមគោលការណ៍ "ដែលតម្រូវមិនឱ្យអនុវត្តច្បាប់ព្រហ្មទណ្ឌតាមលក្ខណពង្រីកដែលបង្កព្យសនកម្មដល់ជនជាប់ចោទ ជាពិសេសតាមវិធីសាស្ត្រសទិសភាព"[288]។

៣២៦. មាត្រា៥ នៃច្បាប់ព្រហ្មទណ្ឌកម្ពុជា ក្រោមចំណងជើងថា "ការបកស្រាយច្បាប់ព្រហ្មទណ្ឌ" ចែងថា៖

> "ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពនៃការអនុវត្ត ឬប្រព្រឹត្តតាមវិធីសទិសភាពបានឡើយ"[289]។

៣២៧. កាលណាមានភាពមន្ទិលសង្ស័យ ឬភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងខ្លឹមសារនៃច្បាប់ព្រហ្មទណ្ឌទោះជាមានការបកស្រាយចង្អៀតហើយក៏ដោយ ក្នុងករណីនេះ គប្បីអនុវត្តគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (*in dubio pro reo*) ដែលជាអនុសាឮនៃគោលការណ៍សច្ចធារណ៍និរទោស ដោយយកវិមតិសង្ស័យជាប្រយោជន៍ដល់សាមីជន។

៣២៨. គោលការណ៍បកស្រាយជាក់លាក់នៃច្បាប់ព្រហ្មទណ្ឌទាំងនេះ មានសរសេរជាលាយលក្ខណ៍អក្សរជាពិសេសនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៅមាត្រា ២២ ក្រោមចំណងជើងថា "គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង" ដែលត្រូវបានបញ្ចូលនៅក្នុងជំពូកទី ៣ ស្តីពី "គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ"៖

---

[287] រឿងក្តី Dragonotiu និង Militaru-Pidhorni តទល់នឹង ប្រទេសរូម៉ានី (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧ កថាខណ្ឌ ៤០។

[288] រឿងក្តី Kokkinakis តទល់នឹង ប្រទេសក្រិច (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៥២។ រឿងក្តី Vasiliauskas តទល់នឹង ប្រទេសលីទុយអានី (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៥៤។

[289] ចំណែកឯមាត្រា ១១១-៤ នៃក្រមព្រហ្មទណ្ឌបារាំងចែងថា ៖ « ច្បាប់ព្រហ្មទណ្ឌគឺជាការបកស្រាយយ៉ាងម៉ត់ចត់ »។

"(២) និយមន័យនៃឧក្រិដ្ឋកម្មត្រូវតែបកស្រាយចង្អៀត ហើយមិនអាចពង្រីកតាមវិធីសាស្ត្រសទិសភាពបានឡើយ។ ក្នុងករណីស្រពិចស្រពិល និយមន័យនេះត្រូវបកស្រាយដើម្បីជាប្រយោជន៍ដល់បុគ្គលដែលជាកម្មវត្ថុនៃការស៊ើបអង្កេត នៃការចោទប្រកាន់ ឬនៃការផ្តន្ទាទោស"។

៣២៩. គោលការណ៍ទាំងនេះត្រូវអនុវត្តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ រួមទាំង អ.វ.ត.ក ផងដែរ។ ឧទាហរណ៍ សាលាឧទ្ធរណ៍នៃតុលាការចំពោះកិច្ចបានរំឭកនៅក្នុងរឿងក្តី Limaj ថាពីមុនមកខ្លួនធ្លាប់ទទួលស្គាល់នៅក្នុងរឿងក្តី Naletilić និង Martinović ថា "គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" ត្រូវតែអនុវត្តចំពោះធាតុផ្សំសត្យានុម័តិដែលជាល័ក្ខខ័ណ្ឌតម្រូវចាំបាច់[290]។ នៅក្នុងរឿងក្តី Renzaho សាលាឧទ្ធរណ៍នៃតុលាការចំពោះកិច្ចបានប្រកាសថា៖

> "គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទចែងថា រាល់វិមតិសង្ស័យត្រូវតែដោះស្រាយដើម្បីជាប្រយោជន៍ដល់ជនជាប់ចោទ។ សាលាឧទ្ធរណ៍ព្យាយាមរំឭកថា គោលការណ៍នេះ ដែលជាអនុសាធ្យនៃសច្ចធារណ៍និរទោស និងបន្ទុកភ័ស្តុតាងហួសពីវិមតិសង្ស័យ ត្រូវអនុវត្តចំពោះសេចក្តីសន្និដ្ឋានដែលជាល័ក្ខខ័ណ្ឌតម្រូវ ដើម្បីប្រកាសពិរុទ្ធភាព <u>ដូចគ្នាចំពោះសេចក្តីសន្និដ្ឋានដែលបង្ហាញអំពីធាតុផ្សំនៃឧក្រិដ្ឋកម្មចោទប្រកាន់</u>"។[291] (យើងជាអ្នកគូសបន្ទាត់ពីក្រោម)

៣៣០. នៅ អ.វ.ត.ក អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា "ក្នុងករណីមិនមានការអនុវត្តរបស់រដ្ឋ និងទស្សនៈច្បាប់ (opinio juris) ដែលបង្ហាញយ៉ាងច្បាស់ថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមាននៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ មិនតម្រូវឱ្យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ដូច្នេះ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទតម្រូវថា រាល់ភាពស្រពិចស្រពិលត្រូវតែបានជាប្រយោជន៍ដល់ជនជាប់ចោទ"[292]។

---

[290] សាលដីកា Limaj (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧ កថាខណ្ឌ ២១ ដែលយោងទៅរឿងក្តី Naletilić និង Martinović (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ កថាខណ្ឌ ១២០ (« ដូច្នេះ បញ្ហានេះនៅមិនទាន់អាចសម្រេចច្បាស់លាស់នៅឡើយ សូម្បីនៅឆ្នាំ ១៩៩៨ ក៏ដោយ។ ដោយសារអវត្តមាននៃការបង្ហាញផ្ទុយគ្នាពីនោះ អត្ថិភាព ឬប្រភេទនៃជម្លោះប្រដាប់អាវុធត្រូវតែយកមកពិនិត្យឡើងវិញ ឱ្យអនុលោមទៅតាមគោលការណ៍ដែលថាវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដូច [...] »)។

[291] សាលដីកា Renzaho (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៤៧៤។

[292] សេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ឯកសារ D427/2/15 កថាខណ្ឌ ១៤៤។

## ជំពូកទី ២. ការកម្ទេចខ្លឹមសារនៃគោលការណ៍នានាដោយអង្គជំនុំជម្រះតុលាការកំពូល

៣៣១. នៅក្នុងសំណុំរឿង 00២/00១ ក្រុមមេធាវីការពារក្តីបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខ អំពីការរំលោភបំពានមួយចំនួនលើគោការណ៍នីត្យានុកូលភាពអំពីសំណាក់អង្គជំនុំជម្រះ។ ក្រុមមេធាវីការពារក្តីបានអះអាងថា ទាក់ទងនឹងឧក្រិដ្ឋកម្ម និងទម្រង់នៃទំនួលខុសត្រូវមួយចំនួន អង្គជំនុំជម្រះបាន "កំណត់មិនច្បាស់លាស់អំពីធាតុផ្សំដែលអាចទម្លាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើជនជាប់ចោទ ដូចដែលវាមាននៅសម័យអង្គហេតុ"។ ក្រុមមេធាវីការពារក្តីក៏បានអះអាងផងដែរថា "អង្គជំនុំជម្រះបានផ្អែកលើវិធានដែលមានក្រោយអង្គហេតុ ដោយវាយតម្លៃថាជនជាប់ចោទដឹងឮ និងអាចគ្រោងទុកបានពីវិធានទាំងនោះ នៅសម័យអង្គហេតុ"[293]។

៣៣២. អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីបានជំទាស់ជាពិសេសចំពោះនិយមន័យនៃធាតុផ្សំអត្តនោម័តៈ នៃអំពើមនុស្សឃាតដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃការសម្លាប់រង្គាលដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃសហឧក្រិដ្ឋកម្មរួម នៃការធ្វើផែនការ នៃការញុះញង់ នៃការជួយ និងការលើកទឹកចិត្ត[294]។ ក្រុមមេធាវីការពារក្តីបានបង្ហាញជាពិសេសអំពីកំហុសច្រំដែលរបស់អង្គជំនុំជម្រះដែលខំទម្លាក់ឱ្យខាងតែបាននូវកម្រិតនៃធាតុផ្សំសត្យានុម័តិដើម្បីបំពេញភាពចន្លោះប្រហោងនៃភ័ស្តុតាងអំពីចេតនាឧក្រិដ្ឋផ្ទាល់ ហើយបានជំទាស់នឹងការអះអាងដោយភ័ន្តច្រឡំ និងគ្មានមូលដ្ឋានទាល់តែសោះ ដែលថា "កម្រិតល័ក្ខខ័ណ្ឌតម្រូវនៃការដឹងឮអាស្រ័យទៅតាមអំពើដែលចោទប្រកាន់ទៅលើជនជាប់ចោទ ដែលបានកើតមានឡើងមុន ក្នុងកំឡុងពេល ឬក្រោយពេលប្រព្រឹត្តឧក្រិដ្ឋកម្ម"[295]។

៣៣៣. ក្រុមមេធាវីការពារក្តីក៏បានជំទាស់ផងដែរទៅនឹងវិធីដែលអង្គជំនុំជម្រះប្រើប្រាស់ពាក់ព័ន្ធនឹងការដឹងឮ និងការអាចគ្រោងទុកបាន និងបានអះអាងថា ជនជាប់ចោទមិនដឹងឮ និងមិនអាចគ្រោងបានទេ

---

[293] សារណាបណ្តឹងសាទុក្ខ 00២/0១ កថាខណ្ឌ ៥0។

[294] សារណាបណ្តឹងសាទុក្ខ 00២/0១ កថាខណ្ឌ ៥៩-៦២ (មនុស្សឃាត) កថាខណ្ឌ ៦៣-៦៧ (ការសម្លាប់រង្គាល) កថាខណ្ឌ ៦៨-៧៣ (សហឧក្រិដ្ឋកម្មរួម) កថាខណ្ឌ ៧៤-៧៩ (ការរៀបចំផែនការ) កថាខណ្ឌ ៨0-៨៦ (ការញុះញង់) កថាខណ្ឌ ៨៧-៩២ (ការជួយ និងជំរុញ)។

[295] សារណាបណ្តឹងសាទុក្ខ 00២/0១ កថាខណ្ឌ ១0៧។

កាលពីឆ្នាំ១៩៧៥ នូវនិយមន័យមិនត្រឹមត្រូវនៃធាតុផ្សំអត្តនោម័តនៃមនុស្សឃាត នៃការសម្លាប់រង្គាល នៃសហឧក្រិដ្ឋកម្មរួម នៃការធ្វើផែនការ នៃការញុះញង់ និងការជួយជ្រោមជ្រែង និងការលើកទឹកចិត្ត[296]។

៣៣៤. ទោះបីជាប្រើពេលអស់ពីរឆ្នាំដើម្បីប្រជុំពិភាក្សាប្រជុំសម្រេចក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលគេចវេសមិនព្រមសម្រេចលើកំហុសទាំងឡាយដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី[297]។ អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់កំហុសរបស់អង្គជំនុំជម្រះទាក់ទងនឹងធាតុផ្សំអត្តនោម័តនៃការសម្លាប់រង្គាល ប៉ុន្តែមិនទទួលស្គាល់កំហុសរបស់អង្គជំនុំជម្រះទាក់ទងនឹងធាតុផ្សំអត្តនោម័តនៃមនុស្សឃាត និងសហឧក្រិដ្ឋកម្មរួមទេ[298]។ អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រវិធីសាស្ត្ររបស់អង្គជំនុំជម្រះទាក់ទងនឹងការដឹងឮ និងការអាចគ្រោងទុកជាមុន[299]។

៣៣៥. តាមរយៈទង្វើនេះ អង្គជំនុំជម្រះតុលាការកំពូលបានរំលោភបំពានដោយខ្លួនឯងផ្ទាល់លើគោលការណ៍នីត្យានុកូលភាព ហើយបានធ្វើឱ្យគោលការណ៍នេះលែងមានន័យខ្លឹមសារ។

៣៣៦. ក៏ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសនៅក្នុងសំណុំរឿង ឌុច នៅឆ្នាំ២០១២ ថា៖

> “លើសពីនេះទៀត ទោះបីជា អ.វ.ត.ក ពឹងផ្អែកយ៉ាងខ្លាំងទៅលើសំអាងហេតុក្នុងការវិភាគ និងការអភិវឌ្ឍច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់តុលាការ *មិនអចិន្ត្រៃយ៍* ក៏ដោយ ក៏ដោយសារតែមុខងារការពារនៃគោលការណ៍នីត្យានុកូលភាព ដូចបានគូសបញ្ជាក់ខាងលើ អង្គជំនុំជម្រះនៃ អ.វ.ត.ក ត្រូវមានកាតព្វកិច្ចក្នុងការសម្រេចថា ការកំណត់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះអាចយកមកអនុវត្តបាននៅក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ខ្លួន ហើយជនជាប់ចោទត្រូវតែអាចយល់ដឹងជាមុនថាជាបទល្មើស និងដឹងជាមុនថាមានច្បាប់ចែង។ បន្ថែមពីនេះទៀត អង្គជំនុំជម្រះតុលាការ

---

[296] សារណាបណ្តឹងសាទុក្ខ ០០២/០១ កថាខណ្ឌ ៩៩-១០២, ១០៤-១០៥។

[297] អង្គជំនុំជម្រះតុលាការកំពូលមិនបានយកចិត្តទុកដាក់ឆ្លើយតបតាមរបៀបទទួលខុសត្រូវផ្សេងទៀត ក្រៅពីសហឧក្រិដ្ឋកម្មរួមឡើយ (ទោះបីជាមានការលើកឡើងនៅ កថាខណ្ឌ ៧៦៦ នៃ សាលដីកា ០០២/០១ យ៉ាងណាក្តី) ហើយក៏មិនឆ្លើយតបចំពោះការអះអាងខុសឆ្គងនៃអង្គជំនុំជម្រះសាលាដំបូងដែលថាកម្រិតចំណេះដឹងគ្រប់គ្រាន់ ប្រែប្រួលទៅតាមពេលវេលា។

[298] សាលដីកា ០០២/០១ កថាខណ្ឌ ៣៨៧-៤១០ (មនុស្សឃាត) កថាខណ្ឌ ៥១៦-៥២២ (ការសម្លាប់រង្គាល) កថាខណ្ឌ ១០៥១-១០៥៥ (សហឧក្រិដ្ឋកម្មរួម។ ត្រង់នេះ តុលាការកំពូលទទួលស្គាល់កំហុសមួយចំនួនតែក៏បានកែប្រែវិញ)។

[299] សាលដីកា ០០២/០១ កថាខណ្ឌ ៧៦១-៧៦៦ និង ១០៩៣-១០៩៥។

កំពូលបញ្ជាក់ថា ការពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ន និងដោយមានសំអាងហេតុអំពីការកំណត់ទាំងនេះ មានសារៈសំខាន់ចាំបាច់ណាស់ក្នុងការធានាអំពី ធម្មានុរូបរបស់ស្ថាប័ន និងសេចក្ដីសម្រេចរបស់ អ.វ.ត.ក" [300]។

៣៣៧. នៅកំណត់ត្រាជើងទំព័រ អង្គជំនុំជម្រះតុលាការកំពូលបានយោងទៅ Kenneth GALLANT "ពាក់ព័ន្ធនឹងគុណតម្លៃនៃការបកស្រាយចង្អៀតបំផុត ផ្ទុយនឹងករណីដែលចៅក្រមឆក់ប្លន់យកមុខងារជាអ្នកបង្កើតច្បាប់ ដោយអនុវត្តច្បាប់ខ្វះភាពច្បាស់លាស់"។ អង្គជំនុំជម្រះតុលាការកំពូលក៏បានដកស្រង់ Guenael METTRAUX ផងដែរទាក់ទងនឹងតុលាការចំពោះកិច្ចៈ

"ការអាចយកទៅប្រើប្រាស់ជាដំណែលយុត្តិសាស្ត្ររបស់តុលាការ ភាគច្រើនមិនអាស្រ័យនឹងការប៉ងប្រាថ្នាផ្នែកទ្រឹស្តីរបស់អ្នកតាក់តែងវាទេ ប៉ុន្តែវាអាស្រ័យនឹងសម្ថភាពរបស់តុលាការក្នុងការបង្កើតសេចក្ដីសម្រេចដោយផ្អែកលើវិធានទាំងអស់ដែលមានកន្លងមក។ ការចូលរួមវិភាគទានរបស់តុលាការទាំងពីរនេះក្នុងប្រវត្តិសាស្ត្រ និងក្នុងវិស័យច្បាប់ អាចមានលក្ខណៈរាក់កំផែលមិនគ្រប់គ្រាន់ ប្រសិនបើតុលាការទាំងពីរនេះនៅតែធ្វើឱ្យគេមានអារម្មណ៍ថាខ្លួនបានជ្រើសយកស្វ័យសោមនស្សផ្នែកបញ្ញា ឬការឈានមុខផ្នែកតុលាការ" [301]។

៣៣៨. ជាអកុសល បួនឆ្នាំក្រោយមក អង្គជំនុំជម្រះតុលាការកំពូលពុំមានសមត្ថភាពដើម្បីធានាធម្មានុរូបនៃ អ.វ.ត.ក។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញនូវភាពជាអ្នកនាំមុខផ្នែកតុលាការយ៉ាងល្អឥតខ្ចោះទៅវិញ (ផ្នែកI)។ លើសពីនេះទៅទៀត អង្គជំនុំជម្រះតុលាការកំពូលនៅតែមិនទាន់ធ្វើការវាយតម្លៃ "លម្អិត និងប្រកបដោយវិចារណញ្ញាណ" ដែលខ្លួនឯងផ្ទាល់បានណែនាំ ប៉ុន្តែផ្ទុយទៅវិញខ្លួនបែរជាឆក់ប្លន់យកមុខងារជាអ្នកបង្កើតច្បាប់ ដោយអនុវត្តច្បាប់ខ្វះភាពច្បាស់លាស់ទៅវិញ (ផ្នែកទី II ដល់ IV)។

៣៣៩. ប្រសិនបើអង្គជំនុំជម្រះមានបំណងប្រាថ្នាចង់ផ្ដល់ធម្មានុរូបដ៏តិចតួចដល់ អ.វ.ត.ក និងបំពេញកាតព្វកិច្ចគោរពគោលការណ៍នីត្យានុកូលភាពដែលសំខាន់ជាងគេបំផុតនៃច្បាប់ព្រហ្មទណ្ឌ ខ្លួនមិន

[300] សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៩៧ និង កំណត់សម្គាល់ជើងទំព័រ ១៨៤។

[301] សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កំណត់សម្គាល់ជើងទំព័រ ១៨៤ (មិនមានឯកសារយោង)។

ត្រូវដាច់ខាតយកគំរូតាម "យុត្តិសាស្ត្រ" ដ៏អកុសល និងមិនថ្លៃថ្នូរ នៃសំណុំរឿង០០២/០០១ នៅក្នុងការជំនុំជម្រះសំណុំរឿង ០០២/០២ នោះឡើយ។

## ផ្នែកទី ១ .ភាពឈានមុខនិយមនៃតុលាការ

៣៤០. ភាពឈានមុខនិយមដ៏ល្អឥតខ្ចោះនៃតុលាការដែលអង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញ ត្រូវបានបញ្ជាក់ឱ្យឃើញតាមរយៈ (I) វិនិច្ឆ័យកិច្ចដ៏មានកំហុស និងលម្អៀង ក៏ដូចជាតាមរយៈ (II) ស្នាដៃនៃគោលនយោបាយឧក្រិដ្ឋរបស់ខ្លួន ដែលណែនាំឱ្យធ្វើការតស៊ូប្រឆាំងនឹងនិទណ្ឌភាព ដោយបង្កផលប៉ះពាល់ទៅលើការតស៊ូប្រឆាំងនឹងការផ្តន្ទាទោសតាមទំនើងចិត្ត។

### ១ .វិនិច្ឆ័យកិច្ចដ៏មានកំហុស និងអគតិ

៣៤១. នៅក្នុងសាលដីកានៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា ដោយហេតុថាឧក្រិដ្ឋកម្ម ឬទម្រង់នៃទំនួលខុសត្រូវដែលចោទប្រកាន់មានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ កាលពីសម័យអង្គហេតុ និងដោយហេតុថាជនជាប់ចោទមានមុខដំណែងខ្ពស់ គោលការណ៍នីត្យានុកូលភាពត្រូវតែគោរព[302]។ អង្គជំនុំជម្រះតុលាការកំពូលបានបន្ថែមទៀតថា៖

> "អង្គជំនុំជម្រះតុលាការកំពូលរំឭកបន្ថែមទៀតថា ទាក់ទងទៅនឹងលក្ខខណ្ឌនៃភាពអាចយល់ដឹងជាមុនបានថាមានច្បាប់ចែងនោះ ក្រៅពីសន្ធិសញ្ញានានា នៅមាន"ច្បាប់នានាដែលបានផ្អែកលើទំនៀមទម្លាប់ [...] អាចយកមកធ្វើជាសំអាងក្នុងការបញ្ជាក់ថា ជនជាប់ចោទអាចយល់ដឹងគ្រប់គ្រាន់បានថា មានច្បាប់ចែង" និងថា ចំពោះភាពអាចយល់ដឹងជាមុនបាន ជនជាប់ចោទ"ត្រូវតែអាចយល់ដឹងថា អំពើដែលខ្លួនប្រព្រឹត្ត គឺជាបទល្មើសក្នុងន័យដែលគេអាចយល់ដឹងជាទូទៅបាន ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយនោះទេ"។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលទទួលយកអំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលបានលើកឡើងថា ដោយសារតែបទឧក្រិដ្ឋមួយចំនួនដែល ខៀវ សំផន ត្រូវបានដាក់ពិរុទ្ធភាពនោះ "គឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុតដែលគេអាចយល់ដឹងបាន។ ខៀវ សំផន មិនអាចប្រកែកថា គាត់មិន

[302] សាលដីកា ០០២/០១ កថាខណ្ឌ ៧៦១-៧៦២, ៧៦៤។

អាចយល់ដឹងបានថា អំពើរបស់គាត់ គឺជាអំពើល្មើសក្នុងន័យដែលមនុស្សទូទៅអាចយល់ដឹងបាននោះឡើយ”[303]។

៣៤២. ដើម្បីធ្វើការ “រំឭកនេះ” អង្គជំនុំជម្រះតុលាការកំពូលបានយោងទៅកថាខណ្ឌ ៩៦ នៃសាលដីកា ឌុច។ ក៏ប៉ុន្តែ កថាខណ្ឌ ៩៦ នៃសាលដីកានេះ មានភាពលម្អិតជាងបន្តិច ហើយបង្គ្រប់ន័យដោយកថាខណ្ឌ ៩៧ ដែលអង្គជំនុំជម្រះតុលាការកំពូលមិនយកមកយោងទេ៖

> “ជាចុងក្រោយ ដើម្បីជាការធានាបន្ថែម ការព្រួយបារម្ភអំពីភាពយុត្តិធម៌ និងដំណើរការនីតិវិធីឆាប់រហ័ស ដែលជាមូលដ្ឋាននៃគោលការណ៍នីត្យានុកូលភាពអន្តរជាតិតម្រូវថា រាល់បទល្មើសដែលបានចោទប្រកាន់ ឬរាល់ទម្រង់នៃការទទួលខុសត្រូវ “ត្រូវមានលក្ខណៈអាចយល់ដឹងជាមុនបានគ្រប់គ្រាន់ថា ជាបទល្មើស ហើយថា ជនជាប់ចោទអាចដឹងច្បាប់ដែលចែងអំពីការទទួលខុសត្រូវបែបនេះ នាពេលនោះ”។ “ចំពោះភាពអាចយល់ដឹងជាមុនថាជាបទល្មើសនោះ ជនជាប់ចោទត្រូវតែអាចដឹងថា អំពើដែលខ្លួនប្រព្រឹត្ត គឺជាអំពើព្រហ្មទណ្ឌក្នុងន័យដែលគេអាចយល់ដឹងជាទូទៅ ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយនោះទេ”។ ចំពោះល័ក្ខខ័ណ្ឌដែលឡអាចដឹងថាមានច្បាប់ចែងនោះ ក្រៅពីច្បាប់សន្ធិសញ្ញានានា នៅមានច្បាប់នានាដែលផ្អែកលើទំនៀមទម្លាប់ ឬគោលការណ៍ទូទៅ ក្នុងការបញ្ជាក់ថា ជនជាប់ចោទអាចដឹងថាមានច្បាប់ចែងគ្រប់គ្រាន់។ បន្ថែមលើនេះអង្គជំនុំជម្រះ “អាចសំអាងលើច្បាប់ជាតិក្នុងគោលបំណងបញ្ជាក់ថា ជនជាប់ចោទអាចដឹងដោយសមហេតុផលថា បទល្មើសដែលជាបញ្ហានេះ ឬបទល្មើសដែលបានប្រព្រឹត្តដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺជាអំពើដែលត្រូវបានហាមឃាត់ និងអាចផ្តន្ទាទោសបាន”។ ជាចុងក្រោយ “ថ្វីត្បិតតែ អំពើអសីលធម៌ ឬអំពើដែលមានចរិតលក្ខណៈគួរឱ្យរន្ធត់ មិនអាចចាត់ជាកត្តាគ្រប់គ្រាន់ដើម្បីកំណត់ថា ជាបទល្មើសព្រហ្មទណ្ឌក៏ដោយ (...) ក៏អំពើបែបនេះអាចដើរតួនាទី (...) ក្នុងការបដិសេធចំពោះការអះអាងណាមួយរបស់ជនជាប់ចោទដែលថា ខ្លួនមិនបានដឹងអំពីចរិតព្រហ្មទណ្ឌនៃអំពើនោះដែរ”។
>
> ៩៧. ដោយយោងតាមគោលការណ៍នីត្យានុកូលភាព និងការការពារដោយគោលការណ៍នេះ ទោះជាយ៉ាងណាក្តី អ.វ.ត.ក មានកាតព្វកិច្ចក្នុងការធានាថាល័ក្ខខ័ណ្ឌតម្រូវកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការចូលរួមពិតជាមានចែងដោយច្បាប់នៅសម័យកាលពាក់ព័ន្ធដែលស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ខ្លួន។ លើសពីនេះទៅទៀត ជនជាប់ចោទត្រូវតែអាចដឹងឮ និងគ្រោងទុកជាមុនថាល័ក្ខខ័ណ្ឌតម្រូវ និងទម្រង់នៃការចូលរួមទាំងនេះពិតជាមានចែងដោយច្បាប់មែន។
>
> លើសពីនេះទៅទៀត អង្គជំនុំជម្រះតុលាការកំពូលគូសបញ្ជាក់ថា ការពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ន និងដោយមានសំអាងហេតុអំពីការកំណត់ទាំងនេះ មានសារៈសំខាន់ចាំបាច់ណាស់ក្នុងការធានាអំពីធម្មានុរូបរបស់ស្ថាប័ន និងសេចក្តីសម្រេចរបស់ អ.វ.ត.ក។ (យើងជាអ្នកគូសបន្ទាត់ពីក្រោម)

[303] សាលដីកា ០០២/០១ កថាខណ្ឌ ៧៦២ (មិនមានឯកសារយោង)។

៣៤៣. រវាងសាលដីកា ឌុច និងសាលដីកាលើសំណុំរឿង ០០២/០១ មានបាត់សេចក្តីប្រកាសមួយចំនួនដែលបានលើកឡើងថា៖

- គឺនិយមន័យនៃធាតុផ្សំនៃឧក្រិដ្ឋកម្ម ឬទម្រង់នៃការចូលរួម ដែលត្រូវតែមាននៅកាលពីសម័យអង្គហេតុ ដែលនិយមន័យនេះមិនត្រឹមតែចែងដោយច្បាប់ប៉ុណ្ណោះទេ តែថែមទាំងត្រូវតែដឹងឮ និងអាចគ្រោងទុកមុនបាន ដោយជនជាប់ចោទទៀតផង
- ចៅក្រមអាចផ្អែកលើច្បាប់ជាតិ ដើម្បីបង្ហាញថាជនជាប់ចោទគួរតែយល់ដឹងសមរម្យល្មមថាឧក្រិដ្ឋកម្មក្នុងករណីនេះ ឬឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តតាមការរៀបរាប់នៅក្នុងដីកាចោទប្រកាន់ ត្រូវបានហាមឃាត់ និងផ្តន្ទាទោស។

៣៤៤. ការមិននិយាយពីសេចក្តីប្រកាសមួយចំនួននេះ គឺពិតជាមិនមែនដោយអចេតនាទេ ដោយហេតុថាវាជាឡូកវណ៍ចម្បងទាំងពីរដែលក្រុមមេធាវីការពារក្តីបានលើកឡើង។

៣៤៥. ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលបានត្រឹមតែឆ្លើយថា "ជនជាប់ចោទត្រូវតែមានសមត្ថភាពដឹង ថាតើអំពើរបស់ខ្លួនមានលក្ខណៈឧក្រិដ្ឋស្របតាមន័យដែលគេយល់ជាទូទៅដែរឬទេ ដោយមិនចាំបាច់យោងទៅលើបទបញ្ញត្តិជាក់លាក់ណាមួយទេ"។ អង្គជំនុំជម្រះតុលាការកំពូលគ្រាន់តែយោងទៅសេចក្តីសម្រេចមួយនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ដែលនៅក្នុងសេចក្តីសម្រេចនេះ មានការអះអាងឡើងដោយគ្មានអៀនខ្មាស និងគ្មានប្រភពថា "<u>ទាក់ទងនឹងការអាចគ្រោងទុកមុនបាន</u> <u>អំពើក្នុងករណីនេះជាអំពើផ្ទាល់របស់ជនជាប់ចោទ</u>។ ជនជាប់ចោទត្រូវតែមានសមត្ថភាពដឹង ថាតើអំពើរបស់ខ្លួនមានចរិតឧក្រិដ្ឋស្របតាមខ្លឹមសារដែលគេយល់ជាទូទៅដែរឬទេ ដោយមិនចាំបាច់យោងទៅលើបទបញ្ញត្តិជាក់លាក់ណាមួយឡើយ"(យើងជាអ្នកគូសបន្ទាត់ពីក្រោម)[304]។ ក៏ប៉ុន្តែ ទាក់ទងនឹងការអាចគ្រោងទុកមុនបាន អំពើក្នុងករណីនេះគឺជាអំពើដែលបានរៀបរាប់នៅក្នុងនិយមន័យនៃអំពើដែលនាំឱ្យមានទោសឧក្រិដ្ឋ គឺប្រាកដណាស់ មិនមែនជាអំពើផ្ទាល់របស់ជនជាប់ចោទទេ (សូមមើលផ្នែកខាងក្រោម II)។

---

[304] សាលដីកា ០០២/០១ កថាខណ្ឌ ៧៦២ កំណត់សម្គាល់ជើងទំព័រ ១៩៨៣ ដែលយោងទៅ រឿងក្តីរបស់រដ្ឋអាជ្ញា តទល់នឹង Hažihasanović និងបក្ខពួក, IT-01-47-AR72 សេចក្តីសម្រេចទាក់ទងនឹងអញ្ញត្រកម្មនៃអសមត្ថភាព (ការទទួលខុសត្រូវនៃថ្នាក់លើ) ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ៣៤។

៣៤៦. បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលបានព្យាយាមបង្វែរបញ្ហាដោយបំភ្លៃសំអាងហេតុ៖

> "ចំពោះអំណះអំណាងដែលបានលើកឡើងថា បទដ្ឋានអន្តរជាតិពុំអាចបង្កើតបានជាផ្នែកមួយនៃច្បាប់ជាតិនៅក្នុងអំឡុងពេលនៃអង្គហេតុដោយសារកម្ពុជាមានប្រព័ន្ធគតិយុត្តទ្វិកនិយម និងថា ពុំអាចរំពឹងទុកបានចំពោះការអនុវត្តបទដ្ឋានអន្តរជាតិនោះ ខៀវ សំផន បានបង្ហាញពុំត្រឹមត្រូវអំពីការយល់ឃើញរបស់អង្គបុរេជំនុំជម្រះដែលខ្លួនបានយោងនៅក្នុងសារណាបណ្ដឹងសាទុក្ខ។ នៅក្នុងកថាខណ្ឌបន្ទាប់ដែល ខៀវ សំផន បានយោងទៅលើនោះ អង្គបុរេជំនុំជម្រះបានយល់ឃើញថា "ច្បាប់ អ.វ.ត.ក [...] តម្រូវឱ្យ អ.វ.ត.ក អនុវត្តយុត្តាធិការរបស់ខ្លួនឱ្យស្របតាមគោលការណ៍នីត្យានុកូលភាពអន្តរជាតិ ដែលបានអនុញ្ញាតសម្រាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសទាំងឡាយដែលមានចរិតលក្ខណៈជាតិ ឬអន្តរជាតិក្នុងអំឡុងពេលនៃការប្រព្រឹត្តបទល្មើសទាំងនេះ" ដែលជាការយល់ឃើញមួយស៊ីសង្វាក់គ្នាយ៉ាងច្បាស់ជាមួយនឹងសាលដីការឿងក្ដី ឌុច (សំណុំរឿង ០០១-F28)" (មានគូសបន្ទាត់ពីក្រោមក្នុងច្បាប់ដើម)[305]។

៣៤៧. ក៏ប៉ុន្តែ ដើម្បីគាំទ្រដល់អំណះអំណាងរបស់ខ្លួន ក្រុមមេធាវីការពារក្ដីមិនបានយោងទៅសេចក្ដីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះទាល់តែសោះ ប៉ុន្តែយោងទៅឧទាហរណ៍នៃយុត្តិសាស្ត្រដែលខ្លួនបានរៀបរាប់នៅផ្នែកទី២នៃកំណត់ត្រាជើងទំព័រដ៏វែងមួយ ដែលនៅក្នុងកំណត់ត្រានេះ ចៅក្រមខ្លះមិនបានអនុវត្តច្បាប់អន្តរជាតិ ក្នុងខណៈពុំមានការតាក់តែងច្បាប់ដូចគ្នាក្នុងថ្នាក់ជាតិ[306]។

---

[305] សាលដីកា ០០២/០១ កថាខណ្ឌ ៧៦៣។

[306] សារណាបណ្ដឹងសាទុក្ខ ០០២/០១ កថាខណ្ឌ ១០១ និង កំណត់សម្គាល់ជើងទំព័រ ២១៨ បានលើកឡើងថា ៖ « សាលក្រមកថាខណ្ឌ ១៨ កំណត់សម្គាល់ ៤០ ៖ រឿងក្ដី Kononov តទល់នឹង ប្រទេសឡេតូនី កថាខណ្ឌ ២០៨ (ស្ដីពីអំឡុងពេលនៃការចងក្រង ច្បាប់ និងច្បាប់ទំនៀមទម្លាប់ទាក់ទងនឹងសង្គ្រាម រហូតដល់គោលការណ៍នៃតុលាការនៅ Nuremberg ៖ *«<u>ទាំងច្បាប់អន្តរជាតិ ទាំងច្បាប់ជាតិ (រួមបញ្ចូលទាំងបទដ្ឋានអន្តរជាតិដែលយកទៅអនុវត្តណៅទីកន្លែងផ្សេង)</u> បានប្រើប្រាស់ប្រើជាមូលដ្ឋានសម្រាប់ធ្វើការចោទប្រកាន់ និងកំណត់ការទទួលខុសត្រូវនៅថ្នាក់ជាតិ »* យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ តុលាការកំពូល-សភាព្រហ្មទណ្ឌ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០០៣ ព្រឹត្តប័ត្រនៃតុលាការកំពូល ឆ្នាំ២០០៣ លេខ ១២២ (រឿងក្ដី Aussaresses ៖ *« ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចកាត់បន្ថយអវត្តមាននៃអត្ថបទចោទប្រកាន់ តាមរយៈការកំណត់ឈ្មោះបទល្មើស [ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ] ចំពោះអង្គហេតុដែលចោទដោយដើមបណ្ដឹងរដ្ឋប្បវេណីបានឡើយ »*)។ ចំពោះឧទាហរណ៍ផ្សេងទៀត សូមមើល ៖ សេចក្ដីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១ **ឯកសារ D427/2/15** កថាខណ្ឌ ៩៧ កំណត់សម្គាល់ ២១៥ ទំព័រ ៤៤, អញ្ញត្រកម្មរួមបញ្ចូលគ្នា របស់ លោក នួន ជា **ឯកសារ E51/3** កថាខណ្ឌ ៤៨, បណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ **ឯកសារ D427/1/6** កថាខណ្ឌ ១២៣ កំណត់សម្គាល់២៥០។ » (មានគូសបន្ទាត់នៅក្នុងឯកសារដើម)។ ជាការច្បាស់ណាស់ដែលថាមេធាវីការពារក្ដីបានយោងទៅ « ឧទាហរណ៍ផ្សេងទៀត »

៣៤៨. លើសពីនេះទៅទៀត សេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះស៊ីគ្នាជាមួយនឹងការពិចារណាអំពីច្បាប់ជាតិដោយចៅក្រម។ ជាក់ស្តែងគឺជាអ្វីដែលអង្គបុរេជំនុំជម្រះខ្លួនឯងផ្ទាល់បានធ្វើក្នុងសេចក្តីសម្រេចមួយ ដើម្បីប្រកាសថាខ្លួនមិនប្រាកដថានៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ជនត្រូវចោទអាចប្រមើលទុកជាមុន ថាខ្លួនអាចមានទំនួលខុសត្រូវអនុលោមតាមទម្រង់ទី៣នៃសហឧក្រិដ្ឋកម្មរួម ដោយហេតុថាអង្គបុរេជំនុំជម្រះមិនអាចកំណត់ក្នុងច្បាប់កម្ពុជានូវបទបញ្ញត្តិមួយនៃសម័យអង្គហេតុដែលអាចធ្វើឱ្យជនត្រូវចោទប្រមើមើលដឹងជាមុន ថាខ្លួនអាចប្រឈមមុខនឹងទម្រង់នៃទំនួលខុសត្រូវនេះ។ អង្គបុរេជំនុំជម្រះក៏បានសន្និដ្ឋានថា គោលការណ៍នីត្យានុកូលភាពប្រឆាំងនឹងការអនុវត្តទម្រង់ទី៣នៃសហឧក្រិដ្ឋកម្មរួមនៅចំពោះមុខ អ.វ.ត.ក[307]។

៣៤៩. មេធាវីការពារក្តីពិតជាបានយោងទៅសេចក្តីសន្និដ្ឋានមួយនៃអង្គបុរេជំនុំជម្រះមែន ក៏ប៉ុន្តែយោងតែទៅនឹងសេចក្តីសន្និដ្ឋានមួយនេះតែប៉ុណ្ណោះ[308]។ អង្គជំនុំជម្រះតុលាការកំពូលព្យាយាមមិនព្រមលើកអំពីចំណុចនេះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលមិនអាចចោទប្រកាន់ក្រុមមេធាវីការពារក្តីថាបានបំភ្លៃសេចក្តីសន្និដ្ឋាននេះ ក្នុងខណៈដែលទាំងអង្គជំនុំជម្រះ ទាំងសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ក៏បានយល់សេចក្តីសន្និដ្ឋាននេះក្នុងន័យដូចគ្នាដែរ[309]។

៣៥០. រីឯការអះអាងរបស់អង្គជំនុំជម្រះតុលាការកំពូលថា ជនជាប់ចោទត្រូវតែមានសមត្ថភាពដឹងថាតើអំពើរបស់ខ្លួនមានចរិតឧក្រិដ្ឋតាមខ្លឹមសារដែលគេយល់ជាទូទៅដែរឬអត់ ដោយមិនចាំបាច់យោងទៅលើបទបញ្ញត្តិជាក់លាក់ណាមួយទេ គឺជាការអះអាងផ្ទុយនឹងគោលការណ៍នីត្យានុកូលភាព និង

---

គឺជាឧទាហរណ៍បន្ថែម និងឧទាហរណ៍ដែលលើកឡើងដោយអង្គបុរេជំនុំជម្រះ នៅក្នុងកំណត់សម្គាល់ជើងទំព័រ ២១៥ ហើយបើនិយាយឱ្យច្បាស់ថែមទៀត គឺនៅទំព័រ ៤៤ (កំណត់សម្គាល់ជើងទំព័រ ២១៥ នៅក្នុងទំព័រ ៤៣ និង ៤៤)។

[307] សេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ **ឯកសារ D97/15/9** កថាខណ្ឌ ៨៧។

[308] សារណាបណ្តឹងសាទុក្ខ ០០២/០១ កថាខណ្ឌ ១០៥ និង កំណត់សម្គាល់ជើងទំព័រ ២២៣ ដែលយោងទៅ សេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ **ឯកសារ D97/15/9** កថាខណ្ឌ ៨៧។

[309] សេចក្តីសម្រេចនៃអង្គជំនុំជម្រះ ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ **ឯកសារ E100/6** កថាខណ្ឌ ២៨។ សាលដីកា Đorđević (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៤ កថាខណ្ឌ ៥០។

ផ្ទុយពីខ្លឹមសារជីវិតនៃគោលការណ៍នេះ។ តាមការពិត ការអះអាងនេះគ្មានប្រយោជន៍អ្វីក្រៅពីជីកកប់គោលការណ៍នេះក្នុងគោលបំណងដាក់ទណ្ឌកម្មតែប៉ុណ្ណោះ។

## ២ .គោលនយោបាយឧក្រិដ្ឋ៖ ការតស៊ូប្រឆាំងនឹងនិន្នាការដែលបង្កផលប៉ះពាល់ដល់ការតស៊ូប្រឆាំងនឹងការផ្ដន្ទាទោសតាមទំនើងចិត្ត

៣៥១. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វាគ្រប់គ្រាន់បាត់ទៅហើយ បើជនជាប់ចោទដឹងថាតើអំពើរបស់ខ្លួនមានចរិតឧក្រិដ្ឋស្របតាមខ្លឹមសារដែលគេយល់ជាទូទៅ ដោយមិនចាំបាច់យោងទៅបទបញ្ញត្តិជាក់លាក់ណាមួយឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយសហព្រះរាជអាជ្ញាក្នុងការពិចារណាថា នៅពេលដែលឧក្រិដ្ឋកម្មស្ថិតក្នុងចំណោមឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរជាងគេបំផុត ជនជាប់ចោទមិនអាចអះអាងយ៉ាងហ្មត់ចត់ថា ខ្លួនមិនយល់ថាអំពើរបស់ខ្លួនមានចរិតឧក្រិដ្ឋតាមខ្លឹមសារដែលគេយល់ជាទូទៅនោះទេ។[310]

៣៥២. បើនិយាយមួយបែបទៀត វាជាការគ្រប់គ្រាន់បាត់ទៅហើយ ក្នុងករណីដែលជនជាប់ចោទមានសម្ថភាពដឹងថាខ្លួនបានធ្វើអាក្រក់។ ហើយនៅពេលដែលជនជាប់ចោទធ្វើមហាអាក្រក់ ដោយម៉ត់ចត់ខ្លួនមិនអាចអះអាងថាខ្លួនមិនយល់ថាខ្លួនបានធ្វើអាក្រក់នោះទេ។

៣៥៣. វាមិនត្រឹមតែជាអ្នកទូន្មានសាមញ្ញប៉ុណ្ណោះទេ អង្គជំនុំជម្រះតុលាការកំពូលថែមទាំងបានអនុវត្តការពិចារណាបែបនេះទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម និងអំពើមនុស្សឃាតដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៀតផង។ គំនិតនេះមានប្រយោជន៍យ៉ាងខ្លាំងណាស់ ដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូលអាចគេចផុតរាល់ដងពីបញ្ហាពាក់ព័ន្ធនឹងនិយមន័យនៃចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម។

៣៥៤. ដូច្នេះ ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា៖

[310] សាលដីកា ០០២/០១ កថាខណ្ឌ ៧៦២។

"ទាក់ទងទៅនឹងអំណះអំណាងអំពីភាពអាចដឹងជាមុនថា ជាបទល្មើស និងមានច្បាប់ចែងអំពីទម្រង់នៃការទទួលខុសត្រូវដែល ខៀវ សំផន ត្រូវបានប្រកាសដាក់ពិរុទ្ធភាពនោះ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញខាងលើរួចហើយថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការយល់ឃើញថា នៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងបទចោទ បុគ្គលម្នាក់អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសារការរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តគោលបំណងល្មើសរួម។ ការយល់ឃើញនេះបានផ្អែកជាពិសេសលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជនជាប់ចោទអាចយល់ដឹងជាមុនបានថា ទម្រង់នៃការទទួលខុសត្រូវនេះ មានច្បាប់ចែង និងជាបទល្មើស ដែលត្រូវដាក់អ្នកបានចូលរួមក្នុងគោលបំណងឧក្រិដ្ឋរួម និងរួមចំណែកក្នុងការអនុវត្ត ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលជា ឬពាក់ព័ន្ធទៅនឹងគោលបំណងរួមនេះ ពោលគឺដោយសារភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនេះ។ ខៀវ សំផន ពុំអាចអះអាងបានថា ខ្លួនពុំអាចដឹងជាមុនថា នឹងត្រូវដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការចូលរួមក្នុងសកម្មភាពដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនោះឡើយ"[311]។

៣៥៥. អង្គជំនុំជម្រះតុលាការកំពូលបានទាញការសន្និដ្ឋានដូចតទៅនេះ៖

"ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន បានដឹងជាមុនគ្រប់គ្រាន់ថា គាត់អាចនឹងត្រូវដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួម ដូចបានបញ្ជាក់ខាងលើ"[312]។

៣៥៦. ដូច្នេះ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មអាចអនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូលរួចផុតពីកាតព្វកិច្ច៖ ១) ពិនិត្យមើលការអាចដឹងឮបានរបស់ ខៀវ សំផន អំពីយុត្តិសាស្ត្រនាសម័យក្រោយសង្គ្រាម ២) ឆ្លើយនូវសំណួរដែលគេសួរទៅខ្លួនអំពីការអាចគ្រោងទុកមុនបានអំពីនិយមន័យនៃធាតុផ្សំអត្តនោម័តនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ ដែលអង្គជំនុំជម្រះបានកំណត់។ ជាក់ស្តែង ផ្ទុយពីអ្វីដែលអង្គជំនុំជម្រះតុលាការកំពូលធ្វើឱ្យគេជឿ ក្រុមមេធាវីការពារក្តីមិនដែលបានអះអាងថា កាលពីសម័យអង្គហេតុ ខៀវ សំផន មិនអាចប្រមើលមើលទុកជាមុនអំពីសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយនោះទេ។ ក្រុមមេធាវីការពារក្តីបានអះអាងថា ខៀវ សំផន មិនអាចប្រមើលមើលទុកជាមុនអំពីសហ

---

[311] សាលដីកា ០០២/០១ កថាខណ្ឌ ១០៩៣។

[312] សាលដីកា ០០២/០១ កថាខណ្ឌ ១០៩៥។

ឧក្រិដ្ឋកម្មរួមទម្រង់ទីមួយដែលមានធាតុផ្សំអត្តនោម័តកម្រិតទាបជាងចេតនាផ្ទាល់ គឺបានន័យថា គាត់មិនអាចប្រមើលមើលទុកជាមុនអំពីសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ ដែលមានធាតុផ្សំអត្តនោម័តនៃសហឧក្រិដ្ឋកម្មទម្រង់ទីបី[313]។ តាមលំអាននេះ អង្គជំនុំជម្រះតុលាការកំពូលបានគេចវេសមិនឆ្លើយតបនឹងបណ្តឹងនេះ ទោះបីជាបណ្តឹងនេះមានលក្ខណៈស្របច្បាប់។

៣៥៧. ម្យ៉ាងទៀត ដោយហេតុធាតុផ្សំសត្យានុម័តិនៃសហឧក្រិដ្ឋកម្មទម្រង់ទីមួយ ដូចគ្នានឹងធាតុផ្សំសត្យានុម័តិនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី បើយើងត្រូវដើរតាមវិនិច្ឆ័យកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូល ដោយហេតុថាឧក្រិដ្ឋកម្មក្នុងករណីនេះធ្ងន់ធ្ងរ ជនជាប់ចោទទាំងអស់គួរតែអាចប្រមើលមើលទុកជាមុនបាននូវសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី។ ក៏ប៉ុន្តែ បើអង្គបុរេជំនុំជម្រះមានសមត្ថភាពយល់ឃើញផ្ទុយពីនេះ គឺមានន័យថាទ្រឹស្តីរបស់អង្គជំនុំជម្រះតុលាការកំពូលមិនអាចដំណើរការបានតាមរបៀបនេះទេ។

៣៥៨. ទាក់ទងនឹងអំពើមនុស្សឃាតដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា ៖

> “ចំពោះភាពអាចយល់ដឹងជាមុនបានថា ជាបទល្មើស និងមានច្បាប់ចែងអំពីធាតុផ្សំ*អត្តនោម័ត*នៃបទមនុស្សឃាត និងបទសម្លាប់រង្គាល អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យពិចារណាឡើងវិញយ៉ាងទូលំទូលាយអំពីធាតុផ្សំអត្តនោម័តនៃបទឧក្រិដ្ឋទាំងនេះ។ ទាក់ទងទៅនឹងបទមនុស្សឃាត ការពិចារណានេះឈានទៅធ្វើសេចក្តីសន្និដ្ឋានបានថា ធាតុផ្សំអត្តនោម័តដែលមានលក្ខណៈពុំសូវរឹតត្បិតដោយយកទាំងចេតនាផ្ទាល់ និងប្រយោល គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ ១៩៧៥។ ដូចបានកត់សម្គាល់ខាងលើ ពាក់ព័ន្ធទៅនឹងភាពអាចយល់ដឹងជាមុនបាន ជនជាប់ចោទ“អាចដឹងគ្រប់គ្រាន់បានថា អំពើដែលខ្លួនប្រព្រឹត្ត គឺជាអំពើល្មើសក្នុងន័យដែលមនុស្សទូទៅអាចយល់ដឹងបាន ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយ”នោះឡើយ។ ដូច្នេះ អ្វីដែលតម្រូវនោះ គឺមិនមែនជាការពិចារណាអំពីពាក្យពេចន៍បច្ចេកទេសក្នុងនិយមន័យនៃឧក្រិដ្ឋកម្មនោះឡើយ ប៉ុន្តែនៅត្រង់ ថាតើជាទូទៅអាចយល់ដឹងជាមុនបានថា អំពើនោះអាចតម្រូវឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែរ ឬយ៉ាងណា។ អាស្រ័យហេតុនេះ ពុំមានភាពចាំបាច់ត្រូវបង្ហាញថា អាចយល់ដឹងជាមុនបានថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌអាចកើតឡើងនៅក្នុងកាលៈទេសៈនៃការប្រព្រឹត្តដោយ*ចេតនាប្រយោល* (dolus eventualis) ដែលផ្ទុយពី*ចេតនាផ្ទាល់* (dolus directus) នោះ

[313] សារណាបណ្តឹងសាទុក្ខ ០០២/០១ កថាខណ្ឌ ១០៥ និង ១០៧។

ទេ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងដែលបានលើកឡើងទាក់ទងទៅនឹងបញ្ហានេះ”[314]។

៣៥៩. ត្រង់នេះដែរ អំពើដែលបង្ហាញឱ្យឃើញនូវឥរិយាបទគួរឱ្យស្តីបន្ទោស អនុញ្ញាតឱ្យតុលាការកំពូលឆក់យកឱកាសគេចឱ្យផុតពីកាតព្វកិច្ចៈ ១) ពិនិត្យលើបញ្ហាសួរថាតើសាមីខ្លួន អាចដឹងពីប្រភពដែលខ្លួនផ្អែកលើដើម្បីទាញការសន្និដ្ឋានរបស់ខ្លួនថា ធាតុផ្សំអត្តនោមតិមានកម្រិតទាបជាងធាតុផ្សំផ្ទាល់ ពិតជាមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិស្តីពីមនុស្សឃាត ២) ពិនិត្យការអាចគ្រោងទុកជាមុនបាននូវនិយមន័យនៃធាតុផ្សំអត្តនោម័តនៃអំពើមនុស្សឃាត។

៣៦០. ម្យ៉ាងទៀត ប្រសិនបើយើងដើរតាមវិនិច្ឆ័យកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូលពីដើមដល់ចប់ យើងមិនយល់ថាហេតុអ្វីបានជាអង្គជំនុំជម្រះតុលាការកំពូលខំព្យាយាមវិភាគពាក្យបច្ចេកទេសនៃនិយមន័យនៃពាក្យសម្លាប់រង្គាល ដើម្បីបង្ហាញថាការសម្លាប់រង្គាលនេះពិតជាមាននៅសម័យអង្គហេតុ។ សរុបទៅ យោងតាមតក្កវិជ្ជានេះ ចាប់ពីពេលដែលអំពើសម្លាប់រង្គាលត្រូវបានចោទប្រកាន់នៅសម័យអង្គហេតុពាក់ព័ន្ធ ទោះបីចារីប្រព្រឹត្តដោយចេតនាផ្ទាល់ក្តី ឬប្រយោលក្តី ចារីអាចដឹងថាអ្វីដែលខ្លួនបានធ្វើ គឺជាអំពើអាក្រក់ ហើយវាអាចនាំឱ្យខ្លួនមានទំនួលខុសត្រូវព្រហ្មទណ្ឌ...។

៣៦១. នៅចុងបញ្ចប់ របៀបគិតគូររបស់អង្គជំនុំជម្រះតុលាការកំពូលដែលប្រដូចការអាចប្រមើលឃើញទុកជាមុនបាននៃការចោទប្រកាន់ជាបទល្មើស ទៅនឹងការអាចប្រមើលឃើញទុកជាមុនបាននូវឥរិយាបថដែលគួរស្តីបន្ទោសរបស់ទង្វើមួយនោះ គឺមានន័យថា សាមីជនអាចប្រមើលឃើញទុកជាមុនបានអំពីឧក្រិដ្ឋកម្មមួយ ឬទម្រង់នៃការចូលរួមមួយដែលមានលក្ខណៈមិនអាចអនុវត្តបានចំពោះរូបគាត់នៅសម័យអង្គហេតុនោះ។ វាជាការងាយស្រួលពេកដើម្បីពង្រីកការចោទប្រកាន់ បង្កើនការផ្តន្ទាទោសព្រហ្មទណ្ឌ និងការដាក់ទោសតាមទំនើងចិត្ត ដោយដើរផ្ទុយទាំងស្រុងទៅនឹងគោលការណ៍នីត្យានុកូលភាព នៃបទល្មើស និងទោស។

៣៦២. ដូច្នេះ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដែលការអះអាងរបស់តុលាការកំពូលផ្ទុយគ្នា១៨០ដឺក្រេទៅនឹងយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុបៈ

[314] សាលដីកា ០០២/០១ កថាខណ្ឌ ៧៦៥។

| អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក | តុលាការជាន់ខ្ពស់នៃតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប |
|---|---|
| "ជនជាប់ចោទ"អាចដឹងគ្រប់គ្រាន់បានថា អំពើដែលខ្លួនប្រព្រឹត្ត គឺជាអំពើល្មើសក្នុងន័យដែលមនុស្សទូទៅអាចយល់ដឹងបាន **ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយ"នោះឡើយ**។ ដូច្នេះ អ្វីដែលតម្រូវនោះ គឺ មិនមែនជាការពិចារណាអំពីពាក្យពេចន៍បច្ចេកទេសក្នុងនិយមន័យនៃឧក្រិដ្ឋកម្មនោះឡើយ ប៉ុន្តែនៅត្រង់ ថាតើជាទូទៅអាចយល់ដឹងជាមុនបានថា អំពើនោះអាចតម្រូវឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែរ ឬយ៉ាងណា" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[315]។ | "មាត្រា៧ មិនកម្រិតមកត្រឹមតែការហាមឃាត់មិនឱ្យអនុវត្តដោយប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ដោយបង្កព្យសនកម្មដល់ជនជាប់ចោទប៉ុណ្ណោះទេ។ នៅក្នុងមាត្រានេះមានចែងជាលក្ខណៈទូទៅផងដែរ អំពីគោលការណ៍នីត្យានុកូលភាពស្តីអំពីបទល្មើស និងទោស *(គ្មានទោស គ្មានបទល្មើស បើគ្មានច្បាប់ចែង)* និងអំពីគោលការណ៍ដែលតម្រូវមិនឱ្យអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលក្ខណៈពង្រីកដែលបង្កព្យសនកម្មដល់ជនជាប់ចោទ ជាពិសេសតាមវិធីសាស្ត្រសទិសភាព។ តាមរយៈនេះ ស្តែងឱ្យឃើញថា អំពើល្មើសត្រូវតែកំណត់ឱ្យបានច្បាស់ដោយច្បាប់ ទោះជាច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្តី។ ល័ក្ខខ័ណ្ឌនេះត្រូវបានបំពេញកាលណាជនទទួលខុសត្រូវចំពោះមុខច្បាប់អាចដឹង **ចាប់តាំងពីពាក្យពេចន៍នៃបទបញ្ញត្តិពាក់ព័ន្ធ** ហើយបើចាំបាច់ ដោយមានការបកស្រាយពីតុលាការ ឬក្រុមប្រឹក្សាច្បាប់ច្បាស់លាស់ ថាតើអំពើសកម្ម ឬអកម្មណានាំឱ្យខ្លួនមានទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ" (យើងជាអ្នកគូសពីក្រោម)[316]។<br>"សញ្ញាណនៃ "ច្បាប់" តម្រូវឱ្យមានល័ក្ខខ័ណ្ឌគុណភាពជាពិសេសល័ក្ខខ័ណ្ឌពីការដឹងឮ និងល័ក្ខខ័ណ្ឌដែលអាចប្រមើលឃើញមុនបាន។ ល័ក្ខខ័ណ្ឌគុណភាពត្រូវតែបានបំពេញទាំងចំពោះនិយមន័យបទល្មើស ទាំងទោសដែលបទល្មើសនេះអាចផ្តន្ទាទោសដោយច្បាប់[317]។ |

315 សាលដីកា ០០២/០១ កថាខណ្ឌ ៧៦៥។

316 រឿងក្តី Vasiliauskas តទល់នឹងប្រទេសលីទុយអានី (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៥៤។

317 រឿងក្តី Kafkaris តទល់នឹងកោះសាយប្រ៊ស (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ១៤០ (គ្មានឯកសារយោងទៅសេចក្តីសម្រេចមុនៗ)។

៣៦៦. ដូច្នេះ វាជាក់ស្តែងណាស់ដែលខុសពីអង្គជំនុំជម្រះតុលាការកំពូល តុលាការសិទ្ធិមនុស្សអឺរ៉ុប ពិចារណាអាស្រ័យតាមគុណភាពច្បាប់ គឺមិនមែនតាមគុណភាពរបស់បុគ្គលទេ។

៣៦៧. ឧទាហរណ៍ នៅក្នុងរឿងក្តី Vasiliauskas ទល់នឹង ប្រទេសលីទុយអានី ដែលយើងបានដកស្រង់កន្លងមក ម្ចាស់បណ្តឹងឧទ្ធរណ៍ដឹងយ៉ាងច្បាស់ថា អំពើមនុស្សឃាតដែលគាត់ត្រូវបានផ្តន្ទាទោសពីបទប្រល័យពូជសាសន៍ ត្រូវបានផ្តន្ទាទោសដោយច្បាប់ និងដឹងយ៉ាងច្បាស់ថា "អំពើរបស់គាត់មានចរិតឧក្រិដ្ឋតាមខ្លឹមសារដែលគេយល់ជាទូទៅ ដោយពុំចាំបាច់យោងទៅបទបញ្ញត្តិជាក់លាក់ណាមួយ"។ ជាក់ស្តែង ការសម្លាប់មនុស្ស គឺវាអាក្រក់ វាធ្ងន់ធ្ងរ។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ តុលាការជាន់ខ្ពស់នៃតុលាការសិទ្ធិមនុស្សអឺរ៉ុបបាន៖ ១. ពិនិត្យលើភាពអាចដឹងឮបានរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍អំពីបទបញ្ញត្តិពាក់ព័ន្ធក្នុងករណីនេះកាលពីសម័យអង្គហេតុ[318] បន្ទាប់មក ២. ពិនិត្យលើការអាចគ្រោងទុកជាមុនបានដោយវិភាគពាក្យបច្ចេកទេសនៃនិយមន័យរបស់ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍នៅសម័យអង្គហេតុ ដែលនិយមន័យនេះមិនទូលាយដល់និយមន័យដែលត្រូវបានអនុវត្តចំពោះរូបគាត់[319]។ តុលាការជាន់ខ្ពស់នេះបានសន្និដ្ឋានថា ទោះបីជាគាត់ដឹងឮអំពីច្បាប់ពាក់ព័ន្ធនៅសម័យនោះក៏ដោយ "ក៏ការផ្តន្ទាទោសគាត់ [...] ពីបទអំពើប្រល័យពូជសាសន៍មិនអាចគ្រោងទុកបានជាមុនទេនៅពេលប្រព្រឹត្តមនុស្សឃាតទៅលើសមាជិកបក្ស"[320]។ អាស្រ័យហេតុដូចនេះ តុលាការជាន់ខ្ពស់នេះបានកត់សម្គាល់ថា មានការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព[321]។ ដូច្នេះ ទោះបីជាអំពើប្រល័យពូជសាសន៍ត្រូវបានចោទប្រកាន់នៅសម័យនោះក៏ដោយ ទោះបីជាម្ចាស់បណ្តឹងឧទ្ធរណ៍ដឹងអំពីច្បាប់ពាក់ព័ន្ធក៏ដោយ ក៏គាត់មិនអាចប្រមើលមើលទុកជាមុនបានអំពីការអនុវត្តនិយមន័យទូលាយនៃអំពើប្រល័យពូជសាសន៍បានឡើយ។ ទោះបីជាគាត់អាចដឹង

[318] រឿងក្តី Vasiliauskas តទល់នឹង Lituanie (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៦៧-១៦៨។

[319] រឿងក្តី Vasiliauskas តទល់នឹង Lituanie (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៦៩-១៨៥។

[320] រឿងក្តី Vasiliauskas តទល់នឹង Lituanie (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៨៦។

[321] រឿងក្តី Vasiliauskas តទល់នឹង Lituanie (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៩១។

អំពីចរិតនៃអំពើរបស់គាត់ដែលត្រូវផ្តន្ទាទោសដោយច្បាប់ក៏ដោយ ក៏គាត់នៅតែជាជនរងគ្រោះនៃការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាពដែរ។

៣៦៨. ទោះជាយ៉ាងណាក្តី គេមិនអាចរិះគន់តុលាការសិទ្ធិមនុស្សអឺរ៉ុបថាមិនដឹងអំពីចរិតនៃអំពើមួយចំនួនដែលត្រូវផ្តន្ទាទោសដោយច្បាប់ និងអំពីភាពធ្ងន់ធ្ងរនៃអំពើទាំងនោះឡើយ។ ជាក់ស្តែង នៅក្នុងរឿងក្តីនៃអំពើពុករលួយមួយ មុននឹងពិនិត្យការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាពដែលរងការចោទប្រកាន់ដែលខ្លួនបានទទួលយកមកជំនុំជម្រះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានប្រកាសដូចតទៅនេះ ៖

> "តុលាការដឹងថាអំពើពុករលួយជាការគំរាមកំហែងដល់ធម្មានុរូបនៃច្បាប់ លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ហើយបំផ្លាញគោលការណ៍អភិបាលកិច្ចល្អ សមធម៌ និងយុត្តិធម៌សង្គម កែកាឡៃការប្រកួតប្រជែង រាំងស្ទះការអភិវឌ្ឍសេដ្ឋកិច្ច បង្កគ្រោះថ្នាក់ដល់ស្ថិរភាពស្ថាប័នប្រជាធិបតេយ្យ និងដល់គ្រឹះសីលធម៌សង្គម។ ទោះជាយ៉ាងនេះក្តី គោលការណ៍ដែលធានាដោយមាត្រា ៧ ត្រូវតែយកមកអនុវត្តដូចគ្នា ចំពោះនីតិវិធីព្រហ្មទណ្ឌផ្សេងទៀត ក៏ដូចជាចំពោះនីតិវិធីព្រហ្មទណ្ឌស្តីអំពីបទល្មើសនៃអំពើពុករលួយ"[322]។

៣៦៩. ជាក់ស្តែង តុលាការនេះមិនរារែកក្នុងការរំឭកដូចតទៅនេះ ៖

> "ការធានានៃមាត្រា ៧ ដែលជាធាតុផ្សំជាមូលដ្ឋាននៃធម្មានុរូបនៃច្បាប់ មានសារៈសំខាន់បំផុតនៅក្នុងប្រព័ន្ធការពារអនុសញ្ញានេះ ដូចដែលមានបញ្ជាក់ដោយប្រការថា មាត្រា ១៥ មិនអនុញ្ញាតឱ្យមានករណីលើកលែងណាមួយទេ ទោះបីជាក្នុងកាលៈទេសៈសង្គ្រាម ឬកាលៈទេសៈគ្រោះថ្នាក់សាធារណផ្សេងទៀតក៏ដោយ។ យោងទៅតាមកម្មវត្ថុ និងគោលបំណងរបស់មាត្រានេះ យើងត្រូវបកស្រាយ និងអនុវត្តវាយ៉ាងណាដើម្បីធានាឱ្យមានការការពារប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងការចោទប្រកាន់ ការផ្តន្ទាទោស និងការដាក់ទណ្ឌកម្មតាមទំនើងចិត្ត"[323]។

---

[322] រឿងក្តី Dragonotiu និង Militaru-Pidhorni តទល់នឹង ប្រទេសរូម៉ានី (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ៤១។

[323] រឿងក្តី Vasiliauskas តទល់នឹង Lituanie (តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប សភាជាន់ខ្ពស់) ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៥៣។

៣៧០. ការហាមឃាត់មិនឱ្យមានករណីលើកលែងនេះ ក៏ត្រូវបង្កាប់បញ្ញាដោយកត្តិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ។ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សក៏បានគូសបញ្ជាក់អំពីចំណុចនេះផងដែរ នៅក្នុងកំណត់សម្គាល់ទូទៅលេខ ២៩ របស់ខ្លួន ក្រោមចំណងជើងថា "ការដាក់ប្រទេសនៅក្នុងភាពអាសន្ន" ៖

"កថាខណ្ឌ ២ នៃមាត្រា ៤ របស់កត្តិកាសញ្ញានេះចែងយ៉ាងច្បាស់ថា មិនអាចមានករណីលើកលែងណាមួយដែលអនុញ្ញាតឱ្យរំលោភបំពានលើមាត្រាដូចតទៅ៖ [...] មាត្រា ១៥ (គោលការណ៍នីត្យានុកូលភាពក្នុងរឿងព្រហ្មទណ្ឌចែងថា ទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងទោស ត្រូវតែ<u>កំណត់តាមរយៈបទបញ្ញត្តិច្បាស់លាស់ និងជាក់លាក់</u>នៃច្បាប់មួយដែលចូលជាធរមាន និងអាចអនុវត្តបាន ក្នុងខណៈដែលអំពើសកម្ម ឬអកម្មបានកើតឡើង លើកលែងក្នុងករណីដែលច្បាប់ចុងក្រោយគេបំផុត ចែងអំពីទោសមួយដែលស្រាលជាង)" (យើងជាអ្នកគូសពីក្រោម)[324]។

៣៧១. លើសពីនេះទៀត អ្នករាយការណ៍ពិសេសអំពីភេរវកម្ម និងសិទ្ធិមនុស្ស បានគូសបញ្ជាក់អំពីសារៈសំខាន់ជាមូលដ្ឋាននៃការគោរពគោលការណ៍នីត្យានុកូលភាពនៅគ្រប់កាលៈទេសៈទាំងអស់[325] មុននឹងរំឭកខ្លឹមសារដូចខាងក្រោម៖

*"អត្ថន័យនៃគោលការណ៍ មិនមែនជាបទល្មើសបើគ្មានច្បាប់ចែង គឺថា ដើម្បីក្លាយជាបទល្មើសមួយ អំពើសកម្មមួយ ឬអំពើអកម្មមួយគួរតែត្រូវបានកំណត់ជាបទល្មើសទៅតាមច្បាប់ជាធរមាន នៅពេលប្រព្រឹត្ត និងជាងនេះទៀត<u>គឺថា និយមន័យនៃបទល្មើសព្រហ្មទណ្ឌត្រូវតែច្បាស់លាស់ ប្រាកដប្រជា និងមិនស្រពិចស្រពិល</u>។ ហេតុនេះ នៅក្នុងយោបល់ទូទៅរបស់ខ្លួនលេខ ២៩ គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ថា គោលការណ៍នីត្យានុកូលភាពនៅក្នុងវិស័យច្បាប់ព្រហ្មទណ្ឌកំណត់ថា ជាការទទួលខុសត្រូវព្រហ្មទណ្ឌ រួមទាំងការផ្តន្ទាទោសផង ត្រូវតែកំណត់និយមន័យនៅក្នុង "បទប្បញ្ញត្តិជាក់លាក់ និងច្បាស់លាស់ នៅក្នុងច្បាប់ដែលមានស្រាប់ និងជាធរមាន នៅពេលអំពើសកម្ម ឬអំពើអកម្មបានកើតឡើង លើកលែងតែក្នុងករណីដែលច្បាប់ក្រោយកំណត់ការផ្តន្ទាទោសស្រាលជាងមុន"។ តុលាការសិទ្ធិមនុស្សអឺរ៉ុបយល់ស្រប ដោយលើកឡើងបន្ថែមថា គោលការណ៍ មិនមែនជាបទល្មើសបើគ្មានច្បាប់ចែង បញ្ជាក់ថា និយមន័យនៃបទល្មើសព្រហ្មទណ្ឌ ឬការកំណត់ជាបទល្មើសព្រហ្មទណ្ឌ ត្រូវតែច្បាស់លាស់ និងមិនស្រពិចស្រពិល។ ហើយតុលាការសិទ្ធិ*

---

[324] កំណត់សម្គាល់ទូទៅ លេខ ២៩ ស្ថានភាពបន្ទាន់ (មាត្រា ៤) គណៈកម្មាធិការសិទ្ធិមនុស្ស CCPR/C/21/Rev.1/Add.11 ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៧។

[325] *Specific Human Rights Issues : New Priorities, in particular Terrorism* គណៈកម្មាធិការសិទ្ធិមនុស្ស E/CN.4/Sub.2/2003/WP.1 ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៣ កថាខណ្ឌ ៦៣-៦៤។

*មនុស្សអន្តរអាមេរិកាំងយល់ស្របថា បទល្មើសត្រូវតែ "ធ្វើចំណាត់ថ្នាក់ និងពិពណ៌នាជាភាសាដែលច្បាស់លាស់ និងមិនស្រពិចស្រពិល ដែលកំណត់និយមន័យយ៉ាងចង្អៀតនៃបទល្មើសដែលអាចផ្តន្ទាទោសបាន ហេតុនេះ វាបានផ្តល់អត្ថន័យយ៉ាងពេញលេញដល់គោលការណ៍ មិនមែនជាបទល្មើសបើច្បាប់ពីមុនមិនបានចែង (nullum crimen nulla poena sine lege praevia) នៅក្នុងច្បាប់ព្រហ្មទណ្ឌ" ដោយបញ្ជាក់បន្ថែមថា ភាពស្រពិចស្រពិលនៅក្នុងការពិពណ៌នាអំពីបទល្មើសបង្កើតឱ្យមានការសង្ស័យ និងឱកាសក្នុងការបំពានអំណាច "ជាពិសេសនៅពេលស្វែងរកបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌ និងផ្តន្ទាទោសចំពោះអាកប្បកិរិយាឧក្រិដ្ឋរបស់ពួកគេទៅតាមទោសទណ្ឌទៅតាមចំនួន ដោយផ្អែកលើចំណុចនានាដែលមានតម្លៃបំផុត ដូចជា ជីវិត និងសេរីភាព"។"* (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[326]។

៣៧២. អ្នករាយការណ៍ពិសេសរូបនេះបានបន្ត ដោយរំឭកគោលការណ៍មួយដែលបញ្ជាក់ថា និយមន័យនៃឧក្រិដ្ឋកម្មត្រូវតែបកស្រាយចង្អៀត ហើយក្នុងករណីមានភាពស្រពិចស្រពិល និយមន័យនេះត្រូវតែបកស្រាយជាប្រយោជន៍ដល់បុគ្គលដែលជាកម្មវត្ថុនៃការស៊ើបអង្កេត ការចោទប្រកាន់ ឬការផ្តន្ទាទោស។[327]

៣៧៣. ដូច្នេះ លក្ខណៈគួរឱ្យស្តីបន្ទោសនៃឥរិយាបថ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម មិនអាចជួសជុលបានទាល់តែសោះនូវអវត្តមាននៃការកំណត់ច្បាស់លាស់ និងជាក់លាក់មួយនៃការចោទប្រកាន់បានឡើយ គឺវាផ្ទុយពីគោលជំហររបស់តុលាការកំពូល និងខ្លឹមសារនៃសារដែលខ្លួនចង់ឱ្យគេយល់។

៣៧៤. ដូច្នេះ ដើម្បីឱ្យគោលការណ៍នីត្យានុកូលភាពត្រូវបានគោរព "ការដែលការចោទប្រកាន់មួយមានចែងដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងការដែលជនជាប់ចោទមានមុខដំណែងខ្ពង់ខ្ពស់ និង/ឬអាចដឹងថាតើអំពើរបស់ខ្លួនមានចរិតឧក្រិដ្ឋតាមខ្លឹមសារដែលគេយល់ជាទូទៅដោយមិនចាំបាច់យោងទៅបទបញ្ញត្តិជាក់លាក់ណាមួយ" មិនអាចជាល័ក្ខខ័ណ្ឌមួយគ្រប់គ្រាន់ទាល់តែសោះ។ ជនជាប់ចោទ ត្រូវតែអាចដឹងឮ និងអាចគ្រោងទុកជាមុនបានជាដាច់ខាត អំពីនិយមន័យនៃការចោទប្រកាន់ ឱ្យបានច្បាស់លាស់គ្រប់គ្រាន់ ដោយគ្មានភាពស្រពិចស្រពិល។

---

[326] *Specific Human Rights Issues : New Priorities, in particular Terrorism* គណៈកម្មាធិការសិទ្ធិមនុស្ស E/CN.4/Sub.2/2003/WP.1 ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៣ កថាខណ្ឌ ៦៥ (គ្មានឯកសារយោង)។

[327] *Specific Human Rights Issues : New Priorities, in particular Terrorism* គណៈកម្មាធិការសិទ្ធិមនុស្ស E/CN.4/Sub.2/2003/WP.1 ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៣ កថាខណ្ឌ ៦៧។

៣៧៥. ជាក់ស្តែង ប្រការនេះថែមទាំងត្រូវបានរំឭកយ៉ាងច្បាស់លាស់ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក្នុងរឿងក្តី Vasiljevic ដែលនៅក្នុងរឿងក្តីនេះមានលើកឡើងអំពីការចោទប្រកាន់ស្តីអំពីការបង្កព្យសនកម្មដល់អាយុជីវិត និងបូរណភាពរូបរាងកាយនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ៖

> "ដូច្នេះ សាលាដំបូងមានកាតព្វកិច្ចធ្វើយ៉ាងណាធានាឱ្យវិធានច្បាប់ដែលខ្លួនអនុវត្តចំពោះបទល្មើសព្រហ្មទណ្ឌណាមួយ ជាធាតុផ្សំពេញត្តដ៏មានប្រសិទ្ធភាពនៃច្បាប់ទំនៀមទម្លាប់។ ល្មើសពីនេះទៀត សាលាដំបូងត្រូវតែច្បាស់ថា បទល្មើសនេះមានចែងច្បាស់លាស់គ្រប់គ្រាន់ដើម្បីឱ្យមានលក្ខណៈអាចគ្រោងទុកជាមុនបាន និងត្រូវបានដឹងឮស្របតាមលក្ខណៈជាក់លាក់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ"(យើងជាអ្នកគូសពីក្រោម)[328]។

៣៧៦. នៅក្នុងរឿងក្តីនេះ ដោយដើរតាមតក្កវិជ្ជាស្រដៀងគ្នានឹងតក្កវិជ្ជារបស់តុលាការកំពូល អយ្យការបានអះអាងថា៖

> *"ម្យ៉ាង ត្រូវបង្ហាញភាពខុសគ្នារវាងអត្ថិភាពនៃបទល្មើសមួយ និងនិយមន័យនៃបទល្មើសនោះ ឬម្យ៉ាងទៀតរវាងអត្ថិភាពរបស់វា និងធាតុផ្សំនៃបទល្មើសនោះ។ និយមន័យនៃបទល្មើសពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាព ឬ មិនមែនជាបទល្មើសបើគ្មានច្បាប់ចែង ចំណែកធាតុផ្សំនៃបទល្មើសពាក់ព័ន្ធនឹងគោលការណ៍ស្តីពីភាពជាក់លាក់។ ការពិត គោលការណ៍នីត្យានុកូលភាពតម្រូវថា មានបទល្មើសនៅក្នុងច្បាប់ នៅពេលដែលអំពើពាក់ព័ន្ធត្រូវបានប្រព្រឹត្ត។ ក៏ប៉ុន្តែ ចំណុចនេះមិនមែនមានន័យថា បទល្មើសត្រូវតែមានធាតុផ្សំរបស់វាជាច្រើនដែលត្រូវបានរៀបរាប់យ៉ាងពិស្តារជាមុននោះទេ។"* (មានគូសបន្ទាត់ពីក្រោមក្នុងច្បាប់ដើម)[329]។

៣៧៧. អំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលថាត្រូវតែបែងចែករវាងអត្ថិភាពនៃបទល្មើស និងនិយមន័យនៃបទល្មើសនេះ ឬធាតុផ្សំនៃបទល្មើសនេះ ត្រូវបានបដិសេធជាផ្លូវការ។[330]

---

[328] សាលក្រម Vasiljević (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ កថាខណ្ឌ ១៩៨។

[329] រឿងក្តី ព្រះរាជអាជ្ញា តទល់នឹង Vasiljević, IT-98-32-T, *Submission by the Prosecution on the Law with Respect to "Violence to Life and Person"* ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០២ កថាខណ្ឌ ៥។

[330] សាលក្រម Vasiljević (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ កំណត់សម្គាល់ ជើងទំព័រ ៥៤១ (នៃកថាខណ្ឌ ១៩៨) ៖ « អង្គជំនុំជម្រះសាលាដំបូងច្រានចោលអំណះអំណាងរបស់រដ្ឋអាជ្ញាដែលថាត្រូវបែងចែកឲ្យច្បាស់រវាងគោលការណ៍នីត្យានុកូល និងគោលការណ៍នៃភាពដោយឡែកពីគ្នា ដោយហេតុថាគោលការណ៍ទី១មិនមែនជាអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ រីឯគោលការណ៍ទី២ជាការកំណត់បទល្មើសដែលលើកឡើងនោះ ឬធាតុផ្សំភស្តុតាងនៃបទល្មើសនោះ »។

៣៧៨. យោងតាមការរៀបរាប់ខាងលើ តាមពិតទៅ វាហួសពីច្បាស់ទៅទៀតដែលថាវិនិច្ឆ័យកិច្ចរបស់តុលាការកំពូលលើគោលការណ៍នីត្យានុកូលភាព ផ្ទុយទាំងស្រុងទៅនឹងកម្មវត្ថុ គោលបំណង និងខ្លឹមសារជីវិតនៃគោលការណ៍ជាមូលដ្ឋាននេះដែលមានអាយុចំណាស់ជាង២០០ឆ្នាំ ដែលតម្រូវមិនឱ្យមាននរណាម្នាក់ត្រូវបានចោទប្រកាន់ ផ្តន្ទាទោស ដាក់ទណ្ឌកម្មតាមទំនើងចិត្តឡើយ។

៣៧៩. ការសង្កេតជាអកុសលនេះមានលក្ខណៈធ្ងន់ធ្ងរជាទីបំផុតនៅឆ្នាំ២០១៦ ពីសំណាក់ចៅក្រមដែលកាត់សេចក្តីលើបណ្តឹងឧទ្ធរណ៍នៃតុលាការអន្តរជាតូបនីយកម្ម ដែលមានកាតព្វកិច្ចគោរពគុណតម្លៃសង្គមប្រជាធិបតេយ្យ និងធម្មានុរូបនៃច្បាប់។

៣៨០. អង្គជំនុំជម្រះមានកាតព្វកិច្ចដាច់ខាតក្នុងការដកខ្លួនឱ្យផុតពីវិនិច្ឆ័យកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលតស៊ូមោះមុតប្រឆាំងនឹងនិទណ្ឌភាពដោយបង្កព្យសនកម្មដល់ការតស៊ូប្រឆាំងនឹងការផ្តន្ទាទោសតាមទំនើងចិត្ត។ កត្តានេះបង្ហាញយ៉ាងច្បាស់ពីបំណងប្រាថ្នាចង់ក្លាយជាអ្នកបង្កើតច្បាប់របស់អង្គជំនុំជម្រះតុលាការកំពូលដែលអនុវត្តចំពោះជនជាប់ចោទនូវច្បាប់មួយដែលគួរឱ្យសង្ស័យ និងខ្វះភាពច្បាស់លាស់ពាក់ព័ន្ធនឹងអំពើមនុស្សឃាតដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងសហឧក្រិដ្ឋកម្មរួម។

## ផ្នែកទី ២ .លក្ខណៈពិសេសរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ

### ១. ការលំបាកក្នុងការកំណត់វិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ

៣៨១. ការគោរពគោលការណ៍នីត្យានុកូលភាព មានសភាពស្មុគស្មាញយ៉ាងខ្លាំង កាលណា “ច្បាប់” ដែលគេយកមកប្រើក្នុងរឿងក្តី ជាវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ជាក់ស្តែង ផ្ទុយពីច្បាប់អន្តរជាតិស្តីអំពីសន្ធិសញ្ញា ទំនៀមទម្លាប់អន្តរជាតិមានសារជាតិជាច្បាប់អត់សំណេរ និងវិវត្តន៍។ ដូច្នេះជាញឹកញាប់ គេមានការលំបាកក្នុងការកំណត់វិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅសម័យកាលណាមួយ។

៣៨២. ការលំបាកនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈរឿងរ៉ាវសាមញ្ញមួយ៖ តាំងពីឆ្នាំ២០១២មក បញ្ហានៃការកំណត់ទំនៀមទម្លាប់អន្តរជាតិ ជាកម្មវត្ថុនៃការងារស្រាវជ្រាវរបស់គណៈកម្មាការច្បាប់អន្តរជាតិ ដែលត្រូវបង្កើតឱ្យបាននូវមគ្គុទេសន៍ណែនាំឱ្យអនុវត្តមួយ អមដោយសេចក្តីអត្ថាធិប្បាយសម្រាប់ចៅក្រម អ្នកច្បាប់ និងអ្នកអនុវត្តច្បាប់ ដែលត្រូវបានអញ្ជើញឱ្យកំណត់អត្តសញ្ញាណនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។[331]

៣៨៣. រហូតដល់ពេលនេះ Michael WOOD ដែលត្រូវបានតែងតាំងជាអ្នករាយការណ៍ពិសេសលើប្រធានបទនេះ បានសរសេររបាយការណ៍ចំនួនបួនក្នុងគោលបំណងនេះ។ របាយការណ៍ទីពីររបស់គាត់និយាយអំពីបញ្ហាសំខាន់ៗទាក់ទងនឹងវិធីសាស្ត្រដែលត្រូវជ្រើសយកដើម្បីកំណត់វិធាននានានៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាពិសេសធាតុផ្សំពីរនៃទំនៀមទម្លាប់ និងរបៀបវាយតម្លៃលើអត្ថិភាពនៃធាតុផ្សំទាំងពីរនេះ។[332] គាត់បានរំឭកនៅក្នុងរបាយការណ៍នេះថា ទំនៀមទម្លាប់អន្តរជាតិត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ ត្រង់មាត្រា ៣៨-១-ខ ថាជា "ការអនុវត្តទូទៅដែលទទួលយកជាច្បាប់"។[333]

៣៨៤. បន្ទាប់ពីបានកត់សម្គាល់អំពីលក្ខណៈសំខាន់នៃការផ្សារភ្ជាប់គ្នារវាងធាតុផ្សំទាំងពីរនៃវិធានរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ("ការអនុវត្តទូទៅ" "ដែលទទួលយកជាច្បាប់" ឬ opinio juris) ដើម្បីសន្និដ្ឋានថាច្បាប់នេះមានអត្ថិភាព[334] Michael WOOD បានលើកឡើងថា៖

---

[331] ការបង្កើតនិងការកំណត់អត្តសញ្ញាណនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ កំណត់សម្គាល់របស់លោក Michael WOOD របាយការណ៍ពិសេស ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ A/CN.4/653 កថាខណ្ឌ ៣, សូមមើលផងដែរឯកសារ A/66/10 ឆ្នាំ ២០១១ ឧបសម្ព័ន្ធ ក កថាខណ្ឌ ៤ (ឯកសារទាំងអស់មាននៅលើគេហទំព័រនៃគណៈកម្មការច្បាប់អន្តរជាតិ តាមតំណភ្ជាប់ដូចតទៅ ៖ http://legal.un.org/ilc/guide/1_13.shtml)។

[332] របាយការណ៍ទី២ស្តីពីការកំណត់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] Michael WOOD ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤, A/CN.4/672 កថាខណ្ឌ ៩។

[333] របាយការណ៍ទី២ស្តីពីការកំណត់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] Michael WOOD ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤, A/CN.4/672 កថាខណ្ឌ ១៧។

[334] របាយការណ៍ទី២ស្តីពីការកំណត់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] Michael WOOD ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤, A/CN.4/672 កថាខណ្ឌ ២១-២៩។

"ការកំណត់ថាតើវិធានណាមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិមានឬអត់ គឺជាការស្វែងរក "ការអនុវត្តដែលត្រូវបានទទួលដោយរដ្ឋជាច្រើន រហូតដល់គេអាចចាត់ទុកថាមានកាតព្វកិច្ចនៅក្នុងច្បាប់អន្តរជាតិទូទៅ"។ ការងារនេះអាចលំបាក និងស្មុគស្មាញខ្លាំងណាស់ ពីព្រោះវិធានជាសន្ទតនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវតែបង្ហាញតាមលក្ខណៈធម្មជាតិឱ្យឃើញថាវាជាវិធានមួយនៃច្បាប់អន្តរជាតិដែលមានសុពលភាព គឺមិនមែនជាគោលគំនិតមួយដែលគ្មានមូលដ្ឋាននោះទេ។ ដូចយើងនឹងឃើញនៅបន្តិចទៀតនេះ ការងារនេះតម្រូវឱ្យមានការប្រុងប្រយ័ត្ន និងមានវិធានការ ពីព្រោះគោលបំណងមិនត្រឹមតែកំណត់បរិមាណសមស្របនៃអ្វីដែលរដ្ឋទាំងឡាយនិយាយនិងធ្វើ ចង់និងជឿ ប៉ុណ្ណោះទេ គឺវាថែមទាំងត្រូវស្គាល់ឱ្យច្បាស់អំពីភាពស្រពិចស្រពិលដែលមាននៅក្នុងធាតុផ្សំជាច្រើននៃការអនុវត្ត"[335]។

៣៨៥. អ្នករាយការណ៍ពិសេសរូបនេះរំឭកថា ដូចដែលតុលាការយុត្តិធម៌អន្តរជាតិ "តែងតែគូសបញ្ជាក់ថាច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺកើតចេញពីការអនុវត្តរបស់រដ្ឋទាំងឡាយ"[336]។ គាត់បន្ថែមទៀតថាការកំណត់ការអនុវត្តរបស់រដ្ឋនានាមិនមែនជារឿងស្រួលទេ។ អ្វីដែលបន្ទាប់បន្សំ និងអ្វីជាស្នូលនៃការអនុវត្ត (នៃទស្សនៈច្បាប់) "នៅតែជាប្រភពនៃបញ្ហាអនុវត្តដ៏ចម្បងនៅក្នុងពិភពលោកយើងសព្វថ្ងៃនេះ ទោះបីជាមានការវិវត្ត នៃធនធានសារព័ត៌មាន និងធនធានទូរគមនាគមន៍ក៏ដោយ"[337]។ គាត់ស្នើឱ្យគណៈកម្មការច្បាប់អន្តរជាតិពិនិត្យជាថ្មីម្តងទៀត (ការពិនិត្យលើកចុងក្រោយបង្អស់នៅឆ្នាំ១៩៥០) លើ "មធ្យោបាយដែលបង្កលក្ខណៈងាយស្រួលដល់ការចូលពិគ្រោះឯកសារស្តីអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិបាន"[338]។ ចាប់តាំងពីឆ្នាំនោះមក ការសិក្សាស្រាវជ្រាវមួយក្នុងគោលបំណងនេះកំពុងតែបន្តធ្វើ[339]។

---

[335] របាយការណ៍ទី២ស្តីពីការកំណត់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] Michael WOOD ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤, A/CN.4/672 កថាខណ្ឌ ៣០។

[336] របាយការណ៍ទី២ស្តីពីការកំណត់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] Michael WOOD ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤, A/CN.4/672 កថាខណ្ឌ ៣៣។

[337] របាយការណ៍ទី២ស្តីពីការកំណត់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] Michael WOOD ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤, A/CN.4/672 កថាខណ្ឌ ៣៥ និង ៨៣។

[338] របាយការណ៍ទី២ស្តីពីការកំណត់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] Michael WOOD ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤, A/CN.4/672 កថាខណ្ឌ ៣៥ និង ៨២-៨៣, របាយការណ៍ទី៤ស្តីពីការកំណត់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] Michael WOOD ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១៦, E/CN.4/695 កថាខណ្ឌ ៤៨។

[339] របាយការណ៍នៃគណៈកម្មការច្បាប់អន្តរជាតិស្តីអំពីការងារនៃសម័យប្រជុំលើកទី៦៨ ឆ្នាំ ២០១៦, A/71/10 ជំពូក V កថាខណ្ឌ ៥៦។

៣៨៦. ដូច្នេះ ក្នុងល័ក្ខខ័ណ្ឌនេះ អ្វីដែលសំខាន់បំផុត គឺត្រូវម៉ត់ចត់ និងប្រយ័ត្នប្រយែងបំផុតក្នុងការកំណត់អត្ថិភាពនៃវិធានរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងក្នុងការពិនិត្យលើការអាចគ្រោងទុកជាមុនបាន និងការអាចដឹងឮបាននៃវិធាននេះ។ ដូច្នេះ វាគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលប៉ុន្មានទេ អង្គជំនុំជម្រះដែលតុលាការកំពូលមិនដែលបានព្យាយាមកំណត់ធាតុផ្សំទាំងពីរនៃវិធានមួយរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ មុននឹងសន្និដ្ឋានថាមានអត្ថិភាពនៃវិធានមួយចំនួននៅសម័យអង្គហេតុចោទប្រកាន់ពោលគឺកាលពីសែសិបឆ្នាំមុន។

៣៨៧. ដោយមិនបាច់និយាយលម្អិតដូចលោក Michael WOOD ជាអ្នករាយការណ៍ពិសេស យើងគប្បីរំឭកដោយសង្ខេបអំពីធាតុផ្សំសំខាន់ៗមួយចំនួននៃនិយមន័យរបស់ការអនុវត្តទូទៅ និងការទទួលយកវាជាច្បាប់ (ទស្សនៈច្បាប់) ដែលកត្តាទាំងពីរនេះសុទ្ធតែមានសារៈសំខាន់ចាំបាច់ចំពោះអត្ថិភាពនៃវិធានណាមួយរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

## ២. ការអនុវត្តទូទៅ

៣៨៨. ការអនុវត្តនៃរដ្ឋនានាអាចមានទម្រង់ផ្សេងៗគ្នា។ ការអនុវត្តនេះស្តែងចេញជាពិសេសតាមរយៈអំពើរបស់រដ្ឋ "នៅមូលដ្ឋាន" (អំពើជាក់ស្តែង) សកម្មភាព និងទំនាក់ទំនងការទូត កិច្ចនីតិបញ្ញត្តិ យុត្តិសាស្ត្រជាតិ ការបោះពុម្ពផ្សាយជាផ្លូវការនៅក្នុងវិស័យច្បាប់អន្តរជាតិ សេចក្តីថ្លែងការណ៍នានាក្នុងនាមរដ្ឋទាក់ទងនឹងការបង្កើតក្រុមផ្សេងៗ ការអនុវត្តស្តីអំពីសន្ធិសញ្ញា និងកិច្ចទាំងឡាយណាដែលកើតចេញពីសេចក្តីសម្រេចអនុម័តដោយអង្គភាពនៃអង្គការ ឬដោយសន្និសីទអន្តរជាតិ[340]។

៣៨៩. ដើម្បីសន្និដ្ឋានថាមានវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិមួយ មិនចាំបាច់មានវត្តមាននៃការអនុវត្តជាឯកច្ឆន្ទ (ឬជាសាកល) នោះទេ ក៏ប៉ុន្តែការអនុវត្តនេះត្រូវតែធ្វើជាទូទៅ ក្នុងលក្ខណៈ"ជាឯកសណ្ឋាន និងមានការទទួលយកយ៉ាងទូលំទូលាយ" "ជាទូទៅគ្រប់គ្រាន់ និងមានលក្ខណៈជាឯក

---

[340] របាយការណ៍ទី ២ ស្តីពីការកំណត់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] Michael WOOD ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤, A/CN.4/672 កថាខណ្ឌ ៣៧-៤៨។

សណ្ឋាន" "មានលក្ខណៈលម្អិតគ្រប់គ្រាន់ និងអាចជឿជាក់បាន"។ វិធាននេះត្រូវតែកើតចេញពី "ការចូលរួមដ៏ទូលំទូលាយ និងមានភាពជាតំណាង"[341]។

៣៩០. លើសពីនេះទៅទៀត ការអនុវត្តរបស់រដ្ឋត្រូវតែ "ខ្ជាប់ខ្ជួន"។ កាលណាអង្គហេតុបង្ហាញ "អំពីភាពមិនច្បាស់លាស់ និងភាពផ្ទុយគ្នា ការប្រែប្រួល និងការចម្រូងចម្រាស់ជាច្រើន [...] គេមិនអាចទាញចេញពីកត្តាទាំងនេះ នូវទំនៀមទម្លាប់ខ្ជាប់ខ្ជួន និងមានឯកសណ្ឋានភាព និងត្រូវបានទទួលយកជាច្បាប់ទាក់ទងនឹងវិធានជាសន្ទតនេះ"[342]។

## ៣. <u>ទស្សនៈច្បាប់ដែលត្រូវបានទទួលយកជាច្បាប់</u> (OPINIO JURIS)

៣៩១. ធាតុផ្សំទីពីរចាំបាច់សម្រាប់កំណត់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺការទទួលយកនៃការអនុវត្តជាទូទៅ ថាជាច្បាប់។ និយាយមួយបែបទៀត រដ្ឋទាំងអស់ត្រូវតែ "ជឿជាក់ថាកំពុងអនុវត្តវិធានមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមានលក្ខណៈចាប់បង្ខំ" ឬត្រូវមានអារម្មណ៍ថា "ខ្លួនជាប់កាតព្វកិច្ចតាមផ្លូវច្បាប់" ដោយវិធាននេះ[343]។

៣៩២. ដូចដែលអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក បានរំឭកថា៖

> "គ្រាន់តែជាការអនុវត្តលើសលប់មួយមិនអាចជាការគ្រប់គ្រាន់ជាទម្លាប់ក្នុងការសន្មតជាមុនថា មានអត្ថិភាពនៃទស្សនៈច្បាប់ទេ ពីព្រោះថា "មិនមែនត្រឹមតែអំពើទេដែលត្រូវតំណាងឱ្យការអនុវត្តខ្ជាប់ខ្ជួននោះ

---

[341] របាយការណ៍ទី ២ ស្តីពីការកំណត់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] Michael WOOD ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤, A/CN.4/672 កថាខណ្ឌ ៥២ និង កំណត់សម្គាល់ជើងទំព័រ ១៥២-១៥៥ ដែលយោងទៅយុត្តិសាស្ត្ររបស់តុលាការយុត្តិធម៌អន្តរជាតិ។

[342] របាយការណ៍ទី ២ ស្តីពីការកំណត់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] Michael WOOD ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤, A/CN.4/672 កថាខណ្ឌ ៥៥ និង កំណត់សម្គាល់ជើងទំព័រ ១៦៨ និង ១៧១ ដែលយោងទៅយុត្តិសាស្ត្ររបស់តុលាការយុត្តិធម៌អន្តរជាតិ។

[343] របាយការណ៍ទី២ស្តីពីការកំណត់ [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] Michael WOOD ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៤, A/CN.4/672 កថាខណ្ឌ ៦០ និង កំណត់សម្គាល់ជើងទំព័រ ១៨២-១៨៣ ដែលយោងទៅយុត្តិសាស្ត្ររបស់តុលាការយុត្តិធម៌អន្តរជាតិ។

គឺលើសពីនេះទៅទៀត តាមចរិត និងរបៀបសម្រេចវា អំពើទាំងនេះត្រូវតែបង្ហាញអំពីការជឿជាក់ថា ការអនុវត្តនេះបានក្លាយជាកាតព្វកិច្ច ដោយសារមានអត្ថិភាពនៃវិធានច្បាប់មួយ[344]"។

៣៩៣. ទោះបីជាមានយុត្តិសាស្ត្រកន្លងមកក៏ដោយ ក៏នៅក្នុងសាលដីកានៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលនៅតែទទួលបានជោគជ័យក្នុងការ "កំណត់" វិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមិនមានអត្ថិភាពនៅសម័យអង្គហេតុ។

## ផ្នែកទី ៣ .ធាតុផ្សំចេតនានៃមនុស្សឃាតដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

៣៩៤. អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា "ធាតុផ្សំអត្តនោម័តនៃការធ្វើមនុស្សឃាតដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែលមានអត្ថិភាពក្នុងឆ្នាំ ១៩៧៥ ត្រូវតែកំណត់និយមន័យឱ្យមាន *លក្ខណៈទូលាយ* (*largo sensu*) ដើម្បីរួមបញ្ចូលនូវ *ចេតនាប្រយោល* (*dolus eventualis*) ផងដែរ"[345]។

៣៩៥. អង្គជំនុំជម្រះមិនអាចដើរតាមផ្លូវនេះទេក្នុងសំណុំរឿង ០០២/០២ នេះ ពីព្រោះការសន្និដ្ឋាននេះជាការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព។ ក្រុមមេធាវីការពារក្តីសូមបញ្ជាក់គោលជំហររបស់ខ្លួនជាថ្មីឡើងវិញម្តងទៀត នៅក្នុងសារណាបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង០០២/០១ ដែលតាមគោលជំហរនេះ នៅសម័យអង្គហេតុ និងក្នុងពេញមួយរយៈពេលពាក់ព័ន្ធ "នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពុំមានបទដ្ឋានផ្សេង វាយរង ឬក៏មានកម្រិតទាបជាងចេតនាសម្លាប់ផ្ទាល់នោះទេ"[346]។

៣៩៦. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលផ្អែកលើការវិភាគមួយដែលទទួលរងការរិះគន់យ៉ាងខ្លាំងបំផុត លើសាលក្រមដែលចេញថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៤៧ ដោយតុលាការយោធាអាមេរិក

---

[344] សេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ **ឯកសារ D97/15/9** កថាខណ្ឌ ៥៣ និង កំណត់សម្គាល់ជើងទំព័រ ១៤៤ (ដែលយោងទៅយុត្តិសាស្ត្ររបស់តុលាការយុត្តិធម៌អន្តរជាតិ)។

[345] សាលដីកា ០០២/០១ កថាខណ្ឌ ៤១០។

[346] សារណាបណ្តឹងសាទុក្ខ ០០២/០១ កថាខណ្ឌ ៥៩។

ប្រចាំទីក្រុង Nuremberg លើរឿងក្ដី*គ្រូពេទ្យ*។ រឿងក្ដីនេះនិយាយជាពិសេសអំពីការចូលរួមរបស់ជនជាប់ចោទទៅក្នុងការដកពិសោធន៍វេជ្ជសាស្ត្រនៅក្នុងជំរំប្រមូលផ្ដុំរបស់ចក្រភពអាល្លឺម៉ង់ទី III (I)[347]។ ការនិយាយលម្អិតបន្តទៀតរបស់អង្គជំនុំជម្រះតុលាការកំពូលអំពីច្បាប់កម្ពុជាផ្សេងៗ មិនអាចជឿជាក់បាន ដើម្បីបង្ហាញអំពីអត្ថិភាពនៃចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មជាយថាហេតុនៅក្នុងការកំណត់និយមន័យនៃឧក្រិដ្ឋកម្មមនុស្សឃាតនៅឆ្នាំ១៩៧៥នោះទេ (II)។

## ១. អវត្តមាននៃចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មដោយប្រយោលនៅក្នុងរឿងក្ដីគ្រូពេទ្យ

៣៩៧. នៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានកំណត់ធាតុផ្សំអត្តនោម័តនៃឧក្រិដ្ឋកម្មមនុស្សឃាតដូចតទៅនេះ

> "ជនជាប់ចោទ [...] ត្រូវមានចេតនាបង្កឱ្យមនុស្សស្លាប់ ឬក៏បង្កការប៉ះពាល់ធ្ងន់ធ្ងរដល់បូរណភាពរូបកាយនៃជនរងគ្រោះ ហើយដែលការប៉ះពាល់នេះគឺជាការប៉ះពាល់ដែលតាមវិចារណញ្ញាណ ជនជាប់ចោទមិនអាចនិយាយថាខ្លួនមិនអាចដឹងជាមុនថា វាអាចបង្កឱ្យមនុស្សស្លាប់នោះទេ"[348]។

៣៩៨. ក្រុមមេធាវីការពារក្ដីបានប្រឆាំងជាពិសេសទៅនឹងនិយមន័យនេះ ដោយមូលហេតុថា ដើម្បីទាញចេញជាការសន្និដ្ឋាននេះ អង្គជំនុំជម្រះផ្អែក "លើតែយុត្តិសាស្ត្ររបស់តុលាការចំពោះកិច្ច ដែលត្រូវបានបង្កើតឡើងក្រោយសម័យអង្គហេតុតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត តុលាការចំពោះកិច្ចទាំងនេះ ក៏មិនបានផ្ដល់ប្រភពនៃសេចក្ដីសម្រេចជាអន្តរជាតិ ដែលត្រូវបានធ្វើឡើងមុនសេចក្ដីសម្រេចរបស់ខ្លួន ក្នុងការអនុវត្តបទដ្ឋានបែបនេះនោះឡើយ"[349]។

៣៩៩. ដើម្បីបដិសេធសំអាងហេតុរបស់ក្រុមមេធាវីការពារក្ដី អង្គជំនុំជម្រះតុលាការកំពូលហាក់ដូចជាបានរកឃើញនៅក្នុងរឿងក្ដី*គ្រូពេទ្យ* នូវករណីមួយដែល "ផ្ដល់ការចង្អុលបង្ហាញយ៉ាងរឹងមាំថា នៅ

---

[347] *United States of America v. Karl BRANDT et al., American Military Court for the Trial of War Criminals,* តុលាការយោធាអន្តរជាតិនៅ Nuremberg ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៤៧, UNWCC, vol. II («*រឿងក្ដីទាក់ទងទៅនឹងវេជ្ជសាស្ត្រ*») ទំព័រ ១៧១-៣០០។

[348] សាលក្រម ០០២/០១ កថាខណ្ឌ ៤១២។

[349] សារណាបណ្ដឹងសាទុក្ខ ០០២/០១ កថាខណ្ឌ ៦០។

សម័យក្រោយសង្គ្រាមលោកលើកទីពីរ មនុស្សឃាតដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានបញ្ចូលសញ្ញាណនៃចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មដោយប្រយោល"[350]។

៤០០. អង្គជំនុំជម្រះតុលាការកំពូលចង្អុលបង្ហាញថា ការដកពិសោធន៍ដែលជនជាប់ចោទត្រូវបានជំនុំជម្រះសេចក្តី "បានបង្កអោយមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើរាងកាយរបស់ជនរងគ្រោះ"។ ត្រង់នេះ តុលាការកំពូលយោងទៅអង្គហេតុចោទប្រកាន់លើជនជាប់ចោទ Karl BRAND, HANDLOSER, Rudolf BRANDT et SIEVERS[351]។

៤០១. អង្គជំនុំជម្រះតុលាការកំពូលបន្តទៀតថា ៖

> "នៅពេលដែលការបង្កព្យសនកម្មធ្ងន់ធ្ងរដល់រូបកាយ គឺជាបំណងដោយផ្ទាល់របស់ជនជាប់ចោទ ពីព្រោះជនជាប់ចោទក្នុងពេលនោះមានមូលហេតុសមស្របដឹងថា ជនរងគ្រោះទំនងជានឹងស្លាប់ដោយសារលទ្ធផលនៃការធ្វើពិសោធន៍នេះ។ ដូច្នេះ ដោយសារមានកង្វះក្នុងការកំណត់និយមន័យជាក់លាក់អំពី *ធាតុផ្សំអត្តនោម័ត* នៃការធ្វើមនុស្សឃាតនៅក្នុងសាលក្រម *រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ* ទើបអាចធ្វើការសន្និដ្ឋានយ៉ាងច្បាស់លាស់ថា តុលាការឧក្រិដ្ឋកម្មយោធារបស់សហរដ្ឋអាមេរិក ពុំបានតម្រូវឱ្យមានការបង្ហាញពីចេតនាដោយផ្ទាល់ក្នុងការសម្លាប់ ដើម្បីសម្រេចដាក់ពិរុទ្ធភាពពីបទមនុស្សឃាតនៅក្នុងកាលៈទេសៈនេះឡើយ"[352]។

៤០២. ត្រង់នេះ អង្គជំនុំជម្រះតុលាការកំពូលផ្តល់វិនិច្ឆ័យកិច្ចមួយ "ប្រាកដប្រជាក្នុងការសន្និដ្ឋាន" ដែលបែរជាមិនផ្អែកលើផ្នែកណាមួយនៃសាលក្រមប្រកាសដោយតុលាការនេះ ឬផ្អែកទៅលើចំណុចណាមួយផ្សេងទៀត ដែលជំរុញអោយខ្លួនយកគំរូតាមទាល់តែសោះ។

---

[350] សាលដីកា ០០២/០១ កថាខណ្ឌ ៣៩៥។ ការសំខាន់គួរតែបញ្ជាក់ថា ទាំងអង្គជំនុំជម្រះខ្លួនឯង នៅក្នុង សាលក្រម ០០២/០១ ទាំងយុត្តិសាស្ត្រដែលត្រូវបានដកស្រង់សម្តីដើម្បីជាសម្អាងដល់សេចក្តីសម្រេចរបស់ខ្លួន ទាំងមេធាវីការពារក្តីនៅក្នុង សារណាបណ្តឹងសាទុក្ខ ០០២/០១ មិនបានហៅថាចេតនាប្រយោលឡើយ ចំពោះចេតនា « ក្នុងការបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់រូបកាយ [...] ដែលអាចនាំឱ្យជនរងគ្រោះស្លាប់ »។ នោះជាជម្រើសរបស់តុលាការកំពូល។ ជម្រើសនោះពាក់ព័ន្ធតែនឹងតុលាការកំពូលតែមួយប៉ុណ្ណោះ។

[351] សាលដីកា ០០២/០១ កថាខណ្ឌ ៣៩៥ និង កំណត់សម្គាល់ជើងទំព័រ ៩៨០។

[352] សាលដីកា ០០២/០១ កថាខណ្ឌ ៣៩៥។

៤០៣. ក៏ប៉ុន្តែ វិនិច្ឆ័យកិច្ចនេះខុសទាំងស្រុង ហើយវាជាការស្តែងឱ្យឃើញយ៉ាងច្បាស់អំពីវិធីសាស្ត្ររបស់ចៅក្រមដែលគិតតែស្វែងរកការដាក់ទណ្ឌកម្ម ដែលធ្វើឱ្យពួកគាត់លះបង់ភាពស្មោះត្រង់ផ្នែកបញ្ញាញាណ និងភាពម៉ត់ចត់ផ្នែកច្បាប់ ដើម្បីបំពេញតម្រូវការបុព្វហេតុរបស់ខ្លួន។ ម៉្យាង អវត្តមាននៃ "និយមន័យច្បាស់លាស់នៃចេតនាប្រព្រឹត្តឧក្រិដ្ឋ" គួរតែបញ្ចប់ការពិភាក្សាដេញដោល និងនាំឱ្យអង្គជំនុំជម្រះតុលាការកំពូលអនុវត្តការបកស្រាយចង្អៀត និងជាប្រយោជន៍ដល់ជនជាប់ចោទ និងគោរពគោលការណ៍នីត្យានុកូលភាពផ្នែកឧក្រិដ្ឋកម្ម (ក)[353]។ ម៉្យាងទៀត លើលពីនេះ យោងតាមកាលៈទេសៈនៃរឿងក្តី *គ្រពេឡ* វាគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងដែលចៅក្រមដែលកាត់ក្តីលើបណ្តឹងឧទ្ធរណ៍បានចេញសេចក្តីសម្រេចមួយ ដោយមានបញ្ចូលអត្ថិភាពនៃកម្រិតចេតនាសម្លាប់ទាបយ៉ាងនេះនៅក្នុងស្មារតីនៃឧក្រិដ្ឋជនណាហ្ស៊ី (ខ)។

## ក .អវត្តមាននៃការកំណត់និយមន័យនៃធាតុផ្សំអត្តនោម័ត

៤០៤. នៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបរាជ័យក្នុងការយោងទៅយុត្តិសាស្ត្រដែលមានអត្ថិភាពមុនអង្គហេតុនៃសំណុំរឿងនេះ ដោយអះអាងថាខ្លួនបានទទួលយកបទដ្ឋានផ្សេងទៀត វាយរង ឬក៏ទាបជាងចេតនាមនុស្សឃាតផ្ទាល់។ បន្ទាប់មក ការដែលអង្គជំនុំជម្រះតុលាការកំពូលផ្អែកលើយុត្តិសាស្ត្រតែមួយគត់ ដោយមិនធ្វើការកំណត់និយមន័យនៃធាតុផ្សំអត្តនោម័តនៃឧក្រិដ្ឋកម្មដើម្បីរក្សាសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ គឺជារោគសញ្ញានៃអវត្តមានទាំងស្រុងនៃភាពច្បាស់លាស់អំពីអត្ថិភាពនៃចេតនាប្រយោលនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅក្នុងការកំណត់និយមន័យអំពើមនុស្សឃាត។

៤០៥. ម្យ៉ាងទៀត ទោះបីជាត្រូវចាត់ទុកថាចេតនាប្រយោលនៃការប្រព្រឹត្តឧក្រិដ្ឋកម្មបានលេចចេញជារូបរៀងនៅក្នុងនិយមន័យអំពើមនុស្សឃាតក្រោយរឿងក្តី "*គ្រពេឡ*" ក៏ដោយ ក៏វានៅតែមិនមានធាតុផ្សំកើតក្រោយសំណុំរឿងនេះណាមួយដែលរំលេចអំពីការអនុវត្តខ្ជាប់ខ្ជួន និងជាប្រព័ន្ធដែលបង្កើតបានជាវិធាននៃច្បាប់ទំនៀមទម្លាប់មុនឆ្នាំ១៩៧៥។ អវត្តមាននៃការយោងណាមួយទៅនឹងរឿងក្តី "*គ្រពេឡ*" ក្នុងយុត្តិសាស្ត្រដែលដកស្រង់ដោយអង្គជំនុំជម្រះ និងដោយអង្គជំនុំជម្រះតុលាការ

[353] សូមមើលខាងលើ កថាខណ្ឌ ៣២៤-៣៣០។

កំពូល ដោយទទួលយកចេតនាខុសគ្នា (ហៅថា ចេតនាប្រយោល ឬមិនមែន)[354] ពីចេតនាសម្លាប់ផ្ទាល់នៅក្នុងនិយមន័យអំពើមនុស្សឃាត ឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីអវត្តមាននៃទំនៀមទម្លាប់។[355]

៤០៦. ដូច្នេះ ដោយហេតុថាពុំមានទស្សនៈច្បាប់ដែលបង្ហាញពីអត្ថិភាពនៃវិធានមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅមុនឆ្នាំ១៩៧៥ អង្គជំនុំជម្រះពុំមានជម្រើសអ្វីក្រៅពីគេចចេញឱ្យផុតពីដំណោះស្រាយមិនត្រឹមត្រូវរបស់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីងាកមកប្រកាន់យកលទ្ធិច្បាប់មួយដែលស្អាតស្អំជាង ដែលគោរពសិទ្ធិជនជាប់ចោទជាង និងដើម្បីប្រកាសថាច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអាចអនុវត្តបាននៅក្នុងឆ្នាំ១៩៧៥ មិនបញ្ចូលចេតនាប្រយោលនៅក្នុងការកំណត់និយមន័យនៃឧក្រិដ្ឋកម្មមនុស្សឃាតនោះទេ។

## ២. អវត្តមាននៃចេតនាប្រយោលនៅក្នុងអន្តរហេតុ

៤០៧. នៅពេលជំនុំជម្រះរឿងក្ដី *"ត្រូពេឡូ"* តុលាការយោធាអាមេរិកាំងបានកាត់ក្ដីជនជាប់ចោទចំនួន ២៣នាក់ ដោយផ្អែកលើមូលដ្ឋាននៃបទចោទជាច្រើន។ មានតែបទចោទទីពីរ និងទីបីតែប៉ុណ្ណោះដែលពាក់ព័ន្ធនៅក្នុងរឿងក្ដីនេះ។ ពួកគេបាននិយាយលម្អិតអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅលើ

---

[354] សូមមើលខាងលើ កថាខណ្ឌ ៣៩៨។

[355] សាលក្រម Kordic និង Cerkez (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ២៣៦៖ សាលក្រម Stakić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ៥៨៧៖ សាលក្រមឌុច ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១០ កថាខណ្ឌ ៣៣១ និង ៣៣៣។ សូមមើលផងដែរ យុត្តិសាស្ត្រដែលជាសម្លាងនៃយុត្តិសាស្ត្រមុនៗ ៖ សាលក្រម Akayesu (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៨៩៖ សាលក្រម Kayishema (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៣៩-១៤០៖ សាលក្រម Kupreskić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៥៦០-៥៦១៖ សាលក្រម Blaskić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ២១៧៖ សាលក្រម Blagojević (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ៥៥៦។

មនុស្សដែលត្រូវបានគេយកទៅពិសោធន៍រាល់ពេលធ្វើពិសោធន៍វេជ្ជសាស្ត្រ បន្ទាប់មកពួកគេបានធ្វើបញ្ជីជនជាប់ចោទដែលបានរងការចោទប្រកាន់ក្នុងការចូលរួមឧក្រិដ្ឋកម្មទាំងនេះ[356]។

៤០៨. ការធ្វើពិសោធន៍ចំនួនដប់ពីរត្រូវបានដាក់ជូនឱ្យចៅក្រមកាត់សេចក្ដី៖ ការពិសោធន៍លើរយៈកម្ពស់ខ្ពស់ (ក) ការពិសោធន៍ពីភាពត្រជាក់ (ខ) ការពិសោធន៍ពីជំងឺគ្រុនចាញ់ (គ) ការពិសោធន៍ពីការបាត់បង់ (Mustard) ឧស្ម័ន (ឃ) ការពិសោធន៍សាល់ហ្វូណាមីដ (ង) ការពិសោធន៍ឆ្អឹង សាច់ដុំ និង ការជួសជុលសរសៃប្រសាទ និង ការប្ដូរឆ្អឹង (ច) ការពិសោធន៍ទឹកសមុទ្រ (ឆ) ការពិសោធន៍រោគសញ្ញានៃជម្ងឺខាន់លឿង (ជ) ការពិសោធន៍ការក្រៀវ (ឈ) ការពិសោធន៍ជំងឺគ្រុនក្ដៅ (ញ) ការពិសោធន៍ជាមួយជាតិពុល (ដ) ការពិសោធន៍បំផ្ទុះគ្រាប់បែក (ឋ)[357]។

៤០៩. ការចោទប្រកាន់ទៅលើការដកពិសោធន៍ (ច) (ឆ) (ឈ) (ឋ) មិនបានរៀបរាប់អំពីការស្លាប់របស់ជនរងគ្រោះទេ។ ដូច្នេះ នៅក្នុងករណីទាំងនេះ ឧក្រិដ្ឋកម្មមនុស្សឃាតមិនត្រូវបានចោទប្រកាន់ទៅលើពួកគាត់ទេ។

៤១០. អាស្រ័យហេតុនេះ នៅសល់ការដកពិសោធន៍ចំនួនប្រាំបីទៀត ដែលការផ្ដន្ទាទោសពីបទមនុស្សឃាតត្រូវបានប្រកាសប្រឆាំងនឹងជនជាប់ចោទចំនួនដប់បួននាក់។[358] ការអានដោយយកចិត្តទុកដាក់នៃសាលក្រមអាចឱ្យដឹងថា គ្មានការផ្ដន្ទាទោសណាមួយក្នុងចំណោមការផ្ដន្ទាទោសទាំងអស់នេះផ្អែកលើចេតនាប្រយោលដោយសន្មត ហើយសេចក្ដីសន្និដ្ឋានផ្ទុយរបស់តុលាការកំពូលបង្ហាញយ៉ាងច្បាស់អំពីការបដិសេធប្រវត្តិនៃជំរំប្រមូលផ្ដុំ។

---

[356] រឿងក្ដីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៧៤-១៧៨។ ទំព័រ ១៧៩ និង ១៨០ រៀបរាប់ពីកម្មវិធីមរណៈផ្សេងទៀត ដែលជាហេតុនាំឱ្យជនជាប់ចោទខ្លះត្រូវគេបញ្ជូនទៅកាត់ទោស។ ដោយសារតែអំពើឃាតកម្មជារបៀបចាំបាច់ក្នុងការប្រព្រឹត្តរបស់ពួកគេ ដូច្នេះចេតនាផ្ទាល់ក្នុងការសម្លាប់ ត្រូវមានជាប់ជាមួយនឹងអំពើនោះ។

[357] រឿងក្ដីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៧៤-១៧៨។

[358] រឿងក្ដីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៩៨ (Karl BRANDT) ទំព័រ ២០៧ (HANDLOSER) ទំព័រ ២១៧ (SCHROEDER) ទំព័រ ២២២ (GENZKEN) ទំព័រ ២២៨ (GEBHARDT) ទំព័រ ២៤១ (Rudolf BRANDT) ទំព័រ ២៤៨ (MRUGOWSKY) ទំព័រ ២៦ (SIEVERS) ទំព័រ ២៧១ (ROSE) ទំព័រ ២៨១ (BRACK) ទំព័រ ២៨៥ (BECKER-FREYSENG) ទំព័រ ២៩០ (HOVEN) ទំព័រ ២៩៥ (OBERHEUSER) និង ទំព័រ ២៩៧ (FISCHER)។

៤១១. ចំណុចដូចគ្នានៃការដកពិសោធន៍ទាំងប្រាំបីនេះ (ដូចការដកពិសោធបួនផ្សេងទៀតដែលនៅសល់) ស្ថិតនៅត្រង់ការរៀបចំពិសោធន៍នៅក្នុងជំរំប្រមូលផ្តុំនៃរបបណាហ្សីដូចគ្នា ឧទាហរណ៍ ជំរំ Ravensbruck សម្រាប់ការដកពិសោធន៍ (ង) និង(ឈ) ជំរំ Saschsenhausen សម្រាប់ការដកពិសោធន៍ (ឃ) និង(ជ) ជំរំ Natzweiler សម្រាប់ការដកពិសោធន៍ (ឃ) និង (ជ) និង (ញ) ជំរំ Dachau សម្រាប់ការដកពិសោធន៍ (ក) (ខ) និង(គ) និងចុងក្រោយ ជំរំ Buchenwald សម្រាប់ការដកពិសោធន៍ (ញ) (ដ)[359]។

៤១២. អ្នកដែលស្គាល់អំពីប្រវត្តិនៃសង្គ្រាមលោកលើកទីពីរបន្តិចបន្តួចក៏ដឹងដែរថា កន្លែងទាំងនេះប្រើសម្រាប់ឃុំឃាំងប្រភេទមនុស្ស (ជាពិសេសពួកជ្វីហ្វ ពួកពនេចរហ្សីកាន ឈ្លើយសឹក និងអ្នកប្រឆាំងនយោបាយ) ដែលរបបអ៊ីត្លែបញ្ជូនឱ្យស្លាប់យ៉ាងច្បាស់ប្រាកដ។ អំពើឃ្លតលីលានៃការសម្លាប់រង្គាលនេះ មានស្តែងចេញពីសាលក្រមនៃតុលាការយោធាអន្តរជាតិដូចតទៅ៖

> *"មធ្យោបាយមួយក្នុងចំណោមមធ្យោបាយដ៏ទុរយសបំផុតនៃការបំភិតបំភ័យប្រជាជននៅក្នុងទឹកដីដែលត្រូវបានកាប់កាន់ គឺការប្រើប្រាស់ជំរុំប្រមូលផ្តុំ។ ជំរុំប្រមូលផ្តុំទាំងនោះត្រូវបានបង្កើតឡើងមុនដំបូងនៅប្រទេសអាល្លឺម៉ង់ នៅពេលរដ្ឋាភិបាលណាហ្ស៊ីក្តោបអំណាចរួច។ គោលបំណងដើមនៃជំរុំប្រមូលផ្តុំគឺចាប់ដាក់ពន្ធនាគារដោយគ្មានការជំនុំជម្រះនូវមនុស្សទាំងអស់ដែលប្រឆាំងរដ្ឋាភិបាល ឬអ្នកដែលស្អប់ខ្ពើមអាជ្ញាធរអាល្លឺម៉ង់។ ដោយមានជំនួយពីកងកម្លាំងនគរបាលសម្ងាត់ ការអនុវត្តនេះត្រូវបានលាតសន្ធឹងយ៉ាងទូលំទូលាយ ហើយតែមួយរយៈខ្លី ជំរុំប្រមូលផ្តុំក្លាយជាកន្លែងមនុស្សឃាតជាប្រព័ន្ធដែលមានអង្គការចាត់តាំង ដែលប្រជាជនរាប់លាននាក់ត្រូវបានសម្លាប់។*
>
> *[...]*
>
> *ជំរុំប្រមូលផ្តុំមួយចំនួនមានបំពាក់ទៅដោយបន្ទប់ឧស្ម័នសម្រាប់ការកម្ទេចអ្នកទោសជាចំនួនច្រើន និងមានឡសម្លាប់ដុតសាកសព។ ការពិតជំរុំប្រមូលផ្តុំមួយចំនួនត្រូវបានប្រើសសម្រាប់សម្លាប់រង្គាលជនជាតិជ្វីហ្វ ដែលជាផ្នែកមួយនៃ "ដំណោះស្រាយចុងក្រោយ" ចំពោះបញ្ហាជនជាតិជ្វីហ្វ។ អ្នកទោសជាច្រើនដែលមិនមែនជាជនជាតិជ្វីហ្វត្រូវបានបង្ខំឱ្យធ្វើការងារ ទោះបីស្ថានភាពដែលពួកគេធ្វើការធ្វើឱ្យការងារ និងការស្លាប់ស្ទើរតែមានន័យដូចគ្នាក៏ដោយ។ អ្នកទោសដែលធ្លាក់ខ្លួនឈឺ និងមិនអាចធ្វើការបាន ត្រូវគេកម្ទេចនៅក្នុងបន្ទប់ឧស្ម័ន ឬបញ្ជូនទៅគិលានដ្ឋានពិសេស ដែលនៅពេលនោះ ពួកគេពុំបានទទួលការព្យាបាលមិនបាន*

---

[359] រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៧៤-១៧៨។

*ពេញលេញ អាហារកាន់តែមានសភាពអាក្រក់ជាងអ្នកទោសដែលធ្វើការ ហើយត្រូវគេទុកចោលឱ្យស្លាប់តែម្តង។"[360]*

៤១៣. ពេលចូលដល់ជំរំ សំណួរដែលត្រូវសួរមិនមែនចង់ដឹងថា តើអ្នកទោសនឹងស្លាប់ឬអត់នោះទេ ប៉ុន្តែចង់ដឹងថាតើពួកគេនឹងស្លាប់របៀបណា។ ការដែលពួកគាត់មិនស្លាប់ដោយលក្ខខ័ណ្ឌនៃការឃុំឃាំងមិនគួរអនុញ្ញាតឱ្យនិយាយថា នៅក្នុងកន្លែងទាំងនេះ សេចក្តីស្លាប់គ្រាន់តែជាភវនិយភាព ឬក៏ជាយថាហេតុប៉ុណ្ណោះបានឡើយ។ ក៏ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលបែរជាជ្រើសរើសយកផ្លូវនេះទៅវិញ។

៤១៤. សេចក្តីសន្និដ្ឋានរបស់ចៅក្រមដែលកាត់សេចក្តីលើបណ្តឹងសាទុក្ខក៏មិនអាចតទល់ការវិភាគលើវិធីសាស្ត្រដកពិសោធន៍ដែលគេយកទៅប្រើលើអ្នកទោស។

៤១៥. ចំពោះការដកពិសោធន៍ (ក) និង(ខ) ការប្រព្រឹត្តិទៅលើអ្នកទោសបានបណ្តាលឱ្យបាត់បង់ជីវិតដោយជៀសមិនរួច។[361] ភាសាដែលប្រើប្រាស់ដោយតុលាការ Nurumberg មានន័យច្បាស់លាស់ពាក់ព័ន្ធនឹងចេតនាសម្លាប់ផ្ទាល់របស់ចារី។ ទាក់ទងនឹងបទពិសោធន៍ (ក) ពួកគេបានលើកឡើងជាអាទិ៍ថា៖

*"អ្នកទោសនៅក្នុងជំរុំប្រមូលផ្តុំត្រូវបានសម្លាប់ នៅពេលពួកគេក្លាយជាឧបករណ៍ពិសោធន៍នៅក្នុងបន្ទប់ពិសោធន៍។"[362]*

៤១៦. ទាក់ទងនឹងការដកពិសោធន៍ (ខ) បន្ថែមលើការស្លាប់នៃមនុស្សដែលយកមកពិសោធ ក៏មានការរៀបរាប់អំពីការប្រើប្រាស់សរីរាង្គដែលយកចេញពី "មនុស្សប្រាំនាក់ដែលត្រូវបានគេសម្លាប់" ដើម្បីយកមកពិសោធន៍ ក្នុងក្របខណ្ឌនៃការដកពិសោធន៍ដទៃទៀត[363]។ ទោះបីជាមានការសង្ស័យ

---

[360] *Trial of the Major War Criminals before the International Criminal Tribunal* ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ TMI, vol. I ទំព័រ ២៣៤-២៣៥។

[361] រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៧៥ ទំព័រ ២៣៦-២៣៧ និង ទំព័រ ២៥៥-២៥៦។

[362] រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ២៨២។

[363] រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ២០០-២០១ ទំព័រ ២៣៧ និង ទំព័រ ២៥៦។

ទៅលើតថភាពនៃការផ្តន្ទាទោសពីបទមនុស្សឃាតតាមរយៈការដកពិសោធន៍ផ្សេងៗទៀតក៏ដោយ ក៏អំពើនេះរំឭកថាពុំមានការសង្ស័យណាមួយទៅលើកម្រិតចេតនាឧក្រិដ្ឋរបស់ចារីដែរ។ ចេតនាសម្លាប់ គឺវាផ្ទាល់តែម្តង។ ចំពោះការដកពិសោធន៍ (ខ) ចៅក្រមនៃតុលាការយោធាអន្តរជាតិថែមទាំងបានអះអាងថា៖

> *"អ្នកទោសក្លាយទៅជាឧបករណ៍ពិសោធន៍យ៉ាងឃោរឃៅ នៅ Dachau នៅខែ សីហា ឆ្នាំ ១៩៤២ ជនរងគ្រោះត្រូវគេជ្រមុកទៅក្នុងទឹកត្រជាក់រហូតទាល់តែសីតុណ្ហភាពក្នុងខ្លួនធ្លាក់ចុះមកនៅត្រឹម ២៨ អង្សារសេ នៅពេលនោះពួកគេស្លាប់មួយរំពេច។"*[364]

៤១៧. ការដកពិសោធន៍បួនផ្សេងទៀត គឺជាការបាញ់បញ្ចូលទៅក្នុងខ្លួនអ្នកទោសនូវជំងឺដែលបង្កឱ្យស្លាប់ជាអាទិ៍ដូចជា ជំងឺគ្រុនចាញ់សម្រាប់ការដកពិសោធន៍ (គ) ជំងឺឈឺក្បាល និងជំងឺតេតាណូសសម្រាប់ការដកពិសោធន៍ (ង) ជំងឺលឿង ចំពោះការដកពិសោធន៍ (ជ) និងជំងឺគ្រុនក្តៅសន្និ និងផ្តួងសម្រាប់ការដកពិសោធន៍ (ញ) បន្ទាប់មកត្រូវសាកល្បងនូវវិធីការព្យាបាលមិនទៀងទាត់លើពួកគេ[365]។ ការដកពិសោធន៍ទាំងអស់នេះសុទ្ធតែបណ្តាលឱ្យបុគ្គលដែលជាកម្មវត្ថុនៃការដកពិសោធន៍ស្លាប់យ៉ាងជាក់ស្បាន់ ពីព្រោះអត្រាស្លាប់មានដល់រហូត ៩០% ចំពោះការដកពិសោធន៍ (ញ)[366]។

៤១៨. នៅចុងបញ្ចប់ ដើម្បីសម្រេចការដកពិសោធន៍ពីរចុងក្រោយ ជនជាប់ចោទក៏បានប្រើសារធាតុដែលបណ្តាលឱ្យស្លាប់ផងដែរ ឧទាហរណ៍ដូចជា ឧស្ម័នម៉ាស្តាដ ចំពោះការដកពិសោធន៍ (ឃ) និងថ្នាំពុលសម្រាប់ការដកពិសោធន៍ (ដ)។[367] ចំពោះការដកពិសោធន៍ (ដ) ជនរងគ្រោះមួយចំនួនត្រូវបានសម្លាប់ភ្លាមៗ ក្រោយពីបញ្ចូលជាតិពុលជាសំងាត់ ក្នុងបំណងធ្វើកោសល្យវិច័យលើសាកសពពួកគាត់[368]។

---

[364] *Trial of the Major War Criminals before the International Criminal Tribunal* ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៤៦ តុលាការយោធាអន្តរជាតិ vol. I ទំព័រ ២៥២។

[365] រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៧៥-១៧៨។

[366] រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៧៧-១៧៨។

[367] រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៧៦ និង ១៧៨។

[368] រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៧៨។

៤១៩. ក្នុងការដកពិសោធន៍ទាំងពីរឈុតនេះ ការសម្រេចដាក់មនុស្សឱ្យប្រឈមមុខនឹងជំងឺ ឬសារធាតុដែលបង្កឱ្យស្លាប់តាមទំនើងចិត្ត បង្ហាញអំពីចេតនាសម្លាប់ដោយផ្ទាល់។ គឺមិនចាំបាច់និយាយវែងឆ្ងាយច្រើនជាងនេះទៀតទេ។ ទស្សនៈយល់ដឹងផ្សេងចំពោះកម្រិតចេតនានេះ មិនអាចការពារបានទេ។

៤២០. ជាការសន្និដ្ឋាន នៅពេលតុលាការកំពូលលើកឡើងនៅក្នុងរឿងក្តី *គ្រូពេទ្យ* ថា "*ជនជាប់ចោទត្រូវដឹងតាមវិចារណញ្ញាណថាតើជាលទ្ធផលនៃការដកពិសោធន៍ ជនរងគ្រោះរបស់ពួកគេអាចស្លាប់ឬទេ*" នៅត្រង់ចំណុចនេះ វាគ្រាន់តែជាវោហាស័ព្ទក្នុងការនិយាយឱ្យតែពីរោះស្តាប់តែប៉ុណ្ណោះ។ ការដឹងឮមានភាពសមហេតុផលគ្រប់គ្រាន់ទៅហើយ ដោយហេតុថាមនុស្សដែលគេយកទៅដកពិសោធន៍ ត្រូវទុកបញ្ជូនទៅឱ្យស្លាប់ ហើយការដកពិសោធន៍ទាំងនេះបណ្តាលឱ្យបាត់បង់ជីវិតមនុស្ស។ ត្រង់កន្លែងដែលច្បាប់តម្រូវឱ្យមានភាពម៉ត់ចត់ តុលាការកំពូលបែរជាឆ្លើយមកវិញតាមរចនាបទសម្រាលន័យដែលលោក វេជ្ជបណ្ឌិត Ernest Robert GRAWITZ ដែលជាប្រធានអង្គភាពពេទ្យនៅ Schutzstaffeln[369] ទំនងជាមិនបដិសេធទេ ហើយដែលរូបគាត់ផ្ទាល់បានសរសេររៀបរាប់អំពីអ្វីដែលគេធ្វើមុនពេលចាក់បញ្ចូលជំងឺឈឺងទៅក្នុងខ្លួនអ្នកទោសដែលត្រូវបានផ្តន្ទាទោសប្រហារជីវិត និងដែលត្រូវបានជ្រើសរើស ដោយសារគុណសម្បត្តិតែមួយនេះគត់៖ "*ការស្លាប់ត្រូវតែបានគ្រោងទុកជាមុន*"[370]។

## ២ .ការមិនអាចអនុវត្តបាននៃច្បាប់ជាតិឆ្នាំ ១៩៧៥

៤២១. ដើម្បីគាំទ្រដល់ការសន្និដ្ឋានដ៏រវើរវាយរបស់ខ្លួនលើរឿងក្តី *គ្រូពេទ្យ* តុលាការកំពូលអះអាងថា៖ "បញ្ហានេះនឹងត្រូវបានបញ្ជាក់បន្ថែមទៀត នៅពេលធ្វើការពិចារណាទៅលើការអនុវត្តក្នុងស្រុកទាក់ទងទៅនឹងបទឧក្រិដ្ឋនៃការធ្វើមនុស្សឃាត"[371] ជាអ្វីដែលខ្លួនព្យាយាមបង្ហាញពេលក្រោយមកដោយផ្តល់ព័ត៌មានលើច្បាប់ដែលអាចអនុវត្តបាននៅក្នុងប្រទេសចំនួន១៤[372]។

---

[369] រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៨៦។

[370] រឿងក្តីទាក់ទងទៅនឹងវេជ្ជសាស្ត្រ ទំព័រ ១៩៥។

[371] សាលដីកា ០០២/០១ កថាខណ្ឌ ៣៩៥។

[372] សាលដីកា ០០២/០១ កថាខណ្ឌ ៣៩៧-៤០៨។

៤២២. ក៏ប៉ុន្តែ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលលើចំណុចច្បាប់ជាតិផ្សេងៗរំលោភបំពានទៅលើគោលការណ៍នីត្យានុកូលភាព ក្រោមមូលហេតុផ្សេងៗគ្នា។ សេចក្តីសន្និដ្ឋានទាំងអស់នេះផ្អែកលើ៖ (ក) ការបកស្រាយច្បាប់កម្ពុជាខុស (ខ) ច្បាប់ក្រោយឆ្នាំ១៩៧៥ និង (គ) ច្បាប់ពីមុនមកដែលមិនអាចបង្កើតចេញជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

## ក. ការយោងមិនត្រឹមត្រូវទៅលើច្បាប់កម្ពុជា

៤២៣. អង្គជំនុំជម្រះតុលាការកំពូលយោងទៅមាត្រា ៥០៣ មាត្រា ៥០៤ និងមាត្រា ៥០៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលមាត្រាទាំងនេះមិនមានចែងទាល់តែសោះអំពីអត្ថិភាពនៃចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មដោយប្រយោល[373]។ មាត្រា ៥០៣ ចែងអំពី "បទមនុស្សឃាតគ្មានមរណចេតនា[374]"។ ដូច្នេះ ខ្លឹមសារនេះវាខុសស្រឡះពីសញ្ញាណនៃចេតនាប្រព្រឹត្តឧក្រិដ្ឋដោយប្រយោល ដែលតម្រូវឱ្យរកអោយឃើញនូវធាតុផ្សំនៃចេតនាមនុស្សឃាត ទោះបីជាចេតនានេះមានកម្រិតតិចតួចយ៉ាងណាក្តី។ មាត្រា ៥០៤ ចែងថា "កាលបើមនុស្សឃាត បណ្តាលមក ឬអាចបណ្តាលមកពីចិត្តដែលស្ទុះឡើងភ្លាមៗ ចង់ឱ្យស្លាប់ មនុស្សឃាតនេះ ឱ្យឈ្មោះថាឃាតកម្ម ឬបំណងឃាតកម្ម[375]។ នេះវាមិនខុសទាល់តែសោះពីការបង្ហាញចេតនាសម្លាប់មនុស្សដោយផ្ទាល់។

៤២៤. មានតែមាត្រា ៥០៥ តែប៉ុណ្ណោះ ដែលគួរឱ្យយើងធ្វើអធិប្បាយ។ មាត្រានេះចែងថា៖

> "ចៅក្រមអាចសន្និដ្ឋានថា ឃាតករមានមរណចេតនាបាន កាលណាបើឃាតករបានប្រើសស្ត្រាវុធគួរដល់ស្លាប់ កាលណាបើឃាតករប្រហាយ៉ាងពេញទំហឹង កាលបើមានមុខរបួសមុតសាំលើខ្លួនអ្នកស្លាប់ កាលណាបើឃើញថា ឃាតករបានរើសរកកន្លែងដំណំ នៅលើខ្លួនអ្នកស្លាប់ គួរដល់ស្លាប់មែន[376]"។

---

[373] សាលដីកា ០០២/០១ កថាខណ្ឌ ៣៩៧។

[374] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ មាត្រា ៥០៣។

[375] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ មាត្រា ៥០៤។

[376] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ មាត្រា ៥០៥។

៤២៥. ការយោងទៅមាត្រានេះ គឺជាការឆ្លុះបញ្ចាំងយ៉ាងល្អបំផុតអំពីភាពអគតិនៃអង្គជំនុំជម្រះតុលាការកំពូល។ ត្រង់នេះ មានចេតនាបែបសន្មតតែមួយគត់ គឺចេតនាផ្ទាល់ចង់សម្លាប់។ ចេតនានេះកើតចេញពីអាកប្បកិរិយានៃចារីដែលភាពធ្ងន់ធ្ងរបំផុតរបស់គាត់បង្ហាញអំពីឆន្ទៈចង់សម្លាប់មនុស្ស។ ដូច្នេះ យើងមិនយល់ថាហេតុអ្វីបានជាអង្គជំនុំជម្រះតុលាការកំពូលបានធ្វើការប្រៀបធៀបមាត្រា ៥០៥ ទៅនឹងចេតនាប្រយោលក្នុងការប្រព្រឹត្តិឧក្រិដ្ឋ "ដែលខ្លួនរកឃើញ" នៅក្នុងរឿងក្ដី *គ្រូពេទ្យ* ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលគួរតែផ្អែកលើការសន្មតទុកជាមុនដែលមានចែងនៅក្នុងមាត្រានេះ ដើម្បីជៀសឱ្យផុតពីឧបសគ្គ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះតុលាការកំពូលគួរណាប្រើមាត្រានេះ ដើម្បីទាញការសន្និដ្ឋានចេញពីការដាក់ដោយចេតនាឱ្យមនុស្សប្រឈមមុខនឹងជំងឺ និងសារធាតុដែលបង្កឱ្យស្លាប់ ថាចារីមានចេតនាផ្ទាល់ចង់សម្លាប់មនុស្សទាំងនោះ[377]។ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការជ្រើសរើសផ្សេងៗខុសគ្នា ដែលគ្មានអ្នកណាអាចយកគំរូតាមបានទេ ដោយសារខ្លួនធ្វើខុស និងមានមូលហេតុមិនត្រឹមត្រូវ។

## ខ. ការយោងទៅច្បាប់ដែលតាក់តែងឡើងក្រោយអង្គហេតុ

៤២៦. ប្រភពផ្សេងៗទៀតភាគច្រើនដែលអង្គជំនុំជម្រះតុលាការកំពូលបានប្រើប្រាស់ សុទ្ធតែបានតាក់តែងឡើងក្រោយឆ្នាំ១៩៧៥[378]។ ដូច្នេះ ប្រភពទាំងនេះមិនអាចបង្កើតបានជាច្បាប់អាចអនុវត្តបាននៅពេលនេះទេ[379]។

## គ .ការយោងទៅច្បាប់ដែលត្រូវបានតាក់តែងឡើងមុនអង្គហេតុដែលមិនអាចបង្កើតបានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ

[377] សូមមើលខាងលើ កថាខណ្ឌ ៤១៩។

[378] សាលដីកា ០០២/០១ កំណត់សម្គាល់ជើងទំព័រ ៩៩៣-៩៩៤ (ប្រទេសបារាំង), ៩៩៥ (ប្រទេសបែលហ្ស៊ិក), ៩៩៦ (ប្រទេសអាឡឺម៉ង់), ៩៩៧ (ប្រទេសអ៊ីតាលី), ៩៩៨ (ប្រទេសអេស្ប៉ាញ), ៩៩៩ (ប្រទេសប៉ូឡូញ), ១០០១ (ប្រទេសអង់គ្លេស និង វ៉េល) ១ ០០៣ (សហរដ្ឋអាមេរិក យោងទៅក្រមព្រហ្មទណ្ឌអាមេរិក ឆ្នាំ ១៩៦២ ដែលចូលជាធរមាន នៅឆ្នាំ ១៩៨៥), ១០០៤ (ប្រទេសកាណាដា), ១០០៧ (ប្រទេសអូស្ត្រាលី ក្នុងចំណោមប្រភពព័ត៌មានតុលាការតែប៉ុណ្ណោះ) និង ១០០៨ (ប្រទេសអូស្ត្រាលី)។

[379] សូមមើលខាងលើ កថាខណ្ឌ ៣០៩-៣១៣ និង ៤០៣។

៤២៧. ក្រៅពីបទបញ្ញត្តិក្រមព្រហ្មទណ្ឌកម្ពុជាដែលត្រូវបដិសេធចោល[380] ឯកសារយោងបន្តិចបន្តួចដែលបានតាក់តែងឡើងមុនឆ្នាំ១៩៧៥ និងដែលត្រូវបានដកស្រង់ដោយតុលាការកំពូល រួមមាន មាត្រាចំនួនមួយនៃរដ្ឋធម្មនុញ្ញប្រទេសប៊ែលហ្សិកឆ្នាំ១៨៧៩ និងបទបញ្ញត្តិចំនួនមួយនៃក្រមព្រហ្មទណ្ឌប៉ូឡូញឆ្នាំ១៩៦៩[381] ចំពោះប្រទេសដែលប្រើច្បាប់ស៊ីវិល។

៤២៨. ទាក់ទងនឹងប្រទេសដែលប្រើច្បាប់ *Common Law* ប្រភពដែលត្រូវបានដកស្រង់រួមមាន សេចក្តីសម្រេចមួយនៃព្រឹទ្ធសភាចក្រភពអង់គ្លេសឆ្នាំ១៩៧៤ បទបញ្ញត្តិដូចគ្នាមួយនៃច្បាប់ព្រហ្មទណ្ឌឥណ្ឌា និងសាំងហ្គាពួរ[382] និងបទបញ្ញត្តិមួយចំនួននៃក្រមព្រហ្មទណ្ឌរបស់រដ្ឋសហព័ន្ធបួនក្នុងចំណោមរដ្ឋសហព័ន្ធចំនួនប្រាំមួយ និងរបស់ដែនដីពីរក្នុងចំណោមដែនដីសហព័ន្ធទាំងបីរបស់ប្រទេសអូស្ត្រាលី សេចក្តីសម្រេចបីនៃតុលាការកំពូលអូស្ត្រាលីចំនួនពីរ សេចក្តីសម្រេចមួយរបស់តុលាការជាន់ខ្ពស់អូស្ត្រាលី និងនៅចុងបញ្ចប់ សេចក្តីសម្រេចតុលាការចំនួនមួយនៅអាហ្វ្រិកខាងត្បូង[383]។

៤២៩. ប្រភពរប៉ាត់រប៉ាយបន្តិចបន្តួចនេះ មិនឆ្លុះបញ្ចាំងអ្វីទាល់តែសោះអំពីការអនុវត្តស្មើរគ្រប់ទិសទីដោយរដ្ឋនានា អំពីការអនុវត្តដោយមានឯកសណ្ឋានភាព ឬអំពីទស្សនៈច្បាប់ (*Opinio Juris*) ដែលបង្ហាញអំពីអត្ថិភាពនៃវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ១៩៧៥[384]។

**ផ្នែកទី ៤. ការបង្កើតសញ្ញាណសហឧក្រិដ្ឋកម្មរួមមួយតាមការកាត់តម្រឹម**

---

[380] សូមមើលខាងលើ កថាខណ្ឌ ៤២៣-៤២៥។

[381] សាលដីកា ០០២/០១ កំណត់សម្គាល់ជើងទំព័រ ៩៩៥ (ប្រទេសបែលហ្សិក) និង ៩៩៩ (ប្រទេសប៉ូឡូញ)។ ក្រមព្រហ្មទណ្ឌប៉ូឡូញ ឆ្នាំ ១៩៦៩ ជំនួសក្រមព្រហ្មទណ្ឌឆ្នាំ ១៩៣២ ដែលបានដកស្រង់ដោយតុលាការកំពូល។

[382] អត្តសញ្ញាណនៃអត្ថបទច្បាប់ទាំងនេះមានសេចក្តីពន្យល់ដោយប្រវត្តិអាណានិគមរួមនៃប្រទេសទាំងពីរ ដែលស្ថិតក្រោមការគ្រប់គ្រងនៃចក្រភពអង់គ្លេសក្នុងពេលដ៏យូរ។

[383] សាលដីកា ០០២/០១ កំណត់សម្គាល់ជើងទំព័រ ១០០០ (ប្រទេសអង់គ្លេស និង វ៉េល), ១០០៥ (ប្រទេសឥណ្ឌា), ១០០៦ (ប្រទេសសិង្ហបុរី) ១០០៧ (ប្រទេសអូស្ត្រាលី ប្រភពឯកសារច្បាប់ សេចក្តីសម្រេចពីរនៃតុលាការកំពូលពីរ និងសេចក្តីសម្រេចនៃសាលាជាន់ខ្ពស់), ១០០៩ (ប្រទេសអូស្ត្រាលី សេចក្តីសម្រេចនៃតុលាការកំពូល) និង ១០១១ (ប្រទេសអាហ្វ្រិកខាងត្បូង)។

[384] សូមមើលខាងលើ កថាខណ្ឌ ៣៨៨-៣៩២។

៤៣០. បន្ទាប់ពីបានរំលោភលើគោលការណ៍នីត្យានុកូលភាពនៃបទមនុស្សឃាតដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តុលាការកំពូលបានដកហូតយកផ្ទើមប្រម៉ាត់ពីគោលការណ៍នេះ តាមរយៈការបង្កើតសហឧក្រិដ្ឋកម្មរួមកូនកាត់មួយតាមការកាត់តម្រឹមរបស់ខ្លួន ដើម្បីផ្តន្ទាទោសជនជាប់ចោទ នៃ អ.វ.ត.ក។

៤៣១. (I) បន្ទាប់ពីបានពិនិត្យអត្ថិភាព ឬនត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ និងសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ (II) តុលាការកំពូលបានផ្តល់និយមន័យដល់សហឧក្រិដ្ឋកម្មរួមកូនកាត់មួយដោយគ្មានមូលដ្ឋានអ្វីទាំងអស់។ (III) និយមន័យនេះមិនត្រឹមតែខ្វាស់ដោយប្រភពដែលខ្លួនបានពិនិត្យដើម្បីកំណត់អំពីអត្ថិភាព ឬនត្ថិភាពនៃប្រភេទសហឧក្រិដ្ឋកម្មរួមនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិប៉ុណ្ណោះទេ (IV) គឺវាថែមទាំងជាកំពូលនិយមន័យដំបូងបំផុតក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិសម័យទំនើប ។ ចុងក្រោយបង្អស់ (V) តុលាការកំពូលបានអនុវត្តជាប្រតិសកម្មនូវច្បាប់មួយដែលខ្លួនបានបង្កើតនៅថ្ងៃ ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ដែលជនជាប់ចោទមិនអាចគ្រោងទុកជាមុនបាន ប៉ុន្តែច្បាប់នេះអាចបង្កលក្ខណៈងាយស្រួលដល់ការផ្តន្ទាទោសជនលើជាប់ចោទ ។

## ១. <u>អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ និងនត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅសម័យអង្គហេតុ</u>

៤៣២. អង្គជំនុំជម្រះតុលាការកំពូលបានចាប់ផ្តើមដោយកត់សម្គាល់ថា អង្គជំនុំជម្រះនៃ អ.វ.ត.ក តុលាការចំពោះកិច្ច តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ បានពិចារណាយ៉ាងយូរទៅលើសំណួរដែលសួរថា តើច្បាប់ទំនៀមទម្លាប់អន្តរជាតិតម្រូវឱ្យមានល័ក្ខខ័ណ្ឌអ្វីខ្លះ ដើម្បីកំណត់ឱ្យមានទំនួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ក្នុងករណីដែលបុគ្គលទាំងនេះដែលមានចេតនាដូចមានចែងនៅក្នុងល័ក្ខខ័ណ្ឌតម្រូវ បានចូលរួមក្នុងការសម្រេចផែនការឧក្រិដ្ឋរួម[385]។

---

[385] សាលដីកា ០០២/០១ កថាខណ្ឌ ៧៧៣។

៤៣៣. អង្គជំនុំជម្រះតុលាការកំពូលបានរំឮកថា នៅក្នុងសាលដីកានៃរឿងក្ដី *Tadic* នៅឆ្នាំ១៩៩៩ គឺជាលើកទីមួយ ដែលតុលាការអន្តរជាតិបានខំព្យាយាមកំណត់និយមន័យនៃធាតុផ្សំនៃអ្វីដែលតុលាការនេះហៅថា "សហឧក្រិដ្ឋកម្មរួម" ដោយផ្អែកទៅលើការវិភាគយុត្តិសាស្ត្រដែលកើតឡើងក្រោយសង្គ្រាមលោកលើកទីពីរ លើយុត្តិសាស្ត្រជាតិ ច្បាប់ជាតិ និងសន្ធិសញ្ញាអន្តរជាតិ។ ការវិភាគនេះបានធ្វើឱ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី កំណត់បានទម្រង់៣នៃសហឧក្រិដ្ឋកម្មរួម៖

១. ទម្រង់ "មូលដ្ឋាន" (សហឧក្រិដ្ឋកម្មរួមទម្រង់ទី១) ដែលទាក់ទងនឹងកិច្ចការ ដែលនៅក្នុងកិច្ចការនេះ "សហជនជាប់ចោទទាំងអស់ ដែលធ្វើសកម្មភាពរួមគ្នាក្នុងគោលបំណងឧក្រិដ្ឋកម្មរួម មានចេតនាឧក្រិដ្ឋដូចគ្នា។ ឧទាហរណ៍ ករណីបង្កើតផែនការសម្លាប់មួយដោយសហចារី។ ក្នុងការសម្រេចគោលបំណងរួមនេះ ទោះបីជាចារីម្នាក់ៗដើរតួនាទីខុសគ្នានៅក្នុងកិច្ចការនេះក៏ដោយ ក៏សហចារីទាំងអស់សុទ្ធតែមានចេតនាសម្លាប់"[386]។

២. ទម្រង់ទីពីរ ហៅថា ទម្រង់ "ជាប្រព័ន្ធ" ដែលគ្របដណ្តប់លើកិច្ចការក្នុងជំរំប្រមូលផ្តុំដែលក្នុងករណីនេះ "សញ្ញាណនៃគោលបំណងរួមត្រូវបានអនុវត្តក្នុងករណីដែលអង្គហេតុចោទប្រកាន់ត្រូវបានសន្មតជាមុនថាបានប្រព្រឹត្តដោយសមាជិកអង្គភាពយោធា ឬរដ្ឋបាលទទួលបន្ទុកនៃជំរំប្រមូលផ្តុំទាំងនេះ ដែលពួកគេបានអនុវត្តស្របតាមផែនការមួយដែល "មានការពិគ្រោះគ្នា" ហើយដែលពួកនេះ "ដឹងអំពីចរិតនៃប្រព័ន្ធនេះ" និងមាន "ចេតនាចូលរួមចំណែកក្នុងគោលបំណងរួម ដោយពិគ្រោះគ្នាដើម្បីធ្វើបាបអ្នកទោស"[387]។

៣. ដែលគេហៅថាទម្រង់ "ពង្រីក" (ទម្រង់ទីបី) គឺជាទម្រង់ដែលទាក់ទងទៅនឹង "កិច្ចការដែលមានគោលបំណងរួម ដែលក្នុងកិច្ចការនេះ ចារីម្នាក់ក្នុងចំណោមចារីនានា ប្រព្រឹត្តអំពើមួយ ដែលទោះបីវាមិនមែនមកពីគោលបំណងរួមក៏ដោយ ក៏វាជាផលវិបាកតាមធម្មជាតិ និងអាចប្រមើលឃើញជាមុនបាននៃការប្រព្រឹត្តអំពើនេះ[388]។

---

[386] សាលដីកា ០០២/០១ កថាខណ្ឌ ៧៧៣។ សាលដីកា Tadić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៩៦។

[387] សាលដីកា ០០២/០១ កថាខណ្ឌ ៧៧៣។ សាលដីកា Tadić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២០២-២០៣។

[388] សាលដីកា ០០២/០១ កថាខណ្ឌ ៧៧៣។ សាលដីកា Tadić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២០៤។

៤៣៤. អង្គជំនុំជម្រះតុលាការកំពូលបានបន្ថែមថា ធាតុផ្សំនៃសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមត្រូវបានរក្សា និងបញ្ជាក់ដោយយុត្តិសាស្ត្រចុងក្រោយនេះ ជាពិសេសដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងរឿងក្តី *Rwamaquba* និង *Brdanin* ដែលផ្អែកលើយុត្តិសាស្ត្រសម័យក្រោយសង្គ្រាមលោកលើកទីពីរ។ អង្គជំនុំជម្រះតុលាការកំពូលបានរំឭកថា អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក បានសន្និដ្ឋានស្របតាមលក្ខន្តិកៈ Nuremberg ច្បាប់លេខ ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យ យុត្តិសាស្ត្រអន្តរជាតិ និងអត្ថបទគតិយុត្តទាំងឡាយ ដែលមានអានុភាពច្បាប់ ថាសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ និងសហឧក្រិដ្ឋកម្មរួមទម្រង់ទីពីរ ត្រូវបានទទួលស្គាល់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅសម័យអង្គហេតុដែលជំនុំជម្រះដោយ អ.វ.ត.ក ហើយវាខុសពីសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ដែលមិនអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក[389]។

៤៣៥. អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា កន្សោមពាក្យ "ការចូលរួមដោយមានប្រសិទ្ធិភាពនៅក្នុងការសម្រេចផែនការរួម" ដែលបង្កើតឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ឆ្លុះបញ្ចាំងអំពីខ្លឹមសារនៃយុត្តិសាស្ត្រក្រោយសង្គ្រាម ដែលស្របតាមយុត្តិសាស្ត្រនេះ បុគ្គលម្នាក់អាចមានទំនួលខុសត្រូវព្រហ្មទណ្ឌ កាលណាបុគ្គលរូបនេះចូលរួមចំណែកក្នុងការសម្រេចផែនការឧក្រិដ្ឋរួម ទោះបីជាការចូលរួមនេះពុំមានទម្រង់ជាធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្ម និងទោះបីជាការចូលរួមនេះនៅឆ្ងាយពីការប្រព្រឹត្តឧក្រិដ្ឋកម្មផ្ទាល់ក៏ដោយ[390]។ អាស្រ័យហេតុដូចនេះ អង្គជំនុំជម្រះតុលាការកំពូលពិនិត្យឧទាហរណ៍រឿងក្តីមួយចំនួន ដែលនៅក្នុងករណីទាំងនេះ ជនជាប់ចោទត្រូវបានប្រកាសថាមានពិរុទ្ធភាពពីបទបានចូលរួមចំណែកក្នុងផែនការឧក្រិដ្ឋរួម ក្នុងខណៈដែលអ្នកដទៃទៀតបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយមានធាតុផ្សំសត្យានុម័តិ ដូចជារឿងក្តី *Almelo* រឿងក្តី *Schonfeld* រឿងក្តីរបស់គ្រួសារ *Einsatzgruppen* រឿងក្តី *RuSHA* និងរឿងក្តី *Justice*[391]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានលើកឡើងជាពិសេសអំពីមាត្រា II-2 ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ដែលតាមមាត្រានេះ បុគ្គលណាម្នាក់បានប្រព្រឹត្តឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលមានរៀបរាប់៖

---

[389] សាលដីកា ០០២/០១ កថាខណ្ឌ ៧៧៤ ដោយយោងទៅសេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ **ឯកសារ D97/15/9**។

[390] សាលដីកា ០០២/០១ កថាខណ្ឌ ៧៧៩។

[391] សាលដីកា ០០២/០១ កថាខណ្ឌ ៧៨០-៧៨៧។

"នៅពេលបុគ្គលនោះ ជា (ក) ចារីផ្ទាល់ ឬ (ខ)ជាអ្នកសមគំនិតចំពោះការប្រព្រឹត្តបទឧក្រិដ្ឋណាមួយនោះ ឬ បានបញ្ជា ឬជំរុញឱ្យប្រព្រឹត្ត ឬ (គ) ចូលរួមដោយចេតនានៅក្នុងការប្រព្រឹត្ត ឬ (ឃ) ជាប់ពាក់ព័ន្ធទៅនឹងផែនការ ឬការរៀបចំដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តនោះ (...)"[392]។

៤៣៦. បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួម ដោយប្រកាសថា ផែនការឧក្រិដ្ឋរួមជាចំណុចស្នូលនៃទម្រង់ទំនួលខុសត្រូវនេះ ដូចបានបញ្ជាក់ដោយយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និងដោយការវិភាគទៅលើយុត្តិសាស្ត្រក្រោយសង្គ្រាម។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានរំឭកថា៖

"នៅក្នុង*រឿងក្តី* Tadić អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានតម្រូវឱ្យមាន"អត្ថិភាពនៃគោលបំណង ឬផែនការរួមដែល*ជាបទឧក្រិដ្ឋ ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ* ដែលមានចែងនៅក្នុងលក្ខន្តិកៈ" (មានគូសបន្ទាត់ពីក្រោមក្នុងច្បាប់ដើម)[393]។

៤៣៧. អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា នៅក្នុងរឿងក្តីមួយចំនួននៃតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សហឧក្រិដ្ឋកម្មរួមជាផលវិបាកនៃផែនការរួមដែលមានគោលដៅចុងក្រោយមិនឧក្រិដ្ឋទេ ក៏ប៉ុន្តែដើម្បីសម្រេចគោលដៅទាំងនេះ វាតម្រូវឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចជារឿងក្តី *Martic* រឿងក្តី *Krajisnik* និង *Prlic* [394]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានគូសបញ្ជាក់ផងដែរថា ក្នុងខ្លឹមសារដូចគ្នា ចៅក្រមនៃសាលាឧទ្ធរណ៍របស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន បានប្រកាសនៅក្នុងរឿងក្តី Brima ថា៖

---

[392] សាលដីកា ០០២/០១ កថាខណ្ឌ ៧៨៨ ដែលបានដកស្រង់ច្បាប់ទី ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យនៃសម្ព័ន្ធមិត្ត ចុះ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៤៥។

[393] សាលដីកា ០០២/០១ កថាខណ្ឌ ៧៨៩, សាលដីកា Tadić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៧-ii ៖ « អត្ថិភាពនៃគម្រោងមួយ គោលបំណង ឬ គោលដៅរួមគ្នាដែលនាំឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានចែងក្នុងលក្ខន្តិកៈ ឬដែលនាំឱ្យមានការប្រព្រឹត្តបទល្មើស »។

[394] សាលដីកា ០០២/០១ កថាខណ្ឌ ៧៨៩ និង កំណត់សម្គាល់ជើងទំព័រ ២០៦៦ និង ២០៦៩។

“តាមការពិនិត្យលើយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ គេអាចយល់បានថា គោលបំណងឧក្រិដ្ឋដែលជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម មិនត្រឹមតែអាចសន្និដ្ឋានចេញពីគោលដៅចុងក្រោយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចេញពីមធ្យោបាយនានាដែលប្រើប្រាស់ដើម្បីសម្រេចគោលដៅនោះផងដែរ។ គោលដៅ និងមធ្យោបាយដើម្បីសម្រេចបានគោលដៅនេះ អាចចាត់ទុកជាការរៀបចំ ឬផែនការរួម”[395]។

៤៣៨. បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យបញ្ហាសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី។ ជាបឋម អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ហើយដែលអង្គជំនុំជម្រះសាលាដំបូងជួយគាំទ្របន្ថែម។ នៅក្នុងសេចក្ដីសម្រេចនេះ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា សេចក្ដីសម្រេចនៅសម័យក្រោយសង្គ្រាមដែលចៅក្រមយកមកធ្វើជាបង្អែកនៅក្នុងសាលាដីកា Tadic មិនមែនជា “បង្អែករឹងមាំគ្រប់គ្រាន់” ដើម្បីពិចារណាថា សហឧក្រិដ្ឋកម្មរួមទម្រង់ទីបីមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[396] នាសម័យនោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យលើរឿងក្ដីជាច្រើនទៀត ដែលកើតឡើងនៅក្រោយសម័យសង្គ្រាម ដែលសហព្រះរាជអាជ្ញាបានយោង[397] រឿងក្ដីអ៊ីតាលី[398] និងរឿងក្ដីសម័យក្រោយសង្គ្រាមចំនួនដប់បីផ្សេងទៀត[399] ដែលតុលាការកំពូលយល់ឃើញថា រឿងក្ដីទាំងនេះក៏មិនអាចអនុញ្ញាតឱ្យទាញការសន្និដ្ឋានថាមានអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅសម័យនោះដែរ។

៤៣៩. ឆ្លើយតបទៅនឹងអំណះអំណាងរបស់សហព្រះរាជអាជ្ញា ដែលថាការពិនិត្យច្បាប់ព្រហ្មទណ្ឌជាតិអាចអនុញ្ញាតឱ្យបង្ហាញអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបីនេះ តុលាការកំពូលបានប្រកាសថារឿងក្ដី និងច្បាប់ជាតិទាំងឡាយណាដែលមិនមានធាតុផ្សំអន្តរជាតិបន្តិចណាសោះ មិនអាចត្រូវបានចាត់ទុកថាជាការអនុវត្តរបស់រដ្ឋនានាដែលបង្កើតឱ្យមានការកំណត់វិធានមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបានឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានបន្ថែមទៀតថា ឧទាហរណ៍ដែលលើកឡើងដោយសហព្រះរាជអាជ្ញាក៏មិនអាចអនុញ្ញាតឱ្យបង្ហាញអំពីអត្ថិភាពនៃគោលការណ៍ទូទៅមួយនៃច្បាប់ដែលស្របតាមគោលការណ៍នេះ អំពើរបស់អ្នកដទៃអាចជាទំនួលខុសត្រូវរបស់

[395] សាលដីកា ០០២/០១ កថាខណ្ឌ ៧៨៩ និង កំណត់សម្គាល់ជើងទំព័រ ២០៦៧។

[396] សាលដីកា ០០២/០១ កថាខណ្ឌ ៧៩១។

[397] សាលដីកា ០០២/០១ កថាខណ្ឌ ៧៩២-៧៩៤។

[398] សាលដីកា ០០២/០១ កថាខណ្ឌ ៧៩៥-៧៩៨។

[399] សាលដីកា ០០២/០១ កថាខណ្ឌ ៧៩៩-៨០៤ និង កំណត់សម្គាល់ជើងទំព័រ ២១០៧។

ជនជាប់ចោទម្នាក់ដែលមិនបានប្រព្រឹត្តដោយខ្លួនឯងនូវធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្ម ដែលមិនមែនជាផ្នែកនៃផែនការរួម។[400]

៤៤០. ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ពុំមានអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបីក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅសម័យអង្គហេតុ[401] មុននឹងកំណត់លក្ខខ័ណ្ឌតម្រូវដែលអាចបង្កើតបានជាឧក្រិដ្ឋកម្មដែលជាផ្នែកនៃផែនការរួម។

## ២ .ការបង្កើតសហឧក្រិដ្ឋកម្មរួមក្នុងការ "សហឧក្រិដ្ឋកម្មរួម ទម្រង់ទីមួយ" របស់អង្គជំនុំជម្រះតុលាការកំពូល

៤៤១. បន្ទាប់ពីបានធ្វើការបរិយាយយ៉ាងវែងដែលយើងបានសង្ខេបខាងលើនេះ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់និយមន័យផែនការរួម។ អង្គជំនុំជម្រះតុលាការកំពូលបានរំឭកថា ចាប់តាំងពីរឿងក្តី Tadic យុត្តិសាស្ត្រតម្រូវថាផែនការរួម "គឺជា" ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬការ "ធ្វើឱ្យមាន" ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ("amounts to" ឬ "involves")[402]។

៤៤២. យោងតាមអង្គជំនុំជម្រះតុលាការកំពូល ផែនការរួម "គឺជា "amounts to" ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ កាលណា "ការប្រព្រឹត្តបទឧក្រិដ្ឋនោះ គឺជា ឬស្ថិតក្នុងចំណោមគោលដៅចម្បងនៃគោលបំណងរួម"[403]។

៤៤៣. អង្គជំនុំជម្រះតុលាការកំពូលបានចង្អុលបង្ហាញថា ករណីនេះកើតមានឡើងជាអាទិ៍ កាលណាផែនការរួមគឺមានបំណងសម្លាប់ក្រុមគូបដិបក្សនយោបាយ។ ក្នុងសេណារីយោនេះ វាគ្មានការ

[400] សាលដីកា ០០២/០១ កថាខណ្ឌ ៨០៥-៨០៦។

[401] សាលដីកា ០០២/០១ កថាខណ្ឌ ៨០៧។

[402] សាលដីកា ០០២/០១ កថាខណ្ឌ ៨០៧។

[403] សាលដីកា ០០២/០១ កថាខណ្ឌ ៨០៧។

មន្ទិលសង្ស័យអ្វីទេដែលថាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ធ្វើសកម្មភាពដោយមានចេតនាផ្ទាល់ក្នុងការសម្លាប់[404]។

៤៤៤. យោងតាមអង្គជំនុំជម្រះតុលាការកំពូលដដែល វាមិនមែនជាករណីដូចគ្នាទេ កាលណាផែនការរួម "តម្រូវឱ្យមាន" ("involves") ការប្រព្រឹត្តិឧក្រិដ្ឋកម្ម។

> "ផ្ទុយទៅវិញ គោលបំណងរួមមានការ"ជាប់ពាក់ព័ន្ធ"ទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ ប្រសិនបើបទឧក្រិដ្ឋនោះគឺជាមធ្យោបាយដើម្បីសម្រេចគោលដៅចុងក្រោយមួយ[405] (ដែលគោលដៅនេះអាចពុំមែនជាបទល្មើស)។ នៅក្នុងកាលៈទេសៈបែបនេះ ពុំចាំបាច់ថា អ្នកដែលយល់ស្របជាមួយគោលបំណងរួមជាក់ស្តែងត្រូវតែមានចេតនាចង់ឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋនោះទេ ដរាបណាអ្នកទាំងនោះបានទទួលស្គាល់ថា បទឧក្រិដ្ឋនឹងត្រូវប្រព្រឹត្តដើម្បីសម្រេចគោលបំណងចុងក្រោយ។ នេះអាចរួមបញ្ចូលបទឧក្រិដ្ឋដែលត្រូវបានគិតទុកជាមុនធ្វើជាមធ្យោបាយក្នុងការសម្រេចគោលបំណងរួមណាមួយនោះ បើទោះបីជាការប្រព្រឹត្តពុំមានលក្ខណៈច្បាស់លាស់ក៏ដោយ" (មានគូសបន្ទាត់ពីក្រោមក្នុងច្បាប់ដើម)[406]។

៤៤៥. អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ឧទាហរណ៍អំពីក្រុមមួយ ដែលស្រុះស្រួលគ្នាក្នុងការវាយទម្លុះជញ្ជាំងផ្ទះមួយ ដើម្បីចូលទៅលួចទ្រព្យសម្បត្តិនៅក្នុងផ្ទះនោះ និងក្នុងករណីចាំបាច់ ក្នុងការប្រើកម្លាំងដែលអាចបង្កឱ្យស្លាប់ ដើម្បីឈ្នះលើការតតាំងដែលខ្លួនអាចជួបប្រទះ។ យោងតាមអង្គជំនុំជម្រះតុលាការកំពូល វា"មិនគួរឱ្យជឿជាក់បានទេ"ក្នុងការសន្និដ្ឋានថា មនុស្សឃាតជាយថាហេតុមិនមែនជាផ្នែកនៃផែនការរួម ដោយសំអាងហេតុថា មនុស្សឃាតនេះមិនប្រាកដថានឹងត្រូវបានប្រព្រឹត្តក្នុងពេលវាយទម្លុះចូលក្នុងផ្ទះគេ។ ក្នុងសេណារីយោបែបនេះ ឧក្រិដ្ឋកម្មមនុស្សឃាតគឺជា "ធាតុផ្សំ" មួយ នៃផែនការដែលត្រូវបានបង្កើតឡើង ទោះបីជាសមាជិកនៃក្រុមនេះមិនដឹងថា មនុស្សឃាតនឹងត្រូវបានប្រព្រឹត្តជាក់ស្តែងក៏ដោយ។[407]

---

[404] សាលដីកា ០០២/០១ កថាខណ្ឌ ៨០៧។

[405] សាលដីកា Brima *(SCSL)* កថាខណ្ឌ ៨០ *("the Appeals Chamber concludes that the requirement that the common plan, design or purpose of a joint criminal enterprise is inherently criminal means that it must either have as its objective a crime within the Statute, or contemplate crimes within the Statute as the means of achieving its objective")*។

[406] សាលដីកា ០០២/០១ កថាខណ្ឌ ៨០៨ (ឯកសារយោងរួមមានកំណត់សម្គាល់ជើងទំព័រ ២១៣២ នៃសាលដីកា)។

[407] សាលដីកា ០០២/០១ កថាខណ្ឌ ៨០៨។

៤៤៦. ចំពោះអង្គជំនុំជម្រះតុលាការកំពូល ប្រសិនបើការសម្រេចគោលបំណងនៃផែនការរួម អាចបង្កឱ្យមានឧក្រិដ្ឋកម្ម ហើយទោះជាយ៉ាងនេះក្តីគេត្រូវតែសម្រេចគោលបំណងនេះ ឧក្រិដ្ឋកម្មទាំងនេះជាផ្នែកនៃផែនការរួម ពីព្រោះទោះបីជា ពុំមានចេតនាផ្ទាល់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនេះក៏ដោយ ក៏ឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានគ្រោងមុនជាស្រេចដោយផែនការនេះ៖

> “បញ្ហា ថាតើបទឧក្រិដ្ឋមួយមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ដែរ ឬយ៉ាងណានោះ ជាចម្បង គឺជាបញ្ហាអង្គហេតុ ដោយសារពុំមានការព្រមព្រៀងច្បាស់លាស់ ទើបតម្រូវឱ្យធ្វើការវាយតម្លៃដោយពិចារណាលើរាល់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងគោលដៅទូទៅនៃគោលបំណងរួម និងភវនីយភាពដែលថាគោលបំណងរួមអាចសម្រេចបាន លុះត្រាតែមានការប្រព្រឹត្តបទឧក្រិដ្ឋ។ អ្វីដែលត្រូវកត់សម្គាល់គឺថា គោលបំណងរួមអាចរួមបញ្ចូលបទឧក្រិដ្ឋដែលចារីពុំមានចេតនាប្រព្រឹត្ត ឬពុំដឹងច្បាស់លាស់ ដោយសារនេះជាការគ្រប់គ្រាន់សម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋមួយចំនួនដែលចារីបានប្រព្រឹត្តដោយ *ចេតនាប្រយោល* បើទោះបីជាចារីពុំចង់ឱ្យមានការប្រព្រឹត្ត និងពុំដឹងច្បាស់លាស់ថា ការប្រព្រឹត្តនឹងអាចកើតមានក៏ដោយ”[408]។

៤៤៧. អង្គជំនុំជម្រះតុលាការកំពូលបានព្យាយាមគូសបញ្ជាក់ថែមទៀតថា នៅក្នុងសេណារីយោដែលខ្លួនបានរៀបរាប់៖

> “មានការយល់ស្របគ្នាជាផ្លូងមួយបើទោះបីជាក់ច្បាស់ក្តី ឬប្រយោលក្តី ទាក់ទងទៅនឹងបទឧក្រិដ្ឋរបស់អ្នកដែលបានយល់ស្របជាមួយគោលបំណងរួម។ ដូច្នេះ សមាជិកនៃសហឧក្រិដ្ឋកម្មរួមត្រូវទទួលយកការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងជាគោលដៅ ទាំងជាផលវិបាកដែលជៀសមិនរួចនៃគោលបំណងបឋម ឬទាំងគ្មានការអើពើពីយថាហេតុដែលអាចកើតឡើង។ ទាក់ទងទៅនឹងអ្នកដែលយល់ស្របជាមួយនឹងគោលបំណងរួម និងពុំត្រូវបានរំពឹងថា ការប្រព្រឹត្តអំពើ*សត្យានុមតិ*នៃបទឧក្រិដ្ឋផ្ទាល់ ប៉ុន្តែបានផ្អែកលើអ្នកដទៃក្នុងការធ្វើដូច្នោះ នេះអាចត្រូវបានបកស្រាយថា ជាទម្រង់នៃការប្រគល់អំណាចឱ្យចារីផ្ទាល់ក្នុងការសម្រេចទាក់ទងទៅនឹងការអនុវត្តចុងក្រោយនៃអំពើ*សត្យានុមតិ* ដែលនេះដូចគ្នាទៅនឹងគោលគំនិតស្តីពី*ចេតនាប្រយោល*។ ផ្ទុយទៅវិញ ក្នុងករណីដែលបទឧក្រិដ្ឋពុំមានរួមបញ្ចូលនៅក្នុងគោលបំណងរួមដូចការបញ្ជាក់ខាងលើនេះ ការប្រព្រឹត្តបទឧក្រិដ្ឋនេះ គឺជាការសម្រេចដោយស្វ័យភាពរបស់ចារីផ្ទាល់ ហើយពុំមានមូលដ្ឋានសម្រាប់ការដាក់ឱ្យអ្នកដទៃទទួលខុសត្រូវឡើយ”[409]។

---

[408] សាលដីកា ០០២/០១ កថាខណ្ឌ ៨០៨។

[409] សាលដីកា ០០២/០១ កថាខណ្ឌ ៨០៩។

៤៤៨. លើសពីនេះ នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យច្បាប់ដែលអាចអនុវត្តបានចំពោះល័ក្ខខ័ណ្ឌតម្រូវនៃចេតនា។ ដោយផ្អែកលើសាលដីកានៃរឿងក្តី *Kvocka* នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អង្គជំនុំជម្រះតុលាការកំពូលបានរំឭកថា ដើម្បីបំពេញល័ក្ខខ័ណ្ឌតម្រូវ ជនជាប់ចោទ និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមត្រូវតែ "មានចេតនាសម្រេចគោលបំណងរួម" ដូចគ្នា។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា នេះគ្រាន់តែជាសេចក្តីប្រកាសទូទៅដែលត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ ដោយចងចាំក្នុងចិត្តនូវឧក្រិដ្ឋកម្មក្នុងករណីនេះ និងកាលៈទេសៈនៃរឿងក្តី។[410] យោងតាមអង្គជំនុំជម្រះតុលាការកំពូល៖

> "អាស្រ័យទៅលើបទឧក្រិដ្ឋ និងអង្គហេតុនៃរឿង និងអាចជាការសមហេតុផលផងដែរក្នុងការពិចារណាលើបញ្ហា ថាតើជនជាប់ចោទបានដឹងអំពីភាវនីយភាពច្បាស់លាស់ដែលថា បទឧក្រិដ្ឋនឹងត្រូវប្រព្រឹត្តឡើង ដែរ ឬយ៉ាងណា"[411]។

៤៤៩. វិនិច្ឆ័យកិច្ចទាំងអស់របស់អង្គជំនុំជម្រះតុលាការកំពូល សុទ្ធតែខុសទាំងស្រុង។ ការទទួលយកវិនិច្ឆ័យកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូល គឺវាស្មើនឹងការយល់ឃើញថាមានសហឧក្រិដ្ឋកម្មរួមមួយទម្រង់ដែលកើតឡើងពីការបូកបញ្ចូលគ្នារវាងធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ និងធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី បូករួមជាមួយធាតុផ្សំអត្តនោម័ត ដែលធាតុផ្សំទាំងអស់នេះប្រែប្រួលតាមអង្គហេតុ និងកាលៈទេសៈ។ ប្រសិនបើវិនិច្ឆ័យកិច្ចហួសពីការពិតនិយមនេះ គោរពតាមតក្កវិជ្ជាបក្សពួកនិយម និងផ្តន្ទាទោសនិយម វិនិច្ឆ័យកិច្ចនេះគ្មានមូលដ្ឋានអ្វីទាល់តែសោះ។

៤៥០. ក្នុងករណីដែលអង្គជំនុំជម្រះតុលាការកំពូលមិនផ្អែកលើប្រភពណាមួយ សម្រាប់គាំទ្រការអះអាងរបស់ខ្លួន វាមិនអាចទៅរួចទេក្នុងការយល់ឃើញថា និយមន័យនៃសហឧក្រិដ្ឋកម្មរួមដែលអង្គជំនុំជម្រះតុលាការកំពូលបានកំណត់ មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅសម័យអង្គហេតុ នៅចំពោះមុខ អ.វ.ត.ក។ និយមន័យតែឯកឯងមួយនេះ មិនអាចបង្កើតជាការអនុវត្តមួយរបស់រដ្ឋនានា ដែលត្រូវបានទទួលយកជាច្បាប់នោះឡើយ ទោះជាក្នុងករណីណាក៏ដោយ។

---

[410] សាលដីកា ០០២/០១ កថាខណ្ឌ ១០៥៤ និង កំណត់សម្គាល់ជើងទំព័រ ២៨៤១។

[411] សាលដីកា ០០២/០១ កថាខណ្ឌ ១០៥៥។

៤៥១. លើសពីនេះទៅទៀត គ្មានអ្វីនៅក្នុងប្រភពដែលតុលាការកំពូលបានសិក្សាវិភាគជាមុន អាច អនុញ្ញាតឱ្យគាំទ្រនិយមន័យបែបនេះបានទេ។

### ៣ . នត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមកូនកាត់ ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ

៤៥២. ដើម្បីគេចជៀសពីបញ្ហានៃការមិនអាចអនុវត្តបាននៃសហឧក្រិដ្ឋរួមទម្រង់ទីបី ចំពោះមុខ អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូលបានអនុវត្តវិធីថ្មីនភ្នែក ដោយបញ្ចូលឧក្រិដ្ឋកម្មដែលអាចគ្រោងទុកជាមុនបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ទៅក្នុងផែនការរួម។ ក៏ប៉ុន្តែតាមការពិត គឺដោយសារតែឧក្រិដ្ឋកម្មទាំងនេះអាចគ្រោងទុកជាមុនបាននឹងហើយ ទើបឧក្រិដ្ឋកម្មទាំងនេះមិនត្រូវបានបញ្ចូលទៅក្នុងផែនការរួម។ យោងតាមប្រភពដែលអង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យពិចារណា គ្មានអ្វីអាចឱ្យអះអាងផ្ទុយពីនេះទេ។

### ក . សាលដីកា *Tadic* និងយុត្តិសាស្ត្រក្រោយពេលសង្គ្រាម

៤៥៣. ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានរំឭក ការវិភាគប្រភពផ្សេងៗនៃសម័យក្រោយសង្គ្រាម អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បែងចែកសហឧក្រិដ្ឋកម្មរួមជាបីប្រភេទនៅក្នុងសាលដីកានៃរឿងក្ដី *Tadic* ហើយយុត្តិសាស្ត្រនេះត្រូវបានបញ្ជាក់គាំទ្រនាពេលបន្តបន្ទាប់មក។[412] យោងតាមអង្គជំនុំជម្រះតុលាការតុលាការកំពូល ទម្រង់ទាំងបីនៃសហឧក្រិដ្ឋកម្មរួមមានធាតុផ្សំសត្យានុម័តដូចគ្នា ប៉ុន្តែធាតុផ្សំអត្តនោម័តខុសគ្នា។

៤៥៤. ធាតុផ្សំសត្យានុម័តិរួមនៃទម្រង់ទាំង៣នៃសហឧក្រិដ្ឋកម្មរួម គឺពហុវចនៈនៃចារី អត្ថិភាពនៃផែនការរួមដែលជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬការធ្វើឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម ការចូលរួមរបស់ជនជាប់

[412] សាលដីកា ០០២/០១ កថាខណ្ឌ ៧៧៣-៧៧៤។

ចោទនៅក្នុងផែនការនេះ តាមរយៈការជួយជ្រោមជ្រែង ឬតាមរយៈការចូលរួមចំណែកដើម្បីសម្រេចផែនការនេះ[413]។

៤៥៥. ដោយឡែក ធាតុផ្សំអត្តនោម័តអាស្រ័យទៅតាមប្រភេទនៃសហឧក្រិដ្ឋកម្មរួម៖

- សហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ: មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មជាក់លាក់ណាមួយពីព្រោះសហចារីទាំងអស់មានចេតនានេះ (ចេតនាឧក្រិដ្ឋផ្ទាល់)

- សហឧក្រិដ្ឋកម្មរួមទម្រង់ទីពីរ: ការដឹងឮជាបុគ្គលអំពីប្រព័ន្ធធ្វើបាប និងចេតនាចូលរួមចំណែកក្នុងប្រព័ន្ធនេះ ដែលនៅក្នុងប្រព័ន្ធនេះ មានការពិភាក្សាគ្នាអំពីការធ្វើបាប (ចេតនាឧក្រិដ្ឋផ្ទាល់)

- សហឧក្រិដ្ឋកម្មរួមទម្រង់ទីបី: ចេតនាចូលរួម និងចូលរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួម ឬទោះជាយ៉ាងណាក្តី ចូលរួមចំណែកក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មជាក្រុម។ លើសពីនេះទៅទៀត "ទំនួលខុសត្រូវចំពោះឧក្រិដ្ឋកម្មមួយផ្សេងទៀត ក្រៅពីឧក្រិដ្ឋកម្មដែលបានគ្រោងទុកនៅក្នុងផែនការរួម អាចអនុវត្តបានតែក្នុងករណី ក្នុងកាលៈទេសៈនៃករណីជាក់លាក់នេះ i) *អាចគ្រោងទុកជាមុនបាន* ថាឧក្រិដ្ឋកម្មបែបនេះនឹងអាចត្រូវបានប្រព្រឹត្តដោយសមាជិកណាម្នាក់នៃក្រុម ii) ជនជាប់ចោទ*មានចេតនា*ប្រថុយប្រថាន" (ចេតនាឧក្រិដ្ឋដោយប្រយោល[414]) ។

៤៥៦. ដូច្នេះ គ្រប់ករណីទាំងអស់នៃសហឧក្រិដ្ឋកម្មរួម ផែនការរួមគឺសំដៅប្រព្រឹត្តឧក្រិដ្ឋកម្ម ឬធ្វើឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ប៉ុន្តែ មានតែក្នុងក្របខ័ណ្ឌនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបីទេ ដែលមានទំនួលខុសត្រូវពីបទប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងទៀតក្រៅពីឧក្រិដ្ឋកម្មដែលបានគ្រោងទុកនៅក្នុងផែនការរួម គឺបានន័យថាជាឧក្រិដ្ឋកម្មដែលអាចប្រមើលឃើញជាមុនបាន ប៉ុន្តែជនជាប់ចោទមានចេតនាប្រថុយនឹងផលវិបាកនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មនេះ ដើម្បីសម្រេចផែនការរួម។

---

[413] សាលដីកា Tadić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៧។

[414] សាលដីកា Tadić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៨ (មានគូសបន្ទាត់ពីក្រោមក្នុងឯកសារដើម)។

៤៥៧. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី បានឱ្យឧទាហរណ៍មួយចំនួនសម្រាប់ប្រភេទនៃសហឧក្រិដ្ឋកម្មរួម។ ឧទាហរណ៍សម្រាប់សហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ គឺជាករណីនៃផែនការមួយមានគោលបំណងសម្លាប់ ដែលនៅក្នុងផែនការនេះសហចារីនីមួយៗដើរតួនាទីខុសៗគ្នា ហើយមានចេតនាសម្លាប់។ ក្នុងករណីនេះ ទោះបីជាជនជាប់ចោទមិនបានប្រព្រឹត្តមនុស្សឃាតដោយខ្លួនឯងផ្ទាល់ក៏ដោយ ក៏ខ្លួននៅតែមានចេតនាសម្រេចលទ្ធផលនេះដែរ[415]។

៤៥៨. ឧទាហរណ៍ពីរនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបីពាក់ព័ន្ធនឹងរឿងក្តី "ដែលក្នុងរឿងក្តីនេះចារីម្នាក់ក្នុងចំណោមចារីទាំងអស់បានប្រព្រឹត្តអំពើមួយ ដែលមិននៅក្នុងគោលបំណងរួម ក៏ប៉ុន្តែ អំពើនេះជាផលវិបាកធម្មជាតិ និងអាចគ្រោងទុកជាមុនបាននៃការសម្រេចគោលបំណងរួមនេះ" មានដូចតទៅនេះ៖

> "ឧទាហរណ៍ វាអាចជាចេតនារួមនៃក្រុមមួយ ក្នុងការប្រើកម្លាំងបណ្តេញសមាជិកនៃក្រុមជាតិពន្ធុមួយចេញពីក្រុង ភូមិ ឬតំបន់របស់ខ្លួន (និយាយមួយបែបទៀត គឺមានចេតនាធ្វើការ "បោសសំអាតជាតិពន្ធុ"មួយ) ដែលផលវិបាកអាចមានមនុស្សម្នាក់ ឬច្រើនត្រូវបានសម្លាប់នៅក្នុងប្រតិបត្តិការនេះ។ ទោះបីបទមនុស្សឃាតអាចមិនត្រូវបានគ្រោងទុកច្បាស់លាស់ក្នុងក្របខ័ណ្ឌនៃគោលបំណងរួមក៏ដោយ ក៏គេអាចគ្រោងទុកជាមុនបានថា ការបណ្តេញជនស៊ីវិលដោយប្រើអាវុធគម្រាមកំហែង អាចគេចមិនផុតពីលទ្ធផលដែលមានជនស៊ីវិលម្នាក់ ឬច្រើនស្លាប់។ អ្នកចូលរួមក្នុងផែនការរួមទាំងអស់ អាចមានទំនួលខុសត្រូវព្រហ្មទណ្ឌ កាលណាហានិភ័យនៃការប្រព្រឹត្តិបទមនុស្សឃាត ជាផលវិបាកដែលអាចគ្រោងទុកជាមុននៃការសម្រេចគោលបំណងរួមនេះផង និងនៃការមិនប្រុងប្រយ័ត្ន និងព្រងើយកន្តើយរបស់ជនជាប់ចោទ ទៅលើហានិភ័យនេះផង។ ឧទាហរណ៍មួយទៀត គឺជាផែនការប្រើកម្លាំងបណ្តេញជនស៊ីវិលនៃក្រុមជាតិពន្ធុមួយ ដោយដុតផ្ទះសម្បែងរបស់ពួកគេ៖ ប្រសិនបើនៅក្នុងពេលប្រតិបត្តិការ អ្នកចូលរួមមួយចំនួនក្នុងផែនការនេះ សម្លាប់ជនស៊ីវិលដោយដុតផ្ទះសម្បែងរបស់ពួកគាត់ អ្នកចូលរួមក្នុងគម្រោងនេះទាំងអស់ សុទ្ធតែមានទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការស្លាប់នៃជនស៊ីវិលទាំងអស់នេះ ប្រសិនបើលទ្ធផលនេះអាចគ្រោងទុកជាមុនបាន"[416]។

---

[415] សាលដីកា Tadić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៩៦។

[416] សាលដីកា Tadić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២០៤។

៤៥៩. ក្នុងឧទាហរណ៍នៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ មនុស្សឃាតត្រូវបានគ្រោងទុកនៅក្នុងផែនការនេះ។ នៅក្នុងឧទាហរណ៍នៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី គឺជាការបណ្ដេញដោយប្រើអាវុធគម្រាមកំហែងដែលគ្រោងទុកជាមុននៅក្នុងផែនការ ដោយហេតុថាការស្លាប់របស់ជនស៊ីវិលគ្រាន់តែជាផលវិបាកធម្មជាតិ និងដែលអាចគ្រោងទុកជាមុនបាននៃការសម្រេចផែនការបណ្ដេញតែប៉ុណ្ណោះ។ ក្នុងឧទាហរណ៍ទីពីរនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី គឺជាការបណ្ដេញដោយដុតផ្ទះសម្បែង ដែលមានគ្រោងទុកជាមុននៅក្នុងផែនការ ប៉ុន្តែមិនមានការគ្រោងទុកអំពីការស្លាប់ជាយថាហេតុទេ ទោះបីជាការស្លាប់នេះជាផលវិបាកធម្មជាតិ និងដែលអាចគ្រោងទុកបានក៏ដោយ។

៤៦០. ដូច្នេះ ក្នុងឧទាហរណ៍ទាំងពីរចុងក្រោយនេះ ការស្លាប់នៃជនស៊ីវិលមិនមែនជាគោលបំណងនោះទេ ទោះបីជាការស្លាប់នេះអាចគ្រោងទុកជាមុនបាន និងទោះបីជាចារីព្រងើយកន្តើយនឹងហានិភ័យនេះក៏ដោយ ក៏ការស្លាប់ជនស៊ីវិលគ្រាន់តែជាផលវិបាកធម្មជាតិនៃការសម្រេចគោលបំណងបណ្ដេញមនុស្សចេញ ហើយវាមិនមែនជាមធ្យោបាយចាំបាច់សម្រាប់ការសម្រេចគោលបំណងនេះទេ។ និយាយមួយបែបទៀត ការស្លាប់មនុស្សដែលអាចគ្រោងទុកជាមុនបាន មិនមានគ្រោងទុកជាមុនក្នុងផែនការទេ។

៤៦១. ក្នុងឧទាហរណ៍អំពី "សហឧក្រិដ្ឋកម្មរួមចូលលួចទ្រព្យសម្បត្តិក្នុងផ្ទះគេ" របស់អង្គជំនុំជម្រះតុលាការកំពូល និយាយអំពីការចូលលួចទ្រព្យសម្បត្តិក្នុងផ្ទះគេដោយវាយទម្លុះជញ្ជាំង ដោយប្រើកម្លាំងដែលអាចធ្វើឱ្យមនុស្សស្លាប់បាន ក្នុងករណីមានការតតាំងជាយថាហេតុ។ ក្នុងករណីនេះ ការចូលលួចទ្រព្យសម្បត្តិគេ គឺជាគោលដៅ។ ទោះបីជាមានចេតនាប្រថុយក៏ដោយ ក៏មនុស្សឃាតជាយថាហេតុនេះ គ្រាន់តែជាផលវិបាកធម្មជាតិនៃការសម្រេចផែនការឧក្រិដ្ឋ។ មនុស្សឃាតជាយថាហេតុនេះ មិនមែនជាមធ្យោបាយចាំបាច់សម្រាប់សម្រេចផែនការនេះទេ។ ដោយហេតុថាមនុស្សឃាតជាយថាហេតុនេះមិនចាំបាច់ត្រូវបានប្រព្រឹត្ត ដើម្បីសម្រេចគោលបំណងនេះ (វាខុសពីការវាយទម្លុះជញ្ជាំង និងការចូលលួច) វាមិនមែនជាផ្នែកមួយនៃផែនការរួមទេ។

៤៦២. ក្នុងគ្រប់ករណីដែលទើបតែបានលើកឡើង អ្នកចូលរួមទាំងអស់សុទ្ធតែស្រុះស្រួលគ្នាដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្ម។ ឧក្រិដ្ឋកម្មទាំងនេះសុទ្ធតែមាននៅក្នុងផែនការរួម។ ដោយឡែក កាលណាអ្នកចូលរួម

ត្រូវរ៉ូវគ្នាដើម្បីប្រថុយនឹងការដែលឧក្រិដ្ឋកម្មមួយអាចត្រូវបានប្រព្រឹត្ត ជាលទ្ធផលនៃការសម្រេចផែនការរបស់ពួកគេ គឺមានតែហានិភ័យនេះតែប៉ុណ្ណោះដែលជាផ្នែកនៃផែនការនេះ ក្នុងខណៈដែលឧក្រិដ្ឋកម្ម ប្រសិនបើវាត្រូវបានប្រព្រឹត្តជាក់ស្តែងមែន វាមិនស្ថិតក្នុងក្របខ័ណ្ឌនៃគម្រោងនេះទេ។ ឧក្រិដ្ឋកម្មជាយថាហេតុ វាហួស ឬលៀនចេញពីផែនការរួម។ ដោយសារមូលហេតុនេះហើយបានជាគេហៅទម្រង់នៃទំនួលខុសត្រូវនេះថា "ជាទម្រង់ទំនួលខុសត្រូវពង្រីក"។

៤៦៣. លោក Antonio CASSESE ជាចៅក្រមសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadic* ដែលជាអ្នកមានគំនិតផ្តួចផ្តើមធ្វើការបែងចែកសហឧក្រិដ្ឋកម្មរួមជាបីប្រភេទ បានហៅសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយថាជា "ទំនួលខុសត្រូវ នៃគោលបំណងរួមមានចេតនា" និងសហឧក្រិដ្ឋកម្មរួមទម្រង់ទីបីថាជា "ទំនួលខុសត្រូវព្រហ្មទណ្ឌបន្ទាប់បន្សំដែលផ្អែកលើការគ្រោងទុកជាមុន និងចេតនាប្រថុយប្រថាន" [417]។

៤៦៤. ដូច្នេះ ត្រូវតែចាប់បង្ខំឱ្យទទួលទំនួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មដោយចេតនានៅក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ។ ក្នុងទម្រង់ទីបី ទំនួលខុសត្រូវនេះអាចត្រូវចាប់ឱ្យទទួលតែចំពោះឧក្រិដ្ឋកម្មដែលអាចគ្រោងទុកជាមុនបានតែប៉ុណ្ណោះ។

៤៦៥. ប្រភពនានានៅក្រោយពេលសង្គ្រាមដែលអង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យដោយផ្ទាល់មុននឹងផ្តល់និយមន័យនៃផែនការរួម បង្ហាញអំពីទំនួលខុសត្រូវយ៉ាងល្អតតខ្ចោះចំពោះឧក្រិដ្ឋកម្មរួមដែលអាចគ្រោងទុកមុនបាននៅក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ។ គ្មានប្រភពណាមួយក្នុងចំណោមប្រភពទាំងនេះដែលបង្ហាញថា ឧក្រិដ្ឋកម្មដែលអាចគ្រោងទុកជាមុនបានត្រូវបានចាត់ទុកថាជាផ្នែកនៃផែនការឧក្រិដ្ឋរួមទេ។

---

[417] ដកស្រង់ពីអនុស្សរណៈនៃអ្នកដែលមិនមែនជាភាគីនៃរឿងក្តីរបស់ Kai AMBOS ស្តីពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨**ឯកសារ D99/3/27** កំណត់សម្គាល់ជើងទំព័រ ៧។

៤៦៦. អង្គជំនុំជម្រះតុលាការកំពូលបានលើកពីបញ្ហានៃការអាចគ្រោងទុកជាមុនបាននេះតែក្នុងពេលដែលខ្លួនពិនិត្យ ពិចារណាដើម្បីកំណត់ថាតើនៅសម័យនោះ ជនជាប់ចោទអាចមានទំនួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម "ដែលពុំមាននៅក្នុងគោលបំណងរួម"...[418]។

៤៦៧. ផ្ទុយពីនេះ នៅក្នុងគ្រប់ប្រភពទាំងអស់ដែលបញ្ជាក់មូលហេតុនៃអត្ថិភាពរបស់សហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ (និងសហឧក្រិដ្ឋកម្មរួមទម្រង់ទីពីរ) នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនដែលមានលើកឡើងអំពីបញ្ហានៃការអាចគ្រោងទុកជាមុនបាន បញ្ហាលទ្ធភាព បញ្ហាភវនិយភាពនោះទេ។ ឧក្រិដ្ឋកម្មទាំងនេះដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀង សុទ្ធតែជាឧក្រិដ្ឋកម្មមានចេតនា។

៤៦៨. ជាក់ស្តែង នៅពេលដែលអង្គបុរេជំនុំជម្រះបានពិនិត្យប្រភពទាំងអស់ដែលមានដកស្រង់នៅក្នុងសាលដីកា *Tadic* ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ អង្គបុរេបានលើកឡើងថា រដ្ឋជាភាគីនៃលក្ខន្តិកៈរបស់តុលាការយោធាអន្តរជាតិ និងរបស់ច្បាប់លេខ ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យ បានទទួលស្គាល់ថា ៖

> "បុគ្គលទាំងឡាយក៏នឹងទទួលខុសត្រូវផងដែរ នៅពេលដែលពួកគេមានចេតនាចូលរួមក្នុងការបង្កើត ឬការអនុវត្តសហកម្ម ឬផែនការរួម ទាក់ទិនទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។ នេះបង្កើតបានជាការគាំទ្រដែលមិនអាចបដិសេធបានឡើយដល់ទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធ (JCE I & II) នៃការទទួលខុសត្រូវ JCE"[419]។

៤៦៩. បន្ទាប់មក អង្គបុរេជំនុំជម្រះបានពិនិត្យរឿងក្តីចំនួនប្រាំបីដែលមានរៀបរាប់នៅក្នុងសាលដីកា *Tadic* ដែលមានដូចជា (រឿងក្តី *Almelo SCHONFELD* និងរបស់គ្រួសារ *Einsatzgruppe* ដែលត្រូវបានពិនិត្យពិចារណាដោយអង្គជំនុំជម្រះតុលាការកំពូល) ដែលបង្ហាញថា ទាល់តែជនជាប់ចោទមាន "ចេតនា" ឱ្យឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត[420]។ អង្គបុរេជំនុំជម្រះបានពិនិត្យពិចារណាផងដែរលើរឿងក្តី*យុត្តិធម៌* និង RuSHA ដែលត្រូវបានជំនុំជម្រះស្របតាមច្បាប់លេខ ១០ នៃក្រុម

---

[418] សាលដីកា ០០២/០១ កថាខណ្ឌ ៧៩០ និងបន្ទាប់មកក្នុង កថាខណ្ឌ ៧៩១ ដល់ ៨០៤ (ជាពិសេស កថាខណ្ឌ ៧៩៣, ៧៩៥, ៧៩៦, ៧៩៨ និង ៨០០)។

[419] សេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៥៨។

[420] សេចក្តីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៦២។

ប្រឹក្សាត្រួតពិនិត្យ (រឿងក្ដីនេះក៏ត្រូវបានពិនិត្យដោយអង្គជំនុំជម្រះតុលាការកំពូលដែរ) ដែលនៅក្នុងរឿងក្ដីទាំងនេះ ឧក្រិដ្ឋកម្មដែលត្រូវបញ្ចូលទៅក្នុងផែនការ និងដែលចំពោះបទឧក្រិដ្ឋទាំងនេះ ជនជាប់ចោទត្រូវបានផ្ដន្ទាទោស សុទ្ធតែជាឧក្រិដ្ឋកម្មមានចេតនាយ៉ាងច្បាស់លាស់ ហើយមិនមែនជាឧក្រិដ្ឋកម្មដែលអាចគ្រោងទុកបានទាល់តែសោះ[421]។

៤៧០. ដូច្នេះ ចាប់តាំងពីក្រោយសង្គ្រាមមក ឧក្រិដ្ឋកម្មមានចេតនា គឺជាឧក្រិដ្ឋកម្មតែមួយគត់ដែលជាផ្នែកនៃផែនការឧក្រិដ្ឋរួម ក្នុងខណៈដែលឧក្រិដ្ឋកម្មដែលអាចគ្រោងទុកមុនបានមិនមែនជាផ្នែកមួយនៃផែនការឧក្រិដ្ឋរួម។

៤៧១. ការបែងចែកដែលលើកឡើងដោយអង្គជំនុំជម្រះតុលាការកំពូលរវាងផែនការដែល "មានបំណង" ប្រព្រឹត្តឧក្រិដ្ឋកម្ម និងផែនការដែល "តម្រូវឱ្យមាន" ការប្រព្រឹត្តិឧក្រិដ្ឋកម្ម មិនធ្វើឱ្យផ្លាស់ប្ដូរអ្វីទាល់តែសោះ។

៤៧២. ម្យ៉ាងទៀត នៅពេលអង្គជំនុំជម្រះតុលាការកំពូលប្រកាសថា "<u>យុត្តិសាស្ត្រចាប់តាំងពី*រឿងក្ដី* *Tadić*</u> មក តម្រូវថា គោលបំណងរួម "គឺជា" ឬ"ជាប់ពាក់ព័ន្ធ"ទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ"[422] អង្គជំនុំជម្រះតុលាការកំពូលមើលរំលងការដែលនៅក្នុងច្បាប់លេខ ១០ នៃក្រុមប្រឹក្សាគ្រប់គ្រង (ដែលខ្លួនបានដកស្រង់ទៀតផង) មានលើកឡើងរួចបាត់ទៅហើយអំពីបញ្ហាឧក្រិដ្ឋ "ដែលជាប់ពាក់ព័ន្ធនឹងផែនការ ឬក៏ការងារដែលតម្រូវឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម"[423]។

៤៧៣. ភាពខុសគ្នាតែមួយគត់រវាង "ពេលមុនយុត្តិសាស្ត្រ *Tadic*" និង"ពេលក្រោយយុត្តិសាស្ត្រ *Tadic*" គឺថាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ចាប់តាំងរឿងក្ដី *Tadic* បានកាត់ក្ដីមួយចំនួនទៀត ដែលនៅក្នុងរឿងក្ដីទាំងនេះ មធ្យោបាយឧក្រិដ្ឋត្រូវបានប្រើប្រាស់សម្រាប់ផែនការមិនឧក្រិដ្ឋ។ ក៏ប៉ុន្តែ ពុំមានរឿងក្ដីប្រភេទ

---

[421] សេចក្ដីសម្រេចនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៦៥-៦៨។

[422] សាលដីកា ០០២/០១ កថាខណ្ឌ ៨០៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[423] សាលដីកា ០០២/០១ កថាខណ្ឌ ៧៨៨ ដែលដកស្រង់ពី មាត្រា II-2 នៃច្បាប់លេខនៃ ក្រុមប្រឹក្សាត្រួតពិនិត្យ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

នេះណាមួយដែលបង្ហាញបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូល បានអនុវត្តសហឧក្រិដ្ឋកម្មរួមក្នុនកាត់ដែលបញ្ចូលឧក្រិដ្ឋកម្មដែលអាចគ្រោងទុកជាមុនបានក្នុងផែនការរួមឡើយ។

## ខ. <u>រឿងក្តីធាក់ទងនឹងគោលបំណងមិនឧក្រិដ្ឋ</u>

៤៧៤. មុននឹងចាប់ផ្តើមលេងសៀកដើម្បីបញ្ចូលចេតនាឧក្រិដ្ឋជាយថាហេតុនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ក្នុងសហឧក្រិដ្ឋរួមទម្រង់ទីមួយ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា "គោលបំណងរួមមានការ"ជាប់ពាក់ព័ន្ធ"ទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ ប្រសិនបើបទឧក្រិដ្ឋនោះ គឺជា*មធ្យោបាយ* ដើម្បីសម្រេចគោលដៅចុងក្រោយមួយ"[424]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានយោងទៅរឿងក្តី *Brinma* នៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ដែលពីមុនមកខ្លួនបានយោងទៅរឿងក្តីនេះដែរព្រមទាំងនឹងរឿងក្តី *Martic Karjisnik* និង *Prlic* នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។[425] គ្មានរឿងក្តីណាមួយក្នុងចំណោមរឿងក្តីទាំងនេះដែលគាំទ្រដល់ការបង្កើតរបស់អង្គជំនុំជម្រះតុលាការកំពូលទេ។

### .1<u>រឿងក្តី *Brima*</u>

៤៧៥. នៅក្នុងរឿងក្តី Brima អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ដីកាចោទប្រកាន់មានកំហុសដោយមូលហេតុនៃចរិតមិនឧក្រិដ្ឋនៃផែនការរួមនៃសហឧក្រិដ្ឋកម្មរួមដែលចោទប្រកាន់៖ *"ចាត់វិធានការចាំបាច់ដើម្បីទទួលបាន និងប្រតិបត្តិអំណាចនយោបាយ និងត្រួតត្រាទៅលើទឹកដីសៀរ៉ាលេអូន"*[426]។ សហសហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសន្និដ្ឋាននេះ។

៤៧៦. អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានប្រកាសថា៖

---

[424] សាលដីកា 00២/0១ កថាខណ្ឌ ៨0៨ (មានគូសបន្ទាត់ពីក្រោមក្នុងឯកសារដើម)។

[425] សាលដីកា 00២/0១ កថាខណ្ឌ ៨0៨ និង កំណត់សម្គាល់ជើងទំព័រ ២១៣២ ព្រមទាំង កថាខណ្ឌ ៧៨៩ និង កំណត់សម្គាល់ជើងទំព័រ ២0៦៦, ២0៦៧ និង ២0៦៩។

[426] សាលដីកា Brima (តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន) ចុះថ្ងៃទី 0៣ ខែ មីនា ឆ្នាំ ២00៨ កថាខណ្ឌ ៦៧។

*"គេអាចពិចារណាតាមទិដ្ឋភាពនៃយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលថា គោលបំណងឧក្រិដ្ឋកម្មដែលជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួមអាចដកស្រង់បាន មិនត្រឹមតែពីគោលដៅចុងក្រោយរបស់វាទេ តែក៏អាចដកស្រង់បានពីមធ្យោបាយដែលរៀបចំ ដើម្បីសម្រេចបានទូវគោលដៅនោះដែរ។ គោលដៅ និងមធ្យោបាយដើម្បីសម្រេចបានទូវគោលដៅបង្កើតជាគំរោងការ ឬផែនការរួម។"*[427]

*"លក្ខខណ្ឌតម្រូវដែលថា ផែនការ គំរោងការ ឬគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមគឺជាមធ្យោបាយឧក្រិដ្ឋដែលជាប់មកជាមួយដែលវាត្រូវមានគោលដៅជាបទឧក្រិដ្ឋនៅក្នុងច្បាប់ ឬត្រូវកំណត់ជាបទឧក្រិដ្ឋនៅក្នុងច្បាប់ពាក់ព័ន្ធនឹងមធ្យោបាយក្នុងការសម្រេចទៅតាមគោលដៅរបស់វា។"*[428]

៤៧៧. អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានពិនិត្យពិចារណាលើដីកាចោទប្រកាន់នេះ ហើយបានសន្និដ្ឋានថាដីកានេះមិនមានកំហុសទេ។[429] ក៏ប៉ុន្តែទន្ទឹមនឹងនោះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចទាំងមិនធ្វើការកែប្រែសេចក្តីសន្និដ្ឋានផ្នែកអង្គហេតុ ទាំងមិនបញ្ជូនរឿងក្តីនេះទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងវិញ ដោយមូលហេតុ "ពាក់ព័ន្ធនឹងផលប្រយោជន៍យុត្តិធម៌"[430]។

៤៧៨. យោងខ្លឹមសារនៃដីកាចោទប្រកាន់៖

*"បទល្មើសដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ រួមមានការសម្លាប់មនុស្សដោយខុសច្បាប់ ការចាប់ពង្រត់ ការងារដោយបង្ខំ អំពើហិង្សាលើរាងកាយ និងផ្លូវភេទ ការប្រើប្រាស់ទាហានជាកុមារ ការលួច និងដុតរចនាសម្ព័ន្ធស៊ីវិល គឺជាសកម្មភាពនៅក្នុងសហឧក្រិដ្ឋកម្មរួមផង ឬគឺជាផលវិបាកដែលអាចប្រមើលមើលដឹងជាមុនយ៉ាងសមហេតុសមផលនៃសហឧក្រិដ្ឋកម្មរួមផង។" (យើងគូសបន្ទាត់ពីក្រោម)។*[431]

៤៧៩. ត្រង់នេះ វាច្បាស់ណាស់ថាឧក្រិដ្ឋកម្មដែលអាចគ្រោងទុកជាមុនបាន ត្រូវបានចាត់ទុកថានៅក្រៅផែនការរួម។

---

[427] សាលដីកា Brima (តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន) ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ៧៦។

[428] សាលដីកា Brima (តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន) ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ៨០។

[429] សាលដីកា Brima (តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន) ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ៨១-៨៦។

[430] សាលដីកា Brima (តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន) ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ៨៧។

[431] សាលដីកា Brima (តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន) ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ៨១ ដែលដកស្រង់កថាខណ្ឌ ៣៤ នៃបទចោទប្រកាន់។

៤៨០. លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានផ្ដល់សុពលភាពដល់វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាដែលអះអាងអំពី *"ទម្រង់ជាមូលដ្ឋាន និងទម្រង់លាតសន្ធឹងនៃសហឧក្រិដ្ឋកម្មរួមតាមជម្រើសផ្សេងទៀត"*[432]។

2. **រឿងក្ដី *Martic***

៤៨១. នៅក្នុងរឿងក្ដី *Martic* មានការវិនិច្ឆ័យថា ប្រសិនបើគោលបំណងនយោបាយនៃអ្នកដឹកនាំស៊ែរប៊ីក្នុងការ "ភ្ជាប់បណ្ដាតំបន់ស៊ែរប៊ីរបស់ក្រូអាស៊ី និង BiH មកជាប្រទេសស៊ែរប៊ី ក្នុងបំណងបង្កើតទឹកដីមួយមានឯកភាពជាតិ" មិនមែនជាគោលបំណងរួមស្របតាមច្បាប់ដែលអនុវត្តចំពោះសហឧក្រិដ្ឋកម្មរួម "ចេតនាបង្រួបបង្រួមតំបន់ទាំងនេះតាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងលក្ខន្តិកៈ អាចជាការគ្រប់គ្រាន់ក្នុងការបំពេញល័ក្ខខ័ណ្ឌតម្រូវនៃគោលបំណងឧក្រិដ្ឋរួម"។[433]

៤៨២. ក្នុងរឿងក្ដីនេះដែលសហព្រះរាជអាជ្ញាបានចោទប្រកាន់ទៅជនជាប់ចោទ ថាបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ និងទម្រង់ទីបី[434] អង្គជំនុំជម្រះសាលដំបូងបានប្រកាសថា៖

> "យ៉ាងយូរបំផុតចាប់ពីខែសីហាឆ្នាំ១៩៩១ គោលបំណងនយោបាយដែលសំដៅផ្សារភ្ជាប់តំបន់ស៊ែរប៊ីនានានៅក្រូអាស៊ី និងនៅ BiH មកប្រទេសស៊ែរប៊ីក្នុងបំណងបង្កើតទឹកដីមានឯកភាពជាតិ ត្រូវបានសម្រេចដោយសារការវាយប្រហារជាទូទៅ និងជាប្រព័ន្ធទៅលើតំបន់ដែលភាគច្រើនមានជនជាតិក្រូអាត និងជនជាតិដទៃទៀតក្រៅពីជនជាតិស៊ែរប៊ីរស់នៅ និងត្រូវបានសម្រេចដោយសារតែអំពើហិង្សា និងបំភិតបំភ័យ [...] ការសម្រេចគោលបំណងនយោបាយបែបនេះ ក្នុងល័ក្ខខ័ណ្ឌនេះ តម្រូវឱ្យមានការផ្លាស់ទីជនជាតិផ្សេងក្រៅពីជនជាតិស៊ែរប៊ីដោយបង្ខំឱ្យទៅក្រៅទឹកដីរបស់ SAO នៃប្រទេស KRAJINA និងនៃសាធារណរដ្ឋសង្គមនិយមក្រាជីណា (RSK)។ ជាផលវិបាក អង្គជំនុំជម្រះសន្និដ្ឋានហួសពីវិមតិសង្ស័យថា គោលបំណងនៃសហឧក្រិដ្ឋកម្មរួម គឺជាការបង្កើតទឹកដីដែលមានតែជនជាតិស៊ែរប៊ីរស់នៅ ដោយបណ្ដេញប្រជាជនក្រូអាស៊ី និង

---

[432] សាលដីកា Brima (តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន) ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ៨៥។

[433] សាលដីកា Martić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ១១២ ដែលយោងទៅ សាលក្រម Martić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៤២។

[434] សាលក្រម Martić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៣៥។

ជនជាតិផ្សេងទៀតក្រៅពីជនជាតិស៊ែរប៊ីចេញ ដែលជាឧក្រិដ្ឋកម្មដែលចោទប្រកាន់ក្នុងបទចោទទី ១០ និង ១១ នៃដីកាចោទប្រកាន់" [435]។

៤៨៣. ដូច្នេះ មានតែឧក្រិដ្ឋកម្មចាំបាច់ចំពោះការសម្រេចគោលបំណងនេះទេ ដែលត្រូវបានដាក់បញ្ចូលក្នុងផែនការរួម។

៤៨៤. បន្ទាប់ពីបានសន្និដ្ឋានថា ជនជាប់ចោទមាន "ចេតនាបម្លាស់ទីដោយបង្ខំប្រជាជនដែលមិនមែនជាជនជាតិស៊ែរប៊ីចេញពីទឹកដី SAO នៃប្រទេស KRAJINA ហើយនិងក្រោយមកទៀតឱ្យចេញពីសាធារណរដ្ឋសង្គមនិយមក្រាជីណា" និងក្រោយពីបានសន្និដ្ឋានថាជនជាប់ចោទបាន "ចូលរួមយ៉ាងសកម្មក្នុងការសម្រេចគោលបំណងនៃសហឧក្រិដ្ឋកម្មរួម[436] អង្គជំនុំជម្រះបានពិចារណាថា ឧក្រិដ្ឋកម្មដទៃទៀតដែលមិនត្រូវបានចោទប្រកាន់ចំពោះរូបគាត់ "មិនចូលក្នុងក្របខណ្ឌនៃគោលបំណងនៃសហឧក្រិដ្ឋកម្មរួមទេ" ប៉ុន្តែគាត់មានចេតនាប្រថុយនឹងការដែលថាឧក្រិដ្ឋកម្មទាំងនេះអាចនឹងត្រូវបានប្រព្រឹត្ត[437]។

៤៨៥. ដូច្នេះ សូម្បីតែក្នុងករណីដែលគោលបំណងផ្ទាល់មិនមានចរិតឧក្រិដ្ឋ ប៉ុន្តែគោលបំណងនេះត្រូវបានសម្រេចដោយមធ្យោបាយឧក្រិដ្ឋ ក៏ឧក្រិដ្ឋកម្មដែលអាចគ្រោងទុកជាមុនបានមិនត្រូវបានបញ្ចូលទៅក្នុងផែនការរួមដែរ គឺខុសពីឧក្រិដ្ឋកម្មដោយចេតនាចាំបាច់សម្រាប់ការសម្រេចគោលបំណងនេះ។

---

[435] សាលក្រម Martić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៤៥។

[436] សាលក្រម Martić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៥៣ (បទចោទ ១០ ៖ ការបណ្តេញចេញ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, បទចោទ១១ ៖ ការជម្លៀសដោយបង្ខំ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ)។

[437] សាលក្រម Martić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៥៣ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖ ការធ្វើទុក្ខបុកម្នេញ, ការធ្វើមនុស្សឃាត, ការដាក់ពន្ធនាគារ, ការធ្វើទារុណកម្ម, អំពើអមនុស្សធម៌ៗ ការរំលោភបំពានលើអនុសញ្ញានៃទីក្រុងហ្សឺណែវ ៖ ការធ្វើមនុស្សឃាត, ការធ្វើទារុណកម្ម, ការប្រព្រឹត្តអំពើកាចសាហាវ, ការបំផ្លិចបំផ្លាញភូមិស្រុកដោយគ្មានមូលហេតុ ឬការបង្ខិនបង្ខោចដោយគ្មានហេតុផលតាមរយៈការទាមទារចង់បានរបស់យោធា, ការបំផ្លាញ ឬការធ្វើឱ្យខូចខាតដោយចេតនានូវអគារសាសនា ឬគ្រឹះស្ថានអប់រំ ការលួចប្លន់ទ្រព្យសម្បត្តិរដ្ឋឬឯកជន)។

### 3. រឿងក្តី *KRAJISNIK*

៤៨៦. ក្នុងរឿងក្តី *KRAJISNIK* គោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម បើតាមដីកាចោទប្រកាន់ គឺជា "ការបណ្តេញពួកមូស្លីម ពួកក្រូអាតនៃតំបន់បូស្នី និងជនជាតិដទៃទៀតដែលមិនមែនជាអំបូរស៊ែរប៊ី ដោយប្រើកម្លាំង និងមធ្យោបាយផ្សេងទៀត ឱ្យចាកចេញជារៀងរហូត ពីចំណែកដីដ៏ធំទូលាយនៃទឹកដី Bosnie-HERZEGOVINE ដោយប្រព្រឹត្តឧក្រិដ្ឋកម្ម" ដែលផ្តន្ទាទោសដោយលក្ខន្តិកៈ។ មានការលើកឡើងផងដែរថា "ឧក្រិដ្ឋកម្មដែលមានរៀបរាប់នៅក្នុងបទចោទនៃដីកាចោទប្រកាន់ ស្ថិតនៅក្នុងក្របខណ្ឌនៃគោលបំណងសហឧក្រិដ្ឋកម្មរួម" ហើយជនជាប់ចោទ "មានចេតនាគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ"[438]។ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញ អំពើមនុស្សឃាត ឃាតកម្ម ការសម្លាប់រង្គាល ការជម្លៀស និងបម្លាស់ទីដោយបង្ខំ[439]។

៤៨៧. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការជម្លៀស និងការផ្លាស់ទីដោយបង្ខំ "ជាការចាំបាច់សម្រាប់ការសម្រេចគោលបំណងរួម ដែលសំដៅបណ្តេញដោយកម្លាំងនូវពួកមូស្លីម និងជនអំបូរក្រូអាតនៃប្រទេសបូស្នី ចេញពីតំបន់ដ៏ធំទូលាយនៃប្រទេស Bosnie-HERZEGOVINE"[440]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ឧក្រិដ្ឋកម្មដទៃទៀតដែលមិនត្រូវបាន "គ្រោងទុកជាមុនកាលពីដើមទី មិនស្ថិតនៅក្នុងផែនការរួមនាពេលបន្ទាប់មកទៀតទេ ដោយមូលហេតុថា គោលបំណងរួមហាក់ដូចជាលែងអាចសម្រេចបានហើយ តាមរយៈឧក្រិដ្ឋកម្មទាំងឡាយដែលបានគ្រោងទុកជាមុនតាំងពីដើមទី"[441]។ អង្គជំនុំជម្រះសាលាដំបូងបានបន្ថែមទៀតថា៖ "តាមរយៈការទទួលយកនូវឧក្រិដ្ឋកម្មថ្មីៗទៀត និងការចូលរួមចំណែកជាប្រចាំក្នុងការសម្រេចគោលបំណងនេះ គឺវា

---

[438] សាលក្រម Krajišnik (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ១០៨៩។

[439] សាលក្រម Krajišnik (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ១០៩៥។

[440] សាលក្រម Krajišnik (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ១០៩៧។

[441] សាលក្រម Krajišnik (TPIY) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ១០៩៨។

កើតមានឡើងនូវចេតនាធ្វើយ៉ាងណាឱ្យឧក្រិដ្ឋកម្មថ្មីទាំងនេះ ក្លាយជាទំនួលខុសត្រូវរបស់សមាជិកនៃសហឧក្រិដ្ឋកម្មរួម ចំពោះការចូលរួមទៅនឹងសហឧក្រិដ្ឋកម្មប្រភេទទីមួយ”[442]។

៤៨៨. ក្នុងខណៈដែលសហព្រះរាជអាជ្ញាបញ្ចុះបញ្ចូលឱ្យដាក់ការទទួលខុសត្រូវលើជនជាប់ចោទ ចំពោះសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ និងជាបន្ទាប់បន្សំចំពោះសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី អង្គជំនុំជម្រះបានសម្រេចយកសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ[443]។ ទោះបីជាអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានផ្តល់សុពលភាពដល់វិធីសាស្ត្រដែលថាមធ្យោបាយឧក្រិដ្ឋចាំបាច់ សម្រាប់ការសម្រេចគោលបំណងរួមអាចវិវត្តន៍តាមពេលវេលាក៏ដោយ[444] ក៏អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានតម្កល់សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានបន្ថែម ដោយសំអាងហេតុថា អង្គជំនុំជម្រះសាលាដំបូងមិនបានបញ្ជាក់ឱ្យបានគ្រប់គ្រាន់ថាតើតាមរបៀបណា ចាប់ពីពេលណាមក ឧក្រិដ្ឋកម្មទាំងនេះត្រូវបានបញ្ចូលទៅក្នុងសហឧក្រិដ្ឋកម្មរួម[445]។

៤៨៩. ទោះជាយ៉ាងណាក្តី ទោះជាចាប់ពីដើមទី ឬក៏ពេលក្រោយមកហើយក៏ដោយ ក៏មានតែឧក្រិដ្ឋកម្មមានចេតនា និងចាំបាច់សម្រាប់ការសម្រេចគោលបំណងនេះតែប៉ុណ្ណោះ ដែលត្រូវបញ្ចូលទៅក្នុងផែនការរួម។

## 4. __រឿងក្តី *Prlic*__

---

[442] សាលក្រម Krajišnik (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ១០៩៨។

[443] សាលដីកា Krajišnik (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៦៧-១៦៩។

[444] សាលដីកា Krajišnik (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៦៣។

[445] សាលដីកា Krajišnik (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៧៧, ១៧៨ និង ២០៣។

៤៩០. នៅក្នុងរឿងក្តី *Prlic* គ្រប់ទម្រង់នៃសហឧក្រិដ្ឋកម្មរួម ត្រូវបានចោទប្រកាន់នៅក្នុងដីកាចោទប្រកាន់[446]។ មានការចោទប្រកាន់ជាពិសេសថា រាល់ឧក្រិដ្ឋកម្ម "ដែលមិនមែនជាផ្នែកនៃគោលបំណងនៃសហឧក្រិដ្ឋកម្មរួម ឬមិនមែនជាផ្នែកដែលគ្រោងទុកដោយសហឧក្រិដ្ឋកម្មរួម គឺជាផលវិបាកធម្មជាតិ និងអាចគ្រោងទុកបាននៃការអនុវត្តផែនការនេះ ឬក៏ការប៉ុនប៉ងអនុវត្តផែនការនេះ (ទម្រង់ទីបី)" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[447]។

៤៩១. មានការសម្រេចសេចក្តីថា គោលបំណងចុងក្រោយនៃសហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់ គឺជា "ការបង្កើតអង្គភាពក្រូអាតមួយ ដោយយកផ្នែកមួយចំនួននៃព្រំប្រទល់របស់ប្រទេស Banoniva ឆ្នាំ១៩៣៩ ដើម្បីបង្រួបបង្រួមប្រជាជនក្រូអាត[448]" អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ធាតុផ្សំភ័ស្តុតាងបង្ហាញថា "មានតែគោលបំណងឧក្រិដ្ឋរួមតែមួយគត់ គឺការគ្រប់ដណ្តប់លើជនជាតិក្រូអាតនៅប្រទេស Bosnie-HERZEGOVINE តាមរយៈការបោសសំអាតជាតិពន្ធនៃប្រជាជនឥស្លាម។ ដើម្បីសម្រេចគោលបំណងនេះ សមាជិកក្រុម ក្នុងនោះមានជនជាប់ចោទទាំងអស់ផងដែរ បានប្រើឧបករណ៍នយោបាយនិងយោធារបស់ប្រទេស Bosnie-HERZEGOVINE"[449]។

៤៩២. អង្គជំនុំជម្រះបានពិចារណាថា ធាតុផ្សំភ័ស្តុតាងបានបញ្ជាក់ថា "ដើម្បីសម្រេចគោលបំណងនយោបាយនេះ សហឧក្រិដ្ឋកម្មរួមត្រូវបានរកឃើញថាពិតជាមានយ៉ាងហោចណាស់ក៏ចាប់តាំងពីពាក់កណ្តាលខែ មករា ឆ្នាំ ១៩៩៣"[450] និងពិចារណាថា ចាប់តាំងពីខែ មិថុនា ឆ្នាំ ១៩៩៣ គោល

[446] សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២២។

[447] សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២៤។

[448] សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ៤ កថាខណ្ឌ ២៤។

[449] សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ៤ កថាខណ្ឌ ៤១។

[450] សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ៤ កថាខណ្ឌ ៤៤។

បំណងឧក្រិដ្ឋរួមបានពង្រីក និងរាលដាលដល់ "ឧក្រិដ្ឋកម្មថ្មីៗទៀត"[451] អង្គជំនុំជម្រះបានប្រកាសថា ជនជាប់ចោទ "មានចេតនាចង់ឱ្យឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តដើម្បីពន្លឿនផែនការរួម"[452]។ ដូច្នេះ អង្គជំនុំជម្រះបានធ្វើបញ្ជី "នៃឧក្រិដ្ឋកម្មទាំងអស់នេះ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃផែនការរួមរបស់ផែនការសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ"[453]។

៤៩៣. ម្យ៉ាងទៀត អង្គជំនុំជម្រះបានសម្រេច "មិនបញ្ចូល" ឧក្រិដ្ឋកម្មដទៃទៀត "ទៅក្នុងគោលបំណងឧក្រិដ្ឋរួម"[454]។ អង្គជំនុំជម្រះបានពិចារណាថា ជនជាប់ចោទទាំងអស់ ដឹងថាឧក្រិដ្ឋកម្មទាំងនេះ ដែលជាផលវិបាកធម្មជាតិ និងអាចគ្រោងទុកមុនបាននៃការអនុវត្តការទម្លាក់ចេញពីតំណែង អាចត្រូវបានប្រព្រឹត្តដើម្បីអនុវត្តការទម្លាក់ចេញពីតំណែងនេះ ហើយជនជាប់ចោទបានសម្រេចប្រថុយប្រថានទោះបីជាដឹងពីលទ្ធផលក៏ដោយ ដែលទាំងនេះជាមូលហេតុនាំឱ្យពួកគាត់មានទំនួលខុសត្រូវតាមសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី[455]។

៤៩៤. ដូច្នេះ ជាថ្មីម្តងទៀត ឧក្រិដ្ឋកម្មដែលអាចគ្រោងទុកមុនបាន មិនមែនជាផ្នែកនៃផែនការឧក្រិដ្ឋរួមទេ។

## គ. សេចក្តីសន្និដ្ឋាន

[451] សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ៤ កថាខណ្ឌ ៥៩។

[452] សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ៤ កថាខណ្ឌ ៦៧។

[453] សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ៤ កថាខណ្ឌ ៦៨។

[454] សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ៤ កថាខណ្ឌ ៧០។

[455] សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ៤ កថាខណ្ឌ ៧២-៧៣។

៤៩៥. យោងតាមការបង្ហាញខាងលើ និយមន័យនៃសហឧក្រិដ្ឋកម្មរួមកូនកាត់របស់អង្គជំនុំជម្រះតុលាការកំពូលមិនមានទាំងមូលដ្ឋាន ទាំងការគាំទ្រផ្នែកច្បាប់ទាល់តែសោះក្នុងច្បាប់អន្តរជាតិ ទោះជាក្នុងក្របខ័ណ្ឌនៃរឿងក្តីពាក់ព័ន្ធនឹងផែនការដែល “តម្រូវឱ្យមាន” ការប្រព្រឹត្តិឧក្រិដ្ឋកម្មក៏ដោយ។

៤៩៦. ក្នុងរឿងក្តីបែបនេះ ផែនការឧក្រិដ្ឋរួមអាចមានគំនូសបំព្រួញដូចតទៅនេះ៖




៤៩៧. រីឯចំពោះអង្គជំនុំជម្រះតុលាការកំពូលវិញ ផែនការឧក្រិដ្ឋរួមមានគំនូសបំព្រួញដូចតទៅនេះ៖




៤៩៨. ក៏ប៉ុន្តែ វត្តមានចំឡែកនៃការប្រមើលឃើញជាមុនបាននៅក្នុងផែនការឧក្រិដ្ឋរួម មិនមានតួនាទីរបស់ខ្លួនឡើយនៅក្នុងច្បាប់អន្តរជាតិ។ សូម្បីតែក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិសម័យទំនើប ក៏ការព្រមព្រៀងទទួលហានិភ័យមិនដែលត្រូវបានចាត់ទុកថាជាការព្រមព្រៀងទទួលឧក្រិដ្ឋកម្មដែរ។

## ៤. លក្ខណៈតែមួយគត់មិនធ្លាប់មាននៃការបូកបញ្ចូលគ្នាអោយខាងតែបានរវាងសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ និងសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី

៤៩៩. ចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិដែលអនុវត្តសហឧក្រិដ្ឋកម្មរួម ទំនួលខុសត្រូវបន្ទាប់បន្សំដែលផ្អែកលើការអាចប្រមើលមើលជាមុនបាន និងការទទួលយកហានិភ័យដោយស្ម័គ្រចិត្ត (សហឧក្រិដ្ឋកម្មរួមទម្រង់ទីបី) មិនដែលជាផ្នែកមួយនៃទំនួលខុសត្រូវពីបទគោលបំណងចេតនារួម ហើយក៏មិនដែលត្រូវបានផ្សារភ្ជាប់ទៅនឹងទំនួលខុសត្រូវពីបទគោលបំណងចេតនារួមដែរ (សហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ)។

៥០០. ក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ លក្ខខ័ណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័តមិនដែលមានបញ្ចូលទាំងការអាចគ្រោងទុកជាមុនបាន ទាំងអ្វីដែលមានកម្រិតទាបជាងចេតនាឧក្រិដ្ឋផ្ទាល់។ ជាក់ស្តែង យោងតាមយុត្តិសាស្រ្តអចិន្ត្រៃយ៍ សហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយតម្រូវឱ្យរកអោយឃើញថា អ្នកចូលរួមមានចេតនាឧក្រិដ្ឋដូចគ្នា និងតម្រូវឱ្យរកអោយឃើញថា ជនជាប់ចោទមានចេតនាចូលរួមក្នុងផែនការនេះ ហើយចង់ឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម៖

> *"ទម្រង់ជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម [...] តម្រូវថា ជនជាប់ចោទត្រូវមានទាំងចេតនាប្រព្រឹត្តបទឧក្រិដ្ឋ និងចេតនាចូលរួមទៅក្នុងគោលបំណងរួមដែលមានគោលបំណងអនុវត្តនូវផែនការនោះ។"*[456]

៥០១. ដូច្នេះ វាមិនមែនជាការគ្រោងទុកអំពីលទ្ធភាពដែលថាឧក្រិដ្ឋកម្មជាយថាហេតុនឹងត្រូវបានប្រព្រឹត្តនោះទេ ៖

---

[456] សាលដីកា Munyakazi (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ១៦០។ សូមមើលផងដែរ ៖ សាលដីកា Stanišić និង Zupljanin (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣៧៥។ សាលដីកា Popović (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ១៣៦៩។ សាលដីកា Brđanin (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៣៦៥ (« លុះត្រាតែជនជាប់ចោទមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មផង និងមានចេតនាចូលរួមក្នុងការសម្រេចគោលបំណងរួមផង »)។

*"ចំពោះសហឧក្រិដ្ឋរួមទម្រង់ទីមួយ ធាតុផ្សំទាមទារឱ្យមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មជាក់លាក់ណាមួយពីសំណាក់សហចារីទាំងអស់"*[457]។

៥០២. ការអាចគ្រោងទុកជាមុនបាននេះ មានតែសម្រាប់សហឧក្រិដ្ឋរួមទម្រង់ទីបីតែប៉ុណ្ណោះ៖

> "កាលណាលក្ខខ័ណ្ឌតម្រូវនៃសហឧក្រិដ្ឋកម្មរួមមានគ្រប់គ្រាន់ក្នុងករណីណាមួយ ជនជាប់ចោទមិនបានប្រព្រឹត្តត្រឹមតែសេពគប់ឧក្រិដ្ឋជនប៉ុណ្ណោះទេ គាត់មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម។ គាត់រួមដៃជាមួយបុគ្គលដទៃទៀតដើម្បីសម្រេចគោលបំណងនេះ ហើយបានចូលរួមយ៉ាងទូលំទូលាយក្នុងឧក្រិដ្ឋកម្ម។ អាស្រ័យហេតុដូចនេះហើយ បានជាគាត់ត្រូវមានទំនួលខុសត្រូវចំពោះអំពើរបស់អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មដទៃទៀត ឬអំពើនៃបុគ្គលដែលប្រើប្រាស់ដោយអ្នកចូលរួមទាំងនោះ ដែលបានចូលរួមចំណែកក្នុងគោលបំណងឧក្រិដ្ឋរួម ([សហឧក្រិដ្ឋកម្មរួម] ប្រភេទទីមួយ) ឬដែលបានចូលរួមចំណែកក្នុងប្រព័ន្ធឧក្រិដ្ឋ ([សហឧក្រិដ្ឋកម្មរួម] ប្រភេទទីពីរ) ឬដែលជាផលវិបាកធម្មជាតិ និងអាចគ្រោងទុកបាននៃឧក្រិដ្ឋកម្មនេះ ([សហឧក្រិដ្ឋកម្មរួម]ប្រភេទទីបី)"[458]។

៥០៣. មានទំនួលខុសត្រូវចំពោះឧក្រិដ្ឋកម្មស្របតាមសហឧក្រិដ្ឋកម្មរួមទម្រង់ទីបីកាលណា៖

> "១. មានការគ្រោងទុកជាមុនបានថា ឧក្រិដ្ឋកម្មបែបនេះអាចនឹងត្រូវបានប្រព្រឹត្តដោយសមាជិកម្នាក់ ឬច្រើននៃក្រុម ២. ជនជាប់ចោទមានចេតនាប្រថុយនឹងការដែលថា ឧក្រិដ្ឋកម្មនេះអាចនឹងត្រូវប្រព្រឹត្តដោយហេតុថាគាត់ដឹងថាឧក្រិដ្ឋកម្មនេះគឺជាផលវិបាកជាភវនីយកម្មនៃការសម្រេចគោលបំណងរួមនេះ និង៣. ដោយ

---

[457] សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១, កថាខណ្ឌ ២១៤។ សូមមើលផងដែរ ៖ សាលដីកា Stanišić និង Simatović (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៧៧ (« *the intent to perpetrate a certain crime* »)، សាលដីកា Stakić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៦៥ (« ចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មជាក់លាក់ »)، សាលដីកា Vasiljević (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ កថាខណ្ឌ ១០១ (« ចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មជាក់លាក់ »)، សាលដីកា Tadić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៨ (« ចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មដោយឡែក »)។

[458] សាលដីកា Martić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ១៧២។

ហេតុថាគាត់បានទទួលយកការប្រព្រឹត្តឧក្រិដ្ឋកម្មនេះដោយសម្រេចចូលរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួម"[459]។

៥០៤. ការអាចគ្រោងទុកជាមុននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី តែងតែត្រូវបានញែកដាច់ពីចេតនាផ្ទាល់នៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ៖

> *"អនុលោមតាមសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ ជនជាប់ចោទត្រូវចែករំលែកចេតនាប្រព្រឹត្តបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមិនត្រឹមតែប្រមើលមើលពីការកើតឡើងនៃបទឧក្រិដ្ឋទាំងនោះទេ។"*[460]
>
> *"បញ្ហា "ដែលអាចប្រមើលមើលដឹងជាមុនថាជាបទល្មើស" ពាក់ព័ន្ធនឹងទម្រង់លាតសន្ធឹងនៃសហឧក្រិដ្ឋកម្មរួម មិនមែនទម្រង់មូលដ្ឋានទេ។"*[461]
>
> *"ទម្រង់ទី១ នៃសហឧក្រិដ្ឋកម្មរួមតម្រូវឱ្យមានចេតនាក្នុងន័យថាជា បទដ្ឋាននៃការចូលរួមដោយផ្ទាល់ (dolus directus) និង [...] ជាការធ្វេសប្រហែសនៃ បទដ្ឋាននៃការធ្វេសប្រហែស មិនគ្រប់គ្រាន់ទេ។"*[462]

---

[459] សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣, ភាគ ១ កថាខណ្ឌ ២១៦។ សូមមើលផងដែរឧទាហរណ៍ ៖ សាលដីកា Stanišić និង Zupljanin (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ៩៥៨ ៖ « *The Appeals Chamber recalls further that the subjective element of the first category of joint criminal enterprise is that an accused had the intent to commit the crimes that form part of the common purpose of the joint criminal enterprise and the intent to participate in a common plan aimed at their commission. <u>For liability pursuant to the third category of joint criminal enterprise</u>, a trial chamber must be satisfied <u>in addition</u> that: (i) it was foreseeable to the accused that a crime outside the common purpose might be perpetrated by one or more of the persons used by him (or by any other member of the joint criminal enterprise) in order to carry out the* actus reus *of the crimes forming part of the common purpose; and (ii) the accused willingly took the risk that the crime might occur by joining or continuing to participate in the enterprise* » (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[460] សាលដីកា Sainović (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៤ កថាខណ្ឌ ១០១៤។

[461] សាលដីកា Karemera និង Ngirumpatse (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ ៥៦៤។

[462] សាលក្រម Stanišić និង Simatović (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣, សៀវភៅទី ២ កថាខណ្ឌ ១២៥៨ និង កំណត់សម្គាល់ជើងទំព័រ ២១៩៣។ សូមមើលផងដែរ កថាខណ្ឌ ២៣៣២ ៖ « *However, as above, the Trial Chamber understands such knowledge and acceptance of the risk that crimes would be committed to be insufficient for the first form of JCE liability* »។

៥០៥. ដូច្នេះ សូម្បីតែតុលាការចំពោះកិច្ចដែលអនុវត្តសហឧក្រិដ្ឋកម្មរួមគ្រប់ទម្រង់ទាំងអស់ តាំងពីយូរឆ្នាំមកហើយ ក៏នៅតែបែងចែកសហឧក្រិដ្ឋកម្មរួមនេះយ៉ាងច្បាស់ ហើយមិនដែលច្របូកច្របល់ដូចអង្គជំនុំជម្រះតុលាការកំពូលទេ។ ក៏ប៉ុន្តែ ប្រសិនបើនិយមន័យសហឧក្រិដ្ឋកម្មរួមកូនកាត់របស់អង្គជំនុំជម្រះតុលាការកំពូលពិតជាមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិមែននោះ តុលាការព្រហ្មទណ្ឌអន្តរជាតិនានាយកវាមកអនុវត្តបាត់ទៅហើយ។ លើសពីនេះទៅទៀត និយមន័យនេះអនុញ្ញាតឱ្យពួកគាត់បោះបង់ទាំងស្រុងតែម្តងនូវសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៩ ដោយសាលដីកា *Tadic* និងអនុញ្ញាតឱ្យពួកគាត់ទប់ទល់នឹងការវាយប្រហារតាំងពីឆ្នាំនោះមកតាមរយៈការជំទាស់របស់ក្រុមមេធាវីការពារក្តី និងចៅក្រមដែលមានមតិដោយឡែក។ ឆ្លើយតបនឹងការជំទាស់ទាំងនេះ ពួកគាត់លើកឡើងតែពីវិធានយុត្តិសាស្ត្រ (Stare decisis) តែមួយគត់ដោយអសុឆន្ទៈដើម្បីទប់ទល់[463]។

៥០៦. កាន់តែមានចរិតឧកាសនិយមជាងការបង្កើតសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី កាលពីឆ្នាំ១៩៩៩ ទៅទៀត ការបង្កើតសហឧក្រិដ្ឋកម្មរួមកូនកាត់ដោយអង្គជំនុំជម្រះតុលាការកំពូល មានគោលបំណងតែមួយគត់ គឺជៀសឱ្យផុតពីភាពអនុវត្តមិនបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី នៅចំពោះមុខ អ.វ.ត.ក ក្នុងខណៈដែលអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងតុលាការនេះ ពិបាកនឹងចាត់ទុកថាស្ថិតនៅក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ។

## ៥. ការបង្កើតដោយកាត់តម្រឹមដើម្បីផ្តន្ទាទោសជនជាប់ចោទនៅ អ.វ.ត.ក

៥០៧. អ.វ.ត.ក ទទួលអណត្តិជំនុំជម្រះរឿងរ៉ាវដែលបានកើតឡើងកាលពី៤០ឆ្នាំមុន ក្នុងបរិបទប្រវត្តិសាស្ត្រ និងនយោបាយយ៉ាងពិសេសនៃសង្គ្រាមត្រជាក់ បន្ទាប់ពីសហរដ្ឋអាមេរិកបានប្រព្រឹត្តអំពើ

---

463 សូមមើលផងដែរឧទាហរណ៍ ៖ សាលដីកា Tolimir (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥ កថាខណ្ឌ ២៨១ និង ២៨៤, សាលដីកា Popović (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ១៦៧២-១៦៧៤, សាលដីកា Dorđevic (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៨-៥៣, សាលក្រម Prlić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២១០។

សាហាវឃោរឃៅក្នុងប្រទេសកម្ពុជាក្នុងក្របខ័ណ្ឌសង្គ្រាមប្រឆាំងនឹងប្រទេសវៀតណាម និងការផ្តួលរំលំអំណាចផ្តាច់ការដោយខ្មែរក្រហមដើម្បីបង្កើតបដិវត្តន៍សង្គមនិយមមួយ។

៥០៨. ដោយបញ្ជូនជនជាប់ចោទមកជំនុំជម្រះក្នុងសំណុំរឿង ០០២ ស្របតាមសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ ទោះបីជាសហចៅក្រមស៊ើបអង្កេតដែលបានស៊ើបអង្កេតដាក់បន្ទុកច្រើនជាងដោះបន្ទុកយ៉ាងខ្លាំងក៏ដោយ ក៏ពួកគាត់គ្មានជម្រើសអ្វីក្រៅពីយល់ស្របគ្នាថា ផែនការរបស់មេដឹកនាំបក្សកម្មុយនីស្តកម្ពុជា "មិនមានចរិតឧក្រិដ្ឋទាំងស្រុងដែរ"[464]។

៥០៩. បន្ទាប់ពីបញ្ចប់សំណុំរឿង ០០២/០១ អង្គជំនុំជម្រះខ្លួនឯងក៏បានសន្និដ្ឋានដែរថា "ផែនការនេះមិនមានចរិតឧក្រិដ្ឋដាច់ខាត ឬទាំងស្រុងនោះទេ"[465]។ អង្គជំនុំជម្រះបានប្រកាសថា "ផែនការរួមនេះផ្ទាល់មិនមានចរិតឧក្រិដ្ឋក៏ពិតមែន ក៏ប៉ុន្តែគោលនយោបាយដែលបង្កើតឡើងដោយខ្មែរក្រហមតម្រូវឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មជាមធ្យោបាយដើម្បីទៅដល់គោលដៅ"[466] ដោយមិនមានសមត្ថភាពក្នុងការបែងចែកឧក្រិដ្ឋកម្មដែលគ្រោងទុកជាមុន ពីឧក្រិដ្ឋកម្មដែលជាផលវិបាកអាចគ្រោងទុកមុនបាន។

៥១០. អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ថា ចំណុចនេះធ្វើឱ្យគេយល់ថាអង្គជំនុំជម្រះយល់ឃើញថាឧក្រិដ្ឋកម្មដែលកើតចេញពីការសម្រេចផែនការរួម អាចត្រូវជាទំនួលខុសត្រូវរបស់ជនជាប់ចោទ[467]។ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា៖ "ដោយយោងទៅលើបទឧក្រិដ្ឋដែលគ្រាន់តែ"បណ្តាល"មកពីការអនុវត្តគោលបំណងរួម អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការប្រើប្រាស់សញ្ញាណនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលពុំមានអត្ថិភាពទាំងក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលនៃការប្រព្រឹត្តបទល្មើស ទាំងពុំមែនជាគោលការណ៍ទូទៅនៃច្បាប់"[468]។

---

[464] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៤។

[465] សាលក្រម ០០២/០១ កថាខណ្ឌ ៧៧៨។

[466] សាលក្រម ០០២/០១ កថាខណ្ឌ ៨០៤។

[467] សាលដីកា ០០២/០១ កថាខណ្ឌ ៧៩០។

[468] សាលដីកា ០០២/០១ កថាខណ្ឌ ៨១០។

៥១១. ទោះជាយ៉ាងនេះក្តី ហើយដោយសារការកំណត់និយមន័យសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ[469] របស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបានជួយសង្គ្រោះមិនឱ្យមានការផ្តន្ទាទោស ដោយបញ្ចូលឧក្រិដ្ឋកម្មដែលមានផលវិបាកធម្មជាតិប៉ុន្តែដែលអាចគ្រោងទុកមុនបានក្នុងផែនការរួម ជាពិសេសឧក្រិដ្ឋកម្មមនុស្សឃាត។ ជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា ការស្លាប់ដែលកើតមានឡើងពេលជម្លៀសពីភ្នំពេញមាន "ភវនិយភាព"[470] ឬអាចប្រមើមើលទុកបានក្នុងករណីដែលមានការប្រឆាំងជាយថាហេតុ[471] និងបានពិចារណាថាការស្លាប់ដែលកើតមានឡើងក្នុងពេលជម្លៀសដំណាក់កាលទីពីរមាន "ភវនិយភាព"[472]។

[469] សាលដីកា ០០២/០១ កថាខណ្ឌ ៨៤៩ ៖ « *Accordingly, the Supreme Court Chamber will now consider whether the crimes [...] were encompassed by the common purpose [...], applying the principles set out above* » ដែលយោងទៅកំណត់សម្គាល់ជើងទំព័រ ២២៦៥ ដល់ កថាខណ្ឌ ៨០៧ និងកថាខណ្ឌបន្តបន្ទាប់ទៀតនៃសាលដីកា ដែលតុលាករកំពូលបានផ្តល់និយមន័យផ្ទាល់របស់ខ្លួន លើសហឧក្រិដ្ឋកម្មរួម។

[470] សាលដីកា ០០២/០១ កថាខណ្ឌ ៨៥៣ ៖ « *it has been established that the common purpose of moving the population from Phnom Penh to the countryside, as reflected in the population movement policy, involved the death civilians resulting from the conditions of the evacuation. This is because it has been established that the members of the JCE – the Party leadership – were aware of the conditions the evacuees, including the most vulnerable, would have to endure and that it was likely that, in particular, the most vulnerable would die during the evacuation.* » (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[471] សាលដីកា ០០២/០១ កថាខណ្ឌ ៨៥៧ ៖ « *This is so because it was evident that the forces tasked with carrying out the evacuation of the city would likely resort to deadly force if they encountered resistance. This is irrespective of whether specific orders to kill were given, who gave such orders, and whether such orders were only given to troops under certain commanders.* » (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ កថាខណ្ឌ ៨៦០ ៖ « *Nevertheless, as regards killings of Khmer Republic soldiers in the context of the evacuation of Phnom Penh, the Supreme Court Chamber considers that the killings were encompassed by the common purpose. This is because, as with civilians who were killed for not fulfilling orders to leave, even in the absence of an order to kill Khmer Republic soldiers, in the circumstances in which the evacuation of Phnom Penh was carried out, it was likely that such killings would take place.* » (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[472] សាលដីកា ០០២/០១ កថាខណ្ឌ ៨៦៨ ៖ « *The occurrence of deaths among the transferees was therefore likely; nevertheless, the members of the JCE engaged in the implementation of the common purpose.* » (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៥១២. ក៏ប៉ុន្តែ ដូចនឹងការស្លាប់ដែលកើតមានឡើងក្នុងអំឡុងពេលបម្លាស់ទីដោយបង្ខំដែលត្រូវបានជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេស យូហ្គោស្លាវី[473] ការស្លាប់ទាំងនេះមិនអាចត្រូវបានចាត់ទុកថាជាអ្វីផ្សេងទៀតក្រៅពីផលវិបាកធម្មជាតិ និងដែលអាចគ្រោងទុកបាននៃការសម្រេចផែនការបម្លាស់ទីប្រជាជននោះទេ។ ដូច្នេះ ដោយហេតុថាសហឧក្រិដ្ឋកម្មរួមទម្រង់ទីបីមិនអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ជនជាប់ចោទគួរណាតែរួចផុតពីការផ្តន្ទាទោសពីបទដែលគ្មានការស្លាប់ណាមួយកើតមានឡើងក្នុងពេលផ្លាស់ទីប្រជាជនដោយគ្មានសហឧក្រិដ្ឋកម្មរួមកូនកាត់របស់អង្គជំនុំជម្រះតុលាការកំពូល។

៥១៣. ដូច្នេះ ការបង្កើតរបស់អង្គជំនុំជម្រះតុលាការកំពូល ជាការផ្តល់ផលប្រយោជន៍ទៅវិញទៅដល់ម្ចាស់ជំនួយរបស់តុលាការ និងសហព្រះរាជអាជ្ញាដែល (ដោយដឹងច្បាស់អំពីការលំបាកក្នុងការផ្តល់ភ័ស្តុតាងអំពីចេតនាឧក្រិដ្ឋផ្ទាល់ខ្លួន) និយាយបញ្ចុះបញ្ចូលឱ្យយកសហឧក្រិដ្ឋកម្មទម្រង់ទីបីតាំងពីការសរសេរដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយខំព្យាយាមជាច្រើនឆ្នាំដើម្បីឱ្យអនុវត្តទម្រង់នេះនៅចំពោះមុខ អ.វ.ត.ក (សហសហព្រះរាជអាជ្ញាថែមទាំងបានបញ្ជាក់ពីរដងថា ទម្រង់នេះត្រូវតែអនុវត្តចំពោះអង្គហេតុរំលោភសេពសន្ថវៈ ដែលចំពោះអង្គហេតុទាំងនេះ ជនជាប់ចោទមិនត្រូវបានបញ្ជូនទៅជំនុំជម្រះផងនោះ)[474]។

---

[473] ក្រៅពីឧទាហរណ៍ដែលមាននៅក្នុងសាលដីកា Tadić ក៏ដូចជាក្នុងរឿងក្តី Martić ដែលបានសង្កេតរួចនៅខាងលើ ក្នុងកថាខណ្ឌ ៤៥៨ និង ៤៨២-៤៨៤, សូមមើលរឿងក្តី Sainović (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, សាលក្រមចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ និង សាលដីកា ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៤) នៅក្នុងសាលក្រមនេះ គេកាត់សេចក្តីថាគោលបំណងរួមបានសម្រេច តាមរយៈការជម្លៀសប្រជាជនដោយបង្ខំ និងឧក្រិដ្ឋកម្មផ្សេងៗទៀតដែលលើកឡើងដោយរដ្ឋអាជ្ញា (ការធ្វើមនុស្សឃាត, ការរំលោភផ្លូវភេទ, ការបំផ្លាញទ្រព្យសម្បត្តិសាសនា) ត្រូវបានសង្កេតសម្រាប់សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣។

[474] សាលដីការបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ **ឯកសារ D97/15/9** កថាខណ្ឌ ៩៧ (អង្គបុរេជំនុំជម្រះបានប្រកាសថា តាមរយៈអំណានយ៉ាងត្រឹមត្រូវនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា អង្គហេតុដែលថាព្រះរាជអាជ្ញាមានចេតនាចោទប្រកាន់ទម្រង់នៃសហឧក្រិដ្ឋកម្មរួមទាំងបីយ៉ាងនេះ "មិនមានភាពស្រពេចស្រពិលឡើយ")។ សំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ **ឯកសារ E100**។ ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ **ឯកសារ E1/240.1** ទំព័រ ៣២ ប្រហែលម៉ោង 10.12.59 (« នេះជាបញ្ហាដ៏សំខាន់ [នៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣] ហើយនឹងមានផលប៉ះពាល់ពីរឿងក្តី០០២/០២ »)។ ចំពោះអង្គហេតុនៃការរំលោភសេពសន្ថវៈ សូមមើលខាងលើ កថាខណ្ឌ ១៨៩។

៥១៤. ជាអកុសល ការផ្តល់ផលប្រយោជន៍ទៅវិញនេះខុសនឹងច្បាប់។ ដូចគ្នានឹងបទមនុស្សឃាតដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមួយនឹងចេតនាប្រយោលក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែរ សហឧក្រិដ្ឋរួមកូនកាត់របស់អង្គជំនុំជម្រះតុលាការកំពូល មិនមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅសម័យអង្គហេតុនោះទេ។ លើសពីនេះទៅទៀត ឧក្រិដ្ឋកម្មនេះ និងទម្រង់នៃទំនួលខុសត្រូវ *ឯកោតែឯង*ដូចដែលតុលាការកំពូលបានកំណត់ មិនអាចនឹងប្រមើលឃើញជាមុនបានដោយជនជាប់ចោទនោះទេ ទោះបីជាមានជំនួយ "ផ្នែកប្រឹក្សាច្បាប់ដ៏ភ្លឺស្វាងក៏ដោយ"[475]។

៥១៥. តាងនាមឱ្យអ្នកគោរពគោលការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះមានកាតព្វកិច្ចមិនត្រូវដើរតាមគន្លងអង្គជំនុំជម្រះតុលាការកំពូលឡើយ។ ជាថ្មីម្តងទៀត ធម្មានុរូប និងការគួរឱ្យជឿជាក់បាននៃតុលាការប្រឈមមុខនឹងការបាត់បង់។

៥១៦. ទាក់ទងនឹងប្រធានបទនេះ យើងគប្បីកត់សម្គាល់ថាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ និងរបស់អង្គជំនុំជម្រះដែលទទួលស្គាល់ថាទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមមិនអាចអនុវត្តបាន ត្រូវបានសាទរនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ជាពិសេសដោយចៅក្រមនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដូចជាលោកចៅក្រម SCHOMBURG និងលោកចៅក្រម ANTONETTI។[476] ចៅក្រម ANTONETTI យល់ថា៖

> "ជាការពិតណាស់ សហឧក្រិដ្ឋកម្មរួមមានចំណុចវិជ្ជមានមួយចំនួន។ ក៏ប៉ុន្តែ ខ្ញុំយល់ថាសហឧក្រិដ្ឋកម្មរួមត្រូវបានផ្តល់និយមន័យទូលាយ និងពង្រីកយ៉ាងឆ្កាំឆ្កងទៅដល់ទិដ្ឋភាពលម្អិតទាំងឡាយនៃទំនួលខុសត្រូវ

---

[475] សូមមើលខាងលើ កថាខណ្ឌ ៣១៩-៣២០។

[476] *Jurisprudence on JCE – revisiting a never ending story*, Wolgang SHOMBURG ចុះថ្ងៃទី 0១ ខែ មិថុនា ឆ្នាំ ២0១0 (មាននៅក្នុងវែបសាយ : http://www.cambodiatribunal.org/assets/pdf/court-filings/ctm_blog_6_1_2010.pdf) ។ សាលដីកា Tolimir (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី 0៨ ខែ មេសា ឆ្នាំ ២0១៥ យោបល់ដាច់ដោយឡែកមួយ ហើយដែលមួយផ្នែកមិនទទួលការយល់ស្របពីលោកចៅក្រម Jean-Claude ANTONETTI ឡើយ, ចំណុច V.C.2. ការអនុវត្តនៅក្នុងតុលាការដទៃទៀត ៖ ឧទាហរណ៍នៃតុលាការកម្ពុជា ទំព័រ ៩៦-៩៨, សាលក្រម Šešelj (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២0១៦, មតិយល់ស្របពីលោកចៅក្រម Jean-Claude ANTONETTI, ប្រធានអង្គជំនុំជម្រះ ភ្ជាប់យោងទៅនឹងសាលក្រម ចំណុច 5.4. តុលាការកម្ពុជានិងទម្រង់ទី៣ នៃសហឧក្រិដ្ឋកម្មរួម ទំព័រ ១៧0-១៧៩។

បុគ្គលផ្នែកព្រហ្មទណ្ឌ រួមបញ្ចូលទាំងវិសាលភាពទីតាំង វិសាលភាពពេលវេលា និងពង្រីកទៅដល់កម្រិតបទល្មើសដែលកើតចេញពីសហឧក្រិដ្ឋកម្មរួមនេះ។ ទម្រង់នៃទំនួលខុសត្រូវព្រហ្មទណ្ឌដែលអនុវត្តទូលាយជាប្រភពនៃការភ័ន្តច្រឡំ នៃការបកស្រាយផ្សេងៗគ្នាហើយជួនកាលខុសរហូតដល់ថ្នាក់ពង្រីកទំនួលខុសត្រូវព្រហ្មទណ្ឌទៅដល់អ្នកចូលរួមនៅថ្នាក់ក្រោមបង្គាប់ ឆ្ងាយតិចឬច្រើន ពីផែនការឧក្រិដ្ឋរួមជាសន្មតនេះ។ សហឧក្រិដ្ឋកម្មរួមក៏ដាក់**អំប្រែកនៃការសន្មតថាមានពិរុទ្ធភាពជាមុន**ទៅលើអ្នកចូលរួមថ្នាក់ខ្ពស់ផងដែរ ក្នុងខណៈដែលផែនការរួមអាចមិនមានចរិតឧក្រិដ្ឋពីដើមទី ប៉ុន្តែផែនការនេះប្រែក្លាយជាមានចរិតឧក្រិដ្ឋវិញក្នុងពេលកំពុងអនុវត្ត ដោយសារភ្នាក់ងារថ្នាក់ក្រោមបង្គាប់ប្រព្រឹត្តហួសហេតុ ឬដោយសារមូលហេតុផ្សេងពីមូលហេតុដែលលើកឡើងពីដើមទីដោយប្រធានរបស់ពួកគេ ហើយថែមទាំងដោយអំពើរបស់អ្នកដឹកនាំដែលធ្វើខុសពីឆន្ទៈសមាជិកក្រុមផ្សេងទៀតតាមរយៈការសម្រេចចិត្តដោយខ្លួនឯងដោយមិនពិភាក្សាជាមុនសិនជាមួយនឹងសមាជិកក្រុមដើម្បីកំណត់គោលជំហរខ្លួន" (មានគូសបន្ទាប់ពីក្រោមនៅច្បាប់ដើម)[477]។ "នៅចុងបញ្ចប់ វាហាក់ដូចជាទស្សនទាននេះមកជួយរដ្ឋអាជ្ញាដែលអន់ខ្សោយ។ តាមការយល់ឃើញរបស់ខ្ញុំ វាមិនមែនជាតួនាទីរបស់ចៅក្រមទេ ដែលត្រូវជាប់**កាតព្វកិច្ចយ៉ាងតឹងរ៉ឹង**ក្នុងការអនុវត្តទម្រង់នៃទំនួលខុសត្រូវជាក់លាក់ដែលមានចែងនៅក្នុងលក្ខន្តិកៈ និងមិនត្រូវបង្កើតទ្រឹស្តី ឬក៏ផ្តល់សម្មតិកម្មដើម្បីបំពេញភាពទទេស្អាតនៃការស៊ើបអង្កេត" (មានគូសបន្ទាត់ពីក្រោមនៅក្នុងច្បាប់ដើម)[478]។

## ភាគទី ៤. <u>វិធានច្បាប់ស្តីអំពីការពិនិត្យភស្តុតាង</u>

៥១៧. ក្នុងរាល់រឿងក្តីព្រហ្មទណ្ឌ ការពិនិត្យភស្តុតាងដែលដាក់បង្ហាញ ត្រូវតែកំណត់ដោយវិធានដែលត្រូវតែគោរពស្របតាមគោលការណ៍ចំពោះមុខ និងគោលការណ៍សច្ចធារណ៍និរទោស។

៥១៨. ក្នុងរឿងក្តីនេះជាពិសេស វិធានទាំងនេះត្រូវតែគោរពប្រកបដោយមនសិការខ្ពស់ ដោយសារភាពកម្សោយយ៉ាងខ្លាំងនៃភស្តុតាងដែលបានបង្ហាញ ដូចភាពកម្សោយនៃការចងចាំរឿងរ៉ាវដែលបានកើតឡើងកាលពី៤០ឆ្នាំមុន។

៥១៩. លើសពីនេះទៅទៀត ឯកសារដែលតាក់តែងនៅសម័យនោះមាននៅក្នុងសំណុំរឿងក៏មែនពិត ក៏ប៉ុន្តែយើងគប្បីរំឭកថា វាជាឯកសារចម្លងដែលប្រមូលចងក្រងដោយស្ថាប័នក្រៅតុលាការ ជា

---

[477] សាលក្រម Šešelj (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦, មតិយល់ស្របពីលោកចៅក្រម Jean-Claude ANTONETTI, ប្រធានអង្គជំនុំជម្រះ យោងទៅនឹងសាលក្រម ទំព័រ ១៦៩-១៧០។

[478] សាលក្រម Šešelj (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦, មតិយល់ស្របពីលោកចៅក្រម Jean-Claude ANTONETTI, ប្រធានអង្គជំនុំជម្រះ យោងទៅនឹងសាលក្រម ទំព័រ ទំព័រ ១៨៣។

ទូទៅ ក្នុងលក្ខខ័ណ្ឌដែលគេមិនដឹង។ ជាក់ស្តែង តុលាការមានឯកសារច្បាប់ដើមតែពីរច្បាប់ប៉ុណ្ណោះដែលផ្តល់ដោយ Stephen HEDER នៅខែ កក្កដា ឆ្នាំ ២០១៣។[479] ទោះជាមជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារដែលស្ថាប័ននេះចាត់ទុកជាច្បាប់ដើមក៏ដោយ ក៏លោក ឆាង យុក ប្រធានមជ្ឈមណ្ឌលនេះ មិនព្រមបង្ហាញដល់អង្គសវនាការ ក្នុងសំណុំរឿង ០០២/០១ អំពីទីកន្លែងនៃឯកសារច្បាប់ដើមទាំងអស់នេះ។ ប្រការនេះមិនបានរំខានអង្គជំនុំជម្រះទេ ហើយលោកប្រធានថែមទាំងបានប្រកាសថា៖

> "សាក្សីចំពោះសំណួរអម្បាញ់មិញរបស់មេធាវី គឺសាក្សីមិនបាច់ឆ្លើយទេ ដោយសំខាន់នៅក្នុងការអនុវត្តគោលការណ៍នៃការរក្សាការសម្ងាត់សុវត្ថិភាពឯកសារ សំខាន់ថាតើវាពាក់ព័ន្ធនឹងបញ្ហាឯកសារដើម និងឯកសារដែលយកមកប្រើប្រាស់នៅទីនេះ។ ប្រសិនបើភាគីចង់ផ្ទៀងផ្ទាត់ជាមួយនឹងឯកសារដើម តើអាចធ្វើបានដែរឬទេ? នេះជាបញ្ហាសំខាន់ វាមិនមែនសំខាន់ថា ស្គាល់ទីកន្លែងរក្សាទុកដោយសុវត្ថិភាព នៃឯកសារនោះទេ។ ហើយបញ្ហាមួយទៀត គឺបញ្ហាដែលលើកឡើងដោយភាគី ក្នុងការស្នើសុំឱ្យមានសវនាការជាសម្ងាត់នោះ គឺអង្គជំនុំជម្រះយល់ថា មិនចាំបាច់ទេ។[480]"

៥២០. ក្នុងលក្ខណៈដូចគ្នា អង្គជំនុំជម្រះបានបន្តផ្តល់តម្លៃពិសេសទៅដល់ការចំណេញពេលតាមរយៈការអោយសាក្សីអានចម្លើយពីមុនៗរបស់ខ្លួនឡើងវិញមុនពេលពួកគេមកផ្តល់សក្ខីកម្ម ខ្ពស់ជាងការផ្តល់សក្ខីកម្មដោយមិនបាច់ព្រាងទុកនៅក្នុងសាលសវនាការ។ ការអនុវត្តដែលអនុម័តតាំងពីឆ្នាំ ២០១២ ក្នុងសំណុំរឿង ០០២/០១ នេះ បានទទួលការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូល[481] ដែលខ្លួនឯងផ្ទាល់បែរជាមិនគោរពការអនុវត្តនេះនៅពេលដែលខ្លួនស្តាប់សាក្សី[482]។ នៅក្នុងសាលដីកានៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា ខ្លួនយល់ឃើញថា៖

---

[479] អនុស្សរណៈ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ **ឯកសារ E297** (ទស្សនាវដ្តីយុវជនយុវនារីបដិវត្ត មួយលេខ និងទស្សនាវដ្តីទង់បដិវត្ត មួយលេខ)។

[480] ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ **ឯកសារ E1/38.1** ទំព័រ ៩ ប្រហែលម៉ោង 09.28.03។

[481] សាលដីកា ០០២/០១ កថាខណ្ឌ ២៥៧-២៦៩។

[482] សេចក្តីណែនាំនៃតុលាការកំពូល ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ F26** ទំព័រ ៥។

"ការបង្ហាញសាក្សីនូវអ្វីដែលគាត់បាននិយាយពីមុននោះអាចជាការជ្រៀតជ្រែក ឬការបំភាន់ដល់ការចងចាំរបស់សាក្សី និងបំភាន់ការពិត ដោយសារកាត់បន្ថយចម្លើយដែលកើតឡើងដោយឯកឯងក្នុងការផ្តល់ភ័ស្តុតាងនៅក្នុងតុលាការ"[483]។

៥២១. ទោះបីជាខ្លួនបានយល់ឃើញថា "អង្គជំនុំជម្រះសាលាដំបូងគួរតែប្រើប្រាស់វិធីសាស្រ្តមួយដែលខុសប្លែកពីវិធីសាស្រ្ត ដែលមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយការអនុវត្តរបស់កម្ពុជា និងទំនៀមទម្លាប់ច្បាប់ដែលបានអនុវត្តក្នុងប្រព័ន្ធរបស់កម្ពុជា"[484] ក៏អង្គជំនុំជម្រះតុលាការកំពូលមិនបានថ្កោលទោសចំពោះការអនុវត្តរបស់អង្គជំនុំជម្រះ។ យើងមិនយល់ថាតើតាមវិធីណាអង្គជំនុំជម្រះតុលាការកំពូលអាចធ្វើខុសពីនេះ ដើម្បីចេញសាលដីកានៅពេលបញ្ចប់សវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ បើយើងគិតអំពីការប៉ះពាល់ដែលបង្កឡើងដោយការអនុវត្តនេះនៅក្នុងការជំនុំជម្រះសេចក្តី...។

៥២២. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះត្រូវតែទាញផលវិបាកពីបរិបទនៃភាពចន្លោះប្រហោងរបស់ភ័ស្តុតាង និងធ្វើការប្រុងប្រយ័ត្នឱ្យបានទ្វេដង ពេលខ្លួនធ្វើការពិភាក្សាសម្រេច។ វិធីសាស្រ្តនៃការពិចារណាលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ របស់អង្គជំនុំជម្រះ បានទទួលរងទណ្ឌកម្មជាច្រើនអំពីសំណាក់អង្គជំនុំជម្រះតុលាការកំពូល។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សេចក្តីណែនាំអនុវត្តន៍ទៅអង្គជំនុំជម្រះក៏ដោយ ក៏ខ្លួនឯងផ្ទាល់មិនបានគោរពតាមសេចក្តីណែនាំអនុវត្តន៍នេះទេ កាលណាការមិនអនុវត្តតាមនេះជួយសម្រួលដល់ខ្លួន ដើម្បីអាចផ្តន្ទាទោសឱ្យបានច្រើន ស្របតាមបន្ទាត់នយោបាយ។

៥២៣. ដូច្នេះ នៅពេលនេះ យើងមិនមែនរំឭកអំពីវិធានស្តីអំពីភ័ស្តុតាងទេ គឺយើងចង់ពិនិត្យមើលបញ្ហាមួយចំនួន ដែលការដកចេញពីលំអានច្បាប់របស់អង្គជំនុំជម្រះជាការគួរឱ្យភ័យខ្លាចបំផុត ឧទាហរណ៍ដូចជា ចម្លើយជាលាយលក្ខណ៍អក្សរ ពាក្យចចាមអារាម អ្នកជំនាញ ធាតុផ្សំនៃភ័ស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម និងវិមតិសង្ស័យ។

---

[483] សាលដីកា ០០២/០១ កថាខណ្ឌ ២៦៧។

[484] សាលដីកា ០០២/០១ កថាខណ្ឌ ២៦៩។

## ជំពូកទី ១. ចម្លើយជាលាយលក្ខណ៍អក្សរ

៥២៤. យើងគប្បីពិនិត្យលើច្បាប់ដែលអាចអនុវត្តន៍បានចំពោះការពិនិត្យពិចារណាលើចម្លើយជាលាយលក្ខណ៍អក្សរ (ផ្នែកទី I) មុននឹងនិយាយអំពីបញ្ហាប្រតិចារឹកសវនាការនៃសំណុំរឿង ០០២/០១ (ផ្នែកទី II) អំពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ផ្នែកទី III) និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (ផ្នែកទី IV)។

## ផ្នែកទី ១. ច្បាប់ដែលអាចអនុវត្តបានចំពោះការពិនិត្យពិចារណាលើចម្លើយជាលាយលក្ខណ៍អក្សរ

៥២៥. ដោយហេតុថា សិទ្ធិរបស់ជនជាប់ចោទក្នុងការសួរដេញដោលសាក្សីដាក់បន្ទុក[485] ជាសិទ្ធិដ៏សំខាន់ ការទទួលយក និងការពិនិត្យពិចារណាលើចម្លើយជាលាយលក្ខណ៍អក្សរជំនួសការផ្តល់សក្ខីកម្មផ្ទាល់មាត់ត្រូវតែគោរពតាមវិធានច្បាប់មួយដ៏តឹងរ៉ឹង។ នៅពេលដែលពុំមានការតទល់គ្នា ចម្លើយជាជាលាយលក្ខណ៍អក្សរទាំងនេះមានតម្លៃជាភ័ស្តុតាងតិចបំផុត (I) ហើយចម្លើយជាលាយលក្ខណ៍អក្សរមួយចំនួនមិនអាចយកមកប្រើប្រាស់ជំនួសការផ្តល់សក្ខីកម្មផ្ទាល់មាត់ទាល់តែសោះ (II)។

### ១. តម្លៃជាភ័ស្តុតាងតិចបំផុត

៥២៦. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានប្រកាសជាច្រើនដងថា "ក្នុងករណីពុំមានឱកាសពិនិត្យទៅលើប្រភពនៃភ័ស្តុតាង ឬបុគ្គលដែលជាម្ចាស់ភ័ស្តុតាងទាំងនោះ ដូច្នេះ ទម្ងន់នៃភ័ស្តុតាងបែបនេះត្រូវមានតិចតួច"[486]។

---

[485] មាត្រា ១៣-១ នៃកិច្ចព្រមព្រៀងនៃ អ.វ.ត.ក វិធាន ៨៤-១ នៃវិធានផ្ទៃក្នុង, មាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ១៤-៣-ង នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៦-៣-ឃ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

[486] សាលក្រម ០០២/០១ កថាខណ្ឌ ៣៤ និង កំណត់សម្គាល់ជើងទំព័រ ៩៤, សេចក្តីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ **ឯកសារ E96/7** កថាខណ្ឌ ២១-២២, ២៤-២៥, ២៧, ២៩, ៣៤, សេចក្តីសម្រេច ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ **ឯកសារ E299** កថាខណ្ឌ ១៩។

៥២៧. នៅក្នុងសាលដីកានៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសទាក់ទងនឹងប្រធានបទនៃចម្លើយជាលាយលក្ខណ៍អក្សរថា៖

> “ភស្តុតាងនេះមានតម្លៃទាប ដែលជាការពិត អង្គជំនុំជម្រះសាលាដំបូងបានត្រឹមតែទទួលស្គាល់ជាទូទៅ ប៉ុន្តែពុំអាចយកប្រើប្រាស់ជាក់ស្តែងបានឡើយ”[487]។

៥២៨. ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានរំឭកថា៖

> “ភស្តុតាងជាលាយលក្ខណ៍អក្សររបស់សាក្សីដែលពុំបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងពុំត្រូវបានសួរដេញដោលដោយអង្គជំនុំជម្រះ និងភាគីនោះ ជាទូទៅត្រូវតែផ្តល់តម្លៃជាភស្តុតាងទាបជាងភស្តុតាងនៃសក្ខីកម្មដែលសាក្សីបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះ។ លើកលែងតែកំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ជាគោលការណ៍ តម្លៃជាភស្តុតាងទាបត្រូវផ្តល់ចំពោះភស្តុតាងដែលពុំត្រូវបានប្រមូលជាក់លាក់សម្រាប់គោលបំណងនៃការជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌ [...] ទីមួយ នេះគឺដោយសារអង្គជំនុំជម្រះសាលាដំបូងអាចនឹងពុំមានឱកាសក្នុងការវាយតម្លៃលើអត្តចរិតរបស់បុគ្គល ក្នុងអំឡុងពេលផ្តល់សក្ខីកម្ម និងសួរដេញដោលបំភ្លឺលើបញ្ហានានាឡើយ។ ទីពីរ យោងតាមយុត្តិសាស្ត្រដែលគួរឱ្យជឿជាក់បានរបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ការដាក់ពិរុទ្ធភាពពុំអាចផ្អែកតែមួយមុខ ឬដោយពុំបានពិចារណាវែងឆ្ងាយទៅលើភស្តុតាងរបស់សាក្សីណាម្នាក់ដែលភាគីការពារក្តីពុំមានឱកាសសួរដេញដោលឡើយ លើកលែងតែជនជាប់ចោទត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ក្នុងការជំទាស់ភស្តុតាងប្រឆាំងនឹងខ្លួន។ ទីបី ភាពគួរជឿទុកចិត្តបាន ភាពច្បាស់លាស់ និងត្រឹមត្រូវនៃចម្លើយក្រៅតុលាការដែល ប្រមូលបានពីខាងក្រៅក្របខ័ណ្ឌនៃនីតិវិធីរបស់តុលាការ ទទួលរងផលប៉ះពាល់ដោយសារកង្វះទម្រង់បែបបទ និងការធានាបាន”[488]។

៥២៩. អាស្រ័យហេតុដូចនេះ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះត្រូវតែអនុវត្តប្រកបដោយសីលធម៌ខ្ពស់នូវគោលការណ៍ទាំងនេះ ជំនួសឱ្យការគ្រាន់តែប្រកាសវា។

---

[487] សាលដីកា ០០២/០១ កថាខណ្ឌ ៤៣០។

[488] សាលដីកា ០០២/០១ កថាខណ្ឌ ២៩៦ (គ្មានឯកសារយោង)។

## ២. ការហាមឃាត់ប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរមួយចំនួន

៥៣០. ក្នុងសំណុំរឿង ០០២/០១ ដោយភាគច្រើនយកលំនាំតាមវិធាននីតិវិធី និងតាមយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះបានពិចារណាថា ប្រសិនបើចម្លើយដែលពាក់ព័ន្ធនឹងចរិត និងអំពើរបស់ជនជាប់ចោទ និងបញ្ហា “ជាមូលដ្ឋាន” ឬ “ចម្រូងចម្រាស់” ត្រូវតែជាកម្មវត្ថុនៃការសួរដេញដោលដោយជនជាប់ចោទ។ ចម្លើយទាំងនេះអាចត្រូវទទួលយកបាន ប៉ុន្តែ អង្គជំនុំជម្រះត្រូវតែគិតអំពីចម្លើយទាំងនេះនៅពេលខ្លួន “ធ្វើការវាយតម្លៃលើទម្ងន់ភស្តុតាងដែលត្រូវផ្តល់ឱ្យរាល់ចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក” នៅពេលប្រកាសសាលក្រម[489]។

៥៣១. អង្គជំនុំជម្រះបានសម្រេចថា ខ្លួននឹងមិនគិត “ទាល់តែសោះ” អំពីព័ត៌មានពាក់ព័ន្ធជាយថាហេតុទាំងឡាយណាដែលអាចបង្ហាញអំពីអំពើ និងអាកប្បកិរិយាចោទប្រកាន់លើជនជាប់ចោទ ដែលមាននៅក្នុងចម្លើយជាលាយលក្ខណ៍អក្សរ ឬក្នុងប្រតិចារឹករបស់បុគ្គលណាម្នាក់ដែលអាចមានភាពទំនេរមកផ្តល់សក្ខីកម្មនៅក្នុងសវនាការបាន[490]។ ជាក់ស្តែង អង្គជំនុំជម្រះបានពិចារណាថា ធាតុផ្សំទាំងនេះដែលទាក់ទងទៅនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ត្រូវបាន “ហាមឃាត់ដោយច្បាប់” ស្របតាមខ្លឹមសារនៃវិធាន ៨៧-៣-ឃ នៃវិធានផ្ទៃក្នុង កាលណាក្រុមមេធាវីការពារក្តីពុំមានលទ្ធភាពតទល់នឹងសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធ[491]។ អង្គជំនុំជម្រះបានពិចារណាថា ខ្លួនអាចបង្កើតករណីលើកលែងចំពោះគោលការណ៍នេះ ដោយទទួលយកធាតុផ្សំទាំងនេះ ដែលផ្តល់ឱ្យដោយបុគ្គលមិនមានភាពទំនេរ ដោយមូលហេតុដែលមានរៀបរាប់នៅក្នុងវិធាន ៩២ ស្ទួន បី និងស្ទួនបួន នៃវិធាននីតិវិធីអំពីភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី គឺបានន័យថា កាលណាបុគ្គលនោះ៖

- ស្លាប់តាំងពីពេលយកចម្លើយពីគាត់បានហើយ
- លែងអាចរកឃើញ ទោះបីជាយើងស្វះស្វែងអស់លទ្ធភាពហើយក៏ដោយ

---

[489] សេចក្តីសម្រេច ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ **ឯកសារ E299** កថាខណ្ឌ ១៩, ២៣។

[490] សេចក្តីសម្រេច ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ **ឯកសារ E299** កថាខណ្ឌ ២៨។

[491] សាលក្រម ០០២/០១ កថាខណ្ឌ ៣១, សេចក្តីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ **ឯកសារ E96/7** កថាខណ្ឌ ២១-២២។ សេចក្តីសម្រេច ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ **ឯកសារ E299** កថាខណ្ឌ ១៧ និង ២៥។ សូមមើលផងដែរនូវឯកសារដែលបានដាក់ចេញមុននោះ ៖ អនុស្សរណៈ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E434/2** កថាខណ្ឌ ១៥, អនុស្សរណៈ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E319/52/5** កថាខណ្ឌ ២។

- គ្មានលទ្ធភាពផ្តល់សក្ខីកម្មផ្ទាល់មាត់ដោយមូលហេតុសុខភាព
-មិនអាចមកផ្តល់សក្ខីកម្មក្នុងសាលសវនាការដោយមូលហេតុមានការគំរាមគំហែង បំភិត បំភ័យ ឬការដាក់សម្ពាធដទៃទៀតមកលើរូបគាត់”[492]។

៥៣២. អង្គជំនុំជម្រះបានបញ្ជាក់ថា ការអនុវត្តពាក់ព័ន្ធបង្ហាញថា តុលាការមួយទទួលយកចម្លើយប្រភេទនេះ កាលណាតុលាការនេះជឿជាក់ថាបុគ្គលរូបនេះ៖

> “ពិតជាមិនមានលទ្ធភាពមកផ្តល់សក្ខីកម្មផ្ទាល់មាត់ ហើយអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្មដែលបានស្នើឡើងគួរឱ្យទុកចិត្តបាន ហើយទោះជាយ៉ាងនេះក្តី តម្លៃជាភស្តុតាងនៃធាតុផ្សំភស្តុតាងដែលត្រូវបានដាក់បង្ហាញក្នុងទម្រង់នេះ មិនត្រូវបង្កព្យសនកម្មដល់លក្ខខ័ណ្ឌតម្រូវនៃការជំនុំជម្រះសេចក្តីប្រកបដោយយុត្តិធម៌ឡើយ”[493]។

៥៣៣. ក្នុងសាលក្រមនៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានបញ្ជាក់ថាខ្លួនបានធ្វើករណីលើកលែងមួយចំពោះគោលការណ៍នេះពាក់ព័ន្ធនឹងបុគ្គលដែលបានទទួលមរណភាព និងដោយបញ្ជាក់ថាក្នុងស្ថានភាពបែបនេះ “ការសម្រេចលើពិរុទ្ធភាព និងមិនផ្អែកលើចម្លើយបែបនេះទេ”[494]។ ក្នុងសាលដីកាសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សុពលភាពដល់វិធីសាស្ត្រនេះរបស់អង្គជំនុំជម្រះ[495]។

៥៣៤. យើងគប្បីបន្ថែមថា យោងតាមតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ការបដិសេធមិនមកបង្ហាញខ្លួនក្នុងសាលសវនាការ មិនអាចត្រូវបានចាត់ទុកថាជាករណីលើកលែងមួយក្នុងចំណោមករណីលើកលែងទាំងអស់នៃការដកចេញនូវចម្លើយជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដែលមានចែងយ៉ាងម៉ត់ចត់នៅក្នុងវិធាននីតិវិធីស្តីអំពីភស្តុតាង និងដែលអង្គជំនុំជម្រះបានអនុវត្តតាម។ ជាក់ស្តែងអង្គជំនុំជម្រះសាលាឧទ្ធរណ៍

---

[492] សេចក្តីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ **ឯកសារ** E96/7 កថាខណ្ឌ ៣២-៣៣។ សេចក្តីសម្រេច ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ **ឯកសារ** E299 កថាខណ្ឌ ១៧។

[493] សេចក្តីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ **ឯកសារ** E96/7 កថាខណ្ឌ ៣២។

[494] សាលក្រម ០០២/០១ កថាខណ្ឌ ៣១។

[495] សាលដីកា ០០២/០១ កថាខណ្ឌ ២៨៤-២៩៤។

នៃតុលាការនេះបានប្រកាសថា វិធានទាំងនេះចែងអំពីការទទួលយកចម្លើយជាលាយលក្ខណ៍អក្សររបស់បុគ្គលម្នាក់ "ដែលពុំមានលទ្ធភាពសត្យានុម័តិក្នុងការបង្ហាញខ្លួនចំពោះមុខតុលាការ" ប៉ុន្តែមិនមែនអំពីការទទួលយកចម្លើយរបស់បុគ្គលម្នាក់ដែលជាក់ស្តែងមានលទ្ធភាពបង្ហាញខ្លួនចំពោះមុខតុលាការ ពីព្រោះបុគ្គលរូបនេះអាចជ្រើសយកការផ្តល់សក្ខីកម្មចំពោះមុខតុលាការ ប៉ុន្តែមិនត្រូវបានបង្ខំឱ្យមកផ្តល់សក្ខីកម្ម[496]។

៥៣៥. លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងនៃតុលាការនេះបានពិចារណាថា ភាពមិនទំនេរមានន័យថាអសមត្ថភាពក្នុងការផ្តល់សក្ខីកម្មដោយមូលហេតុចាំបាច់បំផុត។ មានការសម្រេចជាពិសេសថាអសមត្ថភាពក្នុងការបញ្ចុះបញ្ចូលមនុស្សឱ្យមកផ្តល់សក្ខីកម្ម មិនមែនជាមូលហេតុគ្រប់គ្រាន់ដើម្បីចាត់ទុកថាបុគ្គលទាំងនេះមិនទំនេរ ស្របតាមខ្លឹមសារនៃល័ក្ខខ័ណ្ឌតម្រូវដ៏តឹងរ៉ឹងនៃវិធាននីតិវិធីស្តីពីភ័ស្តុតាងនោះទេ[497]។

៥៣៦. ការរំឭកអំពីគោលការណ៍ទាំងនេះជាការចាំបាច់ ក្នុងស្ថានភាពដែលអង្គជំនុំជម្រះ ក៏ដូចជាអង្គជំនុំជម្រះតុលាការកំពូលបានប្រាសចាកចេញពីគោលការណ៍ទាំងនេះ ក្នុងសំណុំរឿង ០០២/០១ (ក) និងក្នុងស្ថានភាពដែលយើងមានហេតុផលនៃការភ័យខ្លាចថានឹងមានការងាកចេញពីគោលការណ៍នេះ នៅក្នុងសំណុំរឿង ០០២/០២ (ខ)។

## ក. ការប្រាសចាករបស់អង្គជំនុំជម្រះ និងតុលាការកំពូលក្នុងសំណុំរឿង ០០២/០១

---

[496] សាលដីកា Lukić (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៥៦៥។ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Prlić និងបក្ខពួក IT-04-74-AR73.6, សេចក្តីសម្រេចពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចទទួលយកប្រតិចារឹកស្តាប់ចម្លើយរបស់ Jadranko Prlić ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៨។

[497] រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tolimir, IT-05-88/2-T, *Partial Decision on Prosecution's Rule 92* bis *and 92* ter *Motion for Five Witnesses* ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១០ កថាខណ្ឌ ៣២-៣៣។ *Le Procureur* ***តទល់នឹង*** Popović និងបក្ខពួក, IT-05-88-T, *Decision on the Admissibility of the Borovčanin Interview and the Admendment of the Rule 65* ter *Exhibit List* ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៧ កថាខណ្ឌ ៧៤។

៥៣៧. ដើម្បីជួយសង្គ្រោះដល់សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថា ខៀវ សំផន ទំនងជាបានពន្យល់មូលហេតុនៃការជម្លៀសទីក្រុងភ្នំពេញក្នុងវគ្គសិក្សារៀនសូត្រ អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់សុពលភាពគួរឱ្យខ្មាសអៀនទៅដល់ការប្រើប្រាស់សំណេររបស់ Ben KIERNAN ដែលជាពាក្យចចាមអារ៉ាមទាក់ទងនឹងអំពើ និងអាកប្បកិរិយារបស់ ខៀវ សំផន ក្នុងខណៈដែល Ben KIERNAN ខ្លួនឯងផ្ទាល់បានបដិសេធមិនបង្ហាញខ្លួនចំពោះមុខតុលាការ៖

> "ខៀវ សំផន បានអះអាងថា "ការលើកឡើងដាច់ដោយឡែកមួយ"របស់អង្គជំនុំជម្រះសាលាដំបូងដែលថារូបគាត់បានផ្ដល់យុត្តិកម្មចំពោះការជម្លៀសប្រជាជនចេញពីទីក្រុង ក្នុងអំឡុងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជានោះ គឺបានផ្អែកតែទៅលើភ័ស្តុតាងចចាមអារ៉ាមប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ក្នុងចំណោមភ័ស្តុតាងចំនួន ៤ ដែលអង្គជំនុំជម្រះសាលាដំបូងបានយកមកសំអាងដើម្បីគាំទ្រដល់ការយល់ឃើញរបស់ខ្លួននោះ មានភ័ស្តុតាងមួយជាសៀវភៅដែលនិពន្ធដោយ Ben KIERNAN ដែលបានយោងជាក់លាក់ទៅលើការជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានា ធ្វើជាប្រធានបទនៃវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជា ចំណែកប្រភពផ្សេងទៀតពិពណ៌នាជាទូទៅអំពីការចូលរួមរបស់ ខៀវ សំផន ក្នុងវគ្គទាំងនោះ។ Ben KIERNAN បានដកស្រង់កិច្ចសម្ភាសន៍មួយធ្វើជាប្រភពដែលគាត់បានធ្វើឡើងនៅក្នុងឆ្នាំ ១៩៨០ ជាមួយអ្នកជំនាញរូបវិទ្យាកម្ពុជាម្នាក់ ដែលបានត្រឡប់ពីប្រទេសបារាំងមកប្រទេសកម្ពុជា នៅចុងឆ្នាំ ១៩៧៥។ ទោះជាយ៉ាងណាក្ដី ដូចបានកត់សម្គាល់ខាងលើ ដោយហេតុថា Ben KIERNAN ពុំបានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដូច្នេះ អង្គជំនុំជម្រះពុំគប្បីផ្ដល់ទម្ងន់ធ្ងន់ដល់សៀវភៅរបស់គាត់ឡើយ ជាពិសេស នៅពេលផ្ដល់ការយល់ឃើញដែលពាក់ព័ន្ធទៅនឹងអំពើប្រព្រឹត្តរបស់ ខៀវ សំផន និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់គាត់។ ទោះជាយ៉ាងណាក្ដី គួរតត់សម្គាល់ថា នៅក្នុងសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំដែលមានរយៈពេល ១០ ថ្ងៃក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ នៅវិហារព្រះកែវមរកត (ក្នុងបរមរាជវាំង) ដែលក្នុងអំឡុងពេលនោះ មេដឹកនាំបក្សបានផ្ដល់យុត្តិកម្មចំពោះការជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានា។ ដូច្នេះ មានភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលបង្ហាញថា វគ្គបំពាក់បំប៉នមនោគមន៍វិជ្ជានេះបានរួមបញ្ចូលការធ្វើយុត្តិកម្មចំពោះការជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានា និងថា ខៀវ សំផន បានដឹកនាំវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជាមួយចំនួន។ អាស្រ័យហេតុនេះ ដោយពិចារណាលើភ័ស្តុតាងជារួមពាក់ព័ន្ធទៅនឹងចំណុចនេះ រួមទាំងទម្ងន់ដែលអាចផ្ដល់តិចតួចទៅលើការរៀបរាប់របស់ Ben KIERNAN ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានធ្វើយុត្តិកម្មជម្លៀសប្រជាជនយ៉ាងហោចណាស់ម្ដងនៅក្នុងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជាទាំងនោះ មានភាពសមហេតុផល" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[498]។

[498] សាលដីកា ០០២/០១ កថាខណ្ឌ ១០១៥។

៥៣៨. ក៏ប៉ុន្តែទាំងអង្គជំនុំជម្រះ ទាំងអង្គជំនុំជម្រះតុលាការកំពូលមិនអាចផ្ដល់តម្លៃទាល់តែសោះសូម្បីតែបន្តិចបន្តួចទៅដល់សំណោរនេះរបស់ Ben KIERNAN ក្នុងខណៈដែលគាត់មិនបានមកបង្ហាញខ្លួននៅចំពោះមុខតុលាការ ដោយហេតុថា៖ ១. សំណោរនេះផ្ដោតទៅលើអំពើ និងអាកប្បកិរិយារបស់ ខៀវ សំផន និង ២. Ben KIERNAN មិនទាន់ស្លាប់ ហើយគាត់មិនមែនគ្មានលទ្ធភាពសត្យានុម័តក្នុងការបង្ហាញខ្លួនដោយមូលហេតុចាំបាច់បំផុតណាមួយទាល់តែសោះ[499]។

៥៣៩. លើសពីនេះទៅទៀត អ្វីដែលគាត់និយាយក្នុងសំណោរនេះ ជាពាក្យចចាមអារ៉ាមដែលមិនមានឯកសារគាំទ្រ។ ជាក់ស្ដែង នៅក្នុងភស្តុតាងទាំងអស់ទាក់ទងនឹងចំណុចនេះ មិនដែលមាននិយាយពីការដែល ខៀវ សំផន ទំនងជាបានដឹកនាំវគ្គរៀនសូត្រ និងបញ្ជាក់អំពីមូលហេតុនៃការជម្លៀស (រួមបញ្ចូលទាំងនៅវិហារព្រះកែវមរកតដែល ប៉ុល ពត និង នួន ជា ជាអ្នកបង្រៀន ដូច្នេះជាអ្នកផ្ដល់មូលហេតុដូចដែលមានរៀបរាប់នៅក្នុងសាលក្រម) នោះទេ[500]។

៥៤០. ដូច្នេះ សេចក្ដីសន្និដ្ឋានដែលថា ខៀវ សំផន បានផ្ដល់យុត្តិកម្មពីការជម្លៀសយ៉ាងហោចណាស់ក្នុងវគ្គសិក្សាមួយ គួរតែត្រូវបានចាត់ទុកថាជាការសន្និដ្ឋានព្រាវសុទ្ធសាធ។ សេចក្ដីសន្និដ្ឋានរបស់យើងនេះវិញ វាខុសពីសេចក្ដីសន្និដ្ឋានព្រាវរបស់អង្គជំនុំជម្រះតុលាការកំពូលដែលហ៊ានដល់ជាន់ឈ្លីវិធានជាមូលដ្ឋាននៃរឿងក្ដីព្រហ្មទណ្ឌដើម្បីផ្ដន្ទាទោសឱ្យខានតែបាន។ អត្ដចរិកផក់ឧកាសនិយមនេះ មិនអាចទទួលយកបាននោះទេ។

---

[499] អនុស្សរណៈ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ **ឯកសារ E1/166/1/4** អង្គជំនុំជម្រះបានបញ្ជាក់ច្រានចោលសក្ខីកម្មរបស់លោក Ben KIERNAN បន្ទាប់ពីបានព្យាយាមនិយាយបញ្ចុះបញ្ចូលលោកតាមគ្រប់វិធី ហើយបានប្រកាសជូនដំណឹងថា (ទំព័រ ២)៖ «អង្គជំនុំជម្រះ និងស្ថាប័ននានានៃសហរដ្ឋអាមេរិកដែលបានគាំទ្រដល់ អ.វ.ត.ក បានខិតខំប្រឹងប្រែងរួមគ្នា ដើម្បីទទួលបានសក្ខីកម្មរបស់អ្នកជំនាញរូបនេះ ប៉ុន្តែតាមការពិត អ.វ.ត.ក មានមធ្យោបាយអនុវត្តតិចតួចក្នុងការបង្ខំអ្នកជំនាញដែលមិនសហការនេះ ឱ្យឡើងធ្វើសក្ខីកម្ម» (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[500] សាលដីកា ០០២/០១ កំណត់សម្គាល់ជើងទំព័រ ២៦៩៨ តុលាការកំពូលបានយោងទៅកថាខណ្ឌ ៧៤៣ នៃសាលក្រមដែលសាលក្រមនេះក៏យោងទៅកំណត់សម្គាល់ជើងទំព័រ ២៣៤១ នៃសេចក្ដីអះអាងរបស់លោក ខៀវ សំផន ដែលថាលោកបានចូលរួមប្រជុំនៅក្នុងវត្តព្រះកែវ ហើយនិងសេចក្ដីអះអាងរបស់លោក ភី ភួន ដែលថាលោក ប៉ុល ពត និង លោក នួន ជា បានដឹកនាំវគ្គរៀនសូត្រនៅទីនោះ។

ខ. **ការខ្វាចខ្មៅត្រូវមានការប្រាសចាកពីច្បាប់នៅក្នុងសំណុំរឿង ០០២/០២**

៥៤១. នៅចុងបញ្ចប់នៃសវនាការលើអង្គសេចក្តីលើសំណុំរឿង ០០២ អង្គជំនុំជម្រះបាននិយាយខ្លះៗ ដែលធ្វើឱ្យយើងអាចទស្សន៍ទាយទុកជាមុនថានឹងមានការប្រាសចាកពីវិធានច្បាប់ ដែលអាចនាំឱ្យអង្គជំនុំជម្រះប្រើប្រាស់ដោយខុសច្បាប់នូវចម្លើយជាលាយលក្ខណ៍អក្សរមួយចំនួនស្តីពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ។

៥៤២. នៅថ្ងៃទី ២៣ ខែ វិច្ឆកា ឆ្នាំ ២០១៦ តាមសំណើរបស់សហសហព្រះរាជអាជ្ញាអន្តរជាតិ អង្គជំនុំជម្រះបានទទួលយកចម្លើយជាលាយលក្ខណ៍អក្សរចេញពីសំណុំរឿង ០០៤ ដោយប្រកាសថា៖

> "អង្គជំនុំជម្រះពិចារណាថាឯកសារចំនួនប្រាំដែលផ្តល់ព័ត៌មានតែមួយគត់ និងផ្តល់ចំណុចពាក់ព័ន្ធទៅនឹងដំណាក់កាលនៃការជំនុំជម្រះអំពីការបោសសម្អាតផ្ទៃក្នុង។ ឯកសារមួយក្នុងចំណោមឯកសារទាំងនេះនិយាយយ៉ាងច្បាស់លាស់អំពីមន្ទីរស-២១។ ឯកសារពីរផ្សេងទៀតពាក់ព័ន្ធនឹងអំពើ ឬអកប្បកិរិយារបស់ជនជាប់ចោទ។ ឯកសារពីរទៀតនិយាយអំពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង"[501] (យើងជាអ្នកគូសបន្ទាត់ពីក្រោម)

៥៤៣. នៅថ្ងៃទី ២៩ ខែ វិច្ឆកា ឆ្នាំ ២០១៦ ក្រុមមេធាវីការពារក្តីបានសុំឱ្យអង្គជំនុំជម្រះបំភ្លឺថា តើវាជាការផ្លាស់ប្តូរ១៨០ដឺក្រេនៃយុត្តិសាស្ត្រ ឬក៏ជាការភ័ន្តច្រឡំ ដោយហេតុថាកាលពីបីអាទិត្យមុននេះអង្គជំនុំជម្រះបានសម្រេចជាថ្មីម្តងទៀតថា ភ័ស្តុតាងប្រភេទនេះមិនអាចទទួលយកបានទេ[502]។

៥៤៤. នៅថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៦ បន្ទាប់ពីបានរំឭកយុត្តិសាស្ត្ររបស់ខ្លួន អង្គជំនុំជម្រះបានឆ្លើយថា ឯកសារទាំងនេះអាចយកមកប្រើប្រាស់ដើម្បីបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ "តែក្នុងករណីដែលម្ចាស់ចម្លើយបានមកផ្តល់សក្ខីកម្មក្នុងសវនាការ ដែលប្រការនេះអាចអនុញ្ញាត

---

[501] សេចក្តីសម្រេច ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ** E319/52/4 កថាខណ្ឌ ១៥-ឃ។

[502] សំណើសុំបំភ្លឺរបស់លោក ខៀវ សំផន ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ** E319/52/4/1 ដែលយោងទៅ កំណត់សម្គាល់ជើងទំព័រ ៥ ដែលយោងទៅ អនុស្សរណៈ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ** E434/2 កថាខណ្ឌ ១៥ ដែលយោងទៅសេចក្តីសម្រេច ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ **ឯកសារ** E299 កថាខណ្ឌ ១៧ និង ២៥។

ឱ្យជនជាប់ចោទមានលទ្ធភាពសួរផ្ទុយទៅម្ចាស់ចម្លើយទាំងនេះវិញ”។ អង្គជំនុំជម្រះបានបន្ថែមទៀតថា៖

> “ដូច្នេះ អង្គជំនុំជម្រះសូមទាញចំណាប់អារម្មណ៍ភាគីទាំងអស់លើភាពពាក់ព័ន្ធបន្ថែមនេះ ក្នុងករណីដែលភាគីចង់ដាក់សំណើសុំឱ្យសាក្សីទាំងអស់នេះមកផ្តល់សក្ខីកម្ម។ [...] ទោះជាយ៉ាងណាក្តី នៅពេលសមស្របណាមួយ អង្គជំនុំជម្រះនឹងវាយតម្លៃជាភស្តុតាង និងទម្ងន់នៃកំណត់ហេតុស្តាប់ចម្លើយទាំងនេះ ហើយអវត្តមាននៃការផ្តល់សក្ខីកម្មផ្ទាល់មាត់ក្នុងសវនាការ គឺជាកម្មវត្ថុនៃការពិចារណាដ៏ល្អិតល្អន់ចំពោះបញ្ហានេះ ជាពិសេសប្រសិនបើធាតុផ្សំភស្តុតាងដែលបានផ្តល់ឱ្យមានតែឯង ហើយមិនមានធាតុផ្សំភស្តុតាងផ្សេងទៀតគាំទ្រ”[503]។

៥៤៥. ក៏ប៉ុន្តែ ពីមុនមក អង្គជំនុំជម្រះបានកំណត់យ៉ាងតឹងរ៉ឹងយកថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ ជាកាលបរិច្ឆេទកំណត់ចុងក្រោយ សម្រាប់ស្នើសុំការបង្ហាញខ្លួនរបស់សាក្សីថ្មី[504]។ អាស្រ័យហេតុដូច្នេះ ហើយបានជាការពន្យល់មូលហេតុខាងលើគួរឱ្យភ្ញាក់ផ្អើលដែរ។

៥៤៦. យ៉ាងជាក់ស្បាន់ សហព្រះរាជអាជ្ញាបានសម្រុកចូលទៅក្នុងច្រកដែលបានបើករួចស្រេចនេះ។ នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យស្តាប់សាក្សីថ្មីពីរនាក់ ដែលនិយាយពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ ដែលម្នាក់ជាម្ចាស់ចម្លើយជាលាយលក្ខណ៍ដែលត្រូវបានទទួលយកនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ដោយមូលហេតុថាចម្លើយនេះ “មានភាពពាក់ព័ន្ធបន្ថែម” ទៅនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ[505]។

៥៤៧. នៅព្រឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០១៦ អង្គជំនុំជម្រះបានបើកកិច្ចពិភាក្សានៅក្នុងសវនាការអំពីសំណើមួយនេះ។ នៅក្នុងពេលពិភាក្សា ក្រុមមេធាវីការពារក្តីបានជំទាស់នឹងសំណើនេះ ដោយហេតុផលផ្សេងៗ ជាពិសេសដោយសារសំណើនេះដាក់យឺតពេលជ្រុល[506]។ នៅរសៀលថ្ងៃដដែល អង្គជំនុំ

---

[503] អនុស្សរណៈ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ** **E319/52/5** កថាខណ្ឌ ៣។

[504] អនុស្សរណៈ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E421**; អនុស្សរណៈ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ** **E421/3** (សម្អាងហេតុដែលមាននៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E421/4**)។

[505] សំណើរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E452**។

[506] ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/514.1** ទំព័រ ៣-១៧ ពីម៉ោង 09.16.30 ដល់ម៉ោង 09.59.10។

ជម្រះបានបដិសេធសំណើនេះ ដោយខ្លួនយល់ឃើញថា "វាមិនមែនជាពេលវេលាសមស្រប"[507]។ នៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៧ អង្គជំនុំជម្រះបានផ្តល់សំអាងហេតុនៃការបដិសេធនេះ ដោយមូលហេតុថាសំណើនេះមិនត្រូវបានដាក់មុនថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ និងដោយមូលហេតុថាខ្លួនមិនជឿជាក់ថាសក្ខីកម្មរបស់សាក្សីទាំងនេះ មានសារៈសំខាន់រហូតដល់ត្រូវតែកោះហៅពួកគាត់ឱ្យមកបង្ហាញខ្លួនចំពោះមុខតុលាការនោះទេ ទោះបីសំណើនេះត្រូវបានដាក់យឺតពេលក៏ដោយ[508]។

៥៤៨. ទោះបីជានៅទីបញ្ចប់ អង្គជំនុំជម្រះបានប្រញ៉ាប់ប្រញ៉ាលលំបិទច្រកដែលខ្លួនបានបើកយ៉ាងឆ្គាំឆ្គងក៏ដោយ ក៏ពាក្យសម្តីរបស់ចៅក្រម LAVERGNE ក្នុងពេលពិភាក្សាគ្នា នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៦ កាន់តែធ្វើឱ្យយើងខ្លាចក្រែងពីការប៉ុនប៉ងជាសក្តានុពលរបស់អង្គជំនុំជម្រះក្នុងការប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ។ ជាក់ស្តែង បន្ទាប់ពីមានការជំទាស់ពីមេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ចៅក្រម LAVERGNE បានខំធ្វើឱ្យមេធាវីការពារក្តីមានប្រតិកម្ម ដោយប្រកាសថា៖

> "លើកលែងតែខ្ញុំភ័ន្តច្រឡំ ខ្ញុំសូមកត់សម្គាល់ថាសាក្សីទាំងពីររូបដែលមានសំណើសុំឱ្យមកផ្តល់សក្ខីកម្មសុទ្ធតែត្រូវបានសំភាសន៍ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងសូមកត់សម្គាល់ថាការស្តាប់សក្ខីកម្មរបស់គាត់មាននៅក្នុងកំណត់ហេតុដែលត្រូវបានទទួលយក ដូច្នេះកំណត់ហេតុនេះនៅក្នុងសំណុំរឿងហើយ។ បញ្ហាដែលចោទឡើងនោះគឺត្រូវសួរថា តើមានផ្នែកដែលទាក់ទងនឹងតួនាទី... ផ្នែកណាមួយនៃចម្លើយរបស់ពួកគាត់ទាក់ទងនឹងជនជាប់ចោទដែរឬទេ។ ចម្លើយទាំងអស់នេះត្រូវតែមានការសួរតទល់គ្នាជាយថាហេតុ។ ដើម្បីឱ្យច្បាស់ មេធាវី ខៀវ សំផន មិនចង់សួរដេញដោលសាក្សីទាំងនេះទៅលើចម្លើយដែលពួកគាត់បានផ្តល់ជូន និងដែលមាននៅក្នុងសំណុំរឿង"[509]។

៥៤៩. ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បានឆ្លើយតបទាំងហួសចិត្ត និងភាំងស្មារតីថា តាមច្បាប់អង្គជំនុំជម្រះមិនអាចយកមកគិតនូវអ្វីទាំងអស់ដែលទាក់ទងទៅនឹងអំពើរបស់ជនជាប់ចោទនៅក្នុង

---

[507] ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/514.1** ទំព័រ ៧៨ ប្រហែលម៉ោង 15.44.06។

[508] អនុស្សរណៈ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៧ **ឯកសារ E452/1** កថាខណ្ឌ ៣-៤។

[509] ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/514.1** ទំព័រ ១១-១២ ពីម៉ោង 09.40.45 ដល់ម៉ោង 09.42.30។

ចម្លើយជាលាយលក្ខណ៍អក្សរ ហើយដូច្នេះ ក្រុមមេធាវីការពារក្ដីមិនចាំបាច់សួរដេញដោលបុគ្គលទាំងនេះទេ ទោះបីជាកំណត់ហេតុស្ដាប់ចម្លើយរបស់ពួកគេត្រូវបានទទួលយកហើយក៏ដោយ[510]។

៥៥០. វាជាការច្បាស់ណាស់ថា បើអង្គជំនុំជម្រះគ្រាន់តែសម្រេចមិនទទួលយកចម្លើយជាលាយលក្ខណ៍អក្សរទាំងនេះដែលទាក់ទងនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ឬឆ្លើយតបដោយវិជ្ជមានទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០១ ដែលសុំឱ្យលុបព័ត៌មានទាក់ទងនឹងបញ្ហានេះចេញពីចម្លើយជាលាយលក្ខណ៍អក្សរដែលបានស្នើវិញនោះ[511] ប្រហែលជាការច្របូកច្របល់បែបនេះមិនអាចកើតមាននោះទេ។

៥៥១. អង្គជំនុំជម្រះបែរជាបង្គាប់ឱ្យបញ្ចូលទៅក្នុងសំណុំរឿងនូវចម្លើយជាលាយលក្ខណ៍អក្សរឱ្យបានច្រើនបំផុតក្នុងពេញមួយដំណើរការជំនុំជម្រះសេចក្ដី ទោះបីជាតម្លៃជាភ័ស្ដុតាងនៃចម្លើយជាលាយលក្ខណ៍អក្សរទាំងអស់នេះមានតិចតួចយ៉ាងណាក៏ដោយ។ ឥឡូវនេះ អង្គជំនុំជម្រះត្រូវធ្វើការបែងចែកវា ដោយចាំបាច់ក្នុងចិត្តនូវវិធានដ៏សំខាន់ និងត្រូវតែគោរពនេះ ដែលខ្លួនឯងផ្ទាល់បានរំឭកជាច្រើនដង។ យោងតាមវិធាននេះ ទោះជាក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះមិនអាចប្រើប្រាស់ចម្លើយទាំងអស់នេះ ដើម្បីបង្ហាញអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទបានឡើយ។

## ផ្នែកទី ២ .ប្រតិចារឹកសវនាការនៃសំណុំរឿង ០១/០០២

៥៥២. ដោយហេតុថាមានការបំបែកកិច្ចដំណើរការនីតិវិធី សំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ជាសំណុំរឿងពីរដាច់ពីគ្នា[512]។ អាស្រ័យហេតុដូចនេះ ប្រតិចារឹកសវនាការនៃសំណុំរឿង ០០២/០១ គឺជាចម្លើយជាលាយលក្ខណ៍អក្សរនៅក្នុងសំណុំរឿង ០០២/០២។ មានតែករណីលើកលែងពីរតែប៉ុណ្ណោះ៖

- កាលណាបុគ្គលដែលបានផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ បានត្រលប់មកផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២

---

[510] ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/514.1** ទំព័រ ១២ ពីម៉ោង 09.42.30 ដល់ម៉ោង 09.44.17។

[511] សេចក្ដីសម្រេច ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ **ឯកសារ E299** កថាខណ្ឌ ២៤។

[512] សេចក្ដីសម្រេចនៃតុលាការកំពូល ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ **ឯកសារ E301/9/1/1/3** កថាខណ្ឌ ៤២។

- កាលណាបុគ្គលដែលបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងបញ្ហាដែលត្រូវពិនិត្យពិចារណានៅក្នុងសំណុំរឿង ០០២/០២ ហើយអាចត្រូវបានសួរដេញដោលលើបញ្ហាទាំងនេះ។

៥៥៣. ករណីលើកលែងទាំងនេះត្រូវបានផ្តល់យុត្តិកម្មដោយប្រការថា ទោះបីសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ជាសំណុំរឿងដាច់ពីគ្នាក៏ពិតមែន ក៏ប៉ុន្តែភាគី និងចៅក្រម នៅតែដដែលនៅក្នុងសំណុំរឿងទាំងពីរនេះ។ លើសពីនេះទៅទៀត អង្គហេតុមួយចំនួនដែលត្រូវពិភាក្សាដេញដោលដូចគ្នានៅក្នុងសំណុំរឿងទាំងពីរនេះ។

៥៥៤. ដូច្នេះ នៅពេលដែលបុគ្គលដែលបានមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ត្រឡប់មកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ប្រតិចារឹកសវនាការនៃសក្ខីកម្មរបស់ពួកគាត់ក្នុងសំណុំរឿង ០០២/០១ មិនអាចត្រូវបានចាត់ទុកថាជាចម្លើយជាលាយលក្ខណ៍អក្សរជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់បានឡើយ ប៉ុន្តែវាជាចម្លើយពីមុនៗមក។

៥៥៥. កាលណាបុគ្គលដែលបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ មិនបានត្រឡប់មកផ្តល់សក្ខីកម្មនៅក្នុងសាលសវនាការក្នុងសំណុំរឿង ០០២/០២ ប៉ុន្តែគាត់បានផ្តល់សក្ខីកម្មលើផ្នែកខ្លះនៃប្រធានបទរួមក្នុងសំណុំរឿងទាំងពីរ ហើយត្រូវបានសួរដេញដោលដោយជនជាប់ចោទលើប្រធានបទទាំងនេះ ផ្នែកនៃប្រតិចារឹកសវនាការដែលទាក់ទងនឹងបញ្ហាទាំងនេះ អាចត្រូវចាត់ទុកថាជាសក្ខីកម្មផ្ទាល់មាត់។

៥៥៦. អង្គហេតុរួមដែលត្រូវជំនុំជម្រះនៃសំណុំរឿងទាំងពីរ គឺជាអង្គហេតុទាក់ទងនឹងបរិបទប្រវត្តិសាស្ត្ររចនាសម្ព័ន្ធរដ្ឋបាល រចនាសម្ព័ន្ធទំនាក់ទំនង រចនាសម្ព័ន្ធយោធា ព្រមទាំងតួនាទី និងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ[513]។

---

[513] ឧបសម្ព័ន្ធនៃសំណុំរឿង ០០២/០១ **ឯកសារ E301/9/1.1** ក្នុងឧបសម្ព័ន្ធនេះ អង្គជំនុំជម្រះបញ្ជាក់នៅក្នុងកំណត់សម្គាល់ជើងទំព័រនៃ កថាខណ្ឌ នៃដីកាដំណោះស្រាយ ដែលបានដាក់បញ្ចូលពីលើកមុនក្នុងសំណុំរឿង ០០២/០១។

## ផ្នែកទី ៣. ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

៥៥៧. នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានប្រកាសថា "ចម្លើយ ឬឯកសារដទៃទៀតដែលត្រូវបានប្រមូលចងក្រងក្រៅក្របខ័ណ្ឌស៊ើបអង្កេតដោយអង្គការអន្តរការី ឬអង្គភាពផ្សេងទៀតក្រៅពី អ.វ.ត.ក" មិនអាចសន្មតថាអាចទុកចិត្តបានទេ គឺវាខុសគ្នាពីកំណត់ហេតុស្ដាប់ចម្លើយដែលចងក្រងឡើងក្នុងក្របខ័ណ្ឌតុលាការ។ អង្គជំនុំជម្រះបានបន្ថែមទៀតថា៖

> "ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ដែលភាគច្រើនត្រូវបានធ្វើឡើងដោយអង្គការអន្តរការីផ្សេងៗជួសមុខឱ្យម្ចាស់បណ្ដឹង) ដែលមិនមានភ្ជាប់ព័ត៌មានបង្ហាញអំពីកាលៈទេសៈនៃការចុះឈ្មោះ ក៏អាចដាក់ជូនអង្គជំនុំជម្រះដើម្បីពិភាក្សាដេញដោលក្នុងសវនាការ ប៉ុន្តែត្រូវដឹងថាតម្លៃជាភ័ស្តុតាងរបស់វាអាចតិច (ណាស់) ថែមទាំងមិនមានទៀតផង " (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[514]។

៥៥៨. ដូចដែលយើងបានឃើញខាងលើ[515] អង្គជំនុំជម្រះតុលាការកំពូលបែរជាផ្ដល់សុពលភាពទៅដល់គោលការណ៍ដែលមិនត្រូវបានអនុវត្តក្នុងស្ថានភាពជាក់ស្ដែង។

៥៥៩. នៅក្នុងសំណុំរឿង ០០២/០២ ដើមបណ្ដឹងរដ្ឋប្បវេណី បានមកផ្ដល់សក្ខីកម្មនៅក្នុងសាលសវនាការច្រើនជាងនៅក្នុងសំណុំរឿង ០០២/០១ ឆ្ងាយណាស់។ នេះជាអ្វីដែលអាចបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ឯកសារទាក់ទងនឹងការសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មិនអាចទុកចិត្តបានទាល់តែសោះ។

៥៦០. នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ ពោលគឺប៉ុន្មានសប្ដាហ៍មុនពេលបើកសវនាការលើអង្គសេចក្ដី លោកស្រីមេធាវី Guiraud ជាមេធាវីនាំមុខអន្តរជាតិតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី បានបង្ខំចិត្តទទួលស្គាល់ចំណុចនេះ៖

> "ជាថ្មីម្ដងទៀត ខ្ញុំយល់ស្របជាមួយនឹងមេធាវីការពារក្ដីថា ដល់ពេលណាមួយ យើងជាមេធាវីនាំមុខត្រូវតែបំភ្លឺស្ថានភាពនេះ ពីព្រោះមានកំហុសជាក់ស្ដែង និងច្រំដែលជាច្រើននៅក្នុងទម្រង់បែបបទព័ត៌មានស្ដីអំពីជន

---

[514] សេចក្ដីសម្រេច ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ **ឯកសារ** E96/7 កថាខណ្ឌ ២៩។

[515] សូមមើលខាងលើ កថាខណ្ឌ ៥២៦-៥២៩។

រងគ្រោះ ក៏ដូចជានៅក្នុងព័ត៌មានបន្ថែមដែលបានដាក់ជូនតុលាការ។ យើងក៏ដូចជាភាគីដទៃទៀតដែរ ដល់ទីបញ្ចប់ ទើបយើងដឹងអំពីតថភាព និងវិសាលភាពនៃបញ្ហានេះ"[516]។

៥៦១. ក្នុងពេលជំនុំជម្រះ ឆ្លើយតបទៅនឹងឆន្ទៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលចង់បញ្ជូនពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនពីសំណុំរឿង ០០៣ និង០០៤ ដោយយកលេសថាវាជាឯកសារដោះបន្ទុក (Sic) អង្គជំនុំជម្រះក៏មានឱកាសរំឭកថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមានតម្លៃជាភ័ស្តុតាង "តិចជាង" កំណត់ហេតុស្តាប់ចម្លើយឆ្ងាយណាស់[517]។

៥៦២. នៅពេលជិតបញ្ចប់សវនាការលើអង្គសេចក្ដី លោកស្រីមេធាវី Guiraud នៅបន្តរំឭកថា ទម្រង់បែបបទព័ត៌មាន ត្រូវបានប្រមូលចងក្រងដោយអង្គការមិនមែនរដ្ឋាភិបាល (គឺមិនមែនដោយអ្នកស៊ើបអង្កេតនៃតុលាការទេ) នេះជាមូលហេតុដែលបញ្ជាក់ថា "ពីអង្គការមួយទៅអង្គការមួយសំណួរប្រែប្រួល ខ្លឹមសារនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប្រែប្រួល"[518] ជួនកាល "យើងមិនអាចប្រៀបធៀបពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងលក្ខខ័ណ្ឌដោយឡែកមួយ" ទៅនឹងការផ្ដល់ចម្លើយចំពោះមុខសហចៅក្រមស៊ើបអង្កេតនោះទេ[519]។

៥៦៣. យោងតាមភាពខុសគ្នាយ៉ាងជាក់ស្តែងដែលបានឃើញក្នុងពេលជំនុំជម្រះ រវាងចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសាលសវនាការ និងចម្លើយដែលត្រូវបានប្រមូលចងក្រងក្នុងក្របខ័ណ្ឌនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងលក្ខខ័ណ្ឌ "ដោយឡែក" អង្គជំនុំជម្រះមិនអាចប្រើប្រាស់ឯកសារប្រភេទនេះជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់បានឡើយ ទោះជាប្រើដើម្បីបង្ហាញភាពស៊ីសង្វាក់គ្នាក៏ដោយ។

---

516 ប្រតិចារឹក ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ E1/288.1** ទំព័រ ១៣ ប្រហែលម៉ោង 09.40.50។

517 អនុស្សរណៈ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E319/14/2** កថាខណ្ឌ ៤។

518 ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/467.1** ទំព័រ ៤៨ ពីម៉ោង 11.33.01 ដល់ម៉ោង 11.34.30។

519 ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/488.1** ទំព័រ ៤៧-៤៨ មុនម៉ោង 11.38.51។

### ផ្នែកទី ៤. ចម្លើយរបស់ ស សារិន

៥៦៤. នៅខែ វិច្ឆិកា ឆ្នាំ ២០១៦ ក៏ដូចជាក្នុងសំណុំរឿង ០០២/០១ ដែរ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន បានចាប់ផ្តើមផ្តល់សក្ខីកម្មនៅក្នុងសាលសវនាការ ហើយបន្ទាប់មកបានសម្រេចចិត្តយកលេសមិនបន្តផ្តល់សក្ខីកម្មទៀត ដោយមិនដែលឱ្យក្រុមមេធាវីការពារក្តីសួរដេញដោលគាត់បានទេ។ នៅខែធ្នូ ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានស្តាប់ការកត់សម្គាល់ផ្ទាល់មាត់របស់ភាគី និងបានសុំឱ្យភាគីដាក់សារណាស្តីអំពីការប្រើប្រាស់ចម្លើយរបស់ ស សារិន។

៥៦៥. នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៦ ក្រុមមេធាវីការពារក្តីបានរៀបរាប់អំពីសារបាន និងបាននិយាយលម្អិតជាលាយលក្ខណ៍អក្សរអំពីមូលហេតុដែលត្រូវចាត់ទុកចម្លើយរបស់ ស សារិន ថាជាចម្លើយជាលាយលក្ខណ៍អក្សរដែលមិនអាចផ្តល់តម្លៃជាភ័ស្តុតាងបាន ដោយសារដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមិនគួរឱ្យទុកចិត្តបាន និងជឿជាក់បាន[520]។

៥៦៦. ដោយសារអង្គជំនុំជម្រះបានទទួលសារណាទាំងអស់នេះស្រាប់ហើយ ក្រុមមេធាវីការពារក្តីសុំយោងទៅសារណាទាំងអស់នេះជាលាយលក្ខណ៍អក្សរ ដោយសង្កត់ធ្ងន់លើការដែលថា អវត្តមាននៃការសួរដេញដោល ទោះក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះមិនអាចប្រើប្រាស់ចម្លើយរបស់ ស សារិន ពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទបានឡើយ។

### ជំពូកទី ២. ពាក្យចចាមអារាម

៥៦៧. ទោះជាបានផ្តល់នៅក្នុង ឬនៅក្រៅសាលសវនាការក្តី ចម្លើយជាច្រើននិយាយអំពីអង្គហេតុដែលអ្នកនិយាយមិនមែនជាសាក្សីផ្ទាល់ ដូច្នេះ វាជាពាក្យចចាមអារាម។

៥៦៨. ក្នុងកាលៈទេសៈនេះ ដូចដែលតុលាការកំពូលបានរំឭក ទម្ងន់ និងតម្លៃជាភ័ស្តុតាងដែលត្រូវផ្តល់ឱ្យភ័ស្តុតាងចេញពីពាក្យចចាមអារាម ត្រូវតែតិចជាងទម្ងន់ និងតម្លៃជាភ័ស្តុតាងដែលត្រូវផ្តល់ឱ្យសក្ខី

[520] សេចក្តីសន្និដ្ឋានរបស់លោក ខៀវ សំផន ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E453/1**។

កម្មរបស់សាក្សីដែលបានផ្តល់សក្ខីកម្មក្រោមសម្បថ និងដែលជាកម្មវត្ថុនៃការសួរដេញដោយ។ ទោះបីជាអង្គជំនុំជម្រះត្រូវបានប្រគល់សិទ្ធិអំណាចក្នុងការពិចារណាភ័ស្តុតាងប្រភេទនេះក៏ដោយ ក៏អង្គជំនុំជម្រះត្រូវតែប្រយ័ត្នប្រយែងក្នុងកម្រិតសមស្របមួយដែរ។ ភ័ស្តុតាងមកពីពាក្យចរចាមអារាមមិនច្បាស់លាស់ និងមិនអាចផ្ទៀងផ្ទាត់បាន មិនអាចធ្វើជាបង្អែកនៃការសន្និដ្ឋានណាមួយបានឡើយ[521]។

៥៦៩. ក៏ប៉ុន្តែ នៅក្នុងអំឡុងពេលជំនុំជម្រះសំណុំរឿង ០០២/០២ ទោះបីជាបន្ទុកភ័ស្តុតាងនៃការទទួលខុសត្រូវរបស់ជនជាប់ចោទជាកាតព្វកិច្ចរបស់ខ្លួនក៏ដោយ[522] ក៏សហព្រះរាជអាជ្ញាស្ទើរតែមិនចាប់អារម្មណ៍ទៅនឹងប្រភពនៃចម្លើយតាមពាក្យចរចាមអារាមដែលត្រូវបានស្តាប់នៅក្នុងសាលសវនាការ។ អង្គជំនុំជម្រះក៏មិនសូវចាប់អារម្មណ៍នឹងចំណុចនេះដែរ ទោះបីជាខ្លួនមានកាតព្វកិច្ចស្វែងរកការពិតក៏ដោយ។ ដូច្នេះ អង្គជំនុំជម្រះត្រូវទាញផលវិបាកចេញពីបញ្ហានេះ នៅក្នុងពេលពិភាក្សាសម្រេច។

### ជំពូកទី ៣ .អ្នកជំនាញ

៥៧០. នៅក្នុងអំឡុងពេលជំនុំជម្រះសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មលើប្រធានបទផ្សេងៗរបស់មនុស្សប្រាំបីនាក់ ដែលខ្លួនបានផ្តល់ឋានៈជាអ្នកជំនាញ (Elizabeth BECKER, អ៊ីសា ឧស្មាន, Alexander HINTON, Henri LOCARD, Kasumi NAKAGAWA, Peg LEVINE, Stephen MORRIS និង វឿន វុទ្ធី)។ យោងតាមច្បាប់ដែលអាចអនុវត្តបានចំពោះសក្ខីកម្មរបស់អ្នកជំនាញ (ផ្នែកទី I) អង្គជំនុំជម្រះត្រូវតែកត់សម្គាល់អំពីអវត្តមាននៃការគួរឱ្យទុកចិត្តបាន និងតម្លៃជាភ័ស្តុតាងនៃសក្ខីកម្មមួយចំនួនរបស់ពួកគាត់ (ផ្នែកទី II)។

---

[521] សាលដីកា ០០២/០១ កថាខណ្ឌ ៣០២ (ដែលយោងទៅឯកសារយុត្តិសាស្ត្រជាច្រើននៃសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ)។

[522] វិធាន ៨៧-១ នៃ វិធានផ្ទៃក្នុង។

## ផ្នែកទី ១. ច្បាប់ដែលអាចអនុវត្តបានចំពោះការពិនិត្យពិចារណាលើសក្ខីកម្មរបស់អ្នកជំនាញ

៥៧១. យោងតាមវិធាន ៣១ នៃវិធានផ្ទៃក្នុង៖

> ១. សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចស្វែងរកជំនួយជាមតិយោបល់ពីអ្នកជំនាញអំពីបញ្ហាដែលយល់ឃើញថាមានសារៈសំខាន់ចាំបាច់ដល់ការស៊ើបសួរ ឬកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញ។
>
> ២. អ្នកជំនាញដែលយល់ព្រមចំពោះការចាត់តាំង ត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងផ្តល់ជំនួយដល់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដោយស្មោះត្រង់ រក្សាការសម្ងាត់ និងខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព"[523]។

៥៧២. ដោយផ្អែកលើយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះបានប្រកាសថា អ្នកជំនាញ "ត្រូវតែផ្តល់សក្ខីកម្មដោយអព្យាក្រឹត និងសត្យានុម័តិបំផុត"[524]។

៥៧៣. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានលើកឡើងថា ក្នុងករណីខ្លះ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានបដិសេធសំណើកោះហៅអ្នកជំនាញមកផ្តល់សក្ខីកម្ម ដោយមូលហេតុខ្វះការគួរឱ្យទុកចិត្តបាន បង្កមកពីកង្វះភាពមិនលម្អៀង និងឯករាជ្យភាព ឬអាការៈលម្អៀង។ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ការកំណត់បែបនេះត្រូវធ្វើតាមករណីនីមួយៗ ដោយចង្អុលបង្ហាញថា ទោះយ៉ាងណាក្តី ពេលណាភស្តុតាងដែលស្នើឡើងមើលទៅទំនងជាអាចទទួលយកបាន បញ្ហាទាំងនេះត្រូវតែវាយតម្លៃនៅពេលក្រោយ នៅពេលកំណត់ទម្ងន់ភស្តុតាង[525]។

---

[523] សូមមើលផងដែរមាត្រា ១៦២ ដល់ ១៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ជាពិសេស មាត្រា ១៦៣ និង ១៦៤ ដែលចែងថាអ្នកជំនាញត្រូវស្បថថា «ខ្លួននឹងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌។»។

[524] សេចក្តីសម្រេច ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២ **ឯកសារ E215** កថាខណ្ឌ ១៥ និង កំណត់សម្គាល់ជើងទំព័រ ២២។

[525] រឿងក្តីរវាង ព្រះរាជអាជ្ញា តទល់នឹង Popović និងបក្ខពួក, IT-05-88-AR73.2, *Decision on Joint Defence Interlocutory Appeal Concerning the Status of Richard Butler as an Expert Witness* ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៨ កថាខណ្ឌ ២១-២២ និង កំណត់សម្គាល់ជើងទំព័រ ៨៧ និង ៨៨ **ឯកសារ F30/11/1.38**។

៥៧៤. ចាប់តាំងពីសំណុំរឿង ០០២/០១ មក អង្គជំនុំជម្រះបានពិចារណាថា ការរិះគន់ទៅលើភាពអគតិជាយថាហេតុរបស់អ្នកជំនាញពាក់ព័ន្ធនឹង "ការវាយតម្លៃភ័ស្តុតាងរបស់គាត់ គឺមិនមែនពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃសក្ខីកម្មរបស់គាត់ទេ"[526]។

៥៧៥. ម្យ៉ាងទៀត ដោយផ្អែកទៅលើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែរ តុលាការកំពូលបានប្រកាសថា៖

> "យុត្តិសាស្ត្រ និងការអនុវត្តជាអន្តរជាតិបានទទួលស្គាល់ថា សាក្សីជំនាញត្រូវបានប្រើប្រាស់ក្នុងគោលបំណងផ្តល់ចំណេះដឹងឯកទេស ដែលអាចជួយដល់តុលាការអង្គហេតុឱ្យយល់ដឹងអំពីភ័ស្តុតាងដែលបានបង្ហាញ។ យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្ម*មិនអចិន្ត្រៃយ៍*បានបញ្ជាក់ថា តួនាទីរបស់អ្នកជំនាញក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការទាំងនេះ គឺដើម្បីផ្តល់សក្ខីកម្មចំពោះបញ្ហាស្របតាមជំនាញជាក់លាក់របស់ខ្លួន ប៉ុន្តែមិនផ្តល់សក្ខីកម្មលើអង្គហេតុដែលមានជម្លោះ ឬចំពោះអំពើ ឬការប្រព្រឹត្ត ឬការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដូចសាក្សីធម្មតាឡើយ។ យោងតាមមូលហេតុនេះ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងអំពើមនុស្សឃាតដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព ដែលបានផ្អែកតែមួយមុខគត់លើសក្ខីកម្មរបស់សាក្សីជំនាញដែលជាពាក្យចចាមអារ៉ាមតគ្នាពីរជាន់នោះ ត្រូវបានបដិសេធចោលនៅដំណាក់បណ្តឹងសាទុក្ខ។ យុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR បានបញ្ជាក់បន្ថែមទៀតថា នៅចំពោះមុខតុលាការឧក្រិដ្ឋកម្មទាំងនេះ (i) សាក្សីជំនាញត្រូវបានផ្តល់សេរីភាពឆ្លើយទៅតាមជំនាញរបស់ខ្លួន (ii) នៅពេលផ្តល់សក្ខីកម្មលើបញ្ហាក្រៅជំនាញរបស់ខ្លួន សក្ខីកម្មនោះ"នឹងត្រូវចាត់ទុកថា ជាមតិយោបល់ផ្ទាល់ខ្លួនរបស់សាក្សីជំនាញ ហើយនឹងត្រូវថ្លឹងថ្លែងសមស្របផងដែរ" (បញ្ជាក់ថា មតិនេះនៅតែអាចត្រូវបានពិចារណាដោយតុលាការអង្គហេតុ) និង (iii) បុគ្គលនេះអាចមានលទ្ធភាពដើរតួនាទីជាសាក្សីជំនាញផង និងតួនាទីរបស់សាក្សីអង្គហេតុផងដែរ។
>
> [...] ដូចបានកត់សម្គាល់ខាងលើ ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសក្ខីកម្មរបស់អ្នកជំនាញដើម្បីឈានទៅធ្វើការសន្និដ្ឋានអំពីអង្គហេតុណាមួយ *តាមធម្មតា* ពុំត្រូវបានហាមឃាត់ ដរាបណាតួនាទីរបស់អ្នកជំនាញ ត្រូវបានកម្រិតត្រឹមជួយដល់តុលាការអង្គហេតុក្នុងការ"ស្វែងយល់អំពីភ័ស្តុតាងដែលបានបង្ហាញក្នុងអំឡុងពេលនៃការជំនុំជម្រះ" ដោយពុំក្លាយជាយន្តការសម្រាប់លើកបង្ហាញភ័ស្តុតាងដែលពុំអាចជឿទុកចិត្តបាននោះឡើយ។ អាស្រ័យហេតុនេះ កត្តាជាគន្លឹះក្នុងការវាយតម្លៃអំពីភាពអាចជឿទុកចិត្តបាន និងតម្លៃជាភ័ស្តុតាងនៃសក្ខីកម្មរបស់អ្នកជំនាញ ត្រូវមានការពិនិត្យពិច័យដោយប្រុងប្រយ័ត្នអំពីប្រភព

[526] សេចក្តីសម្រេច ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២ **ឯកសារ E215** កថាខណ្ឌ ១៥ និង កំណត់សម្គាល់ជើងទំព័រ ២២។

ដែលអ្នកជំនាញបានទាញយកមកធ្វើសេចក្តីសន្និដ្ឋាន។ ជាទូទៅ នេះត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលនៃការសួរដេញដោល។ ករណីដែលប្រភពដើមពុំអាចទទួលបាន និងផ្ទៀងផ្ទាត់ពេញលេញ ភ័ស្តុតាងរបស់អ្នកជំនាញនេះត្រូវផ្តល់ទម្ងន់ខ្សោយ ដោយសារលទ្ធភាពត្រូវបានរឹតត្បិតសម្រាប់ភាគី និងតុលាការសួរដេញដោលលើការសន្និដ្ឋានរបស់អ្នកជំនាញនោះ” (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[527]។

៥៧៦. តុលាការកំពូលបានបន្តទៀតថា៖

“ការវាយតម្លៃដោយប្រុងប្រយ័ត្នលើប្រភពរបស់អ្នកជំនាញ ជាការសមស្រប ជាពិសេស [...] តុលាការអង្គហេតុពិចារណាលើភ័ស្តុតាងដែលបានផ្តល់ដោយអ្នកជំនាញផ្នែកប្រវត្តិសាស្ត្រ [...] ព្រោះចំណេះដឹងរបស់អ្នកជំនាញនេះ និងការវិភាគ [...] ស្មើរតែដូចគ្នានឹងការពិចារណារបស់ចៅក្រមដែលពាក់ព័ន្ធនឹងរឿងក្តីបច្ចុប្បន្នដែរ”[528]។

## ផ្នែកទី ២. អវត្តមាននៃភាពគួរឱ្យទុកចិត្តបាន និងតម្លៃជាភ័ស្តុតាងនៃសក្ខីកម្មរបស់អ្នកជំនាញមួយចំនួន

៥៧៧. យោងតាមអ្វីដែលយើងបានបង្ហាញកន្លងមក ដូច្នេះ អង្គជំនុំជម្រះត្រូវតែប្រយ័ត្នប្រយែងឱ្យខ្លាំងបំផុតក្នុងការវាយតម្លៃលើតម្លៃជាភ័ស្តុតាងនៃសក្ខីកម្មរបស់អ្នកជំនាញទាំងប្រាំបីនាក់ ដែលខ្លួនបានស្តាប់នៅក្នុងសំណុំរឿង ០០២/០២ ដោយពិនិត្យឱ្យបានម៉ត់ចត់ និងល្អិតល្អន់លើប្រភពនៃសក្ខីកម្មទាំងនេះ ក៏ដូចជាពិនិត្យលើភាពមិនលម្អៀងដែលខ្លួនសន្មតថាមានជាមុន នៅពេលដែលខ្លួនបានសម្រេចចិត្តស្តាប់អ្នកជំនាញទាំងនេះ។

៥៧៨. ខុសពីអ្នកជំនាញ Peg LEVINE ដែលមិនអាចរិះគន់បានទាំងពីរកម្រិត[529] ក៏ប៉ុន្តែយើងគួរកត់សម្គាល់ជាពិសេសថា “អ្នកជំនាញ” បីនាក់ដែលមានប្រភពចោទជាបញ្ហា ស្មើរតែគ្មាន “អព្យាក្រិតភាព និងសត្យានុម័តិបន្តិចណាសោះ”។

---

[527] សាលដីកា ០០២/០១ កថាខណ្ឌ ៣២៨-៣២៩ (គ្មានឯកសារយោង)។

[528] សាលដីកា ០០២/០១ កំណត់សម្គាល់ជើងទំព័រ ៧៩៩។

[529] ប្រតិចារឹក ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/480.1**, ប្រតិចារឹក ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/481.1**, ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/482.1**។ គួរគប្បីកត់សម្គាល់ថា លោកប្រធានមិនដែលសរសើរអ្នកជំនាញនៅពេលគាត់ផ្តល់សក្ខីកម្មចប់ដូចករណីលោកស្រី Peg LEVINE នោះទេ៖ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/482.1** ទំព័រ៩៩ ម៉ោង 11.32.32 («ការមកផ្តល់សក្ខីកម្មរបស់កញ្ញាបណ្ឌិតពីរបីថ្ងៃកន្លងមកនេះប្រកបដោយភាពអត់ធ្មត់

## ១. អ៊ីសា ឧស្មាន

៥៧៩. នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ ក្រុមមេធាវីការពារក្ដីបានជំទាស់ទៅនឹងការស្នើរបស់ព្រះរាជអាជ្ញាឱ្យ អ៊ីសា ឧស្មាន មកផ្ដល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញ។ ក្រុមមេធាវីការពារក្ដីបានលើកឡើងថា ប្រវត្តិនៃការសិក្សាស្រាវជ្រាវរបស់គាត់មិនមានលក្ខណៈជាក់លាក់ ហើយថាគាត់បានធ្វើការយ៉ាងយូរឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា និងសព្វថ្ងៃធ្វើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក។ ក្រុមមេធាវីការពារក្ដីបានគូសបញ្ជាក់ថា គាត់ជាជនជាតិចាម ដែលបានឆ្លងកាត់របបខ្មែរក្រហម ដែលនៅក្នុងរបបនេះគាត់បានបាត់បង់ញាតិមិត្តបងប្អូន។ ប្រការនេះធ្វើឱ្យគាត់មិនអាចមានភាពមិនលម្អៀងក្នុងឋានៈជាអ្នកជំនាញនោះទេ ដោយហេតុថាគាត់ក៏មានឋានៈជាសាក្សីផង និងជនរងគ្រោះផង[530]។

៥៨០. នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានផ្ដល់សំអាងហេតុនៃសេចក្ដីសម្រេចរបស់ខ្លួនក្នុងការស្ដាប់សក្ខីកម្មរបស់ អ៊ីសា ឧស្មាន ក្នុងឋានៈជាអ្នកជំនាញពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិចាម។ អង្គជំនុំជម្រះបានប្រកាសថា ខ្លួននឹងគិតអំពីការចោទប្រកាន់លើភាពអគតិ និងលើឋានៈរបស់គាត់ជាជនរងគ្រោះផង និងជាសាក្សីផង នៅពេលខ្លួនវាយតម្លៃលើធាតុផ្សំភ័ស្ដុតាងដែលបង្ហាញដោយសាមីជន។ អង្គជំនុំជម្រះក៏បានរំឭកផងដែរថា ខ្លួន "មិនជាប់កាតព្វកិច្ចដោយចម្លើយ និងសេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញណាម្នាក់នោះឡើយ។ ចម្លើយ និងសេចក្ដីសន្និដ្ឋានទាំងនេះ ត្រូវតែពិនិត្យស្របតាមវិធានដូចគ្នា និងដោយល្អិតល្អន់ដូចនឹងវិធានដែលអាចអនុវត្តបានចំពោះរាល់ធាតុផ្សំនៃភ័ស្ដុតាងដែលដាក់ជូនចំពោះមុខខ្លួន"[531]។

---

សីលធម៌ និងគុណធម៌ និងវិជ្ជាជីវៈខ្ពស់ ហើយសក្ខីកម្មរបស់កញ្ញាបណ្ឌិតនឹងចូលរួមវិភាគទានសំខាន់ក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។

[530] សេចក្ដីជំទាស់របស់ខៀវ សំផន ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E305/9** កថាខណ្ឌ ៤១-៤២។

[531] សេចក្ដីសម្រេច ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E367** កថាខណ្ឌ ១១-១២ ។

៥៨១. នៅខែ កុម្ភៈ និង មីនា ឆ្នាំ ២០១៦ អ៊ីសា ឧស្មាន បានផ្ដល់សក្ខីកម្មចំនួនបួនថ្ងៃ ក្នុងឋានៈជាអ្នកជំនាញពាក់ព័ន្ធនឹងការប្រព្រឹត្តិទៅលើជនជាតិចាម[532]។

៥៨២. ដូចដែលបង្ហាញខាងក្រោម[533] សក្ខីកម្មរបស់គាត់ធ្វើឱ្យឃើញយ៉ាងជាក់ច្បាស់ថា ការព្រួយបារម្ភរបស់ក្រុមមេធាវីការពារក្ដីមានមូលហេតុយ៉ាងច្បាស់លាស់ និងលើសពីនេះទៅទៀត វាបង្ហាញឱ្យឃើញថា ប្រភពដែលគាត់ប្រើប្រាស់ភាគច្រើនសុទ្ធតែមានបញ្ហាទាំងអស់។

## ២. អ្នកជំនាញ Alexander HINTON

៥៨៣. នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ ក្រុមមេធាវីការពារក្ដីបានជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលសុំឱ្យ Alexander HINTON មកផ្ដល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញ។ ក្រុមមេធាវីការពារក្ដី ថែមទាំងរំឭកទៀតថា គាត់ធ្លាប់មប្រើការឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា នេះជាការបង្កឱ្យមានការសង្ស័យចំពោះភាពមិនលម្អៀងរបស់គាត់។ ក្រុមមេធាវីការពារក្ដីក៏បានរំឭកផងដែរថា អង្គជំនុំជម្រះត្រូវតែគិតអំពីចំណុចនេះ នៅពេលវាយតម្លៃលើសក្ខីកម្មរបស់គាត់ ប្រសិនបើខ្លួនចង់ស្ដាប់សក្ខីកម្មរបស់គាត់[534]។

៥៨៤. នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានផ្ដល់សំអាងហេតុនៃសេចក្ដីសម្រេចស្ដាប់សក្ខីកម្មរបស់ Alexander HINTON ក្នុងឋានៈជាអ្នកជំនាញ "ជាពិសេស ទាក់ទងនឹងបញ្ហាទាំងឡាយណាដែលស្ថិតក្នុងវិសាលភាពនៃការដឹងឮ និងភាពជាអ្នកជំនាញរបស់គាត់ពាក់ព័ន្ធនឹងវិធានការប្រឆាំងនឹងជនជាតិវៀតណាម និងពុទ្ធសាសនិក"។ អង្គជំនុំជម្រះបានធ្វើឱ្យកត់សម្គាល់ថា៖

> "ចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ថា អ្នកជំនាញ 2-TCE-88 ប្រើពាក្យថា "អំពើប្រល័យពូជសាសន៍" នៅក្នុងស្នាដៃនិពន្ធភាគច្រើនរបស់គាត់ នៅពេលយោងដល់ការសម្លាប់រង្គាល។ អង្គជំនុំជម្រះសូមរំឭកថា

---

532 ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/388.1**, ប្រតិចារឹក ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/389.1**, ប្រតិចារឹក ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/407.1**, ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/408.1**.

533 សូមមើលខាងក្រោម កថាខណ្ឌ ១៥៨៨-១៦០៥។

534 សេចក្ដីជំទាស់របស់ ខៀវ សំផន ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E305/9** កថាខណ្ឌ ៣៩-៤០។

មានតែអង្គជំនុំជម្រះមួយគត់ដែលសម្រេចថាតើ ធាតុផ្សំតាមផ្លូវច្បាប់នៃអំពើប្រល័យពូជសាសន៍ ឬ ឧក្រិដ្ឋកម្មផ្សេងៗទៀតដែលត្រូវបានចោទប្រកាន់ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មានអត្ថិភាព និង/ឬ ត្រូវបានបង្ហាញ ឬយ៉ាងណានោះ។ អង្គជំនុំជម្រះក៏រំឭកដែរថា ភ័ស្តុតាង ឬសេចក្តីសន្និដ្ឋានដែលបានធ្វើឡើងដោយអ្នកជំនាញពុំចងកាតព្វកិច្ចអង្គជំនុំជម្រះទេ ហើយថា ភ័ស្តុតាង និងសេចក្តីសន្និដ្ឋានទាំងនេះនឹងស្ថិតក្នុងបញ្ញត្តិនៃវិធានដូចគ្នា និងបើកចំហឱ្យមានត្រួតពិនិត្យដូចគ្នាទៅនឹងផ្នែកភ័ស្តុតាងផ្សេងទៀតដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ"[535]។

៥៨៥. ពីថ្ងៃទី ១៤ ដល់ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ Alexander HINTON បានផ្តល់សក្ខីកម្មរយៈពេលបួនថ្ងៃ ក្នុងឋានៈជាអ្នកជំនាញពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិវៀតណាម និងពុទ្ធសាសនិក[536]។

៥៨៦. ដូចដែលបង្ហាញខាងក្រោម[537] សក្ខីកម្មរបស់គាត់បានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ការព្រួយបារម្ភរបស់ក្រុមមេធាវីការពារក្តីពិតជាមានតិចតួចស្តួចស្តើង និងប្រាសចាកឆ្ងាយពីតថភាពជាក់ស្តែង។ ជាក់ស្តែង នរវិទូរូបនេះមិនត្រឹមតែបង្ហាញភាពអគតិដ៏ច្បាស់ក្រឡែតនោះទេ គឺថែមទាំងបានប្រាប់ថាខ្លួនអលទ្ធភាព ដោយយោងទៅលើវិធីសាស្ត្រនៃការស្រាវជ្រាវផ្នែកនរវិទ្យាក្នុងការបង្ហាញប្រភពមួយចំនួន។ គាត់ថែមទាំងអសមត្ថភាពផ្តល់ប្រភពទាំងនេះ ខណៈដែលគាត់ទាញសេចក្តីសន្និដ្ឋានចេញពីការងារស្រាវជ្រាវរបស់ខ្លួនឯងផ្ទាល់ តែមិនចេញពីការងារស្រាវជ្រាវរបស់អ្នកដទៃ។

### ៣. Henri LOCARD

៥៨៧. នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តីមិនបានលើកឡើងអំពី Henri LOCARD ដែលសហព្រះរាជអាជ្ញាស្នើសុំឱ្យមកផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញ ក្នុង

[535] សេចក្តីសម្រេច ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E388** កថាខណ្ឌ ១៧។

[536] ប្រតិចារឹក ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/401.1**, ប្រតិចារឹក ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/402.1**, ប្រតិចារឹក ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/403.1**, ប្រតិចារឹក ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/404.1**។

[537] សូមមើលខាងក្រោម កថាខណ្ឌ១៩៣៥-១៩៣៦ និង ២២២៦-២២៣៣។

ចំណោមបុគ្គលទាំងឡាយដែល ក្រុមមេធាវីការពារក្ដីជំទាស់ ឬបានសម្ដែងភាពអល់អែក និងប្រុងប្រយ័ត្ន[538]។

៥៨៨. នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានផ្ដល់សំអាងហេតុនៃសេចក្ដីសម្រេចរបស់ខ្លួន ក្នុងការស្ដាប់សក្ខីកម្ម Henri LOCARD ក្នុងឋានៈជាអ្នកជំនាញពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ និងពាក្យស្លោកនយោបាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ដោយចិត្តឯងថា សហព្រះរាជអាជ្ញាបានប្រគល់ភារកិច្ចឱ្យ Henri LOCARD ប្រមូលចងក្រងរបាយការណ៍ជាច្រើនស្ដីអំពីបណ្ដាញមន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ ដោយចំណុចនេះមិនមានរៀបរាប់នៅក្នុងជីវប្រវត្តិដែលគាត់បានផ្ដល់ឱ្យតុលាការ។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានប្រកាសថា៖

> "ទាក់ទិននឹងការព្រួយបារម្ភអំពីភាពលម្អៀងដែលអាចមាន ដោយសារតែការជាប់ពាក់ព័ន្ធរបស់គាត់ជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញានោះ អង្គជំនុំជម្រះរំឭកថា ការជំទាស់នានាប្រសិនបើមាន អំពីឯករាជ្យភាពនិង ភាពមិនលម្អៀងរបស់អ្នកជំនាញ គឺជាបញ្ហាដែលទាក់ទិនទៅនឹងការវាយតម្លៃភ័ស្តុតាងរបស់គាត់។ អង្គជំនុំជម្រះរំឭកផងដែរថា ភ័ស្តុតាង និងសេចក្ដីសន្និដ្ឋានដែលបានធ្វើឡើងដោយអ្នកជំនាញ មិនតម្រូវឱ្យអង្គជំនុំជម្រះត្រូវតែយកតាមនោះទេ ហើយភ័ស្តុតាង និងសេចក្ដីសន្និដ្ឋានទាំងនេះ និងស្ថិតក្រោមបទប្បញ្ញត្តិនៃវិធាន និងការត្រួតពិនិត្យដូចគ្នាទៅនឹងភ័ស្តុតាងផ្សេងៗទៀត ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះផងដែរ។"[539]

៥៨៩. នៅចន្លោះថ្ងៃទី ២៨ ខែ កក្កដា និងថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ Henri LOCARD បានផ្ដល់សក្ខីកម្មរយៈពេលបីថ្ងៃ ក្នុងឋានៈជាអ្នកជំនាញពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ និងពាក្យស្លោកនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ។

៥៩០. ក្នុងពេលផ្ដល់សក្ខីកម្ម ជួនកាល Henri LOCARD បានចេញពីដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្ដល់សក្ខីកម្មលើអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ។ ចម្លើយរបស់គាត់ទាំងអស់លើប្រធានបទនេះ មិនត្រឹមតែត្រូវតែចាត់ទុកថាជាយោបល់ផ្ទាល់ខ្លួន ដែលត្រូវតែវាយតម្លៃក្នុងឋានៈជាយោបល់

---

[538] សេចក្ដីជំទាស់របស់ខៀវ សំផន ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E305/9** កថាខណ្ឌ៣៩-៥០។

[539] សេចក្ដីសម្រេច ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E415**។

ផ្ទាល់ខ្លួនរបស់គាត់ឱ្យស្របទៅតាមយុត្តិសាស្ត្រដែលលើកឡើងដោយតុលាការកំពូលប៉ុណ្ណោះទេ គឺចម្លើយទាំងនេះថែមទាំងបង្ហាញយ៉ាងច្បាស់អំពីភាពអគតិយ៉ាងខ្លាំងរបស់ប្រវត្តិវិទូរូបនេះប្រឆាំងនឹងជនជាប់ចោទ។

៥៩១. ដូចដែលក្រុមមេធាវីការពារក្តីបានបង្ហាញនៅក្នុងសារណាមុនៗ ក្រោយពេលស្តាប់សក្ខីកម្មនេះហើយ[540] ចម្លើយ និងសំណេររបស់ Henri LOCARD ស្តីពីលោក ខៀវ សំផន មិនត្រូវគ្នានឹងប្រភពដែលគាត់បានប្រើ នៅពេលដែលទទួលបានប្រភពទាំងនេះហើយ (ខ)។ ទោះជាក្នុងករណីណាក៏ដោយ ក៏ចម្លើយទាំងនេះខ្វះអព្យាក្រិតភាព និងសត្យានុម័តិយ៉ាងខ្លាំង (ក)។ យើងគប្បីរំឭកក្នុងពេលនេះ អំពីមូលហេតុដែលគ្មានចម្លើយ ឬសំណេរណាមួយរបស់ Henri LOCARD ពាក់ព័ន្ធនឹង ខៀវ សំផន អាចទទួលតម្លៃជាភ័ស្តុតាងណាមួយបានទេ។ អាស្រ័យហេតុដូចនេះ យោបល់អគតិផ្ទាល់ខ្លួនរបស់គាត់ទាំងប៉ុន្មានស្តីពីលោក ខៀវ សំផន ត្រូវតែដកចេញពីការពិភាក្សាសម្រេច។

## ក. ភាពអគតិយ៉ាងខ្លាំង

៥៩២. ពីរបីថ្ងៃក្រោយពេល Henri LOCARD ផ្តល់សក្ខីកម្មចប់ហើយ ក្រុមមេធាវីការពារក្តីបានសុំឱ្យទទួលយកជាភ័ស្តុតាងនូវអត្ថបទពីរ ដែលបោះពុម្ពផ្សាយក្នុងកាសែត Cambodia Daily ដែលដកស្រង់សម្តីដែល Henri LOCARD បានផ្តល់បទសម្ភាសន៍ទៅសារព័ត៌មានបន្តពីអ្វីដែលគាត់បាននិយាយក្នុងសាលសវនាការ (អត្ថបទកាសែតចុះផ្សាយពីថ្ងៃទី ០៣ ដល់ទី ០៦ ខែ សីហា ឆ្នាំ ២០១៦)[541]។ អង្គជំនុំជម្រះបានទទួលយកសំណើនេះ[542]។

៥៩៣. ជាក់ស្តែង នៅពេលចាប់ផ្តើមសវនាការថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ Henri LOCARD បានចោទសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ថា "បានអនុវត្តចំពោះគាត់ [មុននឹងមួយថ្ងៃ]

[540] សំណើរបស់ខៀវ សំផន ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E415/4**។ សំណើរបស់ខៀវ សំផន ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E447/1**។

[541] សំណើរបស់ខៀវ សំផន ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E415/4**។

[542] អនុស្សរណៈ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E415/4/1**។

នូវការធ្វើទារុណកម្មត្រជាក់” ពេលតាំងសំណួរទៅគាត់[543]។ ពេលនោះមេធាវី Anta GUISSÉ ក៏បានសុំឱ្យអង្គជំនុំជម្រះរំឭកទៅអ្នកជំនាញថា មេធាវីគ្រាន់តែបំពេញការងាររបស់ខ្លួនតែប៉ុណ្ណោះ និងថាពាក្យសម្ដីទាំងនេះមិនសមស្របទេ នៅក្នុងស្ថាប័នយុត្តិធម៌។[544]

៥៩៤. ទោះបីមានការរំឭកពីសំណាក់ក្រុមមេធាវីការពារក្ដីដែលខុសពីការរំឭករបស់អង្គជំនុំជម្រះដែលនៅធ្វើមិនដឹង Henri LOCARD មិនត្រឹមតែសុំទោសជាសាធារណៈប៉ុណ្ណោះទេ គឺគាត់ថែមទាំងទៅផ្សព្វផ្សាយទៅកាន់សារព័ត៌មានដោយប្រើពាក្យពេចន៍ជេរប្រមាថក្រុមមេធាវីការពារក្ដីទៀតផង។ ជាក់ស្ដែង តាមពាក្យពេចន៍នៅក្នុងអត្ថបទចុះផ្សាយថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៦៖

> “ដោយមានគេទាក់ទងគាត់បន្ទាប់ពីពេលផ្ដល់សក្ខីកម្មចប់ហើយ លោក Henri LOCARD រិះគន់មេធាវី Anta GUISSÉ និងមេធាវី Victor KOPPE ដែលជាមេធាវីម្នាក់ក្នុងចំណោមមេធាវីទាំងអស់របស់ នួន ជា កាន់តែខ្លាំងទៅទៀត ដោយចាត់ទុកមេធាវីទាំងពីរនាក់ថាជា “ឧក្រិដ្ឋជន” និង “មនុស្សពាលា” ហើយគាត់បានបន្ថែមទៀតថា “មនុស្សទាំងនេះជាឧក្រិដ្ឋជន ពីព្រោះពួកគេធ្វើឱ្យតុលាការខាតបង់ពេលវេលារាប់ម៉ោង រាប់ថ្ងៃ រាប់សប្ដាហ៍ និងរាប់ខែ”។ “តុលាការមិនគួរចំណាយពេលលើសពីបីឆ្នាំទេ ប៉ុន្តែតុលាការអូសបន្លាយពេលវេលាដោយសារតែមនុស្សខូចដ៏កំណាចទាំងនេះ ដែលយើងហៅថាពួកអវិជ្ជមាន ពួកអវិជ្ជមាននិយមដែលមិនទទួលស្គាល់ការពិត”។ ប្រវត្តិវិទូរូបនេះក៏បានចោទប្រកាន់ក្រុមមេធាវីការពារក្ដីថា បានយកសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីខ្មែរ “មកលេងសើច”។
>
> គាត់បានលើកឡើងថា៖ “ខ្ញុំរំពឹងរង់ចាំហេតុការណ៍ហ្នឹងរួចស្រេចហើយ ហើយខ្ញុំដឹងថាត្រូវការពារខ្លួនខ្ញុំយ៉ាងម៉េច។ ប៉ុន្តែ ខ្ញុំគិតទៅដល់ជនជាតិខ្មែរដ៏កម្សត់ដែលមិនបានសិក្សារៀនសូត្របានជ្រាលជ្រៅ ដែលមិនមានសមត្ថភាពតតាំងដូចខ្ញុំ ហើយបាត់បង់សមត្ថភាពតតាំង និងមួរម៉ៅខកចិត្តយ៉ាងខ្លាំង ដោយសារធ្វើអ្វីគេមិនកើត”[545]។

៥៩៥. បន្ទាប់ពីការបោះពុម្ពផ្សាយនៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៦ នៃសេចក្ដីប្រកាសសារព័ត៌មានមួយរបស់អង្គភាពគាំពារការការពារក្ដីនៃតុលាការខ្មែរក្រហម ដែលបដិសេធចំពោះពាក្យសម្ដីទាំងនេះ

---

[543] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/453.1** ទំព័រ ៣ ក្រោយម៉ោង 09.05.13។

[544] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/453.1** ទំព័រ ៤-៥ ចន្លោះម៉ោង 09.07.06 ដល់ 09.09.51។

[545] ប្រវត្តិវិទូជនជាតិបារាំងចោទប្រកាន់មេធាវីនៃតុលាការខ្មែរក្រហមថាបានធ្វី “ទារុណកម្មធម៌ត្រជាក់” មកលើរូបគាត់៖ អត្ថបទរបស់ George WRIGHT, *Cambodia Daily* ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E3/10649**, ERN FR 01325397។

និងដែលរំឭកអំពីសារៈសំខាន់របស់ក្រុមមេធាវីការពារក្តីដើម្បីឱ្យមានការគោរពនីតិវិធីប្រកបដោយយុត្តិធម៌ Henri LOCARD កាន់តែខ្លាំងលើសដើមទៀត។ គាត់មិនត្រឹមតែរក្សាពាក្យសម្តីដែលនិយាយកន្លងមករបស់គាត់ទេ គឺគាត់ថែមទាំងជេរប្រមាថជាថ្មីទៀតចំពោះក្រុមមេធាវីការពារក្តី និងជនជាប់ចោទផ្ទាល់តែម្តង។ ជាក់ស្តែង ពាក្យពេចន៍ដែលមានសរសេរក្នុងអត្ថបទចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៦ មានដូចតទៅនេះ៖

> "លោក Locard នៅតែប្រកាន់ជំហរទៅតាមការអះអាងមុនៗរបស់គាត់ និងបានចោទប្រកាន់ថាមេធាវីមានបំណងលាក់បាំងការពិតអំពីរបប ប៉ុល ពត។
>
> លោក Locard បាននិយាយថា "ជាពិសេស នួន ជា ដែលមេធាវីការពារក្តីហាក់ដូចជាមានការភ័យខ្លាចចំពោះអ្វីដែល [ចុងចោទ] និយាយ រហូតមើលទៅហាក់ដូចជាពួកគេជំរុញឱ្យកូនក្តីរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ពួកគេធ្វើអ្វីៗទាំងអស់ដើម្បីលាក់បាំងការពិត ជាជាងលាតត្រដាងការពិត"។
>
> ដោយលើកឡើងនូវវិធីសាស្ត្រមួយចំនួនជាយោបល់ដល់មេធាវី ដើម្បីការពារកូនក្តីរបស់ខ្លួន លោក Locard បានផ្តល់យោបល់ថា ពួកគេគួរតែយល់ស្របឱ្យមានការវាយតម្លៃរបស់អ្នកជំនាញចិត្តសាស្ត្រចំពោះអតីតមេដឹកនាំខ្មែរក្រហម។
>
> គាត់បាននិយាយថា "ពួកគេគួរតែទទួលយកការពិនិត្យផ្នែកចិត្តសាស្ត្រចំពោះកូនក្តីរបស់ខ្លួន។ ជាក់ស្តែង លោកអ្នកឮការលើកឡើងមួយចំនួនរបស់ នួន ជា ដែលកន្លងមកខ្ទុយពីការពិត ដែលថា បានឃើញផែនការក្បត់របស់ខ្មាំងពិតជាមាននៅគ្រប់ទីកន្លែង។ យើងគួរមានការសង្ស័យអំពីភាពសមហេតុសមផលនៃការលើកឡើងទាំងនោះ"។"[546]

៥៩៦. ពាក្យសម្តីទាំងអស់នេះបង្ហាញថា Henri LOCARD មិនមានសមត្ថភាពផ្តល់សក្ខីកម្មដោយអព្យាក្រឹត្យ និងសត្យានុម័តិទាំងស្រុង និងមិនគោរពសម្បថដែលថាជួយអង្គជំនុំជម្រះដោយស្មោះត្រង់ និងឱ្យអស់ពីសមត្ថភាពខ្លួន[547]។ ប្រការនេះស្តែងចេញយ៉ាងច្បាស់ពីអាកប្បកិរិយារបស់គាត់នៅក្នុងសាលសវនការ។

---

[546] អង្គភាពគាំពារការពារក្តីបដិសេធការអះអាងថាមេធាវីជាឧក្រិដ្ឋជន George WRIGHT, *Cambodia Daily* ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E3/10653**, ERN EN 01321131 (មេធាវីការពារក្តីបានស្នើសុំឱ្យបកប្រែអត្ថបទខ្លីនេះជាភាសាខ្មែរ និងភាសាបារាំង ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦។ បច្ចុប្បន្ននេះ មានតែការបកប្រែជាភាសាខ្មែរទេ។)។

[547] ប្រតិចារឹក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/450.1** ទំព័រ ៣១ ក្រោយម៉ោង 10.51.18។

៥៩៧. ទោះបីជាចូលមកដល់សាលសវនការភ្លាម Henri LOCARD គោរពមនុស្សទាំងអស់គ្នាលើកលែងតែក្រុមមេធាវីការពារក្តី[548] ហើយគាត់បានប្រកាន់ជំហរមិនឆ្លើយទៅនឹងសំណួរមេធាវីការពារក្តីដោយចេតនាល្អដូចគ្នាដែរ ពីព្រោះអត្តចរិតរបស់គាត់ខុសយ៉ាងច្បាស់ក្រលែតនៅពេលដែលគាត់ឆ្លើយទៅចៅក្រម និងភាគីដទៃទៀត។ ជាកស្តែង គ្រាន់តែក្រុមមេធាវីការពារក្តីសួរសំណួរដ៏ងាយស្រួល និងសមស្របអំពីប្រវត្តិរបស់គាត់ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវរបស់គាត់ និងប្រភពនៃការសន្និដ្ឋានរបស់គាត់ Henri LOCARD បដិសេធមិនឆ្លើយឱ្យចំនឹងសំណួរ ឬថែមទាំងមិនឆ្លើយនឹងសំណួរតែម្តង។

៥៩៨. ឧទាហរណ៍ គាត់ឆ្លើយទៅនឹងសហមេធាវីអន្តរជាតិរបស់លោក នួន ជា ដូចតទៅនេះ៖

> "លោកមេធាវី ខ្ញុំសោកស្តាយណាស់ ប៉ុន្តែខ្ញុំគិតថាអ្នកដែលកំពុងស្តាប់ខ្ញុំនៅពីក្រោយខ្ញុំខាតពេលវេលានឹងការស្តាប់សវនាការនេះ ពីព្រោះលោកចោទសំណួរអត់ប្រយោជន៍។ លោកទើបតែនឹងនិយាយប្រាប់ខ្ញុំថាលោកមានពេលវេលាតិច។ ដូច្នេះ បើលោកមានពេលវេលាតិច សូមលោកចោទសំណួរដែលពាក់ព័ន្ធមកចុះ។"[549]
> "សំណួរនេះមិនពាក់ព័ន្ធ ដូច្នេះខ្ញុំមិនចាំបាច់ឆ្លើយទេ។"[550]
> "ខ្ញុំមិនមែនមកទីនេះដើម្បីកាត់សេចក្តីលើមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ។ ខ្ញុំមកទីនេះដើម្បីចូលរួមការជំនុំជម្រះសេចក្តីលើរបបកម្ពុជាប្រជាធិតេយ្យ និងមេដឹកនាំរបបនេះ[551] (ក្នុងខណៈដែលពេលមុននឹង គាត់បានរិះគន់ដោយឯកឯង មជ្ឈមណ្ឌលឯកសារកម្ពុជានៅពេលដែលគាត់ឆ្លើយតបទៅអង្គជំនុំជម្រះ)។"[552]
> "សំណួរនេះច្រំដែល ខ្ញុំបានឆ្លើយទៅនឹងសំណួរនេះហើយៗ"[553]
> "រយៈកាលក្រោយឆ្នាំ១៩៧៩ មិនស្ថិតក្នុងវិសាលភាពនៃរឿងក្តីនេះទេ។"[554]។

៥៩៩. គាត់ឆ្លើយតបទៅនឹងមេធាវីអន្តរជាតិ ខៀវ សំផន ដូចតទៅនេះ៖

---

[548] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ** E1/453.1 ទំព័រ៥ មុនម៉ោង 09.09.52។

[549] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ** E1/452.1 ទំព័រ១៦-១៧ មុំម៉ោង 09.51.32។

[550] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ** E1/452.1 ទំព័រ១៧ មុនម៉ោង 09.52.38។

[551] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ** E1/452.1 ទំព័រ ៣២ មុំម៉ោង 11.00.36។

[552] ប្រតិចារឹក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ** E1/450.1 ទំព័រ៤២, ចន្លោះម៉ោង 11.27.00 ទំព័រ៦៦ ចន្លោះម៉ោង 14.39.11 និង 14.40.43។

[553] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ** E1/452.1 ទំព័រ៣៥ ក្រោយម៉ោង 11.09.10។

[554] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ** E1/452.1 ទំព័រ៣៩, ម៉ោង 11.22.45។

"ជាបឋម គេបានសួរខ្ញុំរួចហើយពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំបានឆ្លើយរួចហើយ។ ដូច្នេះ វាជាសំណួរច្រំដែល។ ហើយលោកស្រីថាពេលវេលារបស់លោកស្រីមានតម្លៃ។"[555]

"លោកស្រីមេធាវី ខ្ញុំសុំទោស ខ្ញុំដូចជាបានឆ្លើយទៅនឹងសំណួរនេះរួចហើយ។ ដូច្នេះវាជាសំណួរជាន់គ្នា។"[556]

"ដូច្នេះអ្វីដែលខ្ញុំនឹងពន្យល់ទៅលោកស្រី ខ្ញុំសូមមើលនាឡិកាខ្ញុំសិន យើងអស់ពេលបាត់ទៅហើយ។"[557]។

៦០០. យើងអាចគិតថាឥរិយាបថការពារខ្លួនរបស់ Henri LOCARD ជារោគសញ្ញានៃអារម្មណ៍មានវិបត្តិដែលមិនអាចប្រកែកបានក្នុងការឆ្លើយតបទៅនឹងសំណួរទាក់ទងវិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវ និងទាក់ទងនឹងប្រភពដើមជាក់លាក់នៃប្រភពរបស់គាត់។ អាស្រ័យហេតុដូចនេះ ការសួរសំណួររបស់មេធាវីការពារក្ដីបានផ្ទុះបញ្ចាំងយ៉ាងច្បាស់អំពីអវត្តមាននៃមូលដ្ឋានម៉ត់ចត់ រឹងមាំនៃការសន្និដ្ឋានជាច្រើនរបស់ "អ្នកជំនាញ" លើជនជាប់ចោទ។

៦០១. ទាក់ទងនឹងលោក ខៀវ សំផន ក្នុងករណីខ្លះ Henri LOCARD បានបង្ខំចិត្តទទួលស្គាល់។ ឧទាហរណ៍ មាន "កំហុស" នៅក្នុងអ្វីដែលគាត់កំណត់ថាជា "ការអះអាងដាច់ខាតដោយមិនបើកឱ្យមានការសួរដេញដោល និងមានលក្ខណៈទូទៅ"[558] ដែលថាគាត់ "ប្រហែលជាមិនគួរលើកឡើងពីចំណុចនេះទេ"[559] ឬក៏លើសពីនេះទៅទៀត "វាពិតណាស់គឺជាការសន្និដ្ឋានព្រាវ"[560]។

---

[555] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ៧១, មុំម៉ោង15.24.55។

[556] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/453.1** ទំព័រ៩ មុំម៉ោង 09.21.09។

[557] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/453.1** ទំព័រ១២, ម៉ោង 09.31.30។

[558] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ៦៨, មុំម៉ោង 15.16.07, ទំព័រ៦៨, ក្រោយម៉ោង 15.13.57 : គឺជាការអះអាងថាខៀវ សំផនជាអ្នកទទួលខុសត្រូវផ្នែកនេះរបស់រដ្ឋាភិបាល ទទួលបន្ទុកខាងពន្ធនាគារ)។

[559] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ៧១, ក្រោយម៉ោង 15.24.55 (ទំព័រ១១២, មុនម៉ោង 15.23.15៖ គឺជាការអះអាងថាខៀវ សំផន នៅពេលបង្រៀនសេដ្ឋកិច្ចនយោបាយនៅសាកលវិទ្យាល័យភ្នំពេញ ជារឿយៗ គាត់មានអកប្បកិរិយារម៉ាំងរម៉ោកជាមួយនិស្សិតអឺរ៉ុប ឬបរទេស ហើយរំលឹកថាគាត់មកបង្រៀនតែកូនសិស្សខ្មែរទេ។ ត្រូវតែជម្រះសម្អាតសង្គមខ្មែរពីពួកពុករលួយទាំងអស់ដែលមកក្រៅ។ »)។

[560] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/453.1** ទំព័រ១៣, មុំម៉ោង 09.19.02 (ទំព័រ 8-11, ចាប់ពីម៉ោង 09.10.47៖ គឺជាការអះអាងរបស់ស្ទួង ស៊ីគឿនដែលលើកឡើងថាមុខការរបស់ម្នាក់ៗមិនត្រូវបានកំណត់ច្បាស់លាស់ ឬតឹងរឹង។គាត់ប្រើប្រាសការអះអាងនេះដើម្បីគាំទ្រដល់សេចក្ដីសន្និដ្ឋានរបស់គាត់ដែលថាមានការលំបាកក្នុងការកំណត់តួនាទីជាក់លាក់របស់ខៀវ សំផន នៅក្នុងគណៈមជ្ឈិមបក្ស ដោយហេតុថាមុខការរបស់គាត់ប្រែប្រួលទៅតាមស្ថានការ។)។

៦០២. ក្នុងករណីផ្សេងទៀត ចម្លើយរបស់គាត់បានស្តែងឱ្យឃើញពីភាពរាក់កំផែលនៃមូលដ្ឋានដល់ការអះអាងគាត់។ ឧទាហរណ៍ ការអះអាងដែលថា "អារម្មណ៍រឹងរក់ចំបងរបស់ ខៀវ សំផន ប្រធានរដ្ឋនៃរបបនេះ គឺបោសសម្អាតសង្គមខ្មែរ" (យើងជាអ្នកគូសបន្ទាត់ពីក្រោម) មានមូលដ្ឋានលើ "ប្រភព" ពីរពាក់ព័ន្ធនឹងទស្សវត្សឆ្នាំ៦០ ៖ ១. ពាក្យសម្តីរបស់អតីតនិស្សិតរបស់លោក ខៀវ សំផន ដែលថា ក្នុងពេលដែលគាត់បង្រៀនសេដ្ឋកិច្ចនយោបាយ គាត់រិះគន់របបពុករលួយរបស់សីហនុ[561] និង ២. ការដែល "មនុស្សភាគច្រើនដឹងឮថា ខៀវ សំផន ត្រូវបានគេហៅថាលោក "ស្អាតស្អំ" "ដែលបដិសេធមិនចូលរួម ឬក៏បណ្តោយឱ្យគេអូសទាញទៅប្រព្រឹត្តអំពើពុករលួយ"[562]។

៦០៣. ដូចគ្នាដែរ ការបន្ថែមនៅក្នុងការបោះពុម្ពផ្សាយថ្មីនៅឆ្នាំ២០១៦ នៃសៀវភៅរបស់គាត់ដែលមានចំណងជើងថា ខៀវ សំផន ក្នុងចំណោមមនុស្សទាំងបីនាក់ "នៅពីក្រោយឆាក[...] មានអំណាចគ្រប់សព្វ និងធ្វើសេចក្តីសម្រេចសំខាន់ៗ" គ្រាន់តែផ្អែកលើពាក្យសម្តីរបស់ សាឡុត បាន ឬ ភី ភួន ដែលនិយាយប្រាប់ Henri LOCARD ថា មុនពេលដណ្តើមបានទីក្រុងភ្នំពេញ "ខៀវ សំផន បានទទួលបន្ទុកខាងភស្តុភារស្រាប់ទៅហើយ ដោយហេតុថាវាជាវិស័យជំនាញដ៏ធំរបស់គាត់។ គេចាត់ទុកគាត់ជាអ្នកទទួលខុសត្រូវខាងចែកចាយអ្វីៗទាំងអស់។ គាត់ជាអ្នកចែកចាយ និងគ្រប់គ្រងការចែកចាយគ្រាប់រំសេវ"[563] លើសពីនេះទៅទៀត គម្លាតយ៉ាងខ្លាំងដែល Henri LOCARD បានធ្វើនៅក្នុងការបោះពុម្ពផ្សាយថ្មីនេះកាន់តែពង្រីកឱ្យធំទៀត តាមរយៈការផ្តល់សក្ខីកម្មក្រោមសម្បថរបស់ សាឡុត បាន នៅក្នុងសាលសវនាការ ដែលបាននិយាយថាគាត់បានឃើញ ខៀវ សំផន ធ្វើបញ្ជីយ៉ាងវែងដែលខ្លួនយល់ឃើញថា វាជាបញ្ជីគ្រាប់រំសេវ។ គាត់ជួយ ពីព្រោះគាត់ចេះសរសេរ[564]។

៦០៤. ក្នុងស្មារតីដូចគ្នាដែរ ទាក់ទងទៅនឹងការបន្ថែមក្នុងការបោះពុម្ពផ្សាយថ្មីឆ្នាំ២០១៦នៃសៀវភៅរបស់គាត់នូវការអះអាងដែលថា "ក្នុងឋានៈជាលេខាគណៈអចិន្ត្រៃយ៍បក្ស ហៅថាមន្ទីរ៨៧០ ខៀវ សំ

[561] ប្រតិចារឹក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/451.1** ទំព័រ២៣-២៤, ចន្លោះម៉ោង10.09.24 និង 10.14.36។

[562] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ៦៩-៧០, ចន្លោះម៉ោង 15.19.00 និង 15.21.00។

[563] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ៧៦-៧៧, ចន្លោះម៉ោង 15.42.00 និង 15.44.00។

[564] ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ **ឯកសារ E1/68.1** ទំព័រ៣៥ បន្ទាត់១៣-១៥ , ក្រោយម៉ោង 11.26.34។

ផន នៅចំណុចស្នូលនៃអំណាចតែម្តង” Henri LOCARD បានឆ្លើយថា គាត់បានអានសៀវភៅរបស់ SHORT ឬ CHANDLER ដែលថា ខៀវ សំផន ទំនងជាបានជំនួស ឌឿន ប៉ុន្តែថាគាត់ “គ្រាន់តែផ្អែកលើការដែល ខៀវ សំផន នៅ ក-៣ ក្នុងអំឡុងរបបនេះតែប៉ុណ្ណោះ”[565]។ ការអះអាងថ្មីនេះពីសំណាក់អ្នក “ជំនាញ” ដែលមិនដែលបានអានកំណត់ហេតុប្រជុំនៃគណៈអចិន្ត្រៃយ៍ និងឯកសារផ្ទៃក្នុងណាមួយរបស់បក្ស[566] កាន់តែលែងអាចទុកចិត្តបានថែមទៀត ដោយហេតុថាគាត់បានឆ្លើយថា “គាត់ពិតជាបានអានយ៉ាងលម្អិតនូវសាលក្រម”នៃសំណុំរឿង ០០២/០១ ក្នុងឆ្នាំ ២០១៤[567]។ ក៏ប៉ុន្តែ នៅក្នុងសាលក្រមនេះ អង្គជំនុំជម្រះថែមទាំងបានពិចារណាថា ទាំង SHORT ទាំង CHANDLER គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងពីរនាក់នេះ “បានរកឃើញឯកសារណាមួយដែលបញ្ជាក់ថា ខៀវ សំផន បានជំនួស ឌឿន ធ្វើជាប្រធានមន្ទីរ៨៧០ ឡើយ”[568]។ ទោះបីជាមានសម្មតិកម្មរបស់អ្នកជំនាញទាំងពីរនាក់នេះក៏ដោយ ក៏តាមការពិនិត្យធាតុផ្សំភ័ស្តុតាងផ្សេងៗទៀត អង្គជំនុំជម្រះបានសន្និដ្ឋានថា “មិនមានការបង្ហាញឱ្យឃើញថា ខៀវ សំផន ធ្លាប់ជាប្រធានមន្ទីរ៨៧០ នៅពេលណាមួយនោះទេ”[569]។

៦០៥. តាមរយៈឧទាហរណ៍ពីរបីនេះ គេអាចយល់បានថា Henri LOCARD ទាល់តម្រិះនឹងសំណួររបស់លោកស្រីមេធាវី Anta GUISSÉ។ ជាការពិតណាស់ នរណាក៏ដោយក៏មានអារម្មណ៍មិនល្អដែរ នៅពេលឃើញការងារស្រាវជ្រាវរបស់ខ្លួនបានចោទជាបញ្ហា។ ក៏ប៉ុន្តែទោះជាយ៉ាងណាក្តី ក៏គ្មានអ្វីដែលអាចបញ្ជាក់អំពីមូលហេតុដែល Henri LOCARD ចោទប្រកាន់មេធាវី Anta

---

[565] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ១២៨-១២៩ , ចន្លោះម៉ោង 15.50.00 និង 15.51.35។

[566] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ៨០, មុំម៉ោង [15.53] ; ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/453.1** ទំព័រ១០, មុនម៉ោង 09.23.20។

[567] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ៧៦-៧៧, មុំម៉ោង 15.38.54 ; និងសូមមើល ប្រតិចារឹក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/450.1** ទំព័រ៣៧, មុំម៉ោង 11.10.32 («ហើយខែនេះមានការបោះពុម្ពផ្សាយលើកទីពីរនៃសៀវភៅនេះជាខ្នាតតូចអាចដាក់ក្នុងហោប៉ៅបាន។ ខ្ញុំបានកែជាច្រើនកន្លែងនៅក្នុងសំណៅបោះពុម្ពថ្មីនេះ។គឺជាកំណែផ្អែកលើអ្វីដែលបាននិយាយនៅក្នុងសាលសវនាការនេះ។ ដូច្នេះ ខ្ញុំគិតថាតុលាការនេះនឹងឆ្លុះបង្ហាញអំពីរបបកម្ពុជាប្រជាធិបតេយ្យជាមួយនឹងពន្លឺថ្មីនេះ។»)។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/450.1** ទំព័រ៤០, មុនម៉ោង 11.21.56 (ហើយទាក់ទងនឹងការបោះពុម្ពផ្សាយថ្មីឆ្នាំ២០១៦នេះដដែល “ខ្ញុំបានប្រឹងប្រែងបន្ថែមព័ត៌មានថ្មីដែលខ្ញុំទទួលបានភាគច្រើនពីការអាន និងពីការងារស្រាវជ្រាវរបស់តុលាការ។»)។

[568] សាលក្រម ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៣៨៨។

[569] សាលក្រម ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៣៨៩។

GUISSÉ ថាបាន "ធ្វើទារុណកម្មគាត់" នៅក្នុងសាលសវនាការ[570]។ ពុំមានអ្វីដែលបញ្ជាក់អំពីមូលហេតុនៃការដែលគាត់ចាត់ទុកមេធាវីការពារក្តីជា "ឧក្រិដ្ឋជន "ជនពាលា" "ពួកអវិជ្ជមាននិយម"[571]។ ពុំមានអ្វីបញ្ជាក់អំពីមូលហេតុនៃការដែលថាពីរបីថ្ងៃក្រោយពេលផ្តល់សក្ខីកម្មរួចហើយ ឬក្រោយពេលមានអារម្មណ៍មួល និងជ្រះស្រឡះហើយ Henri LOCARD ប្រើពាក្យពេចន៍ដ៏គម្រក់ដោយបន្ថែមថាមេធាវីការពារក្តីខំប្រឹងប្រែងរាំងស្ទះមិនឱ្យរកឃើញការពិត ដោយជំទាស់មិនឱ្យមានការពិនិត្យរោគវិកលចរិកទៅលើកូនក្តីរបស់ខ្លួន ដែលមានសតិបញ្ញាគួរឱ្យមន្ទិលសង្ស័យ និងដោយលើកទឹកចិត្តឱ្យពួកគេរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ដោយហេតុថា "ខ្លួនជាមេធាវីភ័យរន្ធត់" ចំពោះអ្វីដែលកូនក្តីរបស់ខ្លួននិយាយ"[572]។

៦០៦. ក្រៅពីការមិនស្គាល់យ៉ាងជាក់ស្បាន់នូវសិទ្ធិរបស់ជនជាប់ចោទក្នុងរឿងក្តីព្រហ្មទណ្ឌ ហេតុផលតែមួយគត់ដែលពន្យល់អំពីខ្លឹមសារ និងភាពធ្ងន់ធ្ងរនៃពាក្យសម្តីរបស់ Henri LOCARD គឺភាពអគតិដែលគាត់ប្រកាន់យកតាំងពីយូរយារណាស់មកហើយប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ គឺភាពអគតិនេះឯង ដែលជាដើមចមនៃភាពរាក់កំភែលនៃការសន្និដ្ឋានប្រញាប់ប្រញាល់ហួសពេករបស់គាត់ទៅលើជនជាប់ចោទ ក៏ដូចជា (ដកស្រង់ពាក្យសម្តីគាត់ផ្ទាល់) "ការអះអាងដាច់ខាតដោយមិនបើកឱ្យមានការសួរដេញដោល" និង "កំហុស" និង "ការសន្និដ្ឋានព្រាវ" របស់គាត់[573]។

៦០៧. បើគ្មានលក្ខណៈសត្យានុម័តិហើយ Henri LOCARD គួរណាតែមានសង្កតភាពនៅក្នុងអ្វីៗដែលគាត់និយាយ។ គាត់បានសម្តែងមតិ និងបុរេវិនិច្ឆ័យអស់ពីពោះ ទៅសារព័ត៌មានក៏ពិតមែន ក៏ប៉ុន្តែមតិយោបល់ និងបុរេវិនិច្ឆ័យទាំងនេះ បានស្តែងចេញជាបន្តបន្ទាប់រួចទៅហើយនៅក្នុងពេលសវនាការ។

---

[570] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/453.1** ទំព័រទី៣-៤, ក្រោយម៉ោង 09.05.11។

[571] ប្រវត្តិវិទូជនជាតិបារាំងម្នាក់ចោទមេធាវីនៅតុលាការខ្មែរក្រហមថាបានប្រព្រឹត្ត "ទារុណកម្មគ្រជាក់មកលើរូបគាត់" អត្ថបទសរសេរដោយ George WRIGHT, *Cambodia Daily* ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E3/10649**, ERN FR 01325397។

[572] អង្គភាពគាំពារការពារក្តីបដិសេធការអះអាងថាមេធាវីជាឧក្រិដ្ឋជន, George WRIGHT, *Cambodia Daily* ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E3/10653**, ERN EN 01321131។

[573] សូមមើលខាងលើនៅកថាខណ្ឌ៦០១។

៦០៨. ឆ្លើយតបនឹងសហព្រះរាជអាជ្ញាដែលអានផ្នែកមួយដែលគាត់បានសរសេរថា មេដឹកនាំខ្មែរក្រហមបានបាត់សុភវិនិច្ឆ័យចំពោះការពិត Henri LOCARD ទប់ខ្លួនមិនបានក្នុងការអត្ថាធិប្បាយក្រៅរឿង ទោះបីជាគាត់មិនមានគុណវុឌ្ឍិទាល់តែសោះនៅក្នុងវិស័យវិកលចរិត និងចិត្តសាស្ត្រ៖

> "[...] អញ្ចឹងសួរថាតើពួកគាត់ឆ្កួត ឬក៏អត់? ខ្ញុំគិតថាមេធាវីការពារក្ដីគួរតែការពារកូនក្ដីខ្លួនដោយបញ្ជាក់ប្រាប់ថាកូនក្ដីខ្លួនឆ្កួត។ ប៉ុន្តែខ្ញុំជឿថា ឥឡូវនេះគេមិនទាន់ជ្រើសរើសផ្លូវនេះទេ។ ពួកគេបានបដិសេធមិនទទួលការពិនិត្យដោយវេជ្ជបណ្ឌិតផ្នែកវិកលចរិត បើតាមខ្ញុំដឹងគឺវាផ្ទុយពី ឌុច។ គួរឱ្យសោកស្ដាយដែរ [...] ហ្នឹងហើយ! វាច្បាស់ណាស់ដែលថាពួកគេទៅតែឯងៗហើយមិនដឹងខ្យល់អ្វីសោះពីតថភាពសង្គម។ ខ្លួនពួកគេចែកជាពីរចំណែកដាច់ពីគ្នាស្រឡះ <u>គឺពួកគេមានជំងឺវិវរវាយមិនអាចបែងចែងតថភាពសង្គមពីរូបភាពដែលលេចធ្លោរចេញពីអារម្មណ៍របស់ពួកគេ (Schizophrenes)</u> ដោយហេតុថានៅក្នុងជីវភាពប្រចាំថ្ងៃជាមួយក្រុមគ្រួសារប្រពន្ធកូនរបស់គេ ពួកគេជាឪពុក និងជាស្វាមីគំរូ [...] ដូចជាករណីលោក ខៀវ សំផន ជាមួយនឹងកូនទាំងបួនរបស់គេ ប្រពន្ធក្មេងគេ។ គេជាស្វាមីគំរូ"[574]។

៦០៩. ក្នុងស្មារតីដូចគ្នា Henri LOCARD មិនអាចឃាត់ខ្លួនមិនឱ្យធ្វើ "រោគវិនិច្ឆ័យ" លើចំណង់ងប់ងុលរបស់ នួន ជា និង ខៀវ សំផន។ បើតាមយោបល់របស់គាត់ "អារម្មណ៍ងប់ងុល" របស់ នួន ជា គឺការសម្លាប់[575] ហើយ "អារម្មណ៍ងប់ងុល" របស់ ខៀវ សំផន គឺសំអាតសង្គមខ្មែរ (ដូចដែលយើងបានឃើញខាងលើអំពីមូលដ្ឋាននៃការអះអាងនេះ)[576]។

៦១០. ការអះអាងរបស់អ្នកគ្មានជំនាញទាំងនេះ សុទ្ធសឹងជាការអះអាងដ៏អសុរសបំផុតពីសំណាក់ Henri LOCARD។ ជាក់ស្ដែង បើសិនជាគាត់គិតមែនទែនថា ជនជាប់ចោទជាមនុស្សវិកលចរិតក្នុងន័យវេជ្ជសាស្ត្រវិញនោះ គាត់មិនអាចស្ដីបន្ទោសទៅជនជាប់ចោទពីបទដែលពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះទេ ដោយហេតុថាអ្វីដែលជនជាប់ចោទអាចនឹងនិយាយមិនមានតម្លៃអ្វីទាំងអស់។ ផ្ទុយទៅវិញ Henri LOCARD វាយតម្លៃថា ការនៅស្ងៀមមិនឆ្លើយតបរបស់ពួកគាត់មានពិរុទ្ធភាព ពីព្រោះការនៅស្ងៀមនេះ "បិទបាំង" ការពិត "ដ៏គួរឱ្យរន្ធត់"[577]។

---

[574] ប្រតិចារឹក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/451.1** ទំព័រ៧៩, ចន្លោះម៉ោង 15.49.50 និង 15.51.27។

[575] ប្រតិចារឹក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/451.1** ទំព័រ៤១, មុនម៉ោង 11.28.56។

[576] សូមមើលខាងលើនៅកថាខណ្ឌ៦០២។

[577] អង្គភាពគាំពារការការពារក្ដីបដិសេធការចោទប្រកាន់ថាមេធាវីការពារក្ដីជាឧក្រិដ្ឋជន៖ អត្ថបទសរសេរដោយ George WRIGHT, *Cambodia Daily* ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E3/10653**, ERN EN 01321131។

៦១១. ដោយមិនចាំបាច់រហូតដល់ចាត់ទុកថាឥរិយាបថនេះជាអារម្មណ៍ងប់ងុល ក្រុមមេធាវីការពារក្ដីសូមលើកឡើងថា នៅក្នុងពេលផ្ដល់សក្ខីកម្ម Henri LOCARD មិនអាចទប់អារម្មណ៍កុំឱ្យធ្វើការរចនាចម្លើយរបស់ខ្លួន ដោយធ្វើការអត្ថាធិប្បាយក្រៅរឿងពាក់ព័ន្ធនឹងការដែល ខៀវ សំផន មានវត្តមានក្នុងសាលសវនាការ និង/ឬ ការដែលគាត់អាចឆ្លើយនឹងសំណួរបាន។ រីឯចំពោះ នួន ជា ដែលមិននៅក្នុងសាលសវនាការវិញ Henri LOCARD បានបរិយាយក្រៅរឿងមួយបែបទៀតអំពីរូបគាត់។

៦១២. ជាក់ស្ដែងពេលឆ្លើយទៅនឹងលោកមេធាវី KOPPE ដែលសួរគាត់ថា ហេតុអ្វីបានជាគាត់មិនបានព្យាយាមរកព័ត៌មានគាំទ្រចេញពីការបោះពុម្ពផ្សាយជាផ្លូវការ Henri LOCARD "បានឆ្លើយ"៖

> "ខ្ញុំសូមត្រឡប់សំណួរនេះទៅលោកវិញ។ លោកមានសំណាងដែលបានការពារឥស្សរជនមួយរូបដែលសំខាន់បំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺ នួន ជា។ [...] អញ្ចឹង ហេតុអ្វីបានជាលោកមិនសួរទៅកូនក្ដីរបស់លោកថាតើរូបគាត់ផ្ទាល់ ឬអ្នកនៅជុំវិញគាត់ ដូចជា ទាវ អុល ខៀវ សំផន ជាអ្នកសរសេរពាក្យស្លោកទាំងនេះ ឬមិនមែនទេ? ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំជឿថាជនជាប់ចោទទាំងពីរនាក់ដែលនៅទីនេះគឺ ខៀវ សំផន និង នួន ជា ដឹងពីរឿងនេះច្រើនជាងខ្ញុំឆ្ងាយណាស់។ ប៉ុន្តែលោកបែរជាណែនាំឱ្យពួកគាត់បន្តរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ដូច្នេះ យើងទៅមុខមិនរួចទេ ហើយក្នុងឋានៈជាប្រវត្តិវិទូ យើងស្ថិតនៅក្នុងភាពមិនច្បាស់លាស់ និងត្រូវផ្អែកលើសម្មតិកម្ម។ អាចថាសម្មតិកម្មខ្លះមានមូលដ្ឋានត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ ប៉ុន្តែមានតែពួកគាត់ទេដែលដឹងថា ត្រឹមត្រូវ ឬមិនត្រឹមត្រូវ"[578]។

៦១៣. ត្រង់នេះ យើងសូមដកស្រង់តែឧទាហរណ៍មួយគត់ដែលទាក់ទងនឹង ខៀវ សំផន៖

> "ទោះយ៉ាងណាក្ដី គឺ [សាឡុត បាន] កាលនោះ ជាក្មេងជំទង់ ជាអ្នកជិះកង់នាំសារពី នួន ជា ទៅ ប៉ុល ពត និងពី ប៉ុល ពត ទៅ នួន ជា។ អញ្ចឹងតើគាត់មាននាំសារទៅឱ្យ ខៀវ សំផន ដែរឬទេ? គឺត្រូវសួរសំណួរនេះទៅ ខៀវ សំផន ផ្ទាល់តែម្ដងទៅ។ ប៉ុន្តែយើងដឹងហើយថាគាត់ប្រហែលជាឆ្លើយថា ទេ"[579]។

---

[578] ប្រតិចារិក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ២០ ចន្លោះម៉ោង 10.00.12 និង 10.03.17។

[579] ប្រតិចារិក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/451.1** ទំព័រ៦៥, មុនម៉ោង 14.43.58។ មានឧទាហរណ៍ផ្សេងៗទៀតដូចជា ប្រតិចារិក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/450.1** ទំព័រ៥២-៥៣, ក្រោយម៉ោង 11.14.13 (« Philip Short [...] បានសម្ភាសមេដឹកនាំខ្មែរក្រហម និងបញ្ញវន្តជាច្រើន ដែលក្នុងនោះមានខៀវ សំផន ដែលមានវត្តមាននៅទីនេះ

៦១៤. Henri LOCARD មានសិទ្ធិដាច់ខាតបំផុតក្នុងការគិតអំពីអ្វីដែលខ្លួនចង់គិត។ ប៉ុន្តែ ការខ្វះសត្យានុម័តិដែលមិនអាចប្រកែកបាន មានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងទៅលើភាពគួរឱ្យទុកចិត្តបាននៃសេចក្តីសន្និដ្ឋានរបស់គាត់។

៦១៥. គាត់មិនត្រឹមតែធ្វើឱ្យគេលែងជឿជាក់លើគាត់ទាំងស្រុងតាមរយៈការជេរប្រមាថជនជាប់ចោទ និងមេធាវីរបស់ជនជាប់ចោទនៅក្នុងសារព័ត៌មានប៉ុណ្ណោះទេ គឺ Henri LOCARD បានធ្វើឱ្យគេលែងជឿជាក់លើគាត់ទាំងស្រុងរួចបាត់ទៅហើយនៅក្នុងសាលសវនាការ តាមរយៈការចោទប្រកាន់លោកស្រីមេធាវី GUISSÉ ថាបានអនុវត្ត “ការធ្វើទារុណកម្មត្រជាក់” លើរូបគាត់។ ជាក់ស្តែង ការប្រៀបប្រដូចសាលសវនាការនៃ អ.វ.ត.ក ទៅនឹងបន្ទប់សួរចម្លើយនៃ មន្ទីរ ស-២១ មិនត្រឹមតែជាទង្វើហួសហេតុ និងប្រមាថមើលងាយប៉ុណ្ណោះទេ គឺវាថែមទាំងមិនគួរឱ្យជឿថាអាចកើតមានឡើងពីសំណាក់បុគ្គលដែលបានកោះហៅមកធ្វើសក្ខីកម្ម ក្នុងឋានៈជាអ្នកជំនាញផ្នែកមន្ទីរសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យសោះឡើយ។

៦១៦. ការសន្និដ្ឋានព្រាវៗរាប់ដងមិនអស់របស់ Henri LOCARD បង្ហាញរួចស្រេចទៅហើយថា គាត់មានចិត្តលម្អៀងប្រឆាំងនឹងជនជាប់ចោទយ៉ាងច្បាស់ ហើយក៏មិនមានចិត្តលម្អៀងគាំទ្រជនរងគ្រោះដែរ ទោះបីជាគាត់បានឆ្លើយថា គាត់ចាត់ទុកខ្លួនឯងជាអ្នកនាំពាក្យរបស់ជនរងគ្រោះទាំងនេះក៏ដោយ។[580] ការដាក់ខ្លួនឯងជាជនរងគ្រោះដោយមិនសមស្របនៅក្នុងពេលតាំងសំណួររបស់

---

ហើយខ្ញុំគិតថាគាត់ជាប្រភពដ៏សំខាន់ជួយឱ្យយើងយល់ពីរបបនេះ។ (“ពួកគាត់ជាខ្មែរក្រហមផ្ទាល់តែម្តង នៅពេលដែលពួកគាត់ចង់និយាយ”) ; ទំព័រ១១២-១១៣, ក្រោយម៉ោង 15.27.04 (“មិនអាចទទួលយកបានទេ! គួរឱ្យសោកស្តាយណាស់ដែលខៀវ សំផន នៅភ្នំពេញស្រាប់ហើយ បែរជាមិនព្រមពន្យល់យើង ត្បិតអីគាត់គួរតែដឹងរឿងទាំងនេះ […] ”) ; ប្រតិចារឹក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/451.1** ទំព័រ២៤, មុនម៉ោង 10.14.33 (“ដូច្នេះ ខ្ញុំសូមអញ្ជើញខៀវ សំផនឱ្យនិយាយប្រឆាំងនឹងខ្ញុំ […] ”) ; ទំព័រ៨៩-៩០, មុនម៉ោង 13.48.53 (“តើរឿងហ្នឹងក្លាយទៅជាអ្វី? ដូច្នេះ សូមចោទសំណួរនេះទៅខៀវ សំផន ទៅ គាត់នៅទីនេះស្រាប់។ គាត់អាចឆ្លើយសំណួរនេះបានល្អជាងខ្ញុំ។”) ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ៣៩, ក្រោយម៉ោង 11.20.27 (“លោកស្រីអាចទទួលបានព័ត៌មាននេះពីខៀវ សំផន គឺមិនមែនពីកូនក្តីលោកស្រីទេ។ កន្លងមកគាត់ដូចជាធ្លាប់ជាប់គុកយ៉ាងហោចណាស់មួយខែ។ គាត់អាចឆ្លើយល្អជាងខ្ញុំ។ ខ្ញុំមិនបានធ្វើការស្រាវជ្រាវជាក់លាក់លើ(...)”)។

[580] ប្រតិចារឹក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/450.1** ទំព័រ៣៤, មុនម៉ោង 11.02.07 ( H. LOCARD ពន្យល់ការជ្រើសរើសធ្វើនិក្ខេបបទនេះដោយសារគាត់ចង់ដឹងអំពីមូលហេតុនៃការបាត់ខ្លួនរបស់មិត្តភ័ក្តិជិតស្និទ្ធមួយចំនួនរបស់គាត់ ដែល

លោកស្រីមេធាវី GUISSÉ គឺជាការមិនចេះទប់អារម្មណ៍ខ្លួនឯងអោយត្រូវកាលៈទេសៈ រហូតដល់ថ្នាក់ជេរប្រមាថដល់ជនរងគ្រោះពិតប្រាកដនៃអំពើទារុណកម្មនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

## ១. "អ្នកជំនាញ" ត្រូវបានផ្តល់ដោយប្រភពរបស់ខ្លួនផ្ទាល់

៦១៧. ពេលឆ្លើយនឹងសំណួរទាក់ទងនឹងប្រភពនៃការអះអាងមួយចំនួនរបស់គាត់ ទាក់ទងនឹង ខៀវ សំផន Henri LOCARD បានឆ្លើយថា វាជាចម្លើយនៃកិច្ចសម្ភាសន៍ជាមួយ សាឡុត បាន ឬ ភី ភួន។ ក្រុមមេធាវីការពារក្តីក៏សុំឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យ Henri LOCARD ផ្តល់កំណត់ត្រា និងខ្សែអាត់នៃកិច្ចសម្ភាសន៍ទាំងនេះមកតុលាការ[581]។

៦១៨. នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានទទួលយកសំណើផ្ទាល់មាត់របស់ក្រុមមេធាវីការពារក្តី ហើយបានដាក់ឯកសារដែល Henri LOCARD បានផ្តល់ជូនឱ្យភាគីពិគ្រោះប្រើប្រាស់[582]។ អង្គជំនុំជម្រះក៏បានផ្តល់ព័ត៌មានដែលអាចឱ្យកំណត់សារបានដូចខាងក្រោម៖

ក. នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានទទួលលិខិតមួយដែល Henri LOCARD ជម្រាបជូនថា ខ្លួនមានកំណត់ត្រាវាយអង្គុលីលេខនៃកិច្ចសម្ភាសន៍របស់ខ្លួនជាមួយ សាឡុត បាន និង ភី ភួន ព្រមទាំងកាសែតថតសម្លេងកិច្ចសម្ភាសន៍ជាមួយ ភី ភួន ចំនួនប្រហែល ២៥។[583] Henri LOCARD បានបន្ថែមថា សួង ស៊ីគឿន អាចមាន

---

បាន ស្គាល់កាលពីសម័យសង្គមរាស្ត្រនិយម) ទំព័រ៦០-៦១, មុនម៉ោង 11.31.14 ("ដូច្នេះ ខ្ញុំក៏ចាត់ទុកខ្លួនឯងដូចជាសម្លេងជនជាតិខ្មែរសាមញ្ញដែលបានស្តាប់យ៉ាងវេទនា និងចាត់ទុកថាខ្ញុំនិយាយជួសមុខឱ្យក្រុមគ្រួសារ របស់ពួកគាត់។") ; ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/453.1** ទំព័រ១០, មុនម៉ោង 09.23.20 ("គឺដោយហេតុថាខ្ញុំធ្វើការស្រាវជ្រាវដោយផ្អែកលើសម្លេងជនរងគ្រោះ គឺមិនមែនលើសម្លេងអ្នកធ្វើទារុណកម្មគេនោះទេ។")។

[581] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ ៧២-៧៣, ចន្លោះ 15.28 និង 15.30 និងទំព័រ១២៦ មុំម៉ោង 15.46.31។ ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/453.1** ទំព័រ ១៥-១៦, ចន្លោះ 09.37.09 និង 09.53.42។

[582] អនុស្សរណៈ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E447**។

[583] អនុស្សរណៈ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E447** កថាខណ្ឌទី២។ ទាក់ទងនឹងកំណត់ត្រាវាយអង្គុលីលេខ Henri LOCARD បញ្ជាក់ថា : « *I carried those interviews over the years with SUONG Sikoeun who was both my interpreter from French to Khmer and vice-versa, and the translator who would type their answers on a laptop*

កាសែតថតសម្លេងនៃកិច្ចសម្ភាសន៍ជាមួយ ភី ភួន ផ្សេងទៀត និងបន្ថែមទៀតថា សួង ស៊ីគៀន ជាអ្នកមានកាសែតថតសម្លេងជាមួយ សាឡុត បាន ទាំងអស់[584]។

ខ. នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ Henri LOCARD បានផ្ញើរជូនអង្គជំនុំជម្រះនូវឯកសារវាយអង្គុលីលេខពីរដែលទាក់ទងនឹងសាឡុត បាន និង ភី ភួន។ ប៉ុន្តែគាត់ពុំបានផ្ញើរកាសែតអាត់សម្លេងណាមួយទេ[585]។

គ. នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ តាមបង្គាប់របស់អង្គជំនុំជម្រះ អង្គភាពគាំពារសក្សី និងអ្នកជំនាញបានទាក់ទង សួង ស៊ីគៀន។ គាត់បានប្រាប់ថា គាត់គ្រាន់តែបានធ្វើការបកប្រែពីភាសាខ្មែរទៅភាសាបារាំងតែប៉ុណ្ណោះ ហើយថាគាត់មិនមានខ្សែអាត់សម្លេងដែលគាត់គ្មានសិទ្ធិរក្សាទុកនោះទេ។ គាត់បានបន្ថែមថា ហេតុអ្វីបានជា Henri LOCARD និយាយផ្ទុយនៅតុលាការ[586]។

ឃ. នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ ឆ្លើយតបនឹង សំណើថ្មីមួយទៀតរបស់អង្គជំនុំជម្រះ អង្គភាពនេះបានទទួលឯកសារបន្ថែមពីរពី Henri LOCARD ដែលបើតាមអង្គភាពនេះហាក់ដូចជាឯកសារទាំងពីរដដែលដែលគាត់បានផ្ញើរឱ្យពីមុន មានតែខ្នាត និងចំណងជើងតែប៉ុណ្ណោះដែលខុសគ្នា។ ហើយនៅលើកនេះក៏ដោយ ក៏គាត់មិនបានផ្តល់កាសែតអាត់សម្លេងណាមួយឱ្យដែរ[587]។

ង. នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានដាក់ឯកសារទាំង៤ដែល Henri LOCARD បានផ្ញើរជូនឱ្យភាគីពិគ្រោះប្រើប្រាស់[588]។

---

*provided by myself. I later somewhat reorganized the text* » (លិខិតរបស់ Henri LOCARD ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E447.1** ទំព័រទី១ កថាខណ្ឌទី២ ). សូមមើលសេចក្តីបញ្ជាក់ដែលបានផ្តល់ជូនក្នុងសវនាការ៖ ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/453.1** ទំព័រ២៤, មុនម៉ោង 09.38.30។

[584] លិខិតរបស់ Henri LOCARD ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E447.1** ទំព័រទី១, កថាខណ្ឌទី៣ និងទី៤ នៃ .

[585] អនុស្សរណៈ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E447** កថាខណ្ឌទី២។

[586] សារអេឡិកត្រូនិករបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញផ្ញើជូនអង្គជំនុំជម្រះ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E447.3**។

[587] អនុស្សរណៈ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E447** កថាខណ្ឌទី២។

[588] អនុស្សរណៈ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E447** កថាខណ្ឌទី២។ តារាងភ្ជាប់ជាឧបសម្ព័ន្ធដែលមានបញ្ជីឯកសារយោង **ឯកសារ E447.2**។

៦១៩. នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ទោះបីជាមិនមានខ្សែអាត់ជាសម្លេងនៃកិច្ចសម្ភាសន៍ដែល Henri LOCARD មានការរារែកយ៉ាងច្បាស់ក្នុងការផ្ដល់ជូនតុលាការខុសពីសុឆន្ទៈដែលគាត់បានបង្ហាញនៅក្នុងតុលាការក៏ដោយ[589] ក៏មេធាវីការពារក្ដីបានស្នើសុំឱ្យទទួលយកសម្រង់ខ្លីៗនៃឯកសារចំនួន ៧២០ទំព័រដែលគាត់បានផ្ញើរជូនដែរ[590]។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ អង្គជំនុំជម្រះបានទទួលយកសំណើនេះ[591]។

៦២០. សម្រង់ទាំងនេះផ្ទុយពីការអះអាងដាច់ខាតដោយមិនបើកឱ្យមានការសួរដេញដោលរបស់ Henri LOCARD និងគាំទ្រដល់ទស្សនៈរបស់មេធាវីការពារក្ដីជាច្រើនចំណុច

## 1. <u>អវត្តមានទំនាក់ទំនងរវាង ប៉ុល ពត និង ខៀវ សំផនក្នុងទសវត្សឆ្នាំ៦០</u>

៦២១. នៅពេលសវនាការ Henri LOCARD បានប្រកាសថាខ្លួន "ជឿជាក់" ថា ខៀវ សំផនមានទំនាក់ទំនងជាមួយមេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជានៅក្នុងទសវត្សឆ្នាំ៦០ គឺមុនពេលដែលគាត់ចូលព្រៃម៉ាគីយ៉ាងយូរ។ ពេលដែលមេធាវីការពារក្ដីសួរគាត់អំពីប្រភព Henri LOCARD បានឆ្លើយថាខ្លួនបានបន្ថែមផ្នែកមួយនៅក្នុងសៀវភៅបោះពុម្ពផ្សាយលើកទីពីររបស់គាត់ក្រោយពីបានសម្ភាសន៍ជាមួយសាឡុត បានដែលទំនងជាបានប្រាប់គាត់ថានៅសម័យដែលគាត់រស់នៅជាមួយពូគាត់ (ប៉ុល ពត) នៅភ្នំពេញ (ចន្លោះឆ្នាំ១៩៥៩-១៩៦៣)៖

> "គេឱ្យគាត់ជិះកង់នាំសារសម្ងាត់ ជាពិសេសសារសម្ងាត់តែម្ដងយកទៅឱ្យជាពិសេស ខៀវ សំផន និង នួន ជា។ កាលនោះគាត់ជាក្មេងជំទង់ អញ្ចឹងគ្មានអ្នកណាចាប់អារម្មណ៍នឹងគាត់ទេ។"[592]

៦២២. ចម្លើយនេះរបស់ Henri LOCARD បណ្ដាលមកពីសំណើរបស់មេធាវីការពារក្ដីសុំឱ្យផ្ដល់កំណត់ត្រា និងខ្សែអាត់នៃកិច្ចសម្ភាសន៍ជាមួយសាឡុត បាន[593]។

---

[589] ប្រតិចារឹក ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/453.1** ទំព័រ១៨ មុនម៉ោង 09.47.20] ទំព័រ៣១ មុនម៉ោង 09.51.44

[590] សំណើរបស់ខៀវ សំផន ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E447/1**។

[591] អនុស្សរណៈ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E447/2**។

[592] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ៧២-៧៣ , ចន្លោះម៉ោង 15.26.33 និង 15.29.58។

៦២៣. ក៏ប៉ុន្តែ នៅក្នុងកំណត់ត្រាដែល Henri LOCARD បានផ្ញើរឱ្យ មិនដែលមាននិយាយថាសាឡុត បាននាំសារទៅឱ្យលោក ខៀវ សំផនទេ។ ផ្ទុយទៅវិញ នៅពេលដែលសាឡុត បាន និយាយអំពីសារដែលពួកគាត់ប្រើឱ្យយកទៅឱ្យគេនៅសម័យនោះ គឺសំដៅយកទៅឱ្យអ្នកផ្សេងក្រៅពី ខៀវ សំផនទេ៖

> "ខ្ញុំត្រូវជិះកង់នាំសារដែលរមូរដាក់ក្នុងបំពង់ ជូនយកទៅឱ្យ នួន ជា អៀង សារី សុន សេន ហ៊ូ យន់ នៃ សារ៉ាន់ នាយកវិទ្យាល័យចំរើនវិជ្ជា។ ហើយអ្នកទាំងអស់នេះ គេឱ្យខ្ញុំយកសារគេទៅឱ្យ សាឡុត ស វិញដោយមូលលាក់ក្នុងបំពង់ដូចគ្នា"[594]។

៦២៤. ដូច្នេះ ការអះអាងរបស់ Henri LOCARD នៅក្នុងសាលសវនាការ ក៏ដូចជានៅក្នុងសៀវភៅបោះពុម្ពផ្សាយលើកទីពីរក្នុងឆ្នាំ២០១៦[595] របស់គាត់ សុទ្ធតែកុហកទាំងអស់។

៦២៥. លើសពីនេះទៅទៀត ចម្លើយរបស់សាឡុត បាន បញ្ជាក់អំពីអ្វីដែល ខៀវ សំផន តែងតែនិយាយ គឺថាគាត់មិនដែលទាក់ទង និងមានទំនាក់ទំនងណាមួយជាមួយបក្សកុម្មុយនីស្តកម្ពុជាមុនពេលគាត់ចូលព្រៃម៉ាគីឡើយ។

## 2. ការសន្និដ្ឋានប្រាថអំពីតួនាទីនិងអំណាចរបស់ ខៀវ សំផន

៦២៦. នៅក្នុងសាលសវនាការ Henri LOCARD បានពន្យល់អំពីមូលហេតុនៃការបន្ថែមនៅក្នុងការបោះពុម្ពផ្សាយទីពីរនៃសៀវភៅរបស់គាត់នូវឈ្មោះ ខៀវ សំផន ពីលើមនុស្សបីនាក់ដែល "នៅពីក្រោយឆាក" [...] មានអំណាច និងធ្វើសេចក្តីសម្រេចសំខាន់ៗទាំងអស់" ដោយផ្អែកលើចម្លើយដែលគាត់ទទួលបានក្នុងពេលសម្ភាសន៍ជាមួយ សាឡុត បាន ឬ ភី ភួន ដែលថា មុនពេលដណ្តើមបានទីក្រុងភ្នំពេញ "ខៀវ សំផន ទទួលបន្ទុកភ័ស្តុភាររួចស្រេចទៅហើយ ដោយសារនេះជាវិស័យជំនាញដ៏សំខាន់របស់គាត់ គេចាត់ទុកគាត់ជាអ្នកទទួលខុសត្រូវនៃការចែកចាយអ្វីៗទាំងអស់។ គាត់ជាអ្នក

---

[593] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ៧៣ ចន្លោះ 15.29.58 និង 15.32.46។

[594] សម្រង់នៃកំណត់ត្រារបស់ Henri LOCARD **ឯកសារ E3/10772**, ERN FR 01339452។

[595] **ហេតុអ្វីបានជាមានខ្មែរក្រហម**, Henri LOCARD, ឆ្នាំ ២០១៦ **ឯកសារ E3/10640 ទំព័រ៩៨**, ERN FR 01321063។

ចែកចាយ និងត្រួតពិនិត្យលើការចែកចាយគ្រាប់រំសេវ”[596]។ បើតាម Henri LOCARD វាជាព័ត៌មានដែលបានមកពីការសម្ភាសន៍ ភី ភួន ទៅវិញទេ[597]។

៦២៧. ចម្លើយទាំងនេះរបស់ Henri LOCARD បណ្តាលមកពីសំណើរបស់មេធាវីការពារក្តីសុំឱ្យផ្តល់កំណត់ត្រា និងខ្សែអាត់នៃកិច្ចសម្ភាសន៍របស់គាត់ជាមួយ ភី ភួន[598]។

៦២៨. ក៏ប៉ុន្តែ ក្នុងកំណត់ត្រាដែល Henri LOCARD បានផ្តល់ឱ្យ មិនមែន ភី ភួនទេ គឺ សាឡុត បាន ជាអ្នកនិយាយអំពីបញ្ហានេះ ដោយប្រើពាក្យពេចន៍ខុសគ្នាឆ្ងាយណាស់៖

> “នៅសម័យនោះ [មុនពេលដណ្តើមបានទីក្រុងភ្នំពេញ] ខ្ញុំជាអ្នកធ្វើបញ្ជីទទួល និងចែកចាយអាវុធ និងគ្រាប់រំសេវ។ ខ្ញុំធ្លាប់និយាយរឿងនេះប្រាប់តុលាការខ្មែរក្រហមហើយ៖ កាលណាខ្ញុំអវត្តមាន គឺបង ខៀវ សំផន ជំនួសខ្ញុំ។ គឺអញ្ចឹងឯង ប្រធានរដ្ឋយើង! គាត់ហើយនិងខ្ញុំ យើងអាចជំនួសគ្នាបាន” (យើងជាអ្នកគូសពីក្រោម)[599]។

៦២៩. ពាក្យសម្តីនេះរបស់ សាឡុត បាន ត្រូវគ្នានឹងចម្លើយរបស់គាត់ក្នុងសាលសវនាការ ដែលថាជួនកាល ខៀវ សំផន ជួយគាត់ក្នុងការធ្វើបញ្ជីគ្រាប់រំសេវ ពីព្រោះគាត់ចេះសរសេរ។[600] ដូច្នេះ វាខុសឆ្ងាយពីការ “ចែកចាយ ឬការគ្រប់គ្រងការចែកចាយគ្រាប់រំសេវ” ដែលនាំឱ្យ Henri LOCARD សន្និដ្ឋាន និងសរសេរក្នុងសៀវភៅដែលបោះពុម្ពផ្សាយថ្មីរបស់គាត់ថា ខៀវ សំផន ស្ថិតក្នុងចំណោមមនុស្សដែល “នៅក្រោយឆាក [...] មានអំណាចទាំងស្រុង និងធ្វើសេចក្តីសម្រេចសំខាន់ៗ”។

---

[596] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ ៧៥-៧៧ , ចន្លោះម៉ោង 15.38.54 និងម៉ោង 15.49.12 ។

[597] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ ៧៨ មុនម៉ោង 15.46.26។

[598] ប្រតិចារឹក ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/452.1** ទំព័រ ៧៨ , ម្ដុំម៉ោង 15.46.31។

[599] សម្រង់នៃកំណត់ត្រារបស់ Henri LOCARD **ឯកសារ E3/10773**, ERN FR 01339489។

[600] ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ **ឯកសារ E1/68.1** ទំព័រ៣៥ បន្ទាត់ ៧-១៩, ក្រោយម៉ោង 11.27។

៦៣០. នៅត្រង់នេះដែរ ការអះអាងរបស់ Henri LOCARD នៅក្នុងសាលសវនាការ ក៏ដូចជាក្នុងសៀវភៅបោះពុម្ពផ្សាយលើកទីពីរក្នុងឆ្នាំ២០១៦[601]របស់គាត់ មិនប្រកបដោយភាពស្មោះត្រង់នោះទេ។

### គ. សេចក្តីសន្និដ្ឋាន

៦៣១. យោងតាមអ្វីដែលយើងឃើញកន្លងមក អង្គជំនុំជម្រះត្រូវចាត់ទុកថា ចម្លើយ និងសំណេររបស់ Henri LOCARD ដែលហួសពីដែនសមត្ថកិច្ចរបស់ខ្លួន (ដែលកម្រិតមកត្រឹមមន្ទីរសន្តិសុខ និងពាក្យស្លោកនៃរបបកម្ពុជាប្រជាធិបតេយ្យ) ជាមតិយោបល់ផ្ទាល់ខ្លួន "ជាអ្នកជំនាញ" ដែលមានភាពអគតិយ៉ាងខ្លាំងប្រឆាំងនឹងជនជាប់ចោទ។ ទោះក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះមិនអាចផ្អែកលើចម្លើយ ការស្មានព្រាវៗ និង "ការសន្និដ្ឋាន" របស់គាត់ទាក់ទងនឹងលោក ខៀវ សំផន ដែលរាក់កំភែលបំផុត និងខ្វះភាពម៉ត់ចត់ រហូតដល់ថ្នាក់ត្រឹមតែជាការនិយាយកុហកតែប៉ុណ្ណោះ។ អាស្រ័យហេតុដូច្នេះ អង្គជំនុំជម្រះត្រូវតែដកចម្លើយ ការស្មានព្រាវៗ និង "ការសន្និដ្ឋាន" របស់គាត់ទាក់ទងនឹងលោក ខៀវ សំផន ចេញពីការពិភាក្សាសម្រេច។

## ជំពូកទី ៤. ធាតុផ្សំដែលទទួលបានពីការធ្វើទារុណកម្ម

៦៣២. ក្នុងពេញមួយអំឡុងពេលជំនុំជម្រះសំណុំរឿង ០០២/០២ មេធាវីរបស់ នួន ជា ក៏ដូចជាសហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះផ្ទាល់ សុទ្ធតែចង់ប្រើធាតុផ្សំភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម។

៦៣៣. នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ ក្រុមមេធាវីការពារក្តីបានរំឭកថា ស្របតាមច្បាប់ដែលអាចអនុវត្តបាន ធាតុផ្សំភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម ឬការគាបសង្កត់លើផ្លូវកាយ ឬផ្លូវចិត្ត អាចយកមកប្រើប្រាស់បានតែក្នុងគោលបំណងបង្ហាញថាចម្លើយមួយត្រូវបានផ្តល់ឱ្យ[602]។

---

[601] ហេតុអ្វីបានជាមានខ្មែរក្រហម Henri LOCARD, 2016 **ឯកសារ E3/10640** ទំព័រ៩២, ERN FR 01321060។

[602] សេចក្តីសន្និដ្ឋានរបស់ខៀវ សំផន ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E350/4**។

៦៣៤. នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានសម្រេច (ចៅក្រម FENZ ជំទាស់) ថា ធាតុផ្សំទាំងនេះអាចប្រើប្រាស់បានក្នុងករណីមួយចំនួន ក្នុងគោលបំណងផ្សេងៗទៀត[603]។

៦៣៥. ទោះបីជាសេចក្តីសម្រេចនេះទទួលរងការជំទាស់រួចហើយក៏ដោយ ដោយហេតុថាវាមិនត្រឹមត្រូវតាមស្មារតីច្បាប់[604] ក៏សេចក្តីសម្រេចនេះមិនទាំងអាចរារាំងចៅក្រម LAVERGNE និង លោកប្រធាន និល ណុន កុំឱ្យព្យាយាមប្រើប្រាស់ធាតុផ្សំភស្តុតាងទាំងនេះឱ្យហួសពីបទបញ្ញត្តិនៃសេចក្តីសម្រេចរបស់ខ្លួន[605]។

៦៣៦. ដូច្នេះ ដោយហេតុថាវាមានភវនីយភាពតិចណាស់ ដែលអង្គជំនុំជម្រះពិចារណាលើសេចក្តីសម្រេចខុសមួយនេះរបស់ខ្លួនឡើងវិញក្នុងពេលពិភាក្សាសម្រេច យ៉ាងហោចណាស់ក៏អង្គជំនុំជម្រះត្រូវតែកុំប្រើប្រាស់ធាតុផ្សំភស្តុតាងទាំងនេះក្រៅពីករណីដែលខ្លួនបានកំណត់ខ្លួនឯង។

## ជំពូកទី ៥. ទិមតិសង្ស័យ

[603] សេចក្តីសម្រេច ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E350/8** ; សំអាងហេតុនៃមតិយោបលដោយឡែករបស់ចៅក្រម FENZ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E350/8.1**។

[604] មេធាវីការពារក្តីគាំទ្រគោលជំហររបស់គាត់ ដូចដែលខ្លួនបានជម្រាបជូនតាំងពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ មកម្ល៉េះ៖ ប្រតិចារឹក ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/392.1** ទំព័រ៤២-៤៣ ចន្លោះម៉ោង 10.36.51 និង 10.37.44 (មេធាវី GUISSE បានលើកឡើងថា៖ «ខ្ញុំចាំបាច់ត្រូវបញ្ជាក់ថាទោះបីជាអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចនេះលើចម្លើយសារភាពដែលទទួលបានពីការធ្វើទារុណកម្មក៏ដោយ ក៏មេធាវីលោកខៀវ សំផននៅតែយល់ឃើញថាលោក លោកស្រីចៅក្រមវិភាគមិនត្រឹមត្រូវលើអ្វីដែលជាអនុសញ្ញា និងលើអ្វីដែលជាករណីលើកលែង (...) ប៉ុន្តែដោយហេតុថាអស់លោកបានចេញសេចក្តីសម្រេចនេះ ហើយដែលសេចក្តី សម្រេច នេះបិទផ្លូវតវ៉ា ក្នុងដំណាក់កាលជំនុំជម្រះសេចក្តី ខ្ញុំគ្រាន់តែចង់លើកឡើងជាទូទៅថាយើងនៅតែយល់ឃើញថា អង្គជំនុំជម្រះបកស្រាយអត្ថបទនេះមិនត្រឹមត្រូវ »)។

[605] ឧទាហរណ៍ នៅពេលសួរចម្លើយកាំងហ្គេកអ៊ាវ ហៅឌុច៖ ប្រតិចារឹក ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/437.1** ទំព័រ ៥៨-៥៩ ចន្លោះម៉ោង 15.15.57 និងម៉ោង 15.19.34 (បន្ទាប់មេធាវីការពារក្តីជំទាស់លោកប្រធាន និល ណុនបាន ប្រកាសថាខ្លួនបានប្រើប្រាស់ឯកសារនេះ ដោយសារតែខ្លួនមិនបានរកឃើញឯកសារដទៃទៀតដែលគាត់តែងនៅសម័យនោះតែប៉ុណ្ណោះ។) ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ៨-៩ ចន្លោះម៉ោង 09.35.21 និងម៉ោង 09.44.07, និង ទំព័រ ២៣-៣២ ចន្លោះម៉ោង 09.54.32 និងម៉ោង 10.15.21 (ចៅក្រម LAVERGNE)។

៦៣៧. វិធាន ២១-១-ឃ នៃវិធានផ្ទៃក្នុង ចែងអំពីគោលការណ៍ជាមូលដ្ឋានថា "រាល់ជនសង្ស័យ ឬទទួលរងការចោទប្រកាន់ត្រូវតែសន្មតជាមុនថាគ្មានពិរុទ្ធភាព ដរាបណាពិរុទ្ធភាពរបស់គាត់មិនត្រូវបានរកឃើញ"។ វិធាន ៨៧-១ នៃវិធានផ្ទៃក្នុង ចែងថា "បន្ទុកភស្តុតាងបង្ហាញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះត្រូវតែមានជំនឿជឿជាក់ដោយឥតស្សរចិត្តអំពីពិរុទ្ធភាពរបស់គាត់"។ យោងតាមពាក្យពេចន៍ក្នុងសំណៅជាភាសាអង់គ្លេស និងភាសាខ្មែរ អង្គជំនុំជម្រះត្រូវជឿជាក់អំពីពិរុទ្ធភាពរបស់គាត់ "Beyond reasonable doubt/ដោយគ្មានវិមតិសង្ស័យ"។

៦៣៨. នៅកថាខណ្ឌ ២២ នៃសាលក្រមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានប្រកាសថា៖

> "ដើម្បីដោះស្រាយភាពមិនស៊ីសង្វាក់គ្នារវាងការចែងខុសគ្នានៅក្នុងសំណៅភាសា ផ្សេងៗនៃវិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង ដែលបង្ហាញពីបទដ្ឋាន "ដោយលើសពីវិមតិសង្ស័យ" តាមច្បាប់កុំមិនឡ (Common Law) និងទស្សនាទាន "*ជំនឿដោយឥតស្សរចិត្ត (intime convinction)*" តាមច្បាប់ស៊ីវិល (Civil Law) អង្គជំនុំជម្រះបានប្រើប្រាស់វិធីសាស្ត្រួមមួយ វាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃភស្តុតាង។ បន្ទាប់ពីបានវាយតម្លៃទៅលើភស្តុតាងដោយមាន សំអាងហេតុរួច អង្គជំនុំជម្រះនឹងធ្វើការបកស្រាយ វិមតិសង្ស័យដោយផ្តល់ប្រយោជន៍ដល់ ជនជាប់ចោទ ។" (យើងជាអ្នកគូសពីក្រោម)[606]

៦៣៩. នៅក្នុងបណ្តឹងសាទុក្ខ ក្រុមមេធាវីការពារក្តីបានរិះគន់អង្គជំនុំជម្រះថាបានពិចារណាថា វាអាចមាន "ភាពចម្រូងចម្រាស" ដែលអាចកើតចេញពីភាពខុសគ្នារវាងសំណៅភាសាផ្សេងៗនៃវិធាននេះ ដោយមូលហេតុថាក្នុងបរិបទនៃ អ.វ.ត.ក ការជឿជាក់ដោយឥតស្សរចិត្តមិនអាចបកប្រែអ្វីផ្សេងទៀតក្រៅពីការជឿជាក់ហួសពីវិមតិសង្ស័យ។ ក្រុមមេធាវីការពារក្តីក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះបានប្រើខុសជាច្រើនដងនូវទស្សនទាននៃលក្ខខ័ណ្ឌតម្រូវ ការជឿជាក់ដោយឥតស្សរចិត្តនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដែលអត្តនោម័ត និងមិនសូវតឹងរ៉ឹងដូចក្នុងប្រព័ន្ធច្បាប់ *Common Law*[607]។

---

[606] សាលក្រម ០០២/០១ កថាខណ្ឌ២២។

[607] សារណាបណ្តឹងសាទុក្ខ ០០២/០១ កថាខណ្ឌ១០៩៖ ការរិះគន់មានលក្ខណៈដូចគ្នានឹងការរិះគន់របស់លោកស្រីចៅក្រម VAN DEN WYNGAERT នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងមតិដោយឡែករបស់គាត់ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធនៃសាលក្រម *Katanga* ក្រោមពាក្យពេចន៍ដូចតទៅនេះ៖ "ការព្រួយបារម្ភដ៏ចម្បងរបស់ខ្ញុំចំពោះសាលក្រមនេះ គឺថាសាលក្រមនេះទាំងមូលខ្វះអង្គហេតុជាក់លាក់ និងជាក់ស្តែងទាំងស្រុង ហើយវាបែរជាពោរពេញទៅដោយ "ការសន្និដ្ឋាន" "ការព្រលយពាក្យ" និង "ការនិយាយបញ្ចិតបញ្ចៀងទូលាយមិនច្បាស់លាស់"។ ទោះបីជាសហភាតាខ្ញុំមានជំនឿដោយឥតស្សរៈចិត្តយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែ

៦៤០. អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធអំណះអំណាងនេះយ៉ាងស្រួល ដោយដកស្រង់កថាខណ្ឌ ២២ នៃសាលក្រម និងប្រកាសថា៖

> "ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់លាស់ថា អង្គជំនុំជម្រះបានសម្រេចយកបទដ្ឋានបង្ហាញភ័ស្តុតាងឱ្យហួសពីវិមតិសង្ស័យ។ លើសពីនេះទៀត តាមការពិនិត្យលើសំណៅនៃសាលក្រមជាភាសាបារាំង ឆ្លុះបញ្ចាំងឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំបានប្រើប្រាស់ពាក្យ ជំនឿដោយឥតស្សរចិត្ត *(intime conviction)* ឡើយ ប៉ុន្តែប្រើពាក្យថា ឱ្យហួសពីវិមតិសង្ស័យ *(il ne fait aucun doute)* ទៅវិញទេ នៅពេលធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួននោះ"[608]។

៦៤១. នៅក្នុងសំណៅជាភាសាបារាំងនៃសាលក្រម អង្គជំនុំជម្រះមិនដែលប្រើពាក្យ "ការជឿជាក់ដោយឥតស្សរចិត្ត" ក៏ពិតមែន ក៏ប៉ុន្តែអង្គជំនុំជម្រះក៏កម្រប្រើពាក្យ "ដោយគ្មានសង្ស័យទាល់តែសោះ"។ ជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលស្រង់បានឧទាហរណ៍បែបនេះតែ១០ប៉ុណ្ណោះក្នុងសាលក្រមជាភាសាបារាំងចំនួន ៧៧៧ទំព័រ ដែលក្នុងចំណោមឧទាហរណ៍ទាំងនេះ មានឧទាហរណ៍មួយដែលអង្គជំនុំជម្រះបានប្រកាសថា "ខ្លួនពុំមានជំនឿជឿជាក់លើសពីវិមតិសង្ស័យ"[609]។ គឺមានតែម្តងហ្នឹងគត់ដែលអង្គជំនុំជម្រះប្រើសញ្ញាណការជឿជាក់ហួសពីវិមតិសង្ស័យក្នុងសាលក្រមទាំងមូលរបស់ខ្លួន។

---

ភ័យខ្លាចថាឥតស្សរៈចិត្តនេះមិនអាចតទល់នឹងវិធានគ្រប់គ្រងភស្តុតាងដែលអាចអនុវត្តន៍បាន និងលក្ខខណ្ឌតម្រូវដ៏តឹងរឹងមិនផ្អែកលើអារម្មណ៍នៃវិធាននេះ។ និយាយឲ្យច្បាស់ជាងនេះទៅទៀតគឺ សំណុំរឿងមានកង្វះខាតជាច្រើន ហើយចំពោះខ្ញុំ មិនមានលក្ខណៈមិនពេញលេញរហូតដល់លើចំនុចជាច្រើន យើងមិនអាចទាញការសន្និដ្ឋានឲ្យហួសពីវិមតិសង្ស័យ។ លើសពីនេះទៀត ធាតុផ្សំភស្តុតាងភាគច្រើន មិនគោរពតាមនិយាមនៃភាពគួរឲ្យទុកចិត្តបាន ដែលខ្ញុំតែងតែអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតៈប្រទេសយូហ្គោស្លាវី។ ចំពោះខ្ញុំ គេមិនអាចយកធាតុផ្សំភស្តុតាងគ្មានទម្ងន់ មកធ្វើជាមូលដ្ឋាននៃការប្រកាសពិរុទ្ធភាពនោះទេ។ វិធានគ្រប់គ្រងភស្តុតាងត្រូវតែអនុវត្តឲ្យដូចគ្នាសម្រាប់មនុស្សគ្រប់គ្នា ទោះបីជារដ្ឋអាជ្ញាជួបការលំបាកយ៉ាងណាក៏ដោយ ។ វិធាននេះមិនអនុញ្ញាតឲ្យប្រព្រឹត្តិដូចខ្ញុំបានលើកឡើងខាងលើនេះទេ។ ប្រភព៖ មតិដោយឡែករបស់ Christine Van den Wyngaert, ICC-01/04-01/07-3436-ឧបសម្ព័ន្ធI ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ១៧២ មានលើកឡើងក្នុងកំណត់សម្គាល់ជើងទំព័រ 229 du MA 002/10)។

[608] សាលដីកា ០០២/០១ កថាខណ្ឌ៣៨០។

[609] សាលដីកា ០០២/០១ កំណត់សម្គាល់ជើងទំព័រ៩៣៧។

៦៤២. ករណីលើកលែងទាំងនេះមិនមានទម្ងន់ទល់នឹងចំនួន ២១៥ដង ដែលអង្គជំនុំជម្រះបានប្រកាសត្រឹមតែ "ជឿជាក់ (" *Satisfied* " អង់គ្លេស)"[610]។ ករណីលើកលែងទាំងនេះក៏គ្មានទម្ងន់ដែរ ទល់នឹងចំនួននៃសេចក្តីសន្និដ្ឋានដែលតុលាការកំពូលបានទម្លាក់ចោលដោយមូលហេតុថាធាតុផ្សំភស្តុតាងដែលជាបង្អែករបស់អង្គជំនុំជម្រះមិនមែនជាមូលដ្ឋានគ្រប់គ្រាន់ ដើម្បីទាញការសន្និដ្ឋានមួយឱ្យហួសពីវិមតិសង្ស័យ[611] ឬដោយមូលហេតុថាវាជាសេចក្តីសន្និដ្ឋានមិនមានហេតុផល[612] ដែលភាគច្រើនមិនមានការពន្យល់អំពីមូលហេតុ[613]។

៦៤៣. ក្នុងល័ក្ខខ័ណ្ឌទាំងនេះ និងដោយសុឆន្ទៈ វាមានការលំបាកក្នុងការមិនទទួលស្គាល់ថា អង្គជំនុំជម្រះមិនបានអនុវត្តស្តង់ដារនៃការជឿជាក់ដែលភាគច្រើនទាបជាងការជឿជាក់ហួសពីវិមតិសង្ស័យ។

៦៤៤. ជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលបានព្យាយាមរំឮកយ៉ាងវែងអំពីវិធីសាស្ត្រដែលត្រូវគោរពក្នុងវិស័យនេះ៖

---

[610] សាលក្រម ០០២/០១ កថាខណ្ឌ ៨០ ១១០ ១១១ ១១២ ១១៦ ១២៤ ១២៧ (**ពីរដង**) ១៣២ ១៣៤ ១៤២ ១៤៤ ១៥១ ១៥២ ១៧៩ ១៨២ ១៩៣ ១៩៥ ១៩៧ (**ពីរដង**) ២២៨ ២៦៤ ២៦៦ ២៧៣ ៣២៣ ៣៦២ ៣៧២ ៣៧៣ ៣៧៨ ៣៩៣ ៤១៩ ៤៥២ ៤៥៣ ៤៩៦ ៥១៥ ៥២០ ៥២១ ៥៣៤ ៥៤៧ ៥៤៨ ៥៥៣ ៥៥៦ ៥៥៨ ៥៦១ ៥៦២ ៥៦៥ ៥៧១ (**ពីរដង**) ៥៨០ ៥៨១ ៦២១ ៦៤៣ ៦៥៦ (**ពីរដង**) ៦៦៧ ៦៧៧ ៦៨១ ៦៨៣ ៦៨៤ ៦៨៦ ៧៤២ ៧៤៦ ៧៤៧ ៧៤៩ ៧៥០ ៧៥៣ ៧៧១ (**ពីរដង**) ៧៧៧ ៨០៤ ៨០៦ ៨០៧ ៨១០ ៨២៦ ៨២៩ ៨៣៥ ៨៣៦ (**ពីរដង**) ៨៤៤ ៨៤៥ ៨៤៦ ៨៤៧ ៨៤៨ ៨៤៩ ៨៥១ ៨៥២ ៨៥៤ ៨៥៦ ៨៥៩ ៨៦១ ៨៦២ (**ពីរដង**)៨៦៧ (**ពីរដង**) ៨៦៩ ៨៧៥ ៨៧៨ ៨៧៩ ៨៨០ ៨៨២ ៨៨៤ ៨៨៥ ៨៨៦ (**ពីរដង**) ៨៨៧ (បីដង) ៨៨៨ (**ពីរដង**) ៨៨៩ ៨៩១ ៨៩៤ ៨៩៦ ៨៩៧ ៨៩៨ ៨៩៩ ៩០៤ (បីដង) ៩០៦ ៩០៨ (បីដង) ៩០៩ (**ពីរដង**) ៩១០ ៩១១ ៩១២ (**ពីរដង**) ៩១៣ ៩១៤ ៩១៥ ៩១៧ ៩១៨ ៩២០ ៩២១ ៩២៣ ៩២៤ ៩២៥ (**ពីរដង**) ៩២៦ (ប្រាំដង) ៩២៧ (**ពីរដង**) ៩២៨ ៩២៩ ៩៣០ ៩៣៣ ៩៣៤ ៩៣៦ ៩៣៧ ៩៣៩ ៩៤៩ ៩៥០ ៩៥២ ៩៥៣ (បីដង) ៩៥៥ ៩៥៧ ៩៥៨ ៩៦៣ ៩៦៥ ៩៧២ (**ពីរដង**) ៩៧៩ ៩៩៥ ៩៩៧ (**ពីរដង**) ៩៩៩ ១០០០ ១០០២ ១០០៥ ១០០៦ (**ពីរដង**) ១០០៨ ១០០៩ ១០១០ ១០១១ (**ពីរដង**) ១០១២ ១០១៥ ១០២១ ១០២២ ១០២៣ ១០៣០ ១០៣២ ១០៣៣ ១០៣៤ ១០៣៥ ១០៣៨ ១០៣៩ ១០៤១ ១០៤២ ៤០១៦ ១០៤៧ ១០៤៨ ១០៤៩ ១០៥០ (**ពីរដង**) កំណត់សម្គាល់ជើងទំព័រ ២០៩៦ និង ២៥៨៦។

[611] ឧទាហរណ៍៖ សាលដីកា ០០២/០១ កថាខណ្ឌ ៤៣០ ៤៣៥ ៤៣៦ ៤៤០ ៤៤១ ៤៤៦ ៤៤៧ ៤៥៤ ៤៥៦ ៤៥៧ ៤៦៩ ៤៧០ ៤៧១ ៤៨៤ ៥៣៧ ៥៤០ ៥៥០ ៦០០ ៩៧២ ១១១៧ កំណត់សម្គាល់ជើងទំព័រ ១១៨២។

[612] ឧទាហរណ៍៖សាលដីកា ០០២/០១ កថាខណ្ឌ ៤៤៣ ៤៤៨ ៤៥៥ ៥៣៦ ៦៣៧ ៦៤០ ៦៥៥ ៦៥៨ ៧០២ ៨៦៥ ៨៨៤ ៩៣២ ១០០៩ ១០៧៣ ១០៨០ ១០៨៣ កំណត់សម្គាល់ជើងទំព័រ ២៦៥៣។

[613] ឧទាហរណ៍៖សាលដីកា ០០២/០១ កថាខណ្ឌ ៤៣០ ៤៣៦ ៤៤៦ ៤៧០ ៥៥០ ៦០០ ៦៤០។

“យោងតាមយុត្តិសាស្ត្រដែលពាក់ព័ន្ធរបស់តុលាការឧក្រិដ្ឋកម្ម*មិនអចិន្ត្រៃយ៍* ដែលអង្គជំនុំជម្រះតុលាការកំពូលជឿជាក់នោះ បានបង្ហាញថា ពុំមែនរាល់អង្គហេតុនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ លើកលែងតែអង្គហេតុដែលជាមូលដ្ឋាននៃធាតុផ្សំបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវ រួមទាំងអង្គហេតុដែលសំខាន់ដោយខ្វះពុំបានសម្រាប់ការសម្រេចដាក់ពិរុទ្ធភាព ជាពិសេសអង្គហេតុដែលបង្កើតបានជាធាតុផ្សំនៃបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់លើជនជាប់ចោទ។ តាមពាក្យពេចន៍ជាក់ស្តែង អាចមានអង្គហេតុដទៃទៀតដែលចាំបាច់ត្រូវបង្ហាញឱ្យហួសពីវិមតិសង្ស័យ ដោយសារតែមានការតវ៉ាក្នុងរឿងក្តី។ ទោះជាយ៉ាងណាក្តី ក្នុងករណីមានតែភ័ស្តុតាងមិនផ្ទាល់ ហើយ“ប្រសិនបើភ័ស្តុតាងណាមួយ ដែលតភ្ជាប់ទៅនឹងភ័ស្តុតាងដទៃទៀតនោះពុំត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យ នោះដំណើរជាខ្សែសង្វាក់នៃភ័ស្តុតាងទាំងមូល ពុំគាំទ្រដល់ការដាក់ពិរុទ្ធភាពឡើយ”។ ទាក់ទងទៅនឹងការបង្ហាញពីធាតុផ្សំចាំបាច់យ៉ាងដូចម្តេច នេះមានន័យថា ត្រូវអនុវត្តតាមបទដ្ឋានក្នុងការបង្ហាញភ័ស្តុតាងនីមួយៗដាច់ដោយឡែកពីគ្នាឱ្យហួសពីវិមតិសង្ស័យ។ ផ្ទុយទៅវិញ តុលាការអង្គហេតុត្រូវតែ“ជឿជាក់ឱ្យហួសពីវិមតិសង្ស័យ ដោយផ្អែកលើភ័ស្តុតាងទាំងមូលថា មានការបង្ហាញរាល់អង្គហេតុទាំងអស់ដែលជាធាតុផ្សំនៃបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវ ត្រូវបានធ្វើឡើង ព្រមទាំងអង្គហេតុដែលសំខាន់មិនអាចខ្វះបានសម្រាប់ការសម្រេចដាក់ពិរុទ្ធភាព។ ដូចគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC យល់ឃើញថា នៅពេលកំណត់ពីបញ្ហា ថាតើបទដ្ឋាននេះត្រូវបានបំពេញ ដែរ ឬយ៉ាងណា តុលាការអង្គហេតុត្រូវបានតម្រូវឱ្យធ្វើការវាយតម្លៃជារួម និងថ្លឹងថ្លែងលើរាល់*ភ័ស្តុតាងទាំងអស់បញ្ចូលគ្នា*ទាក់ទងទៅនឹងអង្គហេតុនោះ។

“ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា វិធីសាស្ត្រប្រើប្រាស់ចំពោះភ័ស្តុតាងត្រួតគ្នា ឬទាំងមូល ត្រូវបានគិតទុកជាមុនដើម្បីប្រើប្រាស់ជាចម្បងទាក់ទងទៅនឹងភាពអាចជឿទុកចិត្តបានចំពោះភ័ស្តុតាងនីមួយៗ ដោយផ្អែកលើអត្ថិភាពនៃការបញ្ជាក់បន្ថែមនៃភ័ស្តុតាង ហើយពាក្យពេចន៍នេះត្រូវបានប្រើប្រាស់ទាក់ទងទៅនឹងភាពគ្រប់គ្រាន់នៃភ័ស្តុតាងមិនផ្ទាល់ក្នុងការបង្ហាញនូវអង្គហេតុសំខាន់ៗ ឱ្យហួសពីវិមតិសង្ស័យ ជាងអង្គហេតុដទៃទៀត។ ទោះជាយ៉ាងណាក្តី យុត្តិសាស្ត្រនេះពុំបានគាំទ្រដល់ការអះអាងដែលថា ភ័ស្តុតាងផ្សេងៗជាច្រើន អាចបូកគ្នាដើម្បីបំពេញតាមលក្ខខណ្ឌក្នុងការបង្ហាញឱ្យហួសពីវិមតិសង្ស័យដោយផ្អែកលើភ័ស្តុតាងរួម ដោយពុំគិតពីទម្ងន់នៃភ័ស្តុតាងនីមួយៗឡើយ។ ពិតណាស់ វិធីសាស្ត្របែបនេះមានន័យ

ថា ជនជាប់ចោទអាចត្រូវបានសម្រេចដាក់ពិរុទ្ធភាព ដោយត្រឹមតែផ្អែកលើមូលដ្ឋាននៃពាក្យចចាមអារ៉ាម ទូទៅប៉ុណ្ណោះ”[614]។

៦៤៥. នៅក្នុងសាលដីកា *Ntagerura* ដែលជាបង្អែកនៃតុលាការកំពូល អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេស Rawanda បានពន្យល់យ៉ាងច្បាស់អំពីលំដាប់លំដោយនៃ “ដំណាក់កាលបីនៃដំណើរការបង្ហាញអង្គហេតុ ដែលនាំឱ្យមានការប្រកាសពិរុទ្ធភាពនៅទីបញ្ចប់”៖

១.អង្គជំនុំជម្រះត្រូវតែវាយតម្លៃលើភាពគួរឱ្យជឿជាក់បាននៃធាតុផ្សំភ័ស្តុតាងពាក់ព័ន្ធដែលដាក់ចំពោះមុខតុលាការ។ ធាតុផ្សំភ័ស្តុតាងដែលទទួលបានពីបុគ្គលត្រូវតែបានវិភាគដោយប្រៀបធៀបជាមួយនឹងមធ្យោបាយភ័ស្តុតាងទាំងអស់ផ្សេងទៀត ដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះ។

២. បន្ទាប់ពីបានវិភាគធាតុផ្សំភ័ស្តុតាងពាក់ព័ន្ធទាំងស្រុងហើយ អង្គជំនុំជម្រះត្រូវសម្រេចថាតើមធ្យោបាយភ័ស្តុតាងត្រូវបានទទួលយកជាភ័ស្តុតាងបង្ហាញអំពីអត្ថិភាពនៃអង្គហេតុចោទប្រកាន់ដែរ ឬអត់ ទោះបីជាមានភ័ស្តុតាងដោះបន្ទុកដែលបានលើកឡើងក្តី។ នៅក្នុងដំណាក់កាលទីពីរនេះ គោលការណ៍បង្ហាញអំពីភ័ស្តុតាងឱ្យហួសពីវិមតិសង្ស័យត្រូវតែអនុវត្តប្រសិនបើវាជាការបង្ហាញអត្ថិភាពនៃធាតុផ្សំឧក្រិដ្ឋកម្មណាមួយ ឬធាតុផ្សំនៃទម្រង់នៃការទទួលខុសត្រូវដែលចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ឬក៏ប្រសិនបើវាជាការបង្ហាញអត្ថិភាពនៃអង្គហេតុដ៏ចាំបាច់ណាមួយដើម្បីអាចផ្តន្ទាទោសជនជាប់ចោទ។

៣. នៅដំណាក់កាលចុងក្រោយ អង្គជំនុំជម្រះត្រូវតែកំណត់ថា តើធាតុផ្សំឧក្រិដ្ឋកម្មទាំងអស់ ឬធាតុផ្សំនៃទម្រង់ទំនួលខុសត្រូវទាំងអស់ដែលចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទត្រូវបានបង្ហាញថា ពិតជាមានមែន ឬអត់ នៅក្នុងដំណាក់កាលទាំងពីរខាងលើ[615]។

៦៤៦. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានសន្និដ្ឋានថា៖

---

[614] សាលដីកា ០០២/០១, 418-419 (ឯកសារយោងភ្លេច)។

[615] សាលដីកា *Ntagerura* (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា) ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ១៧៤។

"គោលការណ៍សច្ចធារណ៍និរទោសតម្រូវឱ្យរាល់អង្គហេតុដែលជាមូលដ្ឋាននៃការផ្ដន្ទាទោសជនជាប់ចោទ ត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យ។ [...] ប្រសិនបើនៅពេលចុងបញ្ចប់នៃរឿងក្ដី អង្គហេតុសំខាន់ៗ ទាំងឡាយសម្រាប់បង្ហាញពីពិរុទ្ធភាពនៅតែជាកម្មវត្ថុនៃការមន្ទិលសង្ស័យ ដោយពុំមានអង្គហេតុដទៃទៀត គាំទ្រ ទាំងនេះបង្កឱ្យមានការសង្ស័យក្នុងស្មារតីរបស់អង្គជំនុំជម្រះ ដើម្បីដឹងថា តើភ័ស្តុតាងត្រូវបានដាក់ ចំពោះមុខខ្លួន ហួសពីវិមតិសង្ស័យដែរ ឬអត់?"[616]

៦៤៧. ក្នុងសាលដីកា *Limaj* អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានប្រកាសទៀតថា៖

"គោលការណ៍វិមតិសង្ស័យត្រូវតែជាប្រយោជន៍ជនជាប់ចោទ ដែលជាអនុសាធ្យនៃសច្ចធារណ៍សច្ចធារណ៍ និរទោសនិរទោសនូវកាតព្វកិច្ចបង្ហាញអំពីពិរុទ្ធភាពឱ្យហួសពីវិមតិសង្ស័យ អនុវត្តចំពោះសេចក្ដីសន្និដ្ឋាន ចាំបាច់ដើម្បីសម្រេចថាជនជាប់ចោទមានពិរុទ្ធភាព ដូចជាការសង្កេតថា ឧក្រិដ្ឋកម្មត្រូវបានរកឃើញថាមាន ធាតុផ្សំគ្រប់គ្រាន់។ វិធីសាស្ត្រនេះមិនត្រឹមតែជាមាគ៌ានៃយុត្តិសាស្ត្រនៃតុលាការអន្តរជាតិប៉ុណ្ណោះទេ គឺវា ថែមទាំងមានហេតុមានផលទៀតផង ដោយហេតុថា ចំពោះបញ្ហាអង្គហេតុ គោលការណ៍សច្ចធារណ៍ និរទោសមិនមែនគ្រាន់តែជាធាតុផ្សំនៃវិធានដែលតម្រូវឱ្យមានការបង្ហាញពិរុទ្ធភាពឱ្យហួសពីវិមតិសង្ស័យ នោះទេ"[617]។

៦៤៨. អាស្រ័យហេតុដូចនេះ អង្គជំនុំជម្រះមិនអាចលាក់ខ្លួននៅក្រោយ "វិធីសាស្ត្ររួម" ដែលត្រូវដោះស្រាយ "ភាពចម្រូងចម្រាស" ដែលមិនមានរវាងការជឿជាក់ដោយឥស្សរចិត្ត និងការជឿជាក់ហួសពីវិមតិសង្ស័យដែលជាសញ្ញាណតែមួយគត់ដែលត្រូវអនុវត្តចំពោះមុខ អ.វ.ត.ក។ អង្គជំនុំជម្រះត្រូវតែអនុវត្តយ៉ាងម៉ត់ចត់នូវវិធានស្ដីអំពីការបង្ហាញពិរុទ្ធភាពឱ្យហួសពីវិមតិសង្ស័យ និងគោលការណ៍ការមន្ទិលសង្ស័យត្រូវតែជាប្រយោជន៍ជនជាប់ចោទដែលជាអនុសាធ្យនៃគោលការណ៍សច្ចធារណ៍និរទោស។

៦៤៩. ការរំឭកនេះកាន់តែចាំបាច់ទៅទៀត ដោយហេតុថាអង្គជំនុំជម្រះបានផ្ដន្ទាទោសជនជាប់ចោទក្នុងសំណុំរឿង ០០២/០១ រួចទៅហើយ ដោយបានទាញការសន្និដ្ឋានទុកជាមុនសម្រាប់សំណុំរឿង ០០២/០២ ដែលក្នុងពេលជំនុំជម្រះខ្លួនបានបង្ហាញពីភាពអគតិ។

---

[616] សាលដីកា *Ntagerura* (TPIR) ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ១៧៥។

[617] សាលដីកា *Limaj* (TPIY) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧ កថាខណ្ឌ ២១។

## ភាគទី ៥ .សមធម៌

៦៥០. ស្នូម្បីតែជនជាប់ចោទនៅ អ.វ.ត.ក ក៏មានសិទ្ធិទទួលបាននូវសច្ចធារណ៍និរទោស និងតុលាការមួយដែលមិនលម្អៀងដែរ[618]។ ជាអកុសល ចៅក្រមនៃ អ.វ.ត.ក មិនមែនជាគំរូផ្នែកគោរពគោលការណ៍នេះទេ។ ជាក់ស្ដែង ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះមិនរារែកក្នុងការសន្និដ្ឋានទុកជាមុនសម្រាប់សំណុំរឿង ០០២/០២ នោះទេ (ជំពូកទី I)។ វាជាការជំនុំជម្រះសេចក្ដីដែលអង្គជំនុំជម្រះបង្ហាញអំពីភាពអគតិរបស់ខ្លួនទៀត (ជំពូកទី II)។

### ជំពូកទី ១. ការសន្និដ្ឋានទុកជាមុនក្នុងសំណុំរឿង ០០២/០១

៦៥១. ពេលចេញសាលក្រមនៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះមិនរារែកក្នុងការទាញការសន្និដ្ឋានលើអង្គហេតុដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ទោះបីជាអង្គហេតុទាំងនេះជាអង្គហេតុដូចគ្នានឹងអង្គហេតុក្នុងសំណុំរឿង ០០២/០១ ក្ដី ឬទោះវាជាអង្គហេតុដាច់ដោយឡែកសម្រាប់តែសំណុំរឿង ០០២/០២ ក្ដី។

៦៥២. ក្រុមប្រឹក្សាជំនុំជម្រះពិសេសមួយបានបដិសេធបណ្ដឹងជំទាស់ប្រឆាំងអង្គជំនុំជម្រះ ដែលបានដាក់ដោយក្រុមមេធាវីការពារក្ដីបន្ទាប់ពីបានចេញសាលក្រម។[619] ទោះបីជាចៅក្រមម្នាក់ក្នុងចំណោមចៅក្រមទាំងអស់នេះ បានបញ្ចេញមតិជំទាស់ដោយផ្អែកដែលមានសំអាងហេតុយ៉ាងច្បាស់ក៏ដោយ ។ ជាក់ស្ដែង តាមយោបល់របស់លោកចៅក្រម DOWNING សេចក្ដីសន្និដ្ឋានទុកជាមុនទាំងនេះវាជាការគ្រប់គ្រាន់ដើម្បីញ៉ាំងឱ្យអ្នកសង្កេតប្រកបដោយវិចារណញ្ញាណ និងដែលដឹងព័ត៌មានត្រឹមត្រូវមានការខ្លាចក្រែងដោយមានហេតុផលអំពីភាពលម្អៀងពីសំណាក់ចៅក្រមដែលទទួលរងបណ្ដឹងជំទាស់។ ចៅក្រម DOWNING ថែមទាំងបានភ្ជាប់ឧបសម្ព័ន្ធយ៉ាងលម្អិតដែលក្នុងនោះ

[618] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា នៅមាត្រា ១២ និង ១៣ ។ ច្បាប់ស្ដីពីការបង្កើត អង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅមាត្រា ៣៣ (ថ្មី) ។ កាតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅមាត្រា ១៤។ វិធានផ្ទៃក្នុងនៅវិធាន ២១ និង ៣៤-២។

[619] **សេចក្ដីសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះពិសេស** ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ **ឯកសារ** E314/12។ សំអាងហេតុនៃ**សេចក្ដីសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះពិសេស** ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ** E314/12/1។

សម្រាប់ជនជាប់ចោទនីមួយៗមានអត្ថបទដកស្រង់ពីដីកាដំណោះស្រាយ និងការសន្និដ្ឋានពាក់ព័ន្ធ ដែលមាននៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០១ ក្រោមចំណងជើងថា "ការកំណត់ទុកជាមុន នៃបញ្ហាអង្គហេតុទាក់ទងនឹងទំនួលខុសត្រូវព្រហ្មទណ្ឌ[ជនជាប់ចោទ]ចំពោះឧក្រិដ្ឋកម្មដែលត្រូវ ជំនុំជម្រះនៅក្នុងសំណុំរឿង [០០២/០២]"[620]។

៦៥៣. ក្នុងសាលដីកានៃសំណុំរឿង ០០២/០១ តុលាការកំពូលបានរំឭកថាខ្លួនបាន *"ចង្អុលបង្ហាញដដែលៗ អំពីបញ្ហានេះ"* និងបានយោងទៅសេចក្តីសម្រេចដែលខ្លួនបានចេញពីមុនមកលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី (ដែលនៅក្នុងសេចក្តីសម្រេចទាំងនេះ តុលាការកំពូលណែនាំឱ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយសម្រាប់សំណុំរឿង ០០២/០២) មុននឹងប្រកាសថាបញ្ហានេះមិនជះឥទ្ធិពលអ្វីទាំងអស់ទៅលើសំណុំរឿង ០០២/០១។[621] ម្យ៉ាងទៀត ចំពោះអង្គជំនុំជម្រះតុលាការកំពូល សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ដែលមិនជះឥទ្ធិពលទាល់តែសោះទៅលើការ ផ្តន្ទាទោស គ្រាន់តែមានតម្លៃជា (*dictum*) ដែលមិនអាចជាកម្មវត្ថុនៃការជំនុំជម្រះក្នុងបណ្តឹងឧទ្ធរណ៍[622] ។

៦៥៤. សញ្ញាណនៃការព្រលយពាក្យ *(Un obiter dictum)* មានន័យដូចខាងក្រោម៖

> "ជាសំនួនវោហារក្នុងភាសាឡាតាំង [...] ដែលប្រើសម្រាប់កំណត់ក្នុងសាលក្រម នូវមតិយោបល់ដែលចៅក្រមសម្តែង ជាមុន ជាការប្រាប់ឱ្យដឹងមុន គឺជាការចង្អុលបង្ហាញម្តងម្កាល ដែលខុសពីសំអាងហេតុ ហើយទោះជាវាមានច្រើនលើសលប់ក៏ដោយ ក៏វាពុំមានបំណងបញ្ជាក់ពីមូលហេតុនៃសេចក្តីសម្រេចដែលមានប្រើពាក្យព្រលយដែរ <u>គឺវាគ្រាន់តែប្រើសម្រាប់ឱ្យដឹងជាមុន ក្នុងគោលបំណងសមស្របទាំងឡាយ នូវអារម្មណ៍របស់ចៅក្រមលើបញ្ហាមួយផ្សេងទៀតក្រៅពីបញ្ហាដែលត្រូវតែអារកាត់ក្នុងរឿងក្តីកំពុងជំនុំជម្រះ"</u> (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។[623]

---

[620] មតិយោបល់ជំទាស់ដោយផ្នែករបស់ចៅក្រម DOWNING ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E319/12/1**។ ឧបសម្ព័ន្ធ **ឯកសារ E319/12/1**។

[621] សាលដីកា ០០២/០១ កថាខណ្ឌ ២២៨ និង កំណត់សម្គាល់ជើងទំព័រ ៥៦០។

[622] សាលដីកា ០០២/០១ កថាខណ្ឌ ២២៩។

[623] នីតិវាក្យស័ព្ទគាត់តែងដោយ G. CORNU, PUF, បោះពុម្ពលើកទី ៨ ឆ្នាំ ២០០៧ « *Obiter dictum* »។

៦៥៥. ជាក់ស្តែង សេចក្តីសន្និដ្ឋានក្នុងសំណុំរឿង ០០២/០២ ដែលអង្គជំនុំជម្រះបានទាញទុកជាមុន មិនត្រឹមតែប៉ះពាល់ដល់សច្ចធារណ៍និរទោសចំពោះជនជាប់ចោទប៉ុណ្ណោះទេ គឺវាថែមទាំងជាការកាត់សេចក្តីលើសំណុំរឿង ០០២/០២ ទុកជាមុន ទៀតផង។

៦៥៦. សូម្បីតែអង្គជំនុំជម្រះតុលាការកំពូលក៏មិនសំចៃមាត់ដែរ ពេលដែលខ្លួនប្រកាសថា៖

> "ជាការពិត ទំនងជាបង្ហាញថា ការដាក់ប្រជាជនឱ្យក្លាយជាទាសករ គឺជាគោលដៅមួយក្នុងចំណោមគោលដៅចម្បងនានានៃរបបខ្មែរក្រហម ដែលការផ្លាស់ទីលំនៅប្រជាជន គឺជាជំហានដំបូងបង្អស់"[624]។

៦៥៧. ការប៉ងប្រាថ្នាកុំឱ្យអង្គជំនុំជម្រះទទួលឥទ្ធិពលពី*ការពោលយពាក្យ (obiter dictum)* របស់អង្គជំនុំជម្រះតុលាការកំពូល និងពីការដែលអង្គជំនុំជម្រះបានបង្ហាញឱ្យដឹងពីអារម្មណ៍របស់ខ្លួនស្រាច់បាត់ទៅហើយ ចំពោះបញ្ហាដែលខ្លួនត្រូវអារកាត់ក្នុងពេលបច្ចុប្បន្ននេះ គ្រាន់តែជាការប៉ងប្រាថ្នារវើរវាយតែប៉ុណ្ណោះ។

៦៥៨. ការពិតគឺថា ខៀវ សំផន ត្រូវបានកាត់សេចក្តីដោយចៅក្រម ដែលទោះជាមិនមើលងាយគាត់យ៉ាងខ្លាំង ក៏មើលងាយសច្ចធារណ៍និរទោសដល់កម្រិតដែរ។

## ជំពូកទី ២. ការបង្ហាញអំពីភាពអគតិក្នុងសំណុំរឿង ០០២/០២

៦៥៩. ទោះបីជាក្នុងពេលនេះ យើងមិនអាចស្រង់រាល់កត្តាបង្ហាញពីភាពលំអៀងរបស់អង្គជំនុំជម្រះទៅខាងសហព្រះរាជអាជ្ញា និងប្រឆាំងនឹង ខៀវ សំផន ក្នុងពេលជំនុំជម្រះក៏ដោយ ក៏គប្បីផ្តល់ឧទាហរណ៍ជាក់ស្តែងមួយចំនួន។

### ផ្នែកទី ១. រឿងក្តីក្នុងដំណាក់កាលស៊ើបអង្កេតជាក់បន្ទុក

[624] សាលដីកា ០០២/០១ កថាខណ្ឌ ៨២៨។

៦៦០. ទោះបីជាមានរយៈពេលយ៉ាងវែងសម្រាប់ដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលត្រៀមលក្ខណៈចូលរួមក្នុងរឿងក្ដីក៏ដោយ ក៏សំណុំរឿង ០០២/០២ ត្រូវបានកែប្រែទាំងស្រុងទៅជាការស៊ើបអង្កេតដាក់បន្ទុក។ ជាក់ស្ដែង អង្គជំនុំជម្រះបណ្ដោយឱ្យសហព្រះរាជអាជ្ញាដាក់ធាតុផ្សំភ័ស្ដុតាងថ្មីជាសក្ខីកម្ម និងជាឯកសារ ជាច្រើន ក្នុងពេលជំនុំជម្រះសេចក្ដី (ដែលភាគច្រើនចេញពីការស៊ើបអង្កេតកំពុងដំណើរការក្នុងសំណុំរឿង ០០៣ និង០០៤)។ នៅពេលដែលអង្គជំនុំជម្រះបានបញ្ចូលភ័ស្ដុតាងដោយចិត្តឯង ក្នុងពេលការជំនុំជម្រះកំពុងដំណើរការ គឺខ្លួនដាក់ធាតុផ្សំដាក់បន្ទុកថែមទៀត[625]។

៦៦១. ដោយផ្ដល់បញ្ជីឈ្មោះសាក្សីដែលខ្លួនចង់ស្ដាប់សក្ខីកម្ម ម្ដងមួយតក់ៗ ដោយគ្មានសំអាងហេតុ អង្គជំនុំជម្រះបានចំហទ្វារទទួលការបញ្ចូលសក្ខីកម្មដាក់បន្ទុកថ្មី ដោយមិនរារែក ដរាបណាភ័ស្ដុតាងទាំងនេះអាចប៉ះប៉ូវកង្វះខាតនៃសក្ខីកម្មដែលខ្លួនបានស្ដាប់រហូតមកដល់ពេលនោះ[626]។

៦៦២. ក្នុងពេញមួយអំឡុងពេលជំនុំជម្រះ ក្រុមមេធាវីការពារក្ដីហើបក្បាលមិនរួចពីទឹក ដោយសារតែត្រូវឆ្លើយតបនឹងសំណើរបស់ភាគីដទៃទៀតផង (ដែលជាទូទៅ ដាក់នៅនាទីចុងក្រោយ) និងដោយសារតែការដាក់ធាតុផ្សំភ័ស្ដុតាងថ្មីទាំងនេះផង។ តាមតថភាពនេះ ក្រុមមេធាវីការពារក្ដីបង្ខំចិត្តត្រៀមខ្លួនសម្រាប់រឿងក្ដីក្នុងរឿងក្ដីដែលផែនការជំនុំជម្រះប្រែប្រួលមិនចេះចប់មិនចេះហើយ។

៦៦៣. ការបញ្ចូលភ័ស្ដុតាងថ្មីទាំងនេះបានអូសបន្លាយការជំនុំជម្រះសេចក្ដីដែលកំពុងតែដំណើរការ។ អង្គជំនុំជម្រះជ្រើសយកការស្ដាប់សក្ខីកម្មរបស់សាក្សីដាក់បន្ទុកថ្មីៗទៀត ដែលជួនកាលក្រៅវិសាលភាព[627] និងជ្រើសយកការទទួលចម្លើយជាលាយលក្ខណ៍អក្សរដ៏សន្ធឹកសន្ធាប់ ដែលភាគច្រើនក្រៅ

---

[625] ឧទាហរណ៍៖ កែវ ចន្ទតារា ម៉ុយ វ៉ាន់នី សយ ឌឿន ព្រាប សុខឿន ច្បាប់ចម្លងនៃឯកសារបកប្រែពីភាសាវៀតណាម ដែលគ្មានតម្លៃជាភស្ដុតាង (សេចក្ដីសម្រេច ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ** E327/4/7)។

[626] ឧទាហរណ៍៖ សាក្សីពាក់ព័ន្ធនឹងការប្រព្រឹត្តលើជនជាតិចាម និងជនជាតិវៀតណាម ដែលស្នើដោយព្រះរាជអាជ្ញា នៅក្នុងសំណើរបស់ខ្លួន ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ** E366, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ** E381 និង ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ** E382។

[627] ឧទាហរណ៍៖ ដើមបណ្ដឹងរដ្ឋប្បវេណីស៊ុន វុទ្ធ (សូមមើលខាងក្រោមនៅកថាខណ្ឌ ១៩១៧-១៩៣៨។

វិសាលភាព និងតែងតែមានតម្លៃជាភស្តុតាងតិចបំផុត[628] ជាជាងការទទួលយកមនុស្សពីរបីនាក់ ដែលក្រុមមេធាវីការពារក្តីបានស្នើតាំងពីមុនពេលចាប់ផ្តើមជំនុំជម្រះ[629]។ អាស្រ័យហេតុនេះហើយ បានជា ក្នុងចំណោមសក្ខីកម្មសរុបចំនួន ១៨៦ ដែលអង្គជំនុំជម្រះបានស្តាប់ មានតែពីរប៉ុណ្ណោះ ដែលត្រូវបានស្នើឡើងដោយក្រុមមេធាវីការពារក្តី គឺត្រូវនឹង ១,០៧ %[630]។

៦៦៤. ទោះបីជាក្រុមមេធាវីការពារក្តីបានទទូចសុំកោះហៅ Stephen HEDER និង François PONCHAUD ដែលទាំងពីរនាក់សុទ្ធតែចាត់ទុកថាអាចជឿជាក់បាន ក្នុងសំណុំរឿង ០០២/០១ និងមានរឿងនិយាយច្រើនលើបញ្ហាទាំងឡាយដែលជាកម្មវត្ថុនៃការពិចារណាក្នុងសំណុំរឿង ០០២/០២ ហើយដែលពួកគាត់មិនត្រូវបានសួរដេញដោលលើបញ្ហាទាំងនេះក្នុងសំណុំរឿង ០០២/០១[631] ក៏ដោយ ក៏អង្គជំនុំជម្រះបានជ្រើសយកការកោះហៅសាក្សីម្នាក់ដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ជាករណីលើកលែង លើអង្គហេតុទាំងអស់នៃសំណុំរឿង ០០២[632]។ ក្នុងខណៈដែលពីដំបូង គ្រោងស្តាប់តែ ៨ នាក់ អង្គជំនុំជម្រះថែមទាំងបានជ្រើសយកការស្តាប់សក្ខីកម្មដល់ទៅ១៦ ក្នុងវគ្គសវនាការលើការរៀបអាពាហ៍ពិពាហ៍ នៅពេលដែលខ្លួនទទួលយកសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំពង្រីកវិសាលភាពនៃការពិនិត្យពិចារណាក្នុងសំណុំរឿង ០០២/០២ ទៅដល់ការចោទប្រកាន់ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ក្នុងកម្រិតទូទាំងប្រទេសតែម្តង[633]។ អង្គជំនុំជម្រះថែមទាំងសម្រេចស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ក្នុងចំណោមពួកគាត់ទាំង

---

[628] ឧទាហរណ៍៖ សេចក្តីសម្រេចចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ **ឯកសារ E319/7**, ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ E319/17/1**, ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E319/22/1**, ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E319/32/1**។

[629] សាក្សី និងអ្នកជំនាញដែលស្នើដោយខៀវ សំផន ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E305/5** និងឧបសម្ព័ន្ធ**ឯកសារ E305/5.2** (សង្ខេប)។

[630] អ្នកជំនាញ Peg LEVINE និងសាក្សីជួន ធី។

[631] ឧទាហរណ៍៖សំណោះរបស់ខៀវ សំផន ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E408/6**, ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E408/6/1**។ អង្គជំនុំជម្រះយល់ឃើញដោយអសុគន្ធៈថាការរលឹកពួកគាត់ក្នុងសំណុំរឿង០០២/០២ មានលក្ខណៈច្រំដែល ហើយ "បានត្រឹមតែពន្យានីតិវិធីដោយគ្មានមូលហេតុគាំទ្រ"។ (អនុស្សរណៈ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E408/6/2** កថាខណ្ឌ ៦) ។ប្រការនេះហួសពីការចំអកឡកលើយទៅទៀត បើយើងពិនិត្យមើលការចំណាយពេលដោយឥតប្រយោជន៍ ដើម្បីទទួលយក និង/ឬស្តាប់សក្ខីកម្មក្រៅវិសាលភាព និង/ឬដែលស្ទើរតែគ្មានតម្លៃជាភស្តុតាង និងដើម្បីកោះហៅ សៅ សារុនមកម្តងទៀត។

[632] សៅ សារុន សូមមើលអនុស្សរណៈ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២ **ឯកសារ E194**។

[633] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1** កថាខណ្ឌ ៣៣។

អស់ បន្ទាប់ពីសហព្រះរាជអាជ្ញាបានបង្ហាញកំណត់ហេតុស្តាប់ចម្លើយចេញពីសំណុំរឿង ០០៤ របស់គាត់ នៅក្នុងពេលសវនាការលើឯកសារគន្លឹះ[634]។ ដោយមិនគិតថាមនុស្សជាច្រើនដែលត្រូវបានស្តាប់សក្ខីកម្មលើវគ្គផ្សេងៗទៀតនៃការជំនុំជម្រះ បានផ្តល់សក្ខីកម្មលើការរៀបអាពាហ៍ពិពាហ៍ដែរ...។

៦៦៥. ដូច្នេះ អង្គជំនុំជម្រះបានសណ្តោស និងសម្រួលយ៉ាងខ្លាំងដល់ការងាររបស់សហព្រះរាជអាជ្ញាក្នុងការស្វែងរកភស្តុតាងថ្មី ទោះបីជាដំណាក់កាលស៊ើបអង្កេតបានអូសបន្លាយយ៉ាងយូរក៏ដោយ។ ទង្វើនេះបង្កផលប៉ះពាល់ដល់សក្ខីកម្មពីរយ៉ាងសំខាន់ចំពោះក្រុមមេធាវីការពារក្តី និងការជំនុំជម្រះឆាប់រហ័ស។

## ផ្នែកទី ២. ការសន្មតទុកជាមុនអំពីសុចន្ទៈរបស់សហព្រះរាជអាជ្ញា និងអសុចន្ទៈរបស់ក្រុមមេធាវីការពារក្តី

៦៦៦. បើសំណុំរឿង ០០២/០២ បានប្រែក្លាយទាំងស្រុងជាការស៊ើបអង្កេតដាក់បន្ទុក គឺភាគច្រើនវាដោយសារតែអង្គជំនុំជម្រះបានបិទភ្នែកមិនមើលការរំលោភបំពានរបស់សហព្រះរាជអាជ្ញា តាមរយៈការផ្តល់ភស្តុតាងដោះបន្ទុក។ ជាក់ស្តែងកាលពីសំណុំរឿង ០០២/០១ សហព្រះរាជអាជ្ញាបានកំហិតខ្លួនឯង វាហាក់ដូចជាខ្លួនមានកាតព្វកិច្ចត្រឹមតែផ្តល់ភស្តុតាងដោះបន្ទុកជាសក្តានុភាពដែលចេញមកពីការស៊ើបអង្កេតកំពុងដំណើរការក្នុងសំណុំរឿង ០០៣ ០០៤ រីឯនៅក្នុងសំណុំរឿង ០០២/០២ វិញ ខ្លួនបានផ្តល់រាល់ឯកសារទាំងឡាយណាដែលខ្លួនយល់ឃើញថាមានភាពពាក់ព័ន្ធ[635]។ ក្នុងខណៈដែលខ្លួនត្រូវដាក់ទណ្ឌកម្មលើសហព្រះរាជអាជ្ញាពីបទអសុចន្ទៈ និងការខកខានក្នុងការគោរពក្រមសីលធម៌វិជ្ជាជីវៈដែលខ្លួនបានបង្ហាញយ៉ាងច្បាស់ អង្គជំនុំជម្រះបែរជាបានត្រឹមតែប្រកាសថាការបកស្រាយថ្មីរបស់សហព្រះរាជអាជ្ញាមានលក្ខណៈទូលាយពេក[636]។

---

[634] ប្រតិចារឹកព្រាង ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៦, ទំព័រទី ១ មុនម៉ោង 09.04.02 (ការប្រកាសសេចក្តីសម្រេចស្តាប់សក្ខីកម្ម ព្រាប សុខឿន។)។

[635] សេចក្តីសន្និដ្ឋានរបស់ខៀវ សំផន ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E363**។ ចម្លើយតបរបស់ខៀវ សំផន ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E363/2**។

[636] សេចក្តីសម្រេច ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ **ឯកសារ E363/3**។

៦៦៧. ផ្ទុយទៅវិញ នៅពេលដែលខ្លួនបានបង្ខំក្រុមមេធាវីការពារក្តីឱ្យជ្រើសរើសយកការត្រៀមលក្ខណៈដើម្បីសរសេរសារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ដែលអាចបង្កការប៉ះពាល់ដល់ការចាប់ផ្តើមសវនាការក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះមិនបានរារែកក្នុងការប្តឹងមេធាវីរបស់លោក ខៀវ សំផន ទៅគណៈមេធាវីរបស់ពួកគេរៀងៗខ្លួននោះទេ[637]។ ពេលដែលអង្គជំនុំជម្រះបានសម្រេចថ្មីៗនេះ បញ្ចប់មុខងាររបស់មេធាវីប្រចាំការដែលខ្លួនបានតែងតាំងដើម្បីជំនួសមេធាវី ខៀវ សំផន ក្នុងករណីចាំបាច់ អង្គជំនុំជម្រះបានរំឭកថាខ្លួនបានធ្វើការចាត់តាំងនេះ "ពីព្រោះខ្លួនយល់ឃើញថា អាកប្បកិរិយារបស់ ខៀវ សំផន និង មេធាវីរបស់គាត់ក្នុងរយៈពេលពីរខែចុងក្រោយនេះបានរាំងស្ទះដល់ដំណើរការនីតិវិធី"។[638] អង្គជំនុំជម្រះបានបង្ខំចិត្តទទួលស្គាល់ថា "ចាប់ពីពេលនោះមក កាលៈទេសៈមិនចាំបាច់តម្រូវឱ្យ" ជំនួសមេធាវីលោក ខៀវ សំផន ទេ[639] ដោយមិនបាននិយាយមួយម៉ាត់ណាសោះអំពីការដែលគណៈមេធាវីរបស់មេធាវីលោក ខៀវ សំផន បានសម្រេចថាពួកគាត់មិនមានកំហុសអ្វីទាំងអស់ ដូចការចោទប្រកាន់អំពីកំហុសវិជ្ជាជីវៈទៅលើពួកគាត់ទេ[640]។

៦៦៨. អង្គជំនុំជម្រះមានទស្សនៈលម្អៀងអំពីការងាររបស់ក្រុមមេធាវីការពារក្តីដែលហាក់ដូចជាធ្វើឱ្យខ្លួនខឹងសម្បារជាញឹកញាប់។ ឧទាហរណ៍ នៅពេលដែលក្រុមមេធាវីការពារក្តីបានធ្វើឱ្យសក្ខីកម្មដាក់បន្ទុកមួយចំនួនលែងសូវមានភាពជឿជាក់បាន អង្គជំនុំជម្រះមិនអាចទប់ចិត្តមិនអន្តរាគមន៍ហួស

---

[637] ដីកា ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ **ឯកសារ E330**។

[638] អនុស្សរណៈ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៧ **ឯកសារ E321/3** កថាខណ្ឌ ១ (នៅកថាខណ្ឌ ៤ អង្គជំនុំជម្រះបានពិចារណាថាលែងមានហេតុផលអ្វីត្រូវចាត់តាំងមេធាវីប្រចាំការបន្តទៅទៀតហើយ "ក្រោយពេលដាក់សេចក្តី សន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល"។មិនត្រឹមតែហេតុផលនេះមិនដែលធ្លាប់មាននោះទេ គឺយើងថែមទាំងមិនយល់ថាហេតុអ្វី បានជាបន្តចាត់តាំងមេធាវីទាំងនេះយូរដល់ម្លឹង ដោយហេតុថាពួកគាត់មិនមែននៅសរសេរសេចក្តីសន្និដ្ឋាន បញ្ចប់ការពិភាក្សា ដេញដោលជំនួសយើងនោះទេ។

[639] អនុស្សរណៈ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៧ **ឯកសារ E321/3** កថាខណ្ឌ ១។

[640] លិខិតរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E330/1/1** ; ប្រកាសរបស់គណៈមេធាវីទីក្រុងប៉ារីស ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ **ឯកសារ E330/3.2**។

ហេតុដើម្បីការពារបុគ្គលទាំងនេះ[641]។ ផ្ទុយទៅវិញ នៅពេលដែលក្រុមមេធាវីការពារក្តីត្រូវបានជេរប្រមាថដោយបុគ្គលដែលសក្ខីកម្មរបស់ខ្លួនត្រូវបានចោទជាបញ្ហា អង្គជំនុំជម្រះបែរជានៅស្ងៀមធ្វើមិនដឹងដូចគ្មានរឿងអ្វីកើតឡើង[642]។ អង្គជំនុំជម្រះខ្លួនឯងផ្ទាល់ក៏ធ្លាប់ជេរប្រមាថក្រុមមេធាវីការពារក្តីដែរ ទោះបីជាមេធាវីការពារក្តីតែងតែមានការគួរសមជានិច្ចជាកាលក៏ដោយ[643]។

៦៦៩. ផ្ទុយទៅវិញ ដោយមិនចង់ប្រើពាក្យថាអនុគ្រោះហួសហេតុ អង្គជំនុំជម្រះមានភាពសណ្តោសយ៉ាងខ្លាំងចំពោះភាពយឺតយ៉ាវក្នុងការងារ និងការធ្វើការងារហួសដែនកំណត់របស់សហព្រះរាជអាជ្ញា។ ឧទាហរណ៍ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាបញ្ចូលសៀវភៅស្ទើរតែពេញមួយក្បាលក្រោយពេលស្តាប់សក្ខីកម្មរបស់អ្នកជំនាញម្នាក់បន្តិច ដែលសហព្រះរាជអាជ្ញាបានស្នើតាំងពីមុនការចាប់ផ្តើមជំនុំជម្រះសេចក្តី[644]។ អង្គជំនុំជម្រះបានបណ្តោយឱ្យសហព្រះរាជអាជ្ញាបង្ហាញទៅអ្នកជំនាញម្នាក់នូវចម្លើយរបស់សាក្សីម្នាក់ដែលទោះបីជាសាក្សីរូបនេះផ្ទាល់បានកែប្រែចម្លើយរបស់គាត់នាពេលក្រោយក៏ដោយ[645]។ អង្គជំនុំជម្រះថែមទាំងបានបណ្តោយឱ្យសហព្រះរាជអាជ្ញាបង្ហាញឯកសារមួយចំនួន នៅពេលធ្វើការឆ្លើយតបក្នុងសវនាការលើឯកសារគន្លឹះ (រួមបញ្ចូលទាំងឯកសារមិនមាននៅក្នុងបញ្ជី) បន្ទាប់ពីខ្លួនបានបោះបង់មិនបង្ហាញឯកសារទាំងអស់នេះដោយខ្លួន

---

[641] ឧទាហរណ៍៖ ការអន្តរាគមន៍របស់លោកប្រធាន និល ណុន ក្នុងពេលសួរចម្លើយឌុច ( ប្រតិចារឹក ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/443.1** ទំព័រ ៩-១០ រវាង 09.27 និង 09.30.36, ទំព័រ ៣៩-៤០ រវាង 10.36.34 និង 10.37.55 ការអន្តរាគមន៍របស់ចៅក្រម FENZ ក្នុងពេលសួរចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/476.1**, ទំព័រ ៩១-៩៣91-93 រវាង 15.28.37 និង 15.32.39 ទំព័រ ៩៥ មុំ 15.37.19។

[642] ឧទាហរណ៍៖ ឌុចជេរមេធាវី អង់តា ហ្គីសេ៖ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/443.1** ទំព័រ ៧ ប្រហែលម៉ោង 09.20.21 ទំព័រ ៣៧ មុនម៉ោង 11.11.01 ; Henri ជេរមេធាវី អង់តា ហ្គីសេ៖ សូមមើលកថាខណ្ឌ ៥៩៣-៥៩៤។

[643] ចៅក្រម LAVERGNE កន្ត្រាក់អារម្មណ៍ខៀវ សំផន ដោយចង់ឲ្យគាត់យល់ថាមេធាវីរបស់គាត់បានលាក់រឿង មួយចំនួនមិនឲ្យគាត់ដឹង ដោយបង្កប់ន័យថាមេធាវីគាត់ចាប់អារម្មណ៍នឹងលុយ ក្នុងខណៈដែលចៅក្រមខ្លួនឯងបានបកស្រាយ សារណារដ្ឋបាលរបស់មេធាវីការពារក្តី ដោយលម្អៀង៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ **ឯកសារ E1/244.1**, ទំព័រ ៤-១៣ ចន្លោះម៉ោង 09.09.35 និង 09.12.02។

[644] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/448.1** ទំព័រ ៥២-៦៦ រវាង 14.14.57 និង 15.20.58។

[645] ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/487.1** ទំព័រ ១១-១៣ រវាង 09.35 និង 09.41.42 (សក្ខីកម្មរបស់ Stephen MORRIS)។

ឯងផ្ទាល់[646]។ ជារឿយៗ អង្គជំនុំជម្រះតែងតែព្យាយាមផងដែរ ក្នុងការបំពេញចន្លោះប្រហោងនៃការតាំងសំណួរមួយចំនួនរបស់សហព្រះរាជអាជ្ញា[647]។

៦៧០. ជាទ្រឹស្តី វាមិនមែនមិនអាចទាំងស្រុងនោះទេ ដែលអង្គជំនុំជម្រះអាចមានភាពលម្អៀងតិចជាងនេះក្នុងពេលពិភាក្សាសម្រេច។ នេះគឺពិតជាអ្វីដែលមេធាវីការពារក្តីប្រាថ្នាចង់បាន ទោះបីជាវាបានត្រឹមតែជាការប៉ងប្រាថ្នាដោយគ្មានលទ្ធផលក៏ដោយ។ ទោះជាយ៉ាងនេះក្តី ទោះជាអង្គជំនុំជម្រះគិតយ៉ាងណាក៏ដោយ ក៏ក្រុមមេធាវីការពារក្តីបានបំពេញការងាររបស់ខ្លួនរហូតដល់ទីបញ្ចប់ ដោយគោរពតាមកាតព្វកិច្ចនៃក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

**មាតិកាទី ២. ជម្លោះប្រដាប់អាវុធ៖ បរិបទសំខាន់**

៦៧១. ទោះបីជាក្រុមមេធាវីការពារក្តីទាំងពីរក្រុមស្នើសុំឱ្យចាប់ផ្តើមការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ តាមរយៈការបង្ហាញភស្តុតាងអំពីជម្លោះប្រដាប់អាវុធ ដោយសារតែប្រធានបទជាសារវ័ន្តនេះមានផលប៉ះពាល់ទៅលើប្រធានបទផ្សេងទៀតក៏ដោយ[648] ក៏អង្គជំនុំជម្រះបានសម្រេចធ្វើសវនាការពិនិត្យមើលអង្គហេតុនៃជម្លោះប្រដាប់អាវុធ នៅវគ្គចុងក្រោយនៃការជំនុំជម្រះក្តី[649]។ ទន្ទឹមនឹងនេះ

---

[646] ប្រតិចារឹកព្រាង ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៧, ទំព័រ ៥-១១ រវាង 13.40.25 និង 13.53.40 (ចៅក្រម FENZ ថែមទាំងបានស្តីបន្ទោសមេធាវីការពារក្តីដែលបានលើកបញ្ហានយោបាយមកនិយាយនៅក្នុងក្របខណ្ឌនៃការបង្ហាញឯកសារលើតួនាទី របស់ជនជាប់ចោទ ក្នុងខណៈដែលអង្គជំនុំជម្រះខ្លួនឯងបានរាំងខ្ទប់ មិនឱ្យបង្ហាញឯកសារទាក់ទងនឹងគោលនយោបាយ ក្រោមហេតុផលថាត្រូវនិយាយអំពីគោលនយោបាយនៅពេលបង្ហាញឯកសារទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ។ សូមមើលប្រតិចារឹកព្រាង ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ចន្លោះម៉ោង 10.46.47 និង 10.48.12).

[647] សូមមើលការសួរចម្លើយ នាង អ៊ូច ដោយចៅក្រម LAVERGNE, ប្រតិចារឹក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ E1/274.1** ទំព័រ៣៥-៦៣, ចន្លោះម៉ោង 11.25.17 និង 16.01.30, និងការសួរចម្លើយ ដូ គឹមឡាន ដោយចៅក្រម LAVERGNE, ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/253.1** ទំព័រ ៨-១២ ចន្លោះម៉ោង 09.27.43 និង 09.46.07។

[648] ក្នុងសវនាការបឋម ( ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ **ឯកសារ E1/240.1** ទំព័រ ៤២-៤៣ ចន្លោះម៉ោង 10.54.12 និង 10.56.32 ទំព័រ ៤៥ ម៉ោង 11.00.14 ទំព័រ ៤៦ ម៉ោង 11.03.53)។

[649] សេចក្តីសម្រេច ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ **ឯកសារ E315** កថាខណ្ឌ ១៤។

ច្បាស់ណាស់ថា សហចៅក្រមស៊ើបអង្កេតរៀបរាប់អំពីបញ្ហានេះតែប្រាំកថាខណ្ឌប៉ុណ្ណោះ នៅក្នុងដីកាដំណោះស្រាយ[650]។

៦៧២. ប៉ុន្តែ ជម្លោះប្រដាប់អាវុធត្រូវតែយកមកពិភាក្សាមុនគេជាចម្បង ពេលលើកឡើងអំពីហេតុការណ៍ដែលបានកើតឡើងនៅកម្ពុជាចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ពីព្រោះវាជាបរិបទនៃការប្រព្រឹត្តទៅនៃហេតុការណ៍ទាំងនេះ។ ដូច្នេះ ការចង់លើកឡើងអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងសម័យកាលនោះ ដោយមិនគិតដល់បរិបទនៃជម្លោះនេះ ជាការបង្ហាញនូវអង្គហេតុក្នុងលក្ខណៈមិនពេញលេញ និងជាឯកតោភាគី ដែលមិនអាចពន្យល់អំពីអាកប្បកិរិយារបស់តួអង្គផ្សេងៗនៅសម័យនោះបាន។

៦៧៣. ពិតមែនតែអង្គជំនុំជម្រះបានលើកឡើងអំពីជម្លោះប្រដាប់អាវុធ នៅក្នុងរឿងក្តី ឌុច ប៉ុន្តែ នេះគ្រាន់តែជាការបរិយាយត្រួសៗប៉ុណ្ណោះ គឺមិនបានពិចារណាអំពីឥទ្ធិពលនៃជម្លោះប្រដាប់អាវុធនេះលើគោលនយោបាយផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យឡើយ[651]។ ដូច្នេះ យើងត្រូវត្រឡប់មកនិយាយឱ្យបានស៊ីជម្រៅអំពីជម្លោះ ដោយរំឭកអំពីដើមហេតុនៃជម្លោះ (ផ្នែកទី ១) ដំណាក់កាលសំខាន់ៗនៃការកកើតជម្លោះ ក្នុងអំឡុងសម័យកាលស្ថិតក្រោមយុត្តាធិការពេលវេលារបស់ អ.វ.ត.ក (ផ្នែកទី ២) និងផលវិបាកនៃជម្លោះ ទាំងអង្គហេតុ និងអង្គច្បាប់ (ផ្នែកទី ៣)។

## ភាគទី ១. ដើមហេតុ និងការចាប់ផ្តើមជម្លោះ

៦៧៤. ក្នុងកថាខណ្ឌខ្លីមួយនៃសាលក្រមលើសំណុំរឿង ឌុច អង្គជំនុំជម្រះបានរំឭកអំពីបរិបទប្រវត្តិសាស្ត្រនៃជម្លោះរវាងកម្ពុជា និងវៀតណាម ដោយគូសបញ្ជាក់ថា "ជម្លោះកើតចេញពីកត្តាផ្សេងៗ ដែលកត្តាមួយចំនួនកើតឡើងតាំងពីរាប់សតវត្សរ៍មុនឯណោះ"[652]។ ជាក់ស្តែង ដូចករណីរបស់ប្រទេស

---

[650] ដីកាដំណោះស្រាយ កថាខណ្ឌ១៥០-១៥៥។ ជាពិតណាស់ដែលមានឯកសារយោងសហសម័យជាច្រើននៅចុងបញ្ចប់នៃដីកានេះ ប៉ុន្តែស្ទើរតែគ្មានឯកសារទាក់ទងនឹងផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធទៅលើការប្រព្រឹត្តទៅនៃអង្គហេតុចោទប្រកាន់នៅផ្នែកផ្សេងៗទៀតនៃដីកាដំណោះស្រាយ។

[651] សាលក្រមឌុច ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ៥៩-៨១។

[652] សាលក្រមឌុច ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៦០។

ជាប់ព្រំដែនជាច្រើនដែរ ប្រវត្តិសាស្ត្រកម្ពុជា និងវៀតណាម ញាំញីទៅដោយសង្គ្រាម ការប៉ុនប៉ងលេបទឹកដី និងការតស៊ូដើម្បីអំណាច ដែលបង្ហាញឱ្យឃើញអំពីឫកធំរបស់ប្រជាជនវៀតណាមចំពោះអ្នកជិតខាងរបស់ខ្លួន។ ប៉ុល ពត បានចាត់ទុកឥរិយាបថនេះជា "ភាពកោងកាច" នៅក្នុងសុន្ទរកថាមួយ[653]។ ការសង្កេតនេះត្រូវបានកត់សម្គាល់ឃើញដោយអ្នកសង្កេតការណ៍បរទេស ដូចលោក Stephen MORRIS បានពន្យល់ថា៖

> "វៀតណាមគិតថា ខ្មែរអន់ខាងវប្បធម៌។ មានប្រវត្តិសាស្ត្រមួយ ក្រោមការកាន់កាប់កម្ពុជាដោយវៀតណាមនៅសតវត្សរ៍ទី ១៩ ជាប្រវត្តិសាស្ត្រដែលការបន្ទាបខ្លួនរបស់ខ្មែរបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងជីវិតនយោបាយ [...]។ វៀតណាមយល់ឃើញថាខ្លួនឯងលើសគេ [...]"[654]។

៦៧៥ សាក្សីមួយចំនួនបានប្រាប់អង្គជំនុំជម្រះថា ខ្លួនបានស្តាប់ឮថាវៀតណាមជា "សត្រូវស្លូពូជ" របស់កម្ពុជា តាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យទៅទៀត[655]។ ការរំឭកនេះមានប្រយោជន៍ ពីព្រោះសហព្រះរាជអាជ្ញាតែងតែអះអាងថា ខ្មែរក្រហមបានកសាងគោលនយោបាយ ដោយផ្អែកលើការស្អប់វៀតណាមរបស់ប្រជាជនខ្មែរមួយផ្នែក ខណៈដែលការស្អប់នេះកើតមានតាំងពីយូរយារណាស់មកហើយ។

៦៧៦. ប្រតិកម្មតបរបស់ប្រជាជនចំពោះរដ្ឋលុកលុយមួយ ឬរដ្ឋដែលចាត់ទុកខ្លួនឯងលើសគេ ដោយសារតែអតីតកាលប្រកបដោយភាពចលាចល ជាពិសេស នៅតាមតំបន់ព្រំដែន ក៏ឃើញមានផងដែរនៅកន្លែងផ្សេងទៀតជាច្រើន លើពិភពលោក។ ទំនាក់ទំនងរវាងបារាំង និងអាល្លឺម៉ង់ ជាឧទាហរណ៍ដ៏

---

[653] នៅក្នុងសុន្ទរកថាថ្លែងខែមេសា ឆ្នាំ១៩៧៨ ប៉ុល ពត និយាយអំពីភាពច្រឡោងខាម បន្ទាប់ពីវៀតណាមឈ្លានពាន នៅចុងឆ្នាំ ១៩៧៧៖ ទង់បដិវត្តន៍ "បទអន្តរាគមន៍របស់សមមិត្តលេខាបក្សកុម្មុយនីស្តកម្ពុជា ក្នុងឱកាសប្រារព្ធខួបទី៣នៃមហាជ័យជម្នះ ១៧ មេសា(...) ចុះខែមេសាឆ្នាំ១៩៧៨ **ឯកសារ E3/4604**, ERN FR 00520350។

[654]Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/485.1** ទំព័រ ៦៧ មុំម៉ោង 15.18។ សូមមើលរបាយការណ៍របស់ Douglas Pike ក្រោមចំណងជើងថា៖ "ជម្លោះវៀតណាមកម្ពុជា ដែលជារបាយការណ៍សរសេរឡើងដោយផ្នែកសិក្សាស្រាវជ្រាវនៃសមាជ តាមសំណើអនុគណៈកម្មការទទួលបន្ទុកអាស៊ីប៉ាស៊ីហ្វិក គណៈកម្មការទំនាក់ទំនង អន្តរជាតិ ក្នុងឱកាសសមាជទី៩៥ នៅថ្ងៃទី ៤ តុលា ឆ្នាំ១៩៧៨ **ឯកសារ E3/2370**, ERN FR 00344747។

[655]សូមមើលសក្ខីកម្ម មាស វឿន MEAS Voeun : ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ២១ មុំម៉ោង 10.07.07 ;សូមមើលសក្ខីកម្មព្រុំ សារ៉ាត់ PRUM Sarat : ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/383.1** ទំព័រ ១០ មុនម៉ោង 09.29។

ល្អតតខ្មោះ។ សង្គ្រាមពិភពលោកពីរលើក និងសង្គ្រាមជារឿយៗមុននេះ កាលពីបណ្ដាសតវត្សរ៍កន្លងទៅ បានបង្កើតឱ្យមានជាអារម្មណ៍មិនទុកចិត្តនៅក្នុងចំណោមប្រជាជនបារាំង ជាមួយនឹងការលេចឡើងនូវពាក្យបញ្ឆោរខ្លះៗ សម្រាប់ហៅអាល្លឺម៉ង់ដែលត្រូវបានចាត់ទុកជាពួកលុកលុយ[656]។

៦៧៧. ទន្ទឹមនឹងនេះ ទំនាក់ទំនងរវាងវៀតណាម និងកម្ពុជា ត្រូវបានលាបពណ៌យ៉ាងខ្លាំងដោយទំនាក់ទំនងប្រវត្តិសាស្ត្រដ៏ស្អិតរមួត ប៉ុន្តែ ជាញឹកញយ ក៏មានភាពតានតឹងខ្លះដែរ (ជំពូកទី ១)។ ដើមកំណើតនៃជម្លោះរវាងកម្ពុជា-វៀតណាម បណ្ដាលមកពីតុល្យភាពដ៏តិចតួចនៃការចរចារវាងរដ្ឋទាំងពីរ និងអធិបតេយ្យភាពជាតិ ដែលមេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានទាមទារក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ (ជំពូកទី ២)។

## ជំពូកទី ១. សត្រូវបងប្អូនឯង

៦៧៨. ប្រទេសទាំងពីរជាបងប្អូននឹងគ្នា មានទីតាំងភូមិសាស្ត្រជិតគ្នា មានមនោគមន៍វិជ្ជាស្រដៀងគ្នា មានការអភិវឌ្ឍចលនាបដិវត្តន៍ដូចគ្នា និងបានតស៊ូប្រឆាំងនឹងសហរដ្ឋអាមេរិកដូចគ្នា ប៉ុន្តែ ក៏ជាសត្រូវនឹងគ្នាផងដែរ តាមរយៈទំនាក់ទំនងពោរពេញដោយជម្លោះ កាលពីអតីតកាល[657]។ ផលប្រយោជន៍ជាតិប្រទាំងប្រទើសគ្នាជារឿយៗ បានចូលរួមចំណែកបង្កើតជាចំណុចប៉ះទង្គិចគ្នា មុនឆ្នាំ ១៩៧៥ (ផ្នែកទី ១) ដែលបានប្រែក្លាយជាលំដាប់ទៅជាជម្លោះព្រំដែន (ផ្នែកទី ២)។

### ផ្នែកទី ១. ចំណុចប៉ះទង្គិចគ្នា មុនឆ្នាំ ១៩៧៥

---

[656] យើងគិតជាពិសេសដល់ពាក្យ "boche សំដៅជនជាតិអាឡឺម៉ង់" ដែលគេប្រើចាប់តាំងពីសតវត្សទី១៩នៅប្រទេសបារាំងប៉ុន្តែពាក្យនេះ មានគេប្រើច្រើនគ្រប់ទិសទីនៅក្នុងអំឡុងពេលសង្គ្រាមលោកលើកទី១ ហើយបន្ទាប់មកមានប្រើនៅប្រទេសបែលហ្ស៊ិក។ សូមមើលគេហទំព័រ https://fr.wikipedia.org/wiki/Boche និង https://www.rtbf.be/14-18/thematiques/detail_l-ennemi-comme-on-le-nomme-la-re-invention-du-boche-et-du-mof?id=8976002។

[657] Nayan CHANDA ក៏បានដាក់ចំណងជើងសៀវភៅរបស់គាត់ដែលនិយាយអំពីទំនាក់ទំនងរវាងប្រទេសទាំងពីរថា៖ "បងប្អូនសត្រូវនឹងគ្នា" បោះពុម្ពឆ្នាំ ១៩៨៦ **ឯកសារ E3/2376**។

៦៧៩. បរិបទប្រវត្តិសាស្ត្រ និងជាពិសេស សង្គ្រាមវៀតណាម មានសារៈសំខាន់ ដើម្បីយល់អំពីចំណុចប៉ះទង្គិចគ្នា ដែលកើតមានឡើងរវាងចលនាបដិវត្តន៍ទាំងពីរ។ ការធ្វើឱ្យចលនាបដិវត្តន៍កម្ពុជាមានភាពផុយស្រួយនៅក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវឆ្នាំ ១៩៥៤ (១) គឺជាឫសគល់នៃការមិនទុកចិត្តវៀតណាម ទោះបីជាធ្លាប់តស៊ូរួមគ្នាប្រឆាំងនឹងអាមេរិក និងរបប លន់ នល់ ក៏ដោយ (២) ចំណែកឯកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ ១៩៧៣ គឺជាការបញ្ចប់អាណាព្យាបាលវៀតណាម (៣)។

## ១. កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ និងការដាក់ជនកុម្មុយនីស្តកម្ពុជាឱ្យនៅក្រៅឆាក

៦៨០. មុនសង្គ្រាមវៀតណាម សង្គ្រាមឥណ្ឌូចិនគឺជាសញ្ញានៃការវាយប្រយុទ្ធនៅក្នុងតំបន់ ដើម្បីទាមទារឯករាជ្យពីអាណានិគមបារាំង។ ទំនាក់ទំនងនៅពេលនោះរវាងជនកុម្មុយនីស្តវៀតណាម និងអ្នកតស៊ូខ្មែរប្រឆាំងនឹងអាណានិគមនិយម មានសារៈសំខាន់ ដើម្បីឱ្យយល់អំពីដំណើរជាហូរហែនៃព្រឹត្តិការណ៍នានា[658]។

៦៨១. ជាក់ស្តែង ការសហការជាលើកដំបូងដែលដាក់ជនកុម្មុយនីស្តកម្ពុជាឱ្យស្ថិតក្រោមអាណាព្យាបាលវៀតណាម បានផ្តល់ជាគំរូដល់ទំនាក់ទំនងរវាងបក្សកុម្មុយនីស្តទាំងពីរ ជាមួយនឹងអារម្មណ៍ "ឧត្តមភាពបដិវត្តន៍" ដោយប្រយោល ដែលជាលក្ខណៈពិសេសរបស់បក្សវៀតណាម។ ដូចលោកបានឆ្លើយនៅក្នុងសវនាការ "វៀតណាមមានមហិច្ឆតាប្រើប្រាស់អ្នកដែលត្រូវបានមើលឃើញថាមានភក្តីភាពជាមួយវៀតណាម ដើម្បីបង្កើតបក្សកុម្មុយនីស្តនៅក្នុងប្រទេសផ្សេងទៀត"[659]។

៦៨២. កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ដែលបិទបញ្ចប់សង្គ្រាមឥណ្ឌូចិន បានបំផ្លាញចលនាកុម្មុយនីស្តខ្មែរ ដោយត្រូវបានដកចេញទាំងស្រុងពីការចរចា។ ដូច្នេះ ការមិនទុកចិត្តបានលេចឡើង នៅក្នុងចិត្តខ្មែរដែលដឹងខ្លួនថា វៀតណាមការពារតែផលប្រយោជន៍របស់ខ្លួន នៅក្នុងគម្រោងនៃបក្សឥណ្ឌូចិន[660]។

[658] សូមអានអត្ថបទវិភាគរបស់ Dmitry MOSYAKOV ដែលមានចំណងជើងថា "រឿងរ៉ាវនៃទំនាក់ទំនងរវាងខ្មែរក្រហម និងពួកកុម្មុយនីស្តវៀតណាម ផ្អែកលើបណ្ណសារសូវៀត" ឆ្នាំ ២០០៤ **ឯកសារ E3/9644**, ERN FR 01125297។

[659] Stephen MORRIS ៖ ប្រតិចារឹក ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/485.1** ទំព័រ៧៣ ម៉ោង 15.39.00។

[660] សូមអានអត្ថបទរបស់ Dmitry MOSYAKOV ដែលមានចំណងជើងថា "រឿងរ៉ាវនៃទំនាក់ទំនងរវាងខ្មែរក្រហម និងពួក

៦៨៣. ចំពោះជនកុម្មុយនីស្តវៀតណាម នេះជាការឃោគយល់ដល់សម្តេច សីហនុ ជាសហាស្ថានិកចលនាមិនចូលបក្សសម្ព័ន្ធ។ អាស្រ័យហេតុនេះ ពួកគេបានដកកម្លាំងចេញពីតំបន់ស្ថិតក្រោមការត្រួតត្រារបស់ខ្លួននៅកម្ពុជា ដោយតម្រូវឱ្យជនកុម្មុនីស្តកម្ពុជាធ្វើសកម្មភាពជាសម្ងាត់។ លើសពីនេះទៀត សេចក្តីណែនាំរបស់ជនកុម្មុយនីស្តវៀតណាមឱ្យគាំទ្រសម្តេច សីហនុ និងឱ្យបញ្ចប់ការតស៊ូប្រដាប់អាវុធ បានបង្កើនអារម្មណ៍ក្បត់ ក្រោយពីមានកិច្ចព្រមព្រៀងនេះ[661]។

៦៨៤. ក្រោយមកទៀត ការបង្ក្រាបសកម្មជនកុម្មុយនីស្តខ្មែរជាច្រើនពីសំណាក់របប សីហនុ បានប៉ះពាល់យ៉ាងខ្លាំងដល់ចលនានេះ។ មេដឹកនាំថ្មី និងជាពិសេស ប៉ុល ពត ដែលបានរៀបចំបក្សឡើងវិញ ដើម្បីបង្កើតជាបក្សកុម្មុយនីស្តកម្ពុជានាពេលអនាគត ចងចាំបទពិសោធន៍នេះជានិច្ច។

## ២. ការមិនទុកចិត្តគ្នា នោះបីជាធ្លាប់តស៊ូរួមគ្នាក៏ដោយ

៦៨៥. រដ្ឋប្រហាឆ្នាំ ១៩៧០ ប្រឆាំងនឹងសម្តេច សីហនុ ធ្វើឱ្យស្ថានការណ៍ប្រែប្រួល ដោយចលនាបដិវត្តន៍ទទួលបានការគាំទ្រពីសម្តេច សីហនុ ក្នុងការតស៊ូប្រឆាំងនឹងរបប លន់ នល់។ ចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការយោធាជាមួយវៀតណាមជាថ្មីម្តងទៀត ដោយវៀតណាមជាអ្នកដឹកនាំប្រតិបត្តិការជាថ្មីម្តងទៀត និងមិនរួញរាក្នុងការចេញបញ្ជាដោយចំហ ក្នុងឋានៈជា "បងធំ"[662]។

៦៨៦. ប៉ុន្តែ ដោយសារតែសភាពការណ៍មានសភាពធ្ងន់ធ្ងរ ចាំបាច់ត្រូវរួបរួមគ្នានៅលើសមរភូមិ និងត្រូវរួមគ្នាប្រយុទ្ធ។ ពិតណាស់ នេះជាការរួបរួមគ្នាខាងទស្សនៈមនោគមន៍វិជ្ជាម៉ាក្សនិយម និងជាភាពចាំបាច់ខាងយុទ្ធវិធី ពីព្រោះអាមេរិកគាំទ្ររបស់ លន់ នល់។ ចំពោះវៀតណាម សមរភូមិក្រោយ

---

កុម្មុយនីស្តវៀតណាម ផ្អែកលើបណ្ណាសារសូវៀត", ឆ្នាំ ២០០៤ **ឯកសារ E3/9644**, ERN FR 01125297។

[661] សូមអានអត្ថបទរបស់ Dmitry MOSYAKOV ដែលមានចំណងជើងថា "រឿងរ៉ាវនៃទំនាក់ទំនងរវាងខ្មែរក្រហម និងពួកកុម្មុយនីស្តវៀតណាម ផ្អែកលើបណ្ណាសារសូវៀត" ឆ្នាំ ២០០៤ **ឯកសារ E3/9644**, ERN FR 01125297។ សៀវភៅរបស់ Philip SHORT, *ប៉ុល ពត ប្រវត្តិនៃសុបិនអាក្រក់* បោះពុម្ពឆ្នាំ ២០០៤ **ឯកសារ E3/9**, ERN FR 00639577។

[662] សូមអានអត្ថបទរបស់ Dmitry MOSYAKOV ដែលមានចំណងជើងថា "រឿងរ៉ាវនៃទំនាក់ទំនងរវាងខ្មែរក្រហម និងពួកកុម្មុយនីស្តវៀតណាម ផ្អែកលើបណ្ណាសារសូវៀត", ឆ្នាំ ២០០៤ **ឯកសារ E3/9644**, ERN FR 01125305-01125306។

លើទឹកដីកម្ពុជាជាចំណុចស្លាប់រស់[663]។ តួនាទីរបស់គណៈកម្មាធិការទំនាក់ទំនងវៀតណាម-កម្ពុជា មានប្រយោជន៍ដល់ការតស៊ូប្រឆាំងនឹងរបប លន់ នល់[664]។ ចំពោះជនកុម្មុយនីស្តកម្ពុជា នេះក៏ជាមធ្យោបាយប្រមូលកម្លាំងផងដែរ។ លោក David CHANDLER បានគូសបញ្ជាក់អំពីសារៈសំខាន់នៃសម្ព័ន្ធភាពនេះ[665]។

៦៨៧. កិច្ចសហប្រតិបត្តិការនេះមិនមែនមានន័យថា ជនកុម្មុយនីស្តខ្មែរមិនបានទទួលមេរៀនពីអតីតកាលនោះទេ។ ភាពតានតឹងនៅតែបន្តកើតមានដដែល ជាអាទិ៍ ពាក់ព័ន្ធនឹងជំនួយយោធារបស់ចិន[666]។ ដោយសារតែជំនួយយោធាចិនត្រូវឆ្លងកាត់តាមវៀតណាម ជំនួយមួយផ្នែកមិនមកដល់កម្ពុជាទេ។ ដោយសារតែការមិនទុកចិត្ត ប៉ុល ពត បានជំទាស់ភ្លាមៗទៅនឹងគំនិតបង្កើតបក្សឥណ្ឌូចិនក្រោមអាណាព្យាបាលវៀតណាម ហើយក្នុងបរិបទថ្មីនេះ ប៉ុល ពត បានសម្តែងការជំទាស់នេះជាចំហ[667]។

---

[663] មុន លន់ ណុល ធ្វើរដ្ឋប្រហារ ជនបដិវត្តន៍ទាំងពីរក្រុមនេះមានផលប្រយោជន៍ខុសគ្នា ដោយសារតែវៀតណាមគិតពីផលប្រយោជន៍របស់ខ្លួនធំជាង។ សូមអានសក្ខីកម្មរបស់ Stephen MORRIS ៖ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.**1 ទំព័រ៨០ ម៉ោង 15.24.33។

[664] Stephen MORRIS៖ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ១៦ ម៉ោង 09.49.30

[665] សៀវភៅរបស់ David CHANDLER ចំណងជើងថា៖ ប៉ុល ពត បងធំទី១ បោះពុម្ពឆ្នាំ 1992 **ឯកសារ E3/17** ទំព័រ ១៤៦ ERN FR 01242724 ៖ "ពួកកុម្មុយនីស្តបានពង្រឹងជួររបស់ពួកគេបានដោយសារគេប្រកាសថាពួកគេមានស្មោះភក្តិជាមួយសម្តេចសីហនុ ក្នុងខណៈដែលវៀតណាមផ្តល់អាវុធឲ្យពួកគេ និងបង្វឹកទាហានពួកគេ។ ក្រោយពីរដ្ឋប្រហារបន្តិច ខ្មែរដែលបានហ្វឹកហាត់ រាប់រយ នាក់បានចាកចេញពីវៀតណាមខាងជើង មកចូលរួមតស៊ូនៅប្រទេសខ្លួនវិញ"។

[666] ទាក់ទងនឹងភាពតានតឹងក្នុងឆ្នាំ១៩៧៣ ដែលគាត់បាននិយាយថាគាត់ជាសាក្សីនៅភូមិភាគបូព៌ា សូមអានចម្លើយសាក្សី 2-TCW-1065 ៖ ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៥២ ម៉ោង 14.07.32។

[667] កែ ពេជ្រវណ្ណៈ ត្រូវជាកូនរបស់ កែ ពក បានចូលរួមក្នុងកិច្ចប្រជុំមួយក្នុងភូមិភាគឧត្តរមុនឆ្នាំ១៩៧៥រវាងប៉ុល ពត និង អ្នកតំណាងវៀតណាមបានលើកឡើងដូចតទៅនេះ៖ "ខ្ញុំបានឃើញ ឡេ យ៉ាន់ និងផាំ វ៉ាន់ដុង។ ឡេ យួន មកម្តង។ ខ្ញុំបម្រើតែគាត់ ហើយថែមច្របាច់ដៃច្របាច់ជើងគាត់ទៀតផង។ រីឯ ផាំ វ៉ាន់ដុង វិញ គាត់មកពីរដង។ ពេលពួកគាត់មានវត្តមាន ខ្ញុំឃើញ ប៉ុល ពតប្រជុំជាមួយឡេ យួន ដោយមានអ្នកបកប្រែ។ ខ្ញុំមិនស្គាល់អ្នកបកប្រែនោះទេ។ ពេលប្រជុំហ្នឹង ខ្ញុំលឺពួកគាត់និយាយអំពីការបញ្ចូលបក្សកុម្មុយនីស្តកម្ពុជាទៅក្នុងបក្សកុម្មុយនិស្តឥណ្ឌូចិន។ ប៉ុល ពត ជំទាស់មិនចូលជាសមាជិក។ គាត់គាត់ពិភាក្សាគ្នាឡើងតឹងសរសៃក។ ខ្ញុំនៅជិតបង្អើយពីកន្លែងប្រជុំ" (កំណត់ហេតុស្តាប់ចម្លើយ កែ ពេជ្រវណ្ណៈ (ស្លាប់) ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៩ **ឯកសារ E3/35**, ERN FR : 00367719-20)។

៦៨៨. ទំនាក់ទំនងជាមួយវៀតណាមក៏បានបង្កើតភាពតានតឹង ក្នុងបក្សកុម្មុយនីស្តកម្ពុជានៅមុនឆ្នាំ១៩៧៥ ទៅទៀត ដោយតាម៉ុកប្រឆាំងយ៉ាងខ្លាំងក្លា[668]។ អារម្មណ៍ឧត្តមភាពមិនសូវលាក់មុខរបស់ "បងធំ" វៀតណាម ដែលមេដឹកនាំជាបន្តបន្ទាប់នៃចលនាកុម្មុយនីស្តខ្មែរធ្លាប់ជួបប្រទះ បានស្តែងឡើង នៅក្នុងស្រទាប់មហាជនថ្នាក់ទាប[669]។ ជាក់ស្តែង ប្រជាជនមូលដ្ឋានប្រឆាំងយ៉ាងខ្លាំងទៅនឹងការកាន់កាប់របស់ទាហានវៀតណាម នៅតាមតំបន់មួយចំនួននៃប្រទេសកម្ពុជា។ ដូច្នេះ សម្ព័ន្ធភាពចាំបាច់ដោយពិចារណាទៅលើកម្លាំងរបស់សត្រូវរួម គឺសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្ត មិនមែនគ្មានការជំទាស់នោះទេ[670]។ ការមិនទុកចិត្តនេះកាន់តែមានសភាពខ្លាំងឡើងៗ ដោយសារតែវៀតណាមធ្លាប់គ្រប់គ្រងតែឯងនូវវគ្គបញ្ចប់នៃសង្គ្រាមវៀតណាម។

## ៣. កិច្ចព្រមព្រៀងទីក្រុងប៉ារីស ឬការបញ្ចប់អាណាព្យាបាលភាពរបស់ "បងធំ"

៦៨៩. ការចុះហត្ថលេខាកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅឆ្នាំ ១៩៧៣ ដោយភាគីវៀតណាម ត្រូវបានមើលឃើញថាជាការក្បត់ថ្មីម្តងទៀតរបស់ជនកុម្មុយនីស្តខ្មែរ ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការតស៊ូប្រដាប់អាវុធ[671]។ ចំពោះជនកុម្មុយនីស្តខ្មែរ គ្មានការចាំបាច់ត្រូវចរចាជាមួយ លន់ នល់ ឬអាមេរិកឡើយ។ ដូច្នេះ ពួកគេមិនបានចុះញ៉មនឹងការប៉ុនប៉ងរបស់វៀតណាមក្នុងការបង្ខំពួកគេឡើយ[672]។ លោក Philip SHORT បានលើកឡើងអំពីរយៈកាលនៃការល្បងកម្លាំងគ្នា។ ក្នុងអំឡុងពេលនោះ

---

[668] កំណត់ហេតុស្តាប់ចម្លើយឈូក រីន ជាទាហាននៅក្រោមបញ្ជាតាម៉ុក ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៨ **ឯកសារ E3/361**, ERN FR 00268880។

[669] កិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សន ឡូន ហៅឡូន ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៥ **ឯកសារ E3/7822**, ERN FR 00665323 ;ចម្លើយរបសស់ Stephen MORRIS សូមអានប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៨៩ ម៉ោង 15.54។

[670] ព្រុំ សារ៉ាត់ (PRUM Sarat) : ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/383.1** ទំព័រ ៣៥ ម៉ោង 11.20.58។

[671] កំណត់ហេតុស្តាប់ចម្លើយម៉ម ណៃ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ **ឯកសារ E3/351**, ERN FR 00165038-39។

[672] អត្ថបទរបស់ François PONCHAUD មានចំណងជើងថា "វៀតណាម កម្ពុជា៖សាមគ្គីតស៊ូផុយស្រួយ" បោះពុម្ពផ្សាយខែមិនា ឆ្នាំ ១៩៧៩ **ឯកសារ E3/7258** ERN FR 00281897។

វៀតណាមបានរឹតត្បិតយ៉ាងខ្លាំងនូវផ្គត់ផ្គង់ស្បៀង និងគ្រាប់រំសេវតាមផ្លូវលំហូជីមិញ។ ប្រការនេះមិនបានរារាំងខ្មែរក្រហមមិនឱ្យបន្តការប្រយុទ្ធនោះទេ[673]។

៦៩០. ភាពរីកលូតលាស់ខាងកម្លាំងយោធា និងការវាយឈ្នះកងទ័ព លន់ នល់ ជាបន្តបន្ទាប់ ទោះបីជាមានការទម្លាក់គ្រាប់បែកពីសំណាក់អាមេរិកយ៉ាងសន្ធឹកសន្ធាប់ក៏ដោយ ធ្វើឱ្យស្ថានការណ៍ប្រែប្រួល។ ជាក់ស្តែង វៀតណាមត្រូវតែវាយតម្លៃយុទ្ធសាស្ត្ររបស់ខ្លួនឡើងវិញ ដោយមើលឃើញថាកងទ័ព ប៉ុល ពត បានកាន់កាប់ទឹកដីកម្ពុជាមួយភាគបីទៅហើយ។ ដូច្នេះ វៀតណាមបានបើកការផ្គត់ផ្គង់ឡើងវិញ[674]។

៦៩១. ទោះបីជាការបន្តសង្គ្រាមប្រឆាំងនឹង លន់ នល់ និងរយៈពេលនៃការទម្លាប់គ្រាប់បែកពីអាមេរិកមានការលំបាកយ៉ាងណាក៏ដោយ ក៏ការកាត់ផ្តាច់សាមគ្គីភាពជាថ្មីរបស់វៀតណាមជាមួយចលនារំដោះកម្ពុជា បានផ្លាស់ប្តូរទំនាក់ទំនងរបស់ពួកគេ ជាស្ថាពរ។ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសបានផ្តល់មធ្យោបាយជាប្រយោលដល់ចលនាខ្មែរក្រហមក្នុងការរំដោះខ្លួន ដោយបង្កើតនូវទំនាក់ទំនងកម្លាំងថ្មី។ វៀតណាមបានភ្ញាក់ខ្លួន និងបង្ខំចិត្តទុកមហិច្ឆតាត្រួតត្រាកម្ពុជាចោលមួយអន្លើសិន[675]។ រយៈពេលនេះក៏ជាសញ្ញានៃការយល់ដឹងអំពីសារៈសំខាន់នៃអធិបតេយ្យភាព និងឯករាជ្យភាពជាតិរបស់កម្ពុជាប្រជាធិបតេយ្យ ដែលស្តែងឡើងកាន់តែខ្លាំង នៅក្នុងក្របខ័ណ្ឌនៃជម្លោះព្រំដែន។

## ផ្នែកទី ២. <u>ជម្លោះព្រំដែន ចាប់ពីឆ្នាំ ១៩៧៥</u>

៦៩២. ឥឡូវនេះ យើងចាំបាច់ត្រូវលើកឡើងអំពីចំណុចតានតឹង ដែលនឹងជាកាតាលិករជំរុញឱ្យកើតជម្លោះប្រដាប់អាវុធ គឺបញ្ហាព្រំដែនដែលបានកើតឡើងជាហូរហែ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដូចលោក

---

[673] សៀវភៅរបស់ SHORT មានជំណងជើងថា ប៉ុល ពត ប្រវត្តិសុបិនអាក្រក់ បោះពុម្ពផ្សាយឆ្នាំ ២០០៤ **ឯកសារ E3/9**, ERN FR 00639777-78។

[674] សៀវភៅរបស់ SHORTមានជំណងជើងថា ប៉ុល ពត ប្រវត្តិសុបិនអាក្រក់ បោះពុម្ពផ្សាយឆ្នាំ ២០០៤ **ឯកសារ E3/9**, ERN FR 00639779។

[675] <u>Stephen MORRIS</u> : ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ១៧ ម៉ោង 09.53។

Steve HEDER[676] បានរៀបរាប់នៅក្នុងសវនាការ។ ដូច្នេះ យើងត្រូវត្រឡប់មកនិយាយត្រួសៗអំពីដើមកំណើតនៃជម្លោះព្រំដែនរវាងប្រទេសទាំងពីរ (១) និងកត្តាដែលនាំឱ្យផ្ទុះជម្លោះ នៅខែ ឧសភា ឆ្នាំ ១៩៧៥ (២)។

## ១. ព្រំដែនដែលបន្សល់ទុកពីរដ្ឋបាលអាណានិគម

៦៩៣. ការសិក្សាដ៏ពិស្តាររបស់ក្រសួងការបរទេសអាមេរិក នៅឆ្នាំ ១៩៧៦ បានរំឭកអំពីប្រវត្តិសាស្ត្រ និងចង្អុលបង្ហាញអំពីចំណុចប្រឈមនៃបញ្ហាព្រំដែន រវាងវៀតណាម និងកម្ពុជា។ ឧទាហរណ៍ ការសិក្សានេះបានដកស្រង់សេចក្តីសម្រេចផ្សេងៗរបស់រដ្ឋបាលបារាំង ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងផលប្រយោជន៍ នៅឥណ្ឌូចិន ក្រោមអាណានិគមរបស់ខ្លួន និងកិច្ចពិភាក្សានានាអំពីព្រំដែនសមុទ្រ។ ចំពោះព្រំដែនសមុទ្រ ខ្សែបន្ទាត់ប្រេវីយេ ទំនងជាត្រូវបានរក្សាទុកដដែល[677]។

៦៩៤. ទោះជាយ៉ាងនេះក្តី ព្រំដែនដែលកំណត់តាមការអនុវត្ត និងគូសលើផែនទីតំបន់ ត្រូវបានវៀតណាមជំទាស់ ដោយជួនកាលចាត់ទុកថាជាព្រំដែនគូសដោយ "ពួកចក្រពត្តិ" ក្នុងពេលចរចាជាមួយកម្ពុជាប្រជាធិបតេយ្យ[678]។ ប៉ុន្តែ ដូចអង្គជំនុំជម្រះបានកត់សម្គាល់នៅក្នុងសាលក្រមលើសំណុំរឿង ឌុច

---

[676] Steve HEDER : ប្រតិចារឹក ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ **ឯកសារ E1/225.1** ទំព័រ ៦៤ ចាប់ពីម៉ោង 14.35.58 ៖ "បាទ! បើយើងទុកមួយអន្លើសិនទូវការលំបាកក្នុងការបែងចែកឱ្យដាច់បញ្ហាវត្តមាននៃកងកម្លាំងយោធាវៀតណាមនៅក្នុងទឹកដីកម្ពុជាក្នុងបរិបទមួយដែលវត្តមាននេះមិនត្រូវបានរៀបរាប់ជាការវាយលុកចូលទឹកដីកម្ពុជាពីបរិបទដែលវត្តមានត្រូវបានចាត់ទុកថាជាការវាយលុកចូលទឹកដីកម្ពុជា ជួនកាលមានគេធ្វើការបែងចែកនេះដែរ។ តាមពិតមានរឿងរ៉ាវដែលកើតមុនខែ មេសា ឆ្នាំ១៩៧៥ និងក្នុងអំឡុងឆ្នាំ ១៩៧៥ ៧៦ ៧៧ និងក្នុងពាក់កណ្តាលឆមាសទីពីរនៃឆ្នាំ ១៩៧៧ ហើយបន្ទាប់មកជាប់រហូត មានការប្រយុទ្ធគ្នានៅតាមកន្លែងដែលភាគីទាំងពីរអាចចាត់ទុកថាជាព្រំដែន។ ដូច្នេះវាជាការពិតចំពោះឯកសារផ្ទៃក្នុងក្រោយឆ្នាំ ៧៥។ ខ្ញុំមិនមានអារម្មណ៍ថាមានចំពោះឯកសារផ្ទៃក្នុងមុនឆ្នាំ ៧៥។ ដូច្នេះ រឿងរ៉ាវបែបនេះកើតមានកាន់តែធំឡើងៗចាប់តាំងពីមុនខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ក្រោយមកទៀត... រហូតមកដល់ខែ មករា ឆ្នាំ ១៩៧៩"។

[677] ការសិក្សាអំពីព្រំដែនអន្តរជាតិ ព្រំដែនរវាងប្រទេស កម្ពុជា និងប្រទេស វៀតណាម លេខ 155 ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៧៦ **ឯកសារ E3/2373** ទំព័រ ១២ ERN FR 00809220។

[678] កំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦ **ឯកសារ E3/217**, ERN FR 00334964 ដែលនិយាយអំពីឆ្នាំ ១៩៧៥៖ "ក្នុងប្រវត្តិសាស្ត្រ បញ្ហាព្រំដែនផ្នែកខាងកើតមិនទាន់បានដោះស្រាយនៅឡើយទេ។ នៅខែមិថុនា ឆ្នាំ ១៩៧៥ ក្នុងពេលចរចារ បក្សយើងក៏បានលើកពីបញ្ហាទាំងនេះដែរ ប៉ុន្តែ វៀតណាមិនឆ្លើយ។ បន្ទាប់មកពួកវាប្រាប់ទៅសមមិត្តនួន ជាថា "ព្រំដែននេះត្រូវបានគូសដោយពួកចក្រព័ត្តិ"។

"ជារឿយៗ បារាំងតែងតែគូសព្រំដែនលម្អៀងទៅខាងប្រទេសវៀតណាម ជាពិសេស ខ្សែបន្ទាត់ប្រេវីយេ ដែលគូសនៅឆ្នាំ ១៩៣៩ ជាខ្សែបន្ទាត់ដែនទឹកសម្រាប់ការគ្រប់គ្រងរដ្ឋបាល និងសណ្តាប់ធ្នាប់"[679]។

## ២. ប្រភពនៃការផ្ទុះជម្លោះ

៦៩៥. នៅក្នុងការពិភាក្សា ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ វៀតណាមតែងតែបង្ហាញមហិច្ឆតាល្អោភមិនចេះស្កប់ស្កល់ ក្នុងការទាមទាររបស់ខ្លួន។ តួយ៉ាងដូចជា សាក្សីម្នាក់មួយរូបមកពីភូមិភាគបូព៌ា បានមកពន្យល់ថា ភូមិខ្មែរមួយចំនួនដែលមាននៅលើផែនទីបានបាត់បង់ គឺមានន័យថាចូលទៅខាងវៀតណាម[680]។ ក្នុងអត្ថបទស្តីពីប្រវត្តិនៃការពិភាក្សាអំពីព្រំដែន លោក François PONCHAUD បានកត់សម្គាល់ថា "វៀតណាមទាមទារដែនទឹកវែងជាងការកំណត់ដោយខ្សែបន្ទាត់ប្រេវីយេ ធ្វើឱ្យកំពង់ផែកំពង់សោម ដែលមានភាពចាំបាច់សម្រាប់ឯករាជ្យកម្ពុជា ស្ទើរតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម។ ដូចគ្នាដែរ អណ្តូងប្រេងកាតភាគច្រើននៅជុំវិញកោះពូលូវ៉ៃនឹងក្លាយជាកម្មសិទ្ធិរបស់វៀតណាម"[681]។ ដូច្នេះ នេះមិនមែនជាការពិភាក្សាឥតប្រយោជន៍នោះទេ គឺជាបញ្ហាប្រឈមនៃជីវិតសេដ្ឋកិច្ចដ៏ពិតប្រាកដ។

៦៩៦. ក្នុងចំណោមការទាមទារផ្សេងទៀត វៀតណាមអះអាងផងដែរថា សម្តេច សីហនុ បានប្រគល់ជូនពួកគេនូវទឹកដីអូររាំង និងអូរលើ នៅតាមព្រំដែនវៀតណាម[682]។ ដូច្នេះក្នុងទិដ្ឋភាពនេះ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេថា ការពិភាក្សាអំពីព្រំដែនគឺជាប្រភពនៃការប៉ះទង្គិចគ្នា ពេញមួយរយៈពេលនៃជម្លោះដោយសារហេតុផលសេដ្ឋកិច្ច យុទ្ធសាស្ត្រ និងនិមិត្តរូប ពាក់ព័ន្ធនឹងឯករាជ្យ និងអធិបតេយ្យភាព

[679] សាលក្រម *Duch* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ៦០។

[680] សាក្សី 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៥៤ ប្រហែលម៉ោង 14.15.30 ; ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ៥ ប្រហែលម៉ោង 09.15.42, និង ទំព័រ ៨ ប្រហែលម៉ោង 09.15.42។

[681] អត្ថបទរបស់ François PONCHAUD មានចំណងជើងថា "វៀតណាម កម្ពុជា៖សាមគ្គីតស៊ូផុយស្រួយ" បោះពុម្ពផ្សាយខែមិនា ឆ្នាំ ១៩៧៩ **ឯកសារ E3/7258** ERN FR 00281898។

[682] **របាយការណ៍របស់ ឈិន** (Chhin) ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ **ឯកសារ E3/8377**។

កម្ពុជា។ ផ្អែកលើបញ្ហាប្រឈមនេះ យើងត្រូវយល់អំពីសារៈសំខាន់នៃបញ្ហាព្រំដែន ដែលជាប្រភពនៃជម្លោះ។

## ជំពូកទី ២. ឆ្នាំ ១៩៧៥-ឆ្នាំ ១៩៧៦៖ តុល្យភាពដ៏លំបាក រវាងសម្ព័ន្ធភាព និងអធិបតេយ្យជាតិ

៦៩៧. ជាមួយនឹងជ័យជម្នះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ អ្នកសង្កេតការណ៍គ្រប់រូបដឹងច្បាស់ណាស់ថាទំនាស់បដិបក្ខតាំងពីយូរលង់ណាស់មកហើយ នៅតែកើតមានរវាងប្រទេសទាំងពីរ[683]។ ជាអាទិ៍ ច្បាស់ណាស់ថា របបកម្ពុជាប្រជាធិបតេយ្យថ្មីមិនអាចទទួលយកគំនិតបង្កើតសហព័ន្ធឥណ្ឌូចិនបានឡើយ[684]។ មេដឹកនាំថ្មីត្រូវស្វែងរកស្វ័យភាព និងអត្តិភាពផ្ទាល់ខ្លួននៅថ្នាក់អន្តរជាតិ និងរក្សាឯករាជ្យដែលទទួលបានក្នុងតម្លៃខ្ពស់ ប៉ុន្តែ ត្រូវធ្វើយ៉ាងណាថែរក្សាសម្ព័ន្ធភាពជាមួយបងធំជិតខាង។ ដូច្នេះ ពួកគេត្រូវផ្តល់អាទិភាពដល់ការចរចា (ផ្នែកទី ១)។ ប៉ុន្តែ ការពន្យារពេលក្នុងពេលដំបូងៗ បាននាំទៅដល់ផ្លូវទ័ល ហើយកម្ពុជាប្រជាធិបតេយ្យបានបដិសេធមហិច្ឆតានៅថ្នាក់តំបន់របស់វៀតណាម ដែលត្រូវបានមើលឃើញថាជាការប៉ះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជាប្រជាធិបតេយ្យ (ផ្នែកទី ២)។

### ផ្នែកទី ១. ការប៉ុនប៉ងចរចា នៅពេលចាប់ផ្តើមជម្លោះ

៦៩៨. ដោយសារតែលក្ខណៈពិសេសទីមួយនៃអធិបតេយ្យភាពរបស់ប្រទេសមួយ គឺបូរណភាពព្រំដែន គ្មានអ្វីត្រូវភ្ញាក់ផ្អើលទេថា ជម្លោះជាចំហបានចាប់ផ្តើមឡើង ដោយសារតែបញ្ហាព្រំដែនដែលកើតមានរាប់ទសវត្សរ៍មកហើយ។ យើងអាចយល់ស្របជាមួយអង្គជំនុំជម្រះ នៅក្នុងរឿងក្តី ឌុច ដែលយល់ឃើញថា "វិវាទ" បានកើតឡើងតាំងពីខែ មេសា ឆ្នាំ ១៩៧៥ ហើយជម្លោះបានផ្ទុះឡើងពិតប្រាកដនៅខែ ឧសភា ឆ្នាំ ១៩៧៥ ជាមួយនឹងហេតុការណ៍នៅកោះត្រល់ និងកោះក្រចកសេះ[685]។

---

[683] សារទូរលេខការទូតដែលផ្ញើរដោយស្ថានទូត អូស្ត្រាលីប្រចាំទីក្រុង ហាណូយ ទៅក្រសួងការបរទេសនៅទីក្រុង កង់បែរ៉ា ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៥ **ឯកសារ E3/9722**, ERN EN 01186941-42។

[684] សារទូរលេខការទូតដែលផ្ញើរដោយស្ថានទូត អូស្ត្រាលីប្រចាំទីក្រុង ហាណូយ ទៅក្រសួងការបរទេសនៅទីក្រុង កង់បែរ៉ា ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៥ **E3/9722**, ERN EN 01186945។

[685] សាលក្រម ឌុច ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ៦៦។

ទោះបីជាជម្លោះនេះបានរីកធំ ដោយដំបូងមានការប្រយុទ្ធគ្នាត្រឹមតែនៅតាមតំបន់យុទ្ធសាស្ត្រមួយចំនួនក៏ដោយ ក្នុងរយៈកាលដំបូង ខាងភាគីកម្ពុជាមានឆន្ទៈបន្ធូរបន្ថយភាពតានតឹង ដោយបានចេញសេចក្តីណែនាំឱ្យផ្តល់អាទិភាពដល់ការចរចា (១) ក្នុងការគ្រប់គ្រងសភាពការណ៍យោធាដែលទាមទារឱ្យមានការតាមដានជាប្រចាំ ដើម្បីថែរក្សាបូរណភាពព្រំដែន និងអធិបតេយ្យជាតិកម្ពុជា (២)។

## ១. ការចរចាដើម្បីប៉ុនប៉ងបន្ធូរបន្ថយភាពតានតឹង

៦៩៩. ចំពោះកម្ពុជាប្រជាធិបតេយ្យ ឆន្ទៈក្នុងការដកខ្លួនចេញពីអាណាព្យាបាលវៀតណាមមិនមែនមានន័យថាជាការប្រឆាំងដាច់ណាត់ទៅនឹងសម្ព័ន្ធមិត្តចាំបាច់នោះទេ។ ដូច្នេះ ប៉ុល ពត យល់ឃើញថាត្រូវសហប្រតិបត្តិការ និងថែរក្សាចំណងទាក់ទង ដោយប្រុងប្រយ័ត្ន។ ក្នុងស្មារតីនេះ ចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៥ មក គណៈអចិន្ត្រៃយ៍បានសម្រេចធ្វើអន្តរាគមន៍ ដោយធ្វើដំណើរទៅប្រទេសវៀតណាម ទោះបីជាមានភាពតានតឹងខាងយោធានៅតាមផ្លូវក៏ដោយ។ លោក Philip SHORT បានលើកឡើងអំពីទស្សនកិច្ចនៅខែឧសភានេះ ដែលកើតឡើងក្រោយពេលប្រឈមមុខដាក់គ្នាបន្តិចនៅតាមកោះជាប់ព្រំដែន។ លោកយល់ឃើញថា ប៉ុល ពត មានយុទ្ធសាស្ត្រ "ប៉ុនប្រសប់"[686]។

៧០០. បើតាមលោក François PONCHAUD ការវាយប្រហារកោះត្រល់ ដែលបណ្តាលឱ្យវៀតណាមវាយបកទៅលើកោះពូលូវៃវិញ ត្រូវបាន ប៉ុល ពត យល់ឃើញថាជាកំហុសរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដោយសារតែ "ការមិនស្គាល់ផែនទីច្បាស់" ហើយគាត់បានសុំទោសដល់អាជ្ញាធរវៀតណាម[687]។ ដូច្នេះ ប៉ុល ពត មានគំនិតធ្វើឱ្យស្ថានការណ៍ស្ងប់ស្ងាត់ និងធ្វើយ៉ាងណាឱ្យទំនាក់ទំនងមានភាពធូរស្រាល តាមដែលអាចធ្វើទៅបាន[688]។ ខាងវៀតណាមយកចិត្តទុកដាក់យ៉ាងខ្លាំងដល់បញ្ហាព្រំដែន និងការគ្រប់គ្រងបញ្ហានេះ។ សាធារណរដ្ឋសង្គមនិយមវៀតណាមមិនចង់បាត់បង់ "ឥទ្ធិពល" លើកម្ពុជា ដោយសារតែភាពតានតឹង និងភាពឆេវឆាវនោះទេ។ ភាគីទាំងពីរមានឆន្ទៈ

---

[686] សៀវភៅរបស់ Philip SHORT, មានចំណងជើងថា ប៉ុល ពត ប្រវត្តិសុបិនអាក្រក់ បោះពុម្ពផ្សាយឆ្នាំ ២០០៤ **ឯកសារ E3/9** ទំព័រ៣៨៤ ERN FR 00639839។

[687] អត្ថបទរបស់ François PONCHAUD មានចំណងជើងថា "វៀតណាម កម្ពុជា៖សាមគ្គីភាពស៊ីជុយស្រួយ" បោះពុម្ពផ្សាយខែ មិនា ឆ្នាំ **១៩៧៩ ឯកសារ E3/7258**, ERN FR 00281897-98។

[688] **ទស្សនាវដ្តី យុវជនបដិវត្តន៍ ចុះខែ សីហា ឆ្នាំ ១៩៧៥ ឯកសារ E3/749**, ERN FR 00593942។

ក្នុងការជម្នះការលំបាក។ ជាក់ស្ដែង ឡៅ យួន បានមកបំពេញទស្សនកិច្ចនៅកម្ពុជា ក្នុងខែ សីហា ឆ្នាំ ១៩៧៥ ដែលស្ថានទូតអូស្ត្រាលីយល់ឃើញថាមិនមែនជារឿងធម្មតានោះទេ[689]។

៧០១. នៅកម្ពុជាប្រជាធិបតេយ្យ សេចក្ដីណែនាំឱ្យបន្ធូរបន្ថយស្ថានការណ៍ត្រូវបានអនុវត្ត ដូចបានបញ្ជាក់ក្នុងកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍។ ជាក់ស្ដែង នៅខែ វិច្ឆិកា ឆ្នាំ ១៩៧៥ របាយការណ៍ស្ដីពីសភាពការណ៍នៅតាមព្រំដែនមានសេចក្ដីដូចតទៅ៖

> "ខាងផ្លូវទូត ពេលយើងទៅជួបវៀតណាម យើងនិយាយថា៖ យើងយកបក្សពលករវៀតណាម ប្រជាជនវៀតណាមជាមិត្តជិតស្និទ្ធ។ នៅមូលដ្ឋាន អាចមានការលើសលស់ខ្លះ តែបក្សយើងខ្ញុំដោះស្រាយបណ្ដើរៗ។ នៅរតនគិរី មានបងប្អូនវៀតណាមមកនៅអូរតាបូក ខាងយើងខ្ញុំបានប្រាប់ឱ្យមិត្តទាំងនោះដក តែមិត្តទាំងនោះមិនដក។ បើមិត្តទាំងនេះមិនដក អាចនាំឱ្យមានការភាន់ច្រឡំ។ ដូច្នេះ ស្នើប្រាប់ឱ្យមិត្តទាំងនោះដកផង។ យើងធ្វើយ៉ាងណាកុំឱ្យមានការប៉ះទង្គិចគ្នា។ បើមានការលើសលស់លើគ្នា យើងដោះស្រាយបណ្ដើរៗ។ យើងត្រូវធ្វើគំរូខាងមិត្តភាព"[690]។

៧០២. សារទូរលេខរបស់អង្គការផ្ញើជូន យ៉ា នៅខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ស្ដីពីសភាពការណ៍នៅតាមព្រំដែនខាងកើត ក៏មានខ្លឹមសារស្រដៀងគ្នានេះដែរ។ ក្រោយពីបានគ្រោងទុកនូវយុទ្ធវិធី និងយុទ្ធសាស្ត្រផ្សេងៗដែលត្រូវអនុវត្តក្នុងករណីប៉ះទង្គិចគ្នា សារទូរលេខនេះសង្ខេបអំពីឥរិយាបថនយោបាយដែលត្រូវប្រកាន់យក គឺត្រូវទាក់ទងមេដឹកនាំ និងព្យាយាមចរចា[691]។

## ២. ការបដិសេធរាល់ការប៉ះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជាប្រជាធិបតេយ្យ

៧០៣. ការផ្ដល់អាទិភាពដល់ការចរចា មិនមែនមានន័យថាភ្លេចការប្រុងប្រយ័ត្ន ឬបង្ហាញពីភាពទន់ខ្សោយនោះទេ។ សម្ព័ន្ធភាពនឹងដំណើរការក្រោមការឃ្លាំមើល។ មិនចាំបាច់ស្ថិតក្រោមអាណាព្យាបាលរបស់អ្នកណាទៀតទេ ក្រោយពីបង្ហាញកម្លាំងប្រមូលផ្ដុំរបស់ប្រជាជនកម្ពុជា។ លោក

---

[689] សារទូរលេខការទូតដែលផ្ញើរដោយស្ថានទូត អូស្ត្រាលីប្រចាំទីក្រុង ហាណូយ ទៅក្រសួងការបរទេសនៅទីក្រុង កង់បែរ៉ា ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៧៥ **ឯកសារ E3/9723**, ERN EN 01186943-45។

[690] កំណត់ហេតុប្រជុំនៃគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ **ឯកសារ E3/227**, ERN FR 00290868។

[691] សារទូរលេខផ្ញើរជូនចំពោះ យ៉ា ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ **ឯកសារ E3/1150**, ERN FR 00532738។

Stephen MORRIS បានលើកឡើងនៅក្នុងសវនាការ អំពីគំរូនៃសហព័ន្ធសូវៀត ដែលវៀតណាម មចង់ចម្លងតាម៖

> “ប្រវត្តិសាស្ត្រវៀតណាម គឺជាប្រវត្តិនៃដំណើរដ៏វែងឆ្ងាយឆ្ពោះទៅកាន់ភាគខាងត្បូង ដែលសព្វថ្ងៃនេះ ជាវៀតណាមខាងជើង ដើម្បីច្បាំងយកទឹកដីដែលពីមុនកាន់កាប់ដោយក្រុមជាតិពន្ធុផ្សេងទៀត រួមទាំងចាម និងខ្មែរ។ ផ្នែកធំៗ ដែលឥឡូវនេះជាវៀតណាមខាងត្បូង ធ្លាប់ជាទឹកដីរបស់កម្ពុជា។ បារាំងបានជួយកាត់ផ្តាច់ជាផ្លូវការពីកម្ពុជា បញ្ចូលទៅផ្នែកខាងត្បូងនៃប្រទេសវៀតណាម នៅក្នុងសម័យអាណានិគមបារាំង។ ខ្ញុំក៏គិតផងដែរថា ទស្សនាទានទាំងមូលនៃសហព័ន្ធឥណ្ឌូចិន ដែលត្រូវបានផ្តួចផ្តើមគំនិតដោយអង្គការកុម្មុយនីស្តអន្តរជាតិ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ ជាកម្លាំងដឹកនាំ និងកត្តាជំរុញ នៅក្នុងអាកប្បកិរិយារបស់កុម្មុយនីស្តវៀតណាមចំពោះកម្ពុជា ក្នុងបណ្តាទសវត្សរ៍ក្រោយមក។ ខ្ញុំគិតថា គំនិតនៃសហព័ន្ធឥណ្ឌូចិនយកគំរូតាមសហភាពសូវៀត។ មានអង្គភាពជាតិពន្ធុនយោបាយ ដែលផ្តល់ភាពជាអ្នកដឹកនាំទៅឱ្យក្រុមជាតិពន្ធុផ្សេងទៀត ដែលរណបខ្លួន។ ដូច្នេះ ដូចករណីសហភាពសូវៀត ក្រុមជាតិពន្ធុរុស្ស៊ីបានត្រួតត្រាប្រជាជនផ្សេងទៀតដែលមិនមែនជាជនជាតិរុស្ស៊ី នៅក្នុងសហភាពសូវៀត។ ដូច្នេះ វៀតណាមមើលឃើញថាឥណ្ឌូចិនជាកន្លែងមួយ ដែលវៀតណាមអាចត្រួតត្រាលើឡាវ និងកម្ពុជា ក្នុងភាពជាអ្នកដឹកនាំ ហើយពួកគេចាត់ទុកខ្លួនឯងថាជឿនលឿនជាងប្រជាជនឡាវ និងកម្ពុជា”[692]។

៧០៥. គម្រោង “វាតទីនិយម” ស្មើនឹង “ជាតិនិយមវៀតណាម”[693] ជាការបដិសេធល្អឥតខ្ចោះនូវឯករាជ្យភាពរបស់កម្ពុជា ដែលធ្វើឱ្យខ្មែរក្រហមច្រានចោលទាំងស្រុង។ ហេតុនេះហើយបានជានៅពេលព្យាយាមគ្រប់គ្រងទំនាក់ទំនងស្មើភាពជាងមុនជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម សភាពការណ៍ប្រទេសនៅតែជាការព្រួយបារម្ភគ្រប់ពេលទាំងអស់។ ជាក់ស្តែង កម្លាំងវៀតណាមតែងតែ

---

[692] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/485.1** ទំព័រ ៦៥-៦៦ ប្រហែលម៉ោង 15.13-15.15 (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

[693] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/485.1** ទំព័រ ៦៨ ប្រហែលម៉ោង 15.22.30៖ “វាស្ថិតនៅក្នុងវប្បធម៌ បើតាមខ្ញុំយល់។ ជាតិនិយមជាវប្បធម៌វៀតណាម។ ខ្ញុំគិតថា ជាតិនិយមវៀតណាមមានលក្ខណៈវាតទីនិយមរហូតដល់ថ្មីៗនេះ។” ប្រតិចារឹក ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/485.1** ទំព័រ ៩៥ មុនម៉ោង 15.17៖ “គោលគំនិតនៃអត្ថិភាពរបស់សហព័ន្ធជាគំនិតមួយស្របតាមមនោគមវិជ្ជា ម៉ាក្សលេនីន ប៉ុន្តែតាមពិតទៅ វាជាផែនការវៀតណាមយ៉ាងជាក់ស្តែងដែលមានការរុំស្រោបបិទបាំងដើម្បីឱ្យស្របតាមលទ្ធិ ម៉ាក្សលេនីន (យើងជាអ្នកគូសបន្ទាត់ពីក្រោម)”។

កាន់កាប់ទឹកដីកម្ពុជាមួយចំណែក នៅភាគឦសាន។ ដូចលោក David CHANDLER បានគូស បញ្ជាក់ ឧទាហរណ៍របស់ឡាវធ្វើឱ្យគ្រប់គ្នាចងចាំជានិច្ច[694]។

៧០៥. ដូច្នេះ ទន្ទឹមនឹងការចរចា កងកម្លាំងយោធាប៉ះទង្គិចគ្នាជាទៀងទាត់ ដែលមានទ្រង់ទ្រាយកាន់តែធំ ឡើងៗប៉ុន្មានខែក្រោយមក។ ប្រវត្តិវិទូ Dmitry MOSYAKOV បានលើកឡើងថា សាធារណរដ្ឋ សង្គមនិយមវៀតណាម មិនធ្លាប់លះបង់មហិច្ឆតាចង់រក្សាទុកកម្ពុជាជាដែនដីបម្រុងរបស់ខ្លួនទាល់ តែសោះ ហើយបើកចំហដោយសេរីគួរសមជាមួយដៃគូសន្ធានរុស្ស៊ី[695]។

៧០៦. ផ្ទុយទៅវិញ កម្ពុជាប្រជាធិបតេយ្យកាន់តែព្យាយាមផ្ដាច់ខ្លួនចេញពីឥទ្ធិពលរបស់វៀតណាម។ ក្នុង បរិបទនេះ បញ្ហាព្រំដែនដែលផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងអធិបតេយ្យជាតិ បានក្លាយជាបញ្ហា ប្រឈមជានិមិត្តរូប។ ដូចលោក Stephen MORRIS បានគូសបញ្ជាក់ "បញ្ហាព្រំដែនជាការផ្ទុះ បញ្ចាំងនូវបញ្ហានយោបាយយ៉ាងស៊ីជម្រៅ"[696]។ តាមពិត ការព្រួយបារម្ភដ៏ចម្បងមួយរបស់កម្ពុជា ប្រជាធិបតេយ្យ គឺចង់មានអត្តិភាពផ្ទាល់ខ្លួននៅលើឆាកអន្តរជាតិ។ ដូច្នេះ ការស្វែងយល់ និងការ ប្រើប្រាស់បរិបទភូមិសាស្ត្រនយោបាយមានសារៈសំខាន់ណាស់។

## ផ្នែកទី ២. <u>បរិបទភូមិសាស្ត្រនយោបាយស្មុគស្មាញ</u>

៧០៧. ការវិវត្តនៃជម្លោះខ្មែរ-វៀតណាមក៏ត្រូវពិនិត្យ ដោយពិចារណាទៅលើបរិបទភូមិសាស្ត្រនយោបាយ នៅសម័យនោះផងដែរ។ ប្រទេសទាំងពីរមិនខ្វល់នឹងក្រសែភ្នែករបស់ប្រទេសផ្សេងទៀត ដែលចង់ រក្សាតុល្យភាព ក្នុងពេលភ្លើងសង្គ្រាមត្រជាក់កំពុងឆេះពេញបន្ទុក នោះឡើយ។ ក្រោយពីទទួលបាន ជ័យជម្នះយោធាលើសហរដ្ឋអាមេរិកដែលជានិមិត្តរូបនៃចក្រពត្តិនិយម កម្ពុជាប្រជាធិបតេយ្យត្រូវ ស្វែងរកការគាំទ្រ ក្នុងចំណោមប្រទេសមិនចូលបក្សសម្ព័ន្ធ និងធ្វើសង្គ្រាមការទូតដើម្បីការពារបុព្វ

---

[694] សៀវភៅរបស់ David CHANDLERមានចំណងជើងថា ប៉ុល ពត បងធំទីមួយ បោះពុម្ពឆ្នាំ ១៩៩២ **ឯកសារ E3/17** ទំព័រ ១៨៣ ERN FR 01242742។

[695] អត្ថបទរបស់ Dmitry MOSYAKOV ដែលមានចំណងជើងថា "រឿងរ៉ាវរវាងពួកខ្មែរក្រហម និងពួកកុម្មុយនីស្ត វៀតណាមផ្អែកលើ បណ្ណសារសូវៀត" ឆ្នាំ ២០០៤ **ឯកសារ E3/9644**, ERN FR 01125297។

[696] <u>Stephen MORRIS</u> : ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/487.1** ទំព័រ ៥៨-៥៩ មុនម៉ោង 11.18.28។

ហេតុរបស់ខ្លួន នៅក្នុងជម្លោះជាមួយវៀណាម (១)។ ក្នុងពេលជាមួយគ្នានេះ ចិន និងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតបានខិតខំចាត់ចែងឥទ្ធិពលរបស់ខ្លួនលើប្រទេសទាំងពីរ (២)។

## ១. ចលនានៃប្រទេសមិនចូលបក្សសម្ព័ន្ធ និងបញ្ហាប្រឈមខាងការទូត

៧០៨. កម្ពុជាប្រជាធិបតេយ្យដឹងអំពីសារៈសំខាន់ ក្នុងការធានាបានមូលដ្ឋានរបស់ខ្លួនលើឆាកអន្តរជាតិ។ កម្ពុជាប្រជាធិបតេយ្យមិនត្រឹមតែត្រូវស្វែងរកសម្ព័ន្ធមិត្តសេដ្ឋកិច្ច ដែលមានមនោគមន៍វិជ្ជាដូចគ្នាប៉ុណ្ណោះទេ គឺត្រូវរួបរួមជាមួយប្រទេសដែលតស៊ូដើម្បីសិទ្ធិស្វ័យសម្រេច ឯករាជ្យភាពជាតិ និងការអភិវឌ្ឍចម្រើននិយម។ ចំពោះរដ្ឋកម្ពុជា ច្បាស់ណាស់ថា ការបង្ហាញបុព្វហេតុរបស់ខ្លួនចំពោះប្រទេសមិនចូលបក្សសម្ព័ន្ធ គឺជាយុទ្ធសាស្ត្រតស៊ូប្រឆាំងនឹងមហិច្ឆតាថ្នាក់តំបន់របស់សាធារណរដ្ឋសង្គមនិយមវៀតណាម ដូចមានបង្ហាញច្បាស់នៅក្នុងកំណត់ហេតុមួយរបស់គណៈអចិន្ត្រៃយ៍[697]។

៧០៩. សាធារណរដ្ឋសង្គមនិយមវៀតណាមក៏យល់ផងដែរ ថាត្រូវគ្រប់គ្រងភាពតានតឹងដោយភាពវៃឆ្លាត ដើម្បីកុំឱ្យគេមានអារម្មណ៍ថាខ្លួនជាកម្លាំងចក្រពត្តិ ខណៈដែលខ្លួនចង់ចូលក្នុងចលនាមិនចូលបក្សសម្ព័ន្ធ[698]។ វៀតណាមក៏ត្រូវទប់ទល់នឹងភាពឆេវឆាវរបស់ចិន ដែលមិនអនុគ្រោះដល់មហិច្ឆតាថ្នាក់តំបន់របស់ខ្លួន។

៧១០. នៅក្នុងទំនាក់ទំនងកម្លាំងថ្មី ក្នុងពិភពលោកដែលបែងចែកជាពីរប្លុកដោយសង្គ្រាមត្រជាក់ កម្ពុជាប្រជាធិបតេយ្យដឹងថាខ្លួនមិនអាចអត់ចិនបានឡើយ ដោយសារតែចិនបានផ្តល់ជំនួយពីអតីតកាលក្នុងអំឡុងសង្គ្រាមប្រឆាំងនឹងរបប លន់ នល់ ហើយចិនជាមហាអំណាចក្នុងតំបន់តែមួយគត់ដែលអាចផ្តល់ជំនួយភ័ស្តុភារ បច្ចេកទេស និងយោធា ដល់ប្រទេសមួយដែលត្រូវកសាងឡើងវិញទាំងស្រុង។។ បញ្ហាប្រឈមខាងភូមិសាស្ត្រនយោបាយមានសារៈសំខាន់ដែលត្រូវយកចិត្តទុកដាក់ ទាំងនៅថ្នាក់អន្តរជាតិ ដើម្បីទទួលបានការគាំទ្រកាន់តែច្រើន និងនៅថ្នាក់តំបន់ ដែលត្រូវគ្រប់គ្រងជាមួយនឹងសង្គ្រាមឥទ្ធិពលរបស់ចិន និងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត។

---

[697] កំណត់ហេតុប្រជុំនៃគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦ **ឯកសារ E3/217**, ERN FR 00334966។

[698] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/487.1** ទំព័រ៤៣ នៅម៉ោង 13.35.57។

## ២. ចិន និងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតនៅពីក្រោយឆាក

៧១១. ចិន និងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត បានដើរតួនាទីយ៉ាងសំខាន់ ក្នុងជម្លោះរវាងខ្មែរ និងវៀតណាម។ ពេលលើកឡើងអំពីដើមកំណើតនៃនិក្ខេបបទថ្នាក់បណ្ឌិតរបស់ខ្លួន នៅសវនាការ លោក Stephen MORRIS បានរំឭកថា វៀតណាមរេទៅរេមក រវាងមហាអំណាចពីរ ក្នុងសម័យសង្គ្រាមត្រជាក់[699]។ ទំនាក់ទំនងរវាងប្រទេសទាំងពីរបានប្រែក្លាយជាល្អក់កករ នៅដើមឆ្នាំ ១៩៧០ ស្ទើរតែឈានទៅដល់ការប្រឈមមុខដាក់គ្នា និង "កាន់តែមានសភាពអាក្រក់ទៅៗ"[700]។ ជម្លោះរវាងកម្ពុជា និងវៀតណាម ជាឧទាហរណ៍ល្អឥតខ្ចោះនៃល្បែងមួយនេះ របស់សាធារណរដ្ឋសង្គមនិយមវៀតណាម និងមហាអំណាចទាំងពីរ និងជាឧទាហរណ៍អំពីរបៀបដែលវៀតណាមបានដើរត្រី ដើម្បីសម្រេចគោលបំណងនយោបាយ និងយោធារបស់ខ្លួន[701]។

៧១២. តម្រូវការសម្ព័ន្ធភាពរវាងកម្ពុជាប្រជាធិបតេយ្យជាមួយរបបជា "មិត្ត" បានពង្រឹងចំណងទាក់ទងជាមួយចិន។ ចិនបានផ្តល់ជំនួយខាងសេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកទេស និងយោធា[702]។ ដូចក្នុងគ្រប់កិច្ចសហប្រតិបត្តិការទាំងអស់ដែរ នេះមិនមែនជាកាយវិការគ្មានល័ក្ខខ័ណ្ឌនោះទេ។ បើតាមលោក Stephen MORRIS ចិនចង់រក្សាឥទ្ធិពលរបស់ខ្លួនក្នុងតំបន់អាស៊ីមួយនេះ និងទប់ "មហិច្ឆតាក្នុងការត្រួតត្រាកម្ពុជា និងឡាវ" របស់វៀតណាម ដែលគេមើលឃើញយ៉ាងឆាប់រហ័ស[703]។

៧១៣. សាធារណរដ្ឋសង្គមនិយមវៀតណាមកសាងទំនាក់ទំនងពិសេស ជាមួយសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត។ វៀតណាមត្រូវការសម្ព័ន្ធមិត្តខ្លាំងដូចជាចិន ហើយគោលជំហរពិសេសរបស់វៀតណាមនៅអាស៊ីអាគ្នេយ៍អាចឱ្យសហភាពសូវៀតមានឥទ្ធិពលទៅលើតំបន់ ក្នុងនាមជាតំណាងឱ្យសូវៀត។ ចិនមើលឃើញការខិតជិតរវាងវៀតណាម និងសូវៀតជាគ្រោះថ្នាក់ និងប្រកបដោយ

---

[699] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/485.1** ទំព័រ ៤៤ ប្រហែលម៉ោង 13.47.03។

[700] Stephen MORRIS, ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ៨៥ ប្រហែលម៉ោង 15.42.07។

[701] សូមមើលខាងក្រោមនៅកថាខណ្ឌ ៨១៧-៨៣២។

[702] ទាក់ទងនឹងជំនួយផ្នែកសម្ភារៈសិក សូមអានសក្ខីកម្មរបស់សាក្សី 2-TCW-1000 ៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/369.1** ទំព័រ ៥៤ ក្រោយម៉ោង 14.34.35។

[703] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/485.1** ទំព័រ ៧១ ប្រហែល 15.40.18។

"ការភ័យខ្លាចមានមូលដ្ឋាន" ហើយចាត់ទុកថាជាសញ្ញានៃភាពអកតញ្ញូពីសំណាក់វៀតណាម ដែលខ្លួនបានផ្តល់ជំនួយជាច្រើន នៅមុន និងក្នុងពេលសង្គ្រាមវៀតណាម[704]។

៧១៤. ការតស៊ូដើម្បីឥទ្ធិពលរវាងចិន និងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតបណ្តាលឱ្យទីប្រឹក្សាប្រធានាធិបតីអាមេរិក និយាយនៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៧៨ ថា ជម្លោះវៀតណាម-កម្ពុជាជា "សង្គ្រាមលាក់មុខ" រវាងចិន និងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត[705]។ ម្យ៉ាងវិញទៀត អាវុធប្រើប្រាស់ដោយវៀតណាមមកពីសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត[706] និងអាវុធប្រើប្រាស់ដោយកម្ពុជាប្រជាធិបតេយ្យមកពីចិន[707]។

## ភាគទី ២. ការប្រព្រឹត្តិនៅនៃជម្លោះ ផ្នែកតាមភ័ស្តុតាងនៅក្នុងសំណុំរឿង

៧១៥. តាមរយៈជ័យជម្នះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩ និងបទពិសោធន៍ការទូតដែលមានការអភិវឌ្ឍជាងបទពិសោធន៍ការទូតរបស់កម្ពុជាប្រជាធិបតេយ្យ សាធារណរដ្ឋសង្គមនិយមវៀតណាមមានឱកាសក្នុងការកែច្នៃអង្គហេតុ ដោយគ្រប់គ្រងលើព័ត៌មានដែលខ្លួនបានផ្តល់ជូនពាក់ព័ន្ធនឹងជម្លោះ។ ម្យ៉ាងទៀត ឆន្ទៈក្នុងការផ្តន្ទាទោសអតីតតំណាងកម្ពុជាប្រជាធិបតេយ្យ បានរារាំងជារឿយៗដល់ការមើលឃើញជម្លោះ ក្នុងលក្ខណៈសត្យានុម័តិ។ ដូច្នេះ សហព្រះរាជអាជ្ញាហាក់ដូចជាស្ងូត្រតាមទស្សនៈដែលថាកម្ពុជាប្រជាធិបតេយ្យចូលចិត្តធ្វើសង្គ្រាម តាមការឃោសនារបស់សាធារណរដ្ឋសង្គមនិយមវៀតណាម (ជំពូកទី ១) ដោយមិនអើពើនឹងភ័ស្តុតាងនៅក្នុងសំណុំរឿង ដែលអាចឱ្យមានទស្សនវិស័យខុសពីនេះ (ជំពូកទី ២)។

### ជំពូកទី ១. ការបកស្រាយជម្លោះជាឯកតោភាគី ដែលសហព្រះរាជអាជ្ញាបានជ្រើសយក

---

704 Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ១៤ ប្រហែល 09.43.07។

705 សៀវភៅរបស់ David CHANDLER, ប៉ុល ពត បងទីមួយ បោះពុម្ពឆ្នាំ 1992 **ឯកសារ E3/17** ទំព័រ ២៣៤ ERN FR 01242768។

706 Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៦៦ មុនម៉ោង 14.22.51។

707 Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៨១ មុនម៉ោង 15.28.45។

៧១៦. ចំពោះការឃោសនា កម្លាំងរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមត្រូវភ្ជាប់ទំនាក់ទំនងការទូត ទាំងក្នុងពេល និងក្រោយជម្លោះ។ នៅពេលកងទ័ពវៀតណាមចូលទីក្រុងភ្នំពេញ បណ្ណសារទាំងអស់ដែលមាននៅតាមមន្ទីរផ្សេងៗ ត្រូវបានគ្រប់គ្រងដោយម្ចាស់ថ្មីនៃកម្ពុជា។ មកទល់នឹងសព្វថ្ងៃនេះ យើងមិនដឹងថាគេយកឯកសារទាំងអស់នោះទៅធ្វើអ្វីនោះទេ។

៧១៧. ចំណងទាក់ទងត្រូវបានរៀបចំយ៉ាងឆាប់រហ័សប្រឆាំងនឹង "បន ប៉ុល ពត - អៀង សារី" ប៉ុន្តែ នៅពេលត្រូវផ្តល់ឯកសារជូនតុលាការ អាជ្ញាធរមិនសូវខ្នះខ្នែងនោះទេ។ ជាភ័ស្តុតាង សំណើរបស់ចៅក្រម អ.វ.ត.ក នៅតែគ្មានចម្លើយតប ឬមានចម្លើយតបមិនពេញលេញ និង/ឬយឺតយ៉ាវ[708]។ នេះជាការពន្យល់មួយដែលយើងអាចធ្វើបាន ចំពោះការប្រើប្រាស់តិចតួចនូវឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យ នៅក្នុងសំណោរអំពីជម្លោះកម្ពុជា-វៀតណាម ដែលចុះផ្សាយមកដល់សព្វថ្ងៃនេះ (ផ្នែកទី ១)។ ដូច្នេះ អង្គជំនុំជម្រះត្រូវយកចិត្តទុកចិត្តចំពោះភ័ស្តុតាងដែលខ្លួនមាន ដើម្បីអាចយល់អំពីជម្លោះ ក្នុងលក្ខណៈសត្យានុម័តិ និងក្នុងទិដ្ឋភាពផ្សេងគ្នា (ផ្នែកទី ២)។

## ផ្នែកទី ១. ការប្រើប្រាស់តិចតួចនូវឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យ

៧១៨. អង្គជំនុំជម្រះបានទទួលយកឯកសារមួយចំនួនធំជាភ័ស្តុតាង ហើយភាគច្រើនជាឯកសារថតចម្លងដែលភាគីមិនអាចពិនិត្យមើលច្បាប់ដើមបាន។ ហេតុអ្វីបានជាឯកសារខ្លះលេចឡើងជាថ្មី ឯខ្លះទៀតមិនលេចឡើងជាថ្មី នៅក្នុងបណ្ណសារដ៏ច្រើនសម្បើម? ទោះបីជាសក្ខីកម្មមួយចំនួនបានលើកឡើងអំពីទម្លាប់បំផ្លាញឯកសារក្រោយឆ្នាំ ១៩៧៩ របស់អាជ្ញាធរមូលដ្ឋានថ្មី[709] ក៏ដោយ ច្បាស់ណាស់

---

[708] ទាក់ទងនឹងប្រធានបទនេះ សូមមើលសេចក្តីសង្ខេបនៃសំណើនៅក្នុងអនុស្សរណៈរបស់ចៅក្រម BOHLANDER ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ **ឯកសារ E327/4/2/1**. សូមមើលផងដែរនូវអនុស្សរណៈ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E327/4/8** (ដែលក្នុងនោះអង្គជំនុំជម្រះស្រង់គ្រប់អ្វីដែលខ្លួនបានព្យាយាមធ្វើ មុននឹងសន្និដ្ឋានថាខ្លួនមិនបានទទួលចម្លើយអ្វីទាំងអស់ពីរដ្ឋាភិបាលវៀតណាម)។

[709] ស៊ុំ អាឡាត់ (SUM Alat) : ប្រតិចារឹក ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ **ឯកសារ E1/218.1** ទំព័រ ៨៣ មុនម៉ោង 16.14.48 ; សែន ស្រ៊ុន (SEN Srun) : ប្រតិចារឹក ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/347.1** ទំព័រ ១១ មុនម៉ោង 09.36.08. សូមមើល កំណត់ហេតុស្តាប់ចម្លើយ **ឯកសារ E3/10616 ឯកសារ E3/10617** និង **ឯកសារ E3/10618**។

ថា អ្នកនិពន្ធ និងអ្នកជំនាញភាគច្រើន ដែលបានសរសេរអំពីជម្លោះមកដល់សព្វថ្ងៃនេះ បានកម្រិតការស្រាវជ្រាវរបស់ខ្លួន និងផ្អែកយ៉ាងខ្លាំងលើប្រភពវៀតណាម។

៧១៩. ករណីរបស់លោក Nayan CHANDA ដែលមិនចង់មានពេលទំនេរ ដើម្បីមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០២[710] គឺជាការបង្ហាញនូវការលំបាកក្នុងការយល់ឃើញអំពីជម្លោះ ដោយមិនលម្អៀង។ ទោះបីជាសហព្រះរាជអាជ្ញាចាត់ទុក Nayan CHANDA ជាអ្នកជំនាញ ដែលបានធ្វើការជាមួយនឹងប្រភពទាំងសងខាងក៏ដោយ[711] ក៏កាលបរិច្ឆេទដែលគាត់សរសេរសៀវភៅ *"សត្រូវបងប្អូនឯង"* និងប្រភព (ការសម្ភាសន៍ ឯកសារ គន្ថនិទ្ទេស) ដែលមាននៅទំព័រចុងក្រោយ បង្ហាញថា ប្រភពទាំងនោះភាគច្រើនចេញមកពីវៀតណាម[712] និងមានកាលបរិច្ឆេទមុនទសវត្សរ៍ឆ្នាំ ១៩៩០[713]។ នៅក្នុងសាលក្រមលើសំណុំរឿង ឌុច អង្គជំនុំជម្រះបានលើកឡើងថា Nayan CHANDA បាន "ទទួលស្គាល់ថាខ្លួនមិនបានទទួលឯកសារផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងប្រភេទដូចដែលបានរៀបរាប់នោះទេ"[714]។

៧២០. ដូចគ្នាផងដែរ លោក Stephen MORRIS បានគូសបញ្ជាក់យ៉ាងច្បាស់នៅក្នុងសវនាការថា ប្រភពចម្បងរបស់គាត់ គឺបណ្ណសារសូវៀត បានមកពីកម្មាភិបាលបក្ស និងអ្នកការទូតផ្សេងទៀត ដែលទទួលបានព័ត៌មានពីសាធារណរដ្ឋសង្គមនិយមវៀតណាម[715]។ ម្យ៉ាងទៀត លោកបានលើកឡើង

---

[710] ប្រតិចារឹក ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/458.1** ទំព័រ ១៧-២៧ រវាង 10.10.05 និង 10.35.29 ; របាយការណ៍របស់អង្គភាពគាំពារសាក្សី និងអ្នកជម្នាញ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E29/492**។

[711] ដីការសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះស្ថាពររបស់សហព្រះរាជអជ្ញា (វិធាន 66) ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ **ឯកសារ D390** កថាខណ្ឌ ៣២។

[712] សៀវភៅរបស់ Nayan CHANDA, បងប្អូនជាសត្រូវនឹងគ្នា៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម បោះពុម្ពឆ្នាំ *1986* **ឯកសារ E3/2376,** កំណត់ត្រាចាប់ពី ទំព័រ ៤១៥ ERN EN 00192600។

[713] សៀវភៅរបស់ Nayan CHANDA បងប្អូនជាសត្រូវនឹងគ្នា៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម បោះពុម្ពឆ្នាំ *1986* **ឯកសារ E3/2376.** សៀវភៅនេះបោះពុម្ពនៅឆ្នាំលើកទីមួយនៅឆ្នាំ 1986 ដូចដែលមានបញ្ជាក់នៅក្នុង "រក្សាសិទ្ធិគ្រប់យ៉ាង" នៃសំណៅជាភាសាអង់គ្លេស l'ERN EN 001972173។

[714] សាលក្រមឌុច *Duch* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៧០។

[715] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/487.1** ទំព័រ ៣០, ក្រោយម៉ោង 10.53.01. ទោះបីជា MORRIS បានបញ្ជាក់ថាខ្លួនបានសំណេះសំណាលជាមួយ អៀង សារី និង សីហនុ ក្រោយអំឡុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយក៏គាត់ទទួលស្គាល់ថាគាត់មិនបាននិយាយជាមួយអ្នកទាំងពីររូបអំពីអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យដែរ។

អំពីលក្ខណៈ "មិនទៀងត្រង់" របស់វៀតណាម នៅក្នុងល្បែងការទូត[716] ដែលត្រូវបានពន្យល់ផង ដែរដោយលោក Dmitry MOSYAKOV[717]។

៧២១. ក្នុងការរិះគន់សៀវភៅរបស់លោក Stephen MORRIS លោក CHANDLER បានបន្ទោសអំពីការបកស្រាយចង្អៀតចង្អល់ពេកនូវគោលជំហររបស់កម្ពុជាប្រជាធិបតេយ្យ ចំពោះវៀតណាម និងគូសបញ្ជាក់យ៉ាងត្រឹមត្រូវថា៖

> "នៅទំព័រ ៦៨ និងផ្នែកផ្សេងទៀត Stephen MORRIS បានរិះគន់ពួកខ្មែរក្រហមចំពោះទំនាក់ទំនងអន្តរជាតិមិនច្បាស់លាស់ និងមិនសមហេតុផលរបស់ពួកគេ ប៉ុន្តែ <u>ខកខានពុំបានលើកឡើងពីអ្វីដែលអាចជាគោលនយោបាយសមស្របចំពោះប្រទេសវៀតណាម</u> ក្រៅពីបន្ទន់ខ្លួនទៅតាមការឧបត្ថម្ភគាំទ្រ និងការទាមទាររបស់វៀតណាម។ ដូច Stephen MORRIS បានលើកឡើង ក្នុងករណីណាក៏ដោយ ប្រទេសវៀតណាមខ្លួនឯងបានអនុវត្តភ្លាមៗនូវគោលនយោបាយមិនសមស្របដែលមានលក្ខណៈស្រដៀងគ្នា ដាក់ប្រទេសចិន ដែលបង្កឱ្យមានជម្លោះលទ្ធិម៉ាក្ស-លេនីន ឬភាពសង្ស័យដ៏លើលា តិចជាងទៅលើទស្សនៈនៃការគំរាមកំហែងដល់អធិបតេយ្យភាព ដោយផ្អែកខ្លះៗទៅលើការពិចារណាលើប្រវត្តិសាស្ត្រ។
>
> នៅទំព័រ ៧២ Stephen MORRIS បានលើកឡើងថា មានភស្តុតាងតិចតួចបញ្ជាក់ថា ថៃ និងវៀតណាម កំពុងវាយប្រហារលើប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩៧៦។ <u>តាមពិត ឯកសាររបស់ខ្មែរក្រហមមួយចំនួនធំពាក់ព័ន្ធនឹងវិស័យការពារជាតិ បានលេចឡើងនៅក្នុងទីក្រុងភ្នំពេញ ចាប់តាំងពី Stephen MORRIS បានបញ្ចប់ការសិក្សាស្រាវជ្រាវរបស់គាត់មកម្ល៉េះ</u>។ ឯកសារទាំងនេះបង្ហាញថា ចាប់តាំងពីឆ្នាំ ១៩៧៦ មក ការប៉ះទង្គិចគ្នាបន្តិចបន្តួចជាញឹកញាប់នៅតាមបណ្តោយព្រំដែនកម្ពុជា បង្កឡើងដោយកងកម្លាំងថៃ វៀតណាម និងខ្មែរ និងក្នុងករណីជាច្រើន ប្រហែលជាកើតចេញពីប្រតិកម្មតបនឹងការបង្ករឿងតិចតួច រីតតែធ្វើឱ្យ ប៉ុល ពត ជឿជាក់ថាប្រទេសកម្ពុជាត្រូវបានហ៊ុំព័ទ្ធដោយសត្រូវ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[718]។

---

៖ ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៧៣ នៅម៉ោង 15.03.12 (IENG Sary) និង ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៧៤ ក្រោយម៉ោង 15.04.16 (SIHANOUK)។

[716] <u>Stephen MORRIS</u> : ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ១២, ប្រហែលម៉ោង 09.35.13។

[717] អត្ថបទរបស់ Dmitry MOSYAKOV ដែលមានចំណងជើងថា "រឿងរ៉ាវរវាងពួកខ្មែរក្រហម និងពួកកុម្មុយនីស្ត វៀតណាមផ្អែកលើ បណ្ណសារសូវៀត" ឆ្នាំ ២០០៤ **ឯកសារ E3/9644**, ERN FR 01125311។

[718] អត្ថបទរបស់ David CHANDLER ដែលមានចំណងជើងថា ៖ "ហេតុអ្វីបានវៀតណាមឈ្លានពានកម្ពុជា" **ឯកសារ E3/10703,** ERN EN 01335287។

៧២២. លោក Stephen MORRIS បានឯកភាពទាំងស្រុង ដោយឌីដងផ្ដែផ្ដាបន្ដិចថា គាត់ពិតជាមិនអាចប្រើប្រាស់ឯកសារដែលគាត់គ្មានលទ្ធភាពទទួលបាន មុនពេលសរសេរសៀវភៅមែន[719]។ លោកក៏បានគូសបញ្ជាក់ផងដែរថា ក្នុងការពិគ្រោះបណ្ណសារសូវៀត គាត់គ្មានលទ្ធភាពចូលទៅពិនិត្យផ្ទាល់ដល់ប្រភពរបស់កម្ពុជាប្រជាធិបតេយ្យនោះទេ គឺគាត់ទទួលបានព័ត៌មានតែតាមការរាយការណ៍ពីសំណាក់អាជ្ញាធរវៀតណាមប៉ុណ្ណោះ[720]។

៧២៣. ឧទាហរណ៍ទាំងនេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា អ្នកស្រាវជ្រាវភាគច្រើនដែលបានចេញផ្សាយមុនពេលបង្កើតតុលាការ បានសរសេរអំពីជម្លោះប្រដាប់អាវុធ ដោយគ្មានភស្ដុតាងអ្វីទាំងអស់។

៧២៤. នៅក្នុងពេលជំនុំជម្រះក្ដី សហព្រះរាជអាជ្ញាតែងតែដកស្រង់ប្រភពចេញពីលោក Ben KIERNAN ដែលបានសរសេរសៀវភៅជាច្រើនអំពីសម័យកម្ពុជាប្រជាធិបតេយ្យ ប៉ុន្ដែមិនបានឆ្លើយតបទៅនឹងការកោះហៅរបស់អង្គជំនុំជម្រះឱ្យមកផ្ដល់សក្ខីកម្ម។ ផ្ទុយទៅវិញ លោក Stephen MORRIS បានគូសបញ្ជាក់ថា ការវិភាគរបស់លោក Ben KIERNAN ពោរពេញទៅដោយភាពអគតិ និង "ស្របតាមការបកស្រាយរបស់បក្សកុម្មុយនីស្ដវៀតណាម ទៅលើហេតុការណ៍ដែលកើតឡើងនៅប្រទេសកម្ពុជា"[721]។

៧២៥. ជាក់ស្ដែង ឯកសារជាច្រើនក្នុងសំណុំរឿង ០០២/០២ ដូចជា កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ កំណត់ហេតុកិច្ចប្រជុំកងពល និងសារទូរលេខស្ដីពីការប្រយុទ្ធគ្នានៅតាមសមរភូមិ គឺជាប្រភពព័ត៌មានដ៏មានតម្លៃបំផុត។

---

[719] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E3/487.1**, ទំព័រ ៣៣ ប្រហែលម៉ោង 11.03.18។

[720] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/487.1**, ទំព័រ ៣១ ប្រហែលម៉ោង 10.56.02។

[721] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/485.1** ទំព័រ ៥២ ប្រហែលម៉ោង 14.14.40 : "Ben Kiernan ជាបុគ្គលដែលទទួលឥទ្ធិពលនយោបាយខ្លាំងដែលមានរបៀបវារៈនយោបាយយ៉ាងតឹងរឹង។ នៅក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត គាត់ជាអ្នកគាំទ្រកម្ពុជាប្រជាធិបតេយ្យយ៉ាងស្មោះស្ម័គ្រ ហើយទាល់តែវៀតណាមបកមកប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យហើយទេបាន Ben Kiernan ចាប់ផ្ដើមរិះគន់ ប៉ុល ពត និងខ្មែរក្រហម។ បន្ទាប់មកទៀត Ben Kiernan បានប្រកាន់គោលជំហរមួយដែលគេអាចចាត់ទុកថាជាគោលជំហរដែលពិតជាស្របគ្នាទៅនឹងការបកស្រាយព្រឹត្តការណ៍ដែលកើតមានឡើងនៅប្រទេសកម្ពុជាដោយបក្សកុំម្មុយនីស្ដវៀតណាម។ "(យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

## ផ្នែកទី ២. ការប្រើប្រាស់ចាំបាច់នូវបណ្ដាសាររបស់កម្ពុជាប្រជាធិបតេយ្យ សម្រាប់ការបកស្រាយបញ្ហាសព្វថ្ងៃនេះ

៧២៦. ចំណុចគួរឱ្យភ្ញាក់ផ្អើល ពេលយើងពិនិត្យមើលឯកសារនៅសម័យនោះ ដែលមាននៅក្នុងសំណុំរឿង គឺទេវកថាដែលត្រូវបានបង្កើតឡើង ជុំវិញឆន្ទៈចូលចិត្តប្រើកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យ (១) ខណៈដែលភស្តុតាងជាច្រើនបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាបានដឹងអំពីភាពខុសគ្នានៃចំនួនកងទ័ពរវាងប្រទេសទាំងពីរ (២) និងគ្មានប្រយោជន៍អ្វីដែលត្រូវបង្កជម្លោះនោះទេ (៣)។

### ១. ទេវកថាអំពីឆន្ទៈចូលចិត្តប្រើកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យ

៧២៧. គោលជំហររបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងពេលចរចាលើកដំបូង នៅខែ មេសា និងខែ ឧសភា ឆ្នាំ ១៩៧៥ ច្បាស់ណាស់ គឺបញ្ចៀសជម្លោះតាមដែលអាចធ្វើទៅបាន[722]។ នៅពេលងើបចេញពីសង្គ្រាមរ៉ាំរ៉ៃយ៉ាងត្រដាបត្រដួស កម្ពុជាប្រជាធិបតេយ្យគ្មានចំណាប់អារម្មណ៍ក្នុងការធ្វើសង្គ្រាមថ្មីទៀតនោះទេ ពីព្រោះខ្លួនគ្មានមធ្យោបាយហិរញ្ញវត្ថុ និងយោធាគ្រប់គ្រាន់។

៧២៨. ក្នុងបរិបទនេះ អាទិភាព គឺការកសាងប្រទេស ដើម្បីធានាបាននូវការបង្កបង្កើនផលឡើងវិញ ដែលចាំបាច់ដល់ការរស់រានរបស់ប្រជាជន និងសេដ្ឋកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យ។ នេះគឺជាខ្លឹមសារនៃសុន្ទរកថារបស់លោក អៀង សារី ចុះខែ តុលា ឆ្នាំ ១៩៧៧ នៅចំពោះមុខមហាសន្និបាតអង្គការសហប្រជាជាតិ ដែលនិយាយសំដៅយ៉ាងច្បាស់ដល់ភាពតានតឹងជាមួយវៀតណាម៖

> "ទោះបីជាក្នុងប្រវត្តិកាលមុនរបស់ខ្លួនខ្លោចផ្សាយ៉ាងណាក៏ដោយ ក៏កម្ពុជាប្រជាធិបតេយ្យមិនចង់សើរើសំណុំរឿងចាស់ទេ។ យើងមើលឆ្ពោះតែបច្ចុប្បន្នកាល និងអនាគតកាលរបស់ខ្លួន។ យើងមិនចិញ្ចឹមចិត្តអមិត្តចំពោះនរណាឡើយ ហើយគ្មានបំណងឈ្លានពាន វាតទី និងពង្រីកទឹកដីទៅលើប្រទេសណាឡើយ សូម្បីតែមួយចំអាមក៏មិនត្រូវការផង។ ប្រទេសយើងជាប្រទេសតូច មានប្រជាជនតិច។ ឋានៈភូមិសាស្ត្រ របបនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យយើង មិនអនុញ្ញាតឱ្យយើងទៅឈ្លានពានប្រទេសដទៃជាដាច់ខាត។ ប្រទេសតូចទន់ខ្សោយមិនដែលទៅលេបប្រទេសធំទេ។ ក្នុងប្រវត្តិសាស្ត្រសកលលោក មានតែវណ្ណៈកាន់

[722] សូមមើលខាងលើនៅកថាខណ្ឌ ៦៩៨-៧០៦។

អំណាចប្រតិកិរិយានៃប្រទេសបែបអ៊ីត្លែរទេ ដែលតែងរកលេសបង្កហេតុចោទប្រកាន់ប្រទេសតូចថារំលោភវា ហើយយកលេសនេះដើម្បីឈ្លានពានគេ ពង្រីកទឹកដីវា”[723]។

៧២៩. ទោះបីជាសុន្ទរកថានេះជាអាវុធការទូតសំដៅទៅវៀតណាមដោយមិនអាចប្រកែកបានក៏ដោយ ក៏នេះមិនមែនជាទឡ្ហីករណ៍ចម្បងរបស់កម្ពុជាប្រជាធិបតេយ្យនោះទេ គឺថាទំហំតូចនៃប្រទេសរបស់ខ្លួនមិនជំរុញឱ្យវាយប្រហារប្រទេសធំ ដូចជាវៀតណាមនោះឡើយ។ នៅក្នុងសុន្ទរកថាដដែលរបស់លោក អៀង សារី ថ្លែងបន្ត ដោយអះអាងថា កម្ពុជាត្រៀមខ្លួនដើម្បីការពារ “ឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដី”[724]។ គឺគោលជំហរនេះហើយ ដែលត្រូវបានផ្សព្វផ្សាយបន្តទៅកាន់ទាហាននៃកងទ័ពបដិវត្តន៍កម្ពុជា។

៧៣០. អៀង ផាន អ្នកទទួលខុសត្រូវឃោឃា[725] បានរៀបរាប់នៅក្នុងសវនាការអំពីសម្ដីរបស់ថ្នាក់លើដែលពន្យល់ថាហេតុអ្វីបានជាកម្ពុជាគ្មានបំណងធ្វើសង្គ្រាមនៅវៀតណាម ដោយបញ្ជាក់អះអាងទៅលើសុន្ទរកថានេះ និងកំណត់ហេតុកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំ នៅពេលចាប់ផ្ដើមជម្លោះ[726] ព្រមទាំងចង្អុលបង្ហាញថា សេចក្ដីណែនាំដដែលនេះត្រូវបានផ្សព្វផ្សាយដល់ជនស៊ីវិល[727] និងទាហាន[728]។

---

[723] នៅសម័យប្រជុំលើកទី ៣២ នៃមហាសន្និបាតនៅអង្គការសហប្រជាជាតិ សម័យប្រជុំពេញអង្គលើកទី ២៨ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ **ឯកសារ E3/1586,** ERN FR 00617795. សង្កថារបស់ អៀង សារី កថាខណ្ឌ៤៥។

[724] នៅសម័យប្រជុំលើកទី ៣២ នៃមហាសន្និបាតនៅអង្គការសហប្រជាជាតិ សម័យប្រជុំពេញអង្គលើកទី ២៨ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ **ឯកសារ E3/1586,** ERN FR 00617795. សង្កថារបស់ អៀង សារី កថាខណ្ឌ៤៦។

[725] សូមមើលខាងលើនៅកថាខណ្ឌ៧៤៣។

[726] សូមមើលខាងក្រោមនៅកថាខណ្ឌ ៦៩៩-៧០២ អៀង ផាន បានបញ្ជាក់ពាក្យសម្ដីរបស់ សុន សេន ជាអាទិ៍ ៖ ពាក់ព័ន្ធនឹងភាពចាំបាច់ “កុំឱ្យក្លាយជាអ្នកបង្ករបញ្ហា” កំណត់ហេតុការប្រជុំរបស់កងពលលេខ ៩២០ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៧៦ **ឯកសារ E3/799,** ERN FR 0033917, ដែលត្រូវបានអាននៅក្នុងសវនាការ៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ៧៦ ប្រហែលម៉ោង 15.52.04. សាក្សីបានបញ្ជាក់ថា បទបញ្ជាទាំងនេះ ក៏ ចេញពីវិរែន ដែលជាកូនប្រសារ តាម៉ុកដែរ៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៧៧ ប្រហែលម៉ោង 15.54.30. នៅទីបញ្ចប់ គាត់បានបញ្ជាក់ថាបានទទួលបញ្ជាស្រដៀងគ្នា “មិនឱ្យធ្វើអ្វីដែលបង្ករបញ្ហាជាមួយប្រជាជាតិជិតខាង”ដែលមានសរសេរនៅក្នុងទស្សនាវដ្ដី យុវជនបដិវត្តន៍ ចុះខែ សីហា ឆ្នាំ ១៩៧៥ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៧៨ **ប្រហែលម៉ោង** 15.57.19. ជួន ធីបានបញ្ជាក់ថាមិនត្រូវបង្ករបញ្ហាដល់ប្រទេសជិតខាង និងមិនត្រូវទៅប្រទេសជិតខាងទេ ៖ ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1,** ទំព័រ ៧៨ ប្រហែលម៉ោង 15.39.50។

[727] អៀង ផាន: ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៧៨ មុនម៉ោង 15.58.25។

ជួន ធី មេបញ្ជាការកងវរសេនាតូច បានផ្តល់សក្ខីកម្មអំពីកិច្ចសន្ទនាជាមួយមេដឹកនាំកងទ័ពរបស់ សុន សេន អំពីកម្លាំងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យតិចជាងវៀតណាម[729]។ ក្នុងទស្សនាវដ្តី *"ទង់បដិវត្តន៍"* ចេញផ្សាយខែ កុម្ភៈ ឆ្នាំ ១៩៧៨ ជាឯកសារផ្ទៃក្នុងសម្រាប់បក្ខជន សារមិនមែនជាការធ្វើសង្គ្រាមឱ្យខានតែបាននោះទេ គឺជាការរំឮកអំពីឆន្ទៈចង់បានឯករាជ្យរបស់ប្រទេសតូច ដែលគ្មានប្រយោជន៍អ្វីត្រូវបង្ករឿងជាមួយប្រទេសធំជាងខ្លួននោះទេ[730]។

៧៣១. ការពិភាក្សាដេញដោលខុសអំពីកម្ពុជាក្រោម គឺជាឧទាហរណ៍ដ៏ល្អឥតខ្ចោះនៃធាតុផ្សំទាំងនេះ ដែលបានចូលរួមចំណែកជួយដល់ទេវកថាអំពីកម្ពុជាប្រជាធិបតេយ្យចូលចិត្តធ្វើសង្គ្រាម។ ជាក់ស្តែង អ័ក្សទំនាក់ទំនងមួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម គឺការចោទប្រកាន់ថាកម្ពុជាប្រជាធិបតេយ្យមានឆន្ទៈចង់បានទឹកដីខ្លះមកវិញ។ ប៉ុន្តែ ចាប់ពីឆ្នាំ ១៩៧៧ មក នៅក្នុងសារទូរលេខការទូតបារាំងមួយច្បាប់ មានការវិភាគថា ច្បាស់ណាស់ ប៉ុល ពត បានច្រានចោលរាល់ឆន្ទៈចង់បានទឹកដីវៀតណាមខ្លះមកវិញដែលពីមុនជារបស់ខ្មែរ ដោយបដិសេធចោលគំនិតបង្កើតសហព័ន្ធឥណ្ឌូចិនក្រោមអាណាព្យាបាលវៀតណាម[731]។

៧៣២. លោក Steve HEDER បានគាំទ្រដល់ការវិភាគនេះ និងបដិសេធសម្តីរបស់ Ben KIERNAN ត្រង់ចំណុចនេះ ដោយពន្យល់ថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានលះបង់ចោលការទាមទារយកកម្ពុជាក្រោមមកវិញយ៉ាងច្បាស់ក្រឡែត[732]។ អៀង ផាន មេបញ្ជាការកងពលតូច អះអាងថា គាត់

---

[728] អៀង ផាន : ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៧៤ ប្រហែលម៉ោង 15.44.08. សូមមើលនៅម៉ោង 15.45.39 ផង។

[729] ជួន ធី : ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ៧៥ ប្រហែលម៉ោង 15.28.28។

[730] ទស្សនាវដ្តីទង់បដិវត្តន៍ ចុះខែ កុម្ភៈ ឆ្នាំ ១៩៧៨ **ឯកសារ E3/744**, ERN FR 00538948។

[731] កំណត់សម្គាល់ដែលមានចំណងជើង "ស្ថានភាពនៅប្រទេសកម្ពុជា" "ទស្សនកិច្ចផ្លូវការរបស់ ប៉ុល ពត នៅចិន និងកូរ៉េខាងជើង" ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៧ **ឯកសារ E3/484**, ERN FR 00390964-65។

[732] អត្ថបទរបស់ Stephen HEDER មានចំណងជើងថា "ការរើសអើងពូជសាសន៍ លទ្ធិម៉ាក្សនិយម ការកំណត់ប្រភេទ និងអំពើប្រល័យពូជសាសន៍នៅក្រោមរបប ប៉ុល ពត ដែលធ្វើដោយ Ben Kiernan" **ឯកសារ E3/3995**, ERN FR 00802821-23. សូមមើល៖ ការសម្ភាសន៍ជាមួយ អៀង សារី ដោយ Steve HEDER ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ **ឯកសារ E3/89**, ERN FR 00332718 ដែលលនៅក្នុងកិច្ចសម្ភាសន៍នេះ អៀង សារី ពន្យល់ថា ទោះបីជាកាលពីអតីតកាល ភូមិភាគនិរតីមានឆន្ទៈក៏ដោយ ក៏ទាំងប៉ុល ពត ទាំង នួន ជា "គ្មាននរណាម្នាក់មានគម្រោងរំដោះកម្ពុជាក្រោមនោះដែរ"

"មិនដឹងអំពីផែនការណាមួយសំដៅយកកម្ពុជាក្រោមមកវិញនោះទេ" ហើយគាត់ក៏មិនធ្លាប់ទទួលបានសេចក្តីណែនាំណាមួយឱ្យធ្វើបែបនេះដែរ[733]។

៧៣៣. ដូច្នេះ យើងមិនអាចសន្និដ្ឋានដោយផ្អែកលើការពិនិត្យភ័ស្តុតាងថា កម្ពុជាប្រជាធិបតេយ្យមានឆន្ទៈធ្វើសង្គ្រាមឱ្យខានតែបាននោះទេ។ ពិតណាស់ថា ក្នុងពេលមានជម្លោះ កម្ពុជាប្រជាធិបតេយ្យដឹងច្បាស់ថា កម្លាំងទ័ពរបស់ខ្លួនខ្សោយជាងកម្លាំងទ័ពរបស់វៀតណាម។

## ២. ការយល់ដឹងពីវិសមភាពកម្លាំងយោធារវាងកងទ័ពទាំងពីរ

៧៣៤. សូម្បីតែពេលប្រទូសរ៉ាយគ្នាខ្លាំងក៏ដោយ ក៏សុន្ទរកថាជាច្រើនរបស់ ប៉ុល ពត និងមេដឹកនាំយោធាផ្សេងទៀត បានគូសបញ្ជាក់អំពីភាពខុសគ្នានៃកម្លាំងរវាងកងទ័ពទាំងពីរ។ ដោយសារតែមានការពិភាក្សាគ្នាយ៉ាងវែងអន្លាយនៅក្នុងសវនាការ យើងចាំបាច់ត្រូវត្រឡប់មកនិយាយអំពីសុន្ទរកថារបស់ ប៉ុល ពត ស្តីពី "១ ទល់ ៣០"[734]។

៧៣៥. សុន្ទរកថាដ៏ល្បីរបស់ ប៉ុល ពត ដែលនិយាយពីការប្រៀបធៀប "១ ទល់ ៣០" រវាងកងទ័ពទាំងពីរ គឺជាភ័ស្តុតាងដ៏ល្អអំពីការទទួលស្គាល់ថាកងទ័ពវៀតណាមមានចំនួនច្រើនជាង ទោះបីជាមានការឃោសនាថាការដកថយរបស់កងទ័ពវៀតណាមជាជ័យជម្នះរបស់កងទ័ពបដិវត្តន៍កម្ពុជា ក៏ដោយ។ សហព្រះរាជអាជ្ញាបានបង្ហាញជូន ព្រុំ សារ៉ាត់ នូវឃ្លាមួយនៃសុន្ទរកថានេះដែលថា ខ្មែរម្នាក់ត្រូវប្រយុទ្ធជាមួយវៀតណាម ៣០ នាក់[735]។

៧៣៦. ព្រុំ សារ៉ាត់ បានឆ្លើយដោយគ្មានមន្ទិលសង្ស័យថា៖

---

[733] អៀង ផាន (ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ២៧ ក្រោយម៉ោង 10.51.28 ៖ "ខ្ញុំសូមបំភ្លឺ។ ខ្ញុំមិនដឹងអំពីផែនការណាមួយដែលមានគោលបំណងដណ្តើមយកកម្ពុជាក្រោមមកវិញទេ។ ការណែនាំដែលខ្ញុំបានទទួលពីមេខ្ញុំ គឺការពារទឹកដីយើងដែលនៅមាន។ ខ្ញុំមិនដែលបានទទួលការណែនាំឱ្យដណ្តើមយកកម្ពុជាក្រោមមកវិញទេ។"

[734] សុន្ទរកថារបស់ប៉ុល ពត ក្នុងទស្សនាវដ្តីទង់បដិវត្តន៍ ចុះខែមេសា 1978 **ឯកសារ E3/4604**, ERN FR 00520342។

[735] ក្នុងទស្សនាវដ្តីទង់បដិវត្តន៍ "បទអន្តរាគមន៍របស់សមមិត្តលេខាបក្សកុម្មុយនីស្តកម្ពុជា ក្នុងឱកាសបុណ្យខួបទី៣នៃថ្ងៃ១៧ មេសាមហាជោគជ័យ មហាអស្ចារ្យ (...)" ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ **ឯកសារ E3/4604**, ERN FR 00520345។

"បើតាមអ្វីដែលលោកបានដកស្រង់ ខ្ញុំយល់ថានេះជាមាគ៌ានយោបាយ និងគោលជំហរមនោគមន៍វិជ្ជា... សំដៅជំរុញ និងលើកទឹកចិត្តទាហានឱ្យត្រៀមខ្លួនចូលសមរភូមិប្រយុទ្ធ ដែលអាចនឹងកើតមានដោយថាហេតុរវាងវៀតណាម និងកម្ពុជា។ នេះជាសេចក្តីថ្លែងការណ៍ជាក់ស្តែងរបស់ ប៉ុល ពត និងជាផែនទីបង្ហាញផ្លូវ"[736]។

"ការពិត នេះការជាការប្រៀបធៀបកម្លាំងយោធា ១ ទល់ ៣០។ ដូច្នេះ ក្នុងឯកសារនេះ គឺបញ្ជាក់ច្បាស់។ ឯកសារនេះជាសុន្ទរកថារបស់សមមិត្តលេខា។ នេះគ្រាន់តែជាសុន្ទរកថាលើកទឹកចិត្តទាហានឱ្យត្រៀមយុទ្ធសាស្ត្រ ប្រើប្រាស់យុទ្ធវិធីវាយកម្ទេចសត្រូវ"[737]។

"តាមពិត មិនមែនកងទ័ពវៀតណាមមានដល់ ៦០ លាននាក់ និងកងទ័ពខ្មែរមាន ២ លាននាក់ នោះទេ។ ប៉ុន្តែ គ្រាន់តែជាសុន្ទរកថា ដែលព្យាយាមជំរុញទាហានកម្ពុជាឱ្យត្រៀមមាគ៌ាប្រយុទ្ធដណ្តើមយកជ័យជម្នះ"[738]។

៧៣៧. ចំពោះ ព្រុំ សារ៉ាត់ ក៏ដូចជាអ្នកផ្សេងទៀតដែលមានអនាគតិ ច្បាស់ណាស់ថា នៅក្នុងសុន្ទរកថានេះ ប៉ុល ពត បាននិយាយសំដៅដល់ការប្រៀបធៀបកម្លាំងយោធា ដែលខាងកម្ពុជាប្រជាធិបតេយ្យមានចំនួនតិចជាង និងបង្ហាញអំពីយុទ្ធសាស្ត្រសង្គ្រាមឈ្លប។ ម្យ៉ាងទៀត ក្នុងផ្នែកនេះនៃសុន្ទរកថា ប៉ុល ពត ប្រើប្រាស់ពាក្យយោធា ដូចជា "ទ័ពថ្មើរជើង" "កងស្រួច" "កងពល" "កងវរសេនាតូច" "កងវរសេនាធំ" និងបញ្ជីអាវុធយុទ្ធភណ្ឌរបស់កងទ័ពបដិវត្តន៍កម្ពុជា ដើម្បីតស៊ូប្រឆាំងនឹងរថក្រោះវៀតណាម[739]។

៧៣៨. នៅពេលសួរដេញដោលនៅក្នុងសវនាការទៅលើសុន្ទរកថាដដែលនេះ ជួន ធី បានឆ្លើយថា៖

"នេះជាការប៉ាន់ប្រមាណមើល យើងឃើញថាប្រជាជនយួន និងប្រជាជនខ្មែរ មានចំនួនខុសគ្នា។ ដូច្នេះ យើងដឹងច្បាស់ថាយួនមានអាវុធច្រើនជាងខ្មែរ។ ដូច្នេះ យើងធ្វើសង្គ្រាម យើងធ្វើតាមយើងម្ចាស់ទឹកម្ចាស់ដី

---

[736] ព្រុំ សារ៉ាត់ (PRUM Sarat) : ប្រតិចារឹក ថ្ងៃទី 26.01.16 **ឯកសារ E1/382.1** ទំព័រ ៥១ **នៅម៉ោង** 15.42.17។

[737] ព្រុំ សារ៉ាត់ (PRUM Sarat) : ប្រតិចារឹក ថ្ងៃទី 26.01.16 **ឯកសារ E1/382.1** ទំព័រ ៥០ **នៅម៉ោង** 15.36.12។

[738] ព្រុំ សារ៉ាត់ (PRUM Sarat) : ប្រតិចារឹក ថ្ងៃទី 26.01.16 **ឯកសារ E1/382.1** ទំព័រ ៥០ **នៅម៉ោង** 15.39.08។

[739] ក្នុងទស្សនាវដ្តីទង់បដិវត្តន៍ "បទអន្តរាគមន៍របស់សមមិត្តលេខាបក្សកុម្មុយនីស្តកម្ពុជា ក្នុងឱកាសបុណ្យខួបទី៣នៃថ្ងៃ១៧ មេសាមហាជោគជ័យ មហាអស្ចារ្យ (...)" ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ **ឯកសារ E3/4604**, ERN FR 00520345។

សង្គ្រាមប្រជាជនគឺសង្គ្រាមឈ្លបហ្នឹង ការពារដាក់មីនដាក់អី បង្កប់ហ្នឹង។ ដូច្នេះ មិនយកមនុស្សទៅប្រើទល់នឹងមនុស្សទេ ពីព្រោះគេច្រើនជាងយើង”[740]។

៧៣៩. ដូច្នេះ គ្មានមធ្យោបាយណាមួយដើម្បីកំណត់ថាសុន្ទរកថានេះជាការញុះញង់ឱ្យវាយប្រហារទៅលើជនស៊ីវិលវៀតណាមនោះឡើយ។ នេះគ្រាន់តែជាសុន្ទរកថាប៉ុនប៉ងលើកទឹកចិត្តកងទ័ព នៅពេលបុណ្យរំឭកខួបជ័យជម្នះ ១៧ មេសា ប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត នៅពេលសួរដេញដោលទៅលើសុន្ទរកថាដដែលនេះ សាក្សី 2-TCW-859 បានឆ្លើយថា វាមិនផ្ទុះបញ្ចាំងការពិតនៅលើសមរភូមិប្រយុទ្ធនោះទេ[741]។

៧៤០. ទោះជាយ៉ាងណាក៏ដោយ តាមរយៈការគូសបញ្ជាក់អំពីភាពខុសគ្នានៃកម្លាំង និងការលាក់បាំងភាពទន់ខ្សោយរបស់កងទ័ពបដិវត្តន៍កម្ពុជា ដោយលើកឡើងអំពីយុទ្ធសាស្ត្រសង្គ្រាមឈ្លប សុន្ទរកថានេះបង្ហាញឱ្យឃើញថា ប៉ុល ពត ដឹងច្បាស់ថាមិនអាចតស៊ូប្រឆាំងនឹងវៀតណាម តែតាមផ្លូវយោធាមួយមុខបានឡើយ។

## ៣. ភាពខុសគ្នាខាងយោធា និងអវត្តមាននៃធនធានក្នុងការប្រើកម្លាំង តាមការសង្កេតរបស់សាក្សីទាំងអស់

៧៤១. សាក្សីជាយោធាទាំងអស់ ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ បានសង្កេតឃើញថា មេដឹកនាំដឹងច្បាស់ថាមិនអាចធ្វើសង្គ្រាមប្រឆាំងនឹងវៀតណាមបានឡើយ។ សាក្សីទាំងនេះបានពន្យល់ថា សេចក្តីណែនាំតែមួយគត់ គឺការពារទឹកដី ទាំងដីគោក (ក) និងដែនទឹក (ខ)។

### ក. ភាពខុសគ្នាខាងយោធា និងការការពារដែនដីគោក

---

[740] **ជួន ធី** (CHUON Thy) : ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៧១ **ប្រហែលម៉ោង** 15.17។

[741] **សាក្សី** 2-TCW-859 : ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៧៣ **ប្រហែលម៉ោង** 15.30 គាត់សន្និដ្ឋានថា៖ “ប្រាកដណាស់ បើកម្លាំងគេបុកយើងយ៉ាងសន្ធឹកសន្ធាប់ យើងនឹងចាញ់ ពីព្រោះប៉ុល ពត មានទៅច្បាំងផ្ទាល់នៅលើទីលានប្រយុទ្ធឯណា។ យោធាខ្លាចស្លាប់ដែរ។ បើយើងទប់មិនជាប់ដោយសារពួកវាបុកសន្ធាប់ពេក យើងមានតែរត់ហ្នឹងឯង។”

៧៤២. សាក្សីទាំងអស់ដែលធ្លាប់ប្រយុទ្ធនៅលើសមរភូមិ បានគូសបញ្ជាក់អំពីភាពខុសគ្នានៃកម្លាំងយោធា។ សាក្សី 2-TCW-859 ដែលត្រូវបានចាត់តាំងទៅភូមិភាគបូព៌ា ក្នុងកងពលមួយក្រោមបញ្ជារបស់សេនាធិការ បាននិយាយយ៉ាងច្បាស់ថា "សម័យនោះ ក្រៅពីកងទ័ពវៀតណាមមានអាវុធច្រើន"[742] ភាពខុសគ្នាខាងកម្លាំងជាបញ្ហាគ្រប់ពេលវេលាទាំងអស់ ដែលតម្រូវឱ្យមានការពង្រាយកម្លាំងដើម្បីកាត់បន្ថយការខូចខាត[743]។

៧៤៣. អៀង ផាន ដែលបានចូលបម្រើកងទ័ពនៅភូមិភាគនិរតី ក្នុងឆ្នាំ ១៩៧០ ជាប្រធានកងវរសេនាតូចនៃកងពលធំលេខ ២ នៅថ្ងៃរំដោះទីក្រុងភ្នំពេញ[744]។ សាក្សីរូបនេះ ដែលកាលនោះ ជាមេបញ្ជាការកងវរសេនាធំលេខ ១២[745] បានបញ្ជាក់ថា គ្រប់កងវរសេនាធំទាំងអស់នៃកងពលតូចលេខ ២ ស្ថិតក្រោមការទទួលខុសត្រូវរបស់ សំ ប៊ិត មេបញ្ជាការកងពលធំ[746] ត្រូវបានដាក់ពង្រាយឱ្យឈរជើងនៅតាមព្រំដែន "ក្នុងឆ្នាំ ១៩៧៦ ឬឆ្នាំ ១៩៧៧" ហើយការប្រយុទ្ធគ្នាលើកដំបូងបានកើតឡើង នៅ "ដើមឆ្នាំ ១៩៧៧"[747]។ នៅចុងឆ្នាំ ១៩៧៦ កងពលធំលេខ ២ បានក្លាយជាកងពលតូច ២១០[748]។ សាក្សីរូបនេះនៅតាកែវ រហូតដល់ពាក់កណ្ដាលឆ្នាំ ១៩៧៨ ហើយពេលនោះ គាត់ត្រូវបានតែងតាំងជា "មេបញ្ជាការកងពលតូច" ដើម្បីទៅស្វាយរៀង និងត្រូវរបួស នៅចុងឆ្នាំ ១៩៧៨[749]។ គាត់បានរៀបរាប់អំពីកិច្ចប្រជុំរវាងមេបញ្ជាការកងពលតូច និងមេបញ្ជាការកងពលធំ រៀងរាល់ ៣ ថ្ងៃម្ដង ដើម្បីពិភាក្សាគ្នាអំពីតែ "ផែនការវាយប្រហារផ្សេងៗ និងស្ថានភាពគ្រាប់រំសេវ" ប៉ុណ្ណោះ "គឺគ្មាន

[742] សាក្សី 2-TCW-1005 : ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/449.1** ទំព័រ៦៨ មុនម៉ោង 14.36.43។

[743] សាក្សី 2-TCW-1005 : ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/449.1** ទំព័រ ៦០ នៅម៉ោង 14.15.50។

[744] សាក្សីអៀង ផាន ៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៦ ប្រហែលម៉ោង 09.26.40 និងម៉ោង 09.29.21។

[745] អៀង ផាន៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ១១ ប្រហែលម៉ោង 09.44.30។

[746] អៀង ផាន៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ២៨ មុនម៉ោង 10.54.33។

[747] អៀង ផាន៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ១២ ក្រោយម៉ោង 09.45។

[748] អៀង ផាន៖ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ១២ ក្រោយម៉ោង 09.47។

[749] អៀង ផាន៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ១៧ ក្រោយម៉ោង 10.06 ; ទំព័រ ៥៥ ប្រហែលម៉ោង 14.13.25។

ពេលនិយាយអំពីនយោបាយទេ" ពីព្រោះ "វៀតណាមនៅគ្រប់ទីកន្លែងទាំងអស់"[750]។ គាត់ក៏បានចូលរួមប្រជុំជាទៀងទាត់ជាមួយតាម៉ុក[751]។

៧៤៤. ក្នុងឋានៈជាអ្នកទទួលខុសត្រូវ "ទាហានប្រមាណពី ១៨០០ ទៅ ២០០០ នាក់" នៅក្នុងកងពលតូច ២១០ ដោយមាន សុខ ឈឿន និង ជាង ជាអនុមេបញ្ជាការ[752] មុខតំណែងរបស់ អៀង ផាន អាចឱ្យគាត់តាមដានអំពីការវិវត្តនៃការប៉ះទង្គិចគ្នា នៅតាមព្រំដែន ក្នុងរយៈពេលយូរ និងដឹងច្បាស់អំពីកម្លាំងទ័ពរបស់ប្រទេសទាំងពីរ។ អៀង ផាន បាននិយាយអំពីកម្លាំងសំខាន់ជាងរបស់វៀតណាម ដោយមានចំនួនទាហាន និងយុទ្ធសាស្ត្រច្រើនជាងដាច់។ ក្រោយពីធ្វើការសង្កេតនេះ គាត់បានគូសបញ្ជាក់ថា គោលបំណងគឺគ្រាន់តែទប់កុំឱ្យវៀតណាមរុលចូលប៉ុណ្ណោះ ដើម្បីការពារទឹកដី[753]។

៧៤៥. នៅពេលនិយាយអំពីការជីកលេណដ្ឋាន អៀង ផាន ក៏បានរៀបរាប់ផងដែរថា មានលេណដ្ឋានទាំងសងខាង ទាំងខាងវៀតណាម គេធ្វើពីបេតុង ឯខាងកម្ពុជា គេធ្វើពីឈើប៉ុណ្ណោះ[754]។ គាត់ក៏បាន

---

[750] អៀង ផាន៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៣៣ មុនម៉ោង 11.44.26 គាត់បានលើកឡើងផងដែរថា គាត់បានចូលរួមក្នុងកិច្ចប្រជុំនៅមន្ទីរចល័តរបស់ សុន សេន នៅក្រោលគោទាក់ទងនឹងការវាយប្រហាររបស់វៀតណាមនៅភូមិ ចាក៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៣៣ ក្រោយម៉ោង 11.12.30 ; ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៣៣ មុនម៉ោង 11.36.23។

[751] អៀង ផាន៖ ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ២៦ ប្រហែលម៉ោង 10.38.45។

[752] អៀង ផាន៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ១៣ មុនម៉ោង 09.51 ; ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៣១ ក្រោយម៉ោង 11.06។

[753] អៀង ផាន៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ១៣ ក្រោយម៉ោង 09.52.05 ទំព័រ ១៨-១៩ ប្រហែលម៉ោង 10.14.40 ទំព័រ ២៨ ក្រោយម៉ោង 10.55 ; ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៣៦ ប្រហែលម៉ោង 11.13.60។

[754] អៀង ផាន៖ ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ២៩ ប្រហែលម៉ោង 10.49.30. គួរកត់សម្គាល់ថាចំពោះលេណដ្ឋានទាំងអស់នេះនៅក្នុងរបាយការណ៍របស់កងទ័ពបដិវត្តន៍កម្ពុជា មានសរសេរថាប្រើប្រាស់គ្រាក់ទ័រ៖ កំណត់ហេតុប្រជុំនៃភូមិភាគនិរតី ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៧៧ **ឯកសារ E3/853**, ERN FR 00290267។

កត់សម្គាល់ឃើញថា វៀតណាមមានអាវុធយុទ្ធភណ្ឌល្អជាង[755]។ អាស្រ័យហេតុនេះ ទាហាននៃកងទ័ពបដិវត្តន៍កម្ពុជាមិនអាចចូលជ្រៅទៅក្នុងទឹកដីវៀតណាមបានឡើយ[756]។

៧៤៦. ជួន ធី បានឆ្លើយស្រដៀងគ្នានេះ នៅក្នុងសវនាការ។ ជាកូនទាហានដែលត្រូវបានដំឡើងឋានៈជាមេបញ្ជាការកងវរសេនាតូច នៃកងវរសេនាធំលេខ ១៥[757] នៅថ្ងៃរំដោះទីក្រុងភ្នំពេញ គាត់ត្រូវបានចាត់តាំងឱ្យទៅព្រំដែននៅស្វាយរៀង ក្នុងខែ មិថុនា ឆ្នាំ ១៩៧៨[758] ហើយនៅទីនោះ រហូតដល់ពេលវៀតណាមចូលលុកលុយ[759]។ ដូច អៀង ផាន ដែលគាត់ស្គាល់តែឈ្មោះដែរ[760] ពេលទៅដល់គាត់ត្រូវបានចាត់ឱ្យនៅក្រោមបញ្ជារបស់ រ៉ែន[761]។ សាក្សីរូបនេះបានបញ្ជាក់ថា ប៉ុល ពត បញ្ជូនគាត់ទៅព្រំដែន ដើម្បី "ដឹកនាំទាហានការពារភូមិភាគ"[762]។ ជួន ធី ឆ្លើយថាបានចូលរួមប្រជុំនៅខែ មិថុនា ឆ្នាំ ១៩៧៨ នៅកំពង់ឆ្នាំង ស្ដីពីការការពារកម្ពុជា និងការកសាងប្រទេស[763]។ ជាអាទិ៍ គាត់បានឆ្លើយថា គ្មានគោលនយោបាយវាយប្រហារវៀតណាមនោះទេ គឺពួកគេគ្រាន់តែទប់ទល់នឹងកម្លាំងវៀតណាម ដែលមានចំនួនច្រើនជាងប៉ុណ្ណោះ[764]។

៧៤៧. ជួន ធី ក៏បានបញ្ជាក់អះអាងនូវចម្លើយរបស់ អៀង ផាន ដែលថា ពួកគេត្រូវវាយដោយមានកម្លាំងតិចតួច និងត្រូវដកថយ ប្រសិនបើចាំបាច់" ហើយ "មេបញ្ជាការនៅតាមកំណាត់ព្រំដែននីមួយៗ" ស្នើសុំកម្លាំងជំនួយ នៅពេលត្រូវការ[765]។

---

[755] អៀង ផាន៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ១៦ ប្រហែលម៉ោង 10.03.25។

[756] អៀង ផាន៖ ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៣៦ ក្រោយម៉ោង 11.15.30, គាត់ឆ្លើយតបទៅនឹងអត្ថបទកាសែតមួយដែលអានដោយព្រះរាជអជ្ញា សូមមើលនូវ ៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ២០-២១ ប្រហែលម៉ោង 10.17.16។

[757] ជួន ធីៈ ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ១៧ ប្រហែលម៉ោង 09.53.46។

[758] ជួន ធី : ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៥៦ ប្រហែលម៉ោង 14.02.17។

[759] ជួន ធីៈ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៦៥ ប្រហែលម៉ោង 14.31.58។

[760] ជួន ធីៈ ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ២០ រវាង 10.02.33 និង 10.04.35។

[761] ជួន ធី : ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៦១ ប្រហែលម៉ោង 14.18.13។

[762] ជួន ធី : ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1**, ទំព័រ ៥៧ ប្រហែលម៉ោង 14.06.36។

[763] ជួន ធី : ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ៥៥ ប្រហែលម៉ោង 14.05.13។

[764] ជួន ធី : ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦, **E1/490.1** ទំព័រ ៦៥ ប្រហែលម៉ោង 15.49.06។

[765] ជួន ធី : ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៦៧ មុនម៉ោង 14.39.51។

៧៥៨. សាក្សី 2-TCW-823 មេបញ្ជាការកងវរសេនាតូច នៃកងពលធំ ១៦៤ នៃកងទ័ពជើងទឹក បាន បញ្ជាក់អះអាងនូវសក្ខីកម្មរបស់សាក្សីផ្សេងទៀត នៅក្នុងសវនាការ អំពីភាពខុសគ្នានៃកម្លាំង និង គោលដៅតែមួយគត់ក្នុងការការពារប្រទេស[766]។ ឆ្លើយតបទៅនឹងសេចក្ដីណែនាំរបស់ថ្នាក់លើ ដូច ការរៀបរាប់របស់ អៀង ផាន សាក្សី 2-TCW-823 បានអះអាងថា វាអាស្រ័យ "ទៅតាមការ យល់ឃើញផ្ទាល់ខ្លួន"[767]។ គាត់ក៏បានឆ្លើយផងដែរថា សេចក្ដីណែនាំទាំងនេះស្របតាម "សេចក្ដី ណែនាំរបស់ ប៉ុល ពត ទៅឱ្យគ្រប់គ្នា នៅទូទាំងប្រទេស" ដោយបានបញ្ជាក់ទៅលើសំណួររបស់ ចៅក្រម Claudia FENZ ថា សេចក្ដីណែនាំទាំងនេះត្រូវបានផ្សព្វផ្សាយ តាមរយៈឯកសារជា លាយលក្ខណ៍អក្សរ ក្នុងវគ្គរៀនសូត្រ[768]។

៧៥៩. ដូច្នេះ កម្ពុជាប្រជាធិបតេយ្យចាញ់ប្រៀបខាងកម្លាំង។ ជាក់ស្ដែង នៅពេលភាពតានតឹងកើនឡើង ខ្លាំងនៅឆ្នាំ ១៩៧៧ មានតែវៀតណាមប៉ុណ្ណោះដែលអាចប្រើប្រាស់កម្លាំងទ័ពអាកាស[769] និងអាវុធ ធុនធ្ងន់[770]។ ម្យ៉ាងវិញទៀត ជួន ធី បានពន្យល់ថា "អង្គភាព" របស់គាត់គ្មាន "អាវុធប្រឆាំងនឹង យន្តហោះ" ដែលអាចការពារខ្លួនពី "ការទម្លាក់គ្រាប់បែក" បានទេ[771]។

---

[766] សាក្សី 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ១៣ ប្រហែលម៉ោង 09.53.54 ទំព័រ ១៨, នៅម៉ោង 10.05.25។

[767] សាក្សី 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ២០ ប្រហែលម៉ោង 10.11.50។

[768] សាក្សី 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ២០-២១ ប្រហែលម៉ោង 10.12.55 និង 10.14.35. សាក្សី 2-TCW-823 ក៏បានបញ្ជាក់ផងដែរថាខ្លួនបានទទួលការណែនាំទាំងនេះពី មាស មុត៖ សាក្សី 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ២១ នៅម៉ោង 10.15.52។

[769] *Refugee's site major SRV Cambodian clashes and reprisals* ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៧៧ (FBIS) **ឯកសារ E3/143**, ERN EN 00168726។

[770] សាក្សី 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៥៨ ប្រហែលម៉ោង 14.28.41 ; ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ៣៦ ប្រហែលម៉ោង 11.22.36 ; សាក្សី 2-TCW-1005: ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/449.1** ទំព័រ ៦៣ នៅម៉ោង 14.24.50. សូមមើល៖ អៀង ផាន៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៤៧ ប្រហែលម៉ោង 13.47.10។

[771] ជួន ធី : ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ២៩ ប្រហែលម៉ោង 10.51.55។

៧៥០. លោក Stephen MORRIS បានអះអាងក្នុងសវនាការអំពីការប្រៀបធៀបជាតួលេខនៃកម្លាំងទ័ពរបស់ប្រទេសទាំងពីរ ដែលមានសរសេរនៅក្នុងសៀវភៅរបស់គាត់៖ ទាហាន ៧០.០០០ នាក់ របស់កម្ពុជាប្រជាធិបតេយ្យ ទល់នឹងទាហាន ៦១៥.០០០ នាក់ របស់សាធារណរដ្ឋសង្គមនិយមវៀតណាម[772]។ លោកបានបន្ថែមទៀតថា ក្រៅពីភាពខុសគ្នាខាងតួលេខនេះ គេត្រូវគិតគូរដល់ភាពខុសគ្នាខាងសព្វាវុធ បទពិសោធន៍ និងការបញ្ជាផងដែរ[773]។ ក្នុងល័ក្ខខ័ណ្ឌនេះ កម្ពុជាចាំបាច់ត្រូវបញ្ជូនកម្លាំងជំនួយទៅសមរភូមិបូព៌ា ក្នុងឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ ដូចមានរៀបរាប់ក្នុងសារទូរលេខ ចុះខែ មេសា ឆ្នាំ ១៩៧៨ របស់ កែ ពក ដែលបានរាយការណ៍អំពីការមកដល់នៃកងទ័ពភូមិភាគ
កណ្តាល[774]។

៧៥១. ជួន ធី បានពន្យល់ថា គាត់បានទទួលបញ្ជាឱ្យវាយប្រហារ តែក្នុងករណីវៀតណាមចូលមកក្នុងទឹកដីកម្ពុជាប៉ុណ្ណោះ[775]។ នៅពេលវៀតណាមវាយប្រហារតាមទីតាំងនៃកងវរសេនាតូចរបស់គាត់ ការប្រយុទ្ធគ្នាបានចាប់ផ្តើម "ពីរ ឬបីថ្ងៃ ក្រោយមក"[776]។

## ខ. ការការពារដែនទឹក

[772] សៀវភៅរបស់ Stephen MORRIS ដែលមានចំណងជើងថា "ហេតុអ្វីបានជាវៀតណាមឈ្លានពានកម្ពុជា" 1999 **ឯកសារ E3/7338** ទំព័រ ១០៣ ERN EN 01001770។

[773] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៦៥ ប្រហែលម៉ោង 14.22។

[774] សារទូរលេខរបស់ កែ ពក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៨ **ឯកសារ E3/1065.** សារទូរលេខនេះនិយាយផ្ទុយពីចម្លើយរបស់សាក្សី 2-TCW-1065 ដែលថាកងទ័ពរបស់ភូមិភាគកណ្តាលបានមកវាយប្រហារកងទ័ពនៃភូមិភាគបូព៌ា៖ សាក្សី 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៧២ ប្រហែលម៉ោង 15.35.56. កងទ័ពភូមិភាគកណ្តាលពិតជាមកមែនដើម្បីជួយនៅសមរភូមិ។ គឺក្រោយមកហើយទេ ដែលបញ្ហាផ្ទៃក្នុងលេចឡើង។ ទាក់ទងនឹងប្រធានបទនេះ សូមមើល៖ ឈុន សាម៉ន៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/445.1** ទំព័រ ១៦ មុនម៉ោង 09.52។

[775] ជួន ធី : ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៦៧ នៅម៉ោង 14.39.30។

[776] ជួន ធី : ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៦៥ ប្រហែលម៉ោង 14.33.56 ; ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ២១ ប្រហែលម៉ោង 10.08.13 ទំព័រ ២៥-២៦ ប្រហែលម៉ោង 10.37.55។

៧៥២. ក្នុងក្របខ័ណ្ឌនៃការទទួលយកភស្តុតាងយ៉ាងច្រើនសន្ធឹកសន្ធាប់ មកពីការស៊ើបអង្កេតនៃសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ អង្គជំនុំជម្រះបានឯកភាពនឹងសំណើសុំកោះហៅសាក្សីជាច្រើនរបស់សហព្រះរាជអាជ្ញា[777]។ ក្នុងចំណោមនោះ មានសាក្សី 2-TCW-1000 ផងដែរ។ គួរកត់សម្គាល់ជាមុនថា សាក្សីនេះបានលើកឡើងជាសំខាន់អំពីការប្រព្រឹត្តិចំពោះជនជាតិវៀតណាមលើផ្ទៃសមុទ្រ ជាប្រធានបទមិនមាននៅក្នុងផ្នែកអង្គហេតុ ឬអង្គច្បាប់ នៃដីកាដំណោះស្រាយ។ នៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានផ្តល់សំអាងហេតុ ដែលបង្កភាពស្រឡាំងកាំងដល់ក្រុមមេធាវីការពារក្តី[778]។

៧៥៣. ជាក់ស្តែង ទោះបីជាបានរំឭកថា "ឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិវៀតណាមដែលបានចោទប្រកាន់លើជនជាប់ចោទ នៅក្នុងសំណុំរឿង ០០២/០២ ផ្តោតយ៉ាងទូលំទូលាយលើឧក្រិដ្ឋកម្មជាក់លាក់ ដែលទំនងជាត្រូវបានប្រព្រឹត្តនៅខេត្តស្វាយរៀង និងខេត្តព្រៃវែង"[779] ក៏ដោយ ក៏អង្គជំនុំជម្រះបានអះអាងថា ការប្រព្រឹត្តិចំពោះជនជាតិវៀណាមដែលចាប់បានលើផ្ទៃសមុទ្រ គឺជាផ្នែកមួយនៃ "អង្គហេតុ" ក្នុងដីកាដំណោះស្រាយ" ដោយយោងទៅលើកំណត់សម្គាល់ចុងឯកសារលេខ ៣៤៨៧ តែមួយគត់ នៃកថាខណ្ឌ ៨១៦ នៃដីកាដំណោះស្រាយ ដែលផ្អែកលើសារទូរលេខមួយរបស់ មាស មុត[780]។

៧៥៤. ដូច្នេះ ទោះបីជាមាននិទ្ទេសតិចតួចបំផុតនេះនៅក្នុងឯកសារមួយ នៅកំណត់សម្គាល់ចុងឯកសារនៃដីកាដំណោះស្រាយ និងទោះបីជាគ្មានបទចោទអំពីការចាប់ជនជាតិវៀតណាមលើផ្ទៃសមុទ្រ[781] ក៏ដោយ ក៏អង្គជំនុំជម្រះចង់កោះហៅសាក្សី 2-TCW-1000 ដែលបណ្តាលឱ្យមានស្នើសុំឱ្យទទួល

[777] សំណើរបស់ព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ **ឯកសារ E319/36** ; ការបញ្ចុះបញ្ចូលរបស់ព្រះរាជអាជ្ញាឱ្យកោះហៅសាក្សី ប៉ាក សុខៈ ប្រតិចារឹក ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/360.1** ទំព័រ ៦-៧ រវាង 09.37.14 និង 09.40.49 ; សេចក្តីសម្រេចវិជ្ជមានរបស់អង្គជំនុំជម្រះ៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/363.1** ទំព័រ ៤១-៤២ រវាង 13.35.13 និង 13.40.17។

[778] សេចក្តីសម្រេច ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E380/2**។

[779] សេចក្តីសម្រេច ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E380/2** កថាខណ្ឌ ៨។

[780] សេចក្តីសម្រេច ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E380/2** កថាខណ្ឌ ២១។

[781] ពត៌មានស្តីអំពីការចោទប្រកាន់មិនមាននៅក្នុងធាតុផ្សំភស្តុតាងគាំទ្រដីកាចោទប្រកាន់។ សូមមើលខាងលើនូវកថាខណ្ឌ ៧៨-៨៦។

យកភ័ស្តុតាងថ្មីពីសំណាក់ក្រុមមេធាវីការពារក្តីទាំងពីរក្រុម[782] ដោយមិនគិតពីសំណើបន្ថែមរបស់សហព្រះរាជអាជ្ញា[783]។ អង្គជំនុំជម្រះបានបង្កើតហេតុការណ៍អាក្រក់ និងបានពង្រីកវិសាលភាពនៃការជំនុំជម្រះក្តីទៅដល់អង្គហេតុពាក់ព័ន្ធនឹងការចាប់ជនជាតិវៀតណាមលើផ្ទៃសមុទ្រ ដោយកងពល ១៦៤ ដែលមិនមែនជាកម្មវត្ថុនៃការស៊ើបអង្កេតក្នុងក្របខ័ណ្ឌនៃកិច្ចស៊ើបសួរលើសំណុំរឿង ០០២។

៧៥៥. ក្នុងការជំនុំជម្រះក្តីដែលមានឆន្ទៈដំណើរការទៅមុខឱ្យលឿន (ដើម្បីផ្តន្ទាទោសឱ្យបានឆាប់) គួរកត់សម្គាល់ថា ការចង់កាត់ក្តីឱ្យឆាប់ចប់លែងជាការព្រួយបារម្ភទៀតហើយ នៅចំពោះមុខលទ្ធភាពជាយថាហេតុក្នុងការទទួលបានភ័ស្តុតាងដាក់បន្ទុកបន្ថែម។ ជាអកុសល ដូចករណីក្នុងពេលជំនុំជម្រះក្តីរហូតមក នេះជាអ្វីតែមួយគត់ដែលអង្គជំនុំជម្រះចង់បានពីសាក្សី 2-TCW-1000។

៧៥៦. ទោះជាយ៉ាងនេះក្តី អង្គហេតុពាក់ព័ន្ធនឹងជោគវាសនារបស់ជនជាតិវៀតណាមលើផ្ទៃសមុទ្រ មិនត្រូវបានយកមកវិភាគនោះទេ ពីព្រោះអង្គហេតុនេះនៅក្រៅវិសាលភាព។ មានតែសក្ខីកម្មរបស់សាក្សី 2-TCW-1000 ស្តីពីការទទួលបញ្ជាយោធា ប៉ុណ្ណោះ ដែលមានភាពពាក់ព័ន្ធសម្រាប់បរិបទជម្លោះប្រដាប់អាវុធ។ ផ្ទុយទៅវិញ ចម្លើយរបស់គាត់ក្នុងប្រធានបទនេះ (១) ផ្ទុយទាំងស្រុងទៅនឹងភ័ស្តុតាងផ្សេងទៀតពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិវៀតណាមដោយកងទ័ព ក្នុងពេលប្រយុទ្ធ (២)។

### 1. <u>**សក្ខីកម្មខុសគេរបស់សាក្សី** 2-TCW-1000 **ស្តីពីបញ្ជាយោធាឱ្យធ្វើបាបជនស៊ីវិលវៀតណាម**</u>

៧៥៧. យើងចាំបាច់ត្រូវពិនិត្យមើលសក្ខីកម្មរបស់សាក្សី 2-TCW-1000 នៅក្នុងបរិបទ ដោយរំឭកថា នៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា គាត់គ្មានឋានន្តរស័ក្តិអ្វីទេ ប៉ុន្តែ គាត់មានតួនាទីការពារទឹកដី (ក)។ម្យ៉ាងវិញទៀត គាត់មិនអាចស្មានបានថាតើបញ្ជាដែលទទួលបានពីមេបញ្ជាការកងវរសេនាតូចរបស់គាត់មានប្រភពមកពីណាឡើយ (ខ)។

---

[782] សំណើរបស់ នួន ជា ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E380** ; សំណើរបស់ ខៀវ សំផន ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E319/23/2**។

[783] សំណើរបស់ព្រះរាជអជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E382**។

## 1.ក. មុខងារជាកូនទាហានឈរជើងការពារដែនទឹកកម្ពុជា

៧៥៨. សាក្សី 2-TCW-1000 បានអះអាងនៅពេលបង្ហាញខ្លួនថា គាត់បានចូលបម្រើកងទ័ពនៅឆ្នាំ ១៩៧២ ក្នុងខេត្តកំពត រួចចូលក្នុងកងពលធំ ១៦៤ នៃកងទ័ពមជ្ឈិម នៅកំពង់សោម[784] នៅឆ្នាំ ១៩៧៦ ក្រោមបង្គាប់របស់ មាស មុត[785]។ អ្នកទទួលខុសត្រូវយោធាផ្សេងទៀត រួមមាន តាសារឿន តាញ៉ាន់ និងតាឌីម[786]។ គាត់ត្រូវបានចាត់តាំងឱ្យទៅកោះតាង នៅឆ្នាំ ១៩៧៥ ក្នុងកងវរសេនាធំលេខ ៦២ និងទៅកោះពូលូវ៉ៃនៅឆ្នាំ ១៩៧៦។ គាត់ទំនងជាស័ក្តិសមជាងគេក្នុងការដឹងឮអំពីការវាយយកកោះដោយកងទ័ពវៀតណាម[787] និងឧប្បត្តិហេតុនាវា *ម៉ាយ៉ាហ្គេស* ដែលជាការប្រយុទ្ធតទល់គ្នារវាងកងទ័ពកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពអាមេរិក[788]។ បន្ទាប់មកទៀត គាត់ឆ្លើយថាបានចូលកងទ័ពជើងទឹកនៃកងពល ១៦៤ ចំណុះឱ្យកងទ័ពមជ្ឈិម[789] និងបានផ្ទេរទៅកំពង់ផែអូរឈើទាល នៅឆ្នាំ ១៩៧៧[790]។

---

[784] ប៉ាក សុខ៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/369.1** ទំព័រ ១៩ ប្រហែលម៉ោង 09.48.30។

[785] ប៉ាក សុខ៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/369.1** ទំព័រ ១៤ ប្រហែលម៉ោង 09.46 et ទំព័រ ១៤ ចន្លោះ 09.46 និង 09.48។

[786] ប៉ាក សុខ៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/369.1** ទំព័រ ១៣ ប្រហែលម៉ោង 09.46.30។

[787] ប៉ាក សុខ៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ៣០ ប្រហែលម៉ោង 11.05.00 "ស៖ ចុះលោកដឹងទេថាតើពេលណាវៀតណាមបានដណ្ដើមយកកោះ ពូលូវ៉ៃ ជាថ្មីម្ដងទៀត? ច៖ គឺនៅឆ្នាំ ១៩៧៥ ប៉ុន្តែខ្ញុំមិនបានចាំថាថ្ងៃខែទេ។ កងវរសេនាតូចរបស់ខ្ញុំឈរជើងនៅទីនោះ វៀតណាមវ៉ៃយើង វៀតណាមដណ្ដើមយកកោះនេះនៅឆ្នាំ ១៩៧៥ ខ្ញុំនិយាយសំដៅទៅលើកោះ ពូលូវ៉ៃ។ ទាហានមួយចំនួននៅក្នុងកងវរសេនាតូចត្រូវបានកងទ័ពវៀតណាមចាប់បាន និងបញ្ជូនទៅកោះត្រល់ [...] នៅពេលនោះខ្ញុំដេកពេទ្យនៅកោះតាង ហើយខ្ញុំលឺសួរ គេនិយាយថាកងទ័ពវៀតណាមវ៉ៃបានកោះនេះនៅចុងឆ្នាំ១៩៧៥។ យោធាជាច្រើននៅក្នុងអង្គភាពខ្ញុំបានបាត់បង់ជីវិត ហើយមានប្រហែល ៣០០នាក់ត្រូវបានវៀតណាមចាប់បាន។ ស៖ ក៏ប៉ុន្តែលោកបាននិយាយថាវៀតណាមវ៉ៃដណ្ដើមបានកោះ ពូលូវ៉ៃតាំងពីឆ្នាំ ៧៥ តើត្រឹមត្រូវដែររឺទេ? ច៖ បាទ! ត្រឹមត្រូវ[...] ក្រោយមកកោះនេះត្រូវបានឱ្យមកកម្ពុជាវិញ។ ហើយអង្គភាពខ្ញុំមានមុខសញ្ញានៅលើកោះនេះ កោះ ពូលូវ៉ៃ។ ដូច្នេះ គេបញ្ជូនយើងពីកោះតាង ទៅកោះពូលូវ៉ៃក្រោយពេលដែលកងទ័ពវៀតណាមដកចេញពីកោះនេះ។ (យើងជាអ្នកគូសបន្ទាត់ពីក្រោម)

[788] ប៉ាក សុខ៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ១០ មុនម៉ោង 09.37.30, ទំព័រ ១៤, ប្រហែលម៉ោង 09.51.10 ទំព័រ ២៣ ចាប់ពីម៉ោង 10.41។

[789] ប៉ាក សុខ៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/369.1** ទំព័រ ១៣ ប្រហែលម៉ោង 09.48.30។

[790] ប៉ាក សុខ៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/369.1** ទំព័រ ១៦ ក្រោយម៉ោង 09.57.30។

៧៥៩. សាក្សីរូបនេះបានរៀបរាប់អំពីតួនាទីនៃកងវរសេនាតូចរបស់គាត់ ដូចតទៅនេះ៖ “យើងមានមុខងារធានាសន្តិសុខដែនទឹក នៅកោះពូលូវៃចាស់ កោះពូលូវៃថ្មី និងកោះតាង។ ដូច្នេះ យើងមានភារកិច្ចយាមនៅក្នុងតំបន់នេះ ហើយយើងចាប់អ្នកណាដែលរំលោភចូលដែនទឹករបស់យើង”[791]។ សក្ខីកម្មនេះបញ្ជាក់យ៉ាងច្បាស់ថា កងទ័ពកម្ពុជាប្រជាធិបតេយ្យមានមុខងារជាសារវន្តការពារទឹកដី[792]។

៧៦០. សាក្សី 2-TCW-1000 បានបញ្ជាក់ថា គាត់គ្រាន់តែជាយុទ្ធជនសាមញ្ញ ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[793] ហើយគាត់ដឹង “តែអ្វីដែលកើតឡើងនៅក្នុងអង្គភាពរបស់គាត់ប៉ុណ្ណោះ”[794] គាត់ “មិនដឹងអំពីគោលនយោបាយរបស់ខ្មែរក្រហមទេ”[795] និង “មិនធ្លាប់ចូលរួមវគ្គរៀនសូត្រនៅថ្នាក់ខ្ពស់ជាងកងវរសេនាតូចទេ”[796]។ ពេលឆ្លើយទៅនឹងសំណួររបស់ក្រុមមេធាវីការពារក្តី គាត់បានអះអាងថា៖

> “សៈ តើលោកធ្លាប់ចូលរួមប្រជុំ ដែលដឹកនាំដោយថ្នាក់កងវរសេនាធំទេ ទាក់ទងទៅនឹងបញ្ហាដែលយើងនិយាយគ្នានេះ? ឆៈ ទេ ខ្ញុំអត់ដែលទេ អត់ដែលបានចូលរួមប្រជុំជាមួយកងវរសេនាធំទេ គ្រាន់តែបានចូលរួមប្រជុំជាមួយកងវរសេនាតូច។ សៈ ចុះទាក់ទងនឹងការប្រជុំកងពល លោកធ្លាប់ចូលរួមប្រជុំកងពលដែរទេ ទាក់ទងនឹងបញ្ហាដែលយើងកំពុងជជែកគ្នាហ្នឹង? ឆៈ <u>ក្នុងឋានៈជាយុទ្ធជន ខ្ញុំមិនធ្លាប់ចូលរួមប្រជុំនៅកងពលទេ។ សូម្បីតែថ្នាក់កងវរសេនាធំហ្នឹង ក៏មិនបានចូលរួមប្រជុំផង</u>” (យើងខ្ញុំជាអ្នកគូសបន្ទាត់ខាងក្រោម)[797]។

៧៦១. សាក្សីរូបនេះបានលើកឡើងអំពីឋានានុក្រមយោធា និងរបៀបដែលគាត់ទទួលបញ្ជាជាទូទៅ ដោយបានបញ្ជាក់ថា “កងវរសេនាតូចមិនអាចបំពេញមុខងារដោយឯករាជ្យបានទេ” ហើយនៅពេលគាត់

---

[791] <u>ប៉ាក សុខ៖</u> ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ៣៨ នៅម៉ោង 11.30.30។

[792] សូមមើលខាងលើនៅ កថាខណ្ឌ ៧៤២-៧៥១។

[793] <u>2-TCW-1000</u> ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ៨ ក្រោយម៉ោង 09.25។

[794] <u>ប៉ាក សុខ៖</u> ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ២៤ ក្រោយម៉ោង 10.44.13។

[795] <u>ប៉ាក សុខ៖</u> ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/369.1** ទំព័រ ១៥ ក្រោយម៉ោង 09.52.25។

[796] <u>ប៉ាក សុខ៖</u> ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ៥០ ចន្លោះម៉ោង 14.07.06 និង 14.08.39។

[797] <u>ប៉ាក សុខ៖</u> ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ៥០ ចន្លោះម៉ោង 14.07.06 និង 14.08.39។

ទទួលបញ្ជាពីកងវរសេនាតូច "កងវរសេនាតូចប្រហែលជាទទួលបញ្ជាពីកងវរសេនាធំ"[798]។ ដូច្នេះ គាត់សន្និដ្ឋានថា បញ្ជាឱ្យចាប់នាវា *ម៉ាយ៉ាហ្គេស* ក្នុងឆ្នាំ ១៩៧៥ "ត្រូវតែចេញមកពីកងពល"[799]។ ប្រឈមមុខនឹងការទាមទារឱ្យបញ្ជាក់ពីសំណាក់ក្រុមមេធាវីការពារក្តីលោក នួន ជា គាត់បានឆ្លើយថា៖ "ខ្ញុំអាចទាញសេចក្តីសន្និដ្ឋានជាសត្យានុម័តិថាត្រូវតែមានបញ្ជាពីកងពល ពីព្រោះ បើមិនអ៊ីចឹងទេ យើងមិនអាចធ្វើអ្វីដែលយើងបានធ្វើទេ"[800]។ ប៉ុន្តែ គាត់បានបញ្ជាក់ថា គាត់មិនដឹងថា "តើមេផ្ទាល់របស់គាត់គោរពឋានានុក្រម ដែរឬអត់នោះទេ"[801]។

## 1.២. បញ្ជាដែលសន្មតថាទទួលបានពីមេបញ្ជាការកងវរសេនាតូច

៧៦២. សាក្សី 2-TCW-1000 បានអះអាងថា គាត់ត្រូវបានចាត់តាំងទៅក្នុង "កងនាវាបណ្តេញ" ដែលធ្វើអន្តរាគមន៍តែ "នៅពេលមានឧប្បត្តិហេតុ" ប៉ុណ្ណោះ[802]។ ខ្លួនគាត់ផ្ទាល់ "កម្រនឹងចេញណាស់" ពីព្រោះគាត់មិនស្ថិតនៅក្នុងកងល្បាត[803]។ គាត់បានរៀបរាប់អំពីឧប្បត្តិហេតុមួយ នៅឆ្នាំ ១៩៧៦ ពេលគាត់ចេញនាវាទៅ កប៉ាល់វៀតណាមបានបាញ់មកលើក្រុមគាត់[804]។ គាត់បានគូសបញ្ជាក់ថា មានបញ្ជាឱ្យចាប់កប៉ាល់វៀតណាមប្រដាប់អាវុធ[805]។ ត្រង់ចំណុចនេះ សក្ខីកម្មរបស់គាត់ស៊ីគ្នានឹង

---

798 <u>ប៉ាក សុខ</u>៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ២៦-២៧ ចន្លោះម៉ោង 10.50.32 និង 10.52.07។

799 <u>ប៉ាក សុខ</u>៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ២៤ ក្រោយម៉ោង 10.40.48។

800 <u>ប៉ាក សុខ</u>៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ២៤ ប្រហែល 10.42.31។

801 <u>ប៉ាក សុខ</u>៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ៥៨ មុនម៉ោង 14.38.44។

802 <u>ប៉ាក សុខ</u>៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/369.1** ទំព័រ ១៧ ប្រហែល 10.00.22។

803 <u>ប៉ាក សុខ</u>៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/369.1** ទំព័រ ៤២ មុនម៉ោង 13.49.19។

804 <u>ប៉ាក សុខ</u>៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/369.1** ទំព័រ ២៥ នៅម៉ោង 10.52.15. ក្នុងឆ្នាំ ១៩៧៦ ខ្ញុំធ្លាប់និយាយពីរឿងនេះហើយ។ ខ្លួនខ្ញុំផ្ទាល់ ខ្ញុំបានចាប់ជនជាតិវៀតណាមនៅលើទូកដែលដឹកមនុស្សប្រហែល ១០នាក់។ ក្នុងចំណោមពួកគេ មានអាវុធ ហើយពួកគេបាញ់មកលើពួកយើង។ ដូច្នេះ ក៏មានបញ្ជាចេញពីលើមកឱ្យបាញ់ទូកនោះពន្លិច ពីព្រោះពួកគេបាញ់មកលើពួកយើង។ អញ្ចឹងហើយបានយើងបាញ់ពន្លិចទូកហ្នឹង។

805 <u>ប៉ាក សុខ</u>៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/369.1** ទំព័រ ២៧ នៅម៉ោង 10.58.57 ; ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ៤២ ក្រោយម៉ោង 13.37.17។

សក្ខីកម្មរបស់ទាហានផ្សេងទៀតនៃកងទ័ពបដិវត្តន៍កម្ពុជា ស្តីពីសេចក្តីណែនាំឱ្យវាយបកនឹងការវាយប្រហារ[806]។

៧៦៣. ពេលសហព្រះរាជអាជ្ញាយកចម្លើយមុនៗរបស់គាត់ នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត មកសួរដេញដោល សាក្សី 2-TCW-1000 បានឆ្លើយថា គាត់បានទទួលបញ្ជាឱ្យសម្លាប់ "ជនជាតិវៀតណាមពេលឃើញភ្លាម ឬនាំមកដីគោក" ប៉ុន្តែ គាត់បានធានាអះអាងថាគាត់ "មិនធ្លាប់សម្លាប់អ្នកណាម្នាក់ទេ"។ ជាពិសេស នៅថ្ងៃនោះ គាត់មិនអាចប្រាប់បានថាតើបញ្ជាទាំងនោះចេញមកពីណាទេ[807]។

៧៦៤. បន្ទាប់មកទៀត នៅពេលឆ្លើយទៅនឹងសំណួររបស់ក្រុមមេធាវីការពារក្តី សាក្សី 2-TCW-1000 បានអះអាងថា បញ្ជាឱ្យ "សម្លាប់" ពេល "មនុស្សចាប់បានមានចំនួនតិចតួច" ចេញមកពីបងសំណាង មេបញ្ជាការកងវរសេនាតូចរបស់គាត់[808] ដែលទំនងជាទទួលបញ្ជា "ពីថ្នាក់កងវរសេនាតូច ឬកងវរសេនាធំ"[809]។ ប៉ុន្តែ នៅពេលគាត់ឆ្លើយបន្តទៀត យើងយល់ថាសាក្សី 2-TCW-1000 ធ្វើការទាយស្មាន ពីព្រោះខ្លួនគាត់ផ្ទាល់មិនធ្លាប់ចូលរួមប្រជុំអំពីបញ្ហានេះទាល់តែសោះ៖

> "ឆ៖ ជាការពិតណាស់ ពេលដែលប្រជុំ គឺថាប្រជុំជាវរសេនាតូច ជាផែនការរួមនៃវរសេនាតូច ហើយវរសេនាតូចហ្នឹង គេថាផ្សព្វផ្សាយពីខាងលើមកហើយ អ៊ីចឹង គឺធ្វើត្រឹមវរនាសេនាតូច។ ហ្នឹងជាការពិតនៃការប្រជុំ គឺច្បាស់តែម្តង។ ស៖ <u>តើលោកធ្លាប់ចូលរួមប្រជុំ ដែលដឹកនាំដោយថ្នាក់កងវរសេនាធំទេ ទាក់ទងទៅនឹងបញ្ហាដែលយើងនិយាយគ្នានេះ? ឆ៖ ទេ ខ្ញុំអត់ដែលទេ អត់ដែលបានចូលរួមប្រជុំជាមួយកងវរសេនាធំទេ គ្រាន់តែបានចូលរួមប្រជុំជាមួយវរសេនាតូច</u>។ ស៖ ចុះទាក់ទងនឹងការប្រជុំកងពល លោកធ្លាប់ចូលរួមប្រជុំកងពលដែរទេ ទាក់ទងនឹងបញ្ហាដែលយើងកំពុងជជែកគ្នាហ្នឹង? ឆ៖ <u>ក្នុងឋានៈជាយុទ្ធជន ខ្ញុំមិនធ្លាប់ចូលរួម</u>

[806] សូមមើលខាងលើនូវ កថាខណ្ឌ ៧៤២-៧៥១។

[807] <u>ប៉ាក សុខ</u>៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/369.1** ទំព័រ ១៩ ប្រហែលម៉ោង 10.06.22 ៖ ស៖ អញ្ចឹង បទបញ្ជារឱ្យសម្លាប់ភ្លាមៗពេលប្រទះហ្នឹង ចេញមកពីណា? ចៈ ខ្ញុំអត់ដឹងទេ។ កាលណាគេបញ្ជាឱ្យចាប់ ខ្ញុំត្រូវគោរពបញ្ជារ <u>ប៉ុន្តែខ្ញុំមិនដែលសម្លាប់អ្នកណាម្នាក់ទេ</u>។ (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

[808] <u>ប៉ាក សុខ</u>៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ៤៨ ប្រហែលម៉ោង 13.59.38។

[809] <u>ប៉ាក សុខ</u>៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ៥០ ប្រហែលម៉ោង 14.06.06។

ប្រជុំនៅកងពលទេ។ សូម្បីតែថ្នាក់កងវរសេនាធំហ្នឹង ក៏មិនបានចូលរួមប្រជុំផង" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[810]។

៧៦៥. ក៏ប៉ុន្តែ សាក្សី 2-TCW-1000 ជាមនុស្សតែម្នាក់គត់ដែលអះអាងថាមានបញ្ជាឱ្យទាហាននៃកងទ័ពបដិវត្តន៍កម្ពុជាវាយប្រហារលើជនស៊ីវិល។ សក្ខីកម្មរបស់គាត់មិនអាចជឿជាក់បាន ពីព្រោះសាក្សីផ្សេងទៀត ទាំងនៅក្នុងសវនាការ ទាំងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត បានឆ្លើយថាបានទទួលសេចក្ដីណែនាំផ្ទុយពីនេះ។

## 2. សក្ខីកម្មស៊ីសង្វាក់គ្នារបស់អតីតយោធានៃកងទ័ពបដិវត្តន៍កម្ពុជា

៧៦៦. ពាក់ព័ន្ធនឹងប្រធានបទនៃការប្រព្រឹត្តិលើជនស៊ីវិល ក្នុងពេលមានជម្លោះប្រដាប់អាវុធ ក្រៅពីសាក្សី 2-TCW-1000 សាក្សី មាស វឿន ព្រុំ សារ៉ាត់ និង 2-TCW-853 បានមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ កំណត់ហេតុស្ដាប់ចម្លើយសាក្សី ប៉ាង រ៉េត និង គឹម ម៉េន អតីតមេបញ្ជាការក្នុងកងពល ១៦៤ លើកឡើងអំពីប្រធានបទនេះ។

៧៦៧. មាស វឿន អតីតអនុលេខាកងវរសេនាតូច នៃកងពលលេខ ១ របស់ភូមិភាគបស្ចិម ដែលត្រូវបានចាត់តាំងឱ្យទៅកោះកុង ក្រោមបង្គាប់របស់តាសឿង[811] បានសង្ខេបយ៉ាងច្បាស់នៅក្នុងសវនាការអំពីការបែងចែករវាងវៀតណាមដែលបានប៉ះទង្គិចគ្នាដោយអាវុធ និងជនស៊ីវិលធម្មតា។ នៅពេលឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា គាត់បានបញ្ជាក់ថា គាត់មិន "ដឹងអំពីផែនការចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ" ហើយផែនការតែមួយគត់ដែលគាត់ដឹងពាក់ព័ន្ធនឹងជនស៊ីវិលវៀតណាម គឺការប្រមូលជនជាតិវៀតណាម ចន្លោះពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥"[812]។ គាត់បានបន្ថែមទៀតថា ប្រសិនបើមានអ្នកទោសវៀតណាមបញ្ជូនទៅក្រោយ "គ្មានផែនការកម្ទេចពួកគេទេ"[813]។ គាត់បានអះអាងយ៉ាងសមហេតុផលថា "អ្នកដែលបានរើគ្នា" [814] ត្រូវចាត់ទុកជា

---

[810] ប៉ាក សុខ៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ៥០ ប្រហែលម៉ោង 14.08.39។

[811] មាស វឿន: ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/386.1** ទំព័រ ៤៤ ប្រហែលម៉ោង 13.57.56។

[812] មាស វឿន: ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៦ នៅម៉ោង 09.19.33។

[813] មាស វឿន: ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៧-៨ នៅម៉ោង 09.24.13។

សត្រូវ ហើយគាត់បន្ថែមយ៉ាងសាមញ្ញថា "អ្នកណាបាញ់គាត់ អ្នកនោះជាសត្រូវ"[815]។ ជាចុងក្រោយ គាត់និយាយយ៉ាងច្បាស់អំពីផែនការតែមួយគត់ ដែលមាននៅសម័យនោះ គឺការការពារទឹកដីកម្ពុជាពីការវាយប្រហារជាយថាហេតុពីសំណាក់វៀតណាម៖

> "បាទ កាលដែលខ្ញុំបានដឹងខ្លះពីផែនការយួន ហើយនិងថ្នាក់ដឹកនាំ ក្នុងនោះ គឺយួន ហើយនិងខ្មែរហ្នឹងមានទំនាស់គ្នា។ ទំនាស់គ្នា ដោយមានការវាយតប់គ្នា ដូចលោកបានដឹងស្រាប់ហើយតាំងពីឆ្នាំ១៩៧០មក។ អ៊ីចឹង ខ្ញុំឃើញថា ជាទិសដៅ បានន័យថា ការតស៊ូរបស់បដិវត្តន៍កម្ពុជាហ្នឹង ហើយនិងយួនហ្នឹង គឺមានការ<u>ទាស់ទែង</u>គ្នា <u>ឈ្លានពាន</u>គ្នាទៅវិញទៅមក ហើយមិនគោរពកិច្ចការអធិបតេយ្យភាពគ្នាទៅវិញទៅមក រហូតដល់យួនវាយបន្តបន្ទាប់មក។ អ៊ីចឹង ក្នុងទិសដៅនៃអ្នកដឹកនាំនោះ គឺថាត្រូវតែវាយយួន ដើម្បីកុំឱ្យវាឈ្លានពានមកលើទឹកដីខ្មែរ ទឹកដីកម្ពុជា នេះដែលយួនពីខាងក្រៅ។ តែដល់យួននៅក្នុងកម្ពុជានោះ ក៏ត្រូវមានការប្រមែប្រមូល ហើយស្រាវជ្រាវថា តើយួនដែលនៅកម្ពុជាយូរហើយនោះ នៅកន្លែងណាខ្លះ ដើម្បីប្រមូលយកមកទុកមួយកន្លែង ដើម្បីយើងគ្រប់គ្រង។ ឯក្នុងការដែលថា កម្ទេចនោះ មិនទាន់មានផែនការថាកម្ទេចទេ គ្រាន់តែថាប្រមូលទុកឃុំ ដើម្បីកុំឱ្យមានការទាក់ទង ពីព្រោះអីយួនពីខាងក្រៅកំពុងតែមានផែនការវ៉ៃ។ អ៊ីចឹង យើងឃើញក្នុងហ្នឹង ការរៀបចំរបស់អ្នកដឹកនាំទប់ទល់នឹងស្ថានការណ៍ហ្នឹង។ ឯក្នុងការកម្ទេច ផែនការថាកម្ទេចយ៉ាងម៉េចនោះ មិនទាន់មានឯកសារ ឬក៏មិនទាន់មានអីណែនាំដល់ថា នៅក្នុងខាងក្នុងទេ។ ដូច្នេះកម្ទេចយួនខាងក្រៅដែលវាឈ្លានពាន ជាសំខាន់។ នេះដែលតាមទិសដៅខ្ញុំក្ដាប់បាន ហើយនិងការណែនាំប៉ុណ្ណឹង" (យើងខ្ញុំជាអ្នកគូសបន្ទាត់ខាងក្រោម)[816]។

៧៦៨. ព្រុំ សារ៉ាត់ អតីតមេបញ្ជាការកងអនុសេនាធំ[817] បានផ្ដល់សក្ខីកម្មស្រដៀងគ្នានេះ ក្នុងសវនាការ។ សាក្សីរូបនេះ ដែលបានឃើញហេតុការណ៍នៅកោះពូលូវ៉ៃ បានបញ្ជាក់អះអាងអំពីការវាយប្រហារដូចបានរៀបរាប់ដោយសាក្សី 2-TCW-1000 និង អៀង ផាន ក៏ដូចជាការចាប់ទាហានវៀតណាមដោយកងទ័ពខ្មែរ នៅចុងឆ្នាំ ១៩៧៥ និងការដោះលែងវិញ ក្រោយការចរចា នៅឆ្នាំ ១៩៧៧[818]។

---

[814] មាស រឿន: ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ១៧ ប្រហែលម៉ោង 09.56.22។

[815] មាស រឿន: ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ២១ ប្រហែលម៉ោង 10.07.07 :ខ្ញុំមានមតិយោបល់ផ្ទាល់ខ្លួនមួយលើខ្មាំងដែលមានកាំភ្លើង និងដែលបាញ់មកលើយើង។ និងមួយទៀត គឺ ពួក "យួន" ធម្មតា។

[816] មាស រឿន: ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៤ ចន្លោះម៉ោង 09.13.58 និង 09.16.12 ដែលអត្ថាធិប្បាយលើកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៤ **ឯកសារ E3/9740**, ស/ចទី 8។

[817] ព្រុំ សារ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/381.1** ទំព័រ ៦៨ ប្រហែលម៉ោង 15.54.24។

[818] ព្រុំ សារ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/382.1** ទំព័រ ៥ មុនម៉ោង 10.42.01 ខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះឲ្យច្បាស់អំពីរឿងនេះ។ នៅដើមឆ្នាំ ១៩៧៥ នៅតាមដែនទឹកមានសមរភូមិក្ដៅរវាងកងទ័ពវៀតណាម និងកងទ័ព

គាត់ត្រូវបានចាត់តាំងទៅកងវរសេនាធំ ១៤០ នៃកងពលធំ ១៦៤ នៅកំពង់ផែអូរឈើទាល ក្នុង ខែ មិថុនា ឆ្នាំ ១៩៧៦ ក្រោយពីបានទទួលការបណ្តុះបណ្តាល ៦ ខែ ដោយមាន "ជំនួយពីចិន"[819]។ គាត់បានក្លាយជា "អ្នកទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលបច្ចេកទេស" និងមេបញ្ជាការនាវា[820]។ សាក្សីបានបញ្ជាក់ថា កងពលធំ ១៦៤ ស្ថិតនៅក្រោមបញ្ជារបស់មាស មុត ឌឹម ឆាន និងញ៉ាន់[821]។ ដូច្នេះ ព្រុំ សារ៉ាត់ ស័ក្តិសមនឹងដឹងអំពីអ្វីដែលកើតឡើង នៅតាមតំបន់ព្រំដែនសមុទ្រ និងជាពិសេស គាត់ទទួលបន្ទុកផ្សព្វផ្សាយបន្តនូវបញ្ជារបស់កងពល។

៧៦៩. នៅក្នុងសវនាការ តាមបទពិសោធន៍របស់ខ្លួន ព្រុំ សារ៉ាត់ អាចបញ្ជាក់អះអាងអំពីចម្លើយរបស់ ហ៊ាង រ៉េត អតីតសមាជិកកងពលលេខ ៣ របស់ភូមិភាគនិរតី ស្ថិតក្រោមបញ្ជារបស់តាម៉ុក[822]។ នៅពេលសួរដេញដោលទៅលើចម្លើយរបស់ ហ៊ាង រ៉េត ដែលបានប្រាប់ការិយាល័យសហចៅក្រម ស៊ើបអង្កេតថា គាត់យល់ថា ខ្មាំងវៀតណាមជា "ទាហានវៀតណាមឈរជើងនៅតាមព្រំដែន"[823] ព្រុំ សារ៉ាត់ បានឆ្លើយដូចតទៅ៖

---

កម្ពុជាកងទ័ពកម្ពុជាប្រជាធិបតេយ្យនៅលើកោះ ពូលូវៃ ចាស់ និងពូលូវៃថ្មីត្រូវបានចាប់ខ្លួន និងដឹកទៅកោះត្បាល់។ ក្រោយមក មានការឈប់ប្រយុទ្ធគ្នា ប៉ុន្តែខ្ញុំមិនចាំកាលបរិច្ឆេទនោះទេ អ្វីដែលខ្ញុំអាចនិយាយបាន គឺថាការប្រយុទ្ធគ្នាត្រូវបានបញ្ចប់នៅចុងឆ្នាំ ១៩៧៥ ។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/383.1** ទំព័រ ៣៣ ក្រោយម៉ោង 11.09 ពេលដែលខ្ញុំប្រើពាក្យ ក្តៅក្នុងបរិបទនេះ គឺថានៅក្នុងឆ្នាំ ១៩៧៥ ទោះបីជាខ្ញុំមិនចាំកាលបរិច្ឆេទច្បាស់លាស់ក៏ដោយ គឺប្រហែលខែ មេសា មានការ ប្រយុទ្ធគ្នារវាងកងកម្លាំងវៀតណាម និងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យនៅតាមកោះ។ កងកម្លាំងវៀតណាមបានចាប់យោធា របស់កម្ពុជាប្រជាធិបតេយ្យចំនួន ៧២០ នាក់ហើយបានឃុំខ្លួនពួកគេនៅលើកោះត្រល់។ កាលហ្នឹង មានការចរចារគ្នា ការចរចា រគ្នាបានប្រព្រឹត្តឡើងនៅក្នុងឆ្នាំ ១៩៧៧ រវាងអជ្ញាធរវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់ពីការចរចារគ្នានេះ ឈ្លើយ សឹកទាំងអស់ដែលគេឃុំខ្លួនត្រូវបានបញ្ជូនមកឱ្យកម្ពុជាវិញ [...] ចៈ តាមពិតទៅការចាប់ខ្លួនត្រូវបានធ្វើឡើងនៅកោះ ពូលូវៃ ចាស់ និងកោះ ពូលូវៃថ្មីដែលជាទឹកដីរបស់កម្ពុជា គឺបានន័យថាផ្នែកខាងលិចនៃដែនទឹករបស់កម្ពុជា។ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/383.1** ទំព័រ ៣៤, ប្រហែលម៉ោង 11.16.23 និង ទំព័រ ៤២ នៅម៉ោង 13.43.46។

[819] ព្រុំ សារ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/381.1** ទំព័រ ៦៨ ក្រោយម៉ោង 15.50.01 ; ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/383.1** ទំព័រ ៥៥ ប្រហែលម៉ោង 15.04.49។

[820] ព្រុំ សារ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/381.1** ទំព័រ ៦៩ ចន្លោះម៉ោង 15.56.35 និង 15.57.57 ។

[821] ព្រុំ សារ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/382.1** ទំព័រ ៤១ ប្រហែលម៉ោង 15.05.04។

[822] កំណត់ហេតុស្តាប់ចម្លើយ HEANG Ret ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E3/9699**, ស/ចទី 6-8។

[823] កំណត់ហេតុស្តាប់ចម្លើយ HEANG Ret ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E3/9699**, ស/ចទី 70 សៈ លោក និយាយថាមានខ្មាំងពីរប្រភេទ គឺខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅ។ បើតាមយោបល់របស់លោក តើវាអាចដែរឬទេ ដែលអ្នក

"បាទ សម្ដីរបស់ ប៉ាង រ៉េត បានចុះនៅក្នុងឯកសារនេះ វាជាការពិតណាស់ ព្រោះព្រំដែនកម្ពុជា-វៀតណាម ពេលនោះ វាជាការប្រយុទ្ធគ្នាតឹងតែង តាំងពីឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៧។ ដោយឡែក ប៉ាង រ៉េត បាននិយាយថា ជនជាតិវៀតណាមឆ្លងកាត់នៅតាមឆ្នេរ នៅតាមដែនសមុទ្ររបស់កម្ពុជា ជាជនភៀសខ្លួន នេះវាជាការត្រឹមត្រូវ ព្រោះជនភៀសខ្លួនមិនមែនជាសត្រូវរបស់កម្ពុជាប្រជាធិបតេយ្យទេ។ សត្រូវរបស់កម្ពុជាប្រជាធិបតេយ្យពេលនោះ កំណត់យកពីរមុខសញ្ញាច្បាស់ គឺថាមួយ ខ្មាំងខាងក្រៅ ចំពោះ<u>កងទ័ពវៀតណាមដែលវាយទន្ទ្រានកាន់កាប់អធិបតេយ្យភាពកម្ពុជាដែនគោក និងដែនកោះរបស់កម្ពុជា</u> ហើយខ្មាំងខាងក្នុង គឺជាភ្នាក់ងារដែលធ្វើឱ្យកម្ពុជាប្រជាធិបតេយ្យមានទំនាស់ផ្ទៃក្នុងផ្នែកកម្មាភិបាលមួយចំនួន ដែលចេះតែបង្កលក្ខណៈធ្វើឱ្យកម្ពុជាមានការគិតគូរដល់សភាពការណ៍គ្រប់បែបយ៉ាងនៅក្នុងផ្ទៃក្នុង"[824]។

៧៧០. សាក្សី 2-TCW-823 ជាអតីតទាហាននៃកងពលធំលេខ ៣ របស់ភូមិភាគនិរតី ដែលក្រោយមកត្រូវបានរំលាយបញ្ចូលជាមួយកងទ័ពភូមិភាគបូព៌ាក្លាយជាកងពលលេខ ១៦៤[825]។ ក្នុងឋានៈជាមេបញ្ជាការកងវរសេនាតូច ៥៦០ នៃកងវរសេនាតូច ៦៣ ឈរជើងនៅកោះថ្មី និងកោះសេះ ទល់មុខកោះត្រល់ដែលវៀតណាមបានកាន់កាប់[826] គាត់បានប្រាប់ថាគាត់ឈរជើងនៅកោះរហូតដល់ "ឆ្នាំ ១៩៧៨ ឆ្នាំ ១៩៧៩"[827]។ ដូច ព្រុំ សារ៉ាត់ ដែរ សាក្សីរូបនេះបានគូសបញ្ជាក់ថា "គោលដៅមិនមែនលុកលុយចូលប្រទេសផ្សេងទេ គឺការពារទឹកដីកម្ពុជាប្រជាធិបតេយ្យ ដោយរក្សាស្ថានភាពពីមុនឱ្យនៅដដែល[828]៖ "គេបើវាយយើង យើងត្រូវវាយបកវិញ ដើម្បីការពារទឹកដីយើង" [829]។ គាត់បាន

---

នៃសាទវៀតណាមទាំងនោះត្រូវបានចាត់ទុកថាជាខ្មាំងខាងក្រៅ ហើយដល់អញ្ចឹង ពួកគេត្រូវបានប្រហារជីវិត? ចៈ ខ្ញុំមិនគិតអញ្ចឹងទេ។ ខ្មាំងខាងក្រៅសំដៅពួកទាហានវៀតណាមដែលឈរជើងនៅតាមព្រំដែន។ តាមយោបល់ខ្ញុំ ការចាប់ខ្លួននេសាទវៀតណាម អ្នកនេសាទវៀតណាមមិនត្រូវបានចាត់ទុកថាជាខ្មាំងខាងក្រៅទេ។ ប៉ុន្តែពួកនេះ រំលោភលំហរសមុទ្រនៃប្រទេសកម្ពុជា។

[824] ព្រុំ សារ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/382.1** ទំព័រ ១០ នៅម៉ោង 10.59.30។

[825] <u>2-TCW-823</u> : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៦១ ក្រោយម៉ោង 14.48.46។

[826] <u>2-TCW-823</u> : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៦២ ប្រហែលម៉ោង 14.52.54។

[827] <u>2-TCW-823</u> : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៦៤ ប្រហែលម៉ោង 14.58.30។

[828] <u>2-TCW-823</u> : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៦៨-៦៩ ក្រោយម៉ោង 15.14.17 ចៈ ពេលដែលគេបញ្ជូនខ្ញុំទៅទីនោះ នៅកោះសេះ មានកងកម្លាំងនៅទីនោះស្រេចហើយ។ យើងត្រូវរក្សាស្ថានការណ៍ដដែល ពោលគឺត្រូវការពារព្រំដែនយើង។ យើងមិនត្រូវឆ្លងព្រំដែនសោះឡើយ។ យើងមិនដែលទៅហួសពីព្រំដែនកោះត្រល់ឡើយ ពីព្រោះយើងដឹងថា កងកម្លាំងវៀតណាមនៅទីនោះស្រេចហើយ។ យើងមិនមានចេតនាដណ្ដើមយកកោះនេះមកវិញនោះទេ។ សាក្សីរូបនេះក៏បានបញ្ជាក់ផងដែរថា ពួកគាត់ផ្អែកលើផែនទីដែលទីបញ្ជាការកងពលផ្ដល់ឱ្យពួកគាត់។ ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៦៩ ក្រោយម៉ោង 15.16.48។

រៀបរាប់ថានៅកន្លែងដែលគាត់ឈរជើង ការប៉ះទង្គិចគ្នាជាមួយវៀតណាមកើតឡើងភាគច្រើន រឿងទូកនេសាទប្រដាប់អាវុធ[830]។

"និយាយរួម គឺថាខាងវៀតណាមហ្នឹង គាត់មកជារូបភាពជានេសាទត្រី ជាកាណូតច្រើនគ្រឿងអ៊ីចឹងទៅ ប៉ុន្តែមានកាំភ្លើង។ ដល់ចូលកោះយើង រហូតមកដល់កោះជិតរាមនេះ ក៏មានដែរ ហើយកោះសំពោចអ៊ីចឹង ហួសពីកោះសេះ មកជិតដល់ដីគោកពីក្រោយ។ អ៊ីចឹង មានការវ៉ៃហើយ ប៉ុន្តែភាគច្រើន គឺវៀតណាមវ៉ៃមុន ប៉ុន្តែទូកគេនេសាទទេ យើងត្រូវតបតវិញដែរ។ ពេលខ្លះ ក៏ត្រូវរបួស ត្រូវអ៊ីចឹងដែរ ស្លាប់អី។ [...] រូបភាព កប៉ាល់ធំ ឬកប៉ាល់ចម្បាំងអី មិនដែលឃើញទេ ប៉ុន្តែរូបភាពកាណូតច្រើន មានកាំភ្លើងមកវ៉ៃគ្នានៅហួសព្រំដែនសមុទ្រយើង ហួសកោះមកក្រោយមក"[831]។

"បាទ ខ្ញុំនិយាយនេះ គឺនិយាយសម្រាប់កាណូត ឬក៏ពួកនេសាទទេ និយាយការបាញ់មុន បាញ់អី តាមខ្សែបន្ទាត់ ហួសខ្សែបន្ទាត់នេះទេ។ អ៊ីចឹង បានន័យថា យើងបាញ់វិញ បាញ់ដើម្បីឱ្យគេកុំឱ្យមកដីយើង ឱ្យគេទៅផ្ទះវិញ បើគេប៉ានបាញ់មុន យើងបាញ់។ បើគេអត់បាញ់ទេ យើងឆាបលិចកើតទៅ គេទៅវិញ យើងក៏អត់បាញ់គេដែរ។ អ៊ីចឹង បានន័យថា មិនជាឈ្លានពានធំដុំ ហៅថារូបភាពគេប្រើតាមរូបភាពនេសាទ"[832]។

"ចំពោះទូកនេសាទ យើងមិនមានការវាយប្រហារអីទេ គឺមានដេញឱ្យគេទៅវិញហ្នឹង កាលណាកាណូតយើងទៅ គេអត់បាញ់ ដឹងតែគេចូលព្រំដែនយើង ពេលកាណូតយើងទៅ គេរត់ហើយ គេរត់ទៅកោះគេវិញ។ ប៉ុន្តែ បើខាងគេបាញ់ ខាងខ្ញុំនេះក៏បាញ់ដែរ"[833]។

៧៧១. ពេលឆ្លើយទៅនឹងសំណួរដ៏ទទូចរបស់ចៅក្រម Jean-Marc LAVERGNE ដែលហាក់ដូចជាស្ដីបន្ទោសឱ្យគាត់ពីរឿងបាញ់ ដោយមិនប្រាកដថាអ្នកជិះជាទាហាន ឬក៏អត់ សាក្សី 2-TCW-823 បានឆ្លើយយ៉ាងច្បាស់ថា ទោះបីកប៉ាល់ប្រភេទណាក៏ដោយ ឱ្យតែអ្នកជិះបាញ់ គាត់បាញ់វិញហើយ៖

"ស៖ អ៊ីចឹងៗ ម៉េចក៏លោកអាចនិយាយថាពួកទាំងអស់ហ្នឹងជាទាហាននោះ បើសិនជាលោកមិនទៅពិនិត្យមើលផងឱ្យដឹងថាគេស្លៀកឯកសណ្ឋានស្អី ជាស៊ីវិល ឬជាទាហានផងនោះ? ឥឡូវនេះ យើងកំពុងតែនិយាយ

[829] 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៦៥ ក្រោយម៉ោង 15.00.49។

[830] 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ៦ នៅម៉ោង 09.19.55 ៖ ពេលដែលទូកនេសាទចូលក្នុងដែនទឹកយើង ទោះបីជា ពួកគេហាក់ដូចជាអ្នកនេសាទក៏ដោយ ក៏ពួកគេមានអាវុធដែរ។

[831] 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៦៦ ប្រហែលម៉ោង 15.07.14។

[832] 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ២០-២១ ប្រហែលម៉ោង 09.49.10។

[833] 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ១០-១១ នៅម៉ោង 09.24.35។

ទូកនេសាទ យើងមិននិយាយអំពីនាវាចម្បាំងទេ គឺយើងនិយាយអំពីទូកនេសាទដែលលោកថាមានអាវុធនៅលើហ្នឹង។ អ៊ីចឹង ខ្ញុំសួរលោកថា ហេតុអ្វីក៏លោកអាចដឹងថានៅលើទូកនេសាទហ្នឹង មានទាហាន? ឆ្លើយ៖ សំណួរនេះលោក ខ្ញុំបានបញ្ជាក់ខាងដើមហើយ។ ដូច្នេះ លោកលើកសំណួរនេះជាន់ដដែលៗ ហើយខ្ញុំបានបញ្ជាក់ទៀតហើយ គឺថា ការបាញ់គ្នានៅក្នុងដែនទឹកយើង ខ្ញុំក៏រូបភាពបាញ់ឈ្លបដែរ បាញ់រត់មកការពារខ្លួនឯងគេក៏អ៊ីចឹង គេបាញ់ហើយ គេរត់ទៅកន្លែងគេវិញ។ ឯការពិនិត្យអី យើងមិនបានទៅពិនិត្យទេ។ ឯរូបភាពជាទាហាន ឬមិនទាហាន ខ្ញុំមិនថាជាទាហាន ឬក៏មិនទាហានទេ។ ប៉ុន្តែ អ្នកណាក៏ដោយ ដែលមានកាំភ្លើងបាញ់ខាងខ្ញុំ ខ្ញុំបាញ់វិញហើយ"[834]។

"បាទ សំណួរនេះដូចខ្ញុំបញ្ជាក់ម្តងហើយ តែខ្ញុំបញ្ជាក់ម្តងទៀត គឺថាន័យដែលៗនេសាទហ្នឹង គឺថាជាក្បួនមានកាំភ្លើងមានអីហ្នឹង គឺមានទូកនេសាទហ្នឹងជារូបរាងទូកនេសាទ ប៉ុន្តែ ជាក់ស្តែង មានកាំភ្លើង"[835]។
"ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង គឺថាជំហរកងទ័ពការពារព្រំដែនមួយគឺថា រូបភាពអ្វីក៏ដោយ បើសិនជាមានការបាញ់ហើយ ហើយយល់ពីភាគីម្ខាង ហើយម្នាក់នោះណាក៏ដោយ ក៏ត្រូវតែវ៉ៃដែរ ជាទស្សនៈខ្ញុំគឺអ៊ីចឹង។ ជាក់ស្តែង ខ្ញុំធ្វើអ៊ីចឹង"[836]។

៧៧២. ម្យ៉ាងវិញទៀត សាក្សី 2-TCW-823 បានពន្យល់ថាគាត់មិនធ្លាប់ឃើញនាវាយោធាវៀតណាមនោះទេ ពីព្រោះ "ទឹកដែលកងស្រួចរបស់គាត់ប្រចាំការមិនសូវជ្រៅនោះទេ ហើយនាវាមិនអាចចូលដល់នោះទេ"[837]។ គាត់បានបញ្ជាក់ថា គាត់មិនធ្លាប់ឃើញទូកនេសាទគ្មានអាវុធនោះទេ ក្នុងពេលគាត់បំពេញមុខងារ[838]។ នៅពេលសួរអំពីការចាប់ជាយថាហេតុ គាត់បានអះអាងថា៖ "បើតាមខ្ញុំដឹងរឿងចាប់បានវៀតណាមអី មិនមានទេ។ នៅលើកោះខ្ញុំ យើងមិនដែលចាប់បានអ្នកណាទេ [...]។ កងខ្ញុំចាប់ទូកយួនអីកន្លែងហ្នឹង មិនមានទេ មិនដែលបានបញ្ជូនទៅនោះទេ អត់ទេ។ វាមិនដែលបានចាប់ផង មានតែបាញ់គ្នា"[839]។

[834] 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ 25 ប្រហែលម៉ោង 10.50.43 (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

[835] 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ 25, ប្រហែលម៉ោង 10.46.21។

[836] 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ៩ ប្រហែលម៉ោង 09.30.43។

[837] 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ២៦ ប្រហែលម៉ោង 10.52.26។

[838] 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ២៥ ប្រហែលម៉ោង 10.46.21

[839] 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៧០-៧១ ប្រហែលម៉ោង 15.22.21។

៧៧៣. មាស វឿន បានរៀបរាប់លម្អិតអំពីដំណើរការអន្តរាគមន៍លើសមុទ្ររបស់កងទ័ពជើងទឹក ដោយបញ្ជាក់ថា មានសេចក្តីណែនាំឱ្យតបត ពេល "គេបាញ់" ប៉ុន្តែមិនធ្លាប់មានសេចក្តីណែនាំឱ្យសម្លាប់ជនស៊ីវិលគ្មានអាវុធនោះទេ។ ពេលសួរអំពីចម្លើយពីមុនៗរបស់គាត់ គាត់បានឆ្លើយដូចខាងក្រោមនៅក្នុងសវនាការ៖

> "ស៖ (...) ប្រសិនបើកាណូតចូលមកដែនទឹក ចម្ងាយពី ១០ ទៅ ១១ គីឡូម៉ែត្រទឹកពីឆ្នេរ យើងត្រូវឆែកឆេរ ហើយចាប់ទូកនោះ តែចាប់ពី ៣០ ទៅ ៧០ គីឡូម៉ែត្រទឹក យើងត្រូវមើល និងទៅដេញបណ្តេញចេញ។ មុននឹងចូលទៅជិតទូក យើងត្រូវពិនិត្យមើលថាជាទូកស៊ីវិល ឬក៏ទូកនេសាទដែលអមដោយកប៉ាល់ចម្បាំង។ល។ ទាំងនេះគឺជាគោលនយោបាយទូទៅ។ តើលោកចាំថាបានឆ្លើយបែបនេះ ទៅអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែរឬទេ? ឆ៖ បាន បានប្រាប់គាត់ដែរតើ។ ស៖ នៅពេលដែលកប៉ាល់ចូលមកក្នុងដែនទឹករបស់លោក តើលោក នៅក្នុងកងពលលេខ ១ ហើយនិងកងល្បាតរបស់លោកហ្នឹង គឺតែងតែចាត់ការដូចម្តេច ហើយមានអ្វីកើតឡើងចំពោះកប៉ាល់ដែលចូលមកដែនទឹកនោះ? ឆ៖ បាទ មុនពេលដែលកប៉ាល់ចូលមកដែនទឹកយើង យើងនឹងប្រាប់ឱ្យកប៉ាល់យើងទៅមើលៗ ដើម្បីដឹងថា កប៉ាល់តូច ឬកប៉ាល់ធំ ឬក៏កាណូតចាប់ត្រី។ តែបើកាលណាទៅមើលទៅ បើគេរត់ទៅ ក៏គេទៅចុះ។ ប៉ុន្តែ បើសិនណាគេបាញ់យើង យើងតបតវិញដែរ។ មានប៉ុណ្ណឹងឯង"[840]។

៧៧៤. ព្រុំ សារ៉ាត់ បានឆ្លើយក្នុងសវនាការថា គាត់ស្តាប់ឮ "ថ្នាក់លើ" ដោយ "មិនដឹងលម្អិតអំពីនីតិវិធី" និយាយថា ប្រសិនបើកងនាវាចាប់បាន "ទូកនេសាទថៃក្តី ទូកណាក្តី" ក្នុង "ដែនទឹក" ត្រូវ "ប្រគល់ជូនទៅផ្នែកទាក់ទងអន្តរជាតិ ដើម្បីក្រុមពួកនេសាទទាំងអស់នេះ ដោះស្រាយយ៉ាងណាទៅតាមកិច្ចការរបស់ក្រសួងការបរទេស"[841]។ សាក្សីក៏បានបញ្ជាក់ផងដែរថា ត្រូវបែងចែកប្រភេទនាវា គឺ "នាវាល្បាត" ដែលមានភារកិច្ចចាប់ទូក និងនាវាខ្នាតធំដែលគាត់បញ្ជា[842]។

[840] មាស វឿន : ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/386.1** ទំព័រ ៤៧ ប្រហែលម៉ោង 14.10.16។

[841] ព្រុំ សារ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/382.1** ទំព័រ ២៩ មុនម៉ោង 14.04.28។

[842] ព្រុំ សារ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/383.1** ទំព័រ ៣០-៣១ នៅម៉ោង 11.02.33 ៖ មាននាវាពីរប្រភេទ។ ក្រុមទីមួយគឺ ក្រុមនាវាល្បាតដែលឈរជើងនៅលើកោះផ្សេងៗ។ ភារកិច្ចរបស់ពួកគេគឺហៅសួរនាំទូកដែលចូលហួស និង "ចូលមកដែនទឹកយើង"។ មាននាវាពីរដែលគេប្រើសម្រាប់ការងារនេះ គឺនាវាអាមេរិកដែលផលិតនៅប្រទេសអាមេរិក។ គឺ នាវា PCS។ នាវាទាំងនេះមានភារកិច្ចល្បាត និងហៅសួរនាំទូកទាំងឡាយណាដែលចូលមកដែនទឹកយើង។ យើងមាននាវាមួយធំជាងឆ្ងាយណាស់ ដូច្នេះយើងមិនអាចប្រើវាដើម្បីតាមសួរនាំបានទេ។ នាវាយើងស៊ីប្រេងពីរតោនក្នុងមួយម៉ោងឯណោះ ដូច្នេះ វាមិនត្រូវជានាវាដែលប្រើសម្រាប់ការអន្តរាគមន៍បែបនេះទេ។ ការអន្តរាគមន៍បែបនេះត្រូវជាភារកិច្ចរបស់ប្រភេទនាវាផ្សេងទៀត។ ខ្ញុំមិនដឹងថាអ្នកដែលធ្វើការលើនាវាផ្សេងទៀតនេះនៅរស់ ឬយ៉ាងណាទេ។

៧៧៥. ដូច្នេះ ព្រុំ សាវ៉ាត់ មានភារកិច្ច "ធានាថានាវាមានការត្រៀមប្រយុទ្ធ នៅពេលខ្មាំងសត្រូវ "រំលោភឈ្លានពាន" [843] ហើយគាត់គ្មានភារកិច្ច "ចាប់អ្នកទោស ឬចាប់នាវានោះទេ"[844]។ ជាចុងក្រោយ គាត់បានអះអាង បញ្ហាតែមួយគត់ដែលទទួលបានពីកងពល ១៦៤ គឺ "ការពារដែនទឹក"[845]។ ពេលលើកឡើងអំពីវគ្គរៀនសូត្រនៅទីក្រុងភ្នំពេញ ដឹកនាំដោយ សុន សេន ក្នុងឆ្នាំ ១៩៧៦ ដែលគាត់បានចូលរួម គាត់បានប្រាប់ថា ប្រធានបទសំខាន់ គឺ "ការរៀបចំកងទ័ព" និង "ការប្រយុទ្ធយុទ្ធសាស្ត្រ" ដែលត្រូវធ្វើ[846]។ ដូច្នេះ គាត់មិនបាននិយាយអំពីសេចក្តីណែនាំឱ្យសម្លាប់ជនស៊ីវិលវៀតណាមទេ។

៧៧៦. សក្ខីកម្មរបស់គាត់ស៊ីសង្វាក់គ្នានឹងចម្លើយរបស់ គឹម ម៉េន។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយមួយ អតីតទាហាន ដែលនៅឆ្នាំ ១៩៧៤ ត្រូវបានចាត់តាំងឱ្យចូលកងពលលេខ ៣ ដែលក្រោយមកក្លាយជាកងពល ១៦៤[847] បានពន្យល់ថា គាត់ជាប្រធានកងអនុសេនាធំ ហើយក្រោយមក ត្រូវបានដំឡើងឋានៈធំជាងនេះ នៅក្នុងកងវរសេនាតូច ៦២៣ នៃកងវរសេនាធំ ៦២ ឈរជើងនៅលើកោះតាង[848]។ គាត់មានវត្តមាននៅលើកោះនេះ ក្នុងពេលជាមួយគ្នានឹងសាក្សី 2-TCW-1000[849] ដែរ។ គាត់បានអះអាងថា កប៉ាល់វៀតណាមរំលោភចូលដែនទឹកកម្ពុជា ជាញឹកញាប់ ហើយមានសេចក្តីណែនាំឱ្យចាប់កប៉ាល់ណាដែលគ្មានអាវុធ និងបាញ់កប៉ាល់ណាដែលមានអាវុធ[850]។

---

[843] ព្រុំ សាវ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/383.1** ទំព័រ ២៥ ចន្លោះម៉ោង 10.40 និង10.41.04

[844] ព្រុំ សាវ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/383.1** ទំព័រ ៤៤-៤៥ មុនម៉ោង 13.56.35 ការណែនាំដែលខ្ញុំបានទទួលគឺ យោធា ឬក្រុមការងារលើនាវាត្រូវបំពេញភារកិច្ចរបស់ខ្លួន និងត្រូវត្រៀមខ្លួនឱ្យរួចរាល់ជាស្រេចក្នុងការវាយប្រហារខ្មាំងដែលចូលមកដែនទឹកកម្ពុជា។ ដូច្នេះ ខ្ញុំមិនមានកាតព្វកិច្ចចាប់ដាក់គុក ឬដកហូតនាវាដែលចូលមក ទឹកដីកម្ពុជាឡើយ។ ដូចដែលខ្ញុំបានលើកឡើងអញ្ចឹង ខ្ញុំបានទទួលបញ្ជារលើបញ្ហាមួយចំនួន។ ខ្ញុំនិយាយត្រង់អស់ពីពោះហើយ។

[845] ព្រុំ សាវ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/383.1** ទំព័រ ១៧ នៅម៉ោង 09.58.51។

[846] ព្រុំ សាវ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/382.1** ទំព័រ ២២ ចន្លោះម៉ោង 13.37.05 និង 13.39.07។

[847] កំណត់ហេតុស្តាប់ចម្លើយ KOEM Men ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E3/10768**, ស/ច 3, 10 និង 14។

[848] កំណត់ហេតុស្តាប់ចម្លើយ KOEM Men ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E3/10768**, ស/ច 17, 20 និង 21។

[849] ប៉ាក សុខ៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ២៥-២៦ ចន្លោះម៉ោង 10.48.49 និង 10.52.07.

[850] កំណត់ហេតុស្តាប់ចម្លើយ KOEM Men ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E3/10768**, ស/ច 47.

៧៧៧. ផ្ទុយពីកូនទាហាន ដូចជាសាក្សី 2-TCW-1000[851] ដោយគាត់មានឋានន្តរស័ក្តិខ្ពស់ជាង កឹម ម៉េន បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលដែលឧទ្ទេសនាមដោយ មាស មុត[852] និងវគ្គសេនាធិការប្រចាំឆ្នាំលើកទីពីរ នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ដែល ព្រុំ សារ៉ាត់ ក៏បានចូលរួមផងដែរ[853]។ ចម្លើយរបស់គាត់ស៊ីគ្នានឹងចម្លើយរបស់ ព្រុំ សារ៉ាត់ ដែលថា វគ្គរៀនសូត្រទាំងនេះផ្តោតលើការការពារប្រទេស ការប្រុងប្រយ័ត្នចំពោះមហិច្ឆតាពង្រីកទឹកដីរបស់វៀតណាម និងតួនាទីសហករណ៍[854]។ ដូច្នេះ កឹម ម៉េន មិនបាននិយាយអំពីបញ្ហាឱ្យវាយប្រហារទៅលើជនស៊ីវិលវៀតណាមនោះទេ។

៧៧៨. សាក្សី 2-TCW-823 ក៏បានអះអាងផងដែរថា គាត់បានចូលរួម "កិច្ចប្រជុំនៅទីបញ្ជាការកងពល" ដែលដឹកនាំដោយតាមុត លេខាកងពល ១៦៤ ឬ "បងឌឹម" អនុលេខា[855]។ ប្រធានបទដែលពិភាក្សាគឺ "ការការពារព្រំដែន ការការពារប្រទេស និងការការពារកោះ"[856]។ ចំពោះសេចក្តីណែនាំ គាត់បានឆ្លើយថា "នៅកន្លែងខ្ញុំ ខ្ញុំមិនធ្លាប់ទទួលបានសេចក្តីណែនាំឱ្យបាញ់ពន្លិច ឬបាញ់ទៅលើកប៉ាល់វៀតណាម ដែលប៉ុនប៉ងគេចទៅបរទេសនោះទេ"[857]។ ម្យ៉ាងវិញទៀត គាត់មិនធ្លាប់ជួបប្រទះទូកជនភៀសខ្លួននោះទេ[858]។ នៅឆ្នាំ ១៩៧៦ គាត់បានចូលរួមវគ្គបណ្តុះបណ្តាលនៅទីក្រុងភ្នំពេញ ក្នុងនោះ ប៉ុល ពត បានបង្រៀនជាសំខាន់អំពីការការពារប្រទេស និងបញ្ហាផ្គត់ផ្គង់ស្បៀង[859]។

---

[851] <u>ប៉ាក់ សុខះ</u> ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ២៦-២៧ ចន្លោះម៉ោង 10.50.32 និង 10.52.07 ទំព័រ 50 មុនម៉ោង 14.08.39 ; កំណត់ហេតុស្តាប់ចម្លើយ KOEM Men ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E3/10768**, R 100។

[852] កំណត់ហេតុស្តាប់ចម្លើយ KOEM Men ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E3/10768**, ស/ច 47 និង 99-115។

[853] កំណត់ហេតុស្តាប់ចម្លើយ KOEM Men ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E3/10768**, ស/ច 99-115 ; *DK Military report entitled « Second General Staff Study Session »* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ **ឯកសារ E3/847**, ERN FR 00623211 ; ព្រុំ សារ៉ាត់ : ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/383.1** ទំព័រ ៦ ប្រហែលម៉ោង 09.20.51។

[854] កំណត់ហេតុស្តាប់ចម្លើយ KOEM Men ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E3/10768**, ស/ច 99-115។

[855] <u>2-TCW-823</u> : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៧២ ប្រហែលម៉ោង 15.30.57។

[856] <u>2-TCW-823</u> : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៧៣-៧៤ មុនម៉ោង 15.35.45។

[857] <u>2-TCW-823</u> : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ១០-១១ មុនម៉ោង 09.36.55។

[858] <u>2-TCW-823</u> : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ២៥ ក្រោយម៉ោង 10.46.21។

[859] <u>2-TCW-823</u> : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៦៨-៧៥ ចន្លោះម៉ោង 15.13.45 និង 15.40.14។

៧៧៩. ដូចសាក្សីផ្សេងទៀតមកពីកងពល ១៦៤ ដែរ គាត់មិនបាននិយាយអំពីសេចក្ដីណែនាំរបស់កងពល ឬអ្នកផ្សេងទៀត ឱ្យសម្លាប់ជនស៊ីវិលវៀតណាមនោះទេ៖

> "បាទ ជាទស្សនៈរបស់ខ្ញុំ ខ្ញុំយល់ថាប្រជាជនរត់ពីវៀតណាម គេចសង្គ្រាមទៅក្រៅ មិនមែនជាសត្រូវនោះទេ គឺជាប្រជាជនសុទ្ធសាធ ភ័យអាសន្នអីទៅក្រៅ។ ដូច្នេះ យើងជាកងទ័ពមិនអាចវ៉ៃ ទៅធ្វើបាបអីទេ។ ឯទស្សនៈរួមរបស់កងពល ខ្ញុំបាននិយាយ គឺថាខ្ញុំនិយាយជាទស្សនៈរបស់ខ្ញុំ ឯទស្សនៈរបស់កងពលយ៉ាងម៉េច អីយ៉ាងម៉េច រឿងនេះ យល់ដូចខ្ញុំ ឬមួយយ៉ាងម៉េច ខ្ញុំក្លាប់មិនបានទេ មុខសញ្ញាផ្សេង ជួនកាល ខ្ញុំថាគេយល់ដូចខ្ញុំទៅ ជួនកាល ក៏វាមិនថាយល់ ប៉ុន្តែ ការណែនាំរបស់ខាងលើ គឺមានបញ្ជាក់ថា មិនជាខ្លាំងទេ បើថារត់រកក៏រត់ រត់ឱ្យហួសបាត់ទៅ។ អាហ្នឹងជារួមរបស់កងពល។ អានេះខ្ញុំក្លាប់បានអ៊ីចឹង"[860]។

៧៨០. ចម្លើយរបស់ ហ៊ាង រ៉េត បញ្ជាក់ថា សេចក្ដីណែនាំរបស់ មាស មុត ក្នុងសន្និបាតរបស់កងពល ១៦៤ គឺឱ្យជនភៀសខ្លួនរត់ទៅប្រទេសថៃ[861]។

៧៨១. ដូច្នេះ យោងតាមសក្ខីកម្មទាំងនេះ ជម្លោះប្រដាប់អាវុធនៅតាមដែនទឹក និងការទាស់ទែងគ្នា ក៏ដូចជាការបាញ់គ្នា បានកើតឡើងពេលនាវាវៀតណាមចូលមកក្នុងដែនទឹកកម្ពុជា។ ភាគច្រើន ទោះបីជាមិនមែនជាកប៉ាល់យោធាក៏ដោយ ប៉ុន្តែ កប៉ាល់ទាំងនោះមានអាវុធ។ សាក្សីទាំងនេះបានអះអាងថាត្រូវការពារទឹកដីកម្ពុជា ទោះក្នុងតម្លៃណាក៏ដោយ និងត្រូវបញ្ចៀសរាល់ការវាយប្រហារពីខាងវៀតណាម។ ជាថ្មីម្ដងទៀត សក្ខីកម្មទាំងនេះអាចអះអាងផ្ទុយទៅនឹងទស្សនៈរបស់សហព្រះរាជអាជ្ញា ដែលថារបបខ្មែរក្រហមចូលចិត្តប្រើកម្លាំង។

---

[860] 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ១៣-១៤ 17-19, ចន្លោះម៉ោង 09.43.30 និង 09.46.52 (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

[861] កំណត់ហេតុស្ដាប់ចម្លើយ HEANG Ret ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E3/9699**, ស/ច 75 ៖ នៅចុងឆ្នាំ ១៩៧៧ ខ្ញុំបានចូលរួមក្នុងសមាជមួយក្នុងទីក្រុងភ្នំពេញដើម្បីបូកសរុបការងារដែលបានសម្រេចដោយកងពលលេខ ១៦៤។ នៅក្នុងឱកាសនេះ ខ្ញុំបានលឺ មាស មុត បង្ហាញរបាយការណ៍អំពីទូកវៀតណាមដែលបានចូលក្នុងដែនទឹកកម្ពុជា។ កាលណោះ សុន សេន ប្រាប់ មាស មុតថា បើសិនជនជាតិវៀតណាមទាំងនេះជាជនភៀសខ្លួនដែលសំដៅទៅប្រទេសថៃមិនត្រូវចាប់ខ្លួនពួកគេទេ ប៉ុន្តែត្រូវទុកឱ្យពួកគេបន្តដំណើរទៀតទៅ។(យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

## ជំពូកទី ២. កាលប្បវត្តិសង្ខេបនៃការប៉ះទង្គិចដោយអាវុធ

៧៨២. កាលប្បវត្តិសង្ខេបនៃជម្លោះប្រដាប់អាវុធអមដោយការកើនឡើងនូវជម្លោះព្រំដែនពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦ (ផ្នែកទី ១) ជម្លោះឡើងកម្តៅខ្លាំង ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨ (ផ្នែកទី ២) និងការបញ្ចប់ជម្លោះដោយការប្រកាសបរាជ័យរបស់កម្ពុជាប្រជាធិបតេយ្យ នៅក្នុងខែ មករា ឆ្នាំ ១៩៧៩ (ផ្នែកទី ៣)។

៧៨៣. ប្រសិនបើនៅក្នុងផ្នែកទាំងនេះ យើងលើកឡើងនូវអង្គហេតុនៅក្នុងទឹកដីវៀតណាម ដែលលោក ខៀវ សំផន មិនត្រូវឆ្លើយតប ដោយហេតុថាអង្គជំនុំជម្រះបានផ្តាច់ខ្លួនចេញពីអង្គហេតុទាំងនេះតាមរយៈការបំបែកបទចោទ ព្រោះតែសហព្រះរាជអាជ្ញា និងចៅក្រម Jean-Marc LAVERGNE បានចំណាយពេលវេលាយ៉ាងច្រើន នៅក្នុងសវនាការ ដោយគាំទ្រយ៉ាងច្បាស់ក្រឡែតដល់អំណះអំណាងថា កម្ពុជាប្រជាធិបតេយ្យចូលចិត្តប្រើកម្លាំងដោយឆ្គួតលីលា[862]។ ដូច្នេះ ពេលវេលាសវនាការត្រូវបានលើកឡើងនៅទីនេះ គឺគ្រាន់តែដើម្បីបង្ហាញឱ្យឃើញច្បាស់អំពីភ័ស្តុតាងនៅក្នុងវិសាលភាពពាក់ព័ន្ធនឹងអង្គហេតុនៅលើទឹកដីកម្ពុជា និងកំណត់អង្គហេតុនៅក្នុងកាលវេលាឡើងវិញ។

### ផ្នែកទី ១. ការកើនឡើងនូវជម្លោះព្រំដែន ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦

៧៨៤. ដូចយើងបានរំឭកពីមុនរួចមកហើយ ក្រោយជ័យជម្នះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ របបកម្ពុជាប្រជាធិបតេយ្យថ្មី បានផ្តោតជាសំខាន់ទៅលើការកសាងប្រទេស។ នៅពេលងើបចេញពីសង្គ្រាមរ៉ាំរ៉ៃយ៉ាងត្រដាបត្រដួស កម្ពុជាប្រជាធិបតេយ្យគ្មានប្រយោជន៍អ្វីត្រូវបង្កជម្លោះជាថ្មីទៀតនោះទេ។ ការប៉ះទង្គិចគ្នាពេលដំបូងមិនបានបន្ទុចបង្អាក់ដល់ការបន្តការចរចាឡើយ (១) ប៉ុន្តែ ការប្រយុទ្ធគ្នាកាន់តែមានសភាពខ្លាំងឡើងៗ (២)។

#### ១. ការប៉ះទង្គិចគ្នាដំបូងៗ និងការបន្តការចរចា

---

[862]សូមមើលខាងលើនៅកថាខណ្ឌ 204-212។

៧៨៥. បណ្ណសាររបស់កម្ពុជាប្រជាធិបតេយ្យបង្ហាញថា ទោះបីជាមានជម្លោះព្រំដែនក៏ដោយ ក៏ការពិភាក្សាគ្នានៅតែបន្ត ក្នុងពេលជាមួយគ្នានេះ ស្របតាមសេចក្ដីណែនាំតាំងពីឆ្នាំ ១៩៧៥ ឱ្យការពារទឹកដី ដោយបញ្ចៀសការប៉ះទង្គិចគ្នា[863]។ យោធានៃកងទ័ពបដិវត្តន៍កម្ពុជាមានឆន្ទៈផ្ដល់នូវមូលដ្ឋានផែនទីចំពោះការទាមទារទឹកដីរបស់ខ្លួន ទល់នឹងគូបដិបក្ខ។

៧៨៦. ជាក់ស្ដែង សារទូរលេខ ចុះខែ មករា ឆ្នាំ ១៩៧៦ រាយការណ៍អំពីលទ្ធផលនៃជំនួបជាមួយគណៈប្រតិភូវៀតណាម និងរៀបរាប់អំពីប្រតិកម្មកម្រោលចូលរបស់វៀតណាមទៅនឹងទឡ្ហីករណ៍របស់កម្ពុជា ដែលចេះទប់អារម្មណ៍[864]។ ឧទាហរណ៍នៃប្រតិកម្មខ្លាំងក្លារបស់វៀតណាម ពាក់ព័ន្ធនឹងការកំណត់ព្រំដែន ពន្យល់អំពីការលំបាកក្នុងការឈានទៅដល់ការស្រុះស្រួលគ្នា និងការកើនឡើងនូវកម្ដៅជម្លោះបន្តិចម្ដងៗ ទន្ទឹមនឹងឧបសគ្គនយោបាយដល់ការចរចា។ ការចោទថាកម្ពុជាប្រជាធិបតេយ្យជាអ្នកឈ្លានពាននាំអាទិ៍ឱ្យមានការប្រយុទ្ធគ្នា មិនផ្ទុះបញ្ចាំងការពិតនោះទេ។ ជាក់ស្ដែង ឯកសារជាច្រើននៅឆ្នាំ ១៩៧៦ បង្ហាញថា កងទ័ពបដិវត្តន៍កម្ពុជាតបតនឹងការវាយប្រហាររបស់វៀតណាម ហើយសេចក្ដីណែនាំ គឺគ្រាន់តែឱ្យតបត ពេលគ្មានជម្រើសផ្សេងក្រៅពីនេះប៉ុណ្ណោះ។ យើងត្រូវដកស្រង់នូវសេចក្ដីណែនាំមួយចំនួន ដើម្បីឱ្យយល់អំពីកាលប្បវត្តិនៃហេតុការណ៍។

៧៨៧. កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បង្ហាញឱ្យឃើញច្បាស់អំពីសេចក្ដីណែនាំឱ្យចៀសវាងបង្កើនការតានតឹងចំពោះមុខការចូលលុកលុយ និងការបង្ខិតបង្គោលព្រំដែនដោយកងទ័ពវៀតណាម[865]។

---

[863]វាគួរជាទីចាប់អារម្មណ៍ក្នុងការកត់សម្គាល់ថា បទបញ្ជារទាំងនេះត្រូវបានដាក់ចេញផងដែរទៅដល់កងកម្លាំងជើងទឹក។ ប៉ាក សុខ៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/370.1** ទំព័រ ៤១-៤២ នៅម៉ោង 13.35.12។

[864]សារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៧៦ **ឯកសារ E3/893**, ERN FR 00386272 ; ព្រំ សារ៉ាត់ អាស្រ័យហេតុដូចនេះ អតីតមេបញ្ជាការកងទ័ពជើងទឹកនៃកងពលលេខ ១៦៤ មានចំណេះដឹងលម្អិតអំពីទីតាំងភូមិសាស្ត្រទាំងអស់នៃកោះនៅសម័យនោះ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/382.1** ទំព័រ ៤ ក្រោយម៉ោង 10.39.09។

[865]កំណត់ហេតុប្រជុំនៃគណអចិន្ត្រៃយ៍ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ **ឯកសារ E3/229**, ERN FR 00334958។ តាមរយៈឧទាហរណ៍នេះ គឺពិតជាកងកម្លាំងវៀតណាមដែលបានចូលមកក្នុងទឹកដីកម្ពុជាដោយហេតុថា ពួកវាកាន់កាប់ជាពិសេសបន្ទាយទាហានចាស់របស់ លន់ នល់។ ពាក់ព័ន្ធនឹងការរំកិលបង្គោលព្រំដែន សូមមើល៖ របាយការណ៍របស់គណអចិន្ត្រៃយ៍នៃតំបន់ ២៣ (កែវ អាន) ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ **ឯកសារ E3/1019**, ERN FR 00588787 អៀង ផានបានលើកឡើងអំពីការហេតុការណ៍ដែលកើតឡើងនៅដើមឆ្នាំ ១៩៧៧ នៅខេត្តតាកែវ៖ ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ២៣-២៤ ប្រហែលម៉ោង 10.10.56។

៧៨៨. ពីខែ មករា ដល់ខែ ធ្នូ ឆ្នាំ ១៩៧៦ មានការប៉ះទង្គិចគ្នាជាប្រចាំ[866] ប៉ុន្តែច្បាស់ណាស់ សេចក្តីណែនាំនៅតែឱ្យស្វែងរកដំណោះស្រាយនយោបាយ មុនពេលប្រយុទ្ធគ្នា[867]។ របាយការណ៍របស់ ឈិន មកពីកងពល ៩២០ ឈរជើងនៅព្រំដែនខេត្តមណ្ឌលគិរី ផ្តល់នូវសេចក្តីណែនាំក្នុងគោលដៅនេះជាបន្តបន្ទាប់អស់រយៈពេលជាច្រើនសប្តាហ៍ និងធ្វើឱ្យយើងយល់អំពីការវិវត្តនៃសភាពការណ៍ ដោយមានព័ត៌មានលម្អិតច្បាស់លាស់អំពីគោលជំហររបស់កងទ័ពទាំងពីរ និងការប៉ុនប៉ងចរចាគ្នាទៅវិញទៅមក។ យើងត្រូវតែអានឯកសារទាំងនេះ តាមលំដាប់កាលប្បវត្តិ ពីព្រោះសារទូរលេខ និងរបាយការណ៍ដែលអានក្រៅបរិបទ អាចនាំឱ្យមានការភាន់ច្រឡំ។ ឧទាហរណ៍ ការវាយប្រហារ ដែលបានលើកឡើង នៅពេលណាមួយ ក្នុងឯកសារមួយ អាចចាត់ទុកថាជាការវាយប្រហារពីខាងកម្ពុជា ផ្ទុយទៅវិញប្រសិនបើយើងពិនិត្យផ្នែកផ្សេងទៀតនៃឯកសារ ឬឯកសារមុនមួយផ្សេងទៀត យើងដឹងថា តាមពិត មានកាលប្បវត្តិដែលអាចឱ្យសន្និដ្ឋានថាមានការវាយបក។

៧៨៩. នៅខែ កុម្ភៈ ឆ្នាំ ១៩៧៦ ឈិន បានរាយការណ៍ដូចតទៅ៖

> **ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦៖** "នៅម៉ោង ១០ និង ៣០ នាទីព្រឹក នាថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ នេះ ពួក ៧ បាននាំទ័ព និងសម្ភារៈ មានកន្ទេល ខ្មៅយ មកបោះទ័ពត្រង់អូរដាំបាយ និងអូរព្រុល និងពីដើមថ្នល់ដល់ពូឌី ប្រមាណគ្នា ៥៥ នាក់ ដោយមានអាវុធគ្រប់ដៃ គ្រប់ចុន ដូចយើងដែរ ហើយមានមេបញ្ជាការ ៦ នាក់ អាហៀង និងអាធឿង ក្រៅពីនេះ ឥតស្គាល់ទេ។ <u>កន្លងមក ពីថ្ងៃទី ១៥ ខែ កុម្ភៈ ដល់ថ្ងៃទី ២១ ខែ កុម្ភៈ នេះ យើងបានតស៊ូនយោបាយជាប់</u> តែមិនសម្រេច។ ឥឡូវនេះ យើងខ្ញុំក៏បានរៀបចំផែនការវាយវាតែម្តង" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[868]។
>
> **ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៦៖** "យើងខ្ញុំសូមរាយការណ៍អំពីសភាពការណ៍នៅព្រំដែន ដូចខាងក្រោមនេះ៖ ១- ចំពោះមុខសញ្ញាពួកវាក់ ចាប់ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ពួក ៧ បានចូលមកដីយើង

---

[866] ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ជាអតីតយោធានៃអង្គភាពពិសេសឈរជើងនៅព្រំដែនវៀតណាមបានរៀបរាប់ជាពិសេសអំពីការប្រយុទ្ធយ៉ាងតានតឹងនៅក្នុងខេត្ត ស្វាយរៀង។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/445.1** ទំព័រ ១២-១៤ ចន្លោះម៉ោង 09.39.54 **និង** 09.44.11 ; ទំព័រ ៧០ មុនម៉ោង 15.12.30 ; ទំព័រ ៧១ ក្រោយម៉ោង 15.15.38 ; ទំព័រ ៧២ នៅម៉ោង 15.17.08 ; ទំព័រ ៤៧ នៅម៉ោង 13.39.24។

[867] សារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យផ្ញើចេញពី ០៥ ទៅបង ៨៩ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៧៦ **ឯកសារ E3/887**។

[868] របាយការណ៍របស់ ឈិន Rapport de Chhin ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ **ឯកសារ E3/1020**, ERN FR 00711511។

ចម្ងាយ ២ គ.ម ត្រង់អូរដាង ដោយមានគ្នា ៦០ នាក់ ក្នុងនោះ មានអាវុធអាអ៊ែរ-១៥ ធីណែ និងបេ-៤០ យើងបានកម្ទេចអស់ដោយគ្រាប់បែកដៃ។ កន្លងមក យើងបានតស៊ូនយោបាយ តែពួកនេះមិនព្រមដកថយទេ ដល់ថ្ងៃទី ២៥ ខែ កុម្ភៈ យើងខ្ញុំបានរៀបចំវាយ អស់ពេលមួយយប់មួយថ្ងៃ តែពួកនេះមិនព្រមដកថយទៀត [...] ពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ យើងបានធ្វើការតាមព្រំដែនខាងយើង ខាងជើងអូរ ពីកូនរកទៅពួតរាក់ ស្រាប់តែពួក ៧ ព័ទ្ធចាប់យើង តែយើងគេចរួច ហើយនៅម៉ោង ១១ និង ៣០ នាទីព្រឹក យើងចាប់ផ្ទុះអាវុធ ពួក ៧ ក៏រត់ចូលដីវាវិញ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[869]។

៧៩០. ក្រុម ៧ ជាអង្គភាពទាហានវៀតណាម ត្រូវបានចាត់តាំងឱ្យទៅវាយប្រហារនៅតាមព្រំដែន ហើយត្រូវបានលើកឡើងជាទៀងទាត់ នៅក្នុងរបាយការណ៍នានារបស់ ឈិន ថាជាអ្នកវាយប្រហារនៅលើទឹកដីកម្ពុជា ដោយចេតនា។ អន្តរាគមន៍របស់កងទ័ពបដិវត្តន៍កម្ពុជា ជាការតបត ឬរៀបចំការតបតជាយថាហេតុ[870]។

៧៩១. នៅខែ មីនា ឆ្នាំ ១៩៧៦ កំណត់ហេតុមួយនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បានគូសបញ្ជាក់ជាថ្មី អំពីភាពចាំបាច់ក្នុងការធ្វើសកម្មភាពនៅលើសមរភូមិចរចានយោបាយ ទោះបីត្រូវការពារខ្លួនពីការវាយប្រហារ ជាអាទិ៍ នៅរតនគិរី តាកែវ និងក្រចេះ ក៏ដោយ[871]។ ទង្វើនេះមិនគ្រាន់តែផ្ទុះបញ្ចាំងពីឆន្ទៈ

---

[869]របាយការណ៍របស់ ឈិន ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ **ឯកសារ E3/8373**, ERN FR 00283108។ របាយការណ៍នេះគ្រាន់តែបានដកស្រង់ដោយផ្នែកតែប៉ុណ្ណោះដោយព្រះរាជអជ្ញានៅក្នុងសវនាការស្ដីអំពីឯកសារគន្លឹះដោយគាត់បានលើកឡើងពីការវាយប្រហារទៅលើទាហានវៀតណាមចំនួន ៦០ នាក់ ដោយកងទ័ពបដិវត្តន៍កម្ពុជាដោយរំលងចោលនៅផ្នែកដែលមានបញ្ជាក់ថា ទាហានវៀតណាមទាំងនេះមានបំពាក់អាវុធយ៉ាងក្រាស់ក្រែល ហើយស្ថិតនៅក្នុងទឹកដីកម្ពុជា ហើយព្រះរាជអជ្ញារំលងចោលមិនព្រមប្រាប់ថាការវាយប្រហារនេះកើតឡើងក្រោយហើយទេដោយមូលហេតុខាងលើ។ ( ប្រតិចារឹក ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/495.1** ទំព័រ ១៣ ក្រោយម៉ោង 09.43.55 (សំណៅជាភាសាអង់គ្លេស))។

[870]របាយការណ៍របស់ ឈិន ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៧៦ **ឯកសារ E3/923**, ERN FR 00623151 (យើងជាអ្នកគូសបន្ទាត់ពីក្រោម). សំណៅជាភាសាអង់គ្លេស់នេះមានកំហុសនៅត្រង់លេខ l'ERN EN 00185238 ដោយហេតុថា នៅត្រង់នេះមានបញ្ជាក់ថាកងកម្លាំងរបស់កងទ័ពបដិវត្តន៍កម្ពុជា "ទំនងជាបានរុញច្រានពួកគេឱ្យថយក្រោយមួយគីឡូម៉ែត្រនៅក្នុង[ទឹកដីរបស់ពួកគេ]"។ ពាក្យពេចន៍ដែលស្ថិតនៅក្នុងឃ្នៀបជាភាសាអង់គ្លេសមិនមានទាំងនៅក្នុងសំណៅជាភាសាបារាំង ទាំងសំណៅជាភាសាខ្មែរដែលជាច្បាប់ដើម។ លើសពីនេះទៅទៀតមានបញ្ជាក់យ៉ាងច្បាស់នៅក្នុងផ្នែកដែលគូសបន្ទាត់ពីក្រោមនូវសម្រង់ដែលដកស្រង់ជាភាសបារាំង៖ ខ្មាំងបានឈរជើងជាថ្មីម្ដងទៀតនៅលើទឹកដីយើងដោយយើងដឹងអំពីទីតាំងដែលពួកគេឈរជើងយ៉ាងច្បាស់។ ដូច្នេះការអន្តរាគមន៍របស់កម្ពុជាជាការការពារទឹកដីជាតិយ៉ាងច្បាស់លាស់។ របាយការណ៍របស់ ឈិន ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៧៦ **ឯកសារ E3/1022**។

[871]កំណត់ហេតុប្រជុំនៃគណអចិន្ត្រៃយ៍ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦ **ឯកសារ E3/217**, ERN FR 00334965. **សូមមើល** 2-

សន្តិភាពនិយមរបស់កម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ តែថែមទាំងផ្ទុះបញ្ចាំងពីការដឹងជ្រួតជ្រាបរបស់ពួកគេ ថាកម្លាំងរបស់កងទ័ពបដិវត្តន៍កម្ពុជាមិនខ្លាំងដូចកម្លាំងទ័ពរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងការប្រយុទ្ធទ្រង់ទ្រាយធំ នោះឡើយ។ ការលើកឡើងអំពីការរៀបចំកម្លាំង និងការចំណេញពេលវេលា តាមរយៈការបន្តការចរចា "ក្នុងលក្ខណៈមិត្តភាព" បង្ហាញថា គណៈអចិន្ត្រៃយ៍ដឹងខ្លួនថាគ្មានចំណេញអ្វីទេ បើតតាំងគ្នានោះ។

៧៩២. ប៉ុន្តែ ការចរចាបានជួបប្រទះការលំបាក ដូចមានបញ្ជាក់នៅក្នុងឯកសារឆ្នាំ ១៩៧៦ ជាពិសេសដោយសារតែការវាយប្រហារនៅជិតព្រំដែន[872]។ ទោះជាយ៉ាងនេះក្តី ការលំបាកទាំងនេះមិនបានរារាំងកម្ពុជាប្រជាធិបតេយ្យមិនឱ្យបន្តចេញសេចក្តីណែនាំឱ្យជជែកគ្នានៅលើសមរភូមិ ក្នុងពេលការចរចាបន្តធ្វើនៅថ្នាក់កំពូល។ ជាក់ស្តែង នៅខែ ឧសភា ឆ្នាំ ១៩៧៦ សុន សេន បានលើកឡើងក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍អំពី "សេចក្តីណែនាំរបស់បក្ស" ដាច់ខាតមិនឱ្យ "តឹងតែង" ទោះបីជាមានការវាយប្រការជាបន្តពីសំណាក់វៀតណាមក៏ដោយ[873]។ នៅក្នុងសវនាការ ពេលសួរអំពីសម្តីរបស់ សុន សេន សាក្សី សៅ សារុន ដែលប្រយុទ្ធនៅខេត្តមណ្ឌលគិរី បានបញ្ជាក់អះអាងអំពីការវាយប្រហារមិនឈប់ឈរពីសំណាក់វៀតណាម ក្នុងពេលចរចា[874]។ គាត់បានបញ្ជាក់ពីមុនថា "វៀតណាមជាអ្នកវាយមុន"[875]។ ទោះជាយ៉ាងណាក៏ដោយ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យនៅតែ

---

TCW-1005, ដែលជាទាហានបញ្ជូនទៅសមរភូមិបូព៌ានៅឆ្នាំ ១៩៧៦ : ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/449.1** ទំព័រ ៤២-៤៣ នៅម៉ោង 11.23.21 ; ទំព័រ ៤៤ មុនម៉ោង 11.28.40។

[872] ជិន សារឿន, អតីតប្រធានកងអនុសេនាធំនៃវរសេនាធំលេខ ៩៣ នៃកងពល ៩២០ ដែលឈរជើងនៅមណ្ឌលគិរី នៅឆ្នាំ ១៩៧៦ ក្រោមបញ្ជាការរបស់ ឈិន ហើយ សាយ បានផ្តល់សក្ខីកម្មលើស្ថានការណ៍នៅក្នុងតំបន់នេះ៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/454.1** ទំព័រ ៥ ក្រោយម៉ោង 09.13.27 ៖ "នៅពេលខ្ញុំនៅក្នុងកងពល ៩២០ គេមិនឲ្យកាំភ្លើងខ្ញុំកាន់ទេ។ គឺទាល់តែពេលខ្ញុំផ្ទេរទៅមណ្ឌលគិរីហើយទេ ដែលគេឲ្យកាន់។ នៅពេលនោះ វៀតណាមបានឈ្លានពានលើទឹកដីកម្ពុជា ហើយយើងដែលជាកងទ័ពនៅក្នុងតំបន់នោះបានត្រូវបំពាក់អាវុធ" កំណត់ហេតុប្រជុំនៃគណអចិន្ត្រៃយ៍ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៧៦ **ឯកសារ E3/218**, ERN FR 00334969។ (នៅក្នុងសវនាការស្តីពីឯកសារគន្លឹះ ព្រះរាជអាជ្ញាបានប្រើកំណត់ហេតុនេះ ប៉ុន្តែមិនបានបញ្ជាក់អំពីគោលជំហររបស់វៀតណាម និងឆន្ទៈចរចារដោយដកស្រង់ចម្លើយរបស់អ្នកតំណាងឲ្យកម្ពុជាប្រជាធិបតេយ្យ និងដកស្រង់ការព្រួយបារម្ភរបស់ភាគីកម្ពុជា (T. 03.11.16 **ឯកសារ E1/495.1** ទំព័រ ១៨ ក្រោយម៉ោង 09.45.58 (សំណៅជាភាសាអង់គ្លេស))។

[873] កំណត់ហេតុប្រជុំគណអចិន្ត្រៃយ៍ ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៦ **ឯកសារ E3/221**, ERN FR 00386178។

[874] សៅ សារុន : T. 30.03.16 **ឯកសារ E1/411.1** ទំព័រ ៥-៦ ប្រហែលម៉ោង 09.13.40។

[875] សៅ សារុន : T. 30.03.16 **ឯកសារ E1/411.1** ទំព័រ ៥-៦ ប្រហែលម៉ោង 09.10.00។

សង្ឃឹមថាការចរចានឹងវិវត្តទៅមុខ។ ក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នៅដំណាច់ខែ ឧសភា ឆ្នាំ ១៩៧៦ គេបានកត់សម្គាល់ឃើញនូវ "ដំណើរវិវត្តទៅរកភាពល្អប្រសើរ"[876]។

## ២. ការប្រយុទ្ធកាន់តែមានសភាពខ្លាំងឡើង

៧៩៣. ទោះជាយ៉ាងណាក៏ដោយ ជម្លោះនៅតាមកន្លែងនានាបន្តរីកធំឡើងៗ។ របាយការណ៍ស្តីពីសភាពការណ៍យោធា ពីថ្ងៃទី ១៥ ខែ កក្កដា ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៧៦ បានរៀបរាប់លម្អិតអំពីការប្រយុទ្ធគ្នា នៅខេត្តមណ្ឌលគិរី និងនៅភូមិភាគបូព៌ា និងលើកឡើងពីសកម្មភាពរបស់វៀតណាមជាប្រចាំ[877]។ កងពល ៩២០ តែងតែនិយាយអំពីក្រុម ៧ នៅក្នុងរបាយការណ៍ និងកំណត់ហេតុប្រជុំរបស់ខ្លួន។ ចំណុចនេះអាចឱ្យសន្និដ្ឋានថា ក្រុម ៧ ជាអង្គភាពវៀតណាម ដែលធ្វើសកម្មភាពយ៉ាងសកម្មនៅតំបន់ព្រំដែន។

៧៩៤. ភ័ស្តុតាងដែលបង្ហាញអំពីការចូលក្នុងទឹកដីកម្ពុជារបស់អង្គភាពនេះ មានសារៈសំខាន់ដែលត្រូវលើកឡើង ដើម្បីជំទាស់ទៅនឹងគំនិតដែលថា កងទ័ពបដិវត្តន៍កម្ពុជាចូលលុកលុយក្នុងទឹកដីវៀតណាម ដើម្បីវាយប្រហារដោយគ្មានហេតុផលទៅលើជនស៊ីវិល ដូចដែលសហព្រះរាជអាជ្ញាបានអះអាង ពេលសួរដេញដោលលោក Stephen MORRIS[878] ឬក្នុងពេលចៅក្រម Jean-Marc LAVERGNE ប្រើប្រាស់សារទូរលេខ ដោយសម្រិតសម្រាំងយកតែឯកសារដាក់បន្ទុក ដើម្បីមកសួរដេញដោលសាក្សី 2-TCW-1065[879]។ ឧទាហរណ៍នេះបង្ហាញឱ្យឃើញនូវកង្វះអនាគតិរបស់អង្គជំនុំជម្រះ ដែលបណ្តាលឱ្យមានការសម្រេចហួសពីសេចក្តីពិត ក្នុងអំឡុងពេលជំនុំជម្រះក្តី[880]។

---

[876]កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៧៦ **ឯកសារ E3/794**, ERN FR 00611617-18.

[877]របាយការណ៍ស្តីពីស្ថានការណ៍នៅចន្លោះ ថ្ងៃទី ១៥ កក្កដា និង ថ្ងៃទី ៣១ សីហា ដែលមិនមានដាក់កាលបរិច្ឆេទ **ឯកសារ E3/9289,** ERN FR 01248463-65 ;

[878]Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៥៧-៥៨ ចាប់ពីម៉ោង 13.56.54។

[879]2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1,** ទំព័រ ១១ និង ទំព័របន្ទាប់, ចាប់ពីម៉ោង 09.35.16។បន្ទាប់ពីប្រគល់មុនហ្នឹងមួយថ្ងៃនូវឯកសារមួយបាច់ ដែលសំខាន់ណាស់ត្រូវតែគូសបញ្ជាក់ថាសាក្សីមិនស្គាល់ថាឯកសារទាំងអស់នេះនៅសម័យអង្គហេតុ ចៅក្រម LAVERGNE បានព្យាយាមឱ្យគាត់ពិព័រនាអំពីការវាយប្រហារ "ទៅលើបន្ទាយលេខ ២៧"សន្មតជាមុនថានៅលើទឹកដីវៀតណាម ហើយដែលមានរៀបរាប់នៅក្នុងសារទូរលេខរបស់ ឆុន ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៧៧ **ឯកសារ E3/891**។ សាក្សីរូបនេះមិនអាចនិយាយច្រើនបានទេ អំពីព្រឹត្តិការណ៍ដែលខ្លួនមិនបានឃើញ (ទំព័រ ២០

៧៩៥. ទោះបីជាចៅក្រម Jean-Marc LAVERGNE បានប្រគល់ជូនសាក្សី 2-TCW-1065 នូវឯកសារសម័យនោះមួយបាច់ ដែលសាក្សីមិនធ្លាប់ឃើញ[881] ក៏គាត់មិនអាចទទួលបានចម្លើយដែលខ្លួនចង់បាន ពាក់ព័ន្ធនឹងការចូលលុកលុយរបស់កងទ័ពបដិវត្តន៍កម្ពុជាទៅក្នុងទឹកដីវៀតណាមនោះឡើយ។ ជាក់ស្តែង សាក្សី 2-TCW-1065 ជាប្រធានក្រុមពេទ្យនៃមន្ទីរពេទ្យចល័ត ១៥៦ នៃកងពលលេខ ៤ របស់ភូមិភាគបូព៌ា ពីឆ្នាំ ១៩៧៧ ដល់ខែ ឧសភា ឆ្នាំ ១៩៧៨[882] បានអះអាងថា ក្រុមពេទ្យរបស់គាត់ស្ថិតនៅ "ឆ្ងាយ" ពីសមរភូមិ[883] ហើយគាត់ "មិនចូលរួមក្នុងការប្រយុទ្ធទេ"[884]។ ម្យ៉ាងវិញទៀត គាត់មិនធ្លាប់ចូលរួមកិច្ចប្រជុំរបស់កងពល "ទាល់តែសោះ"[885]។

៧៩៦. ប្រឈមមុខនឹងសំណួរជាច្រើនរបស់ចៅក្រមរូបនេះ សាក្សី 2-TCW-1065 បង្ខំចិត្តទទួលស្គាល់ថាគាត់ "មិនដឹងទាល់តែសោះ" អំពីយុទ្ធសាស្ត្រយោធា[886] និងបានអះអាងថាគាត់មិនធ្លាប់ទៅទីតាំង

---

ទំព័របន្ទាប់ ចន្លោះម៉ោង 09.48.53 និង 09.52.12)។ ទោះយ៉ាងណាក្តីនៅពេលសួរចម្លើយដោយមេធាវីការពារក្តី សាក្សីរូបនេះនឹកឃើញថា មុនពេលវាយប្រហារលើបន្ទាយលេខ ២៧ មានការវាយប្រហារអំពីសំណាក់វៀតណាមនៅតាមព្រំដែន៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/497.1** ទំព័រ ១៨-១៩ ប្រហែលម៉ោង 09.40.18។

[880] ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ១០ ក្រោយម៉ោង 09.30.45។

[881] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ១១-១២ ម៉ោង 09.37.42។ សាក្សីមានការដឹងលឺយ៉ាងតិចបំផុតអំពីឯកសារដែលដាក់បង្ហាញដល់គាត់នៅក្នុងសាលសវនាការ រហូតដល់ថ្នាក់គាត់ហ៊ានប្រកាសថា វាជាឯសារក្លែងក្លាយ ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ ទំព័រ ៧៣ E1/493.1** ប្រហែលម៉ោង 15.37.32. គាត់ក៏បានគាំទ្រផងដែរថា ឌុន មិនមែនមានឈ្មោះហៅក្រៅថា សោ ភឹម នោះទេ ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ៧៧ មុនម៉ោង 15.57.34. ក្រោយមកទៀត សាក្សីរូបនេះក៏បានប្រកាសផងដែរថា៖ "អង្គភាពរបស់ខ្ញុំត្រូវសង្គ្រោះជីវិតមនុស្ស។ ដោយអាស្រ័យហេតុដូចនេះហើយបានយើងមានព័ត៌មានតិចតួចណាស់។ ហើយយើងមិនបានទទួលទស្សនាវដ្តី ឬក៏ឯសារអ្វីនោះទេ។ យើងមិនបានទទួលដំណឹងអ្វីទាំងអស់។ ( ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ៥០ ប្រហែលម៉ោង 14.10.03)។

[882] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/497.1** ទំព័រ ៤-៥ មុនម៉ោង 09.09.39។

[883] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ៤ ប្រហែលម៉ោង 09.12.15។

[884] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ៣២ ប្រហែលម៉ោង 11.09.15។

[885] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/496.1** ទំព័រ ៧៣ ប្រហែលម៉ោង 15.58.47, ប្រតិចារឹក ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/497.1** ទំព័រ ៦ ប្រហែលម៉ោង 09.12.53។

[886] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ១៥ ប្រហែលម៉ោង 09.52.12 ទំព័រ ១៧ ក្រោយម៉ោង 09.58.52. ដូច្នេះសាក្សីនៅតែចចេះបិទភ្នែកធ្វើការសន្និដ្ឋាន៖ ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯក**

បន្ទាយ ២៧ ដែលសហព្រះរាជអាជ្ញា និងចៅក្រម Jean-Marc LAVERGNE ចាប់អារម្មណ៍នោះដែរ[887]។ នៅពេលឆ្លើយទៅនឹងសំណួររបស់ក្រុមមេធាវីការពារក្តី សាក្សីបានបញ្ជាក់ថាលទ្ធផលនៃការវាយគ្នា គឺថា "កងទ័ពវៀតណាមបានដកថយ" ក្រោយពីបានប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញនៅតាមព្រំដែន[888]។

៧៩៧. អ្នកជំនាញ Philip SHORT បានឆ្លើយក្នុងសវនាការលើសំណុំរឿង ០០២/០១ ថា "មានកម្លាំងទាំងសងខាង។ កម្ពុជាលុកលុយចូលវៀតណាម ហើយវៀតណាមលុកលុយចូលកម្ពុជា"[889]។ ទោះជាយ៉ាងនេះក្តី នៅពេលសហព្រះរាជអាជ្ញាសួរដេញដោលទៅលើអត្ថបទសារព័ត៌មានមួយស្តីពីការលុកលុយចូលទឹកដីវៀតណាម និងឃ្លាមួយនៃសៀវភៅរបស់ Ben KIERNAN ចំពោះប្រធានបទដដែលនេះ អៀង ផាន មេបញ្ជាការកងពលតូច បានបញ្ជាក់ថា៖

> "ការប្រយុទ្ធគ្នានេះ វាមានទៅមានមក ប៉ុន្តែឱ្យខាងខ្ញុំចូលទៅជ្រៅ អត់ចូលទៅបានទេ ឧបមាព្រែកជីកវិញទេ ចូលបានតែ ១០០-២០០ ម៉ែត្រទេ ត្រូវវៀតណាមវ៉ៃថយមកវិញហើយ ព្រោះវៀតណាមច្រើនណាស់"[890]។

> "ខ្ញុំមានយោបល់ទាក់ទងនឹងរបាយការណ៍ដែលបានមកពីខាងវៀតណាមអម្បាញ់មិញ។ ខ្ញុំជឿជាក់ថារបាយការណ៍នេះ ខ្ញុំយល់ឃើញថាដូចជាមិនពិតប្រាកដ ពីព្រោះខ្ញុំនៅកន្លែងជាក់ស្តែង គឺខាងខ្ញុំមិនមានសិទ្ធិវ៉ៃចូលដល់អានយ៉ាងអី មិនមានទេ ខាងទ័ពនិរតីហ្នឹង ពិសេស វរសេនាធំខ្ញុំហ្នឹង គឺមិនមានសិទ្ធិវាយចូលជ្រៅម្ល៉ឹងៗអត់ទេ។ អ៊ីចឹង របាយការណ៍នេះ ខ្ញុំមិនយល់ថាយ៉ាងម៉េចទេ អាហ្នឹង សូមលោកប្រធានពិនិត្យឡើងវិញចុះ ប៉ុន្តែ ជាក់ស្តែង គឺថា មិនមានសិទ្ធិវ៉ៃចូលជ្រៅម្ល៉ឹងទេ បានតែត្រឹមកៀកៗព្រំដែនទេ"[891]។

---

**សារ E1/493.1** ទំព័រ ៥៩ មុនម៉ោង 14.30.35។

887 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ៥១-៥២ ក្រោយម៉ោង 14.17.56។

888 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ១២ ប្រហែលម៉ោង 09.40.18, ឆ្លើយតបទៅនឹងសំនួររបស់មេធាវីការពារក្តីស្តីអំពីសារទូរលេខរបស់ នុន ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៧៧ **ឯកសារ E3/981**, ERN FR 00386265. ទាក់ទងនឹងប្រធានបទនេះ, សូមមើលនូវកថាខណ្ឌ : 2-TCW-1005 : ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/449.1** ទំព័រ ៤៤ មុនម៉ោង 11.28.40។

889 Philip SHORT : ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ **ឯកសារ E1/192.1** ទំព័រ ៧៩-៨០ ប្រហែលម៉ោង 15.39.05 ។ ទាក់ទងនឹងការចោទប្រកាន់គ្នាទៅវិញទៅមកនៅតាមវិទ្យុ សូមមើលសក្ខីកម្មរបស់ IENG Phan : ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៧៨ ប្រហែលម៉ោង 16.00.16។

890 អៀង ផាន : ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ២០ ប្រហែលម៉ោង 10.16.40។

891 អៀង ផាន : ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ២៥ ក្រោយម៉ោង 10.44.22។

៧៩៨. នៅពេលសួរដេញដោលទៅលើអត្ថបទសារព័ត៌មានដដែល ដែលលើកឡើងអំពីការលុកលុយរបស់កងពល ៣៤០[892] ជួន ធី ក៏បានប្រកែកផងដែរ។ គាត់បានអះអាងថា វាមិនអាចទៅរួចទេ ដែលសារព័ត៌មានស្គាល់លេខកងពលទើបនឹងបង្កើតថ្មីនោះ[893] និងជាពិសេស គាត់មិនធ្លាប់ចូលទៅទឹកដីវៀតណាមទេ[894]។

៧៩៩. សៅ ម៉ាំង ជាប្រធានកងអនុសេនាធំ ដែលមានកូនទាហាន ១០០ នាក់ ឈរជើងនៅសែនមនោរម្យ ស្រុកអូរាំង និងដាក់ដាំ តំបន់ ១០៥ ខេត្តមណ្ឌលគិរី[895]។ កងអនុសេនាធំរបស់គាត់ត្រូវបានចាត់តាំងឱ្យទៅយាមព្រំដែន នៅដាក់ដាំ ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩[896] នៅមិនឆ្ងាយប៉ុន្មានពីកងពល ៩២០ ហើយពួកគេសហការគ្នា[897]។ គាត់បានរៀបរាប់ថា ការប្រយុទ្ធគ្នា នៅដាក់ដាំ បានចាប់ផ្ដើមនៅឆ្នាំ ១៩៧៥ និងកើតឡើងញឹកញាប់ នៅឆ្នាំ ១៩៧៨[898]។ សៅ ម៉ាំង បាននិយាយអំពីសេចក្ដីណែនាំដែលគាត់ទទួលបានសម្រាប់កូនទាហានរបស់គាត់៖ “បើគេចូលមកទឹកដីយើង អាហ្នឹងយើងក៏ប្រយុទ្ធគ្នាទៅ បើអត់ចូល ក៏យើងនៅតែដីយើងទៅ”[899]។

៨០០. ការបង្ហិតបង្គោលព្រំដែនតែងតែជាប្រភពនៃការប៉ះទង្គិចគ្នា[900]។ ទោះជាយ៉ាងនេះក្ដី នៅខែ កញ្ញា ឆ្នាំ ១៩៧៦ មានសេចក្ដីណែនាំយោធាច្បាស់លាស់ណាស់។ ត្រូវបញ្ចៀសការប្រឈមមុខដាក់គ្នា ប៉ុន្តែ ត្រូវការពារទឹកដី ក្នុងករណីកងទ័ពវៀតណាមចូលមក[901]។ ដូច្នេះ ត្រូវតែតបត។ អៀង ផាន

[892]របាយការណ៍របស់ VNA ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៧៨ **ឯកសារ E3/1608**, ERN FR 00793493-94។

[893]ជួន ធី : ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ៤១ ប្រហែលម៉ោង 11.28.26។

[894]ជួន ធី : ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ៣៩ ប្រហែលម៉ោង 11.22.58។

[895]SOV Maing : ប្រតិចារឹក ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/491.1** ទំព័រ ៧ ប្រហែលម៉ោង 09.22.23។

[896]SOV Maing : ប្រតិចារឹក ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/491.1** ទំព័រ ១២ មុនម៉ោង 09.40.43។

[897]SOV Maing : ប្រតិចារឹក ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/491.1** ទំព័រ ១២ ប្រហែលម៉ោង 09.43.49។

[898]SOV Maing : ប្រតិចារឹក ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/491.1** ទំព័រ ១៦ ប្រហែលម៉ោង 09.58.06 ទំព័រ ១៧ មុនម៉ោង 10.01.43។

[899]SOV Maing : ប្រតិចារឹក ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/491.1** ទំព័រ ៣៤ ប្រហែលម៉ោង 11.19.00 ; សូមមើល ទំព័រ ៣៥ ក្រោយម៉ោង 11.23.39។

[900]កំណត់ហេតុប្រជុំរបស់កងពលលេខ ៩២០ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៧៦ **ឯកសារ E3/805**, ERN FR 00315068។

[901]កំណត់ហេតុប្រជុំកងពលលេខ ៩២០ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៧៦ **ឯកសារ E3/799**, ERN FR 00323917។

បានបញ្ជាក់អះអាងសម្ដីរបស់ មាស វឿន ដែលថា គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ នៅសម័យនោះ គឺ "មិនបង្កបញ្ហា"[902]។ ប៉ុន្តែ សភាពការណ៍ចេះតែមានសភាពធ្ងន់ធ្ងរទៅៗ។

## ផ្នែកទី ២. ជម្លោះឡើងកម្ដៅខ្លាំង ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨

៨០១. ការចុះសម្រុងគ្នាក្នុងបរិយាកាសស្និទ្ធស្នាល នៅឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៦ បានទទួលបរាជ័យ។ ឆ្នាំ ១៩៧៧ ជាឆ្នាំដែលមានការលុកលុយកាន់តែញឹកញាប់ទៅក្នុងទឹកដីសត្រូវ ជាមួយនឹងចំណុច របត់ (១) ដែលបង្កើតឡើងដោយការឈ្លានពានរបស់វៀតណាមនៅខែធ្នូ និងការចាប់ផ្ដើមសង្គ្រាម ជាចំហ ដោយសារតែការឈ្លានពាននេះ (២)។

### ១. ការលុកលុយកាន់តែញឹកញាប់ និងចំណុចរបត់ នៅឆ្នាំ ១៩៧៧

៨០២. នៅឆ្នាំ ១៩៧៧ ការប្រយុទ្ធគ្នាកាន់តែញឹកញាប់ ដូចការចូលលុកលុយក្នុងទឹកដីកម្ពុជាដែរ។ របាយការណ៍ និងសារទូរលេខជាច្រើន បានលើកឡើងអំពីការពើបប្រយុទ្ធគ្នាកាន់តែច្រើនឡើងៗ[903] ដូចការការបញ្ជាក់អះអាងរបស់សាក្សីជាច្រើន នៅក្នុងសវនាការ។ ក្នុងចំណោមនោះ សាក្សី 2-TCW-1005 គឺជាទាហានចាត់តាំងទៅសមរភូមិបូព៌ា តាំងពីឆ្នាំ ១៩៧៦ នៅក្នុងកងពល ១១៧

---

[902] <u>IENG Phan</u>, ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៧៥ ប្រហែលម៉ោង 15.49.34, បញ្ជាក់អំពី មាស វឿន៖ កិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១០ **ឯកសារ E3/8752**, ERN FR 001309292-93។

[903] សូមមើលជាអាទិ៍៖ របាយការណ៍ស្ដីពីស្ថានការណ៍ខ្មាំងនៅតាមបណ្ដោយព្រំដែនខាងកើត ចុះខែមេសា ឆ្នាំ១៩៧៧ **ឯកសារ E3/852**, ERN FR 00386227-231, តាមរបាយការណ៍នេះមានលើកឡើងអំពីសកម្មភាពនិងការប៉ះទង្គិចគ្នានៅខាងស្វាយរៀង ការផ្ទោងដាក់គ្នាក៏ដូចជាការប៉ះទង្គិចផ្សេងទៀត នៅខែមេសា ឆ្នាំ ១៩៧៧។ សូមមើល៖ កំណត់ហេតុរបស់ភូមិភាគនិរតី ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៧៧ **ឯកសារ E3/853**, ERN FR 00290267-271។ នៅក្នុងកំណត់ហេតុនេះមានលើកឡើងអំពីការវាយលុក និងការផ្ទោងរ៉ុក្កែតពីសំណាក់កងទ័ពវៀតណាមមកលើទឹកដីកម្ពុជានៅខែ មិថុនា ឆ្នាំ ១៩៧៧។ សូមមើលផងដែរនូវរបាយការណ៍របស់តំបន់ ២០ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៧៧ **ឯកសារ E3/854**, ERN FR 00386232 ដែលមានរៀបរាប់អំពីទីតាំងខ្មាំងនៅតាមបណ្ដោយព្រំដែននៃភូមិភាគបូព៌ា និងទីតាំងរបស់កងទ័ពនៃកម្ពុជាប្រជាធិបតេយ្យដែលរងរបួស។ នៅពេលលើកឡើងអំពីការវាយបកពីសំណាក់កម្ពុជា និងការបាត់បង់ខាងវៀតណាម មានបញ្ជាក់ថាពួកវៀតណាមបាន "លើក និងដឹកសាកសពរបហូតទៅដល់ទឹកដីរបស់ពួកគេ" នេះជាអ្វីដែលបញ្ជាក់ថាការប្រយុទ្ធគ្នាបានកើតមានឡើងនៅលើទឹកដីកម្ពុជា។

ស្ថិតក្រោមការទទួលខុសត្រូវរបស់សេនាធិការផ្ទាល់ គឺ ស៊ូ ម៉េត មាស មុត និងសុន សេន។ គាត់បានរៀបរាប់អំពីការប្រយុទ្ធគ្នា ក្នុងអំឡុងពេលនោះ[904]។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ នួន ប៉ែត ហៅ យុន គីម បាននិយាយអំពីកិច្ចប្រជុំមួយជាមួយតាម៉ុក នៅចុងឆ្នាំ ១៩៧៧ ដែលពេលនោះតាម៉ុកនិយាយអំពីការដោះដូរអ្នកទោសខ្មែរ ៣៣០ នាក់ ជាមួយអ្នកទោសវៀតណាម រវាងកងទ័ពទាំងពីរ នៅលើកោះពូលូវ៉ៃ ក្រោយពីវៀតណាមវាយចូលខេត្តកំពត[905]។ ទោះជាយ៉ាងនេះក្តី ការចរចាកាន់តែមានសភាពតានតឹងទៅៗ។ អៀង ផាន ឈរជើងនៅតាកែវ បានឆ្លើយក្នុងសវនាការថា "ចាប់ពីដើមឆ្នាំ ១៩៧៧ មក ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៧ ការប្រយុទ្ធគ្នារវាងកម្ពុជា និងវៀតណាម នៅតែបន្ត"[906] "ដោយសារតែបញ្ហាបូរណភាពដែនដី"[907]។

៨០៣. នៅក្នុងសារទូរលេខមួយ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៧ ការផ្លាស់ប្តូរយោបល់គ្នារវាង ឈាន និងគណៈប្រតិភូវៀតណាម ត្រូវបានលើកឡើង និងបង្ហាញអំពីការកើនឡើងនូវភាពតានតឹងនេះ។ ភាគីទាំងពីរចោទគ្នាទៅវិញទៅមកអំពីការវាយប្រហារ និងការកាប់សម្លាប់។ ចម្លើយពីខាងកម្ពុជាគួរឱ្យចាប់អារម្មណ៍ណាស់ ពីព្រោះតបទៅនឹងការស្តីបន្ទោសពីខាងវៀតណាមរឿងវាយប្រហារនៅថ្ងៃទី ១៤ ខែ មិថុនា ឈាន បាននិយាយអំពីការរំលោភបូរណភាពដែនដី និងការទម្លាក់គ្រាប់បែករបស់កងទ័ពវៀតណាមទៅលើប្រជាជន៖

---

[904] 2-TCW-1005 : ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/449.1** ទំព័រ ៥១ មុនម៉ោង 13.50.01 (ស្តីពីកងពល ១១៧) ទំព័រ ៤៨-៤៩ (ស្តីអំពីស្ថានការណ៍នៅក្រចេះ ពីឆ្នាំ ១៩៧៦ ដល់ ១៩៧៧) ទំព័រ ៤០ ប្រហែលម៉ោង 11.16.02 (ស្តីពីកន្លែងដែលកងទ័ពវៀតណាមយកជាគោលដៅ) ទំព័រ ៣៧ ក្រោយម៉ោង 11.07.14 ; ទំព័រ ៤១ ចន្លោះម៉ោង 11.17.58 និង 11.20.03 ; ទំព័រ ៤២ ប្រហែលម៉ោង 11.21.39 ; ទំព័រ ៦៦ ប្រហែលម៉ោង 14.33.41។

[905] កំណត់ហេតុស្តាប់ចម្លើយរបស់ នួន ប៉ែត ដែលមានឈ្មោះក្រៅ យុន គីម ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ **ឯកសារ E3/422**, ERN FR 00434801-02។ គាត់ក៏បានបញ្ជាក់ផងដែរថានៅក្នុងកិច្ចប្រជុំនេះដែលមានវត្តមាន សុន សេនដែរ អ្នកទទួលខុសត្រូវទាំងពីរនាក់បាននិយាយថា "វៀតណាមចង់បញ្ចូលប្រទេសកម្ពុជាទៅក្នុងសហព័ន្ធឥណ្ឌូចិន ដូច្នេះយើងត្រូវវាយបកទៅវៀតណាមវិញដើម្បីទប់ការវាយលុកចូលប្រទេសកម្ពុជានៅលេខ ERN FR 00434802 មានការរៀបរាប់អំពីការដោះដូរទាហានដូចគ្នាដោយ ហ៊ូ នឹម នៅពាក់កណ្តាលឆ្នាំ ១៩៧៧។

[906] IENG Phan : ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ២៦ ក្រោយម៉ោង 10.47.39។

[907] IENG Phan : ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ១៣ ប្រហែលម៉ោង 09.53.18 ; ទំព័រ១៥ ប្រហែលម៉ោង 09.59.03 "ជម្លោះបានចាប់ផ្តើមតាំងពីឆ្នាំ ១៩៧៧ ហើយការប្រយុទ្ធគ្នាកាន់តែខ្លាំងទៅៗ នៅក្នុងពាក់កណ្តាលឆ្នាំ ១៩៧៧។ យើងរុញគ្នាទៅវិញទៅមក។ ប៉ុន្តែយើងអាចរុញវៀតណាមបានដល់ត្រឹមតែប៉ុណ្ណោះ នៅព្រែកជីក វិញ តេ។ ប៉ុន្តែកងទ័ពវៀតណាមវិញអាចរុញយើងស្ទើររហូតដល់ត្រង់ខេត្តតាកែវ។"។

"យើងខ្ញុំមិនដែលនឹកឃើញចង់ឈ្លានពានប្រទេសណាទេ... កុំថាដល់ទៅឈ្លានពាន (ប៉ុន្តែគេទាំងឡាយប្តេជ្ញាដាច់ខាត ការពារឯករាជ្យ អធិបតេយ្យភាព និងបូរណភាពដែនដីរបស់ខ្លួន... ចំណែកឯរណ្តៅគ្រាប់បែកដែលកងទ័ពខាងសមមិត្តទម្លាក់គ្រាប់បែកសម្លាប់ប្រជាជនកម្ពុជាយើងខ្ញុំ ដែលកំពុងវាយសម្រុកយ៉ាងសស្រាក់សស្រាំធ្វើស្រែនោះ ខ្ញុំជឿជាក់ថា មិនទាន់រលុបងាយទេ។ នេះជាឧទាហរណ៍តែមួយ ខ្ញុំជូនសមមិត្ត)។ កាលណាខ្ញុំនិយាយដល់យន្តហោះនោះ គេដោះដៃទៅនិយាយពីអ្វីទៅវិញ"[908]។

៨០៤. ដូច្នេះ ភាគីនីមួយៗទម្លាក់ដាក់គ្នាទៅវិញទៅមក។ អស់រយៈពេលជាច្រើនសប្តាហ៍ ការចរចាកាន់តែក្លាយទៅជាការមិនស្តាប់គ្នា[909]។ នៅចុងខែ សីហា ឆ្នាំ ១៩៧៧ ឈាន បានសង្ខេបអំពីគោលជំហរផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យ ដូចគាត់បានរៀបរាប់ប្រាប់ដៃគូសន្ទនាវៀតណាម គឺគោរពទឹកដីវៀតណាម និងការពារទឹកដីផ្ទាល់របស់ខ្លួន[910]។

៨០៥. គួរកត់សម្គាល់ថា តួនាទីរបស់អ្នកទទួលខុសត្រូវភូមិភាគអាចមានភាពរឹងមាំខ្លាំងទៅលើដំណើរការនៃប្រតិបត្តិយោធាប្រចាំថ្ងៃ។ ឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងគ្នាបុគ្គលិកលក្ខណៈ និងបុព្វសិទ្ធិរបស់មេយោធា ដែលមានសិទ្ធិអំណាចលើកងទ័ពដែលខ្លួនគ្រប់គ្រង តាំងពីពេលចូលព្រៃតស៊ូ។

៨០៦. នៅក្នុងសវនាការ មាស វឿន អតីតអនុប្រធានកងពល នៃភូមិភាគបស្ចិម ក៏បាននិយាយអំពីសិទ្ធិអំណាចខ្លាំងរបស់តាម៉ុកទៅលើកម្លាំងផ្សេងៗនៃកងទ័ព ដែលបញ្ជាក់អះអាងអំពីចម្លើយរបស់គាត់

---

[908]សារទូរលេខរបស់ ឈៀន ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៧ **ឯកសារ E3/878**, ERN FR 00611723។ ឯកសារដ៏ទៃមួយចំនួនទៀតលើកឡើងអំពីការខូចខាតកាន់តែច្រើនទៅៗនៅពាក់កណ្តាលឆ្នាំ ១៩៧៧។

[909]សូមមើលជាអាទិ៍សារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៧៧ **ឯកសារ E3/880**។ សារទូរលេខនេះចុះហត្ថលេខាដោយ ឈៀន លើកឡើងអំពីការសន្ទនាគ្នាជាមួយ ស៊ុន ដែលជាអ្នកទទួលខុសត្រូវជនជាតិវៀតណាម។ សារទូរលេខនេះត្រូវបានប្រើដោយព្រះរាជអាជ្ញានៅពេលសួរចម្លើយអ្នកជំនាញ MORRIS ( ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៩៨-៩៩ ប្រហែលម៉ោង 14.33.49) បន្ទាប់ពីខ្មែរឆ្លងដាក់ទឹកដីវៀតណាមដែលទំនងជាកើតឡើងចន្លោះថ្ងៃទី ១៦ និងថ្ងៃ ១៨ កក្កដា (ក្រៅវិសាលភាពនៃសំណុំរឿង០០២/០២) ប៉ុន្តែព្រះរាជអាជ្ញាបានព្យាយាមគេចវេសមិនព្រមដកស្រង់ចម្លើយរបស់ ហុង ចំពោះខាងខ្មែរដែលរៀបរាប់អំពីការវាយប្រហារពីសំណាក់វៀតណាមពីមុន (**ឯកសារ E3/880**, ERN 00623013-14)។

[910]សារទូរលេខរបស់ ឈៀន ផ្ញើរទៅ ម-៨១ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៧ **ឯកសារ E3/884**, ERN FR 00386258។

នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត[911]។ ម្យ៉ាងវិញទៀត នៅពេលឆ្លើយទៅនឹងសំណួររបស់លោកប្រធាន សាក្សី 2-TCW-1065 បានអះអាងថា នៅមុនខែ ធ្នូ ឆ្នាំ ១៩៧៧ គ្មានកងទ័ពមជ្ឈិមនៅក្នុងភូមិភាគបូព៌ា ដែលគាត់ឈរជើងជាទាហានឈរជើងនោះទេ[912] ដោយគាត់បានរៀបរាប់កងពលចំនួនបី ក្នុងចំណោមនោះ កងពលមួយដឹកនាំដោយ ហេង សំរិន[913]។

## ២. សារទូរលេខបញ្ជាក់អំពីសង្គ្រាមចំហ

៨០៧. ក្នុងសារទូរលេខមួយ ចុះខែ សីហា ឆ្នាំ ១៩៧៧ ឈាន បានប្រាប់យុទ្ធសាស្ត្រការទូតរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ដល់ស្ថានទូតបរទេសប្រចាំនៅទីក្រុងហាណូយ "ដែលដឹងបញ្ហាទំនាស់រវាងព្រំដែន [កម្ពុជាប្រជាធិបតេយ្យ] និងវៀតណាម" ដែលត្រូវបានរក្សាជាការសម្ងាត់ ដោយ "ឃោសនាកាច់មួល [កម្ពុជាប្រជាធិបតេយ្យ]"[914]។ បន្ទាប់មកទៀត ឈាន បានរៀបរាប់អំពីរបៀបដែលសាធារណរដ្ឋសង្គមនិយមវៀតណាមតាំងខ្លួនជាភាគីផ្សះផ្សា និងបាននិយាយលម្អិតអំពី "ពាក្យចចាមអារ៉ាម" ផ្សេងៗ ដែលវៀតណាមបានផ្សព្វផ្សាយ។ គាត់បានបន្ថែមថា៖ "វៀតណាមឈានដល់រយៈកាលមួយថ្មី ខំប្រមូលមហាជនបណ្តើរ និងបង្កើនការចូលឈ្លានពានមកលើយើងកាន់តែខ្លាំង។ តែទន្ទឹមនឹងនេះ ក៏នៅប្រើឧបាយកល បន្លំបន្លំភ្នែកគេឯងនៅឡើយ មិនទាន់ហ៊ានចំហមួយរយភាគរយទេ"[915]។ សេចក្តីសន្និដ្ឋានរបស់ ឈាន នៅក្នុងសារទូរលេខនេះ រៀបរាប់អំពីការយល់ឃើញរបស់គាត់ទៅលើសភាពការណ៍ ពាក់ព័ន្ធនឹងឥរិយាបថរបស់វៀតណាម ក៏ដូចជាគោលជំហរនៃសម្ព័ន្ធមិត្តរបស់កម្ពុជាប្រជាធិបតេយ្យ។ សម្ព័ន្ធមិត្តទាំងនេះមិនជឿវៀតណាម ដែលជាក់ស្តែងគេឃើញថាជាអ្នករាតត្បាតនោះទេ[916]។

---

[911] MEAS Voeun : ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/386.1** ទំព័រ ៤២ ប្រហែលម៉ោង 13.51.30 ; កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ **ឯកសារ E3/9738**, Q/R 4 et Q/R 24។

[912] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៥៦ ប្រហែលម៉ោង 14.20.36។

[913] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៥៥ ប្រហែលម៉ោង 14.18.18។

[914] សារទូរលេខរបស់ ឈៀន ផ្ញើរទៅ ម-៨១ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ **ឯកសារ E3/882**, ERN FR 00386253។

[915] សារទូរលេខរបស់ ឈៀន ផ្ញើរទៅ ម-៨១ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ **ឯកសារ E3/882**, ERN FR 00386254។

[916] សារទូរលេខរបស់ ឈៀន ផ្ញើរទៅ ម-៨១ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ **ឯកសារ E3/882**, ERN FR 00386255។

៨០៨. ក្រៅពីការវាយសម្រុកលើសមរភូមិការទូត ការប៉ះទង្គិចគ្នានៅតាមកន្លែងផ្សេងៗកាន់តែមានភាពហិង្សាឡើង ជាពិសេស ចាប់ពីខែតុលា ដូចបានបញ្ជាក់ក្នុងសារទូរលេខមួយចំនួនរបស់ ឆុន (សោ ភឹម) ដែលរាយការណ៍អំពីការប្រយុទ្ធគ្នានៅភូមិភាគបូព៌ា។ សារទូរលេខទាំងនេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា កងទ័ពភូមិភាគកាន់តែពិបាកឡើងៗក្នុងការទប់ទល់នឹងការរុលចូលរបស់ពួកវៀតណាម[917]។ ឧទាហរណ៍ នៅខែ ធ្នូ ឆ្នាំ ១៩៧៧ សោ ភឹម បានផ្ញើសារទូរលេខពីរ ដែលរាយការណ៍អំពីសភាពការណ៍មិនល្អ៖

> **ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៧៖** "សភាពការណ៍ខ្លាំង នៅសមរភូមិផ្លូវលេខ ២២ ក្នុងថ្ងៃទី ០៩ ខែ ធ្នូ និងយប់ថ្ងៃទី ០៩ ខែ ធ្នូ ខ្មាំងចូលតាមច្រកត្រាចខោលនេះ បច្ចុប្បន្ន វាបោះនៅម្តុំត្រពាំងស្នាច់ ព្រៃបូតកង និងសាពួនខាងលិចភូមិត្រពាំងថ្លុង មួយចំនួនទៀត នៅម្តុំភូមិព្រះផ្តៅ"[918]។

> **ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧៖** "ភូមិដា អាខ្មាំងបុកយើងយ៉ាងខ្លាំងក្លា បណ្តាលឱ្យខ្សែត្រៀមរបស់យើងដាច់ធ្លាក់ចុះ ហើយខ្មាំងចូលធ្វើសកម្មភាពបាញ់រះជិតផ្ទះសម្បែង ធ្វើឱ្យស្លាប់ប្រជាជន និងគោក្របីអស់ជាច្រើន បច្ចុប្បន្ន អាខ្មាំងនៅភូមិដានេះ ផ្លាកសំរោង ភូមិរោងគោ នៅលើផ្លូវជាតិលេខ ៧"[919]។

៨០៩. នៅពេលសួរដេញដោលសាក្សី 2-TCW-1065 លោកប្រធាន និល ណុន បានពិនិត្យមើលសារទូរលេខជាច្រើនរបស់ ភ្លួង ដែលរាយការណ៍អំពីការចូលលុកលុយរបស់វៀតណាមក្នុងទឹកដីកម្ពុជា និងការវាយប្រហាររោងចក្រ និងចម្ការកៅស៊ូ ដែលគាត់ជាអ្នកគ្រប់គ្រង[920]។ ការវាយប្រហារពីថ្ងៃទី ២៣ ដល់ថ្ងៃទី ២៧ ខែ ធ្នូ បណ្តាលឱ្យទាហានដកថយ និងបង្ខំឱ្យប្រជាជន និងកម្មករ រត់

---

[917]សារទូរលេខរបស់ ឆុន ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៧ **ឯកសារ E3/888**, ERN FR 00386261 សារទូរលេខរបស់ ឆុន ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៧ **ឯកសារ E3/889**, ERN FR 00946194 សារទូរលេខរបស់ ឆុន ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៧ **ឯកសារ E3/554** (កាលណាឯកសារមានតែមួយទំព័រ មេធាវីការពារក្តីមិនដាក់លេខ ERN ជាស្វ័យប្រវត្តិនោះទេ) ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ **ឯកសារ E3/976**។

[918]សារទូរលេខរបស់ ឆុន ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៧ **ឯកសារ E3/8370**។

[919]សារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧ **ឯកសារ E3/8372**, ERN FR 00291043។

[920]សាក្សី 2-TCW-1065 បានបញ្ជាក់អំពីមុខងាររបស់ ភ្លួង និងបាននឹកឃើញអំពីព្រឹត្តិការណ៍ទាក់ទងនឹងចម្ការកៅស៊ូ៖ ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ១០៧-១០៨ ប្រហែលម៉ោង 15.55.46។

គេច[921]។ ការវាយប្រហារនេះ ជាការឱ្យដំណឹងមុនអំពីការចូលមករបស់កងទ័ពវៀតណាមដ៏ច្រើនសន្ធឹកសន្ធាប់ នៅចុងខែ ធ្នូ ឆ្នាំ ១៩៧៧។

៨១០. ដូច្នេះ ក្រោយពីការចរចាមិនរីវត្តទៅមុខ និងការប៉ះទង្គិចគ្នាឡើងកម្តៅខ្លាំង សារទូរលេខចុងក្រោយទាំងនេះបញ្ជាក់អំពីការបញ្ចប់ការតស៊ូរបស់កងទ័ពបូព៌ា និងការចូលមករបស់កងទ័ពវៀតណាមក្នុងទឹកដីកម្ពុជាមួយភាគធំ[922]។ នៅក្នុងបរិបទនេះ កម្ពុជាប្រជាធិបតេយ្យបានផ្តាច់ទំនាក់ទំនងការទូតជាចំហ[923] និងប្រកាសជាផ្លូវការនូវជម្លោះដែលបង្កឡើងដោយវៀតណាម ដូចអ្នកជំនាញ Philip SHORT បានពន្យល់នៅក្នុងសៀវភៅរបស់គាត់[924]។

៨១១. លោក Stephen MORRIS បានអះអាងនៅក្នុងសៀវភៅរបស់គាត់ថា ហេតុនេះហើយបានជាទោះបីជាវៀតណាមមានលទ្ធភាពទន្ទ្រាន និងត្រួតត្រាកម្ពុជា តាំងពីចុងឆ្នាំ ១៩៧៧ ក៏ដោយ ក៏មិនអាចទៅរួចឡើយខាងនយោបាយនៅពេលនោះ[925]។ ដូច្នេះ យុទ្ធសាស្ត្រ គឺត្រូវផ្លាស់ប្តូរស្ថានការណ៍នយោបាយ និងត្រៀមលក្ខណៈសម្រាប់ជ័យជម្នះ ដែលគ្រាន់តែជាបញ្ហាពេលវេលាប៉ុណ្ណោះ។ អ្នក

---

[921]សារទូរលេខរបស់ ភួង ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ **ឯកសារ E3/905** សារទូរលេខរបស់ ភួង ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ **ឯកសារ E3/906** សារទូរលេខរបស់ ភួង ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៧៧ **ឯកសារ E3/909** សារទូរលេខរបស់ ភួង ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៧៧ **ឯកសារ E3/908** សារទូរលេខរបស់ ភួង ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៧ **ឯកសារ E3/912**។

[922]IENG Phan : ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ១៧ មុនម៉ោង 09.57.25 ; SIN Oeng : ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/506.1** ទំព័រ ១៥-១៦ ក្រោយម៉ោង 09.36.26. វៀតណាមបានចូលមណ្ឌលគិរីម្តងដែរ៖ សារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៧៨ **ឯកសារ E3/248**, ERN 00631446 របាយការណ៍ថ្ងៃទី ០២ មីនា នៃសាធារណរដ្ឋប្រជាមានិតវៀតណាមចូលនៅក្នុងខេត្តមណ្ឌលគិរី ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៧៨ (SWB) **ឯកសារ E3/1360**, ERN EN 00169884។

[923]ការផ្តាច់ទំនាក់ទំនងបណ្តោះអាសន្នរវាងប្រទេសកម្ពុជា និងវៀតណាម ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៨ **ឯកសារ E3/267** ERN FR 00693825 សេចក្តីប្រកាសរបស់អ្នកនាំពាក្យនៃក្រសួងឃោសនាការ និងព័ត៌មាននៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៨ **ឯកសារ E3/1263**, ERN FR 0087630-635។ សារទូរលេខការទូតដែលផ្ញើរពី កង់បេរ៉ាដោយទូតអាមេរិកប្រចាំនៅទីក្រុងបាងកកទៅ រដ្ឋលេខាធិការអាមេរិកនៅ វ៉ាស៊ីនតោន ចុះខែ កុម្ភៈ ឆ្នាំ ១៩៧៨ **ឯកសារ E3/9727**។

[924]សៀវភៅរបស់ Philip SHORT មានចំណងជើងថា ប៉ុល ពត ប្រវត្តិសុបិនអាក្រក់ ឆ្នាំ ២០០៤ **ឯកសារ E3/9** ERN FR 00639949-50។

[925]សៀវភៅរបស់ Stephen MORRIS ដែលមានចំណងជើងថា ហេតុអ្វីបានជាវៀតណាមឈ្លានពានកម្ពុជា ឆ្នាំ ១៩៩៩ **ឯកសារ E3/7338** ទំព័រ 102, ERN EN 01001769។

ជំនាញ Stephen MORRIS បានលើកឡើងជាច្រើនដងអំពីចរិតលក្ខណៈ "ខ្វះវិចារណញ្ញាណ" របស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ ដូចលោក Douglas PIKE បានសរសេរនៅក្នុងរបាយការណ៍របស់គាត់ដែលមានភាពច្បាស់លាស់ម៉ត់ចត់បំផុតនោះ គឺ "ចំពោះកម្ពុជា សង្គ្រាមនេះទាក់ទងដល់អាយុជីវិត"[926]។

## ផ្នែកទី ៣. ការប្រកាសបរាជ័យរបស់កម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ ១៩៧៨ ដល់ឆ្នាំ ១៩៧៩

៨១២. ដូច្នេះ នៅឆ្នាំ ១៩៧៨ ជម្លោះក្លាយជាបើកចំហ និងសម្គាល់ដោយយុទ្ធនាការការទូតប្រកបដោយប្រសិទ្ធភាពរបស់វៀតណាម (២) ទល់នឹងកងទ័ពអន់ថយរបស់កម្ពុជាប្រជាធិបតេយ្យ (១)។ ការរួមផ្សំចំណុចទាំងពីរនេះនាំឱ្យកម្ពុជាទទួលបរាជ័យ នៅថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩។

### ១. កងទ័ពអន់ថយរបស់កម្ពុជាប្រជាធិបតេយ្យ

៨១៣. ភាពខុសគ្នាខាងយោធា ដូចបានរៀបរាប់ខាងលើ នាំឱ្យកងទ័ពវៀតណាមត្រួតត្រាលើកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យបានយ៉ាងងាយ ចាប់ពីពេលវៀតណាមយល់ថាខ្លួនអាចដាក់ពង្រាយកម្លាំងយោធារបស់ខ្លួនបានដោយសេរី[927]។ នៅក្នុងសវនាការ អ្នកជំនាញ Stephen MORRIS បានគាំទ្រយោបល់របស់លោក Nayan CHANDA ដែលថា កម្ពុជាប្រជាធិបតេយ្យគ្មានលទ្ធភាពទប់ទល់នឹងវៀតណាម នៅក្នុង "សង្គ្រាមធម្មតា" បានឡើយ[928]។ ជាទូទៅ អតីតយោធា ដែលមកផ្តល់សក្ខីកម្មបន្តបន្ទាប់គ្នា នៅក្នុងសវនាការ ដើម្បីនិយាយអំពីជម្លោះប្រដាប់អាវុធ បានឆ្លើយដូចៗគ្នាថា នៅ

---

[926] របាយការណ៍របស់ Douglas PIKE ដែលមានចំណងជើងថា "ជម្លោះរវាងវៀតណាមនិងកម្ពុជា ដែលជារបាយការណ៍រៀបរាងឡើងដោយផ្នែកសិក្សានៃសមាជ នៅសមាជលើកទី ៩៥ តាមសំណើរបស់អនុគណកម្មាការអាស៊ី ប៉ាស៊ីហ្វិក គណកម្មាការទំនាក់ទំនងអន្តរជាតិ ដែលចុះ ថ្ងៃទី ៤ តុលា ឆ្នាំ ១៩៧៨**ឯកសារ E3/2370**, ERN FR 00344747។

[927] សូមមើលខាងក្រោមនៅ កថាខណ្ឌ ៨១៧-៨៣២។

[928] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦**ឯកសារ E1/486.1** ទំព័រ ៦៦ នៅម៉ោង 14.26.05៖ "ចំពោះជនជាតិវៀតណាម វាជាការងាយស្រួលក្នុងការសម្រេចគោលដៅយោធារបស់ពួកគេនៅទឹកដីកម្ពុជា។ កងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យពុំមានសមត្ថភាពធ្វើសង្គ្រាមតាមទម្លាប់ប្រឆាំងនឹងវៀតណាមទេ ជម្រើសតែមួយគត់របស់កម្ពុជាប្រជាធិបតេយ្យគឺសង្គ្រាម ឈ្លប ប៉ុន្តែពួកគេមិនបានធ្វើសង្គ្រាមឈ្លបនេះទេ។"

លើសមរភូមិប្រយុទ្ធ ខាងកម្ពុជាបាត់បង់ច្រើនជាង។ នេះដោយហេតុថា កងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យមានចំនួនតិចជាង ហើយកងទ័ពវៀតណាមមានអាវុធយុទ្ធភណ្ឌ និងហ្វឹកហ្វឺនបានល្អជាងដូចដែលបានរៀបរាប់នៅខាងលើ[929]។

៨១៤. អៀង ផាន មេបញ្ជាការកងពលតូច បានឆ្លើយថា ឧត្តមភាពរបស់កងទ័ពវៀតណាមបណ្តាលឱ្យខាងកម្ពុជាមាន "អ្នករបួសច្រើន" និង "បាត់បង់ច្រើន"[930]។ នៅពេលរៀបរាប់លម្អិតអំពីពេលទៅដល់ខេត្តស្វាយរៀង ក្នុងពាក់កណ្តាលឆ្នាំ ១៩៧៨ ដើម្បីផ្តល់កម្លាំងជំនួយដល់កងទ័ពដែលឈរជើងនៅទីនោះស្រាប់ ក្រោមបញ្ជារបស់ អ៊ែន (កូនប្រសាររបស់តាម៉ុក) [931] សាក្សីរូបនេះបាននិយាយថា គាត់ឃើញសភាពការណ៍នៅទីនោះមានភាពច្របូកច្របល់។ ជាក់ស្តែង សាក្សីបានរៀបរាប់អំពីសភាពការណ៍អាសន្នសម្រាប់កងទ័ពបដិវត្តន៍កម្ពុជាពីជុំទិស ដោយសារតែមានការចូលលុកលុយរបស់ខ្មាំង នៅខេត្តតាកែវ ដែលកងទ័ពពិបាកនឹងទប់ទល់[932]។

៨១៥. យោធាជាច្រើនបានផ្តល់សក្ខីកម្មអំពីការចាប់បានទាហានខ្មែរ និងការពង្រឹងកងទ័ពខ្មាំងក្នុងវិធីសាស្ត្រប្រយុទ្ធ ជាពិសេស ការប្រើប្រាស់មីន[933]។ ដូច្នេះ ការអះអាងថា កងទ័ពបដិវត្តន៍កម្ពុជាទំនងជាប្រើប្រាស់វិធីសាស្ត្រសង្គ្រាមសាហាវឃោរឃៅចំពោះវៀតណាម ដែលអនុវត្តវិធីសាស្ត្រថ្លៃថ្នូរជាង គឺជាទេវកថាមួយទៀត[934]។ ការពិតជាសាកលតែមួយគត់ដែលយើងអាចចងចាំ គឺថាគ្មានស

---

[929] សូមមើលខាងលើ កថាខណ្ឌ ៧៤២-៧៥១។

[930] អៀង ផាន : ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ១៦ ក្រោយម៉ោង 10.01.11។

[931] អៀង ផាន : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ១២-១៣ ប្រហែលម៉ោង 09.41.41។

[932] អៀង ផាន : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៣១ ប្រហែលម៉ោង 10.58.38។

[933] កំណត់ហេតុស្តាប់ចម្លើយ SOKH Chhien ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ **ឯកសារ E3/428** ERN FR 00485477. អៀង ផាន: ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៣៧ ប្រហែលម៉ោង 11.17.49 (បានបញ្ជាក់អំពីការប្រើមីនជាយុទ្ធវិធីដែលប្រទេសទាំងពីរប្រើដូចគ្នា) ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៥២ ក្រោយម៉ោង 14.03.10 (បានបញ្ជាក់អំពីអវត្តមាននៃការចាប់ជនជាតិវៀតណាមនៅក្នុងអង្គភាពរបស់គាត់) សូមមើល : កំណត់ហេតុស្តាប់ចម្លើយ KUNG Kim ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ **ឯកសារ E3/3959**, ERN FR 00486101 ; CHUON Thy : ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ៤២ ក្រោយម៉ោង 11.30.17 ; ទំព័រ ៤៤ ក្រោយម៉ោង 11.36.21។

[934] សាក្សីដ៏ទៃទៀតបាននិយាយអំពីវត្តមានមីននៅភូមិភាគបូព៌ា 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/497.1** ទំព័រ ២២ ប្រហែលម៉ោង 09.48.54។ សូមមើលចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក

ង្គ្រាមស្អាតស្អំនោះទេ ជាពិសេស បើជាសង្គ្រាមក្នុងលេណដ្ឋាន ដូចករណីនៅតាមតំបន់ព្រំដែននោះ។

៨១៦. ប្រឈមមុខនឹងការរុលចូលយ៉ាងខ្លាំងក្លារបស់កងទ័ពវៀតណាម និងការបាត់បង់ខាងច្រើនពីខាងកម្ពុជាប្រជាធិបតេយ្យ[935] ការវិភាគនានាយល់ស្របក្នុងការសន្និដ្ឋានអំពីសេណារីយ៉ោនៃរបបថ្មីក្រោមអាណាព្យាបាល ដូចនៅឡាវ ធ្វើឱ្យថៃព្រួយបារម្ភយ៉ាងខ្លាំង ដោយសារតែបញ្ហាផ្ទៃក្នុងរបស់ខ្លួន[936]។ ភស្តុតាងបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា វៀតណាមបានរៀបចំយុទ្ធសាស្ត្រមានប្រសិទ្ធភាព ដើម្បីសម្រេចគោលដៅរបស់ខ្លួន។

## ២. យុទ្ធសាស្ត្រមានប្រសិទ្ធភាពរបស់វៀតណាម

៨១៧. អាជ្ញាធរវៀតណាមលែងអត់ឱនដល់ការតស៊ូរបស់កម្ពុជាប្រជាធិបតេយ្យទៀតហើយ គឺពួកគេបានគ្រោងទុកនូវសេណារីយ៉ោផ្សេងៗ ដើម្បីជម្រុះចោលរដ្ឋអំណាចខ្មែរ[937]។ ដើម្បីឈ្នះសង្គ្រាម វៀតណាមបានពឹងផ្អែកលើសម្ព័ន្ធភាពជាមួយខ្មែរខាងក្នុង (ក) រួមផ្សំនឹងប្រតិបត្តិការការទូតទ្រង់ទ្រាយធំ (ខ)។

---

ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/445.1** ទំព័រ ៤៧ នៅម៉ោង 13.41.12។ សូមមើល 2-TCW-1005 ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/449.1** ទំព័រ ៣៨, ក្រោយម៉ោង 11.07.14 ; ទំព័រ ៦២-៦៣ ចន្លោះម៉ោង 14.22.42 និង 14.24.25។

[935] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៧៩ ក្រោយម៉ោង 15.57.4 ; BAN Seak : ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ **ឯកសារ E1/354.1** ទំព័រ ១៩ ក្រោយម៉ោង 10.06.25 ; បាន សៀក T.ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ **ឯកសារ E1/354.1** ទំព័រ ២៨ មុនម៉ោង 10.11.20 ; កំណត់ហេតុស្តាប់ចម្លើយ KE Pich Vannak (ស្លាប់) ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៩ **ឯកសារ E3/35**, ERN FR 00367728។

[936] សារទូរលេខការទូតដែលផ្ញើរពី កង់បេរ៉ា ដោយទូតអាមេរិកប្រចាំនៅបាងកកទៅរដ្ឋលេខាធិការអាមេរិកនៅ វ៉ាស៊ីនតោន ចុះខែ សីហា ឆ្នាំ ១៩៧៨ **ឯកសារ E3/9724**, ERN EN 01186946-47, 01186947, 01186949-50, 01186951។

[937] អត្ថបទរបស់ Dmitry MOSYAKOV ដែលមានចំណងជើងថា "រឿងរ៉ាវរវាងពួកខ្មែរក្រហម និងពួកកុម្មុយនីស្ត វៀតណាម ផ្អែកលើ បណ្ណសារសូវៀត" ឆ្នាំ ២០០៤ **ឯកសារ E3/9644**, ERN FR 01125320។

## ក. <u>សម្ព័ន្ធភាពជាមួយអ្នកផ្ដាច់ខ្លួនចេញពីបក្សកុម្មុយនីស្តកម្ពុជា</u>

៨១៨. នៅទីបំផុត វៀតណាមបានសម្រេចប្រើប្រាស់ក្រុមប្រឆាំងនឹងគណៈអចិន្ត្រៃយ៍ ដើម្បីយកមកធ្វើជាសម្ព័ន្ធមិត្ត ក្នុងគោលដៅផ្ដួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ និងលើកបន្តុបរដ្ឋអំណាចថ្មីមួយដែលគាំទ្រវៀតណាម។ ចាប់ពីដើមឆ្នាំ ១៩៧៨ មក វៀតណាមបានផ្សព្វផ្សាយពាក្យចចាមអារ៉ាមដល់ប្រទេសជាមិត្តថា ខ្លួនមានសម្ព័ន្ធភាពជាមួយនឹង "កម្លាំងស្នេហាជាតិ"[938]។

៨១៩. ប៉ុន្តែ អ្វីៗត្រូវបានបញ្ជាក់ច្បាស់ ប៉ុន្មានខែក្រោយមក ជាមួយនឹងអ្នកផ្ដាច់ខ្លួន ដែលបោះទីតាំងនៅវៀតណាម។ ដូចលោក Dmitry MOSYAKOV បានលាតត្រដាង ជំនួបជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម និងការហ្វឹកហ្វឺន បានកើនឡើង និងមានការកសាងកម្លាំងយោធា[939]។

៨២០. លោក Stephen MORRIS ក៏បានសរសេរផងដែរអំពីយុទ្ធសាស្ត្រប្រើប្រាស់ខ្មែរខាងក្នុងកម្ពុជាប្រជាធិបតេយ្យ នៅក្នុងសៀវភៅរបស់គាត់។ គាត់បានរៀបរាប់អំពីកិច្ចសម្ភាសន៍ ក្នុងខែ កញ្ញា ឆ្នាំ ១៩៧៨ រវាងឯកអគ្គរដ្ឋទូតសូវៀតប្រចាំនៅទីក្រុងហាណូយ និង ឡេ យួន ហើយក្នុងពេលនោះ ឡេ យួន ពន្យល់ថា ពួកគេកំពុងរៀបចំបង្កើតចលនាតស៊ូកម្ពុជាមួយ[940]។

៨២១. នៅក្នុងសវនាការ សាក្សី 2-TCW-1065 បានរៀបរាប់អំពីបទពិសោធន៍របស់គាត់ក្នុងឋានៈជាជនផ្ដាច់ខ្លួន។ គាត់ជាសាច់ញាតិរបស់ សោ ភឹម ហើយគាត់បានបោះបង់ចោលមុខតំណែងជាប្រធានក្រុមពេទ្យ[941] ដើម្បីរួមដៃជាមួយក្រុមទាហានផ្ដាច់ខ្លួន ដែលបានចូលព្រៃតស៊ូ ពីខែ ឧសភា ដល់

---

[938] *Abschrift eines Briefes des ADN-Korrespondenten in Hanoi vom 3.1.78, gez. Klaus-Dieter Pflaum* ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៨ **ឯកសារ E3/540**, ERN FR 01246939.

[939] អត្ថបទរបស់ Dmitry MOSYAKOV ដែលមានចំណងជើងថា "រឿងរ៉ាវរវាងពួកខ្មែរក្រហម និងពួកកុម្មុយនីស្ត វៀតណាម ផ្អែកលើ បណ្ណសារសូវៀត" ឆ្នាំ ២០០៤ **ឯកសារ E3/9644**, ERN FR 01125320-21។

[940] សៀវភៅរបស់ Stephen MORRIS ដែលមានចំណងជើងថា ហេតុអ្វីវៀតណាមឈ្លានពានកម្ពុជា នៅឆ្នាំ ១៩៩៩ **ឯកសារ E3/7338** ទំព័រ ១០៩ ERN EN 01001776។

[941] <u>2-TCW-1065</u> : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៤៧ ប្រហែលម៉ោង 13.52 ; ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ៦០ ប្រហែលម៉ោង 14.45.06។

ខែ វិច្ឆិកា ឆ្នាំ ១៩៧៨[942]។ គាត់យល់ស្របថា ក្នុងរយៈពេលនោះ មាន "ជម្លោះផ្ទៃក្នុង" នៅកម្ពុជាប្រជាធិបតេយ្យ[943]។ សាក្សីក៏បានពន្យល់ផងដែរថា ក្រុមមួយដែលមានសមាសភាព "វៀតណាម និងខ្មែរពីរបីនាក់ ដែលចង់ទាក់ទង និងសហប្រតិបត្តិការជាមួយកងទ័ពខ្មែរ" បានមករកគាត់[944]។ "ក្រោយពីពិភាក្សាគ្នាយ៉ាងយូរមក" គាត់ត្រូវបានគេ "អញ្ជើញគាត់ឱ្យទៅវៀតណាម ដើម្បីយកគ្រាប់រំសេវ"[945]។ ក្រោយពីប្រតិបត្តិការប្រមូល និងដឹកនាំប្រជាជននៅទឹកដីវៀតណាម គាត់ត្រូវគេអញ្ជើញទៅទីក្រុងហូជីមិញ តាមឧទ្ធម្ភាគចក្រ ជាមួយ អ៊ុក ប៊ុនឈឿន[946] ដើម្បីរៀបចំរណសិរ្ស។ គាត់បានរៀបរាប់លម្អិតអំពីការធ្វើដំណើរនេះ និងការរៀនសូត្រ[947]។ ជាចុងក្រោយ សាក្សី បានគូសបញ្ជាក់ថា ក្នុងក្របខ័ណ្ឌនៃការបង្កើតរណសិរ្សតស៊ូនេះ គាត់បានជួបឥស្សរជនជាច្រើនដែលក្រោយមកកាន់កាប់មុខងារនៅកម្ពុជា ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ និងអតីតកម្មាភិបាលភូមិភាគបូព៌ា[948]។

៨២២. រណសិរ្សដែលដឹកនាំដោយវៀតណាមនេះ អាចឱ្យវៀតណាមមានមុខមាត់ជាខ្មែរស្របច្បាប់សម្រាប់គម្រោងលុកលុយរបស់ខ្លួននេះ។ អាស្រ័យហេតុនេះ វាជាការសំខាន់ត្រូវឱ្យសារព័ត៌មាន

[942] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ១៩ ប្រហែលម៉ោង 10.06.57 ; ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៤៧ ប្រហែលម៉ោង 13.52.14។

[943] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/496.1** ទំព័រ ៥៨ ប្រហែលម៉ោង 15.07.51។

[944] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៤៨ ក្រោយម៉ោង 13.53.57។

[945] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៤៨ ប្រហែលម៉ោង 13.56.05។

[946] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ៧២ ក្រោយម៉ោង 15.40.49។

[947] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/493.1** ទំព័រ ៤៨ ប្រហែលម៉ោង 13.56.05។

[948] 2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ២១ មុនម៉ោង 10.14.55 ទំព័រ ៧៤ ប្រហែលម៉ោង 15.46.58។

និយាយអំពីក្រុមជនផ្ដាច់ខ្លួនទាំងនេះ[949] ប៉ុន្តែ ជាចុងក្រោយ នៅពេលវាយប្រយុទ្ធ កងកម្លាំងវៀតណាមមានវត្តមានជាមួយពួកគេ[950]។

៨២៣. ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន ក៏បានឆ្លើយនៅក្នុងសវនាការផងដែរថា គាត់បានចូលកងទ័ពរណសិរ្សតស៊ូប្រឆាំងនឹងកម្លាំងរបស់កងទ័ពបដិវត្តន៍កម្ពុជា[951] និងបានអះអាងថា គាត់បានចូលរួមវគ្គរៀនសូត្រ ក្នុងក្របខ័ណ្ឌនៃកិច្ចសហការជាមួយវៀតណាមនេះ[952]។

## ខ. ការរៀបចំសមរភូមិការទូត

### 1. ការគ្រប់គ្រងល្បែងការទូតដោយវៀតណាម

៨២៤. ក្នុងបរិបទសង្គ្រាមត្រជាក់[953] វៀតណាមត្រូវរៀបចំសមរភូមិការទូត បន្ថែមលើសមរភូមិយោធា។ ដូចលោក Dmitry MOSYAKOV បានលើកឡើង ការទទួលបានការគាំទ្រពីសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត គឺជាអាទិភាព[954]។

---

[949] អត្ថបទដែលមានចំណងជើងថាតួនាទីរបស់ហាណូយមានចរិតមិនច្បាស់លាស់ក្នុងរបាយការណ៍ស្ដីអំពីការក្រោកឡើង របស់ប្រជាជននៅក្នុងប្រទេសកម្ពុជា *The Washington Post* ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៧៨ **ឯកសារ E3/7265**, ERN EN 00166105 ; របាយការណ៍ផ្សេងទៀតស្ដីអំពី ប្រទេសវៀតណាម និងប្រទេសកម្ពុជា ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៧៨ (SWB) **ឯកសារ E3/7315**, ERN EN S00013210 ; ការបង្កើតរណសិរ្សសាមគ្គីជាតិកម្ពុជា ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៧៨ (SWB) **ឯកសារ E3/7310**, ERN FR 01378346-48។

[950] មាស សឿន៖ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/447.1** ទំព័រ ១៣ នៅម៉ោង 09.42.14 ៖ “ស៖ តើលោកដឹងថាកងកម្លាំងរបស់ ហេង សំរិន មានកងកម្លាំងវៀតណាមមកចូលរួមជាមួយដែររឺអត់នៅពេលក្រោយមក? ច៖ ខ្ញុំមិនច្បាស់ពីរយៈកាលហ្នឹងទេ អ្វីដែលខ្ញុំដឹងគឺថា វាកើតឡើងនៅចុងឆ្នាំ ១៩៧៨ និងដើមឆ្នាំ ១៩៧៩។”

[951] ឈុន សាម៉ន : ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/445.1** ទំព័រ ៧៨ ប្រហែលម៉ោង 15.37.34។

[952] ឈុន សាម៉ន : ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/445.1** ទំព័រ ៨០ ប្រហែលម៉ោង 15.42.32។

[953] សូមមើលខាងលើនៅ កថាខណ្ឌ ៧០៧-៧១៤។

[954] អត្ថបទរបស់ Dmitry MOSYAKOV ដែលមានចំណងជើងថា “រឿងរ៉ាវរវាងទំនាក់ទំនងខ្មែរក្រហម និងពួកកុម្មុយនីស្ដវៀតណាមផ្អែកលើបណ្ណសារសូវៀត” ឆ្នាំ ២០០៤ **ឯកសារ E3/9644**, ERN FR 01125297។

៨២៥. ជាក់ស្តែង ការចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពជាមួយសហភាពសូវៀត មុនពេលលុកលុយបន្តិច ធ្វើឱ្យវៀតណាមទទួលបានការគាំទ្រពីមហាអំណាចនេះ ដើម្បីបង្ការប្រតិកម្មជាយថាហេតុពីចិន[955]។ លោកស្រី Elizabeth BECKER បានរំឭកនៅក្នុងសវនាការអំពីល្បែងសម្ព័ន្ធភាពដែលបានធ្វើឱ្យសហរដ្ឋអាមេរិកវង្វេង ដោយថ្លែងថា៖

> "លោក-លោកស្រីនៅចាំទេ មុនពេលលុកលុយបន្តិច វៀតណាមបានចុះសន្ធិសញ្ញាមិត្តភាពជាមួយសហភាពសូវៀត។ នៅពេលនោះ ទាំងវៀតណាម និងតំណាងកម្ពុជាប្រជាធិបតេយ្យ កំពុងធ្វើទស្សនកិច្ចនៅតាមបណ្តារដ្ឋធានីអាស៊ាន ដើម្បីព្យាយាមបញ្ចុះបញ្ចូលប្រទេសទាំងនោះឱ្យនៅខាងខ្លួនរៀងៗខ្លួន។ ដូច្នេះ នេះជាបរិយាកាសតើអ្នកណាត្រូវគាំទ្រអ្នកណា។ ពិតណាស់ សហរដ្ឋអាមេរិកមានទំនោរទោរទន់ទៅរកចិន ប៉ុន្តែបញ្ហាហ្នឹងគឺថា កម្ពុជាប្រជាធិបតេយ្យជាសម្ព័ន្ធមិត្តរបស់ចិន ហើយក្នុងពេលដំណាលគ្នានោះ អាមេរិកបានបង្កើតសំណុំរឿងមិនគួរឱ្យជឿអំពីការរំលោភសិទ្ធិមនុស្សនៅកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះអ្នកធ្វើគោលនយោបាយបានទ័លគំនិត។ ក្រសួងការបរទេសមានការិយាល័យដាច់ដោយឡែកមួយសម្រាប់វៀតណាម ឡាវ និងកម្ពុជា ហើយឈ្មោះហៅក្រៅ គឺ "ការិយាល័យបុព្វហេតុខាតបង់បំផុត។ នេះជាការយល់ច្រឡំដ៏ធំបំផុតរបស់សហរដ្ឋអាមេរិក"[956]។

៨២៦. លោកស្រីក៏បានបន្ថែមទៀតថា សន្ធិសញ្ញាមិត្តភាពនេះបាន "បិទបញ្ចប់ការព្រមព្រៀងគ្នារួចទៅហើយ"[957] គឺការព្រមព្រៀងគ្នាជាសម្ងាត់។ ការចរចាជាសម្ងាត់របស់វៀតណាម និងគម្រោងលុកលុយនេះ បានធ្វើឱ្យសហរដ្ឋអាមេរិកភ្ញាក់ផ្អើលយ៉ាងខ្លាំង ពីព្រោះសហរដ្ឋអាមេរិកមិនបាននឹកស្មានទាល់តែសោះអំពីអ្វីដែលគេកំពុងតែរៀបចំដោយសម្ងាត់នៅក្នុងតំបន់។

៨២៧. អ្នកជំនាញ Stephen MORRIS បានបញ្ជាក់អះអាងថា សាធារណរដ្ឋសង្គមនិយមវៀតណាមបានធ្វើសកម្មភាព ដើម្បីទទួលបានការគាំទ្រពីសូវៀត នៅក្នុងជម្លោះនេះ ពីព្រោះនេះក៏ជាការធានាផងដែរថាប្រទេសទាំងអស់នៅក្នុងប្លុកនេះនឹងគាំទ្រវៀតណាម[958]។ បន្ថែមពីលើការគាំទ្រពីសូវៀត វៀតណាមបានធ្វើយុទ្ធនាការឃោសនា ដើម្បីអូសទាញមតិអន្តរជាតិ។ នៅក្នុងរបាយការណ៍ផ្ញើជូនសភាអាមេរិក លោក Douglas PIKE បានកត់សម្គាល់ថា "ទាំងសងខាងបានចេញសេចក្តី

---

[955] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/487.1** ទំព័រ ៤៧ នៅម៉ោង 13.51.03។

[956] Elizabeth BECKER : ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/259.1** ទំព័រ ២២ ប្រហែលម៉ោង 10.09.56។

[957] Elizabeth BECKER : ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/259.1** ទំព័រ ៦៨ ប្រហែលម៉ោង 15.11.35។

[958] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/487.1**, ទំព័រ ៤០ ប្រហែលម៉ោង 11.29.42។

ថ្លែងការណ៍ទៅកាន់មតិអន្តរជាតិ ប៉ុន្តែ វៀតណាមប៊ិនប្រសប់ជាងកម្ពុជា"[959]។ លោក Stephen MORRIS បានបញ្ជាក់អះអាងអំពីចំណុចនេះ នៅក្នុងសវនាការ ដោយពន្យល់ថា "វៀតណាមមានប្រវត្តិរៀនសូត្រពីសូវៀត និងចិន យូរជាងកម្ពុជា អំពីសិល្បៈនៃការឃោសនា"[960]។

៨២៨. យើងចាំបាច់ត្រូវវិភាគសម្ដីរបស់ ប៉ុល ពត នៅចុងឆ្នាំ ១៩៧៨ ដូចលោកស្រី Elizabeth BECKER បានរៀបរាប់ នៅក្នុងកិច្ចសម្ភាសន៍។ ការបរិយាយថាវៀតណាម "រណបសហភាពសូវៀត" ដែលទៅ "លិទ្ធជើងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត" ដើម្បីចុះ "សម្ព័ន្ធភាពយោធា" ក្នុងគោលដៅធ្វើឱ្យជម្លោះជាមួយកម្ពុជាក្លាយជាបញ្ហាអន្តរជាតិ ពិតជាត្រូវគ្នានឹងយុទ្ធសាស្ត្ររបស់សាធារណរដ្ឋសង្គមនិយមវៀតណាម[961]។

## 2. សេចក្ដីថ្លែងការណ៍គ្មានប្រសិទ្ធភាពរបស់កម្ពុជាប្រជាធិបតេយ្យ

៨២៩. ដោយសារទ័លច្រក មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានប៉ុនប៉ងកម្ទេចឧបាយកលតាមផ្លូវការទូតរបស់វៀតណាម[962] ប៉ុន្តែ យឺតពេល និងបរាជ័យ។ កម្ពុជាប្រជាធិបតេយ្យពិតជាអាចពឹងផ្អែកលើសម្ព័ន្ធមិត្តដ៏ស្មោះត្រង់របស់ខ្លួន គឺចិន និងកូរ៉េ[963]។

---

[959] របាយការណ៍របស់ Douglas PIKE ដែលមានចំណងជើងថា "ជម្លោះរវាងវៀតណាមនិងកម្ពុជា ដែលជារបាយការណ៍រៀបរាងឡើងដោយផ្អែកសិក្សានៃសមាជ នៅសមាជលើកទី ៩៥ តាមសំណើរបស់អនុគណកម្មាការអាស៊ី ប៉ាស៊ីហ្វិក គណកម្មាការទំនាក់ទំនងអន្តរជាតិ ចុះថ្ងៃទី ៤ តុលា ឆ្នាំ ១៩៧៨ **ឯកសារ E3/2370**, ERN FR 00344740។

[960] Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៤៥ ប្រហែលម៉ោង 11.38.42។

[961] សៀវភៅនិពន្ធដោយ Elizabeth BECKER មានចំណងជើងថា *Les Larmes du Cambodge* ឆ្នាំ 1986 **ឯកសារ E3/20** ទំព័រ ៤១៤ ERN FR 00638674។

[962] សុន្ទរកថារបស់ នួន ជា ថ្លែងក្នុងឱកាសទស្សនកិច្ចរបស់គេង យិនចាវ នៅកម្ពុជា ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៧៨ (SWB) **ឯកសារ E3/1407**, ERN FR S00687049។

[963] របាយការណ៍ ព័ត៌មាន និងអនុស្សរណៈស្ដីពីកិច្ចពិភាក្សាអំពីទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ឆ្នាំ ១៩៧៧-១៩៧៨ **ឯកសារ E3/1773**, ERN FR 01353498-99 ; ចិនជួយកម្ពុជាក្នុងជម្លោះជាមួយវៀតណាម ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៧៨ (SWB) **ឯកសារ E3/7306**, ERN FR 01376051 ; មេរៀនបណ្ដុះបណ្ដាលយោធានៅអាន យ៉ាង (An Giang) ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៧៨ (SWB) **ឯកសារ E3/7306**, ERN EN S0001075។

៨៣០. ប៉ុន្តែ ទោះបីជាមានការវាយសម្រុកនៅក្នុងសារព័ត៌មាន ដើម្បីប្រឆាំងនឹងការលុកលុយនៅខែ ធ្នូ ឆ្នាំ ១៩៧៧[964] យ៉ាងណាក៏ដោយ ក៏ប៉ុន្មានខែក្រោយមក នៅចន្លោះឧបាយកលនយោបាយរបស់វៀតណាម និងបរាជ័យខាងយោធា[965] រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានវិនាសក្ស័យប្រាណ។ ដើមខែ មករា ឆ្នាំ ១៩៧៩ គឺជាថ្ងៃអវសាន្ត និងការរត់គេច[966]។

៨៣១. នៅក្នុងបរិបទនេះ សារទូរលេខចុងក្រោយរបស់ អៀង សារី ផ្ញើជូនក្រុមប្រឹក្សាសន្តិសុខ នៅថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៩ គឺជាការតស៊ូចុងក្រោយដើម្បីស្តារកិត្តិយសកម្ពុជាប្រជាធិបតេយ្យនៅលើឆាកអន្តរជាតិ មុនពេលរត់គេច នៅថ្ងៃទី ០៧ ខែ មករា[967]។ ទន្ទឹមនឹងនេះដែរ សេចក្តីអំពាវនាវរបស់ ប៉ុល ពត ចំពោះប្រជាជនកម្ពុជា គឺជាភ្លេងក្លងខែកដ៏អាម៉ាស់ ដែលមិននិយាយចំណោះ[968]។

---

[964] របាយការណ៍ ព័ត៌មាន និងអនុស្សរណៈស្តីពីកិច្ចពិភាក្សាអំពីទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ឆ្នាំ ១៩៧៧-១៩៧៨ **ឯកសារ E3/1773**, ERN FR 01353497 ; ការផ្តាច់ទំនាក់ទំនងបណ្តោះអាសន្នរវាងប្រទេសកម្ពុជា និងវៀតណាម ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៨ (SWB) **ឯកសារ E3/267**, ERN FR S 00858044-00858049 ; របាយការណ៍ស្តីពីសេវាផ្សព្វផ្សាយព័ត៌មានបរទេស ខែ កក្កដា ឆ្នាំ ១៩៧៨ **ឯកសារ E3/293,** 00169689-00169777. ប្រកាសសារព័ត៌មានរបស់អ្នកនាំពាក្យប្រសួងឃោសនាការ និងព័ត៌មាននៃកម្ពុជាប្រជាធិបតេយ្យគ្មានចុះកាលបរិច្ឆេទ **ឯកសារ E3/9378 ou ឯកសារ E3/1262** ERN FR 0007614 ។ អត្ថបទមានចំណងជើងថា "សេចក្តីថ្លែងការរបស់អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេស" *ដំណឹងពីកម្ពុជា* ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៧៨ **ឯកសារ E3/1583**, ERN FR S00763961-66 ; អត្ថបទសារព័ត៌មាន "តួនាទីរបស់ទីក្រុងហាណូយមានភាពមិនច្បាស់លាស់នៅក្នុងរបាយការណ៍នៃការបះបោររបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា" *The Washington Post* ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៧៨ **ឯកសារ E3/7265**, ERN EN 00166105។

[965] សារទូរលេខរបស់សៅ សារុន ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៨ **ឯកសារ E3/937** និង ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៧៨ **ឯកសារ E3/1072** ទាក់ទងនឹងសកម្មភាពខ្លាំង ការដែលវៀតណាមចូលក្រុង ទេស (Krong Teh) និងការវាយបករបស់ខ្មែរក្រហម។

[966] ជួន ធី៖ ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ៤៩ ប្រហែលម៉ោង 13.44.55។

[967] សារទូរលេខរបស់អៀង សារី ផ្ញើទៅក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៩ **ឯកសារ E3/555**, ERN FR 00224428។

[968] ការអំពាវនាវរបស់ប៉ុល ពត ទៅកាន់ប្រជាជនកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៧៩ (SWB) **ឯកសារ E3/7311**, ERN FR 01378198។

៨៣២. ពេលវេលាប្រកបដោយគ្រោះថ្នាក់នេះ នៅតែជាដំណាក់កាលដ៏សំខាន់នៃជម្លោះ ដែលនឹងបន្តប៉ុន្មានឆ្នាំទៀត ជាមួយនឹងការក្រឡាប់ចាក់ខាងការទូត នៅខែ វិច្ឆិកា ឆ្នាំ ១៩៧៩ ជាពិសេស ដោយសារតែសម្ព័ន្ធភាពជាមួយសម្តេច សីហនុ[969] ប៉ុន្តែ នេះគឺជាជំពូកមួយទៀតនៃសង្គ្រាមដ៏រ៉ាំរ៉ៃនេះ។

## ភាគទី ៣. ផលវិបាកនៃជម្លោះប្រដាប់អាវុធក្នុងវិធីសាស្ត្រនៃសំណុំរឿង ០០២/០២

៨៣៣. យើងចាំបាច់ត្រូវចាប់ផ្តើមពិនិត្យលើអង្គហេតុនៃសំណុំរឿង ០០២/០២ ពីបរិបទទូទៅនៃជម្លោះប្រដាប់អាវុធជាមុន គឺដើម្បីបង្ហាញថា ការកាត់ជាកង់ៗតាមប្រធានបទដើម្បីងាយស្រួលកោះហៅសាក្សី មានគុណវិបត្តិជាចម្បងក្នុងការទុកជម្លោះប្រដាប់អាវុធមួយអន្លើ ហាក់ដូចជាអង្គហេតុផ្សេងទៀតកើតឡើងទន្ទឹមគ្នា និងផ្តាច់ដោយឡែកពីគ្នា ដោយមិនសមហេតុសមផល។ ផ្ទុយទៅវិញ ដូចសម្តីរបស់ក្រុមមេធាវីការពារក្តីបាននិយាយ នៅក្នុងការរំឭកជាបុព្វកថា ចង់បង្ហាញថា អង្គហេតុទាំងអស់ដែលកើតឡើងក្នុងសម័យកាលនៃយុត្តាធិការរបស់ អ.វ.ត.ក ជាប់ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ដោយមិនអាចកាត់ផ្តាច់ចេញបាន ដូចយើងនឹងឃើញនៅខាងក្រោម។

៨៣៤. ចំណុចនេះតម្រូវឱ្យអង្គជំនុំជម្រះទាញផលវិបាក ក្នុងការពិនិត្យលើអង្គហេតុ (ផ្នែកទី ១) និងលើការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ (ផ្នែកទី ២)។

### ផ្នែកទី ១. ផលវិបាកនៃជម្លោះនៅលើការពិនិត្យលើអង្គហេតុ

៨៣៥. ក្នុងសំណុំរឿង ០០២/០២ បទចោទប្រល័យពូជសាសន៍ពាក់ព័ន្ធនឹងជនជាតិចាម និងវៀតណាម។ បទចោទនេះនឹងត្រូវពិភាក្សាលម្អិតខាងក្រោម។ ប៉ុន្តែ គួរកត់សម្គាល់ថា ពាក្យប្រល័យពូជសាសន៍បានលេចឡើងលឿន នៅក្នុងការឃោសនារបស់វៀតណាម ដើម្បីផ្តល់យុត្តិកម្មចំពោះការលុកលុយចូលកម្ពុជា។

---

[969] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ នាសម័យប្រជុំលើកទី៣៤ ផ្តោតលើស្ថានការណ៍នៅកម្ពុជា A/RES/34/22 ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ **ឯកសារ E3/7247**, ERN FR 00644357។

៨៣៦. ប៉ុន្តែ លេស "មនុស្សធម៌" មិនថិតថេរបានយូរទេ[970]។ ដូចលោក Stephen MORRIS បានបញ្ជាក់នៅក្នុងសវនាការ វៀតណាមតែងតែចង់ក្តោបក្តាប់កិច្ចការកម្ពុជា ប៉ុន្តែ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រចាប់ពីឆ្នាំ ១៩៧៥ មក បានទប់ស្កាត់គោលបំណងរបស់ពួកគេ[971]។ ក្នុងល័ក្ខខ័ណ្ឌបែបនេះ វៀតណាមត្រូវបានសហគមន៍អន្តរជាតិមើលឃើញក្នុងរូបភាពថ្មី ដោយសារយកឈ្មោះជាប្រទេសរំដោះមិនអាចបោកបញ្ឆោតគេបាន។ អ្នកជំនាញក៏បានគូសបញ្ជាក់ផងដែរថា៖

> "ដោយសារតែវៀតណាមមិនត្រឹមតែផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ គឺកាន់កាប់កម្ពុជា១០ ឆ្នាំ និងប៉ុនប៉ងបង្កើតរបបមួយតាមការចង់បានរបស់ខ្លួន នៅកម្ពុជា។ ដូច្នេះ មនុស្សភាគច្រើនយល់ឃើញថាសកម្មភាពរបស់វៀតណាមមិនមែនជាការពារនោះទេ គឺឈ្លានពាន ដើម្បីបង្កើតរដ្ឋរណបមួយនៅកម្ពុជា" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[972]។

៨៣៧. ការចាត់ទុកអន្តរាគមន៍របស់វៀតណាមជាអន្តរាគមន៍មនុស្សធម៌ ជួយផ្តល់ឱ្យវៀតណាមនូវសម្បកស្របច្បាប់ចំពោះការលុកលុយចូលប្រទេសមួយ ដែលខ្លួនមានបំណងតាំងពីយូរយារណាស់មកហើយ។ លោក Philip SHORT បានរៀបរាប់អំពីគោលនយោបាយឃោសនា ដែលត្រូវបានរបបវៀតណាមរៀបចំឡើងភ្លាមៗ ដោយប្រកាសប្រាប់ប្រជាជនកម្ពុជាថាខ្លួនជាអ្នករំដោះ[973]។

៨៣៨. សាក្សី ដូចជា 2-TCW-1065 ដែលដំបូងឡើយ បានទទួលមុខតំណែងនៅក្នុងរបបថ្មី[974] ក្រោយមកត្រូវបានចាប់ដាក់គុក ដោយចោទថាប៉ុនប៉ងបះបោរ ដោយគ្មានការជំនុំជម្រះ ដោយសារតែបានតវ៉ាប្រឆាំងនឹងទិដ្ឋភាពនៃគោលនយោបាយថ្មី[975]។

---

[970]Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៤៨ ក្រោយម៉ោង 11.47.09 ៖ "ខ្ញុំមិនគិតថាវៀតណាមចូលឈ្លានពានប្រទេសកម្ពុជាដោយចេតនាមនុស្សធម៌ទេ។ ខ្ញុំគិតថាគុណតម្លៃជាមនុស្សមិនមាននៅ ក្នុងសារជាតិនៃការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តវៀតណាមនោះទេ ទោះបីជាការឈ្លានពាននេះមានលទ្ធផលមនុស្សធម៌ក៏ដោយ។ ប៉ុន្តែ លទ្ធផលនេះមិនមែនជាចេតនាវៀតណាមឡើយ។"

[971]Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/487.1** ទំព័រ ២៧-២៨។

[972]Stephen MORRIS : ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៤៧-៤៨ មុនម៉ោង 11.45.20។

[973]សៀវ ភៅរបស់ Philip SHORT, ប៉ុល ពត ប្រវត្តិនៃសុបិនអាក្រក់ ឆ្នាំ ២០០៤ **ឯកសារ E3/9** ទំព័រ ៥២៥-៥២៦ ERN FR 00639988។

[974]2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ២៣ ក្រោយម៉ោង 10.38.44។

[975]2-TCW-1065 : ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/494.1** ទំព័រ ២៥ ចាប់ពីម៉ោង 10.48.00។ សូម

៨៣៩. ទោះជាយ៉ាងនេះក្ដី សាធារណរដ្ឋសង្គមនិយមវៀតណាមប្រញាប់ប្រញាល់បង្កើតតុលាការបដិវត្តន៍ប្រជាជន ដែលបាន "កាត់សេចក្ដី" និងផ្ដន្ទាទោស ប៉ុល ពត និង អៀង សារី ដោយកំបាំងមុខ តាំងពីខែ សីហា ឆ្នាំ ១៩៧៩[976]។ គួរកត់សម្គាល់ថា ជុំវិញតុលាការនេះ សាធារណរដ្ឋសង្គមនិយមវៀតណាមបានបញ្ចេញនូវទស្សនាទាននៃ"អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងប្រជាជនខ្មែរ" ដែលក្លាយជាពាក្យស្លោកនៅប៉ុន្មានទសវត្សរ៍ខាងមុខ។

៨៤០. ម្យ៉ាងវិញទៀត គួរកត់សម្គាល់ថា សព្វថ្ងៃនេះ សាធារណរដ្ឋសង្គមនិយមវៀតណាមនៅតែរក្សាការទំនាក់ទំនងតាមរបៀបដដែល។ នៅក្នុងចម្លើយតែមួយគត់ ដែល អ.វ.ត.ក ទទួលបាន ទៅនឹងសំណើជាច្រើនស្ដីពីការសុំផ្ដល់ឯកសារ អាជ្ញាធរវៀតណាមបានប្រើភាសាដូចខាងក្រោម៖

> "ក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាមសូមសម្ដែងនូវសេចក្ដីកោតសរសើរចំពោះ អ.វ.ត.ក ហើយចំពោះឯកសារពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយខ្មែរក្រហមនៅវៀតណាមក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩..." (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[977]។

៨៤១. ដូច្នេះ ផលវិបាកដំបូងនៃការពិចារណាទៅលើជម្លោះប្រដាប់អាវុធ និងការប្រព្រឹត្តទៅជាហូរហែ គឺដើម្បីមានវិធីសាស្ត្រពិនិត្យមើលអង្គហេតុ ក្នុងគោលដៅចៀសវាងការភាន់ច្រឡំ រវាងការបង្ហាញនូវការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដូចការចោទប្រកាន់ និងផលវិបាកនៃសង្គ្រាមទៅលើសភាពការណ៍ផ្ទៃក្នុង។

## ផ្នែកទី ២. ផលវិបាកទៅលើការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ

---

មើល SUOS Thy : ប្រតិចារឹក ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/431.1** ទំព័រ ៥២-៥៣ ប្រហែលម៉ោង 11.25.42, ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/433.1** ទំព័រ ៤២-២៥ ចន្លោះម៉ោង 10.51.17 និង 10.57.31។

[976] ឯកសាររបស់អង្គការសហប្រជាជាតិ លេខ A/34/49 សាលក្រមនៃតុលាការប្រជាជនបដិវត្តន៍ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ១៩៧៩។

[977] លិខិតរបស់ក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអវតក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ **ឯកសារ E319/54.1**។

៨៤២. ក្រុមមេធាវីការពារក្តីបានចង្អុលបង្ហាញថា ខ្លួនយល់ស្របជាមួយអង្គជំនុំជម្រះថា ជម្លោះប្រដាប់អាវុធ រវាងវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ អាចចាប់ផ្តើម នៅខែ ឧសភា ឆ្នាំ ១៩៧៥។ ជម្លោះនេះបន្តដល់ហួសសម័យកាលយុត្តាធិការរបស់ អ.វ.ត.ក ទៅទៀត។ ចំណុចនេះនាំឱ្យមានផលវិបាកពីរខាងអង្គច្បាប់។

៨៤៣. ផលវិបាកទីមួយនៃអត្ថិភាពជម្លោះប្រដាប់អាវុធ ចន្លោះពីខែ ឧសភា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩ គឺភាពគ្មានប្រយោជន៍នៃការពិភាក្សាដេញដោលលើអត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធក្នុងការកំណត់ធាតុផ្សំបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ផលវិបាកមួយទៀតដោយប្រយោលនៃការប្រព្រឹត្តិទៅនៃជម្លោះប្រដាប់អាវុធ ពីខែ ឧសភា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩ (និងហួសពីនេះ) គឺការអនុវត្តអនុសញ្ញាទីក្រុងហ្សឺណែវ ចំពោះអង្គហេតុទាំងអស់ដែលកើតឡើងក្នុងរយៈកាលនោះ[978]។ អនុសញ្ញានេះត្រូវយកមកអនុវត្ត ទោះបីជារដ្ឋទាំងពីរបដិសេធស្ថានភាពសង្គ្រាមនេះក៏ដោយ[979]។ នេះជាករណី ក្នុងអំឡុងរយៈពេលជម្លោះមួយផ្នែកធំក្នុងទ្រង់ទ្រាយផ្សេងៗ។

៨៤៤. ការពិនិត្យមើលលម្អិតទៅលើជម្លោះប្រដាប់អាវុធ និងផលវិបាកទាំងនេះ គឺជាបុរេល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការពិចារណាលើអង្គហេតុ និងឧក្រិដ្ឋកម្ម។ ជាពិសេស នេះជាចំណុចសំខាន់ ដើម្បីយល់អំពីតួនាទី និងអាកប្បកិរិយារបស់លោក ខៀវ សំផន ក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ។

---

[978]មាត្រា ២ ជាមាត្រារួមសម្រាប់គ្រប់អនុសញ្ញាក្រុងហ្សឺណែវទាំងអស់៖ "អនុសញ្ញានេះ ត្រូវអនុវត្តក្នុងករណីមានការប្រកាសសង្គ្រាម ឬនៅក្នុងករណីមានជម្លោះប្រដាប់អាវុធផ្សេងទៀត ដែលបានផ្ទុះឡើងរវាងឧត្តមភាគីគូសញ្ញាពីរ ឬ ច្រើន ទោះបីជាឧត្តមភាគីគូសញ្ញាណាមួយក្នុងចំណោមនោះ ពុំទទួលស្គាល់ស្ថានភាពសង្គ្រាមក៏ដោយ"។ ដូចដែលបានកត់សម្គាល់នៅក្នុងសាលក្រម *ឌុច* គេគ្រាន់តែបង្ហាញឱ្យឃើញពី"ដំណោះស្រាយដោយប្រើកម្លាំងអាវុធរវាងរដ្ឋនានា"។ (សាលក្រម *ឌុច* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤១២)។

[979]គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ សេចក្តីអធិប្បាយលើអនុសញ្ញាក្រុងហ្សឺណែវ IV (Jean S. Pictet នាយកបោះពុម្ពផ្សាយ ឆ្នាំ ១៩៥៨) ទាក់ទងនឹងមាត្រា ២ ទំព័រ ២៦ (ភាសាបារាំង)។

# មាតិកាទី ៣. ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់

## ភាគទី ១. សហករណ៍ និងការដ្ឋានការងារ

### ជំពូកទី ១. សហករណ៍ត្រាំកក់

#### ផ្នែកទី ១ .បទចោទ

៨៤៥. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់ពីអង្គហេតុដែលបានកើតឡើងនៅសហករណ៍ត្រាំកក់ ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតកំណត់នៅក្នុងដីកាដំណោះស្រាយថា ជាការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា និងអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ) ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[980]។

៨៤៦. បទចោទមួយចំនួនត្រូវបានពិភាក្សានៅក្នុងផ្នែកផ្សេងទៀតនៃសេចក្តីសន្និដ្ឋាននេះ។ ដូចគ្នាដែរចំពោះអង្គហេតុដែលគាំទ្រដល់ការចោទប្រកាន់អំពីការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅកថាខណ្ឌ ១៤១៦ ការធ្វើទុកបុកម្នេញដោយមូលហេតុសាសនាប្រឆាំងនឹងពុទ្ធសាសនិក នៅកថាខណ្ឌ ១៤២១ នៃដីកាដំណោះស្រាយ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅកថាខណ្ឌ ១៤៤២[981]។

៨៤៧. ការពិនិត្យមើលការកម្រិតផ្នែកភូមិសាស្ត្រ (១) និងសម្ការភាពនៃបទចោទសេសសល់ (២) កំណត់នូវវិសាលភាពនៃអង្គហេតុ ដែលដាក់ជូនអង្គជំនុំជម្រះពិចារណា។ ជួនកាល សហចៅក្រមស៊ើប

[980] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១, ១៣៩១, ១៤០២, ១៤០៨, ១៤១៦, ១៤២១, ១៤៣៤, ១៤៤២ និង ១៤៧០, សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ** E301/9/1 កថាខណ្ឌ ៤៤, ឧបសម្ព័ន្ធ កំណត់ពីវិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ** E301/9/1.1 ទំព័រ ៣-៦។

[981] សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ១៤៨៧-១៥២១ (ពុទ្ធសាសនិក) កថាខណ្ឌ ២៣១០ និងកថាខណ្ឌបន្តបន្ទាប់ទៀត (ការរៀបអាពាហ៍ពិពាហ៍)។

អង្កេតធ្វើឲ្យហួសវិសាលភាពនៃបណ្ដឹង ពាក់ព័ន្ធនឹងអាណត្តិការងារ ដែលសហព្រះរាជអាជ្ញាបាន ប្រគល់ជូនពីដំបូង។

## ១. ការកម្រិតផ្នែកភូមិសាស្ត្រនៃបទចោទ

៨៤៨. នៅកថាខណ្ឌ ៣០២ នៃដីកាដំណោះស្រាយ ជាកថាខណ្ឌទីមួយនៃចំណងជើង "ទីតាំង និងការបង្កើត" សហករណ៍ត្រាំកក់ សហចៅក្រមស៊ើបអង្កេតបានបង្ហាញអំពីដែនដីអនុវត្តបណ្ដឹង ដូចបាន កំណត់នៅក្នុងកថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ជា កថាខណ្ឌតែមួយគត់នៃដីកានេះស្ដីពីសហករណ៍ត្រាំកក់៖

> "ស្រុកត្រាំកក់ ខេត្តតាកែវ មានឃុំចំនួន ៨៖ គូស សំរោង ត្រពាំងធំត្បូង ត្រពាំងធំជើង ត្រាំកក់ ញ៉ែងញ៉ង ស្រែរនោង និងតាភេម។ ផ្អែកតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ឃុំ ទាំងនេះស្ថិតនៅក្នុងស្រុក ១០៥ តំបន់ ១៣ ភូមិភាគនិរតី"[982]។

៨៤៩. ភាពខុសគ្នាតែមួយគត់រវាងកថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងកថាខណ្ឌ ៣០២ នៃដីកាដំណោះស្រាយ គឺពាក្យប្រើប្រាស់សម្រាប់ហៅអង្គភាពរដ្ឋបាល ដែលជាកម្មវត្ថុនៃ ការស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតហៅថា « sous-district » (sub-district) ឯសហ ព្រះរាជអាជ្ញាហៅថា « commune »។ សហចៅក្រមស៊ើបអង្កេតមិនដែលពន្យល់ថាហេតុអ្វីបាន ជាខ្លួនចូលចិត្តពាក្យនេះជាងពាក្យប្រើប្រាស់ដោយសហព្រះរាជអាជ្ញានោះទេ ហើយពេលខ្លះ សហ ចៅក្រមស៊ើបអង្កេតប្រើពាក្យទាំងពីរនេះ សម្រាប់ហៅកន្លែងតែមួយ[983]។

៨៥០. នៅចុងកថាខណ្ឌ ៣០៣ នៃដីកាដំណោះស្រាយ ជាកថាខណ្ឌទីពីរ និងចុងក្រោយ នៃចំណងជើង "ទីតាំង និងការបង្កើត" សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា៖

---

[982] ដីកាដំណោះស្រាយ កថាខណ្ឌ ៣០២។ បើទោះជាពេលខ្លះ ការបកប្រែភស្តុតាងនៅក្នុងសំណុំរឿង មានភាពខុសគ្នាខ្លះក៏ដោយ ក៏ឈ្មោះឃុំនៅតែសរសេរដូចគ្នាដដែល ដូចនៅក្នុងកថាខណ្ឌ ៣០២ នៃដីកាដំណោះស្រាយ ក្នុងផ្នែកបន្ទាប់ទៀតនៃសារណានេះ លើកលែងតែក្នុងករណីដែលឈ្មោះទាំងនោះត្រូវបានស្រង់ពីការយោង។ អត្ថន្តរសញ្ញា នឹងប្រាប់ពីករណីទាំងនេះ រៀងរាល់ពេល ដែលវាកើតមានម្ដងៗ។

[983] ដីកាដំណោះស្រាយ សូមមើលជាឧទាហរណ៍ កថាខណ្ឌ ៣១៧ និង ១៤០៥ រួមគ្នា។

"ទោះជាយ៉ាងនេះក្តី ឃុំទាំងអស់ក្នុងស្រុកត្រាំកក់ ទំនងជាត្រូវបានប្តូរទៅជាសហករណ៍ នៅខែ មេសា ឆ្នាំ ១៩៧៧ និងបន្តរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ" (យើងខ្ញុំជាអ្នកគូរបន្ទាត់ពីក្រោម)។

៨៥១. ការសន្និដ្ឋាននេះនាំឱ្យគេគិតថា ឃុំទាំង ៨ នៃស្រុកត្រាំកក់ បង្កើតបានជាស្រុកទាំងមូល ហើយអង្គជំនុំជម្រះទទួលបណ្តឹងទៅលើអង្គហេតុ ដែលកើតឡើងនៅទូទាំងស្រុកនេះ។

៨៥២. ការសន្និដ្ឋាននេះដោយពាក្យពេចន៍នៃដីកាដំណោះស្រាយ មិនត្រឹមត្រូវទេ។ ការគិតថាស្រុកនេះមាន ៨ ឃុំ ដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងក្នុងដីកាដំណោះស្រាយ ត្រូវបានបដិសេធដោយការពិនិត្យលើភស្តុតាងដូចខាងក្រោម[984]។ ចំណុចនេះមានផលវិបាកដ៏ធំធេងទៅលើយុត្តាធិការរបស់អង្គជំនុំជម្រះ។

## ២. ការកម្រិតជាក់ស្តែងនៃបទចោទ

### ក. ការសម្លាប់រង្គាល

៨៥៣. ក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅកថាខណ្ឌ ១៣៨១ ថាឧក្រិដ្ឋកម្មសម្លាប់រង្គាលមានធាតុផ្សំគ្រប់គ្រាន់ ហើយពាក់ព័ន្ធទៅនឹង "ជនដែលត្រូវបានសម្លាប់ ឬជនដែលបានស្លាប់ ក្នុងទ្រង់ទ្រាយធំ" នៅតាមទីតាំងជាច្រើន ដូចជា សហករណ៍ត្រាំកក់ ជាដើម។

៨៥៤. បន្ទាប់មកទៀត នៅក្នុងកថាខណ្ឌ ១៣៨២ និងកថាខណ្ឌ ១៣៨៣ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា៖

"១៣៨២. ទាក់ទងនឹងធាតុផ្សំសត្យានុម័តិ អំពើសកម្ម និងអកម្មរបស់ចារី ទោះបីជាអំពើនោះត្រូវបានប្រព្រឹត្តដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី បានបណ្តាលឱ្យមានការស្លាប់បាត់បង់អាយុជីវិតមនុស្សជាច្រើននាក់ រួមទាំងការបង្កើតនូវល័ក្ខខ័ណ្ឌជីវិតដ៏លំបាកលំបិន ដើម្បីឈានទៅរកការបំផ្លាញប្រជាជនមួយភាគ។ ទោះបីជាគេពុំមានតួលេខច្បាស់លាស់ដែលបញ្ជាក់អំពីចំនួននៃអ្នកស្លាប់ និងការកំណត់អត្តសញ្ញាណនៃ

[984]សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ៩១៥-៩២៣។

សាកសពទាំងឡាយរបស់ជនរងគ្រោះក៏ដោយ ក៏ភស្តុតាងនានានៃសំណុំរឿងមានលក្ខណៈគ្រប់គ្រាន់អាចបញ្ជាក់អំពីការស្លាប់របស់មនុស្សដែលមានចំនួនដល់ទៅរាប់ម៉ឺននាក់។

១៣៨៣. ប្រសិនណាជាពុំមានចំនួនអប្បបរមានៃជនរងគ្រោះ ដើម្បីធ្វើការកំណត់ប្រភេទបទល្មើសសម្លាប់រង្គាលនោះទេ ក្នុងករណីជាក់ស្តែងនីមួយៗ ដូចបានរៀបរាប់ខាងលើ [គឺដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៣៨១] ដោយយោងទៅលើចំនួននៃអ្នកស្លាប់ដែលបានកំណត់នៅក្នុងឯកសារ ឬតាមរយៈសក្ខីកម្មនានា និងដែលបានបញ្ជាក់តាមរយៈសាកសពដ៏ច្រើនសន្ធឹកសន្ធាប់ ដែលគេបានរកឃើញនៅក្នុងរណ្តៅសពនានា <u>ក៏ដូចជាភស្តុតាងរឹងមាំលម្អិតនានាខាងក្រោម</u> អំពើដែលបានលើកឡើងនេះបានឈានដល់ទំហំធំគ្រប់គ្រាន់ និងមានចរិតលក្ខណៈជាសមូហភាព" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីខាងក្រោម)។

៨៥៥. កថាខណ្ឌ ១៣៨២ ដល់កថាខណ្ឌ ១៣៨៧ រៀបរាប់អំពី "ធាតុផ្សំពាក់ព័ន្ធ" ដែលត្រូវពិចារណាសម្រាប់ទីតាំងនីមួយៗ។ នៅក្នុងឃ្លាទាំងនេះ មានការនិយាយសំដៅដល់សហករណ៍ត្រាំកក់។

៨៥៦. ដូច្នេះ មានតែរឿងរ៉ាវនៃអង្គហេតុ ដែលកើតឡើងនៅសហករណ៍ត្រាំកក់ ពីកថាខណ្ឌ ៣០២ ដល់កថាខណ្ឌ ៣២១ នៃដីកាដំណោះស្រាយ អាចឱ្យកំណត់អំពីវិសាលភាពនៃអង្គហេតុដែលត្រូវបានកំណត់ថាជាការសម្លាប់រង្គាល នៅកថាខណ្ឌ ១៣៨១។

៨៥៧. សម្រង់បីនៃកថាខណ្ឌ ៣១២ កថាខណ្ឌ ៣១៣ និងកថាខណ្ឌ ៣២០ បង្ហាញអំពីមនុស្សស្លាប់។ យោងតាមកថាខណ្ឌ ១៣៨២ នៃដីកាដំណោះស្រាយ មានតែអង្គហេតុទាំងនេះដែលអាចបង្កើតបានជាឧក្រិដ្ឋកម្មសម្លាប់រង្គាល។

1. <u>**ការស្លាប់ដោយសារអត់អាហារ**</u>

៨៥៨. កថាខណ្ឌ ៣១២ នៃដីកាដំណោះស្រាយ ចែងថា "សាក្សីខ្លះបានបញ្ជាក់ថា មានប្រជាជនស្លាប់ដោយសារអត់បាយ ខណៈដែលអ្នកខ្លះទៀតអះអាងថាមិនបានដឹង"។ ផ្នែកដំបូងនៃសេចក្តីសន្និដ្ឋានស្របតាមអាណត្តិដែលប្រគល់ជូនដោយកថាខណ្ឌ ៥៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលចង្អុលបង្ហាញថា "ប្រជាជនរាប់ពាន់នាក់បានអត់បាយរហូតដល់ស្លាប់" នៅតាមសហករណ៍ត្រាំកក់។ ខៀវ សំផន ត្រូវទទួលខុសត្រូវ។

2. **ការស្លាប់ដោយសារបញ្ហាសុខភាព**

៨៥៩. នៅកថាខណ្ឌ ៣១៣ នៃដីកាដំណោះស្រាយ នៅពេលបញ្ចប់ការរៀបរាប់អំពីបញ្ហាសុខភាព នៅតាមសហករណ៍ សហចៅក្រមស៊ើបអង្កេតបានលើកឡើងអំពីការស្លាប់មនុស្ស៖

> "មនុស្សជាច្រើនរស់នៅក្នុងសហករណ៍មានបញ្ហាសុខភាព ជាពិសេស អ្នកដែលត្រូវបានគេជម្លៀសដែលមិនស៊ាំនឹងការរស់នៅតាមទីជនបទ។ អ្នកមានជំងឺត្រូវបានព្យាបាលដោយពេទ្យឃុំ។ ក៏ប៉ុន្តែ ការព្យាបាលធ្វើឡើងតាមបែបបុរាណ និងថ្នាំដែលត្រូវបានផលិតនៅក្នុងស្រុក។ អ្នកជំងឺត្រូវបានផ្តល់ថ្នាំដែលធ្វើពីឫសឈើ និងថ្នាំអាចម៍ទន្សាយ។ អ្នកជំងឺត្រូវបានផ្តល់ថ្នាំចាក់ជាប្រភេទប៉េនីសេលីន លាយជាមួយទឹកដូង។ គ្រូពេទ្យគឺជាកម្មាភិបាលនារីរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមិនបានទទួលការបណ្តុះបណ្តាលជាផ្លូវការឡើយ។ ពួកគេភាគច្រើនមានអាយុចន្លោះពី ១២ ទៅ ១៣ ឆ្នាំ។ <u>នៅពេលមានមនុស្សស្លាប់ សាកសពត្រូវកប់ និងគ្មានការជូនដំណឹងដល់គ្រួសារទេ</u>" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៨៦០. ម្យ៉ាងវិញទៀត ទោះបីជាកថាខណ្ឌ ៣១៣ ចែងបែបនេះក៏ដោយ ក៏ឃ្លាចុងក្រោយមិនបានបង្ហាញទំនាក់ទំនង រវាងការស្លាប់មនុស្ស និងបញ្ហាសុខភាព ឬភាពទន់ខ្សោយនៃប្រព័ន្ធព្យាបាលដោយសារតែគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាឡើយ គឺគ្រាន់តែប្រាប់អំពីអវត្តមាននៃពិធីបុណ្យសពប៉ុណ្ណោះ។

៨៦១. ម្យ៉ាងវិញទៀត ទោះបីជាឧបមាថាពិតជាមានទំនាក់ទំនងនេះមែន ក៏សហព្រះរាជអាជ្ញាមិនធ្លាប់ប្តឹងចៅក្រមស៊ើបអង្កេតឱ្យស៊ើបសួរអំពីការស្លាប់ ដោយសារតែបញ្ហាសុខភាពនៅត្រាំកក់នោះទេ។ ពិតណាស់ ការលំបាកទាំងនេះអាចកើតចេញពីកង្វះស្បៀងអាហារដែលសហចៅក្រមស៊ើបអង្កេតបានទទួលបណ្តឹង។ ប៉ុន្តែ នៅកថាខណ្ឌ ៣១៣ សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញអំពីទំនាក់ទំនងហេតុ និងផល រវាងការខ្វះខាតស្បៀង និងការលេចឡើងនូវជំងឺនោះទេ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតបានរៀបរាប់តែអំពីការពិបាកស៊ាំរបស់អ្នកទីក្រុងនឹងការរស់នៅទីជនបទ ថាជាមូលហេតុនៃជំងឺ។ លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេតបានប្រាប់អំពីការផ្តល់ការព្យាបាលជាមូលដ្ឋានដល់អ្នកជំងឺ។

៨៦២. ជាក់ស្តែង នៅកថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហព្រះរាជអាជ្ញាស្នើសុំឱ្យស៊ើបអង្កេតលើការសម្លាប់ "មនុស្សរាប់ពាន់នាក់" ដោយសារការអត់អាហារដែលបញ្ហានេះកាន់តែធ្ងន់ធ្ងរឡើងដោយសារការរឹបអូសស្បៀងអាហារ តាមបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា។ សហចៅក្រមស៊ើបអង្កេតបានឆ្លើយតប តាមរយៈការសង្កេតជាធម្មតា ទៅលើការស៊ាំរបស់អ្នកទីក្រុង ភាពទន់ខ្សោយនៃប្រព័ន្ធសុខាភិបាលសាធារណៈ និងការមិនជូនដំណឹងដល់គ្រួសារ ក្នុងករណីមានមនុស្សស្លាប់។

៨៦៣. ការសន្និដ្ឋានបែបនេះរំលោភបំពានលើការប្តឹងទៅសហចៅក្រមស៊ើបអង្កេត។ លោក ខៀវ សំផន មិនត្រូវទទួលខុសត្រូវចំពោះអង្គហេតុ ដែលមានចែងនៅក្នុងកថាខណ្ឌ ៣១៣ ដែលអង្គជំនុំជម្រះបានទទួលដោយខុសច្បាប់។

3. **ការសម្លាប់ជនជាតិវៀតណាម**

៨៦៤. កថាខណ្ឌ ៣២០ នៃដីកាដំណោះស្រាយ លើកឡើងអំពីសក្ខីកម្មរបស់បុគ្គលម្នាក់អំពីការប្រព្រឹត្តិចំពោះជនជាតិវៀតណាម នៅពេលបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ៖

> "អតីតគ្រូបង្រៀន ក្នុងកងកុមារ ក្នុងឃុំញ៉ៀងញ៉ង បាននិយាយថា ក្នុងឆ្នាំ ១៩៧៦ ប្រធានឃុំបានប្រកាសថា សមាជិកឃុំជាជនជាតិវៀតណាមនឹងត្រូវបញ្ជូនត្រឡប់ទៅវៀតណាមវិញ។ គាត់បានចាំថាមានការចាប់ខ្លួន និងការសម្លាប់អ្នកដែលនិយាយកុហកអំពីពូជសាសន៍របស់ខ្លួន ដែលសង្ស័យថាអាចបានរួចខ្លួន។ សាក្សីរូបនេះបាននិយាយថា មានពីរដំណាក់កាល ពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិវៀតណាម។ លើកទីមួយ ប្រជាជនវៀតណាមពិតជាត្រូវបានបញ្ជូនទៅវៀតណាមវិញមែន។ ក៏ប៉ុន្តែ ក្នុងដំណាក់កាលទី ២ ប្រជាជនវៀតណាមត្រូវបានចាប់យកទៅសម្លាប់"។

៨៦៥. កថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនមានលើកឡើងអំពីការចោទប្រកាន់អំពីការសម្លាប់ជនជាតិវៀតណាមនោះទេ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋាន នៅកថាខណ្ឌ ៣២០ នៃដីកាដំណោះស្រាយ ដោយរំលោភលើអាណត្តិរបស់ខ្លួន។

៨៦៦. ម្យ៉ាងវិញទៀត ការសម្លាប់ជនជាតិវៀតណាម នៅឃុំញ៉ែងញ៉ង់ ទំនងជាត្រូវបានប្រព្រឹត្ត ក្នុងបរិបទជាទូទៅនៃការបញ្ជូនជនជាតិវៀតណាមទៅវៀតណាមវិញ។ ក៏ប៉ុន្តែ ដូចបានបញ្ជាក់ពេលចាប់ផ្តើមការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ និងរំឭកខាងលើ សហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបសួរខុសច្បាប់ទៅលើអង្គហេតុនេះដោយខ្លួនឯង[985]។ ដូច្នេះ អង្គជំនុំជម្រះគ្មានយុត្តាធិការកាត់សេចក្តីទៅលើអង្គហេតុទាំងនេះទេ។

## ខ. ការធ្វើឱ្យទៅជាទាសករ

៨៦៧. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយ ថា ឧក្រិដ្ឋកម្មនៃការធ្វើឱ្យជាទាសករនៅត្រាំកក់ មានធាតុផ្សំគ្រប់គ្រាន់ យោងតាមកថាខណ្ឌ ១៣៩២៖

> "បុគ្គលិកនៃសហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខទាំងនេះ បាន<u>អនុវត្តការគ្រប់គ្រង និងអំណាចទាំងស្រុង</u> ដែលដូចគ្នានឹងសិទ្ធិកម្មសិទ្ធិ ទៅលើបុគ្គលដែលស្ថិតនៅទីនោះ ដោយមិនឱ្យបុគ្គលទាំងនោះមានលទ្ធភាពក្នុងការយល់ព្រមទទួលយកឡើយ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៨៦៨. សហចៅក្រមស៊ើបអង្កេតបន្ថែមទៀតនៅកថាខណ្ឌ ១៣៩៤ ថា៖

> "ជាងនេះទៅទៀត នៅគ្រប់កន្លែងដែលបានរៀបរាប់ខាងលើ រួមទាំងមន្ទីរសន្តិសុខផង ជនរងគ្រោះត្រូវបានបង្ខំឱ្យធ្វើការដែលខ្លួនមិនចង់ធ្វើ ដោយគ្មានប្រាក់ខែ និងដោយពួកគេមិនបានទទួលផលដោយផ្ទាល់ពីការងារនោះ។ កន្លែង ពេលវេលា និងម៉ោងធ្វើការ ត្រូវបានគេកំណត់។ ជនរងគ្រោះមិនមានសិទ្ធិបដិសេធមិនទទួលការងារដែលប្រគល់ឱ្យនោះទេ។ ការងារនេះ ជាមួយនឹងធាតុការគ្រប់គ្រងដែលបានរៀបរាប់ខាងលើ បានដកហូតពីជនរងគ្រោះនូវអំណាចសម្រេចរបស់ខ្លួន និងបង្កើតបានជាការធ្វើឱ្យទៅជាទាសករ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៨៦៩. ដូច្នេះ បើតាមសហចៅក្រមស៊ើបអង្កេត ឧក្រិដ្ឋកម្មបានសម្រេចឡើង ដោយការបំពេញធាតុផ្សំពីរ៖ ការអនុវត្តការគ្រប់គ្រងជាបន្តទៅលើអ្នកទោស និងការបង្ខំឱ្យពួកធ្វើការ ដោយគ្មានប្រាក់កម្រៃ។

---

[985]សូមមើលផ្នែកខាងលើ កថាខណ្ឌ ២១៩-២៧៦។

៨៧០. ការសន្និដ្ឋាននេះផ្អែកលើអង្គហេតុជាច្រើន ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ៣០២ និងកថាខណ្ឌ ៣២១ នៃដីកាដំណោះស្រាយ ដែលលោក ខៀវ សំផន ត្រូវតែជំនុំជម្រះដោយផ្អែកលើអង្គហេតុទាំងនេះ។

## គ. ការដាក់ក្នុងមន្ទីរឃុំឃាំង

៨៧១. នៅកថាខណ្ឌ ១៤០២ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំងនៅត្រាំកក់ មានធាតុផ្សំគ្រប់គ្រាន់។ នៅកថាខណ្ឌ ១៤០៥ សហចៅក្រមស៊ើបអង្កេតរៀបរាប់លម្អិតអំពីអង្គហេតុ ដែលស្ថិតនៅក្នុងការកំណត់ប្រភេទនៃកថាខណ្ឌ ១៤០២៖

> "នៅសហករណ៍ត្រាំកក់ ឈ្លបឃុំចាប់ឃុំខ្លួន និងសួរចម្លើយមនុស្ស នៅក្នុងមន្ទីរឃុំឃាំង ដែលស្ថិតនៅក្រោមឱវាទកងឈ្លបឃុំ"។

៨៧២. ដូច្នេះ បើតាមសហចៅក្រមស៊ើបអង្កេត ឧក្រិដ្ឋកម្មមានធាតុផ្សំគ្រប់គ្រាន់ ទៅទីតាំងមួយ ដែលគ្មានឈ្មោះ ប៉ុន្តែ កំណត់ថាជា "មន្ទីរឃុំឃាំងស្ថិតក្រោមឱវាទកងឈ្លបឃុំ"។

៨៧៣. អត្ថិភាពនៃមន្ទីរឃុំឃាំងឃុំមួយត្រូវបានលើកឡើង នៅកថាខណ្ឌ ៣១៧ នៃដីកាដំណោះស្រាយ ស្តីពីសហករណ៍ត្រាំកក់។ សម្រង់នេះជាមូលដ្ឋានៃការចោទប្រកាន់នៅកថាខណ្ឌ ១៤០៥ នៃដីកាដំណោះស្រាយ។ អត្ថសញ្ញាណ នៃរូបមន្តដែលប្រើប្រាស់នៅកថាខណ្ឌ ៣១៧ និងកថាខណ្ឌ ១៤០៥ ធានាអំពីទំនាក់ទំនងរវាងកថាខណ្ឌទាំងពីរ ដែលបង្កើតឡើងដោយសហចៅក្រមស៊ើបអង្កេត។ ជាក់ស្តែង យោងតាមកថាខណ្ឌ ៣១៧៖

> "ពួកឈ្លបឃុំមានសិទ្ធិចាប់ខ្លួន ឃុំខ្លួន និងសួរចម្លើយប្រជាជន។ ប៉ុន្តែ សាក្សីខ្លះបញ្ជាក់ថា ឈ្លបមិនមានអំណាចក្នុងការសម្លាប់ឡើយ ដែលនេះត្រូវសម្រេចដោយថ្នាក់ស្រុក។ សាក្សីម្នាក់ ដែលរស់នៅក្នុងឃុំសំរោង បាននិយាយបញ្ជាក់អំពីកិច្ចប្រជុំ ដែលពេលនោះ ប្រជាជនត្រូវគេចោទថាបានប្រព្រឹត្តមិនត្រឹមត្រូវ ហើយគាត់បានឃើញកម្មាភិបាលកោរសក់បុរស និងស្ត្រី ចេញជាសញ្ញាខ្វែងជើងក្អែក មុនពេលបណ្តើរពួកគេមក

មុខអង្គប្រជុំ។ បន្ទាប់មក ប្រជាជនទាំងនេះត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងដោយឈ្លបឃុំ” (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៨៧៤. ដូច្នេះ មាន “មន្ទីរឃុំឃាំងមួយ ស្ថិតក្រោមកងឈ្លបឃុំ” នៅក្នុងឃុំសំរោង ជាឃុំមួយក្នុងចំណោមឃុំទាំង ៨ ស្ថិតក្រោមវិសាលភាពនៃកិច្ចស៊ើបសួរនៅស្រុកត្រាំកក់[986]។

៨៧៥. ទោះបីជាសហព្រះរាជអាជ្ញាមិនបានបង្ហាញច្បាស់អំពីអត្ថិភាពនៃមន្ទីរឃុំឃាំងនេះក៏ដោយ ក៏អង្គហេតុរៀបរាប់ដោយសហចៅក្រមស៊ើបអង្កេត ស្ថិតនៅក្នុងវិសាលភាពដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣ ដែលលើកឡើងអំពីអង្គហេតុនៃការ “ឃុំឃាំងខុសច្បាស់”[987]។ លោក ខៀវ សំផន ត្រូវតែជំនុំជម្រះពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ។

## ឃ. ការធ្វើទារុណកម្ម

៨៧៦. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤០៨ នៃដីកាដំណោះស្រាយ ថា ឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម មានធាតុផ្សំគ្រប់គ្រាន់ នៅតាមទីតាំងជាច្រើន ក្នុងនោះ មានសហករណ៍ត្រាំកក់ផងដែរ។

៨៧៧. អង្គហេតុនៃការធ្វើទារុណកម្មត្រូវបានរៀបរាប់នៅកថាខណ្ឌ ៣១៧ នៃដីកាដំណោះស្រាយ ស្តីពីសហករណ៍ត្រាំកក់។ ក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីអង្គហេតុនៃការឃុំឃាំង សហចៅក្រមស៊ើបអង្កេតគូសបញ្ជាក់ថា៖

> “ឯកសារស្រុក ១០៥ ជាច្រើនបានបញ្ជាក់ថា ឈ្លបឃុំបានសួរចម្លើយអ្នកទោស ដោយប្រើវិធីក្តៅ និងត្រជាក់ មុនពេលបញ្ជូនមកថ្នាក់ស្រុក។ ឧទាហរណ៍ ឯកសារមួយ ដែលផ្ញើពីឃុំមួយក្នុងស្រុកត្រាំកក់ទៅគណៈស្រុក បានស្នើសុំឱ្យស្រុកផ្តល់យោបល់អំពីយុវជនមួយរូប ដែលត្រូវបានចោទប្រកាន់ថាប្រព្រឹត្តអំពើលួចជាច្រើនដង ថាបាន៖ *ធ្វើមិទ្ទិងក្នុងកងឱ្យកាត់ទោស ៣ ដង រហូតបណ្តោយឱ្យយុវជនកងយកមកវុំកៅស៊ូមុខវៀវចសួរចម្លើយ ក៏នៅមិនរាងចោលដែរ* ”។

[986]ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៣, ដីកាដំណោះស្រាយ កថាខណ្ឌ ៣០២។

[987]ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៣។

៨៧៨. សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្ដីសន្និដ្ឋានទាំងនេះ ដោយរំលោភទៅនឹងបណ្ដឹងមកកាន់ខ្លួន។ អង្គហេតុនៃការសួរចម្លើយ ឬធ្វើទារុណកម្មលើរូបកាយ ឬផ្លូវចិត្ត មិនមានចែងនៅក្នុងកថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នោះទេ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនបានទទួលអាណត្តិ ដើម្បីស៊ើបអង្កេតលើអង្គហេតុទាំងនេះទេ[988]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនបានទទួលបណ្ដឹងត្រឹមត្រូវតាមច្បាប់នោះទេ ហើយលោក ខៀវ សំផន មិនមានអ្វីត្រូវជំនុំជម្រះពីអង្គហេតុទាំងនេះឡើយ។

## ខ. ការធ្វើទុកបុកម្នេញដោយមូលហេតុពូជសាសន៍

៨៧៩. នៅកថាខណ្ឌ ១៤២២ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានកំណត់យកឧក្រិដ្ឋកម្មនៃការធ្វើទុកបុកម្នេញដោយមូលហេតុពូជសាសន៍ ជាអង្គហេតុដែលបានប្រព្រឹត្តចំពោះជនជាតិភាគតិចវៀតណាម នៅតាមសហករណ៍ត្រាំកក់[989]។ ការកំណត់ប្រភេទនេះមានបង្ហាញច្បាស់នៅកថាខណ្ឌ ៣២០ នៃដីកាដំណោះស្រាយ ស្ដីពីការបញ្ជូនជនជាតិវៀតណាមទៅប្រទេសវៀតណាមវិញ ជាអង្គហេតុដែលត្រូវបានស៊ើបអង្កេតដោយគ្មានអាណត្តិ[990]។

៨៨០. សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្ដីសន្និដ្ឋានទាំងនេះ ដោយរំលោភទៅនឹងបណ្ដឹងមកកាន់ខ្លួន។ នៅកថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហព្រះរាជអាជ្ញាមិនបានចោទប្រកាន់អំពីអង្គហេតុនៃការរើសអើងពូជសាសន៍នៅត្រាំកក់នោះឡើយ។ អាស្រ័យហេតុនេះ លោក ខៀវ សំផន មិនត្រូវជំនុំជម្រះលើអង្គហេតុទាំងនេះឡើយ។

៨៨១. ប៉ុន្តែ ភ័ស្តុតាងមួយទាក់ទាញចំណាប់អារម្មណ៍ ក្នុងចំណោមសេចក្ដីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត។ ដើម្បីជាការគាំទ្រដល់សេចក្ដីអត្ថាធិប្បាយដោយខុសច្បាប់ នៅក្នុងកថាខណ្ឌ ៣២០ នៃដីកាដំណោះស្រាយ "របាយការណ៍មួយរបស់ឃុំអង្គតាសោម ស្ដីពីការចុះបញ្ជីខ្មែរក្រោម" ត្រូវ

[988] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២២។

[989] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២២។

[990] ដីកាដំណោះស្រាយ កថាខណ្ឌ ៣២០, សូមមើលផ្នែកខាងលើ កថាខណ្ឌ ២១៩-២៧៦។

បានដកស្រង់មកយកធ្វើជាសំអាង។ ក៏ប៉ុន្តែ "អង្គតាសោម" ជាឃុំមួយដែលមិនមានលើកឡើងនៅក្នុងកថាខណ្ឌ ៣០២ នៃដីកាដំណោះស្រាយ។ កថាខណ្ឌនេះរៀបរាប់តែឃុំចំនួន ៨ នៃស្រុកត្រាំកក់ប៉ុណ្ណោះ។

៨៨២. វិធីអនុវត្តន៍ដោយអយុត្តធម៌នេះ នាំឱ្យមានមតិយោបល់ជាច្រើន។ ជាដំបូង ក្នុងពេលស៊ើបសួរ សហចៅក្រមស៊ើបអង្កេតតែងតែចាត់ទុកថាខ្លួនឯងទទួលបានបណ្តឹងអំពីអង្គហេតុដោយឯកឯង ដើម្បីបំពេញបន្ថែមអវត្តមាននៃអាណត្តិដែលទទួលបានពីសហព្រះរាជអាជ្ញា។ បន្ទាប់មកទៀត វិធីនេះបង្ហាញអំពីការមានះរបស់ចៅក្រមក្នុងការស៊ើបអង្កេតតែដាក់បន្ទុក ដោយបំភ្លេចចោលនូវភារកិច្ចរបស់ខ្លួនដែលត្រូវស៊ើបអង្កេតដោះបន្ទុកផងដែរ។ វិធីនេះបញ្ជាក់ផងដែរថា អង្គហេតុដែលមានចែងនៅក្នុងដីកាដំណោះស្រាយ មិនត្រូវបានបញ្ជូនទៅជំនុំជម្រះទាំងអស់នោះទេ។ ចំណុចនេះបញ្ជាក់ច្បាស់អំពីសម្តីរបស់ចៅក្រម Marcel LEMONDE ស្តីពីភាពចាំបាច់ក្នុងការសេចសេចក្តីសន្និដ្ឋាន "ដើម្បីប្រវត្តិសាស្ត្រ[991]។ ជាចុងក្រោយ វិធីសាស្ត្រនេះទាមទារឱ្យមានការប្រុងប្រយ័ត្ន ពីព្រោះព័ត៌មានអំពីអត្ថិភាពនៃឃុំផ្សេងទៀត ក្នុងស្រុកត្រាំកក់ ក្រៅពីឃុំទាំង ៨ នៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ មិនអាចពង្រីកវិសាលភាពនៃបណ្តឹងខាងភូមិសាស្ត្រទៅកាន់សហចៅក្រមស៊ើបអង្កេតបានឡើយ។

## ច. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

៨៨៣. នៅកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានកំណត់យកឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅតាមទីតាំងជាច្រើន ក្នុងនោះមានសហករណ៍ត្រាំកក់ផងដែរ។

៨៨៤. ជាបឋម កថាខណ្ឌ ១៤១៧ បានផ្តល់ព័ត៌មានទូទៅអំពីការយល់ដឹងអំពីឧក្រិដ្ឋកម្ម ដែលអនុវត្តចំពោះគ្រប់ទីតាំងឧក្រិដ្ឋកម្មទាំងអស់៖

[991]សូមមើលផ្នែកខាងលើ កថាខណ្ឌ ៩៥។

"អាជ្ញាធរនៃបក្សកុម្មុយនីស្តកម្ពុជាបានកំណត់អត្តសញ្ញាណខ្មាំងជាច្រើនក្រុម ដោយសារមូលហេតុទស្សនៈនយោបាយពិតប្រាកដ ឬសន្មត របស់ក្រុមមនុស្សទាំងនោះ ឬដោយសារមូលហេតុនៃការប្រឆាំងរបស់ពួកគេទៅនឹងអ្នកកាន់អំណាច នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ មនុស្សប្រភេទខ្លះនៃក្រុមមនុស្សទាំងនេះ ដូចជា អតីតថ្នាក់ដឹកនាំស៊ីវិល និងយោធា នៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានរាប់បញ្ចូលក្នុងផែនការរួមនៃការកសាងលទ្ធិសង្គមនិយម។ ចំណែកឯភ្នាក់ងារតូចតាចនៃរបបចាស់ អ្នកខ្លះត្រូវបានចាប់ខ្លួនភ្លាមៗ បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាដណ្តើមបានអំណាច ដោយសារការគាំទ្ររបស់ខ្លួនដល់រដ្ឋាភិបាលចាស់ ហើយជាញឹកញាប់ ពួកគេត្រូវបានសម្លាប់នៅតាមមន្ទីរសន្តិសុខ ដូចជា មន្ទីរ ស-២១ ឬទួលពោធិ៍ជ្រៃ។ ប្រជាជនទាំងអស់ ដែលស្ថិតនៅតាមទីប្រជុំជន នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាដណ្តើមបានអំណាច ត្រូវបានចាត់ទុកជាប្រជាជនថ្មី ឬប្រជាជន ១៧ មេសា និងបានស្ថិននៅក្រោមការប្រព្រឹត្តិតឹងរ៉ឹងជាងប្រជាជនចាស់ ក្នុងគោលបំណងលត់ដំ ឬកំណត់អត្តសញ្ញាណខ្មាំង នៅក្នុងចំណោមពួកគេ។ បញ្ញវន្ត និស្សិត និងអ្នកការទូតដែលរស់នៅបរទេស ត្រូវបានហៅឱ្យត្រឡប់ចូលស្រុកវិញ ហើយនៅពេលមកដល់ ពួកគាត់ត្រូវបានបញ្ជូនទៅជំរំលត់ដំ ឬទៅមន្ទីរ ស-២១" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[992]។

៨៨៥. ដូច្នេះ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា មនុស្សបីក្រុមត្រូវបានចាត់ទុកជាខ្មាំង៖ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងខ្មែរមកពីបរទេស។

៨៨៦. នៅកថាខណ្ឌ ១៤១៧ ដដែល នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា៖

"ខ្មាំងប្រភេទនេះកាន់តែមានច្រើនទៅៗ ទៅតាមពេលវេលា។ ម្យ៉ាងទៀត ការកំណត់មនុស្សដែលជាគោលដៅនៃការធ្វើទុក្ខបុកម្នេញ ដោយឈរលើមូលដ្ឋាននៃការបំបាត់រាល់បុគ្គលទាំងឡាយណា ដែលមិនយល់ស្របនឹងមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ជាក់ស្តែង គឺជាទម្រង់មួយនៃការធ្វើទុក្ខម្នេញដោយសារមូលហេតុនយោបាយ"។

៨៨៧. គ្មានព័ត៌មានបន្ថែមណាមួយត្រូវបានផ្តល់អំពីអត្តសញ្ញាណនៃខ្មាំងប្រភេទនេះ។ សហចៅក្រមស៊ើបអង្កេតបានបង្កើតដោយចេតនានូវចន្លោះប្រហោងនៃការគិតគូររបស់ខ្លួន និងបានស្នើឱ្យអង្គជំនុំជម្រះ ចាត់ការ ដើម្បីបំពេញកង្វះខាតនៃកិច្ចស៊ើបសួររបស់ខ្លួន។ ធ្វើរបៀបនេះគឺអយុត្តិធម៌ចំពោះ ខៀវ សំផន។

---

[992]អង្គហេតុទាំងឡាយទាក់ទងនឹងទីតាំង ស-២១ និងព្រៃស ត្រូវបានរៀបរាប់នៅផ្នែកខាងលើ ត្រង់កថាខណ្ឌ ១១៧៥ និងកថាខណ្ឌបន្តបន្ទាប់ទៀត។

៨៨៨. ចំពោះឃ្លាចុងក្រោយនៃកថាខណ្ឌ ១៤១៧ ដែលមិនសូវមានភាពច្បាស់លាស់ គេពិបាកយល់ថាតើសហចៅក្រមស៊ើបអង្កេតចង់ទៅដល់ណា។ សហចៅក្រមស៊ើបអង្កេតបាននិយាយអំពី "ការបំបាត់រាល់បុគ្គលទាំងឡាយណា ដែលមិនយល់ស្របនឹងមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា" ដែលហាក់ដូចជាចេញផុតពីនិយមន័យនៃក្រុមនានា នៅកថាខណ្ឌ ១៤១៧។ ដូច្នេះ បុគ្គលគ្រប់រូបអាចក្លាយជាជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញ ទោះបីជាមិនស្ថិតនៅក្នុងក្រុមណាមួយក៏ដោយ។ គេភ្លេចថា ការធ្វើទុក្ខបុកម្នេញ ដូចបានកំណត់និយមន័យដោយសហចៅក្រមស៊ើបអង្កេតដដែល នៅកថាខណ្ឌ ១៤១៥ នៃដីកាដំណោះស្រាយ សំដៅដល់ក្រុមមនុស្សទាំងឡាយត្រូវបានកំណត់ដោយអាជ្ញាធរនៃបក្សកុម្មុយនីស្តកម្ពុជា[993]។

៨៨៩. ក្នុងន័យនេះ អង្គជំនុំជម្រះតុលាការកំពូលមានគោលជំហរច្បាស់លាស់ទៅលើការលេចឡើងយ៉ាងគំហុកនូវឧក្រិដ្ឋកម្ម ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ៖

> "ទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលបដិវត្តន៍កំពុងឆ្ពោះទៅមុខ បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួន ធ្វើបាប និងបោសសម្អាត ដោយមិនរើសមុខ និងដោយគ្មានការធ្វើយុត្តិកម្មដ៏សមហេតុផល ដោយមូលហេតុនយោបាយនោះទេ។ <u>សកម្មភាពបែបនេះមិនមែនជាការធ្វើទុក្ខបុកម្នេញតទៅទៀតនោះទេ ប៉ុន្តែ បង្កើតឱ្យមានការភ័យខ្លាច ដែលពុំមានលក្ខណៈវិនិច្ឆ័យដែលស្តែងឱ្យឃើញក្នុងការកំណត់គោលដៅលើជនរងគ្រោះឡើយ</u>" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[994]។

៨៩០. តែបើដូច្នេះ ដោយលែងមានក្រុមដែលត្រូវបានកំណត់ច្បាស់លាស់ គឺលែងមានឧក្រិដ្ឋកម្មហើយ។ នេះគឺជាគោលជំហរស្របនឹងការពិតនៃអង្គហេតុ ដែលសហចៅក្រមស៊ើបអង្កេតគួរតែប្រកាន់យកដើម្បីឱ្យស៊ីសង្វាក់គ្នានឹងសម្តីរបស់ខ្លួន នៅកថាខណ្ឌ ១៤១៥ ជាជាងការធ្វើសេចក្តីសន្និដ្ឋានមិនច្បាស់លាស់ និងមានភាពផ្ទុយគ្នា។

---

[993]ធាតុផ្សំមួយនេះដែលត្រូវបានផ្តល់ដោយចៅក្រមស៊ើបអង្កេត គឺជាការបន្ស៊ីគ្នា ក្នុងទិដ្ឋភាពអង្គហេតុ ទៅនឹងសមាសធាតុនៃនិយមន័យផ្លូវច្បាប់នៃបទឧក្រិដ្ឋកម្ម ដែលសន្មតថា និយមន័យនៃក្រុមដែលកំណត់ដោយចារីនៃបទឧក្រិដ្ឋកម្ម ត្រូវធ្វើឡើង "ដោយផ្អែកលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យជាក់លាក់មួយចំនួន" ហើយថាក្រុម "ត្រូវតែអាចកំណត់បាន"។ សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ១២១២-១២១៣។

[994]សាលដីកា *ឌុច* ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៨៣។

៨៩១. ទោះជាក្នុងករណីណាក៏ដោយ ភាពមិនស៊ីសង្វាក់គ្នាក្នុងការគិតគូររបស់សហចៅក្រមស៊ើបអង្កេត មិនត្រូវបង្កព្យសនកម្មដល់លោក ខៀវ សំផន ដែលត្រូវទទួលខុសត្រូវចំពោះតែបទចោទស្ដីពីការធ្វើទុក្ខបុកម្នេញទៅលើមនុស្សបីក្រុម ដូចបានកំណត់ច្បាស់ នៅកថាខណ្ឌ ១៤១៧ ប៉ុណ្ណោះ។ ការឆ្លើយតបដែលពង្រីកទៅដល់ក្រុមមនុស្សដែលគាត់មិនស្គាល់សមាសភាព និងឈ្មោះ គឺស្មើនឹងគាត់ចោទប្រកាន់ខ្លួនឯងអំពីឧក្រិដ្ឋកម្ម ដែលគាត់មិនត្រូវបានចោទប្រកាន់។

៨៩២. បន្ទាប់មកទៀត នៅកថាខណ្ឌ ១៤១៨ សហចៅក្រមស៊ើបអង្កេតបានលើកឡើងជាពិសេសអំពីសហករណ៍ត្រាំកក់៖

> "នៅតាមសហករណ៍ និងការដ្ឋានធ្វើការដោយបង្ខំ ដូចនៅពេលផ្លាស់ទីលំនៅប្រជាជនដែរ ខ្មាំងពិតប្រាកដ ឬតាមការសន្មតរបស់បក្សកុម្មុយនីស្ដកម្ពុជា ត្រូវបានគេធ្វើបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខ័ណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត។ មនុស្សទាំងនេះក៏ត្រូវបានគេចាប់ជាក្រុមៗផងដែរ ដើម្បីយកទៅអប់រំឡើងវិញ ឬទៅកម្ទេចចោល នៅតាមមន្ទីរសន្ដិសុខ និងកន្លែងសម្លាប់មនុស្ស" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[995]។

៨៩៣. ដូច្នេះ ការរើងអើង ដែលបានសង្កេតឃើញ នៅត្រាំកក់ កម្រិតត្រឹមអង្គហេតុនៃការចាប់ខ្លួន និងអប់រំឡើងវិញ។ អង្គហេតុផ្សេងទៀត ពាក់ព័ន្ធនឹងការដ្ឋានធ្វើការដោយបង្ខំ ការជម្លៀសប្រជាជន និងការសម្លាប់នៅតាមមន្ទីរសន្តិសុខ ត្រូវបានពិភាក្សានៅក្នុងជំពូកផ្សេងទៀតស្ដីពីទីតាំងឧក្រិដ្ឋកម្មនីមួយៗនៃសារណានេះ ទៅតាមភាពសមហេតុផល ដូចនៅក្នុងដីកាដំណោះស្រាយដែរ[996]។

៨៩៤. អង្គហេតុដែលត្រូវបានកំណត់ថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅកថាខណ្ឌ ១៤១៧ និងកថាខណ្ឌ ១៤១៨ យោងទៅដល់កថាខណ្ឌ ៣០៤ ដល់កថាខណ្ឌ ៣០៦ និងកថាខណ្ឌ ៣១៩ ស្ដីពីប្រជាជនថ្មី និងបន្តពីកថាខណ្ឌ ៣១៩ ស្ដីពីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

---

[995]ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៨។ ផ្នែកទាក់ទងនឹងអង្គហេតុរងការចោទប្រកាន់ នៅតាមទីតាំងពលកម្មដោយបង្ខំ និងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ពុំជាប់ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់នោះទេ ដែលនេះជាមូលហេតុដែលទីកន្លែងទាំងអស់នោះ មិនត្រូវបានរាយការណ៍នៅទីនេះ។

[996]សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ១២២០ និងកថាខណ្ឌបន្តបន្ទាប់ (ក្រាំងតាចាន់) កថាខណ្ឌ ១១៧៥ និងកថាខណ្ឌបន្តបន្ទាប់ (ស-២១) កថាខណ្ឌ ១៣០៦ និងកថាខណ្ឌបន្តបន្ទាប់ (អូរកន្សែង) កថាខណ្ឌ ១៣៥១ និងកថាខណ្ឌបន្តបន្ទាប់ (ភ្នំក្រោល)
។

អង្គហេតុគាំទ្រដល់បទចោទស្តីពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសិក្សានៅខាងក្រោម[997]។

៨៩៥. នៅចន្លោះកថាខណ្ឌ ៣០៤ ដល់កថាខណ្ឌ ៣០៦ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានរៀបរាប់លម្អិតអំពីជោគវាសនារបស់អ្នកជម្លៀសចេញពីទីក្រុង ក្រោយពីទៅដល់សហករណ៍ត្រាំកក់។ ច្បាស់ណាស់ថាអតីតអ្នកទីក្រុងបានទទួលរងនូវការរើសអើងពីរប្រភេទ។ ទីមួយ ក្រោយពីតាំងទីលំនៅនៅត្រាំកក់ ជួនកាល ពួកគេត្រូវបាន "ផ្លាស់ក្នុងទ្រង់ទ្រាយធំ ពីកន្លែងមួយទៅកន្លែងមួយ នៅក្នុងស្រុកទាំងមូល"[998]។ ទីពីរ ក្រោយពីការបែងចែកប្រជាជនជាបីប្រភេទ ហើយខុសពីប្រជាជនមូលដ្ឋាន អតីតអ្នកទីក្រុង "មិនមានសិទ្ធិនយោបាយដែលអាចឱ្យអ្នកទាំងនោះធ្វើជាប្រធានកងនៅក្នុងសហករណ៍ទេ"[999]។ គ្មានការលើកឡើងអំពីការរើសអើងផ្សេងទៀតទេ។

៨៩៦. នៅកថាខណ្ឌ ៣១៩ ក្រោមចំណងជើង "ការប្រព្រឹត្តិលើក្រុមមនុស្សជាក់លាក់" ឃ្លាតែមួយគត់អំពីអតីតអ្នកទីក្រុងនាំឱ្យគេគិតថាមានការរើសអើងផ្សេងទៀត បណ្តាលមកពីការអនុវត្តការឃ្លាំមើលយ៉ាងតឹងរ៉ឹងចំពោះប្រជាជនថ្មី៖

> "ឈ្លបឃុំឃ្លាំមើលអ្នកដែលត្រូវបានផ្លាស់ទីលំនៅមកពីភ្នំពេញយ៉ាងជិតដល់។ ប្រសិនបើពួកគេនិយាយអ្វីប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា ពួកគេនឹងត្រូវបានចាប់ខ្លួន និងនាំយកទៅ"។

៨៩៧. ធាតុផ្សំទាំងបីនេះបង្កើតបានជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋាននៅកថាខណ្ឌ ១៤១៨ អំពីការដាក់ឱ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំង សម្រាប់ប្រជាជនថ្មី ដែលបណ្តាលឱ្យមានការកំណត់ថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

៨៩៨. បើសិនជាយើងអានដាច់ដោយឡែកពីគ្នា អង្គហេតុទាំងនេះគឺជាការរើសអើងដោយមិនអាចប្រកែកបាន ដែលលោក ខៀវ សំផន ត្រូវទទួលខុសត្រូវ។ បើសិនជាអានរួមគ្នាជាមួយអង្គហេតុផ្សេង

---

[997]សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ២២៥៨ និងកថាខណ្ឌបន្តបន្ទាប់។

[998]ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៤។

[999]ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៥។

ទៀតនៅត្រាំកក់ ដូចបានរៀបរាប់លម្អិត នៅកថាខណ្ឌ ៣០២ និងកថាខណ្ឌ ៣២១ នៃដីកាដំណោះស្រាយ ភាពច្បាស់លាស់នេះត្រូវរលាយដូចអំបិលត្រូវទឹក។

៨៩៩. កថាខណ្ឌ ៣១០ គូសបញ្ជាក់ថា "នៅពេលខ្លះ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបញ្ជូនប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី ចេញពីផ្ទះទៅរស់នៅទីកន្លែងផ្សេងគ្នាក្នុងស្រុកតែមួយ"។ ឃ្លានេះគឺជាការចម្លងចេញពីកថាខណ្ឌ ៣០៤ ដូចបានលើកឡើងខាងលើ ខុសគ្នាត្រង់ថា គំនិតនៃការរើសអើងបានរលាយបាត់ ដោយសារតែប្រជាជនមូលដ្ឋានក៏ត្រូវបានផ្លាស់ទីលំនៅដូចប្រជាជនថ្មីដែរ។ ប្រសិនបើលែងមានការរើសអើង ក៏លែងមានការធ្វើទុក្ខបុកម្នេញដែរ។

៩០០. ម្យ៉ាងវិញទៀត ឃ្លាជាច្រើននៃកថាខណ្ឌ ៣១១ និងកថាខណ្ឌ ៣១២ ក្រោមចំណងជើង "ស្ថានភាពរស់នៅ និងការងារ" និងកថាខណ្ឌ ៣១៥ ដល់កថាខណ្ឌ ៣១៨ ក្រោមចំណងជើង "សន្តិសុខ" បង្ហាញថា ប្រជាជនទៅតាមសហករណ៍ត្រូវបានចាប់យកទៅដោយមិនរើសមុខ ដោយសារមូលហេតុគ្រប់បែបយ៉ាង។ ដូច្នេះ គ្មានភាពខុសប្លែកគេនៃជោគវាសនារបស់ប្រជាជនថ្មី នៅកថាខណ្ឌ ៣១៩ ដូចបានរៀបរាប់ខាងលើ នោះទេ។

៩០១. ការសង្កេតឃើញនេះត្រូវបានធ្វើឱ្យកាន់តែរឹងមាំដោយសេចក្តីសន្និដ្ឋាននៃកថាខណ្ឌ ៣១២៖

> "ឯកសាររបស់ស្រុក ១០៥ បានកត់ត្រាទុកផងដែរនូវការចាប់ខ្លួនមនុស្សដែលបានត្អូញត្អែរអំពីការងារ និងស្ថានភាពរស់នៅក្នុងសហករណ៍"។

៩០២. ក៏ប៉ុន្តែ នៅក្នុងតុលាការនេះ គ្មាននរណាម្នាក់អាចអះអាងដោយសុទ្ធចិត្តថា ឃ្លានៃកថាខណ្ឌ ៣១៩ "និយាយអ្វីប្រឆាំងនឹងបក្ស" ចំពោះប្រជាជនថ្មី និងឃ្លានៃកថាខណ្ឌ ៣១២ "ត្អូញត្អែរអំពីការងារ និងស្ថានភាពរស់នៅ" ចំពោះប្រជាជនទៅតាមសហករណ៍ទាំងអស់ បង្ហាញនូវការពិតផ្សេងពីនេះទេ។ ដូច្នេះ យើងមិនអាចដឹងថា តើអតីតអ្នកទីក្រុងជាជនរងគ្រោះនៃការរើសអើងបែបណានោះទេ ដោយសារតែការប្រព្រឹត្តដូចគ្នាត្រូវបានអនុវត្តចំពោះប្រជាជនទាំងអស់នៅតាមសហករណ៍។

៩0៣. ភាពស្រដៀងគ្នានៃកថាខណ្ឌ ៣១២ និងកថាខណ្ឌ ៣១៩ ប្រសិនបើយើងមើលត្រឡប់ទៅក្រោយវិញ អាចឱ្យយល់កាន់តែច្បាស់នូវកថាខណ្ឌ ១៤១៧ និងកថាខណ្ឌ ១៤១៨ អំពីការកំណត់ប្រភេទនៃបទល្មើស។

៩0៤. កថាខណ្ឌ ១៤១៧ ចាប់ផ្តើម ដោយលើកឡើងថា៖ "អាជ្ញាធរនៃបក្សកុម្មុយនីស្តកម្ពុជាបានកំណត់អត្តសញ្ញាណខ្មាំងជាច្រើនក្រុម ដោយសារមូលហេតុទស្សនៈនយោបាយពិតប្រាកដ ឬសន្មត"។

៩0៥. ឃ្លាបន្តទៀតនៃកថាខណ្ឌ ១៤១៧ ធ្វើឱ្យស្រឡាំងកាំងបន្តិច។ តាមការពិនិត្យបឋម ប្រជាជនថ្មីហាក់ដូចជាស្ថិតនៅក្នុងចំណោមក្រុមខ្មាំង ប៉ុន្តែ បន្ទាប់មកទៀត កថាខណ្ឌដដែលនេះសរសេរថាបក្សកុម្មុយនីស្តកម្ពុជាព្យាយាមកំណត់អត្តសញ្ញាណខ្មាំងនៅក្នុងចំណោមប្រជាជនថ្មី។ យើងត្រូវតែជ្រើសរើសយកមួយ គឺប្រជាជនថ្មីជាក្រុមខ្មាំង និងត្រូវបានរើសអើង ឬមួយ អ្នកខ្លះនៅក្នុងក្រុមនេះត្រូវបានចាត់ទុកជាខ្មាំង ហើយប្រជាជនថ្មីមិនត្រូវបានប្រព្រឹត្តតឹងរ៉ឹងជាងប្រជាជនផ្សេងទៀតនោះទេ។ គួរកត់សម្គាល់ថា ការកំណត់នេះមិនច្បាស់លាស់ និងមិនសមហេតុផល ដោយហេតុថាសហចៅក្រមស៊ើបអង្កេតគ្មានភាពម៉ត់ចត់។

៩0៦. ភាពមិនស៊ីសង្វាក់គ្នានេះ ឆ្លុះបញ្ចាំងឱ្យឃើញអំពីការអនុវត្តដដែលៗរបស់សហចៅក្រមស៊ើបអង្កេតក្នុងការប្រកាន់យកគោលការណ៍ ដើម្បីសច្ចភាពប្រវត្តិសាស្ត្រ សូម្បីតែភ័ស្តុតាងពុំមានភាពប្រទាក់ក្រឡាគ្នាក៏ដោយ។

៩0៧. បន្ទាប់មកទៀត នៅកថាខណ្ឌ ១៤១៨ សហចៅក្រមស៊ើបអង្កេតលើកឡើងអំពី "ខ្មាំងពិតប្រាកដឬតាមសន្មត" ដូចនៅកថាខណ្ឌ ១៤១៧ ដែរ (ក្នុងចំណោមនោះ មានប្រជាជនថ្មី ឬខ្មាំងបង្កប់ខ្លួនក្នុងនោះ បើតាមការអានកថាខណ្ឌ ១៤១៧)។ សហចៅក្រមស៊ើបអង្កេតនិយាយអំពីជោគវាសនារបស់ខ្មាំង នៅតាមសហករណ៍ ការដ្ឋានធ្វើការដោយបង្ខំ និងនៅពេលជម្លៀសប្រជាជន ជាទីតាំងដែលពួកគេទទួលរងនូវការរើសអើងពីរប្រភេទ៖ ការប្រព្រឹត្តិតឹងរ៉ឹង និងការចាប់ខ្លួនជាក្រុម ដើម្បីយកទៅអប់រំឡើងវិញ ឬកម្ទេចចោល នៅតាមទីតាំងទាំងនោះ។

៩០៨. ក៏ប៉ុន្តែ អង្គហេតុនៃកថាខណ្ឌ ៣០២ ដល់កថាខណ្ឌ ៣២១ នៃដីកាដំណោះស្រាយ មិនបង្ហាញអំពីការរើសអើងពាក់ព័ន្ធនឹងការចាប់ខ្លួននៅតាមសហករណ៍ ដោយសារតែការរើសអើងទាំងនេះមានតែនៅការដ្ឋាន និងក្នុងពេលជម្លៀសប្រជាជន ហើយនៅត្រាំកក់ ការប្រព្រឹត្តិតឹងរ៉ឹងជាងអាចត្រូវបានស្តែងឡើង។

៩០៩. ដោយយោងទៅលើភាពស្របគ្នានៃកថាខណ្ឌ ៣០៤ និងកថាខណ្ឌ ៣១០ ក៏ដូចជាកថាខណ្ឌ ៣១២ និងកថាខណ្ឌ ៣១៩ ការប្រព្រឹត្តិតឹងរ៉ឹងនេះធ្វើឱ្យ "ប្រជាជនថ្មីមិនអាចក្លាយជាប្រធានកងនៅតាមសហករណ៍"[1000]។

៩១០. ដូច្នេះ លោក ខៀវ សំផន ត្រូវទទួលបានការជំនុំជម្រះតែលើអង្គហេតុដែលពាក់ព័ន្ធនឹងការលុបបំបាត់អ្វីដែលសហចៅក្រមស៊ើបអង្កេតហៅថាជា "សិទ្ធិនយោបាយ"[1001]។

## ឆ. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស)

៩១១. នៅកថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស។ សេចក្តីសន្និដ្ឋាននេះផ្អែកលើព័ត៌មានជាច្រើននៃកថាខណ្ឌ ៣០២ ដល់កថាខណ្ឌ ៣២១ នៃដីកាដំណោះស្រាយ។ លោក ខៀវ សំផន ត្រូវជំនុំជំម្រះទៅលើការចោទប្រកាន់នេះ។

## ជ. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ)

៩១២. នៅកថាខណ្ឌ ១៤៧០ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ។ សេចក្តីសន្និដ្ឋាននេះបន្ទរតាមកថាខណ្ឌ ៣១២ ដែលថា "អ្នកដែលប្រឆាំងនឹងត្រូវចាប់ខ្លួន ហើយ

---

[1000] ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៦។

[1001] ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៦។

បាត់ខ្លួន"។ លោក ខៀវ សំផន ត្រូវជំនុំជម្រះទៅលើការចោទប្រកាន់នេះ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ក្នុងព្រំដែននៃអាណត្តិដែលសហព្រះរាជអាជ្ញាបានប្រគល់ជូន។

## ផ្នែកទី ២. ភ័ស្តុតាងគាំទ្រដល់សេចក្តីសន្និដ្ឋាននៃដីកាដំណោះស្រាយ

៩១៣. ការពិនិត្យលើភ័ស្តុតាងគាំទ្រនៃដីកាដំណោះស្រាយ ប្រាប់អំពីចរិតលក្ខណៈគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់នៃបទចោទ ដែលជនជាប់ចោទត្រូវបានបញ្ជូនទៅជំនុំជម្រះ។ ផ្ទុយពីការរំពឹងទុក ការពិនិត្យនេះបង្ហាញថា សហចៅក្រមស៊ើបអង្កេតបានរំលោភទៅលើវិធាននៃបណ្តឹងរបស់ខ្លួន យោងតាមព័ត៌មានអំពីបទចោទដែលទើបតែពិនិត្យមើល។

៩១៤. ដោយសារមូលហេតុទាំងពីរនេះ ភ័ស្តុតាងដែលសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ពាក់ព័ន្ធនឹងសមាសភាពស្រុកត្រាំកក់ (១) ការស្លាប់ដោយអត់អាហារ (២) អង្គហេតុនៃការដាក់ក្នុងមន្ទីរឃុំឃាំង (៣) អង្គហេតុនៃការធ្វើទារុណកម្ម (៤) ការលុបបំបាត់ "សិទ្ធិនយោបាយ" របស់ប្រជាជនថ្មី (៥) ការតាមដានកាន់តែខ្លាំងឡើងទៅលើសមាជិកនៃអតីតរបបសាធារណរដ្ឋខ្មែរ (៦) ត្រូវបានវិភាគដូចខាងក្រោម។

### ១. អំពីសមាសភាពស្រុកត្រាំកក់

៩១៥. សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតនៅកថាខណ្ឌ ៣០២ នៃដីកាដំណោះស្រាយ ដូចបានលើកឡើងខាងលើ អំពីសមាសភាពស្រុកត្រាំកក់ ត្រូវបានគាំទ្រដោយកំណត់សម្គាល់ចុងឯកសារតែមួយគត់ ដែលយោងទៅរកឯកសារតែមួយគត់ គឺរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងរបស់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០។

៩១៦. នៅក្នុងរបាយការណ៍នេះ អ្នកស៊ើបអង្កេតបានរំឭកអំពីវិសាលភាពនៃបណ្តឹង ត្រង់កថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងប្រើប្រាស់ពាក្យ « commune » ដើម្បីសំដៅដល់ឃុំទាំង

៨ ស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[1002]។ នេះបញ្ជាក់ថា ការប្រើប្រាស់ពាក្យ « commune » ឬពាក្យ « sous-district » (ឬ "sub-district" ជាភាសាអង់គ្លេស) ដោយសហចៅក្រមស៊ើបអង្កេត នៅកថាខណ្ឌ ៣០២ នៃដីកាដំណោះស្រាយ មិនមានផលប៉ះពាល់ទៅលើការយល់អំពីបំណែងចែករដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យនោះទេ។

៩១៧. ទំព័រចុងក្រោយនៃរបាយការណ៍នេះ ផ្តល់ការចាប់អារម្មណ៍ច្រើនទៅលើផែនទីមួយ ក្រោមចំណងជើងថា "ផែនទីបង្ហាញអំពីឃុំនៃស្រុកត្រាំកក់ដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"[1003] ជាងទៅលើការប្រើប្រាស់ពាក្យពេចន៍តាមទំនើងចិត្ត។ ចំណងជើងនេះនាំឱ្យយើងយល់ថា មានឃុំផ្សេងទៀតក្នុងស្រុកត្រាំកក់ ប៉ុន្តែមិនត្រូវបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដូច្នេះ ការវិភាគនេះផ្ទុយនឹងការវិភាគនៃកថាខណ្ឌ ៣០៣ នៃដីកាដំណោះស្រាយ ដែលហាក់ដូចជានិយាយថា ទីតាំងទាំង ៨ នៃបណ្តឹង បង្កើតបានជាឃុំទាំងអស់នៃស្រុកត្រាំកក់"[1004]។

៩១៨. គេកាន់តែមានចំណាប់អារម្មណ៍លើចំណងជើងផែនទី នៅពេលគេសង្កេតមើលផែនទីនេះ។ ឃុំទាំង ៨ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវបានគូសរង្វង់មូលឱ្យខុសពីទីតាំងផ្សេងទៀតដែលមិនមានសរសេរនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧទាហរណ៍ លាយបូរ ឧត្តមសូរិយាពពេល ឬអង្គតាសោម។ ផ្ទុយទៅវិញ ផែនទីមិនប្រាប់អំពីទំហំនៃទីតាំងទាំងនេះ ឬការដាក់បញ្ចូលជាយថាហេតុទៅក្នុងស្រុកត្រាំកក់ ឬអំពីលទ្ធភាពដែលស្រុកនេះមានឃុំផ្សេងទៀតដែលមិនត្រូវបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ឬផែនទី។

៩១៩. ភ័ស្តុតាងមួយចំនួន ដែលសហចៅក្រមស៊ើបអង្កេតយកមកប្រើប្រាស់ក្នុងដីកាដំណោះស្រាយ ផ្តល់នូវចម្លើយទៅនឹងការងឿងឆ្ងល់ទាំងនេះ។ នៅក្នុងកថាខណ្ឌ ៣២០ នៃដីកាដំណោះស្រាយ សហ

---

[1002]របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ **ឯកសារ E3/8051** ERN 00463074-76។

[1003]របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ **ឯកសារ E3/8051** ERN 00450445 (ភាសាបារាំង)។

[1004]សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៤៨-៨៥២។

ចៅក្រមស៊ើបអង្កេតមិនបានបង្ហាញអំពីវត្តមាននៃឃុំអង្គតាសោម នៅក្នុងស្រុកត្រាំកក់នោះទេ[1005]។ ភ័ស្តុតាងមួយ ដែលបានលើកយកមកគាំទ្រដល់សេចក្ដីសន្និដ្ឋានមួយទៀតនៃកថាខណ្ឌ ៣២០ បញ្ជាក់អំពីអត្ថិភាពនៃឃុំនេះ[1006]។ ឯកសារដដែលនេះប្រាប់អំពីអត្ថិភាពនៃឃុំ "លាយបូរ"[1007]។ ឯកសារពីរផ្សេងទៀត ដែលគាំទ្រដល់សេចក្ដីសន្និដ្ឋានដដែលនេះ ប្រាប់អំពីអត្ថិភាពនៃឃុំ "ខ្ទុបត្របែក" និង "ពពេល"[1008]។

៩២០. ឧទាហរណ៍ទាំងនេះបញ្ជាក់ថា ទីមួយ ស្រុកត្រាំកក់ នៅសម័យកាលកើតហេតុ មានឃុំច្រើនជាង ៨ ដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងទីពីរ សហចៅក្រមស៊ើបអង្កេតបានស៊ើបសួរក្រៅវិសាលភាពនៃបណ្ដឹង នៅតាមទីតាំង ដែលសហព្រះរាជអាជ្ញាមិនបានចោទប្រកាន់ថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម។

៩២១. ចៅក្រមម៉ត់ចត់គួរតែយកផែនទីរបស់អ្នកស៊ើបអង្កេត ទៅផ្ទៀងផ្ទាត់នឹងភ័ស្តុតាងជាច្រើនដែលខ្លួនមាន និងគួរតែសន្និដ្ឋានយ៉ាងស្រួលអំពីអត្ថិភាពនៃឃុំផ្សេងទៀតក្រៅពីឃុំទាំង ៨ ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ពេលដឹងអំពីអត្ថិភាពនៃអង្គហេតុថ្មីជាយថាហេតុនេះ ចៅក្រមដដែលនេះគួរតែជូនដំណឹងដល់សហព្រះរាជអាជ្ញា យោងតាមវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង ដើម្បីឱ្យសហព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ក្នុងគោលដៅពង្រីកវិសាលភាពនៃបណ្ដឹងទៅកាន់ខ្លួន[1009]។

---

[1005]ដីកាដំណោះស្រាយ កថាខណ្ឌ ៣២០ ជើងទំព័រ ១៣២២ យោងទៅលើរបាយការណ៍អង្គតាសោម ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៧៧ **ឯកសារ E3/2435** ERN 00271001។ សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៨១។

[1006]ដីកាដំណោះស្រាយ កថាខណ្ឌ ៣២០ ជើងទំព័រ ១៣២១ យោងទៅលើរបាយការណ៍ឃុំអង្គតាសោម ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៧៦ **ឯកសារ E3/2447** ERN 00270732។

[1007]របាយការណ៍ឃុំអង្គតាសោម ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៧៦ **ឯកសារ E3/2447** ERN 00270734។

[1008]ដីកាដំណោះស្រាយ កថាខណ្ឌ ៣២០ ជើងទំព័រ ១៣២១ យោងទៅលើរបាយការណ៍មួយ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៧ **ឯកសារ E3/2050** ERN 00079111 និងរបាយការណ៍មួយស្ដីពីឃុំពពេល **ឯកសារ E3/2424** ERN 00270754។

[1009]វិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង។ សូមមើលផ្នែកខាងលើ កថាខណ្ឌ ៦៣។

៩២២. បើមិនគោរពតាមទម្រង់បែបបទនៃនីតិវិធីមិនអាចផ្ដោះរំលងបាននេះ សេចក្ដីសន្និដ្ឋានទាំងអស់ដែលបានធ្វើឡើងនៅក្នុងដីកាដំណោះស្រាយ ដោយផ្អែកលើភ័ស្តុតាងស្តីពីអង្គហេតុនៅក្រៅឃុំទាំង ៨ ដំបូង មិនមែនជាបទចោទ ដែលលោក ខៀវ សំផន ត្រូវជំនុំជម្រះទេ។

៩២៣. ឥឡូវនេះ អង្គជំនុំជម្រះត្រូវគាំទ្រសេចក្ដីសន្និដ្ឋានអំពីឧក្រិដ្ឋកម្មជាយថាហេតុរបស់ខ្លួន ដោយផ្អែកលើភ័ស្តុតាងចេញពីឃុំទាំង ៨ ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងកថាខណ្ឌ ៣០២ នៃដីកាដំណោះស្រាយ។ រាល់ការអនុវត្តផ្ទុយពីនេះ គឺជាការរំលោភទៅលើសិទ្ធិរបស់ក្រុមមេធាវីការពារក្ដី និងបង្កឱ្យមានព្យសនកម្មដល់ជនជាប់ចោទ។

## ២. ការស្លាប់ ដោយការស្រេកឃ្លាន នៅតាមឃុំនៃស្រុកត្រាំកក់

៩២៤. ត្រង់កន្លែងដែលសហព្រះរាជអាជ្ញាបានចោទប្រកាន់ថា “ទុរ្ភិក្សទ្រង់ទ្រាយធំ” គឺជារឿងធម្មតា នៅត្រាំកក់ និង “ប្រជាជនរាប់ពាន់នាក់បានស្លាប់ដោយការស្រេកឃ្លាន”[1010] សហចៅក្រមស៊ើបអង្កេតបានអះអាងដោយរាបសាជាងនេះ ថា “សាក្សីខ្លះបញ្ជាក់ថា មានប្រជាជនស្លាប់ដោយសារអាហារខណៈដែលអ្នកខ្លះទៀតអះអាងមិនបានដឹង ឬគ្មានករណីនេះកើតឡើងឡើយ”[1011]។

៩២៥. សេចក្ដីសន្និដ្ឋានបង្ហាញអំពីវត្តមាននៃភ័ស្តុតាងដាក់បន្ទុក និងដោះបន្ទុក ក្នុងចំណោមភ័ស្តុតាងដែលប្រមូលបានក្នុងអំឡុងពេលស៊ើបសួរ។ ក្នុងន័យនេះ សាក្សីបីនាក់ឯកភាពថាមានមនុស្សស្លាប់នៅឃុំបីដាច់ដោយឡែកពីគ្នាក្នុងស្រុកត្រាំកក់ ហើយពីរនាក់ទៀត “ប្រកែក” ថាគ្មានការស្លាប់ នៅឃុំបីផ្សេងទៀតក្នុងស្រុកត្រាំកក់នោះទេ[1012]។

---

[1010]ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៣។

[1011]ដីកាដំណោះស្រាយ កថាខណ្ឌ ៣១២។

[1012]ដីកាដំណោះស្រាយ កថាខណ្ឌ ៣១២ ជើងទំព័រ ១២៨៣ សម្រាប់ភ័ស្តុតាងដាក់បន្ទុក បានយោងទៅលើកំណត់ហេតុស្តាប់ចម្លើយ សុក សុត **ឯកសារ E3/5835** (D25/32) ទំព័រ ៥-៧, កំណត់ហេតុស្តាប់ចម្លើយ សឹម ឈៀង **ឯកសារ E3/7980** (D40/16) ទំព័រ ៤ និងកំណត់ហេតុស្តាប់ចម្លើយ សុក ស៊ឹម **ឯកសារ E3/5519** (D232/67) ទំព័រ ៥-៧, ជើងទំព័រ ១២៨៤ សម្រាប់ភ័ស្តុតាងដោះបន្ទុក យោងទៅលើកំណត់ហេតុស្តាប់ចម្លើយ គុប ជេ **ឯកសារ E3/7982** (D40/19) ទំព័រ ២-៤ និងកំណត់ហេតុស្តាប់ចម្លើយ នុត នូវ **ឯកសារ E3/5521** (D232/70) ទំព័រ ១២-១៤។

៩២៦. ពាក់ព័ន្ធនឹងការពិតនៃការស្លាប់ សាក្សីទីមួយនិយាយអំពីហេតុការណ៍ ដែលបានកើតឡើងនៅភូមិអង្គបក្សី ឃុំជាងទង[1013]។ សាក្សីទីពីរលើកឡើងអំពីការស្លាប់របស់មនុស្សម្នាក់ ដែលគ្មានឈ្មោះ នៅភូមិប៉ែនមាស ឃុំសំរោង[1014]។ សាក្សីចុងក្រោយរៀបរាប់អំពីការស្លាប់របស់មនុស្សបីនាក់ឈ្មោះ តាប៊ីន តាម៉ាក និងយាយតង នៅភូមិតាស្វ ឃុំតាភេម[1015]។

៩២៧. ចំពោះការគ្មានការស្លាប់ សាក្សីទីមួយ ជាសមាជិកសហករណ៍ភូមិព្រៃក្តី ឃុំត្រពាំងធំត្បូង និយាយថាគាត់មិនបានឃើញ "ប្រជាជនស្លាប់ដោយអត់អាហារ" នោះទេ[1016]។ សាក្សីទីពីរ ជាកម្មាភិបាលខ្មែរក្រហម បានរស់នៅក្នុងឃុំញ៉ែងញ៉ង រហូតដល់ឆ្នាំ ១៩៧៧ រួចត្រូវបានតែងតាំងជាមេឃុំស្រែរនោង។ គាត់បាននិយាយថា គ្មានអ្នកណាម្នាក់ស្លាប់ដោយអត់អាហារ នៅកន្លែងទាំងនោះទេ[1017]។

៩២៨. ជារួម សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថាមានមនុស្សបួននាក់ស្លាប់ នៅឃុំពីរ ក្រោមវិសាលភាពនៃកិច្ចស៊ើបសួរ (ឃុំសំរោង ម្នាក់ និងឃុំតាភេម បីនាក់)[1018]។ ចំពោះឃុំបីផ្សេងទៀត ក្រោមវិសាលភាពនៃកិច្ចស៊ើបសួរ (ឃុំត្រពាំងធំត្បូង ឃុំញ៉ែងញ៉ង និងឃុំស្រែរនោង) សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា សាក្សីដែលបានស្តាប់ចម្លើយ មិនបានឃើញមនុស្សស្លាប់ដោយអត់បាយនោះទេ។ ចំពោះឃុំបីផ្សេងទៀត ក្រោមវិសាលភាពនៃកិច្ចស៊ើបសួរ (ឃុំគូស ឃុំត្រាំកក់ និងឃុំត្រពាំងធំជើង) សហចៅក្រមស៊ើបអង្កេតមិនបាននិយាយអ្វីទាំងអស់។ ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញការស្លាប់មនុស្សនៅឃុំមួយ នៅក្រៅវិសាលភាពនៃកិច្ច

[1013]កំណត់ហេតុស្តាប់ចម្លើយ សុក សុត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៧ **ឯកសារ E3/5835** ERN 00163525-26។ សាក្សី សុក សុត ពុំបាននិយាយឲ្យបានច្បាស់ថា អង្គបក្សីស្ថិតនៅក្នុងឃុំជាងទង នោះទេ។ ប៉ុន្តែ ភស្តុតាងផ្សេងៗទៀតដែលមានក្នុងសំណុំរឿង បានបញ្ជាក់អះអាងថា ភូមិអង្គបក្សីគឺពិតជាស្ថិតក្នុងឃុំជាងទង។ ក្នុងន័យនេះ សូមមើលជាឧទាហរណ៍៖ កិច្ចសម្ភាសមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ងឹម នឿន ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១១ **ឯកសារ E3/9082** ERN 00731233, របាយការណ៍របស់ អាន់ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៧៧ **ឯកសារ E3/2434** ERN 00270769។

[1014]កំណត់ហេតុស្តាប់ចម្លើយ សឹម ឈៀង ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ **ឯកសារ E3/7980** ERN 00165301-04។

[1015]កំណត់ហេតុស្តាប់ចម្លើយ សុក ស៊ឹម ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ **ឯកសារ E3/5519** ស/ឆ ៥ និង ៤៣។

[1016]កំណត់ហេតុស្តាប់ចម្លើយ តុប ដេ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ **ឯកសារ E3/7982** ERN 00165322-25។

[1017]កំណត់ហេតុស្តាប់ចម្លើយ នុត នូវ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩ **ឯកសារ E3/5521** ស/ឆ ៣២, ៣៦ និង ១០០។

[1018]ដីកាដំណោះស្រាយ កថាខណ្ឌ ៣០២។ សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៤៨-៨៥២។

ស៊ើបសួរ (ឃុំជាងទង)[1019]។ សេចក្តីសន្និដ្ឋាននេះគឺជាឧទាហរណ៍នៃការបញ្ចូលភស្តុតាងដាក់បន្ទុកទៅក្នុងដីកាដំណោះស្រាយ ដើម្បីគាំទ្រដល់អង្គហេតុ ដែលសហចៅក្រមស៊ើបអង្កេតមិនបានទទួលអាណត្តិឱ្យស៊ើបសួរ។ ដោយសារតែសេចក្តីសន្និដ្ឋានេះរំលោភទៅលើការធានានៃនីតិវិធីដែលផ្តល់ជូនជនជាប់ចោទគ្រប់រូប លោក ខៀវ សំផន មិនត្រូវជំនុំជម្រះលើអង្គហេតុទាំងនេះទេ។

៩២៩. ភស្តុតាងដាក់បន្ទុក ដែលសហចៅក្រមស៊ើបអង្កេតប្រមូលបាន មានទម្ងន់ស្រាលបំផុត គឺពាក់ព័ន្ធតែនឹងឃុំពីរ ក្នុងចំណោមឃុំទាំង ៨ ក្រោមវិសាលភាពនៃកិច្ចស៊ើបសួរក្នុងស្រុកត្រាំកក់។ ម្យ៉ាងវិញទៀត ភស្តុតាងដាក់បន្ទុកនេះមានចំនួនប្រហាក់ប្រហែលគ្នានឹងភស្តុតាងដោះបន្ទុក ដែលសហចៅក្រមស៊ើបអង្កេតបានច្រានចោល ដោយគ្មានការពន្យល់។

៩៣០. ប្រសិនបើសហចៅក្រមស៊ើបអង្កេត មិនអាចរកភស្តុតាងគាំទ្រដល់ការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ស្តីពី "ទុរ្ភិក្សទ្រង់ទ្រាយធំ" និងការស្លាប់របស់ "ប្រជាជនរាប់ពាន់នាក់" ដោយសារការស្រេកឃ្លាន សហចៅក្រមស៊ើបអង្កេតគួរតែប្រកាសលើកលែងការចោទប្រកាន់ដល់លោក ខៀវ សំផន ពីព្រោះ ការស្លាប់របស់មនុស្សបួននាក់ មិនអាចយកមកស្តីបន្ទោសលើគោលនយោបាយថ្នាក់ជាតិរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយគ្មានការពន្យល់ឱ្យបានលម្អិតជាងនេះ នោះទេ។

៩៣១. លោក ខៀវ សំផន មិនគួរត្រូវបានបញ្ជូនទៅជំនុំជម្រះ ចំពោះអង្គហេតុនៃការសម្លាប់រង្គាល នៅក្នុងឃុំទាំង ៨ នៃស្រុកត្រាំកក់នោះទេ។ យ៉ាងច្រើនបំផុត ក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ គាត់ត្រូវទទួលបានការជំនុំជម្រះចំពោះតែអង្គហេតុ ដែលបានកើតឡើងនៅឃុំសំរោង និងឃុំតាភេម ប៉ុណ្ណោះ។

## ៣. អំពីអង្គហេតុដែលត្រូវបានកំណត់ថាជាការដាក់ក្នុងមន្ទីរឃុំឃាំង

៩៣២. សហចៅក្រមស៊ើបអង្កេតបានកំណត់ថាជាការដាក់ក្នុងមន្ទីរឃុំឃាំង នូវអង្គហេតុនៃការឃុំខ្លួនដោយខុសច្បាប់ នៅក្នុងមន្ទីរឃុំឃាំងមួយរបស់កងឈ្លបឃុំ។ ការពិនិត្យមើលភស្តុតាងគាំទ្រដល់សេចក្តី

---

[1019] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៤៨-៨៥២។

សន្និដ្ឋាននេះ បង្ហាញថា កន្លែងតែមួយគត់នេះមិនស្ថិតនៅក្នុងស្រុកត្រាំកក់នោះទេ។ ទោះបីជាសេចក្តីសន្និដ្ឋានរបស់ខ្លួនស្របទៅនឹងបណ្តឹងដែលខ្លួនបានទទួលក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតបានរំលោភទៅលើដែនសមត្ថកិច្ចរបស់ខ្លួន។

៩៣៣. កំណត់សម្គាល់ចុងឯកសារតែមួយគត់ ដែលគាំទ្រដល់កថាខណ្ឌ ៣១៧ បង្ហាញពីភាពមិនសមហេតុផលរួចបាត់ទៅហើយ។ កថាខណ្ឌ ៣១៧ ចង្អុលបង្ហាញថា សាក្សីម្នាក់ ដែលរស់នៅក្នុងឃុំសំរោង បាននិយាយអំពីការធ្វើបាបបុរស និងស្ត្រី។ ក៏ប៉ុន្តែ កំណត់សម្គាល់ចុងឯកសារលេខ ១៣០៩ ដែលគាំទ្រដល់សេចក្តីសន្និដ្ឋាននេះ និងសេចក្តីសន្និដ្ឋានដែលថាប្រជាជនទាំងនេះត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងដោយឈ្លបឃុំ ផ្អែកលើចម្លើយរបស់សាក្សីពីររូប គឺ ពិល ឃៀង និង ប៊ុន ធៀន។

៩៣៤. ផ្ទុយទៅវិញ ការអានកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេ ដែលមិនអាចកែតម្រូវកំហុសច្បាស់ក្រឡែតបាន បង្ហាញឱ្យឃើញអំពីការបន្តិភ័ស្តុតាង និងការរំលោភជាថ្មីទៀតទៅលើវិសាលភាពនៃបណ្តឹងទៅកាន់សហចៅក្រមស៊ើបអង្កេត។

៩៣៥. ជាដំបូង ពិល ឃៀង ជាសាក្សីតែម្នាក់គត់ ដែលបានរៀបរាប់អំពីការកោរសក់ ដូចបានលើកឡើងនៅក្នុងកថាខណ្ឌ ៣១៧។ លើសពីនេះទៅទៀត ទោះបីជាគាត់ពិតជាធ្លាប់រស់នៅឃុំសំរោង ស្រុកត្រាំកក់ មែនក៏ដោយ ក៏ក្រោយមក គាត់ត្រូវបានបញ្ជូនទៅ "សហករណ៍ពង្រ ស្ថិតនៅឃុំខ្វាវ ស្រុកទ្រាំង"។ នៅកន្លែងនេះ គឺជាកន្លែងកោរសក់មនុស្ស រួចនាំយកទៅឃុំ" ដោយមិនបានបញ្ជាក់ថានៅកន្លែងណាឱ្យប្រាកដ[1020]។ ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតមិនទទួលបានអាណត្តិ ដើម្បីស៊ើបសួរលើអង្គហេតុ ដែលកើតឡើងនៅស្រុកទ្រាំងនោះទេ។ នេះគឺជាការរំលោភដែនបណ្តឹង។

៩៣៦. ចំពោះសាក្សី ប៊ុន ធៀន គាត់បានឆ្លើយថា "នៅក្នុងឃុំ គ្មានមន្ទីរសន្តិសុខទេ [...] គឺមានតែកន្លែងឃុំឃាំង ក្រោមការគ្រប់គ្រងរបស់ពួកឈ្លប"[1021]។ ម្យ៉ាង ចម្លើយមួយនេះចង់មានន័យថា គ្មាន

---

[1020] កំណត់ហេតុស្តាប់ចម្លើយ ពិល ឃៀង ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧ **ឯកសារ E3/5135** ERN 00165295, 00165297-98។

[1021] កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធៀន ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ **ឯកសារ E3/5498** ERN 00368603។

"មន្ទីរឃុំឃាំង ក្រោមការគ្រប់គ្រងរបស់កងឈ្លបឃុំ" នោះទេ ពីព្រោះ ដូចបានរៀបរាប់ខាងលើ គ្មានការបញ្ជាក់ថាពាក្យ « commune » និងពាក្យ « sous-district » មានន័យខុសគ្នានោះទេ[1022]។ ម្យ៉ាងទៀត សាក្សីនេះបានរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាបន្តបន្ទាប់ នៅឃុំសន្លុង និងឃុំជីខ្មារ ដែលជាឃុំនៃស្រុកទ្រាំង មិនមែនស្រុកត្រាំកក់[1023]។ ដូច្នេះ រហូតទាល់តែមានភស្តុតាងផ្ទុយពីនេះ គ្មានចម្លើយណាមួយរបស់គាត់ពាក់ព័ន្ធនឹងឃុំណាមួយ ក្នុងចំណោមឃុំទាំង ៨ ក្រោមវិសាលភាពនៃកិច្ចស៊ើបសួរឡើយ។ ជាចុងក្រោយ ដូចបានលើកឡើងខាងលើ សហចៅក្រមស៊ើបអង្កេតគ្មានសិទ្ធិអំណាចស៊ើបសួរនៅស្រុកទ្រាំងទេ។

៩៣៧. ការកត់សម្គាល់ទៅលើការរំលោភលើបណ្តឹងទៅកាន់សហចៅក្រមស៊ើបអង្កេត បន្ថែមពីលើការកត់សម្គាល់អំពីជនជាតិវៀតណាម នៅត្រាំកក់[1024]។ ការកត់សម្គាល់ទាំងនេះរំលេចឱ្យឃើញពីការអនុវត្តហួសដែនរបស់សហចៅក្រមស៊ើបអង្កេតដែលមិនគោរពទាល់តែសោះវិធាននីតិវិធី និងសិទ្ធិរបស់ជនជាប់ចោទ។

៩៣៨. អង្គជំនុំជម្រះមានកាតព្វកិច្ចរិះគន់ទៅលើឧបាយកលទាំងនេះ និងត្រូវប្រកាសថាខ្លួនគ្មានយុត្តាធិការក្នុងការកាត់សេចក្តីអង្គហេតុទាំងនេះ។ រឿងនេះទាក់ទងដល់យុត្តិធម៌នៃការជំនុំជម្រះក្តី។

## ៤. អំពីអង្គហេតុដែលត្រូវបានកំណត់ថាជាការធ្វើទារុណកម្ម

៩៣៩. យើងបានលើកឡើងខាងលើថា សហចៅក្រមស៊ើបអង្កេតបានរំលោភលើបណ្តឹងទៅកាន់ខ្លួន ដោយធ្វើការស៊ើបសួរទៅលើអង្គហេតុនៃកថាខណ្ឌ ៣១៧ នៃដីកាដំណោះស្រាយ ដែលត្រូវបានកំណត់ថាជាការធ្វើទារុណកម្ម។ ការកែច្នៃបាយការណ៍បី ដែលដកស្រង់នៅក្នុងកំណត់សម្គាល់ចុងឯក

---

[1022] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៩៩។

[1023] កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធៀន ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ **ឯកសារ E3/5498** ERN 00368599, 00368600 និង 00368605។

[1024] សូមមើលផ្នែកខាងលើ កថាខណ្ឌ ២១៩-២៧៦ (ការជម្លៀសប្រជាជន) កថាខណ្ឌ ៨៦៤-៨៦៦ (ការសម្លាប់រង្គាល) កថាខណ្ឌ ៨៧៩ (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍)។

សារ ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានទាំងនេះ ជាការបន្ថែមទៅលើការរំលោភបំពានជាហូរហែមក របស់សហាចៅក្រមស៊ើបអង្កេត ដែលគួរតែត្រូវផ្តន្ទាទោស[1025]។

៩៤០. តាមការពិនិត្យបឋម ការរៀបរាប់តុបតែងដើម្បីដាក់បន្ទុកនៃកថាខណ្ឌ ៣១៧ ចង់ឲ្យគេឃើញថា អង្គហេតុចោទប្រកាន់នៃការធ្វើទារុណកម្ម បានកើតឡើង នៅក្នុងមន្ទីរសន្តិសុខរបស់កងឈ្លបឃុំ។ ក៏ប៉ុន្តែ គួរឱ្យភ្ញាក់ផ្អើលទៀតហើយ ការអានឯកសារបីបញ្ជាក់ថា គ្មានភស្តុតាងអ្វីទាំងអស់។ គ្មានឯកសារណាមួយបង្ហាញព័ត៌មានអំពីមន្ទីរសន្តិសុខជាសម្មតិកម្មនេះឡើយ។

៩៤១. អាក្រក់ជាងនេះទៅទៀត របាយការណ៍ពីរមិនបានបញ្ជាក់អំពីកន្លែងបញ្ជូន និងកន្លែងដែលអ្នកទាំងនោះត្រូវបានធ្វើទារុណកម្មតាមសន្មតនោះឡើយ ពោលគឺមិនអាចនិយាយថា អង្គហេតុទាំងនេះបានកើតឡើងនៅតាមឃុំ ក្រោមវិសាលភាពនៃកិច្ចស៊ើបសួរនៃស្រុកត្រាំកក់ នោះឡើយ។ របាយការណ៍មួយ ក្នុងចំណោមរបាយការណ៍ទាំងពីរ មិនទាំងមានបញ្ជាក់កាលបរិច្ឆេទនៃការបញ្ជូនផង[1026]។ របាយការណ៍ចុងក្រោយប្រមូលផ្តុំឯកសារពីរមកពីឃុំអង្គតាសោម និងឃុំលាយបូរ ជាឃុំពីរដែលសហាចៅក្រមស៊ើបអង្កេតមិនទទួលបានអាណត្តិក្នុងការស៊ើបសួរ[1027]។

## ៥. អំពីការចោទប្រកាន់អំពីការលុបបំបាត់ "សិទ្ធិនយោបាយ" របស់ប្រជាជនថ្មី

៩៤២. យើងបានលើកឡើងពីខាងលើថា លោក ខៀវ សំផន ត្រូវជំនុំជម្រះតែលើអង្គហេតុចោទប្រកាន់អំពីការលុបបំបាត់ "សិទ្ធិនយោបាយ" របស់ប្រជាជនថ្មីដែលត្រូវបានហាមឃាត់មិនឱ្យកាន់មុខងារជាប្រធានកង នៅតាមសហករណ៍[1028]។

---

[1025]ដីកាដំណោះស្រាយ ជើងទំព័រ ១៣១០-១៣១១ យោងទៅលើរបាយការណ៍នានា **ឯកសារ E3/2445** (D157.63) "ពាក់ព័ន្ធនឹង ភួង", **ឯកសារ E3/2447** (D157.73) "ពាក់ព័ន្ធនឹង គឹង ហ៊ិន និង ហ៊ី ឌី" និង **ឯកសារ E3/4094** (D157.14) "ពាក់ព័ន្ធនឹង សុខា ហៅ សឿន"។

[1026]របាយការណ៍ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៧៧ **ឯកសារ E3/2445** ERN 00270984, របាយការណ៍ **ឯកសារ E3/4094**, 00270970-71។

[1027]របាយការណ៍ពីរ **ឯកសារ E3/2447** ERN 00270731-34។

[1028]សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៨៣-៩១០។

៩៤៣. ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត នៅកថាខណ្ឌ ៣០៥ ត្រូវបានគាំទ្រដោយសម្រង់នៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ភ្លៅ យ៉ារ និង ពិល យៀង ជាប្រជាជនមូលដ្ឋានឃុំសំរោង[1029]។

៩៤៤. ភ្លៅ យ៉ារ បានរៀបរាប់អំពីរចនាសម្ព័ន្ធសហករណ៍ និងឈ្មោះរបស់មេកងមួយចំនួន ប៉ុន្តែ គាត់មិនបានបញ្ជាក់ថា តើអ្នកទាំងនេះជាប្រជាជនថ្មី ឬប្រជាជនមូលដ្ឋាននោះទេ។ ទោះបីមានជាលទ្ធភាពខ្ពស់ថាមេៗទាំងនេះត្រូវបានជ្រើសចេញពីប្រជាជនមូលដ្ឋានក៏ដោយ ក៏សាក្សីនេះមិនបាននិយាយអ្វីទាំងអស់ត្រង់ចំណុចនេះ។ ដូច្នេះ សម្តីរបស់គាត់មិនអាចកំណត់ថាជាការរើសអើងចំពោះប្រជាជនថ្មីនោះឡើយ[1030]។ ផ្ទុយទៅវិញ ចម្លើយរបស់គាត់ទៅនឹងសំណួរអំពីការស្នាក់នៅ និងរបបអាហាររបស់ប្រជាជនថ្មី បង្ហាញអំពីការប្រព្រឹត្តិដូចគ្នាទៅនឹងប្រជាជនមូលដ្ឋានដែរ។

> "ពេលប្រជាជនថ្មីមកដល់ភ្លាម គេឱ្យរស់នៅក្នុងរោងសិប្បកម្ម ឬសាលារៀន ចំណែកឯការហូបចុកវិញ គេឱ្យប្រជាជនទាំងនោះហូបបាយនៅតាមរោងសហករណ៍ភូមិ"[1031]។

៩៤៥. ម្យ៉ាងវិញទៀត ក្រោយពីប្រជាជនថ្មីមកដល់ សាក្សីរូបនេះត្រូវបានចាត់ឱ្យទៅធ្វើការនៅ "កង ១" ដែលមានសមាសភាពប្រជាជនចាស់ ហើយប្រជាជនថ្មីស្ថិតនៅក្នុង "កង ៣"។ បន្ទាប់មកទៀត គាត់បានឆ្លើយទៅនឹងសំណួរអំពីបទពិសោធន៍ នៅក្នុងកងរបស់គាត់ ដោយគូសបញ្ជាក់ថា គាត់មិនដឹងរឿងរ៉ាវដែលកើតឡើងនៅក្នុងកង ៣ នោះទេ[1032]។ ដូច្នេះ វាជាការបោកប្រាស់ក្នុងការនិយាយថា ភ្លៅ យ៉ារ ផ្តល់ព័ត៌មានអំពីការលុបបំបាត់សិទ្ធិរបស់ប្រជាជនមួយក្តាប់តូច ដែលគាត់លែងមានការទាក់ទង។

---

[1029]ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៥ និងជើងទំព័រ ១២៤៥ យោងទៅលើកំណត់ហេតុស្តាប់ចម្លើយ ភ្លៅ យ៉ារ **ឯកសារ E3/5515** (D232/62) ទំព័រ ៤-៦ និងកំណត់ហេតុស្តាប់ចម្លើយ ពិល យៀង **ឯកសារ E3/5135** (D40/15) ទំព័រ ២-៥។

[1030]កំណត់ហេតុស្តាប់ចម្លើយ ភ្លៅ យ៉ារ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ **ឯកសារ E3/5515** ស/ឆ ១៣។

[1031]កំណត់ហេតុស្តាប់ចម្លើយ ភ្លៅ យ៉ារ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ **ឯកសារ E3/5515** ស/ឆ ៦។

[1032]កំណត់ហេតុស្តាប់ចម្លើយ ភ្លៅ យ៉ារ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ **ឯកសារ E3/5515** ស/ឆ ១២, ១៣-២៤, ២៧។

៩៤៦. ចំពោះ ពិល ឃៀង គាត់និយាយយ៉ាងច្បាស់ថា ប្រជាជនថ្មី "មិនមានសិទ្ធិធ្វើជាមេកង ឬមេភូមិឡើយ"[1033]។ ទោះជាយ៉ាងនេះក្ដី ចាប់ពីសំណួរបន្ទាប់មក គាត់បោះបង់ចោលនូវគំនិតនៃការប្រព្រឹត្តដោយរើសអើងចំពោះប្រជាជនថ្មី ដោយបញ្ជាក់ថា ប្រជាជនថ្មីត្រូវបាន "របបអាហារដូចប្រជាជនមូលដ្ឋានដែរ"[1034]។

៩៤៧. ដោយផ្អែកលើឯកសារតែមួយដែលមានភ័ស្តុតាងដាក់បន្ទុក និងមិនសូវមានមូលដ្ឋាន នៅឃុំតែមួយគត់នៃស្រុកត្រាំកក់ ហើយដែលឯកសារនោះមានភ័ស្តុតាងដោះបន្ទុកសំខាន់ផងដែរអំពីអវត្តមាននៃការរើសអើងចំពោះប្រជាជនថ្មី សហចៅក្រមស៊ើបអង្កេតគួរតែប្រកាសថា គ្មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ។

៩៤៨. នៅក្នុងល័ក្ខខ័ណ្ឌទាំងនេះ លោក ខៀវ សំផន មិនមានអ្វីត្រូវជំនុំជម្រះពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការលុបបំបាត់ "សិទ្ធិនយោបាយ" របស់ប្រជាជនថ្មីឡើយ។

## ផ្នែកទី ៣. ការបង្ហាញភ័ស្តុតាង

៩៤៩. ក្នុងចំណោមភ័ស្តុតាង ដែលបានបង្ហាញជូនក្នុងពេលជំនុំជម្រះក្ដី (១) ភ័ស្តុតាងជាច្រើនស្ថិតនៅក្រៅយុត្តាធិការរបស់អង្គជំនុំជម្រះ (២)។ ភ័ស្តុតាងខ្លះទៀតអាចឱ្យយើងគិតថា ឧក្រិដ្ឋកម្មមួយចំនួនអាចមានធាតុផ្សំគ្រប់គ្រាន់ (៣)។

### ១. បញ្ជីភ័ស្តុតាង

៩៥០. ពីថ្ងៃទី ០៨ ខែ មករា ដល់ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ បុគ្គល ៣២ រូប បានមកផ្ដល់សក្ខីកម្មនៅសវនាការ ក្នុងវគ្គសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។

---

[1033]កំណត់ហេតុស្ដាប់ចម្លើយ ពិល ឃៀង ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ **ឯកសារ E3/5135** ERN 00165295-96។

[1034]កំណត់ហេតុស្ដាប់ចម្លើយ ពិល ឃៀង ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ **ឯកសារ E3/5135** ERN 00165296។

៩៥១. ក្នុងសវនាការរយៈពេល ៥០ ថ្ងៃ (ស្មើនឹង ១២,៥ សប្តាហ៍ ក្នុង ១ សប្តាហ៍ មាន ៤ ថ្ងៃសវនាការ) សាក្សី ១៧ រូប អ្នកជំនាញ ១ រូប និងដើមបណ្តឹងរដ្ឋប្បវេណី ១៤ រូប បានមកផ្តល់សក្ខីកម្មបន្តបន្ទាប់គ្នា នៅក្នុងសវនាការ។ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំង ១៤ រូប ដើមបណ្តឹងរដ្ឋប្បវេណី ៧ រូប បានផ្តល់សក្ខីកម្មអំពីអង្គហេតុ ដើមបណ្តឹងរដ្ឋប្បវេណី ៦ រូប បានផ្តល់សក្ខីកម្មអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម និងដើមបណ្តឹងរដ្ឋប្បវេណី ១ រូប (ចាន់ ធីម) បានផ្តល់សក្ខីកម្ម ដំបូងអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម និងក្រោយមកទៀត ត្រូវបានកោះហៅម្តងទៀតឱ្យមកផ្តល់សក្ខីកម្មអំពីអង្គហេតុ។

៩៥២. ចំពោះសាក្សីទាំង ១៧ រូប ដែលត្រូវបានស្តាប់ចម្លើយ គួរកត់សម្គាល់ថា ក្នុងចំណោមសាក្សីទាំងនេះ សាក្សី ៤ រូប មិនត្រូវបានស្តាប់ចម្លើយនោះទេ ក្នុងអំឡុងពេលស៊ើបអង្កេតលើសំណុំរឿង ០០២ (ស្មើនឹងប្រហែល ២០% នៃសាក្សី ដែលត្រូវបានស្តាប់ចម្លើយ ក្នុងវគ្គនេះ)[1035]។ ក្នុងចំណោមសាក្សី ទាំង ៤ រូបនេះ សាក្សី ៣ រូប ជាអតីតកម្មាភិបាលខ្មែរក្រហម ធ្វើឱ្យចំនួនកម្មាភិបាលដែលត្រូវបានស្តាប់ចម្លើយក្នុងវគ្គនេះ មាន ៥ នាក់ និងម្នាក់ជាអ្នកទោសស្រីនៅក្រាំងតាចាន់ធ្វើឱ្យចំនួនអ្នកទោសដែលត្រូវបានស្តាប់ចម្លើយ មាន ៣ នាក់[1036]។ តួលេខនេះបង្ហាញយ៉ាងច្បាស់អំពីភាពខ្វះចន្លោះនៃកិច្ចស៊ើបសួរ។

៩៥៣. បុគ្គលស្ទើរតែទាំងអស់បានផ្តល់ព័ត៌មានអំពីសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ មន្ទីរសន្តិសុខក្រាំងតាចាន់នឹងត្រូវសិក្សាខាងក្រោម[1037]។

៩៥៤. ក្នុងពេលសវនាការស្តីពីវគ្គផ្សេងទៀតនៃការជំនុំជម្រះក្តី សាក្សីមួយចំនួនក៏បានផ្តល់ព័ត៌មានអំពីស្រុកត្រាំកក់ផងដែរ ឧទាហរណ៍ សាក្សី សៅ វ៉ាន់ សាក្សី 2-TCW-1005 និងសាក្សី ឡុង វុន។

---

[1035] សាក្សីដែលអ្នកស៊ើបអង្កេតពុំធ្លាប់ដែលបានស្តាប់ចម្លើយ ក្នុងសំណុំរឿង ០០២ មានសាក្សី នាង អ៊ូច, ខឹម ហឿន, ឯក ហឿន និង វង សារុន។

[1036] នាង អ៊ូច, ខឹម ហឿន និង ឯក ហឿន ធ្លាប់ធ្វើជាកម្មាភិបាលខ្មែរក្រហម រីឯ វង សារុន ធ្លាប់ជាអ្នកទោសនៅក្រាំងតាចាន់។

[1037] សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ១២២០និងកថាខណ្ឌបន្តបន្ទាប់ទៀត។

៩៥៥. ម្យ៉ាងវិញទៀត ក្រៅពីកំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០២ កំណត់ហេតុស្តាប់ចម្លើយយ៉ាងច្រើនសន្ធឹកសន្ធាប់មកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលត្រូវបានដាក់បញ្ចូល ក្នុងពេលជំនុំជម្រះក្តីលើសំណុំរឿង ០០២ លើកឡើងអំពីសហករណ៍ត្រាំកក់។

## ២. ភស្តុតាងក្រៅវិសាលភាព

៩៥៦. យើងមិនអាចរៀបរាប់អស់នូវភស្តុតាងក្រៅវិសាលភាព ដែលអង្គជំនុំជម្រះបន្តដាក់ចូលក្នុងសំណុំរឿងនេះ នោះទេ។ ការបង្ហាញភស្តុតាងច្រើនសន្ធឹកសន្ធាប់ ពាក់ព័ន្ធនឹងទីតាំងក្រៅវិសាលភាព (ក) និងការដោះដូរវៀតណាម និងខ្មែរក្រោម (ខ) គឺជាឧទាហរណ៍ជាក់ស្តែងនៃការគេចវេះបញ្ហា។ ឧទាហរណ៍ទាំងនេះបង្ហាញអំពីការបាត់បង់ម្ចាស់ការរបស់អង្គជំនុំជម្រះទៅលើសវនាការ ដែលមានរយៈពេលជាងបួនខែ ខណៈដែលបទចោទស្របច្បាប់មានភាពតឹងរ៉ឹងគួរសម។

### ក. ឧទាហរណ៍អំពីអង្គហេតុកើតឡើងនៅតាមឃុំក្រៅវិសាលភាព

៩៥៧. ដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះមិនបានទទួលបណ្តឹងតាមផ្លូវច្បាប់អំពីអង្គហេតុ ដែលកើតឡើងនៅតាមឃុំផ្សេងទៀត ក្រៅពីឃុំដូចបានរៀបរាប់ក្នុងកថាខណ្ឌ ៣០២ នៃដីកាដំណោះស្រាយនោះទេ។ រាល់ភស្តុតាងដែលបង្ហាញជូនពាក់ព័ន្ធនឹងឃុំផ្សេងទៀត ស្ថិតនៅក្រៅវិសាលភាព។

៩៥៨. ឈ្មោះឃុំមួយចំនួននៅក្រៅវិសាលភាព ត្រូវបានសាក្សី ពេជ្រ ជឹម រៀបរាប់នៅក្នុងសវនាការ។ ក្រោយពីបានបញ្ជាក់ថា "ស្រុកត្រាំកក់មាន ១៤ ឃុំ" និងរំឭកអំពីឃុំ នៅក្នុងកថាខណ្ឌ ៣០២ នៃដីកាដំណោះស្រាយ សាក្សីបានរៀបរាប់ឈ្មោះឃុំ "អង្គតាសោម លាយបូរ ពពេល ជាងទង ខ្ពបរុន

បឹងស្រង៉ែ"។ ឃុំពីរចុងក្រោយនេះមិនមានបង្ហាញនៅលើផែនទីរបស់អ្នកស៊ើបអង្កេតនោះទេ[1038]។ បន្ទាប់មកទៀត ពេជ្រ ជឹម បានបញ្ចប់ចម្លើយរបស់ខ្លួន ដោយនិយាយថា "អស់ហើយ"[1039]។

៩៥៩. រាល់ភ័ស្តុតាងទាំងអស់អំពីអង្គហេតុ ដែលកើតឡើងនៅឃុំទាំងនេះ ស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តី ឧទាហរណ៍ ព័ត៌មានដែលផ្តល់ដោយសាក្សី មាស សុខា អំពីអង្គហេតុ ដែលកើតឡើងនៅ "ឃុំជាងទង" ជាកន្លែងដែលគាត់រស់នៅ[1040]។ ដោយសារហេតុផលដដែលនេះ ការរៀបរាប់អំពីអង្គហេតុ ដែលកើតឡើងនៅ "ឃុំលាយបូរ" ជាកន្លែងដែលសាក្សី នាង អ៊ួច បានរស់នៅ ចាប់ពីខែ មិថុនា ឆ្នាំ ១៩៧៧ ត្រូវដកចេញពីការពិភាក្សាដេញដោល[1041]។ ការកត់សម្គាល់ដូចគ្នានេះត្រូវអនុវត្តចំពោះរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន អំពីការបាត់បង់កូនម្នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី ជួ គឹមឡុន អំពីការស្លាប់ប្តី និងកូនម្នាក់ ដោយសារហេតុការណ៍ទាំងនេះកើតឡើងនៅ "ឃុំលាយបូរ"[1042]។

៩៦០. ក្នុងឃុំដដែលនេះ សាក្សី ឯក ហឿន បានឆ្លើយ ដោយមិនផ្តល់ប្រភព ឬការពន្យល់ ថា "ប្រជាជន ៥០០ នាក់ បានស្លាប់ដោយអត់បាយ"[1043]។ ក្រៅពីចម្លើយមិនសូវជឿជាក់បានមួយនេះ និងចម្លើយផ្សេងទៀតរបស់សាក្សីរូបនេះ ដែលចូលចិត្តនិយាយច្រើន ដោយមិនបញ្ជាក់ប្រភពម្តងណាសោះ (ការសួរដេញដោលលើបញ្ហាប្រភពពីសំណាក់សហព្រះរាជអាជ្ញា និងចៅក្រម Jean-Marc

---

[1038]របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ **ឯកសារ E3/8051** ERN 00450445 (ភាសាបារាំង)។

[1039]<u>ពេជ្រ ជឹម</u> ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ E1/291.1** ទំព័រ ៣២ ចន្លោះម៉ោង [១១.២៩.២៥] និង [១១.៣២.២៣], ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ E1/292.1** ទំព័រ ៣៥ ចន្លោះម៉ោង [១១.២៤.២៥] និង [១១.២៨.២៨]។

[1040]<u>មាស សុខា</u> កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៧ **ឯកសារ E3/5825** ERN 00163511, ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២៣ ប្រហែលម៉ោង [១០.០៤.៤៣]។

[1041]<u>នាង អ៊ួច</u> ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ E1/273.1** ទំព័រ ១២ ប្រហែលម៉ោង [០៩.៣៩.១៧]។

[1042]<u>អ៊ុង សារឿន</u> ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ E1/283.1** ទំព័រ ៤-៧ ចន្លោះម៉ោង [០៩.១៣.២០] និង [០៩.២២.១៥], <u>ជួ គឹមឡុន</u> ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/252.1** ទំព័រ ៣៥ ប្រហែលម៉ោង [១១.០៩.៥០] និងទំព័រ ៣៨ ចន្លោះម៉ោង [១១.២០.០០] និង [១១.២៤.១៩], ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/253.1** ទំព័រ ២៧-២៩ ចន្លោះម៉ោង [១០.៥៣.១២] និង [១០.៥៩.៥៩]។

[1043]<u>ឯក ហឿន</u> ប្រតិចារឹក ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/299.1** ទំព័រ ១៣ ប្រហែលម៉ោង [០៩.៤៣.០០]។

LAVERGNE នៅតែមិនទទួលបានចម្លើយច្បាស់លាស់) អង្គហេតុដែលបានរៀបរាប់ស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តី[1044]។

៩៦១. នេះក៏ជាករណីនៃសក្ខីកម្មស្ទើរតែទាំងអស់របស់សាក្សី ខឹម បឿន មេឃុំជាងទង ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ សាក្សីរូបនេះមិនត្រូវបានស្តាប់ចម្លើយដោយអ្នកស៊ើបអង្កេតក្នុងសំណុំរឿង ០០២ នោះទេ ប៉ុន្តែ ត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម តាមការស្នើសុំរបស់សហព្រះរាជអាជ្ញា ដែលផ្អែកលើកំណត់ហេតុស្តាប់ចម្លើយគាត់នៅក្នុងសំណុំរឿង ០០៤[1045]។

៩៦២. ព័ត៌មាន ដែលបានលាតត្រដាងនៅក្នុងសវនាការ ឬមានក្នុងឯកសារសម័យនោះ ក៏ត្រូវបានបង្ហាញនៅក្នុងការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ ស្តីពីឃុំខ្ពបត្របែកផងដែរ[1046]។ ភ័ស្តុតាងទាំងនេះសុទ្ធតែនៅក្រៅវិសាលភាព។ ដើម្បីឱ្យច្បាស់ គួរកត់សម្គាល់ថា នៅពេលឆ្លើយទៅនឹងសំណួររបស់ចៅក្រម Jean-Marc LAVERGNE អំពីទីតាំង "ទំនប់ខ្ពបត្របែក" ក្រៅវិសាលភាព សាក្សី សូត្រ សាំង បានអះអាងថាទំនប់នេះស្ថិតក្នុង "ឃុំអូរសារ៉ាយ ស្រុកត្រាំកក់" ជាឃុំនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២[1047]។

៩៦៣. ភ័ស្តុតាងផ្សេងទៀត ដែលបង្ហាញជូននៅក្នុងសវនាការ ពាក់ព័ន្ធនឹងការឃុំឃាំង នៅទីតាំងអង្គរកា។ ដោយសារអង្គជំនុំជម្រះមិនបានទទួលបណ្តឹងអំពីអង្គហេតុនៃការឃុំឃាំងនៅទីតាំងនេះ ភ័ស្តុតាងទាំងនេះសុទ្ធតែនៅក្រៅវិសាលភាព។ ទោះបីជាសហចៅក្រមស៊ើបអង្កេតបានស៊ើបសួរដោយគ្មាន

---

[1044]ឧទាហរណ៍ សូមមើល ឯក ហឿន ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/298.1** ទំព័រ ៤១-៤២ ប្រហែលម៉ោង [១៣.៣៩.០៥] ដែលនៅត្រង់នោះ សាក្សីបាននិយាយរៀបរាប់ ដោយគាត់ពុំប្រាប់ថានរណាជាអ្នកប្រាប់គាត់ថាមានមនុស្សស្លាប់នៅទីកន្លែងមួយដែលគ្មាននៅក្នុងដីកាដំណោះស្រាយ និងស្ថិតក្រៅវិសាលភាពនៃសំណុំរឿង (មន្ទីរ ២០៤ នៅព្រៃក្តួច)។

[1045]សំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ E319/17** កថាខណ្ឌ ៥-១០។

[1046]<u>រី ពៅ</u> ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/262.1** ប្រហែលម៉ោង [០៩.១៤.២៣] និង [១០.៤៤.១៥], <u>រៀល សន</u> ប្រតិចារឹក ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ E1/278.1** ប្រហែលម៉ោង [០៩.២៨.៣១], របាយការណ៍កម្ពុជាប្រជាធិប- តេយ្យ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៧ **ឯកសារ E3/2050** ERN 00079111។

[1047]<u>សូត្រ សាំង</u> ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ E1/281.1** ទំព័រ ៥៥-៥៦ ចន្លោះម៉ោង [១៤.៣៣.០៦] និង [១៤.៣៩.១២]។

អាណត្តិទៅលើមន្ទីរឃុំឃាំងដ៏អាថ៌កំបាំងមួយក្នុងស្រុកទ្រាំងក៏ដោយ[1048] ក៏ពួកគាត់មិនបានស៊ើបសួរលើអង្គហេតុនៃការឃុំឃាំងនៅអង្គរកា ក្នុង "ឃុំជាងទង" ស្រុកត្រាំកក់[1049] នោះទេ។

## ខ. វិសាលភាពនៃអង្គហេតុពាក់ព័ន្ធនឹងជនជាតិភាគតិចវៀតណាម

៩៦៤. ភ័ស្តុតាងអំពីជនជាតិវៀតណាមនៅត្រាំកក់ ស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តីនេះ។ យើងបានលើកឡើងពីខាងលើថា សហព្រះរាជអាជ្ញាមិនបានប្តឹងឱ្យសហចៅក្រមស៊ើបអង្កេតស៊ើបសួរអំពីអង្គហេតុពាក់ព័ន្ធជាពិសេសនឹងក្រុមមនុស្សប្រភេទនេះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នោះឡើយ[1050]។

៩៦៥. គួររំឭកថា ដោយរំលោភទៅលើវិសាលភាពនៃបណ្តឹងមកកាន់ខ្លួន សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្មជម្លៀសប្រជាជននៅតាមសហករណ៍ត្រាំកក់[1051]។ បន្ទាប់មកអង្គជំនុំជម្រះសម្រេចដោយខ្លួនឯងថាមិនទទួលយកបទចោទនេះ នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ ទោះបីជាអង្គជំនុំជម្រះមិនបានផ្តល់ការពន្យល់ក៏ដោយ ក៏ឧបសម្ព័ន្ធនៃសេចក្តីសម្រេចមានភាពច្បាស់លាស់៖ ឧក្រិដ្ឋកម្មនៃការជម្លៀសមិនស្ថិតនៅក្នុងបទចោទប្រឆាំងនឹង ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០២ ចំពោះអង្គហេតុដែលកើតឡើងនៅត្រាំកក់ នោះទេ[1052]។

---

[1048]សូមមើលផ្នែកខាងលើ កថាខណ្ឌ ៩៣២-៩៣៨។

[1049]កំណត់ហេតុស្តាប់ចម្លើយ ខៀវ នៅ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៩ **ឯកសារ E3/507** ERN 00355440, ឯម ភឿង ប្រតិចារឹក ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/263.1** ទំព័រ ១០ ប្រហែលម៉ោង [០៩.៣៨.០៨]។

[1050]សូមមើលផ្នែកខាងលើ កថាខណ្ឌ ២១៩-២៧៦។

[1051]ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៧-១៣៩៨។

[1052]សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1**, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ៥ ("ការនិរទេស (កថាខណ្ឌ ១៣៩៧-១៤០១) (កម្រិតត្រឹមសហករណ៍ត្រាំកក់ និងការប្រព្រឹត្តលើជនជាតិវៀតណាមនៅខេត្តព្រៃវែង និងស្វាយរៀង")), សូមមើលផ្នែកខាងលើ កថាខណ្ឌ ២១៩-២៧៦។

៩៦៦. ដំណោះស្រាយរបស់អង្គជំនុំជម្រះ គឺជាការជួយកែកំហុសនៃការរំលោភបំពានរបស់សហចៅក្រមស៊ើប អង្កេត។ ប៉ុន្តែ ទោះបីជាអង្គជំនុំជម្រះគ្មានយុត្តាធិការក្នុងការជំនុំជម្រះលើអង្គហេតុនៃការជម្លៀសនេះក៏ដោយ ក៏ភ័ស្តុតាងជាច្រើននៅតែត្រូវបានដាក់បង្ហាញពាក់ព័ន្ធនឹងអង្គហេតុនេះ។

៩៦៧. ដូច្នេះ អង្គជំនុំជម្រះត្រូវបដិសេធចោលសក្ខីកម្មមួយផ្នែកធំរបស់ដើមបណ្តឹងរដ្ឋប្បវេណី វី ពៅ ជាខ្មែរក្រោមមកពីវៀតណាម ក្នុងឆ្នាំ ១៩៧៦ ក្នុងក្របខ័ណ្ឌនៃកម្មវិធីដោះដូរ[1053]។

៩៦៨. នេះក៏ជាករណីនៃសក្ខីកម្មផ្នែកខ្លះរបស់សាក្សី ជាំង ស្រីមុំ ផងដែរ ដែលបានរៀបរាប់អំពីការចាកចេញរបស់ជនជាតិវៀតណាមពីឃុំញ៉ែងញ៉ង់របស់គាត់។ សក្ខីកម្មរបស់សាក្សីរូបនេះក្នុងសវនាការមានលក្ខណៈគួរឱ្យចាប់អារម្មណ៍ ពីព្រោះវាបង្ហាញនូវការធ្វេសប្រហែសរបស់សហចៅក្រមស៊ើបអង្កេត ដែលផ្អែកតែលើកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីរូបនេះ ដើម្បីអះអាងថា "ប្រជាជនវៀតណាមត្រូវបានចាប់យកទៅសម្លាប់"[1054]។ ពេលសួរដេញដោលក្នុងសវនាការលើប្រធានបទនេះ ទោះបីមានសេចក្តីសន្និដ្ឋានខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេតក៏ដោយ[1055] ជាំង ស្រីមុំ បានទទួលស្គាល់ភ្លាមថា គាត់ជឿតាមពាក្យចចាមអារ៉ាម៖

> "គេនិយាយថា អ្នកទាំងនេះទៅកន្លែងក្រាំងតាចាន់ ទៅកន្លែងសម្លាប់មនុស្ស [...]។ ហេតុការណ៍ គឺវាបែបនេះឯង។ ចិត្តខ្ញុំស្មានទៅនឹង១០០ភាគរយហើយ ព្រោះអីវាមានឃើញអ្នកផ្សេងៗសុទ្ធតែទៅផ្លូវហ្នឹងទាំងអស់ ហើយគ្មានវិលត្រឡប់មកវិញ"[1056]។

៩៦៩. ដូច្នេះ ដំរីបង្កើតបានកូនកណ្តុរ ហើយភាពច្បាស់លាស់នៃឧក្រិដ្ឋកម្មគួរឱ្យស្ញប់ស្ញែង ដូចបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ គ្រាន់តែជាគំនិតស្មានគ្មានមូលដ្ឋានគ្រប់គ្រាន់ សម្រាប់បញ្ជូន

---

[1053] <u>វី ពៅ</u> ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/262.1**។

[1054] ដីកាដំណោះស្រាយ កថាខណ្ឌ ៣២០ ជើងទំព័រ ១៣២០ យោងទៅលើកំណត់ហេតុស្តាប់ចម្លើយ ជាំង ស្រីមុំ **ឯកសារ E3/5832** (D232/58) ទំព័រ ៦-៨។

[1055] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៦៤-៨៦៦។

[1056] <u>ជាំង ស្រីមុំ</u> ប្រតិចារឹក **ឯកសារ E1/254.1** ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៦៧-៦៩ ចន្លោះម៉ោង [១៥.៣០.១៨] និង [១៥.៣៧.២៥]។

ជនជាប់ចោទទៅជំនុំជម្រះពីបទសម្លាប់រង្គាលឡើយ ប្រសិនបើសហចៅក្រមស៊ើបអង្កេតបង្ហាញ សម្ពតិកម្មនេះ តាំងពីដំណាក់កាលស៊ើបអង្កេតនោះ។

## ៣. ភស្តុតាងអំពីឧក្រិដ្ឋកម្មមួយចំនួន

៩៧០. ភស្តុតាងមួយផ្នែកដែលបានបង្ហាញ អាចនាំឱ្យយើងគិតថា មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករ ដូចបានចោទប្រកាន់នៅក្នុងកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយ។

៩៧១. ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតបានកំណត់ថាជាអំពើអមនុស្សធម៌ផ្សេងទៀតនូវអង្គហេតុនៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស (កថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយ) និងការបាត់ខ្លួនដោយបង្ខំ (កថាខណ្ឌ ១៤៧០)។

៩៧២. យោងតាមវិធីសាស្ត្រ "ទូទៅ" របស់អង្គជំនុំជម្រះតុលាការកំពូល នៅសម័យកាលកើតអង្គហេតុអំពើមនុស្សធម៌ផ្សេងទៀតដែលសេសសល់ ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមានបែងចែកជាអនុប្រភេទ ដូចបានគ្រោងឡើងក្នុងដីកាដំណោះស្រាយ និងសាលក្រមលើសំណុំរឿង ០០២/០១ នោះទេ[1057]។ ក្រុមមេធាវីការពារក្តីមិនជំទាស់នឹងការវិភាគនេះទេ ហើយក៏មិនជំទាស់ដែរថា អំពើដែលអាចកំណត់ជាទូទៅថាជាអំពើអមនុស្សធម៌ផ្សេងទៀត អាចកើតឡើង នៅសហករណ៍ត្រាំកក់។

៩៧៣. ទោះជាយ៉ាងនេះក្តី ក្រុមមេធាវីការពារក្តីសូមរំឭកថា ឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀត អាចមានធាតុផ្សំគ្រប់គ្រាន់ តែប្រសិនបើវាកើតឡើងនៅក្នុងឃុំណាមួយ ក្នុងចំណោមឃុំទាំង ៨ ក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[1058]។

---

[1057] សាលដីកា ០០២/០១ កថាខណ្ឌ ៥៧២-៥៩០។

[1058] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៤៨។

## ផ្នែកទី ៤. ការពិនិត្យមើលភស្តុតាងពាក់ព័ន្ធ

៩៧៤. ដើម្បីជាការរំឭក យើងបានលើកឡើងពីខាងលើថា អង្គហេតុពាក់ព័ន្ធនឹងការប្រព្រឹត្តិទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងពុទ្ធសាសនិក និងការចោទប្រកាន់អំពីការរៀបការដោយបង្ខំ ត្រូវបានរៀបរាប់លម្អិតនៅក្នុងផ្នែកផ្សេងទៀតនៃសារណានេះ[1059]។ ការវិភាគទៅលើភស្តុតាងពាក់ព័ន្ធនឹងប្រធានបទទាំងនេះ ត្រូវបានលម្អិតក្នុងពេលជាមួយគ្នានោះ។

៩៧៥. អង្គហេតុ ដែលលោក ខៀវ សំផន ត្រូវឆ្លើយតប គឺការស្លាប់ដោយអត់បាយ នៅឃុំសំរោង និងឃុំតាភេម ដែលត្រូវបានកំណត់ថាជាការសម្លាប់រង្គាល។

### ១. គ្មានមនុស្សស្លាប់ដោយអត់បាយ នៅតាមឃុំក្នុងវិសាលភាពនៃបណ្តឹង

៩៧៦. ដើម្បីជាការរំឭក ទោះបីជាសហព្រះរាជអាជ្ញាបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតស៊ើបសួរលើ "ប្រជាជនរាប់ពាន់នាក់បានអត់បាយរហូតដល់ស្លាប់" ក៏សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានយ៉ាងលំបាកថា មានមនុស្សខ្លះស្លាប់ដោយសារខ្វះស្បៀង គឺតែ ៤ នាក់ប៉ុណ្ណោះ នៅក្នុងឃុំសំរោង និងឃុំតាភេម ក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ។

៩៧៧. ក្នុងការគិតគូរដ៏កម្រដល់សុចរិតភាព សហចៅក្រមស៊ើបអង្កេតក៏បានបញ្ជាក់ផងដែរថា មិនមានមនុស្សស្លាប់ យ៉ាងហោចណាស់ នៅក្នុងឃុំបីផ្សេងទៀត ក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ។ ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតមិនបាននិយាយអ្វីអំពីបីឃុំចុងក្រោយ ក្នុងវិសាលភាពនៃកិច្ចស៊ើបសួរនោះទេ។ ដោយសារភស្តុតាង ដែលប្រមូលបាន មិនអាចឱ្យសហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញអំពីឧក្រិដ្ឋកម្ម នៅឃុំចំនួន ៦ ក្នុងចំណោមឃុំទាំង ៨ អង្គជំនុំជម្រះមិនអាចចាត់ទុកថាខ្លួនបានទទួលដោយត្រឹមត្រូវតាមច្បាប់បណ្តឹងអំពីអង្គហេតុ ដែលកើតឡើងនៅក្នុងឃុំទាំង ៦ នោះទេ[1060]។

---

[1059] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៤៦។

[1060] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៩២៤-៩៣១។

៩៧៨. អង្គជំនុំជម្រះមិនបានបង្គាប់ឱ្យកោះហៅបុគ្គលតែពីររូបគត់ ដែលត្រូវបានស្តាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេតទៅលើអង្គហេតុក្នុងវិសាលភាពនៃបណ្តឹង គឺ ស៊ឹម ឈៀង ចំពោះអង្គហេតុនៅឃុំសំរោង និង សុក ស៊ឹម ចំពោះអង្គហេតុនៅឃុំតាភេម។ ដូច្នេះ អ្នកទាំងពីរនេះមិនត្រូវបានស្តាប់ចម្លើយនៅក្នុងកិច្ចពិភាក្សាដេញដោលជាសាធារណៈនោះទេ។ អង្គជំនុំជម្រះមិនអាចធ្វើសេចក្តីសន្និដ្ឋានអំពីឧក្រិដ្ឋកម្មដោយផ្អែកតែលើកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគាត់ឡើយ[1061]។

៩៧៩. ភស្តុតាង ដែលបានបង្ហាញជូនអំពីឃុំសំរោង (ក) និងឃុំតាភេម (ខ) មិនអាចឱ្យសន្និដ្ឋានថាមានមនុស្សស្លាប់ដោយអត់បាយ នៅក្នុងឃុំទាំងនេះបានទេ។

## ក. ឃុំសំរោង

៩៨០. ក្នុងចំណោមបុគ្គលដែលបានកោះហៅ មានតែដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ (១) និងសាក្សី ភ្នៅ យ៉ារ (២) និង ផាន់ ផេន (៣) ប៉ុណ្ណោះ និយាយថា ខ្លួនរស់នៅឃុំសំរោង[1062]។ អ្នកទីពីរពិតជាបានរស់នៅក្នុងឃុំសំរោង ស្រុកត្រាំកក់ មែន ឯអ្នកទីមួយមិនសូវច្បាស់ទេ ខណៈដែលអ្នកទីបីមិនមែនរស់នៅក្នុងឃុំសំរោងទេ។

### 1. រី ពៅ

៩៨១. រី ពៅ បានលើកឡើងអំពីទីកន្លែងជាច្រើន ដែលគាត់ធ្លាប់រស់នៅ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រោយពីវិលត្រឡប់មកពីវៀតណាមវិញ ក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៦។ គាត់បាននិយាយថាគាត់រស់នៅភូមិត្នោតជ្រុំ ឃុំខ្ពបត្របែក ស្រុកត្រាំកក់ រួចត្រូវបានបញ្ជូនទៅកងចល័តនៅក្បាលពោធិ៍ "ខាង

---

[1061] កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម ឈៀង ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ **ឯកសារ** **E3/7980**, កំណត់ហេតុស្តាប់ចម្លើយ សុក ស៊ឹម ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ **ឯកសារ** **E3/5519**។

[1062] <u>រី ពៅ</u> កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣ **ឯកសារ** **E3/9604** ស/ឆ ២៤ និងប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ** **E1/262.1** ទំព័រ ៣៨ ប្រហែលម៉ោង [១១.២៣.០៦], <u>ភ្នៅ យ៉ារ</u> ប្រតិចារឹក ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ** **E1/264.1** ទំព័រ ៤ ប្រហែលម៉ោង [០៩.១១.៤៨], <u>ផាន់ ផេន</u> ប្រតិចារឹក ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ** **E1/268.1** ទំព័រ ៥០ ប្រហែលម៉ោង [១៤.០១.៥៦]។

ត្បូងខេត្តតាកែវ"[1063]។ ទោះបីជាមានការលំបាកស្រាប់ក្នុងការដឹងថាតើការបញ្ជូនទៅនេះកើតឡើងនៅពេលណាក៏ដោយ ក៏គាត់បានឆ្លើយថាគេផ្លាស់គាត់ "ពីភូមិស្ទឹងទៅខ្ពបត្របែក ឃុំសំរោង"។ គាត់បានបន្ថែមថាគាត់ត្រូវ "ភ្ជួរស្រែ និងជីកប្រឡាយនៅភូមិពងទឹក"[1064]។ ជាចុងក្រោយ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ គាត់បានឆ្លងកាត់ "ភូមិព្រៃតាខាប ឃុំសំរោង"[1065]។

៩៨២. ក្នុងពេលផ្តល់សក្ខីកម្ម រី ពៅ បាននិយាយអំពីមរណភាពរបស់មនុស្សពីរនាក់នៅក្នុងកងចល័តរបស់គាត់៖

> "បាទ សម័យនោះ មានកងយុវជនរបស់ខ្ញុំហ្នឹង នៅអូរក្រូចហ្នឹង មានអ្នកអត់បាយហ្នឹង អត់បាយស្លាប់ហ្នឹងពីរនាក់ដែរ។ អ៊ីចឹងគេបន្តប់បន្លែ គេថាមកពីខ្យល់គ ប៉ុន្តែ អ្នកហ្នឹងកាលពីសម័យនោះ វាកើត វាត្រូវមុតចប អ៊ីចឹងវាចេញទៅជាដំបៅ ទៅជាមហារីក។ អ៊ីចឹងគេឱ្យហូបអត់ឆ្អែតទេ។ កាលណាហូប យើងឈឺហើយ ហូបបាយ គេថាយើងសតិអារម្មណ៍។ អ៊ីចឹងគេចេះតែបន្ថយៗអាហារអ៊ីចឹងរហូតដាច់ពោះស្លាប់នៅអូរក្រូច បាទ"[1066]។

៩៨៣. ដោយសារ រី ពៅ មិនបានផ្តល់សេចក្តីបញ្ជាក់នៅក្នុងសវនាការ និងមិនបានលើកឡើងអំពីការស្លាប់របស់យុវជនពីរនាក់នេះនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆ្នាំ ២០០៩ ក៏ដូចជា នៅចំពោះមុខអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនៅឆ្នាំ ២០១៣[1067] យើងមិនអាចកំណត់បានថា តើកន្លែងស្លាប់ "អូរក្រូច" នៅទីណា ក្នុងឃុំសំរោង នោះឡើយ។

៩៨៤. ជាក់ស្តែង នៅក្នុង Zylab (មូលដ្ឋានទិន្នន័យរបស់តុលាការ ដែលប្រមូលផ្តុំភស្តុតាងទាំងអស់ ដែលត្រូវបានដាក់បញ្ចូល ឬអត់ ក្នុងសំណុំរឿង "អូរក្រូច" មានតែនៅក្នុងឯកសារពីរផ្សេងទៀតប៉ុណ្ណោះ

---

[1063] រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/262.1** ទំព័រ ២៥ ប្រហែលម៉ោង [១០.៤៤.១៥]។

[1064] រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/262.1** ទំព័រ ៣៨ ប្រហែលម៉ោង [១១.២៣.០៦]។

[1065] កំណត់ហេតុស្តាប់ចម្លើយ រី ពៅ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣ **ឯកសារ E3/9604** ស/ឆ ២៤។

[1066] រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/262.1** ទំព័រ ៣៣ ម៉ោងប្រហែល [១១.០៨.០០]។

[1067] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៩ **ឯកសារ E3/5842**, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣ **ឯកសារ E3/9604**។

ក្រៅពីសក្ខីកម្មរបស់ រី ពៅ។ ឯកសារទាំងពីរពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លឹង ឡាំ ដែលនិយាយអំពី "ភូមិ" "អូរក្រូច" ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ[1068]។

៩៨៥. ចំណែកឯនៅក្នុងអ៊ីនធឺណិត យើងរកឃើញថា "អូរក្រូច" ស្ថិតនៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ[1069]។

៩៨៦. ប្រសិនបើទីតាំង ដែល រី ពៅ បានលើកឡើង ជាភូមិស្ថិតនៅស្រុកត្រាំកក់ ដែលមានឈ្មោះជាផ្លូវការ ត្រពាំងភ្លូ ប៉ុន្តែ សព្វថ្ងៃនេះ នៅតែត្រូវបានអ្នកភូមិហៅក្រៅផ្លូវការថា "អូរក្រូច" ភូមិនេះមិនស្ថិតនៅក្នុងឃុំសំរោងនោះទេ គឺស្ថិតនៅក្នុងឃុំអូរសារាយ[1070] ដែលមិនស្ថិតនៅក្នុងវិសាលភាពនៃបណ្តឹងទៅកាន់អង្គជំនុំជម្រះ។

៩៨៧. ជាការសន្និដ្ឋាន រឿងរ៉ាវរបស់ រី ពៅ ដែលនៅក្រៅវិសាលភាពរួចទៅហើយចំពោះផ្នែកពាក់ព័ន្ធនឹងការដោះដូរជនជាតិវៀតណាម និងខ្មែរកម្ពុជាក្រោម ក៏នៅក្រៅវិសាលភាពផងដែរចំពោះការស្លាប់ដោយអត់បាយ[1071]។

## 2. ភ្នៅ យ៉ាវ

៩៨៨. សាក្សី ភ្នៅ យ៉ាវ មិនដែលនិយាយអំពីមនុស្សស្លាប់ដោយសារខ្វះស្បៀងទាល់តែសោះ ទាំងនៅក្នុងចម្លើយឆ្លើយជូនអ្នកស៊ើបអង្កេត ទាំងនៅក្នុងសវនាការ[1072]។

---

[1068] ទម្រង់បែបបទព័ត៌មានជនរងគ្រោះ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ **ឯកសារ E3/6510**, ERN KH 00551020, *Report on Civil Party Application* ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០ **D22/2508/1**, ERN EN 00551008។

[1069] https://www.google.com.kh/search?q=ou+krouch&rlz=1C1GGRV_enKH754KH757&oq=ou+krouch&aqs=chrome..69i57.6991j0j8&sourceid=chrome&ie=UTF-8។

[1070] ខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា (ភាសាអង់គ្លេស និងភាសាខ្មែរ) ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ១១៣ (ភាសាអង់គ្លេស) និងទំព័រ ២១៧ (ភាសាខ្មែរ)៖ https://mekhea.files.wordpress.com/2010/07/cities-and-provinces-of-cambodia-15072008-v-2b.pdf, សូមមើលផងដែរ៖ ឯកសារ **D250/3/5.3**, ERN EN 00526996។

[1071] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៩៦៤-៩៦៧។

[1072] ភ្នៅ យ៉ាវ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ **ឯកសារ E3/5515**, ប្រតិចារឹក ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ

3. ផាន់ ឆេន

៩៨៩. សាក្សី ផាន់ ឆេន បាននិយាយនៅក្នុងសវនាការថា គាត់ធ្លាប់រស់នៅឃុំសំរោង[1073]។ តាមពិត ឃុំនេះឈ្មោះ "សំរោងយ៉ោង" ដូច ផាន់ ឆេន បានប្រាប់អ្នកស៊ើបអង្កេត ជាច្រើនដង។ គាត់ក៏បាននិយាយថា ឃុំនេះស្ថិតនៅក្នុងស្រុកទន្លេបាទី ខេត្តតាកែវ[1074]។

ខ. ឃុំតាភេម

៩៩០. គ្មានសាក្សីណាមួយ ដែលបានផ្តល់សក្ខីកម្មនៅក្នុងសវនាការ ធ្លាប់រស់នៅចំពោះឃុំតាភេមនោះទេ។ មានតែដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ដែលមកផ្តល់សក្ខីកម្មអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មប៉ុណ្ណោះ បានរស់នៅឃុំនេះ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[1075]។ សក្ខីកម្មរបស់គាត់មិនអាចយកធ្វើជាមូលដ្ឋាន សម្រាប់ការកំណត់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្មបានឡើយ។ ទោះជាយ៉ាងណាក៏ដោយ គាត់មិនធ្លាប់និយាយអំពីមនុស្សស្លាប់ដោយអត់អាហារទាល់តែសោះ។

៩៩១. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីក៏លើកឡើងផងដែរអំពីមនុស្សស្លាប់ខុសៗគ្នា នៅក្នុងឃុំតាភេម[1076]។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនបានស្នើសុំឱ្យកោះហៅបុគ្គលណាម្នាក់ ក្នុងចំណោមអ្នកទាំងបីនេះទេ។ ម្យ៉ាងវិញទៀត ឯកសារ

---

២០១៥ **ឯកសារ E1/263.1** ទំព័រ ៧៥-៧៧, ប្រតិចារឹក ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/264.1** ទំព័រ ៣-៦៤។

[1073] ប្រតិចារឹក ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/268.1** ទំព័រ ៥០ [១៤.០១.៥៦], ប្រតិចារឹក ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/269.1** ទំព័រ ៤-៥ ចន្លោះម៉ោង [០៩.១២.០៦] និង [០៩.១៦.២៩]។

[1074] ផាន់ ឆេន កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ **ឯកសារ E3/5524** ERN 00414448, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៤ **ឯកសារ E3/9465** ឆ៤។

[1075] ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ E1/288.1** ទំព័រ ២០-៤០។

[1076] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជុំ ញ៉ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៨ **ឯកសារ E3/7088a** ERN 00477414-21, ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុខ យុន ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ **ឯកសារ E3/7089a** ERN 00477424-31, ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មាស សុគន្ធ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ **ឯកសារ E3/6186** ERN 00521364-71។

ទាំងនេះមិនត្រូវបានធ្វើឡើងដោយស្ថាប័នតុលាការនោះទេ គឺព័ត៌មានត្រូវបានបំពេញ និងបញ្ជូនមក អ.វ.ត.ក ដោយអង្គការអាដហុក ចំពោះដើមបណ្តឹងរដ្ឋប្បវេណីមួយរូប និងមជ្ឈមណ្ឌលឯកសារកម្ពុជា ចំពោះដើមបណ្តឹងរដ្ឋប្បវេណីពីររូបទៀត[1077]។ អវត្តមាននៃការពិភាក្សាដេញដោលចំពោះមុខ ជុំវិញព័ត៌មានទាំងអស់នេះ និងបញ្ហានៃភាពមធ្យ័តរបស់អង្គការនានា ដែលបានប្រមូលពាក្យសុំនៅក្រៅតុលាការ ធ្វើឱ្យភ័ស្តុតាងទាំងនេះមានជឿទុកចិត្តបានតិចតួចបំផុត[1078]។ ឧក្រិដ្ឋកម្មមួយមិនអាចមានធាតុផ្សំគ្រប់គ្រាន់ ដោយផ្អែកតែទៅលើមូលដ្ឋាននេះទេ។

៩៩២. ម្យ៉ាងវិញទៀត សាក្សី សៅ វ៉ាន់ បានប្រាប់ដល់អង្គសវនាការថា គាត់ជាអ្នកទទួលបន្ទុក "ផ្គត់ផ្គង់ស្បៀងក្នុងឃុំបីនៃស្រុកត្រាំកក់ ក្នុងនោះមានឃុំតាភេមផងដែរ"[1079]។ ទោះបីជាលោក ខៀវ សំផន ត្រូវបានចោទប្រកាន់ពីការស្លាប់ដោយការអត់បាយនៅឃុំតាភេមក៏ដោយ ក៏សហព្រះរាជអាជ្ញាមិនយល់ថាមានប្រយោជន៍ក្នុងការសួរដេញដោលសាក្សីរូបនេះទៅលើចំណុចនេះឡើយ។ ផ្ទុយទៅវិញ សាក្សីរូបនេះដឹងច្បាស់អំពីបញ្ហាស្បៀងអាហារនៅក្នុងឃុំនេះ។ សហព្រះរាជអាជ្ញាបែរជាទៅចោទសួរអំពីការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទៅវិញ[1080] ដែលជាប្រធានបទនៅក្រៅវិសាលភាពនៃបណ្តឹងទៅកាន់សហចៅក្រមស៊ើបអង្កេត[1081]។

៩៩៣. ជាចុងក្រោយ គួរកត់សម្គាល់ថា សាក្សី កែវ ច័ន្ទតារា បានឆ្លើយថាគាត់ធ្លាប់ជាមេឃុំតាភេម ប៉ុន្តែក្រោយរបបកម្ពុជាប្រជាធិបតេយ្យ គឺពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨២[1082]។

## ផ្នែកទី ៥. ការកំណត់ប្រភេទបទល្មើស

[1077] មជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រមូលព័ត៌មានរបស់ ជុំ ញ៉ (**ឯកសារ E3/7088a**) និងសុខ យុន (**ឯកសារ E3/7089a**)។ អង្គការអាដហុក បានប្រមូលព័ត៌មានរបស់ មាស សុគន្ធ (**ឯកសារ E3/6186**)។

[1078] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៥៥៧-៥៦៣។

[1079] សៅ វ៉ន ប្រតិចារឹក ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/385.1** ទំព័រ ៦៣ ប្រហែលម៉ោង [១៥.៣០.៣៨]។

[1080] សៅ វ៉ន ប្រតិចារឹក ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/385.1** ទំព័រ ៧០-៧១ ចន្លោះម៉ោង [១៥.៥៥.០៨] និង [១៦.០០.១០]។

[1081] សូមមើល កថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា។

[1082] កែវ ច័ន្ទតារ៉ា ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/255.1** ទំព័រ ៣១ ប្រហែលម៉ោង [១១.១២.៤៥]។

៩៩៤. ចំពោះអង្គហេតុដែលកើតឡើងនៅសហករណ៍ត្រាំកក់ លោក ខៀវ សំផន ទទួលខុសត្រូវចំពោះតែការស្លាប់ដោយការស្រេកឃ្លានប៉ុណ្ណោះ ដែលត្រូវបានកំណត់ថាជាការសម្លាប់រង្គាល។

**១. និយមន័យនៃការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)**

៩៩៥. ធាតុផ្សំសត្យានុម័តិនៃការសម្លាប់រង្គាល ត្រូវបានកំណត់ដោយការសម្លាប់មនុស្សក្នុងចំនួនច្រើន[1083]។

៩៩៦. ចំពោះធាតុផ្សំអត្តនោម័តិ ចារីត្រូវមានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្សច្រើន ឬធ្វើឱ្យពួកគេរស់នៅក្នុងល័ក្ខខ័ណ្ឌជីវិតដ៏លំបាកលំបិនបណ្តាលឱ្យស្លាប់[1084]។

**២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ**

៩៩៧. ការពិនិត្យមើលអង្គហេតុបានបង្ហាញថា គ្មានការស្លាប់ដោយអត់បាយនោះទេ ក្នុងឃុំសំរោង និងឃុំតាភេម។ អង្គហេតុនេះជាអង្គហេតុតែមួយគត់ ដែលសហចៅក្រមស៊ើបអង្កេតបានបញ្ជូនទៅឱ្យអង្គជំនុំជម្រះពិចារណា។ អាស្រ័យហេតុនេះ ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលមិនមានធាតុផ្សំគ្រប់គ្រាន់នោះទេ។

**ជំពូកទី ២. ទំនប់ត្រពាំងថ្ម**

**ផ្នែកទី ១. ការចោទប្រកាន់**

៩៩៨. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់អំពីអង្គហេតុកើតឡើងនៅទំនប់ត្រពាំងថ្ម ដែលត្រូវបានកំណត់ក្នុងដីកាដំណោះស្រាយថាជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ

---

[1083] សាលដីកា ០០២/០១ កថាខណ្ឌ ៥១៧។

[1084] សាលដីកា ០០២/០១ កថាខណ្ឌ ៥១៧-៥២២។

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូជាមនុស្ស ការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1085]។

៩៩៩. អង្គហេតុ ដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅកថាខណ្ឌ ១៤៤២ នៃដីកាដំណោះស្រាយ ត្រូវបានវែកញែកលម្អិតខាងក្រោមក្នុងការសិក្សាជាពិសេសអំពីអង្គហេតុដែលកើតឡើងនៅទូទាំងប្រទេស ក្នុងក្របខ័ណ្ឌនៃគោលនយោបាយស្តីពីការដាក់បទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍[1086]។

១០០០. ការពិនិត្យលើបទចោទផ្សេងទៀតអាចឱ្យកំណត់អំពីវិសាលភាពនៃអង្គហេតុ ដែលដាក់ជូនអង្គជំនុំជម្រះពិចារណា។ ជួនកាល សហចៅក្រមស៊ើបអង្កេតធ្វើហួសវិសាលភាពនៃបណ្តឹង ពាក់ព័ន្ធនឹងអាណត្តិការងារ ដែលសហព្រះរាជអាជ្ញាបានប្រគល់ជូនពីដំបូង។

## ១. អំពើមនុស្សឃាត

១០០១. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៧៣ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាត នៅតាមទីតាំងឧក្រិដ្ឋកម្មជាច្រើន ឧទាហរណ៍ ទំនប់ត្រពាំងថ្ម។

១០០២. នៅកថាខណ្ឌ ១៣៧៧ សហចៅក្រមស៊ើបអង្កេតបានរៀបរាប់អំពីអង្គហេតុជាក់លាក់ ដែលត្រូវបានកំណត់ថាជាអំពើមនុស្សឃាត នៅតាមការដ្ឋានការងារ និងជាពិសេស នៅទំនប់ត្រពាំងថ្ម ដោយអះអាងថា "ជារឿយៗ ជនរងគ្រោះត្រូវបានសម្លាប់នៅនឹងកន្លែង"។ ដូច្នេះ មានតែការស្លាប់

[1085]ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៨១, ១៣៩១, ១៤១៦, ១៤៣៤, ១៤៤២, ១៤៧០, សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1** កថាខណ្ឌ ៣៤, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ២-៨។

[1086]សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ២៣១៩និងកថាខណ្ឌបន្តបន្ទាប់ទៀត។

ដោយការសម្លាប់ប៉ុណ្ណោះ ដែលត្រូវបានកំណត់ថាជាអំពើមនុស្សឃាត ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

១០០៣. ការសម្លាប់នេះត្រូវបានរៀបរាប់ពីកថាខណ្ឌ ៣៤៤ ដល់កថាខណ្ឌ ៣៤៩ នៃដីកាដំណោះស្រាយ។ លោក ខៀវ សំផន ត្រូវជំនុំជម្រះលើអង្គហេតុទាំងនេះ។

## ២. ការសម្លាប់រង្គាល

១០០៤. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៨១ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមរូបភាពជាការសម្លាប់រង្គាល ទៅលើ “ជនដែលត្រូវបានសម្លាប់ ឬជនដែលបានស្លាប់ក្នុងទ្រង់ទ្រាយធំ” នៅតាមទីកន្លែងសម្លាប់មនុស្សទាំងឡាយ រួមមាន ទំនប់ត្រពាំងថ្ម។ កថាខណ្ឌ ១៣៨២ និងកថាខណ្ឌ ១៣៨៣ ដែលត្រូវបានដកស្រង់ខាងលើ បានបញ្ជាក់អំពីធាតុផ្សំទូទៅដែលត្រូវពិចារណា សម្រាប់ទីតាំងទាំងអស់ដែលត្រូវបានចោទប្រកាន់ថាមានការសម្លាប់រង្គាល[1087]។ កថាខណ្ឌទាំងនេះក៏បានចង្អុលបង្ហាញផងដែរថា “ធាតុផ្សំពាក់ព័ន្ធផ្សេងទៀត” ត្រូវពិចារណា សម្រាប់ទីតាំងនីមួយៗដែលឧក្រិដ្ឋកម្មមានធាតុផ្សំគ្រប់គ្រាន់។

១០០៥. ធាតុផ្សំទាំងនេះត្រូវបានផ្តល់ជូននៅកថាខណ្ឌ ១៣៨៧ សម្រាប់គ្រប់ការដ្ឋានធ្វើការងារដោយបង្ខំទាំងអស់៖

> “ដោយឡែក [...] មានមនុស្សជាច្រើននាក់បានស្លាប់ដោយសារស្ថានភាពរស់នៅមានការលំបាកវេទនា [...]។ មនុស្សទាំងនោះទទួលបានរបបអាហារមិនគ្រប់គ្រាន់ គ្មានជម្រក គ្មានការថែទាំវេជ្ជសាស្ត្រ និងអនាម័យ។ ដូចគ្នានេះដែរ ចំពោះអ្នកដែលធ្វើការនៅការដ្ឋានធ្វើការងារដោយបង្ខំ ពួកគេស្ថិតនៅក្នុងស្ថានភាពរស់នៅដូចគ្នា មិនតែប៉ុណ្ណោះ ពួកគេត្រូវបានបង្ខំឱ្យធ្វើការជាទម្ងន់ថែមទៀតផង”។

១០០៦. មិនមានការនិយាយសំដៅដល់ការស្លាប់ដោយការសម្លាប់នោះទេ។ ជាក់ស្តែង មានតែការស្លាប់ដោយសារស្ថានភាពរស់នៅប៉ុណ្ណោះ ត្រូវបានសហចៅក្រមស៊ើបអង្កេតកំណត់ថាជាការសម្លាប់

[1087] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៥៤។

រង្គាល។ គួរកត់សម្គាល់ថា នៅពេលសហចៅក្រមស៊ើបអង្កេតចង់កំណត់អង្គហេតុនៃការសម្លាប់ថាជាអំពើមនុស្សឃាតផង និងការសម្លាប់រង្គាលផង ពួកគាត់និយាយច្បាស់ណាស់។ គឺជាករណីនៅកថាខណ្ឌ ១៣៨៥ នៃដីកាដំណោះស្រាយ ចំពោះអង្គហេតុដែលកើតឡើងនៅតាមមន្ទីរសន្តិសុខនានា និងនៅព្រៃស ឬនៅកថាខណ្ឌ ១៣៨៦ ពាក់ព័ន្ធនឹងការសម្លាប់ជនជាតិវៀតណាម និងចាម។

១០០៧. អង្គហេតុគាំទ្រដល់ការចោទប្រកាន់អំពីការសម្លាប់រង្គាល ត្រូវបានរៀបរាប់នៅកថាខណ្ឌ ៣៤១ និងកថាខណ្ឌ ៣៤២ នៃដីកាដំណោះស្រាយ។ លោក ខៀវ សំផន ត្រូវឆ្លើយតបចំពោះការចោទប្រកាន់នេះ។

## ៣. ការធ្វើឱ្យទៅជាទាសករ

១០០៨. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយ ថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ នៅទំនប់ត្រពាំងថ្ម។ ការចោទប្រកាន់នេះផ្អែកលើអង្គហេតុ ដូចបានរៀបរាប់ពីកថាខណ្ឌ ៣៣៤ ដល់កថាខណ្ឌ ៣៤៥ ក្រោមចំណងជើង "ល័ក្ខខ័ណ្ឌការងារ និងការរស់នៅ"។ លោក ខៀវ សំផន ត្រូវជំនុំជម្រះលើអង្គហេតុទាំងនេះ។

## ៤. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

១០០៩. នៅកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅទំនប់ត្រពាំងថ្ម។ យើងបានលើកឡើងពីខាងលើថា មានតែមនុស្សបីក្រុមប៉ុណ្ណោះដែលត្រូវបានកំណត់ នៅកថាខណ្ឌ ១៤១៧ ថាជាមុខសញ្ញានៃការធ្វើទុក្ខបុកម្នេញខាងនយោបាយ៖ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងខ្មែរមកពីបរទេស[1088]។

[1088] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៨៣-៨៨៥។

១០១០. នៅកថាខណ្ឌ ១៤១៨ ដែលត្រូវបានដកស្រង់ខាងលើ មានការចោទប្រកាន់ថា នៅតាមការដ្ឋានការងារ មនុស្សមកពីក្រុមទាំងនេះទទួលរងនូវស្ថានភាពរស់នៅដ៏លំបាកលំបិន និងត្រូវបានចាប់ខ្លួនក្នុងទ្រង់ទ្រាយធំ[1089]។

១០១១. ពីកថាខណ្ឌ ៣២៣ ដល់កថាខណ្ឌ ៣៤៩ នៃដីកាដំណោះស្រាយ ស្ដីពីទំនប់ត្រពាំងថ្ម សហចៅក្រមស៊ើបអង្កេតនិយាយតែអំពីប្រជាជនថ្មីប៉ុណ្ណោះ។ គួរកត់សម្គាល់ថា ទោះបីជាមានការចោទប្រកាន់ពីសំណាក់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ ៤៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពាក់ព័ន្ធនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតមិនបានសន្និដ្ឋានថាមានអង្គហេតុនៃការរើសអើងចំពោះអ្នកទាំងនេះដែរ។

១០១២. ជោគវាសនារបស់ប្រជាជនថ្មីនៅទំនប់ត្រពាំងថ្ម ត្រូវបានលើកឡើងនៅកថាខណ្ឌ ៣៣៥ កថាខណ្ឌ ៣៤៣ និងកថាខណ្ឌ ៣៤៦ នៃដីកាដំណោះស្រាយ។

១០១៣. កថាខណ្ឌ ៣៣៥ លើកឡើងពីវត្តមាននៃប្រជាជនថ្មីក្នុងចំណោមអ្នកធ្វើការ ដោយមិនមានបញ្ជាក់អំពីការរើសអើងណាមួយចំពោះអ្នកទាំងនេះឡើយ។

១០១៤. កថាខណ្ឌ ៣៤៣ បានបញ្ជាក់ថា "ប្រជាជនថ្មីបានទទួលរងនូវល័ក្ខខ័ណ្ឌការងារធ្ងន់ធ្ងរជាង ដូចជាម្នាក់ៗត្រូវធ្វើការច្រើនជាងអ្នកដទៃ ឬទទួលរងនូវការដាក់ទណ្ឌកម្មដោយមិនសមហេតុផល"។

១០១៥. នៅកថាខណ្ឌ ៣៤៦ ស្ដីពីការចាប់ខ្លួនអ្នកធ្វើការ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា "អ្នកលើកទំនប់មួយចំនួន ជាពិសេស ប្រជាជនថ្មី ត្រូវបានចាប់ខ្លួនដោយកម្មាភិបាលរបស់បក្ស"។ នៅក្នុងឃ្លានេះ ឬក្នុងឃ្លាបន្ទាប់ទៀតនៃកថាខណ្ឌ ៣៤៦ មិនមានការនិយាយសំដៅដល់ការរើសអើងចំពោះប្រជាជនថ្មីនោះទេ។ មានតែការរៀបរាប់អំពីការចាប់ខ្លួនប្រជាជនថ្មីខ្លះ ក្នុងចំណោមអ្នកផ្សេងទៀត។

[1089] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៩២។

១០១៦. ដូច្នេះ លោក ខៀវ សំផន ត្រូវជំនុំជម្រះតែលើអង្គហេតុ ដូចបានចោទប្រកាន់នៅកថាខណ្ឌ ៣៤៣ នៃដីកាដំណោះស្រាយប៉ុណ្ណោះ។

## ៥. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស)

១០១៧. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស) នៅទំនប់ត្រពាំងថ្ម។ ការចោទប្រកាន់នេះផ្អែកលើអង្គហេតុ ដូចបានរៀបរាប់ពីកថាខណ្ឌ ៣៣៤ ដល់កថាខណ្ឌ ៣៤៥ នៃដីកាដំណោះស្រាយ ដែលលោក ខៀវ សំផន ត្រូវទទួលខុសត្រូវ។

## ៦. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ)

១០១៨. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤៧០ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ) នៅទំនប់ត្រពាំងថ្ម។ ការចោទប្រកាន់នេះផ្អែកលើអង្គហេតុ ដូចបានរៀបរាប់នៅកថាខណ្ឌ ៣៣៦ កថាខណ្ឌ ៣៤៦ និងកថាខណ្ឌ ៣៤៨។

១០១៩. សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋានទាំងអស់នេះ ដោយរំលោភទៅលើវិសាលភាពនៃបណ្តឹងទៅកាន់ខ្លួន។ នៅកថាខណ្ឌ ៤៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលជាកថាខណ្ឌមួយគត់ពាក់ព័ន្ធនឹងអង្គហេតុកើតឡើងនៅទំនប់ត្រពាំងថ្ម មិនមានលើកឡើងអំពីការបាត់ខ្លួនរបស់អ្នកធ្វើការនោះទេ។

១០២០. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបង្ហាញនូវឧទាហរណ៍ ដែលសហព្រះរាជអាជ្ញាបានប្តឹងយ៉ាងច្បាស់ទៅសហចៅក្រមស៊ើបអង្កេតអំពីអង្គហេតុនៃការបាត់ខ្លួន។ ឧទាហរណ៍ កថាខណ្ឌ ៤៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានលើកឡើងពាក់ព័ន្ធនឹងព្រលានយន្តហោះកំពង់ឆ្នាំងថា

"ប្រជាជនដែលបាត់ខ្លួនត្រូវបានជំនួសជាប្រចាំដោយអ្នកជាប់ឃុំថ្មី"។ កថាខណ្ឌ ៦៧ បានបញ្ជាក់ថា នៅភ្នំក្រោល "ពួកអ្នកទោសដែលត្រូវបានដឹកចេញទៅទាំងនោះ គឺត្រូវគេសម្លាប់"។

១០២១. នេះមិនមែនជាករណីសម្រាប់អង្គហេតុនៅទំនប់ត្រពាំងថ្ម ដូចបានរៀបរាប់នៅកថាខណ្ឌ ៤៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នោះឡើយ។ ដូច្នេះ លោក ខៀវ សំផន មិនចាំបាច់ឆ្លើយតបទៅនឹងការចោទប្រកាន់ខុសច្បាប់ប្រឆាំងនឹងរូបគាត់នោះទេ។

## ផ្នែកទី ២. ភស្តុតាងគាំទ្រដល់សេចក្តីសន្និដ្ឋាននៃដីកាដំណោះស្រាយ

១០២២. ការពិនិត្យមើលភស្តុតាងគាំទ្រដល់ដីកាដំណោះស្រាយ បង្ហាញឱ្យឃើញអំពីភាពគ្រប់គ្រាន់ ឬភាពមិនគ្រប់គ្រាន់នៃបទចោទ ដែលជនចោទជាប់ត្រូវបានបញ្ជូនទៅជំនុំជម្រះ។

១០២៣. ដូច្នេះ ភស្តុតាង ដែលសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ ដើម្បីគាំទ្រដល់អង្គហេតុនៃការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនថ្មី ត្រូវបានវិភាគដូចខាងក្រោម។ វាបង្ហាញជាថ្មីម្តងទៀតនូវទម្លាប់អនុវត្តន៍របស់សហចៅក្រមស៊ើបអង្កេតក្នុងការបកស្រាយភស្តុតាងដាក់បន្ទុកនីមួយៗ ដោយបានអះអាងខុសពីភស្តុតាង ជារឿយៗ។

១០២៤. យើងបានឃើញពីខាងលើថា ឧក្រិដ្ឋកម្មក្រោមរូបភាពជាការធ្វើទុក្ខបុកម្នេញដែលបានចោទប្រកាន់ទៅលើ ខៀវ សំផន ផ្អែកលើសេចក្តីសន្និដ្ឋានតែមួយគត់នៃកថាខណ្ឌ ៣៤៣ នៃដីកាដំណោះស្រាយដែលអះអាងអំពីអត្ថិភាពនៃការប្រព្រឹត្តិធ្ងន់ធ្ងរទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[1090]។ សេចក្តីសន្និដ្ឋាននេះផ្អែកលើកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីបីរូប។

១០២៥. សាក្សីទីមួយ ឈ្មោះ ដាន់ ស បានឆ្លើយថា អ្នកដែលមិនសម្រេចបានតាមផែនការបង្កបង្កើនផលត្រូវបានកាត់បន្ថយរបបអាហារ។ គាត់បានបន្ថែមទៀតថា អ្នកទទួលរងទណ្ឌកម្មភាគច្រើនជា

[1090]សូមមើលផ្នែកខាងលើ កថាខណ្ឌ ១០០៩-១០១៦។

ប្រជាជនថ្មី។ ដូច្នេះ ពុំមានការនិយាយអំពីការប្រព្រឹត្តិជាក់លាក់ទៅលើប្រជាជនថ្មី ឬការដាក់ឱ្យរស់នៅក្នុងល័ក្ខខ័ណ្ឌលំបាកជាងគេ នោះដែរ[1091]។

១០២៦. សាក្សីទីពីរ ឈ្មោះ ដាន់ ថេវ បាននិយាយអំពី "ការវាយ" ជាទណ្ឌកម្មសម្រាប់ "អ្នកខ្ជិល"។ គាត់បានរៀបរាប់អំពីរឿងរបស់បុគ្គលម្នាក់ដែលត្រូវបានគេវាយ។ ជនរងគ្រោះនោះជាប្រជាជនថ្មី។ ដាន់ ថេវ មិនបានបញ្ជាក់ថា ជននោះបានទទួលរងនូវអំពើហិង្សា ដោយសារតែគាត់ជាប្រជាជនថ្មីនោះទេ[1092]។

១០២៧. សាក្សីទីបី ឈ្មោះ សោម ផាន់ បានរៀបរាប់ថាកងរបស់គាត់ភាគច្រើនជាប្រជាជនថ្មី រួចគាត់និយាយអំពីអំពើហិង្សាដែលទទួលរងដោយកម្មករ ដែលគេគិតថា "ឈឺពុត"។ ដូច្នេះ គាត់មិនបាននិយាយថា អ្នកដែលទទួលរងនូវអំពើហិង្សាជាប្រជាជនថ្មី ឬពួកគេបានទទួលរងនូវអំពើហិង្សាដោយសារតែជាប្រជាជនថ្មីនោះទេ[1093]។

១០២៨. ដូច្នេះ សេចក្តីសន្និដ្ឋាននៃកថាខណ្ឌ ៣៤៣ ស្តីពីអត្ថិភាពនៃការរើសអើងទៅលើប្រជាជនថ្មី ផ្អែកលើភ័ស្តុតាងដែលមិនអាចគាំទ្រដល់ការអះអាងបែបនេះបាន។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតគួរតែសម្រេចថាភ័ស្តុតាងដាក់បន្ទុកមិនគ្រប់គ្រាន់ និងគួរកុំបញ្ជូនលោក ខៀវ សំផន ទៅជំនុំជម្រះ ចំពោះអង្គហេតុនៃការធ្វើទុក្ខបុកម្នេញ។ ដូច្នេះ លោក ខៀវ សំផន មិនចាំបាច់ឆ្លើយតប នៅក្នុងសារណានេះនោះទេ។

## ផ្នែកទី ៣. ការបង្ហាញភ័ស្តុតាង

១០២៩. ក្នុងចំណោមភ័ស្តុតាង ដែលបានបង្ហាញជូនក្នុងពេលជំនុំជម្រះក្តី (១) ភ័ស្តុតាងជាច្រើនស្ថិតនៅក្រៅយុត្តាធិការរបស់អង្គជំនុំជម្រះ (២)។ ភ័ស្តុតាងខ្លះទៀតអាចឱ្យយើងគិតថា ឧក្រិដ្ឋកម្មមួយចំនួនអាចមានធាតុផ្សំគ្រប់គ្រាន់ (៣)។

---

[1091]កំណត់ហេតុស្តាប់ចម្លើយ ដាន់ ស ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩**ឯកសារ E3/9354** ERN 00279083។

[1092]កំណត់ហេតុស្តាប់ចម្លើយ ដាន់ ថេវ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨**ឯកសារ E3/7802** ERN 00267749។

[1093]កំណត់ហេតុស្តាប់ចម្លើយ សោម ផាន់ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩**ឯកសារ E3/510** ERN 00279104-05។

## ១. បញ្ជីភស្តុតាង

១០៣០. ពីថ្ងៃទី ២៧ ខែ កក្កដា ដល់ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ បុគ្គល ១៥ រូប (សាក្សី ១១ រូប ដើមបណ្តឹងរដ្ឋប្បវេណី ៤ រូប ក្នុងនោះ ២ រូប ផ្តល់សក្ខីកម្មអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម) ត្រូវបានអង្គជំនុំជម្រះស្តាប់ចម្លើយ ក្នុងវគ្គទំនប់ត្រពាំងថ្ម។ ក្នុងចំណោមសាក្សីទាំង ១១ រូប ដែលបានផ្តល់សក្ខីកម្ម សាក្សី ៥ រូប មិនត្រូវបានស្តាប់ចម្លើយ ក្នុងអំឡុងកិច្ចស៊ើបសួរលើសំណុំរឿង ០០២ នោះទេ (ស្មើនឹង ៤៥,៤៥%)[1094]។

១០៣១. កំណត់ហេតុស្តាប់ចម្លើយជាង ២០ មកពីសំណុំរឿង ០០២ និងយ៉ាងហោចណាស់ កំណត់ហេតុស្តាប់ចម្លើយជាង ៤០ មកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ពាក់ព័ន្ធនឹងទំនប់ត្រពាំងថ្ម ត្រូវបានទទួលយកជាភស្តុតាង។

## ២. ភស្តុតាងក្រៅវិសាលភាព

១០៣២. ភស្តុតាងជាច្រើនស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តី ដូចជា ភស្តុតាងគាំទ្រដល់អង្គហេតុដែលសហចៅក្រមស៊ើបអង្កេតបានស៊ើបសួរដោយគ្មានអាណត្តិ ឧទាហរណ៍ អង្គហេតុនៃការបាត់ខ្លួន[1095]។

១០៣៣. នេះជាករណីនៃភស្តុតាងដែលបានបង្ហាញជូននៅក្នុងសវនាការ ពាក់ព័ន្ធនឹងកន្លែងឃុំឃាំងមួយឈ្មោះ ភ្នំត្រយ៉ូង។ ទោះបីជាមានការចោទប្រកាន់ពីសហព្រះរាជអាជ្ញា នៅកថាខណ្ឌ ៤៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អំពីអត្ថិភាពនៃ "មន្ទីរសន្តិសុខក្បែរនោះ" សម្រាប់សម្លាប់មនុស្សក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតបានអះអាងនៅកថាខណ្ឌ ៣៤៨ នៃដីកាដំណោះស្រាយ ថា "មិនមានសាក្សីណាមួយនិយាយថា មានមន្ទីរសន្តិសុខស្ថិតនៅក្បែរការដ្ឋានទំនប់ត្រពាំងថ្មនោះទេ"

---

[1094] ឡុត សួយ, ឈិត យឿក, ឈុំ សេង (CHHUM Seng), តាក់ ប៊ុយ (TAK Buy) និង 2-TCW-918។

[1095] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១០១៨-១០២១។

។ ដូច្នេះ លោក ខៀវ សំផន មិនត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មនៅក្រៅទីតាំងទំនប់ត្រពាំងថ្មឡើយ។

១០៣៤. ប៉ុន្តែ ទោះបីជាសហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋានយ៉ាងច្បាស់បែបនេះក៏ដោយ ក៏ចៅក្រម Jean-Marc LAVERGNE បានសួរសំណួរទៅសាក្សី ឈិត យឿក អំពីមន្ទីរសន្តិសុខភ្នំត្រយូង[1096]។ ក្រោយពីអន្តរាគមន៍របស់ក្រុមមេធាវីការពារក្តីដែលបញ្ជាក់ថា អង្គហេតុកើតឡើងនៅកន្លែងនេះស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តី ចៅក្រម Jean-Marc LAVERGNE បានពន្យល់ថា សំណួរទាំងនេះមានភាពពាក់ព័ន្ធ ដើម្បីឱ្យយល់ថា "តើសាក្សីចាត់ចែងការងារយ៉ាងដូចម្តេច ពេលគាត់ទទួលបន្ទុកចែកអង្ករដល់កងចល័តទាំងអស់"[1097]។ អង្គជំនុំជម្រះតែងតែមានទម្លាប់ចាត់ទុកអង្គហេតុនៅក្រៅវិសាលភាពថាមានភាពពាក់ព័ន្ធ។ ប៉ុន្តែអង្គជំនុំជម្រះមិនផ្អែកលើមូលដ្ឋានគតិយុត្តអ្វីនោះទេ និងធ្វើឱ្យកិច្ចដំណើរការនីតិវិធីអូសបន្លាយពេលវេលាឥតប្រយោជន៍។

១០៣៥. ម្យ៉ាងវិញទៀត ចម្លើយទាំងអស់ នៅក្នុងសវនាការ ទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា អំពីទីតាំងមួយឈ្មោះ ចម្ការខ្នុរ ក៏ស្ថិតនៅក្រៅវិសាលភាពផងដែរ[1098]។ អង្គជំនុំជម្រះបានសម្រេច (គួរឱ្យភ្ញាក់ផ្អើល) ថាការជំទាស់របស់មេធាវីការពារទៅលើបញ្ហានេះមានមូលដ្ឋានត្រឹមត្រូវ[1099]។

## ៣. ភស្តុតាងអំពីឧក្រិដ្ឋកម្មមួយចំនួន

---

[1096]ឈិត យឿក ប្រតិចារឹក ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/330.1** ទំព័រ ៧៧-៧៨ ប្រហែលម៉ោង [១៦.០១.៥៦]។

[1097]ប្រតិចារឹក ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/330.1** ទំព័រ ៧៨ ប្រហែលម៉ោង [១៦.០១.៥៦]។

[1098]ឧទាហរណ៍ សូមមើល ឡុត សួយ ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/328.1** ទំព័រ ៤៥-៤៦ ចន្លោះម៉ោង [១៤.០២.២០] និង [១៤.០៨.២០], ប្រតិចារឹក ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/329.1** ទំព័រ ៤៥ ប្រហែលម៉ោង [១០.៤៦.៣៦] (ភាសាបារាំង)។

[1099]ស៊ុត សុផល ប្រតិចារឹក ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/352.1** ទំព័រ ១៦-១៨ ចន្លោះម៉ោង [០៩.៥៣.០០] និង [១០.០២.៤៦]។

១០៣៦. ភស្តុតាងមួយផ្នែកដែលបានបង្ហាញ អាចនាំឱ្យយើងគិតថា មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាអំពើមនុស្សឃាត និងការធ្វើឱ្យទៅជាទាសករ ដូចបានចោទប្រកាន់ នៅកថាខណ្ឌ ១៣៧៣ និងកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយ។

១០៣៧. ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតបានកំណត់ថាជាអំពើអមនុស្សធម៌ផ្សេងទៀត នូវអង្គហេតុនៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស (កថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយ)។ យោងតាមវិធីសាស្ត្រ "ទូទៅ" របស់អង្គជំនុំជម្រះតុលាការកំពូល នៅសម័យកាលកើតអង្គហេតុ ប្រភេទសំណល់នៃអំពើមនុស្សធម៌ផ្សេងទៀត ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមានបែងចែកជាអនុប្រភេទ ដូចបានគ្រោងឡើងក្នុងដីកាដំណោះស្រាយ និងសាលក្រមលើសំណុំរឿង ០០២/០១ នោះទេ[1100]។ ក្រុមមេធាវីការពារក្តីមិនជំទាស់នឹងការវិភាគនេះទេ ហើយក៏មិនជំទាស់ដែរថា អំពើដែលអាចកំណត់ជាទូទៅថាជាអំពើអមនុស្សធម៌ផ្សេងទៀត អាចកើតឡើងនៅទំនប់ត្រពាំងថ្ម។

## ផ្នែកទី ៤. ការពិនិត្យមើលភស្តុតាងពាក់ព័ន្ធ

១០៣៨. អង្គហេតុ ដែលលោក ខៀវ សំផន ត្រូវឆ្លើយតបនៅទីនេះ គឺការស្លាប់ដោយសារលក្ខខណ្ឌរស់នៅលំបាកលំបិន នៅការដ្ឋានទំនប់ត្រពាំងថ្ម ដែលត្រូវបានកំណត់ថាជាការសម្លាប់រង្គាលនៅក្នុងដីកាដំណោះស្រាយ។

១០៣៩. ចម្លើយខ្លះរបស់សាក្សី នៅក្នុងសវនាការ ឬនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ អាចឱ្យសន្និដ្ឋានថាមានការស្លាប់ដោយការស្រេកឃ្លាន ឬបាក់កម្លាំង។ ឧទាហរណ៍ ករណីនៃចម្លើយរបស់សាក្សី ស៊ុត សុផល នៅក្នុងសវនាការ[1101]។

---

[1100] សាលដីកា ០០២/០១ កថាខណ្ឌ ៥៧២-៥៩០។

[1101] ស៊ុត សុផល ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ** E1/351.1 ទំព័រ ៦៧ ប្រហែលម៉ោង [១៥.០៧.៣៦], ប្រតិចារឹក ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ** E1/352.1 ទំព័រ ៣៣ ប្រហែលម៉ោង [១១.០៥.៣៥]។

១០៤០. ទន្ទឹមនឹងនេះ សាក្សីមួយចំនួនបានគូសបញ្ជាក់នៅក្នុងសវនាការថា អ្នកឈឺទទួលបានការព្យាបាល។ ជាក់ស្តែង សាក្សី កាន ថុល បានថ្លែងថា អ្នកជំងឺដែលមិនធូរស្រាលក្នុងរយៈពេលប្រាំថ្ងៃ ត្រូវបញ្ជូនទៅមន្ទីរពេទ្យ[1102]។ សាក្សី ឈុំ សេង បានឆ្លើយថាពិតជាមានការបញ្ជូនទៅមន្ទីរពេទ្យមែន[1103]។ សាក្សី ឡូត ស្វយ និងដើមបណ្តឹងរដ្ឋប្បវេណី ញ៉ិប ហាល់ ក៏បានសង្កេតឃើញផងដែរថា អ្នកជំងឺខ្លះត្រូវបានព្យាបាលនៅនឹងកន្លែង[1104]។ កំណត់ហេតុស្តាប់ចម្លើយជាច្រើន លើកឡើងអំពីដំណើរការនៃមន្ទីរពេទ្យដែលត្រូវបានប្រើប្រាស់សម្រាប់ព្យាបាលអ្នកជំងឺ[1105]។

១០៤១. ម្យ៉ាងវិញទៀត សាក្សី ឡាត់ ស្វយ បានរៀបរាប់អំពីការផលិតថ្នាំបុរាណសម្រាប់អ្នកជំងឺ[1106]។ ថ្នាំបុរាណ ឬហៅតាមបែបចំអក "ថ្នាំអាចម៍ទន្សាយ" ត្រូវបាននិយាយបែបបន្ទាបបន្ថោកយ៉ាងច្រើននៅក្នុងការជំនុំជម្រះក្តីនេះ។ ប៉ុន្តែ យើងត្រូវគិតដល់សម្តីរបស់លោក Michael VICKERY ដែលបាននិយាយថា អ្នកស្រែចូលចិត្តថ្នាំប្រភេទនេះជាង។ លោកបានបញ្ជាក់ថា "ការអះអាងថាអ្នកភូមិចូលចិត្តថ្នាំបុរាណមិនមែនគ្រាន់តែជាការឃោសនា ដូចអ្នកអានខ្លះអាចគិតនោះទេ" និង "អ្នកភូមិដាច់ស្រយាលចូលចិត្តថ្នាំបុរាណ ហើយថ្នាំមានប្រយោជន៍ខ្លះអាចត្រូវបានផលិតនៅក្នុងមូលដ្ឋាន"។ ជាចុងក្រោយ គាត់បានកត់សម្គាល់ថា ថ្នាំបុរាណខ្លះ "មានប្រសិទ្ធភាពគួរឱ្យកត់សម្គាល់"[1107]។

១០៤២. គួរកត់សម្គាល់ថា សាក្សី 2-TCW-996 បាននិយាយនៅក្នុងសវនាការអំពីការចែកឱសថទំនើបដល់អ្នកជំងឺ[1108]។

---

[1102] កាន ថុន ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/328.1** ទំព័រ ៩ ប្រហែលម៉ោង [០៩.៣២.៥៨]។

[1103] ឈុំ សេង ប្រតិចារឹក ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/333.1** ទំព័រ ១៣ ប្រហែលម៉ោង [០៩.៣៩.២៤]។

[1104] ឡូត ស្វយ ប្រតិចារឹក ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/329.1** ទំព័រ ១០៥-១០៦ ប្រហែលម៉ោង [១៥.២៣.២៨] (ភាសាបារាំង), ញ៉ិប ហាល់ ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/336.1** ទំព័រ ១៤ ប្រហែលម៉ោង [១០.០២.៣៨]។

[1105] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ **ឯកសារ E3/9575** ស/ឆ ១១៣, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ **ឯកសារ E3/9549** ស/ឆ ៦៨, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៤ **ឯកសារ E3/9494** ស/ឆ ១៤ និង ២៧, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ **ឯកសារ E3/9535** ស/ឆ ២៧។

[1106] ប្រតិចារឹក ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/329.1** ទំព័រ ១០៥ ប្រហែលម៉ោង [១៥.២១.០៩] (ភាសាបារាំង)។

[1107] សៀវភៅនិពន្ធដោយ Michael VICKERY មានចំណងជើងថា "កម្ពុជា ១៩៧៥-១៩៨២" (ភាសាអង់គ្លេស) **ឯកសារ E3/1757** ទំព័រ ១៨១-១៨៣ ERN 00397096-98។

[1108] ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៥ **ឯកសារ E1/356.1** ទំព័រ ២៧ ប្រហែលម៉ោង [១៤.០៩.៥៥]។

១០៤៣. ដូច្នេះ ទោះបីជាម្នាក់ៗមានយោបល់ផ្សេងគ្នាអំពីគុណភាពវិធានការដែលបានចាត់ឡើងក៏ដោយ ក៏អត្ថិភាពនៃវិធានការទាំងនេះបង្ហាញថា បុគ្គលិកនៅទំនប់ត្រពាំងថ្មគ្មានចេតនាសម្លាប់អ្នកលើកទំនប់តាមរយៈការដាក់ឱ្យរស់នៅក្នុងល័ក្ខខ័ណ្ឌជីវិតដ៏លំបាកលំបិនបណ្ដាលឱ្យស្លាប់ នោះឡើយ។

**ផ្នែកទី ៥. ការកំណត់ប្រភេទបទល្មើស**

**១. និយមន័យនៃការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)**

១០៤៤. ធាតុផ្សំសត្យានុម័តិនៃការសម្លាប់រង្គាលត្រូវបានកំណត់ដោយការសម្លាប់មនុស្សក្នុងចំនួនច្រើន[1109]។ ចំពោះធាតុផ្សំអត្តនោម័តិ ចារីត្រូវមានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្សច្រើន ឬធ្វើឱ្យពួកគេរស់នៅក្នុងល័ក្ខខ័ណ្ឌជីវិតដ៏លំបាកលំបិនបណ្ដាលឱ្យស្លាប់[1110]។

**២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ**

១០៤៥. ការពិនិត្យមើលអង្គហេតុបានបង្ហាញថា ការស្លាប់នៅទំនប់ត្រពាំងថ្មមិនមែនជាលទ្ធផលនៃអំពើរបស់បុគ្គលិកការដ្ឋាន ក្នុងចេតនាសម្លាប់មនុស្សច្រើនឡើយ។ អាស្រ័យហេតុនេះ ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលមិនមានធាតុផ្សំគ្រប់គ្រាន់នោះទេ។

**ជំពូកទី ៣. ទំនប់ ១ មករា**

**ផ្នែកទី ១. បទចោទ**

១០៤៦. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់អំពីអង្គហេតុកើតឡើងនៅទំនប់ ១ មករា ដែលត្រូវបានកំណត់ដោយសហចៅក្រមស៊ើបអង្កេតថាជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជា

---

[1109] សាលដីកា ០០២/០១ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥១៧។

[1110] សាលដីកា ០០២/០១ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥១៧-៥២២។

ទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូជាមនុស្ស ការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1111]។

១០៤៧. ការចោទប្រកាន់អំពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ចំពោះអង្គហេតុដែលបានប្រព្រឹត្តទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានពិនិត្យខាងក្រោម ក្នុងជំពូកស្តីពីអង្គហេតុពាក់ព័ន្ធនឹងទីតាំងផ្សេងៗ[1112]។ ដូចគ្នាផងដែរ អង្គហេតុដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅកថាខណ្ឌ ១៤៤២ ត្រូវបានវែកញែកលម្អិតខាងក្រោម ក្នុងផ្នែកស្តីពីការចេញបទបញ្ជាពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍[1113]។

១០៤៨. ការពិនិត្យលើបទចោទផ្សេងទៀតអាចឱ្យកំណត់អំពីវិសាលភាពនៃអង្គហេតុ ដែលដាក់ជូនអង្គជំនុំជម្រះពិចារណា។ ជួនកាល សហចៅក្រមស៊ើបអង្កេតធ្វើហួសវិសាលភាពនៃបណ្តឹង ពាក់ព័ន្ធនឹងអាណត្តិការងារ ដែលសហព្រះរាជអាជ្ញាបានប្រគល់ជូនពីដំបូង។

## ១. អំពើមនុស្សឃាត

១០៤៩. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៧៣ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាត នៅតាមទីតាំងឧក្រិដ្ឋកម្មជាច្រើន ឧទាហរណ៍ ទំនប់ ១ មករា។ ដូចបានឃើញពីខាងលើ សម្រាប់ទំនប់ត្រពាំងថ្ម មានតែការស្លាប់របស់ជនដែលត្រូវគេសម្លាប់ប៉ុណ្ណោះ ត្រូវបានកំណត់ជាអំពើមនុស្សឃាត នៅទំនប់ ១ មករា[1114]។ ផ្ទុយទៅវិញ ខុសពីទំនប់ត្រពាំងថ្ម ដែលមនុស្សទំនងជាត្រូវបាន "សម្លាប់នៅនឹងកន្លែង" កថាខណ្ឌ

[1111] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៨១, ១៣៩១, ១៤១៦, ១៤២០, ១៤៣៤, ១៤៤២, ១៤៧០, សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1** កថាខណ្ឌ ៤៤, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ២-៨។

[1112] សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ២២៥៨ និងកថាខណ្ឌបន្តបន្ទាប់ទៀត។

[1113] សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ២៣១៩និងកថាខណ្ឌបន្តបន្ទាប់ទៀត។

[1114] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១០០១-១០០៣,ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៧។

១៣៧៧ លើកឡើងថា ចំពោះទំនប់ ១ មករា "ជនរងគ្រោះត្រូវបានចាប់ខ្លួន បន្ទាប់មក នាំយកទៅសម្លាប់នៅក្បែរៗនោះ"។

១០៥០. ការសម្លាប់នេះត្រូវបានរៀបរាប់នៅកថាខណ្ឌ ៣៦៦ និងកថាខណ្ឌ ៣៦៧ នៃដីកាដំណោះស្រាយ។ កថាខណ្ឌ ៣៦៦ បញ្ជាក់ថា មីក្រូត្រូវបានបើកសំឡេងឱ្យឮខ្លាំង នៅពេលគេកំពុងសម្លាប់មនុស្ស ដើម្បីកុំឱ្យឮសំឡេងស្រែក ឯកថាខណ្ឌ ៣៦៧ លើកឡើងថា៖

> "សាក្សីខ្លះឃើញការចាប់ខ្លួន ឯសាក្សីខ្លះទៀតបានឮថាមានការសម្លាប់មនុស្ស [...]។ សាក្សីមួយរូបបានឃើញគេសម្លាប់មនុស្សម្នាក់។ វត្តបារាយណ៍ជាន់ដែក ដែលនៅក្បែរការដ្ឋាននោះ ត្រូវបានដឹងថាជាកន្លែងដែលយកមនុស្សទៅសម្លាប់ ប៉ុន្តែ អ្នកខ្លះត្រូវបាននាំយកទៅសម្លាប់នៅកន្លែងដទៃទៀតផងដែរ"។

១០៥១. សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋានទាំងនេះ ក្រៅសមត្ថកិច្ចរបស់ខ្លួន។ ជាក់ស្តែង នៅកថាខណ្ឌ ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជាកថាខណ្ឌតែមួយគត់ដែលប៉ះពាល់អំពីទំនប់ ១ មករា មិនមានការនិយាយអំពីអត្ថិភាពនៃទីតាំងសម្លាប់មនុស្សនៅក្រៅបរិវេណការដ្ឋានឡើយ។ ផ្ទុយទៅវិញ កថាខណ្ឌបានលើកឡើងអំពីការស្លាប់ "នៅការដ្ឋាន" គឺមិននិយាយអំពី "មនុស្សដែលត្រូវបាននាំយកទៅសម្លាប់នៅក្បែរនោះ" ឡើយ។

១០៥២. ម្យ៉ាងវិញទៀត កថាខណ្ឌ ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បាននិយាយសំដៅដល់វត្តបារាយណ៍ជាន់ដែក គ្រាន់តែដើម្បីលើកឡើងអំពីវត្តមាននៃទីស្មសានដែលគេកប់សាកសពមនុស្សប៉ុណ្ណោះ។ កថាខណ្ឌនេះមិនបាននិយាយសំដៅកន្លែងមួយ "ដែលគេស្គាល់ថាជា" ទីតាំងសម្លាប់មនុស្ស ដូចការអះអាងខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេត នោះឡើយ។

១០៥៣. ការប្រៀបធៀបជាមួយអង្គហេតុ ដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពាក់ព័ន្ធនឹង ស-២១ បង្ហាញអំពីអវត្តមាននៃបណ្តឹងទៅកាន់សហចៅក្រមស៊ើបអង្កេតទៅលើទីតាំងនេះ។ កថាខណ្ឌ ៥៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បញ្ជាក់ជាពិសេសថា ជើងឯក ជាកន្លែងសម្លាប់អ្នកទោសនៅ ស-២១។ គឺមិនដូចករណីវត្តបារាយណ៍ជាន់ដែក ដែលមានតែវត្តមាននៃរណ្តៅសាកសពប៉ុណ្ណោះ ត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

១០៥៤. ពេលកត់សម្គាល់ឃើញមានទីតាំងសម្លាប់មនុស្សមួយ ឬច្រើន នៅជិតទំនប់ ១ មករា ដូចបាន បញ្ជាក់នៅក្នុងកថាខណ្ឌ ៣៦៧ និងកថាខណ្ឌ ១៣៧៧ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើប អង្កេតគួរតែជូនដំណឹងដល់សហព្រះរាជអាជ្ញា ឱ្យចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដើម្បីស៊ើបសួរលើអង្គហេតុថ្មីនេះ។ បើមិនគោរពវិធាននីតិវិធីដ៏សំខាន់ៗទាំងនេះ សហចៅក្រម ស៊ើបអង្កេតមិនអាចស៊ើបសួរលើអង្គហេតុដែលកើតឡើងនៅកន្លែងផ្សេងទៀត ក្រៅពីការដ្ឋានទំនប់ ១ មករា ឡើយ។

១០៥៥. អាស្រ័យហេតុនេះ លោក ខៀវ សំផន ត្រូវជំនុំជម្រះតែលើការស្លាប់នៅការដ្ឋានទំនប់ ១ មករា ប៉ុណ្ណោះ។

## ២. ការសម្លាប់រង្គាល

១០៥៦. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៨១ នៃដីកាដំណោះស្រាយ ថាមានធាតុ ផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមរូបភាពជាការសម្លាប់រង្គាល ទៅលើ "ជនដែលត្រូវបានសម្លាប់ ឬជនដែលបានស្លាប់ក្នុងទ្រង់ទ្រាយធំ" នៅតាមទីកន្លែងសម្លាប់មនុស្សទាំងឡាយ រួមមាន ទំនប់ ១ មករា។

១០៥៧. ទឡ្ហីករណ៍ទាំងអស់ ដូចបានរៀបរាប់ខាងលើ ពាក់ព័ន្ធនឹងទំនប់ត្រពាំងថ្ម ដែលថាមានតែការស្លាប់ ដោយសារល័ក្ខខ័ណ្ឌរស់នៅប៉ុណ្ណោះត្រូវបានកំណត់ថាជាការសម្លាប់រង្គាល ត្រូវយកមកអនុវត្តនៅ ទីនេះ[1115]។

១០៥៨. ការចោទប្រកាន់នេះផ្អែកលើការស្លាប់ ដូចបានបញ្ជាក់នៅកថាខណ្ឌ ៣៦៣ នៃដីកាដំណោះស្រាយ ដែលចង្អុលបង្ហាញថា ក្នុងចំណោមអ្នកលើកទំនប់ "អ្នកខ្លះស្លាប់ដោយសារជំងឺ អត់អាហារ និង/ឬ ធ្វើការហួសកម្លាំង"។

[1115] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១០០៤-១០០៧, ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១, ១៣៨២, ១៣៨៣ និង ១៣៨៧។

១០៥៩. កថាខណ្ឌ ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកឡើងតែអំពី "មនុស្ស ២០០០០ នាក់ស្លាប់ដោយការអត់ឃ្លាន ការធ្វើការហួសកម្លាំង ឬការសម្លាប់"។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតហាក់ដូចជាមិនត្រូវបានអនុញ្ញាតឱ្យស៊ើបសួរលើការស្លាប់បណ្តាលមកពីជំងឺឡើយ។

១០៦០. ប៉ុន្តែ ខុសពីសេចក្តីសន្និដ្ឋានអំពីសហករណ៍ត្រាំកក់ នៅពេលនេះ សហចៅក្រមស៊ើបអង្កេតបានបង្កើតទំនាក់ទំនងគ្រប់គ្រាន់ រវាងកង្វះស្បៀង និងការស្លាប់ដោយសារជំងឺ យ៉ាងហោចណាស់ចំពោះប្រជាជនថ្មី[1116]។ កថាខណ្ឌ ៣៦០ នៃដីកាដំណោះស្រាយ អះអាងថា របបអាហារតិចតួចដែលចែកឱ្យប្រជាជនថ្មី គឺជាមូលហេតុមួយ ក្នុងចំណោមមូលហេតុផ្សេងទៀត ដែលធ្វើឱ្យពួកគេធ្លាក់ខ្លួនឈឺ។

១០៦១. ដូច្នេះ សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអំពីការស្លាប់បណ្តាលមកពីបញ្ហាសុខភាពត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ លោក ខៀវ សំផន ត្រូវជំនុំជម្រះលើអង្គហេតុទាំងនេះ។

### ៣. ការធ្វើឱ្យទៅជាទាសករ

១០៦២. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយ ថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ នៅទំនប់ ១ មករា។ ការចោទប្រកាន់នេះផ្អែកលើអង្គហេតុ ដូចបានរៀបរាប់ពីកថាខណ្ឌ ៣៥៨ ដល់កថាខណ្ឌ ៣៦៣ ក្រោមចំណងជើង "ល័ក្ខខ័ណ្ឌការងារ និងការរស់នៅ"។ លោក ខៀវ សំផន ត្រូវជំនុំជម្រះលើអង្គហេតុនេះ។

### ៤. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

---

[1116] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៥៩-៨៦៣។

១០៦៣. នៅកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅទំនប់ ១ មករា។ យើងបានលើកឡើងពីខាងលើថា មានតែមនុស្សបីក្រុមប៉ុណ្ណោះដែលត្រូវបានកំណត់ នៅកថាខណ្ឌ ១៤១៧ ថាជាមុខសញ្ញានៃការធ្វើទុក្ខបុកម្នេញខាងនយោបាយ៖ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងខ្មែរមកពីបរទេស[1117]។

១០៦៤. នៅកថាខណ្ឌ ១៤១៨ ដែលត្រូវបានដកស្រង់ខាងលើ មានការចោទប្រកាន់ថា នៅតាមការដ្ឋានការងារ មនុស្សមកពីក្រុមទាំងនេះទទួលរងនូវស្ថានភាពរស់នៅដ៏លំបាកលំបិន និងត្រូវបានចាប់ខ្លួនក្នុងទ្រង់ទ្រាយធំ[1118]។

១០៦៥. ការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ផ្អែកលើកថាខណ្ឌ ៣៦០ នៃដីកាដំណោះស្រាយ ដែលបញ្ជាក់ជាអាទិ៍ថា "អ្នកលើកទំនប់ទទួលរងនូវការប្រព្រឹត្តិផ្សេងៗគ្នា អាស្រ័យលើក្រុមរបស់ពួកគេ និង/ឬអាស្រ័យថាតើពួកគេជាប្រជាជនថ្មី"។

១០៦៦. សេចក្តីសន្និដ្ឋានទាំងអស់របស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ទាំងស្រុង។ ជាក់ស្តែង កថាខណ្ឌ ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនបានលើកឡើងអំពីការរើសអើង និងការបែងចែកកម្មករជាក្រុមនោះទេ។ កថាខណ្ឌនេះគ្រាន់តែបញ្ជាក់ថា "កម្មកររាប់សិបពាន់នាក់ មកពីតំបន់ ៤១ ៤២ និង ៤៣ ត្រូវបានបង្ខំឱ្យមកធ្វើការនៅក្នុងផែនការកសាងទំនប់នេះ"។

១០៦៧. គួរកត់សម្គាល់ថា នៅពេលសហព្រះរាជអាជ្ញាចង់ប្តឹងសហចៅក្រមស៊ើបអង្កេតអំពីការរើសអើងដែលក្រុមណាមួយបានទទួលរង សហព្រះរាជអាជ្ញាបានធ្វើដោយនិយាយច្បាស់ណាស់។ ជាអាទិ៍ គឺដូចករណីដែលបានឃើញពីខាងលើ ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ ដែលអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវទទួលរងការរើសអើង បើតាមកថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[1119]។

---

[1117]សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៨៣-៨៨៥។

[1118]សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៩២។

[1119]សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៨៣-៩១០។

១០៦៨. ដូច្នេះ លោក ខៀវ សំផន មិនមានអ្វីត្រូវជំនុំជម្រះលើអង្គហេតុគាំទ្រដល់ការចោទប្រកាន់នេះឡើយ។

## ៥. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា

១០៦៩. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤២០ នៃដីកាដំណោះស្រាយ ថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាម នៅទំនប់ ១ មករា។ ដូចការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយខាងលើដែរ ការចោទប្រកាន់នេះផ្អែកលើអង្គហេតុ ដូចបានរៀបរាប់ នៅកថាខណ្ឌ ៣៦០ នៃដីកាដំណោះស្រាយ និងកថាខណ្ឌ ៣៦៦ ដែលចង្អុលបង្ហាញថា "មនុស្សភាគច្រើនដែលបាត់ខ្លួន គឺ [...] ចាម"។

១០៧០. ដោយសារមូលហេតុដូចបានរៀបរាប់លម្អិតខាងលើ ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្ដីសន្និដ្ឋាន ដោយរំលោភលើវិសាលភាពនៃបណ្ដឹងមកកាន់ខ្លួន។ ដូច្នេះ លោក ខៀវ សំផន មិនចាំបាច់ឆ្លើយតបនោះទេ។

## ៦. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស)

១០៧១. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស) នៅទំនប់ ១ មករា។ ការចោទប្រកាន់នេះផ្អែកលើអង្គហេតុ ដូចបានរៀបរាប់ពីកថាខណ្ឌ ៣៥៨ ដល់កថាខណ្ឌ ៣៦៣ នៃដីកាដំណោះស្រាយ ដែលលោក ខៀវ សំផន ត្រូវឆ្លើយតប។

## ៧. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ)

១០៧២. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤៧០ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ) នៅទំនប់ ១ មករា។ ការចោទប្រកាន់នេះផ្អែកលើអង្គហេតុនៃការបាត់ខ្លួន ដូចបានរៀបរាប់នៅកថាខណ្ឌ ៣៦៦ ដែលលើកឡើងជាអាទិ៍ថា មានមនុស្ស "បាត់ខ្លួនពីការដ្ឋានទំនប់ ១ មករា"។

១០៧៣. ជាថ្មីម្តងទៀត សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋាននេះ ដោយរំលោភលើវិសាលភាពនៃបណ្តឹងទៅកាន់ខ្លួន ដោយសារតែកថាខណ្ឌ ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនមានលើកឡើងអំពីអង្គហេតុនៃការបាត់ខ្លួននោះទេ។

១០៧៤. យើងបានលើកឡើងពីខាងលើថា នៅកន្លែងខ្លះនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហព្រះរាជអាជ្ញាបានប្តឹងយ៉ាងច្បាស់ទៅសហចៅក្រមស៊ើបអង្កេតអំពីអង្គហេតុនៃការបាត់ខ្លួន[1120]។ មិនមានជាប់ទាក់ទងជាមួយអង្គហេតុ ដូចបានរៀបរាប់នៅកថាខណ្ឌ ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពាក់ព័ន្ធនឹងទំនប់ ១ មករា ដែលនិយាយតែអំពីការសម្លាប់មនុស្ស ឬការស្លាប់ដោយសារស្ថានភាពរស់នៅ។

## ផ្នែកទី ២. **ការបង្ហាញភ័ស្តុតាង**

១០៧៥. ក្នុងចំណោមភ័ស្តុតាង ដែលបានបង្ហាញជូនក្នុងពេលជំនុំជម្រះក្តី (១) ភ័ស្តុតាងជាច្រើនស្ថិតនៅក្រៅយុត្តាធិការរបស់អង្គជំនុំជម្រះ (២)។ ភ័ស្តុតាងខ្លះទៀតអាចឱ្យយើងគិតថា ឧក្រិដ្ឋកម្មមួយចំនួនអាចមានធាតុផ្សំគ្រប់គ្រាន់ (៣)។

### ១. **បញ្ជីភ័ស្តុតាង**

[1120] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១០១៨-១០២១។

១០៧៦. ពីថ្ងៃទី ១៩ ខែ ឧសភា ដល់ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ បុគ្គល ១៣ រូប (សាក្សី ៨ រូប ដើមបណ្តឹងរដ្ឋប្បវេណី ៥ រូប ក្នុងនោះ ២ រូប ផ្តល់សក្ខីកម្មអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម) បានមកផ្តល់សក្ខីកម្ម ក្នុងវគ្គទំនប់ ១ មករា។

១០៧៧. ជាចុងក្រោយ ក្រៅពីកំណត់ហេតុស្តាប់ចម្លើយជាង ៣០ នៅក្នុងសំណុំរឿង ០០២ យ៉ាងហោចណាស់ កំណត់ហេតុស្តាប់ចម្លើយ ២ មកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ និយាយអំពីការដ្ឋានទំនប់ ១ មករា[1121]។

## ២. ភស្តុតាងក្រៅវិសាលភាព

១០៧៨. ភស្តុតាងជាច្រើនស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តី ដូចជា ភស្តុតាងគាំទ្រដល់អង្គហេតុដែលសហចៅក្រមស៊ើបអង្កេតបានស៊ើបសួរ ដោយគ្មានអាណត្តិ ឧទាហរណ៍ អង្គហេតុនៃការបាត់ខ្លួន នៅទំនប់ ១ មករា[1122]។

១០៧៩. នេះជាករណីនៃភស្តុតាងដែលបានស្តាប់ស្តីពីអង្គហេតុនៃការសម្លាប់នៅវត្តបារាយណ៍ជាន់ដែក ដែលសាក្សីជាច្រើនបានអះអាង នៅក្នុងវសវនាការ[1123]។ ពាក់ព័ន្ធហ៊ឹងអង្គហេតុនេះ អង្គជំនុំជម្រះ

[1121] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ** E3/9563, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ** E3/9755។

[1122] ឱ ហួ ប្រតិចារឹក ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ** E1/301.1 ទំព័រ ២២ ប្រហែលម៉ោង [១០.៤៥.១៦], មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ** E1/304.1 ទំព័រ ៦៧ ប្រហែលម៉ោង [១៥.០៨.១៥] ទំព័រ ៧៤ ប្រហែលម៉ោង [១៥.៣៤.៥៤], អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ** E1/307.1 ទំព័រ ២៨ ប្រហែលម៉ោង [១០.៥៨.១៥], សៀង សុវិដា ប្រតិចារឹក ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ** E1/308.1 ទំព័រ ៣៣ ប្រហែលម៉ោង [១១.០៥.០៨], អ៊ុត សេង ប្រតិចារឹក ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ** E1/308.1 ទំព័រ ៨១ ប្រហែលម៉ោង [១៥.៥០.០៩], ស៊ូ សឿន ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ** E1/310.1 ទំព័រ ២២ ប្រហែលម៉ោង [១០.៣៩.០៩], កង អ៊ុត ប្រតិចារឹក ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ** E1/322.1 ទំព័រ ២០ ប្រហែលម៉ោង [១០.៣៩.១៥]។

[1123] ឱ ហួ ប្រតិចារឹក ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ** E1/301.1 ទំព័រ ៥៨ ប្រហែលម៉ោង [១៤.៤៦.៥២], មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ** E1/304.1 ទំព័រ ៧១-៧២ ប្រហែលម៉ោង [១៥.២២.៥៤] ទំព័រ ៧៨

បានបដិសេធការជំទាស់របស់ក្រុមមេធាវីការពារក្ដីទៅលើអវត្តមាននៃបណ្ដឹង[1124]។ យើងបានឃើញខាងលើថា សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្ដីសន្និដ្ឋានត្រង់ចំណុចនេះ ដោយរំលោភលើវិសាលភាពនៃបណ្ដឹងមកកាន់ខ្លួន[1125]។ ដូច្នេះ ទោះបីជាអង្គជំនុំជម្រះគិតយ៉ាងម៉េចក៏ដោយ អង្គជំនុំជម្រះមិនអាចទទួលបណ្ដឹងនេះបានទេ។

## ៣. ភស្តុតាងអំពីឧក្រិដ្ឋកម្មមួយចំនួន

១០៨០. ភស្តុតាងមួយផ្នែកដែលបានបង្ហាញ អាចនាំឱ្យយើងគិតថា មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ ដូចបានចោទប្រកាន់នៅកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយ។

១០៨១. ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតបានកំណត់ថាជាអំពើអមនុស្សធម៌ផ្សេងទៀតនូវអង្គហេតុនៃការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស (កថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយ)។ យោងតាមវិធីសាស្ត្រ "ទូទៅ" របស់អង្គជំនុំជម្រះតុលាការកំពូល នៅសម័យកាលកើតអង្គហេតុ ប្រភេទនៃអំពើមនុស្សធម៌ផ្សេងទៀតដែលនៅសេសសល់ ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមានបែងចែកជាអនុប្រភេទ ដូចបានគ្រោងឡើងក្នុងដីកាដំណោះស្រាយ និងសាលក្រមលើសំណុំរឿង ០០២/០១ នោះទេ[1126]។ ក្រុមមេធាវីការពារក្ដីមិនជំទាស់នឹងការវិភាគនេះទេ ហើយក៏មិន

---

ប្រហែលម៉ោង [១៥.៤៨.៤៧], ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ៤៣-៤៤ ប្រហែលម៉ោង [១៣.៤៩.៣១], ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/306.1** ទំព័រ ១៣ ប្រហែលម៉ោង [០៩.៥០.១២], ហ៊ុន សុគ្គានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/306.1** ទំព័រ ២៤-២៥ ប្រហែលម៉ោង [១០.៥០.៥៧], សៀង សុវិដា ប្រតិចារឹក ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/308.1** ទំព័រ ៣០ ប្រហែលម៉ោង [១០.៥៧.២៣], អ៊ុត សេង ប្រតិចារឹក ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/309.1** ទំព័រ ១៣ ប្រហែលម៉ោង [០៩.៤៤.២២], កង អ៊ុត ប្រតិចារឹក ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/322.1** ទំព័រ ១៩ ប្រហែលម៉ោង [១០.៣៣.៣៣], អ៊ុំ ជី ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/326.1** ទំព័រ ៤៧ ប្រហែលម៉ោង [១៣.១៩.៥០]។

[1124] ប្រតិចារឹក ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/304.1** ទំព័រ ៧៣ ប្រហែលម៉ោង [១៥.៣០.០១] ទំព័រ ៧៥-៧៦ ប្រហែលម៉ោង [១៥.៣៧.១៩] ទំព័រ ៧៧-៧៨ ប្រហែលម៉ោង [១៥.១៧.១៧]។

[1125] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១០៤៩-១០៥៥។

[1126] សាលដីកា ០០២/០១ កថាខណ្ឌ ៥៧២-៥៩០។

ជំទាស់ដែរថា អំពើដែលអាចកំណត់ជាទូទៅថាជាអំពើអមនុស្សធម៌ផ្សេងទៀត អាចកើតឡើងនៅទំនប់ ១ មករា។

### ផ្នែកទី ៤. ការពិនិត្យមើលភ័ស្តុតាងពាក់ព័ន្ធ

១០៨២. អង្គហេតុ ដែលលោក ខៀវ សំផន ត្រូវជំនុំជម្រះនៅទីនេះ គឺការស្លាប់ដោយសារលក្ខខ័ណ្ឌរស់នៅលំបាកលំបិន នៅការដ្ឋានទំនប់ ១ មករា។

១០៨៣. ចម្លើយខ្លះរបស់សាក្សី នៅក្នុងសវនាការ ឬនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ អាចឱ្យសន្និដ្ឋានថាមានការស្លាប់ដោយអត់អាហារ ជំងឺ ឬបាក់កម្លាំង។

១០៨៤. ទោះជាយ៉ាងនេះក្តី សាក្សីបាននិយាយអំពីការបង្កើតមន្ទីរពេទ្យ និងអង្គភាពេទ្យ សម្រាប់ឱ្យកម្មករសម្រាក និងទទួលការព្យាបាល តាមបែបបូរាណ និងសម័យ[1127]។ ក្នុងន័យនេះ ក្រុមមេធាវីការពារក្តីសូមលើកឡើងដដែលនូវសេចក្តីសង្កេតរបស់ខ្លួនអំពីការអនុវត្តការព្យាបាលតាមបែបបុរាណ ក្នុង និងមុនសម័យកម្ពុជាប្រជាធិបតេយ្យ នៅជំពូកមុនស្តីពីទំនប់ត្រពាំងថ្ម[1128]។

[1127]ឌិ ហ្វូ ប្រតិចារឹក ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/302.1** ទំព័រ ៧-៩ ចន្លោះម៉ោង [០៩.២៣.៤៨] និង [០៩.៣១.២៣], ប៊ិច សុខា ប្រតិចារឹក ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/302.1** ទំព័រ ៧១ ប្រហែលម៉ោង [១៥.៥៩.៣៧], ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/303.1** ទំព័រ ២៦ ប្រហែលម៉ោង [១០.៤៨.២៨] ទំព័រ ៣៦ ប្រហែលម៉ោង [១១.២៣.១៩], មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/304.1** ទំព័រ ៥៦ ប្រហែលម៉ោង [១៤.០៨.៤៣], ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ១៨-១៩ ប្រហែលម៉ោង [១០.០២.៤៥], ហ៊ិន សុគ្គានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/306.1** ទំព័រ ៣៩ ប្រហែលម៉ោង [១៣.៥៣.៣៥], អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/307.1** ទំព័រ ៩ ប្រហែលម៉ោង [០៩.២៨.៣៦] ទំព័រ ១០ ប្រហែលម៉ោង [០៩.៣៣.១៧] ទំព័រ ២៤ ប្រហែលម៉ោង [១០.៤២.៣៣]។ សៀង សុវិដា ប្រតិចារឹក ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/308.1** ទំព័រ ១៩-២០ ប្រហែលម៉ោង [១០.០៣.៥៩], ស៊ូ សឿន ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/310.1** ទំព័រ ៥៦ ប្រហែលម៉ោង [១៤.៤០.០១], អ៊ុំ ជី ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/326.1** ទំព័រ ៦២ ប្រហែលម៉ោង [១៤.១០.០៥]។

[1128]សូមមើលផ្នែកខាងលើ កថាខណ្ឌ ១០៤១-១១៥៣។

១០៨៥. គួរកត់សម្គាល់ផងដែរថា សាក្សីជាច្រើនបាននិយាយអំពីការចាត់វិធានការ ដើម្បីកែលម្អលក្ខខណ្ឌអនាម័យឱ្យកាន់តែប្រសើរឡើង[1129]។

## ផ្នែកទី ៤. ការកំណត់ប្រភេទបទល្មើស

### ១. និយមន័យនៃការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)

១០៨៦. ធាតុផ្សំសត្យានុម័តិនៃការសម្លាប់រង្គាលត្រូវបានបំពេញដោយការសម្លាប់មនុស្សក្នុងចំនួនច្រើន[1130]។ ចំពោះធាតុផ្សំអត្តនោម័តិ ចារីត្រូវមានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្សច្រើន ឬធ្វើឱ្យពួកគេរស់នៅក្នុងលក្ខខណ្ឌជីវិតដ៏លំបាកលំបិនបណ្តាលឱ្យស្លាប់[1131]។

### ២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ

១០៨៧. ការពិនិត្យមើលអង្គហេតុបានបង្ហាញថា ការស្លាប់នៅទំនប់ ១ មករា មិនមែនជាលទ្ធផលនៃអំពើរបស់បុគ្គលិកការដ្ឋាន ក្នុងចេតនាសម្លាប់មនុស្សច្រើនឡើយ។ អាស្រ័យហេតុនេះ ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលមិនមានធាតុផ្សំគ្រប់គ្រាន់នោះទេ។

## ជំពូកទី ៤. ព្រលានយន្តហោះកំពង់ឆ្នាំង

## ផ្នែកទី ១. បទចោទ

---

[1129] ប៉ិច សុខា ប្រតិចារឹក ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ** E1/303.1 ទំព័រ ៣៩ ប្រហែលម៉ោង [១១.៣៣.២៤], សៀង សុវិដា ប្រតិចារឹក ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ** E1/308.1 ទំព័រ ៣១ ប្រហែលម៉ោង [១០.៥៩.៣៥] និង ស្វៃ សឿន ប្រតិចារឹក ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ** E1/311.1 ទំព័រ ៥៨ ប្រហែលម៉ោង [១៤.៣៤.០៤], អ៊ុត សេង ប្រតិចារឹក ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ** E1/309.1 ទំព័រ ២៥ ប្រហែលម៉ោង [១០.៥១.១០]។

[1130] សាលដីកា ០០២/០១ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥១៧។

[1131] សាលដីកា ០០២/០១ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥១៧-៥២២។

១០៨៨. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់អំពីអង្គហេតុកើតឡើងនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ដែលត្រូវបានកំណត់ដោយសហចៅក្រមស៊ើបអង្កេតថាជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូជាមនុស្ស ការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1132]។

១០៨៩. ការពិនិត្យលើបទចោទអាចឱ្យកំណត់អំពីវិសាលភាពនៃអង្គហេតុ ដែលដាក់ជូនអង្គជំនុំជម្រះពិចារណា។ ជួនកាល សហចៅក្រមស៊ើបអង្កេតធ្វើហួសវិសាលភាពនៃបណ្ដឹង ពាក់ព័ន្ធនឹងអាណត្តិការងារ ដែលសហព្រះរាជអាជ្ញាបានប្រគល់ជូនពីដំបូង។

## ១. អំពើមនុស្សឃាត

១០៩០. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៧៣ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាត ទៅលើ "ជនដែលត្រូវបានសម្លាប់នៅតាមមន្ទីរសន្តិសុខនានា" ឧទាហរណ៍ ព្រលានយន្តហោះកំពង់ឆ្នាំង។ សហចៅក្រមស៊ើបអង្កេតបានបន្ថែមនៅកថាខណ្ឌ ១៣៧៤ ថា "ការស្លាប់របស់ជនរងគ្រោះ គឺជាលទ្ធផលនៃអំពើសកម្ម ឬអកម្មនៃចារី ដែលជាមូលហេតុចម្បងនៃការស្លាប់របស់ជនរងគ្រោះ"។

១០៩១. នៅកថាខណ្ឌ ១៣៧៧ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ជាបឋមថា នៅតាមការដ្ឋានការងារ "មនុស្សត្រូវបានសម្លាប់"។ ច្បាស់ជាងនេះទៅទៀត ពាក់ព័ន្ធនឹងព្រលានយន្តហោះកំពង់ឆ្នាំង សហចៅក្រមស៊ើបអង្កេតបានអះអាងជាបន្តទៀតថា "ជនរងគ្រោះ [...] ត្រូវបានចាប់ខ្លួន បន្ទាប់មក នាំយកទៅសម្លាប់នៅក្បែរៗនោះ"។

[1132] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៨១, ១៣៩១, ១៤១៦, ១៤៣៤ និង ១៤៧០, សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1** កថាខណ្ឌ ៤៤, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ២-៦។

១០៩២. យោងតាមកថាខណ្ឌពាក់ព័ន្ធនៃការកំណត់ប្រភេទបទល្មើស សហចៅក្រមស៊ើបអង្កេតបានកំណត់ថាជាអំពើមនុស្សឃាត ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តែអង្គហេតុនៃការសម្លាប់នៅព្រលានយន្តហោះកំពង់ឆ្នាំងប៉ុណ្ណោះ។

១០៩៣. អង្គហេតុគាំទ្រដល់ការចោទប្រកាន់នេះត្រូវបានរៀបរាប់ពីកថាខណ្ឌ ៣៩៣ ដល់កថាខណ្ឌ ៣៩៨ នៃដីកាដំណោះស្រាយ ក្រោមចំណងជើង "សន្តិសុខ"។ អង្គហេតុនេះចែកចេញជាបីប្រភេទ ហើយសហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានអំពី៖

- អង្គហេតុនៃការសម្លាប់នៅការដ្ឋាន ឬនៅក្បែរៗនោះ ពីកថាខណ្ឌ ៣៩៣ ដល់កថាខណ្ឌ ៣៩៥
- ការបញ្ជូនកម្មករទៅ ស-២១ នៅកថាខណ្ឌ ៣៩៦
- ការសម្លាប់ទាហានភូមិភាគបូព៌ា នៅវត្តមង្គលខ័ណ្ឌ ទន្ទឹមគ្នានឹងការបំពាក់អាវុធដល់កម្មករជាច្រើន ដើម្បីប្រយុទ្ធជាមួយវៀតណាម នៅដើមឆ្នាំ ១៩៧៩ នៅកថាខណ្ឌ ៣៩៨។

១០៩៤. មានតែអង្គហេតុទីមួយប៉ុណ្ណោះដែលមានភាពគួរឱ្យចាប់អារម្មណ៍។ អង្គហេតុទីពីរពាក់ព័ន្ធនឹង ស-២១ ដែលការស្លាប់របស់មនុស្សដែលត្រូវបានបញ្ជូនទៅ មិនត្រូវបានចោទប្រកាន់នោះទេ។

១០៩៥. ចំពោះអង្គហេតុទីបី សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋាន ដោយរំលោភលើវិសាលភាពនៃបណ្តឹងទៅកាន់ខ្លួន។ នៅកថាខណ្ឌ ៤៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលជាកថាខណ្ឌតែមួយគត់ដែលប្តឹងទៅសហចៅក្រមស៊ើបអង្កេតអំពីអង្គហេតុ នៅព្រលានយន្តហោះកំពង់ឆ្នាំង មានការលើកឡើងពីការចាប់ខ្លួនមនុស្សដោយសារតែការប្រព្រឹត្តិកំហុស រួចនាំយកទៅសម្លាប់។ អង្គហេតុទាំងនេះមិនមានទំនាក់ទំនងអ្វីជាមួយហេតុការណ៍ ដែលអ្នកដែលត្រូវបានសម្លាប់ហាក់ដូចជាត្រូវបានបោកបញ្ឆោតដោយជនដែលមានសិទ្ធិអំណាចលើពួកគេ ក្នុងពេលមានជម្លោះជាមួយវៀតណាម និងការបំពាក់អាវុធដល់កម្មករ នោះទេ។ ក៏ពុំមានការបញ្ជាក់អំពីមូលហេតុនៃការសម្លាប់ផងដែរ។ ជាចុងក្រោយ ការស្លាប់បានកើតឡើង នៅវត្តមួយស្ថិតក្នុងស្រុកផ្សេង

(ទឹកផុស) ពីស្រុកនៃព្រលានយន្តហោះកំពង់ឆ្នាំង (រលាប្អៀរ)[1133]។ អង្គហេតុទាំងនេះមិនមាន ទំនាក់ទំនងអ្វីជាមួយដំណើរការការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងនោះទេ។ ដូច្នេះ លោក ខៀវ សំផន មិនមានអ្វីត្រូវជំនុំជម្រះលើអង្គហេតុទាំងនេះនោះទេ។

១០៩៦. ឥឡូវនេះ ពាក់ព័ន្ធនឹងប្រធានបទទីមួយ និងការសម្លាប់ ដែលបានចោទប្រកាន់ ពីកថាខណ្ឌ ៣៩៣ ដល់កថាខ័ណ្ឌ ៣៩៥ នៃដីកាដំណោះស្រាយ ការបញ្ជូនលោក ខៀវ សំផន ទៅជំនុំជម្រះ ចំពោះអង្គហេតុទាំងនេះ នាំឱ្យមានការរិះគន់យ៉ាងខ្លាំង។

១០៩៧. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ៣៩៣ នៃដីកាដំណោះស្រាយ បន្ទាប់ពីបាន សង្កេតឃើញថាមានមនុស្សត្រូវបានចាប់ខ្លួន៖

> "សាក្សីជាច្រើនបាននិយាយថា ពួកគេមិនដឹងច្បាស់អំពីជោគវាសនារបស់កម្មករដែលបាត់ខ្លួនឡើយ ដោយសារពួកគេមិនដែលឃើញមានការកាប់សម្លាប់នោះទេ"។

១០៩៨. នៅកថាខណ្ឌ ៣៩៥ ក្រោយពីលើកឡើងនូវចម្លើយរបស់សាក្សីមួយរូប ដែលនិយាយពីអត្ថិភាពនៃ "រណ្តៅសពរួមមួយដែលកប់សាកសពកម្មករដែលបានសម្លាប់ក្នុងឆ្នាំ ១៩៧៧" សហចៅក្រមស៊ើបអង្កេតបានអះអាងថា៖

> "ក៏ប៉ុន្តែ មិនមានសំណល់សាកសពមនុស្ស ដែលអាចមើលឃើញនៅទីនោះឡើយ នាពេលបច្ចុប្បន្ននេះ"។

១០៩៩. នៅកថាខណ្ឌ ៣៩៥ ដដែល សហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា៖

> "មិនមានសាក្សីណាដែលបានឃើញការសម្លាប់កម្មករ ដែលធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងនោះឡើយ ហើយក៏មិនមានភស្តុតាងបញ្ជាក់ថាមានការសម្លាប់កើតឡើងនៅក្នុងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងផងដែរ"។

---

[1133] ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨៣ និង ៣៨៤។

១១០០. ជាចុងក្រោយ នៅចុងកថាខណ្ឌ ៣៩៦ ស្តីពីការបញ្ជូនអ្នកទោសទៅ ស-២១ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា៖

> "សាក្សីខ្លះបានអះអាងថា តាមតែខ្លួនបានដឹង មិនមានការបាត់ខ្លួន ការចាប់ខ្លួន ឬការសម្លាប់កម្មករទេ"។

១១០១. ក្នុងស្មារតីរបស់ចៅក្រមអនាគតដែលស៊ើបសួរទាំងដោះបន្ទុក និងដាក់បន្ទុក ភ័ស្តុតាងទាំងនេះគួរតែនាំឱ្យប្រកាសលើកលែងការចោទប្រកាន់។

១១០២. ដើម្បីឈានទៅដល់ដំណោះស្រាយផ្ទុយពីនេះ សហចៅក្រមស៊ើបអង្កេតដែលខ្វល់តែពីរឿងតួនាទីរបស់ខ្លួនក្នុង "ប្រវត្តិសាស្ត្រ" ផ្អែកលើសេចក្តីសន្និដ្ឋានគ្មានមូលដ្ឋាន និងមិនច្បាស់លាស់ នៅដើមកថាខណ្ឌ ៣៩៥៖

> "សាក្សីជាច្រើនគិតថាអ្នកទោសដែលបានបាត់ខ្លួននោះត្រូវគេសម្លាប់ហើយ ដោយបញ្ជាក់ថាកម្មករភាគច្រើនមកពីភូមិភាគបូព៌ា ឬអ្នកដែលមានជាប់ពាក់ព័ន្ធជាមួយភូមិភាគបូព៌ា។ សាក្សីម្នាក់បានឮថា គេយកមនុស្សទៅសម្លាប់នៅខាងលិចព្រលានយន្តហោះ។ សាក្សីម្នាក់ទៀតបាននិយាយថា គាត់បានឃើញសាកសពមនុស្សក្នុងរណ្តៅនៅភ្នំពាមលោក ដែលមានចម្ងាយប្រមាណ ៥ គីឡូម៉ែត្រ ពីការដ្ឋានសាងសង់ព្រលានយន្តហោះ ហើយគាត់បានសន្មតថា សាកសពទាំងនេះជាសាកសពរបស់កម្មករខ្លះមកពីការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង តែគាត់មិនអាចបញ្ជាក់ឱ្យបានច្បាស់លាស់ឡើយ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

១១០៣. ដូច្នេះ នៅពេលបញ្ចប់កិច្ចស៊ើបសួរ ចៅក្រមបានសន្និដ្ឋានអំពីអវត្តមាននៃសាក្សីផ្ទាល់ភ្នែកនៃការសម្លាប់ ដែលបានចោទប្រកាន់នៅកថាខណ្ឌ ៥៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អវត្តមាននៃរណ្តៅសាកសព និង/ឬអដ្ឋិធាតុ និងភវនីយភាពខ្វះថា គ្មានអ្នកណាម្នាក់ត្រូវបានសម្លាប់នៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងឡើយ។

១១០៤. ទោះជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតបានបញ្ជូនលោក ខៀវ សំផន ទៅជំនុំជម្រះ ដោយផ្អែកលើការប៉ាន់ស្មានមិនសមហេតុផលរបស់សាក្សីដែល "គិតថា" "ឮថា" និងមិនអាច "បញ្ជាក់ឱ្យបានច្បាស់លាស់" ថា កម្មករនៅព្រលានយន្តហោះកំពង់ឆ្នាំងត្រូវបានសម្លាប់ ។

១១០៥. នីតិវិធីដឹកនាំដោយចៅក្រមមិនស័ក្តិសមនឹងគោលបំណងនៃភាពជាគំរូ ដែលការពារដោយតុលាការអន្តរជាតិនោះឡើយ។ នៅពេលបន្ទុកភ័ស្តុតាងមិនគ្រាន់គ្រាន់ ជនសង្ស័យមិនអាចត្រូវបានបញ្ជូនទៅជំនុំជម្រះឡើយ[1134]។ ដូច្នេះ លោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបនឹងសេចក្តីសន្និដ្ឋាន ដែលរំលោភលើសិទ្ធិដ៏ចាំបាច់បំផុតរបស់គាត់ នោះទេ។

## ២. ការសម្លាប់រង្គាល

១១០៦. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៨១ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមរូបភាពជាការសម្លាប់រង្គាល ទៅលើ "ជនដែលត្រូវបានសម្លាប់ ឬជនដែលបានស្លាប់ក្នុងទ្រង់ទ្រាយធំ នៅតាមទីកន្លែងសម្លាប់មនុស្ស និងការដ្ឋានការងារ" រួមមានព្រលានយន្តហោះកំពង់ឆ្នាំង។ កថាខណ្ឌ ១៣៨២ និងកថាខណ្ឌ ១៣៨៣ ដែលត្រូវបានដកស្រង់ខាងលើ បានបញ្ជាក់អំពីធាតុផ្សំទូទៅដែលត្រូវពិចារណាសម្រាប់ទីតាំងទាំងអស់ដែលត្រូវបានចោទប្រកាន់ថាមានការសម្លាប់រង្គាល[1135]។ កថាខណ្ឌទាំងនេះក៏បានចង្អុលបង្ហាញផងដែរថា "ធាតុផ្សំពាក់ព័ន្ធផ្សេងទៀត" ត្រូវពិចារណា សម្រាប់ទីតាំងនីមួយៗដែលឧក្រិដ្ឋកម្មមានធាតុផ្សំគ្រប់គ្រាន់។

១១០៧. ធាតុផ្សំទាំងនេះត្រូវបានផ្តល់ជូន នៅកថាខណ្ឌ ១៣៨៧ សម្រាប់ការដ្ឋានធ្វើការដោយបង្ខំទាំងអស់ជាទូទៅ៖

> "ដោយឡែក [...] មានមនុស្សជាច្រើននាក់បានស្លាប់ដោយសារស្ថានភាពរស់នៅមានការលំបាកវេទនា [...]។ មនុស្សទាំងនោះទទួលបានរបបអាហារមិនគ្រប់គ្រាន់ គ្មានជម្រក គ្មានការថែទាំវេជ្ជសាស្ត្រ និងអនាម័យ។ ដូចគ្នានេះដែរ ចំពោះអ្នកដែលធ្វើការនៅការដ្ឋានធ្វើការងារដោយបង្ខំ ពួកគេស្ថិតនៅក្នុងស្ថានភាពរស់នៅដូចគ្នា មិនតែប៉ុណ្ណោះ ពួកគេត្រូវបានបង្ខំឱ្យធ្វើការជាទម្ងន់ថែមទៀតផង"។

---

[1134] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៦៧។

[1135] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៥៤។

១១០៨. យោងតាមកថាខណ្ឌពាក់ព័ន្ធនៃការកំណត់ប្រភេទបទល្មើស សហចៅក្រមស៊ើបអង្កេតបានកំណត់ថាជាការសម្លាប់រង្គាល តែការសម្លាប់បណ្ដាលមកពីស្ថានភាពរស់នៅនៅព្រលានយន្តហោះកំពង់ឆ្នាំងប៉ុណ្ណោះ។

១១០៩. ដោយសារតែភាពទន់ខ្សោយនៃទឡ្ហីករណ៍របស់សហចៅក្រមស៊ើបអង្កេតអំពីការចោទប្រកាន់ពីការសម្លាប់មនុស្ស នៅព្រលានយន្តហោះកំពង់ឆ្នាំង មិនត្រូវបានកំណត់ថាជាអំពើមនុស្សឃាត សហចៅក្រមស៊ើបអង្កេតក៏មិនអាចកំណត់អង្គហេតុទាំងនេះថាជាការសម្លាប់រង្គាលបានដែរ[1136]។

១១១០. ការចោទប្រកាន់ពីការសម្លាប់រង្គាលបណ្ដាលមកពីតែការស្លាប់ដោយសារស្ថានភាពរស់នៅ ផ្អែកលើសេចក្ដីសន្និដ្ឋាននៃកថាខណ្ឌ ៣៩១ និងកថាខណ្ឌ ៣៩២ នៃដីកាដំណោះស្រាយ។

១១១១. កថាខណ្ឌ ៣៩១ លើកឡើងអំពីការស្លាប់ពាក់ព័ន្ធនឹង "គ្រោះថ្នាក់ការងារ"៖

> "សាក្សីជាច្រើនបានអះអាងថា ជាញឹកញាប់ កម្មករបានរងរបួស ឬស្លាប់ដោយសារតែថ្មខ្ទាតត្រូវ ឬធ្លាក់លើ។ សាក្សីម្នាក់បានឃើញកម្មករម្នាក់ស្លាប់ ដោយសារបំណែកថ្មដែលបំផ្ទុះធ្លាក់ត្រូវ"។

១១១២. កថាខណ្ឌ ៣៩២ លើកឡើងអំពីស្ថានភាពរស់នៅជាទូទៅ៖

> "សាក្សីជាច្រើនបានបញ្ជាក់ថា កម្មករមួយចំនួនបានស្លាប់ដោយសារស្រេកឃ្លាន ជំងឺ ធ្វើការហួសកម្លាំង និងបាក់កម្លាំង"។

១១១៣. ជាថ្មីម្ដងទៀត សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្ដីសន្និដ្ឋានជាច្រើន ដោយរំលោភលើវិសាលភាពនៃបណ្ដឹងមកកាន់ខ្លួន។ កថាខណ្ឌ ៤៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកឡើងអំពីការស្លាប់ពីរប្រភេទ។ ជាដំបូង មានការស្លាប់បណ្ដាលមកពីកង្វះស្បៀង ដោយ "កម្មករអត់បាយស្លាប់បន្តិចម្ដងៗ"។

---

[1136] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១០៩០-១១០៥។

១១១៤. បន្ទាប់មកទៀត មានការស្លាប់ដោយសារការសម្លាប់ ដែលសហចៅក្រមស៊ើបអង្កេតមិនបានកំណត់ថាជាការសម្លាប់រង្គាល។

១១១៥. ដូច្នេះ ពុំមានការលើកឡើងអំពីការស្លាប់ ដោយសារគ្រោះថ្នាក់នៅការដ្ឋាន ជំងឺ ឬការធ្វើការហួសកម្លាំងនោះទេ។ យើងអាចកត់សម្គាល់ឃើញថា ការបាក់កម្លាំង គឺបណ្ដាលមកពីការធ្វើការហត់ខ្លាំង និងការខ្វះអាហារ។ ផ្ទុយទៅវិញ ទំនាក់ទំនងរវាងកង្វះអាហារ និងការកើតជំងឺ មិនសូវជាមានលក្ខណៈស្វ័យប្រវត្តិនោះទេ។ យោងតាមសេចក្ដីសន្និដ្ឋាននៃកថាខណ្ឌ ៣៩២ នៃដីកាដំណោះស្រាយ ដែលនិយាយអំពីការអត់ឃ្លាន និងជំងឺ ទំនាក់ទំនងរវាងកត្ដាទាំងពីរនៃការស្លាប់មិនអាចសន្និតបានទេ។

១១១៦. អាស្រ័យហេតុនេះ លោក ខៀវ សំផន ត្រូវជំនុំជម្រះតែទៅលើការស្លាប់ ដោយសារកង្វះស្បៀង ឬការនឿយហត់បណ្ដាលមកការងារធ្ងន់ និងការបង្អត់អាហារ។

## ៣. ការធ្វើឱ្យទៅជាទាសករ

១១១៧. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយ ថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ នៅព្រលានយន្តហោះកំពង់ឆ្នាំង។ ដូចបានឃើញខាងលើ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៩២ និងកថាខណ្ឌ ១៣៩៤ ថា ឧក្រិដ្ឋកម្មបានសម្រេចឡើង ដោយការបំពេញធាតុផ្សំពីរ៖ ការអនុវត្តការត្រួតពិនិត្យជាប្រចាំលើអ្នកទោស និងការបង្ខំពួកគេឱ្យធ្វើការដោយគ្មានប្រាក់កម្រៃ[1137]។

១១១៨. ភាពច្បាស់លាស់នៃឧក្រិដ្ឋកម្មនេះ ផ្អែកលើសេចក្ដីសន្និដ្ឋានអំពីអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេត នៅកថាខណ្ឌ ៣៨៩ ដល់កថាខណ្ឌ ៣៩២ នៃដីកាដំណោះស្រាយ ក្រោមចំណងជើង "ស្ថានភាពរស់នៅ និងល័ក្ខខ័ណ្ឌការងារ"។

[1137] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៦៧-៨៦៩។

១១១៩. លោក ខៀវ សំផន ត្រូវជំនុំជម្រះលើអង្គហេតុគាំទ្រដល់ការចោទប្រកាន់នេះ។

## ៤. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

១១២០. នៅកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅព្រលានយន្តហោះកំពង់ឆ្នាំង។

១១២១. យើងបានឃើញនៅជំពូកស្តីពីសហករណ៍ត្រាំកក់ថា មនុស្សបីក្រុមប៉ុណ្ណោះដែលត្រូវបានសហចៅក្រមស៊ើបអង្កេតកំណត់យ៉ាងច្បាស់ នៅកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយ គឺជាជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញខាងនយោបាយ៖ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងខ្មែរមកពីបរទេស[1138]។

១១២២. ការកំណត់ប្រភេទបទល្មើសនេះមានភាពផ្ទុយគ្នាពីអង្គហេតុ ដូចបានរៀបរាប់ពីកថាខណ្ឌ ៣៨៣ ដល់កថាខណ្ឌ ៣៩៨ អំពីព្រលានយន្តហោះកំពង់ឆ្នាំង ដែលមិនបានលើកឡើងអំពីក្រុមមនុស្សណាមួយ ដែលបានកំណត់នៅកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយ នោះឡើយ។

១១២៣. ប្រសិនបើក្រុមមនុស្សណាមួយ ដូចបានកំណត់នៅកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយ មិនត្រូវបានកំណត់អត្តសញ្ញាណនោះទេ ការចោទប្រកាន់នៅកថាខណ្ឌ ១៤១៦ មិនមានមូលដ្ឋាន។ លោក ខៀវ សំផន មិនត្រូវជំនុំជម្រះលើអង្គហេតុទាំងនេះឡើយ។

## ៥. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស)

[1138] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៨៣-៨៨៥។

១១២៤. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស) នៅព្រលានយន្តហោះកំពង់ឆ្នាំង។

១១២៥. កថាខណ្ឌ ១៤៣៧ បានរៀបរាប់លម្អិតអំពីធាតុផ្សំ ដែលសហចៅក្រមស៊ើបអង្កេតបានគិតគូរដើម្បីពិចារណាលើឧក្រិដ្ឋកម្មដែលកើតមាន (ការផ្តល់អាហារមិនគ្រប់គ្រាន់ដល់អ្នកទោស ការសម្រាកនៅតាមជម្រកយ៉ាងតោកយ៉ាក កង្វះការថែទាំ)។ ធាតុផ្សំទាំងនេះត្រូវបានរៀបរាប់នៅកថាខណ្ឌ ៣៨៩ ដល់កថាខណ្ឌ ៣៩២ នៃដីកាដំណោះស្រាយ អំពីល័ក្ខខ័ណ្ឌនៃការឃុំឃាំង។

១១២៦. ជាថ្មីម្តងទៀត កថាខណ្ឌ ៤៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនបានលើកឡើងអំពីបញ្ហាសុខភាព នៅព្រលានយន្តហោះកំពង់ឆ្នាំង នោះទេ។ ដូច្នេះ លោក ខៀវ សំផន ត្រូវជំនុំជម្រះលើគ្រប់អង្គហេតុទាំងអស់ដែលនាំឱ្យមានការចោទប្រកាន់ លើកលែងតែអង្គហេតុចុងក្រោយនេះ។

## ៦. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ)

១១២៧. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤៧០ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ) នៅព្រលានយន្តហោះកំពង់ឆ្នាំង។ ធាតុផ្សំនៃឧក្រិដ្ឋកម្មត្រូវបានរៀបរាប់នៅកថាខណ្ឌ ១៤៧១ និងកថាខណ្ឌ ១៤៧២។ ធាតុផ្សំទាំងនេះត្រូវបានពន្យល់ខាងក្រោម[1139]។

១១២៨. ការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតផ្អែកលើសេចក្តីសន្និដ្ឋានមួយ ពីកថាខណ្ឌ ៣៩៣ ដល់កថាខណ្ឌ ៣៩៨ នៃដីកាដំណោះស្រាយ ក្រោមចំណងជើង “សន្តិសុខ” ដែលនិយាយសំដៅដល់ការបាត់ខ្លួនកម្មករ ជាច្រើនលើកច្រើនសា។

១១២៩. លោក ខៀវ សំផន ត្រូវជំនុំជម្រះលើអង្គហេតុទាំងនេះ។

[1139] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២៧៧-១២៧៩។

## ផ្នែកទី ២. ការបង្ហាញភស្តុតាង

១១៣០. ក្នុងចំណោមភស្តុតាង ដែលបានបង្ហាញជូនក្នុងពេលជំនុំជម្រះក្តី (១) ភស្តុតាងជាច្រើនស្ថិតនៅក្រៅយុត្តាធិការរបស់អង្គជំនុំជម្រះ (២)។ ភស្តុតាងខ្លះទៀតអាចឱ្យយើងគិតថា ឧក្រិដ្ឋកម្មមួយចំនួនអាចមានធាតុផ្សំគ្រប់គ្រាន់ (៣)។

### ១. បញ្ជីភស្តុតាង

១១៣១. ពីថ្ងៃទី ០៩ ខែ មិថុនា ដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ បុគ្គល ៨ រូប (សាក្សី ៦ រូប និងដើមបណ្តឹងរដ្ឋប្បវេណី ២ រូប) បានមកផ្តល់សក្ខីកម្មក្នុងសវនាការ វគ្គព្រលានយន្តហោះកំពង់ឆ្នាំង[1140]។

១១៣២. ក្នុងពេលសវនាការលើវគ្គផ្សេងទៀតនៃការជំនុំជម្រះក្តី សាក្សីក៏បានផ្តល់ព័ត៌មានអំពីព្រលានយន្តហោះកំពង់ឆ្នាំងផងដែរ ឧទាហរណ៍ សាក្សី 2-TCW-1005 សាក្សី សយ សៅ សាក្សី ជួន ធី សាក្សី អៀង ផាន និងសាក្សី 2-TCW-920។

១១៣៣. ម្យ៉ាងវិញទៀត ក្រៅពីកំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០២ កំណត់ហេតុមួយចំនួនមកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលត្រូវបានដាក់បញ្ចូលយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងសំណុំរឿង ០០២ និយាយអំពីព្រលានយន្តហោះកំពង់ឆ្នាំង។

### ២. ភស្តុតាងក្រៅវិសាលភាព

[1140]សាក្សី៖ ចាន់ ម៉ន, កែវ គីន, កែវ ញឿ, សែម ហឿន, ហ៊ីម ហាន (Him Han), ឃិន វ៉ាត, ដើមបណ្តឹងរដ្ឋប្បវេណី៖ គង់ សៀក (KONG Siek) ជុំ សាមឿ (CHUM Samoeur)។

១១៣៤. ជាថ្មីម្តងទៀត ភ័ស្តុតាងមួយចំនួនស្ថិតនៅក្រៅយុត្តាធិការរបស់អង្គជំនុំជម្រះ។ ដោយសារតែមិនអាចដកស្រង់បានទាំងអស់ យ៉ាងហោចណាស់ យើងសូមបង្ហាញភ័ស្តុតាងពាក់ព័ន្ធនឹងការងាររបស់សាក្សី នៅតាមការដ្ឋានក្រៅពីការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។

១១៣៥. ជាក់ស្តែង ឧទាហរណ៍ ចម្លើយរបស់សាក្សី កែវ គីន អំពីការងាររបស់គាត់នៅស្រែជុំវិញនោះ[1141] ត្រូវតែដកចេញពីការពិភាក្សាសម្រេចរបស់ចៅក្រម។ ដូចគ្នាផងដែរចំពោះចម្លើយរបស់សាក្សី ឃិន វ៉ាត ដែលលើកឡើងអំពីការចាត់តាំងគាត់ឱ្យទៅធ្វើការនៅកសិដ្ឋានមួយ ក្រៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង[1142]។

### ៣. ភ័ស្តុតាងអំពីឧក្រិដ្ឋកម្មមួយចំនួន

១១៣៦. ភ័ស្តុតាងមួយផ្នែកដែលបានបង្ហាញ អាចនាំឱ្យយើងគិតថា មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ ដូចបានចោទប្រកាន់នៅកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយ។

១១៣៧. ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតបានកំណត់ថាជាអំពើអមនុស្សធម៌ផ្សេងទៀតនូវអង្គហេតុនៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស (កថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយ)។

១១៣៨. យោងតាមវិធីសាស្រ្ត "ទូទៅ" របស់អង្គជំនុំជម្រះតុលាការកំពូល នៅសម័យកាលកើតអង្គហេតុ ប្រភេទនៃអំពើមនុស្សធម៌ផ្សេងទៀត ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលនៅសេសសល់ មិនមានបែងចែកជាអនុប្រភេទ ដូចបានគ្រោងឡើងក្នុងដីកាដំណោះស្រាយ និងសាលក្រមលើសំណុំរឿង ០០២/០១ នោះទេ[1143]។ ក្រុមមេធាវីការពារក្តីមិនជំទាស់នឹងការវិភាគនេះទេ ហើយ

[1141] កែវ គីន ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/314.1** ទំព័រ ១៩-២០ ក្រោយម៉ោង [០៩.៥៨.៤៣]។

[1142] ឃិន វ៉ាត ប្រតិចារឹក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/325.1** ទំព័រ ៤៤ ប្រហែលម៉ោង [១៣.៣៧.៥៣] ទំព័រ ៤៦ ប្រហែលម៉ោង [១៣.៤៦.៣៨] ទំព័រ ៥២ ប្រហែលម៉ោង [១៤.១៣.១៦]។

[1143] សាលដីកា ០០២/០១ កថាខណ្ឌ ៥៧២-៥៩០។

ក៏មិនជំទាស់ដែរថា អំពើដែលអាចកំណត់ជាទូទៅថាជាអំពើអមនុស្សធម៌ផ្សេងទៀត អាចកើតឡើងនៅព្រលានយន្តហោះកំពង់ឆ្នាំង។

**ផ្នែកទី ៣. ការពិនិត្យមើលភស្តុតាងពាក់ព័ន្ធ**

១១៣៩. អង្គហេតុ ដែលលោក ខៀវ សំផន ត្រូវជំនុំជម្រះនៅទីនេះ គឺការស្លាប់ដោយសារការហូបចុកមិនគ្រប់គ្រាន់ និងការបាក់កម្លាំងបណ្ដាលមកពីការធ្វើការលំបាកលំបិន ដែលត្រូវបានកំណត់ថាជាការសម្លាប់រង្គាល នៅក្នុងដីកាដំណោះស្រាយ។

១១៤០. ចម្លើយខ្លះរបស់សាក្សី នៅក្នុងសវនាការ ឬនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ អាចឱ្យសន្និដ្ឋានថាមានការស្លាប់ នៅព្រលានយន្តហោះកំពង់ឆ្នាំង ឧទាហរណ៍ ចម្លើយរបស់សាក្សី ចាន់ ម៉ន និង កែវ លឿ។ កំណត់ហេតុស្ដាប់ចម្លើយរបស់ពួកគាត់ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការចោទប្រកាន់នៃដីកាដំណោះស្រាយ[1144]។ សាក្សី សែម ហឿន ក៏បាននិយាយផងដែរអំពីការស្លាប់ដោយសារស្ថានភាពរស់នៅ[1145]។

១១៤១. សាក្សីក៏បានអះអាងផងដែរថា ជួនកាល របបអាហារគឺគ្រប់គ្រាន់ ហើយអ្នកឈឺដោយសារខ្វះអាហារូបត្ថម្ភ បានទទួលការព្យាបាល។ ទោះបីជាសាក្សីនីមួយៗគិតយ៉ាងម៉េចអំពីគុណភាពនៃការព្យាបាលក៏ដោយ នេះបង្ហាញថាការស្លាប់មិនត្រូវបានគ្រោងទុក ឬប្រាថ្នាចង់បាននោះទេ។

១១៤២. ជាក់ស្ដែង សាក្សី ចាន់ ម៉ន បានពន្យល់ថា ជួនកាល របបអាហារមានភាពសមរម្យ៖

"ស៖ ចុះគេមានចាត់វិធានការអីផ្សេងៗ ដើម្បីកុំមានហេតុការណ៍ហ្នឹងកើតឡើងតទៅទៀត ឧទាហរណ៍ដូច

---

[1144] ឧទាហរណ៍ សូមមើល ចាន់ ម៉ន កំណត់ហេតុស្ដាប់ចម្លើយ **ឯកសារ E3/5278** ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៩ ERN 00287527-29, កែវ លឿ កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៨ **ឯកសារ E3/467** ERN 00170620, ប្រតិចារឹក ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/315.1** ទំព័រ ១៣-១៤ ប្រហែលម៉ោង [១៤.១៤.៥៣] ទំព័រ ២១-២២ ក្រោយម៉ោង [១៥.១០.៤៥]។

[1145] សែម ហឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/319.1** ទំព័រ ៤៤ ក្រោយម៉ោង [១៣.៤៩.៣៩]។

ជាករណីអត់ម្ហូប ប្រជាជនដឹងថា ពួកគាត់ខ្វះការហូបចុកអ៊ីចឹង គេមានដោះស្រាយបញ្ហាការហូបចុកហ្នឹងជូនពួកគាត់ដែរឬទេ? ពីព្រោះការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងនេះ គឺជាកន្លែងសំខាន់មួយ ដែលខាងបក្សហ្នឹង គាត់គិតថាការសាងសង់ហ្នឹងជារឿងសំខាន់។ អ៊ីចឹងតើគេមានបានគិតគូរដោះស្រាយបញ្ហាម្ហូបអាហាររបស់ពួកគាត់ទេ នៅក្នុងករណីដែលមានការខ្វះខាតដូច្នេះ?

ឆ៖ ដូចវាមានដែរ វាមានតិចតួច ដូចថាបបរពីដើមទៅ វាជួនកាលទៅវាមានទៅ វាខាប់ទៅ ជួនកាល វារាវទៅ។ ហើយត្រីសាច់អី គេយកមកចែកតាមអង្គភាពហ្នឹង វាដឹកមកពីទន្លេហ្នឹងឯង។ គេមានអ្នកយកត្រីមកឱ្យ ម្ហូបហ្នឹង តែវាមិនបរិបូរ ដូចថា នៅសម័យហ្នឹងពិបាកប្រាប់ណាស់ ខ្ញុំនិយាយមិនរួចទេ”[1146]។

១១៤៣. សាក្សី កែវ លឿ បានលើកឡើងអំពីការព្យាបាលអ្នកជំងឺ៖

“ស៖ បើសិនជាកម្មករមិនស្រួលខ្លួន ឬក៏ធ្លាក់ខ្លួនឈឺ តើគេអាចទទួលការព្យាបាលបានដែរឬទេ? ហើយមានគេឱ្យថ្នាំសង្កូវអីដែរឬទេ?

ឆ៖ ចំពោះបងប្អូនពលករដូចគ្នាឈឺទាល់តែក្រោកលែងរួចបានគេហៅពេទ្យ ឱ្យយកទៅកន្លែងពេទ្យ”[1147]។

១១៤៤. ភស្តុតាងទាំងនេះបង្ហាញថា បុគ្គលិកព្រលានយន្តហោះកំពង់ឆ្នាំងមិនមានចេតនាសម្លាប់កម្មករនៅការដ្ឋាននោះទេ។

## ផ្នែកទី ៤. ការកំណត់ប្រភេទបទល្មើស

### ១. និយមន័យនៃការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)

១១៤៥. ធាតុផ្សំសត្យានុម័តិនៃការសម្លាប់រង្គាលត្រូវបានកំណត់ដោយការសម្លាប់មនុស្សក្នុងចំនួនច្រើន[1148]។ ចំពោះធាតុផ្សំអត្តនោម័តិ ចារីត្រូវមានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្សច្រើន ឬធ្វើឱ្យពួកគេរស់នៅក្នុងលក្ខខ័ណ្ឌជីវិតដ៏លំបាកលំបិនបណ្តាលឱ្យស្លាប់[1149]។

---

[1146]ចាន់ ម៉ន ប្រតិចារឹក ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/312.1** ទំព័រ ៥៥ មុនម៉ោង [១៤.២៦.៣៥]។

[1147]កែវ លឿ ប្រតិចារឹក ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/315.1** ទំព័រ ២២ ក្រោយម៉ោង [១៥.១៤.០៥]។

[1148]សាលដីកា ០០២/០១ កថាខណ្ឌ ៥១៧។

[1149]សាលដីកា ០០២/០១ កថាខណ្ឌ ៥១៧-៥២២។

## ២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ

១១៤៦. ការពិនិត្យមើលអង្គហេតុបានបង្ហាញថា ការស្លាប់នៅព្រលានយន្តហោះកំពង់ឆ្នាំង មិនមែនជាលទ្ធផលនៃអំពើរបស់បុគ្គលិកការដ្ឋាន ក្នុងចេតនាសម្លាប់មនុស្សច្រើនឡើយ។ អាស្រ័យហេតុនេះ ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលមិនមានធាតុផ្សំគ្រប់គ្រាន់នោះទេ។

## ជំពូកទី ៤. គោលនយោបាយស្តីពីសហករណ៍ និងការដ្ឋានការងារ

១១៤៧. ការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ មានគោលដៅពិនិត្យមើលអង្គហេតុ ដែលកើតឡើងនៅតាមសហករណ៍ និងការដ្ឋានការងារ។ ប្រធានបទទាំងពីរនេះមានទំនាក់ទំនងដោយផ្ទាល់ជាមួយសភាពការណ៍ទូទៅនៃប្រទេសកម្ពុជា និងរបៀបដែលបក្សកុម្មុយនីស្តកម្ពុជាចង់ស្តារសេដ្ឋកិច្ចជាតិឡើងវិញ។

១១៤៨. នៅកថាខណ្ឌ ១៥៦ និងកថាខណ្ឌ ១៥៧ សហចៅក្រមស៊ើបអង្កេតបានកំណត់ផែនការរួមរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា តាមរយៈនិយមន័យ និងការអនុវត្តគោលនយោបាយទាំងប្រាំ ដែលក្នុងនោះ មានគោលនយោបាយមួយស្តីពី "ការបង្កើត និងការទាញយកផលប្រយោជន៍ពីសហករណ៍ និងការដ្ឋាន"។

១១៤៩. នៅកថាខណ្ឌ ១៦៩ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានរៀបរាប់អំពីគោលដៅរបស់សហករណ៍ និងការងារ៖ "ចំណុចនេះពាក់ព័ន្ធជាពិសេសនឹងការបង្កើនផលិតផលស្រូវយ៉ាងយ៉ាងឆាប់រហ័សឱ្យបាន ៣ តោនក្នុងមួយហិចតា ការស្ថាបនាប្រព័ន្ធស្រោចស្រពទឹកបញ្ចូលស្រែទូទាំងផ្ទៃប្រទេស ការបង្កើននូវផលិតផលកសិកម្មផ្សេងទៀត ដូចជា ដំណាំកៅស៊ូ និងអំបិល ការកសាងហេដ្ឋរចនាសម្ព័ន្ធដូចជា ព្រលានយន្តហោះ ឬទំនប់ទឹក"។ សហចៅក្រមស៊ើបអង្កេតបានបន្តទៀតថា៖ "លទ្ធផលទាំងអស់នេះត្រូវតែធ្វើឱ្យបានសម្រេច ទោះបីជាមានផលប៉ះពាល់ដែលកើតមានឡើងចំពោះប្រជាជនយ៉ាងណាក៏ដោយ"។ ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតបន្ថែមថា៖ "គោលនយោបាយនេះគឺដើម្បីស្រាវជ្រាវរកខ្មាំង ការពារទប់ទល់នឹងខ្មាំង អប់រំខ្មាំង និងកម្ទេចខ្មាំង"។

១១៥០. ទោះបីជាលោក ខៀវ សំផន មិនបានជំទាស់នឹងគោលដៅ "ផលិតស្បៀងអាហារសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង និងសម្រាប់ការនាំចេញ" ក៏ដោយ ក៏គាត់ជំទាស់យ៉ាងខ្លាំងនឹងគោលដៅសន្តិសុខ។ ម្យ៉ាងវិញទៀត ការវិភាគរបស់សហចៅក្រមស៊ើបអង្កេតបំភ្លេចចោលទាំងស្រុងនូវទិដ្ឋភាពសំខាន់នៃសភាពការណ៍ គឺផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធទៅលើស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស។ ក៏ប៉ុន្តែ គេមិនអាចវិភាគគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា សេចក្តីសម្រេចនៅថ្នាក់ជាតិ និងនៅមូលដ្ឋាន ដោយមិនគិតអំពីស្ថានភាពសង្គ្រាម ដែលបានបង្កើតឱ្យមានវិបត្តិនោះទេ។

១១៥១. ស្ថានភាពនេះបានរារាំងដល់ការប្រព្រឹត្តិទៅ "ជាធម្មតា" នៃកម្ពុជាប្រជាធិបតេយ្យ ដែលរស់នៅក្រោមសេដ្ឋកិច្ចសង្គ្រាម (ផ្នែកទី ១)។ ប៉ុន្តែ គោលបំណងមិនមែនឈានទៅដល់ការអនុវត្តប្រាសចាកគោលការណ៍នោះទេ ដូចឯកសារផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាបានបញ្ជាក់ (ផ្នែកទី ២)។

## ផ្នែកទី ១. <u>សេដ្ឋកិច្ចសង្គ្រាម</u>

១១៥២. ស្ថានភាពមហន្តរាយរបស់កម្ពុជា នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ គឺជាបញ្ហាប្រឈមមិនអាចដោះស្រាយបាន សម្រាប់របបថ្មី។ អ្វីៗត្រូវស្តារឡើងវិញទាំងអស់។ គ្មានឧស្សាហកម្ម គ្មានប្រាក់កសិកម្មខ្ទេចខ្ទី។ គួរឱ្យភ្ញាក់ផ្អើលណាស់ដែរ សវនការមួយភាគធំផ្តោតលើសភាពការណ៍ប្រទេសកង្វះស្បៀងអាហារ កង្វះមន្ទីរពេទ្យ និងកង្វះហេដ្ឋារចនាសម្ព័ន្ធ ដោយមិនរវីរវល់នឹងសភាពការណ៍ពីមុន។

### ១. <u>ទំនើបកម្មជាចាំបាច់នូវប្រព័ន្ធចាស់ និងហួសសម័យ</u>

១១៥៣. ការងាររបស់លោក Michael VICKERY បានបង្ហាញឱ្យឃើញច្បាស់ថា មានអ្នកស្រាវជ្រាវ និងអ្នកវិភាគអំពីរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងចំនួនតិចតួចស្តួចស្តើង បានចាប់អារម្មណ៍លើជីវិតនៅតាមស្រុកស្រែ មុនពេលខ្មែរក្រហមចូលមកដល់[1150]។ គាត់បានរកឃើញឫសគល់នៃ "អារម្មណ៍

[1150]សៀវភៅនិពន្ធដោយ Michael VICKERY មានចំណងជើងថា "កម្ពុជា៖ ១៩៧៥-១៩៨២" (ភាសាបារាំង) បោះពុម្ពឆ្នាំ ១៩៨៤ **ឯកសារ E3/1757** ERN 01237539-40។

ចង់សងសឹក" ដែលអាចកើតមាន នៅតាមជនបទដែលត្រូវបានទីក្រុងបំភ្លេចចោល។ អ្នកស្រុកស្រែ រស់នៅ "តាមសមាជីវោ ខ្លួនទីពឹងខ្លួន" និងទម្លាប់រស់នៅក្នុងសភាពលំបាកលំបិន[1151]។ លោក Michael VICKERY បានរំឭកផងដែរអំពីតួនាទីនៃវេជ្ជសាស្ត្របុរាណ នៅតាមស្រុកស្រែ ដោយពន្យល់ថា វេជ្ជសាស្ត្របុរាណនៅតែបន្តអនុវត្ត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[1152]។ ជាចុងក្រោយ គាត់បានរៀបរាប់អំពីប្រព័ន្ធកសិកម្មហួសសម័យ ដែលនាំឱ្យកសិករជំពាក់បំណុល[1153]។

១១៥៤. ក៏ប៉ុន្តែ ទំនើបកម្មវិស័យកសិកម្មអន់ថយ ដែលជាមូលហេតុនៃភាពក្រីក្ររបស់អ្នកជនបទ គឺជាច្រកចេញតែមួយគត់ ក្នុងសម័យកាលពិសេសនៃការរឹតត្បិត ប្រឈមមុខនឹងសេដ្ឋកិច្ចជិតដាច់ខ្យល់នៅក្រោយសង្គ្រាម។ មានពាក្យស្លោកមួយថា "មានស្រូវ មានអ្វីៗគ្រប់យ៉ាង"[1154]។ "ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ"៖ សុភាសិតបុរាណខ្មែរ ដែលដកស្រង់ដោយលោក François PONCHAUD ពន្យល់ថា ហេតុអ្វីបានជាក្នុងវាក្យស័ព្ទរបស់ខ្មែរក្រហម ការដ្ឋានសាងសង់ទំនប់អាចត្រូវបានគេហៅថាសមរភូមិ។ តាមន័យត្រង់ គឺជាការធ្វើសង្គ្រាម ដើម្បីបានប្រព័ន្ធស្រោចស្រពយូរអង្វែង។

១១៥៥. ទំនាក់ទំនងជាមួយចិន ដែលជាសម្ព័ន្ធមិត្តដ៏សំខាន់ ក្នុងក្របខណ្ឌនៃជម្លោះប្រដាប់អាវុធ និងកិច្ចសហប្រតិបត្តិការបច្ចេកទេស ក៏ផ្តោតលើការកសាងហេដ្ឋារចនាសម្ព័ន្ធថ្មីៗ រួមបញ្ចូលទាំងព្រលានយន្តហោះកំពង់ឆ្នាំង ក្រោមការគ្រប់គ្រងរបស់ សុន សេន[1155]។

---

[1151]សៀវភៅនិពន្ធដោយ Michael VICKERY មានចំណងជើងថា "កម្ពុជា៖ ១៩៧៥-១៩៨២" (ភាសាបារាំង) បោះពុម្ពឆ្នាំ ១៩៨៤ **ឯកសារ E3/1757** ERN 01237540-41។

[1152]សៀវភៅនិពន្ធដោយ Michael VICKERY មានចំណងជើងថា "កម្ពុជា៖ ១៩៧៥-១៩៨២" (ភាសាបារាំង) បោះពុម្ពឆ្នាំ ១៩៨៤ **ឯកសារ E3/1757** ERN 00763587។

[1153]សៀវភៅនិពន្ធដោយ Michael VICKERY មានចំណងជើងថា "កម្ពុជា៖ ១៩៧៥-១៩៨២" (ភាសាបារាំង) បោះពុម្ពឆ្នាំ ១៩៨៤ **ឯកសារ E3/1757** ERN 00763550។

[1154]អត្ថបទមានចំណងជើងថា "កម្ពុជា៖ សេដ្ឋកិច្ចបែបបដិវត្តន៍" និពន្ធដោយ François PONCHAUD ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៧៩ **ឯកសារ E3/2412** ERN 00812343។

[1155]កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ **ឯកសារ E3/182** ERN 00019108, កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៧៦ **ឯកសារ E3/222** ERN 00000771, សរុបសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ ក្នុងអង្គប្រជុំ ថ្ងៃ ១៩-២០-២១ មេសា ១៩៧៦ **ឯកសារ E3/235** ERN 00019145, កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ **ឯកសារ E3/229** ERN 00000713-14, តើប្រទេសចិនមានតួនាទី[អ្វី]ខ្លះក្នុងរបបខ្មែរក្រហម? ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១១ សារព័ត៌មាន *The Diplomat* **ឯកសារ**

១១៥៦. ដូច្នេះ ក្នុងពេលដ៏លំបាកខ្វះមុខខ្វះក្រោយ សញ្ញាណនៃទ្រព្យសម្បត្តិរួម និងផលិតកម្មសមូហភាព ក្នុងក្របខ័ណ្ឌនៃមនោគមន៍វិជ្ជាកុម្មុយនីស្ត ជាការខិតខំប្រឹងប្រែងក្នុងការផ្គត់ផ្គង់ តាមគ្រប់សមាសធាតុនៃសង្គម ដើម្បីឱ្យប្រទេសរស់[1156]។ នេះមិនមែនជាការធ្វើការ ដើម្បីផលប្រយោជន៍របស់មនុស្សមួយក្តាប់តូចនោះទេ គឺដើម្បីកសាង ឈរលើមូលដ្ឋាននៃសង្គមថ្មី ដែលមនុស្សគ្រប់រូបអាចទទួលបានផលពីការងារសមូហភាព។

១១៥៧. ប៉ុន្តែ ភាពរីកវររបស់ប្រទេសជាសម្ព័ន្ធមិត្ត និងអសមត្ថភាពរបស់មេដឹកនាំជាច្រើន ទាំងអ្នកទទួលខុសត្រូវ និងកម្មាភិបាល បានធ្វើឱ្យខូចខាតដល់ផែនការនយោបាយមួយ ដែលពិតជាមិនមែនធ្វើឱ្យទៅជាទាសករ ឬធ្វើបាបប្រជាជននោះទេ។ មុននឹងពិនិត្យមើលសេចក្តីណែនាំចំពោះកម្មាភិបាលក្នុងការគ្រប់គ្រងសហករណ៍ និងការដ្ឋានការងារ យើងត្រូវកត់សម្គាល់ថា ចំពោះបក្សកុម្មុយនីស្តកម្ពុជា ការស្តារសេដ្ឋកិច្ចឡើងវិញនេះគឺជាសង្គ្រាមមួយ។

## ២. ការប្រយុទ្ធខាងសេដ្ឋកិច្ច ដែលបំផ្លាញដោយការប្រយុទ្ធនៅសមរភូមិ

១១៥៨. ក្នុងលក្ខខ័ណ្ឌបែបនេះ នៅឆ្នាំ ១៩៧៥ ពេលងើបចេញពីសង្គ្រាម កងទ័ពមួយភាគធំត្រូវបានរំសាយដើម្បីចូលរួមការងារកសាងប្រទេសដ៏ធំធេង។ នៅក្នុងកំណត់ហេតុប្រជុំកងពលមួយចំនួន ក្រៅពីសេចក្តីណែនាំខាងយោធា មានការរំឭកអំពីភារកិច្ចជួយប្រជាជន[1157]។ ក៏ប៉ុន្តែ ការប្រមូលកម្លាំង

---

**E3/7294** ERN 01114224-27, ការរកឃើញពន្លឺលើរូងក្រោមដីរបស់ពួកខ្មែរក្រហមដែលត្រូវបានគេបំភ្លេចចោល ចេញផ្សាយថ្ងៃទី ២៧-២៨ ខែ មីនា ឆ្នាំ ២០១០ សារព័ត៌មាន *The Cambodia Daily Weekend* **ឯកសារ E3/7321** ERN 00714181-86។

[1156]កិច្ចសម្ភាសន៍ សមមិត្ត ប៉ុល ពត ជាមួយអ្នកសារព័ត៌មានយូហ្គោស្លាវី ចុះខែ មីនា ឆ្នាំ ១៩៧៨ **ឯកសារ E3/5713** ERN 00775901-03, 00775905-07, សុន្ទរកថារបស់ ខៀវ សំផន ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ **ឯកសារ E3/201** ERN 00292804-07។ សូមមើលផងដែរ សាក្សី 2-TCW-938 ប្រតិចារឹក ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/380.1** (សវនាការអសាធារណៈ) ទំព័រ ៤៥-៤៧ ប្រហែលម៉ោង [១៣.៥៧.២៧], សាក្សី 2-TCW-894 ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/377.1** (សវនាការអសាធារណៈ) ទំព័រ ៣៣-៣៤ ប្រហែលម៉ោង [១១.១៥.៣៣] ទំព័រ ៤០-៤១ ប្រហែលម៉ោង [១៣.៣៨.១៥]។

[1157]ឧទាហរណ៍ សូមមើល កំណត់ហេតុនៃការប្រជុំកងពល ៩២០ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៧៦ **ឯកសារ E3/805** ERN 00052334 ("វិធីដឹកនាំប្រយុទ្ធគឺ [...] ៤. បញ្ហាបង្គោលព្រំដែន ត្រូវពិនិត្យ បើខ្មាំងវាបង្អិតដាក់ក្នុងដីយើង ត្រូវរើចេញ។ [...]

ទៅការពារព្រំដែន រារាំងមិនឱ្យផ្តោតលើភារកិច្ចបន្ទាន់ផ្សេងទៀតបាន។ ប្រការនេះបានរារាំងដល់ការចល័តទាហាន ដើម្បីធ្វើកសិកម្ម ឬកសាង ក្នុងពេលដ៏លំបាកនោះ។

១១៥៩. ជាក់ស្តែង ក្រោយពេលរំដោះ អៀង ផាន មេបញ្ជាការកងវរសេនាតូច បានចំណាយពេលបីខែ នៅព្រៃស "ដើម្បីដាំដុះ" មុននឹងត្រូវបានបញ្ជូនទៅខេត្តតាកែវ ដើម្បីការពារព្រំដែន[1158]។ មានសក្ខីកម្មជាច្រើនលើកឡើងអំពីការប្រមូលកម្លាំង នៅឆ្នាំ ១៩៧៧។ ឃុន គីម ហៅ នួន ប៉ែត មេបញ្ជាការកងវរសេនាតូច នៅតាមការដ្ឋានសាងសង់នានា ក្រោយរំដោះ បានពន្យល់ថា គាត់បាន "ត្រឡប់ទៅសមរភូមិវិញ" ក្នុងឆ្នាំ ១៩៧៧ "ក្រោយពីកងទ័ពវៀតណាមចូលលុកលុយ"[1159]។ សំ ប៊ីត លេខាតំបន់កំពត និងជាអនុរបស់តាម៉ុក "បានហៅកងចល័តជាច្រើនឱ្យត្រឡប់ទៅកាន់ខ្សែត្រៀមជួរមុខ"[1160]។ ចាន់ ម៉ន បានលើកឡើងអំពីករណីដែលបងប្អូនជីដូនមួយរបស់គាត់ត្រូវបានបញ្ជូនពីកងចល័តទៅសមរភូមិ[1161]។

១១៦០. នួន ត្រិច ក៏បានអះអាងផងដែរថា គាត់ត្រូវបានគេប្រមូល ពីការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[1162]។ កែវ លឿ បានផ្តល់សក្ខីកម្មនៅក្នុងសវនាការថា នៅឆ្នាំ ១៩៧៥ "ទាហានទាំងអស់

---

III.ទិសដៅការងារជាយុទ្ធសាស្ត្ររបស់កងទ័ពដែលរស់នៅមណ្ឌលគិរី គឺ[អានមិនបាន]កែប្រែមុខមាត់សង្គម កែប្រែភូមិសាស្ត្រនៅកន្លែងនោះ និងការពារព្រំដែនឱ្យបាន។ ភារកិច្ចរបស់យើងគឺការពារព្រំដែនឱ្យបាន និងរួមសាមគ្គីជាមួយប្រជាជន ឧបត្ថម្ភប្រជាជន ជួយធ្វើស្រែជូនប្រជាជន ធ្វើជាគំរូប្រជាជន កែប្រែជីវភាពប្រជាជន និងកងទ័ពឱ្យបានល្អ។ ផ្ទះសំបែងកងទ័ព ត្រូវរៀបចំឱ្យស្អាត")។

[1158]<u>អៀង ផាន</u> ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ១០ ប្រហែលម៉ោង [០៩.៣៨.១៥]។

[1159]កំណត់ហេតុស្តាប់ចម្លើយ ឃុន គីម ហៅ នួន ប៉ែត ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ **ឯកសារ E3/360** ERN 00186337-39 (សាក្សីរូបនេះដែលត្រូវបានតុលាការកោះហៅ មិនអាចមកផ្តល់សក្ខីកម្មបាន ដោយសារតែបញ្ហាសុខភាព), កំណត់ហេតុស្តាប់ចម្លើយ គង់ គីម ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ **ឯកសារ E3/3959** ERN 00270168-69។ ក្នុងកំណត់ហេតុស្តាប់ចម្លើយ គង់ គីម សាក្សីបានពន្យល់ថា ក្នុងអំឡុងពេលនៃកិច្ចប្រជុំមួយនៅព្រលានយន្តហោះកំពង់ឆ្នាំង គេបានប្រាប់ទាហានដែលត្រូវបានកោះហៅឡើងវិញ និងដែលត្រូវបញ្ជូនទៅព្រំដែនថា ប្រជាជនខ្មែរជាច្រើននាក់ត្រូវបានសម្លាប់ ហើយផ្ទះសំបែង និងស្រែស្រូវត្រូវបានដុតបំផ្លាញ។

[1160]កំណត់ហេតុស្តាប់ចម្លើយ ឃុន គីម ហៅ នួន ប៉ែត ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ **ឯកសារ E3/360** ERN 00186338។

[1161]<u>ចាន់ ម៉ន</u> ប្រតិចារឹក ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/313.1** ទំព័រ ៤៥-៤៦ ក្រោយម៉ោង [១៣.៥៧.៤៨]។

[1162]<u>នួន ត្រិច</u> ប្រតិចារឹក ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/507.1** ទំព័រ ៥៤ ប្រហែលម៉ោង [១៣.៥៦.៣១], ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/508.1** ទំព័រ ២១-២២ ក្រោយម៉ោង [១០.០៤.៥៧]។

ត្រូវបានដកអាវុធ"[1163]។ កែវ លឿ សមាជិកកង ក-៤ ដែលមានសមាសភាពទាហានរបួសនៃកងពល ៣១០ បានឆ្លើយថា នៅខែ តុលា ឆ្នាំ ១៩៧៧ "ទាហានដែលជាពីរបួសត្រូវបានបញ្ជូនត្រឡប់ទៅសមរភូមិវិញ"[1164]។ ជួន ធី បានអះអាងថា គាត់បានធ្វើ "កសិកម្ម និងជួសជុលផ្លូវ" មុនពេលបញ្ជូនទៅខេត្តស្វាយរៀង ក្នុងឆ្នាំ ១៩៧៨[1165]។

១១៦១. ការបាត់បង់មធ្យោបាយហិរញ្ញវត្ថុ និងកម្លាំងយោធា បណ្តាលមកពីជម្លោះប្រដាប់អាវុធ បានបង្កផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំង លើលទ្ធភាពរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការកសាងប្រទេសដោយផ្អែកលើមូលដ្ឋានរឹងមាំ។ អសន្តិសុខនៅតាមតំបន់ព្រំដែន និងផលប៉ះពាល់ទៅលើជីវិត និងការធ្វើដំណើររបស់ប្រជាជន[1166] ការរឹតត្បិតរបបអាហារដោយសារខ្វះស្បៀងនៅតាមសហករណ៍ក៏ដូចជានៅតាមសមរភូមិ និងអលទ្ធភាពក្នុងការប្រមើលមើលការដោះដូរសេដ្ឋកិច្ចក្នុងរយៈពេលវែងដោយសារតែប្រទេសអស្ថិរភាព គឺជាផលវិបាកផ្ទាល់នៃជម្លោះប្រដាប់អាវុធ[1167]។

---

[1163] កែ លឿ ប្រតិចារឹក ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/316.1** ទំព័រ ៥៦ មុនម៉ោង [១៥.១៧.៣៦]។

[1164] កែ លឿ ប្រតិចារឹក ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/316.1** ទំព័រ ៥២ ប្រហែលម៉ោង [១៤.៤៤.២៧]។

[1165] ជួន ធី ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៥៦ ប្រហែលម៉ោង [១៤.០២.២៨], ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **E1/490.1** ទំព័រ 112-114, vers 15.49.06 [mauvaise référence ?]។

[1166] ឧទាហរណ៍ សូមមើល ទូរលេខរបស់ភួង ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៧៨ **ឯកសារ E3/913** ERN 00020934-36 ទាក់ទងនឹងផលវិបាកនៃការប្រយុទ្ធគ្នានៅមេមត់៖ ដុតបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ គោក្របីត្រូវងាប់ ឬលួច, សេចក្តីរាយការណ៍របស់កងពល ២៦០ ផ្នែកនយោបាយ ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៨ **ឯកសារ E3/860** ERN 00021003 (ផលវិបាកនៃការប្រយុទ្ធគ្នានៅត្រមូង៖ "១. ចំពោះខ្មាំងយួនដែលវាឈ្លានពានចូលមកភូមិភាគបូព៌ានោះ ពិសេសស្រុកត្រមូង ម៉ុក្តុល និង ... ឥឡូវ យើងវ៉ៃហើយរត់ទៅស្រុកវាអស់ហើយ។ ២. ខ្មាំងយួនដែលចូលមកភូមិក្តុលនេះ វាយកគោក្របីអស់ច្រើនណាស់ វាប់រយក្បាល ឯជ្រូក មាន់ ក៏វាយកជិតអស់ នៅសល់តិចតួចណាស់។ [...] ៤. ខ្ញុំសូមជម្រាបបក្សថា បញ្ហាគោក្របី និងជ្រូក មាន់ នៅភូមិក្តុលសម្បូរណាស់ ខ្ញុំប្រាប់គណៈស្រុកគេ និងតំបន់ ឲ្យយកទៅក្រោយច្រើនដងណាស់ តែគេមិនតាម ឥឡូវ យួនយកអស់ជាង ៩៥ ភាគរយហើយ សូមបក្សជួយមានវិធានការ")។ អៀង ផាន បានលើកឡើងពីការជម្លៀសប្រជាជនខេត្តស្វាយរៀង៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៤៣ មុនម៉ោង [១៣.៣២.៥៥] ("[...] ពេលដែលខ្ញុំដល់ហ្នឹង ប្រជាជនជម្លៀសចេញអស់ហើយ។ មូលហេតុដែលជម្លៀសចេញនោះគឺថា ការប្រយុទ្ធគ្នារវាងកងទ័ពកម្ពុជា និងវៀតណាម មានសភាពខ្លាំងក្លា អ៊ីចឹងមិនអាចនៅបានទេគាត់ជម្លៀសមកខាងក្រោយហើយ"), ជួន ធី ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៦២ មុនម៉ោង [១៤.២២.៥២] (គាត់បានបញ្ជាក់អះអាងថា៖ "កាលខ្ញុំទៅដល់ហ្នឹង គឺប្រជាជននៅស្វាយរៀង អត់មានឃើញទេ មានឃើញតែកងទ័ពដែលនេះហ្នឹងទេ អត់ឃើញមានប្រជាជន តែម្នាក់ក៏អត់មានផង")។

[1167] សូមមើលការវាយប្រហារនៅតាមចម្ការកៅស៊ូ ផ្នែកដោះដូរសេដ្ឋកិច្ច៖ 2-TCW-1005 ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/449.1** ទំព័រ ៣៩-៤០ ប្រហែលម៉ោង [១១.១៣.៣១]។

## ផ្នែកទី ២. ការកំណត់គោលដៅកែលម្អជីវភាពប្រជាជនឱ្យប្រសើរឡើង

១១៦២. ទោះបីជាមានសង្គ្រាម និងជួបបរាជ័យនាពេលក្រោយយ៉ាងណាក៏ដោយ ក៏គោលដៅសហករណ៍ និងការដ្ឋានការងារ គឺកែលម្អជីវភាពប្រជាជនឱ្យប្រសើរឡើង ដោយចាប់ផ្ដើមពីកសិករដែលត្រូវបានសង្គមកម្ពុជាផាត់ចោលអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ។ លទ្ធិម៉ាក្សនិយមរបស់បក្សកុម្មុយនីស្តកម្ពុជាបានផ្ដល់រូបភាពល្អឥតខ្ចោះដល់កសិករក្រ ដែលជាគំរូនៃសង្គមថ្មីស្មើភាពក្នុងកម្ពុជាប្រជាធិបតេយ្យឯករាជ្យ ដោយមិនបានគិតទុកជាមុនដល់អារម្មណ៍ចង់សងសឹក ដូចបានរៀបរាប់ដោយលោក Michael VICKERY ដែលនាំឱ្យមានការអនុវត្តប្រាសចាកគោលការណ៍នៅតាមមូលដ្ឋាន នោះទេ។

១១៦៣. ប៉ុន្តែ ផែនការមានគោលដៅឆ្ងាយពីឧក្រិដ្ឋកម្ម ដែលលោក ខៀវ សំផន ត្រូវបានចោទប្រកាន់ (១)។ ម្យ៉ាងវិញទៀត កសិកម្មជាមធ្យោបាយតែមួយគត់ក្នុងការទទួលបានដើមទុនសំខាន់សម្រាប់ជីវភាពប្រជាជន (២)។

### ១. គោលដៅនៃដំណើរការសហករណ៍ និងការដ្ឋានការងារ

១១៦៤. នៅក្នុងកំណត់ហេតុប្រជុំមួយរបស់គណៈអចិន្ត្រៃយ៍ មានការរំឭកចំណុចស្នូលនៃគោលនយោបាយតែមួយគត់ដែលពិតជាត្រូវបានគ្រោងទុក៖ "គោលការណ៍របស់បក្ស គឺដោះស្រាយជីវភាព"[1168]។ នេះជាគោលដៅតែមួយគត់របស់សហករណ៍ គឺមិនមែនស្វែងរកខ្មាំង ដូចបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយនោះទេ។

១១៦៥. ជាក់ស្ដែង សហករណ៍មានគោលដៅកែលម្អមធ្យោបាយផលិតកម្ម ដើម្បីមាន "ត្រី សាច់ និងបន្លែច្រើនជាងមុន" និងជាទូទៅ មានជីវភាពល្អប្រសើរជាងមុន[1169]។ ការកែលម្អជីវភាពប្រចាំថ្ងៃ គឺជា

[1168]កំណត់ហេតុអំពីទស្សនកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃ ២០-២៤ សីហា ១៩៧៥ **ឯកសារ E3/216** ERN 00008490។

[1169]ទង់បដិវត្ត ចេញផ្សាយខែ សីហា ឆ្នាំ ១៩៧៥ **ឯកសារ E3/5** ERN 00063350។

កាតព្វកិច្ចបដិវត្តន៍[1170] និងជាផ្នែកដ៏សំខាន់នៃការការពារប្រទេស ដើម្បីឱ្យប្រជាជនចូលរួមជាមួយបដិវត្តន៍[1171]។

១១៦៦. បន្ទាប់មកទៀត ទស្សនាវដ្ដី "ទង់បដិវត្ត" រៀបរាប់លម្អិតអំពីវិធានការជាក់ស្ដែងសម្រាប់ប្រជាជន ដោយលើកឡើងអំពីរបបអាហារចាំបាច់ដោយសារខ្វះស្បៀង និងស្នើជាដំណោះស្រាយខាងដាំដុះ ចិញ្ចឹមសត្វ មធ្យោបាយស្លៀកពាក់ ឬទីជម្រក[1172]។ ការប្រើប្រាស់ប្រជាជនជាកម្លាំងការងារមិនមែនជាឧទ្ទៈក្នុងការធ្វើឱ្យទៅជាទាសករនោះទេ គឺជាជំហានសម្រាប់ឱ្យប្រទេសត្រូវរស់សិន ក្នុងពេលដ៏លំបាកនោះ។ គោលដៅ គឺមានមធ្យោបាយទិញម៉ាស៊ីន[1173]។ វិធានការប្រភេទនេះក៏ជាការព្រួយបារម្ភចំពោះយោធាផងដែរ[1174] និងត្រូវបានគ្រោងទុក រហូតដល់ចប់របបនោះ[1175]។

១១៦៧. នៅកថាខណ្ឌ ១៧២ នៃដីកាដំណោះស្រាយ កំណត់ហេតុប្រជុំឆ្នាំ ១៩៧៦ ត្រូវបានលើកឡើង ដើម្បីបញ្ជាក់អំពីទស្សនកិច្ចនៅតាមមូលដ្ឋានដែលខ្វះស្បៀង ដោយមិនបង្ហាញអំពីការខិតខំប្រឹងប្រែងដើម្បីប៉ុនប៉ងដោះស្រាយបញ្ហានេះ និងការកែលម្អឱ្យប្រសើរឡើង ធៀបនឹងឆ្នាំមុន[1176]។ ម្យ៉ាងវិញ

---

[1170] ទង់បដិវត្ត ចេញផ្សាយខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ **ឯកសារ E3/748** ERN 00063258៖ "ត្រូវឃើញភារកិច្ចដោះស្រាយជីវភាពប្រជាជន ជាភារកិច្ចមូលដ្ឋាន យូរអង្វែងរហូតទៅ"។

[1171] ទង់បដិវត្ត ចេញផ្សាយខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ **ឯកសារ E3/748** ERN 00063259-61, ទង់បដិវត្ត ចេញផ្សាយខែ វិច្ឆិកា ឆ្នាំ ១៩៧៦ **ឯកសារ E3/139** ERN 00064965 ("ហេតុអីបានបក្សកំណត់ ១៣ ថាំង? មកពីមានន័យសេដ្ឋកិច្ច និងនយោបាយ។ សំណូមពរគឺឱ្យប្រជាជនបានហូបគ្រប់គ្រាន់។ សម័យមុនរាប់សតវត្សមកហើយ ប្រជាជនពលករមិនដែលបានហូបឆ្អែតទេ។ ក្នុងសង្គ្រាម ប្រជាជនត្រូវទ្រាំទ្រនូវការលំបាកវេទនាជាច្រើន ខ្វះមុខ ខ្វះក្រោយ។ ក្រោយរំដោះហើយ ឆ្នាំ ១៩៧៥-១៩៧៦ ក្នុងរយៈកាលមួយឆ្នាំកន្លះ ប្រជាជនក៏នៅតែខ្វះខាតទៀត។ ដូច្នោះហើយ បានជាយើងខិតខំបង្កបង្កើនផលស្រូវឆ្នាំ ១៩៧៦ នេះ គឺដើម្បីផ្គត់ផ្គង់ប្រជាជនឲ្យបានគ្រប់គ្រាន់។ បើប្រជាជនបានហូបគ្រប់គ្រាន់ហើយ ប្រជាជនកក់ក្ដៅ ហើយជំរុញចលនាបដិវត្តសង្គមនិយម និង កសាងសង្គមនិយមឲ្យកាន់តែលោតផ្លោះ")។

[1172] ទង់បដិវត្ត ចេញផ្សាយខែ កុម្ភៈ-មីនា ឆ្នាំ ១៩៧៦ **ឯកសារ E3/166** ERN 00063213-15។

[1173] ទង់បដិវត្ត ចេញផ្សាយខែ កុម្ភៈ-មីនា ឆ្នាំ ១៩៧៦ **ឯកសារ E3/166** ERN 00063216-17។

[1174] កំណត់ហេតុកិច្ចប្រជុំកងទ័ព ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៦ **ឯកសារ E3/804** ERN 00008483។

[1175] របាយការណ៍របស់ ញឹម ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៨ **ឯកសារ E3/950** ERN 00021044, របាយការណ៍របស់ ញឹម ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៧៨ **ឯកសារ E3/863** ERN 00076286។

[1176] កំណត់ហេតុនៃអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទី២ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៧៦ **ឯកសារ E3/794** ERN 00000788, 00000791-92, 00000794-96, 00000798។

ទៀត ក្រៅពីស្ថានភាពអាសន្ន គួរបញ្ជាក់ថា ការលំបាកក្នុងការដោះស្រាយស្ថានការណ៍កាន់តែមានសភាពអាក្រក់ទៅៗ ដោយសារបញ្ហាធម្មជាតិ ដូចជា ទឹកជំនន់ធំៗ នៅឆ្នាំ ១៩៧៨[1177] ឬកំហុសខាងការដាំដុះ[1178]។

១១៦៨. លក្ខខ័ណ្ឌ ដែលសាក្សីមួយចំនួននៅតាមការដ្ឋានបានរៀបរាប់ មិនឆ្លុះបញ្ចាំងអំពីសេចក្តីណែនាំស្តីពីលក្ខខ័ណ្ឌការងារ អនាម័យ ក៏ដូចជាអវត្តមាននៃការរើសអើង នៅក្នុងមនោគមន៍វិជ្ជាបក្ស។ នេះគឺជារឿងមួយ ដែលសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា មិនលើកយកមកនិយាយ នៅពេលដកស្រង់សារទូរលេខមួយចំនួន[1179]។

១១៦៩. ប៉ុន្តែ ទស្សនាវដ្តីរបស់បក្សកុម្មុយនីស្តកម្ពុជាបានណែនាំច្បាស់លាស់អំពីភាពចាំបាច់ក្នុងការប្រព្រឹត្តិឱ្យបានសមរម្យជាមួយប្រជាជន។ ក្នុងទស្សនៈនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា កម្មាភិបាលមានភារកិច្ចមើលថែប្រជាជន ដែលត្រូវបានទស្សនាវដ្តីទង់បដិវត្ត ប្រៀបប្រដូចទៅនឹង "គ្រាប់ពេជ្រដ៏ថ្លៃថ្លា"[1180]។

១១៧០. យុវបក្ខជនត្រូវបានលើកទឹកចិត្ត ជាពិសេស ឱ្យយកចិត្តទុកដាក់ទៅលើការលំបាករបស់ប្រជាជន និងធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីដោះស្រាយបញ្ហាលំបាកទាំងនេះ[1181]។ ផ្ទុយទៅវិញ ការដាក់ទោសមាន

---

[1177] ឧទាហរណ៍ សូមមើល៖ <u>កាន ធុន</u> ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/328.1** ទំព័រ ៣៥ ប្រហែលម៉ោង [១១.៣៣.២៥] ("នៅឆ្នាំ ៧៨ ទឹកធំ") ទំព័រ ៦៣ ប្រហែលម៉ោង [១៥.៣៥.០០], <u>សែន សុធុន</u> ប្រតិចារឹក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/324.1** ទំព័រ ៩ ប្រហែលម៉ោង [០៩.២៧.៤៤] និងទំព័រ ១០-១១ ក្រោយម៉ោង [០៩.៣១.០៦], <u>មាស សឿន</u> ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/446.1** ទំព័រ ២៩ ក្រោយម៉ោង [១០.៥៦.១៨], <u>នួន ត្រិច</u> ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/508.1** ទំព័រ ២១ ក្រោយម៉ោង [១០.០៤.៥៣]។

[1178] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៧៨ **ឯកសារ E3/918** ERN 00001061-62។

[1179] ទូរលេខរបស់ កែ ពក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ **ឯកសារ E3/511** ERN 00000766។

[1180] ទង់បដិវត្ត ចេញផ្សាយខែ វិច្ឆិកា ឆ្នាំ ១៩៧៦ **ឯកសារ E3/139** ERN 00064988, 00064992-93។

[1181] យុវជន និងយុវនារីបដិវត្ត ចេញផ្សាយខែ វិច្ឆិកា ឆ្នាំ ១៩៧៥ **ឯកសារ E3/750** ERN 00063605 ("[...] ក្នុងឋានៈយើងជាអ្នកបម្រើប្រជាជន និងជាសាច់ឈាមរបស់ប្រជាជន ដើម្បីយើងមានវិធានការជាក់ស្តែង ហើយចុះប្រឡូកផ្ទាល់ ជួយដោះស្រាយជីវភាពប្រជាជនយើង ឱ្យអស់លទ្ធភាព"), ERN 00063608-12, យុវជន និងយុវនារីបដិវត្ត ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៦ **ឯកសារ E3/732** ERN 00064301។

សភាពធូន់ធ្ងរទៅលើកម្មាភិបាលដែលមិនគោរពតាមគោលការណ៍ទាំងនេះ ហើយឥរិយាបថនេះត្រូវបានរាយការណ៍ថាប្រឆាំងបដិវត្តន៍[1182] ប្រឆាំងគោលការណ៍បក្ស[1183]។

១១៧១. ការប្រព្រឹត្តិចំពោះប្រជាជនថ្មីជាចំណុចស្នូលនៃការប្រព្រឹត្តិរបស់របស់សហករណ៍។ ដូច្នេះ យើងចាំបាច់ត្រូវត្រឡប់មកនិយាយអំពីខ្លឹមសារនៃសេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបង្ហាញអំពីភាពផ្ទុយគ្នានៃការរើសអើង[1184]។ ការប្រមូលផ្តុំត្រូវបានមើលឃើញថាមានភាពចាំបាច់ដល់ភាពជោគជ័យរបស់បដិវត្តន៍[1185]។ម្យ៉ាងវិញទៀត នៅក្នុងសំណុំរឿង ០០២/០១ លោក Steve HEDER បានបញ្ជាក់អះអាងនូវអត្ថបទមួយរបស់គាត់ ពាក់ព័ន្ធនឹងខ្លឹមសារនៃឯកសារបោះពុម្ពផ្សាយជាច្រើនរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានន័យជាការណែនាំឱ្យចៀសវាងការរើសអើងចំពោះប្រជាជនថ្មី នៅតាមសហករណ៍[1186]។

## ២. កសិកម្មជាប្រភពដើមទុនតែមួយគត់

១១៧២. ការសង្ខេបដោយសាមញ្ញពេករបស់សហព្រះរាជអាជ្ញាថា ការនាំចេញអង្ករគឺជាដើមហេតុនៃការខ្វះស្បៀងរបស់កម្ពុជាប្រជាធិបតេយ្យ គឺជាការមើលឃើញពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា

---

[1182]យុវជន និងយុវនារីបដិវត្ត ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៦ **ឯកសារ E3/732** ERN 00064297-98, 00064301។

[1183]ទង់បដិវត្ត ចេញផ្សាយខែ កក្កដា ឆ្នាំ ១៩៧៦ **ឯកសារ E3/738** ERN 00062932, លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា គ្មានចុះកាលបរិច្ឆេទ **ឯកសារ E3/214** ERN 00053018-19។

[1184]កំណត់ហេតុអំពីទស្សនកិច្ចគណៈអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃ ២០-២៤ សីហា ១៩៧៥ **ឯកសារ E3/216** ERN 00008488 ("ក. បញ្ហាគន្លឹះគឺដោះស្រាយសភាពការណ៍នយោបាយរបស់ប្រជាជន៖ បញ្ហាសំខាន់គឺដោះស្រាយសភាពការណ៍នយោបាយរបស់ប្រជាជន ធ្វើយ៉ាងណាឲ្យប្រជាជននឹងន សាមគ្គីជាធ្លុងមួយ ជាមួយរដ្ឋអំណាចបដិវត្ត។ រដ្ឋអំណាចបដិវត្តត្រូវគ្រប់គ្រងប្រជាជនឲ្យបានល្អលើគ្រប់ផ្នែក នយោបាយ សតិអារម្មណ៍ និងចាត់តាំង។ បើធ្វើដូច្នេះ គ្មានខ្មាំងណា មកវាយយើងបានទេ"), ERN 00008489 ("ដើម្បីការពារប្រទេសឲ្យមានប្រសិទ្ធភាព ត្រូវដោះស្រាយជីវភាពប្រជាជនក្នុងសហករណ៍។ ប្រជាជនថ្មីក៏យើងខំដោះស្រាយឲ្យគេ ឲ្យគេពេញចិត្តពេញថ្លើមនឹងបដិវត្តន៍ ឲ្យគេឃើញថារបបនេះ ជារបបរបស់គេ លែងឲ្យគេចង់ទៅណាទៀត")។

[1185]ទង់បដិវត្ត ចេញផ្សាយខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៧ **ឯកសារ E3/737** ERN 00064810-13។

[1186]អត្ថបទមានចំណងជើងថា "ការវាយតម្លៃឡើងវិញអំពីតួនាទីរបស់មេដឹកនាំជាន់ខ្ពស់ និងមន្ត្រីថ្នាក់មូលដ្ឋាន ចំពោះឧក្រិដ្ឋកម្មទាំង ឡាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ការទទួលខុសត្រូវរបស់កម្ពុជាក្នុងទស្សនវិស័យប្រៀបធៀប" និពន្ធដោយ Steve HEDER ចុះខែ មីនា ឆ្នាំ ២០០៣ **ឯកសារ E3/4527** ERN 00830768-71។

ប្រជាធិបតេយ្យ តែមួយជ្រុង។ ជាក់ស្តែង ដោយសារតែគ្មានឧស្សាហកម្ម និងគ្មានបច្ចេកវិទ្យា គេត្រូវការដើមទុន ដើម្បីទិញផលិតផល និងសម្ភារៈដែលចាំបាច់សម្រាប់កម្ពុជា និងប្រជាជន[1187]។ ការទិញឱសថ ស្ថិតនៅក្នុងចំណោមតម្រូវការទាំងនេះ[1188]។ ដូច្នេះ ការរក្សាការដោះដូរពាណិជ្ជកម្មជាមួយប្រទេសជាមិត្តឱ្យបានជាអប្បបរមា មានសារៈសំខាន់ណាស់[1189]។

១១៧៣. ស្រូវសម្រាប់នាំចេញត្រូវបានសន្មតថាជាអតិរេក[1190] ក្រោយពីបម្រុងទុករួចហើយ ក្នុងករណីខ្លះស្បៀង[1191]។ របាយការណ៍ក្លែងក្លាយធ្វើពីមូលដ្ឋានស្តីពីអតិរេក គឺជាការឆ្លុះបញ្ចាំងឱ្យឃើញថា គណៈមជ្ឈិម និងបក្សកុម្មុយនីស្តកម្ពុជា មិនអាចក្តាប់សភាពការណ៍នៅទូទាំងប្រទេសបានទេ[1192]។

---

[1187]កំណត់ហេតុអំពីទស្សនកិច្ចគណៈអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃ ២០-២៤ សីហា ១៩៧៥ **ឯកសារ E3/216** ERN 00008491, កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ "ស្តីពីគម្រោងផែនការ៤ឆ្នាំ កសាងសង្គមនិយមគ្រប់ផ្នែក ឆ្នាំ ១៩៧៧-១៩៨០" ពីថ្ងៃ ២១ ខែ ៧ ដល់ថ្ងៃទី ២ ខែ ៨ ឆ្នាំ ១៩៧៦ **ឯកសារ E3/213** ERN 00075827-28, អត្ថបទនិពន្ធដោយ François PONCHAUD មានចំណងជើងថា "កម្ពុជារំដោះ" ចុះខែ មករា ឆ្នាំ ១៩៧៦ **ឯកសារ E3/4589** ERN 00323722-23។

[1188]កិច្ចសម្ភាសជាមួយ ខូ វ៉ាន់ឌី ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៥ **ឯកសារ E3/5659** ERN 00602360-62, កំណត់ហេតុស្តាប់ចម្លើយ កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៩ **ឯកសារ E3/35** ERN 00340564។

[1189]ខៀវ សំផន ទទួលស្វាគមន៍គណៈប្រតិភូពាណិជ្ជកម្មយូហ្គោស្លាវី ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៧៧ (FBIS) **ឯកសារ E3/1485** ERN 00714165-67, សៀវភៅនិពន្ធដោយ Philip SHORT មានចំណងជើងថា *"Pol Pot : Anatomie d'un cauchemar"* **ឯកសារ E3/9** ទំព័រ 389-390 ERN 00639844 (ភាសាបារាំង), កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ **ឯកសារ E3/230** ERN 00000711-12។

[1190]ទង់បដិវត្ត ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៦ **ឯកសារ E3/759** ERN 00062765, ទង់បដិវត្ត ចេញផ្សាយខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៧ **ឯកសារ E3/737** ERN 00064819-20។

[1191]កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៧៦ **ឯកសារ E3/232** ERN 00017121 ("ស្នើសុំចំនួនស្រូវពិតប្រាកដ។ ខាងលើដឹងចំនួន ដើម្បីងាយចាត់ចែង ម្យ៉ាងសម្រាប់ដោះស្រាយជីវភាពប្រជាជន តែម្យ៉ាងទៀត ក៏គិតគូរលក់ដូរដែរ។ [...] ឯ ១០៣ ពីមុន អង្គការសម្រេចយក ១ 000 តោន។ ឥឡូវ យកតែ ៥០០ តោនទេ។ ចំនួននេះក៏ទុកនៅកន្លែងនោះសិនចុះ ដើម្បីបម្រុងក្រែងខ្វះខាត")។

[1192]<u>មាស វឿន</u> ប្រតិចារឹក ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ **ឯកសារ E1/130.1** ទំព័រ ៥៤-៥៦ ចន្លោះម៉ោង [១៤.០០.៥៩] និង [១៤.១១.១៥]។ នៅចុងឆ្នាំ ១៩៧៨ មាស វឿន ត្រូវបានបញ្ជូនទៅខេត្តព្រះវិហារ បន្ទាប់ពីមានសកម្មភាពរបស់ កង ចាប ប្រធានភូមិភាគឧត្តរថ្មី ធ្វើទៅលើប្រជាជន។ ក្នុងជំនួបពិភាក្សាជាមួយ ប៉ុល ពត មាស វឿន ត្រូវបាន ប៉ុល ពត ស្នើឱ្យស៊ើបអង្កេតលើរឿងដែលបានកើតឡើង ហើយដែលនេះ វាបង្ហាញឱ្យឃើញពីការណ៍ដែលក្តាប់សភាពការណ៍មិនបាន។ ទាក់ទងនឹងរបាយការណ៍មិនពិតប្រាកដរបស់មូលដ្ឋាន សូមមើលផងដែរ៖ កិច្ចសម្ភាសជាមួយ ខូ វ៉ាន់ឌី ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៥ **ឯកសារ E3/5659** ERN 00602369-72។

សក្ខីកម្មស្តីពីការលាក់បាំងបញ្ហាមិនឱ្យថ្នាក់លើដឹង គឺជាការផ្ទុះបញ្ជាំងមួយទៀត[1193]។ ឥរិយាបថមិនល្អរបស់អ្នកដឹកនាំសហករណ៍ អាចឱ្យយើងយល់អំពីការអនុវត្តប្រាសចាកពីគោលការណ៍[1194]។

១១៧៤. ដូច្នេះ យើងត្រឡប់មកនិយាយអំពីសញ្ញាណនៃភាពខុសគ្នាស្រឡះរវាងផែនការគ្រោងទុកនៅក្នុងគោលនយោបាយ និងការអនុវត្តនៅតាមមូលដ្ឋាន។ នេះគឺជាបញ្ហាប្រឈមនៃការពិភាក្សាអំពីសហឧក្រិដ្ឋកម្មរួម ពីព្រោះគោលនយោបាយតែមួយគត់ ដែលលោក ខៀវ សំផន បានចូលរួម គឺការគ្រោងគិតគូរ និងដោះស្រាយបញ្ហារបស់ប្រជាជន។ គាត់មិនចង់ឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅតាមមូលដ្ឋាននោះទេ ហើយគាត់ក៏មិនបានចូលរួមចំណែកអ្វីដែរ។ តុលាការអនាគតគិតគួរតែអាចពិចារណាទៅលើព័ត៌មានទាំងនេះ។

[1193] ញឹប ហាល់ ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/336.1** ទំព័រ ២៤ មុនម៉ោង [១០.៥២.៣៣], ម៉ម សឿម ហៅ ហេង សាម្មត ប្រតិចារឹក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/324.1** ទំព័រ ៦៧ ប្រហែលម៉ោង [១៥.៣៧.២៩], ប្រតិចារឹក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/325.1** ទំព័រ ២៨ ក្រោយម៉ោង [១០.៤២.៣០]។ សូមមើលផងដែរ សេចក្តីថ្លែងការណ៍របស់សម្តេចសីហនុ ក្នុងកិច្ចសម្ភាសមួយ ដែលត្រូវបានចាក់បញ្ចាំងក្នុងអំឡុងពេលសវនាការបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ **ឯកសារ E1/234.1** ទំព័រ ៣០-៣១ ចន្លោះម៉ោង [១០.៥៨.៣៥] និង [១១.០៥.៤៩]។

[1194] បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជា នៅព្រំដែនកម្ពុជា-ថៃ ធ្វើដោយ Masato MATSUSHITA និង Steve HEDER ខែ កុម្ភៈ-មីនា ឆ្នាំ ១៩៨០ **ឯកសារ E3/1714** ERN 00324687 [numéro ERN à rectifier dans l'original (bon ERN 00648969)] ("យើងយល់ឃើញថា បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើននោះ គឺក្នុងសហករណ៍នីមួយៗ ត្រូវបានគេសន្មតថាជាសង្គមតូចមួយដែលពឹងអាស្រ័យលើខ្លួនឯង ហើយថាគ្រប់សហករណ៍ទាំងអស់ត្រូវផ្តល់នូវស្ថិតិអំពីការបង្កបង្កើនផលស្រូវ ចំនួនប្រជាជន និងតម្រូវការរបស់ប្រជាជនជូនទៅថ្នាក់លើ។ ចំនួនស្រូវដែលត្រូវបញ្ជូនទៅរដ្ឋ គឺជាការទទួលខុសត្រូវតែមួយគត់របស់ប្រធានសហករណ៍នីមួយៗ ប៉ុន្តែប្រធានសហករណ៍ជាច្រើនបានបំប៉ោងតួលេខផលិតផល ដើម្បីធ្វើឱ្យបក្សមើលទៅពួកគេថាជាមនុស្សល្អ ហើយពួកគេបានបញ្ជូនស្រូវទៅឱ្យរដ្ឋយ៉ាងច្រើនរហូតដល់ធ្វើឱ្យប្រជាជនខ្វះខាតអង្ករបរិភោគ"), អត្ថបទដកស្រង់ចេញពីសៀវភៅនិពន្ធដោយ R.A. BURGLER មានចំណងជើងថា "*The eyes of the pineapple*" បោះពុម្ពឆ្នាំ ១៩៩០ **ឯកសារ E3/7260** ERN 01056957-58។

## ភាគទី ២. មន្ទីរសន្តិសុខ

## ជំពូកទី ១. ស-២១

## ផ្នែកទី ១. បទចោទ

១១៧៥. ចំពោះអង្គហេតុដែលកើតឡើងនៅមន្ទីរសន្តិសុខ ស-២១ លោក ខៀវ សំផន ត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស (អំពើអមនុស្សធម៌ផ្សេងទៀត) ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1195]។ គាត់ក៏ត្រូវបានចោទប្រកាន់ផងដែរអំពីឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការប្រព្រឹត្តិដោយអមនុស្សធម៌ ការបង្កឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ ឬរបួសស្នាមធ្ងន់ធ្ងរដល់រូបកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់សេចក្ដីប្រកបដោយយុត្តិធម៌ និងទៀងទាត់ ការនិរទេសជនស៊ីវិលដោយខុសច្បាប់ ស្មើនឹងការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[1196]។

---

[1195]ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៧៦, ១៣៧៩-១៣៨០ (មនុស្សឃាត) កថាខណ្ឌ ១៣៨១-១៣៨៣, ១៣៨៥, ១៣៨៧-១៣៩០ (ការសម្លាប់រង្គាល) កថាខណ្ឌ ១៣៩១-១៣៩៦ (ការធ្វើឱ្យទៅជាទាសករ) កថាខណ្ឌ ១៤០២-១៤០៤, ១៤០៦-១៤០៧ (ការដាក់ក្នុងមន្ទីរឃុំឃាំង) កថាខណ្ឌ ១៤០៨-១៤១៤ (ការធ្វើទារុណកម្ម) កថាខណ្ឌ ១៤១៥-១៤១៨, ១៤២៤-១៤២៥ (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ) កថាខណ្ឌ ១៤១៥, ១៤២២-១៤២៣ (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍) កថាខណ្ឌ ១៤៣៤-១៤៣៥, ១៤៣៨-១៤៤១ (ការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស), ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ៤-៦។

[1196]ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៩១-១៤៩៣ (ការធ្វើមនុស្សឃាតដោយចេតនា) កថាខណ្ឌ ១៤៩៨-១៥០០ (ការធ្វើទារុណកម្ម) កថាខណ្ឌ ១៥០១-១៥០៣ (ការធ្វើបាបដោយអមនុស្សធម៌) កថាខណ្ឌ ១៥០៤-១៥០៦ (ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព) កថាខណ្ឌ ១៥០៧-១៥១០ (ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់) កថាខណ្ឌ ១៥១៥-១៥១៧ (ការនិរទេសជនស៊ីវិលដោយខុសច្បាប់) កថាខណ្ឌ ១៥១៨-១៥២០ (ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់), ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ៧-៨។

១១៧៦. អង្គហេតុពាក់ព័ន្ធនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវបានកំណត់ថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានសិក្សាខាងក្រោម នៅក្នុងជំពូកស្តីពីការសិក្សាអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលទាំងនេះ ដែលត្រូវបានចោទប្រកាន់[1197]។

១១៧៧.ម្យ៉ាងវិញទៀត ទោះបីជា ឧបសម្ព័ន្ធដែលកំណត់អំពីវិសាលភាពនៃសំណុំរឿង ០០២/០២ មានបញ្ជាក់អំពីការនិរទេសជនស៊ីវិលដោយខុសច្បាប់ ស្មើនឹងការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ក៏ដោយ ក៏អង្គជំនុំជម្រះមិនបានទទួលបណ្តឹងអំពីករណីនេះទេ។ ជាក់ស្តែង ក្នុងដីកាដំណោះស្រាយ អង្គហេតុដែលអាចជាធាតុផ្សំនៃការនិរទេសជនស៊ីវិលដោយខុសច្បាប់ គឺពាក់ព័ន្ធនឹងការចាប់ខ្លួនជនស៊ីវិលវៀតណាមដោយកងទ័ពបដិវត្តន៍កម្ពុជា នៅលើទឹកដីវៀតណាម ដើម្បីបញ្ជូនទៅ ស-២១[1198]។ ក៏ប៉ុន្តែ នៅពេលសម្រេចបំបែកបទចោទ អង្គជំនុំជម្រះបានដកអង្គហេតុទាំងនេះចេញ[1199]។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសម្រេចលើអង្គហេតុទាំងនេះបានទេ។

## ផ្នែកទី ២. ការបង្ហាញភស្តុតាង

### ១. ភស្តុតាងបានមកពីសក្ខីកម្ម

១១៧៨. នៅក្នុងសវនាការលើអង្គសេចក្តី ពាក់ព័ន្ធនឹង ស-២១ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សី ១០ រូប (ញ៉ែម អេន, តាយ ឡេង, ឡាច មាន, ប្រាក់ ខន, ម៉ក់ ធឹម, ហ៊ឹម ហ៊ុយ, សួស ធី, កាំង ហ្កេកអ៊ាវ ហៅ ឌុច, នឹម អ៊ឹម, ហ៊ិន សុផានី[1200]) ដើមបណ្តឹងរដ្ឋប្បវេណី ១ រូប (ជុំ ម៉ី) និងអ្នកជំនាញ ១ រូប (វឿន វុទ្ធី)។

---

[1197] សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ២២៧៣-២២៧៦។

[1198] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥១៥-១៥១៧។

[1199] ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ២ និង ៦។

[1200] ហ៊ិន សុផានី ពុំត្រូវបានស្តាប់ចម្លើយទាក់ទងនឹងអង្គហេតុនោះទេ តែគាត់បានផ្តល់ចម្លើយពាក់ព័ន្ធនឹងការរៀបចំបញ្ជីអ្នកទោសរបស់ការិយាល័យសហាថៅក្រុមស៊ើបអង្កេត។

## ២. ភ័ស្តុតាងឯកសារ

១១៧៩. ចំពោះកំណត់ហេតុស្តាប់ចម្លើយ កំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួន មកពីសំណុំរឿង ០០២ សំណុំរឿង ០០៣ សំណុំរឿង ០០៤ និងប្រតិចារឹកនៃសំណុំរឿង ០០២/០១ ក៏ដូចជាប្រតិចារឹកនៃសំណុំរឿង ០០១ ត្រូវបានទទួលយកនៅក្នុងសំណុំរឿងនេះ។

១១៨០.ម្យ៉ាងវិញទៀត ឯកសារជាច្រើន ពាក់ព័ន្ធនឹង ស-២១ មាននៅក្នុងសំណុំរឿង។ ឯកសារខ្លះត្រូវបាន កាំង ហ្គេកអ៊ាវ ហៅ ឌុច ("ឌុច") ផ្តល់យថាភាព ឬធ្វើសេចក្តីអត្ថាធិប្បាយ ក្នុងពេលជំនុំជម្រះក្តីគាត់ និងក្នុងពេលជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២។ ទោះបីជានៅក្នុងសក្ខីកម្មរបស់ ឌុច យើងត្រូវចែកឱ្យដាច់រវាងឯកសារដែលគាត់បានកំណត់អត្តសញ្ញាណ និងឯកសារដែលគាត់គ្រាន់តែស្មាន ក៏ដោយ ក៏ក្រុមមេធាវីការពារក្តីមិនជំទាស់ទេថា បញ្ជីអ្នកទោសត្រូវបានធ្វើនៅ ស-២១ ហើយអ្នកដែលមានឈ្មោះនៅក្នុងបញ្ជីទាំងនេះត្រូវបានសម្លាប់ ក្រោយពីឃុំខ្លួន។

១១៨១. ប៉ុន្តែ យើងត្រូវត្រឡប់មកនិយាយអំពីបញ្ជីអ្នកទោសចំនួន ៣ ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលត្រូវបានទទួលយកជាភ័ស្តុតាងនៅក្នុងសំណុំរឿង (ក) និងសៀវភៅបញ្ជីមួយដែលត្រូវបានទទួលយក នៅពេលការជំនុំជម្រះក្តីជិតចប់ទៅហើយ (ខ)។

### ក. បញ្ជីអ្នកទោសធ្វើឡើងដោយសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត

១១៨២. ទីមួយ គឺបញ្ជីអ្នកទោស ១២.២៧៣ នាក់ ដែលត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញា នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ នៅក្នុងសំណុំរឿង ០០១ និងត្រូវបានទទួលយកជាស្វ័យប្រវត្តិ នៅក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ (ឯកសារ E3/342)[1201]។ ទីពីរ គឺបញ្ជីអ្នកទោស ១៥.១០១ នាក់ នៅ ស-២១ ដែលត្រូវបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងទទួលយកដោយបញ្ញត្តដោយអង្គជំនុំជម្រះ នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦

[1201] អនុស្សរណៈ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ **ឯកសារ E302/5**។

(ឯកសារ E3/10604)[1202]។ បញ្ជីទីបីត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញា នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៦ ដែលមានអ្នកទោស ១.៦០៦ នាក់ ដែលមិនត្រូវបានដាក់បញ្ចូលក្នុងបញ្ជីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត (ឯកសារ E393/2.1)។ ទោះបីជាមានការជំទាស់ពីក្រុមមេធាវីការពារក្តីទៅនឹងបញ្ជីនេះ ដែលជាឯកសារការងារផ្ទៃក្នុងគាំទ្រដល់ការទាមទាររបស់សហព្រះរាជអាជ្ញារ ជាជាងភ័ស្តុតាង[1203] អង្គជំនុំជម្រះបានទទួលយកបញ្ជីនេះ នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦[1204]។ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាបានកែប្រែបញ្ជីចុងក្រោយរបស់ខ្លួន ដែលឥឡូវនេះ មានឈ្មោះអ្នកទោស ១៥៩២ នាក់[1205]។

១១៨៣. សូមបញ្ជាក់ថា បញ្ជីទាំងនេះមិនមែនជាភ័ស្តុតាងផ្ទាល់ទេ គឺគ្រាន់តែជាលទ្ធផលចេញពីការវិភាគភ័ស្តុតាងដែលមានស្រាប់។ អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីមិនជំទាស់ទៅនឹងការទទួលយកជាភ័ស្តុតាងនូវឯកសារ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតយកមកធ្វើជាមូលដ្ឋានសម្រាប់ធ្វើបញ្ជីនោះទេ[1206]។ ដូច្នេះ អង្គជំនុំជម្រះត្រូវធ្វើការសន្និដ្ឋាន ដោយផ្អែកលើភ័ស្តុតាង គឺមិនមែនផ្អែកលើបញ្ជី ដែលគ្រាន់តែជាមធ្យោបាយមួយសម្រាប់ឱ្យអង្គជំនុំជម្រះធ្វើជាសំអាងនោះទេ។ ការរំឭកនេះមានការចាំបាច់ ពីព្រោះបញ្ជីរបស់សហព្រះរាជអាជ្ញា ជាភាគីនៃរឿងក្តី ដែលមានភាពអគតិ គឺជាផ្លែផ្កានៃការវិភាគ និងបកស្រាយភ័ស្តុតាងដាក់បន្ទុក។

១១៨៤. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះត្រូវចៀសវាងទាញសេចក្តីសន្និដ្ឋានប្រញាប់ប្រញាល់ពេក ពីឯកសារនៅសម័យនោះ ដែលត្រូវបានប្រើប្រាស់សម្រាប់ធ្វើបញ្ជី។ ជាក់ស្តែង អ្នកខ្លះដែលមានឈ្មោះនៅក្នុងបញ្ជីទាំងនោះ អាចនៅរស់រហូតមកដល់សព្វថ្ងៃនេះ ឧទាហរណ៍ បុរសម្នាក់នៅលេខរៀង ១២៤៨ នៃបញ្ជីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាស នៅឆ្នាំ ២០០៣ និងឆ្នាំ ២០០៦...[1207]។

---

[1202]អនុស្សរណៈ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E393**។

[1203]ចម្លើយតបរបស់ ខៀវ សំផន ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E393/3/1**។

[1204]អនុស្សរណៈ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E393/4**។

[1205]សំណើសុំការកែតម្រូវរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៧ **ឯកសារ E393/2/Corr-1** និង **ឯកសារ E393/2.1/Corr-1**។

[1206]ប្រតិចារឹក ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E1/425.1** ទំព័រ ៤៨ មុនម៉ោង [១៣.៥២.០៣]។

[1207]បញ្ជីអ្នកទោស ស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត **ឯកសារ E3/10604** លេខរៀងទី ១២៤៨ ញ៉ែម សល់

## ខ. សៀវភៅបញ្ជី E3/10770

១១៨៥. យើងត្រូវតែនិយាយអំពីសៀវភៅបញ្ជីមួយ ដែលត្រូវបានទទួលយកនៅថ្ងៃចុងក្រោយនៃការបង្ហាញភស្តុតាង ហើយដែលការប្រព្រឹត្តិរបស់អង្គជំនុំជម្រះចោទជាបញ្ហា។ គឺឯកសារ E3/10770[1208]។ ឯកសារនេះបិទភ្ជាប់គ្នា ដែលត្រូវបានបង្ហាញថាជាសៀវភៅបញ្ជីដើម មានប្រហែល ២៥០ ទំព័រ មានតារាង ស-២១ ដែលត្រូវបានធ្វើឡើង ក្នុងអំឡុងឆ្នាំ ១៩៧៧ ("សៀវភៅបញ្ជី") និងទទួលបានតាមរយៈលោក Walter HEYNOWSKI។ ភាគីទើបតែទទួលបានការជូនដំណឹងអំពីអត្ថិភាពនៃសៀវភៅបញ្ជីនេះ នៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦[1209]។ ភាគីត្រូវបញ្ចេញយោបល់លើការទទួលយកឯកសារនេះ នៅក្នុងសវនាការថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦[1210]។ ភាគីមានពេលខ្លីពេក ចន្លោះពីពេលដឹងអំពីឯកសារដ៏ធំនេះ និងសវនាការអំពីការទទួលយកឯកសារ។ ដូច្នេះ ក្រុមមេធាវីការពារក្តីមិនមានលទ្ធភាពវិភាគលម្អិតទៅលើសៀវភៅបញ្ជីនេះទេ។ ក្រុមមេធាវីការពារក្តីបានលើកឧទាហរណ៍មួយអំពីភាពខុសគ្នាច្បាស់ក្រឡែត រវាងឯកសារមួយដែលមាននៅក្នុងសំណុំរឿងរួចហើយ និងទំព័រមួយនៃសៀវភៅបញ្ជីពាក់ព័ន្ធនឹងការចូលនៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៧៧[1211] ដោយលើកឡើងអំពីបញ្ហានៃភាពអាចជឿទុកចិត្តបាននៃឯកសារនេះ។

១១៨៦. ដូច្នេះ ក្រុមមេធាវីការពារក្តីបានស្នើសុំឱ្យកោះហៅមកសវនាការម្តងទៀតនូវសាក្សីពីរនាក់គត់ដែលអាចកំណត់យថាភាពនៃសៀវភៅបញ្ជីនោះបាន និងផ្តល់ការពន្យល់បញ្ហានេះ គឺ សួស ធី និង

---

ដែលនៅត្រង់បន្ទាត់នៃឈ្មោះនេះ មានការបញ្ជាក់ដូច្នេះថា៖ *"(D01139)-p.80 or (ERN01009876-01009981), and (D15712)-p.10 and p.11*។ បុគ្គលនេះត្រូវបានសម្ភាសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៣ *(TKI0280)* និងនៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៦ (សម្រាប់ចុះផ្សាយក្នុងទស្សនាវដ្តី "ស្វែងរកការពិត" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ដែល ក្នុងពេលនោះ គាត់បាននិយាយថា គេបានបញ្ជូនគាត់ពីមន្ទីរ ស-២១ ទៅព្រៃស ហើយគាត់បានរត់រួចខ្លួន។ *(D01139)-p.80* លើក ឡើងថា មនុស្សម្នាក់នេះចូល ស-២១ នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៦"។ (ភាសាអង់គ្លេស)

[1208] បញ្ជីក្តាប់កម្លាំងអ្នកទោសប្រចាំថ្ងៃ **ឯកសារ E3/10770**។

[1209] អនុស្សរណៈ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៧ **ឯកសារ E443/2**។

[1210] ប្រតិចារឹក ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/510.1** ទំព័រ ៦-១៦ ចន្លោះម៉ោង [០៩.១៥.៥៥] និង [០៩.៤៦.៣៥]។

[1211] ប្រតិចារឹក ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/510.1** ទំព័រ ១៥-១៦ ចន្លោះម៉ោង [០៩.៤២.១១] និង [០៩.៤៦.៣៥]។

ខុច[1212]។ គួរឱ្យភ្ញាក់ផ្អើលណាស់ សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់នៅនឹងសំណើនេះ[1213]។ ក្រុមមេធាវីការពារក្តីក៏បានស្នើសុំឱ្យកោះហៅលោក Walter HEYNOWSKI ដើម្បីសួរដេញដោលគាត់អំពីដំណើរការនៃការទទួលបានឯកសារនេះ។ សំណើសុំកោះហៅសាក្សីទាំងពីររូបនេះសាជាថ្មីត្រូវបានបដិសេធ ហើយក្រោយពីប៉ុនប៉ងជាច្រើនលើកច្រើនសា អង្គជំនុំជម្រះបានលះបង់ចោលការស្តាប់សក្ខីកម្មលោក Walter HEYNOWSKI។ អង្គជំនុំជម្រះបានទទួលយកសៀវភៅបញ្ជី នៅក្នុងអនុស្សរណៈ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦ គឺពីរសប្តាហ៍មុនពេលបញ្ចប់សវនាការលើអង្គសេចក្តី[1214]។

១១៨៧. ប្រឈមមុខនឹងកង្វះឯកសារច្បាប់ដើមស្ទើរតែទាំងស្រុង នៅក្នុងការជំនុំជម្រះក្តីនេះ ពិតជាគួរឱ្យសោកស្តាយណាស់ដែលឯកសារច្បាប់ដើមតែមួយគត់ បែរជាមិនសូវមានការយកចិត្តទុកទៅវិញ។ ទោះបីជាអង្គជំនុំជម្រះទទួលបានព័ត៌មានពីលោក Walter HEYNOWSKI ក៏ដោយ កាលៈទេសៈនៃការទទួលបានឯកសារនេះចោទជាបញ្ហាដែលមិនទទួលបានចម្លើយ។ ជាក់ស្តែង ឆ្លងតាមការឆ្លើយឆ្លងជាមួយអង្គជំនុំជម្រះ យើងមិនយល់ថា តើអ្នកណាជាអ្នកប្រគល់ឯកសារនេះជូនលោក Walter HEYNOWSKI ហើយតើគាត់អាចត្រឡប់ទៅប្រទេសអាល្លឺម៉ង់វិញ តាមរបៀបណា។

១១៨៨. រូបថតនៃសៀវភៅបញ្ជីនេះត្រូវបានថត ក្នុងពេលទទួល នៅ អ.វ.ត.ក។ គ្រាប់កិប ដែលយើងអាចមើលឃើញនៅលើរូបថតមួយចំនួន ចោទជាបញ្ហាអំពីរបៀបរៀបចំឯកសារពីដើមទីមក[1215]។ តើវាជាក្រដាសមួយសន្លឹកៗ ដែលត្រូវបានបិទភ្ជាប់គ្នាជាសៀវភៅបញ្ជី នៅសម័យកើតអង្គហេតុមែនទេ? តើក្រដាសទាំងនេះត្រូវបានបិទភ្ជាប់គ្នានៅពេលណា និងដោយអ្នកណា? តើតួលេខនៅលើឯកសារបិទភ្ជាប់គ្នានេះជាតួលេខអ្វី? តើអក្សរផ្សេងគ្នានៅលើឯកសារនេះជាអ្វី? តើចំណារត្រូវបានចុះនៅលើសៀវភៅបញ្ជីនេះ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដែរឬទេ? តើអ្នកណាជាអ្នកកាន់

---

[1212]ប្រតិចារឹក ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/510.1** ទំព័រ ១១-១៣ ចន្លោះម៉ោង [០៩.៣៣.៣៨] និង [០៩.៣៧.៤៩], ទំព័រ ១៥-១៦ ចន្លោះម៉ោង [០៩.៤២.១១] និង [០៩.៤៦.៣៥]។

[1213]ប្រតិចារឹក ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/510.1** ទំព័រ ១៤ ចន្លោះម៉ោង [០៩.៤០.៥៩] និង [០៩.៤២.១១]។

[1214]អនុស្សរណៈ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E443/3**។

[1215]រូបភាពចេញពីសៀវភៅកំណត់ហេតុពណ៌ទឹកក្រូច **ឯកសារ E3/10789** ERN 01376695, 01376712។

កាប់សៀវភៅបញ្ជីនេះ អស់រយៈពេលជាង ៤០ ឆ្នាំ នៅក្រៅប្រទេសកម្ពុជា? ប៉ុន្តែ សំណួរស្រប ច្បាប់ទាំងនេះ នៅក្នុងការជំនុំជម្រះក្តីដ៏ធំធេងនេះ នៅតែគ្មានចម្លើយ។

១១៨៩. ចំពោះអង្គជំនុំជម្រះ ការដែលគ្រាន់តែ សួស ធី ទទួលស្គាល់ថាគាត់បានកាន់បញ្ជីនេះ នៅពេលគាត់ធ្វើការនៅ ស-២១[1216] គឺគ្រប់គ្រាន់ហើយ មិនចាំបាច់កោះហៅគាត់មកវិញទេ[1217]។ អង្គជំនុំជម្រះគិតថា ភាគីបានសួរដេញដោលសាក្សី ឌុច និង សួស ធី គ្រប់គ្រាន់ហើយ ទៅលើខ្លឹមសារប្រមាណ ១២ ទំព័រ ស្រដៀងគ្នានឹងសៀវភៅបញ្ជីនេះ ដែលមាននៅក្នុងសំណុំរឿង នៅពេលសួរដេញដោលសាក្សីទាំងពីររូបនេះ[1218]។

១១៩០. ប៉ុន្តែ “១២ ទំព័រ” មិនអាចប្រៀបធៀបនឹង ២៥០ ទំព័រនៃសៀវភៅបញ្ជីបានទេ។ លើសពីនេះទៀត ភាពខុសគ្នា ដែលក្រុមមេធាវីការពារក្តីបានកត់សម្គាល់ឃើញ រវាងទំព័រមួយ ដែលទទួលយកនៅក្នុងសំណុំរឿង និងសៀវភៅបញ្ជីរបស់លោក Walter HEYNOWSKI ចោទជាបញ្ហា ដោយសារតែការវិភាគកាន់តែស៊ីជម្រៅអាចឱ្យទាញចេញបញ្ហាជាច្រើនទៀតពាក់ព័ន្ធនឹងឯកសារមួយនេះ។

១១៩១. យើងអាចសង្កេតឃើញថា ទំព័រជាច្រើនមានអក្សរសរសេរដោយទឹកប៊ិចពណ៌ផ្សេងគ្នា អាស្រ័យទៅតាមទំព័រ ឬនៅលើទំព័រតែមួយ[1219]។ លេខជាច្រើនត្រូវបានឆូតចោល និងកែ[1220]។ យើងឃើញមានអក្សរខុសគ្នា នៅលើទំព័រតែមួយ[1221]។ ដោយសារតែ សួស ធី ជាអ្នកកាន់សៀវភៅបញ្ជីនេះ គាត់គួរតែអាចឆ្លើយទៅនឹងសំណួរទាំងនេះបាន និងអាចកំណត់បានថា គំនូស ការឆូតចោល ឬ

---

[1216]ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/432.1** ទំព័រ ៥៧-៦០ ចន្លោះម៉ោង [១៤.៣០.៤៩] និង [១៤.៣៨.១៩]។

[1217]អនុស្សរណៈ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E443/3** កថាខណ្ឌ ៤។

[1218]អនុស្សរណៈ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E443/3** កថាខណ្ឌ ៤។

[1219]បញ្ជីក្តាប់កម្លាំងអ្នកទោសប្រចាំថ្ងៃ **ឯកសារ E3/10770** ឧទាហរណ៍ សូមមើលត្រង់ ERN 01355911, 01355931, 01355935, 01355978 និង 01356133។

[1220]បញ្ជីក្តាប់កម្លាំងអ្នកទោសប្រចាំថ្ងៃ **ឯកសារ E3/10770** ឧទាហរណ៍ សូមមើលត្រង់ ERN 01356053-54, 01356013-14។

[1221]បញ្ជីក្តាប់កម្លាំងអ្នកទោសប្រចាំថ្ងៃ **ឯកសារ E3/10770** ឧទាហរណ៍ សូមមើលត្រង់ ERN 01355908, 01355913, 01356112។

អក្សរខុសគ្នា មកពីគាត់ ឬអ្នកផ្សេងទៀតធ្វើការនៅ ស-២១ ឬអ្វីៗទាំងអស់នេះត្រូវបានធ្វើឡើងនៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។

១១៩២. បើគ្មានសក្ខីកម្មរបស់លោក Walter HEYNOWSKI ជាអ្នកកាន់កាប់បញ្ជីនេះអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ យើងមិនអាចដឹងថា តើគំនូស និងចំណារទាំងនេះមាន តាំងពីពេលគាត់ពិគ្រោះសៀវភៅបញ្ជីនេះលើកដំបូង ឬត្រូវបានបន្ថែមនៅពេលក្រោយ។ យើងមិនអាចសួរនាំគាត់អំពីកាលៈទេសៈនៃការទទួលបានឯកសារនេះ ក៏ដូចជារបៀបនៃការប្រើប្រាស់ និងរក្សាទុក។

១១៩៣. សេចក្តីសង្កេតទាំងនេះមានភាពចាំបាច់ ពីព្រោះ នៅក្នុងកាលៈទេសៈបែបនេះ អង្គជំនុំជម្រះទាញសេចក្តីសន្និដ្ឋានចេញពីការចន្លោះប្រហោង នៅក្នុងការទទួលយកសៀវភៅបញ្ជីនេះជាភ័ស្តុតាង។ ចំនួនមនុស្សឃុំ និងសម្លាប់ នៅ ស-២១ នាំឱ្យមានជជែកវែកញែកជាច្រើន ហើយអង្គជំនុំជម្រះនឹងប្រាកដជាប៉ុនប៉ងទាញសេចក្តីសន្និដ្ឋានលើបញ្ហានេះ ក្នុងពេលពិភាក្សាសម្រេច។ ប៉ុន្តែ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលបានរារាំងដល់ការឆ្លើយទៅនឹងសំណួរស្របច្បាប់ទាំងនេះស្តីពីភាពអាចជឿជាក់បាននៃឯកសារ E3/10770 នាំទៅដល់ការចាត់ទុកឯកសារនេះថាមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។ ដូច្នេះ អង្គជំនុំជម្រះត្រូវផាត់ចោលឯកសារនេះក្នុងពេលពិភាក្សាសម្រេច។

## ៣. អង្គហេតុក្រៅវិសាលភាពនៃការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២

១១៩៤. ទោះបីជាអង្គជំនុំជម្រះយល់ព្រមស្តាប់សាក្សីលើកឡើងអំពីអង្គហេតុ ដែលអាចកំណត់បានថាជាការរំលោភសេពសន្ថវៈ នៅ ស-២១ ក៏ដោយ ក៏អង្គហេតុទាំងនេះមិនស្ថិតនៅក្នុងបទចោទ ដែលលោក ខៀវ សំផន ត្រូវបានបញ្ជូនទៅជំនុំជម្រះនោះដែរ[1222]។ ដូច្នេះ ក្នុងពេលពិភាក្សាសម្រេច អង្គជំនុំជម្រះត្រូវផាត់ចោលនូវភ័ស្តុតាងដែលទទួលបាន ឬស្តាប់ឮ ពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ ដែលលោក ខៀវ សំផន មិនត្រូវបានចោទប្រកាន់។

[1222] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១៧១-២០៣។

១១៩៥. ចំពោះឧក្រិដ្ឋកម្មដែលទំនងជាត្រូវបានប្រព្រឹត្តនៅព្រៃស (ស-២៤) សហចៅក្រមស៊ើបអង្កេតបានសម្រេចពិនិត្យមើលអង្គហេតុនៅព្រៃស ដាច់ដោយឡែកពីអង្គហេតុ នៅ ស-២១[1223]។ ជាក់ស្តែងការពិនិត្យមើលអង្គហេតុពាក់ព័ន្ធនឹងព្រៃស ស្ថិតនៅក្នុងផ្នែកស្តីពីការដ្ឋានការងារ ចំណែកការពិនិត្យមើលអង្គហេតុនៅ ស-២១ ស្ថិតនៅក្នុងផ្នែកស្តីពីមន្ទីរសន្តិសុខ។ នៅក្នុងឧបសម្ព័ន្ធភ្ជាប់ទៅនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះបានរៀបរាប់លម្អិតពីកថាខណ្ឌនៃដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មនៅតាមការដ្ឋានការងារ។ ទីតាំងព្រៃសមិនមាននៅក្នុងកថាខណ្ឌទាំងនោះ[1224] ឬនៅកន្លែងផ្សេងទៀតនៃឧបសម្ព័ន្ធនោះទេ។ អាស្រ័យហេតុនេះ អង្គហេតុដែលអាចផ្តុំបានជាឧក្រិដ្ឋកម្មនៅព្រៃស មិនស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ នោះទេ។ ដូច្នេះ ក្នុងពេលពិភាក្សាសម្រេច អង្គជំនុំជម្រះត្រូវផាត់ចោលនូវភ័ស្តុតាងដែលទទួលបាន ឬស្តាប់ឮ ពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ ដែលលោក ខៀវ សំផន មិនត្រូវបានចោទប្រកាន់។

## ផ្នែកទី ៣. ការពិនិត្យមើលភ័ស្តុតាងពាក់ព័ន្ធ

១១៩៦. ដោយបានឃើញភ័ស្តុតាងទាំងអស់អំពី ស-២១ ជាពិសេស ចម្លើយរបស់ ឌុច ប្រធានមន្ទីរសន្តិសុខ និងចម្លើយរបស់អ្នកយាមដែលធ្វើការនៅទីនោះ ក្រុមមេធាវីការពារក្តីមិនជំទាស់ទេថា មានអង្គហេតុដែលអាចកំណត់ថាជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ (ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស) ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការប្រព្រឹត្តិដោយអមនុស្សធម៌ ការបង្កឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ ឬរបួសស្នាមធ្ងន់ធ្ងរដល់រូបកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ និងទៀងទាត់ ការឃុំខ្លួនជនស៊ីវិល ស្មើនឹងការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ ផ្ទុយទៅវិញ ចំពោះការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ការវិភាគភ័ស្តុតាងមិនអាចឱ្យសន្និដ្ឋានថាមានអង្គហេតុគ្រប់គ្រាន់ដើម្បីទទួលយកឧក្រិដ្ឋកម្មនេះឡើយ។

[1223] ដីកាដំណោះស្រាយ កថាខណ្ឌ ៩១៥។

[1224] ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ៣។

១១៩៧. នៅក្នុងដីកាដំណោះស្រាយ ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ចំពោះជនជាតិវៀតណាម សំអាងយ៉ាងទូលំទូលាយទៅលើអង្គហេតុដែលថា "បក្សកុម្មុយនីស្តកម្ពុជាចាត់ទុកជនជាតិវៀតណាមជាពូជសាសន៍ដទៃ ខុសពីពូជសាសន៍ខ្មែរ ដោយផ្អែកលើសែស្រឡាយខាងម្ដាយ។ [...] ជនជាតិវៀតណាមត្រូវបានកំណត់អត្តសញ្ញាណ និងកំណត់មុខសញ្ញាដោយចេតនា និងជាលក្ខណៈប្រព័ន្ធ ដោយផ្អែកលើមូលដ្ឋានពូជសាសន៍របស់គេ"[1225]។ នៅក្នុងការកត់សម្គាល់អំពីអង្គហេតុនៃឧក្រិដ្ឋកម្មនៅ ស-២១ សហចៅក្រមស៊ើបអង្កេតបានបរិយាយអំពីអង្គហេតុស្ដីពីវត្តមានអ្នកទោសវៀតណាមនៅ ស-២១ ការចាប់ខ្លួន គោលបំណងនៃការចាប់ខ្លួន និងការសម្លាប់[1226]។

## ១. វត្តមាន និងការចាប់ជនជាតិវៀតណាម នៅ ស-២១

### ក. វត្តមានជនបរទេសនៅ ស-២១

១១៩៨. បើតាមដីកាដំណោះស្រាយ នៅ ស-២១ អ្នកទោសភាគច្រើនជាជនជាតិខ្មែរ។ ក្រុមអ្នកទោសដែលសំខាន់ជាងគេ គឺអ្នកទោសដែលជាអតីតសមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជាគ្រប់លំដាប់ថ្នាក់ អតីតសមាជិកសេនាធិការ អតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និងបុគ្គលិកនៃមន្ទីរ ស-២១[1227] មនុស្សគ្រប់ប្រភេទវិជ្ជាជីវៈ ដែលមានទំនាក់ទំនងជាមួយអ្នកដែលសង្ស័យថាធ្វើសកម្មភាពប្រឆាំងនឹងរបបនោះ[1228]។ វត្តមាននៃជនបរទេសមួយចំនួន ក្នុងចំណោមអ្នកទោសនៅ ស-២១ ក៏ត្រូវបានលើកឡើងផងដែរ៖ ថៃ ឡាវ ឥណ្ឌា ពួកបស្ចិមប្រទេស និងវៀតណាម[1229]។ អង្គហេតុទាំងនេះមិនត្រូវបានជំទាស់ទេ នៅក្នុងសវនាការលើអង្គសេចក្ដី។

---

[1225] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២២។

[1226] ដីកាដំណោះស្រាយ កថាខណ្ឌ ៤៣៣, ៤៣៧-៤៣៨, ៤៥៤-៤៥៥, ៤៦៨។

[1227] ដីកាដំណោះស្រាយ កថាខណ្ឌ ៤២៤-៤៣១។

[1228] ដីកាដំណោះស្រាយ កថាខណ្ឌ ៤៣២។

[1229] ដីកាដំណោះស្រាយ កថាខណ្ឌ ៤៣៣។

## ខ. គ្មានព័ត៌មានអំពីចំនួនជនជាតិវៀតណាម នៅ ស-២១

១១៩៩. សាក្សី ឡាច មាន, ប្រាក់ ខន, ហ៊ីម ហ៊ុយ, សួស ធី, ឌុច និង នឹម អ៊ុំ បានបញ្ជាក់អះអាងនៅក្នុងសវនាការថា ជនជាតិវៀតណាមត្រូវបានឃុំនៅ ស-២១[1230]។ អ្នកខ្លះឆ្លើយថាបានឃើញតែទាហានវៀតណាម[1231] ឯអ្នកខ្លះទៀតថាបានឃើញជនស៊ីវិលផងដែរ[1232]។ ឌុច បានបញ្ជាក់ថាភាគច្រើនជាទាហានវៀតណាម[1233]។ ទោះបីជាបញ្ជីអ្នកទោសវៀតណាមមាននៅក្នុងសំណុំរឿងក៏ដោយ ចំនួនអ្នកទោសវៀតណាមសរុបមិនត្រូវបានពិភាក្សាដេញដោល នៅក្នុងសវនាការនោះទេ[1234]។ ឡាច មាន ឆ្លើយថាបានឃើញម្តង មានរថយន្តប្រហែលបីគ្រឿងដឹកជនជាតិវៀតណាមជាង ១០០ នាក់ចូល ស-២១[1235]។

## គ. គ្មានភាពច្បាស់លាស់ពាក់ព័ន្ធនឹងថ្ងៃដំបូងនៃការដឹកជនជាតិវៀតណាមចូល ស-២១

[1230] ឡាច មាន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E1/421.1** ទំព័រ ៧១ ប្រហែលម៉ោង [១៥.៣៣.០៣], ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E1/423.1** ទំព័រ ៧៨ ចន្លោះម៉ោង [១៥.៥៧.០៧] និង [១៥.៥៩.០៤]។ ហ៊ីម ហ៊ុយ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E1/427.1** ទំព័រ ៥៩ ចន្លោះម៉ោង [១៤.២៤.៤០] និង [១៤.២៧.១៩]។ សួស ធី ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E1/433.1** ទំព័រ ២៣-២៦ ចន្លោះម៉ោង [១០.៣៣.២៥] និង [១០.៤៤.៤៥]។ ឌុច ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ២៦-២៧ ចន្លោះម៉ោង [១១.០២.០៤] និង [១១.០៥.០០]។ នឹម អ៊ុំ ប្រតិចារឹក ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/474.1** ទំព័រ ៤៦ ចន្លោះម៉ោង [១៣.៥២.៣៧] និង [១៣.៥៤.១៦]។

[1231] ហ៊ីម ហ៊ុយ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E1/427.1** ទំព័រ ៥៩ ចន្លោះម៉ោង [១៤.២៤.៤០] និង [១៤.២៧.១៩]។

[1232] ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E1/423.1** ទំព័រ ៧៨ ចន្លោះម៉ោង [១៥.៥៧.០៧] និង [១៥.៥៩.០៤]។ សួស ធី ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E1/433.1** ទំព័រ ២៣-២៦ ចន្លោះម៉ោង [១០.៣៣.២៥] និង [១០.៤៤.៤៥]។

[1233] ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/436.1** ទំព័រ ៦០ ប្រហែលម៉ោង [១៥.០៩.០៤], ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ៧-៨ ចន្លោះម៉ោង [០៩.២៨.០២] និង [០៩.៣២.០១] ទំព័រ ២១ មុនម៉ោង [១០.៤០.៤៨] ទំព័រ ២៦-២៧ ចន្លោះម៉ោង [១១.០២.០៤] និង [១១.០៥.០០]។

[1234] ចំពោះបញ្ជីអ្នកទោសវៀតណាម សូមមើលជាអាទិ៍ **ឯកសារ E3/9423**, **E3/9424**, **E3/9525** និង **E3/9426**។

[1235] ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E1/421.1** ទំព័រ ៧១ មុនម៉ោង [១៥.៣៥.១០]។

១២០០. សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា បើតាមបញ្ជី ការចាប់ខ្លួនជនជាតិវៀតណាមលើកទីមួយបានធ្វើឡើងនៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៦[1236] និងបន្ទាប់មកទៀត អះអាងថា បើតាម ឌុច ជនជាតិវៀតណាមមួយចំនួនត្រូវបានចាប់ឃុំ ចាប់តាំងពីឆ្នាំ ១៩៧៥។ ប៉ុន្តែ ត្រង់ចំណុចទីមួយ មិនមានការយោងទៅលើបញ្ជីណាមួយនោះទេ ហើយត្រង់ចំណុចទីពីរ ចម្លើយរបស់ ឌុច នៅក្នុងការជំនុំជម្រះក្តីគាត់[1237] មានភាពផ្ទុយគ្នានឹងសក្ខីកម្មរបស់គាត់ នៅក្នុងសំណុំរឿង ០០២/០២។ តាមពិត នៅក្នុងសវនាការថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ ឌុច បានឆ្លើយថា បើតាមគាត់ចាំ វ៉ូ ឌិញង៉ូ ជាទាហានវៀតណាមដំបូងគេដែលត្រូវបានចាប់ខ្លួន នៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៨[1238]។

១២០១. ដោយសារតែសក្ខីកម្មកែប្រែរបស់ ឌុច និងយោងតាមចម្លើយរបស់សាក្សីផ្សេងទៀត កាលបរិច្ឆេទនៃការមកដល់របស់ជនជាតិវៀតណាមដំបូងគេ មិនអាចត្រូវបានបង្ហាញឱ្យបានច្បាស់នោះទេ។ តាមរយៈសក្ខីកម្មទាំងនេះ យើងអាចកំណត់បានថា ពេលជម្លោះប្រដាប់អាវុធជាមួយវៀតណាមឡើងកម្តៅខ្លាំង អ្នកទោសវៀតណាមជាច្រើនត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ គឺប្រហែលជានៅឆ្នាំ ១៩៧៧ ឬឆ្នាំ ១៩៧៨[1239]។ សាក្សីទាំងនេះនិយាយដូចៗគ្នាថា អ្នកទោសវៀតណាមភាគច្រើនត្រូវបានចាប់នៅព្រំដែនវៀតណាម ក្នុងពេលមានជម្លោះប្រដាប់អាវុធ[1240]។

## ២. លក្ខខណ្ឌនៃការឃុំខ្លួន និងសួរចម្លើយ

[1236] ដីកាដំណោះស្រាយ កថាខណ្ឌ ៤៣៣។

[1237] ប្រតិចារឹក សំណុំរឿង ០០១ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ **ឯកសារ** **E3/525** ទំព័រ ២។

[1238] ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/436.1** ទំព័រ ៥៨ ប្រហែលម៉ោង [១៥.០១.០៤], ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ៧-៨ ចន្លោះម៉ោង [០៩.២៣.២០] និង [០៩.៣២.០១]។

[1239] ឡាច មាន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E1/421.1** ទំព័រ ៧១ មុនម៉ោង [១៥.៣៥.១០], ប្រតិចារឹក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E1/422.1** ទំព័រ ២៥ ប្រហែលម៉ោង [១០.៤៨.២៤], ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E1/423.1** ទំព័រ ៧៨ ចន្លោះម៉ោង [១៥.៥៧.០៧] និង [១៥.៥៩.០៤]។ សួស ធី ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E1/433.1** ទំព័រ ២២ ចន្លោះម៉ោង [១០.៣០.៤៣] និង [១០.៣៣.២៥]។

[1240] ហ៊ីម ហ៊ុយ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E1/427.1** ទំព័រ ១៨-១៩ ក្រោយម៉ោង [០៩.៥៦.០០] ទំព័រ ៥៩ ចន្លោះម៉ោង [១៤.២៤.៤០] និង [១៤.២៧.១៩], ឌុច ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ២៦-២៧ ចន្លោះម៉ោង [១១.០២.០៤] និង [១១.០៥.០០]។

១២០២. ល័ក្ខខ័ណ្ឌឃុំខ្លួនជនជាតិវៀតណាមមិនត្រូវបានលើកឡើង នៅក្នុងដីកាដំណោះស្រាយ ឬក្នុងពេលសាក្សីមកផ្ដល់សក្ខីកម្មនៅក្នុងសវនាការនោះទេ។ ឌុច គឺជាសាក្សីសំខាន់ជាងគេបង្អស់នៃវគ្គស្ដីពី ស-២១ ហើយសក្ខីកម្មរបស់គាត់ជាស្នូលនៃការពិនិត្យភ័ស្ដុតាង។ បើតាម ឌុច ជនជាតិវៀតណាមត្រូវបានសួរចម្លើយឱ្យសារភាព ហើយចម្លើយសារភាពខ្លះត្រូវបានចាក់ផ្សាយតាមវិទ្យុ។ គោលដៅគឺដើម្បីបង្ហាញថា វៀតណាមមានគោលបំណងលុកលុយចូលកម្ពុជា និងបង្កើតសហព័ន្ធឥណ្ឌូចិន[1241]។ ម៉ម ណៃ អតីតបុគ្គលិក ស-២១ និង ផន ថនចាន់ អ្នកទោសដែលចេះនិយាយភាសាវៀតណាម ត្រូវបានចាត់តាំងឱ្យសួរចម្លើយអ្នកទោសវៀតណាម ដែលទទួលរងនូវការធ្វើបាននៅពេលនោះ[1242]។ ម៉ម ណៃ ក៏ត្រូវបានចាត់តាំងឱ្យសួរចម្លើយជនបរទេសមួយចំនួនដែលត្រូវបានឃុំនៅ ស-២១[1243]។

## ក. ឌុច តទល់នឹងចម្លើយរបស់ ផន ថនចាន់ ស្ដីពីការសួរចម្លើយយោធាវៀតណាម

១២០៣. នៅក្នុងកិច្ចសម្ភាសន៍ជាមួយលោក ប៉ាន់ រិទ្ធី សាក្សី ផន ថនចាន់ បានរៀបរាប់អំពីការសួរចម្លើយអ្នកទោសវៀតណាម និងការយល់ឃើញរបស់គាត់ចំពោះជម្លោះជាមួយវៀតណាម[1244]។ គាត់បានអះអាងថា អ្នកទោសវៀតណាមភាគច្រើននិយាយការពិត ក្នុងពេលសួរចម្លើយ គឺពួកគេគ្រាន់តែជា

---

[1241] ឌុច ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/436.1** ទំព័រ ៥៨ ចន្លោះម៉ោង [១៥.០១.០៤] និង [១៥.០៣.៣៣], ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ១១-១២ ចន្លោះម៉ោង [០៩.៤៥.៣៨] និង [០៩.៤៨.៣៣], ប្រតិចារឹក សំណុំរឿង ០០១ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ **ឯកសារ E3/525** ERN 00339792-93។

[1242] ឌុច ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/436.1** ទំព័រ ៥៨ ចន្លោះម៉ោង [១៥.០១.០៤] និង [១៥.០៣.៣៣], ឌុច ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ១២ ក្រោយម៉ោង [០៩.៤៨.៣៣] ទំព័រ ២១-២២ ប្រហែលម៉ោង [១០.៤០.៤៨], កំណត់ហេតុនៃការសួរចម្លើយ ឌុច ក្នុងសំណុំរឿង ០០១ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ **ឯកសារ E3/452** ERN 00146553, កំណត់ហេតុសួរចម្លើយ ឌុច នៅតុលាការយោធា ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៩ **ឯកសារ E3/528** ERN 00320781, កិច្ចសម្ភាស ឌុច ជាមួយអង្គការ UNHCR ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៩ **ឯកសារ E3/347** ERN 00160901។

[1243] ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E1/424.1** ទំព័រ ១៥ ប្រហែលម៉ោង [០៩.៤៦.០៤], ឌុច ប្រតិចារឹក ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/434.1** ទំព័រ ៥៩-៦០ ចន្លោះម៉ោង [១៥.១៥.០៣] និង [១៥.១៧.៣៩]។

[1244] កិច្ចសម្ភាស ផាន់ ចាន់ថន (អ្នករស់រានមានជីវិតនៅមន្ទីរ ស-២១) **ឯកសារ E3/2352R** ចន្លោះម៉ោង [00.៤៨.២១] និង [00.៥៤.៥១] (ប្រតិចារឹកនៃកិច្ចសម្ភាសនេះ គឺមានលេខឯកសារ E3/2352)។

ប្រជាជនសាមញ្ញដែលរត់ទៅថៃ ប៉ុន្តែ ពួកគេត្រូវបានបង្ខំឱ្យឆ្លើយថាពួកគេជាទាហាន ដើម្បីចាក់ផ្សាយចម្លើយសារភាពនៅតាមវិទ្យុ[1245]។ គេទំនងជាផ្តល់ឯកសណ្ឋាន និងផ្លាកសញ្ញាយោធា ឱ្យជនជាតិវៀតណាមទាំងនោះពាក់[1246]។

១២០៤. ពេលតទល់នឹងចម្លើយជាលាយលក្ខណ៍អក្សរនេះ ឌុច បានឆ្លើយថា ផន ថនចាន់ និយាយបំផ្លើស និងបានធ្វើការវិភាគជម្លោះប្រដាប់អាវុធ "ដែលបន្ទូរបន្ថយអ្វីដែលវៀតណាមបានធ្វើ"[1247]។ គាត់បានពន្យល់ជាអាទិ៍ថា ទាហានវៀតណាមពិតជាចូលលុកលុយមែន ហើយឯកសណ្ឋានជាយោធារបស់ពួកវៀតណាមដែលចាប់បាន[1248] ខុសពីការចោទប្រកាន់របស់ ផន ថនចាន់ ដែលថាឯកសណ្ឋានទាំងនេះត្រូវបានផ្តល់ជូនជនជាតិវៀតណាម។ ទោះបីជា ឌុច បានឯកភាពថា ជនស៊ីវិលមួយចំនួនតូចអាចត្រូវបានបង្ខំឱ្យឆ្លើយថាជាគិញក៏ដោយ ក៏គាត់នៅតែរក្សាចម្លើយយ៉ាងម៉ឺងម៉ាត់ថា នៅ ស-២១ អ្នកទោសវៀតណាមភាគច្រើនជាទាហាន[1249]។

## ខ. __អវត្តភាពក្នុងការសន្និដ្ឋានថាមានការប្រព្រឹត្តិខុសគ្នានៅលើអ្នកទោសវៀតណាម__

១២០៥. សហព្រះរាជអាជ្ញាក៏សួរតទល់ ឌុច ជាមួយនឹងឃ្លាមួយនៃសៀវភៅរបស់ ទុយ អ្នកសួរចម្លើយនៅ ស-២១ ដែលនិយាយអំពីផែនការសួរចម្លើយអ្នកទោសតាមវិធីថ្មីមួយ[1250]។ ផែនការខែ តុលា ឆ្នាំ ១៩៧៨ នេះ គឺត្រូវបន្ថយការវាយខ្មែរ ចំណែកឯជនបរទេស វៀតណាម និងពួកចក្រពត្តិសេអ៊ីអា ត្រូវប្រើវិធីដាច់ខាតរបស់ក្រុមពិសេស[1251]។ ឌុច បានពន្យល់ថា គាត់ពិតជាបានគ្រោងទុកថា

[1245] ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ២៤-២៥ ចន្លោះម៉ោង [១០.៥០.២៧] និង [១០.៥៧.០០]។

[1246] ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ២៤-២៥ ចន្លោះម៉ោង [១០.៥០.២៧] និង [១០.៥៧.០០]។

[1247] ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ២៥ ក្រោយម៉ោង [១០.៥៧.០០]។

[1248] ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ២៦ ប្រហែលម៉ោង [១១.០២.០៤]។

[1249] ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ២៧ ចន្លោះម៉ោង [១១.០២.០៤] និង [១១.០៥.០០]។

[1250] ប្រតិចារឹក ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/437.1** ទំព័រ ៣២-៣៣ ចន្លោះម៉ោង [១១.១១.១៧] និង [១១.២១.៥៧], សៀវភៅកំណត់ហេតុរបស់ ប៊ុន និង ទុយ **ឯកសារ E3/834** ERN 00077518។

[1251] សៀវភៅកំណត់ហេតុរបស់ ប៊ុន និង ទុយ **ឯកសារ E3/834** ERN 00077518។

នឹងឈប់សួរចម្លើយជនជាតិខ្មែរ ក្នុងពេលណាមួយ ហើយផ្តោតលើជនបរទេស វៀតណាម និង សមាជិកសេអ៊ីអាតាមសន្ទូត[1252]។ ប៉ុល ពត ថែមទាំងបានសុំឱ្យបញ្ឈប់ការសួរចម្លើយទាំងអស់នៅ ស-២១[1253]។ សាក្សីបានបញ្ជាក់ថា គាត់បានផ្សព្វផ្សាយបន្តសេចក្តីណែនាំដល់អ្នកធ្វើការក្រោម បង្គាប់របស់គាត់។ ប៉ុន្តែ ក្រោយមក "បងនួន" បានហៅគាត់ទៅជួប ហើយសើចចំអកឱ្យគាត់ថា គាត់ "ដឹងច្បាស់មាគ៌ាបក្ស"។ ពេលនោះ ឌុច បានរៀបចំកិច្ចប្រជុំមួយជាមួយអ្នកធ្វើការក្រោម បង្គាប់របស់គាត់ ដើម្បីបញ្ជាឱ្យពួកគេបន្តសួរចម្លើយទាំងខ្មែរ និងបរទេស[1254]។ ក្រៅពីចម្លើយ របស់ ឌុច អំពីផែនការបរាជ័យក្នុងការផ្លាស់ប្តូរវិធីសួរចម្លើយ គ្មានខ្លឹមសារនៃចម្លើយរបស់សាក្សី ផ្សេងទៀតអាចឱ្យអះអាងថា អ្នកទោសបរទេសត្រូវបានប្រព្រឹត្តខុសពីខ្មែរនោះទេ។

## គ. ការចាប់ទាហានវៀតណាម ភាគច្រើន នៅតាមព្រំដែន

១២០៦. នៅពេលសួរតទល់ជាមួយនឹងឃ្លាផ្សេងទៀតនៃសៀវភៅរបស់អ្នកសួរចម្លើយ អំពីបញ្ហាជនជាតិ វៀតណាមលាក់ខ្លួននៅកម្ពុជា ដែលអ្នកខ្លះត្រូវចាប់បាននៅភូមិភាគពាយ័ព្យ[1255] ឌុច បានបញ្ជាក់ថា ពួកនេះជាទាហានវៀតណាមនៅតាមព្រំដែន ហើយគាត់មិនចាំអំពីវៀតណាម ដែលចាប់បាននៅ ភូមិភាគពាយ័ព្យនោះទេ[1256]។ គាត់បានបន្ថែមថា ជនស៊ីវិលវៀតណាមទាំងអស់ត្រូវបានបញ្ជូន ត្រឡប់ទៅប្រទេសវៀតណាមវិញ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដោយសារកិច្ចព្រម ព្រៀងរវាង ប៉ុល ពត និង ឡេ យួន ដោយ ឡេ យួន ចង់ឱ្យវៀតណាមត្រឡប់ទៅវិញ ដើម្បីចូលរួម ក្នុងការបោះឆ្នោតនាពេលខាងមុខ[1257]។

---

[1252]ប្រតិចារឹក ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ** E1/437.1 ទំព័រ ៣៣ ចន្លោះម៉ោង [១១.១៣.៥៩] និង [១១.១៧.៤៤]។

[1253]ប្រតិចារឹក ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ** E1/437.1 ទំព័រ ៣៣ ក្រោយម៉ោង [១១.១៧.៤៤]។

[1254]ប្រតិចារឹក ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ** E1/437.1 ទំព័រ ៣១-៣៤ ចន្លោះម៉ោង [១១.១១.១៧] និង [១១.២១.៥៧]។

[1255]ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ** E1/436.1 ទំព័រ ៦៣-៦៤ ចន្លោះម៉ោង [១៥.២០.៥៤] និង [១៥.២៦.៤៤]។

[1256]ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ** E1/436.1 ទំព័រ ៦៥ ចន្លោះម៉ោង [១៥.២៦.៤៤] និង [១៥.២៨.៤៥]។

[1257]ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ** E1/436.1 ទំព័រ ៦៥-៦៦ ចន្លោះម៉ោង [១៥.២៨.៤៥] និង [១៥.៣៣.៤៥]។

## ឃ. ខ្សែភាពយន្តឃោសនា និងទាហានវៀតណាម

១២០៧. សាក្សី ឡាច មាន និង ហ៊ឹម ហ៊ុយ បានលើកឡើងអំពីការថត និងចាក់ផ្សាយខ្សែភាពយន្តមួយឱ្យបុគ្គលិក ស-២១ មើល ដែលមានឆាកបង្ហាញអំពីទាហានវៀតណាម[1258]។ ឌុច ក៏បានទទួលស្គាល់ថា ខ្សែភាពយន្តស្តីពីទាហានវៀតណាមត្រូវបានថតដោយ សេង លីថេង ជាក្មួយប្រុសរបស់ ប៉ុល ពត[1259]។ ប៉ុន្តែ គាត់មិនទទួលស្គាល់ឈុតដកស្រង់ដែលចៅក្រម Jean-Marc LAVERGNE បានចាក់បញ្ចាំងឱ្យគាត់មើលទេ[1260]។ ដោយជំទាស់តវ៉ាទៅលើសក្ខីកម្មរបស់ ហ៊ឹម ហ៊ុយ និង ឡាច មាន ដែលសម្រេចជាក់លាក់មួយនេះមិនត្រូវបានចាក់បញ្ចាំងឱ្យមើល ឌុច ធានាអះអាងថា ខ្សែភាពយន្ត ដែលត្រូវបានដកស្រង់នេះ មិនត្រូវបានចាក់បញ្ចាំងនៅ ស-២១ នោះទេ[1261]។ ដើម្បីជាការគាំទ្រដល់ការអះអាងនេះ ឌុច បានកត់សម្គាល់ឃើញអំពីភាពខុសគ្នានៃការតែងលម្អផ្ទះរបស់គាត់ ធៀបទៅនឹងផ្ទះរបស់គាត់នៅសម័យនោះ ដែលបង្ហាញថា ឈុតឆាកនេះ គឺជា "ការប្រឌិតសុទ្ធសាធ និងត្រូវបានថតនៅពេលក្រោយ" ដូចឆាកទាហានវៀតណាមដើរជាក្បួន នៅជិតមហាវិថីម៉ៅសេទុង ដែរ[1262]។ ចំពោះ សួស ធី វិញ គាត់បានឆ្លើយថាគាត់មិនចាំអំពីការចាក់បញ្ចាំងខ្សែភាពយន្តនេះ នៅក្នុងវគ្គរៀនសូត្រទេ។ នៅពេលចៅក្រម Jean-Marc LAVERGNE ចាក់បញ្ចាំងឈុតដកស្រង់ដដែលឱ្យគាត់មើលដូច ឌុច ដែរ គាត់ឆ្លើយថាគាត់នឹកមិនឃើញអ្វីទេ[1263]។

១២០៨. គួរកត់សម្គាល់ត្រង់ចំណុចនេះថា សេង លីថេង បានអះអាងនៅក្នុងសវនាការថា គាត់បានថតខ្សែភាពយន្តមួយស្តីពីអ្នកទោសវៀតណាម[1264] ហើយគាត់ចាំថា គាត់បានថតខ្សែភាពយន្តនោះនៅ

---

[1258] ឡាច មាន ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E1/422.1** ទំព័រ ២៥-២៧ ចន្លោះម៉ោង [១០.៤៨.២៤] និង [១០.៥៦.១០], ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ E1/427.1** ទំព័រ ៦០-៦១ ចន្លោះម៉ោង [១៤.២៩.៣៣] និង [១៤.៣៤.០៩]។

[1259] ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/436.1** ទំព័រ ៦១ ប្រហែលម៉ោង [១៥.១៣.១៩]។

[1260] ភាពយន្តឯកសារ *Cambodia Kampuchéa* **ឯកសារ E3/2354R** ចន្លោះម៉ោង [០០.១៣.២៩] និង [០០.១៣.៤០]។

[1261] ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ២៨-៣០ ចន្លោះម៉ោង [១១.០៨.២០] និង [១១.១៥.០៦]។

[1262] ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ៣០-៣១ ក្រោយម៉ោង [១១.១៥.០៦]។

[1263] ប្រតិចារឹក ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/431.1** ទំព័រ ៦៥ ក្រោយម៉ោង [១៥.៤២.១៦]។

[1264] ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/503.1** ទំព័រ ៥១-៥២ ចន្លោះម៉ោង [១៤.២៣.២១] និង

ភ្នំពេញ និងមានរយៈពេលខ្លី ហើយនិយាយតែអំពីទាហានវៀតណាមតែម្នាក់ប៉ុណ្ណោះ[1265]។ ដូច្នេះ ការរៀបរាប់នេះមិនត្រូវគ្នានឹងខ្សែភាពយន្ត (ឯកសារ E3/2354R) ដែលបានចាក់បញ្ចាំងនៅក្នុងសវនាការនោះទេ។ ក្រោយមក ខ្សែភាពយន្តរបស់ សេង លីថេង និងកាម៉េរ៉ា ទំនងជាត្រូវបានប្រគល់ឱ្យចិន[1266]។

១២០៩. សូមរំឮកថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងក្នុងអំឡុងពេលក្រោយរបបនេះ ខ្មែរ ក៏ដូចជាវៀណាម និងចិន បានប្រើប្រាស់ខ្សែភាពយន្តដែលត្រូវបានរៀបចំជាសេណារីយោ និងកាត់តគ្រប់បែបយ៉ាង សម្រាប់ការឃោសនារៀងៗខ្លួន។ សក្ខីកម្មផ្សេងៗអំពីខ្សែភាពយន្តឃោសនា ដែលត្រូវបានថតនៅ ស-២១ មិនអាចឱ្យសន្និដ្ឋានថាសម្រង់ខ្សែភាពយន្តដែលចាក់បញ្ចាំងដោយចៅក្រម Jean-Marc LAVERGNE ពិតជាខ្សែភាពយន្តដែលបានចាក់បញ្ចាំងឱ្យបុគ្គលិក ស-២១ មើលនោះទេ។ ព័ត៌មានតែមួយគត់ ដែលមិនមានការជំទាស់តវ៉ា គឺថាមានទាហានវៀតណាម នៅ ស-២១ ដែលចម្លើយសារភាពត្រូវបានប្រើប្រាស់សម្រាប់គោលដៅឃោសនា។

### ខ. ជនស៊ីវិលវៀតណាម នៅ ស-២១ ជាតិញដូចអ្នកផ្សេងដែរ

១២១០. ឌុច បានអះអាងថា ជនស៊ីវិលវៀតណាមត្រូវបានចាត់ទុកជាខ្មាំង[1267]។ ប៉ុន្តែ យើងមិនអាចសន្និដ្ឋានថា គេប្រព្រឹត្តទៅលើជនស៊ីវិលវៀតណាមខុសពីគេ ដោយសារតែពួកគេជនជាតិវៀតណាមនោះទេ ដោយហេតុថាសក្ខីកម្មផ្សេងៗបានបញ្ជាក់ថា ជនបរទេសភាគច្រើនដែលគេចាប់បាន ជាអាទិ៍ ពួកបស្ចិមប្រទេស និងអ្នកនេសាទថៃប៉ុន្មាននាក់ ក៏ត្រូវបានចុះឈ្មោះជាតិញដែរ[1268]។ម្យ៉ាងទៀត

---

[១៩.២៧.៤៥]។

[1265] ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/503.1** ទំព័រ ៥១-៥២ ចន្លោះម៉ោង [១៤.២៤.៣៣] និង [១៤.៣០.០៩]។

[1266] ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/503.1** ទំព័រ ៥៣ ក្រោយម៉ោង [១៤.៣០.០៩]។

[1267] ឌុច ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/436.1** ទំព័រ ៦០ ប្រហែលម៉ោង [១៥.០៩.០៤], ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦, ឌុច **ឯកសារ E1/439.1** ទំព័រ ៨ ប្រហែលម៉ោង [០៩.៣២.០១] ទំព័រ ២០-២១ ចន្លោះម៉ោង [១០.១៥.២១] និង [១០.៤០.៤៨] ទំព័រ ២៧ ប្រហែលម៉ោង [១១.០៥.០០]។

[1268] ឡាច មាន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E1/421.1** ទំព័រ ៧៧-៧៨ ចន្លោះម៉ោង [១៥.៥៤.៥៤] និង [១៥.៥៦.៥២]។ ឌុច ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/439.1** ទំព័រ ២១ ក្រោយម៉ោង [១០.៤០.៤៨]។

ឌុច បានឆ្លើយនៅក្នុងសវនាការថា៖ "ភារកិច្ចចម្បងរបស់ ស-២១ គឺប្រឆាំងនឹងចារកម្ម ប្រឆាំងនឹងគិញ មកពីវៀតណាម អាមេរិក ឬប្រទេសផ្សេងទៀត"[1269]។

១២១១. ដូច្នេះ ជនជាតិវៀតណាមត្រូវបានចាត់ទុកជាអ្នកប្រឆាំងនឹងបដិវត្តន៍ ដូចភ្នាក់ងារសេអ៊ីអា និងភ្នាក់ងារកាហ្សេបេដែរ។ ម្យ៉ាងវិញទៀត អ្នកសួរចម្លើយបានទទួលការណែនាំឱ្យស្វែងរកទំនាក់ទំនងរវាងអ្នកទោស ជាមួយខ្សែរយៈសេអ៊ីអា កាហ្សេបេ និងបក្សពលករវៀតណាម[1270]។ ជាក់ស្តែង ឌុច បានពន្យល់ថា នេះគ្រាន់តែជាការដាក់ឈ្មោះ ដើម្បីកម្ទេចអ្នកដែលជាឧបសគ្គរាំងស្ទះដល់របប[1271]។ គាត់បានបន្ថែមថា៖ "ការកម្ទេចតម្រង់ទិសដៅទៅលើអ្នកដែលប្រឆាំងបដិវត្តន៍"[1272]។ ហ៊ឹម ហ៊ុយ បានឆ្លើយក្នុងន័យដូចគ្នានេះថា "ក្នុងវគ្គរៀនសូត្រ គេប្រាប់យើងថា អ្នកដែលអង្គការចាប់បាន គឺជាខ្មាំងប្រឆាំងនឹងអង្គការ"[1273]។ ជារួម អ្នកដែលបញ្ជូនទៅ ស-២១ ត្រូវបានចាត់ទុកជាជនក្បត់ជាតិ ឬជាទូទៅ ខ្មាំង[1274] ដោយគ្មានការបែងចែកសញ្ជាតិ។

## ផ្នែកទី ៤. ការកំណត់ប្រភេទបទល្មើស

### ១. និយមន័យនៃការធ្វើទុក្ខបុកម្នេញ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)

១២១២. ធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញរួមមានអំពើសកម្ម ឬអកម្ម ដែលនាំឱ្យមានការរើសអើងតាមព្រឹត្តិន័យ និងបដិសេធ និងរំលោភសិទ្ធិជាមូលដ្ឋាន ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ឬអនុសញ្ញា[1275]។ ចំពោះការរើសអើងដែលតម្រូវឱ្យមាន ដើម្បីផ្គុំបានជាធាតុផ្សំសត្យានុម័តិ៖

---

[1269]ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ** E1/441.1 ទំព័រ ៦៣ ប្រហែលម៉ោង [១៥.០៦.៣៦]។

[1270]ឡាច មាន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ** E1/421.1 ទំព័រ ៧៨ ប្រហែលម៉ោង [១៥.៥៦.៥២]។

[1271]ឌុច ប្រតិចារឹក ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ** E1/435.1 ទំព័រ ៤៤-៤៥ ចន្លោះម៉ោង [១៤.០៥.៣៣] និង [១៤.០៨.១៤]។

[1272]ប្រតិចារឹក ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ** E1/435.1 ទំព័រ ៤៥ ប្រហែលម៉ោង [១៤.០៨.១៤]។

[1273]ប្រតិចារឹក ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ **ឯកសារ** E1/427.1 ទំព័រ ៤ ប្រហែលម៉ោង [០៩.១០.៣៦]។

[1274]ឡាច មាន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ** E1/421.1 ទំព័រ ៧៧-៧៨ ចន្លោះម៉ោង [១៥.៥៤.៥៤] និង [១៥.៥៦.៥២]។ ឌុច ប្រតិចារឹក ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ** E1/438.1 ទំព័រ ៤០ ចន្លោះម៉ោង [១៣.៥២.១២] និង [១៣.៥៧.២០]។

[1275]សាលក្រម ០០២/០១ កថាខណ្ឌ ៤២៧, សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២២៦។

"ការរើសអើងជាក់ស្តែងកើតមានឡើង នៅពេលដែលជនរងគ្រោះណាម្នាក់ត្រូវបានគេកំណត់ជាគោលដៅ ដោយសារតែជនរងគ្រោះនោះជាសមាជិកនៅក្នុងក្រុមណាមួយ ដែលចារីបានកំណត់ដោយផ្អែកលើមូលហេតុជាក់លាក់មួយចំនួន ពោលគឺ មូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ហើយជនរងគ្រោះនោះត្រូវតែស្តែងឱ្យឃើញច្បាស់លាស់គ្រប់គ្រាន់ថា គាត់បានស្ថិតក្នុងក្រុមនយោបាយ ពូជសាសន៍ ឬសាសនាណាមួយ ដែលផលវិបាកនៃការធ្វើទុក្ខបុកម្នេញដែលជាល័ក្ខខ័ណ្ឌតម្រូវនោះត្រូវតែកើតមានទៅលើក្រុមនោះ"[1276]។

១២១៣. ធាតុផ្សំអត្តនោម័តិដែលតម្រូវឱ្យមាន ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ទាមទារឱ្យបង្ហាញឱ្យឃើញអំពីការប្រព្រឹត្តអំពើសកម្ម ឬអកម្ម ដោយមានចេតនារើសអើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[1277]។

## ២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ

១២១៤. ភ័ស្តុតាងបង្ហាញថា អ្នកទោសវៀតណាមពិតជាត្រូវបានឃុំ នៅ ស-២១ ក្នុងអំឡុងឆ្នាំ ១៩៧៧ ឬឆ្នាំ ១៩៧៨។ ពួកគេពិតជាត្រូវបានចាប់ខ្លួន ឃុំ និងសួរចម្លើយឱ្យសារភាព និងប្រហែលជាត្រូវបានធ្វើបាប មុននឹងសម្លាប់ចោល។ ពិតណាស់ថា អំពើទាំងនេះត្រូវបានប្រព្រឹត្ត ដោយរំលោភសិទ្ធិជាមូលដ្ឋានរបស់អ្នកទោសទាំងនេះ ប៉ុន្តែ គ្មានការរើសអើងតាមព្រឹត្តិន័យ ដោយមូលហេតុពូជសាសន៍នោះទេ។ ជាក់ស្តែង អំពើទាំងនេះមិនបានសំដៅតែទៅលើជនជាតិវៀតណាម ដោយមូលហេតុពូជសាសន៍នោះឡើយ គឺសំដៅទៅលើអ្នកទោសទាំងអស់ នៅ ស-២១ ក្នុងឋានៈជាអ្នកប្រឆាំងនឹងរបប។

១២១៥. ការចាប់ខ្លួនជនជាតិវៀតណាមភាគច្រើនកើតឡើង ដោយសារតែមានជម្លោះប្រដាប់អាវុធជាមួយវៀតណាម។ ដូច្នេះ ចម្លើយសារភាពរបស់អ្នកទោសវៀតណាមអាចត្រូវបានចាក់ផ្សាយតាមវិទ្យុ។ ទោះជាយ៉ាងនេះក្តី ការវិភាគទៅលើភ័ស្តុតាងបានបង្ហាញឱ្យឃើញថា ជនជាតិវៀតណាម ក៏ដូចជាអ្នកទោសផ្សេងទៀតដែរ ត្រូវបានចាត់ទុកជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។ កំណត់ហេតុស្តាប់

---

[1276]សាលក្រម ០០២/០១ កថាខណ្ឌ ៩២៨, សាលដីកា ០០២/០១ កថាខណ្ឌ ៦៦៧។

[1277]សាលក្រម ០០២/០១ កថាខណ្ឌ ៩២៧, សាលដីកា ខុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២២៦។

ចម្លើយសាក្សីបញ្ជាក់ថា ជនស៊ីវិលបរទេសទាំងអស់ត្រូវបានចាត់ទុកជាគិញសេអ៊ីអា កាហ្សេបេ ឬវៀតណាម។ ជនជាតិវៀតណាមត្រូវបានសម្លាប់នៅជិតអគារទួលស្លែង គឺមិនមែននៅជើងឯក ហើយអ្នកទោសផ្សេងទៀត ជាអាទិ៍ បុគ្គលិក ស-២១ កម្មាភិបាលជាន់ខ្ពស់ និងពួកបស្ចិមប្រទេស ក៏ត្រូវបានសម្លាប់នៅជិត ស-២១ ដែរ។ អាស្រ័យហេតុនេះ គ្មានការរើសអើងតាមព្រឹត្តិន័យទៅលើជនជាតិវៀតណាមនោះទេ។

១២១៦. ភ័ស្តុតាងបង្ហាញថា ភ្នាក់ងារសេអ៊ីអា កាហ្សេបេ ឬវៀតណាម គ្រាន់តែជាការដាក់ឈ្មោះ ដើម្បីកម្ទេចអ្នកដែលប្រឆាំងនឹងរបប។ អ្នកទោស នៅ ស-២១ ត្រូវបានចាត់ទុកជាខ្មាំងរបស់របបនោះ និងទុកសម្រាប់សម្លាប់ចោល (បើតាមសក្ខីកម្ម)។ ជនបរទេសទាំងអស់ (ជនជាតិវៀតណាមក៏មិនខុសគ្នាដែរ) ត្រូវបានចាត់ទុកជាគិញ គឺអ្នកប្រឆាំងនឹងរបប។ ភ័ស្តុតាងទាំងនេះមិនអាចបង្ហាញអំពីចេតនារើសអើង ដោយមូលហេតុពូជសាសន៍ឡើយ។

១២១៧. នេះជាទឡ្ហីករណ៍របស់អង្គជំនុំជម្រះ នៅក្នុងសំណុំរឿង ឌុច[1278]។ ជាក់ស្តែង ឌុច ត្រូវបានផ្តន្ទាទោសដោយអង្គជំនុំជម្រះសាលាដំបូង ពីបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពីព្រោះអ្នកទោសនៅ ស-២១ ត្រូវបានកំណត់មុខសញ្ញាថាជាអ្នកប្រឆាំងនឹងរបប[1279]។ ក្នុងការវិភាគរបស់ខ្លួន អង្គជំនុំជម្រះបាននិយាយសំដៅដល់អ្នកទោសវៀតណាមទាំងអស់ ដោយបានសន្និដ្ឋានថាពួកគេត្រូវបានធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ជាការពិត បើតាមអង្គជំនុំជម្រះ "គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ទាក់ទងនឹងជនជាតិវៀតណាម និងជនជាតិភាគតិច ឬក្រុមសាសនាផ្សេងទៀត ចាត់ទុកបុគ្គលទាំងនេះជាគិញ ដែលប្រឆាំងនឹងបក្ស"[1280]។ ភ័ស្តុតាងដែលបានពិនិត្យមើលនៅក្នុងសំណុំរឿង ០០២/០២ មិនមានផ្តល់អ្វីថ្មី ដែលអាចឱ្យកែប្រែសេចក្តីសន្និដ្ឋាននេះឡើយ។

១២១៨. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះតុលាការកំពូលមិនបានជំទាស់នឹងអង្គជំនុំជម្រះសាលាដំបូងទៅលើចំណុចនេះទេ ប៉ុន្តែ បានកែប្រែសេចក្តីសន្និដ្ឋានស្តីពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

---

[1278] សាលក្រម ឌុច ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៨៦-៣៨៧។

[1279] សាលក្រម ឌុច ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៨១-៣៨៦។

[1280] សាលក្រម ឌុច ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៨៦។

ពាក់ព័ន្ធនឹងចំនួនកំណត់នៃអ្នកទោស ស-២១ ដែលត្រូវបានកំណត់គោលដៅដោយមិនរើសមុខ[1281]។ ជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា៖

> "ទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលបដិវត្តន៍កំពុងឆ្ពោះទៅមុខ បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួន ធ្វើបាប និងបោសសម្អាត ដោយមិនរើសមុខ និងដោយគ្មានការធ្វើយុត្តិកម្មដ៏សមហេតុផល ដោយមូលហេតុនយោបាយនោះទេ។ សកម្មភាពបែបនេះមិនមែនជាការធ្វើទុក្ខបុកម្នេញតទៅទៀតនោះទេ ប៉ុន្តែ បង្កើតឱ្យមានការភ័យខ្លាច ដែលពុំមានលក្ខណៈវិនិច្ឆ័យដែលស្តែងឱ្យឃើញក្នុងការកំណត់គោលដៅលើជនរងគ្រោះឡើយ"[1282]។

១២១៩. ដូច្នេះ អង្គជំនុំជម្រះក៏ត្រូវពិចារណាទៅលើទឡ្ហីករណ៍នេះផងដែរ ក្នុងក្របខ័ណ្ឌនៃការពិនិត្យមើលអង្គហេតុនៅ ស-២១។ ទោះជាយ៉ាងណាក៏ដោយ យោងតាមភ័ស្តុតាងនៅក្នុងសំណុំរឿង គ្មានធាតុផ្សំណានៃឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ទៅលើជនជាតិវៀតណាម ត្រូវបានរកឃើញនោះទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចផ្តន្ទាទោសជនជាប់ចោទចំពោះឧក្រិដ្ឋកម្មនេះបានឡើយ។

## ជំពូកទី ២. ក្រាំងតាចាន់

### ផ្នែកទី ១. បទចោទ

១២២០. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់អំពីអង្គហេតុកើតឡើងនៅមន្ទីរសន្តិសុខក្រាំតាចាន់ ដែលត្រូវបានកំណត់ដោយសហចៅក្រមស៊ើបអង្កេតថាជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស និងការបាត់ខ្លួនដោយបង្ខំ) ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1283]។

[1281] សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៨៤។

[1282] សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៨៣។

[1283] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៨១, ១៣៩១, ១៤០២, ១៤០៨, ១៤២២, ១៤១៦, ១៤៣៤ និង ១៤៧០, សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ** E301/9/1 កថាខណ្ឌ ៤៤, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ** E301/9/1.1 ទំព័រ ៣-៦។

១២២១. ការចោទប្រកាន់អំពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ចំពោះអង្គហេតុដែលបានប្រព្រឹត្តទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មិនត្រូវបានពិភាក្សានៅទីនេះទេ គឺនឹងត្រូវពិនិត្យខាងក្រោម ក្នុងជំពូកស្តីពីជោគវាសនារបស់បុគ្គលទាំងនេះ ក្នុងកម្ពុជាប្រជាធិបតេយ្យ[1284]។

១២២២. ការពិនិត្យលើបទចោទផ្សេងទៀតអាចឱ្យកំណត់អំពីវិសាលភាពនៃអង្គហេតុ ដែលដាក់ជូនអង្គជំនុំជម្រះពិចារណា។ ជួនកាល សហចៅក្រមស៊ើបអង្កេតធ្វើហួសវិសាលភាពនៃបណ្តឹង ពាក់ព័ន្ធនឹងអាណត្តិការងារ ដែលសហព្រះរាជអាជ្ញាបានប្រគល់ជូនពីដំបូង។

## ១. អំពើមនុស្សឃាត

១២២៣. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៧៣ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាត ទៅលើ "ជនដែលត្រូវបានសម្លាប់នៅតាមមន្ទីរសន្តិសុខនានា" ឧទាហរណ៍ ក្រាំងតាចាន់។ សហចៅក្រមស៊ើបអង្កេតបានបន្ថែមនៅកថាខណ្ឌ ១៣៧៤ ថា "ការស្លាប់របស់ជនរងគ្រោះ គឺជាលទ្ធផលអំពើសកម្ម ឬអកម្មនៃចារី ដែលជាមូលហេតុចម្បងនៃការស្លាប់របស់ជនរងគ្រោះ"។

១២២៤. នៅកថាខណ្ឌ ១៣៧៦ សហចៅក្រមស៊ើបអង្កេតផ្តល់ព័ត៌មានលម្អិតអំពីការស្លាប់ ដែលកើតឡើងនៅតាមមន្ទីរសន្តិសុខនានា ដូចមានរៀបរាប់នៅកថាខណ្ឌ ១៣៧៣៖

> "ទាក់ទងដល់**មន្ទីរសន្តិសុខនានា** នៅក្នុងរបបនោះ បុគ្គលិកមន្ទីរសន្តិសុខ គឺជាអ្នកដែលបានបង្កដោយផ្ទាល់ ឬដោយប្រយោល ឱ្យមានការស្លាប់បាត់បង់ជីវិតដល់ជនជាប់ឃុំឃាំងយ៉ាងច្រើនសន្ធឹកសន្ធាប់។ ជាទូទៅ អ្នកទោសត្រូវបានគេសម្លាប់ដោយចេតនា តាមរយៈមធ្យោបាយច្រើនយ៉ាង ជាពិសេស ការសម្លាប់ភ្លាមៗនៅក្នុងមន្ទីរសន្តិសុខតែម្តង ឬក៏នៅក្បែរៗនោះ។ ក៏ប៉ុន្តែមានអ្នកទោសជាច្រើនបានស្លាប់ដោយសារការធ្វើទារុណកម្ម និងការធ្វើបាបផ្សេងៗដែលប្រព្រឹត្តមកលើពួកគេ" (អក្សរដិត នៅក្នុងច្បាប់ដើម)។

[1284] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៦-១៤១៨, សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ២២៥៨និងកថាខណ្ឌបន្តបន្ទាប់ទៀត។

១២២៥. ការបរិយាយអង្គហេតុ ដែលកើតឡើងនៅក្រាំងតាចាន់ ពីកថាខណ្ឌ ៤៨៩ ដល់កថាខណ្ឌ ៥១៤ នៃដីកាដំណោះស្រាយ អាចឱ្យកំណត់ថា អង្គហេតុទាំងនេះទទួលបានប្រភេទជាអំពើមនុស្សឃាតក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមបទបញ្ញត្តិដែលបានរៀបរាប់ខាងលើ។

១២២៦. នៅកថាខណ្ឌជាច្រើននៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានលើកឡើងអំពីការស្លាប់នៅក្រាំងតាចាន់ ដោយសារតែការសម្លាប់ (កថាខណ្ឌ ៥០០ និងកថាខណ្ឌ ៥១០ ដល់កថាខណ្ឌ ៥១៤ នៃដីកាដំណោះស្រាយ ក្រោមចំណងជើង "ការបាត់ខ្លួន និងការសម្លាប់") ជំងឺ (កថាខណ្ឌ ៥០២ និងកថាខណ្ឌ ៥០៨) ការអត់អាហារ (កថាខណ្ឌ ៥០២ និងកថាខណ្ឌ ៥០៨) សង្កើចខាំ (កថាខណ្ឌ ៥០២) ឬការវាយដំក្នុងពេលសួរចម្លើយ (កថាខណ្ឌ ៥០៨)។

១២២៧. ជារឿយៗ សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋានទាំងនេះ ដោយរំលោភលើវិសាលភាពនៃបណ្តឹងមកកាន់ខ្លួន ដូចបានកំណត់ដោយកថាខណ្ឌ ៤៣ និងកថាខណ្ឌ ៦០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

១២២៨. យោងតាមកថាខណ្ឌ ៤៣ ស្តីពីសហករណ៍ត្រាំកក់ សហចៅក្រមស៊ើបអង្កេតបានទទួលអាណត្តិឱ្យស៊ើបសួរលើអង្គហេតុនៃការសម្លាប់ប្រជាជនថ្មី ដែលត្រូវបានបញ្ជូនទៅក្រាំងតាចាន់។

១២២៩. យោងតាមកថាខណ្ឌ ៦០ ស្តីពីមន្ទីរសន្តិសុខក្រាំតាចាន់ សហចៅក្រមស៊ើបអង្កេតបានទទួលអាណត្តិឱ្យស៊ើបសួរតែទៅលើអង្គហេតុនៃការសម្លាប់អ្នកទោស ដោយគ្មានបែងចែកសមាជិកភាពនៃក្រុមណាមួយនោះទេ៖

> "ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៨ មន្ត្រីបក្សកុម្មុយនីស្តកម្ពុជាបានសម្លាប់មនុស្សប្រហែលជា ១២.០០០ នាក់ នៅកន្លែងសន្តិសុខ និងឃុំឃាំង នៅក្រាំងតាចាន់ ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ ភូមិភាគនិរតី។ ពួកអ្នកជាប់ឃុំរួមមានប្រជាជនថ្មី គ្រួសារអតីតទាហាន និងប្រជាជនផ្សេងៗ ក្នុងខេត្តតាកែវ។ ពួកអ្នកជាប់ឃុំត្រូវបានដាក់ខ្នោះគ្រប់ពេលវេលា និងសម្លាប់តាមកាលកំណត់ជាទៀងទាត់ ក្នុងនោះ រួមមានការវាយរហូតដល់ស្លាប់ផង។ មុនការចូលរលំនៃកម្ពុជាប្រជាធិបតេយ្យបន្តិច ក្នុងឆ្នាំ ១៩៧៨ ពួកអ្នកទោសនៅសល់ទាំងអស់ត្រូវសម្លាប់។ ពេលគាស់ផ្នូរក្រោយឆ្នាំ ១៩៧៩ សំណល់សាកសពអ្នកទោសប្រមាណ ២០០០ នាក់ ត្រូវបានរកឃើញនៅទីនោះ ឬក្បែរនោះ។ សំណល់សាកសពមនុស្សជាង ១០.០០០ នាក់ទៀត អាចស្ថិតនៅក្នុងរណ្តៅសាកសពរួមនៅក្នុងតំបន់នេះ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

១២៣០. ដូច្នេះ សហចៅក្រមស៊ើបអង្កេតត្រូវបានប្ដឹងឱ្យស៊ើបសួរតែអំពីការស្លាប់របស់អ្នកដែលត្រូវបានសម្លាប់នៅក្រាំងតាចាន់ប៉ុណ្ណោះ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតមិនទទួលបានអាណត្តិឱ្យស៊ើបសួរអំពីការស្លាប់ដោយសារតែលក្ខខណ្ឌរស់នៅ ក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ (អាហារ សុខភាព អនាម័យ) ឬការស្លាប់ដោយសារតែការធ្វើទារុណកម្មនោះទេ។ បើគ្មានបណ្ដឹង ការចោទប្រកាន់ផ្អែកលើហេតុការណ៍បែបនេះ គឺខុសច្បាប់។ អាស្រ័យហេតុនេះ លោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបនោះទេ។

១២៣១. ការមិនប្ដឹងទៅសហចៅក្រមស៊ើបអង្កេតមានភាពច្បាស់ក្រឡែត ពីព្រោះពេលសហព្រះរាជអាជ្ញាចង់ប្ដឹងទៅសហចៅក្រមស៊ើបអង្កេត អំពីការស្លាប់ដោយសារតែលក្ខខណ្ឌរស់នៅ ឬបណ្ដាលមកពីអំពើទារុណកម្ម នៅទីតាំងផ្សេងទៀត សហព្រះរាជអាជ្ញាបានធ្វើដោយច្បាស់ៗ។

១២៣២. ជាក់ស្ដែង នៅកថាខណ្ឌ ៥៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស្ដីពីអង្គហេតុនៅ ស-២១ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញថា "ពួកអ្នកជាប់ឃុំខ្លះបានស្លាប់ក្នុងពេលទទួលរងទារុណកម្ម ឬដោយសារបរិភាគមិនគ្រប់គ្រាន់ ដោយជំងឺ ឬលក្ខណៈរស់នៅអមនុស្សធម៌"។ ដូចគ្នាផងដែរ នៅកថាខណ្ឌ ៥៩ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស្ដីពីមន្ទីរសន្តិសុខកោះខ្យង សហព្រះរាជអាជ្ញាបានបញ្ជាក់ថា "ជារៀងរាល់ថ្ងៃ មានអ្នកទោសស្លាប់ ៥ ឬ ៦ នាក់ ដោយសារជំងឺ អត់ឃ្លាន ឬការបង្ខំសួរចម្លើយ"[1285]។

១២៣៣. ម្យ៉ាងវិញទៀត ក្នុងចំណោមសេចក្ដីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ស្ដីពីការសម្លាប់នៅក្រាំងតាចាន់ ជាអង្គហេតុតែមួយគត់ដែលត្រូវបានប្ដឹងទៅសហចៅក្រមស៊ើបអង្កេតដោយដីកា

---

[1285] សូមមើលផងដែរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៣ ទាក់ទងនឹងសហករណ៍ត្រាំកក់ ("ប្រជាជនរាប់ពាន់នាក់បានអត់បាយរហូតដល់ស្លាប់") កថាខណ្ឌ ៥៧-៥៨ ទាក់ទងនឹងមន្ទីរសន្តិសុខព្រៃដំរីស្រុត ("ពួកគេមួយចំនួនធំបានស្លាប់ដោយសារអត់បាយ ការធ្វើការងារហួសកម្លាំង") កថាខណ្ឌ ៦១ ទាក់ទងនឹងមន្ទីរសន្តិសុខសង់ ("អ្នកទោសត្រូវស្លាប់ដោយការអត់បាយ និងជំងឺជាទៀងទាត់") កថាខណ្ឌ ៦៧ ទាក់ទងនឹងមន្ទីរសន្តិសុខភូមិ៣ ("មនុស្សប្រមាណ ២០០០ នាក់ ត្រូវស្លាប់ដោយអត់បាយ")។

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថាមានការសម្លាប់ជនជាតិវៀតណាម។ ជាក់ស្ដែង នៅថាខណ្ឌ ៥០០ នៃដីកាដំណោះស្រាយ៖

> "ជនជាតិវៀតណាម [...] ពីដំបូង ត្រូវបានបញ្ជូនទៅវៀតណាមវិញ ក៏ប៉ុន្តែ អ្នកដែលមិនទាន់បានបញ្ជូនក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់ ប្រហែលជានៅមន្ទីរសន្តិសុខក្រាំតាចាន់នេះ"។

១២៣៤. ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតមិនត្រូវបានប្ដឹងឱ្យស៊ើបសួរអំពីជោគវាសនារបស់ជនជាតិវៀតណាមនៅក្រាំងតាចាន់ទាល់តែសោះ។ កថាខណ្ឌ ៥០០ បង្ហាញថា សហចៅក្រមស៊ើបអង្កេតបានទទួលព័ត៌មានអំពីការសម្លាប់ជនជាតិវៀតណាម ដោយស៊ើបសួរខុសច្បាប់ទៅលើជោគវាសនារបស់ពួកគេ នៅស្រុកត្រាំកក់[1286]។

១២៣៥. ដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនបានស៊ើបសួរអំពីការស្លាប់ នៅក្រាំងតាចាន់ តាមការស្នើសុំរបស់សហព្រះរាជអាជ្ញានោះទេ ប៉ុន្តែ បានទាញផលចំណេញដោយអយុត្តិធម៌ពីសេរីភាពដែលខ្លួនបានពីការរំលោភបំពានលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ប្រឆាំងលោក ខៀវ សំផន។ ដូច្នេះ ដោយសារតែនេះជាការព្យាយាមបង្ហាញលើសពីឧក្រិដ្ឋកម្មដែលចោទប្រកាន់ដោយសហព្រះរាជអាជ្ញា សេចក្ដីសន្និដ្ឋានអំពីការសម្លាប់ជនជាតិវៀតណាមនៅក្រាំងតាចាន់ ត្រូវតែបដិសេធចោល បើមិនដូច្នេះទេ វានឹងប៉ះពាល់ដល់យុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី។ លោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបឡើយ។

១២៣៦. ជាចុងក្រោយ លោក ខៀវ សំផន ត្រូវឆ្លើយតបតែទៅនឹងការសម្លាប់នៅក្រាំងតាចាន់ ក្រៅពីការសម្លាប់សមាជិកជនជាតិភាគតិចវៀតណាម។

## ២. <u>ការសម្លាប់រង្គាល</u>

១២៣៧. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៨១ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមរូបភាពជាការសម្លាប់រង្គាល ទៅលើ "ជនដែលត្រូវបានសម្លាប់

[1286] សូមមើលផ្នែកខាងលើ កថាខណ្ឌ ២១៩-២៧៦។

ឬជនដែលបានស្លាប់ក្នុងទ្រង់ទ្រាយធំ” នៅតាមមន្ទីរសន្តិសុខនានា រួមមានក្រាំងតាចាន់។ កថាខណ្ឌ ១៣៨២ និងកថាខណ្ឌ ១៣៨៣ ដែលត្រូវបានដកស្រង់ខាងលើ បានបញ្ជាក់អំពីធាតុផ្សំទូទៅដែលត្រូវពិចារណា សម្រាប់ទីតាំងទាំងអស់ដែលត្រូវបានចោទប្រកាន់ថាមានការសម្លាប់រង្គាល[1287]។ កថាខណ្ឌទាំងនេះក៏បានចង្អុលបង្ហាញផងដែរថា “ធាតុផ្សំពាក់ព័ន្ធផ្សេងទៀត” ត្រូវពិចារណាសម្រាប់ទីតាំងនីមួយៗដែលឧក្រិដ្ឋកម្មមានធាតុផ្សំគ្រប់គ្រាន់។

១២៣៨. ធាតុផ្សំទាំងនេះត្រូវបានផ្តល់ជូនក្នុងកថាខណ្ឌ ១៣៨៥ សម្រាប់គ្រប់មន្ទីរសន្តិសុខទាំងអស់ជាទូទៅ រួមទាំងក្រាំងតាចាន់ ប៉ុន្តែ ក៏សម្រាប់ក្រាំងតាចាន់ ជាពិសេស៖

> “ទាក់ទងដល់**មន្ទីរសន្តិសុខ** ក៏ដូចជាព្រៃស ក្រៅពីអំពើមនុស្សឃាតជាលក្ខណៈបុគ្គល មានភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់អំពីការសម្លាប់ និងការស្លាប់បណ្តាលមកពីអំពើទារុណកម្ម និងអំពើហិង្សាដទៃទៀត ដែលបានប្រព្រឹត្តក្នុងទ្រង់ទ្រាយធំ និងជាលក្ខណៈសមូហភាព។ ជាឧទាហរណ៍ ផ្អែកលើឯកសារនានា គេអាចសន្និដ្ឋានបានថា មានមនុស្សលើសពី ១២.០០០ នាក់ ត្រូវបានសម្លាប់នៅមន្ទីរ ស-២១ ហើយច្បាស់ណាស់ក៏មានមនុស្សលើសពី ១៥.០០០ នាក់ ត្រូវបានសម្លាប់នៅក្រាំងតាចាន់ដែរ” (អក្សរដិត ក្នុងច្បាប់ដើម)។

១២៣៩. ធាតុផ្សំពាក់ព័ន្ធផ្សេងទៀតត្រូវបានផ្តល់ជូនក្នុងកថាខណ្ឌ ១៣៨៧៖

> “ដោយឡែក [...] មានមនុស្សជាច្រើននាក់បានស្លាប់ដោយសារស្ថានភាពរស់នៅមានការលំបាកវេទនា [...] នៅតាម**មន្ទីរសន្តិសុខ**ទាំងនោះ។ មនុស្សទាំងនោះទទួលបានរបបអាហារមិនគ្រប់គ្រាន់ គ្មានជម្រក គ្មានការថែទាំវេជ្ជសាស្ត្រ និងអនាម័យ” (អក្សរដិត នៅក្នុងច្បាប់ដើម)។

១២៤០. ដូច្នេះ ក្រៅពីធាតុផ្សំអំពីទំហំនៃឧក្រិដ្ឋកម្ម គ្មានអង្គហេតុណាមួយ ដែលមិនត្រូវបានពិចារណាសម្រាប់ការកំណត់ជាអំពើមនុស្សឃាត ត្រូវបានជ្រើសយកសម្រាប់ការកំណត់ជាអំពើសម្លាប់រង្គាលឡើយ[1288]។ ចំពោះការស្លាប់ដោយសារការសម្លាប់ និងការធ្វើទារុណកម្ម ភាពស្របគ្នារវាងឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាតនៃកថាខណ្ឌ ១៣៧៦ និងការសម្លាប់រង្គាលនៃកថាខណ្ឌ ១៣៨៥ ស្តែងឡើងយ៉ាងច្បាស់។ ការស្លាប់ដោយសារតែលក្ខខណ្ឌរស់នៅ ដូចបានលើកឡើងនៅ

---

[1287] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៥៤។

[1288] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២២៣-១២៣៦។

កថាខណ្ឌ ១៣៨៧ នៃដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងការសម្លាប់រង្គាល ស្មើនឹងការស្លាប់ដោយសារ "ការធ្វើបាប" នៅកថាខណ្ឌ ១៣៧៦ ពាក់ព័ន្ធនឹងអំពើមនុស្សឃាត។

១២៤១. ការកត់សម្គាល់ខាងលើរបស់ក្រុមមេធាវីការពារក្តី ស្តីពីភាពខុសច្បាប់នៃសេចក្តីសន្និដ្ឋានមួយចំនួនរបស់សហចៅក្រមស៊ើបអង្កេត ដើម្បីគាំទ្រដល់ការកំណត់ជាអំពើមនុស្សឃាត ត្រូវអនុវត្តដោយគ្មានការលើកលែងចំពោះអង្គហេតុដែលត្រូវបានកំណត់ថាជាការសម្លាប់រង្គាល[1289]។

១២៤២. ដូច្នេះ លោក ខៀវ សំផន ត្រូវឆ្លើយតបតែទៅនឹងការសម្លាប់អ្នកទោសនៅក្រាំងតាចាន់ លើកលែងតែការសម្លាប់អ្នកទោសវៀតណាម។

### ៣. ការធ្វើឱ្យទៅជាទាសករ

១២៤៣. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយ ថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ នៅក្រាំងតាចាន់។ ដូចបានឃើញខាងលើ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅកថាខណ្ឌ ១៣៩២ និងកថាខណ្ឌ ១៣៩៤ ថា ឧក្រិដ្ឋកម្មបានសម្រេចឡើង ដោយការបំពេញធាតុផ្សំពីរ៖ ការអនុវត្តការគ្រប់គ្រងជាបន្តទៅលើអ្នកទោស និងការបង្ខំឱ្យពួកគេធ្វើការ ដោយគ្មានប្រាក់កម្រៃ[1290]។

១២៤៤. ភាពច្បាស់លាស់នៃឧក្រិដ្ឋកម្មនេះ ផ្អែកលើសេចក្តីសន្និដ្ឋានអំពីអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេត នៅកថាខណ្ឌ ៤៩៧ ដល់កថាខណ្ឌ ៥០៥ នៃដីកាដំណោះស្រាយ ក្រោមចំណងជើង "ការចាប់ខ្លួន និងការឃុំខ្លួន"។ កថាខណ្ឌ ៥០៣ មានលក្ខណៈច្បាស់ជាពិសេស ពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌការងារនៅក្រាំងតាចាន់៖

> "មានអ្នកទោសខ្លះនិយាយថា ពួកគេត្រូវបានបង្ខំឱ្យធ្វើការងារផ្សេងៗ នៅខាងក្នុងបរិវេណគុក។ អ្នកធ្វើការទទួលបានអាហារច្រើនជាងអ្នកដែលជាប់ខ្នោះ នៅក្នុងអគារឃុំឃាំង។ អ្នកដែលធ្វើការនៅក្នុងវាលស្រែមិន

---

[1289] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២២៣-១២៣៦។

[1290] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៦៧-៨៦៩។

ត្រូវបានដាក់ខ្នោះទេ ប៉ុន្តែ ស្ថិតនៅក្រោមការឃាមកាម។ អ្នកទោសខ្លះដែលត្រឡប់មកពីធ្វើការខាងក្រៅវិញ ត្រូវបានដាក់ខ្នោះ ក្នុងអគារឃុំឃាំង នៅពេលយប់"[1291]។

១២៤៥. សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការងាររបស់អ្នកទោសនៅក្រាំងតាចាន់ មានភាពខុសច្បាប់ទាំងស្រុង ពីព្រោះកថាខណ្ឌ ៤៣ និងកថាខណ្ឌ ៦០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនបាននិយាយអំពីការតម្រូវឱ្យអ្នកទោសឱ្យធ្វើការអ្វីនោះទេ។

១២៤៦. សហចៅក្រមស៊ើបអង្កេតបានបញ្ចូលអង្គហេតុថ្មី ដើម្បីសន្និដ្ឋានថាមានអត្ថិភាពនៃឧក្រិដ្ឋកម្ម។ ដូច្នេះ លោក ខៀវ សំផន មិនចាំបាច់ឆ្លើយតបនឹងអង្គហេតុគាំទ្រដល់ការចោទប្រកាន់នេះទេ។

## ៤. ការដាក់ក្នុងមន្ទីរឃុំឃាំង

១២៤៧. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានៅកថាខណ្ឌ ១៤០២ នៃដីកាដំណោះស្រាយ ថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមរូបភាពជាការដាក់ក្នុងមន្ទីរឃុំឃាំង នៅក្រាំងតាចាន់ ពីព្រោះ "ជនរងគ្រោះត្រូវបានដកហូតសេរីភាព តាមទំនើងចិត្ត ដោយបំពានទៅលើសិទ្ធិនានាដែលមានចែងនៅក្នុងច្បាប់"[1292]។

១២៤៨. ការកំណត់នេះផ្អែកលើអង្គហេតុនៃការឃុំឃាំងទាំងអស់ ដូចបានរៀបរាប់ ពីកថាខណ្ឌ ៤៩៧ ដល់កថាខណ្ឌ ៥០៥ នៃដីកាដំណោះស្រាយ ដែលលោក ខៀវ សំផន ត្រូវឆ្លើយតប។

## ៥. ការធ្វើទារុណកម្ម

១២៤៩. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤០៨ នៃដីកាដំណោះស្រាយ ថា ឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម មានធាតុផ្សំគ្រប់គ្រាន់ នៅក្រាំងតាចាន់។ អង្គហេតុនៃការធ្វើទារុណកម្ម ដែល

[1291]សូមមើលផងដែរ ដីកាដំណោះស្រាយ កថាខណ្ឌ ៥០១ ដែលនៅត្រង់នោះ មាននិយាយយ៉ាងខ្លីថា "មនុស្សត្រូវបានបញ្ជូនឱ្យទៅធ្វើការ"។

[1292]ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០៣។ សូមមើលផងដែរ ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០៥។

ត្រូវបានរៀបរាប់ ពីកថាខណ្ឌ ៥០៧ ដល់កថាខណ្ឌ ៥០៩ នៃដីកាដំណោះស្រាយ ជាមូលដ្ឋាននៃការចោទប្រកាន់នៅកថាខណ្ឌ ១៤០៨។

១២៥០. សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋានទាំងនេះ ដោយរំលោភទៅលើបណ្តឹងមកកាន់ខ្លួន។ អង្គហេតុនៃការសួរចម្លើយ ឬធ្វើទារុណកម្មលើរូបកាយ ឬផ្លូវចិត្ត មិនមានចែងនៅក្នុងកថាខណ្ឌ ៤៣ និងកថាខណ្ឌ ៦០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នោះទេ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនបានទទួលអាណត្តិ ដើម្បីស៊ើបអង្កេតលើអង្គហេតុទាំងនេះឡើយ។

១២៥១. ជាថ្មីម្តងទៀត នៅពេលសហព្រះរាជអាជ្ញាចង់ឱ្យសហចៅក្រមស៊ើបអង្កេតស៊ើបសួរលើអង្គហេតុនៃការធ្វើទារុណកម្ម សហព្រះរាជអាជ្ញាបាននិយាយច្បាស់។

១២៥២. ជាក់ស្តែង នៅកថាខណ្ឌ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស្តីពី ស-២១ សហព្រះរាជអាជ្ញាបានអះអាងថា "ពួកអ្នកជាប់ឃុំភាគច្រើនលើសលុបត្រូវទទួលរងទារុណកម្ម ដើម្បីបង្ខំទាញយកចម្លើយសារភាព"។ ដូចគ្នាផងដែរ នៅកថាខណ្ឌ ៥៩ ស្តីពីមន្ទីរសន្តិសុខកោះខ្យង សហព្រះរាជអាជ្ញាបានចោទប្រកាន់ថា "ប្រជាជនរាប់ពាន់នាក់ត្រូវបានដាក់ឃុំ ធ្វើទារុណកម្ម ហើយបន្ទាប់មកសម្លាប់ចោល"។ សហព្រះរាជអាជ្ញាក៏បានបញ្ជាក់នៅកថាខណ្ឌ ៦៣ ស្តីពីមន្ទីរសន្តិសុខគោកក្តួចថា "ពួកអ្នកទោសត្រូវបានដាក់ខ្នោះគ្រប់ពេលវេលា និងទទួលរងទារុណកម្មជាប្រចាំ"[1293]។

១២៥៣. នៅកថាខណ្ឌ ៤០ និងកថាខណ្ឌ ៦០ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស្តីពីក្រាំងតាចាន់ មិនមានលើកឡើងអំពីអង្គហេតុប្រភេទនេះទេ។ អាស្រ័យហេតុនេះ ដោយសារអង្គជំនុំជម្រះមិនបានទទួលបណ្តឹងត្រឹមត្រូវតាមច្បាប់អំពីអង្គហេតុនៃការធ្វើទារុណកម្ម នៅក្រាំងតាចាន់ លោក ខៀវ សំផន មិនចាំបាច់ឆ្លើយតបទេ។

---

[1293]សូមមើលផងដែរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៩, ៥០, ៥៣ និង ៥៥ ទាក់ទងនឹង ស-២១, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ **ឯកសារ D202** កថាខណ្ឌ ៧ ទាក់ទងនឹងមន្ទីរសន្តិសុខក្បាលឈើពុក ("ការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់អ្នកទោស បានកើតឡើងជាទៀងទាត់នៅឯមណ្ឌលសន្តិសុខមួយនេះ")។

## ៦. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

១២៥៤. នៅកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅក្រាំងតាចាន់។

១២៥៥. នៅក្នុងជំពូកស្តីពីសហករណ៍ត្រាំកក់ យើងបានឃើញថា មានតែមនុស្សបីក្រុមប៉ុណ្ណោះដែលត្រូវបានកំណត់ នៅកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយ ថាជាមុខសញ្ញានៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងខ្មែរមកពីបរទេស[1294]។

១២៥៦. នៅកថាខណ្ឌ ១៤១៨ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ តើថាការធ្វើទុក្ខបុកម្នេញបានកើតឡើងយ៉ាងដូចម្តេច នៅតាមទីតាំងឧក្រិដ្ឋកម្មនានា៖

> “នៅតាម**សហករណ៍** និង**ការដ្ឋានធ្វើការដោយបង្ខំ** ដូចនៅពេល**ផ្លាស់ទីលំនៅប្រជាជន**ដែរ ខ្មាំងពិតប្រាកដ ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគេធ្វើបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខ័ណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត។ មនុស្សទាំងនេះក៏ត្រូវបានគេចាប់ជាក្រុមៗផងដែរ ដើម្បីយកទៅអប់រំឡើងវិញ ឬទៅកម្ទេចចោល នៅតាមមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស” (អក្សរដិត នៅក្នុងច្បាប់ដើម)។

១២៥៧. មានតែអង្គហេតុនៃការចាប់ខ្លួន អប់រំឡើងវិញ និងកម្ទេចមនុស្សប៉ុណ្ណោះ ដែលមានភាពពាក់ព័ន្ធនឹងក្រាំតាចាន់ និងបង្ហាញអំពីការរើសអើងដែលបានទទួលរង។

១២៥៨. ផ្ទុយទៅវិញ មិនមានការបញ្ជាក់អំពីការដាក់ឱ្យរស់នៅក្នុងលក្ខខ័ណ្ឌពិបាកខ្លាំង នៅក្រាំងតាចាន់ចំពោះសមាជិកក្រុម ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតកំណត់អត្តសញ្ញាណ នៅកថាខណ្ឌ ១៤១៧ នោះឡើយ។ សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតនេះ គឺបន្តពីការសង្កេតឃើញ

[1294] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៨៤-៨៨៥។

ពីមុនរបស់ខ្លួននៅត្រាំកក់ ដែលសហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានយ៉ាងលំបាកថាមានការលុបបំបាត់ "សិទ្ធិនយោបាយ" របស់ប្រជាជនថ្មី សម្រាប់ជាធាតុផ្សំតែមួយគត់នៃការរើសអើង។ ដោយសារអ្នកទោសស្ថិតនៅក្នុងស្ថានភាពទុក្ខវេទនាដូចគ្នា វាជារឿងធម្មតាទេដែលសហចៅក្រមស៊ើបអង្កេតមិនបានបន្ធូរសេចក្តីសន្និដ្ឋានរបស់ខ្លួន លើការប្រព្រឹត្តិតឹងរ៉ឹងជាងនៅក្រាំងតាចាន់ ចំពោះអ្នកទោសដែលជាប្រជាជនថ្មី។

១២៥៩. យើងបាននិយាយពីខាងលើថា អង្គហេតុទាំងអស់ ដែលគាំទ្រដល់ការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវសិក្សាខាងក្រោម។

១២៦០. ចំពោះប្រជាជនថ្មី មានការលើកឡើងពីរដងក្នុងសេចក្តីអត្ថាធិប្បាយអំពីអង្គហេតុនៃដីកាដំណោះស្រាយ ស្តីពីក្រាំងតាចាន់ ដែលជាមូលដ្ឋាននៃការកំណត់ប្រភេទបទល្មើសរបស់សហចៅក្រមស៊ើបអង្កេត។

១២៦១. កថាខណ្ឌ ៤៩៨ បានបញ្ជាក់ថា នៅពេលមកដល់ត្រាំកក់ "ប្រជាជនថ្មី" បានសរសេរប្រវត្តិរូប។

១២៦២. សេចក្តីសន្និដ្ឋាននេះផ្តោតលើជោគវាសនារបស់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ពីព្រោះយោងតាមកថាខណ្ឌ ៤៩៨ ការសរសេរប្រវត្តិរូបអាចឱ្យកំណត់អត្តសញ្ញាណអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងចំណោមអ្នកមកដល់ថ្មី ដើម្បីបញ្ជូនពួកគេទៅក្រាំងតាចាន់។ ដូច្នេះ អង្គហេតុទាំងនេះនឹងត្រូវវែកញែកនៅជំពូកស្តីពីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

១២៦៣. ការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតបង្ហាញថា ខុសពីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មីមិនត្រូវបានបញ្ជូនទៅក្រាំងតាចាន់ ដោយផ្អែកលើឋានៈជាប្រជាជនថ្មីនោះទេ។ ចំណុចនេះពង្រឹងការសង្ស័យទៅលើភាពពាក់ព័ន្ធនៃការចាត់ទុកក្រុមនេះជាក្រុមខ្មាំង ដោយសហចៅក្រមស៊ើបអង្កេត នៅកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ[1295]។

[1295] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៨៣-៩១០។

១២៦៤. បន្ទាប់មកទៀត នៅកថាខណ្ឌ ៥០០ ស្ដីពីសមាសភាពអ្នកជាប់ឃុំ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា៖

> "បុរស ស្ត្រី និងកុមារ រួមទាំងគ្រួសារ ត្រូវបានឃុំខ្លួននៅក្រាំងតាចាន់។ មានសាក្សីចំនួន ៨ នាក់ ជាអតីតអ្នកជាប់ឃុំឃាំង។ សាក្សីបានឱ្យដឹងថា ភាគច្រើននៃអ្នកជាប់ឃុំឃាំងជាប្រជាជនថ្មីមកពីភ្នំពេញ។ ប៉ុន្តែ ក៏មានប្រជាជនមូលដ្ឋាន អតីតទាហាន លន់ នល់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ចិន វៀតណាម និងចាម ស្ថិតនៅក្នុងចំណោមអ្នកជាប់ឃុំឃាំងដែរ"។

១២៦៥. សេចក្ដីសន្និដ្ឋាននេះផ្ទុយនឹងការចោទប្រកាន់ពីការរើសអើង ពីព្រោះមនុស្សទាំងអស់ត្រូវបានចាប់ខ្លួន ដោយគ្មានបែងចែកអាយុ ភេទ សញ្ជាតិ ឬមុខងារ។ សហចៅក្រមស៊ើបអង្កេតទំនងជាចង់និយាយថា ប្រជាជនថ្មីត្រូវបានចាប់ខ្លួនញឹកញាប់ជាងប្រជាជនផ្សេងទៀត ប៉ុន្តែ គ្មានការផ្ដល់ទិន្នន័យអំពីចំណុចនេះទេ។ ពុំមានការលើកឡើងថា អ្នកទាំងនេះត្រូវបានចាប់ខ្លួន ដោយសារតែមានឋានៈជាប្រជាជនថ្មីឡើយ ហើយគំនិតដែលអះអាងនៅកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយថា ក្រុមនេះត្រូវបានចាត់ទុកជា "ខ្មាំង" គឺមានលក្ខណៈប្រឌិតកាន់តែខ្លាំងឡើងៗ។

១២៦៦. ការរៀបរាប់របស់សហចៅក្រមស៊ើបអង្កេតពើបប្រទះនឹងការរិះគន់ នៅកថាខណ្ឌ ៥០១ នៃដីកាដំណោះស្រាយ ដែលលើកឡើងថា៖

> "ភ័ស្តុតាងបានបង្ហាញថា អ្នកទោសត្រូវបានបែងចែកជាពីរប្រភេទ មានអ្នកទោសកម្រិតស្រាល និងធ្ងន់"។

១២៦៧. កថាខណ្ឌ ៥០១ មិនមាននិយាយសំដៅដល់ក្រុមណាមួយដូចបានកំណត់នៅកថាខណ្ឌ ៥០០ ឡើយ ហើយក៏មិនមាននិយាយសំដៅដល់ប្រជាជនថ្មីដែរ។

១២៦៨. ដូច្នេះ គេមិនអាចនិយាយថាបើអ្នកណាម្នាក់ជាប្រជាជនថ្មី អ្នកនោះនឹងមានឱកាសខ្ពស់ក្នុងការចាត់ចូលទៅក្នុងប្រភេទអ្នកទោសធ្ងន់ឡើយ។ ផ្ទុយទៅវិញ សេចក្ដីសន្និដ្ឋាននេះបង្ហាញឱ្យឃើញអំពីការរើសអើងដែលអាចច្រានចោលនូវការកំណត់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

១២៦៩. ជាចុងក្រោយ ពីកថាខណ្ឌ ៥១០ ដល់កថាខណ្ឌ ៥១៤ ក្រោមចំណងជើង "ការបាត់ខ្លួន និងការសម្លាប់" មិនមានការនិយាយអ្វីទាល់តែសោះអំពីប្រជាជនថ្មី។ ផ្ទុយពីអ្វីដែលយើងអាចយល់បានពីកថាខណ្ឌ ១៤១៨ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតមិនបានផ្អែកលើការរៀបរាប់នេះ សម្រាប់ជាមូលដ្ឋាននៃការរើសអើងទៅលើប្រជាជនថ្មីឡើយ។

១២៧០. ការអះអាងទាំងនេះអាចឱ្យបង្ហាញអំពីការភាន់គំនិតរបស់សហចៅក្រមស៊ើបអង្កេត ក្នុងអំឡុងកិច្ចស៊ើបសួរ។ សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត អំពីការដាក់ប្រជាជនថ្មីទៅក្នុងក្រុមខ្មាំង មិនអាចយកជាការបានទេ នៅពេលគេបង្អែបង្អង់បន្តិចត្រឹមអង្គហេតុដែលបង្ហាញសម្រាប់ជាការគាំទ្រ។

១២៧១. ជាចុងក្រោយ សេចក្តីសន្និដ្ឋានទាំងនេះបម្រើឱ្យតែតម្រូវការនៃការកំណត់ប្រភេទបទឧក្រិដ្ឋរបស់សហចៅក្រមស៊ើបអង្កេត និងការចចេសឱ្យផ្តន្ទាទោស។ នៅពេលមិនអាចរកឃើញអត្ថិភាពនៃការរើសអើងទៅលើប្រជាជនថ្មីនៅក្រាំងតាចាន់ នៅក្នុងកថាខណ្ឌពាក់ព័ន្ធនៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតគួរតែប្រកាសថាគ្មានភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ជូនលោក ខៀវ សំផន ទៅជំនុំជម្រះ។ អាស្រ័យហេតុនេះ លោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបទៅនឹងការចោទប្រកាន់នេះទេ។

## ៧. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍

១២៧២. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤២២ នៃដីកាដំណោះស្រាយ ថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ នៅក្រាំងតាចាន់។ អង្គហេតុគាំទ្រដល់ការចោទប្រកាន់នេះ ត្រូវបានរៀបរាប់ នៅកថាខណ្ឌ ៥០០ នៃដីកាដំណោះស្រាយ ដែលត្រូវបានដកស្រង់នៅកថាខណ្ឌ ១២៣៣ នៃសារណានេះ។

១២៧៣. យើងបានលើកឡើងពីខាងលើថា សហព្រះរាជអាជ្ញាមិនបានប្ដឹងឱ្យសហចៅក្រមស៊ើបអង្កេតស៊ើបសួរអំពីការរើសអើងដោយមូលហេតុពូជសាសន៍នៅទីតាំងក្រាំងតាចាន់នោះទេ[1296]។ រាល់សេចក្ដីសន្និដ្ឋានទាំងអស់របស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ហើយលោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបនោះទេ។ ជាថ្មីម្ដងទៀត នេះទាក់ទងដល់យុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី។

## ៨. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស)

១២៧៤. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស) នៅក្រាំងតាចាន់។

១២៧៥. កថាខណ្ឌ ១៤៣៨ រៀបរាប់លម្អិតអំពីធាតុផ្សំដែលសហចៅក្រមស៊ើបអង្កេតបានយកមកពិចារណាដើម្បីពិនិត្យមើលឧក្រិដ្ឋកម្មដែលកើតឡើង (អាហារមិនគ្រប់គ្រាន់សម្រាប់អ្នកជាប់ឃុំ ល័ក្ខខ័ណ្ឌឃុំឃាំងគួរឱ្យអាណោមអាធ័ម)។ ធាតុផ្សំទាំងនេះត្រូវបានរៀបរាប់ពីកថាខណ្ឌ ៤៩៧ ដល់កថាខណ្ឌ ៥០៥ នៃដីកាដំណោះស្រាយ ស្ដីពីល័ក្ខខ័ណ្ឌនៃការឃុំឃាំង។

១២៧៦. កថាខណ្ឌ ១៤៣៨ ក៏បានលើកឡើងផងដែរអំពី "ការទទួលរងការធ្វើបាបពីសំណាក់កងសន្តិសុខ និងអ្នកសួរចម្លើយ" ដែលយោងទៅកថាខណ្ឌ ៥០៦ ដល់កថាខណ្ឌ ៥០៩ ស្ដីពី "ការសួរចម្លើយ"។ ដូចយើងបាននិយាយពីខាងលើពាក់ព័ន្ធនឹងការធ្វើទារុណកម្ម សេចក្ដីសន្និដ្ឋានទាំងអស់របស់សហចៅក្រមស៊ើបអង្កេតលើប្រធានបទនេះ គឺខុសច្បាប់ ពីព្រោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមិនបានប្ដឹងទៅសហចៅក្រមស៊ើបអង្កេតឱ្យស៊ើបសួរលើចំណុចនេះទេ[1297]។ ដូច្នេះ លោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបនោះទេ។

---

[1296] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២៣៤។

[1297] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២៤៩-១២៥៣។

## ៩. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ)

១២៧៧. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤៧០ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ) នៅក្រាំងតាចាន់។

១២៧៨. ធាតុផ្សំដែលត្រូវបានជ្រើសយក ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្ម ត្រូវបានរៀបរាប់ខាងក្រោម។ នៅកថាខណ្ឌ ១៤៧១ មានការលើកឡើងជាអាទិ៍អំពីការដកហូតពីបុគ្គលនូវការគាំពារពីច្បាប់ និង "ការបដិសេធក្នុងការប្រគល់ ឬក៏ផ្តល់ឱ្យ [ជនរងគ្រោះ] នូវព័ត៌មានអំពីជោគវាសនា ឬទីកន្លែងឃុំខ្លួន" សាច់ញាតិរបស់ពួកគេ[1298]។

១២៧៩. កថាខណ្ឌ ១៤៧២ ក៏បានលើកឡើងផងដែរអំពីការដាក់ឱ្យអនុវត្ត "វិធានការមួយដែលមានគោលបំណងលាក់បាំងអំពីជោគវាសនារបស់បុគ្គលដែលបាត់ខ្លួន ដោយធ្វើឱ្យប្រាកដថា មិនមានសាក្សីណាម្នាក់បង្ហាញនូវព័ត៌មានទាក់ទងនឹងបុគ្គលនោះឡើយ"។

១២៨០. ការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតផ្អែកលើភ័ស្តុតាងមួយចំនួន ដែលត្រូវបានបង្ហាញពីកថាខណ្ឌ ៥១០ ដល់កថាខណ្ឌ ៥១៤ នៃដីកាដំណោះស្រាយ ក្រោមចំណងជើង "ការបាត់ខ្លួន និងការសម្លាប់"។

១២៨១. ជាថ្មីម្តងទៀត សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីអង្គហេតុនៃការបាត់ខ្លួន គឺខុសច្បាប់ទាំងស្រុង។ សហចៅក្រមស៊ើបអង្កេតមិនត្រូវបានប្តឹងដោយផ្អែកពាក់ព័ន្ធ ស្តីពីសហករណ៍ត្រាំកក់ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដោយកថាខណ្ឌ ៦០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស្តីពីការបាត់មនុស្សនៅត្រាំកក់ឡើយ។

១២៨២. នៅកថាខណ្ឌ ៦០ សហព្រះរាជអាជ្ញាបានអះអាងថា "មនុស្សរហូតដល់ ១២.០០០ នាក់" ត្រូវបានសម្លាប់ នៅក្រាំងតាចាន់ គឺស្មើនឹងចំនួនអ្នកទោសទាំងអស់នៅទីតាំងនោះ បើតាមការរាប់ផ្អឹងនា

---

[1298]ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧១។

ពេលក្រោយមក[1299]។ សេចក្ដីសន្និដ្ឋាននេះហាក់ដូចជាមានភាពខុសគ្នា បើតាមសហាចៅក្រមស៊ើបអង្កេត ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតគ្មានតួនាទីប៉ះប៉ូវកង្វះខាតរបស់សហព្រះរាជអាជ្ញាឡើយ។

១២៨៣. ជាថ្មីម្ដងទៀត ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ផ្ដល់ឧទាហរណ៍យ៉ាងច្បាស់លាស់ត្រង់កន្លែងដែលសហព្រះរាជអាជ្ញាបានប្ដឹងទៅកាន់សហចៅក្រមស៊ើបអង្កេតឱ្យស៊ើបសួរលើអង្គហេតុនៃការបាត់ខ្លួន[1300]។ នេះមិនមែនជាករណីសម្រាប់អង្គហេតុនៅក្រាំងតាចាន់នោះទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសម្រេចលើអង្គហេតុនេះបានឡើយ។ ដូច្នេះ លោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបនោះទេ។

## ផ្នែកទី ២. ការបង្ហាញភ័ស្ដុតាង

១២៨៤. ក្នុងចំណោមភ័ស្ដុតាង ដែលបានបង្ហាញជូនក្នុងពេលជំនុំជម្រះក្ដី (១) ភ័ស្ដុតាងជាច្រើនស្ថិតនៅក្រៅយុត្តាធិការរបស់អង្គជំនុំជម្រះ (២)។ ភ័ស្ដុតាងខ្លះទៀតអាចឱ្យយើងគិតថា ឧក្រិដ្ឋកម្មមួយចំនួនអាចមានធាតុផ្សំគ្រប់គ្រាន់ (៣)។

### ១. បញ្ជីភ័ស្ដុតាង

១២៨៥. ពីថ្ងៃទី ០៨ ខែ មករា ដល់ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ បុគ្គល ៣២ រូប បានមកផ្ដល់សក្ខីកម្មនៅសវនាការ ក្នុងវគ្គរួមស្ដីពីសហករណ៍ត្រាំកក់ និងមន្ទីរសន្ដិសុខក្រាំងតាចាន់។

១២៨៦. នៅក្នុងជំពូកស្ដីពីសហករណ៍ត្រាំកក់ យើងបានបញ្ជាក់ថា ក្នុងអំឡុងសវនាការរយៈពេល ៥០ ថ្ងៃ សាក្សី ១៧ រូប អ្នកជំនាញ ១ រូប និងដើមបណ្ដឹងរដ្ឋប្បវេណី ១៤ រូប បានមកផ្ដល់សក្ខីកម្មបន្ត

[1299]នៅត្រង់កថាខណ្ឌ ៦០ សហព្រះរាជអាជ្ញានិយាយថា សាកសពមនុស្សប្រមាណ ២០០០ នាក់ ត្រូវបានរកឃើញ ហើយថា សាកសពប្រមាណ ១០ ០០០ នាក់ទៀត អាចនឹងមាននៅក្នុងរណ្ដៅសាកសពដែលនៅជុំវិញកន្លែងនោះ។

[1300]ដីកាដំណោះស្រាយ [c'est plutôt RIP et non pas OC] កថាខណ្ឌ ៤៧ សម្រាប់ទីតាំងព្រលានយន្តហោះកំពង់ឆ្នាំង ("ប្រជាជនដែលបាត់ខ្លួន ត្រូវបានជំនួសជាប្រចាំដោយអ្នកជាប់ឃុំថ្មី") និង កថាខណ្ឌ ៦៤ សម្រាប់មន្ទីរសន្ដិសុខភ្នំក្រោល ("អ្នកទាំងនេះបានបាត់ខ្លួន និងអាចត្រូវបានសម្លាប់")។

បន្ទាប់គ្នា នៅក្នុងសវនាការ។ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំង ១៤ រូប ដើមបណ្តឹងរដ្ឋប្បវេណី ៧ រូប បានផ្តល់សក្ខីកម្មអំពីអង្គហេតុ ដើមបណ្តឹងរដ្ឋប្បវេណី ៦ រូប បានផ្តល់សក្ខីកម្មអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម និងដើមបណ្តឹងរដ្ឋប្បវេណី ១ រូប (ចាន់ ធីម) បានផ្តល់សក្ខីកម្ម ដំបូងអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម និងក្រោយមកទៀត ត្រូវបានកោះហៅម្តងទៀតឱ្យមកផ្តល់សក្ខីកម្មអំពីអង្គហេតុ។

១២៨៧. ចំពោះសាក្សីទាំង ១៧ រូប ដែលត្រូវបានស្តាប់ចម្លើយ សាក្សី ៤ រូប មិនត្រូវបានស្តាប់ចម្លើយនោះទេ ក្នុងអំឡុងពេលស៊ើបអង្កេតលើសំណុំរឿង ០០២ (ស្មើនឹងប្រហែល ២០% នៃសាក្សី ដែលត្រូវបានស្តាប់ចម្លើយ ក្នុងវគ្គនេះ)[1301]។

១២៨៨. បុគ្គលស្ទើរតែទាំងអស់បានផ្តល់ព័ត៌មានអំពីសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ ប៉ុន្តែ សាក្សីខ្លះបានផ្តល់ព័ត៌មានលម្អិតអំពីក្រាំងតាចាន់ថា ខ្លួនជាអតីតកម្មាភិបាលខ្មែរក្រហមមានទំនាក់ទំនងជាមួយក្រាំងតាចាន់ (ផាន់ ឆេន និងពេជ្រ ជឹម) អ្នកយាមនៅទីតាំងនោះ (ស្រី ថន, វ៉ាន់ សឿន និង សូត្រ ទាំង) ឬជាអ្នកទោស (សយ សែន, មាស សុខា និង វង សារុន)។ វង សារុន ដែលត្រូវបានស្នើសុំឱ្យកោះហៅដោយក្រុមមេធាវីការពារក្តីលោក នួន ជា ស្ថិតនៅក្នុងចំណោមមនុស្ស ៤ នាក់ ដែលត្រូវបានស្តាប់ចម្លើយ នៅក្នុងពេលស៊ើបអង្កេត។

១២៨៩. ក្នុងពេលសវនាការស្តីពីវគ្គផ្សេងទៀតនៃការជំនុំជម្រះក្តី សាក្សីមួយចំនួនក៏បានផ្តល់ព័ត៌មានអំពីក្រាំងតាចាន់ផងដែរ[1302]។

១២៩០. ម្យ៉ាងវិញទៀត ក្រៅពីកំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០២ កំណត់ហេតុស្តាប់ចម្លើយយ៉ាងច្រើនសន្ធឹកសន្ធាប់មកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលត្រូវបានដាក់បញ្ចូល ក្នុងពេលជំនុំជម្រះក្តីលើសំណុំរឿង ០០២ លើកឡើងអំពីក្រាំងតាចាន់។

---

[1301] នាង អ៊ួច, ខឹម ហឿន, ឯក ហឿន និង វង សារុន។

[1302] ឧទាហរណ៍ សាន់ ឡួន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/384.1**, សៅ វ៉ន ប្រតិចារឹក ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/385.1**, ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/386.1**។

## ២. ភ័ស្តុតាងក្រៅវិសាលភាព

១២៩១. ភ័ស្តុតាងជាច្រើន ដែលបានបង្ហាញជូនពាក់ព័ន្ធនឹងក្រាំងតាចាន់ ស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តី ឧទាហរណ៍ ភ័ស្តុតាងទាំងអស់ស្តីពីការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈ នៅមន្ទីរសន្តិសុខ ដែលជនជាប់ចោទមិនត្រូវបានបញ្ជូនទៅជំនុំជម្រះ[1303]។

១២៩២. ផ្ទុយទៅវិញ សំណួរអំពីអង្គហេតុទាំងនេះត្រូវបានសួរទៅកាន់សាក្សីដែលមកផ្តល់សក្ខីកម្ម នៅក្នុងសវនាការ។ ទោះជាយ៉ាងណាក៏ដោយ ចម្លើយទៅនឹងសំណួរទាំងនេះត្រូវតែច្រានចោល ដោយគ្មានការលើកលែង ឧទាហរណ៍ ចម្លើយដែលសាក្សី សយ សែន បានឆ្លើយទៅនឹងសំណួររបស់ចៅក្រម Claudia FENZ[1304]។ ដំណោះស្រាយដូចគ្នានេះ ក៏ត្រូវអនុវត្តចំពោះព័ត៌មានផ្តល់ដោយ វ៉ាន់ ស៊ិន ផងដែរ[1305]។

១២៩៣. ភ័ស្តុតាងក្រៅវិសាលភាពពាក់ព័ន្ធនឹងរឿងរ៉ាវដែលសាក្សីខ្លះបានរៀបរាប់អំពីការធ្វើការងារ នៅក្នុងបរិវេណមន្ទីរសន្តិសុខ ឬនៅវាលស្រែក្បែរនោះ។ យើងបានលើកឡើងពីខាងលើថា សហចៅក្រមស៊ើបអង្កេតមិនត្រូវបានប្តឹងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អំពីអង្គហេតុនៃការធ្វើការងារដោយបង្ខំនៅក្រាំងតាចាន់នោះទេ។ ដូច្នេះ អង្គជំនុំជម្រះពុំមានយុត្តាធិការដើម្បីជំនុំជម្រះអង្គហេតុទាំងនេះទេ។ ភ័ស្តុតាង ដែលត្រូវបានបង្ហាញជូនក្នុងគោលដៅនេះ ស្ថិតនៅក្រៅវិសាលភាព និងត្រូវច្រានចោល។

១២៩៤. ដំណោះស្រាយនេះត្រូវអនុវត្តជាអាទិ៍ចំពោះចម្លើយរបស់សាក្សី មាស សុខា, សយ សែន និង វង សារុន ស្តីពីការងាររបស់អ្នកទោស[1306]។

---

[1303]សូមមើលផ្នែកខាងលើ កថាខណ្ឌ ១៧១-២០៣។

[1304]សយ សែន ប្រតិចារឹក ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/257.1** ទំព័រ ២៦-២៧ ចន្លោះម៉ោង [១០.៤៦.០០] និង [១០.៥១.៤១]។

[1305]វ៉ាន់ ស៊ឿន ប្រតិចារឹក ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ E1/271.1** ទំព័រ ៦៣-៦៤ ចន្លោះម៉ោង [១៥.១១.៥៣] និង [១៥.១៨.០០]។

[1306]មាស សុខា ប្រតិចារឹក ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/249.1** ទំព័រ ៨ ប្រហែលម៉ោង [១០.០៥.០០] និង ទំព័រ ៥៨ ចន្លោះម៉ោង [១៤.១៨.៤៦] និង [១៤.២១.៣៥], សយ សែន ប្រតិចារឹក ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/256.1**

## ៣. <u>ភ័ស្តុតាងដែលមិនអាចយកមកធ្វើជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានអំពីឧក្រិដ្ឋកម្ម</u>

១២៩៥. ដោយសារបញ្ហាធ្ងន់ធ្ងរនៃភាពអាចទុកចិត្តបាន យថាភាព ឬភាពអាចជឿជាក់បាន ភ័ស្តុតាងមួយចំនួនត្រូវផាត់ចេញពីការពិភាក្សាដេញដោល ឧទាហរណ៍ ឯកសារ E3/2107 (ក) ឬសក្ខីកម្មនៅក្នុងសវនាការរបស់សាក្សី សយ សែន (ខ)។

### ក. <u>ភាពគ្មានយថាភាពនៃឯកសារ E3/2107</u>

១២៩៦. ឯកសារនេះជារបាយការណ៍គ្មានចុះកាលបរិច្ឆេទ ផ្ញើដោយប្រធានក្រាំងតាចាន់ទៅកាន់គណៈស្រុកត្រាំកក់។ យថាភាពនៃឯកសារនេះត្រូវបានជំទាស់តវ៉ា ក្នុងពេលសួរដេញដោលសាក្សី ស្រី ថន[1307] ជាអាទិ៍ ពាក់ព័ន្ធនឹងចំណារថា៖

> “មន្ទីរអប់រំ ១០៥
>
> ចាប់ពីថ្ងៃយើងកម្ទេចពួកអាខ្មាំងមកទល់សព្វថ្ងៃនេះ អស់ចំនួន ១៥00 នាក់
>
> សូមបក្សជ្រាប
>
> ម. អប់រំស្រុក ១០៥
>
> [ហត្ថលេខា]
>
> អាន់”[1308]។

---

ទំព័រ ៣៧-៤១ ចន្លោះម៉ោង [១១.១៦.0៨] និង [១១.២៦.៤៨], ប្រតិចារឹក ថ្ងៃទី 0៥ ខែ កុម្ភៈ ឆ្នាំ ២0១៥ **ឯកសារ E1/257.1** ទំព័រ ៥៧-៦៣ ចន្លោះម៉ោង [១៥.៤១.១៦] និង [១៦.0៣.៤៦], ប្រតិចារឹក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២0១៥ **ឯកសារ E1/282.1** ទំព័រ ៨៦-៨៧ ចន្លោះម៉ោង [១៦.១៩.២២] និង [១៦.២១.៣៦], <u>វង សារុន</u> ប្រតិចារឹក ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២0១៥ **ឯកសារ E1/300.1** ទំព័រ ២១ ប្រហែលម៉ោង [១០.៤៧.២៤] និងទំព័រ ៤៦ ប្រហែលម៉ោង [១៤.0១.៥៦]។

[1307] ប្រតិចារឹក ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២0១៥ **ឯកសារ E1/268.1** ទំព័រ ៣៦-៣៧ ប្រហែលម៉ោង [១១.៣៣.៤៤] និង [១១.៣៦.៥១]។

[1308] របាយការណ៍មន្ទីរសន្តិសុខក្រាំងតាចាន់ គ្មានចុះកាលបរិច្ឆេទ **ឯកសារ E3/2107** ERN 00655725 (ភាសាបារាំង), ERN 00290205 (ភាសាអង់គ្លេស) និង ERN 00068049 (ភាសាខ្មែរ)។

១២៩៧. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ ដោយសារតែមានមន្ទិលសង្ស័យលើយថាភាពនៃឯកសារនេះ លោក ខៀវ សំផន បានស្នើសុំឱ្យធ្វើកោសល្យវិច័យ[1309]។ នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានឆ្លើយតបតាមរយៈអនុស្សរណៈ និងបានបញ្ជាក់ថា ម្ចាស់សំណើ "ពុំបានបង្ហាញថាវាជាការចាំបាច់ ក្នុងការបង្គាប់ឱ្យមានការវាយតម្លៃដោយអ្នកជំនាញ លើអក្សរសរសេរដៃនៃឯកសារនោះឡើយ"[1310]។ អង្គជំនុំជម្រះក៏បានចង្អុលបង្ហាញផងដែរថាទឡ្ហីករណ៍ខ្លះរបស់លោក ខៀវ សំផន ផ្ដោតលើទម្ងន់ និងតម្លៃជាភស្តុតាងនៃឯកសារនេះ ហើយ "ទាំងនេះ គឺជាបញ្ហាដែលតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណា នៅក្នុងអំឡុងនៃការពិភាក្សារបស់អង្គជំនុំជម្រះទៅលើអង្គហេតុនានា"[1311]។

១២៩៨. នេះជាពេលវេលាសមស្របសម្រាប់អង្គជំនុំជម្រះ ក្នុងការដកឯកសារនេះចេញពីពិភាក្សាសម្រេច។ នៅក្នុងសំណើរបស់ខ្លួន លោក ខៀវ សំផន បានសម្ដែងនូវមន្ទិលសង្ស័យទាំងអស់លើយថាភាពនៃឯកសារនេះ។ គាត់បានយោងទៅសារណាមុនៗរបស់គាត់ ដែលត្រូវបានសំយោគដោយសង្ខេបនៅទីនេះ។ ម្យ៉ាង ចំណារដែលជំទាស់តវ៉ាត្រូវបានសរសេរលើក្រដាសដាច់ដោយឡែកមួយ ភ្ជាប់នឹងឯកសារ ដោយមិនដឹងមូលហេតុ និងមានអក្សរពីរផ្សេងគ្នា ខុសពីអក្សរដែលសរសេរនៅផ្នែកផ្សេងទៀតនៃឯកសារ[1312]។ ចំណុចនេះបង្កើតឱ្យមានភាពមន្ទិលសង្ស័យច្រើនទៅលើឯកសារដែលគ្មាននរណាម្នាក់ធ្លាប់ឃើញច្បាប់ដើម បើទោះជាឧបមាថាមានក៏ដោយ។ ម្យ៉ាងទៀត ព័ត៌មានតួលេខដែលបានបង្ហាញនៅក្នុងឯកសារនេះផ្ទុយទៅនឹងសក្ខីកម្ម ដែលត្រូវបានស្ដាប់ ក្នុងអំឡុងសវនាការលើអង្គសេចក្ដី[1313]។

១២៩៩. គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេ សហចៅក្រមស៊ើបអង្កេតមិនបានសង្ស័យលើភាពអាចជឿជាក់បាននៃឯកសារដាក់បន្ទុកមួយ ដែលខ្លួនបានផ្អែកលើដើម្បីធ្វើការប៉ាន់ប្រមាណអំពីចំនួនមនុស្សស្លាប់នោះ

[1309]សំណើ ខៀវ សំផន ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E349**។

[1310]អនុស្សរណៈ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ **ឯកសារ E349/1** កថាខណ្ឌ ៨។

[1311]អនុស្សរណៈ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ **ឯកសារ E349/1** កថាខណ្ឌ ៧។

[1312]សំណើ ខៀវ សំផន ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E349** កថាខណ្ឌ ៨-១១។

[1313]អនុស្សរណៈ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ **ឯកសារ E349/1** កថាខណ្ឌ ១២-១៧។

ឡើយ[1314]។ អង្គជំនុំជម្រះមិនអាចមិនយកចិត្តទុកដាក់ទៅលើឯកសារនេះដូចសហចៅក្រមស៊ើបអង្កេតនោះទេ ហើយត្រូវតែបដិសេធការប្រើប្រាស់ឯកសារនេះ។

## ខ. ភាពមិនអាចជឿជាក់បាននៃសក្ខីកម្មរបស់សាក្សី សយ សែន

១៣០០. សាក្សី សយ សែន ត្រូវបានស្តាប់ចម្លើយយ៉ាងយូរ ក្នុងអំឡុងសវនាការស្តីពីក្រាំងតាចាន់[1315]។ គាត់បានធ្វើការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរជាច្រើនលើកច្រើនសាលើអតីតអ្នកយាមនៅទីតាំងនោះ គឺសាក្សី ស្រី ថន និងដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ហើយយើងក៏មិនយល់ថាហេតុអ្វីបានជាពួកគេទទួលបានឋានៈខុសគ្នា នៅក្នុងការជំនុំជម្រះក្តីនេះ។ អ្នកទាំងពីរនេះបានប្រកែកចំពោះការចោទប្រកាន់នេះ។

១៣០១. នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ លោក ខៀវ សំផន បានធ្វើសំណើសុំឱ្យបុគ្គលទាំងបីរូបនេះមកតទល់គ្នា[1316]។ ក្រុមមេធាវីការពារក្តីសូមយោងទៅសារណារបស់ខ្លួន ដែលបានលើកឡើងអំពីភាពផ្ទុយគ្នានៃសក្ខីកម្មនានា នៅក្នុងសវនាការ។

១៣០២. នៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានបដិសេធសំណើរបស់លោក ខៀវ សំផន ដោយហេតុថា វិធានការដែលបានស្នើសុំមាន "ផលប្រយោជន៍មួយចំនួន" ហើយ "ការតទល់គ្នានឹងមិនរួមចំណែកបន្ថែមទៀតចំពោះការវាយតម្លៃអំពីភាពគួរឱ្យជឿជាក់បានរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទេ" "ហើយក៏មិនជួយដល់ការបញ្ជាក់ការពិតដែរ"[1317]។

---

[1314]ដីកាដំណោះស្រាយ កថាខណ្ឌ ៥១៤ កំណត់សម្គាល់ជើងទំព័រ ២២៣១។

[1315]សយ សែន ប្រតិចារឹក ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ** E1/256.1, ប្រតិចារឹក ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ** E1/257.1, ប្រតិចារឹក ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ** E1/258.1, ប្រតិចារឹក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ** E1/282.1។

[1316]សំណើ ខៀវ សំផន ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ** E348។

[1317]សេចក្តីសម្រេច ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ** E348/4 កថាខណ្ឌ ១៣-១៤។

១៣០៣. ផ្ទុយទៅវិញ ភាពខុសគ្នានេះមានភាពច្បាស់ក្រឡែតរវាងសក្ខីកម្មទាំងនេះ ហើយវាពាក់ព័ន្ធនឹងធាតុផ្សំសំខាន់នៃការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តី។ ដោយបានមើលឃើញភាពច្បាស់លាស់នៃសម្តីរបស់ម្នាក់ៗដែលយើងកំពុងជជែកនេះ វាច្បាស់ណាស់ថា អាចជា សយ សែន ឬ ស្រី ថន ឬក៏ សូត្រ សាំង ដែលនិយាយកុហក។ ដោយសារតែចម្លើយរបស់សាក្សី សយ សែន បានប្រែក្រឡាស់នៅក្នុងកិច្ចដំណើរការនីតិវិធី ការសង្ស័យថាគាត់និយាយកុហកកាន់តែមានមូលដ្ឋានរឹងមាំ[1318]។ ដូច្នេះ អង្គជំនុំជម្រះត្រូវទាញផលវិបាកចេញពីភាពរឹងត្អឹងនៃសេចក្តីសម្រេចរបស់ខ្លួន។ នៅពេលបដិសេធមិនកោះហៅបុគ្គលទាំងនេះមកតទល់គ្នាក្នុងសវនាការតែមួយ អង្គជំនុំជម្រះបានបាត់បង់លទ្ធភាពក្នុងការស្វែងរកការពិត។ ដូច្នេះ អង្គជំនុំជម្រះត្រូវច្រានចោលសក្ខីកម្មទាំងស្រុងរបស់ សយ សែន ពីព្រោះការសង្ស័យថាគាត់កុហក មានទម្ងន់ទៅលើគាត់ខ្លាំងជាងគេ។

**៤. ភស្តុតាងអំពីឧក្រិដ្ឋកម្មមួយចំនួន**

១៣០៤. ភស្តុតាងមួយផ្នែកដែលបានបង្ហាញ អាចនាំឱ្យយើងគិតថា មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស) នៅទីតាំងក្រាំងតាចាន់។

១៣០៥. ប៉ុន្តែ ការសង្កេតនេះអនុញ្ញាតឱ្យអង្គជំនុំជម្រះ តែក្នុងល័ក្ខខ័ណ្ឌពីរ គឺគោរពដែនកំណត់នៃបណ្តឹងមកកាន់ខ្លួន និងប្រកាន់យកឥរិយាបថតឹងរ៉ឹងចំពោះភស្តុតាងដែលមាន។

**ជំពូកទី ៣. អ្នកខៀវ**

**ផ្នែកទី ១. បទចោទ**

១៣០៦. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់អំពីអង្គហេតុកើតឡើងនៅមន្ទីរសន្តិសុខអូរកន្សែង ដែលត្រូវបានកំណត់ដោយសហចៅក្រមស៊ើបអង្កេតថាជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើ

[1318] សំណើ ខៀវ សំផន ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ E348/4** កថាខណ្ឌ ១៤។

ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូជាមនុស្ស និងការបាត់ខ្លួនដោយបង្ខំ) ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (១)។ អង្គហេតុទាំងនេះក៏ត្រូវបានកំណត់ផងដែរថាជាការធ្វើមនុស្សឃាតដោយចេតនា ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ និងទៀងទាត់ យោងតាមអនុសញ្ញាទីក្រុងហ្សឺណែវ (២)[1319]។ ការពិនិត្យបទចោទនីមួយៗកំណត់អំពីវិសាលភាពនៃអង្គហេតុ ដែលដាក់ជូនអង្គជំនុំជម្រះពិចារណា។

## ១. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

### ក. អំពើមនុស្សឃាត

១៣០៧. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៧៣ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាត ទៅលើ "ជនដែលត្រូវបានសម្លាប់នៅតាមមន្ទីរសន្តិសុខនានា" ឧទាហរណ៍ អូរកន្សែង។ យើងបានឃើញពីខាងលើថា សហចៅក្រមស៊ើបអង្កេតបានផ្តល់ព័ត៌មានលម្អិតច្រើនជាងគេអំពីអំពើមនុស្សឃាតជាទូទៅ នៅកថាខណ្ឌ ១៣៧៤ នៃដីកាដំណោះស្រាយ និងអំពីអំពើមនុស្សឃាត នៅតាមមន្ទីរសន្តិសុខនានា ជាពិសេស នៅកថាខណ្ឌ ១៣៧៦[1320]។

១៣០៨. ការបរិយាយអង្គហេតុ ដែលកើតឡើងនៅអូរកន្សែង ពីកថាខណ្ឌ ៥៨៩ ដល់កថាខណ្ឌ ៦២៤ នៃដីកាដំណោះស្រាយ អាចឱ្យកំណត់ថា អង្គហេតុណាខ្លះទទួលបានការកំណត់ជាអំពើមនុស្សឃាត យោងតាមបទប្បញ្ញត្តិដែលបានរៀបរាប់ខាងលើ។

---

[1319] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៨១, ១៣៩១, ១៤០២, ១៤១៦, ១៤២២, ១៤៣៤, ១៤៩៤ និង ១៥១១, សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1**, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ៣-៧។

[1320] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២២៣-១២២៤។

១៣០៩. នៅកថាខណ្ឌជាច្រើននៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានលើកឡើងអំពីការស្លាប់ដោយសារ "ជំងឺ ឬការអត់អាហារ (កថាខណ្ឌ ៦០៨ និងកថាខណ្ឌ ៦២៣) ឬដោយសារការសម្លាប់ (កថាខណ្ឌ ៦១៦ ដល់កថាខណ្ឌ ៦២៣)។

១៣១០. សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋានអំពីការស្លាប់របស់ជនរងគ្រោះ ដោយរំលោភលើវិសាលភាពនៃបណ្តឹងមកកាន់ខ្លួន។ នៅកថាខណ្ឌ ៦៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជាកថាខណ្ឌតែមួយគត់ដែលប្តឹងទៅសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាបានអះអាងថា "មនុស្សប្រមាណ ២០០០ នាក់ ត្រូវស្លាប់ដោយអត់បាយ និងដោយការសម្លាប់" នៅអូរកន្សែង។ ពុំមាននិយាយអំពីការស្លាប់ដោយសារជំងឺ ឬភាពទន់ខ្សោយខាងវេជ្ជសាស្ត្រ ឬសុខភាពនោះទេ។

១៣១១. ម្យ៉ាងវិញទៀត ខ្លឹមសារនៃកថាខណ្ឌ ៦០៨ នៃដីកាដំណោះស្រាយបញ្ជាក់អំពីអវត្តមាននៃទំនាក់ទំនងរវាងកង្វះស្បៀង និងការលេចឡើងនូវជំងឺ ដោយសារតែកថាខណ្ឌនេះបានលើកឡើងអំពីភាពផ្ទុយគ្នានៃ "ជំងឺ" និង "អាហារមិនគ្រប់គ្រាន់"។ ដូច្នេះ លោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបទៅនឹងអង្គហេតុ ដែលសហចៅក្រមស៊ើបអង្កេតមិនត្រូវបានប្តឹងឱ្យស៊ើបសួរ នោះឡើយ។

១៣១២. ក្នុងចំណោមការសម្លាប់ដែលបានចោទប្រកាន់ សហចៅក្រមស៊ើបអង្កេតបានលើកឡើងអំពីការសម្លាប់ជនជាតិចាម៉ាយ (កថាខណ្ឌ ៦១៨ ដល់កថាខណ្ឌ ៦២៣) និងការសម្លាប់ជនជាតិវៀតណាមមួយក្រុមមានគ្នា ៦ នាក់ (កថាខណ្ឌ ៦២២)។ សហចៅក្រមស៊ើបអង្កេតមិនត្រូវបានប្តឹងឱ្យស៊ើបសួរលើអង្គហេតុពាក់ព័ន្ធនឹងជនជាតិចាម៉ាយ និងវៀតណាមឡើយ។ ប៉ុន្តែ ប្រសិនបើអង្គហេតុណាត្រូវបានបង្ហាញអំពីការសម្លាប់នៅអូរកន្សែង នោះសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានធ្វើឡើងនៅក្នុងវិសាលភាពនៃបណ្តឹងហើយ។

១៣១៣. ក្រុមមេធាវីការពារក្តីគិតទុកជាមុនអំពីការកត់សម្គាល់របស់សហព្រះរាជអាជ្ញា ដែលនឹងលើកឡើងអំពីបញ្ហានៃភាពស៊ីសង្វាក់គ្នា រវាងសម្តីពីមុនរបស់ក្រុមមេធាវីការពារក្តី និងសម្តីអំពីការសម្លាប់ជនជាតិវៀតណាម នៅក្រាំងតាចាន់[1321]។ ក្រុមមេធាវីការពារក្តីសូមរំឭកថា សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋានស្តីពីក្រាំងតាចាន់ ដោយរំលោភលើវិសាលភាពនៃបណ្តឹង ពីព្រោះ

[1321]សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២៣៣-១២៣៥។

សហចៅក្រមស៊ើបអង្កេតអះអាងអំពីការស្លាប់របស់ជនជាតិវៀតណាម ដោយបានស៊ើបសួរលើការជម្លៀសពីស្រុកត្រាំកក់ ទៅប្រទេសវៀតណាម ជាអង្គហេតុនៅក្រៅវិសាលភាពនៃបណ្តឹង។ ដូច្នេះ ការស៊ើបសួរដោយខុសច្បាប់បានជះឥទ្ធិពលដោយមិនរំពឹងទុក ដែលចាំបាច់ត្រូវរិះគន់ និងបដិសេធចោល ដើម្បីរក្សាភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី។ ចំពោះអូរកន្សែង ការវិភាគខុសពីនេះ។ សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីអង្គហេតុនៃការសម្លាប់ ហើយការស៊ើបសួរលើទីតាំងនេះហាក់ដូចជាបង្ហាញអំពីការសម្លាប់ជនជាតិចារ៉ាយ និងវៀតណាម។ ប្រការនេះមិននាំឱ្យមានការរិះគន់ទៅលើកិច្ចដំណើរការនីតិវិធីនោះទេ ពីព្រោះសេចក្តីសន្និដ្ឋាននេះមិនមានផលប៉ះពាល់អ្វីទៅលើអង្គហេតុផ្សេងទៀត ដែលសហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹង នោះឡើយ។

១៣១៤. អាស្រ័យហេតុនេះ លោក ខៀវ សំផន ត្រូវឆ្លើយតបទៅនឹងអង្គហេតុនៃការស្លាប់នៅអូរកន្សែង លើកលែងតែការស្លាប់ដោយសារជំងឺ។

## ខ. ការសម្លាប់រង្គាល

១៣១៥. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៨១ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមរូបភាពជាការសម្លាប់រង្គាល ទៅលើ “ជនដែលត្រូវបានសម្លាប់ឬជនដែលបានស្លាប់ក្នុងទ្រង់ទ្រាយធំ” នៅតាមមន្ទីរសន្តិសុខនានា រួមមានអូរកន្សែង។

១៣១៦. បើតាមទម្លើករណ៍ស្រដៀងគ្នាទៅនឹងទម្លើករណ៍ដែលបានលើកឡើងខាងលើ ពាក់ព័ន្ធនឹងការកំណត់បទចោទនៅក្រាំងតាចាន់ សហចៅក្រមស៊ើបអង្កេតគ្រាន់តែបានកំណត់ថាជាការសម្លាប់រង្គាលនូវការស្លាប់ ដែលពីដំបូង ត្រូវបានកំណត់ថាជាអំពើមនុស្សឃាត[1322]។ គ្មានអង្គហេតុបន្ថែមណាមួយត្រូវបានទទួលយកឡើយ។

១៣១៧. ដូច្នេះ លោក ខៀវ សំផន ត្រូវឆ្លើយតបទៅនឹងអង្គហេតុនៃការស្លាប់ទាំងអស់នៅអូរកន្សែង លើកលែងតែការស្លាប់ដោយសារជំងឺ។

---

[1322] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២៣៧-១២៤១។

## គ. ការធ្វើឱ្យនៅជាទាសករ

១៣១៨. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយ ថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ នៅអូរកន្សែង។ ដូចបានឃើញខាងលើ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅកថាខណ្ឌ ១៣៩២ និងកថាខណ្ឌ ១៣៩៤ ថា ឧក្រិដ្ឋកម្មបានសម្រេចឡើង ដោយការបំពេញធាតុផ្សំពីរ៖ ការអនុវត្តការគ្រប់គ្រងជាបន្តទៅលើអ្នកទោស និងការបង្ខំឱ្យពួកធ្វើការ ដោយគ្មានប្រាក់កម្រៃ[1323]។

១៣១៩. ភាពច្បាស់លាស់នៃឧក្រិដ្ឋកម្មនេះ ផ្អែកលើសេចក្តីសន្និដ្ឋានអំពីអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេត នៅកថាខណ្ឌ ៦០៥ នៃដីកាដំណោះស្រាយ ដែលបញ្ជាក់ជាច្រើនលើកច្រើនសាថាអ្នកទោសនៅមន្ទីរសន្តិសុខត្រូវធ្វើការ។

១៣២០. លោក ខៀវ សំផន ត្រូវឆ្លើយតបទៅនឹងអង្គហេតុទាំងអស់ ដែលត្រូវបានលើកឡើង ដើម្បីគាំទ្រដល់ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។

## ឃ. ការដាក់ក្នុងមន្ទីរឃុំឃាំង

១៣២១. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានៅកថាខណ្ឌ ១៤០២ នៃដីកាដំណោះស្រាយ ថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមរូបភាពជាការដាក់ក្នុងមន្ទីរឃុំឃាំង នៅអូរកន្សែង ពីព្រោះ "ជនរងគ្រោះត្រូវបានដកហូតសេរីភាពយ៉ាងតឹងរ៉ឹង តាមទំនើងចិត្ត ដោយបំពានទៅលើសិទ្ធិនានាដែលមានចែងនៅក្នុងច្បាប់"[1324]។

---

[1323] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៦៧-៨៦៩។

[1324] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០៣។ សូមមើលផងដែរ ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០៥។

១៣២២. ការកំណត់នេះផ្អែកលើអង្គហេតុនៃការឃុំឃាំងទាំងអស់ ដូចបានរៀបរាប់ ពីកថាខណ្ឌ ៦០៥ ដល់កថាខណ្ឌ ៦០៩ នៃដីកាដំណោះស្រាយ ដែលលោក ខៀវ សំផន ត្រូវឆ្លើយតប។

## ខ. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

១៣២៣. នៅកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅអូរកន្សែង។

១៣២៤. នៅក្នុងជំពូកស្ដីពីសហករណ៍ត្រាំកក់ យើងបានឃើញថា មានតែមនុស្សបីក្រុមប៉ុណ្ណោះដែលត្រូវបានកំណត់ នៅកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយ ថាជាមុខសញ្ញានៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងខ្មែរមកពីបរទេស[1325]។

១៣២៥. ការកំណត់ប្រភេទបទល្មើសនេះផ្ទុយនឹងអង្គហេតុ ដូចបានរៀបរាប់ពីកថាខណ្ឌ ៥៨៩ ដល់កថាខណ្ឌ ៦១៥ នៃដីកាដំណោះស្រាយ ស្ដីពីអូរកន្សែង ពីព្រោះពុំមានលើកឡើងអំពីក្រុមណាមួយដែលត្រូវបានកំណត់ នៅកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយឡើយ។ ដូច្នេះ លោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបទៅនឹងអង្គហេតុទាំងនេះទេ។

## គ. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍

១៣២៦. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤២២ នៃដីកាដំណោះស្រាយ ថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ ទៅលើជនជាតិវៀតណាម នៅអូរកន្សែង ។

---

[1325] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៨៤-៨៨៥។

១៣២៧. អង្គហេតុគាំទ្រដល់ការចោទប្រកាន់នេះ ត្រូវបានរៀបរាប់ នៅកថាខណ្ឌ ៦២២ នៃដីកាដំណោះស្រាយ ស្តីពីការសម្លាប់ជនជាតិវៀតណាម។ យើងសង្ស័យថា តើសហចៅក្រមស៊ើបអង្កេតចង់បញ្ចូលឧក្រិដ្ឋកម្មចំពោះជនជាតិចាម៉ាយនៅអូរកន្សែង ក្នុងប្រភេទនៃការធ្វើទុក្ខបុកម្នេញ ដែរឬទេ?

១៣២៨. ចម្លើយទៅនឹងសំណួរនេះមិនមានប្រយោជន៍ជាដុំកំភួននោះទេ ពីព្រោះ ទោះជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេតមិនត្រូវបានប្តឹងឱ្យស៊ើបសួរលើអង្គហេតុនៃការរើសអើងពូជសាសន៍ នៅអូរកន្សែងនោះឡើយ។

១៣២៩. នេះជាឧទាហរណ៍នៃការប្រាសចាកពីគោលការណ៍ ដូចបានលើកឡើងនៅចុងកថាខណ្ឌ ១៣១៣ នៃសារណានេះ។ ដោយទទួលបានបណ្តឹងអំពីអង្គហេតុនៃការសម្លាប់នៅអូរកន្សែង សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋាននៅក្នុងព្រំដែននៃសមត្ថកិច្ចរបស់ខ្លួន អំពីការស្លាប់របស់ជនជាតិវៀតណាម និងចាម៉ាយ។ ផ្ទុយទៅវិញ ព័ត៌មាននេះមិនផ្តល់សិទ្ធិឱ្យសហចៅក្រមស៊ើបអង្កេតស៊ើបសួរលើការប្រព្រឹត្តិជាក់លាក់ណាមួយទៅលើបុគ្គលទាំងនេះទេ។ ដូច្នេះ រាល់សេចក្តីសន្និដ្ឋានបម្រើដល់អំណះអំណាងនេះ គឺខុសច្បាប់។ លោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបនោះទេ។

## ឆ. អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស)

១៣៣០. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស) នៅអូរកន្សែង។

១៣៣១. កថាខណ្ឌ ១៤៣៨ រៀបរាប់លម្អិតអំពីធាតុផ្សំដែលសហចៅក្រមស៊ើបអង្កេតបានយកមកពិចារណា ដើម្បីពិនិត្យមើលឧក្រិដ្ឋកម្មដែលកើតឡើង (អាហារមិនគ្រប់គ្រាន់សម្រាប់អ្នកជាប់ឃុំ លក្ខខណ្ឌឃុំឃាំងគួរឱ្យអាណោចអាធ័ម កង្វះអនាម័យ...)។ ធាតុផ្សំទាំងនេះត្រូវបានរៀបរាប់ ពីកថាខណ្ឌ ៦០៥ ដល់កថាខណ្ឌ ៦០៩ នៃដីកាដំណោះស្រាយ ក្រោមចំណងជើង "ការឃុំឃាំង"។

១៣៣២. ដូចបានឃើញពីខាងលើ លោក ខៀវ សំផន ត្រូវឆ្លើយតបទៅនឹងអង្គហេតុទាំងនេះ លើកលែងតែ អង្គហេតុពាក់ព័ន្ធនឹងការព្យាបាលអ្នកទោស ដែលសហចៅក្រមស៊ើបអង្កេតមិនបានទទួលបណ្តឹង។

១៣៣៣. កថាខណ្ឌ ១៤៣៨ ក៏បានលើកឡើងផងដែរអំពី "ការទទួលរងការធ្វើបាបពីសំណាក់កងសន្តិសុខ និងអ្នកសួរចម្លើយ" ដែលយោងទៅកថាខណ្ឌ ៦១០ ដល់កថាខណ្ឌ ៦១៥ ស្តីពី "ការសួរចម្លើយ"។ សេចក្តីសន្និដ្ឋានទាំងអស់របស់សហចៅក្រមស៊ើបអង្កេតលើប្រធានបទនេះ គឺខុសច្បាប់ ពីព្រោះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម មិនបានប្តឹងទៅ សហចៅក្រមស៊ើបអង្កេតឱ្យស៊ើបសួរលើចំណុចនេះទេ[1326]។ ដូច្នេះ លោក ខៀវ សំផន មិនចាំបាច់ ត្រូវឆ្លើយតបនោះទេ។

## ២. ការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ

### ក. អំពើមនុស្សឃាតដោយចេតនា

១៣៣៤. សហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋាន ពីកថាខណ្ឌ ១៤៩៤ ដល់កថាខណ្ឌ ១៤៩៥ ថា អំពើ មនុស្សឃាតដោយចេតនា ដែលបង្កើតបានជារំលោភបំពាន់ធ្ងន់ធ្ងន់ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានប្រព្រឹត្តទៅលើ "អ្នកជាប់ឃុំជាជនជាតិចាវ៉ាយ [...] រួមទាំងស្ត្រី និងកុមារផងដែរ"។

១៣៣៥. ដូចយើងបានលើកឡើងនៅពេលវិភាគទៅលើបទចោទពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាអំពើ មនុស្សឃាត ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការចោទប្រកាន់នេះផ្អែកលើអង្គហេតុ ដូច បានរៀបរាប់ ពីកថាខណ្ឌ ៦១៨ ដល់កថាខណ្ឌ ៦២១ និងកថាខណ្ឌ ៦២៣ នៃដីកាដំណោះស្រាយ ដែលលោក ខៀវ សំផន ត្រូវតែឆ្លើយតប។

### ខ. ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់សេចក្តី ប្រកបដោយយុត្តិធម៌ និងទៀងទាត់

---

[1326] សូមមើល ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៧។

១៣៣៦. សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្ដីសន្និដ្ឋាន ពីកថាខណ្ឌ ១៥១១ ដល់កថាខណ្ឌ ១៥១៤ ថា បុគ្គលិកអូរកន្សែងបានដកហូតពីជនជាតិចាវ៉ាយ នូវសិទ្ធិទទួលបានការកាត់សេចក្ដីប្រកបដោយយុត្តិធម៌ និងទៀងទាត់ ជាបទល្មើសនៃការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។

១៣៣៧. កថាខណ្ឌ ១៥១៣ នៃដីកាដំណោះស្រាយ បានរៀបរាប់អំពីសិទ្ធិមួយចំនួន ដែលដកហូតពីជនជាតិចាវ៉ាយ ដូចជា សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយតុលាការមួយឯករាជ្យ និងអនាគតិ សិទ្ធិទទួលបានការជូនដំណឹងយ៉ាងឆាប់រហ័សអំពីបទល្មើសដែលខ្លួនត្រូវបានចោទប្រកាន់ ឬសិទ្ធិសច្ចធារណ៍និរទោស។

១៣៣៨. នៅក្នុងផ្នែកអង្គហេតុស្ដីពីជនជាតិចាវ៉ាយ នៅអូរកន្សែង (ពីកថាខណ្ឌ ៦១៨ ដល់កថាខណ្ឌ ៦២១ និងកថាខណ្ឌ ៦២៣) ពុំមានការបញ្ជាក់ថា កេតនភណ្ឌនៃបុគ្គលភាពគតិយុត្តទាំងនេះ (ដែលជនជាប់ឃុំគ្រប់រូបនៅតាមតំបន់ជនបទកម្ពុជា ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ឬជនជាប់ចោទ នៅទីក្រុងភ្នំពេញ នៅក្នុងការជំនុំជម្រះក្ដីអន្តរជាតិ នៅឆ្នាំ ២០១៧ ត្រូវទទួលបាន) ត្រូវបានដកហូតពីជនជាតិចាវ៉ាយឡើយ។

១៣៣៩. ដោយមិនផ្អែកលើអង្គហេតុជាសត្យានុម័តិដែលគាំទ្រដោយភ័ស្តុតាងពាក់ព័ន្ធ ការចោទប្រកាន់នេះមិនមានមូលដ្ឋានតាមផ្លូវច្បាប់ឡើយ។ ដូច្នេះ លោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបទៅនឹងការចោទប្រកាន់ដែលមិនផ្អែកលើអង្គហេតុរូបីឡើយ។

១៣៤០. ម្យ៉ាងវិញទៀត ទោះបីជាឧបមាថាការចោទប្រកាន់នេះមានមូលហេតុត្រឹមត្រូវក៏ដោយ ក៏ការចោទប្រកាន់នេះ គឺខុសច្បាប់ ពីព្រោះពុំមានការលើកឡើងអំពីការលុបបំបាត់សិទ្ធិជាមូលដ្ឋានរបស់អ្នកទោស នៅកថាខណ្ឌ ៦៧ ស្ដីពីអូរកន្សែង នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឡើយ។

## ផ្នែកទី ២. ការបង្ហាញភ័ស្តុតាង

១៣៤១. ក្នុងចំណោមភ័ស្តុតាង ដែលបានបង្ហាញជូនក្នុងពេលជំនុំជម្រះក្តី (១) ភ័ស្តុតាងជាច្រើនស្ថិតនៅក្រៅយុត្តាធិការរបស់អង្គជំនុំជម្រះ (២)។ ភ័ស្តុតាងខ្លះទៀតអាចឱ្យយើងគិតថា ឧក្រិដ្ឋកម្មមួយចំនួនអាចមានធាតុផ្សំគ្រប់គ្រាន់ (៣)។

## ១. បញ្ជីភ័ស្តុតាង

១៣៤២. ពីថ្ងៃទី ០២ ដល់ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៦ សាក្សី ៣ នាក់ បានមកផ្តល់សក្ខីកម្ម នៅសវនាការក្នុងវគ្គស្តីពីមន្ទីរសន្តិសុខអូរកន្សែង។ ក្នុងចំណោមសាក្សីទាំង ៣ នាក់នេះ ២ នាក់ ជាអ្នកទោសនៅអូរកន្សែង និងម្នាក់ជាកម្មាភិបាល។

១៣៤៣. បុគ្គលទាំង ៣ រូបនេះ ស្ថិតនៅក្នុងបញ្ជីបឋមរបស់អង្គជំនុំជម្រះ ផ្ញើជូននៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦[1327]។ បុគ្គលចុងក្រោយស្ថិតនៅក្នុងបញ្ជីនេះ គឺសាក្សី 2-TCW-840។ នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា បុគ្គលរូបនេះបានទទួលមរណភាពហើយ[1328]។ ដូច្នេះ យោងតាមនីតិវិធីដូចសព្វមួយដង កំណត់ហេតុស្តាប់ចម្លើយរបស់គាត់អាចត្រូវបានប្រើប្រាស់ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ដោយប្រុងប្រយ័ត្ន[1329]។

១៣៤៤. កំណត់ហេតុស្តាប់ចម្លើយជាច្រើនទៀតមាននៅក្នុងសំណុំរឿង ឧទាហរណ៍ កំណត់ហេតុស្តាប់ចម្លើយ ដោយអ្នកស៊ើបអង្កេត ក្នុងអំឡុងកិច្ចស៊ើបសួរលើសំណុំរឿង ០០២។

## ២. ភ័ស្តុតាងក្រៅវិសាលភាព

---

[1327]សារអេឡិកត្រូនិករបស់អ្នកច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះ មានចំណងជើងថា “ការរៀបចំកម្មវិធី-មន្ទីរសន្តិសុខអូរកន្សែង” ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ (ភាសាអង់គ្លេស)។

[1328]សារអេឡិកត្រូនិករបស់អ្នកច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះ មានចំណងជើងថា “2-TCW-840” ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ (ភាសាអង់គ្លេស)។

[1329]សូមមើលផ្នែកខាងលើ កថាខណ្ឌ ៥២៥-៥៥១។

១៣៤៥. ជាថ្មីម្តងទៀត អង្គជំនុំជម្រះបានអនុញ្ញាតឱ្យបង្ហាញភ័ស្តុតាងនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តីដោយសេរី។

១៣៤៦. នេះជាករណីនៃភ័ស្តុតាងដែលបានមកពីសក្ខីកម្មផ្ទាល់មាត់ទាំងអស់ ពាក់ព័ន្ធនឹងអង្គហេតុនៃការសួរចម្លើយ ឬការធ្វើទារុណកម្ម នៅអូរកន្សែង ខណៈដែលគ្មានអង្គហេតុនៃការធ្វើទារុណកម្មណាមួយត្រូវបានដីកាដំណោះស្រាយបញ្ជូនទៅឱ្យអង្គជំនុំជម្រះពិចារណាឡើយ[1330]។

១៣៤៧. ដូចគ្នាផងដែរ ជាឧទាហរណ៍ដដែល ចម្លើយរបស់សាក្សីមួយរូប នៅក្នុងសវនាការ ទៅនឹងសំណួររបស់សហព្រះរាជអាជ្ញារង Travis FARR ពាក់ព័ន្ធនឹងការងាររបស់គាត់នៅក្នុងចម្ការកៅស៊ូ ស្ថិតនៅក្រៅវិសាលភាពទាំងស្រុងនៃសំណុំរឿង ០០២[1331]។

## ៣. ភ័ស្តុតាងអំពីឧក្រិដ្ឋកម្មមួយចំនួន

១៣៤៨. ភ័ស្តុតាងមួយផ្នែកដែលបានបង្ហាញ អាចនាំឱ្យយើងគិតថា មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យក្លាយជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការសម្លាប់មនុស្សដោយចេតនា ដែលជាការរំលោភបំពានទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។

១៣៤៩. ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតបានកំណត់ថាជាអំពើអនុស្សធម៌ផ្សេងទៀត នូវអង្គហេតុនៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស។

[1330] ឧទាហរណ៍ សូមមើល <u>ផន ធុល</u> ប្រតិចារឹក ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/395.1** ទំព័រ ៤៦-៤៨ ចន្លោះម៉ោង [១៣.៣៩.៥៦] និង [១៣.៤៨.៤០], <u>មៀង ចាន់ឌី</u> ប្រតិចារឹក ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/396.1** ទំព័រ ៣១-៣៨ ចន្លោះម៉ោង [១១.០២.០៩] និង [១១.២១.២៨], <u>2-TCW-900</u> ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ៦៣-៦៤ ចន្លោះម៉ោង [១៥.២៨.២២] និង [១៥.៣៤.៣៥]។

[1331] <u>ផន ធុល</u> ប្រតិចារឹក ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/395.1** ទំព័រ ២៧-២៩ ចន្លោះម៉ោង [១០.៤១.០៣] និង [១០.៤៧.២៦]។

១៣៥០. យោងតាមវិធីសាស្ត្រ "ទូទៅ" របស់អង្គជំនុំជម្រះតុលាការកំពូល នៅសម័យកាលកើតអង្គហេតុ ប្រភេទនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលនៅសេសសល់ មិនមានបែងចែកជាអនុប្រភេទ ដូចបានគ្រោងឡើងក្នុងដីកាដំណោះស្រាយ និងសាលក្រមលើសំណុំរឿង ០០២/០១ នោះទេ[1332]។ ក្រុមមេធាវីការពារក្តីមិនជំទាស់នឹងការវិភាគនេះទេ ហើយក៏មិនជំទាស់ដែរថា អំពើដែលអាចកំណត់ជាទូទៅថាជាអំពើអមនុស្សធម៌ផ្សេងទៀត អាចកើតឡើង នៅអូរកន្សែង។

**ជំពូកទី ៤. ត្នំក្រោល**

**ផ្នែកទី ១. បទចោទ**

១៣៥១. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់ពីអង្គហេតុដែលបានកើតឡើង នៅមន្ទីរសន្តិសុខភ្នំក្រោល ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតកំណត់នៅក្នុងដីកាដំណោះស្រាយថា ជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស និងការបាត់ខ្លួនដោយបង្ខំ) ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1333]។

១៣៥២. រចនាសម្ព័ន្ធទីតាំងភ្នំក្រោលមានចរិតលក្ខណៈដែលត្រូវបញ្ជាក់ ដើម្បីឱ្យយល់ថាតើបទចោទត្រូវបានរៀបចំយ៉ាងដូចម្តេច (១)។ ការពិនិត្យមើលបទចោទអាចឱ្យកំណត់បាននូវវិសាលភាពនៃអង្គហេតុដែលដាក់ជូនអង្គជំនុំជម្រះពិចារណា។ ជួនកាល សហចៅក្រមស៊ើបអង្កេតធ្វើហួសវិសាលភាពនៃបណ្តឹង ពាក់ព័ន្ធនឹងអាណត្តិការងារ ដែលសហព្រះរាជអាជ្ញាបានប្រគល់ជូនពីដំបូង (២)។

---

[1332] សាលដីកា ០០២/០១ កថាខណ្ឌ ៥៧២-៥៩០, សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ២៤០០-២៤០៦ និង ២៤១០។

[1333] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣, ១៣៨១, ១៣៩១, ១៤០២, ១៤០៨, ១៤១៦, ១៤៣៤ និង ១៤៧០, សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1**, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ៣-៧។

## ១. ការកម្រិតផ្នែកភូមិសាស្ត្រនៃបទចោទ

១៣៥៣. នៅក្នុងផ្នែក "ការកំណត់ប្រភេទបទល្មើស" នៃដីកាសំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបាន អះអាងថាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តនៅ "ភ្នំក្រោល"។ ផ្ទុយទៅវិញ ការវិភាគអង្គហេតុ ពីកថាខណ្ឌ ៦២៥ ដល់កថាខណ្ឌ ៦៤២ នៃដីកាដំណោះស្រាយ ស្តីពី "មន្ទីរសន្តិសុខភ្នំក្រោល" លើកឡើងអំពី ចំណុចលម្អិតនៃសមាសភាពកន្លែងនោះ។

១៣៥៤. ពេលចាប់ផ្តើមការវិភាគរបស់ខ្លួន ក្រោមចំណងជើង "ទីតាំង និងការបង្កើត" សហចៅក្រមស៊ើប អង្កេតបានជូនដំណឹងអំពីអត្ថិភាពនៃមន្ទីរសន្តិសុខមួយឈ្មោះភ្នំក្រោល និងទីតាំងពីរទៀត "ដែលមាន ទំនាក់ទំនងគ្នា" គឺ មន្ទីរ ក-១១ និង ក-១៧[1334]។

១៣៥៥. នៅកថាខណ្ឌ ៦២៦ សហចៅក្រមស៊ើបអង្កេតផ្តល់ព័ត៌មានលម្អិតអំពីរចនាសម្ព័ន្ធ ទីកន្លែង និងការ ប្រើប្រាស់ទីតាំងទាំងបីនេះ៖

> "គុកភ្នំក្រោលធ្វើពីឈើ ក្រាលរនាបឫស្សី មានដំបូលប្រក់ស្បូវ។ មន្ទីរ ក-១៧ ជាអគារមានកម្ពស់ពីរជាន់ ជញ្ជាំងក្តារ ប្រក់ស័ង្កសី។ មន្ទីរនេះដំណើរការជាកន្លែងធ្វើការរបស់លេខាតំបន់ ១០៥ និងធ្លាប់ជាកន្លែងឃុំ ខ្លួនបណ្តោះអាសន្នមួយរយៈពេលផងដែរ។ មន្ទីរ ក-១១ ស្ថិតនៅចម្ងាយប្រហែល ១ គីឡូម៉ែត្រ ភាគឦសាន ពីគុកភ្នំក្រោល ដែលដំណើរការជាមន្ទីរឃុំឃាំង និងជាកន្លែងធ្វើការរបស់កងទ័ព។ មន្ទីរនេះធ្វើពីឈើ មាន ដំបូលប្រក់ស្បូវ ជញ្ជាំងឫស្សី និងក្រាលរនាបក្តារ"។

១៣៥៦. បន្ទាប់មក នៅកថាខណ្ឌ ៦២៧ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ត្រពាំងព្រីង "គឺជាកន្លែង សម្លាប់មនុស្សរបស់មន្ទីរសន្តិសុខនេះ"។

១៣៥៧. ដូច្នេះ យើងត្រូវយល់ថានៅក្នុងផ្នែក "ការកំណត់ប្រភេទបទល្មើស" ក្រោមចំណងជើង "ភ្នំក្រោល" សហចៅក្រមស៊ើបអង្កេតបាននិយាយសំដៅដល់ទីតាំងទាំងបួនតែម្តង គឺ ភ្នំក្រោល ក-១១ ក-១៧ និងត្រពាំងព្រីង។

---

[1334] ដីកាដំណោះស្រាយ កថាខណ្ឌ ៦២៥។

១៣៥៨. សេចក្តីសន្និដ្ឋានទាំងនេះរបស់សហចៅក្រមស៊ើបអង្កេត គឺជាលទ្ធផលនៃការស៊ើបសួរ ដោយផ្អែកលើកថាខណ្ឌ ៦៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងកថាខណ្ឌ ៨ ដល់កថាខណ្ឌ ១១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

១៣៥៩. កថាខណ្ឌ ៦៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានលើកឡើងអំពីមន្ទីរសន្តិសុខតែមួយគត់ឈ្មោះភ្នំក្រោល ដែលត្រូវបានរៀបរាប់ថាជា "អតីតមន្ទីរដ្ឋបាលនៃតំបន់ ១០៥" និងបានដំណើរការពីឆ្នាំ ១៩៧៧ ដល់ខែ មករា ឆ្នាំ ១៩៧៩។ អ្នកទោសពីរប្រភេទត្រូវបានឃុំនៅទីនោះ៖ អ្នកទោសឋានៈខ្ពស់ "នៅក្នុងបន្ទប់ជាន់លើធ្វើពីឈើ" និងអ្នកទោសធម្មតា "នៅផ្ទាល់ដី"។ ទោះបីជាមានការលើកឡើងតែអំពីទីតាំង "ភ្នំក្រោល" ក៏ដោយ ក៏ការពិពណ៌នាអំពីទីកន្លែងនេះត្រូវគ្នានឹងមន្ទីរ ក-១៧ ជាជាងភ្នំក្រោល ដែលត្រូវបានរៀបរាប់នៅកថាខណ្ឌ ៦២៦ នៃដីកាដំណោះស្រាយ។

១៣៦០. ការយល់ឃើញបែបនេះត្រូវបានគាំទ្រដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលសហព្រះរាជអាជ្ញាបានចេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ ដើម្បី "បញ្ជាក់ និងបំពេញបន្ថែមអង្គហេតុ" ដែលសហចៅក្រមស៊ើបអង្កេតត្រូវស៊ើបសួរ[1335]។

១៣៦១. សហព្រះរាជអាជ្ញាបានប្តឹងសហចៅក្រមស៊ើបអង្កេតឱ្យស៊ើបសួរទៅលើអង្គហេតុ ដែលកើតឡើងនៅ "មន្ទីរសន្តិសុខពីរ" ដែលត្រូវបានធ្វើបច្ចុប្បន្នភាពដោយកិច្ចស៊ើបសួរ ផ្អែកលើកថាខណ្ឌ ៦៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺ មន្ទីរ ក-១១ និងមន្ទីរសន្តិសុខទំនប់ភ្នំក្រោល[1336]។

១៣៦២. ខុសពីអតីតមន្ទីរតំបន់ ១០៥ ដូចបានរៀបរាប់នៅកថាខណ្ឌ ៦៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បើតាមសហព្រះរាជអាជ្ញា មន្ទីរទាំងពីរនេះបានដំណើរការ "ចាប់ពីខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩"។

១៣៦៣.ម្យ៉ាងទៀត កថាខណ្ឌ ៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម បានលើកឡើងអំពីអត្ថិភាពនៃទីតាំងសម្លាប់មនុស្សត្រពាំងព្រីង ដែលសហចៅក្រមស៊ើបអង្កេតទទួលភារៈស៊ើបសួរផងដែរ។

---

[1335] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ **ឯកសារ D202** កថាខណ្ឌ ១ និង ៨។

[1336] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ **ឯកសារ D202** កថាខណ្ឌ ៨-១១។

១៣៦៤. សេចក្តីបញ្ជាក់ទាំងនេះមានសារៈសំខាន់ណាស់ ពីព្រោះនៅក្រោមចំណងជើង "ភ្នំក្រោល" ក្នុងផ្នែក "ការកំណត់ប្រភេទបទល្មើស" នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតអាចចង់និយាយសំដៅដល់ទីតាំងទាំងបួន ដូចបានលើកឡើងខាងលើ។ ផ្ទុយទៅវិញ អង្គហេតុអំពីទីតាំងនីមួយៗដែលប្តឹងទៅសហចៅក្រមស៊ើបអង្កេត ត្រូវបានកំណត់ខុសពីគ្នា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

## ២. ការកម្រិតជាក់ស្តែងនៃបទចោទ

### ក. អំពើមនុស្សឃាត

១៣៦៥. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៧៣ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាត ទៅលើ "ជនដែលត្រូវបានសម្លាប់នៅតាមមន្ទីរសន្តិសុខនានា" ដូចជា ភ្នំក្រោល។ សហចៅក្រមស៊ើបអង្កេតបានផ្តល់ព័ត៌មានលម្អិតអំពីអំពើមនុស្សឃាតជាទូទៅ នៅកថាខណ្ឌ ១៣៧៤ នៃដីកាដំណោះស្រាយ និងអំពីអំពើមនុស្សឃាត នៅតាមមន្ទីរសន្តិសុខនានា ជាពិសេស នៅកថាខណ្ឌ ១៣៧៦[1337]។

១៣៦៦. ការបរិយាយអង្គហេតុដែលកើតឡើងនៅភ្នំក្រោល ពីកថាខណ្ឌ ៦២៥ ដល់កថាខណ្ឌ ៦៤២ នៃដីកាដំណោះស្រាយ អាចឱ្យកំណត់ថា អង្គហេតុទាំងនេះទទួលបានប្រភេទជាអំពើមនុស្សឃាត យោងតាមបទប្បញ្ញត្តិដែលបានរៀបរាប់ខាងលើ។

១៣៦៧. មានតែកថាខណ្ឌ ៦៤១ និងកថាខណ្ឌ ៦៤២ ប៉ុណ្ណោះ លើកឡើងអំពីការស្លាប់របស់ទោស និយាយឱ្យចំ គឺការសម្លាប់អ្នកទោស។ យោងតាមកថាខណ្ឌ ៦៤១ អ្នកទោសត្រូវគេវាយរហូតដល់ស្លាប់នៅភ្នំក្រោល។ ដូចគ្នាផងដែរ មនុស្សមួយចំនួនត្រូវបានគេដឹកចេញពីមន្ទីរ ក-១១ យកទៅសម្លាប់។ យើងតាមកថាខណ្ឌ ៦៤២ សហចៅក្រមស៊ើបអង្កេតបានអះអាងថា ត្រពាំងព្រីង ជាកន្លែងសម្លាប់

[1337]សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២២៣-១២២៤។

មនុស្ស ហើយមនុស្សប្រហែល ២០០ នាក់ ត្រូវបានកប់ក្នុងរណ្តៅតែមួយនៅត្រពាំងព្រីង។ ម្យ៉ាងវិញទៀត "អ្នកទោសត្រូវបានគេសម្លាប់នៅក្បែរគុកភ្នំក្រោល"។

១៣៦៨. ដូច្នេះ លោក ខៀវ សំផន ត្រូវឆ្លើយតបទៅនឹងអង្គហេតុនៃការសម្លាប់មនុស្ស ដូចបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ។

## ខ. ការសម្លាប់រង្គាល

១៣៦៩. ក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅកថាខណ្ឌ ១៣៨១ ថាឧក្រិដ្ឋកម្មសម្លាប់រង្គាលមានធាតុផ្សំគ្រប់គ្រាន់ ហើយពាក់ព័ន្ធទៅនឹង "ជនដែលត្រូវបានសម្លាប់ ឬជនដែលបានស្លាប់ ក្នុងទ្រង់ទ្រាយធំ នៅតាមមន្ទីរសន្តិសុខនានា" ដូចជា ភ្នំក្រោល ជាដើម។

១៣៧០. បើតាមទឡ្ហីករណ៍ស្រដៀងគ្នាទៅនឹងទឡ្ហីករណ៍ដែលបានលើកឡើងខាងលើ ពាក់ព័ន្ធនឹងការកំណត់បទចោទនៅក្រាំងតាចាន់ សហចៅក្រមស៊ើបអង្កេតគ្រាន់តែបានកំណត់ថាជាការសម្លាប់រង្គាលនូវការស្លាប់ ដែលពីដំបូង ត្រូវបានកំណត់ថាជាអំពើមនុស្សឃាត[1338]។ គ្មានអង្គហេតុបន្ថែមណាមួយត្រូវបានទទួលយកឡើយ។

១៣៧១. លោក ខៀវ សំផន ត្រូវឆ្លើយតបទៅនឹងអង្គហេតុដូចគ្នានឹងអង្គហេតុ ដូចបានរៀបរាប់ នៅក្នុងផ្នែក "ក. អំពើមនុស្សឃាត"[1339]។

## គ. ការធ្វើឱ្យទៅជាទាសករ

១៣៧២. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយ ថា ឧក្រិដ្ឋកម្មនៃការធ្វើឱ្យជាទាសករនៅភ្នំក្រោល មានធាតុផ្សំគ្រប់គ្រាន់។

---

[1338]សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២៣៧-១២៤១។

[1339]សូមមើលផ្នែកខាងលើ កថាខណ្ឌ ១៣៦៥-១៣៦៨។

១៣៧៣. ដូចយើងបានឃើញពីខាងលើ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៣៩២ និង កថាខណ្ឌ ១៣៩៤ ថា ឧក្រិដ្ឋកម្មបានសម្រេចឡើង ដោយការបំពេញធាតុផ្សំពីរ៖ ការអនុវត្តការគ្រប់គ្រងជាបន្តទៅលើអ្នកទោស និងការបង្ខំឱ្យពួកធ្វើការ ដោយគ្មានប្រាក់កម្រៃ[1340]។

១៣៧៤. ភាពច្បាស់លាស់នៃឧក្រិដ្ឋកម្មនេះ ផ្អែកលើសេចក្ដីសន្និដ្ឋានអំពីអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេត នៅកថាខណ្ឌ ៦៣៦ ដល់កថាខណ្ឌ ៦៣៨ នៃដីកាដំណោះស្រាយ ស្ដីពីអង្គហេតុនៃការបង្ខំអ្នកទោសឱ្យធ្វើការ។

១៣៧៥. យោងតាមកថាខណ្ឌ ៦៣៦ សហចៅក្រមស៊ើបអង្កេតបានអះអាងថា "យោងតាមសក្ខីកម្មមួយចំនួន អ្នកទោសស្រាលមិនត្រូវបានគេដាក់ខ្នោះទេ ដោយពេលថ្ងៃគេឱ្យអ្នកទោសទាំងនោះធ្វើការ" ដោយមិនបានបញ្ជាក់ថាទៅធ្វើការនៅការដ្ឋានណានោះទេ។

១៣៧៦. យោងតាមកថាខណ្ឌ ៦៣៨ សហចៅក្រមស៊ើបអង្កេតបានអះអាងថា "អ្នកទោសស្រាលនៅមន្ទីរសន្ដិសុខភ្នំក្រោលត្រូវគេបង្ខំឱ្យធ្វើការនៅពេលថ្ងៃ ដោយដៃមានជាប់ចំណង"។

១៣៧៧. ក្នុងចំណោមសេចក្ដីសន្និដ្ឋានទាំងពីរនេះ មានតែសេចក្ដីសន្និដ្ឋាននៅកថាខណ្ឌ ៦៣៦ ប៉ុណ្ណោះ ដែលត្រូវបានធ្វើឡើង ដោយគោរពវិសាលភាពនៃបណ្ដឹងទៅកាន់សហចៅក្រមស៊ើបអង្កេត ដែលត្រូវបានកំណត់ដោយកថាខណ្ឌ ៨ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម សម្រាប់អង្គហេតុនៃការធ្វើការដោយបង្ខំ៖

> "មន្ទីរ ក-១១ ត្រូវបានគេប្រើប្រាស់ពីដំបូងធ្វើជាកន្លែងឃុំខ្លួនបណ្ដោះអាសន្នមួយ ដែលពួកអ្នកទោសត្រូវបានបញ្ជូនពីទីនោះទៅកាន់ភ្នំក្រោលដើម្បីដាក់គុក <u>អប់រំកែប្រែ តាមការដ្ឋានមូលដ្ឋាន</u> [...]" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1340]សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៦៧-៨៦៩។

១៣៧៨. សហព្រះរាជអាជ្ញាបានប្ដឹងទៅសហចៅក្រមស៊ើបអង្កេតឱ្យស៊ើបសួរតែ លើអង្គហេតុនៃការបង្ខំអ្នកទោសឱ្យធ្វើការ នៅមន្ទីរ ក-១១ ដោយដកចេញនូវអង្គហេតុពាក់ព័ន្ធនឹងអ្នកទោស នៅមន្ទីរ ក-១៧ និងភ្នំក្រោល។

១៣៧៩. ដូច្នេះ លោក ខៀវ សំផន ត្រូវឆ្លើយតបទៅនឹងអង្គហេតុដែលបានលើកឡើង នៅកថាខណ្ឌ ៦៣៦ ពាក់ព័ន្ធនឹងមន្ទីរ ក-១១ តែប៉ុណ្ណោះ។

## ឃ. ការដាក់ក្នុងមន្ទីរឃុំឃាំង

១៣៨០. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤០២ នៃដីកាដំណោះស្រាយ ថាឧក្រិដ្ឋកម្មក្រោមរូបភាពជាការដាក់ក្នុងមន្ទីរឃុំឃាំងនៅភ្នំក្រោលមានធាតុផ្សំគ្រប់គ្រាន់ ពីព្រោះ "ជនរងគ្រោះត្រូវបានដកហូតសេរីភាពយ៉ាងតឹងរ៉ឹង តាមទំនើងចិត្ត ដោយបំពានទៅលើសិទ្ធិនានាដែលមានចែងនៅក្នុងច្បាប់"[1341]។

១៣៨១. ការកំណត់នេះផ្អែកលើអង្គហេតុនៃការឃុំឃាំងទាំងអស់ ដូចបានរៀបរាប់ ពីកថាខណ្ឌ ៦៣៤ ដល់កថាខណ្ឌ ៦៣៨ នៃដីកាដំណោះស្រាយ ដែលលោក ខៀវ សំផន ត្រូវឆ្លើយតប។

## ង. ការធ្វើទារុណកម្ម

១៣៨២. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤០៨ នៃដីកាដំណោះស្រាយ ថា ឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម មានធាតុផ្សំគ្រប់គ្រាន់ នៅភ្នំក្រោល។ អង្គហេតុនៃការធ្វើទារុណកម្ម ដែលត្រូវបានរៀបរាប់ ពីកថាខណ្ឌ ៦៣៩ ដល់កថាខណ្ឌ ៦៤០ នៃដីកាដំណោះស្រាយ ជាមូលដ្ឋាននៃការចោទប្រកាន់នៅកថាខណ្ឌ ១៤០៨។

---

[1341]ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០៣។ សូមមើលផងដែរ ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០៥។

១៣៨៣. សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្ដីសន្និដ្ឋានទាំងនេះ ដោយរំលោភទៅលើបណ្ដឹងមកកាន់ខ្លួន។ អង្គហេតុនៃការសួរចម្លើយ ឬធ្វើទារុណកម្មលើរូបកាយ ឬផ្លូវចិត្ត មិនមានចែងនៅក្នុងកថាខណ្ឌ ៦៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬកថាខណ្ឌ ៨ ដល់កថាខណ្ឌ ១១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម នោះឡើយ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនបានទទួលអាណត្តិដើម្បីស៊ើបអង្កេតលើអង្គហេតុទាំងនេះទេ។

១៣៨៤. ការធ្វើឲ្យរួសវិសាលភាពនៃបណ្ដឹងដដែលត្រូវបានរៀបរាប់ខាងលើ ក្នុងពេលសិក្សាលើអង្គហេតុស្ដីពីក្រាំងតាចាន់។ យើងបានលើកឡើងថា សហព្រះរាជអាជ្ញាបានបញ្ជាក់យ៉ាងច្បាស់ នៅពេលសហព្រះរាជអាជ្ញាចង់ឱ្យសហចៅក្រមស៊ើបអង្កេតស៊ើបសួរលើអង្គហេតុនៃការធ្វើទារុណកម្ម[1342]។

១៣៨៥. អាស្រ័យហេតុនេះ ដោយសារអង្គជំនុំជម្រះមិនបានទទួលបណ្ដឹងត្រឹមត្រូវតាមច្បាប់អំពីអង្គហេតុនៃការធ្វើទារុណកម្ម នៅភ្នំក្រោល លោក ខៀវ សំផន មិនចាំបាច់ឆ្លើយតបនោះទេ។

### ច. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

១៣៨៦. នៅកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅភ្នំក្រោល។

១៣៨៧. នៅក្នុងជំពូកស្ដីពីសហករណ៍ត្រាំកក់ យើងបានឃើញថា មានតែមនុស្សបីក្រុមប៉ុណ្ណោះដែលត្រូវបានកំណត់ នៅកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយ ថាជាមុខសញ្ញានៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងខ្មែរមកពីបរទេស[1343]។

---

[1342]សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២៤៩-១២៥៣។

[1343]សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៨៤-៨៨៥។

១៣៨៨. ការកំណត់ប្រភេទបទល្មើសនេះផ្អែកលើអង្គហេតុដូចបានរៀបរាប់ពីកថាខណ្ឌ ៦២៥ ដល់កថាខណ្ឌ ៦៤២ នៃដីកាដំណោះស្រាយ ស្ដីពីភ្នំក្រោល ពីព្រោះពុំមានលើកឡើងអំពីក្រុមណាមួយដែលត្រូវបានកំណត់ នៅកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយឡើយ។ មានតែកថាខណ្ឌ ៦៣៤ នៃដីកាដំណោះស្រាយ ប៉ុណ្ណោះ ដែលនិយាយសំដៅដល់ឋានៈរបស់អ្នកទោស៖

> "អតីតអ្នកទោសនៅមន្ទីរសន្តិសុខភ្នំក្រោល ដែលត្រូវបានស្ដាប់ចម្លើយ បាននិយាយថា ពួកគេត្រូវបានចាប់ខ្លួន ដោយសារត្រូវបានគេសង្ស័យថាជាជនក្បត់បដិវត្តន៍ អាចជាការជាប់ពាក់ព័ន្ធជាមួយវៀតណាម ឬអាចត្រូវបានចោទថាជាខ្សែរយៈសេអ៊ីអា"។

១៣៨៩. ប្រសិនបើរកមិនឃើញអត្តសញ្ញាណក្រុមណាមួយ ដូចបានកំណត់ នៅកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយ ការចោទប្រកាន់នៅកថាខណ្ឌ ១៤១៦ គឺគ្មានមូលដ្ឋាន។ លោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបនោះទេ។

## ង. <u>អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស)</u>

១៣៩០. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស) នៅភ្នំក្រោល។

១៣៩១. កថាខណ្ឌ ១៤៣៨ រៀបរាប់លម្អិតអំពីធាតុផ្សំដែលសហចៅក្រមស៊ើបអង្កេតបានយកមកពិចារណា ដើម្បីពិនិត្យមើលឧក្រិដ្ឋកម្មដែលកើតឡើង (អាហារមិនគ្រប់គ្រាន់សម្រាប់អ្នកជាប់ឃុំ លក្ខខណ្ឌឃុំឃាំងគួរឱ្យអាណោចអាធ័ម កង្វះអនាម័យ...)។ ធាតុផ្សំទាំងនេះត្រូវបានរៀបរាប់ ពីកថាខណ្ឌ ៦៣៤ ដល់កថាខណ្ឌ ៦៣៨ នៃដីកាដំណោះស្រាយ ស្ដីពីល័ក្ខខ័ណ្ឌនៃការឃុំឃាំង។

១៣៩២. កថាខណ្ឌ ១៤៣៨ ក៏បានលើកឡើងផងដែរអំពី "ការទទួលរងការធ្វើបាបពីសំណាក់កងសន្តិសុខ និងអ្នកសួរចម្លើយ"។ ដូចយើងបាននិយាយពីខាងលើពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម សេចក្តីសន្និដ្ឋានទាំងអស់របស់សហចៅក្រមស៊ើបអង្កេតលើប្រធានបទនេះ គឺខុសច្បាប់[1344]។

១៣៩៣. ដូច្នេះ លោក ខៀវ សំផន ត្រូវឆ្លើយតបទៅនឹងអង្គហេតុទាំងអស់ លើកលែងតែអង្គហេតុពាក់ព័ន្ធនឹងការធ្វើទារុណកម្ម។

## ៥. __អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ)__

១៣៩៤. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤៧០ នៃដីកាដំណោះស្រាយ ថាមានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ) នៅភ្នំក្រោល។

១៣៩៥. ធាតុផ្សំដែលត្រូវបានជ្រើសយក ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្ម ត្រូវបានរៀបរាប់ខាងក្រោម។ នៅកថាខណ្ឌ ១៤៧១ មានការលើកឡើងជាអាទិ៍អំពីការដកហូតពីបុគ្គលនូវការគាំពារពីច្បាប់ និង "ការបដិសេធក្នុងការប្រគល់ ឬក៏ផ្តល់ឱ្យ [ជនរងគ្រោះ] នូវព័ត៌មានអំពីជោគវាសនា ឬទីកន្លែងឃុំខ្លួន" សាច់ញាតិរបស់ពួកគេ[1345]។

១៣៩៦. កថាខណ្ឌ ១៤៧២ ក៏បានលើកឡើងផងដែរអំពីការដាក់ឱ្យអនុវត្ត "វិធានការមួយដែលមានគោលបំណងលាក់បាំងអំពីជោគវាសនារបស់បុគ្គលដែលបាត់ខ្លួន ដោយធ្វើឱ្យប្រាកដថា មិនមានសាក្សីណាម្នាក់បង្ហាញនូវព័ត៌មានទាក់ទងនឹងបុគ្គលនោះឡើយ"។

១៣៩៧. ការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតផ្អែកលើសេចក្តីសន្និដ្ឋានមួយ នៅកថាខណ្ឌ ៦៤១ នៃដីកាដំណោះស្រាយ ក្រោមចំណងជើង "ការសម្លាប់ និងការបាត់ខ្លួន" ដែលលើកឡើងថា អតីត

[1344]សូមមើលផ្នែកខាងលើ កថាខណ្ឌ ១៣៨២-១៣៨៥។

[1345]ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧១។

អ្នកទោសជាច្រើនបានឃើញ "អ្នកទោសត្រូវបានគេដឹកចេញនៅពេលយប់ ហើយមិនដែលឃើញត្រឡប់មកវិញទេ"។

១៣៩៨. សហចៅក្រមស៊ើបអង្កេត ត្រូវបានសហព្រះរាជអាជ្ញាប្ដឹងឱ្យស៊ើបសួរតែអង្គហេតុនៃការបាត់ខ្លួននៅទីតាំង "ភ្នំក្រោល នៅកថាខណ្ឌ ៦៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលតាមពិត ជាមន្ទីរ ក-១៧[1346]។ គ្មានអង្គហេតុនៃការបាត់ខ្លួនផ្សេងទៀត ត្រូវបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ស្ដីពី "ក-១១" ឬ "ភ្នំក្រោល"[1347] នោះឡើយ។

១៣៩៩. ដូច្នេះ លោក ខៀវ សំផន ត្រូវឆ្លើយតបតែទៅនឹងអង្គហេតុនៃការបាត់ខ្លួនដោយបង្ខំ នៅមន្ទីរ ក-១៧ប៉ុណ្ណោះ។

## ផ្នែកទី ២. ភស្តុតាងគាំទ្រដល់សេចក្ដីសន្និដ្ឋាននៃដីកាដំណោះស្រាយ

១៤០០. ការពិនិត្យលើភស្តុតាងគាំទ្រនៃដីកាដំណោះស្រាយ ប្រាប់អំពីចរិតលក្ខណៈគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់នៃបទចោទ ដែលជនជាប់ចោទត្រូវបានបញ្ជូនទៅជំនុំជម្រះ។ ផ្ទុយពីការរំពឹងទុក ការពិនិត្យនេះបង្ហាញឱ្យឃើញថែមទៀតថា សហចៅក្រមស៊ើបអង្កេតក៏បានរំលោភទៅលើវិធាននៃបណ្ដឹងរបស់ខ្លួន យោងតាមព័ត៌មានអំពីបទចោទដែលទើបតែពិនិត្យមើលនេះ។

១៤០១. ដូចបង្ហាញដោយសេចក្ដីសន្និដ្ឋានអំពី "ភ្នំក្រោល" ក្នុងផ្នែក "ការកំណត់ប្រភេទបទល្មើស" នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតមិនបានយកចិត្តទុកដាក់ដល់សមាសភាពដោយឡែកនៃទីតាំងភ្នំក្រោល និងអាណត្តិដោយឡែកដែលខ្លួនទទួលបាន ពាក់ព័ន្ធនឹងទីតាំងនីមួយៗឡើយ។

១៤០២. ដោយសារមូលហេតុទាំងនេះ ភស្តុតាងដែលសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ពាក់ព័ន្ធនឹងអង្គហេតុនៃការធ្វើការដោយបង្ខំ (១) និងការបាត់ខ្លួនដោយបង្ខំ (២) ត្រូវបានវិភាគដូចខាងក្រោម។

---

[1346]សូមមើលផ្នែកខាងលើ កថាខណ្ឌ ១៣៥៣-១៣៦៤។

[1347]ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩**ឯកសារ D202** កថាខណ្ឌ ៨-១១។

## ១. អំពីអង្គហេតុនៃការធ្វើការដោយបង្ខំ

១៤០៣. ដូចយើងបានលើកឡើងពីខាងលើ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានអំពីអត្ថិភាពនៃឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាការធ្វើឱ្យទៅជាទាសករ នៅ "ភ្នំក្រោល" ផ្អែកលើកថាខណ្ឌ ៦៣៦ និងកថាខណ្ឌ ៦៣៨ នៃដីកាដំណោះស្រាយ[1348]។ កថាខណ្ឌ ៦៣៦ មិនមានលើកឡើងអំពីកន្លែងឃុំឃាំងនោះទេ។ កថាខណ្ឌ ៦៣៨ និយាយអំពីភ្នំក្រោល។ ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតត្រូវបានប្ដឹងឱ្យស៊ើបសួរតែទៅលើអង្គហេតុនៃការធ្វើការដោយបង្ខំ នៅទីតាំង ក-១១ ប៉ុណ្ណោះ។ ដូច្នេះ សេចក្ដីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត នៅកថាខណ្ឌ ៦៣៨ គឺខុសច្បាប់។

១៤០៤. ការវិភាគទៅលើភ័ស្តុតាង ដែលគាំទ្រដល់សេចក្ដីសន្និដ្ឋាននៃកថាខណ្ឌ ៦៣៦ បង្ហាញឱ្យឃើញថា សេចក្ដីសន្និដ្ឋាននេះ គឺខុសច្បាប់ដូចគ្នាដែរ។ សេចក្ដីសន្និដ្ឋានេះផ្អែកលើកំណត់ហេតុស្ដាប់ចម្លើយពីររបស់សាក្សីពីររូបផ្សេងគ្នា គឺ អ្នូង ដុស និងសុវណ្ណ ហាន។

១៤០៥. សាក្សីទីមួយបានឆ្លើយថាគាត់បានធ្វើការ ប៉ុន្តែ គាត់ត្រូវបានឃុំខ្លួនតែនៅគុកភ្នំក្រោលប៉ុណ្ណោះ[1349]។ សាក្សីទីពីរក៏បានធ្វើការផងដែរ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ នៅតែភ្នំពេញប៉ុណ្ណោះ។ គាត់បានរៀបរាប់ទៀតថា គាត់ទៅ ក-១៧ តែមិនបានបញ្ជាក់អំពីការធ្វើការដោយបង្ខំ ឬការឃុំឃាំង[1350] នោះទេ។ ដូច្នេះ គ្មានភ័ស្តុតាងណាមួយអាចនាំឱ្យឈានទៅដល់ការចោទប្រកាន់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះឡើយ។

១៤០៦. ការយកកំណត់ហេតុស្ដាប់ចម្លើយទាំងនេះមកធ្វើជាមូលដ្ឋាន សម្រាប់ការធ្វើសេចក្ដីសន្និដ្ឋានអំពីឧក្រិដ្ឋកម្ម គឺការបង្ហាញព្រមគ្នាពីការធ្វើហួសវិសាលភាពនៃបណ្ដឹង និងពីការកែបន្លំភ័ស្តុតាង ដែលជាឧបាយកលដែលសហចៅក្រមស៊ើបអង្កេតតែងធ្លាប់បានធ្វើ ហើយដែលវាបណ្ដាលឲ្យមានផលប៉ះពាល់ទៅលើបណ្ដឹងទៅអង្គជំនុំជម្រះ។ លោក ខៀវ សំផន មិនគួរត្រូវបានបញ្ជូនទៅជំនុំជម្រះ

---

[1348]សូមមើលផ្នែកខាងលើ កថាខណ្ឌ ១៣៧២-១៣៧៩។

[1349]កំណត់ហេតុស្ដាប់ចម្លើយ អ្នូង ដុស ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨**ឯកសារ E3/7703** ERN 00236746។

[1350]កំណត់ហេតុស្ដាប់ចម្លើយ សុវណ្ណ ហាន ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨**ឯកសារ E3/365** ERN 00242435។

ចំពោះអង្គហេតុនៃការធ្វើការដោយបង្ខំ ដែលត្រូវបានកំណត់ថាជាការធ្វើឱ្យទៅជាទាសករ នោះឡើយ។ ដូច្នេះ លោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបឡើយ នៅក្នុងសារណានេះ។

## ៤. អំពីអង្គហេតុនៃការបាត់ខ្លួនដោយបង្ខំ

១៤០៧. យើងបានលើកឡើងខាងលើថា សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងឱ្យស៊ើបសួរតែលើអង្គហេតុនៃការបាត់ខ្លួន នៅទីតាំង ក-១៧ ប៉ុណ្ណោះ។ ក៏ប៉ុន្តែ ទាំងសេចក្តីសន្និដ្ឋានអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំនៅ "ភ្នំក្រោល" នៅកថាខណ្ឌ ១៤៧០ នៃដីកាដំណោះស្រាយ ទាំងអង្គហេតុគាំទ្រដល់សេចក្តីសន្និដ្ឋាននេះ នៅកថាខណ្ឌ ៦៤១ មិនធ្វើការបែងចែករវាងទីតាំងឧក្រិដ្ឋកម្មផ្សេងៗនោះឡើយ។

១៤០៨. គ្រាន់តែការវិភាគភស្តុតាងដែលបានបង្ហាញជូន ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋាននៅកថាខណ្ឌ ៦៤១ បង្ហាញឱ្យឃើញអំពីភាពគ្រប់គ្រាន់នៃបទចោទ។ វាមិនដូច្នេះ វាទៅជាបង្ហាញឱ្យឃើញជាសំខាន់អំពីការធ្វើហួសវិសាលភាពនៃបណ្តឹងជាថ្មីទៀត។ សាក្សីពីររូប ដែលត្រូវបានស្តាប់ចម្លើយទៅលើប្រធានបទនេះ គឺ ចាន់ ទូយ និង អ៊ួង ដុស ត្រូវបានឃុំនៅភ្នំក្រោល មិនមែននៅ ក-១៧ ទេ។

១៤០៩. សហចៅក្រមស៊ើបអង្កេតមានចេតនាលាក់បាំងនូវចរិតលក្ខណៈក្រៅវិសាលភាពនៃភស្តុតាង ដែលទទួលបាន និងបានធ្វើសេចក្តីសន្និដ្ឋានដោយខុសច្បាប់ទៅលើអង្គហេតុ ដែលខ្លួនមិនត្រូវបានប្តឹងឱ្យស៊ើបសួរ។

១៤១០. លោក ខៀវ សំផន មិនអាចជាជនរងគ្រោះជាប់ជាប្រចាំនៃនីតិវិធីអយុត្តិធម៌នោះទេ។ ដូច្នេះ គាត់មិនចាំបាច់ត្រូវឆ្លើយតបទៅនឹងអង្គហេតុនៃការបាត់ខ្លួនដោយបង្ខំនៅភ្នំក្រោលនោះឡើយ។

## ផ្នែកទី ៣. ការបង្ហាញភស្តុតាង

១៤១១. ក្នុងចំណោមភស្តុតាង ដែលបានបង្ហាញជូនក្នុងពេលជំនុំជម្រះក្តី (១) ភស្តុតាងជាច្រើនស្ថិតនៅក្រៅយុត្តាធិការរបស់អង្គជំនុំជម្រះ (២)។ ភស្តុតាងខ្លះទៀតអាចឱ្យយើងគិតថា ឧក្រិដ្ឋកម្មមួយចំនួនអាចមានធាតុផ្សំគ្រប់គ្រាន់ (៣)។

## ១. **បញ្ជីភស្តុតាង**

១៤១២. ពីថ្ងៃទី ១០ ខែ មីនា ដល់ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៦ បុគ្គល ៦ រូប ក្នុងនោះ មានសាក្សី ៥ រូប និងដើមបណ្តឹងរដ្ឋប្បវេណី ១ រូប បានមកផ្តល់សក្ខីកម្មនៅសវនាការក្នុងវគ្គមន្ទីរសន្តិសុខភ្នំក្រោល។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមិនធ្លាប់ត្រូវបានស្តាប់ចម្លើយ ក្នុងអំឡុងកិច្ចស៊ើបសួរលើសំណុំរឿង ០០២ ឡើយ[1351]។

១៤១៣. ក្នុងចំណោមសាក្សីទាំង ៥ រូប ដែលត្រូវបានស្តាប់ចម្លើយ សាក្សី ២ រូប ជាអតីតកម្មាភិបាលខ្មែរក្រហម ដែលមិនមានមុខងារនៅក្នុងរចនាសម្ព័ន្ធនៃកន្លែងឃុំឃាំងណាមួយឡើយ។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី គាត់ត្រូវបានឃុំឃាំងនៅកន្លែងមួយនៅក្រៅវិសាលភាព[1352]។

១៤១៤. ដូច្នេះ នៅពេលបញ្ចប់សវនាការ គ្មានអ្នកទោសណាមួយ នៅ ក-១១ ឬនៅភ្នំក្រោល ត្រូវបានស្តាប់ចម្លើយនោះឡើយ ហើយក៏គ្មានអ្នកយាម ឬកម្មាភិបាលនៃទីតាំងណាមួយក្នុងចំណោមទីតាំងទាំងបីនេះត្រូវបានស្តាប់ចម្លើយនោះដែរ។

១៤១៥. ម្យ៉ាងវិញទៀត បុគ្គលពីររូបទៀត ដែលមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ បានផ្តល់ព័ត៌មានអំពីមន្ទីរសន្តិសុខភ្នំក្រោល។ ក្នុងពេលសវនាការស្តីពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម ដែលបានទទួលរងក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការដាក់បទបញ្ជាទៅលើការរៀបអាពាហ៍ពិពាហ៍ ដើមបណ្តឹងរដ្ឋប្បវេណី គល់ ណែម ក៏បាននិយាយអំពីមន្ទីរសន្តិសុខភ្នំក្រោលផងដែរ[1353]។ សាក្សី សៅ ចាំពី អតីតកម្មាភិបាលខ្មែរក្រហម ដែលបានមកផ្តល់សក្ខីកម្មក្នុងវគ្គស្តីពីជម្លោះប្រដាប់អាវុធ ក៏ត្រូវបាន

---

[1351] សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ១៤១៩-១៤២៨។

[1352] សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ១៤២៩-១៤៣៨។

[1353] <u>គុល ណែម</u> ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/488.1**។

គេសួរដេញដោលអំពីភ្នំក្រោលផងដែរ[1354]។ ការដឹងឮរបស់បុគ្គលទាំងពីររូបនេះមានកម្រិតតិចបំផុត។

## ២. ភ័ស្តុតាងក្រៅវិសាលភាព

១៤១៦. ជាថ្មីម្តងទៀត ភ័ស្តុតាងជាច្រើនស្ថិតនៅក្រៅវិសាលភាពនៃបណ្តឹងទៅកាន់អង្គជំនុំជម្រះ។ ដោយមិនអាចរៀបរាប់អស់ យើងសូមដកស្រង់តែភ័ស្តុតាងមួយចំនួនប៉ុណ្ណោះ (ក)។ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ស្ថិតនៅក្រៅវិសាលភាពទាំងស្រុង។ ការកោះហៅគាត់ គឺជាការប្រមាថមើលងាយចំពោះសម្តីរបស់ក្រុមមេធាវីការពារក្តីពីសំណាក់អង្គជំនុំជម្រះ (ខ)។

## ក. ការក្រឡេកមើលគ្រួសៗនៅលើភ័ស្តុតាងក្រៅវិសាលភាព

១៤១៧. នេះជាករណីនៃភ័ស្តុតាងគាំទ្រដល់អង្គហេតុ ដែលសហចៅក្រមស៊ើបអង្កេតបានធ្វើការស៊ើបសួរដោយរំលោភលើវិសាលភាពនៃបណ្តឹងទៅកាន់ខ្លួន ឧទាហរណ៍ភ័ស្តុតាងអំពីការសួរចម្លើយនៅតាមទីតាំងនានានៃមន្ទីរសន្តិសុខភ្នំក្រោល[1355]។

១៤១៨. នេះក៏ជាករណីនៃភ័ស្តុតាងដែលគ្មាននៅក្នុងដីកាដំណោះស្រាយទាល់តែសោះ ហើយហេតុនេះក៏នៅក្រៅវិសាលភាពនៃបណ្តឹងទៅកាន់អង្គជំនុំជម្រះដែរ។ ក្នុងន័យនេះ ឧទាហរណ៍ ត្រូវផាត់ចេញពីការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះ នូវភ័ស្តុតាងស្តីពីអង្គហេតុពាក់ព័ន្ធនឹងការធ្វើការនៅការដ្ឋាននានានៃតំបន់មណ្ឌលគិរី[1356] មន្ទីរអប់រំកែប្រែណាងឃីលឹក[1357] ការចាប់ និងការសម្លាប់នៅតាមទី

---

[1354] សៅ ចាំពី ប្រតិចារឹក ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/491.1**។

[1355] ឧទាហរណ៍ សូមមើល ភ័ស្តុតាងទាំងអស់ដែលត្រូវបានយោងនៅកំណត់សម្គាល់ជើងទំព័រនៃកថាខណ្ឌ ៦៣៩ និង ៦៤០ នៃដីកា ដំណោះស្រាយ, ចាន់ ទូយ ប្រតិចារឹក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/399.1** ទំព័រ ១៧ ប្រហែលម៉ោង [០៩.៥២.៤៩]។

[1356] ឧទាហរណ៍ សូមមើល ចាន់ ទូយ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ **ឯកសារ E3/7694** ERN 00236706-07, ប្រតិចារឹក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/399.1** ទំព័រ ២១-២២ ចន្លោះម៉ោង [១០.០៧.៥៧] និង [១០.១០.៤១] ទំព័រ ៥០-៥១ ចន្លោះម៉ោង [១៣.៤៦.៥៥] និង [១៣.៥០.០៥], ណោត សាវ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ មីនា ឆ្នាំ

តាំងក្រៅវិសាលភាព[1358] ការបាត់ខ្លួនមនុស្សនៅតាមទីតាំងក្រៅវិសាលភាព[1359] ជោគវាសនារបស់ជនជាតិវៀតណាមនៅមណ្ឌលគិរី និងការលុកលុយរបស់ខ្មែរក្រហមចូលទឹកដីវៀតណាម[1360] និងជោគវាសនារបស់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងខេត្តមណ្ឌលគិរី[1361]។

## ខ. <u>សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ទុត</u>

### 1. <u>ការរំឭកនីតិវិធី</u>

១៤១៩. នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានផ្ញើជូនភាគីនូវបញ្ជីឈ្មោះបុគ្គលដែលខ្លួនចង់ស្តាប់ចម្លើយ នៅក្នុងសវនាការស្តីពីមន្ទីរសន្តិសុខភ្នំក្រោល[1362]។

---

២០១៦ **ឯកសារ E1/400.1** ទំព័រ ១៥ ប្រហែលម៉ោង [០៩.៥៩.០៦], <u>ប៊ុន ឡឹងចូយ</u> ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1** ទំព័រ ៩ ប្រហែលម៉ោង [០៩.៣៥.៣៦] ទំព័រ ១០ ប្រហែលម៉ោង [០៩.៤០.០០]។

[1357]<u>ប៊ុន ឡឹងចូយ</u> ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1** ទំព័រ ១៧-១៨ ចន្លោះម៉ោង [១០.០៧.១៦] និង [១០.០៩.១៩]។

[1358]<u>ប៊ុន ឡឹងចូយ</u> ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1** ទំព័រ ៦-៧ ប្រហែលម៉ោង [០៩.២៣.០៥] (ការចាប់ ខ្លួន កាស៊ី នៅ ក-១៦ និងការសម្លាប់), <u>ស៊ុន វុត</u> ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/411.1**, ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/412.1** (ការឃុំឃាំងនៅកន្លែងមួយមិនស្គាល់)។

[1359]<u>ចាន់ ទូយ</u> ប្រតិចារឹក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/399.1** ទំព័រ ៣៨ ប្រហែលម៉ោង [១១.១៨.២៨] ទំព័រ ៥១ ប្រហែលម៉ោង [១៣.៥០.០៥], <u>ណោត សាវ៉ាត</u> ប្រតិចារឹក ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/400.1** ទំព័រ ២៧ ប្រហែលម៉ោង [១១.០៧.៥២], <u>ស៊ុន វុត</u> ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/411.1** ទំព័រ ៤៧ ប្រហែលម៉ោង [១៤.០១.១៣]។

[1360]<u>ចាន់ ទូយ</u> ប្រតិចារឹក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/399.1** ទំព័រ ៤២ ប្រហែលម៉ោង [១១.២៨.៥០], <u>ប៊ុន ឡឹងចូយ</u> ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1** ទំព័រ ៤១ ប្រហែលម៉ោង [១៣.៥៤.០០] ទំព័រ ៣៨-៤៤ ចន្លោះម៉ោង [១៣.៤០.០០] និង [១៤.០៧.២៦], <u>សៅ សារុន</u> ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/410.1** ទំព័រ ៦៥-៧០ ចន្លោះម៉ោង [១៥.១៣.២២] និង [១៥.៣១.២៤]។

[1361]<u>ចាន់ ទូយ</u> ប្រតិចារឹក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/399.1** ទំព័រ ៤២ ប្រហែលម៉ោង [១១.៣១.២៧], <u>ប៊ុន ឡឹងចូយ</u> ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1** ទំព័រ ១៣-១៦ ចន្លោះម៉ោង [០៩.៥០.០៣] និង [១០.០៥.២០] (ជោគវាសនាអតីតអ្នកសាធារណរដ្ឋខ្មែរ នៅក្នុងតំបន់ឦសាន)។

[1362]សារអេឡិកត្រូនិករបស់អ្នកច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះ មានចំណងជើងថា "បញ្ជីសាក្សីពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំក្រោល និង ការបែងចែកពេលវេលា" ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ (ភាសាអង់គ្លេស)។

១៤២០. នៅថ្ងៃទី ១០ និងថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៦ សាក្សីពីររូបដំបូង គឺ ចាន់ ទូយ និង ណោត សាវ៉ាត អតីតអ្នកទោស ក្នុងចំណោមសាក្សីដែលកោះហៅមកក្នុងសវនាការ បានមកផ្តល់សក្ខីកម្ម[1363]។

១៤២១. នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅ "សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ជំនួសអតីតអ្នកទោសពីរនាក់ដែលបានទទួលមរណភាព (សុខ អ៊ែល និង អួម ម៉ុល)"[1364]។ ក្នុងគោលបំណងនេះ សហព្រះរាជអាជ្ញាបានស្នើជាអាទិ៍ឱ្យកោះហៅ ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត អតីតទាហាននៃកងពល ៩២០ ដែលត្រូវបានសន្មតថាត្រូវបាន "ឃុំខ្លួនក្នុងមន្ទីរសន្តិសុខពិសេសជិតភ្នំក្នុងស្រុកកោះញែក (ទីតាំងភ្នំក្រោល)"។ សហព្រះរាជអាជ្ញា បានរំឭកថា ទីតាំងភ្នំក្រោលមានរចនាសម្ព័ន្ធផ្សេងៗគ្នា នៅក្នុងដីកាដំណោះស្រាយ ហើយសាក្សីជា អ្នកទោស គឺ ចាន់ ទូយ និង ណោត សាវ៉ាត ត្រូវបានឃុំនៅ ក-១៧។ ក៏ប៉ុន្តែ សុន វុត ទំនងជាត្រូវ បានឃុំនៅភ្នំក្រោល ដោយសារតែការកោះហៅគាត់អាចឱ្យឈានទៅដល់ការចោទប្រកាន់នៃដីកា ដំណោះស្រាយ[1365]។

១៤២២. នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានស្តាប់ចម្លើយតបផ្ទាល់មាត់របស់ភាគីទៅនឹង សំណើរបស់សហព្រះរាជអាជ្ញា។ ក្រុមមេធាវីការពារក្តីបានស្នើឱ្យអង្គជំនុំជម្រះបដិសេធសំណើ របស់សហព្រះរាជអាជ្ញា[1366]។

១៤២៣. ម្យ៉ាង សំអាងហេតុនៃសំណើនោះមានលក្ខណៈបោកបញ្ឆោត។ សហព្រះរាជអាជ្ញាបានលើកយក ករណីមរណភាពរបស់ សុខ អ៊ែល និង អួម ម៉ុល មកបញ្ជាក់អំពីហេតុផលនៃការស្នើសុំ ខណៈ ដែលអ្នកទាំងពីរនេះមិនមានឈ្មោះនៅក្នុងបញ្ជីបឋមរបស់អង្គជំនុំជម្រះ នៅថ្ងៃទី ០៥ ខែ កុម្ភៈ

---

[1363] ចាន់ ទូយ ប្រតិចារឹក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/399.1**, ណោត សាវ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/400.1**។

[1364] សំណើសហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E390** កថាខណ្ឌ ៦។

[1365] សំណើសហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E390** កថាខណ្ឌ ៦-៧។

[1366] ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/405.1** ទំព័រ ៤-១៥ ចន្លោះម៉ោង [០៩.១៤.២៧] និង [០៩.៤៤.២២]។

ឆ្នាំ ២០១៦ នោះឡើយ។ តាមពិត សំណើនេះគ្រាន់តែបម្រើឱ្យគោលដៅនៃការកែខៃមូលដ្ឋាននៃការចោទប្រកាន់ ក្រោយពីបានស្តាប់សក្ខីកម្មរបស់ ចាន់ ទូយ និង ណេត សាវ៉ាត តែប៉ុណ្ណោះ[1367]។

១៤២៤. ម្យ៉ាងទៀត ក្រុមមេធាវីការពារក្តីបានចង្អុលបង្ហាញថា នៅក្នុងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ពុំមាននិយាយអំពីមន្ទីរសន្តិសុខភ្នំក្រោលទាល់តែសោះ។ ដូច្នេះ គេមិនអាចអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រូវបានឃុំនៅទីតាំងនោះឡើយ[1368]។

១៤២៥. ក្រោយពីធ្វើការកត់សម្គាល់ទាំងនេះ តបទៅនឹងទឡ្ហីករណ៍ទីពីររបស់ក្រុមមេធាវីការពារក្តី សហព្រះរាជអាជ្ញារង Dale LYSAK បានធានាអះអាងចំពោះអង្គជំនុំជម្រះ និងភាគី ថាសំណើរបស់ខ្លួនមានមូលដ្ឋាន៖

> "ជាចុងក្រោយ តបទៅនឹងចំណុចជាក់លាក់ ដែលក្រុមមេធាវីការពារក្តី ខៀវ សំផន បានលើកឡើង ពាក់ព័ន្ធនឹងសាក្សីទាំងពីររូបនេះ គុកដែលឃុំដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1016 <u>ពិតជាមន្ទីរសន្តិសុខភ្នំក្រោលមែន</u>។ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គាត់បានរៀបរាប់ថាមានមន្ទីរសន្តិសុខមួយ នៅក្បែរភ្នំក្នុងស្រុកកោះញែក។ <u>នេះគឺជាគុកភ្នំក្រោល</u>។ នេះគឺជាមន្ទីរសន្តិសុខតែមួយគត់ នៅជិតភ្នំ។ នេះក៏ជាកន្លែងតែមួយដែលគេឃុំទាហានមកពីកងពល ៩២០។ <u>ដូច្នេះ ប្រាកដណាស់ថា បុគ្គលរូបនេះមានភាពពាក់ព័ន្ធនឹងនឹងសវនាការវគ្គនេះ</u>" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[1369]។

១៤២៦. ប្រឈមមុខនឹងការធានាអះអាងបែបនេះ ក្រុមមេធាវីការពារក្តីបានត្រឹមតែនិយាយដដែលៗថា នៅក្នុងចម្លើយរបស់ សុន វុត គ្មានពាក្យ "ភ្នំក្រោល" នោះទេ[1370]។

---

[1367] ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/405.1** ទំព័រ ៧-១០ ចន្លោះម៉ោង [០៩.២៣.១៦] និង [០៩.២៩.៤៨]។ សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ១៤៤៦-១៤៤៨។

[1368] ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/405.1** ទំព័រ ១០-១១ ចន្លោះម៉ោង [០៩.៣២.១៤] និង [០៩.៣៣.៤៦]។

[1369] ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/405.1** ទំព័រ ១៣ ចន្លោះម៉ោង [០៩.៣៦.២៣] និង [០៩.៣៩.៤៣]។

[1370] ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/405.1** ទំព័រ ១៣-១៤ ចន្លោះម៉ោង [០៩.៣៩.៤៣] និង [០៩.៤១.៤៦]។

១៤២៧. នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញា ដោយជ្រើសយកតាមការធានាអះអាងគ្មានមូលដ្ឋានរបស់លោក Dale LYSAK ជាជាងតាមភ័ស្តុតាងអំពីអង្គហេតុ និងការព្រួយបារម្ភដ៏សមហេតុសមផលរបស់ក្រុមមេធាវីការពារក្តី[1371]។

១៤២៨. ពិតជាមិនខុសមែន ចម្លើយរបស់ សុន វុត នៅក្នុងសវនាការ បានបញ្ជាក់អះអាងនូវមន្ទិលសង្ស័យនៃក្រុមមេធាវីការពារក្តី គឺថាគាត់មិនធ្លាប់ជាប់ឃុំនៅក្នុងទីតាំងណាមួយ ដូចបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយឡើយ។

## 2. ចម្លើយក្រៅវិសាលភាពនៃការជំនុំជម្រះក្តី

១៤២៩. ការកោះហៅ សុន វុត ត្រូវបានស្នើសុំដោយសហព្រះរាជអាជ្ញា ដើម្បីទទួលបានភ័ស្តុតាងអំពីទីតាំងណាមួយនៃដីកាដំណោះស្រាយ គឺទីតាំងភ្នំក្រោល។

១៤៣០. នៅកថាខណ្ឌ ៦២៦ នៃដីកាដំណោះស្រាយ ទីតាំងនេះត្រូវបានពិពណ៌នាថា "គុកភ្នំក្រោលធ្វើពីឈើក្រាលរនាបឫស្សី មានដំបូលប្រក់ស្បូវ"។ កថាខណ្ឌ ៦៣៧ នៃដីកាដំណោះស្រាយ បានបញ្ជាក់ថាចំនួនអ្នកទោសនៅទីនោះអាចមានរហូតដល់ ៣៨៥ នាក់។

១៤៣១. ពេលសួរដេញដោលអំពីទីតាំងនេះ សាក្សី ប៊ុន ឡឹងចូយ អតីតកម្មាភិបាលខ្មែរក្រហម បានឆ្លើយថា៖

> "បាទ មន្ទីរសន្តិសុខនេះ បើប្រៀបធៀបទៅ មិនបានស្មើក្រោលគោមួយទេ បាទ ប៉ុន្តែ អាចដាក់មនុស្សបានច្រើនដែរ ប្រហែលជាខ្ទង់ ១០០ នាក់អី។ វាជាជញ្ជាំងឫស្សីប្រក់ស្បូវ ហើយដាក់ចម្រូងជុំវិញមិនអាចរត់បានអី បាទ។ មិនដែលឃើញមានឮថារត់រួចផង"[1372]។

---

[1371] ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/408.1** ទំព័រ ២-៣ ក្រោយម៉ោង [០៩.០៧.៥០]។ សំអាងហេតុនៃសេចក្តីសម្រេចនេះ ចេញនៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E390/3**។

[1372] <u>ប៊ុន ឡឹងចូយ</u> ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1 [numéro à rectifier dans l'original]** ទំព័រ ២១ មុនម៉ោង [១០.៤៣.១៧]។

១៤៣២. គាត់ក៏បានបន្ថែមថា គុកនេះស្ថិតនៅជិតទំនប់មួយដែល “មិនតូចពេក” ពីព្រោះ “ឡានអាចបើកលើផ្លូវនោះបាន” ហើយ ទំនប់នេះ “មានទ្វារទឹក”[1373]។

១៤៣៣. ដោយហេតុថា បុគ្គលដែលត្រូវបានអង្គជំនុំជម្រះស្តាប់ចម្លើយ គ្មានអ្នកណាជាអ្នកទោស អ្នកយាម ឬកម្មាភិបាល នៅទីតាំងនោះ យើងមានការលំបាកក្នុងការផ្តល់ព័ត៌មានអំពីការពិពណ៌នាទីតាំងនោះឱ្យបានលម្អិត។

១៤៣៤. ពេលសួរដេញដោលអំពីរចនាសម្ព័ន្ធ និងទីតាំង ដើម្បីជម្រះមន្ទិលសង្ស័យអំពីភាពជាប់ពាក់ព័ន្ធនៃសក្ខីកម្មរបស់គាត់នៅក្នុងសវនាការ សុន វុត បានឆ្លើយថា៖

> “បាទ ដែលទៅខ្ញុំអាចដឹង មិនចង់ចាំបានអស់ទេ ប៉ុន្តែ ថាដែលយកខ្ញុំទៅ ខ្ញុំអាចដឹង គឺវាមានអូរមួយ អូរច្បារនោះឯង ថាអូរច្បារ គឺមានកូនភ្នំ ដើរបន្តិចប្រហែលជាមិនខ្ពស់ប៉ុន្មានទេ ភ្នំនោះបាទ នៅឯចម្រាក់មាត់ព្រៃរាងស្តុកស្រូវ រាងសំយាក ស្តុកគ្រាន់បាទ។ ហើយមានឃើញកន្លែងគុកគេធ្វើនោះឯង ប៉ុន្តែមិនដឹងថាធ្វើយូរឆាប់ ខ្ញុំមិនដឹងដែរ ប៉ុន្តែដែលខ្ញុំជាប់ទៅក៏ គុកនោះក៏វាបណ្តោយប្រហែលជាវា ១០ ម៉ែត្រ គឺទទឹងប្រហែលជា ៥ ទៅ ៦ ម៉ែត្រ។ ហើយមានបីបន្ទប់គុកបាទ ដែលខ្ញុំចូល គឺនៅខាងត្បូង គ្រាន់តែគុកដែលខ្ញុំចូលមុនដំបូង គឺដាក់តែខ្ញុំម្នាក់ឯងទេ ដែលខ្ញុំសំខាន់ជាងគេបាទ។ ដល់ចាប់ពីថ្ងៃក្រោយទៀត ឃើញរំលងពីរថ្ងៃឃើញយកពីរនាក់មកដាក់ជាមួយខ្ញុំ។ បែបបន្ទប់ប៉ុន្មាននោះវាពេញ ក៏មិនដឹង ខ្ញុំក៏មិនដឹងដែរ”[1374]។

១៤៣៥. គាត់ក៏បានបន្ថែមទៀតថា៖

> “អត់មានទេរឿងរបងជុំវិញ គឺធ្វើធម្មតា ហើយកន្លែងសួរចម្លើយ ក៏កន្លែងខ្ទមសម្រាក ចងអង្រឹងដេកចំនួនគ្នាបីបួននាក់តែប៉ុណ្ណឹងទេបាទ [...]។ បើតាមធ្វើនោះមើលទៅមិនមែនជាគុកអីសម្រាប់មួយជីវិតដាក់យូរអង្វែងតាមខ្ញុំមើលទៅវាមិនមែន គ្រាន់តែចាប់ដូចថាបន្ទាន់ ឬមួយម៉េចក៏មិនដឹងដែរ។ ដាក់បណ្តោះអាសន្នសិន ឱ្យ

---

[1373] ប៊ុន ឡឹងចូយ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1 [numéro à rectifier dans l'original]** ទំព័រ ២៣-២៦ ចន្លោះម៉ោង [១០.៥១.១៤] និង [១១.០១.២២]។

[1374] ស៊ុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/411.1** ទំព័រ ៤៨-៤៩ ចន្លោះម៉ោង [១៤.០៤.២៦] និង [១៤.០៨.៥៨]។

តែមានអ្នកទោសអី ក៏មិនដឹងដែរ ប៉ុន្តែ ថាឱ្យធ្វើជាប់ដូចជាណែនណាន់មែន ក៏វាអត់មានទៀត។ បើណែនណាន់ ខ្ញុំរើមិនរួចផងទេដឹងតាមមើលទៅ"[1375]។

១៤៣៦. ជាចុងក្រោយ ដើម្បីឱ្យការពិពណ៌នាមានលក្ខណៈពេញលេញ ពេលឆ្លើយទៅនឹងសំណួរ៖ "តើលោកនៅចាំឬទេថា តើមានអាងទឹកនៅក្នុងបរិវេណគុកហ្នឹងដែរឬទេ?" គាត់បានបញ្ជាក់ថា៖

> "អត់មានទេអាងទឹក មានអូរ។ អូរវាមិនសូវធំទេ អូរតូច ប៉ុន្តែ វាមានទឹក វាមិនងាយដាច់ មានដោយបនៗវា បើខែប្រាំង វាដាច់ វានៅតាមអន្លង់វាបាទ"[1376]។

១៤៣៧. យើងមិនចាំបាច់និយាយច្រើនទៅលើសក្ខីកម្មរបស់សាក្សីម្នាក់ ដែលមិនជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ ដែលលោក ខៀវ សំផន ត្រូវឆ្លើយតបនោះទេ។ ក្រុមមេធាវីការពារក្ដីគ្រាន់តែសោកស្ដាយថាទឡ្ហីករណ៍របស់ខ្លួនមិនត្រូវបានគេស្ដាប់ ពេលឆ្លើយតបផ្ទាល់មាត់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលគួរតែជួយឱ្យភាគីទាំងអស់មិនចំណាយពេលសវនាការមួយថ្ងៃដោយឥតប្រយោជន៍។

១៤៣៨. ចំណុចមួយទៀត គឺវាគួរតែជួយមិនបង្កឱ្យមានការរិះគន់កាន់តែខ្លាំងបន្ថែមទៀតទៅលើភាពអគតិរបស់អង្គជំនុំជម្រះនោះដែរ។

## 3. ភស្តុតាងអំពីឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស)

១៤៣៩. ភស្តុតាងមួយផ្នែកដែលបានបង្ហាញ អាចនាំឱ្យយើងគិតថាមានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំង ដូចបានចោទប្រកាន់ នៅកថាខណ្ឌ ១៤០២ នៃដីកាដំណោះស្រាយ។

---

[1375] ស៊ុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/411.1** ទំព័រ ៧៣ ចន្លោះម៉ោង [១៥.៤៧.៥៨] និង [១៥.៥០.០០]។

[1376] ស៊ុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/411.1** ទំព័រ ៧៤ ក្រោយម៉ោង [១៥.៥០.០០]។

១៤៤០. ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតបានកំណត់ថាជាអំពើអមនុស្សធម៌ផ្សេងទៀតនូវអង្គហេតុនៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស នៅកថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយ។

១៤៤១. យោងតាមវិធីសាស្ត្រ "ទូទៅ" របស់អង្គជំនុំជម្រះតុលាការកំពូល នៅសម័យកាលកើតអង្គហេតុ ប្រភេទនៃអំពើមនុស្សធម៌ផ្សេងទៀត ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលនៅសេសសល់ មិនមានបែងចែកជាអនុប្រភេទ ដូចបានគ្រោងឡើងក្នុងដីកាដំណោះស្រាយ និងសាលក្រមលើសំណុំរឿង ០០២/០១ នោះទេ[1377]។

១៤៤២. ក្រុមមេធាវីការពារក្តីមិនជំទាស់នឹងការវិភាគនេះទេ ហើយក៏មិនជំទាស់ដែរថា អំពើដែលអាចកំណត់ជាទូទៅថាជាអំពើអមនុស្សធម៌ផ្សេងទៀត អាចកើតឡើង នៅភ្នំក្រោល។

## ផ្នែកទី ៤. ការពិនិត្យមើលភ័ស្តុតាងពាក់ព័ន្ធ

១៤៤៣. អង្គហេតុ ដែលលោក ខៀវ សំផន ត្រូវឆ្លើយតប គឺអង្គហេតុនៃការសម្លាប់ ដែលត្រូវបានកំណត់ថាជាការសម្លាប់រង្គាល នៅក្នុងដីកាដំណោះស្រាយ។

១៤៤៤. ដើម្បីជាការរំឭក សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា អ្នកទោសត្រូវគេវាយរហូតដល់ស្លាប់ ហើយអ្នកខ្លះត្រូវបានគេដឹកចេញពី ក-១១ យកទៅសម្លាប់នៅត្រពាំងព្រីង ជាទីតាំងសម្លាប់មនុស្សអស់យ៉ាងតិច ២០០ នាក់ យោងតាមដីកាដំណោះស្រាយ។ ជាចុងក្រោយ អ្នកទោសត្រូវបានគេ "សម្លាប់នៅក្បែរគុកភ្នំក្រោល"[1378]។

១៤៤៥. ការសិក្សាទៅលើចម្លើយរបស់បុគ្គលនីមួយៗ ដែលត្រូវបានស្តាប់ចម្លើយនៅក្នុងសវនាការ មិនអាចឱ្យសន្និដ្ឋានថា ការស្លាប់បានកើតឡើង នៅ "មន្ទីរសន្តិសុខភ្នំក្រោល" នោះទេ។

[1377] សាលដីកា ០០២/០១ កថាខណ្ឌ ៥៧២-៥៨០។

[1378] ដីកាដំណោះស្រាយ កថាខណ្ឌ ៦៤១-៦៤២។

## ១. ចម្លើយរបស់ ចាន់ ទូយ

១៤៤៦. សាក្សី ចាន់ ទូយ បានឆ្លើយថា អ្នកជាប់ឃុំជាមួយគាត់ "មិនត្រូវបាននាំយកទៅសម្លាប់ទេ"[1379]។ បន្ទាប់មកទៀត នៅពេលសួរតទល់នឹងចម្លើយដែលគាត់ឆ្លើយជូនអ្នកស៊ើបអង្កេតថា អ្នកទោសត្រូវបាននាំយកទៅសម្លាប់[1380] គាត់បានអះអាងថា៖

> "តាមការសន្និដ្ឋានរបស់ខ្ញុំ តែគេនាំមនុស្សទៅ គឺនាំយកទៅសម្លាប់ហើយ"[1381]។

១៤៤៧. ចាន់ ទូយ ក៏បានអះអាងផងដែរថា គាត់មិនដឹងអំពីការសម្លាប់រង្គាល ក្នុងពេលគាត់ជាប់ឃុំនោះទេ ហើយគាត់បានបន្ថែមទៀតថា គាត់ដឹងរឿងនេះ "នៅពេលក្រោយ"។ ម្យ៉ាងវិញទៀត គាត់មិនបានផ្សារភ្ជាប់ការដឹងឮឃើតពេលរបស់គាត់ ទៅនឹងជោគវាសនាអ្នកទោសនៅមន្ទីរសន្តិសុខភ្នំក្រោលនោះទេ ធ្វើឱ្យយើងមិនអាចនិយាយថាគាត់លើកឡើងអំពីមនុស្សទាំងនេះ[1382]។ ជាចុងក្រោយ នៅពេលសួរអំពីត្រពាំងព្រីង គាត់បានឆ្លើយថាគាត់មិនដឹងស្ថិតនៅកន្លែងណានោះទេ[1383]។

## ២. ចម្លើយរបស់ ណោត សាវ៉ាត

១៤៤៨. ពេលសួរដេញដោលទៅលើប្រធានបទនេះ និងតទល់នឹងចម្លើយរបស់គាត់ សាក្សី ណោត សាវ៉ាត ឆ្លើយមិនស៊ីសង្វាក់គ្នា និងមិនបាននិយាយអំពីអ្នកទោសស្លាប់ទេ៖

> "ស៖ តើលោកធ្លាប់ឮអ្វីមួយអំពីការសម្លាប់មនុស្សដែលត្រូវបានគេឃុំឃាំងនោះទេ? តើគេយកអ្នកទាំងនោះទៅសម្លាប់នៅឯណាដែរ លោកដឹងទេ? ឆ៖ អត់ដឹងដែរ។ ប៉ុន្តែឃើញគេចេះតែដកចេញពីអាបន្ទប់ឃុំឃាំងនោះដាក់នឹងឡានទៅ មិនដឹងជាទៅសម្លាប់យ៉ាងម៉េច ភ្នែកវាអត់ឃើញ។ ស៖ ខ្ញុំសូមអានសម្រង់ខ្លីមួយចេញ

---

[1379] ចាន់ ទូយ ប្រតិចារឹក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/399.1** ទំព័រ ១៧ ក្រោយម៉ោង [០៩.៥៥.៥៥]។

[1380] ចាន់ ទូយ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ **ឯកសារ E3/7694** ERN 00236706។

[1381] ចាន់ ទូយ ប្រតិចារឹក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/399.1** ទំព័រ ២៣ មុនម៉ោង [១០.១៣.៤៣]។

[1382] ចាន់ ទូយ ប្រតិចារឹក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/399.1** ទំព័រ ៣៥-៣៦ ចន្លោះម៉ោង [១១.០៧.២៥] និង [១១.០៩.៤៤]។

[1383] ចាន់ ទូយ ប្រតិចារឹក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/399.1** ទំព័រ ៥១ ក្រោយម៉ោង [១៣.៥០.០៥]។

ពីកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/7696 ខ្មែរ 00231531 អង់គ្លេស 00384152 បារាំង 00384258។ លោកបានឆ្លើយដូចតទៅ សូមដកស្រង់៖ មានការសម្លាប់ខ្លះ ប៉ុន្តែមិនសម្លាប់នៅក្នុងគុកទេ គេនាំទៅតាមផ្លូវទៅកាន់ខេត្តក្រចេះ។ ហើយមុននេះ លោកក៏បាននិយាយថា លោកបានស្តាប់ឮអ្នកដែលគេឃុំខ្លួននៅជាន់ខាងលើត្រូវបានគេដឹកទៅកាន់ទិសខាងលិច។ តើអ្នកណាដែលបានប្រាប់លោកថា អ្នកទោសដែលគេយកចេញទៅក្រៅហ្នឹង គឺត្រូវគេបញ្ជូនចេញទៅលិច គឺជាផ្លូវសំដៅទៅកាន់ខេត្តក្រចេះ អ្នកណាជាអ្នកប្រាប់លោក? ឆ៖ ទេ ការងារនេះ វាចេះតែឮទៅតាមពាក្យពេចន៍គេនិយាយ ប៉ុន្តែភ្នែកអត់ឃើញទេណា។ ឮគេនិយាយខ្សឹបៗគ្នាទៅ”[1384]។

## ៣. ចម្លើយរបស់ ប៊ុន ឡឹងចូយ

១៤៤៩. សាក្សី ប៊ុន ឡឹងចូយ ដែលមិនមែនជាអ្នកទោស បានផ្តល់ចម្លើយមិនស៊ីសង្វាក់គ្នា ពាក់ព័ន្ធនឹងការសម្លាប់។ ជាដំបូង គាត់ឆ្លើយថា គាត់ដឹងថា ក្រោយពីជាប់ឃុំបានមួយសប្តាហ៍នៅភ្នំក្រោល “អ្នកទោសធ្ងន់ [...] ត្រូវបាននាំយកទៅសម្លាប់” ប៉ុន្តែ គាត់មិនអាចផ្តល់ឈ្មោះអ្នកណាម្នាក់ដែលត្រូវគេសម្លាប់បានទេ ខណៈដែលអ្នកខ្លះជាសមាជិកគ្រួសាររបស់គាត់[1385]។ ចម្លើយរបស់គាត់ធ្វើឱ្យលេចឡើងនូវមន្ទិលសង្ស័យអំពីការសម្លាប់មនុស្ស៖

> “សរ៖ តើលោកមានសាច់ញាតិណាដទៃទៀតត្រូវបានគេបញ្ជូនទៅឃុំខ្លួននៅភ្នំក្រោល ហើយមិនរស់រានមានជីវិតពីរបបនោះដែរឬទេ? ឆ៖ បាទ សូមរៀបរាប់អ្នកដែលខ្ញុំចាំទេបាទ មានអ្នកដែលគេចាប់ស្រករជាមួយខ្មោចឪពុកមាខ្ញុំហ្នឹង តាកាស៊ី ហ្នឹង មានបីបួននាក់ហ្នឹង អត់មានមកវិញទេ។ ហើយចំពោះគ្នាពួកគាត់ច្រើនដែរ រាប់មិនអស់ទេ គាត់អត់បានមកវិញដែរ។ តាមខ្ញុំដឹង ឃើញមកតែម្នាក់ពីរនាក់ ប៉ុន្តែ ម្នាក់ហ្នឹងខ្ញុំចាំច្បាស់ គឺជាប្អូនថ្លៃខ្ញុំ ហើយប៉ុន្មាននាក់ហ្នឹង ខ្ញុំអត់ចាំទេ ព្រោះគេទៅស្រុកទៅស្រែគេវិញអស់ បាទ”[1386]។

១៤៥០. គាត់ក៏បានឆ្លើយផងដែរថា គាត់មិនធ្លាប់ឃើញហេតុការណ៍កើតឡើងនៅក្នុងមន្ទីរសន្តិសុខនោះទេ ពីព្រោះគេមិនអនុញ្ញាតឱ្យគាត់ចូល។ គាត់បានត្រឹមតែក្រឡេកឃើញពីចម្ងាយប្រហែលជាខ្ទង់ “៥០

---

[1384]ណោត សាវ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/400.1** ទំព័រ ២៨-២៩ ចន្លោះម៉ោង [១១.១១.០២] និង [១១.១៧.០៦]។

[1385]ប៊ុន ឡឹងចូយ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1** ទំព័រ ២០ ប្រហែលម៉ោង [១០.៣៨.៣៧]។

[1386]ប៊ុន ឡឹងចូយ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1** ទំព័រ ២០ ប្រហែលម៉ោង [១០.៣៨.៧៧]។

ទៅ ១០០ ម៉ែត្រ” ពីកន្លែងនោះ[1387]។ គាត់បានឆ្លើយបន្ត ដោយអះអាងថា គាត់ដឹងថា អ្នកទោសត្រូវបានគេនាំយកទៅសម្លាប់ ប៉ុន្តែ មិនបានប្រាប់ប្រភពនៃព័ត៌មាននេះទេ[1388]។

១៤៥១. ជាចុងក្រោយ ពេលសួរអំពីទីតាំងត្រពាំងព្រីង គាត់បានឆ្លើយថា គាត់ដឹងថាគេជីករណ្តៅ ប៉ុន្តែ គាត់មិនធ្លាប់ឃើញរណ្តៅនោះទេ ហើយក៏មិនបានប្រាប់ថា អ្នកទោសនៅភ្នំក្រោលត្រូវបានគេសម្លាប់នោះដែរ[1389]។

១៤៥២. ចម្លើយមិនជាប់ពាក់ព័ន្ធ និងមិនលម្អិត របស់បុគ្គលម្នាក់ដែលមិនធ្លាប់ជាប់ឃុំ គ្មានទំនួលខុសត្រូវនៅទីតាំងទាំងនេះ និងមិនផ្តល់ប្រភពនៃការដឹងឮរបស់គាត់អំពីអង្គហេតុដ៏ធ្ងន់ធ្ងរដែលត្រូវបានចោទប្រកាន់ចំពោះលោក ខៀវ សំផន មិនអាចយកធ្វើជាមូលដ្ឋាននៃភាពច្បាស់លាស់នៃឧក្រិដ្ឋកម្មមួយបានឡើយ។

## ៤. ភស្តុតាងផ្សេងទៀត

១៤៥៣. មានភស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿង ដែលលើកឡើងអំពីការស្លាប់របស់អ្នកទោសនៅមន្ទីរសន្តិសុខភ្នំក្រោល[1390]។

១៤៥៤. ដោយសារតែចម្លើយផ្ទុយគ្នានៅក្នុងសវនាការរបស់ ចាន់ ទូយ និង ណោត សារ៉ាត ដែលជាសាក្សីផ្ទាល់តែពីរនាក់គត់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងចម្លើយផ្ទុយគ្នានៅចំពោះមុខសហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះមិនអាចទាញសេចក្តីសន្និដ្ឋានអំពីឧក្រិដ្ឋកម្ម ដោយផ្អែកលើចម្លើយដែលមិនទាន់បានពិភាក្សាដេញដោលចំពោះមុខនោះឡើយ។

---

[1387] ប៊ុន ឡឹងចូយ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1** ទំព័រ ២១ មុនម៉ោង [១០.៤៣.១៧]។

[1388] ប៊ុន ឡឹងចូយ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1** ទំព័រ ២១ ប្រហែលម៉ោង [១០.៤៣.១៧]។

[1389] ប៊ុន ឡឹងចូយ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1** ទំព័រ ២២-២៧ ចន្លោះម៉ោង [១០.៤៣.១៧] និង [១១.០៥.៤៩]។

[1390] សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ ៦៤១-៦៤២ កំណត់សម្គាល់ជើងទំព័រ ២៧៨៧-២៧៩០។

១៤៥៥. សហព្រះរាជអាជ្ញានឹងមិនខកខានក្នុងការផ្អែកលើចម្លើយរបស់ សុខ អ៊ែល ដែលមានឈ្មោះនៅក្នុងបញ្ជីបឋម[1391] ដោយអះអាងថា ដោយសារគាត់ទទួលមរណភាពទៅហើយ ខ្លួនអាចប្រើប្រាស់ចម្លើយទាំងនេះ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់។ នីតិវិធីអនុញ្ញាតឱ្យធ្វើបែបនេះ ប៉ុន្តែ ដោយសារតែភាពចន្លោះប្រហោងនៃកិច្ចស៊ើបសួរដែលដាក់បន្ទុកផ្តាច់មុខ អង្គជំនុំជម្រះអាចប្រើប្រាស់ភ័ស្តុតាងទាំងនេះបាន ដោយប្រយ័ត្នប្រយែងបំផុត[1392]។

១៤៥៦. ការផ្លាស់ប្តូរស្ថានភាព ដែលបានសង្កេតឃើញនៅក្នុងសវនាការ គឺជាឧបសគ្គរាំងដាច់ខាតដល់ការផ្តន្ទាទោសលោក ខៀវ សំផន ដោយផ្អែកតែទៅលើកំណត់ហេតុស្តាប់ចម្លើយ ដែលមានតម្លៃជាភ័ស្តុតាងទាបបំផុត។

**ផ្នែកទី ៥. ការកំណត់ប្រភេទបទល្មើស**

**១. អំពើមនុស្សឃាត (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)**

**ក. និយមន័យ**

១៤៥៧. ធាតុផ្សំសត្យានុម័តិនៃអំពើមនុស្សឃាតរួមមានអំពើសកម្ម ឬអកម្មរបស់ជនជាប់ចោទ ឬរបស់ជនណាម្នាក់ ឬច្រើនម្នាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើសកម្ម ឬអកម្មដែលបណ្តាលឱ្យជនរងគ្រោះស្លាប់[1393]។ ចំពោះធាតុផ្សំអត្តនោម័តិ ចារីត្រូវមានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្ស[1394]។

**២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ**

[1391] បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤ **ឯកសារ E307/3/2.2**។

[1392] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៥២៥-៥៥១។

[1393] សាលក្រម ០០២/០១ កថាខណ្ឌ ៤១២។

[1394] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៣៩៤-៤២៩។

១៤៥៨. ការពិនិត្យមើលអង្គហេតុបានបង្ហាញថា គ្មានការស្លាប់នៅតាមទីតាំងនានានៃមន្ទីរសន្តិសុខភ្នំក្រោលនោះទេ។ អាស្រ័យហេតុនេះ ឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាតមិនមានធាតុផ្សំគ្រប់គ្រាន់នោះទេ។

## ២. ការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)

### ក. និយមន័យ

១៤៥៩. ធាតុផ្សំសត្យានុម័តិនៃការសម្លាប់រង្គាលត្រូវបានកំណត់ដោយការសម្លាប់មនុស្សក្នុងចំនួនច្រើន[1395]។ ចំពោះធាតុផ្សំអត្តនោម័តិ ចារីត្រូវមានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្សច្រើន ឬធ្វើឱ្យពួកគេរស់នៅក្នុងល័ក្ខខ័ណ្ឌជីវិតដ៏លំបាកលំបិនបណ្ដាលឱ្យស្លាប់[1396]។

### ខ. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ

១៤៦០. ការពិនិត្យមើលអង្គហេតុបានបង្ហាញថា គ្មានការស្លាប់នៅតាមទីតាំងនានានៃមន្ទីរសន្តិសុខភ្នំក្រោលនោះទេ។ អាស្រ័យហេតុនេះ ឧក្រិដ្ឋកម្មក្រោមទម្រង់ជាការសម្លាប់រង្គាលមិនមានធាតុផ្សំគ្រប់គ្រាន់ឡើយ។

## ជំពូកទី ៥. ការចោទប្រកាន់ចំពោះគោលនយោបាយទាក់ទងនឹងមន្ទីរសន្តិសុខ

១៤៦១. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មមួយចំនួនដែលត្រូវបានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល ហើយដែលការចោទប្រកាន់ទាំងនោះ បានទទួលការឆ្លើយតបវិញ ដូចមានបញ្ជាក់ពីខាងលើ[1397]។ យោងតាមសហចៅក្រមស៊ើបអង្កេត ការបង្កើត និងដំណើរការមន្ទីរសន្តិសុខទាំងអស់នោះ បាន

---

[1395] សាលដីកា ០០២/០១ កថាខណ្ឌ ៥១៧។

[1396] សាលដីកា ០០២/០១ កថាខណ្ឌ ៥១៧-៥២២។

[1397] សូមមើលផ្នែកខាងលើ, ជំពូកទី ១៖ ស-២១, ជំពូកទី ២៖ ក្រាំងតាចាន់, ជំពូកទី ៣៖ អូរកន្សែង និងជំពូកទី ៤៖ ភ្នំក្រោល។

បម្រើឱ្យការអនុវត្តគោលនយោបាយដែលរងការចោទប្រកាន់ស្តីពីការ“លត់ដំ “សមាសភាពមិនល្អ” និងកម្ទេច“ខ្មាំង” ដែលមានទាំងខាងក្នុងបក្ស និងខាងក្រៅបក្ស”[1398]។ អង្គហេតុទាំងឡាយទាក់ទងនឹងការអនុវត្តគោលនយោបាយនេះ ត្រូវបានដាក់ជូនអង្គជំនុំជម្រះពិនិត្យសម្រេច[1399]។

១៤៦២. យោងតាមដីកាដំណោះស្រាយ គោលនយោបាយទាំងប្រាំ ដែលក្នុងនោះមានគោលនយោបាយចំនួនមួយកំពុងត្រូវបានលើកយកមកពិនិត្យនាពេលនេះ ត្រូវបានកំណត់ដោយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីសម្រេចផែនការរួម។ តាមពិតទៅ គំនូសបត់បែននៃគោលនយោបាយទាំងនេះ ត្រូវបានគូរតាមរបៀបស្រេចតែចិត្ត ដោយសហចៅក្រមស៊ើបអង្កេត ក្នុងគោលដៅតែមួយគត់គឺដើម្បីអាចផ្តន្ទាទោសលោក ខៀវ សំផន ព្រោះថាអ្វីដែលសំខាន់សម្រាប់សហចៅក្រមស៊ើបអង្កេត គឺការបង្កើតឱ្យមានទំនាក់ទំនងរវាងទីតាំងឧក្រិដ្ឋកម្ម ដែលនៅទីនោះ គេកត់សម្គាល់ថាគ្មានវត្តមានលោក ខៀវ សំផន ជាមួយនឹងតួនាទី មុខងាររបស់គាត់ ក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ។

១៤៦៣. ដោយមិនអាចបង្ហាញភ័ស្តុតាងឱ្យឃើញពីការទទួលខុសត្រូវផ្ទាល់របស់លោក ខៀវ សំផន នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬតាមរយៈការចេញបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ការប្រឌិតរឿងមួយ ដោយបានទម្លាក់ការទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះទៅលើការអនុវត្តគោលនយោបាយសម្រេចដោយអង្គភាពនានារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលក្នុងនោះ លោក ខៀវ សំផន អាចជាសមាជិកមួយរូប។

១៤៦៤. ដូច្នេះ វាលែងមានទំនាក់ទំនងរវាងជនជាប់ចោទ ជាមួយនឹងឧក្រិដ្ឋកម្ម តទៅទៀត តែផ្ទុយទៅវិញ វាមានទំនាក់ទំនងរវាងជនជាប់ចោទ និងនយោបាយដែលត្រូវបានសន្មតថាបាននាំទៅឱ្យមានអំពើឧក្រិដ្ឋកម្ម។

១៤៦៥. ទស្សីករណ៍ពោរពេញដោយភាពអយុត្តិធម៌មួយនេះ បង្ហាញឱ្យឃើញភ្លាមៗពីភាពមានកម្រិតរបស់វាក្នុងក្របខ័ណ្ឌគោលនយោបាយមន្ទីរសន្តិសុខដែលត្រូវបានចោទប្រកាន់។

---

[1398] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៧ និង ១៧៨-២០៣។

[1399] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី **ឯកសារ** **E1/301/9/1**,ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ២។

១៤៦៦. ម្យ៉ាង មន្ទីរសន្តិសុខត្រូវបានប្រើប្រាស់ដើម្បីបំបែកមនុស្សដែលគេគិតថាគ្រោះថ្នាក់ ឱ្យទៅនៅឆ្ងាយ ដើម្បីស្ថិរភាពកម្ពុជាប្រជាធិបតេយ្យ។ ចលនាបះបោរ គឺពិតជាមានប្រាកដមិនអាចប្រកែកបាន ហើយខ្មែរក្រហមបានឆ្លើយតបយ៉ាងម៉ឺងម៉ាត់បំផុត (១)។

១៤៦៧. ម្យ៉ាងទៀត ភ័ស្តុតាងជាច្រើនបង្ហាញឱ្យឃើញថា មន្ទីរសន្តិសុខស្ថិតនៅក្រោមបញ្ជារបស់កងទ័ព។ ក៏ប៉ុន្តែ ដូចដែលអង្គជំនុំជម្រះធ្លាប់បានសម្រេចលើចំណុចនេះ នៅក្នុងសំណុំរឿង ០០២/០១ លោក ខៀវ សំផន ពុំធ្លាប់ដែលមានអំណាចនៅក្នុងកងទ័ពរបស់បក្សម្តងណាឡើយ (២)។

១៤៦៨. ជាចុងក្រោយ គេត្រូវនិយាយបន្តិចពាក់ព័ន្ធនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលជាមន្ទីរមួយមិនអាស្រ័យលើអង្គការលេខឃោធា តែការណ៍ដែលវាមិនអាស្រ័យលើឃោធានេះ ក៏ពុំអាចរារាំងសហចៅក្រមស៊ើបអង្កេតបានដែរ ព្រោះពួកគាត់មិនសូវអើពើនឹងស្ថានភាពខុសគ្នាៗឡើយ នៅពេលពួកគាត់ចេញសេចក្តីសន្និដ្ឋានរបស់ខ្លួន (III)។

## ផ្នែកទី ១. ពីរដ្ឋមានសន្តិសុខមួយ ក្លាយជារដ្ឋអសន្តិសុខ

១៤៦៩. ក្នុងអំឡុងពេលសវនាការ លោក Stephen MORRIS បានពន្យល់ពីការបោសសម្អាត ដោយសារតែរបបនេះភ័យរន្ធត់រវើរវាយ[1400]។ ទោះវាជាការភ័យរវើរវាយមែនឬអត់ក៏ដោយ ក៏គាត់ថែមទាំងបានបង្ហាញថាគាត់បានរកឃើញនៅក្នុងបណ្ណសារដ្ឋានសូវៀត នូវភ័ស្តុតាងមួយចំនួនទាក់ទងនឹងការប៉ុនប៉ងផើបបះបោរប្រឆាំងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងឆ្នាំ ១៩៧៧ ហើយដូច្នេះ វាសបញ្ជាក់ឱ្យ

[1400] Stephen MORRIS ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ៨៣ ប្រហែលម៉ោង [១៥.៣៥.៤៩]៖ "ខ្ញុំគិតថានេះគឺជាការអភ័យ -- ជំងឺភ័យខ្លាចពីសំណាក់ ប៉ុល ពត ដែលគិតថាអ្នកនៅក្នុងជួរបក្សហ្នឹង ដែលធ្លាប់ស្មោះនឹងបក្ស ក្នុងអំឡុងពេលដ៏វែងឆ្ងាយមកហើយ ជាការពិត អ្នកទាំងអស់នោះ គឺជាភ្នាក់ងាររបស់វៀតណាម។ មិនមែនគ្រាន់តែគាត់មានជំងឺត្រដេវរិចប៉ុណ្ណោះទេ ក៏ប៉ុន្តែដើម្បីបង្ហាញឲ្យឃើញអំពីចំណុចខ្សោយក្នុងការមានជម្លោះជាមួយវៀតណាមនេះ។ ឬអាចនិយាយម្យ៉ាងទៀតបានថា ប្រជាជនមកពីភូមិភាគបូព៌ា គឺថាដែលវាយប្រយុទ្ធជាមួយនឹងវៀតណាម ហើយមិនទទួលបានជោគជ័យក្នុងការប្រយុទ្ធជាមួយវៀតណាមនោះ ត្រូវតែជាជនក្បត់ហើយ ពីព្រោះអ្នកទាំងអស់នោះមិនអាចយកជ័យជម្នះទៅលើវៀតណាមបាន។ នេះជាវប្បធម៌នៃជំងឺភ័យខ្លាចខាងផ្នែកនយោបាយ ដែលជ្រាបចូលគ្រប់ចលនាបដិវត្តន៍ទាំងអស់"។

ឃើញថាសម្មតិកម្មស្តីពីការប៉ុនប៉ងបះបោរ ឬចលនាផ្តួលរំលំ ពិតជាត្រឹមត្រូវប្រាកដមែន[1401]។ សាក្សីជាច្រើនបាននិយាយពីរឿងនេះ នៅចំពោះមុខអង្គជំនុំជម្រះ។

១៤៧០. ព្រុំ សារ៉ាត និយាយថាគាត់បានស្តាប់ឮគេនិយាយពីការសមគំនិតក្បត់ នៅក្នុងវគ្គរៀនសូត្រជាមួយ សុន សេន[1402]។ មាស វឿន បានរៀបរាប់ប្រាប់តុលាការពីឧប្បត្តិហេតុមួយចំនួនដែលមិត្តភ័ក្តិបាន រាយការណ៍ប្រាប់គាត់ ទាក់ទងនឹង "បន្ទាយរបស់ សោ ភឹម" នៅតាមព្រំដែនវៀតណាម និងបាន និយាយពីសំបុត្រមួយដែលត្រូវបានរកឃើញ ដែលនៅក្នុងសំបុត្រនោះមាននិយាយពីគម្រោងធ្វើរដ្ឋ ប្រហារ[1403]។ សាក្សីផ្សេងទៀត គឺជាសាក្សីដែលបានឃើញផ្ទាល់នូវអង្គហេតុ និងព្រឹត្តិការណ៍ ដែលអាចបញ្ជាក់ពីការតស៊ូផ្ទៃក្នុង និងពីភាពអនាធិបតេយ្យដែលកើតមាននៅតាមកន្លែងផ្សេងៗ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ស៊ិន អ៊ីង ធ្លាប់ធ្វើជាអង្គរក្សការពារ សោ ភឹម បានបញ្ជាក់ អះអាងប្រាប់តុលាការថាចម្លើយពីមុនរបស់គាត់ទាក់ទងនឹងការប្រជុំ "ចាប់ផ្តើមចលនាតស៊ូ" គឺពិត ជាត្រឹមត្រូវ[1404]។

១៤៧១. ម្យ៉ាងវិញទៀត សាក្សី ស៊ិន អ៊ីង បានបញ្ជាក់ថាក្រោយឆ្នាំ ១៩៧៨ គាត់បានដឹងថាមានការប្រឈម មុខគ្នាដោយអាវុធរវាងកងទ័ពមជ្ឈិម និងកងទ័ពភូមិភាគបូព៌ា[1405]។

---

[1401] Stephen MORRIS ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/486.1** ទំព័រ ២៣ ប្រហែលម៉ោង [១០.០៧.៥៩]៖ "អ្វីដែលខ្ញុំបានជួបប្រទះនោះ គឺភស្តុតាងដែលថាមានបំណងធ្វើការបះបោរ មិនមែនជារដ្ឋប្រហារទេ។ ទស្សនៈនៃការធ្វើរដ្ឋប្រហារនេះ គឺថាខ្ញុំមិនបានរកឃើញនៅក្នុងការស្រាវជ្រាវរបស់ខ្ញុំនេះទេ ហើយខ្ញុំក៏មិនបាននិយាយថារឿងនេះ គឺមិនបានកើតឡើងនោះទេ។ ខ្ញុំនិយាយតែអ្វីដែលខ្ញុំបានឃើញ អ្វីដែលខ្ញុំបានអាន អ្វីដែលខ្ញុំបានជួបប្រទះ ខ្ញុំអានទៅអត់ឃើញថាមានគោលបំណង ឬក៏ផែនការធ្វើរដ្ឋប្រហារប្រឆាំងមកលើកម្ពុជាប្រជាធិបតេយ្យទេ។ តែមានការបង្កើតចលនាបះបោរ"។

[1402] ព្រុំ សារ៉ាត ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/382.1** ទំព័រ ២៥ មុនម៉ោង [១៣.៤៩.២១]។

[1403] មាស វឿន ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/386.1** ទំព័រ ៥៨-៥៩ ចន្លោះម៉ោង [១៥.០៦.១៨] និង [១៥.១០.៤០] ទំព័រ ៦០-៦១ ក្រោយម៉ោង [១៥.១៣.៥១]។

[1404] ស៊ិន អ៊ីង ប្រតិចារឹក ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/505.1** ទំព័រ ៨០-៨២ ចន្លោះម៉ោង [១៥.៤៩.០៦] និង [១៥.៥៧.១៣]។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/506.1** ទំព័រ ៥៩-៦០ ប្រហែលម៉ោង [១៤.២៣.០៨]។

[1405] ស៊ិន អ៊ីង ប្រតិចារឹក ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/505.1** ទំព័រ ៧៣ ប្រហែលម៉ោង [១៥.២៥.០៣]។

១៤៧២. នង នីម ដែលជាញាតិម្នាក់ដែររបស់ សោ ភឹម គឺជាសមាជិកកងការពាររបស់ សោ ភឹម មាននាទីជាអ្នកបើកបរ។ ដូចគ្នានឹង ស៊ិន អ៊ឹង ដែរ នង នីម គឺជាសាក្សីដែលបានឃើញពីទស្សនកិច្ចរវាងរស់ ញឹម និង សោ ភឹម នៅបាត់ដំបង។ គាត់បានបញ្ជាក់ថាសំដីរបស់ ស៊ិន អ៊ឹង ទាក់ទងនឹងការប្រឈមមុខដាក់គ្នារវាងមជ្ឈិម និងភូមិភាគបូព៌ា គឺពិតជាត្រឹមត្រូវ[1406]។

១៤៧៣. សាក្សី បាន សៀក ដែលត្រូវបានចាត់តាំងជាលេខាស្រុកក្រូចឆ្មារ នៅឆ្នាំ ១៩៧៨ ត្រូវបានថ្នាក់លើប្រាប់គាត់អំពីអំពើក្បត់របស់ ហេង សំរិន ជា ស៊ីម និង "កម្មាភិបាលភូមិភាគបូព៌ាមួយចំនួន" ដែលបានចូលជាមួយវៀតណាម។ សាក្សីបាននិយាយថា វាចាំបាច់ដែលត្រូវ "ប្រមូលកម្លាំង" នៅចំពោះមុខកម្លាំងនៅនឹងកន្លែង។ បើតាមចម្លើយរបស់សាក្សី គឺថា"វាមានចលនាមួយដើម្បីកសាងកម្លាំងសង្គ្រោះជាតិឡើងវិញ និងមានកម្លាំងតស៊ូដែលសកម្មយ៉ាងខ្លាំងនាពេលនោះ"។ ក្នុងបរិបទបែបនេះគេបានសុំឱ្យ "គាត់រើសមនុស្សដើម្បីទៅសមរភូមិ"[1407]។

១៤៧៤. បើតាមចម្លើយសាក្សី បាន សៀក ស្ថានការណ៍មានភាព "តានតឹង" ដោយសារតែការបង្កើតរណសិរ្សសង្គ្រោះ និង"ការបះបោររបស់ក្រុមកងចល័ត"។ បាន សៀក បានពន្យល់ថា នៅពេលដែលគាត់ព្យាយាមរើសទាហាន កងទ័ពមជ្ឈិមទំនងជា"បារម្ភ"លើបញ្ហានេះ ដោយគិតថាគាត់មានបំណងចង់រៀបចំការបះបោរ។ បញ្ហាកាន់តែធ្ងន់ធ្ងរឡើងនៅពេលដែលទាហាន ១០០ នាក់ ដែលគាត់ធ្លាប់បានបង្វឹក បានរត់ចូលព្រៃ "ជាមួយនឹងអាវុធ"[1408]។

១៤៧៥. ក្នុងអំឡុងពេលសវនាការ សាក្សី មាស សឿន កូនប្រុសរបស់ ចាន់ សេងហុង អ្នកទទួលខុសត្រូវបក្សកុម្មុយនីស្តកម្ពុជានៅថ្នាក់មូលដ្ឋាន ក្នុងភូមិភាគបូព៌ា បានលើកឡើងដូចគ្នាពីការប្រឈមមុខ

[1406] <u>នង នីម</u> ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ** E1/511.1 ទំព័រ ៨-៩ ចន្លោះម៉ោង [០៩.២៧.០៤] និង [០៩.២៩.៣២] ទំព័រ ១៦ប្រហែលម៉ោង [០៩.៥២.៤២] ទំព័រ ៣៦ប្រហែលម៉ោង [១១.១៤.៣៩]។

[1407] <u>បាន សៀក</u> ប្រតិចារឹក ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ **ឯកសារ** E1/353.1 ទំព័រ ៥០ ក្រោយម៉ោង [១៣.៥១.០៨] ទំព័រ ៥១ ប្រហែលម៉ោង [១៣.៥៥.០១] ទំព័រ ៦១ មុនម៉ោង [១៤.៣៣.៤១] ទំព័រ ៧២ មុនម៉ោង [១៥.៣២.៣០]។

[1408] <u>បាន សៀក</u> ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ **ឯកសារ** E1/354.1 **[date et numéro du document à rectifier dans l'original]** ទំព័រ ១៨ ក្រោយម៉ោង [១០.០៤.២១], ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ **ឯកសារ** E1/354.1 ទំព័រ ៤៩-៥០ ក្រោយម៉ោង [១៤.១៦.៥៦]។

ដាក់គ្នារវាងកងកម្លាំងផ្សេងៗ ក្នុងនោះមានកម្លាំងរបស់ ហេង សំរិន ប្រឆាំងនឹងកម្លាំងរបស់ មជ្ឈិម[1409]។

១៤៧៦. សាក្សី សែម អំ អ្នកទទួលខុសត្រូវប្រព័ន្ធវិទ្យុទាក់ទងនៅក្នុងអង្គភាពប្រចាំការនៅត្រពាំងថ្កុង ក្នុងខេត្តកំពង់ចាម បាននិយាយថាគាត់បានស្តាប់ឮ"ជនជាតិខ្មែរម្នាក់ដែលកំពុងនិយាយតាមវិទ្យុទាក់ទង ដោយគាត់និយាយថាយើងត្រូវប្រមូលកម្លាំងដើម្បីចូលរួមធ្វើរដ្ឋប្រហារទម្លាក់ ប៉ុល ពត"[1410]។

១៤៧៧. បន្ថែមពីលើនេះ នៅមានការរត់ចោលជួរ និងឧប្បត្តិហេតុផ្សេងៗទៀតទាក់ទងនឹងទាហាន ដែលធ្វើឱ្យទាហាននៅសល់ ត្រូវស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់[1411]។ សាក្សី 2-TCW-1005 បានលើកឡើងជាអាទិ៍ពីឧប្បត្តិហេតុមួយដែលក្នុងនោះ អ្នកបញ្ជាវិទ្យុទាក់ទងបានផ្តល់សេចក្តីណែនាំខុស បណ្តាលឱ្យស្លាប់ទាហាន ២០០ នាក់[1412]។ សាក្សីយល់ឃើញថា ឧប្បត្តិហេតុប្រភេទនេះ ក៏ជាមូលហេតុនៃការបោសសម្អាត និងបង្កឱ្យមានការសង្ស័យទាក់ទងនឹងការលេចធ្លាយព័ត៌មាន ដោយមិនទាន់រាប់បញ្ចូលនូវការរត់គេចខ្លួនរបស់ទាហាន និងចលនាបះបោរនៅក្នុងភូមិភាគ[1413]។

---

[1409] មាស សឿន ប្រតិចារឹក ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/447.1** ទំព័រ ១២ ចន្លោះម៉ោង [០៩.៣៨.២៨] និង [០៩.៤១.៣០]។

[1410] សែម អំ ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/477.1** ទំព័រ ៣១ ប្រហែលម៉ោង [១០.៥១.១០] ទំព័រ ៦០-៦១ ប្រហែលម៉ោង [១៤.២៦.៥០]។

[1411] 2-TCW-1005 : ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/448.1** ទំព័រ ៤៤ មុនម៉ោង [១៣.៤៨.៣០] "[...] ឧទាហរណ៍ថា គាត់បាញ់ដៃគាត់របួសមកសម្រាកមន្ទីរពេទ្យនៅក្រោយ អាហ្នឹងខ្ញុំនិយាយឱ្យអស់រឿង ដល់អីចឹងទៅមកដល់គាត់អុកឡុកនៅក្រោយហ្នឹង។ អុកឡុកអី? អាររបួសឈឺល្មមៗ គាត់ថាររបួសគាត់ធ្ងន់ធ្ងរ អីចឹងគាត់មកក្រោយទៀតមក ដល់អីចឹងទាញអ្នកនៅមុខប៉ុន្មានដូចថា ១០០, ២០០ នាក់ហ្នឹង។ អាម្នាក់ពីរនាក់ហ្នឹងធ្វើខូចអាប៉ុន្មានរយនាក់នោះ បាក់មកតាមគ្នា រឿងអីចឹង"។

[1412] 2-TCW-1005 ប្រតិចារឹក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/450.1** ទំព័រ "មានតែរឿងថា កែតេអូឱ្យអ្នកកាន់តេអូនោះ វាកែគ្រាប់ផ្លោងពីយួនមកទម្លាក់ -- មកផ្លោងចំគ្នាឯងនេះ អាហ្នឹងៗ មានអាចៗ [...] ដូចថាវរៈសេនាធំនៅត្រង់នុំង តេអូអ្នកហូបបាយជប់លៀងរៀបទៅវ៉ៃហ្នឹង នៅត្រង់នេះ បាទ នៅហូបត្រង់នេះ កំពុងតែហូបបាយរាប់រយនាក់ហ្នឹង ដល់គ្រាប់ផ្លោងយួនជាន់មកហ្នឹង [...] បាទ អាហ្នឹង អាចលោកៗ អាចចម្លើយខ្ញុំនិយាយយ៉ាងម៉េច អាហ្នឹងជាក់ស្តែងលោកពិនិត្យសាថ្មីមើល"។

[1413] 2-TCW-1005 : ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/449.1** ទំព័រ ៦១-៦២ ប្រហែលម៉ោង [១៤.២០.៥០] ទំព័រ ៦៣-៦៤ ប្រហែលម៉ោង [១១.២៤.៥០] ទំព័រ ៨៧-៨៨ ប្រហែលម៉ោង [១៥.៥៤.៣៧]។

១៤៧៨. សាក្សី អៀង ផាន និយាយថា ក្រោយសមាហរណកម្ម គាត់បានទទួលការបញ្ជាក់មកថា “ក្នុងចំណោមកងទ័ពវៀតណាម មានទាហានខ្មែរដែលទទួលបានការបណ្តុះបណ្តាលនៅប្រទេសវៀតណាម ហើយដែលបានរត់ពីភូមិភាគបូព៌ា” ក្នុងចន្លោះចុងឆ្នាំ ១៩៧៧ និងពាក់កណ្តាលឆ្នាំ ១៩៧៨ ហើយពេលនេះ ពួកគាត់ “ជាមេបញ្ជាការកងទ័ព”[1414]។

១៤៧៩. ដោយរងការគំរាមកំហែងទាំងខាងក្នុង និងខាងក្រៅ កម្ពុជាប្រជាធិបតេយ្យត្រូវធ្លាក់ក្នុងសភាពអសន្តិសុខ ដែលបញ្ហានេះទំនងជាមិនអាចកើតមាននៅក្រៅបរិបទផ្សេងទៀតនោះទេ។ តាមរយៈការបង្កើតឱ្យមានអសន្តិសុខនៅកន្លែងផ្សេងៗក្នុងប្រទេស ជម្លោះប្រដាប់អាវុធបានជះឥទ្ធិពលលើរបៀបដែលការសង្ស័យត្រូវបានកើតឡើងនៅតាមតំបន់ព្រំដែន និងផ្នែកដទៃទៀតក្នុងប្រទេស។ ហេតុដូច្នេះ មនុស្សត្រូវបានចាប់ខ្លួនដោយសារតែខ្លាចពួកគេធ្វើឱ្យប៉ះពាល់ដល់ភាពគង់វង្ស និងស្ថិរភាពរបស់កម្ពុជាប្រជាធិបតេយ្យ និងពុំមែនដោយសារតែមនោគន៍វិជ្ជាសន្មតដែលបានកើតមានមុនការប្រើប្រាស់មន្ទីរសន្តិសុខឡើយ។

## ផ្នែកទី ២. ផ្នែកសន្តិសុខក្រោមការគ្រប់គ្រងរបស់កងទ័ព

១៤៨០. ទាក់ទងនឹងមន្ទីរសន្តិសុខដែលអង្គហេតុកើតឡើងនៅទីនោះ ត្រូវបានយកមកជំនុំជម្រះ គឺមានមន្ទីរសន្តិសុខចំនួនបី ស្ថិតក្រោមបញ្ជាការកងទ័ព។

១៤៨១. ស-២១ ជាមន្ទីរដែលគ្រប់គ្រងភាគច្រើនដោយទាហានកងពលធំ ៧០៣។ តាណាត ដែលជាប្រធាន ស-២១ ដំបូងគេ ស្ថិតក្នុងកងពលធំ ៧០៣ ដែលគ្រប់គ្រងដោយសេនាធិការ[1415]។ ហ៊ី ជាអនុប្រធានមន្ទីរ ស-២១ នៅពេល ឌុច ក្លាយជាប្រធាន ក៏ស្ថិតនៅក្នុងកងពលធំ ៧០៣ ដែរ ដូចគ្នា

---

[1414] អៀង ផាន ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/492.1** ទំព័រ ៧០ ប្រហែលម៉ោង [១៥.៣០.៣៣]។

[1415] សួស ធី ប្រតិចារឹក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/432.1** ទំព័រ ២២ ចន្លោះម៉ោង [១០.៣៤.៣៥] និង [១០.៣៧.០៧] ទំព័រ ២៩ ចន្លោះម៉ោង [១០.៥៧.២៣] និង [១០.៥៩.៥៦]។ ឌុច ប្រតិចារឹក ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/434.1** ទំព័រ ៦ មុនម៉ោង [០៩.១៩.១៧]។

នឹង សួស ធី, ហ៊ុយ ស្រែ, ហ៊ឹម ហ៊ុយ, ម៉េង, ប៉េង ហើយបើនិយាយជាទូទៅ គឺ ៩៥ ភាគរយនៃកម្មាភិបាលរបស់មន្ទីរ ស-២១ គឺជាទាហានកងពលធំ ៧០៣[1416]។

១៤៨២. ក្នុងសវនាការ ឌុច បានបញ្ជាក់ថា នៅ ស-២១ កម្មាភិបាលត្រូវបានចាត់ទុកថាជាកងទ័ព។ ចាប់ពីពេលបើករហូតដល់ពេលបិទ មន្ទីរ ស-២១ គឺជាអង្គភាពកងទ័ព[1417]។

១៤៨៣. សាក្សីដែលបានមកផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរសន្តិសុខអូរកន្សែង និងភ្នំក្រោល ក៏បញ្ជាក់ដូចគ្នាដែរថា មន្ទីរសន្តិសុខទាំងពីរនេះស្ថិតក្រោមការគ្រប់គ្រងរបស់កងទ័ព[1418]។

១៤៨៤. អង្គហេតុទាំងនេះ ពុំត្រូវបានតវ៉ានោះទេ។ ដូច្នេះ អង្គជំនុំជម្រះដែលធ្លាប់បានវិនិច្ឆ័យយ៉ាងត្រឹមត្រូវថា លោក ខៀវ សំផន ពុំធ្លាប់មានការទទួលខុសត្រូវក្នុងផ្នែកកងទ័ពនោះ គឺមិនអាចឱ្យគាត់ទទួលខុសត្រូវលើការអនុវត្តគោលនយោបាយដែលត្រូវបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតឡើយ[1419]។

## ផ្នែកទី ៣. មន្ទីរសន្តិសុខក្រាំងតាចាន់ ក្រោមការគ្រប់គ្រងរបស់ស្រុក

[1416] ឌុច ប្រតិចារឹក ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/437.1** ទំព័រ ៦៤ ប្រហែលម៉ោង [១៥.៣៧.៣១], ប្រតិចារឹក ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/441.1** ទំព័រ ២៦ មុនម៉ោង [១០.៤៥.១៥]។

[1417] ឌុច ប្រតិចារឹក ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/440.1** ទំព័រ ៣១ ប្រហែលម៉ោង [១១.១០.១៦], កិច្ចសម្ភាស ឌុច ជាមួយអង្គការ UNHCR ចុះថ្ងៃទី ០៤-០៦ ខែ ឧសភា ឆ្នាំ ១៩៩៩ **ឯកសារ E3/347** ERN 0002523 (ភាសាអង់គ្លេស)។

[1418] ចំពោះ អូរកន្សែង សូមមើល ផន ផុល ប្រតិចារឹក ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/395.1** ទំព័រ ៣៤ ក្រោយម៉ោង [១១.០៥.១២], ជិន គីមធុង ប្រតិចារឹក ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/405.1** ទំព័រ ២៩ ក្រោយម៉ោង [១០.៥៣.២៨]។ ចំពោះមន្ទីរសន្តិសុខភ្នំក្រោល សូមមើល ប៊ុន ឡឹងចូយ ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/409.1** ទំព័រ ២១ មុនម៉ោង [១០.៤៣.១៧], ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/410.1** ទំព័រ ២២ ក្រោយម៉ោង [១០.៤០.១៥], សៅ សារុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/411.1** ទំព័រ ៣៧ ក្រោយម៉ោង [១១.៣២.១២]។

[1419] សាលក្រម ០០២/០១ កថាខណ្ឌ ៣៦៥។

១៤៨៥. សាក្សីជាច្រើននាក់បានពន្យល់ថា ផ្ទុយពីទីតាំងផ្សេងៗទៀតដែលត្រូវបានលើកយកមកពិនិត្យក្នុងពេលជំនុំជម្រះ មន្ទីរសន្តិសុខក្រាំងតាចាន់គឺស្ថិតក្រោមការគ្រប់គ្រងរបស់ស្រុក[1420]។ ម្យ៉ាងវិញទៀត គ្មានសាក្សីណាម្នាក់បានបញ្ជាក់ថា ព័ត៌មានទាក់ទងនឹងមន្ទីរសន្តិសុខមួយនេះ ត្រូវបានបញ្ជូនទៅថ្នាក់លើ ឬថ្នាក់តំបន់ឡើយ[1421]។

១៤៨៦. ភ័ស្តុតាងទាំងនេះបង្ហាញឱ្យឃើញថា សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងអត្ថិភាពនៃគោលនយោបាយសម្រេចដោយបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានប្រឌិតឡើង ព្រោះថាក្នុងករណីរបស់មន្ទីរសន្តិសុខក្រាំងតាចាន់ គឺវាគ្មានភ័ស្តុតាងអ្វីពាក់ព័ន្ធជាមួយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាឡើយ។ ហេតុដូច្នេះ អង្គហេតុទាំងឡាយដែលបានកើតឡើងនៅក្នុងមន្ទីរសន្តិសុខនេះ មិនអាចត្រូវបានចាត់ទុកថាជាការបង្ហាញឱ្យឃើញពីការអនុវត្តនូវគោលនយោបាយមួយនេះដែលសហចៅក្រមស៊ើបអង្កេតបានបង្កើតឡើងដោយចេតនា ដើម្បីផ្តន្ទាទោសលោក ខៀវ សំផន បានឡើយ។

### ភាគទី ៣. ការប្រព្រឹត្តលើក្រុមជាក់លាក់

### ជំពូកទី ១. ពុទ្ធសាសនិក

១៤៨៧. យោងតាមដីកាដំណោះស្រាយ និងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី លោក ខៀវ សំផន ត្រូវបានចោទប្រកាន់ចំពោះអង្គហេតុដែលបានកើតឡើងប្រឆាំងនឹងពុទ្ធសាសនិក ក្នុងសហករណ៍ត្រាំកក់ (ផ្នែកទី ១)[1422]។

---

[1420] ឧទាហរណ៍ សូមមើល ខឹម ហឿន ប្រតិចារឹក ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/297.1** ទំព័រ ៥៤ ក្រោយម៉ោង [១៥.០៧.១៨], ផាន់ ឆេន ប្រតិចារឹក ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/268.1** ទំព័រ ៥៨-៦០ មុនម៉ោង [១៤.៣៥.១៩]។

[1421] ឧទាហរណ៍ សូមមើល នាង អ៊ួច ប្រតិចារឹក ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ E1/274.1** ទំព័រ ៤៥ មុនម៉ោង [១៤.១២.៣៨] ទំព័រ ៥៩ ក្រោយម៉ោង [១៥.៣៦.២០], ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ E1/292.1** ទំព័រ ៣១-៣២ ក្រោយម៉ោង [១១.១៣.១៦]។

[1422] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២១, សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1** កថាខណ្ឌ ៣៨, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ៥។

១៤៨៨. ប៉ុន្តែ សេចក្តីសន្និដ្ឋានទាំងអស់នេះត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ដោយរំលោភលើអាណត្តិរបស់ខ្លួន (ផ្នែកទី ២)។ បន្ទាប់មក សហព្រះរាជអាជ្ញាបានកេងយកប្រយោជន៍ពីការរំលោភទាំងអស់នេះ ដែលវាកើតចេញពីកំហុសរបស់សហព្រះរាជអាជ្ញាផ្ទាល់តែម្តង (ផ្នែកទី ៣)។

១៤៨៩. ដូច្នេះ អង្គជំនុំជម្រះត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុទាំងនេះ ដោយមិនត្រឹមត្រូវ ហើយអង្គជំនុំជម្រះត្រូវសម្រេចថាខ្លួនគ្មានយុត្តាធិការជំនុំជម្រះអង្គហេតុទាំងនេះឡើយ ដោយខ្លាចធ្វើឱ្យបាត់បង់ដល់យុត្តិធម៌នៃដំណើរការនីតិវិធី (ផ្នែកទី ៤)។

## ផ្នែកទី ១. ការចោទប្រកាន់ក្នុងដីកាដំណោះស្រាយ

១៤៩០. អង្គហេតុដែលលោក ខៀវ សំផន ត្រូវរងការជំនុំជម្រះ ត្រូវបានសហចៅក្រមស៊ើបអង្កេតកំណត់ថាជាអំពើធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅត្រង់កថាខណ្ឌ ១៤២១ នៃដីកាដំណោះស្រាយ។

១៤៩១. អង្គហេតុគាំទ្រការចោទប្រកាន់នេះ គឺមានរៀបរាប់លម្អិតនៅក្នុងកថាខណ្ឌ ៣២១ នៃដីកាដំណោះស្រាយ ក្នុងផ្នែកទាក់ទងនឹងសហករណ៍ត្រាំកក់ ក្រោមចំណងជើងថា "ការប្រព្រឹត្តលើក្រុមមនុស្សជាក់លាក់"៖

> "នៅក្នុងផ្នែកខ្លះនៃស្រុកត្រាំកក់ ប.ក.ក បានហាមមិនឱ្យគោរពសាសនា និងបានផ្សឹកព្រះសង្ឃចាប់តាំងពី [...] ឆ្នាំ ១៩៧២ មក។ [ក្នុង] ខែ មេសា ឆ្នាំ ១៩៧៥ គោលនយោបាយនេះ គឺត្រូវបានបង្កើតឡើងឱ្យមាននៅទូទាំងស្រុក។ សាក្សីម្នាក់ជាអតីតព្រះសង្ឃ [នៅចាំបាន]ថា ក្រោយខែមេសា ឆ្នាំ ១៩៧៥ ព្រះសង្ឃទាំងអស់ ដែលមានកំណើតក្នុងខេត្តតាកែវ ឬ ភ្នំពេញ ត្រូវបានណែនាំឱ្យរស់នៅក្នុងវត្តអង្គរកា ក្នុងស្រុកត្រាំកក់។ ក្រោយមក កម្មាភិបាល ប.ក.ក បានមកបង្គាប់ព្រះសង្ឃទាំងអស់ឱ្យសឹក។ សាក្សីបាន [នៅចងចាំ] ពីការបំផ្លាញពុទ្ធបដិមា និងប្តូរវត្តអារាមទៅជាកន្លែងប្រជុំ មន្ទីរឃុំឃាំង រោងបាយ កន្លែងចិញ្ចឹមជ្រូក និងឃ្លាំងដាក់សម្ភារៈ។ ប្រជាពលរដ្ឋមិនត្រូវអនុញ្ញាតឱ្យអុជធូបទេ។ លោកសង្ឃដែលត្រូវបានផ្សឹក ត្រូវបានបញ្ជូនទៅធ្វើកងចល័ត ឬបង្ខំឱ្យធ្វើការងារ។ បន្ថែមពីលើនេះ សមាជិកគ្រួសារមិនត្រូវបានអនុញ្ញាតបូជាសាកសព ឬ ធ្វើពិធីបុណ្យសពឡើយ"។

## ផ្នែកទី ២. វិសាលភាពបណ្តឹងដាក់ជូនសហចៅក្រមស៊ើបអង្កេត ត្រូវបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា

១៤៩២. យោងតាមកថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទាក់ទងនឹងសហករណ៍ត្រាំកក់ គឺគ្មានការចោទប្រកាន់ណាមួយទាក់ទងនឹងជោគវាសនារបស់ពុទ្ធសាសនិកឡើយ។ យោងតាមកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទាក់ទងនឹងការប្រព្រឹត្តលើពុទ្ធសាសនិក គ្មានការចោទប្រកាន់ណាមួយទាក់ទងនឹងសហករណ៍ត្រាំកក់ឡើយ។ ការកត់សម្គាល់យ៉ាងសាមញ្ញមួយនេះគួរតែបានជួយសហចៅក្រមស៊ើបអង្កេតឱ្យឃ្លាតឆ្ងាយពីចេតនាតិចតួចក្នុងការស៊ើបអង្កេតហួសពីអ្វីដែលត្រូវបានស្នើសុំឱ្យខ្លួនពិនិត្យ។

១៤៩៣. សេចក្តីសន្និដ្ឋានពុំត្រឹមត្រូវតាមច្បាប់របស់សហចៅក្រមស៊ើបអង្កេត ផ្អែកលើមូលដ្ឋាននៃការបកស្រាយបែបលាតសន្ធឹងនៃបណ្តឹងដែលចេញមកពីកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

១៤៩៤. យោងតាមកថាខណ្ឌ ៧២ ដែលមានចំណងជើងថា "ពុទ្ធសាសនិកនៅក្នុងខេត្តកណ្តាល ក្រចេះ កំពត ស្ទឹងត្រែង និង បាត់ដំបង" សហព្រះរាជអាជ្ញាបានពិពណ៌នានូវអង្គហេតុដូចខាងក្រោម៖

> "ពុទ្ធសាសនិកត្រូវទទួលរងការរើសអើង តាមនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលតម្រូវឱ្យលុបបំបាត់សាសនាទាំងអស់ចោល។ ជាពិសេស ព្រះសង្ឃទាំងអស់ត្រូវចាប់ផ្សឹក វត្តជាច្រើនត្រូវធ្វើឱ្យខូចខាត ឬ កម្ទេចចោលតែម្តង ហើយព្រះសង្ឃជាច្រើនអង្គត្រូវបានធ្វើគត់។ នយោបាយនេះត្រូវបានអនុវត្តនៅគ្រប់វត្តទូទាំងកម្ពុជាប្រជាធិបតេយ្យ ក្នុងនេះរួមមានវត្តចំបក់ ភូមិទួលស្តី ឃុំទួលស្តី ស្រុកចន្ទ្រា ខេត្តស្វាយរៀង វត្តតាគុត ឬ វត្តម៉ៃ ភូមិជ័យតូច ឃុំ [ជ័យធំ] ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល វត្តអន្ទង់វៀន ដែលត្រូវបានគេស្គាល់ថាជាវត្តមុនី[វណ្ណារាម]អន្ទង់វៀន ភូមិអន្ទង់វៀន ឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ វត្តដំណាក់ត្រយឹង ស្រុកទូកមាស ខេត្តកំពត វត្តជ័យមង្គល ភូមិកំភុន ឃុំកំភុន ស្រុកសេសាន ខេត្តស្ទឹងត្រែង និងវត្តសំរោង ភូមិសំរោង ឃុំសំរោង ស្រុកឯកភ្នំ ខេត្តបាត់ដំបង"[1423]។

---

[1423] កថាខណ្ឌមួយនេះ ត្រូវបានចម្លងឡើងវិញដោយចេតនា ពីក្នុងឯកសារដើមជាភាសាអង់គ្លេស ដើម្បីជៀសវាងនូវរាល់ការភាន់ច្រឡំនានាជាមួយនឹងការបកប្រែជាភាសាបារាំង។ មូលហេតុគឺថា នៅត្រង់កន្លែងដែលការបកប្រែជាភាសាបារាំងនិយាយពីរ

១៤៩៥. ដូច្នេះ អង្គហេតុដែលត្រូវបានបង្ហាញនៅក្នុងកថាខណ្ឌ ៧២ ត្រូវបានចែកចេញជាព្រឹត្តិការណ៍ពីរឈុតផ្សេងគ្នា។

១៤៩៦. ឈុតទីមួយដែលលើកឡើងនៅដើមកថាខណ្ឌ ៧២ គឺការហាមឃាត់មិនឱ្យមានសាសនាចំពោះ "ពុទ្ធសាសនិក" ដែលត្រូវបានគេយល់ថា "ជាអ្នកប្រតិបត្តិព្រះពុទ្ធសាសនា" ដែលក្នុងនោះរួមមានទាំងពុទ្ធបរិស័ទ និងព្រះសង្ឃ (១)[1424]។

១៤៩៧. ឈុតទីពីរដែលមានរៀបរាប់លម្អិតរហូតដល់ចុងកថាខណ្ឌ ៧២ គឺលើកឡើងអំពីការប៉ះពាល់ដល់ "ព្រះសង្ឃពុទ្ធសាសនា" និងទីសក្ការៈបូជានានា ដែលបានកើតឡើងនៅតាមវត្តចំនួនប្រាំពីរ នៅក្នុងខេត្តចំនួនប្រាំមួយ។ គឺមានតែព្រះសង្ឃប៉ុណ្ណោះដែលពាក់ព័ន្ធនឹងព្រឹត្តការណ៍ទាំងនេះ ដោយដកចេញនូវពុទ្ធបរិស័ទ (២)។

## ១. **<u>បណ្ដឹងទាក់ទងនឹងអង្គហេតុពាក់ព័ន្ធនឹង "ពុទ្ធសាសនិក"</u>**

១៤៩៨. ការអានកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បង្ហាញឱ្យឃើញពីភាពមិនច្បាស់លាស់ ប៉ុន្តែ ខ្លឹមសារនៃកថាខណ្ឌមួយនេះ ពុំបានផ្តល់អំណាចឱ្យសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបសួរលើអង្គហេតុមួយចំនួន "ប្រឆាំងនឹងពុទ្ធសាសនិកនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ" ដូចដែលសហចៅក្រមស៊ើបអង្កេតបានចង្អុលបង្ហាញនៅក្នុងកថាខណ្ឌ ២០៦ នៃដីកាដំណោះស្រាយបានឡើយ។

១៤៩៩. ទាក់ទងនឹងអង្គហេតុទាំងអស់ដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ ៧២ ចំណងជើងនៃកថាខណ្ឌនេះនាំឱ្យគេគិតថា ការប្ដឹងនេះត្រូវបានកម្រិតត្រឹមតែអង្គហេតុដែលបានកើតឡើងនៅក្នុងខេត្តចំនួនប្រាំ ក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។ ក៏ប៉ុន្តែ ក្នុងចំណោមអង្គហេតុទាំងឡាយដែលត្រូវបានលើកឡើង

---

លើកអំពី "ពុទ្ធសាសនិក" នោះ នៅក្នុងឯកសារជាភាសាអង់គ្លេស លើកឡើងជាដំបូងពី "ពុទ្ធសាសនិក" និងបន្ទាប់មក គឺនិយាយអំពី "ព្រះសង្ឃពុទ្ធសាសនា"។

[1424] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២-ឃ។

ក្នុងកថាខណ្ឌ ៧២ នេះ មានអង្គហេតុខ្លះត្រូវបានសន្មតថាបានកើតឡើងនៅក្នុងវត្តមួយស្ថិតក្នុងខេត្តមួយផ្សេងទៀត នោះគឺខេត្តស្វាយរៀង។

១៥០០. ភាពមិនទាក់ទងគ្នានេះ ពាក់ព័ន្ធតែជាមួយអង្គហេតុដែលត្រូវបានចោទប្រកាន់ទាក់ទងនឹង"ព្រះសង្ឃពុទ្ធសាសនា" ប៉ុណ្ណោះ។ ដូច្នេះ តាមរយៈចំណងជើងកថាខណ្ឌ ៧២ គេមិនអាចនិយាយបានថា សហចៅក្រមស៊ើបអង្កេតត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុដែលបានកើតឡើងនៅក្រៅខេត្តទាំងប្រាំ សម្រាប់អង្គហេតុទាក់ទងនឹង "ពុទ្ធសាសនិក" ឡើយ ក្នុងនោះមានខេត្តកណ្តាល ក្រចេះ កំពតស្ទឹងត្រែង និងបាត់ដំបង។

១៥០១. ក៏ប៉ុន្តែ សហករណ៍ត្រាំកក់គឺស្ថិតនៅក្នុងខេត្តតាកែវ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតពុំមានសមត្ថកិច្ចស៊ើបសួរនៅក្នុងសហករណ៍ត្រាំកក់ លើអង្គហេតុដែលត្រូវបានចោទប្រកាន់ នៅដើមកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានឡើយ។

## ២. <u>បណ្តឹងទាក់ទងនឹងអង្គហេតុពាក់ព័ន្ធនឹង "ព្រះសង្ឃពុទ្ធសាសនា"</u>

១៥០២. ពាក់ព័ន្ធនឹងការប៉ះពាល់ចំពោះ"ព្រះសង្ឃពុទ្ធសាសនា" និងទីសក្ការៈបូជាវិញ សហចៅក្រមស៊ើបអង្កេតបានកេងចំណេញដោយចេតនាលើសំនួនសេចក្តីរបស់សហព្រះរាជអាជ្ញា "នយោបាយនេះត្រូវបានអនុវត្តនៅគ្រប់វត្តទូទាំងកម្ពុជាប្រជាធិបតេយ្យ ក្នុងនេះរួមមាន" ដែលត្រូវបានប្រើប្រាស់ក្នុងកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មុនពេលរៀបចំបញ្ជីវត្តចំនួនប្រាំពីរដើម្បីពន្យល់ពីពាក្យពេចន៍របស់ខ្លួនឱ្យកាន់តែច្បាស់លាស់។

១៥០៣. នៅពេលអានសំនួនសេចក្តីនេះ និងកថាខណ្ឌ ៧២ អ្វីដែលច្បាស់នោះគឺថា បណ្តឹងស្នើសុំឱ្យសហ-ចៅក្រមស៊ើបអង្កេតពិនិត្យ ពាក់ព័ន្ធតែលើអង្គហេតុកើតឡើងនៅតាមវត្តមួយចំនួនប៉ុណ្ណោះ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនអាចអះអាងនៅកថាខណ្ឌ ២០៦ ដោយគ្មានការភាន់ច្រឡំថាខ្លួនត្រូវបានប្តឹងឱ្យពិនិត្យលើអង្គហេតុ "នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ" បានឡើយ។

១៥០៤.ម្យ៉ាងវិញទៀត ទឡ្ហីករណ៍ជាច្រើន គឺជំទាស់ទៅនឹងការលើកឡើងថាមានការប្ដឹងឱ្យបើកការស៊ើបអង្កេតនៅតាមវត្តផ្សេងៗទៀត ក្រៅពីវត្តដែលមានបង្ហាញក្នុងកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

១៥០៥. ចំណុចទីមួយគឺថា នៅក្នុងកថាខណ្ឌ ៧២ សហព្រះរាជអាជ្ញាមានគោលបំណងបង្ហាញអង្គហេតុមួយចំនួនដែលបានកើតឡើងនៅតាមកន្លែងផ្សេងៗក្នុងប្រទេសកម្ពុជា ដើម្បីគាំទ្រគំនិតដែលលើកឡើងថាមានគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលមានអត្ថិភាពមុនពេលដែលអង្គហេតុទាំងអស់នោះកើតឡើង។

១៥០៦. ក្នុងន័យនេះ សហព្រះរាជអាជ្ញាបានធ្វើបទបង្ហាញមួយស្ដីពីវត្តអារាមចំនួនប្រាំពីរ ស្ថិតនៅក្នុងខេត្តចំនួនប្រាំមួយផ្សេងគ្នា។ ខេត្តទាំងប្រាំមួយដែលស្ថិតនៅក្នុងភូមិភាគប្រាំ ក្នុងចំណោមភូមិភាគទាំងប្រាំពីរដែលខ្មែរក្រហមបានបង្កើតឡើងក្រោយពេលរំដោះប្រទេស បង្ហាញឱ្យឃើញពីទ្រឹស្ដីនៃការផ្សព្វផ្សាយក្នុងកម្រិតជាតិ នូវគោលនយោបាយចោទប្រកាន់ ប្រឆាំងនឹងពុទ្ធសាសនិក[1425]។ បទបង្ហាញនេះ ក៏ជាធាតុផ្សំមួយផងដែរនៃការសន្មតជាទូទៅរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងដំណើរការរបស់កម្ពុជាប្រជាធិបតេយ្យ ដោយបទបង្ហាញនេះលើកឡើងដូច្នេះថា៖

> "បក្សកុម្មុយនីស្តកម្ពុជាមានរចនាសម្ព័ន្ធជារបៀបឋានានុក្រម ដែលជាអង្គការរដ្ឋបាលខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា មានសមត្ថភាពក្នុងការបង្កើត រៀបចំ ណែនាំ បញ្ជា និងតាមដានគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ អង្គការរដ្ឋបាលថ្នាក់ក្រោមរបស់បក្សកុម្មុយនីស្តកម្ពុជា - ភូមិភាគ តំបន់ ស្រុក និងសាខា - នឹងអនុវត្ត ព្រមទាំងរាយការណ៍ពីគោលនយោបាយទាំងនេះ នៅទូទាំងផ្ទៃប្រទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ"[1426]។

---

[1425] នៅត្រង់កថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាបានបញ្ជាក់តែអំពីខេត្តទាំងឡាយដែលជាទីតាំងនៃវត្តដែលខ្លួនបង្ហាញ។ យោងតាមកថាខណ្ឌ ៧៤៣ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានធ្វើការស៊ើបសួរនៅតាមភូមិភាគដែលខេត្តទាំងអស់នោះស្ថិតនៅ។ ដូច្នេះ ភូមិភាគនិរតី ភូមិភាគពាយ័ព្យ ភូមិភាគបូព៌ា ភូមិភាគឦសាន និងតំបន់ ៥០៥ ត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជ-អាជ្ញា។ គឺមានតែភូមិភាគឧត្តរ និងបស្ចិមតែពីរគត់ ដែលមិនត្រូវបានលើកឡើង។

[1426] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២២។

១៥០៧. ដូច្នេះ សហព្រះរាជអាជ្ញាពុំមានបំណងប្ដឹងឱ្យសហចៅក្រមស៊ើបអង្កេតពិនិត្យលើអង្គហេតុដែលបានកើតឡើងនៅគ្រប់វត្តដែលកម្ពុជាមាននោះឡើយ ប៉ុន្តែ សហព្រះរាជអាជ្ញាប្ដឹងឱ្យពិនិត្យតែលើអង្គហេតុកើតឡើងនៅតាមវត្តមួយចំនួនដែលត្រូវបានចាត់ទុកថាមានភាពជាតំណាង សម្រាប់គាំទ្រសម្អតិកម្មរបស់ខ្លួន ប៉ុណ្ណោះ។

១៥០៨. ចំណុចទីពីរគឺថា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម សហព្រះរាជអាជ្ញាបានបង្ហាញអំពីអត្ថិភាពនៃវត្តផ្សេងៗទៀតចំនួនបួនលើក តែសហព្រះរាជអាជ្ញាពុំបានលើកឡើងពីជោគវាសនារបស់ពុទ្ធសាសនិក នៅតាមទីកន្លែងទាំងអស់នេះឡើយ[1427]។ ជាពិសេសទៅទៀតនោះ ការកត់សម្គាល់មួយនេះកាន់តែអាចជឿជាក់បានថែមទៀតសម្រាប់វត្តបី ក្នុងចំណោមវត្តអារាមទាំងអស់នោះ ក្នុងនោះមានវត្តធ្លក វត្តគិរីរម្យ និង វត្តអូរត្រកួន[1428]។ វត្តអារាមទាំងអស់នោះបានប្រែក្លាយជាមន្ទីរឃុំឃាំង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយសហចៅក្រមស៊ើបអង្កេតត្រូវបានស្នើឱ្យពិនិត្យលើអង្គហេតុកើតឡើងនៅតាមទីតាំងវត្តអារាមទាំងនោះ[1429]។ សហព្រះរាជអាជ្ញាពិតជាបានកត់សម្គាល់ច្បាស់ណាស់ថា ទីកន្លែងទាំងនោះ មានព្រះសង្ឃគង់នៅ មុនពេលខ្មែរក្រហមមកដល់ ហើយថាវត្តអារាមទាំងនោះ ត្រូវបានរងការរំផ្លិចបំផ្លាញដើម្បីធ្វើជាគុក។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាពុំបានយោងទៅលើភស្តុតាងទាំងអស់នេះ ឬក៏ទៅលើ ភស្តុតាងណាមួយផ្សេងទៀត ទាក់ទងនឹងការលុបបំបាត់សាសនានៅតាមទីកន្លែងទាំងអស់នេះឡើយ[1430]។

១៥០៩. សហព្រះរាជអាជ្ញាមានសេរីភាពជ្រើសរើសអង្គហេតុទាំងឡាយដែលខ្លួនចង់ឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបសួរ។ សហព្រះរាជអាជ្ញាបានសម្រេចមិនប្ដឹងសុំឱ្យសហចៅក្រមស៊ើបអង្កេតពិនិ

---

[1427] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៥ (វត្តបារាយណ៍[ជាន់]ដែក ដែលត្រូវបានគិតថាស្ថិតនៅក្នុងខេត្តកំពង់ធំ) កថាខណ្ឌ ៦៦ (វត្តធ្លកស្ថិតក្នុងខេត្តស្វាយរៀង) និង កថាខណ្ឌ ៦៨ (វត្តគិរីរម្យស្ថិតក្នុងខេត្តបាត់ដំបង), ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ **ឯកសារ D196** កថាខណ្ឌ ៨-១២ (វត្តអូរត្រកួនស្ថិតក្នុងខេត្តកំពង់ចាម)។

[1428] ដីកាដំណោះស្រាយ កថាខណ្ឌ ៧៧៦-៧៨៣។

[1429] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៦ (វត្តធ្លក) និងកថាខណ្ឌ ៦៨ (វត្តគិរីរម្យ)។

[1430] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៦ (វត្តធ្លក) និងកថាខណ្ឌ ៦៨ (វត្តគិរីរម្យ)។

ត្យលើអង្គហេតុទាក់ទងនឹងពុទ្ធសាសនិកនៅតាមវត្តដែលបានលើកបង្ហាញពីខាងដើម ដូចដែលខ្លួនធ្លាប់បានសម្រេចមិនពិចារណាលើជោគវាសនារបស់ពុទ្ធសាសនិកនៅក្នុងសហករណ៍ត្រាំកក់។

១៥១០. ហេតុដូច្នេះ ដោយសារតែពុំបានប្ដឹងឱ្យសហចៅក្រមស៊ើបអង្កេតពិនិត្យលើជោគវាសនារបស់ពុទ្ធសាសនិកនៅតាមវត្តដទៃទៀតដែលមានបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺគេពុំអាចនិយាយថា សហព្រះរាជអាជ្ញាមានបំណងសុំឱ្យសហចៅក្រមស៊ើបអង្កេតលើអង្គហេតុដែលបានកើតឡើងនៅតាមវត្តមួយចំនួនដែលមិនត្រូវបានលើកឡើងទាល់តែសោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នោះទេ។

១៥១១. ចំណុចទីបីគឺថា សហចៅក្រមស៊ើបអង្កេតបានសម្រេចនៅក្នុងកថាខណ្ឌ ៧៤៣ នៃដីកាដំណោះស្រាយថា "ការបំផ្លិចបំផ្លាញវត្តអារាម និងការប្រើប្រាស់វត្តអារាម ក្នុងគោលបំណងផ្សេងទៀត ។ល។ បានកើតជាទូទៅនៅគ្រប់ខេត្តទាំងអស់នៃប្រទេសកម្ពុជា ក្រោមរបបកម្ពុជាប្រជាធិប- តេយ្យ"។ បន្ទាប់មក សហចៅក្រមស៊ើបអង្កេតបានកំណត់អត្តសញ្ញាណគ្រប់ភូមិភាគទាំងអស់របស់កម្ពុជាប្រជាធិបតេយ្យ ថាជាកន្លែងនៃការវាយប្រហារទាំងនេះ ហើយបានយោងទៅលើកំណត់ហេតុស្ដាប់ចម្លើយជាច្រើន នៅចុងដីកាដំណោះស្រាយ។ ទោះបីជាបានកត់សម្គាល់យ៉ាងច្បាស់លើអង្គហេតុដែលបានកើតឡើងនៅតាមទីកន្លែងដទៃទៀតដែលមិនត្រូវបានបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនានារបស់សហព្រះរាជអាជ្ញាក៏ដោយ ក៏ក្នុងកថាខណ្ឌ ១៤២១ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានកំណត់ថាជាអំពើធ្វើទុក្ខបុកម្នេញ តែចំពោះអង្គហេតុកើតឡើងនៅតាមវត្តអារាមដែលមានបង្ហាញនៅក្នុងកថាខណ្ឌ ៧២ ព្រមទាំងអង្គហេតុដែលបានប្រព្រឹត្តឡើងនៅវត្តធ្លក វត្តគិរីរម្យ និងក្នុងសហករណ៍ត្រាំកក់ ប៉ុណ្ណោះ ពោលគឺនៅគ្រប់ទីតាំងទាំងអស់ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជ- អាជ្ញា។

១៥១២. ដូច្នេះ នៅពេលកំណត់បទចោទ សហចៅក្រមស៊ើបអង្កេតបានបង្ហាញឱ្យឃើញថាខ្លួនបានដឹងពីដែនកំណត់នៃបណ្ដឹងដែលស្នើសុំឱ្យខ្លួនពិនិត្យ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតគិតខ្លួនឯងថាត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុទូទាំងប្រទេសនោះ សហចៅក្រមស៊ើបអង្កេតទំនងជានឹងកំណត់បទចោទថាជាអំពើធ្វើទុក្ខបុកម្នេញ ចំពោះអង្គហេតុផ្សេងៗទៀតដែលបានកើតឡើងនៅ

តាមទីតាំងមួយចំនួនដែលមានបង្ហាញរួចមកហើយ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយសហចៅក្រមស៊ើបអង្កេតក៏បានទទួលភ័ស្តុតាងដាក់បន្ទុករួចហើយដែរ ដូចដែលខ្លួនបាននិយាយនៅត្រង់កថាខណ្ឌ ៧៤៣។ វាជាភ័ស្តុតាងបញ្ជាក់ច្បាស់ថែមទៀតសម្រាប់អង្គហេតុដែលបានកើតឡើងនៅតាមតំបន់មួយចំនួនដែលមិនបានលើកឡើងនៅក្នុងកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ព្រោះថាអង្គហេតុទាំងនោះអាចនឹងជួយគាំទ្រការចោទប្រកាន់របស់សហព្រះរាជអាជ្ញាដែលថាមានការផ្សព្វផ្សាយកម្រិតជាតិ នូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

១៥១៣. ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតបានធ្លាក់ខ្លួនចូលក្នុងភាពមិនច្បាស់លាស់របស់សហព្រះរាជអាជ្ញា ដើម្បីស៊ើបសួរឱ្យបានច្រើនលើទីតាំងទាំងបី មានវត្តធ្លក វត្តគិរីរម្យ និងត្រាំកក់ ដែលទីតាំងទាំងអស់នេះស្ថិតក្នុងភូមិភាគមួយចំនួនដែលមានបង្ហាញក្នុងកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា[1431]។ ប៉ុន្តែ វិសាលភាពនៃអង្គហេតុដែលជាកម្មវត្ថុនៃបណ្តឹងដាក់ជូនសហចៅក្រមស៊ើបអង្កេតពិនិត្យ ទាក់ទងនឹងទីតាំងនីមួយៗក្នុងចំណោមទីតាំងទាំងបី ត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ម្យ៉ាងវិញទៀត អង្គហេតុកើតឡើងនៅវត្តគិរីរម្យ ថែមទាំងបានក្លាយជាកម្មវត្ថុនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលក្នុងដីកានោះ ជោគវាសនារបស់ពុទ្ធសាសនិកនៅតែពុំត្រូវបានលើកឡើងដដែល[1432]។

១៥១៤. វាគឺជាការបង្ហាញឱ្យឃើញឡើងវិញពីការស៊ើបសួរដាក់បន្ទុករបស់សហចៅក្រមស៊ើបអង្កេត បើទោះបីជាមានវិធាននីតិវិធីសំខាន់ៗទាំងអស់ក៏ដោយ។ សរុបរួមមក សហចៅក្រមស៊ើបអង្កេតបានព្យាយាមប្រើប្រាស់ជាអតិបរមានូវទីតាំងក្រិដ្ឋកម្មទាំងអស់ដែលខ្លួនត្រូវស៊ើបអង្កេត បើទោះបីជាបណ្តឹងស្នើសុំឱ្យខ្លួនពិនិត្យ ទាក់ទងនឹងទីតាំងនីមួយៗក្នុងចំណោមទីតាំងទាំងបី មានដែនកំណត់ត្រឹមតែអង្គហេតុដែលមានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក៏ដោយ។

១៥១៥. ក្នុងន័យនេះ ឧទាហរណ៍ចុងក្រោយមួយ អាចឱ្យគេយល់បានពីភាពព្រហើនរបស់សហចៅក្រមស៊ើបអង្កេតចំពោះបណ្តឹងស្នើឱ្យខ្លួនពិនិត្យ ទាក់ទងនឹងអង្គហេតុកើតឡើងនៅត្រាំកក់។ ក្រោយពី

---

[1431] វត្តធ្លកស្ថិតក្នុងភូមិភាគបូព៌ា។ វត្តគិរីរម្យស្ថិតក្នុងភូមិភាគពាយ័ព្យ ហើយត្រាំកក់ស្ថិតក្នុងភូមិភាគនិរតី។

[1432] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២-១៣។

បាននិយាយនៅក្នុងកថាខណ្ឌ ២០៦ នៃដីកាដំណោះស្រាយ ថាខ្លួនត្រូវបាន "ប្តឹងអំពីអំពើនានាដែលបានប្រព្រឹត្តប្រឆាំងនឹងជនជាតិចាមនៅក្នុងភូមិភាគកណ្តាល ភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ" រួចមក សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានក្នុងកថាខណ្ឌ ៣២០ ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ដែលស្ថិតនៅភូមិភាគនិរតី ថា "ជនជាតិចាម [...] បានទទួលរងការប្រព្រឹត្តដូចអ្នកដទៃទៀតដែរ" ។ លោក ខៀវ សំផន បានកត់សម្គាល់យ៉ាងយកចិត្តទុកដាក់លើសេចក្តីសន្និដ្ឋានខុសច្បាប់មួយនេះដែលវាជាលើកទីមួយ ដែលសេចក្តីសន្និដ្ឋានបែបនេះ មិនខាតប្រយោជន៍ដល់គាត់ទេ ផ្ទុយទៅវិញបម្រើប្រយោជន៍ឱ្យគាត់[1433]។

## ផ្នែកទី ៣. កំហុសនីតិវិធី

១៥១៦. នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣ ពាក់ព័ន្ធនឹងការប្រព្រឹត្តមកលើពុទ្ធសាសនិក សហព្រះរាជអាជ្ញាបានស្នើដាក់បញ្ចូលក្នុងការជំនុំជម្រះសំណុំរឿង ០០២/០២ នូវអង្គហេតុកើតឡើងក្នុងសហករណ៍ត្រាំកក់ ដោយលើកលែងទីតាំងឧក្រិដ្ឋកម្មផ្សេងទៀត។

១៥១៧. ដូច្នេះ ក្នុងពេលដំណាលគ្នានៃការស្នើសុំដាក់បញ្ចូលសហករណ៍ត្រាំកក់ ទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០២ សហព្រះរាជអាជ្ញាបានស្នើឱ្យធ្វើការសង្កេតដូច្នេះថា៖

> "ឧក្រិដ្ឋកម្មនានាដែលទាក់ទងទៅនឹងការធ្វើបាបចំពោះពុទ្ធសាសនិក [...] ក៏គួរត្រូវបានដាក់បញ្ចូល និងជំនុំជម្រះផងដែរ តាមរយៈ*សហករណ៍ត្រាំកក់* ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រឆាំងនឹងជនជាប់ចោទដែលពាក់ព័ន្ធទៅនឹងទីតាំងនោះ រួមបញ្ចូលទាំងការធ្វើទុក្ខបុកម្នេញខាងសាសនាទៅលើពុទ្ធសាសនិក [...]។ នៅពេលសហព្រះរាជអាជ្ញាមិនបានស្នើឱ្យដាក់បញ្ចូលវត្តនៅតាមតំបន់នានានៃទូទាំងប្រទេស ចូលក្នុងទីតាំងឧក្រិដ្ឋកម្ម [...] សហព្រះរាជអាជ្ញាស្នើឱ្យដាក់បញ្ចូលនូវការចោទប្រកាន់ទូទៅ នៅក្នុងដីកាដំណោះស្រាយ ទាក់ទងនឹងការធ្វើបាបចំពោះពុទ្ធសាសនិក (កថាខណ្ឌទី ៧៤០-៧៤៣) [...]។ ការណ៍នេះនឹងធានាឱ្យប្រាកដថាភស្តុតាងទូទៅអាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញឱ្យឃើញអំពីគោលនយោបាយរបស់ បកក លើបញ្ហាទាំងនេះ អំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម និងអំពីលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធនៃប្រភេទឧក្រិដ្ឋកម្ម ដើម្បីគាំទ្រ

[1433] សូមមើលផងដែរ ផ្នែកខាងក្រោម កថាខណ្ឌ ១៨៧៥។

ចំពោះបទចោទប្រកាន់នានាប្រឆាំងនឹងជនជាប់ចោទ ទាក់ទងទៅនឹង*សហករណ៍ត្រាំកក់* [...]"[1434] (សរសេរជាអក្សរទ្រេត នៅក្នុងអត្ថបទដើម)។

១៥១៨. ខណៈដែលសហព្រះរាជអាជ្ញាពុំធ្លាប់ដែលបានប្ដឹងឱ្យសហចៅក្រមស៊ើបអង្កេតពិនិត្យលើអង្គហេតុទាក់ទងនឹងពុទ្ធសាសនិកនៅត្រាំកក់ ដូច្នេះ សំណើនេះមានគោលដៅតែមួយគត់គឺដើម្បីផ្ដល់ភាពត្រឹមត្រូវដល់អំពើដែលសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តហួសហេតុលើសពីបណ្ដឹងដែលខ្លួនបានទទួល ។

១៥១៩. ម្យ៉ាងវិញទៀត គេពិតជាមិនអាចយល់បានដែលថាសហព្រះរាជអាជ្ញាបានស្នើសុំឱ្យដាក់បញ្ចូលក្នុងការជំនុំជម្រះសំណុំរឿង ០០២/០២ នូវអង្គហេតុមួយចំនួនដែលខ្លួនមិនធ្លាប់ដែលបានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ផ្ទុយពីបទចោទប្រកាន់ទាំងអស់ដែលសហព្រះរាជអាជ្ញាខ្លួនឯងបានធ្វើទាក់ទងនឹងអង្គហេតុកើតឡើងនៅគ្រប់ទីតាំងទាំងអស់ក្នុងកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

១៥២០. សហព្រះរាជអាជ្ញាទំនងជាច្រឡំរវាងកាលានុវត្តភាពនៃការចោទប្រកាន់ និងកាលានុវត្តនិយម។ លោក ខៀវ សំផន ពុំមែនជាអ្នកដែលត្រូវរ៉ាប់រងអំពើលាមករបស់សហព្រះរាជអាជ្ញានោះទេ។

## ផ្នែកទី ៤. អង្គជំនុំជម្រះគ្មានយុត្តាធិការជំនុំជម្រះ

១៥២១. យោងតាមការរៀបរាប់ទាំងអស់ពីខាងដើមរួចមក អង្គជំនុំជម្រះត្រូវកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតបានឃ្លាតចេញហួសពីបណ្ដឹងស្នើសុំឱ្យខ្លួនពិនិត្យ និងកត់សម្គាល់អំពីកំហុសសហព្រះ-រាជអាជ្ញា ហើយអង្គជំនុំជម្រះត្រូវសម្រេចថាខ្លួនគ្មានយុត្តាធិការជំនុំជម្រះលើអង្គហេតុទាក់ទងនឹងជោគវាសនាពុទ្ធសាសនិកនៅត្រាំកក់នោះទេ។ រាល់សេចក្ដីសម្រេចផ្សេងពីនេះ អាចបង្កជាផលវិបាកបំផ្លាញដល់យុត្តិធម៌នៃដំណើរនីតិវិធីចំពោះលោក ខៀវ សំផន។

[1434] សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣ **ឯកសារ E301/2** កថាខណ្ឌ ១៤។

## ជំពូកទី ២. ការចោទប្រកាន់ស្ដីពីគោលនយោបាយពាក់ព័ន្ធនឹងវិធានការដាក់លាក់ប្រឆាំងនឹងពុទ្ធសាសនិក

១៥២២. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងពុទ្ធសាសនិក ដែលត្រូវបានសន្មតថាបានប្រព្រឹត្តឡើងដោយអនុវត្តតាមគោលនយោបាយ "វិធានការផ្សេងៗដែលបានធ្វើឡើងប្រឆាំងនឹងក្រុមជាក់លាក់នានា" ដោយក្នុងនោះ "ពុទ្ធសានិក" ត្រូវបានចាត់ទុកថាជាផ្នែកមួយក្នុងចំណោមក្រុមជាក់លាក់ទាំងនោះ[1435]។

១៥២៣. ដូចដែលបានឃើញពីខាងដើមរួចមកហើយថា ការចោទប្រកាន់នានាមកលើរូបលោក ខៀវ សំផន ទាក់ទងនឹងពុទ្ធសាសនិក គឺផ្អែកលើសេចក្ដីសន្និដ្ឋានដែលសហចៅក្រមស៊ើបអង្កេតបានធ្វើឡើងដោយរំលោភលើបណ្ដឹងដាក់ជូនខ្លួន[1436]។ ផ្ទុយពីអ្វីដែលសហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់នៅត្រង់កថាខណ្ឌ ២០៦ នៃដីកាដំណោះស្រាយ នោះគឺថាសហចៅក្រមស៊ើបអង្កេតពុំដែលត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុ "ប្រឆាំងនឹងពុទ្ធសាសនិក នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ" ឡើយ គឺសហចៅក្រមស៊ើបអង្កេតត្រូវពិនិត្យតែលើអង្គហេតុដែលត្រូវបានកំណត់ក្នុងផ្នែកមួយចំនួនក្នុងប្រទេសកម្ពុជា ស្របតាមខ្លឹមសារកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ប៉ុណ្ណោះ។

១៥២៤. ក៏ប៉ុន្តែ ពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋានទាំងអស់របស់សហចៅក្រមស៊ើបអង្កេត មានសេចក្ដីសន្និដ្ឋានមួយចំនួនទាក់ទងនឹងស្រុកត្រាំកក់ ដែលជាតំបន់មួយដែលសហចៅក្រមស៊ើបអង្កេតពុំធ្លាប់ដែលបានទទួលភារកិច្ចឱ្យស៊ើបសួរលើជោគវាសនារបស់ពុទ្ធសាសនិកឡើយ។ ទោះបីជាសេចក្ដីសន្និដ្ឋានទាំងនេះមិនស្របតាមច្បាប់ក៏ដោយ ក៏វាជាសេចក្ដីសន្និដ្ឋានតែមួយគត់ដែលសហព្រះរាជអាជ្ញាស្នើឱ្យមានការពិនិត្យ ក្នុងអំឡុងពេលជំនុំជម្រះសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះដែល

[1435] ដីកាដំណោះស្រាយ កថាខណ្ឌ ២០៥-២០៧ និង ២១០, សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1** កថាខណ្ឌ ៣៨, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ១-២។

[1436] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១៤៨៧-១៥១៥។

តែងតែមានចិត្តប្រណីមេត្តាចំពោះសហព្រះរាជអាជ្ញា បានឯកភាពតាមសំណើ ដោយបានកម្រិតការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងពុទ្ធសាសនិកត្រឹមតែក្នុងស្រុកត្រាំកក់។

១៥២៥. ដោយសារអនីត្យានុកូលភាពនៃដំណើរការនីតិវិធីនេះ ដែលវានឹងនាំឱ្យទៅជាការកាយកប់យុត្តិធម៌នៃដំណើរការនីតិវិធី អង្គជំនុំជម្រះត្រូវតែបដិសេធដាច់ខាតក្នុងការជំនុំជម្រះលើអង្គហេតុទាំងឡាយដែលគាំទ្រដល់ការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងពុទ្ធសាសនិកនៅត្រាំកក់។

១៥២៦. ដោយសារតែលោក ខៀវ សំផន ពុំមានភាពចាំបាច់ក្នុងការឆ្លើយតបចំពោះអង្គហេតុទាំងឡាយដែលអង្គជំនុំជម្រះពុំត្រូវបានប្តឹងឱ្យជំនុំជម្រះដោយត្រឹមត្រូវនោះ ដូច្នេះវាពុំចាំបាច់ក្នុងការធ្វើសេចក្តីអត្ថាធិប្បាយទាក់ទងនឹងការអនុវត្តដោយបក្សកុម្មុយនីស្តកម្ពុជា នូវគោលនយោបាយបែបសន្ធតដែលបានលើកឡើង ក្នុងគោលបំណងផ្តន្ទាទោសលោក ខៀវ សំផន ឡើយ ព្រោះថាគោលនយោបាយនេះ គឺជាការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។

## ជំពូកទី ៣. ជនជាតិចាម

### ផ្នែកទី ១. ការចោទប្រកាន់

១៥២៧. ពាក់ព័ន្ធនឹងការប្រព្រឹត្តលើសមាជិកក្រុមជនជាតិចាម លោក ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក្រោមទម្រង់ជាអំពើមនុស្សឃាត និងពីបទឧក្រិដ្ឋកម្មមនុស្សឃាត ការសម្លាប់រង្គាល ការចាប់ឃុំឃាំង អំពើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ដែលទាំងអស់នេះស្ថិតក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1437]។

---

[1437] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៣៦-១៣៤២, ១៣៧៣, ១៣៨១, ១៤០២, ១៤០៨, ១៤២០, សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1** កថាខណ្ឌ ៣១ និង ៤៣, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ៣-៧។

## ១. វិសាលភាពនៃការចោទប្រកាន់ យោងតាមដីកាដំណោះស្រាយ

## ក. បទប្រល័យពូជសាសន៍ដោយអំពើមនុស្សឃាត

១៥២៨. ដូចដែលធ្លាប់បានចង្អុលបង្ហាញខាងលើជាច្រើនដងរួចមកហើយថា ការតាក់តែងដីកាដំណោះស្រាយ មានការខ្វះខាតជារឿយៗនូវភាពច្បាស់លាស់ ទាក់ទងនឹងវិសាលភាពនៃការចោទប្រកាន់។ ករណីនេះកើតមានចំពោះបទចោទប្រកាន់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយអំពើមនុស្សឃាត (១)។ ដូច្នេះ វាមានភាពចាំបាច់ក្នុងការត្រលប់ទៅមើលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ដែលជាអ្នកកំណត់អំពីវិសាលភាពនៃបណ្តឹងស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតពិនិត្យ ដើម្បីអាចកំណត់ឱ្យបានច្បាស់នូវអង្គហេតុទាំងឡាយដែលត្រូវបានរាប់បញ្ចូលក្នុងការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ក្រោមទម្រង់ជាអំពើមនុស្សឃាត (២)។

### 1. ការចោទប្រកាន់ក្នុងដីកាដំណោះស្រាយ

១៥២៩. ពាក់ព័ន្ធនឹងធាតុផ្សំនៃបទល្មើស គេអាចអានកថាខណ្ឌ ១៣៣៦ នៃដីកាដំណោះស្រាយ ដែលមានន័យសេចក្តីដូច្នេះថា៖

> "ចំពោះធាតុផ្សំសត្យានុម័តិ បុគ្គលដែលជាសមាជិកនៃក្រុមជនជាតិចាម (ជាក្រុមជនជាតិភាគតិច និងសាសនាជាក់លាក់មួយដែលកំណត់ខ្លួនឯងថាជាក្រុមនេះ និងត្រូវបានកំណត់អត្តសញ្ញាណថាជាក្រុមនេះផងដែរដោយប្រជាជនផ្សេងទៀតនៅក្នុងសង្គម) ត្រូវបានសម្លាប់តាមវិធីសាស្ត្រមួយ" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

១៥៣០. កថាខណ្ឌ ១៣៣៨ ទាក់ទងនឹងធាតុផ្សំអត្តនោម័តិ មានន័យសេចក្តីដូចខាងក្រោម៖

> "ចំពោះធាតុអត្តនោម័តិ ចារីមានចេតនាបំផ្លាញទាំងស្រុង ឬ មួយផ្នែកនូវក្រុមជនជាតិចាម ដោយសារពួកគេជាក្រុមហ្នឹងតែម្តង។ ការសម្លាប់ត្រូវបានធ្វើឡើងនៅក្នុងបរិបទមួយដោយមានការប្រកាសជាសាធារណៈដែលរៀបរាប់ពីគោលដៅនៃការបំផ្លិចបំផ្លាញខាងរូបកាយទៅលើក្រុម៖ ជនជាតិចាមត្រូវបានគេកំណត់មុខសញ្ញា និងសម្លាប់ជាលក្ខណៈប្រព័ន្ធ និងដោយមានវិធីសាស្ត្រជាក់លាក់ ដោយសារសមាជិកភាពរបស់ខ្លួននៅក្នុងក្រុមជនជាតិចាម ខណៈដែលអ្នកដែលមិនមែន

ជាជនជាតិចាម ត្រូវបានគេដកចេញយ៉ាងច្បាស់ និងជាពិសេសពីការវាយប្រហារទាំងនេះ” (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

១៥៣១. ក្នុងផ្នែកទាក់ទងនឹងការកំណត់បទចោទលើអង្គហេតុអំពើប្រល័យពូជសាសន៍ ក្រោមទម្រង់ជាអំពើមនុស្សឃាត សហចៅក្រមស៊ើបអង្កេតគ្មានភាពច្បាស់លាស់ថាខ្លួនផ្អែកលើមូលដ្ឋានអង្គហេតុណាមួយឱ្យច្បាស់លាស់ បើនិយាយពីលក្ខណៈភូមិសាស្ត្រ និងពេលវេលា។

## 1.ក. **<u>វិសាលភាពភូមិសាស្ត្រ</u>**

១៥៣២. កថាខណ្ឌ ១៣៤០ នៃដីកាដំណោះស្រាយ បញ្ជាក់យ៉ាងដូច្នេះថា៖

“លក្ខណៈជាប្រព័ន្ធ ទំហំ វិធីសាស្ត្រប្រតិបត្តិការ និងសមកាលកម្មនៃការសម្លាប់ដែលធ្វើចំពោះក្រុមជនជាតិចាមនៅក្នុងភូមិភាគបូព៌ា និងភូមិភាគកណ្តាល (ឧត្តរចាស់) គឺជាធាតុផ្សំដែលចង្អុលបង្ហាញយ៉ាងច្បាស់ថា អំពើប្រល័យពូជសាសន៍ត្រូវបានសម្រេច និងសម្របសម្រួលដោយមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងក្របខណ្ឌនៃផែនការរួម។ ការណ៍ដែលថាការសម្លាប់ត្រូវបានធ្វើឡើងមិនត្រឹមតែនៅក្នុងភូមិភាគកណ្តាល (ឧត្តរចាស់) និងបូព៌ា ប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានធ្វើនៅតាមភូមិភាគផ្សេងៗទៀតក្នុងពេលជាមួយគ្នា បង្ហាញឱ្យឃើញថា នេះមិនមែនជាអំពើល្មើសដែលបានប្រព្រឹត្តឡើងដោយគ្មានការអនុញ្ញាត និងតាមបែបមិនទៀងដោយកម្មាភិបាលមូលដ្ឋាននោះទេ ប៉ុន្តែផ្ទុយមកវិញ អំពើល្មើសទាំងនេះត្រូវបានរៀបចំឡើងដោយមេដឹកនាំបក្ស”។

១៥៣៣. ដូច្នេះ មួយផ្នែកគឺមានអំពើមនុស្សឃាតជាលក្ខណៈទ្រង់ទ្រាយធំ ប្រព្រឹត្តឡើងនៅក្នុងភូមិភាគបូព៌ា និងភូមិភាគកណ្តាល ហើយមួយផ្នែកទៀត គឺមានការកាប់សម្លាប់ “នៅតាមភូមិភាគជាច្រើន”។ ទោះបីជាមិនត្រូវបានកំណត់ឱ្យបានច្បាស់ក៏ដោយ ក៏ភូមិភាគច្រើនទាំងអស់នោះ មិនអាចក្តោបបញ្ចូលនូវទឹកដីដែលមិនត្រូវបានបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនានារបស់សហព្រះរាជអាជ្ញា បានឡើយ។

## 1.ខ. **<u>វិសាលភាពពេលវេលា</u>**

១៥៣៤. ក្នុងផ្នែកស្តីពីការកំណត់ប្រភេទអង្គហេតុ នៅត្រង់កថាខណ្ឌ ២១២ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា គោលនយោបាយកម្ទេចក្រុមជនជាតិចាម ត្រូវបានបង្កើតឡើងក្រោយឆ្នាំ ១៩៧៧ ហើយបានរីករាលដាលចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៨។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតបានកំណត់ពេលវេលាកើតមានចេតនាប្រល័យពូជសាសន៍ ដែលជាធាតុផ្សំឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ថាបានកើតមានចាប់តាំងពីឆ្នាំ ១៩៧៧ មក។

១៥៣៥. ជាថ្មីម្តងទៀត ត្រង់ចំណុចនេះ មានការបង្ហាញពីការសម្លាប់ជនជាតិចាមជាលក្ខណៈទ្រង់ទ្រាយធំ ដែលទំនងជាបានកើតឡើងនៅក្នុងភូមិភាគកណ្តាល និងភូមិភាពបូព៌ា ដោយពុំបានបញ្ជាក់ពីទីកន្លែងឱ្យបានជាក់លាក់។ ដូច្នេះ វាចាំបាច់ត្រូវត្រលប់ទៅមើលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទាំងអស់របស់អយ្យការ ដើម្បីសម្រេចថាតើទីតាំងមួយណាដែលជាកម្មវត្ថុនៃការស៊ើបអង្កេត។

## 2. <u>**បណ្តឹងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទាំងអស់របស់សហព្រះរាជអាជ្ញា**</u>

១៥៣៦. សហព្រះរាជអាជ្ញាបានបើកការស៊ើបអង្កេតប្រឆាំងនឹងលោក ខៀវ សំផន លើអង្គហេតុដែលត្រូវបានពិពណ៌នានៅក្នុងកថាខណ្ឌ ៤០-៤១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការជម្លៀសប្រជាជនចាមចាប់ពីចុងឆ្នាំ ១៩៧៥ ជាពិសេស ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម និងឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល ឆ្ពោះទៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ។ នៅក្នុងកថាខណ្ឌ ១២២ សហព្រះរាជអាជ្ញាបានកំណត់បទចោទចំពោះអង្គហេតុទាំងអស់នេះថាជាអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃការជម្លៀស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងអំពើប្រល័យពូជសាសន៍ ដោយពុំបានបញ្ជាក់ថាជាអំពើប្រល័យពូជសាសន៍ក្រោមទម្រង់ជាអំពើមនុស្សឃាតឡើយ។

១៥៣៧. ពីរឆ្នាំក្រោយ សហព្រះរាជអាជ្ញាបានធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលនិយាយជាពិសេសពីអង្គហេតុទាក់ទងនឹងអំពើប្រល័យពូជសាសន៍ជនជាតិចាម[1438]។ នៅក្នុងកថាខណ្ឌ ៧ មានការបង្ហាញថា “នៅឆ្នាំ ១៩៧៧ និង ១៩៧៨ ការធ្វើទុក្ខបុកម្នេញជាទូទៅរបស់ ប.ក.ក ទៅលើ

[1438] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩**ឯកសារ D196**។

ប្រជាជនចាម បានក្លាយទៅជាអំពើប្រល័យពូជសាសន៍”។ អំពើទាំងនេះ ហាក់ដូចជាបានកើតឡើង នៅក្នុងស្រុកកងមាស (ភូមិភាគកណ្ដាល) និងក្រូចឆ្មារ (ភូមិភាគបូព៌ា) និងនៅក្នុងតំបន់ ៥ (ភូមិភាគពាយ័ព្យ) ហើយសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តបណ្ដឹងដែលស្នើសុំឱ្យខ្លួនពិនិត្យ តែទៅលើទាំងបីទីតាំងនេះប៉ុណ្ណោះ។

១៥៣៨. អង្គហេតុទាំងឡាយដែលត្រូវបានកំណត់ថាជាអំពើមនុស្សឃាត និងជាធាតុផ្សំនៃបទប្រល័យពូជសាសន៍ ត្រូវបានកំណត់ត្រឹមអង្គហេតុទាំងឡាយដែលបានកើតឡើងនៅក្នុងស្រុកកងមាស (ភូមិភាគកណ្ដាល) និង នៅក្នុងស្រុកក្រូចឆ្មារ (ភូមិភាគបូព៌ា)។

១៥៣៩. ហេតុដូច្នេះ អង្គជំនុំជម្រះត្រូវបានស្នើសុំឱ្យពិនិត្យតែលើអង្គហេតុដែលជាធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ ក្រោមទម្រង់ជាអំពើមនុស្សឃាត ប្រព្រឹត្តមកលើសមាជិកក្រុមជនជាតិចាម ចាប់ពីឆ្នាំ ១៩៧៧ នៅក្នុងស្រុកកងមាស (ភូមិភាគកណ្ដាល) និងស្រុកក្រូចឆ្មារ (ភូមិភាគបូព៌ា) ដោយដកចេញនូវអង្គហេតុដែលបានប្រព្រឹត្តឡើងនៅក្នុងមន្ទីរសន្តិសុខក្រូចឆ្មារ ដែលត្រូវបានអង្គជំនុំជម្រះដកចេញយ៉ាងច្បាស់ តាមរយៈសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី។

## ខ. អំពើមនុស្សឃាត

### 1. វិសាលភាពភូមិសាស្ត្រ

១៥៤០. នៅត្រង់កថាខណ្ឌ ១៣៧៨ នៃដីកាដំណោះស្រាយ មានការបញ្ជាក់ថា អំពើមនុស្សឃាតត្រូវបានប្រព្រឹត្តឡើង “ក្នុងក្របខណ្ឌនៃការធ្វើបាបទៅលើជនជាតិចាម” នៅតាមមន្ទីរសន្តិសុខក្រូចឆ្មារ និងមន្ទីរសន្តិសុខវត្តអូរត្រកួន។ ក៏ប៉ុន្តែ នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះបានដកមន្ទីរសន្តិសុខក្រូចឆ្មារចេញយ៉ាងច្បាស់ពីក្នុងវិសាលភាពនៃសំណុំរឿង០០២/០២។ ដូច្នេះ លោក ខៀវ សំផន ត្រូវបានចោទប្រកាន់តែចំពោះអង្គហេតុអំពើមនុស្សឃាតដែលបានកើតឡើងនៅក្នុងមន្ទីរសន្តិសុខអូរត្រកួន ប៉ុណ្ណោះ។

១៥៤១. ហេតុដូច្នេះ អង្គជំនុំជម្រះត្រូវបានប្ដឹងឱ្យជំនុំជម្រះតែលើអង្គហេតុជាធាតុផ្សំនៃអំពើមនុស្សឃាត ក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាប់ពីឆ្នាំ ១៩៧៧ និងនៅតែក្នុងមន្ទីរសន្តិសុខវត្តអូរត្រកួន ប៉ុណ្ណោះ។

2. **ទំហំពេលវេលា**

១៥៤២. យោងតាមដីកាដំណោះស្រាយ អំពើមនុស្សឃាតលើជនជាតិចាម ក្នុងនាមជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានរីករាលដាលជាទូទៅចាប់ពីឆ្នាំ ១៩៧៧ ដូចដែលត្រូវបានពិពណ៌នាសម្រាប់ការកំណត់បទចោទអំពើប្រល័យពូជសាសន៍។

**គ. ការសម្លាប់រង្គាល**

១៥៤៣. នៅត្រង់កថាខណ្ឌ ១៣៨៦ នៃដីកាដំណោះស្រាយ មានការបញ្ជាក់ដូច្នេះថា៖

> "ទាក់ទងដល់ការប្រព្រឹត្តលើក្រុម [...] **ជនជាតិចាម** ចាប់ផ្ដើមតាំងពីដើមឆ្នាំ ១៩៧៧ ការសម្លាប់សមាជិកនៃក្រុមមនុស្សទាំងនេះ បានវិវត្តឈានដល់ទ្រង់ទ្រាយធំ និងជាសមូហភាព ដែលបង្កជាការសម្លាប់រង្គាល។ សម្រាប់ជនជាតិចាម ការសម្លាប់រង្គាលបានកើតឡើងជាពិសេសនៅមន្ទីរសន្តិសុខភូមិទ្រា ក្នុងភូមិភាគបូព៌ា និងមន្ទីរសន្តិសុខវត្តអូរត្រកួន ក្នុងភូមិភាគកណ្ដាល (ឧត្តរចាស់)" (យើងជាអ្នកដាក់អក្សរដិត)។

១៥៤៤. ម្យ៉ាងវិញទៀត នៅត្រង់កថាខណ្ឌ ២១២ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានរក្សាទុកក្នុងផ្នែកកត់សម្គាល់អំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួមថា "ការសម្លាប់ [...] ជាលក្ខណៈទ្រង់ទ្រាយធំ ត្រូវបានប្រព្រឹត្តនាឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ នៅក្នុងភូមិភាគកណ្ដាល [...] និងភូមិភាគបូព៌ា"។

១៥៤៥. ដូចដែលបានលើកឡើងខាងលើ ក្នុងផ្នែកទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ក្រោមទម្រង់ជាអំពើមនុស្សឃាត សហចៅក្រមស៊ើបអង្កេតបានកម្រិតខ្លួនឯងត្រឹមអង្គហេតុកើតឡើងនៅក្នុងស្រុកកងមាស (ភូមិភាគកណ្ដាល) និងស្រុកក្រូចឆ្មារ (ភូមិភាគបូព៌ា)។

១៥៤៦. ដូច្នេះ អង្គជំនុំជម្រះត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុជាធាតុផ្សំនៃអំពើសម្លាប់រង្គាលជនជាតិចាម ចាប់ពីដើមឆ្នាំ ១៩៧៧ ជាពិសេស នៅមន្ទីរសន្តិសុខភូមិទ្រា ក្នុងភូមិភាគបូព៌ា និងនៅក្នុងមន្ទីរសន្តិសុខវត្តអូរត្រកួន ក្នុងភូមិភាគកណ្តាល តែអង្គហេតុទាំងនោះកម្រិតត្រឹមស្រុកកងមាស និងស្រុកក្រូចឆ្មារ ប៉ុណ្ណោះ។

## ឃ. ការដាក់ក្នុងមន្ទីរឃុំឃាំង

១៥៤៧. ក្នុងកថាខណ្ឌ ១៤០២ នៃដីកាដំណោះស្រាយ លោក ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋដាក់មនុស្សក្នុងមន្ទីរឃុំឃាំង ក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "ក្នុងក្របខ័ណ្ឌនៃការធ្វើបាបជនជាតិចាម" ដោយគ្មានការបញ្ជាក់ណាមួយទាក់ទងនឹងការពិតនៃអង្គហេតុដែលត្រូវបានជ្រើសរើស ឬក៏ការចង្អុលបង្ហាញពេលវេលាច្បាស់លាស់ណាមួយ នោះឡើយ។

១៥៤៨. គេត្រូវកត់សម្គាល់ថា នៅក្នុងកថាខណ្ឌ ១៣៣៧ នៃដីកាដំណោះស្រាយ ដែលនិយាយអំពីអំពើប្រល័យពូជសាសន៍លើជនជាតិចាម មានការបញ្ជាក់ដូច្នេះថា៖

> "ជនរងគ្រោះត្រូវបានគេកំណត់ជាមុខសញ្ញាដោយសារសមាជិកភាពរបស់ខ្លួននៅក្នុងក្រុមជនជាតិចាម៖ ជាទូទៅ ជនរងគ្រោះមិនត្រូវបាន<u>ឃុំឃាំង</u> ឬ <u>សួរចម្លើយ</u>ដើម្បីទទួលបានចម្លើយសារភាពឡើយ ប៉ុន្តែ ផ្ទុយទៅវិញ ពួកគេត្រូវបានសម្លាប់ភ្លាមៗ និងជាញឹកញាប់ គឺក្រោយពេលដែលពួកគេត្រូវបានសួរដើម្បីបញ្ជាក់ថា ពួកគេជាជនជាតិចាម" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

១៥៤៩. ភាពមិនច្បាស់លាស់នៃអង្គហេតុដែលត្រូវបានជ្រើសរើស ដើម្បីគាំទ្រដល់ការកំណត់បទចោទថាជាបទឧក្រិដ្ឋចាប់មនុស្សឃុំឃាំង តម្រូវឱ្យគេត្រលប់ទៅមើលការកត់សម្គាល់អំពីអង្គហេតុនៃឧក្រិដ្ឋកម្មឡើងវិញ។

១៥៥០. នៅកថាខណ្ឌ ៧៥២ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា "មុនឆ្នាំ ១៩៧៥ ចាមមួយចំនួនត្រូវបានគេចាប់ឃុំខ្លួន ធ្វើទារុណកម្ម និង សម្លាប់"។ សម្រាប់អង្គហេតុដែលបានកើតឡើងក្រោយឆ្នាំ ១៩៧៥ ពោលគឺជាពេលវេលាស្ថិតក្នុងដែនយុត្តាធិការពេលវេលារបស់តុលាការនេះ ការដាក់ក្នុងមន្ទីរឃុំឃាំង គឺពាក់ព័ន្ធនឹងមន្ទីរសន្តិសុខទាំងបីដែលស្ថិតនៅក្នុងភូមិភាគ

កណ្ដាល និងភូមិភាគបូព៌ា ក្នុងនោះមានមន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខវត្តអូរត្រកួន និងមន្ទីរសន្តិសុខភូមិទ្រា។

១៥៥១. ក៏ប៉ុន្តែ ម្យ៉ាង មន្ទីរសន្តិសុខក្រាំងតាចាន់ ត្រូវបានអង្គជំនុំជម្រះដកចេញពីក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ហើយម្យ៉ាងទៀត ផ្នែកស្ដីពីមន្ទីរសន្តិសុខវត្តអូរត្រកួន ពុំមានបង្ហាញពីអង្គហេតុណាមួយទាក់ទិននឹងការឃុំខ្លួនជនជាតិចាមនោះទេ។ ប្រសិនបើគេអានតាមអ្វីដែលសហចៅក្រមស៊ើបអង្កេត បានសន្និដ្ឋាននៅក្នុងកថាខណ្ឌ ៧៨៣ នៃដីកាដំណោះស្រាយ៖

> "នៅពេលចាប់ខ្លួន ជនជាតិចាមទំនងជាមិនត្រូវបានយក<u>ទៅដាក់ឃុំទេ</u> គឺសម្លាប់ភ្លាមៗតែម្ដង។ សាក្សីដដែលនេះរៀបរាប់ថា នៅក្នុងវត្តអូរត្រកួន មិនមានគុកសម្រាប់ដាក់អ្នកទោសទេ ពេលយកអ្នកទោសមកដល់ "*គេសម្លាប់ចោលនៅពេលយប់នោះទាំងអស់*" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

១៥៥២. ហេតុដូច្នេះ លោក ខៀវ សំផន ត្រូវបានចោទប្រកាន់តែលើអង្គហេតុនៃការដាក់ឃុំឃាំងជនជាតិចាមនៅក្នុងមន្ទីរសន្តិសុខទ្រា ប៉ុណ្ណោះ។

## ខ. <u>ការធ្វើទារុណកម្ម</u>

១៥៥៣. នៅត្រង់កថាខណ្ឌ ១៤០៨ នៃដីកាដំណោះស្រាយ លោក ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មធ្វើទារុណកម្ម ក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះការធ្វើបាបទៅលើជនជាតិចាម។

១៥៥៤. ដោយសារពុំមានការបញ្ជាក់ទាក់ទងនឹងអង្គហេតុដែលត្រូវបានជ្រើសរើសយកធ្វើជាមូលដ្ឋាននៃការចោទប្រកាន់តាមផ្លូវច្បាប់នេះ គេត្រូវយោងឡើងវិញទៅលើផ្នែកស្ដីពីការកត់សម្គាល់អង្គហេតុនៃឧក្រិដ្ឋកម្ម។

១៥៥៥. នៅត្រង់កថាខណ្ឌ ១៤០៩ នៃដីកាដំណោះស្រាយ មានការបញ្ជាក់ថា៖

"ចំពោះធាតុផ្សំសត្យានុម័តិ បុគ្គលិកមន្ទីរសន្តិសុខបានបង្កដោយចេតនាឱ្យមានទុក្ខវេទនា និងការឈឺចាប់ធ្ងន់ធ្ងរ ទាំងខាងផ្លូវកាយ និងផ្លូវចិត្ត ក្នុងអំឡុងពេលសួរចម្លើយ ជាច្រើនលើកច្រើនសាតាមរយៈអំពើសកម្ម និងអកម្មរបស់ខ្លួន" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

១៥៥៦. ដូច្នេះ ការធ្វើទារុណកម្មដែលបានលើកឡើងនេះ គឺទាក់ទងនឹងការសួរចម្លើយ ក្នុងក្របខ័ណ្ឌនៃការឃុំឃាំង។

១៥៥៧. នៅត្រង់កថាខណ្ឌ ៧៥២ នៃដីកាដំណោះស្រាយ មានការបង្ហាញពីអង្គហេតុកើតឡើង "មុនឆ្នាំ ១៩៧៥" ដែលក្នុងពេលនោះ "ចាមមួយចំនួនត្រូវបានគេចាប់ឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។ ក៏ប៉ុន្តែ គឺមានតែអង្គហេតុកើតឡើងក្រោយឆ្នាំ១៩៧៥ ប៉ុណ្ណោះ ដែលស្ថិតក្នុងដែនយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ហើយត្រូវបានសម្រេចយកសម្រាប់បទឧក្រិដ្ឋធ្វើទារុណកម្ម "ក្នុងអំឡុងពេលសួរចម្លើយ"។ ដូច្នេះ គឺមានតែអំពើទារុណកម្មកើតឡើងនៅតាមមន្ទីរសន្តិសុខដែលត្រូវបានបង្ហាញនៅក្នុងផ្នែកនៃការប្រព្រឹត្តលើជនជាតិចាម ពោលគឺនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខវត្តអូរត្រកួន និងមន្ទីរសន្តិសុខទ្រា ប៉ុណ្ណោះ ដែលអាចត្រូវយកមកពិចារណាបាន។

១៥៥៨. ក៏ប៉ុន្តែ ដូចដែលបានរំឭកពីខាងដើមរួចមកហើយថា ទាក់ទងនឹងបទឧក្រិដ្ឋឃុំឃាំងមនុស្ស សហចៅក្រមស៊ើបអង្កេតពុំបានសន្និដ្ឋានថាមានអំពើទារុណកម្មនៅមន្ទីរសន្តិសុខវត្តអូរត្រកួន នោះទេ ហើយមន្ទីរសន្តិសុខក្រាំងតាចាន់ ត្រូវបានដកចេញពីក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។

១៥៥៩. ហេតុដូច្នេះ លោក ខៀវ សំផន ត្រូវបានចោទប្រកាន់តែអំពីអង្គហេតុទាំងឡាយដែលកើតឡើងនៅមន្ទីរសន្តិសុខទ្រា ប៉ុណ្ណោះ។

### ច. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា

១៥៦០. នៅក្នុងកថាខណ្ឌ ១៤២០ មានការបញ្ជាក់ដូច្នេះថា៖

"ធាតុផ្សំនៃឧក្រិដ្ឋកម្មការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាទៅលើពួកចាម ត្រូវបានបង្ហាញ (សូមពិនិត្យមើល "ការប្រព្រឹត្តមកលើពួកចាម" "ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគកណ្តាល/ឧត្តរចាស់ភូមិភាគនិរតី ភូមិភាគបូព៌ា និងភូមិភាគបស្ចឹម" និង "ការដ្ឋានទំនប់ ១ មករា") [...]។ ការលុបបំបាត់ចោលនូវវប្បធម៌ ប្រពៃណី និងភាសារបស់ជនជាតិចាម កើតមានឡើងនៅថ្នាក់ ជាតិ។ ប.ក.ក បានហាមឃាត់ជនជាតិចាមប្រតិបត្តិសាសនាអ៊ីស្លាម ហាមរឹបអូសយក និងដុតចោលគម្ពីរក្ញរ៉អាន បិទទ្វារ និងបំផ្លាញវិហារ ហើយជនជាតិចាមត្រូវបានគេបង្ខំឱ្យហូបសាច់ ជ្រូក។ មេសាសនា និងនិស្សិតសាសនា ត្រូវបានចាប់ខ្លួន និងសម្លាប់។ ស្ត្រីជនជាតិចាម ត្រូវបានបង្ខំឱ្យកាត់សក់ និងហាមមិនឱ្យរុំក្បាល។ សហគមន៍ជនជាតិចាម ត្រូវបានបំបែក ផ្លាស់ទីលំនៅដោយបង្ខំនៅទូទាំងប្រទេស និងត្រូវបានបំបែកឱ្យទៅរស់នៅក្នុងសហគមន៍នានា"។

១៥៦១. គេត្រូវបញ្ជាក់ថា ដីកាដំណោះស្រាយបានយោងទៅលើអង្គហេតុទាំងឡាយដែលត្រូវបានបង្ហាញក្នុងផ្នែក "ការប្រព្រឹត្តលើជនជាតិចាម" "ការផ្លាស់ទីលំនៅដំណាក់កាលទី២" និង "ការដ្ឋានការងារទំនប់ ១ មករា"។ ក្នុងក្របខ័ណ្ឌនៃការពិនិត្យភ័ស្តុតាង អង្គហេតុទាំងអស់នេះ នឹងត្រូវលើកយកមកពិភាក្សាដេញដោលនាពេលនេះតែប៉ុណ្ណោះ ក្រោមទិដ្ឋភាពនៃការប្រព្រឹត្តទៅលើក្រុមជនជាតិចាម។ ដូចដែលបានឃើញពីខាងលើរួចមកហើយថា បើគិតតាមអនីត្យានុកូលភាពនៃបណ្តឹងដាក់ជូនខ្លួនឱ្យពិនិត្យ អង្គជំនុំជម្រះគ្មានយុត្តាធិការដើម្បីជំនុំជម្រះលើអង្គហេតុទាក់ទងនឹងការប្រព្រឹត្តលើជនជាតិចាមនៅទំបន់ ១ មករា នោះឡើយ[1439]។

១៥៦២. អង្គហេតុជាធាតុផ្សំនៃបទចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាទៅលើជនជាតិចាម ត្រូវបានបង្ហាញនៅក្នុងកថាខណ្ឌ ១៤២០ នៃដីកាដំណោះស្រាយ ហើយអង្គហេតុទាំងនោះ លើកឡើងពីសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យជាទូទៅ។ ដូច្នេះ អង្គហេតុទាំងនេះនឹងត្រូវពិនិត្យក្នុងរយៈពេលចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។

[1439] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១០៦៩-១០៧០។

២. **វិសាលភាពនៃការចោទប្រកាន់ពីបទផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី ២ ក្រោយពីមានសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី**

១៥៦៣. បើទោះជានៅក្នុងឧបសម្ព័ន្ធដែលកំណត់អំពីវិសាលភាពនៃសំណុំរឿង ០០២/០២ មានការបង្ហាញពីឧក្រិដ្ឋកម្មសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងអំពើអមនុស្សធម៌ដទៃទៀត (ក្រោមរូបភាពជាអំពើធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ) ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងដែលទំនងជាបានកើតឡើងក្នុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី ២ ក៏ដោយ ក៏អង្គជំនុំជម្រះមិនត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុទាំងអស់នេះឡើយ។

១៥៦៤. ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅជនជាតិចាម អង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដូច្នេះថា៖

> "ដោយឡែក អង្គជំនុំជម្រះកត់សម្គាល់ថា ការផ្លាស់ទីលំនៅជនជាតិភាគតិចចាម បង្កើតជាមូលដ្ឋាននៃការចោទប្រកាន់ស្តីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា រួមទាំងជាមធ្យោបាយមួយនៃការអនុវត្តគោលនយោបាយដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) និងការប្រព្រឹត្តចំពោះក្រុមដែលក្លាយជាគោលដៅ។ អង្គជំនុំជម្រះបានដកនូវអង្គហេតុនៃការចោទប្រកាន់ទាំងនោះចេញ ដោយផ្អែកលើគោលនយោបាយដែលពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិចាម រួមទាំងអង្គហេតុស្តីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា ចេញពីវិសាលភាពនៃសំណុំរឿង ០០២/០១"។ ទោះជាយ៉ាងណាក្តី ការប្រព្រឹត្តចំពោះជនជាតិចាម និងអង្គហេតុស្តីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា រួមទាំងក្នុងដំណើរការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ត្រូវបានបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[1440]។

១៥៦៥. ដូច្នេះ តាមរយៈកថាខណ្ឌមួយនេះ វាស្តែងឱ្យឃើញច្បាស់ថា អង្គជំនុំជម្រះបានចាត់ទុកការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) ថាស្ថិតនៅក្នុងបទឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា តែមួយគត់។

---

[1440] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1** កថាខណ្ឌ ៤៣។

១៥៦៦. ម្យ៉ាងវិញទៀត គឺនៅក្នុងន័យនេះហើយដែលឧបសម្ព័ន្ធនៃសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលបានកំណត់វិសាលភាពសំណុំរឿង ០០២/០២ បានធ្វើការបញ្ជាក់ត្រង់ចំណុចទី ៣ ស្តីពីអង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដូច្នេះថា៖ "ការផ្លាស់ទីលំនៅប្រជាជន ១) ដំណាក់កាលទី២ (កថាខណ្ឌ ២៦៦, ២៦៨, ២៨១) (កម្រិតត្រឹមតែការប្រព្រឹត្តលើជនជាតិចាម)" ។

១៥៦៧. ការចោទប្រកាន់ផ្សេងៗទៀត (ជាពិសេស ការចោទប្រកាន់ក្នុងកថាខណ្ឌ ២៦៩) ពុំស្ថិតនៅក្នុងចំណោមនោះឡើយ។ អង្គហេតុដែលជាមូលដ្ឋាននៃការកំណត់បទចោទប្រកាន់សម្លាប់រង្គាល ក្នុងកថាខណ្ឌ ១៣៨៧ នៃដីកាដំណោះស្រាយ ពុំមានទាក់ទងទៅនឹងការប្រព្រឹត្តជាក់លាក់ណាមួយលើជនជាតិចាម ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ឡើយ ហើយអង្គហេតុទាំងនេះ ធ្លាប់ត្រូវបានពិនិត្យរួចមកហើយក្នុងពេលជំនុំជម្រះសំណុំរឿង ០០២/០១។ ហេតុដូច្នេះ តាមលក្ខណៈសមហេតុសមផល អង្គហេតុទាំងនេះត្រូវបានដកចេញពីយុត្តាធិការរបស់អង្គជំនុំជម្រះសម្រាប់សំណុំរឿង ០០២/០២។

១៥៦៨. យោងតាមកថាខណ្ឌ ២៦៨ នៃដីកាដំណោះស្រាយ ដែលពិនិត្យជាពិសេសលើការផ្លាស់ទីលំនៅប្រជាជនចាម គឺថា"មេដឹកនាំសាសនា [...] ត្រូវបានចាប់ខ្លួន និងសម្លាប់<u>មុនពេល</u>ការផ្លាស់ទីលំនៅរបស់ប្រជាជនបានចាប់ផ្តើម" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។ ដូច្នេះ អង្គហេតុទាំងនេះ មិនត្រូវបានដាក់បញ្ចូលក្នុងក្របខ័ណ្ឌនៃការផ្លាស់ទីលំនៅប្រជាជនចាម ឡើយ។

១៥៦៩. ហេតុដូច្នេះ អនុលោមតាមសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដែលត្រូវបានយោងពីខាងដើម អង្គជំនុំជម្រះត្រូវបានស្នើឱ្យពិនិត្យលើអង្គហេតុនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ សម្រាប់តែឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាប្រឆាំងជនជាតិចាម ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ ប៉ុណ្ណោះ។

### ផ្នែកទី ២. <u>ភស្តុតាងដែលត្រូវបានបង្ហាញ</u>

១៥៧០. ក្នុងចំណោមភ័ស្តុតាងទាំងអស់ដែលត្រូវបានបង្ហាញក្នុងសវនាការ (១) គឺមានភ័ស្តុតាងជាច្រើនមិនពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ (២)។ ភ័ស្តុតាងផ្សេងទៀត ធ្វើឱ្យគេយល់ថា អាចមានធាតុផ្សំសម្រាប់ឧក្រិដ្ឋកម្មមួយចំនួន (៣)។

## ១. បញ្ជីភ័ស្តុតាង

១៥៧១. ក្នុងចន្លោះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ដល់ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ សាក្សី ១៤ នាក់ អ្នកជំនាញ ១ នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី ៣ នាក់ បានមកផ្តល់សក្ខីកម្មទាក់ទងនឹងវគ្គស្តីពីការប្រព្រឹត្តលើជនជាតិចាម។ ដើមបណ្តឹងរដ្ឋប្បវេណី ២ នាក់ផ្សេងទៀត បានផ្តល់សក្ខីកម្មទាក់ទងនឹងផលវិបាកនៃឧក្រិដ្ឋកម្ម។

១៥៧២. ក្នុងចំណោមអ្នកទាំងអស់នោះ មាន ៣ នាក់ ពុំធ្លាប់ដែលបានស្តាប់ចម្លើយដោយអ្នកស៊ើបអង្កេតក្នុងអំឡុងពេលស៊ើបសួរសំណុំរឿង ០០២ ឡើយ (មុយ វ៉ាន់នី, 2-TCW-894 និង សយ ឌឿន)។

១៥៧៣. ម្យ៉ាងវិញទៀត ចម្លើយជាច្រើនក្នុងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានដាក់បញ្ចូល ក្នុងអំឡុងពេលនៃការជំនុំជម្រះបច្ចុប្បន្ន។ ក្រុមមេធាវីការពារក្តីតែងតែរំឮកឥតឈប់ឈរពីចរិតលក្ខណៈមិនត្រឹមត្រូវ និងធ្វើឱ្យប៉ះពាល់ដល់សិទ្ធលោក ខៀវ សំផន ដោយសារតែការដាក់បញ្ចូលនូវភ័ស្តុតាងជាច្រើនសន្ធឹកសន្ធាប់ជាកំណត់ហេតុស្តាប់ចម្លើយ បានមកពីការស៊ើបអង្កេតដែលលោក ខៀវ សំផន ពុំមែនជាភាគីនៅក្នុងនោះ។

១៥៧៤. ពាក់ព័ន្ធនឹងបញ្ហាជនជាតិចាម ការយល់ព្រមតាមសំណើយ៉ាងច្រើនរបស់អយ្យការសុំឱ្យដាក់បញ្ចូលភ័ស្តុតាងបន្ថែម បានឈានទៅដល់ការទទួលយកចម្លើយចំនួន ៣២ ទាក់ទងនឹងការប្រព្រឹត្តលើជនជាតិចាម។ គេត្រូវរំឮកប្រាប់អង្គជំនុំជម្រះថា ដោយសារពុំមានការកោះហៅឱ្យមកផ្តល់សក្ខីកម្ម ដូច្នេះតម្លៃជាភ័ស្តុតាងនៃចម្លើយទាំងនេះ មានតិចតួចបំផុត។ ដូច្នេះ អង្គជំនុំជម្រះត្រូវតែពិចារណាលើចំណុចមួយនេះ ក្នុងក្របខ័ណ្ឌនៃការធ្វើសេចក្តីសម្រេចរបស់ខ្លួន។

## ២. ភ័ស្តុតាងស្តីពីកងចលនាឈ្មោះទៅទីតាំងនៅក្រៅទីលានរៀង

១៥៧៥. ភ័ស្តុតាងជាច្រើនទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី៣ គឺពុំមានភាពពាក់ព័ន្ធជាមួយនឹងបណ្តឹងដាក់ជូនអង្គជំនុំជម្រះពិនិត្យ។

១៥៧៦. សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីខ្លះដែលបានមកផ្តល់សក្ខីកម្ម បានបង្ហាញពីការបំបែកអ្នកភូមិនៅក្នុងឃុំក្រូចឆ្មារ និងនៅក្នុងឃុំប៊ឹស ក្រោយពីការមកដល់របស់អ្នកភូមិភាគកណ្តាល ឬ អ្នកភូមិភាគនិរតី ក្នុងឆ្នាំ ១៩៧៨[1441]។

១៥៧៧. វ៉ាន់ ម៉ាត់ ជាសាក្សីជនជាតិចាម មកពីភូមិជំនីក ឃុំជំនីក ស្រុកក្រូចឆ្មារ បានធ្វើការពិពណ៌នាពីការប្រឈមមុខដាក់គ្នារវាងភូមិភាគកណ្តាល និងភូមិភាគបូព៌ា ដែលជាប្រភពដើមនៃការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា និងការជម្លៀសប្រជាជននាពេលក្រោយមកទៀត[1442]។ វ៉ាន់ ម៉ាត់ ថ្លែងថាគាត់ស្ថិតក្នុងចំណោមប្រជាជនដែលត្រូវបានជម្លៀសលើកចុងក្រោយនេះ ហើយក្នុងការជម្លៀសនោះ ក៏មានប្រជាជនខ្មែរផងដែរ[1443]។

១៥៧៨. ជី ថន ជាជនជាតិខ្មែរ ហើយក៏ជាប្រជាជនជម្លៀសម្នាក់ដែរ បានបញ្ជាក់ប្រាប់អ្នកស៊ើបអង្កេតថាវាពិតជាចាំបាច់ក្នុងការជម្លៀសប្រជាជន ដោយសារតែមានការប្រយុទ្ធគ្នារវាងភូមិភាគឧត្តរ និងភូមិភាគបូព៌ា[1444]។

---

1441 អ៊ុត សេន ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/343.1** ទំព័រ ៥២ ក្រោយម៉ោង [១៣.៥៨.១៥] (គឺនៅពេលទឹកស្រក ក្នុងឆ្នាំ ១៩៧៨), ម៉ាត់ ស ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/375.1** ទំព័រ ៤៨ មុនម៉ោង [១៣.៤០.០៧], នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/350.1** ទំព័រ ៤៥ ប្រហែលម៉ោង [១៤.១២.៤៥], ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/351.1** ទំព័រ ១៥ ប្រហែលម៉ោង [០៩.៤៨.៣៨]។

1442 វ៉ាន់ ម៉ាត់ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/398.1** ទំព័រ ១៧ ក្រោយម៉ោង [១០.០១.២២]។

1443 វ៉ាន់ ម៉ាត់ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/398.1** ទំព័រ ១៤ ប្រហែលម៉ោង [០៩.៥២.៤៨] ទំព័រ ២៧ ប្រហែលម៉ោង [១០.៥៣.៤០] ទំព័រ ៣០ មុនម៉ោង [១១.០១.២១]។

1444 កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ **ឯកសារ E3/5253** ERN 00235002។ ជី ថន ជាអ្នកដាំបាយនៅមន្ទីរពាណិជ្ជកម្មស្រុក ត្រូវបានយោងសម្តីនៅក្នុងដីកាដំណោះស្រាយ ដោយសហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី៣ ក្នុងកំណត់សម្គាល់ជើងទំព័រ ១១៤៥, ១១៤៩ និង ១២២៣។

១៥៧៩. បាន សៀក ជាប្រធានស្រុកក្រូចឆ្មារ នៅឆ្នាំ ១៩៧៨ ក៏បានលើកឡើងដូចគ្នាពីការផ្លាស់ទីលំនៅអ្នកភូមិក្នុងស្រុកនេះ ទៅកាន់ស្រុកចំការលើ ក្នុងភូមិភាគកណ្តាល ប្រហែលជានៅពេលជិតដាច់របបខ្មែរក្រហម ព្រោះថា "ផែនការទ័ពគេជម្លៀសដែរ ដោយថាគ្រប់គ្រងមិនបាន"[1445]។

១៥៨០. សូវ ញឹត មកពីភូមិ៤ ឃុំស្វាយឃ្លាំង បានពន្យល់ប្រាប់អ្នកស៊ើបអង្កេតថា នៅឆ្នាំ ១៩៧៨ ជនជាតិចាមត្រូវបានផ្លាស់ទីលំនៅទៅស្រុកក្រូចឆ្មារ ហើយថាជនជាតិខ្មែរក៏"ត្រូវបានបង្ខំឱ្យចេញពីភូមិដូចគ្នា"។ នៅទីបញ្ចប់ កម្មាភិបាលមូលដ្ឋានបានជម្លៀសប្រជាជនចេញអស់[1446]។

១៥៨១. សុះ វំលី ក៏បានលើកឡើងដូចគ្នាពីការជម្លៀសប្រជាជនចាមទៅកាន់សាលាស្រុកនៅទ្រា ក្រោយការមកដល់របស់កម្មាភិបាលភូមិភាគកណ្តាល ដោយគាត់ប្រាប់អ្នកស៊ើបអង្កេតថា ព្រឹត្តិការណ៍នេះបានកើតឡើងនៅចុងខែ តុលា ឆ្នាំ ១៩៧៨[1447]។

១៥៨២. យោងតាមផែនទីសម័យខ្មែរក្រហមដែលមាននៅក្នុងសំណុំរឿង និងផែនទីប្រទេសកម្ពុជានាពេលបច្ចុប្បន្ន បង្ហាញឱ្យឃើញថាចំណុចប្រសព្វគ្នារវាងស្រុកក្រូចឆ្មារ និងស្រុកស្ទឹងត្រង់ ស្ថិតនៅជិតភូមិទ្រា ក្នុងទិសដៅឆ្ពោះទៅព្រែកអាជី[1448]។ ដូច្នេះ ដើម្បីទៅស្ទឹងត្រង់ គេត្រូវធ្វើដំណើរតាមផ្លូវទឹកពីទ្រា។

១៥៨៣. ភស្តុតាងទាំងអស់នេះស្តែងឱ្យឃើញច្បាស់ថា ការជម្លៀសប្រជាជននៅឆ្នាំ ១៩៧៨ ក្នុងអំឡុងពេលស្ថានការណ៍ច្របូកច្របល់ និងជាពេលដែលមានជម្លោះផ្ទៃក្នុង និងការប្រយុទ្ធគ្នាខ្លាំងក្លាជាមួយនឹង

---

[1445] បាន សៀក ប្រតិចារឹក ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ **ឯកសារ E1/353.1** ទំព័រ ៥៩ ក្រោយម៉ោង [១៥.១៦.១៣], ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ **ឯកសារ E1/354.1** ទំព័រ ៥១ ក្រោយម៉ោង [១៤.២២.១១]។

[1446] កំណត់ហេតុស្តាប់ចម្លើយ សូវ ញឹត ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨ **ឯកសារ E3/5208** ERN 00218545។

[1447] សុះ វំលី ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/372.1** ទំព័រ ៩-១០ ចន្លោះម៉ោង [០៩.២៨.១១] និង [០៩.៣៣.៥០], កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៨ **ឯកសារ E3/5196** ERN 00204457។

[1448] ឧបសម្ព័ន្ធ ខ ផែនទីផ្លូវកំពង់ចាម **ឯកសារ E3/8033** ERN 00371266, ឧបសម្ព័ន្ធ គ ប្លង់ភូមិទ្រា **ឯកសារ E3/8037** ERN 00367316; https://www.google.com.kh/maps/place/Stueng+Trang+District/@12.2511169,105.5365725,15z.។

វៀតណាម គឺពាក់ព័ន្ធជាមួយប្រជាជនគ្រប់គ្នា ដោយគ្មានការរើសអើង[1449]។ ជាពិសេសទៅទៀត នោះ អង្គហេតុទាំងនេះពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី៣ ដូចមានពិពណ៌នា នៅក្នុងកថាខណ្ឌ ១៦៦ និងកថាខណ្ឌ ២៨៣-២៩៨ នៃដីកាដំណោះស្រាយ ហើយការផ្លាស់ទីលំនៅ ប្រជាជន ដំណាក់កាលទី៣ នេះ ត្រូវបានដកចេញពីក្នុងវិសាលភាពសំណុំរឿង០០២/០២ តាមរយៈ សេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ[1450]។ ដូច្នេះ លោក ខៀវ សំផន ពុំ ចាំបាច់ឆ្លើយតបចំពោះការចោទប្រកាន់មួយនេះឡើយ។

## ៣. ភ័ស្តុតាងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដាក់ក្នុងមន្ទីរឃុំឃាំង

១៥៨៤. ភ័ស្តុតាងមួយផ្នែកដែលត្រូវបានបង្ហាញ អាចឱ្យគេគិតថាធាតុផ្សំនៃឧក្រិដ្ឋកម្មដាក់ក្នុងមន្ទីរឃុំឃាំង ដូចដែលបានចោទប្រកាន់នៅក្នុងកថាខណ្ឌ ១៤០២ នៃដីកាដំណោះស្រាយ អាចត្រូវបានបំពេញ។

## ផ្នែកទី ៣. ការពិនិត្យលើភ័ស្តុតាងពាក់ព័ន្ធ

១៥៨៥. មុននឹងយកចិត្តទុកដាក់ពិនិត្យលើភ័ស្តុតាងទាក់ទងនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់ (២) គេ ត្រូវធ្វើការកត់សម្គាល់បឋមខ្លះៗលើភ័ស្តុតាងដែលត្រូវបានបង្ហាញ ទាក់ទងនឹងការប្រព្រឹត្តលើជន ជាតិចាម ហើយដែលភ័ស្តុតាងទាំងនេះមានសារៈសំខាន់ខ្លាំងណាស់លើរបៀបដែលអង្គជំនុំជម្រះ ត្រូវពិនិត្យលើវា (១)។

## ១. ការកត់សម្គាល់បឋម

១៥៨៦. ចំណុចគួរឱ្យកត់សម្គាល់ក្នុងដំណើរការពិនិត្យភ័ស្តុតាង ក្នុងអំឡុងពេលនៃការជំនុំជម្រះនេះ គឺថា ស្ទើរតែគ្មានឯកសារសម័យកម្ពុជាប្រជាធិបតេយ្យណាមួយនៅក្នុងសំណុំរឿង ដែលនិយាយលើក ឡើងពីជនជាតិចាមនោះទេ។ មេធាវីការពារក្ដីយល់ឃើញថា ជាការពិតណាស់ វាបង្ហាញឱ្យឃើញ

[1449] នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ** E1/350.1 ទំព័រ ៤២ ក្រោយម៉ោង [១៣.៥៦.៥០]។

[1450] សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ** E301/9/1។

ច្បាស់ថាពុំមានគោលនយោបាយជាក់លាក់ចំពោះជនជាតិចាមនោះទេ ដូចដែលអ្វីដែលនឹងត្រូវលើកយកមកពិភាក្សានៅផ្នែកខាងក្រោយបន្តិចទៀត[1451]។

១៥៨៧. អវត្តមាននៃស្ទើរតែទាំងស្រុងនូវឯកសារសម័យខ្មែរក្រហម នាំឱ្យសហចៅក្រមស៊ើបអង្កេតផ្អែកជាសំខាន់លើមូលដ្ឋានភ័ស្តុតាងជាចម្លើយ ដែលភាគច្រើនបានមកពីកិច្ចសម្ភាសធ្វើឡើងដោយលោក អ៊ីសា ឧស្មាន។ ក៏ប៉ុន្តែ ភាពអគតិរបស់លោក អ៊ីសា ឧស្មាន គឺជាគុណវិបត្តិធំសម្បើម នៅក្នុងការប្រមូលភ័ស្តុតាង និងការពិនិត្យនៅពេលបន្ទាប់មកទៀត (ក) ដោយមិនទាន់គិតដល់បញ្ហានៃភាពជឿជាក់បាន ដែលបណ្តាលមកពីការដាក់កំណត់ហេតុស្តាប់ចម្លើយយ៉ាងច្រើនសន្ធឹកសន្ធាប់ ធ្វើជាភ័ស្តុតាង ក្នុងពេលស៊ើបអង្កេតសំណុំរឿង ០០២ (ខ) ។

## ក. ការខ្វះលម្អៀងរបស់លោក អ៊ីសា ឧស្មាន

១៥៨៨. អង្គជំនុំជម្រះបានកោះហៅលោក អ៊ីសា ឧស្មាន ឱ្យមកផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ នៅចំពោះមុខអង្គជំនុំជម្រះ។ ក្នុងរយៈពេលជិតបួនថ្ងៃនៃការផ្តល់សក្ខីកម្ម ចម្លើយរបស់គាត់បានត្រឹមតែជួយគាំទ្រចំពោះការជំទាស់របស់ក្រុមមេធាវីការពារក្តី ទាក់ទងនឹងរូបគាត់ ដូចបានលើកឡើងនៅក្នុងការជំទាស់របស់ក្រុមមេធាវីការពារក្តី ទៅនឹងការកោះហៅបុគ្គលមួយចំនួនសម្រាប់សំណុំរឿង ០០២/០២[1452]។ ឋានៈជាជនរងគ្រោះ (ក) និងកង្វះនូវគុណវុឌ្ឍិត្រឹមត្រូវ ក្នុងនាមជាអ្នកជំនាញ (ខ) បានជះឥទ្ធិពលលើសេចក្តីសន្និដ្ឋាន និងការងាររបស់គាត់ជាទូទៅ (គ)។

### 1. "អ្នកជំនាញ" ជាជនរងគ្រោះផង និងជាអ្នកស៊ើបអង្កេតផង

១៥៨៩. លោក អ៊ីសា ឧស្មាន ជាជនជាតិចាម ដែលបានណែនាំខ្លួនឯងជាច្រើនលើកច្រើនសាថា គាត់ជាជនរងគ្រោះរបបខ្មែរក្រហម ហើយម្យ៉ាងទៀត គាត់បានបង្ហាញពីដំណើរការស្រាវជ្រាវរបស់ខ្លួនថា

[1451] សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ១៨៤០-១៨៧៧។

[1452] សេចក្តីជំទាស់របស់លោក ខៀវ សំផន ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E305/9** កថាខណ្ឌ ៤១-៤២។

ដោយសារតែគាត់មានចំណាប់អារម្មណ៍ ក្នុងនាមគាត់ជាជាតិសាសន៍ចាម[1453]។ ដំណើរការយ៉ាងសកម្មនេះ គឺជាប្រភពនៃវិធីដែលគាត់ដឹកនាំធ្វើកិច្ចសម្ភាស ជាមួយនឹងការលំបាកក្នុងការពិនិត្យលើកិច្ចសម្ភាសទាំងអស់នោះ ប្រកបដោយស្មារតីវិភាគពិចារណា។ នៅពេលសួរតទល់នឹងចម្លើយមិនច្បាស់លាស់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ លោក អ៊ីសា ឧស្មាន បានបង្ខំចិត្តទទួលស្គាល់ថា "ជនរងគ្រោះចង់ទទួលបានយុត្តិធម៌ ហើយពេលខ្លះ ពួកគាត់អាចរៀបរាប់នូវរឿងរ៉ាវដែលមិនប្រាកដថាត្រឹមត្រូវទាំងស្រុងទៅនឹងអ្វីដែលបានកើតឡើងជាក់ស្តែង"[1454]។

១៥៩០. ម្យ៉ាងវិញទៀត ដោយសារតែលោក អ៊ីសា ឧស្មាន បានបញ្ជាក់ប្រាប់តុលាការថា នៅក្នុងកិច្ចសម្ភាសទាំងនោះ គាត់បានកត់ត្រា "តែអ្វីដែលអ្នកត្រូវបានសម្ភាសនិយាយប្រាប់គាត់" ប៉ុណ្ណោះ ដូច្នេះ វាចោទឡើងយ៉ាងច្បាស់ និងដោយបន្ទាន់នូវបញ្ហារបស់រឿងរ៉ាវ និងកិច្ចសម្ភាសដែលបានមកពីការងារស្រាវជ្រាវរបស់គាត់ ដែលភាគីទាំងអស់ពុំមានលទ្ធភាពធ្វើការល្បងលើភាពជឿទុកចិត្តបាន នៅក្នុងសវនាការ[1455]។

១៥៩១. ដំណើរការក្នុងនាមជាសមាគម និងជាសកម្មជនរបស់លោក អ៊ីសា ឧស្មាន បានចោទជាបញ្ហានៅក្នុងក្របខ័ណ្ឌសំណុំរឿង ០០២/០២ ព្រោះថាមិនមែនមានតែការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះទេ ដែលផ្អែកជាពិសេសលើការងារស្រាវជ្រាវរបស់គាត់ ដើម្បីតាមស្វែងរកសាក្សី ប៉ុន្តែ លោក អ៊ីសា ឧស្មាន ក៏ជាអ្នកវិភាគតែម្នាក់គត់ដែលមានវត្តមាននៅគ្រប់ពេលជួបសម្ភាសជាមួយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជនជាតិចាម ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត[1456]។

---

[1453] ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/388.1** ទំព័រ ១០ មុនម៉ោង [០៩.៣២.៤៧] "ខ្ញុំត្រូវតែធ្វើការស្រាវជ្រាវ ដើម្បីបង្ហាញការពិតថាហេតុអីបានជារបបនោះមានការ<u>កាប់សម្លាប់ជនជាតិរបស់ខ្ញុំ</u>" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

[1454] <u>អ៊ីសា ឧស្មាន</u> ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/408.1** ទំព័រ ៩ ប្រហែលម៉ោង [០៩.៣១.២៨]។

[1455] <u>អ៊ីសា ឧស្មាន</u> ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/408.1** ទំព័រ ៩ ប្រហែលម៉ោង [០៩.៣១.២៨]។

[1456] ឧទាហរណ៍ សូមមើល <u>2-TCW-938</u> កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ **ឯកសារ E3/9496,** កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៤ **ឯកសារ E3/9499,** កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៣ **ឯកសារ E3/9522,** កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៣ **ឯកសារ E3/9525,** កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៣ **ឯកសារ E3/9539,** <u>2-TCW-894</u> កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ **ឯកសារ E3/9500,** កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ**

១៥៩២. សាក្សីជនជាតិចាមស្ទើរតែគ្រប់គ្នាដែលត្រូវបានស្តាប់ចម្លើយដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ធ្លាប់ត្រូវបានសម្ភាសដោយលោក អ៊ីសា ឧស្មាន ក្នុងក្របខ័ណ្ឌនៃការសរសេរសៀវភៅទាំងពីរក្បាលរបស់គាត់។ ជារឿយៗ ការស្តាប់ចម្លើយសាក្សីទាំងនោះ គឺគ្រាន់តែចង់ឱ្យពួកគាត់បញ្ជាក់ពីភាពត្រឹមត្រូវនៃផ្នែកមួយចំនួននៃកិច្ចសម្ភាស។ គេក៏ត្រូវកត់សម្គាល់ផងដែរថា បើទោះជាគ្មានការបញ្ជាក់ពីវត្តមានរបស់លោក អ៊ីសា ឧស្មាន នៅក្នុងកំណត់ហេតុស្តាប់ចម្លើយក៏ដោយ ក៏ខ្សែអាត់សំឡេងភាគច្រើន បានបង្ហាញឱ្យឃើញពីអន្តរាគមន៍របស់គាត់ ក្នុងអំឡុងពេលសម្ភាសរបស់អ្នកស៊ើបអង្កេត ហើយប្រសិនបើគ្មានអន្តរាគមន៍របស់គាត់ទេ យ៉ាងហោចណាស់ក៏មានវត្តមានគាត់ដែរ[1457]។

១៥៩៣. ក៏ប៉ុន្តែ បុរេវិនិច្ឆ័យរបស់លោក អ៊ីសា ឧស្មាន ពិតជាមានប្រាកដដោយមិនអាចប្រកែកបាន។ ឆ្លើយទៅនឹងសំណួររបស់ក្រុមមេធាវីការពារក្តី ទាក់ទងនឹងចម្លើយរបស់អតីតកម្មាភិបាលមួយចំនួនដែល

---

**E3/9507**, <u>នោ សាទ៖</u> កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៨ **ឯកសារ E3/5193**, <u>ម៉ាត់ ស</u> កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៨ **ឯកសារ E3/5194**។ តាំងពីក្នុងពេលស៊ើបអង្កេតមក មេធាវីការពារក្តីបានលើកឡើងពីបញ្ហានានាទាក់ទងនឹងតួនាទីរបស់ អ៊ីសា ឧស្មាន។ សូមមើល សំណើលោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១០ **ឯកសារ D361**។

[1457] ឧទាហរណ៍ សូម<u>មើល</u> <u>ស្មុះ មីន</u> កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៨ **ឯកសារ E3/5210** (ខ្សែអាត់សំឡេង **ឯកសារ D125/105R**), <u>អ៊ីត សេន</u> កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៨ **ឯកសារ E3/5195** (ខ្សែអាត់សំឡេង **ឯកសារ D125/78R**), <u>ស្មុះ កំរ៉ី</u> កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៨ **ឯកសារ E3/5216** (ខ្សែអាត់សំឡេង **ឯកសារ D125/126R**), <u>ហ៊ីម ម៉ាន</u> កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៨ **ឯកសារ E3/5203** (ខ្សែអាត់សំឡេង **ឯកសារ D125/97R**), <u>វ៉ាន់ ម៉ាត់ [nom à vérifier]</u> កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៨ **ឯកសារ E3/5209** (ខ្សែអាត់សំឡេង **ឯកសារ D125/104R**), កំណត់ហេតុស្តាប់ចម្លើយ <u>ឯល សំ</u> ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ **ឯកសារ E3/5192** (ខ្សែអាត់សំឡេង **ឯកសារ D125/73R**), កំណត់ហេតុស្តាប់ចម្លើយ <u>ស្មាន អាត</u> ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨ **ឯកសារ E3/5204** (ខ្សែអាត់សំឡេង **ឯកសារ D125/99R**), កំណត់ហេតុស្តាប់ចម្លើយ <u>រៀស ទូត</u> ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ **ឯកសារ E3/7766** (ខ្សែអាត់សំឡេង **ឯកសារ D166/160R**), កំណត់ហេតុស្តាប់ចម្លើយ <u>ម៉ាន សឺន</u> ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ **ឯកសារ E3/5205** (ខ្សែអាត់សំឡេង **ឯកសារ D125/100R**), កំណត់ហេតុស្តាប់ចម្លើយ <u>តេះ ស្រ៊ិន</u> ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ **ឯកសារ E3/5206** (ខ្សែអាត់សំឡេង **ឯកសារ D125/101R**), កំណត់ហេតុស្តាប់ចម្លើយ ស្វូរ ញ៉ើត ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨ **ឯកសារ E3/5208** (ខ្សែអាត់សំឡេង **ឯកសារ D125/103R**), កំណត់ហេតុស្តាប់ចម្លើយ កើ ណោះ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩ **ឯកសារ E3/5289**, កំណត់ហេតុស្តាប់ចម្លើយ ជិ លី ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ **ឯកសារ E3/5290**។

ជាសាក្សីដោះបន្ទុកដ៏មានសក្តានុពល គាត់បានថ្លែងដូច្នេះថា៖ "[...] សាក្សីដែលខ្លួនគាត់ផ្ទាល់ [...] វាប៉ះពាល់ដល់ខ្លួនគាត់ [...]។ អ៊ីចឹង បើលោកស្រីៗជឿ ប៉ុន្តែសម្រាប់ខ្ញុំៗជឿលើប្រភពខាងជនរងគ្រោះច្រើនជាង [...]"[1458]។ ការថ្លែងបែបនេះ បានសង្ខេបឱ្យឃើញច្បាស់ល្អឥតខ្ចោះនូវគោលជំហររបស់លោក អ៊ីសា ឧស្មាន ហើយវាបានបដិសេធចោលនូវភាពឥតលម្អៀងដែលគាត់បានប្រកាស។

១៥៩៤.ម្យ៉ាងទៀត ការខឹងច្រឡោតក្នុងអំឡុងពេលសវនាការនេះ គឺពុំមែនជាភ័ស្តុតាងតែមួយគត់ដែលបង្ហាញពីភាពអគតិរបស់គាត់នោះទេ។

2. <u>"អ្នកជំនាញ" គ្មានការបណ្តុះបណ្តាលច្បាស់លាស់</u>

១៥៩៥. លោក អ៊ីសា ឧស្មាន ត្រូវបានអង្គជំនុំជម្រះកោះហៅក្នុងនាមជាអ្នកជំនាញ ប៉ុន្តែ គេចាំបាច់ត្រូវកត់សម្គាល់ថាគាត់ពុំធ្លាប់ទទួលបានការបណ្តុះបណ្តាលលើផ្នែកនេះនោះទេ។ ជាការពិតណាស់ លោក អ៊ីសា ឧស្មាន ស្គាល់មជ្ឈដ្ឋានចាមយ៉ាងល្អឥតខ្ចោះ ដើម្បីស្ថិតក្នុងសហគមន៍នេះបាន។ ប៉ុន្តែ ការបណ្តុះបណ្តាលរបស់គាត់លើផ្នែកភាសា និងវិធីសាស្ត្រធ្វើការសម្ភាស នៅមិនទាន់សមស្របទៅនឹងវិធីសាស្ត្រវិភាគ និងរបៀបវិទ្យាបែបវិទ្យាសាស្ត្រ ដែលមជ្ឈដ្ឋានអ្នកច្បាប់ចង់បានពីអ្នកជំនាញដែលត្រូវមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការនោះទេ[1459]។

១៥៩៦. របៀបដែលគាត់ត្រូវបាននាំឱ្យទៅប្រាស្រ័យជាមួយបុគ្គលផ្សេងៗដែលបានជួប គឺបង្ហាញឱ្យឃើញពីវិធីសាស្ត្របែបសហគមន៍ ដែលវាពិបាកស៊ីគ្នាជាមួយនឹងការងារឥតលម្អៀង[1460]។ ភាពអគតិ

---

[1458] <u>អ៊ីសា ឧស្មាន</u> ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/408.1** ទំព័រ ៦៦ ប្រហែលម៉ោង [១៥.២០.០០]។

[1459] <u>អ៊ីសា ឧស្មាន</u> ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/388.1** ទំព័រ ៨ មុនម៉ោង [០៩.២៧.១៦], ប្រតិចារឹក ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/407.1** ទំព័រ ៧២ មុនម៉ោង [១៥.៣៦.៥៧]។

[1460] <u>អ៊ីសា ឧស្មាន</u> ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/408.1** ទំព័រ ៣៨ ប្រហែលម៉ោង [១១.៣៣.២៧], សៀវភៅនិពន្ធដោយ អ៊ីសា ឧស្មាន មានចំណងជើងថា *The Chams rebellion* បោះពុម្ពឆ្នាំ ២០០៦ **ឯកសារ E3/2653** ERN 00219059 (ភាសាអង់គ្លេស), សៀវភៅនិពន្ធដោយ អ៊ីសា ឧស្មាន មានចំណងជើងថា *Oukoubah* បោះពុម្ពឆ្នាំ ២០០២ **ឯកសារ E3/1822** ERN 00078562 (ភាសាអង់គ្លេស)។

របស់គាត់ ក៏ត្រូវបានបង្ហាញឱ្យឃើញផងដែរតាមរយៈការពិនិត្យលើឯកសារសម័យខ្មែរក្រហមដ៏កម្រមួយចំនួនដែលគាត់បានយកមកសិក្សា។

១៥៩៧. ក្រុមមេធាវីការពារក្តីបានតទល់លោក អ៊ីសា ឧស្មាន ទៅនឹងការបកស្រាយខុសរបស់គាត់លើសារទូរលេខមួយច្បាប់របស់កម្ពុជាប្រជាធិបតេយ្យ ទាក់ទងនឹងអង្គហេតុកើតឡើងនៅស្រុកចំការលើ (ភូមិភាគកណ្តាល) នៅក្នុងសៀវភៅរបស់គាត់ មានចំណងជើងថា *The Cham rebellion*[1461] ហើយនៅក្នុងសៀវភៅនោះ សារទូរលេខបានលើកឡើងពីមនុស្សមួយក្រុមផ្សេងៗគ្នា ក្នុងនោះមានចាមមួយចំនួន និងពុំមែន "ពូជសាសន៍ចាមទាំងមូល" (« *the entire cham race* ») ដូចដែលមាននៅក្នុងសៀវភៅរបស់គាត់ឡើយ។ លោក អ៊ីសា ឧស្មាន ពុំបានទទួលស្គាល់កំហុស តែគាត់បែរជាបដិសេធឆ្លើយសំណួរ ដោយគាត់និយាយដោះសាថាអង់គ្លេសពុំមែនជា "ភាសាកំណើតរបស់គាត់" ដោយគាត់គេចវេសមិនព្រមផ្តល់ការពន្យល់លើការបកស្រាយបែបលម្អៀងលើឯកសារមួយដែលលើកឡើងខុសស្រឡះពីសេចក្តីសន្និដ្ឋានរបស់គាត់[1462]។

១៥៩៨. ប៉ុន្តែ លោក អ៊ីសា ឧស្មាន ត្រូវបង្ខំចិត្តទទួលស្គាល់ថា ទោះបីជាការយល់ឃើញរបស់គាត់ ដែលជាមូលដ្ឋាននៃការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាដំណោះស្រាយ គឺជនជាតិចាមទាំងអស់ត្រូវបានប្រមូល និងនាំយកទៅសម្លាប់ ដោយសារពួកគេត្រូវបានចោទថាជា "ខ្មាំង"[1463] ក៏ដោយ ក៏គ្មានឯកសារបក្សកុម្មុយនីស្តកម្ពុជាណាមួយ បានលើកឡើងពីគោលនយោបាយកំណត់មុខសញ្ញាជាពិសេសលើជនជាតិចាមនៅទូទាំងប្រទេសដែរ។ ដូច្នេះ បើទោះជាមានការ

---

[1461] សៀវភៅនិពន្ធដោយ អ៊ីសា ឧស្មាន មានចំណងជើងថា *The Chams rebellion* បោះពុម្ពឆ្នាំ ២០០៦ **ឯកសារ E3/2653** ERN 00219176 (ភាសាអង់គ្លេស) (អ៊ីសា ឧស្មាន និយាយថា ទូរលេខនេះ ទំនងជាពាក់ព័ន្ធនឹង "ពូជសាសន៍ចាមទាំងអស់" ខណៈដែលការអានទូរលេខនេះ ធ្វើឱ្យគេដឹងថាគឺវាពាក់ព័ន្ធតែនឹងជនជាតិចាម ព្រមទាំងមនុស្សផ្សេងទៀត មានដូចជាអតីតកម្មាភិបាលខ្មែរក្រហម និងអ្នកដទៃទៀតនៅក្នុងស្រុកចំការលើ ដែលបានប្រព្រឹត្តសកម្មភាពជាក់លាក់ប្រឆាំងនឹងរបបខ្មែរក្រហមប៉ុណ្ណោះ)។ សូមមើលផងដែរ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ **ឯកសារ E3/511** ERN 00000766។

[1462] អ៊ីសា ឧស្មាន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/408.1** ទំព័រ ៣១-៣២ ចន្លោះម៉ោង [១១.០៨.៤៦] និង [១១.១៣.៥៨]។

[1463] អ៊ីសា ឧស្មាន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/408.1** ទំព័រ ៤២ មុនម៉ោង [១៣.៤៣.១៤]។

ស្រាវជ្រាវរបស់គាត់ ទាក់ទងនឹងប្រធានបទនេះ ចាប់ពីឆ្នាំ ២០០១ រហូតដល់ពេលបច្ចុប្បន្ន[1464]ក៏ដោយ ក៏គាត់បានបញ្ជាក់ថា៖

> "ដូចខ្ញុំបានលើកឡើងអ៊ីចឹង យើងអត់ឃើញជាក្រដាសស្នាមទេ។ [...] ខ្ញុំអត់ទាន់បានក្រដាសស្នាមណាមួយបញ្ជាពីមជ្ឈិមទៅភូមិភាគ ឬក៏ពីភូមិភាគទៅតំបន់ ឬក៏ពីតំបន់ទៅស្រុកឱ្យរើសចាមទៅសម្លាប់ [...]" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[1465]។

១៥៩៩. ការសារភាពមួយនេះរបស់ "អ្នកជំនាញ" គឺពិតជាសំខាន់ណាស់ក្នុងការរំឭកឡើងវិញ មុននឹងត្រូវពិនិត្យលើភស្តុតាង ពីព្រោះវាមានន័យថា រាល់ការអះអាងរបស់លោក អ៊ីសា ឧស្មាន ការអះអាងរបស់សហចៅក្រមស៊ើបអង្កេត និងការអះអាងរបស់អយ្យការ គឺផ្អែកតែទៅលើសក្ខីកម្មដើម្បី "សន្និដ្ឋានអំពី" អត្ថិភាពនៃនយោបាយបែបនេះ ដូចដែលលោក "អ្នកជំនាញ" បានបញ្ជាក់នៅក្នុងសវនាការ[1466]។ ម្យ៉ាងវិញទៀត ទាក់ទងនឹងរបៀបវិទ្យាស្រាវជ្រាវដើម្បីសន្និដ្ឋានឱ្យឃើញអំពីអត្ថិភាពនៃគោលនយោបាយប្រល័យពូជសាសន៍ជនជាតិចាមនេះ អ្នកជំនាញបានបន្ថែមដូច្នេះថា៖

> "[...] ការស្រាវជ្រាវរបស់ខ្ញុំនេះ គឺយើងកំណត់យកទីកន្លែងធ្វើការស្រាវជ្រាវ គឺពិសេសទាក់ទងនឹងស្រុកក្រូចឆ្មារ ស្រុកកងមាស ដែលនៅក្នុងនោះ នៅក្នុងភូមិសាស្ត្រភូមិភាគបូព៌ាផង ហើយនឹងភូមិភាគកណ្តាលផង។ ហើយអ្វីដែលកើតឡើងនៅក្នុងភូមិភាគពីរនេះ ទោះបីថាការសម្លាសមិនបានគ្រប់ទីកន្លែងនៅក្នុងភូមិភាគហ្នឹងក៏ដោយ [...] ខ្ញុំអត់មានលទ្ធភាពស្រាវជ្រាវឱ្យមានភាពទូលំទូលាយគ្រប់ទីកន្លែងនៅក្នុងប្រទេសហ្នឹងដែរ [...]។ អ៊ីចឹងហើយសៀវភៅនេះគឺ សំខាន់គឺទៅលើស្រុកក្រូចឆ្មារ ស្រុកកងមាស [...]។ ហើយត្រង់លោកគិតថា តើវាអាចតំណាងឱ្យរឿងរ៉ាវជនជាតិចាមនៅក្នុងសម័យនោះគ្រប់ទីកន្លែងនៅក្នុងទូទាំងប្រទេសហ្នឹងអត់ ខ្ញុំមិនមានចម្លើយនេះជូនលោកទេ [...]"[1467]។

---

[1464] អ៊ីសា ឧស្មាន ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/388.1** ទំព័រ ១៤ ក្រោយម៉ោង [០៩.៤៧.០៧], ប្រតិចារឹក ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/407.1** ទំព័រ ២៩ មុនម៉ោង [១០.៥២.៣០] ("ប៉ុន្តែ ដូចខ្ញុំបញ្ជាក់ខាងដើមសម្រាប់ខ្ញុំ ខ្ញុំអត់បានរកឃើញឯកសារដែលថាជនជាតិចាមទូទាំងប្រទេសត្រូវបោសសម្អាតទេ (សុំទោស) អត់ទាន់ឃើញឯកសារនោះនៅឡើយទេ") ទំព័រ ៣០ មុនម៉ោង [១០.៥៦.០៧]។

[1465] អ៊ីសា ឧស្មាន ប្រតិចារឹក ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/389.1** ទំព័រ ២៥ មុនម៉ោង [១០.៤៩.២៨]។

[1466] អ៊ីសា ឧស្មាន ប្រតិចារឹក ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/407.1** ទំព័រ ២៤ មុនម៉ោង [១០.១៦.២១] ដែលនៅត្រង់នោះ អ៊ីសា ឧស្មាន បានឆ្លើយសំណួរមេធាវីការពារក្តី នួន ជា ថា ការអះអាងរបស់គាត់ដែលថាចាមត្រូវបានប្រមូល និងសម្លាប់ គឺផ្អែកលើរឿងរ៉ាវទាំងឡាយរបស់អ្នកផ្តល់បទសម្ភាស ដែលរស់នៅក្នុងស្រុក "កងមាស និងក្រូចឆ្មារ"។

[1467] អ៊ីសា ឧស្មាន ប្រតិចារឹក ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/407.1** ទំព័រ ២៤ មុនម៉ោង [១០.១៦.២១]។

១៦០០. ដូច្នេះ ដំណើរការនៃការវិភាគរបស់អង្គជំនុំជម្រះ ក្នុងក្របខ័ណ្ឌនៃការពិនិត្យលើសក្ខីកម្ម គឺត្រូវតែមានភាពហ្មត់ចត់ខ្លាំងជាទីបំផុត ដោយហេតុថាតួលេខលើកឡើងដោយលោក អ៊ីសា ឧស្មាន ក៏មិនអាចទុកចិត្តបានដូចគ្នា។

## 3. តាមន័យវិទ្យាសាស្ត្រ ការចោទរកាក់ទងនឹងស្ថិតិ គឺគ្មានមូលដ្ឋាន និងលម្អៀង

១៦០១. នៅពេលចោទសួរទាក់ទងនឹងចំនួនជនជាតិចាមនៅមុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ លោក អ៊ីសា ឧស្មាន បានពន្យល់ថា មុនឆ្នាំ ១៩៧៥ ជនជាតិចាមមានចំនួន ៧០០ ០០០ នាក់ ហើយក្រោយឆ្នាំ ១៩៧៩ គឺនៅសល់តែ ២០០ ០០០ នាក់ ប៉ុណ្ណោះ[1468]។ បើទោះជាត្រូវធ្វើការប្រុងប្រយ័ត្នលើបញ្ហាតួលេខ ដោយសារតែគ្មានប្រភពស្ថិតិជឿទុកចិត្តបាន ទាក់ទងនឹងក្រុមជនជាតិភាគតិចនៅកម្ពុជា ក្នុងទសវត្សរ៍ឆ្នាំ ៧០[1469] ក៏ដោយ ក៏គេត្រូវកត់សម្គាល់ថា លោកស្រី Ewa TABEAU បានលាតត្រដាងពីបញ្ហានៃរបៀបវិទ្យារបស់លោក អ៊ីសា ឧស្មាន ដោយគាត់យករបៀបបែបនេះទៅប្រៀបធៀបជាមួយនឹងការងាររបស់លោក Ben KIERNAN៖

> "ការពិភាក្សារបស់ Kiernan ចំពោះការសន្និដ្ឋានរបស់ Ysa មានលក្ខណៈគួរឱ្យចាប់អារម្មណ៍។ Ysa អះអាងថាមានប្រជាជនចាមនៅក្នុងប្រទេសកម្ពុជាចំនួន ៧០០ ០០០ នាក់ នៅក្នុងឆ្នាំ ១៩៧៥ ដែលក្នុងចំនួននេះ មានអ្នកនៅរស់តែ ១៣៨ ៦០៧ - ២០០ ០០០ នាក់ ប៉ុណ្ណោះ ដែលជាលទ្ធផលនោះ គឺខ្មែរក្រហមបានសម្លាប់អស់ចំនួនពី ៥០០ ០០០ - ៥៦០ ០០០ នាក់។ ផ្អែកតាម Kiernan ទស្សនៈរបស់ Ysa គឺមិនមានភស្តុតាងច្បាស់លាស់ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ទស្សនៈទាំងនេះគឺ៖ "យោងទាំងស្រុងលើការអះអាងពីអតីតកាល ហើយដែលបានធ្វើឡើងនៅចន្លោះឆ្នាំ ១៩៩៩ - ២០០០ ដោយសម្ភាស និងអះអាងថា នៅដើម[ទស]វត្សរ៍ឆ្នាំ ១៩៧០ ពួកគេបានឃើញស្ថិតិ និងបានឮការប្រកាស ឬតាមរយៈឯកសារមិនផ្លូវការមួយដែលនិយាយពី "ការចងចាំនៃថ្នាក់ដឹកនាំជន

[1468] អ៊ីសា ឧស្មាន ប្រតិចារិក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/388.1** ទំព័រ ១៣ ក្រោយម៉ោង [០៩.៤៣.១៧] ទំព័រ ១៧ ក្រោយម៉ោង [០៩.៥៦.៤៩], ប្រតិចារិក ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/407.1** ទំព័រ ១៩ មុនម៉ោង [១០.០២.២៧], ប្រតិចារិក ថ្ងៃទីចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/408.1** ទំព័រ ៤៦ មុនម៉ោង [១៣.៥៦.៤០]។

[1469] សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ១៩០៤-១៩២៤។

ជាតិចាម"" (Kiernan ទំព័រ ៥៨៩)។ តួលេខនៃការសម្លាប់អាចមានចំនួនលើសជនជាតិចាម ទាំងមូលដែលគណនានៅក្នុងខែ មេសា ឆ្នាំ ១៩៧៥"[1470]។

១៦០២. ក្នុងអំឡុងពេលសវនាការ លោក អ៊ីសា ឧស្មាន បានថ្លែងថាគាត់ធ្លាប់បានដឹងពីតួលេខខុសគ្នារបស់ លោក Ben KIERNAN លោក Michael VICKERY ព្រមទាំងបានដឹងពីការរិះគន់របស់លោក Henri LOCARD[1471] ប៉ុន្តែគាត់បានពន្យល់ថា គាត់សុខចិត្តផ្អែកតាមការរៀបរាប់របស់សាក្សី និង លើឯកសារដែលរកបាន ជាជាងធ្វើការស្រាវជ្រាវលើឯកសារយោងដែលបានលើកឡើងនៅក្នុង សៀវភៅរបស់អ្នកនិពន្ធ និងអ្នកស្រាវជ្រាវផ្សេងៗ ដែលគាត់គ្មាន[1472]។ ការពន្យល់បែបនេះ គឺពិត ជាស្ទើរតែគ្មានទម្ងន់បន្តិចសោះ ព្រោះគាត់បានទទួលស្គាល់ថាពុំទទួលបាននូវ "ចំនួនជនជាតិចាម ពិតប្រាកដណាមួយ[1473]"ឡើយ ហើយសេចក្តីសន្និដ្ឋានរបស់គាត់ គឺជាលទ្ធផលនៃការចងចាំរបស់ សមាជិកសហគមន៍ចាម និងតាមការឮគេនិយាយតគ្នា[1474]។

---

[1470] របាយការណ៍រៀបរៀងដោយ Ewa TABEAU ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩ **ឯកសារ E3/2413**, ERN 00499521 (TABEAU បានកត់សម្គាល់ពីការមិនយល់ស្របរបស់ KIERNAN ចំពោះការប៉ាន់ប្រមាណតិចជាង និងច្រើនជាង នៃចំនួនអ្នកស្លាប់ ធ្វើដោយ Michael VICKERY និង អ៊ីសា ឧស្មាន)។ សូមមើលផងដែរ សៀវភៅនិពន្ធដោយ Ben KIERNAN មានចំណងជើងថា *របបប៉ុល ពត ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍* បោះពុម្ពឆ្នាំ ១៩៩៦ **ឯកសារ E3/1593** ទំព័រ ៣៩៩-៤០០ ERN 00637754-55 ទំព័រ 641-642 ERN 00639349-50 (កំណត់សម្គាល់ជើងទំព័រ ៣២) (ភាសាបារាំង), អត្ថបទដកស្រង់ចេញពី សៀវភៅនិពន្ធដោយ Ben KIERNAN មានចំណងជើងថា *អំពើប្រល័យពូជសាសន៍ និងការតស៊ូនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ឯកសារ ការបដិសេធ យុត្តិធម៌នៅកម្ពុជា និងនៅទីម័រខាងកើត* **ឯកសារ E3/9686** ERN 01215481-88។

[1471] <u>អ៊ីសា ឧស្មាន</u> ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/408.1** ទំព័រ ២៥ មុនម៉ោង [១០.៤៥.៥៥] ("ខ្ញុំធ្លាប់ឮការរិះគន់នេះ មិនមែនតែ ហង់រី ឡូកា ទេ។ ចំពោះអ្នកស្រាវជ្រាវ អ្នកប្រវត្តិសាស្ត្រផ្សេងៗទៀត ក៏អ្នកខ្លះមកគាត់រកឃើញចំនួនមួយផ្សេង ហើយគាត់រិះគន់មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើ គឺគិតថាមិនសុក្រឹត ត្រឹមត្រូវ។ ប៉ុន្តែ មជ្ឈមណ្ឌលឯកសារកម្ពុជានៅតែរក្សាជំហរដែលធ្វើអ្វី គឺយោងទៅតាមសាក្សីដែលបញ្ជាក់ប្រាប់។ បើសាក្សីប្រាប់លើស បើសិនជារឿងហ្នឹងលើស ដូចសាក្សីនិយាយ គាត់បន្ថែមមែន យើងអត់មានលទ្ធភាពទៅដាក់បន្ថយទៅវិញទេ")។

[1472] <u>អ៊ីសា ឧស្មាន</u> ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/408.1** ទំព័រ ៥៣ មុនម៉ោង [១៤.១៧.៥៩]។

[1473] <u>អ៊ីសា ឧស្មាន</u> ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/388.1** ទំព័រ ១៣ ក្រោយម៉ោង [០៩.៤៣.១៧] ("ខ្ញុំបញ្ជាក់ពីរឿងតួលេខនេះ គឺតាមការស្រាវជ្រាវរបស់ខ្ញុំ គឺអត់ទាន់មានឯកសារដែលសរសេរចងក្រងឲ្យច្បាស់ថាមានប៉ុន្មានទេ។ ប៉ុន្តែផ្អែកទៅលើការសម្ភាសរបស់ខ្ញុំជាមួយអ្នកដែលបានឃើញឯកសារ [...]")។

[1474] <u>អ៊ីសា ឧស្មាន</u> ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/408.1** ទំព័រ ១២ ប្រហែលម៉ោង [០៩.៤២.៤៦] ទំព័រ ១៣ ប្រហែលម៉ោង [០៩.៤៥.២៦], អ៊ីសា ឧស្មាន បានបញ្ជាក់ថា ជនជាតិចាមដែលផ្តល់បទសម្ភាស បានប្រាប់គាត់ថា ពួកគេពុំដែលបានឃើញគេធ្វើជំរឿនចាមនោះទេ ហើយ អ៊ីសា ឧស្មាន និយាយថាប្រភពព័ត៌មានដែលទុកចិត្តបំផុតរបស់គាត់ គឺសម្តី

១៦០៣. ក្នុងអំឡុងពេលសវនាការ សុះ កំរី ដែលត្រូវបានលោក អ៊ីសា ឧស្មាន ណែនាំថាជាប្រភពយោងមួយសំខាន់សម្រាប់កាងារស្រាវជ្រាវរបស់គាត់ បានទទួលស្គាល់ថា តួលេខជនជាតិចាម ៣០០ ០០០ ក្រោយឆ្នាំ ១៩៧៩ ដែលមាននៅក្នុងចម្លើយរបស់គាត់ គ្រាន់តែជា "ការប៉ាន់ប្រមាណធម្មតា" និងគ្មាន "ការធ្វើជំរឿនពិតប្រាកដ" ណាមួយ ត្រូវបានធ្វើឡើងនៅសម័យនោះឡើយ ហើយថា "គ្មាននរណាម្នាក់បានដឹងពីរឿងនោះទេ"[1475]។ សុះ កំរី បានបន្ថែមថា "អត់មានអ្វីជាគោល" ដើម្បីឈានទៅដល់តួលេខ ៧០០ ០០០ មុនឆ្នាំ ១៩៧៥ ដែលផ្ដល់ដោយលោក អ៊ីសា ឧស្មាន[1476]។ គេត្រូវរំឭកថាតួលេខមួយនេះត្រូវបានលោក Ben KIERNAN ធ្វើការរិះគន់ ហើយគាត់ផ្ទាល់បានផ្ដល់តួលេខផ្សេង[1477] ហើយតួលេខនោះក៏បានរងការរិះគន់ពីលោក Michael VICKERY [1478]។

---

របស់ ហ្សាការីយ៉ា អាដាម ដែលគាត់ថាជាអ្នកជំនិតរបស់ឈ្មោះ រ៉េស ឡោះ ដែលជាអ្នកធ្លាប់ធ្វើការជាមួយបុគ្គលដែលទទួលបន្ទុកគ្រប់គ្រងជនជាតិចាមទាំងអស់ក្នុងរបបសង្គមរាស្ត្រនិយម រហូតដល់របប លន់ នល់។

[1475] អត្ថបទមានចំណងជើងថា "តើជនជាតិចាមប៉ុន្មាននាក់ត្រូវបានសម្លាប់ ទើបជាភ័ស្តុតាងសំខាន់សម្រាប់អំពើប្រល័យពូជសាសន៍" រៀបរៀងដោយ អ៊ីសា ឧស្មាន ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៦ **ឯកសារ E3/9701** ERN 01206398-401។ <u>សុះ កំរី</u> ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E1/415.1** ទំព័រ ៥១-៥៣ ចាប់ពីក្រោយម៉ោង [១៣.៤៨.១៥]។

[1476] <u>សុះ កំរី</u> ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ **ឯកសារ E1/415.1** ទំព័រ ៥២ ប្រហែលម៉ោង [១៣.៥៣.១៨]។ ការកត់សម្គាល់មួយនេះ ពិតជាសំខាន់នៅពេលគេដឹងថា តួលេខនេះត្រូវបាន ម៉ាត់ លី និយាយឡើងវិញ៖ កិច្ចសម្ភាស ម៉ាត់ លី ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ E3/7821** ERN 00229127, កិច្ចសម្ភាស ម៉ាត់ លី ជាមួយ Steve HEDER គ្មានចុះកាលបរិច្ឆេទ **ឯកសារ E3/390** ERN 00392106។

[1477] អត្ថបទដកស្រង់ចេញពីសៀវភៅនិពន្ធដោយ Ben KIERNAN មានចំណងជើងថា *អំពើប្រល័យពូជសាសន៍ និងការតស៊ូនៅក្នុង តំបន់អាស៊ីអាគ្នេយ៍ ឯកសារ ការបដិសេធ យុត្តិធម៌នៅកម្ពុជា និងនៅទីម័រខាងកើត* **ឯកសារ E3/9686** ERN 01215486៖ "នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ របាយការណ៍សម្ងាត់របស់របបកម្ពុជាប្រជាធិបតេយ្យបានឱ្យដឹងថា មានជនជាតិចាមចំនួន ១៥០ ០០០ នាក់ នៅក្នុងភូមិភាគបូព៌ា [...] នេះមិនមែនជាជំរឿនជាក់លាក់ទេ ប៉ុន្តែវាទំនងជាការប៉ាន់ស្មានតែប៉ុណ្ណោះ ដែលមានតួលេខប្រហែល ៥០ ០០០ នាក់ និង ១០០ ០០០ នាក់។ យើងពុំមានទិន្នន័យអំពីចំនួនជនជាតិចាមមុនឆ្នាំ ១៩៧៥ ឲ្យបានគ្រប់គ្រាន់មកពីបណ្ដាខេត្ត ជាក់លាក់ទាំងនោះ ដើម្បីធ្វើការប្រៀបធៀបជាមួយតួលេខនេះឲ្យបានច្បាស់លាស់ឡើយ។ ដោយហេតុផលនេះហើយ យើងគ្មានវិធីណាមួយដើម្បី<u>ធ្វើការព្យាករណ៍</u>ចេញពីតួលេខ ១៥០ ០០០ នាក់នេះ ទៅដល់តួលេខទូទាំងប្រទេសណាមួយនៅក្នុងឆ្នាំ១៩៧៥ <u>និងឱ្យធ្លាក់មកត្រឹមចំនួន ៧០០ ០០០ នាក់ទេ</u>" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

[1478] អត្ថបទចងក្រងដោយ Michael VICKERY មានចំណងជើងថា "មតិយោបល់នានាអំពីតួលេខជនជាតិចាម" ចុះខែ មករា-មីនា ឆ្នាំ ១៩៩០ (BCAS) **ឯកសារ E3/9682** ERN 01215490 "ខ្ញុំចាំបាច់ត្រូវតែធ្វើសេចក្ដីពន្យល់ដូចខាងក្រោម។ ក្នុងនាមជាអ្នកអានអត្ថបទនេះម្នាក់ មុនពេលបោះពុម្ពផ្សាយ ខ្ញុំបានក្រើនរំលឹកដល់ BCAS និង Kiernan ដោយផ្ទាល់អំពីភាពមិនអាចជឿជាក់បាននៃតួលេខដែលបានដាក់បញ្ចូលទាំងនោះ។ លើសពីនេះ ខ្ញុំមិនចង់ឱ្យអ្នកអានផ្សេងទៀត ដែលដឹងថាខ្ញុំចូលរួមពាក់ព័ន្ធ

១៦០៤. នៅក្នុងកថាខណ្ឌ ២២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម សហព្រះរាជអាជ្ញាខ្លួនឯងហាក់ដូចជាទទួលស្គាល់ថា ចំនួនជនជាតិចាមដែលត្រូវបានសន្មតថាត្រូវបានសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អាចមានតិចជាងចំនួនដែលលោក អ៊ីសា ឧស្មាន បានស្នើឡើង[1479]។ ដូច្នេះ វាមិនសមហេតុផលដែលត្រូវចាត់ទុកថា "សេចក្តីសន្និដ្ឋាន" របស់លោក អ៊ីសា ឧស្មាន ទាក់ទងនឹងចំនួនជនជាតិចាម មុនឆ្នាំ ១៩៧៥ និងចំនួនអ្នកស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អាចជឿទុកចិត្តបាន។

១៦០៥. ដូច្នេះ អង្គជំនុំជម្រះត្រូវចាំទុកជាប់ជានិច្ចអំពីបញ្ហាទាំងអស់ទាក់ទងនឹងភាពអគតិ និងបញ្ហានៃការវាយតម្លៃប្រហាក់ប្រហែលនៃកាងារស៊ើបអង្កេត និងស្រាវជ្រាវរបស់លោក អ៊ីសា ឧស្មាន សម្រាប់ការពិនិត្យលើភ័ស្តុតាងទាក់ទងនឹងជនជាតិចាមជាទូទៅ និងដោយឡែក ទាក់ទងនឹងសក្ខីកម្មលោក អ៊ីសា ឧស្មាន តែម្តង។

## ខ. **<u>កំណត់ហេតុស្លាប់ចម្លើយច្រើនសម្បើម</u>**

---

យល់ឃើញថាខ្ញុំគាំទ្រវិធីសាស្ត្រនៃការប្រើប្រាស់ស្ថិតិទាំងនោះឡើយ។ ទោះបីជាយ៉ាងនេះក្តី សេចក្តីក្រើនរំលឹកដែលខ្ញុំបានធ្វើឡើងនេះ ពុំត្រូវសង្កត់ធ្ងន់ពេកទេ។ *ស្ថិតិទាំងអស់ស្តីពីចំនួនប្រជាជនកម្ពុជាក្នុងសម័យកាលណាក៏ដោយ* ដាក់បញ្ចូលសម្មតិកម្ម សេចក្តីសន្និដ្ឋាន ការព្យាករណ៍ និងការប៉ាន់ស្មានសុទ្ធសាធ ហើយស្ថិតិទាំងនោះ ប្រហែលជាពុំអាចទទួលយកបានចំពោះបែបផែននៃការគណនា ដែលអនុវត្តដោយ Kiernan និងរូបខ្ញុំឡើយ"។

[1479] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ **ឯកសារ D196** កថាខណ្ឌ ២២៖ "ក្នុងចំណោមប្រជាជន ១៥៨ ០០០ នាក់ ដែលត្រូវបានគេជឿថាត្រូវបានគេសម្លាប់នៅក្នុងខេត្តកំពង់ចាម ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យហើយនោះ មានប្រជាជនប្រមាណតែ ៧៤ ០០០ នាក់ ក្នុងចំណោមប្រជាជនទាំងនោះ (ប្រជាជនជិត ៥០% នៃប្រជាជនសរុបបានស្លាប់) ត្រូវបានគេស្គាល់អត្តសញ្ញាណថាជា "ជនជាតិភាគតិច"។ នេះគឺជាអត្រាភាគរយដែលខ្ពស់ជាងអត្រាភាគរយនៃខេត្តដទៃៗទៀតយ៉ាងខ្លាំង។ ឧទាហរណ៍ដូចជាក្នុងចំណោមប្រជាជនជាង ៣២៤ ០០០ នាក់ ដែលបានស្លាប់នៅក្នុងខេត្តកំពង់ធំ គឺមានតែចំនួន ១ ៥០០ នាក់ ប៉ុណ្ណោះដែលត្រូវបានគេស្គាល់អត្តសញ្ញាណថាជាជនជាតិភាគតិច និងក្នុងចំណោមប្រជាជនជាង ៤៦០ ០០០ នាក់ ដែលត្រូវបានគេសម្លាប់នៅក្នុងខេត្តបន្ទាយមានជ័យ និងបាត់ដំបង មានប្រមាណជា ៩២ [៥]០០ នាក់ គឺជាជនជាតិភាគតិច"។ សហព្រះរាជអាជ្ញាផ្អែកលើទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

១៦០៦. នៅក្នុងផ្នែកនៃដីកាដំណោះស្រាយ ទាក់ទងនឹងផ្នែកនៃការប្រព្រឹត្តទៅលើក្រុមជនជាតិចាម សហ-ចៅក្រមស៊ើបអង្កេតបានផ្អែកជាច្រើនលើកច្រើនសាលើមូលដ្ឋានកិច្ចសម្ភាសជាច្រើនធ្វើឡើងដោយ *Indochina Studies Program, Social Science Research Council* ។ កិច្ចសម្ភាសទាំងអស់នោះភាគច្រើន គឺជាកិច្ចសម្ភាសធ្វើដោយ Nate THAYER និងក្រុមការងាររបស់គាត់ ជាមួយជនភៀសខ្លួននៅប្រទេសថៃឡង់ដ៍ ក្នុងទសវត្សរ៍ឆ្នាំ ៨០[1480]។

១៦០៧. ក្រៅពីការណ៍ដែលកិច្ចសម្ភាសទាំងអស់នេះត្រូវបានធ្វើឡើងនៅក្រៅក្របខ័ណ្ឌតុលាការ ហើយមិនត្រូវបានពិភាក្សាដេញដោលនៅក្នុងសវនាការ បញ្ហាមួយផ្សេងទៀតបានចោទឡើង។ កិច្ចសម្ភាសទាំងនេះត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃទម្រង់បែបបទមួយរៀបចំជាមុន ជាភាសាអង់គ្លេស និងបំពេញដោយដៃ ហើយពេលខ្លះក៏អាចអានបាន ពេលខ្លះទៀត ព័ត៌មានដែលមាននៅក្នុងនោះ មិនពេញលេញថែមទៀត[1481]។ តម្លៃជាភ័ស្តុតាងនៃឯកសារទាំងនោះ មានតិចតួចបំផុត។

## ២. ការពិនិត្យភ័ស្តុតាងទាក់ទងនឹងអង្គហេតុ

១៦០៨. ការពិនិត្យលើអង្គហេតុទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនចាម ដំណាក់កាលទី២ មិនអាចឱ្យគេសន្និដ្ឋានថាមានការធ្វើទុក្ខបុកម្នេញលើក្រុមជនជាតិចាម (ក) បានទេ ហើយវាក៏ដូចគ្នាដែរថាជីវភាពនៅតាមភូមិក្នុងស្រុកក្រូចឆ្មារ និងស្រុកកងមាស និងនៅក្នុងភូមិភាគបូព៌ា និងភូមិភាគកណ្តាល មិនអាចឱ្យគេសន្និដ្ឋានបានថាមានការធ្វើទុក្ខបុកម្នេញលើជនជាតិចាម (ខ)។ បន្ទាប់មកគេត្រូវពិនិត្យលើកាលៈទេសៈនៃការសម្លាប់ដែលរងការចោទប្រកាន់ នៅក្នុងស្រុកទាំងពីរ គឺស្រុកក្រូចឆ្មារ និងស្រុកកងមាស (គ)។

---

[1480] នៅក្នុងដីកាដំណោះស្រាយ មានកំណត់សម្គាល់ជើងទំព័រយ៉ាងតិច ១៨២ ទាក់ទងនឹងផ្នែកស្តីពីវិធានការប្រឆាំងក្រុមជនជាតិចាម ដែលជើងទំព័រទាំងនោះ ផ្អែកលើមូលដ្ឋានកិច្ចសម្ភាសទាំងអស់នេះ។ ដូច្នេះ កង្វះភាពជឿទុកចិត្តបាននៃភ័ស្តុតាងដ៏ច្រើនសម្បើមនេះ ពិតជាមានឥទ្ធិពលលើការពិភាក្សាដេញដោលមិនខាន។

[1481] ឧទាហរណ៍ សូមមើល កិច្ចសម្ភាសជាមួយ អ៊ីស្មាអែល ប៊ីន អាតាំ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៨៥ **ឯកសារ E3/7582** ERN 01378922-25, កិច្ចសម្ភាស Nate THAYER ជាមួយ MUHAMAD Ali ចុះខែ សីហា ឆ្នាំ ១៩៨៥ **ឯកសារ E3/7490** ERN 00636660។

## ក. ការផ្លាស់ទីលំនៅប្រជាជនចាម ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២

១៦០៩. ដូចបានរំឭកខាងលើ លោក ខៀវ សំផន ត្រូវបានចោទប្រកាន់តែពីបទឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនចាម ដំណាក់កាលទី២[1482] ប៉ុណ្ណោះ។ ជាបឋម គេត្រូវរំឭកពីកាលៈទេសៈនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ ដោយកត់សម្គាល់ថាវាជាការផ្លាស់ទីលំនៅប្រជាជនជាទូទៅ ដែលមិនពាក់ព័ន្ធជាពិសេសតែជាមួយជនជាតិចាមនោះទេ (ក) បើទោះបីជាវាត្រូវបានអនុវត្តឡើងក្រោយពីមានការបះបោររបស់ជនជាតិចាម នៅក្នុងភូមិភាគបូព៌ា ក៏ដោយ (ខ)។

### 1. គ្មានការរើសអើងលើប្រជាជនចាម ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២

១៦១០. ក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០១ មូលហេតុ និងហេតុផលផ្នែកសេដ្ឋកិច្ចនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ ត្រូវបានពន្យល់។ ដូច្នេះ ជាបឋម នៅទីនេះ គេត្រូវធ្វើការយោងទៅលើទទ្ធីករណ៍ទាំងឡាយដែលមាននៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល សម្រាប់សំណុំរឿង ០០២/០១ ទាក់ទងនឹងប្រធានបទនេះ[1483]។ ប៉ុន្តែ គេត្រូវពិនិត្យឡើងវិញលើឯកសារសម័យខ្មែរក្រហមខ្លះៗដែលបានបញ្ជាក់ពីភាពគ្មានការរើសអើងសាសនាចំពោះជនជាតិចាម ក្នុងក្របខ័ណ្ឌនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២។

### 1.ក. ឯកសារឆ្នាំ ១៩៧៥ ដែលបង្ហាញពីការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២

---

[1482] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១៥៦៣-១៥៦៩។

[1483] សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ **ឯកសារ E295/6/4** កថាខណ្ឌ ៦១-៧១។

១៦១១. នៅក្នុងកំណត់ហេតុទស្សនកិច្ចគណៈកម្មាធិការអចិន្ត្រៃយ៍ នៅភូមិភាគពាយ័ព្យ ចុះថ្ងៃទី២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ កង្វះកម្លាំងពលកម្មនៅតាមភូមិភាគមួយចំនួន ត្រូវបានលើកយកមកពិភាក្សា ក្នុងក្របខ័ណ្ឌនៃការបង្កើត និងដាក់ឱ្យដំណើរការសហករណ៍[1484]។

១៦១២. ក្នុងឯកសារមួយផ្សេងទៀត ចុះកាលបរិច្ឆេទខែ កញ្ញា ឆ្នាំ ១៩៧៥ ដែលគេមិនស្គាល់អ្នកនិពន្ធ និង ដែលនិយាយពី "ការកសាងសេដ្ឋកិច្ចឡើងវិញ"[1485] ការបែងចែកប្រជាជន ត្រូវបានលើកយកមក បង្ហាញជាទូទៅ។ គោលជំហររបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងឯកសារនេះ គឺដូចមុនដែរ គឺថា ត្រូវធ្វើឱ្យសម្រេចបាននូវផែនការបែងចែកប្រជាជន "កុំឱ្យឃ្លោងម្ខាងៗ" នៅក្នុងប្រទេស ដើម្បី គោលដៅសេដ្ឋកិច្ច៖

> "យើងត្រូវបែងចែកប្រជាជនទៅតាមសេចក្តីត្រូវការនៃផលិតកម្ម។ យើងរៀបចំឱ្យសមស្របនឹង សេចក្តីត្រូវការ។ ត្រូវរៀបចំឱ្យល្មម កុំឱ្យឃ្លោងម្ខាងៗ។ នៅពាយ័ព្យ ត្រូវការកម្លាំងថែ្លម ៥ សែន នាក់ទៀត។ [...] នៅឧត្តរ ក៏ត្រូវការប្រជាជន ផ្តល់ឱ្យខេត្តកំពង់ធំ។ បូព៌ា ក៏ត្រូវការកម្លាំង សម្រាប់ផ្តល់ឱ្យតំបន់ដែលខ្វះខាតប្រជាជន។ ដូច្នេះ ភូមិភាគមួយៗ ត្រូវរៀបចំឱ្យសមស្រប កុំឱ្យ ឃ្លោងម្ខាងៗ សេសសល់ប៉ុន្មានខាងលើ នឹងដកយកទៅចែកកន្លែងផ្សេងៗទៀត"[1486]។

១៦១៣. ដូច្នេះ ផែនការនៃការផ្លាស់ទីលំនៅប្រជាជន ត្រូវបានសម្រេចឡើងក្នុងគោលដៅបំពេញកង្វះខាត កម្លាំង ជាពិសេសនៅក្នុងភូមិភាគពាយ័ព្យ ភូមិភាគឧត្តរ និងភូមិភាគបូព៌ា។ ដូច្នេះ គ្មានក្រុមប្រជា-ជនណាមួយ ត្រូវបានកំណត់ជាគោលដៅជាក់លាក់ នៅពេលអនុវត្តផែនការនេះឡើយ។

## 1.២. ការរំឭកអំពីសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូល

១៦១៤. គេត្រូវរំឭកឡើងវិញថា អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលសេចក្តីសន្និដ្ឋានរបស់អង្គជំនុំ ជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០១ ទាក់ទងនឹងការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញ

[1484] កំណត់ហេតុអំពីទស្សនកិច្ចគណៈអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃ ២០-២៤ សីហា ១៩៧៥ **ឯកសារ E3/216**។

[1485] ឯកសារមានចំណងជើងថា "ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយ ស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក" ចុះខែ កញ្ញា ឆ្នាំ ១៩៧៥ **ឯកសារ E3/781**។

[1486] ឯកសារមានចំណងជើងថា "ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយ ស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក" ចុះខែ កញ្ញា ឆ្នាំ ១៩៧៥**ឯកសារ E3/781** ERN 00072396-97។

លើប្រជាជនថ្មី ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២[1487]។ នៅត្រង់កថាខណ្ឌ ៧០១ នៃសាលដីកាក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ដើម្បីបង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញមកលើប្រជាជនថ្មី គេត្រូវបង្ហាញភ័ស្តុតាងឱ្យឃើញពីការប្រព្រឹត្តមួយផ្សេងមកលើប្រជាជន ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី ២ ប៉ុន្តែ ក្នុងករណីជាក់ស្តែង វាពុំមែនដូច្នេះ៖

> "ដូច្នេះ ដើម្បីបង្ហាញអំពីការធ្វើទុក្ខបុកម្នេញលើ "ប្រជាជនថ្មី" ដូចមាននៅក្នុងសំណុំរឿងបច្ចុប្បន្ន ចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ការផ្លាស់ទីលំនៅប្រជាជនបានធ្វើឱ្យប៉ះពាល់យ៉ាងហោចណាស់ជាចម្បង ឬ តែ "ប្រជាជនថ្មី" ប៉ុណ្ណោះ ដូច្នេះ គឺជាការរើសអើង ឬថា នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ "ប្រជាជនថ្មី"បានទទួលរងការប្រព្រឹត្តខុសប្លែកពី"ប្រជាជនចាស់"" (យើងជាអ្នកគូសបន្ទាត់ពីក្រោម[1488]។

១៦១៥. នៅត្រង់កថាខណ្ឌ ៧០២ នៃសាលដីកា ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ផងដែរថា៖

> "ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកការយល់ឃើញរបស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយពុំសមហេតុផលថា "ប្រជាជនភាគច្រើនលើសលុប" ដែលត្រូវបានផ្លាស់ទីលំនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ គឺជា "ប្រជា-ជនថ្មី" ដោយសារភ័ស្តុតាងតិចតួចគាំទ្រការសន្និដ្ឋាននេះ។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងភ័ស្តុតាងដែលបានយកមកសំអាងនោះ ឃើញថាការផ្លាស់ទីលំនៅប្រជាជនដោយសារមូលហេតុសេដ្ឋកិច្ច និងចេញពីព្រំដែនវៀតណាម ពាក់ព័ន្ធទាំងប្រជាជន*ចាស់* ទាំង *ថ្មី* ដែលជាការពិតមួយត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់របស់ខ្លួន។ ដោយសារការផ្លាស់ទីលំនៅនេះបានប៉ះពាល់មិនត្រឹមតែប្រជាជន*ថ្មី* ដូច្នេះ ពុំអាចនិយាយបានថា ជាការរើសអើងជាក់ស្តែង ឬបង្ហាញពីចេតនារើសអើងឡើយ" (យើងជាអ្នកគូសបន្ទាត់ពីក្រោម។

១៦១៦. ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅក្រុមជនជាតិចាមវិញ ទោះបីជាអង្គហេតុផ្ទាល់មិនអាចប្រកែកបានក៏ដោយ ក៏ទឡ្ហីករណ៍នានាដែលត្រូវបានរៀបរាប់ដោយអង្គជំនុំជម្រះតុលាការកំពូល ក៏អាចអនុវត្ត

[1487] សាលក្រម ០០២/០១ កថាខណ្ឌ ៧០១-៧០៦។

[1488] ដីកាដំណោះស្រាយ កំណត់សម្គាល់ជើងទំព័រ ១០២៦, ១០៣៣, ១១៣២, ១១៣៦។

បានដូចគ្នាចំពោះអង្គហេតុទាំងនោះ។ ការផ្លាស់ទីលំនៅប្រជាជន បានធ្វើឡើងក្រោយពីមានសេចក្តីសម្រេចដែលត្រូវបានលើកបង្ហាញនៅក្នុងឯកសារយោងទាំងពីរខាងលើ ហើយការផ្លាស់ទីលំនៅនោះ ពាក់ព័ន្ធនឹងប្រជាជនទាំងអស់ រួមមានទាំងជនជាតិចាមផងដែរ។

## 1.គ. សារទូរលេខ ១៥ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥

១៦១៧. សារទូរលេខ ១៥ ដ៏ល្បីមួយនេះ ត្រូវបានយោងជាច្រើនលើកច្រើនសាដោយសហចៅក្រមស៊ើបអង្កេត ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួន ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនចាម[1489]។ សហចៅ-ក្រមស៊ើបអង្កេតបានបញ្ជាក់នៅក្នុងកថាខណ្ឌ ២៨១ នៃដីកាដំណោះស្រាយ ដូច្នេះថា៖

> "សារទូរលេខ ១៥ បង្ហាញជាសំខាន់អំពីបញ្ហាមួយដែលកើតឡើងពីការផ្លាស់ទីលំនៅប្រជាជនចាម ដោយឱ្យដឹងថា *"ដូច្នេះ ប្រជាជនអ៊ីស្លាមនៅសល់ក្នុងភូមិភាគបូព៌ា ជាង ១ សែននាក់ទៀត។ (...) ដកនេះជាគោលការណ៍ បំបែកដូចមតិបងបានពិភាក្សាជាមួយយើងខ្ញុំរួចស្រេចហើយ។ តែបើឧត្តរមិនព្រមទទួល យើងខ្ញុំក៏ស្ម័គ្រទាំក្តោបក្តាប់ប្រជាជនអ៊ីស្លាមតទៅទៀតដែរ គ្មានបញ្ហាអ្វីទេ"*។ ហេតុការណ៍នេះកើតឡើងប៉ុន្មានសប្តាហ៍បន្ទាប់ពីការបះបោររបស់ប្រជាជនចាមនៅកោះផល និងស្វាយឃ្លាំង។ នៅក្នុងបរិបទដូច្នេះ ភស្តុតាងនេះអាចបង្ហាញថា មូលហេតុចម្បងចំពោះការផ្លាស់កន្លែង និងការបំបែកប្រជាជនចាមតាមការគ្រោងទុក គឺជាការដោះស្រាយបញ្ហាគំរាមកំហែងផ្នែកសន្តិសុខដែលមានជាមួយប្រជាជនចាម ព្រមទាំងជាការឆ្លុះបញ្ចាំងអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បី *"បំបែក"* ប្រជាជនចាម"។

១៦១៨. ក៏ប៉ុន្តែ នេះគ្រាន់តែជាការបកស្រាយដោយលម្អៀងរបស់សហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ។ ក្នុងករណីដែលសារទូរលេខនេះពិតជាកើតមុនការបះបោរនៅកោះផល និងស្វាយឃ្លាំង មែននោះ គឺមានន័យថាការបះបោរនេះបានកើតមាន ខណៈដែលការជម្លៀសប្រជាជន ត្រូវបានរៀបចំផែនការជាមុនរួចស្រេចមកហើយ។ ការអានសារទូរលេខទាំងស្រុង អាចឱ្យគេយល់បានប្រសើរជាងនេះនូវបរិបទរបស់វា។ នៅក្នុងកថាខណ្ឌដដែលនេះ ដែលសហចៅក្រមស៊ើបអង្កេតបានយោងមួយផ្នែក គេអាចអានដូច្នេះថា៖

[1489] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ **ឯកសារ E3/154** ERN 00008494-95។

"ជាគោលការណ៍ ខាង ភ.ភ ដកប្រ.ជ ចំនួន ៥ ម៉ឺននាក់ ប្រគល់ទៅឱ្យឧត្តរ។ ដូច្នេះ ប្រ.ជឥស្លាម នៅសល់ក្នុងភ.ភបូព៌ាជាង ១ សែននាក់ទៀត។ យើងខ្ញុំដកតែតាមចំណុចសំខាន់នៅតាមដងទន្លេ និងព្រំដែន ឯខាងត្បូងឃុំ មិនដកទេ។ ដកនេះជាគោលការណ៍បំបែកដូចមតិបងបានពិភាក្សាជាមួយយើងខ្ញុំរួចស្រេចហើយ។ តែបើឧត្តរមិនព្រមទទួល យើងខ្ញុំក៏ស៊ូទ្រាំក្តោបក្តាប់ប្រ.ជឥស្លាមតទៅទៀតដែរ គ្មានបញ្ហាអីទេ។ ប៉ុន្តែ មនុស្សមិនអាចគ្រប់ចំនួនទៅដល់ ១ សែន ៥ ម៉ឺននាក់ទេ បើប្រសិនភ.ភឧត្តរ មិនទទួលយកប្រ.ជឥស្លាម" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

១៦១៩. បើទោះបីថាបញ្ហាបំបែកជនជាតិចាម ពិតជាមានប្រាកដនៅក្នុងសារទូរលេខមួយនេះ ដើម្បីបែងចែកកម្លាំងក៏ដោយ ក៏ផែនការឱ្យបានគ្រប់ចំនួន ១៥០ ០០០ នាក់ នៅភូមិភាគឧត្តរ គឺបានប៉ះពាល់ទាំងជនជាតិខ្មែរ ទាំងជនជាតិចាម។ ក្នុងន័យនេះ គឺវាសមស្របទៅនឹងផែនការជាទូទៅក្នុងការបែងចែកប្រជាជននៅតាមតំបន់ដែលមិនសូវមានមនុស្សរស់នៅ។ ម្យ៉ាងវិញទៀត ការផ្លាស់ទីលំនៅនេះ ពាក់ព័ន្ធតែប្រជាជនចាមមួយភាគបី ព្រោះដូចដែលបានលើកឡើងនៅក្នុងសារទូរលេខស្រាប់ ប្រជាជនចាមចំនួន ១០០ ០០០ នាក់ បានបន្តរស់នៅក្នុងភូមិភាគដដែល។

១៦២០. គេត្រូវកត់សម្គាល់ផងដែរថា មនុស្សមួយចំនួនដែលត្រូវជម្លៀសចេញ គឺរស់នៅតាមព្រំដែន។ ដូច្នេះការផ្លាស់ទីលំនៅប្រជាជន ត្រូវដាក់ឱ្យជាប់ទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធនៅតាមព្រំដែនវៀតណាម ជាជាងជាមួយនឹងការបះបោរជនជាតិចាម។ ម្យ៉ាងវិញទៀត មូលហេតុនៃការផ្លាស់ទីលំនៅទៅកាន់កន្លែងកំណត់ច្បាស់លាស់ ត្រូវបានកត់សម្គាល់ដោយអង្គជំនុំជម្រះតុលាការកំពូលនៅត្រង់កថាខណ្ឌ ៧០២ នៃសាលដីកាក្នុងសំណុំរឿង ០០២/០១។

១៦២១. គេរឹតតែមិនអាចសន្និដ្ឋានបានថាមានការផ្លាស់ទីលំនៅ ជាមួយនឹងការរើសអើងចំពោះជនជាតិចាមនៅក្នុងបរិបទនៃការធ្វើទុក្ខបុកម្នេញសាសនា ព្រោះថាសារទូរលេខ ១៥ បានលើកឡើងពីការផ្លាស់ទីលំនៅប្រជាជនខ្មែរទៅកាន់កន្លែងផ្សេងៗទៀត។ នៅត្រង់កថាខណ្ឌ ២ នៃសារទូរលេខនេះ គេអាចអានបានដូច្នេះថា៖

"តំបន់ និងស្រុក បានប្រមូលប្រ.ជគ្រប់ចំនួនដែលត្រូវដកពីតំបន់២១ ហើយក៏បានដឹកជញ្ជូនទៅត្រៀមម្ខាង។ ចំណុចទាំង២នេះដាច់ខាតមិនទទួលយកប្រ.ជឥស្លាមទេ យកតែខ្មែរសុទ្ធ។ ដូច្នេះ សភាពប្រ.ជ អ្នកដែលត្រូវដកថ្ងៃ៣០នេះ មានការជ្រួលច្របល់យ៉ាងខ្លាំង" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

១៦២២. សក្ខីកម្មនានាដែលត្រូវបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះ ក៏មិនអាចឱ្យគេសន្និដ្ឋានបានថាមានអំពើធ្វើទុក្ខបុកម្នេញសាសនាបានឡើយ។ សាក្សីជនជាតិចាម សុះ រំលី បានថ្លែងប្រាប់អង្គជំនុំជម្រះថាគាត់បានរស់នៅក្នុងភូមិទ្រា២ មុនការមកដល់របស់ពួកខ្មែរក្រហម។ ដោយសារតែមានប្រភពដើមចេញមកពីមជ្ឈដ្ឋានសង្គមក្រីក្រ បានធ្វើឱ្យគាត់មានលទ្ធភាពកាន់កាប់តួនាទីបន្តបន្ទាប់ជាច្រើនក្នុងជួរខ្មែរក្រហម ហើយចាប់ពីចុងឆ្នាំ ១៩៧៥ គាត់បានធ្វើជាជំនួយការប្រធានបន្តបន្ទាប់ក្នុងឃុំក្រូចឆ្មាររបស់គាត់ រហូតដល់ពេលគាត់រត់គេចខ្លួនជាមួយអ្នកភូមិផ្សេងទៀត មួយខែមុនពេលរបបខ្មែរក្រហមដួលរលំ ក្រោយពីមានការនិយាយតៗគ្នាពីការសម្លាប់មនុស្ស[1490]។

១៦២៣. ដូច្នេះ សុះ រំលី អាចនៅក្នុងភូមិរបស់គាត់ ដូចប្រជាជន ១៥ ទៅ ២០% ទៀត រហូតដល់កាលបរិច្ឆេទមួយយ៉ាងយូរក្រោយមកទៀត ប៉ុន្តែគាត់បានពន្យល់ពីការផ្លាស់ទីលំនៅប្រជាជនផ្សេងទៀតតាមរយៈការណ៍ដែលគេបានប្រាប់គាត់ថា នៅបាត់ដំបង "[...] ស្រូវ [...] ច្រើនណាស់ យើងទៅត្រង់នុ៎ង ហូបបាយបានឆ្អែត" ខណៈដែលនៅក្នុងភូមិ មិនសូវសម្បូរបាយហូប[1491]។ សុះ រំលី និយាយថាក្រោយឆ្នាំ ១៩៧៩ មានជនជាតិចាម "៦០%" បានវិលត្រលប់មកភូមិវិញ។ គាត់ក៏បានប្រាប់ឱ្យដឹងផងដែរថា គឺនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ និងស្រុកស្ទឹងត្រង់ ក្នុងខេត្តកំពង់ចាម ដែលមានប្រជាជនចាមជាច្រើននាក់បានបាត់ខ្លួន[1492]។

## 1.ឃ. ប្រភេទផ្សេងៗនៃការផ្លាស់ទីលំនៅប្រជាជន

១៦២៤. ជនជាតិចាមមួយចំនួនក្នុងភូមិភាគបូព៌ា និងក្នុងភូមិភាគកណ្តាល ត្រូវបានបញ្ជូនទៅកាន់ទីកន្លែងផ្សេងៗក្នុងភូមិភាគដដែល ហើយក្នុងស្រុកដដែល ឬទៅកំពង់ធំ ក្រចេះ ឬក៏បាត់ដំបង ស្របតាមអ្វី

---

[1490] សុះ រំលី ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ** E1/371.1 ទំព័រ ៧៥-៧៧ ចន្លោះម៉ោង [១៥.៤១.៤៧] និង [១៥.៥២.២៦], ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ** E1/372.1 ទំព័រ ១២-១៣ ប្រហែលម៉ោង [០៩.៤១.៣៣] ទំព័រ ៦០ ប្រហែលម៉ោង [១៤.៣១.១៨]។

[1491] ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ** E1/372.1 ទំព័រ ១៣ មុនម៉ោង [០៩.៤៥.១៥] ទំព័រ ១៤ មុនម៉ោង [០៩.៤៨.១៥]។

[1492] ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ** E1/372.1 ទំព័រ ៣៥ មុនម៉ោង [១១.១៣.៤៩]។

ដែលមានសរសេរនៅក្នុងឯកសារទាំងអស់ដែលចុះកាលបរិច្ឆេទក្នុងខែ កញ្ញា ឆ្នាំ ១៩៧៥ ខណៈដែលជនជាតិចាមផ្សេងទៀត រស់នៅក្នុងភូមិដដែល[1493]។ ដូចគ្នានេះដែរ ប្រជាជនខ្មែរត្រូវបានផ្លាស់ទីលំនៅផងដែរ ក្នុងរយៈពេលដូចគ្នា ហើយបានផ្លាស់ប្តូរភូមិ[1494]។

១៦២៥. ក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួន សាក្សី រៀល នាង ជាប្រជាជនភូមិអង្គរបាន និងជា "អតីតប្រធាននារីឃុំ" បានបញ្ជាក់ថា មុនឆ្នាំ ១៩៧៥ ប្រជាជនក្នុងឃុំរបស់គាត់ ត្រូវបានផ្លាស់ទីលំនៅ "ពីកន្លែងមួយទៅកន្លែងមួយទៀត" តែគាត់ពុំបានប្រាប់ថា គឺមានតែជនជាតិចាមប៉ុណ្ណោះដែលត្រូវបានផ្លាស់ទីលំនៅ[1495]។

១៦២៦. ដូចគ្នានេះដែរ សាក្សី តាយ គឹមហ៊ាន់ បានថ្លែងថា ក្នុងភូមិរបស់គាត់ គ្មានចាមរស់នៅឡើយ មុនពេលខ្មែរក្រហមមកដល់។ ក្រោយមក គាត់បានឃើញមានគ្រួសារចាម ប៉ុន្តែ ក៏មានគ្រួសារខ្មែរដែរ ដែលមកពីភ្នំពេញ បានទៅរស់នៅអង្គរបាន[1496]។ ពេលខ្លះ ក្នុងចំណោមប្រជាជន មានអ្នកដែល

---

[1493] នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/350.1** ទំព័រ ៣៩ ប្រហែលម៉ោង [១៣.៤៤.៤៩], ម៉ាត់ ស ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/375.1** ទំព័រ ៤ ក្រោយម៉ោង [០៩.១៥.៣២] ទំព័រ ៣២ ក្រោយម៉ោង [១០.៤៨.២១] ទំព័រ ៤០ មុនម៉ោង [១១.១៣.៣៩], កំណត់ហេតុស្តាប់ចម្លើយ ជិ លី ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ **ឯកសារ E3/5290** ERN 00330738, កំណត់ហេតុស្តាប់ចម្លើយ ស្មាន អាត ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨ **ឯកសារ E3/5204** ERN 00218587 (គាត់ និងគ្រួសារ ត្រូវគេបញ្ជូនទៅបារាយណ៍អស់មួយរយៈ ហើយក្រោយមកទៀត ក៏ត្រូវគេបញ្ជូនទៅកំពង់ធំ រហូតដល់ដាច់របបខ្មែរក្រហម), កំណត់ហេតុស្តាប់ចម្លើយ ម៉ាត់ អ៊ីសា ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨ **ឯកសារ E3/5207** ERN 00221864, កំណត់ហេតុស្តាប់ចម្លើយ កើ ណោះ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩ **ឯកសារ E3/5289** ERN 00330754, កំណត់ហេតុស្តាប់ចម្លើយ ស្មាន អាត ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨ **ឯកសារ E3/5204** ERN 00218587, កំណត់ហេតុស្តាប់ចម្លើយ ទូល័ស ស្មាអេល ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៩ **ឯកសារ E3/1678** ERN 00349513, ឯកសារអង្គការលើកលែងទោសអន្តរជាតិ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៧៨ **ឯកសារ E3/4198** ERN 00338194, អ៊ីត សេន ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/342.1** ទំព័រ ៥១ ក្រោយម៉ោង [១៣.៥៦.៤៣], កំណត់ហេតុស្តាប់ចម្លើយ ម៉ាត់ អ៊ីសា ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨ **ឯកសារ E3/5207** ERN 00221864។

[1494] ម៉ាត់ ស ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/375.1** ទំព័រ ១៧ ប្រហែលម៉ោង [០៩.៤៩.៣៨], កំណត់ហេតុស្តាប់ចម្លើយ ជី ថន ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ **ឯកសារ E3/5253** ERN 00235002។

[1495] កំណត់ហេតុស្តាប់ចម្លើយ រៀល នាង ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ **ឯកសារ E3/9652** ស/ឆ ៤ និង ៣១។

[1496] តាយ គឹមហ៊ាន់ ប្រតិចារឹក ថ្ងៃទីចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/348.1** ទំព័រ ២៤ ប្រហែលម៉ោង [១០.៣៥.៥៩] ទំព័រ ៤៦ ប្រហែលម៉ោង [១៣.៤៩.១៧]។

មានសមត្ថភាពជំនាញដែលសហករណ៍ចង់បាន។ មានប្រភពមកពីភូមិកំពង់ក្របី ស្រុកកំពង់សៀម សាក្សី ម៉ាត់ ទូល័ស ដែលជាជនជាតិចាមម្នាក់ដែលត្រូវបានជម្លៀសពីភ្នំពេញ ក្នុងឆ្នាំ ១៩៧៥ បានត្រលប់ទៅកំពង់ចាមវិញ។ ក្រោយពីរស់នៅកំពង់សៀមបានមួយរយៈ គាត់ត្រូវបានបញ្ជូនទៅស្រុកកងមាស ដោយសារតែគាត់មានទេពកោសល្យផ្នែកជាងម៉ាស៊ីន មុននឹងគាត់ចូលក្នុងក្រុមអ្នកនេសាទចាម ក្នុងឆ្នាំ ១៩៧៦[1497]។

១៦២៧. ការផ្លាស់ទីលំនៅប្រជាជនទៅក្នុងកម្រិតមួយដែលមានលក្ខណៈមូលដ្ឋានជាងនេះ គឺស្របគ្នាផងដែរទៅនឹងការរៀបចំកងចល័តស្រុក ឬ កងចល័តតំបន់។ ជាអ្នកស្រុកមកពីភូមិមួយក្នុងឃុំស្វរគង ក្នុងស្រុកកងមាស សាក្សី មុយ វ៉ាន់នី បានជម្រាបប្រាប់តុលាការថា គាត់នៅក្នុងកងចល័តស្រុក ដែលនៅក្នុងកងនោះ មានចាមមកពីភូមិនៅជុំវិញនោះ[1498]។ សាក្សី ម៉ន ប៊ាង មកពីភូមិដំណាក់ជ្រៃ ឃុំពាមជីកង ស្រុកកំពង់សៀម បានប្រាប់អ្នកស៊ើបអង្កេតថាគាត់ជាអតីតប្រធានកងចល័ត ដែលក្នុងនោះមាន "ប្រជាជនថ្មី ប្រជាជនចាស់ និងជនជាតិចាម"[1499]។

១៦២៨. ដូចគ្នានេះដែរ សាក្សី សេង ឃុយ មកពីឃុំអង្គរបាន ស្រុកកងមាស ក៏បានឃើញផងដែរថា ជនជាតិចាមត្រូវបានដាក់ចូលនៅតាមសហករណ៍ ដើម្បីធ្វើស្រែជាមួយជនជាតិខ្មែរ[1500]។ សាក្សី សំរិត មុយ ជាជនជាតិខ្មែរ មកពីឃុំពាមជីកង បានជម្រាបប្រាប់តុលាការថា នៅសម័យខ្មែរក្រហម គាត់រស់នៅក្នុងសហករណ៍ភូមិសាច់ស្វរ ដែលប្រជាជនភាគច្រើនជាចាម[1501]។

១៦២៩. ដូច្នេះ ការផ្លាស់ទីលំនៅប្រជាជន គឺពាក់ព័ន្ធជាមួយប្រជាជនទាំងអស់គ្នា និងពុំមែនតែជនជាតិចាមនោះទេ។ ការណ៍ដែលការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ ត្រូវបានធ្វើឡើងនៅពេលមាន

[1497] កំណត់ហេតុស្តាប់ចម្លើយ ម៉ាត់ ទូល័ស ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ **ឯកសារ E3/9360** ស/ឆ ៧-៨, ១០, ១៣-១៤។

[1498] <u>មុយ វ៉ាន់នី</u> ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/373.1** ទំព័រ ១៤ ប្រហែលម៉ោង [១០.២២.១៥]។

[1499] កំណត់ហេតុស្តាប់ចម្លើយ ម៉ន ប៊ាង ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ **ឯកសារ E3/5529** ស/ឆ ៤។

[1500] <u>សេង ឃុយ</u> ប្រតិចារឹក ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៧ **ឯកសារ E1/344.1** ទំព័រ ៦០ ចាប់ពីម៉ោង [១៤.០៧.៤១]។

[1501] <u>សំរិត មុយ</u> ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/347.1** ទំព័រ ២០-២១ ប្រហែលម៉ោង [១០.០៤.១៤]។ សាក្សីបានបញ្ជាក់ផងដែរថា នៅក្នុងភូមិសំប្តូរមាស ពុំមានជនជាតិចាមនោះទេ៖ ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/347.1** ទំព័រ ៤៩ មុនម៉ោង [១៣.៥៩.០៤]។

ការបះបោររបស់ប្រជាជនចាម ក្នុងភូមិភាគបូព៌ា ពុំអាចដកចេញនូវលក្ខណៈទូទៅ និងគ្មានការរើសអើង ដូចដែលគេធ្លាប់បានឃើញនៅក្នុងសំណុំរឿង ០០២/០១ ឡើយ។

## 2. <u>ការបះបោររបស់ជនជាតិចាមនៅក្នុងភូមិភាគបូព៌ា ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២</u>

### 2.ក. <u>ការបះបោរនៅស្វាយឃ្លាំង</u>

១៦៣០. មានភស្តុតាងបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះថា ការបះបោរមួយចំនួនបានកើតឡើងនៅក្នុងភូមិភាគបូព៌ា ដែលនាពេលនោះ ការបះបោរត្រូវបានគ្រប់គ្រងដោយកម្លាំងយោធារបស់ភូមិភាគមួយនេះ[1502]។ សាក្សី មាស សឿន ជាកូនប្រុសរបស់ ចាន់ សេងហុង លេខាតំបន់២១ ហើយក្រោយមកជាអនុប្រធានភូមិភាគបូព៌ា បាននិយាយពីការបះបោរជនជាតិចាមនៅស្វាយឃ្លាំង[1503]។ គាត់បានបន្ថែមថា ក្រោយមកជនជាតិចាមទាំងអស់ត្រូវបាន "បញ្ជូនទៅស្រុកតំបែរ" ប៉ុន្តែ សាក្សីបានបញ្ជាក់ថា"ជាទូទៅនៅក្នុងតំបន់ភូមិភាគបូព៌ាទាំងមូល មានការជម្លៀសទាំងអស់តាំងពីឆ្នាំ ១៩៧៥ ក្រោយ ១៧ មេសា ១៩៧៥ [...]"[1504]។

១៦៣១. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានណែនាំខ្លួនឯងថាជាមេដឹកនាំម្នាក់ក្នុងការបះបោរនៅស្វាយឃ្លាំង កាលពីខែ តុលា ឆ្នាំ ១៩៧៥ ហើយគាត់គិតថាការបះបោរនេះកើតឡើង ១៥ ថ្ងៃ ក្រោយពីមានការបះបោរនៅកោះផល ហើយការបះបោរនៅទ្រា កើតឡើងមុនខែ វិច្ឆិកា ឆ្នាំ ១៩៧៥។ ការ

[1502] <u>នោ សាទុះ</u>៖ ឯកសារ **E1/351.1** ទំព័រ ៩ ក្រោយម៉ោង 09.27.13 (កងទ័ពមានថ្នាក់ផ្សេងៗ ដូចជា យោធាស្រុក ឃុំ និងឈ្លបភូមិ), <u>សុះ រ៉លី</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/372.1** ទំព័រ ៥១ ក្រោយម៉ោង 14.02.51 (យោធាតំបន់), កំណត់ហេតុស្តាប់ចម្លើយ សូ សីម៉ុច ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៨ឯកសារ **E3/5261**, ERN KH 00250943 (កងវរសេនាតូច ៥៥ នៃភូមិភាគបូព៌ា), សៀវភៅរបស់ Ben KIERNAN *"អំពើប្រល័យពូជសាសន៍នៅកម្ពុជា ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩៖ ពូជសាសន៍ មនោគមន៍វិជ្ជា និងអំណាច"* ឆ្នាំ ១៩៩៦ ឯកសារ **E3/1593** ទំព័រ 321, ERN KH 00637770។

[1503] <u>មាស សឿន</u>៖ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ឯកសារ **E1/446.1** ទំព័រ ១៧ មុនម៉ោង 09.53.36 ទំព័រ ៦២ មុនម៉ោង 15.17.17, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ឯកសារ **E3/5531** សំណួរ/ចម្លើយទី ៥២។

[1504] <u>មាស សឿន</u>៖ ប្រតិចារឹក ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ឯកសារ **E1/447.1** ទំព័រ ២០ ក្រោយម៉ោង 10.12.31។

បង្ក្រាបការបះបោរនៅស្វាយឃ្លាំង បានចំណាយពេលអស់មួយថ្ងៃមួយយប់[1505]។ សុះ មីន បាន ពន្យល់ថាខ្លួនគាត់ត្រូវបានគេចាប់ឃុំឃាំងអស់ ២៩ ថ្ងៃ ក្នុងសាលាមួយ មុននឹងគាត់ទទួលបញ្ជាឱ្យ ចាកចេញពីភូមិ[1506]។

១៦៣២. គេត្រូវកត់សម្គាល់ថា ក្នុងរឿងរ៉ាវប្រកបដោយគំរូវីរភាពនៃការបះបោរនេះ សុះ មីន បានផ្តល់សារៈសំខាន់ឱ្យខ្លួនឯង ដោយបានតាំងខ្លួនជាមេដឹកនាំម្នាក់ក្នុងចលនានេះ។ ក៏ប៉ុន្តែ សក្ខីកម្ម ផ្សេងៗទៀត បានបង្ហាញឱ្យឃើញថា គឺ ឡិប បាន់ម៉ាត់ ទៅវិញទេ ដែលជាមេដឹកនាំចលនាបះបោរនេះ តែសព្វថ្ងៃនេះ គាត់បានស្លាប់បាត់ទៅហើយ[1507]។ ហេតុដូច្នេះ សក្ខីកម្មរបស់ សុះ មីន ទាក់ទងនឹងការប្រើប្រាស់ទារុណកម្មក្នុងអំឡុងពេលសួរចម្លើយមនុស្ស ទំនងជាអាចជឿជាក់បានតិចតួចបំផុត ព្រោះថាសាក្សីផ្សេងទៀតបាននិយាយផ្ទុយពីនេះ[1508]។

១៦៣៣. ក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួន សាក្សី ម៉ាន ស៊ើន ជាបងប្រុសរបស់ សុះ មីន បានអះអាងថាការសួរចម្លើយត្រូវធ្វើឡើង "[ដើម្បី]សួររកមេដឹកនាំបះបោរ" និងអ្នកដែលធ្វើការក្នុងសង្គមចាស់[1509]។ ក្នុងចំណោមមេដឹកនាំទាំងប្រាំពីរនាក់ក្នុងក្រុមបះបោរ មនុស្សមួយចំនួននៅរស់រានមានជីវិត ដែលនេះវាបង្ហាញឱ្យឃើញថា ពុំមានភាពចាំបាច់ក្នុងការរៀបចំផែនការកម្ចាត់ជនជាតិចាម

---

[1505] <u>សុះ មីន</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/343.1** ទំព័រ ៨៤ មុនម៉ោង 16.02.55, ប្រតិចារឹក ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/344.1** ទំព័រ ២០ ក្រោយម៉ោង 10.02.32 ទំព័រ ២២ ក្រោយម៉ោង 10.08.22។

[1506] <u>អ៊ុត សេន</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/343.1** ទំព័រ ៧១ មុនម៉ោង 15.18.35។

[1507] កំណត់ហេតុស្តាប់ចម្លើយ ម៉ាន ស៊ើន ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ **E3/5205**, ERN KH 00221849, សៀវភៅរបស់ អ៊ីសា ឧស្មាន *ការបះបោររបស់ជនជាតិចាម* ឆ្នាំ ២០០៦ឯកសារ **E3/2653** ទំព័រ ១៣១ ERN KH 00904326។

[1508] <u>សុះ មីន</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/343.1** ទំព័រ ៦៥ មុនម៉ោង 14.44.54, កំណត់ហេតុស្តាប់ចម្លើយ ម៉ាន ស៊ើន ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ឯកសារ **E3/5205**, ERN KH 00221850 ("ខ្ញុំមិនបានរងទារុណកម្មអ្វីទេ"), កំណត់ហេតុស្តាប់ចម្លើយ តេះ ស្រ៊េន ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ឯកសារ **E3/5206**, ERN KH 00221890, កំណត់ហេតុស្តាប់ចម្លើយ ស្មាន អាត ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨ឯកសារ **E3/5204**, ERN KH 00218586 (ការបះបោរនៅកោះផល៖ "ប្រជាជនទាំងអស់ ដែលរួចជីវិត [...] ត្រូវបានគេដឹកតាមកាណូតទៅរការខ្មុរ ដើម្បីសួរចម្លើយរយៈពេលពីរថ្ងៃ។ ពួកគេចង់រកអ្នកណាជាមេខ្លោងបះបោរ។ គេមិនធ្វើទារុណកម្មយើងទេ ហើយគេក៏មិនបានវាយដំអ្នកណាដែរ")។

[1509] កំណត់ហេតុស្តាប់ចម្លើយ ម៉ាន ស៊ើន ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ឯកសារ **E3/5205**, ERN KH 00221850។

ឡើយ ទោះបីជាអ្នកបះបោរក៏ដោយ[1510]។ ក្រោយពីជាប់ឃុំឃាំងរួច ពួកគេត្រូវបានបញ្ជូនទៅកាន់ស្រុកតំបែរ ក្នុងខេត្តកំពង់ចាម[1511]។ ជនជាតិចាមម្នាក់ផ្សេងទៀត គឺ តេះ ស្រ៊េន ជាប្រជាជនភូមិ៥ ឃុំស្វាយឃ្លាំង ដូច សុះ មីន ដែរ បានពន្យល់ប្រាប់អ្នកស៊ើបអង្កេតថា ក្រោយពីជាប់ឃុំឃាំងបានមួយខែមក គាត់ត្រូវបានដោះលែង ហើយបន្ទាប់មក គាត់បានទៅជួបជុំប្រពន្ធ និងកូនៗរបស់គាត់នៅវត្តក្រូចឆ្មារ មុននឹងគេបញ្ជូនគាត់ទៅបន្ទាយជ័យ[1512]។

១៦៣៤. បើទោះជា សុះ មីន បានពន្យល់ថា ពុំមែនតែជនជាតិចាមទេដែលត្រូវបានផ្លាស់ទីលំនៅក៏ដោយ ក៏គាត់បាននិយាយផងដែរថា មានជនជាតិខ្មែរតិចតួចបំផុតក្នុងភូមិទាំងបី ក្នុងឃុំរបស់គាត់[1513]។

១៦៣៥. សាក្សី សូវ ញឹត ជាជនជាតិខ្មែរនៅភូមិ៤ ជាប់គ្នានឹងភូមិរបស់ សុះ មីន បានពន្យល់ប្រាប់អ្នកស៊ើបអង្កេតថា ក្រុមគ្រួសាររបស់គាត់ក៏ត្រូវបានជម្លៀសដែរ។ គាត់ថែមទាំងបានរិះគន់អកប្បកិរិយារបស់កម្មាភិបាលភូមិ ជាពិសេសគឺទាក់ទងនឹងការជ្រើសរើសតាមទំនើងចិត្តនូវមនុស្សដែលត្រូវជម្លៀស[1514]។ ដូច្នេះ ដូចដែលបានបញ្ជាក់ខាងលើ ការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ គឺពាក់ព័ន្ធប្រជាជនទាំងអស់។

---

[1510] <u>សុះ មីន</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/343.1** ទំព័រ ៦៦ ក្រោយម៉ោង 14.48.43, កំណត់ហេតុស្តាប់ចម្លើយ ម៉ាន សេីន ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ឯកសារ **E3/5205**, ERN KH 00221849។

[1511] <u>សុះ មីន</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៥៦ ក្រោយម៉ោង 14.11.43 ទំព័រ ៧១ ក្រោយម៉ោង 15.18.35។

[1512]កំណត់ហេតុស្តាប់ចម្លើយ តេះ ស្រ៊េន ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ឯកសារ **E3/5206**, ERN KH 00221891។

[1513] <u>សុះ មីន</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/343.1** ទំព័រ ៧២ ក្រោយម៉ោង 15.21.28, ប្រតិចារឹក ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/344.1** ទំព័រ ៤៧ មុនម៉ោង 11.49.24 ("ក្នុងចំណោមភូមិទី ៥ ភូមិទី ៦ និងភូមិទី ៧ មានតែភូមិទី ៧ ទេ ដែលមានបងប្អូនខ្មែររស់នៅចម្រុះគ្នាជាមួយចាម ឯចំណែកភូមិទី ៥ និងភូមិទី ៦ ចាមសុទ្ធ"។

[1514] កំណត់ហេតុស្តាប់ចម្លើយ សូវ ញឹត ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨ឯកសារ **E3/5208**, ERN KH 00218545 ("ការសម្រេចជ្រើសរើសជម្លៀសអ្នកភូមិ គឺធ្វើឡើងដោយសម្ងាត់។ គេប្រាប់យើងថា គេឲ្យទៅភូមិសោយ ប៉ុន្តែពេលដែលយើងបររទេះដល់ពាក់កណ្តាលផ្លូវ មេកងធំនៅភូមិ ២ ក្នុងឃុំស្វាយឃ្លាំងក៏បានឃាត់យើងនៅទីនោះ ហើយក៏បានឲ្យចូលធ្វើការងារក្នុងសហករណ៍ រហូតដល់ឆ្នាំ ១៩៧៨")។

១៦៣៦. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ដែលជាប្រជាជនរស់នៅភូមិស្វាយឃ្លាំង ដូច សុះ មីន ដែរ បានឱ្យដឹងថា ក្រោយការបះបោរក្នុងភូមិរបស់គាត់រួចមក ចាមទាំងអស់ត្រូវ "ចេញ"[1515]។ គាត់បានពន្យល់ថា មូលហេតុនៃការចាប់ខ្លួនអ្នកភូមិជនជាតិចាម គឺដោយសារតែមានការចោទប្រកាន់ថា ពួកគេជាសមាជិកចលនាខ្មែរស ឬក៏ជាសេ.អ៊ី.អា ដែលត្រូវគេចាត់ទុកថាជាមូលហេតុនាំឱ្យមានការបះបោរនៅស្វាយឃ្លាំង[1516]។

១៦៣៧. គេគួរកត់សម្គាល់ថា គ្មានការយោងណាមួយទៅលើសាសនារបស់ "អ្នកបះបោរ" ឡើយ ប៉ុន្តែគេបានយោងទៅលើសកម្មភាពបំផ្លិចបំផ្លាញរបស់ពួកគេ។ ក្រោយការបង្ក្រាប អ្នកដែលមិនព្រមចាកចេញពីភូមិ ត្រូវបានមេស្រុក ឬក៏មេឃុំ ចោទថាជាខ្មាំង ឬ ជាភ្នាក់ងារសេ.អ៊ី.អា[1517]។

១៦៣៨. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ដដែលនេះបានឱ្យដឹងថា មនុស្សត្រូវបានចាប់ឃុំឃាំងក្នុងគោលបំណងកំណត់អត្តសញ្ញាណខ្មាំង និងហានិភ័យបង្កឱ្យមានការបះបោរ។ គាត់បានបញ្ជាក់ថា ទាហានពុំបានធ្វើបាបគាត់ឡើយ[1518]។ អ្នកដែលត្រូវបានចាត់ទុកថាគ្មានទំនាក់ទំនងជាមួយសេ.អ៊ី.អា អាចត្រលប់ទៅជួបជុំគ្រួសារវិញបាន។ ដូច្នេះ ចំណុចត្រង់នេះពិតជាដូចគ្នា គឺថាសាសនាពុំមែនជាគោលដៅនៃការឃុំខ្លួនឡើយ។ ចំណែកស្ត្រីដែលប្តីត្រូវបាននាំទៅ ត្រូវបានដោះលែង និងបញ្ជូនឱ្យទៅរស់នៅតាមច្រាំងទន្លេ ដូចករណីគ្រួសាររបស់គាត់ផ្ទាល់ដែលត្រូវបានគេបញ្ជូនទៅនៅភូមិខ្សាច់ប្រឆេះលើ[1519]។

**2.១. <u>ការបះបោរនៅកោះផល</u>**

---

[1515] <u>នោ សាទះ</u>៖ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/351.1** ទំព័រ ៩ មុនម៉ោង 09.27.13។

[1516] <u>នោ សាទះ</u>៖ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/351.1** ទំព័រ ៥ ក្រោយម៉ោង 09.13.16។

[1517] <u>នោ សាទះ</u>៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/350.1** ទំព័រ ៦៤ ក្រោយម៉ោង 15.42.37, ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៩ មុនម៉ោង 09.27.13 ទំព័រ ២៦ មុនម៉ោង 10.46.18 ទំព័រ ២៦ ក្រោយម៉ោង 10.48.35 ទំព័រ ២៧ មុនម៉ោង 10.51.50។

[1518] <u>នោ សាទះ</u>៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/350.1** ទំព័រ ៤១ ក្រោយម៉ោង 13.51.30។

[1519] <u>នោ សាទះ</u>៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/350.1** ទំព័រ ៤១ មុនម៉ោង 13.56.50, ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ១១ ក្រោយម៉ោង 09.35.03។

១៦៣៩. សាក្សី អ៊ីត សេន ជាអ្នកភូមិសោយ ជាប់គ្នានឹងកោះផល បានជម្រាបជូនតុលាការអំពីការបង្ក្រាបរបស់ទាហានស្រុក ក្រោយមានការបះបោរ។ បងថ្លៃរបស់គាត់បានប្រាប់គាត់ថា អ្នកដែលប្រឆាំងនឹងអង្គការ ត្រូវបានកម្ទេច ហើយអ្នកដែលមិនប្រឆាំង ខ្មែរក្រហមមិនធ្វើអ្វីពួកគេឡើយ[1520]។ ជាថ្មីម្តងទៀត គេអាចកត់សម្គាល់ថា ការបង្ក្រាបពុំមានគោលដៅលើសាសនាឡើយ តែសំដៅលើការប្រឆាំងនឹងរបបនេះ។

១៦៤០. សាក្សី អ៊ីត សេន បានឱ្យដឹងថា ប្រហែលក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៥ អ្នកភូមិប្រហែលពាក់កណ្តាល ក្នុងនោះមានគាត់ និងគ្រួសារផង ត្រូវបានគេបញ្ជូនទៅបាត់ដំបង ហើយអ្នកផ្សេងទៀត ត្រូវទៅស្ទឹងត្រង់ ឬក៏ក្រចេះ។ អ្នកភូមិពាក់កណ្តាលទៀត អាចបន្តនៅក្នុងភូមិដដែល ក្នុងនោះមានគ្រួសារបងស្រីគាត់ឈ្មោះ អាហ្សៀស ផងដែរ។ ស្របគ្នាទៅនឹងការពន្យល់ប្រាប់ទៅ សុះ រំលី ដូចគ្នាដែរ គេបានប្រាប់សាក្សី អ៊ីត សេន ថា ភូមិនៅក្នុងស្រុក មានមនុស្សចង្អៀត ខណៈដែលនៅបាត់ដំបងមានដីមានជីជាតិច្រើន[1521]។ នៅទីនេះ គេបានឃើញឡើងវិញពីមូលហេតុចម្បងនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ នៅកន្លែងផ្សេងទៀត។

១៦៤១. បើទោះជាសាក្សី អ៊ីត សេន បញ្ជាក់ថា មានតែជនជាតិចាមប៉ុណ្ណោះដែលត្រូវជម្លៀសក៏ដោយ ក៏គាត់ពុំមានលទ្ធភាពប្រាប់ពីចំនួនចាមទាំងអស់នោះ ដោយគាត់គ្រាន់តែពន្យល់ថាមាន "ប្រហែលជាជិត ១០០ ទូក" ដឹកមនុស្សពេញៗ[1522]។ ហេតុដូច្នេះ ដោយសារតែគាត់ពុំដឹងថាមនុស្សដែលត្រូវដាក់ឡើងលើទូកនីមួយៗក្នុងចំណោមទូកដ៏ច្រើនទាំងអស់ ជាអ្នកណាខ្លះនោះ ការអះអាងរបស់គាត់ដែលថាការជម្លៀសពាក់ព័ន្ធតែប្រជាជនចាម គឺគ្រាន់តែជាការស្មានៗប៉ុណ្ណោះ។ម្យ៉ាងវិញទៀត ការណ៍ដែលគាត់ត្រូវបានបញ្ជូនទៅព្រែកអាជី គឺដោយសារតែមនុស្សដែលត្រូវបញ្ជូនទៅបាត់ដំបងមានចំនួនច្រើនពេក[1523]។ ចំណុចនេះ នៅតែគាំទ្រដល់ការប្រព្រឹត្តទៅនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ គឺក្នុងគោលបំណងឱ្យមានការបែងចែកប្រជាជនក្នុងប្រទេស ឱ្យបានល្អប្រសើរ។

---

1520 អ៊ីត សេន៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ E1/342.1 ទំព័រ ៥០-៥១ ក្រោយម៉ោង 13.54.11។

1521 អ៊ីត សេន៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/342.1 ទំព័រ ៥១ ក្រោយម៉ោង 13.56.43 ទំព័រ ៥៣ ក្រោយម៉ោង 14.03.23, ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/343.1 ទំព័រ ៣០ ក្រោយម៉ោង 10.40.12 ទំព័រ ៣៣ មុនម៉ោង 10.53.11។

1522 អ៊ីត សេន៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/342.1 ទំព័រ ៥២ មុនម៉ោង 14.03.23។

1523 អ៊ីត សេន៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/342.1 ទំព័រ ៥៣ ក្រោយម៉ោង 14.05.33។

## 2.គ. ស្ថានភាពនៅជំនីក

១៦៤២. នៅក្នុងអំឡុងពេលសវនាការ សាក្សី វ៉ាន់ ម៉ាត់ បានពន្យល់ថា ទោះបីជាមានការបះបោរយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមពុំបានធ្វើអ្វីចំពោះប្រជាជនឃុំជំនីក ស្រុកក្រូចឆ្មារ ដែលជាកន្លែងគាត់ស្នាក់នៅឡើយ[1524]។ គាត់បានបញ្ជាក់ថា ទោះជាអ្នកភូមិក្នុងឃុំជំនីក និងស្រុកផ្លូង មួយចំនួនត្រូវបានបញ្ជូនទៅខេត្តកំពង់ធំ ក្នុងឆ្នាំ ១៩៧៦ ក៏ដោយ ក៏មានអ្នកភូមិជាច្រើនផ្សេងទៀត ដូចករណីរបស់គាត់ និងគ្រួសារ ពុំធ្លាប់ដែលត្រូវបានជម្លៀសទៅណានោះឡើយ ហើយពួកគេបានបន្តរស់នៅក្នុងភូមិរហូតដល់ដាច់របបខ្មែរក្រហម[1525]។

១៦៤៣. លោក អ៊ីសា ឧស្មាន យល់ឃើញថា ការជម្លៀសក្នុងខែ វិច្ឆិកា និងខែ ធ្នូ ឆ្នាំ ១៩៧៥ នេះ ពាក់ព័ន្ធតែជនជាតិចាមផ្លាស់ទីលំនៅ ដោយសារតែការបះបោរ ប៉ុណ្ណោះ។ បើតាមលោកអ្នកជំនាញរូបនេះ ខ្មែរក្រហមមិនចង់ឱ្យប្រជាជនចាមរស់នៅជាសហគមន៍ គឺដើម្បីចៀសវាងកុំឱ្យមានការបះបោរឡើងទៀត។ ការដាក់ឱ្យប្រជាជនជាតិចាមនៅរាយប៉ាយតាមកន្លែងផ្សេងៗគ្នា គឺដើម្បីធានាកុំឱ្យមានការបះបោរសាជាថ្មី ទន្ទឹមនឹងនោះដែរ វាក៏មានភាពងាយស្រួលក្នុងការតាមដានពួកគេ[1526]។

១៦៤៤. ក៏ប៉ុន្តែ ដូចដែលបានឃើញពីខាងលើរួចមកហើយថា ផ្ទុយពីសេចក្ដីសន្និដ្ឋានបែបលម្អៀងនេះ ផែនការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ ពុំមែនត្រឹមតែកើតឡើងមុនពេលមានការបះបោរទេ តែលើសពីនេះទៅទៀត ទាំងជនជាតិខ្មែរ ទាំងជនជាតិចាម ត្រូវបានគេជម្លៀសទៅកាន់កន្លែងផ្សេងៗក្នុងប្រទេស។ ការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ ត្រូវបានធ្វើឡើងស្របតាមសេចក្ដីសម្រេចជម្លៀសដែលត្រូវបានធ្វើឡើងដោយផ្អែកលើមូលហេតុសេដ្ឋកិច្ច ហើយវាពាក់ព័ន្ធប្រជាជនទាំងអស់។ ការណ៍ដែលខ្មែរក្រហមក្នុងភូមិភាគបូព៌ា ចាត់ទុកថាការផ្លាស់ទីលំនៅនេះបាន

---

[1524] <u>វ៉ាន់ ម៉ាត់</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/398.1** ទំព័រ ១៤ ក្រោយម៉ោង 09.50.44។

[1525] <u>វ៉ាន់ ម៉ាត់</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/398.1** ទំព័រ ១៤ ចន្លោះម៉ោង 09.50.04 ដល់ម៉ោង 09.54.40 ទំព័រ ១៦ ប្រហែលម៉ោង 09.56.24។

[1526] <u>អ៊ីសា ឧស្មាន</u>៖ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ឯកសារ **E1/408.1** ទំព័រ ២០ ក្រោយម៉ោង 10.06.34។

ចូលរួមធ្វើឱ្យស្ថានភាពបះបោរ "ស្ងប់ស្ងាត់" គឺវាគ្រាន់តែជាផលវិបាកបន្ទាប់បន្សំប៉ុណ្ណោះ និងពុំមែនជាមូលហេតុដើមឡើយ។

## ២. គ្មានការរើសអើងប្រឆាំងជនជាតិចាម

១៦៤៥. យោងតាមសក្ខីកម្មនានា ក្នុងការរៀបចំសង្គមសាជាថ្មី ប្រជាជនចាម និងប្រជាជនខ្មែរ គឺត្រូវរស់ក្នុងល័ក្ខខ័ណ្ឌដូចគ្នា នៅក្នុងភូមិភាគបូព៌ា និងភូមិភាគកណ្តាល ទោះជាក្នុងជីវភាពប្រចាំថ្ងៃក្តី (១) ឬក៏ប្រឈមនឹងការហាមឃាត់ការប្រតិបត្តិសាសនាក្តី (២)។

១៦៤៦. ក្នុងឯកសារយោងខាងលើ ដែលចុះកាលបរិច្ឆេទខែ កញ្ញា ឆ្នាំ ១៩៧៥ ការរៀបចំទទួលប្រជាជននៅតាមភូមិភាគខ្លះ ត្រូវបានលើកឡើង។ គឺត្រូវយកចិត្តទុកដាក់នឹងជីវភាពប្រជាជន ដោយមិនត្រូវគិតទុកនូវការរើសអើងណាមួយចំពោះជនជាតិចាម ឬក៏ជាតិពន្ធុណាមួយផ្សេងទៀត[1527]។

១៦៤៧. ដូចគ្នានេះដែរ កំណត់ហេតុទស្សនកិច្ចរបស់គណៈកម្មាធិការមជ្ឈិម ចុះកាលបរិច្ឆេទខែ សីហា ឆ្នាំ ១៩៧៥ បានបង្ហាញពីការទទួលប្រជាជនថ្មី និងកម្លាំងថ្មី ដែលត្រូវ "ហ្វឹកហ្វឺនអប់រំ [...] កុំឱ្យខ្មាំងធ្វើសកម្មភាព (*sic*) នាំរត់" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[1528]។

---

[1527] ឯកសារ ចុះខែ កញ្ញា ឆ្នាំ ១៩៧៥ ឯកសារ **E3/781**, ERN KH 00072397៖ "យើងត្រូវរៀបចំផ្ទះសម្បែងបណ្តើរៗ ធ្វើជាឥដ្ឋ ស៊ីម៉ង់ត៍។ ដូច្នេះ ត្រូវដុតឥដ្ឋ ក្បឿង ដើម្បីសម្រាប់សង់ផ្ទះ ឃ្លាំង និងរោងចក្រ [...]។ ឧទាហរណ៍៖ បាញ់ចម្ការកៅស៊ូ តាមភូមិដែលមានព្រៃឈើ ហើយគ្រុនចាញ់ជាងគេ។ ពេលបាញ់ យើងនឹងចាប់ផ្តើមពីឆ្នាំ ១៩៧៦ នេះទៅ [...]។ ស្នើឱ្យភូមិភាគរៀបចំគម្រោងការបាញ់នេះ ដោយមានចាត់តាំងឱ្យច្បាស់លាស់។ សព្វថ្ងៃ មានជំងឺគ្រុនចាញ់នេះច្រើនណាស់ យើងត្រូវការព្យាបាលដោយម្យ៉ាង ព្យាបាលដោយថ្នាំ និងម្យ៉ាងទៀត កម្ចាត់មូស។ [...] មណ្ឌលកុមារត្រូវយើងរៀបចំថ្ងៃក្រោយ ដើម្បីរំដោះកម្លាំងនារី [...]។

[1528] កំណត់ហេតុអំពីទស្សនកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ ឯកសារ **E3/216**, ERN KH 00008493។

## 1. ស្ថានភាពរស់នៅរបស់ប្រជាជនជាតិចាមនៅក្នុងភូមិភាគបូព៌ា និងភូមិភាគកណ្ដាល

### 1.ក. ស្ថានភាពរស់នៅក្នុងភូមិភាគបូព៌ា ក្រោយការបះបោរ

១៦៤៨. អ៊ីត សេន បានឱ្យដឹងថា នៅពេលទៅដល់ភូមិថ្មី ជនជាតិចាមត្រូវបានដាក់ឱ្យរស់នៅតាមផ្ទះរបស់ប្រជាជនខ្មែរ។ នៅព្រៃកអាជី ដែលជាភូមិថ្មីរបស់គាត់ អ៊ីត សេន បាននិយាយថា មេភូមិ និងកម្មាភិបាលមូលដ្ឋាន "ពុំបានធ្វើអ្វីពួកគាត់" ឡើយ។ នៅពេលគាត់នៅទីនោះរហូតដល់ពាក់កណ្ដាលឆ្នាំ ១៩៧៨ គាត់ពុំដែលឮគេនិយាយពីការសម្លាប់មនុស្សឡើយ[1529]។

១៦៤៩. សាក្សី ម៉ាត់ ស បានពន្យល់ថា ក្រុមគ្រួសាររបស់គាត់ត្រូវបានជម្លៀសពីភូមិខ្សាច់ប្រឆេះកណ្ដាល ទៅនៅភូមិក្រូចឆ្មារក្រោម ក្នុងស្រុកដដែល។ គ្រួសាររស់នៅជួបជុំគ្នា រីឯយុវជន ត្រូវធ្វើការនៅកងចល័ត[1530]។

១៦៥០. ដើមបណ្ដឹងរដ្ឋប្បវេណី សុះ មីន ដែលត្រូវបានជម្លៀសពីស្វាយកាំបិត ស្រុកតំបែរ បានពន្យល់ថា គាត់បានរស់នៅជាមួយជនជាតិខ្មែរ[1531] ហើយគាត់ត្រូវបានគេចាត់ទុកថាជាប្រជាជនថ្មី ដោយមានឋានៈដូចគ្នានឹងប្រជាជនថ្មីដែរ[1532]។ ទោះបីជាដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានលើកឡើងពីការបាត់បង់ជីវិតមនុស្សក្នុងសហគមន៍ចាម ដោយសារតែភាពអត់ឃ្លាន និងបណ្ដាលមកពីមូលហេតុផ្សេងទៀត ដូចជាជំងឺគ្រុនចាញ់ ក៏ដោយ ក៏គាត់ត្រូវបានគេដាក់ឱ្យស្ថិតក្នុងស្ថានភាពដូចគ្នានឹងប្រជាជនដទៃទៀតដែរ។ សុះ មីន ដែលពុំធ្លាប់ឃើញការសម្លាប់មនុស្សម្ដងសោះ ធ្លាប់បានឃើញ

---

[1529] អ៊ីត សេន៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/342.1** ទំព័រ ៥៣ ក្រោយម៉ោង 14.05.33 ("ឱ្យនៅជាមួយបងប្អូនខ្មែរគ្រប់ផ្ទះ ដាក់មួយគ្រួសារ ដាក់ជាមួយបងប្អូនខ្មែរ ផ្ទះមួយគ្រួសារ ១ គ្រប់ផ្ទះ លាយគ្នាទៅ ក៏ច្រឡំគ្នា") ទំព័រ ៥៤ មុនម៉ោង 14.08.54 ("បើយើងចង់ទៅ ទៅ បើចង់នៅ នៅ។ គេអត់ឃាត់ទេ", ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៣១ ក្រោយម៉ោង 10.43.10 ទំព័រ ៤០ ក្រោយម៉ោង 11.15.03។

[1530] ម៉ាត់ ស៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/375.1** ទំព័រ ៤១ មុនម៉ោង 11.13.36។

[1531] សុះ មីន៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/343.1** ទំព័រ ៧៤ ក្រោយម៉ោង 15.28.40។

[1532] សុះ មីន៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/343.1** ទំព័រ ៧៥ ក្រោយម៉ោង 15.30.47។ សូមមើលផងដែរ អ៊ីសា ឧស្មាន៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ឯកសារ **E1/388.1** ទំព័រ ៥០ មុនម៉ោង 14.20.58 ("អ៊ីចឹង ស្ថានភាពសម្រាប់ជនជាតិចាមគ្រប់កន្លែងទាំងអស់ មិនខុសពីស្ថានភាពប្រជាជនខ្មែរទូទៅដែលត្រូវគេជម្លៀសចេញពីទីក្រុងទេ"។

តែការចាប់ខ្លួនជនជាតិខ្មែរដែលត្រូវបានចោទថាមានខ្លួនជាខ្មែរ តែក្បាលវៀតណាម ហើយគាត់ពុំដែលបានឃើញការចាប់ខ្លួនជនជាតិចាមម្តងណាឡើយ[1533]។

១៦៥១. ក្រោយការបះបោរឆ្នាំ ១៩៧៥ សាក្សី ជិ លី ដែលមានដើមកំណើតនៅកោះផល ត្រូវបានជម្លៀសចេញពីភូមិក្របីគ្រៀក។ គាត់បានប្រាប់អ្នកស៊ើបអង្កេតថា ជនជាតិចាមនៅក្នុងភូមិនេះ រស់នៅក្នុងស្ថានភាពដូចគ្នានឹងប្រជាជនធម្មតា លាយឡំជាមួយអ្នកភូមិ អាស្រ័យទៅតាមទំហំគ្រួសារ។ ការហូបបាយរួម បានចាប់ផ្តើមពីឆ្នាំ ១៩៧៦ ទៅ ហើយប្រជាជនទាំងអស់ទទួលបានរបបអាហារ និងមានសិទ្ធិដូចគ្នា។ ទោះបីជាគាត់បានកត់សម្គាល់ថាមានមនុស្សស្លាប់ដោយសារជំងឺគ្រុនចាញ់ ក្នុងចំណោមអ្នកដែលមកពីកោះផល ក៏ដោយ ក៏អ្នកភូមិគ្រប់ជាតិពន្ធុទាំងអស់លាយឡំគ្នា បានទទួលរងផលប៉ះពាល់ពីជំងឺនេះដូចគ្នា[1534]។

១៦៥២. សាក្សី តេះ ស្រ៊ែន ជាប្រជាជនរស់នៅភូមិ៥ ឃុំស្វាយឃ្លាំង បានពន្យល់ប្រាប់ថា ក្រោយគាត់ត្រូវបានជម្លៀសរួចមក ស្ថានភាពរស់នៅនៅបន្ទាយជ័យ ស្រុកតំបែរ ភូមិភាគបូព៌ា មានលក្ខណៈល្អប្រសើរ។ ទោះយ៉ាងណាក៏ដោយ គាត់បានបញ្ជាក់ថា "មានមនុស្សតែម្នាក់ដែលត្រូវបានគេចាប់ខ្លួន ហើយក៏បាត់រហូត ប៉ុន្តែអ្នកផ្សេងទៀតស្លាប់ដោយសារជំងឺគ្រុនចាញ់ និងការប្រើថ្នាំព្យាបាលមិនត្រឹមត្រូវ"[1535]។ ស្ថានភាពរស់នៅ និងការងារ ដែលគាត់បានរៀបរាប់ប្រាប់អ្នកស៊ើបអង្កេត មិនខុសគ្នាពីអ្វីដែលប្រជាជនផ្សេងទៀតបានឆ្លងកាត់ នោះឡើយ។

## 1.១. ស្ថានភាពរស់នៅក្នុងភូមិភាគកណ្តាល

---

[1533] ស្មុះ មីនះ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/343.1** ទំព័រ ៧៦ មុនម៉ោង 15.36.26, ប្រតិចារឹក ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/344.1** ទំព័រ ៥ ប្រហែលម៉ោង 09.09.37។

[1534] កំណត់ហេតុស្តាប់ចម្លើយ ជិ លី ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ឯកសារ **E3/5290**, ERN KH 00330738។

[1535] កំណត់ហេតុស្តាប់ចម្លើយ តេះ ស្រ៊ែន ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ឯកសារ **E3/5206**, ERN KH 00221891។

១៦៥៣. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ដែលមកពីភូមិសាច់សូរ ឃុំពាមជីកង បានឱ្យដឹងថា ចំពោះខ្មែរក្រហម "គ្មានចាមគ្មានអីទៀតទេ មានតែខ្មែរតែមួយ"[1536]។ គាត់បានរៀបរាប់ពីការចាត់តាំងភូមិរបស់ពួកខ្មែរក្រហម ដូច្នេះថា៖

> "ខ្មែរក្រហមចាត់តាំងឱ្យខ្មែរយើងហ្នឹងចូលទៅនៅភូមិចម្រុះគ្នាបាទ។ ចម្រុះចាមខ្មែរ នៅចម្រុះគ្នាបាទ ហើយនៅចម្រុះគ្នាអ៊ីចឹងទៅ គេហៅថាគ្មានចាមគ្មានអីទៀតទេ មានតែខ្មែរមួយបាទ"[1537]។

១៦៥៤. ក្នុងអំឡុងពេលសវនាការ សាក្សី សេង ឃុយ បានអះអាងថា៖ "[...] ខ្មែរយើងធ្វើការយ៉ាងម៉េចរបៀបរបបម៉េច គឺសម្របខ្លួនតាមខ្មែរយើងទាំងអស់តែម្ដង"[1538]។

១៦៥៥. សាក្សី សេង ស្រ៊ុន ថ្លែងថា នៅឆ្នាំ ១៩៧៦ ជនជាតិចាមដែលមកទល់ពេលនោះ រស់នៅភាគច្រើនក្នុងភូមិសាច់សូរ "[...] ត្រូវគេបំបែកឱ្យមកនៅលាយឡំជាមួយបងប្អូនខ្មែរ តាមភូមិនីមួយៗហ្នឹង [...] ហើយ [...] គេឱ្យស្លៀកពាក់ធម្មតា ដូចខ្មែរយើងអ៊ីចឹង"[1539]។ គឺក្នុងរបៀបនេះហើយដែលប្រជាជនចាមជាង ២០ គ្រួសារ មកពីឃុំពាមជីកងដូចគ្នា បានមករស់នៅក្នុងភូមិសំបួរមាសរបស់គាត់។

១៦៥៦. សាក្សី ម៉ន ប៉ាង ជាជនជាតិចាម មកពីភូមិដំណាក់ជ័យ ឃុំពាមជីកង ស្រុកកងមាស បាននិយាយប្រាប់អ្នកស៊ើបអង្កេតថាគាត់ជាអតីតមេកងចល័ត ដែលមានអ្នកជា "ប្រជាជនមូលដ្ឋាន ប្រជាជនថ្មី និងជនជាតិចាម"[1540]។ គាត់បានឱ្យដឹងថា ដូច្នេះ នៅសម័យនោះ មនុស្សត្រូវធ្វើការរួមគ្នា។

## 2. <u>ការហាមឃាត់ជានូវនៅមិនឱ្យមានការប្រតិបត្តិសាសនា និងប្រពៃណី</u>

---

[1536] <u>ហ៊ឹម ម៉ាន</u>៖ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/349.1** ទំព័រ ៣២ ក្រោយម៉ោង 11.15.25។

[1537] <u>ហ៊ឹម ម៉ាន</u>៖ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/349.1** ទំព័រ ៣២ ក្រោយម៉ោង 11.15.25។

[1538] <u>សេង ឃុយ</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៧ឯកសារ **E1/344.1** ទំព័រ ៦៣ ក្រោយម៉ោង 14.16.59។

[1539] <u>សេង ស្រ៊ុន</u>៖ ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/346.1** ទំព័រ ១០ ក្រោយម៉ោង 09.32.12។

[1540] កំណត់ហេតុស្ដាប់ចម្លើយ ម៉ន ប៉ាង ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ឯកសារ **E3/5529** សំណួរ/ចម្លើយទី ៥។

១៦៥៧. ជាការពិតណាស់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សាសនា និងការប្រតិបត្តិប្រពៃណី ត្រូវបានហាមឃាត់ ប៉ុន្តែ នេះមិនមែនជាវិធានការសំដៅតែលើជនជាតិចាមតែមួយនោះទេ។ ការហាមឃាត់នេះ ពាក់ព័ន្ធប្រជាជនទាំងអស់គ្នា គ្រប់ជាតិពន្ធ និងសាសនាទាំងអស់ ក្នុងនោះមាន ខ្មែរ ចិន ចាម ពុទ្ធសាសនិក ឬ គ្រីស្តបរិស័ទ ពោលគឺមនុស្សគ្រប់គ្នាមានជាប់ពាក់ព័ន្ធ ក៏ប៉ុន្តែ កម្រិតនៃការហាមឃាត់ អាចខុសគ្នាទៅតាមអ្នកទទួលខុសត្រូវមូលដ្ឋាន។ ទាក់ទងនឹងប្រធានបទមួយនេះ មានសក្ខីកម្មគឺដូចគ្នាទាំងអស់។

## 2.ក. ស្ថានភាពនៅភូមិភាគបូព៌ា

១៦៥៨. សាក្សី បាន សៀក ជាអតីតកម្មាភិបាលតំបន់ ៤២ ក្នុងភូមិភាគកណ្តាល ហើយក្រោយមកជាប្រធានស្រុកក្រូចឆ្មារ បានឱ្យដឹងថា ការប្រតិបត្តិសាសនា មិនត្រូវបានអនុញ្ញាតឡើយ មិនថាចំពោះជនជាតិខ្មែរ ឬ ជនជាតិចាម នោះទេ[1541]។ កំណត់ហេតុស្តាប់ចម្លើយជាច្រើន បានបញ្ជាក់អះអាងដូចគ្នាពីចម្លើយមួយនេះ[1542]។

១៦៥៩. សុះ រំលី ជាអតីតជំនួយការប្រធានស្រុកក្រូចឆ្មារបន្តបន្ទាប់មក បានពន្យល់ប្រាប់អង្គជំនុំជម្រះថា ការហាមឃាត់ការប្រតិបត្តិសាសនា បានចាប់ផ្តើមពីឆ្នាំ ១៩៧៥ ព្រោះថា "សាសនាទាំងអស់" ត្រូវបានចាត់ទុកថាជាប្រតិកិរិយា[1543]។ ម្យ៉ាងវិញទៀត លោក អ៊ីសា ឧស្មាន បានទទួលស្គាល់ថាអ៊ីស្លាមពុំមែនជាសាសនាតែមួយដែលពាក់ព័ន្ធនោះទេ[1544]។

---

[1541] <u>បាន សៀក</u>៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **E1/353.1** ទំព័រ ៣១ ប្រហែលម៉ោង 10.55.47, ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **E1/354.1** ទំព័រ ២៨ មុនម៉ោង 11.02.25, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ **E3/375**, ERN KH 00348800។

[1542] ឧទាហរណ៍ សូមមើល៖ កំណត់ហេតុស្តាប់ចម្លើយ ម៉ាត់ អ៊ីសា ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ **E3/5207**, ERN KH 00221864 (ពួកគេចង់បំបាត់សាសនាទាំងអស់ រួមទាំងសាសនាអ៊ីស្លាម និងព្រះពុទ្ធសាសនា"), កំណត់ហេតុស្តាប់ចម្លើយ ជិ លី ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារ **E3/5290**, ERN KH 00330736, ERN KH 00330738។

[1543] <u>សុះ រំលី</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/371.1** ទំព័រ ៧៤ ក្រោយម៉ោង 15.39.17, ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/372.1** ទំព័រ ៦០ មុនម៉ោង 14.31.18 ទំព័រ ៣-៤ ក្រោយម៉ោង 09.10.00 ទំព័រ ៣៣ ក្រោយម៉ោង 11.05.31 (វិហារចាមត្រូវបានបិទ និងធ្វើជាមន្ទីរពេទ្យ ហើយវត្តគុលកណ្តោលត្រូវបានយកមកធ្វើជាស្នាក់ការ

១៦៦០. មាស សឿន ជាកូនប្រុសរបស់ ចាន់ សេងហុង ហៅ ចាន់ លេខាតំបន់ ២១ ហើយក្រោយមកជាអនុប្រធានភូមិភាគបូព៌ា បានពន្យល់ថា គាត់ពុំដែលបានដឹងពីគោលការណ៍ណាមួយ ឬក៏ពីឯកសារសំណេរណាមួយ ទាក់ទងនឹងចេតនាបក្សកុម្មុយនីស្តកម្ពុជាក្នុងការចាត់ទុកចាមថាជាខ្មែរ តាមរយៈការហាមឃាត់ការប្រតិបត្តិសាសនាឡើយ។ គាត់គ្រាន់តែបញ្ជាក់ថា“[...] កុំថាឡើយដល់សាសនាអ៊ីស្លាម សូម្បីតែ [...] ព្រះពុទ្ធសាសនា ក៏គ្មាននៅបានគោរពដូចសព្វថ្ងៃនេះដែរ”[1545]។

១៦៦១. សាក្សី ម៉ាត់ អ៊ីសា ជាជនជាតិចាមមកពីឃុំប៉ឺស ស្រុកក្រូចឆ្មារ បាននិយាយប្រាប់អ្នកស៊ើបអង្កេតថាគាត់មិនដែលត្រូវបានជម្លៀសទៅណាឡើយ រហូតដល់ដាច់របបកម្ពុជាប្រជាធិបតេយ្យ។ នៅពេលនិយាយរៀបរាប់ពីការប្រជុំ គាត់បានបន្ថែមថា៖ “អង្គការចង់ឱ្យយើងរស់នៅដូចៗគ្នា ស្មើភាពគ្នា សាមគ្គីគ្នា រស់នៅជាមួយគ្នា និងហូបចុកជាមួយគ្នា” ហើយថា “យើងជាប្រជាជនធម្មតា ខំធ្វើការទៅ អង្គការចាប់តែអ្នកណាដែលជាខ្មាំងទេ”[1546]។ ដូច្នេះ ការចាប់ខ្លួន ពុំអាស្រ័យលើប្រភពជាតិពន្ធុ ឬក៏ការប្រកាន់សាសនាអ្វីឡើយ។

១៦៦២. សាក្សី នោ សាទះ ដែលសម័យនោះរស់នៅឃុំក្រូចឆ្មារ បាននិយាយប្រាប់អ្នកស៊ើបអង្កេតថា ក្នុងរបបខ្មែរក្រហម ជនជាតិចាម និងជនជាតិខ្មែរ ស្លៀកពាក់របៀបតែមួយ កាត់សក់ខ្លីដូចគ្នា និងនិយាយភាសាតែមួយ[1547]។

១៦៦៣. លោក វ៉ាន់ ម៉ាត់ មកពីភូមិជាមួយគ្នានឹងលោក អ៊ីត សេន ដែរ បានបង្ហាញពីការប្រជុំថ្នាក់ឃុំមួយដែលក្នុងពេលនោះ គេបានហាមឃាត់មិនឱ្យប្រតិបត្តិសាសនាទាំងអស់ ដោយគាត់បានបញ្ជាក់

ចល័ត)។ សូមមើលផងដែរនូវបទសម្ភាសន៍របស់ ម៉ាត់ លី ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7821**, ERN KH 00229133 (“សាសនាហ្នឹងប្រតិកិរិយាទាំងអស់”)។

[1544] <u>អ៊ីសា ឧស្មាន</u>៖ ប្រតិចារឹក ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ឯកសារ **E1/389.1** ទំព័រ ៦៩ មុនម៉ោង 15.48.43។

[1545] <u>មាស សឿន</u>៖ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/446.1** ទំព័រ ៦២ ក្រោយម៉ោង 15.17.17, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ឯកសារ **E3/5531** សំណួរ/ចម្លើយទី ៥២។

[1546] កំណត់ហេតុស្តាប់ចម្លើយ ម៉ាត់ អ៊ីសា ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨ឯកសារ **E3/5207**, ERN KH 00221862, ERN KH 00221865។

[1547] <u>នោ សាទះ</u>៖ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៨ឯកសារ **E3/5193**, ERN KH 00204446។

ប្រាប់ក្រុមមេធាវីការពារក្តីថា ការហាមឃាត់នេះ ពាក់ព័ន្ធនឹងសាសនាអ៊ីស្លាម ក៏ដូចជាសាសនាដទៃទៀត មានរួមទាំងព្រះពុទ្ធសាសនា ផងដែរ[1548]។ ជនជាតិខ្មែរ និងជនជាតិចាម បានចូលរួមក្នុងការប្រជុំនេះ ដែលក្នុងពេលនោះ នារីជនជាតិខ្មែរក៏ទទួលបានការណែនាំឱ្យកាត់សក់ខ្លីដូចគ្នា[1549]។

១៦៦៤. លោក អ៊ីសា ឧស្មាន បានលើកឡើងពីការសម្លាប់អ្នកប្រកែកមិនបរិភោគសាច់ជ្រូក[1550]។ ក៏ប៉ុន្តែ បទពិសោធន៍ គឺខុសៗគ្នា អាស្រ័យទៅតាមទីកន្លែង។ អ៊ុត សេន បានអះអាងប្រាប់អង្គជំនុំជម្រះថា ពេលអាហារមានលាយសាច់ជ្រូក ពេលហូបបាយរួម "[...] ខ្លះមកគេហូបអត់ចូល គេឱ្យអំបិលឱ្យអីហូបទៅ"[1551]។ ចំណែកឯ ម៉ាត់ ស វិញ បើទោះជាគាត់បានជម្រាបប្រាប់តុលាការថា ខ្មែរក្រហមបានបញ្ជាគាត់ឱ្យហូបសាច់ជ្រូកសាកក៏ដោយ ក៏គាត់ពុំបានបង្ហាញពីការទទួលរងធ្វើបាបដោយសារតែការប្រកែករបស់គាត់ដែរ[1552]។

## 2.២. ស្ថានភាពនៅក្នុងភូមិភាគកណ្តាល

### i. ស្រុកកងមាស

១៦៦៥. ហ៊ីម ម៉ាន ជាដើមបណ្តឹងរដ្ឋប្បវេណីមកពីភូមិសាច់សូរ ឃុំពាមជីកង បានលើកឡើងពីការប្រជុំមួយដែលគាត់ថាបានធ្វើឡើងនៅក្នុងឆ្នាំ ១៩៧៦[1553] ដែលក្នុងពេលនោះ គេបាននិយាយប្រាប់ ៣០ គ្រួសារដែលនៅក្នុងភូមិរបស់គាត់ថា ការប្រតិបត្តិសាសនា ត្រូវបានហាមឃាត់ចាប់ពីពេលនេះទៅ ហើយថាត្រូវតែហូបសាច់ជ្រូក[1554]។

---

[1548] រ៉ាន់ ម៉ាត់៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/398.1** ទំព័រ ៣៩ ក្រោយម៉ោង 11.30.25 ទំព័រ ៦៦ ក្រោយម៉ោង 15.11.05 ទំព័រ ៦៧ មុនម៉ោង 15.13.20។

[1549] រ៉ាន់ ម៉ាត់៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ឯកសារ **E1/398.1** ទំព័រ ៦៧ ក្រោយម៉ោង 15.13.20។

[1550] អ៊ីសា ឧស្មាន៖ ប្រតិចារឹក ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ឯកសារ **E1/389.1** ទំព័រ ៣៦ មុនម៉ោង 11.31.34។

[1551] អ៊ុត សេន៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/342.1** ទំព័រ ៧៧ មុនម៉ោង 15.56.41។

[1552] ម៉ាត់ ស៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/375.1** ទំព័រ ៤៦ ក្រោយម៉ោង 11.32.43។

[1553] ហ៊ីម ម៉ាន៖ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/349.1** ទំព័រ ៣១ មុនម៉ោង 11.15.25។

[1554] ហ៊ីម ម៉ាន៖ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/349.1** ទំព័រ ២៨ ក្រោយម៉ោង 10.57.09។

១៦៦៦. ពាក់ព័ន្ធនឹងបញ្ហានេះ ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បាននិយាយថា បើទោះជាពេលខ្លះ មានការគំរាមកំហែងខ្លះក៏ដោយ ក៏អ្នកខ្លះបានហូបសាច់ជ្រូក ដើម្បីឱ្យគេមើលខ្លួនក្នុងន័យវិជ្ជមាន[1555]។ គាត់ក៏បានបញ្ជាក់ផងដែរថា សាសនាអនុញ្ញាតឱ្យគាត់ហូបសាច់ជ្រូកបាន ដើម្បីការពារអាយុជីវិតតទៅទៀត[1556]។ ដោយសារតែបែបនេះ គាត់ក៏បានបរិភោគសាច់ជ្រូក នៅពេលហូបបាយរួម ក្នុងពិធីរៀបការមួយ[1557]។

១៦៦៧. ផ្ទុយទៅវិញ សាក្សី ម៉ន ប៊ាង ជាជនជាតិចាមមកពីឃុំពាមជីកង បានបញ្ជាក់ថា ក្រោយពីគាត់បានប្រកែកមិនហូបសាច់ជ្រូក កាន បានប្រកាសក្នុងពេលប្រជុំថាមិនត្រូវបង្ខំឱ្យគាត់ហូបសាច់ជ្រូកទេ[1558]។

១៦៦៨. ក្នុងអំឡុងពេលសវនាការ លោក មុយ វ៉ាន់នី បានថ្លែងថា "[...] ខ្មែរក៏ដូចចាម ចាមក៏ដូចខ្មែរ គឺអត់មានការគោរពតាមសាសនាអ៊ីចឹងទេ [...]"[1559]។ មានស្រុកកំណើតនៅភូមិសំបួរមាស លោក ហុក ហឿន បានបញ្ជាក់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយថា ចាម ១០ គ្រួសារ ត្រូវបានជម្លៀសចេញពីភូមិសាច់សូរ ទៅកាន់ភូមិរបស់គាត់ ហើយថាសាសនាទាំងអស់ ត្រូវបានហាមឃាត់[1560]។

១៦៦៩. ដូចគ្នានឹងសាក្សីទាំងអស់ដែរ លោក សេង ស្រ៊ុន បានបញ្ជាក់អះអាងពីការហាមមិនឱ្យប្រតិបត្តិសាសនា ទាំងសម្រាប់ជនជាតិចាម ទាំងពុទ្ធសាសនិក។ ទីសក្ការៈបូជា ត្រូវបានប្រើប្រាស់ធ្វើជាឃ្លាំង ឬ មន្ទីរសន្តិសុខ[1561]។

---

[1555] ហ៊ីម ម៉ាន៖ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/349.1** ទំព័រ ២៩-៣០ ក្រោយម៉ោង 11.07.25 ទំព័រ ៥២ មុនម៉ោង 14.32.16, ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/350.1** ទំព័រ ១១ ក្រោយម៉ោង 09.34.13។

[1556] ហ៊ីម ម៉ាន៖ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/349.1** ទំព័រ ៣០ មុនម៉ោង 11.10.12។

[1557] ហ៊ីម ម៉ាន៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/350.1** ទំព័រ ១៤ មុនម៉ោង 09.45.00។

[1558] កំណត់ហេតុស្តាប់ចម្លើយ ម៉ាត់ ទូល័ស ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ឯកសារ **E3/9360** សំណួរ/ចម្លើយទី ៣៨។

[1559] មុយ វ៉ាន់នី៖ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/373.1** ទំព័រ ១៦ មុនម៉ោង 10.30.00។

[1560] កំណត់ហេតុស្តាប់ចម្លើយ ហុក ហឿន ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ឯកសារ **E3/5256**, ERN KH 00243082។

[1561] សេង ស្រ៊ុន៖ ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៧ឯកសារ **E1/346.1** ទំព័រ ១០ ក្រោយម៉ោង 09.32.12 ទំព័រ ១១ មុនម៉ោង 09.38.13។

១៦៧០. ដូច្នេះ ដូចគ្នានឹងស្រុកក្រូចឆ្មារដែរ ការបំបិទសាសនា គឺមានលក្ខណៈជាទូទៅ និងមិនសំដៅជាពិសេសតែទៅលើប្រជាជនចាម នោះទេ។

## ii. ស្រុកកំពង់សៀម

១៦៧១. តបតាមសំណើរបស់អយ្យការ សាក្សីពីររូបដែលជាអតីតកម្មាភិបាលខ្មែរក្រហម ក្នុងស្រុកកំពង់សៀម ហើយដែលត្រូវបានសម្ភាសក្នុងក្របខ័ណ្ឌសំណុំរឿង ០០៣ និង ០០៤ ត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ សាក្សី 2-TCW-894 គឺជាមេកងចល័ត ហើយក៏ជាអនុប្រធានរបស់សាក្សី 2-TCW-938 ហើយគាត់មានតួនាទីខ្ពស់ក្នុងថ្នាក់ដឹកនាំស្រុក[1562]។ ពួកគាត់ជាស្ត្រីទាំងពីរនាក់ បានមកផ្តល់សក្ខីកម្មទាក់ទងនឹងការប្រព្រឹត្តលើជនជាតិចាម នៅក្នុងស្រុកកំពង់សៀម និងជាពិសេស ទាក់ទងនឹងសេចក្តីណែនាំដែលត្រូវបានសន្និដ្ឋានថាទទួលបានមកពីថ្នាក់ដឹកនាំរបស់គាត់ទាំងពីរនៅតំបន់ (ស្រុកកងមាស ជាផ្នែកមួយក្នុងតំបន់នោះ) និងការចាប់ខ្លួននៅពេលក្រោយមកទៀត។

១៦៧២. កំណត់ហេតុស្តាប់ចម្លើយមួយចំនួន បានលើកឡើងយ៉ាងខ្លីពីស្ថានភាពជនជាតិចាមនៅក្នុងស្រុកកំពង់សៀម ប៉ុន្តែ តម្លៃជាភ័ស្តុតាងនៃកំណត់ហេតុទាំងនោះ គឺមានតិចតួចបំផុត បើយោងតាម អវត្តមាននៃភាពលម្អិតទាក់ទងនឹងភ័ស្តុតាងទាំងឡាយដែលត្រូវបានបង្ហាញ និងប្រភពព័ត៌មានរបស់សាក្សី[1563]។

### • ស្ថានភាពរស់នៅរបស់ជនជាតិចាម ក្នុងស្រុកកំពង់សៀម

[1562] 2-TCW-894៖ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/377.1** (សវនាការសម្ងាត់) ទំព័រ ៣៣ មុនម៉ោង 11.12.33។

[1563] កំណត់ហេតុស្តាប់ចម្លើយ វ៉ា លីមហ៊ាន់ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **E3/9756**, កំណត់ហេតុស្តាប់ចម្លើយ ពៅ សារ៉ុម ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E3/9670**, កំណត់ហេតុស្តាប់ចម្លើយ ស្បោង យ៉ាន់ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤ឯកសារ **E3/9656**។

១៦៧៣. សាក្សី 2-TCW-938 បានឱ្យដឹងថា "[ចាម និង ខ្មែរ]គឺរួមរស់នៅជាមួយគ្នា"[1564] ហើយនេះក៏ជាអ្វីដែលសាក្សី 2-TCW-894 បានបញ្ជាក់អះអាងដូចគ្នា[1565]។ សាក្សី 2-TCW-938 បានថ្លែងថា សាសនាត្រូវបានហាមឃាត់នៅក្នុងស្រុកកំពង់សៀម ប៉ុន្តែ គាត់ថាពុំដែលបានទទួលបញ្ជាហាមមិនឱ្យជនជាតិចាមនិយាយភាសាខ្លួនឡើយ[1566]។

១៦៧៤. សាក្សី 2-TCW-894 បានបញ្ជាក់ថា នៅក្នុងកងចល័តដែលគាត់ទទួលខុសត្រូវ "គឺមានចម្រុះគ្នា" ខ្មែរ និង ចាម ហើយចំណែកឯការងារវិញ "គឺធ្វើទូទៅទាំងអស់" ដោយមិនមានការបែងចែកអ្វីទាំងអស់[1567]។ សាក្សី 2-TCW-894 បានថ្លែងផងដែរថា ប្ដីប្រពន្ធជនជាតិចាម បានរៀបការនៅក្នុងកងចល័តរបស់គាត់ ក្រោយមកហើយ នៅប្រហែលចុងឆ្នាំ ១៩៧៨ ដែលនេះជាភ័ស្តុតាងសំខាន់មួយសម្រាប់វគ្គបន្ទាប់ទៀត[1568]។

• **<u>បញ្ជារបស់តំបន់</u>**

១៦៧៥. សាក្សី 2-TCW-938 បានលើកឡើងពីការប្រជុំតំបន់ ដោយមានការចូលរួមពីសំណាក់អ្នកទទួលខុសត្រូវស្រុកទាំងអស់ រួមមានទាំងអ្នកទទួលខុសត្រូវស្រុកកងមាស ផងដែរ។ ក្នុងពេលប្រជុំនោះ សាក្សីបានទទួល "បញ្ជាពីថ្នាក់តំបន់" ឱ្យ "បោសសម្អាតចាម" ហើយគាត់ក៏បានចាប់ផ្ដើមអនុវត្ត

---

[1564] <u>2-TCW-938</u> : ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/377.1** (សវនាការសម្ងាត់) ទំព័រ ៧២ មុនម៉ោង 15.39.36។ សូមមើលផងដែរ <u>Alexander HINTON</u>៖ ប្រតិចារឹក ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/402.1** ទំព័រ ៥៧ ប្រហែលម៉ោង 14.01.31. ក្នុងក្របខ័ណ្ឌនៃការអង្កេតរបស់គាត់ នៅស្រុកកំពង់សៀម លោក Alexander HINTON បានឆ្លើយថា គាត់បានសម្ភាសអ្នកភូមិ ដែលបានលើកឡើងអំពីការកាត់សក់ និងការធ្វើឱ្យមានឯកសណ្ឋានភាពមួយ គឺ "ឆន្ទៈចង់បង្កើតសមភាព" ដោយធ្វើឱ្យស្ត្រីមានស្វ័យភាពខ្លះ។

[1565] 2-<u>TCW-894</u>៖ ប្រតិចារឹក ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/376.1** (សវនាការសម្ងាត់) ទំព័រ ៤៩ មុនម៉ោង 14.59.08។

[1566] <u>2-TCW-938</u>៖ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/377.1** (សវនាការសម្ងាត់) ទំព័រ ៧២ ក្រោយម៉ោង 15.39.36។

[1567] <u>2-TCW-894</u>៖ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/377.1** ទំព័រ ៣៣ មុនម៉ោង 11.12.33។

[1568] សូមមើលខាងលើ កថាខណ្ឌ ១៦៧៤ និងកថាខណ្ឌ ១៦៩២ ដល់កថាខណ្ឌ ១៦៩៣ (នៅក្នុងសវនាការសាក្សី 2-TCW-894 និង 2-TCW-938 ក៏បានផ្ដល់សក្ខីកម្មផងដែរអំពីដំណើរការនៃការរៀបអាពាហ៍ពិពាហ៍)។

បទបញ្ជានេះ ដោយមិនដឹងពីមូលហេតុឱ្យបានច្បាស់លាស់[1569]។ គេឱ្យគាត់ស្វែងរកចាមក្នុងស្រុករបស់គាត់ ហើយគាត់បានធ្វើការងារនេះដោយមានជំនួយពីសាក្សី 2-TCW-894[1570]។ សាក្សី 2-TCW-894 បានថ្លែងប្រាប់តុលាការថា គាត់ពិតជាត្រូវបានគេប្រើឱ្យធ្វើបញ្ជីអតីតអ្នកសាធារណរដ្ឋខ្មែរ ជនជាតិចាម ជនជាតិវៀតណាម និងឈ្មោះមេភូមិទាំងអស់ ដោយគាត់បានបញ្ជាក់ថា "[...] គេសរុបជាចំនួនតាមភូមិៗមក [...]"[1571]។ ដូច្នេះ តាមរយៈចម្លើយទាំងអស់នេះ វាបង្ហាញឱ្យឃើញថា ក្នុងបញ្ជីនោះ ពុំមែនមានតែឈ្មោះជនជាតិចាមឡើយ តែវាជាបញ្ជីទូទៅ ហើយសាក្សី 2-TCW-894 មិនទាំងដឹងពីសេចក្តីលម្អិតនៃបញ្ជីនោះផង ព្រោះថាគាត់ពុំបានចូលរួមប្រជុំ[1572]។

១៦៧៦. ចម្លើយរបស់សាក្សី 2-TCW-938 ក្នុងអំឡុងពេលសវនាការ មានភាពច្របូកច្របល់ និងផ្ទុយគ្នាក្នុងរយៈពេលពេញបីថ្ងៃនៃការផ្តល់សក្ខីកម្មរបស់គាត់។ ជាកិច្ចចាប់ផ្តើម គាត់និយាយពីការ "បោសសម្អាតចាម" ដោយគាត់ថ្លែងថា ការចាប់ខ្លួន និងការសម្លាប់ជនជាតិចាមនៅក្នុងស្រុករបស់គាត់បានចាប់ផ្តើមក្រោយពីការប្រជុំជាមួយប្រធានតំបន់ ដោយគាត់ថែមទាំងបានបញ្ជាក់ថា គាត់ពុំបានដឹងពីសេចក្តីលម្អិតនៃការបោសសម្អាតនោះឡើយ ព្រោះគាត់ពុំមែនជាអ្នកអនុវត្តផ្ទាល់[1573]។ ការប្រជុំតំបន់នេះ បានប្រព្រឹត្តទៅដោយមានវត្តមានប្រធានស្រុកទាំងអស់ ក្នុងនោះមានស្រុកកងមាសផងដែរ[1574]។ ផ្ទុយទៅវិញ ក្រោយមកទៀត សាក្សី 2-TCW-938 បានពន្យល់ថា ពុំមែនត្រូវចាប់ចាមទាំងអស់ទេ៖

---

[1569] 2-TCW-938៖ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/377.1** (សវនាការសម្ងាត់) ទំព័រ ៦០-៦១ មុនម៉ោង 14.45.57។

[1570] 2-TCW-938៖ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/377.1** (សវនាការសម្ងាត់) ទំព័រ ៦១-៦២ មុនម៉ោង 14.49.49។

[1571] 2-TCW-894៖ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/377.1** (សវនាការសម្ងាត់) ទំព័រ ១២-១៣ ចន្លោះម៉ោង 09.46.30 ដល់ម៉ោង 09.51.45។

[1572] 2-TCW-894៖ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/377.1** (សវនាការសម្ងាត់) ទំព័រ ៣២ ប្រហែលម៉ោង 11.06.16។

[1573] 2-TCW-938៖ ប្រតិចារឹក ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/380.1** (សវនាការសម្ងាត់) ទំព័រ ៧ ប្រហែលម៉ោង 09.24.08 ទំព័រ ៨-៩ មុនម៉ោង 09.31.37។

[1574] 2-TCW-938៖ ប្រតិចារឹក ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/378.1** (សវនាការអសាធារណៈ) ទំព័រ ៨ ប្រហែលម៉ោង 09.29.24។

"ជនជាតិចាមទាំងអស់នៅស្រុកកំពង់សៀម ទោះបីបញ្ហាមកខាងលើពិតប្រាកដមែន តែការពិនិត្យពិច័យរបស់ខ្ញុំនៅក្នុងស្រុកកំពង់សៀម ក៏មិនចេះតែខុសដៃយកដៃ ខុសជើងយកជើង គឺខ្ញុំបានពិនិត្យពិច័យអ្នកខុស អ្នកត្រូវដែរ នៅក្នុងស្រុក ដូចថាខ្លះក៏អត់មានការប្រឆាំងអីក៏ ខ្លះក៏មានការប្រឆាំង។ នេះខ្ញុំសូមជម្រាប។ ហេតុនេះ ការចាប់ ការចងនេះ មុននឹងចាប់ក៏ខ្ញុំពិនិត្យពិច័យច្បាស់លាស់ដែរ ព្រោះថាអ្នកណាក៏ល្អ ខ្លះក៏អាក្រក់ ខ្លះក៏ល្អ មិនមែនអាក្រក់ទាំងអស់ ហើយក៏មិនមែនល្អទាំងអស់"[1575]។

១៦៧៧. ហេតុដូចនេះ សាក្សី 2-TCW-938 បានទទួលស្គាល់ថា គាត់មានអំណាចក្នុងការកំណត់ថានរណាជាអ្នកប្រឆាំង ឬ "សមាសភាពមិនល្អ" ហើយដូច្នេះ វាពុំមែនសំដៅចំពោះតែក្រុមមួយណាជាក់លាក់នោះឡើយ។ ទោះយ៉ាងណាក៏ដោយ សក្ខីកម្មរបស់សាក្សីរូបនេះមានភាពច្របូកច្របល់ខ្លាំង ហើយមិនអាចឱ្យគេសន្និដ្ឋានបានថា សេចក្ដីសម្រេចចាប់ជនជាតិចាម ចេញមកពីថ្នាក់ខ្ពស់ជាងតំបន់ បានឡើយ។ សាក្សី 2-TCW-938 ខ្លួនឯង បានទទួលស្គាល់ថាគាត់មិនបានដឹងអ្វីសោះពីការទំនាក់ទំនងរវាងតំបន់ និងភូមិភាគ[1576]។

១៦៧៨. ខ្លឹមសារបកស្រាយខាងលើទាក់ទងនឹងជម្លោះប្រដាប់អាវុធ អាចឱ្យគេដឹងថា បើយោងទៅលើកាលបរិច្ឆេទនៃព្រឹត្តិការណ៍ដែលត្រូវបានជ្រើសរើស កម្ពុជាប្រជាធិបតេយ្យ កំពុងស្ថិតក្នុងស្ថានភាពជម្លោះដ៏លំបាក ឬមួយក៏កំពុងជិតទទួលបរាជ័យ។ ដូច្នេះ ក្នុងរយៈពេលដ៏សំខាន់នេះ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានខិតខំដោះស្រាយបញ្ហានានារបស់កងទ័ព និងបញ្ហាទំនាក់ទំនងក្រៅប្រទេសក្ដៅគគុក ច្រើនជាងការគ្រប់គ្រងស្រុក និងតំបន់។

### iii. <u>ស្រុកផ្សេងទៀតក្នុងភូមិភាគកណ្ដាល</u>

---

[1575] <u>2-TCW-938</u> : ប្រតិចារឹក ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/378.1** (សវនាការអសាធារណៈ) ទំព័រ ៨-៩ មុនម៉ោង 09.30.50។

[1576] <u>2-TCW-938</u> : ប្រតិចារឹក ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/378.1** (សវនាការអសាធារណៈ) ទំព័រ ១៤-១៥ មុនម៉ោង 09.57.00។

១៦៧៩. សក្ខីកម្មផ្សេងទៀតទាក់ទងនឹងភូមិភាគកណ្ដាល ត្រូវបានពិនិត្យក្នុងផ្នែកស្ដីពីការចោទប្រកាន់លើគោលនយោបាយទាក់ទងនឹងជនជាតិចាម។

១៦៨០. ទោះយ៉ាងណាក៏ដោយ របៀបដែលកងឈ្លប និងអាជ្ញាធរមូលដ្ឋាន បានគ្រប់គ្រងសន្តិសុខតាមស្រុក ក្នុងភូមិភាគបូព៌ា ឬ ក្នុងភូមិភាគកណ្ដាល គឺមិនស្របគ្នាទៅនឹងគោលនយោបាយណាមួយរបស់បក្សកុម្មុយនីស្ដកម្ពុជា ដែលសំដៅដល់ការបំផ្លិចបំផ្លាញក្រុមជនជាតិចាម ដូចដែលគេនឹងបានឃើញយ៉ាងលម្អិត នៅផ្នែកខាងក្រោមឡើយ[1577]។

## 2.គ. ស្ថានភាពក្នុងភូមិភាគពាយ័ព្យ

១៦៨១. នៅត្រង់កថាខណ្ឌ ៧៥៥ នៃដីកាដំណោះស្រាយ មានការលើកឡើងពីរបាយការណ៍ប្រចាំសប្ដាហ៍របស់តំបន់៥ នៃភូមិភាគពាយ័ព្យ ផ្ញើជូនលេខាភូមិភាគ និង ម.៥៦០ (មន្ទីរភូមិភាគពាយ័ព្យ)[1578]។ របាយការណ៍នេះ រៀបរាប់ពីស្ថានភាពទូទៅនៅក្នុងតំបន់ រួមមានទាំងការងារសន្តិសុខផងដែរ។ ពាក់ព័ន្ធនឹងចំណុចសន្តិសុខនេះ ទោះបីជាមានការបញ្ជាក់ពី "សមាសភាព ១៧ មេសា" ដែលជាជនជាតិចាមក៏ដោយ ក៏អ្វីដែលចម្បងគឺពុំមែនអត្តសញ្ញាណជាជនជាតិចាមរបស់ពួកគេឡើយ ប៉ុន្តែគឺការណ៍ដែលពួកគេ "បានតវ៉ា" ទៅវិញទេ បើទោះបីដើម្បីបានទទួលអាហារ "ស្របតាមសាសនារបស់ពួកគេ" ក៏ដោយ។ ម្យ៉ាងវិញទៀត ផ្នែកផ្សេងទៀតនៃរបាយការណ៍ បានរៀបរាប់ពីឧប្បត្តិហេតុផ្សេងៗដែលត្រូវបានចាត់ទុកថាជាអំពើក្បត់ ឬ ខុសសីលធម៌ ដោយរបាយការណ៍នេះដាក់សកម្មភាពទាំងអស់នេះឱ្យនៅកម្រិតជាមួយគ្នា ហើយគោលបំណងគឺដើម្បីបំផ្លាញ"ខ្សែ" ប្រឆាំង។

## គ. គ្មានផែនការកម្ទេចក្រុមជនជាតិចាម

---

[1577] សូមមើលខាងក្រោម កថាខណ្ឌ ១៨៤០-១៨៧៧។

[1578] សេចក្ដីរាយការណ៍របស់គណៈកម្មាធិការតំបន់ ៥ ប្រចាំអាទិត្យ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៧ ឯកសារ **E3/178**, ERN KH 00275588។

១៦៨២. លក្ខណៈសម្គាល់សំខាន់របស់អំពើប្រល័យពូជសាសន៍ គឺឆន្ទៈក្នុងការបំផ្លាញក្រុមមួយ។ ការបង្ហាញមួយក្នុងចំណោមការបង្ហាញឱ្យឃើញពីឆន្ទៈបំផ្លាញ គឺការរារាំងមិនឱ្យកើតមានជាគ្រួសារ ហើយដូច្នេះ គឺការហាមឃាត់ ឬការដាក់កំហិតការរៀបអាពាហ៍ពិពាហ៍។ ក៏ប៉ុន្តែ ភស្តុតាងក្នុងសំណុំរឿងបានបញ្ជាក់ឱ្យឃើញថា ក្នុងរយៈពេលពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ គូស្រករដែលមានដើមកំណើតចាម អាចរៀបការក្នុងល័ក្ខខ័ណ្ឌដូចគ្នានឹងប្រជាជនឯទៀត (១)។

១៦៨៣. ការពិនិត្យលើអង្គហេតុទាក់ទងនឹងមូលហេតុនៃការចាប់ខ្លួនមនុស្សនៅក្រូចឆ្មារ និងកងមាស ក៏មិនអាចឱ្យគេសន្និដ្ឋានបានពីអត្ថិភាពនៃផែនការកម្ទេចក្រុមជនជាតិចាម (២) បានឡើយ បើទោះបីជាភស្តុតាងមួយចំនួន ធ្វើឱ្យគេយល់ថាមានការចាប់ខ្លួន និងការសម្លាប់ ក៏ដោយ (៣)។

1. **ការរៀបអាពាហ៍ពិពាហ៍ជនជាតិចាម**

១៦៨៤. លោក អ៊ីសា ឧស្មាន បានឱ្យដឹងថា នៅប្រហែលចុងឆ្នាំ ១៩៧៥ មុនការបះបោរនៅកោះផល គេបានដាក់ល័ក្ខខ័ណ្ឌ ៥ ខ ដល់ជនជាតិចាម។ ខចុងក្រោយគឺថា "បុរស និងស្រីជនជាតិចាមហ្នឹងត្រូវតែរៀបការជាមួយជនជាតិដទៃទៀត"[1579] បើទោះជា "ជាក់ស្តែង វាពុំបានកើតឡើងដូច្នេះក្តី" ដោយសារតែការបះបោរនៅកោះផល។ ទោះយ៉ាងណា លោក អ៊ីសា ឧស្មាន បានទទួលស្គាល់ថាគាត់ពុំបានធ្វើការសិក្សាស៊ីជម្រៅលើការរៀបអាពាហ៍ពិពាហ៍ឡើយ[1580]។

១៦៨៥. ជាថ្មីម្តងទៀត ការសារភាពទទួលស្គាល់ដូច្នេះ គឺវាបង្ហាញឱ្យឃើញពីភាពលំៗនៃសេចក្តីសន្និដ្ឋានរបស់អ្នកវិភាគរបស់សហចៅក្រមស៊ើបអង្កេត ក្នុងឆន្ទៈរបស់គាត់បង្ហាញឱ្យឃើញថាខ្មែរក្រហមមានផែនការកម្ទេចក្រុមជនជាតិចាម។ ការពិតនៃរឿងនេះ គឺផ្ទុយពីនេះ។

១៦៨៦. នៅក្នុងអំឡុងពេលសវនាការ សុះ រំលី ពុំបានបង្ហាញពីការធ្វើបាបមកលើក្រុមគ្រួសាររបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នោះឡើយ។ គាត់បានរស់នៅក្នុងភូមិកំណើត រហូតដល់ពេលគាត់

[1579] <u>អ៊ីសា ឧស្មាន</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/388.1** ទំព័រ ២៥ ក្រោយម៉ោង 10.45.12។

[1580] <u>អ៊ីសា ឧស្មាន</u>៖ ប្រតិចារឹក ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/389.1** ទំព័រ ៤១-៤២ ចន្លោះម៉ោង 13.44.37 ដល់ម៉ោង 13.49.48។

រត់ មុនពេលដាច់របបខ្មែរក្រហម។ ក្នុងចំណោមបងប្អូនគាត់ទាំងប្រាំនាក់ ទោះជាមានម្នាក់បានបាត់ខ្លួននៅឆ្នាំ ១៩៧៣[1581] ក៏ដោយ ក៏មានម្នាក់ទៀត បានរៀបការជាមួយនារីជនជាតិចាមឈ្មោះ ម៉ាត់ ស នៅប្រហែលចុងឆ្នាំ ១៩៧៨[1582]។

១៦៨៧. លោកស្រី ម៉ាត់ ស បានថ្លែងប្រាប់អង្គសវនាការថា មុនពេលរត់គេចខ្លួន គាត់បានរៀបការក្នុងពិធីមួយមាន ៦០ គូ ហើយក្នុងនោះ គាត់មិនអាចបញ្ជាក់បានថាមានចាម និងជាតិសាសន៍ផ្សេងទៀតប៉ុន្មាននាក់បានទេ។ គាត់បានពន្យល់ថា គឺគ្រួសារខាងប្ដីគាត់ដែលជាអ្នកមកសុំគាត់រៀបការ ហើយ "បានរៀបចំការឱ្យពួកគាត់"។ គាត់ និងប្ដី បានជួបគ្នាក្នុងកងចល័ត។ ប្ដីរបស់គាត់រស់នៅក្នុងភូមិទ្រា២ ហើយកម្មាភិបាលខ្មែរក្រហមដឹងថាពួកគាត់ទាំងពីរជាជនជាតិចាម[1583]។ បើតាមលោកស្រី ម៉ាត់ ស ឈ្មោះ ហូ គឺជាអ្នកផ្ដួចផ្ដើមការរៀបការនេះ បើទោះជាគាត់គ្មានវត្តមានក្នុងពិធីរៀបការនោះក្ដី[1584]។

១៦៨៨. ពេលចោទសួរដោយចៅក្រម FENZ លោកស្រី ម៉ាត់ ស ឆ្លើយថាគាត់ពុំដែលបានឮពីការហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងជនជាតិចាម នោះទេ ដោយគាត់បានបញ្ជាក់ថា តាមដែលគាត់បានដឹង ការរៀបការរបស់គាត់ គឺជាការរៀបការតែមួយគត់ដែលអាជ្ញាធរភូមិបានដឹង[1585]។ ទោះយ៉ាងណាក៏ដោយ លោក សុះ រំលី ដែលជាបងថ្លៃរបស់គាត់ និងជាអ្នកធ្វើការនៅឃុំ បានផ្ដល់ព័ត៌មានជូនអង្គជំនុំជម្រះបានយ៉ាងលម្អិតជាងនេះ ទាក់ទងនឹងការរៀបការជនជាតិចាម នៅក្នុងសម័យខ្មែរក្រហម។

---

[1581] <u>សុះ រំលី</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/372.1** ទំព័រ ១៨ មុនម៉ោង 10.01.03។

[1582] <u>ម៉ាត់ ស</u>៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/375.1** ទំព័រ ៨៧ មុនម៉ោង 16.04.05, <u>សុះ រំលី</u>៖ កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៨ឯកសារ **E3/5196**, ERN KH 00204457។

[1583] <u>ម៉ាត់ ស</u>៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/375.1** ទំព័រ ៦៨ មុនម៉ោង 14.39.39 ទំព័រ ៦៧ ក្រោយម៉ោង 14.36.57 ទំព័រ ៨៤ ក្រោយម៉ោង 15.48.33 ទំព័រ ៨៥ មុនម៉ោង 15.53.38 ទំព័រ ៨៨ ប្រហែលម៉ោង 16.05.38។

[1584] <u>ម៉ាត់ ស</u>៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/375.1** ទំព័រ ៨៧ មុនម៉ោង 16.01.16។ អំណះអំណាងនេះស៊ីសង្វាក់គ្នាជាមួយចម្លើយរបស់ បាន សៀក ដែលបានឆ្លើយថាគាត់មិនធ្លាប់ចូលរួមក្នុងការរៀបអាពាហ៍ពិពាហ៍នៅក្រូចឆ្មារនោះទេ ៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ឯកសារ **E1/354.1** ទំព័រ ៥៨ មុនម៉ោង 15.13.03។

[1585] <u>ម៉ាត់ ស</u>៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/375.1** ទំព័រ ៨៨-៨៩ មុនម៉ោង 16.07.56។

១៦៨៩. សុះ រំលី បានពន្យល់ថា មានការរៀបអាពាហ៍ពិពាហ៍ចំនួនពីរ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្លួនគាត់ផ្ទាល់បាននិយាយថាបានរៀបការនៅឆ្នាំ ១៩៧៧ នៅក្នុងពិធីរៀបការរួមលើកទី១ មានគ្នាប្អូនគូ[1586]។ ពិធីលើកទី២ គឺនៅឆ្នាំ ១៩៧៨ មានចំនួនជាង ២០ គូ។ គាត់បានឱ្យដឹងថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងរវាងមនុស្សជាតិសាសន៍ដូចគ្នា ហើយគ្មានគូចម្រុះជាតិសាសន៍ទេ។ អ្នកខ្លះរៀបការដោយស្ម័គ្រចិត្ត ហើយខ្លះទៀត ត្រូវគេបង្ខំឱ្យរៀបការ[1587]។

១៦៩០. លោក ហ៊ីម ម៉ាន ជាដើមបណ្ដឹងរដ្ឋប្បវេណី មកពីភូមិសាច់សូរ ស្រុកកងមាស បានលើកឡើងផងដែរពីការរៀបការជនជាតិចាម។ នៅឆ្នាំ ១៩៧៧ ក្នុងពិធីមួយជាសមូហភាពដែលមានខ្មែរ និងចាម គាត់បានរៀបការនៅវត្តអូរត្រកួន ជាមួយនារីចាមម្នាក់ ដោយមានវត្តមានបងប្អូនខាងប្រពន្ធរបស់គាត់។ ផ្ទុយពី សុះ រំលី នៅក្នុងពិធីនោះ ហ៊ីម ម៉ាន បានកត់សម្គាល់ផងដែរពីវត្តមាន "[...] ម្នាក់ទៀតដែរចំខ្មែរ គូដណ្ដឹងចាស់ដែរ"[1588]។

១៦៩១. សុះ កំរ៉ី មានដើមកំណើតមកពីស្រុកចំការលើ។ បើទោះជាគាត់បានជម្រាបប្រាប់តុលាការថា គាត់បានរៀបការមុនការមកដល់របស់ខ្មែរក្រហមក៏ដោយ ក៏គាត់បានបញ្ជាក់ថាបានចូលរួមពិធីរៀបការជនជាតិចាម ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ គាត់បានបញ្ជាក់ថា គ្មានការហាមមិនឱ្យចាមរៀបការជាមួយចាមដូចគ្នា ឬរវាងចាម ជាមួយនឹងក្រុមជាតិពន្ធុណាផ្សេងឡើយ[1589]។

១៦៩២. ក្នុងអំឡុងពេលសវនាការ សាក្សី 2-TCW-894 និងសាក្សី 2-TCW-938 បានផ្ដល់សក្ខីកម្មផងដែរទាក់ទងនឹងការប្រព្រឹត្តទៅនៃពិធីរៀបការជនជាតិចាម នៅក្នុងស្រុកកំពង់សៀម ស្ថិតក្នុងភូមិភាគ

---

[1586] សុះ រំលី៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/372.1** ទំព័រ ៣៥ ក្រោយម៉ោង 11.13.49។

[1587] សុះ រំលី៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/372.1** ទំព័រ ៣៥ ក្រោយម៉ោង 11.13.49 ទំព័រ ៦១ ក្រោយម៉ោង 14.33.52។

[1588] ហ៊ីម ម៉ាន៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ១៣-១៥ ចន្លោះម៉ោង 09.41.39 ដល់ម៉ោង 09.49.02។

[1589] សុះ កំរ៉ី៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/415.1** ទំព័រ ៤២ ប្រហែលម៉ោង 11.21.47 ទំព័រ ៦៥ មុនម៉ោង 14.35.15។

កណ្ដាល។ សាក្សី 2-TCW-894 ជាមេកងចល័ត នៅចាំបានថាគាត់បានរៀបចំពិធីរៀបការ "ចាម ប្អូនគូ ខ្មែរប្អូនគូ"[1590]។

១៦៩៣. បើទោះបីជាចម្លើយរបស់សាក្សី 2-TCW-938 មានភាពច្របូកច្របល់ ទាក់ទងនឹងការហាមប្រាម ឬអត់ មិនឱ្យមានចាមការជាមួយខ្មែរក៏ដោយ ក៏គេស្ថិតនៅឆ្ងាយនៅឡើយពីគោលនយោបាយបែប សន្មតលើកឡើងដោយលោក អ៊ីសា ឧស្មាន។ ទោះយ៉ាងណាក៏ដោយ គាត់នៅចាំបានពីការរៀបការ រវាងចាម និងចាមដូចគ្នា ដែលសាក្សី 2-TCW-894 បានលើកឡើង[1591]។

១៦៩៤. ម្យ៉ាងវិញទៀត សក្ខីកម្មរបស់ ហ៊ីម ម៉ាន នៅកងមាស បង្ហាញឱ្យឃើញថា ការអនុវត្តគឺពុំមានការ ឯកភាពគ្នានៅតាមទីកន្លែងផ្សេងៗគ្នា ដែលនេះជាការបដិសេធចោលនូវសម្មតិកម្មលើកឡើងស្ដីពី គោលនយោបាយខ្មែរក្រហមក្នុងការរារាំងជនជាតិចាមឱ្យរៀបការជាមួយចាមដូចគ្នា ឬក៏ជាមួយ ជនជាតិខ្មែរ។

## 2. ភ័ស្តុតាងទាក់ទងនឹងព្រឹត្តិការណ៍កើតឡើងនៅក្រូចឆ្មារ និងកងមាស

១៦៩៥. លោក អ៊ីសា ឧស្មាន បានពន្យល់ប្រាប់ក្នុងសវនាការថា ចាមត្រូវបានគេនាំទៅ ដោយសារគេចោទ ប្រកាន់ថាពួកគេជាខ្មែរស ជាសមាជិកសេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ ឬមួយក៏ជាភ្នាក់ងារវៀតណា ម[1592]។ ហេតុដូច្នេះ ពុំមែនសាសនា ឬមួយក៏ជាតិពន្ធុរបស់ពួកគេទេ ដែលជាកម្មវត្ថុនៃការចោទ ប្រកាន់។ ទោះជាភ័ស្តុតាងមួយចំនួនអាចឱ្យគេសន្និដ្ឋានបានពីការចាប់ខ្លួន និងការសម្លាប់ជនជាតិ ចាម ក៏ពិតមែន តែក៏មានភ័ស្តុតាងផ្សេងទៀត ដូចជាភ័ស្តុតាងទាក់ទងនឹងអង្គហេតុក្នុងស្រុក

---

[1590] 2-TCW-894៖ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/377.1** (សវនាការសម្ងាត់) ទំព័រ ៣០ មុនម៉ោង 11.01.50 និងទំព័រ ៤២ គេធ្វើរួចហើយ បានគេយកមករៀបការ។ បានស្នើមកការបណ្ដោយ៖ ទំព័រ ៤២ មុនម៉ោង 13.46.34។

[1591] 2-TCW-938៖ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/377.1** (សវនាការសម្ងាត់) ទំព័រ ៧១ ក្រោយម៉ោង 15.39.36 ទំព័រ ៧៣ ប្រហែលម៉ោង 15.42.21, ប្រតិចារឹក ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/378.1** (សវនាការអសាធារណៈ) ទំព័រ ៣៥ មុនម៉ោង 11.30.33 ទំព័រ ៣៥-៣៦ មុនម៉ោង 11.33.32 ទំព័រ ៣៧ មុនម៉ោង 13.37.40, ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** (សវនាការសម្ងាត់) ទំព័រ ២៥ មុនម៉ោង 10.43.40, ប្រតិចារឹក ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/380.1** (សវនាការសម្ងាត់) ទំព័រ ១០ ក្រោយម៉ោង 09.35.57 ទំព័រ ១១ ក្រោយម៉ោង 09.39.37។

[1592] អ៊ីសា ឧស្មាន៖ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/407.1** ទំព័រ ៦៤ ក្រោយម៉ោង 14.44.18។

ក្រូចឆ្មារ (ក) និងស្រុកកងមាស (ខ) អាចឱ្យគេអះអាងបានថា ការចាប់ខ្លួន និងការសម្លាប់នេះ កើតឡើងក្រោមមូលហេតុដូចគ្នានឹងប្រជាជនដទៃទៀតដែរ។

**2.ក. ករណីស្រុកក្រូចឆ្មារ**

១៦៩៦. លោក សុះ រំលី បានពន្យល់ប្រាប់តុលាការថា នៅឆ្នាំ ១៩៧៧ ក្នុងឋានៈគាត់ជាស្មៀនរបស់ឈាន មេឃុំទ្រា "សន្តិសុខតំបន់" បាននិយាយប្រាប់គាត់ថា "អនាគត ចាមទាំងអស់ហ្នឹង គេកម្ទេចឱ្យទាំងអស់ហ្នឹង"[1593]។ ទោះយ៉ាងណាក៏ដោយ លោក សុះ រំលី ពុំអាចប្រាប់ឈ្មោះបុគ្គលម្នាក់នោះ និងឈ្មោះរបស់ប្រធានគាត់ និងអ្នកមកជាមួយ បានទេ[1594]។ គាត់រឹតតែមិនអាចដឹងបានថាតើផែនការនេះមានគោលបំណងអ្វីឱ្យច្បាស់[1595]។ ដូច្នេះ សក្ខីកម្មរបស់គាត់ គឺមិនអាចជឿជាក់បាន ហើយយ៉ាងណាក៏ដោយ ក៏គ្មានប្រភពជឿទុកចិត្តបានថែមទៀត។

១៦៩៧. ម្យ៉ាងវិញទៀត សាក្សី សុះ រំលី បានបញ្ជាក់ថា គាត់ពុំដឹងថានរណាជាប្រធានស្រុក នោះទេ ហេតុដូច្នេះ គាត់ក៏មិនបានដឹងពីសេចក្តីសម្រេចរបស់ថ្នាក់លើ[1596]។ ដោយគ្មានសេចក្តីលម្អិតផ្សេងទៀត បើទោះជាគេត្រូវទុកចិត្តលើពាក្យនិយាយតៗគ្នាបែបអនាមិកមួយនេះក៏ដោយ ក៏គេមិនអាចសន្និដ្ឋានបានពីអត្ថិភាពនៃផែនការមកពីថ្នាក់លើ ហើយកាន់តែមិនអាចថាមកពីថ្នាក់មជ្ឈិមបក្សបានថែមទៀត។

១៦៩៨. លោក វ៉ាន់ ម៉ាត់ ជាសាក្សីចាមម្នាក់ទៀត បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះពីការប្រជុំមួយ រៀបចំដោយ កែ ពក ប្រធានភូមិភាគកណ្តាល នៅកំពង់ថ្ម (ភូមិភាគកណ្តាល) ក្រោយពេលមានការបោសសម្អាតភូមិភាគបូព៌ា ក្នុងឆ្នាំ ១៩៧៨។ នៅពេលរង់ចាំ ហ៊ុន ដែលជាមេឃុំជំនីក ទើប

---

[1593] <u>សុះ រំលី</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/372.1** ទំព័រ ១៣ មុនម៉ោង 09.45.15 ទំព័រ ៦២ មុនម៉ោង 14.41.17។

[1594] <u>សុះ រំលី</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/372.1** ទំព័រ ១៣ ប្រហែលម៉ោង 09.45.15 និងទំព័រ ៦៤ មុនម៉ោង 15.05.38។

[1595] <u>សុះ រំលី</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/372.1** ទំព័រ ១៤ មុនម៉ោង 09.48.15។

[1596] <u>សុះ រំលី</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/372.1** ទំព័រ ៥៨ ក្រោយម៉ោង 14.25.57។

តែងតាំងថ្មី នៅក្រៅកន្លែងប្រជុំ[1597]គាត់បានស្តាប់ឮការពិភាក្សាគ្នាទាក់ទងនឹងគោលនយោបាយកម្ទេច "កុំថាតែចាម ខ្មែរចល័តអីមក <u>កម្ទេចអស់</u> ព្រោះខាងនោះ វាពួកក្បត់អង្គការ" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[1598]។ ម្យ៉ាងទៀត លោក វ៉ាន់ ម៉ាត់ បានបន្ថែមថា ចំនួនភាគរយនៃការបោសសម្អាតធ្វើដោយតំបន់នីមួយៗ ដែលត្រូវបានលើកយកមកនិយាយក្នុងពេលប្រជុំ "[...] មិននិយាយរឿងភាគរយជនជាតិចាមទេ"[1599]។

១៦៩៩. ពេលចោទសួរឡើងវិញដោយចៅក្រម LAVERGNE ទាក់ទងនឹងមនុស្សកំណត់ជាគោលដៅក្នុងការប្រជុំនេះ លោក វ៉ាន់ ម៉ាត់ បានបញ្ជាក់ថា "[...] គោលការណ៍គេ បោសសម្អាតចោលទាំងអស់ [...]"[1600]។ ហើយនៅក្នុងសំណួរចុងក្រោយរបស់ចៅក្រមដដែល ទាក់ទងនឹងប្រធានបទនេះ៖

> "ស៖ ដូច្នេះ ក្នុងពេលប្រជុំនោះ គេមិនបានបញ្ជាក់ថា កម្ទេចតែជនជាតិចាម ឬក៏យ៉ាងម៉េចទេ គេថាកម្ទេចទាំងអស់ឱ្យតែជាជនក្បត់មែនទេ?
>
> ឆ៖ បាទ <u>ហ្នឹងហើយ</u>។ ឱ្យតែជនក្បត់ គេយកកម្ទេចទាំងអស់ហ្នឹង" (យើងជាអ្នកគូសបន្ទាត់ពីក្រោម[1601]។

១៧០០. សាក្សី វ៉ាន់ ម៉ាត់ បានសន្និដ្ឋានដូច្នេះថា៖ "[...] ខ្ញុំឆ្លើយតាំងពីយូរមក ខ្ញុំឆ្លើយថា រឿងមិនប្រកាន់ថាចាម ខ្មែរអីទេ ព្រោះគោលការណ៍វាបោសសម្អាត សម្អាតខាងបូព៌ា [...]"[1602]។ ពេលត្រលប់មកពី

---

[1597] <u>វ៉ាន់ ម៉ាត់</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/398.1** ទំព័រ ២៣ មុនម៉ោង 10.38.31 ទំព័រ ២៣ ក្រោយម៉ោង 10.38.31។

[1598] <u>វ៉ាន់ ម៉ាត់</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/398.1** ទំព័រ ២៤-២៥ មុនម៉ោង 10.44.38 ទំព័រ ៤៣ មុនម៉ោង 13.35.40, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ **E3/8735**, ERN KH 00716487។

[1599] <u>វ៉ាន់ ម៉ាត់</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/398.1** ទំព័រ ៦១ មុនម៉ោង 14.36.49។

[1600] <u>វ៉ាន់ ម៉ាត់</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/398.1** ទំព័រ ៤៤ មុនម៉ោង 13.35.40 ទំព័រ ៤៥ មុនម៉ោង 13.40.05 ("គោលការណ៍របស់វា យកទៅកម្ទេចទាំងអស់ហ្នឹង ចល័តទាំងប៉ុន្មាន ទាំងចាម ទាំងខ្មែរ")។ សូមមើលផងដែរនូវចម្លើយរបស់គាត់ទៅកាន់មេធាវីការពារក្តី៖ ទំព័រ ៦០ មុនម៉ោង 14.33.25 ("មិនមែនតែចាមទេដែលត្រូវបោសសម្អាត មានទាំងខ្មែរ មានទាំងចិនទៀត") ទំព័រ ៦០ ក្រោយម៉ោង 14.33.25 (ការប្រជុំ គឺដាក់ផែនការកម្ទេចចោរព្រៃឱ្យអស់តែម្តង")។

[1601] <u>វ៉ាន់ ម៉ាត់</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/398.1** ទំព័រ ៤៥ មុនម៉ោង 13.42.21។

[1602] <u>វ៉ាន់ ម៉ាត់</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/398.1** ទំព័រ ៧៩ ក្រោយម៉ោង 16.02.16, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ **E3/8735**, ERN KH 00716487 ("គេនិយាយសំដៅដល់ខ្មាំងទូទៅទាំងអស់តែម្តង មិនថា ចាម ខ្មែរ ឬចិនទេ")។

ប្រជុំវិញ គាត់បាននិយាយរៀបរាប់ផែនការនេះប្រាប់មិត្តភក្តិគាត់ជាប្រធានកងចល័ត មានទាំងខ្មែរ មានទាំងចាម[1603]។

១៧០១. ការអះអាងនេះត្រូវបានគាំទ្រដោយសាក្សី បាន សៀក ដោយគាត់បានអះអាងថាមិនដែលបាន ទទួលផែនការពី កែ ពក ឬពីបុគ្គលណាផ្សេង ក្នុងពេលប្រជុំ ឱ្យសម្លាប់ជនជាតិចាម នោះទេ[1604]។ គាត់បានបញ្ជាក់ថា៖

> "[...] បងប្អូនខ្មែរ និងបងប្អូនអ៊ីស្លាម ក្នុងពេលនោះ ដូចតែគ្នា [...]។ ដូច្នេះ ឱ្យតែខ្លាំង ខ្លាំង សេ.អ៊ី .អា និង ខ្លាំង កា.ហ្សេ.បេ គឺកម្ទេចទាំងអស់។ អត់ឮថាគេនេះចាម នេះចិន នេះខ្មែរ ខ្មែរយើងក៏អស់ច្រើនដែរ មិនមែនអស់តែបងប្អូនអ៊ីស្លាមទេ [...]"[1605]។

១៧០២. ពេលចោទសួរដោយក្រុមមេធាវីការពារក្តី ទាក់ទងនឹងការចោទប្រកាន់ថាមានការប្រជុំជាមួយ កែ ពក នៅស្រុកសណ្តាន់ ដែលក្នុងពេលនោះ មានបទបញ្ជាឱ្យកម្ទេចជនជាតិចាមទាំងអស់ ហើយក្នុង ពេលនោះដែរ មានមនុស្សម្នាក់បានដឹកគាត់លើម៉ូតូ លោក បាន សៀក បានបញ្ជាក់ថាគាត់មិនដែល បានចូលរួមប្រជុំនេះឡើយ ដោយគាត់បញ្ជាក់ថា គាត់បើកម៉ូតូខ្លួនឯង សម្រាប់ការធ្វើដំណើររបស់ គាត់[1606]។

១៧០៣. ពាក់ព័ន្ធនឹងការចោទប្រកាន់ថាមានការសម្លាប់ជនជាតិចាម នៅក្រូចឆ្មារ លោក បាន សៀក បាន ពន្យល់ថា គាត់ពុំបានដឹងពីរឿងនេះទេ ហើយគាត់បានបញ្ជាក់ថា៖

> "បាទ ខ្ញុំបាទមិនដឹងទេទាន ព្រោះខ្ញុំបាទរៀនសូត្រ <u>មិនដែលខាងលើឱ្យធ្វើការបោសសម្អាតចាមទេ</u> ព្រោះកាលទៅហ្នឹង សភាពការណ៍វាតឹងតែងហើយ។ ដូច្នេះ ការបោសសម្អាតគ្មានការ ផែនការ អី ធ្វើអីចឹងទេទាន។ ហើយ <u>បងពក ក៏មិនដែលធ្វើផែនការថា អ្ហែ យើងត្រូវបោសសម្អាតចាម</u>។ [...]

[1603] <u>វ៉ាន់ ម៉ាត់</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ឯកសារ **E1/398.1** ទំព័រ ២៧ ក្រោយម៉ោង 10.49.22។

[1604] <u>បាន សៀក</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ឯកសារ **E1/354.1** ទំព័រ ២៥ ក្រោយម៉ោង 10.48.38 ទំព័រ ៥៨ មុនម៉ោង 15.13.03 ទំព័រ ៥៩ មុនម៉ោង 15.16.13 ទំព័រ ៥៩ មុនម៉ោង 15.18.06។

[1605] <u>បាន សៀក</u>៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ឯកសារ **E1/353.1** ទំព័រ ៣៧ មុនម៉ោង 11.14.05។

[1606] <u>បាន សៀក</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ឯកសារ **E1/354.1** ទំព័រ ៥៩ មុនម៉ោង 15.16.13។

បងប្អូនចាមនៅហ្នឹង ក៏ប៉ុន្តែគេមិនធ្វើផែនការបោសសម្អាតផង ព្រោះអ្នកបះបោរទេ ដែលខ្ញុំដឹង ខ្ញុំ ទៅគឺមានតែអ្នកបះបោរទេ [...]" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[1607]។

១៧០៤. គេត្រូវកត់សម្គាល់ថាលោកស្រី នោ សាទះ បាននិយាយរៀបរាប់ពីការសួរចម្លើយនៅពេលគាត់ជាប់ឃុំ នៅទ្រា ក្នុងឆ្នាំ ១៩៧៨ ដែលក្នុងពេលសួរចម្លើយនោះ សំណួរទាំងឡាយហាក់ដូចជាផ្តោតលើទំនាក់ទំនងរបស់គាត់ជាមួយវៀតណាម។ គាត់បានពន្យល់ថា គេបានសួរគាត់ថាជាកូនយួនពិតដែរឬអត់ ហើយចិត្តមានះរបស់គាត់ក្នុងការនិយាយថាខ្លួនជាកូនខ្មែរ បានជួយឱ្យគាត់ត្រូវគេដោះលែង[1608]។ គាត់បានបញ្ជាក់ថា៖

> "គេចោទអ៊ីចេះ គេថាអ្នកនៅខាងបូព៌ាហ្នឹង សុទ្ធតែក្បាលយួន ខ្លួនខ្មែរ។ ចាមក៏ដោយ ខ្មែរក៏ដោយ [...] ចូលជាមួយខ្សែវៀតណាមទាំងអស់ [...]។ អ្នកនៅខាងនិរតីអត់អីទេ នៅខាងណោះ គេហៅខាងណោះ នៅខាងបូព៌ាហ្នឹងគឺថាក្បាលយួន ខ្លួនខ្មែរតែម្តងហើយ។ អ៊ីចឹងហើយបានគេថា គេប្រមូលចាម ហើយយកទៅទាំងអស់ ទាល់តែរាល់ថ្ងៃនេះ អត់ឃើញមកទេ។ [...] ទាំងម្តាយទាំងឪពុក ទាំងប្អូនខ្ញុំទាំងអស់ មីងមាខ្ញុំ [...]។ នៅសល់ម្នាក់គត់ហ្នឹង ប៊ិះតែនឹងស្លាប់ទៀត អានេះដោយសារថាមាត់ឆ្លើយថា កូនខ្មែរមួយម៉ាត់ទេ ខ្ញុំនៅរស់មានជីវិតដល់រាល់ថ្ងៃនេះ។ ឆ្លើយជាមួយវាបីដង វាចោទខ្ញុំថាយួនទេណា។ ខ្ញុំស្រែកបីដង បានវាបញ្ឈប់ខ្ញុំ វាជឿថា ខ្ញុំកូនខ្មែរមែន"[1609]។

១៧០៥. ដូច្នេះ បើតាមលោកស្រី នោ សាទះ គឺពុំមែនការណ៍ដែលជាជនជាតិចាមទេដែលចោទជាបញ្ហានោះ។ ម្យ៉ាងវិញទៀត សក្ខីកម្មរបស់ សុះ មីន មានអត្ថន័យដូចគ្នានេះដែរ ព្រោះថាគាត់បានពន្យល់ប្រាប់អង្គជំនុំជម្រះថា ការសម្លាប់មនុស្សធ្វើឡើង "ដោយមិនប្រកាន់អ្នកណាជាអ្នកណាឡើយ" ព្រោះថា ជនជាតិចាម និងជនជាតិចិន ក្នុងភូមិភាគបូព៌ា ត្រូវកម្មាភិបាលភូមិភាគកណ្តាលចោទថាមានក្បាលយួន[1610]។

---

[1607] បាន សៀក៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ឯកសារ **E1/354.1** ទំព័រ ៥៩ មុនម៉ោង 15.18.06។

[1608] នោ សាទះ៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/350.1** ទំព័រ ៤៦ មុនម៉ោង 14.17.12 ("រួចគេសួរខ្ញុំថា នាងឯងកូនចាម កូនខ្មែរ? ខ្ញុំឆ្លើយថា ខ្ញុំកូនខ្មែរ! ក្រោយពីឆ្លើយជាមួយវា ខ្ញុំហ្នឹងកូនខ្មែរ បានវាទទួលស្គាល់ថាខ្មែរមែន")។

[1609] នោ សាទះ៖ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/351.1** ទំព័រ ១៩-២០ ក្រោយម៉ោង 10.03.07។

[1610] សុះ មីន៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/344.1** ទំព័រ ៨ ក្រោយម៉ោង 09.22.13។

១៧០៦. ដូចដែលបានរំឭកពីខាងលើ ក្នុងផ្នែកជម្លោះប្រដាប់អាវុធ ១៩៧៨ គឺជាឆ្នាំវាយសម្រុកនៃសង្គ្រាមប្រឆាំងនឹងវៀតណាម[1611]។ សាក្សី បាន សៀក ពន្យល់ប្រាប់អង្គជំនុំជម្រះថា ក្រោយលោក ហេង សំរិន និងលោក ជា ស៊ីម រត់គេចខ្លួន ថ្នាក់លើបានបញ្ជាឱ្យប្រមូលកម្លាំងបញ្ជូនទៅសមរភូមិ តស៊ូប្រឆាំងជនក្បត់ ប៉ុន្តែគាត់ពុំមានអ្វីនិយាយទាក់ទងនឹងជនជាតិចាមឡើយ[1612]។ ផ្ទុយទៅវិញ ក្រោយមានការបះបោរនៅក្រូចឆ្មារ លោក បាន សៀក បានថ្លែងថាគាត់បានទទួលបញ្ជាពីមេរបស់គាត់ឱ្យកម្ទេចអ្នកដែលត្រូវចាត់ទុកថាជាភ្នាក់ងារ កា.ហ្សេ.បេ ទោះជាពួកគេមានជាតិសាសន៍អ្វីក៏ដោយ[1613]។ ដូច្នេះ ការបង្ក្រាបនេះ ត្រូវបានធ្វើឡើងក្នុងបរិបទជម្លោះប្រដាប់អាវុធ ក្រោយមានការបះបោរ និងពុំមែនដោយសារមូលហេតុសាសនា ឬជាតិពន្ធុ អ្វីឡើយ។

១៧០៧. គេត្រូវកត់សម្គាល់ផងដែរថា បើតាមលោក វ៉ាន់ ម៉ាត់ ជម្លោះប្រដាប់អាវុធរវាងភូមិភាគកណ្តាល និងភូមិភាគបូព៌ា បានចាប់ផ្តើមឡើងនៅឆ្នាំ ១៩៧៧។ គាត់បានឃើញការវាយប្រហារ និងការបាញ់គ្នាទៅវិញទៅមក ដោយផ្ទាល់ភ្នែក ក្នុងភូមិព្រែកតាហុក ដែលនៅទីនោះ ផ្ទះសម្បែងអ្នកភូមិ ត្រូវដុតបំផ្លាញ។ "កងទ័ពអង្គការ" មកពីខាងត្បូង ហើយភូមិភាគបូព៌ា ចង់នៅចាំស្កាត់នៅព្រំប្រទល់ខេត្តក្រចេះ និងកំពង់ចាម។ ក្រោយបរាជ័យ កងទ័ពភូមិភាគបូព៌ា បានទម្លាក់អាវុធ ហើយរត់គេចខ្លួន[1614]។

១៧០៨. លោក វ៉ាន់ ម៉ាត់ បានរៀបរាប់ប្រាប់អង្គជំនុំជម្រះផងដែរពីការបាញ់ប្រហាររបស់កងចល័តទៅលើលេខាស្រុក មេឃុំ និងទាហានខ្មែរក្រហមពីរនាក់ ធ្វើឱ្យពួកគេស្លាប់ទាំងអស់ ក្នុងពេលជម្លៀស

---

[1611] សូមមើលខាងលើ កថាខណ្ឌ ៨០១ ដល់កថាខណ្ឌ ៨១១។

[1612] <u>បាន សៀក</u>៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **E1/353.1** ទំព័រ ៦១ មុនម៉ោង 14.33.41 ទំព័រ ៧៣ ក្រោយម៉ោង 15.34.22 ទំព័រ ៨១ ក្រោយម៉ោង 16.00.55។

[1613] <u>បាន សៀក</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **E1/354.1** ទំព័រ ២៧ ប្រហែលម៉ោង 10.58.42, កំណត់ហេតុស្តាប់ចម្លើយ បាន សៀក ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩ឯកសារ **E3/375**, ERN KH 00348794, កំណត់ហេតុស្តាប់ចម្លើយ បាន សៀក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ឯកសារ **E3/9517** សំណួរ/ចម្លើយទី ៥០ សំណួរ/ចម្លើយទី ៥៧, កំណត់ហេតុស្តាប់ចម្លើយ បាន សៀក ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E3/9649** សំណួរ/ចម្លើយទី ៤ សំណួរ/ចម្លើយទី ៦។

[1614] <u>វ៉ាន់ ម៉ាត់</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ឯកសារ **E1/398.1** ទំព័រ ៨១ មុនម៉ោង 16.10.24។

ប្រជាជន[1615]។ ព្រឹត្តិការណ៍នេះ ត្រូវបានបញ្ជាក់អះអាងដោយសាក្សី បាន សៀក ដោយគាត់នៅចាំថាអនុលេខារបស់គាត់ឈ្មោះ ឌី ត្រូវបានសម្លាប់ដោយគ្រាប់កាំភ្លើងរបស់កងឈ្លប ក្នុងពេលកើតមានចលាចល។ ហេតុដូច្នេះ គាត់ក៏ប្រយ័ត្នខ្លួន[1616]។

១៧០៩. លោក បាន សៀក ទទួលស្គាល់ថាគាត់បានឃើញការឃុំខ្លួនមនុស្សកងចល័តពី ១០ ទៅ ២០ នាក់ ដែលបានធ្វើការបះបោរ នៅលើកោះមួយ នៅក្នុងស្រុកក្រូចឆ្មារ។ តាមរយៈកងឈ្លប គាត់បានដឹងថាមានអ្នកបះបោរខ្មែរ និងចាម ក្នុងចំនួនមួយមិនច្បាស់។ គាត់យល់ថា កងទ័ពមជ្ឈិម និងទាហានស្រុកក្រូចឆ្មារ បានសម្លាប់មនុស្ស[1617]។ ជាថ្មីម្ដងទៀត នៅត្រង់នេះ វាគឺជាការបង្ក្រាបទាក់ទងនឹងចលនាបះបោរ និងពុំមែនពាក់ព័ន្ធនឹងសាសនា ឬក្រុមជាតិពន្ធុ អ្វីនោះទេ។

១៧១០. ម្យ៉ាងវិញទៀត លោកស្រី ម៉ាត់ ស ជាជនជាតិចាម បានបញ្ជាក់ប្រាប់តុលាការថា ប្ដី និងគ្រួសារសាច់ថ្លៃរបស់គាត់ គឺនៅមានជីវិតមកទល់សព្វថ្ងៃ ហើយថាមនុស្សគ្រប់គ្នាបានរត់គេចខ្លួន ក្រោយការរៀបការរបស់គាត់ នៅពេលឮគេនិយាយថាខ្មែរក្រហមសម្លាប់មនុស្ស[1618]។ គាត់បានបញ្ជាក់ថា ពេលនោះ ចាម និងខ្មែរ បានជួបគ្នាពេលរត់គេចខ្លួន[1619]។

១៧១១. ចំណែកឯលោក កែ ពេជ្រវណ្ណៈ វិញ គាត់បានថ្លែងប្រាប់អ្នកស៊ើបអង្កេតថា ឪពុកគាត់ កែ ពក បានទទួលបញ្ជាពី ប៉ុល ពត "ឱ្យចុះស្រាវជ្រាវរឿងនេះជាបន្ទាន់" លើសាកសពដែលគាត់បានឃើញអណ្ដែតទឹកក្នុងទន្លេមេគង្គ។ នៅពេលស៊ើបអង្កេតចប់ គេបានសន្និដ្ឋានថាមានការសម្លាប់ចាម នៅក្រូចឆ្មារ ហើយទម្លាក់សាកសពចូលក្នុងទន្លេដោយ "កងអន្តរាគមន៍របស់មជ្ឈិម ដែល

[1615] វ៉ាន់ ម៉ាត់៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ឯកសារ E1/398.1 ទំព័រ ៧៣ មុនម៉ោង 15.39.34។

[1616] បាន សៀក៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ឯកសារ E1/353.1 ទំព័រ ៥៣ មុនម៉ោង 14.02.36 ទំព័រ ៧៤ មុនម៉ោង 15.39.16, ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ឯកសារ E1/354.1 ទំព័រ ១៨ ក្រោយម៉ោង 10.04.21 ទំព័រ ៤៧ ប្រហែលម៉ោង 14.07.23។

[1617] បាន សៀក៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ឯកសារ E1/353.1 ទំព័រ ៥៨ ប្រហែលម៉ោង 14.20.14, ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ឯកសារ E1/354.1 ទំព័រ ២៥ មុនម៉ោង 10.51.18 ទំព័រ ២៧ មុនម៉ោង 10.58.42។

[1618] ម៉ាត់ ស៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/375.1 ទំព័រ ៨៥ ក្រោយម៉ោង 15.53.38, ស៊ុះ រំលី៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ឯកសារ E1/372.1 ទំព័រ ១២ ក្រោយម៉ោង 09.41.33។

[1619] ម៉ាត់ ស៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ឯកសារ E1/375.1 ទំព័រ ៦៨ ក្រោយម៉ោង 14.41.53។

ដឹកនាំដោយ ពិន"។ កែ ពក បានផ្ញើរបាយការណ៍មួយទៅ "ម.៨៧០" ទាក់ទងនឹងបញ្ហានេះ។ ក្នុងពេលជាមួយគ្នានោះ ប្រជាជនភូមិភាគកណ្ដាលមួយចំនួនបានរត់ចូលព្រៃ ដោយសារតែមានការបោសសម្អាតភូមិភាគបូព៌ា។ គឺស្ថិតក្នុងបរិបទនេះហើយដែលខិតប័ណ្ណអំពាវនាវលើកលែងទោសត្រូវបានចេញដោយ "មន្ទីរ ម.៨៧០" ដើម្បីដោះលែងអ្នកទោស។ លោក កែ ពេជ្រវណ្ណៈ និយាយថាព្រឹត្តិការណ៍ទាំងនេះកើតឡើងប្រហែលពាក់កណ្ដាលឆ្នាំ ១៩៧៨ ពេលស្ថានការណ៍កំពុងច្របូកច្របល់[1620]។

១៧១២. ដោយសារមរណភាពរបស់សាក្សី ដូច្នេះសក្ខីកម្មរបស់គាត់អាចត្រូវបានយកមកពិចារណា ដោយពុំមានលទ្ធភាពសួរដេញដោលគាត់បាន។ ក៏ប៉ុន្តែ ចម្លើយរបស់សាក្សីបង្ហាញឱ្យឃើញថា "មេ" ប៉ុល ពត ពុំបានដឹងពីហេតុការណ៍ដែលបានកើតឡើងនៅក្រួចឆ្មារ ដែលនាំឱ្យគាត់សុំឱ្យ កែ ពក ចុះទៅស្រាវជ្រាវ។ វាជាការគាំទ្រដល់ការលើកឡើងរបស់ក្រុមមេធាវីការពារក្ដី ដែលថាការសម្លាប់មនុស្សធ្វើឡើងក្នុងស្រុកនេះ គឺជាគំនិតចេញមកពីមូលដ្ឋាន ដោយបក្សកុម្មុយនីស្ដកម្ពុជានៅភ្នំពេញពុំបានដឹងឡើយ។ ម្យ៉ាងវិញទៀត ទោះបីជាគេត្រូវជឿជាក់លើសំដីរបស់ កែ ពេជ្រវណ្ណៈ ក៏ដោយ ក៏វិធានការបន្ទាន់របស់ ប៉ុល ពត គឺត្រូវចេញសារាចរមួយដើម្បីឱ្យរឿងរ៉ាវបានស្ងប់ស្ងាត់ ក្នុងភូមិភាគជាប់ព្រំដែនមួយនេះ។

១៧១៣. នៅត្រង់នេះ គេត្រូវរំឭកឡើងវិញថា ពាក់កណ្ដាលឆ្នាំ ១៩៧៨ គឺជាពេលដែលអ្វីៗគ្រប់យ៉ាងដំណើរការមិនល្អ ក្នុងផ្នែកយោធា ហើយកងទ័ពបានទទួលបរាជ័យនៅតាមមូលដ្ឋាន និងបានធ្វើសកម្មភាពដោយគ្មានសណ្ដាប់ធ្នាប់។ ទោះយ៉ាងណា ចម្លើយនេះមិនអាចនាំឱ្យគេយល់ថាមានផែនការណាមួយចេញពីថ្នាក់លើបក្សកុម្មុយនីស្ដ បានឡើយ តែរឿងវាផ្ទុយពីនេះ។

១៧១៤. ការប្រជុំជាច្រើនរបស់ កែ ពក ជាមួយអ្នកនៅក្រោមឱវាទ ត្រូវបានលើកឡើងដោយសាក្សីមួយចំនួន ដែលយ៉ាងហោចណាស់ក៏ពីរនាក់ដែរ ដោយក្នុងនោះ ការប្រជុំដែលត្រូវបានរាយការណ៍ដោយ វ៉ាន់ ម៉ាត់ គឺខុសគ្នាពីការប្រជុំលើកឡើងដោយសាក្សី បាន សៀក។ ក៏ប៉ុន្តែ ដូចដែលបានឃើញពីខាងលើ សាក្សីទាំងពីរនាក់នេះបានអះអាងថា រាល់កិច្ចប្រជុំជាមួយ កែ ពក គឺពុំដែលលើកយកប្រធានបទជនជាតិចាម មកពិភាក្សាម្ដងណាឡើយ។ ពុំមានភ័ស្ដុតាង បទបញ្ជា ឬ ផែនការ

[1620] កំណត់ហេតុស្ដាប់ចម្លើយ កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៩ឯកសារ **E3/35**, ERN KH 00340570។

សម្លាប់ណាមួយប្រឆាំងនឹងក្រុមជាក់លាក់នេះ នោះទេ។ ភ័ស្តុតាង ហាក់ដូចជាបង្ហាញថា មានការបះបោរកើតឡើងប្រឆាំងរបបខ្មែរក្រហម ហើយថាទាំងចាម ទាំងខ្មែរ បានទទួលរងលទ្ធផលនៃចលនាបះបោរ។ ដូច្នេះ វាមិនសមហេតុសមផលទេដែលត្រូវសន្និដ្ឋានថា ជនជាតិចាម គឺជាគោលដៅនៃការសម្លាប់ក្នុងឆ្នាំ ១៩៧៨ ហើយវារឹតតែមិនអាចថែមទៀត បើចាមជាគោលដៅសម្លាប់ចាប់ពីឆ្នាំ ១៩៧៧ មក ដូចដែលលោក អ៊ីសា ឧស្មាន បានលើកឡើងនោះ។

### 2.ខ. ករណីស្រុកកងមាស

#### i. បញ្ជាឱ្យចាប់ខ្លួន

១៧១៥. លោក ហ៊ីម ម៉ាន បានឱ្យដឹងថាមានពាក្យចចាមអារ៉ាម "ពេញភូមិ" ថា ចាមហ្នឹងខ្មាំងទី១ ទាំងបងប្អូនខ្មែរខ្មាំងទី២"។ គាត់បានដឹងរឿងនេះពីខ្មែរម្នាក់ តែគាត់ "មិនដឹងថាឈ្មោះអីទេ" ដែលបានប្រាប់គាត់ថា "គាត់និយាយជំនាន់ព្រះហ្នឹងមក [...]ហ្នឹងចាមហ្នឹងឈ្មោភសង្គ្រាមណាស់ ច្បាំងមួយជំនាន់ព្រះមកហើយ"[1621]។

១៧១៦. ការថ្លែងចម្លែកបែបនេះ អំពីខ្មែរម្នាក់ដែលគេពុំស្គាល់ គឺមិនស៊ីគ្នាបន្តិចសោះទៅនឹងអ្វីដែលអង្គភាពណាមួយរបស់បក្សកុម្មុយនីស្ត អាចនិយាយឡើងដូច្នេះ។ ដូច្នេះ វានៅគ្រាន់តែជាការនិយាយតគ្នារបស់អ្នកភូមិម្នាក់ ហើយដែលវាទំនងកើតចេញមកពីបុរេវិនិច្ឆ័យរបស់គាត់ តែប៉ុណ្ណោះ។

១៧១៧. លោក ហ៊ីម ម៉ាន បានថ្លែងផងដែរថា ថ្ងៃមួយ "មិនដឹងឆ្នាំប៉ុន្មាន វា ១៩៧៨ ក៏មិនដឹង ៧៩ មិនដឹង"[1622] មានការប្រមូលផ្តុំជនជាតិចាមដោយពួកដាវវែង ហើយក្នុងពេលនោះ គាត់បាន "ជួបអ្នកតំបន់ម្នាក់"[1623]។ ប៉ុន្តែ គាត់គ្មានបានផ្តល់ការបញ្ជាក់ណាមួយទាក់ទងនឹងឈ្មោះរបស់មនុស្សម្នាក់នោះ ហើយថាតើគាត់ដឹងដោយរបៀបណាថាបុគ្គលនោះមកពីភូមិភាគ។

---

[1621] ហ៊ីម ម៉ាន៖ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/349.1** ទំព័រ ៣១ មុនម៉ោង 11.15.25។

[1622] ហ៊ីម ម៉ាន៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/350.1** ទំព័រ ៣២ មុនម៉ោង 11.16.24។

[1623] ហ៊ីម ម៉ាន៖ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/349.1** ទំព័រ ៣៣-៣៤ មុនម៉ោង 11.25.18។

១៧១៨. ភស្តុតាងដទៃទៀត គឺជាសក្ខីកម្មផ្ទុយគ្នាមួយចំនួន ដែលទំនងជាចូលរួមគាំទ្រដល់គំនិតដែលគិតថា មានការចាប់ខ្លួនប្រជាជនទាំងអស់តាមទំនើងចិត្ត។

១៧១៩. លោក សេង ស្រ៊ុន បានឱ្យដឹងថា ជនជាតិចាមដែលកម្មាភិបាលមូលដ្ឋានស្គាល់ ត្រូវបានចាប់ខ្លួនទៅតាមបញ្ជី "សម្រង់ឈ្មោះ" ដែលគេបានឱ្យប្រធានកងរៀបចំ។ ប៉ុន្តែ ក្រោយពីបានអះអាងពីភាពផ្ទុយគ្នានៅក្នុងចម្លើយពីមុនរបស់ខ្លួន[1624] លោក សេង ស្រ៊ុន បានទទួលស្គាល់ក្នុងអំឡុងពេលសវនាការថា ខ្លួនគាត់ផ្ទាល់ គឺពុំដែលបានអានលិខិតណែនាំ "ឱ្យធ្វើស្ថិតិប្រជាពលរដ្ឋចាម[...] ប៉ុន្មាននាក់ [...]" ឡើយ តែគាត់ថាបានដឹងពីខ្លឹមសារនៃលិខិតនោះ[1625]។

១៧២០. លោក សេង ស្រ៊ុន បានបញ្ជាក់អះអាងប្រាប់តុលាការពីចម្លើយកាលពីឆ្នាំ ២០០៨ ដែលក្នុងចម្លើយនោះ គាត់បានបញ្ជាក់ថាបានចូលរួមប្រជុំនៅស្ពានពាមជីកង ហើយ "អ្នកភូមិទាំងអស់គ្នា" និង "មេកងទាំងអស់" ត្រូវបាន កាន ជាគណៈស្រុក កោះហៅឱ្យចូលរួម ក្រោមវត្តមានរបស់ អាន ជាគណៈតំបន់។ អាន បាន "និយាយដល់ខ្មាំង" ក្នុងចំណោមប្រជាជន តែមិនបានបញ្ជាក់ឱ្យច្បាស់ថានរណាខ្លះជាខ្មាំង ហើយ "ក្រោយកិច្ចប្រជុំនេះ" ក៏មានការចាប់ខ្លួនមនុស្ស។

១៧២១. មុនការចាប់ខ្លួនមនុស្ស លោក សំរិត មុយ បាននិយាយពីការប្រជុំក្នុងសហករណ៍ទាំងមូល ដោយពេលនោះ អាន បានឧទ្ទេសនាមខ្លួនឯងថាជាប្រធានតំបន់។ ផ្ទុយពីអ្វីដែលលោក សេង ស្រ៊ុន បានជម្រាបប្រាប់តុលាការ អាន ដូចជាពុំបាននិយាយលើកឡើងពីឈ្មោះ កុយ ធួន ទេ តែគាត់បានជំរុញ " [...] ឱ្យគោរព ប្រឹងធ្វើការ គោរពបក្ស [...]"[1626]។ អាន បាននិយាយពី "ខ្មាំងបង្កប់" ប៉ុន្តែ "អត់មាននិយាយពីរឿងចាមទេ"[1627]។

---

[1624] សេង ស្រ៊ុន៖ ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/346.1** ទំព័រ ២៦ ក្រោយម៉ោង 10.41.57។

[1625] សេង ស្រ៊ុន៖ ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/346.1** ទំព័រ ៤៤ ក្រោយម៉ោង 11.46.08 ទំព័រ ៤៥ ក្រោយម៉ោង 11.49.15។

[1626] សំរិត មុយ៖ ប្រតិចារឹក ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/347.1** ទំព័រ ៦៦ ក្រោយម៉ោង 15.11.57។

[1627] សំរិត មុយ៖ ប្រតិចារឹក ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/347.1** ទំព័រ ៦៨ ក្រោយម៉ោង 15.17.55។ គាត់បានបញ្ជាក់ថា កម្មាភិបាលតិចតួចប៉ុណ្ណោះត្រូវបានឃុំ "ពីរបីថ្ងៃ"។

១៧២២. លោក សយ ឌឿន ពុំបានឮពីការប្រជុំនៅស្ពានពាមជីកង ដែលលើកឡើងដោយលោក សំរិត មុយ និង លោក សេង ស្រ៊ុន នោះទេ[1628]។ នៅក្នុងសវនាការ គាត់គ្រាន់តែបានបញ្ជាក់ថា ឃុំបាននិយាយថា "[បញ្ជាចេញមក] ពីស្រុកដល់ឃុំ" ដោយគាត់បញ្ជាក់ថា ភាព ជាអ្នកសរសេរបញ្ជាឱ្យចាប់ខ្លួន[1629]។ ប៉ុន្តែ គាត់មិនដែលបានឃើញ គណៈស្រុក កាន និយាយគ្នាជាមួយ ភាព ម្តងណាឡើយ ទាក់ទងនឹងបញ្ជានេះ ហើយគាត់ក៏បានបញ្ជាក់ផងដែរថា គាត់មិនដឹងនរណាជាអ្នកដាក់បញ្ជានេះឱ្យហាន ហើយគាត់ក៏មិនដែលធ្លាប់ឃើញ កាន នៅជាមួយកម្មាភិបាលតំបន់ឡើយ[1630]។

១៧២៣. លោក មុយ វ៉ាន់នី ក៏មិនដែលឃើញគណៈស្រុក កាន ហើយគាត់មិនដឹងថាសេចក្តីសម្រេចត្រូវធ្វើឡើងរបៀបណាដែរ។ គាត់ក៏មិនដែលធ្លាប់ចូលរួមប្រជុំជាសាធារណៈ[1631]។ ទោះបីជាគាត់បានថ្លែងថាបានឃើញ "មនុស្សណែនវិហារ" ក្នុងវត្តអូរត្រកួន ដែល "ភាគច្រើន" គឺចាម ហើយពួកគេត្រូវបានដឹកមកតាមកាណូត ហើយគាត់ "ឮគេនិយាយថាមានផែនការមួយប្រមូលចាម"[1632] ក៏ដោយ តែគាត់ពុំបានប្រាប់ថាគាត់ដឹងព័ត៌មាននេះ តាមរយៈអ្នកណា និងដោយរបៀបណាឡើយ។ម្យ៉ាងវិញទៀត ក្នុងអំឡុងពេលសវនាការ គាត់បានធ្វើការបញ្ជាក់ ទាក់ទងនឹងការចាប់ខ្លួនមនុស្សថាគាត់ "មិនដឹងថាគេបញ្ជាយ៉ាងម៉េច" ហើយ "រឿងផែនការយ៉ាងម៉េចៗ គឺអត់ដឹង។ គេមិនបានប្រាប់ខ្ញុំទេ"[1633]។

---

[1628] សយ ឌឿន៖ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/374.1** ទំព័រ ២៨-២៩ ចន្លោះម៉ោង 10.45.00 និងម៉ោង 10.48.18 ទំព័រ ៥២-៥៤ ចន្លោះម៉ោង 14.00.00 និងម៉ោង 14.06.35។

[1629] សយ ឌឿន៖ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/374.1** ទំព័រ ៣៣ ក្រោយម៉ោង 11.03.05 ទំព័រ ៧១ ប្រហែលម៉ោង 15.24.43។

[1630] សយ ឌឿន៖ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/374.1** ទំព័រ ៦២-៦៣ មុនម៉ោង 14.36.49។

[1631] មុយ វ៉ាន់នី៖ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/373.1** ទំព័រ ៣០ ក្រោយម៉ោង 11.32.21 ទំព័រ ៣២ មុនម៉ោង 13.36.58 ទំព័រ ៥៩ ក្រោយម៉ោង 15.18.58។

[1632] មុយ វ៉ាន់នី៖ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/373.1** ទំព័រ ៤៨ មុនម៉ោង 14.27.42 ទំព័រ ៣៦ ក្រោយម៉ោង 13.53.15។

[1633] មុយ វ៉ាន់នី៖ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/373.1** ទំព័រ ៣៤ ក្រោយម៉ោង 13.45.31 ទំព័រ ៣៥ មុនម៉ោង 13.48.57។

១៧២៤. លោកស្រី រៀល នាង បានឱ្យដឹងថា បញ្ជាចាប់ខ្លួនមនុស្សបញ្ជូន "ចេញពីលេខាស្រុកទៅគណៈឃុំ" ហើយការចាប់ខ្លួនពេលខ្លះធ្វើឡើងដោយ "ឈ្លបស្រុក" ហើយជួនកាល "ឈ្លបឃុំក៏ចូលរួមចាប់ខ្លួនមនុស្សដែរ"។ ប៉ុន្តែ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ សាក្សីរូបនេះមិនបានពន្យល់ថាគាត់ទទួលបានព័ត៌មាននេះមកពីណា និងថាតើគាត់និយាយពីសម័យណាឱ្យពិតប្រាកដ ព្រោះថាខ្លួនគាត់ផ្ទាល់ ក្នុងនាមជាអ្នកទទួលខុសត្រូវឃុំ គាត់ពុំដែលបានទទួលបញ្ជាប្រភេទនេះទេ[1634]។

១៧២៥. លោក សុខ ម៉េងលី បាននិយាយប្រាប់អ្នកស៊ើបអង្កេតថា ក្រុមដាវវែងរបស់គាត់ ចាប់មនុស្សទៅតាមបញ្ជីដែលគណៈស្រុកបញ្ជូនមកគណៈឃុំ តែគាត់មិនដឹងអ្វីលើសពីនេះ នោះទេ[1635]។

១៧២៦. លោក ម៉ាត់ ទូល័ស បានប្រាប់អ្នកស៊ើបអង្កេតថា ក្នុងពេលប្រជុំ គាត់បានឮគេនិយាយថា ប្រធានក្រុម ឬប្រធានកងណា "សម្លាប់បានច្រើនជាងគេនោះនឹងត្រូវបានឡើងឋានៈ"[1636]។ ត្រង់ចំណុចនេះ ក៏ដូចគ្នា គឺគេមិនត្រឹមតែមិនដឹងថាអ្នកណាជាអ្នកនិយាយពាក្យទាំងអស់នេះនោះទេ តែអ្វីដែលសំខាន់ គឺពុំមានកន្លែងណាមួយដែលនិយាយថាជនជាតិចាមត្រូវបានកំណត់ជាគោលដៅជាក់លាក់នោះឡើយ។

១៧២៧. លោក ហុក ហឿន បាននិយាយប្រាប់អ្នកស៊ើបអង្កេតថា បញ្ជាចាប់ខ្លួនមនុស្សចេញមកពី "គណៈស្រុក" និងមកពី កាន ប៉ុន្តែ ថ្នាក់លើរបស់គាត់ ពុំដែលនិយាយប្រាប់គាត់ពីគោលនយោបាយណាមួយពាក់ព័ន្ធនឹងជនជាតិចាមម្តងណាឡើយ[1637]។ គាត់ក៏មិនដឹងថាគេចេញបញ្ជាឱ្យចាប់ខ្លួនមនុស្សរបៀបយ៉ាងម៉េចដែរ។

---

[1634] កំណត់ហេតុស្តាប់ចម្លើយ រៀល នាង ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ **E3/9652** សំណួរ/ចម្លើយទី ២២ និង សំណួរ/ចម្លើយទី ៣១។

[1635] កំណត់ហេតុស្តាប់ចម្លើយ សុខ ម៉េងលី ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **E3/9654** សំណួរ/ចម្លើយទី ១២។

[1636] កំណត់ហេតុស្តាប់ចម្លើយ ម៉ាត់ ទូល័ស ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ ឯកសារ **E3/9360** សំណួរ/ចម្លើយទី ៣៨។

[1637] កំណត់ហេតុស្តាប់ចម្លើយ ហុក ហឿន ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ **E3/5256**, ERN KH 00243081-00243082 និង 00243083។

## ii. មូលហេតុនៃការចាប់ខ្លួន

១៧២៨. លោក មុយ វ៉ាន់នី បានថ្លែងថា គាត់ "អត់ដឹងថាទោសអីយ៉ាងម៉េចៗទេ (*sic*)"[1638]។ លោក សេង ស្រ៊ុន បាននិយាយថាគាត់មិនដឹងពីមូលហេតុចាប់ខ្លួននេះឡើយ[1639]។ ដូចគ្នានេះដែរ លោក សយ ឌឿន បានបញ្ជាក់ថាគាត់មិនដឹងថាហេតុអ្វីបានជាអ្នកទាំងនោះត្រូវចាប់ខ្លួន ហើយគាត់បានឆ្លើយថា បានទទួលបញ្ជា "[...] ឱ្យចាប់ទៅ គេអត់មានប្រាប់ទិសដៅអីផង"[1640]។

១៧២៩. លោក សេង ឃុយ បានឱ្យដឹងថា "នៅពេលចាប់ភ្លាមៗហ្នឹង [...] ប្រធានកងសន្តិសុខឃុំហ្នឹងមាន ជេរអីចឹងដែរ។ ជេរថាអាចាមអាអីចឹង ក្បត់ជាមួយអង្គការ អីចឹងត្រូវតែបោសសម្អាត [...]"។ ដូច្នេះ ទោះជាសាក្សីបានបញ្ជាក់ថាពួកចាមដែលត្រូវចាប់ខ្លួន "មិនមានធ្វើអ្វីខុស"[1641] ក៏ដោយ ក៏គាត់គិតថា មូលហេតុនៃការចាប់ខ្លួនដែលមេឃុំបានប្រាប់គាត់ គឺដោយសារប្រហែលមកពី "អំពើក្បត់"។

១៧៣០. ម្យ៉ាងវិញទៀត លោក សេង ឃុយ បានអះអាងថា ខ្មែរក្រហម "ចង់សម្លាប់ជនជាតិភាគតិច" "គេអត់ចង់ឱ្យមានជនជាតិចាម ជនជាតិអីចឹង" ព្រោះថា រុន បាននិយាយថា "សម្លាប់ចោលឱ្យអស់ពូជអាកំពូជចាម កុំឱ្យនៅសល់"។ ក៏ប៉ុន្តែ គេត្រូវកត់សម្គាល់ថា ពាក្យសម្តីទាំងអស់នេះ គឺពុំស៊ីគ្នានឹងពាក្យសម្តីរបស់មេភូមិ នោះទេ[1642] តែវាប្រហែលជាសម្តីរបស់អ្នកធ្វើទារុណកម្មគួរឱ្យខ្លាចក្នុងកម្លាំងសន្តិសុខ ហើយវាគ្រាន់តែជាសម្តីគាត់ម្នាក់ឯងប៉ុណ្ណោះ។

១៧៣១. លោក សេង ឃុយ បានបញ្ជាក់ថា រុន ត្រូវបានគេហៅថាជា "ឃាតករ" ពីព្រោះ រុន នេះ បានចាប់ "បងប្អូន" គេជាច្រើននាក់ ហើយអ្នកភូមិបានសងសឹក ដោយបានសម្លាប់គាត់ក្រោយឆ្នាំ ១៩៧៩

---

[1638] <u>មុយ វ៉ាន់នី</u>៖ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ឯកសារ E1/373.1 ទំព័រ ៦៤ មុនម៉ោង 15.42.26។

[1639] <u>សេង ស្រ៊ុន</u>៖ ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ E1/346.1 ទំព័រ ៧៨ មុនម៉ោង 15.26.03។

[1640] <u>សយ ឌឿន</u>៖ ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/374.1 ទំព័រ ៥៤ មុនម៉ោង 14.06.35 ទំព័រ ៥៦ មុនម៉ោង 15.06.13។

[1641] <u>សេង ឃុយ</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៧ឯកសារ E1/344.1 ទំព័រ ៧៣ ប្រហែលម៉ោង 15.07.28។

[1642] <u>សេង ឃុយ</u>៖ ប្រតិចារឹកថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៧ឯកសារ E1/345.1 ទំព័រ ២៣ ក្រោយម៉ោង 10.16.37។

[1643]។ ដូច្នេះ តាមរយៈសក្ខីកម្មរបស់លោក សេង ឃុយ គេយល់បានផងដែរថា ការចាប់ខ្លួនមនុស្ស ក្នុងឃុំ មិនមែនកម្រិតត្រឹមតែការចាប់ខ្លួនជនជាតិចាមតែមួយនោះឡើយ។

១៧៣២. ម្យ៉ាងទៀត លោក សេង ឃុយ ខ្លួនឯង បានកត់សម្គាល់ថា គាត់បានទាញសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួន ទាក់ទងនឹងអត្តិភាពបែបសន្មតនៃផែនការកម្ទេចជនជាតិចាម។ ជាមួយគ្នានេះដែរ គាត់ត្រូវបង្ខំចិត្ត ទទួលស្គាល់ថា "ចាមហ្នឹង មិនដឹងគេយកទៅណា សម្លាប់ក៏មិនដឹង"[1644]។

១៧៣៣. លោក តាយ គឹមហ៊ាន់ បានបញ្ជាក់ជាទូទៅថា គាត់មិនដឹងពីមូលហេតុនៃការចាប់ខ្លួន ហើយក៏មិន ដឹងដូចគ្នាថា មនុស្សដែលគេចាប់ មកពីណា តែគាត់បានឃើញជនជាតិខ្មែរចូលក្នុងវត្តនោះ[1645]។ គាត់បានបន្ថែមថា សមាជិកគ្រួសារគាត់មួយចំនួន ក៏ត្រូវបានចាប់ខ្លួន ហើយនាំយកទៅវត្តអូរត្រកួន ដូចគ្នា ហើយ "ប្រហែលជាគេសម្លាប់បាត់ហើយ"[1646]។

១៧៣៤. កំណត់ហេតុស្តាប់ចម្លើយ ទាក់ទងនឹងស្រុកកងមាស មានខ្លឹមសារប្រហាក់ប្រហែលគ្នាខ្លះដែរ។ លោក សុខ ម៉េងលី បាននិយាយប្រាប់អ្នកស៊ើបអង្កេតថា "សម្រាប់ការចាប់ជនជាតិចាម ក៏ដូចជា ការចាប់ជនជាតិខ្មែរដែរ គឺពួកគេពុំបានប្រាប់ពីមូលហេតុនៃការចាប់ខ្លួនទេ"[1647]។ លោក ម៉ន ហ៊ាង បាននិយាយថា គាត់មិនដឹងពីមូលហេតុដែលចាមក្នុងក្រុមរបស់គាត់ត្រូវបានចាប់ខ្លួន នោះទេ[1648]។

១៧៣៥. ជនជាតិចាម លោក ម៉ាត់ ទូល័ស បានបញ្ជាក់ប្រាប់អ្នកស៊ើបអង្កេតដូចគ្នាថា គាត់ "មិនដឹង" រឿង ទាក់ទងនឹងការបោសសម្អាតប្រជាជនចាម នោះទេ។ គាត់បានបន្ថែមថា អ្នកទោសភាគច្រើននៅ វត្តអូរត្រកួន គឺជាអ្នក ១៧ មេសា[1649]។ ជាចុងក្រោយ លោក ហុក ហឿន បានឆ្លើយប្រាប់អ្នក

---

[1643] សេង ឃុយ៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៧ឯកសារ **E1/344.1** ទំព័រ ៦៧ មុនម៉ោង 14.35.25។

[1644] សេង ឃុយ៖ ប្រតិចារឹក ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៧ឯកសារ **E1/345.1** ទំព័រ ២៥ មុនម៉ោង 10.24.00។

[1645] តាយ គឹមហ៊ាន់៖ ប្រតិចារឹកថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/348.1** ទំព័រ ១១ ប្រហែលម៉ោង 09.34.16។

[1646] តាយ គឹមហ៊ាន់៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/348.1** ទំព័រ ៣៩ ក្រោយម៉ោង 11.29.45។

[1647] កំណត់ហេតុស្តាប់ចម្លើយ សុខ ម៉េងលី ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ឯកសារ **E3/9654** សំណួរ/ចម្លើយទី ១៣។

[1648] កំណត់ហេតុស្តាប់ចម្លើយ ម៉ន ហ៊ាង ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ឯកសារ **E3/5529** សំណួរ/ចម្លើយទី ៩។

[1649] កំណត់ហេតុស្តាប់ចម្លើយ ម៉ាត់ ទូល័ស ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ឯកសារ **E3/9360** សំណួរ/ចម្លើយទី ២២។

ស៊ើបអង្កេតថា គាត់ពុំដឹងមូលហេតុដែលជនជាតិចាមត្រូវចាប់ខ្លួនឡើយ។ គាត់យល់ថា គេចាប់ជនជាតិចាមទាំងនោះ "[...] ជាបន្តបន្ទាប់តាមខ្សែរយៈដែលបានឆ្លើយដាក់គ្នាពីមួយទៅមួយ"[1650]។

### 3. ការចោទប្រកាន់ពីការសម្លាប់មនុស្សនៅស្រុកក្រូចឆ្មារ និងស្រុកកងមាស

### 3.ក. ស្រុកក្រូចឆ្មារ

១៧៣៦. ការចាប់ខ្លួនដែលបានលើកឡើង និងការសម្លាប់ជាយថាហេតុនានាដែលកើតឡើងក្រោយការចាប់ខ្លួននេះ មិនអាចត្រូវបានចោទប្រកាន់ថាជាផែនការសំដៅជាពិសេសលើជនជាតិចាមបានឡើយ។

#### i. ការចាត់ខ្លួនពាក់ព័ន្ធជាមួយនឹងការបោសសម្អាតភូមិភាគបូព៌ា

១៧៣៧. លោក សុះ វំលី ជាជំនួយការមេឃុំទ្រា ចាប់ពីឆ្នាំ ១៩៧៥ បានលើកឡើងពីករណីរបស់ យ៉ា យ៉ូប ជនជាតិចាម ជាគណៈស្រុកក្រូចឆ្មារ ជាមួយនឹងជនជាតិខ្មែរពីរនាក់ទៀតគឺ ស៊ឹម និង ហាន។ យ៉ា យ៉ូប ត្រូវបានកម្មាភិបាលភូមិភាគកណ្ដាល នាំយកចេញទៅជាមួយកម្មាភិបាលខ្មែរពីររូបទៀត នៅប្រហែលពាក់កណ្ដាលឆ្នាំ ១៩៧៨[1651]។ តាមរយៈសក្ខីកម្មរបស់ សុំ វំលី វាបង្ហាញឱ្យឃើញថា យ៉ា យ៉ូប ត្រូវបាននាំទៅ ក្នុងក្របខ័ណ្ឌនៃការបោសសម្អាតក្នុងភូមិភាគបូព៌ា។ ដូច្នេះ ការចាប់ខ្លួនគាត់ក្នុងពេលដំណាលគ្នានឹងកម្មាភិបាលខ្មែរផ្សេងទៀត មិនមានអ្វីពាក់ព័ន្ធនឹងដើមកំណើតចាមរបស់គាត់ឡើយ។

#### ii. ករណីជាក់លាក់របស់ភូមិទ្រា

---

[1650] កំណត់ហេតុស្ដាប់ចម្លើយ ហុក ហឿន ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ឯកសារ **E3/5256**, ERN KH 00243082 និង 00243083។

[1651] <u>សុះ វំលី</u>៖ ប្រតិចារិក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/372.1** ទំព័រ ៨ មុនម៉ោង 09.24.14 ទំព័រ ៦៧ មុនម៉ោង 15.15.55។

១៧៣៨. ភូមិទ្រា ស្ថិតនៅតាមច្រាំងទន្លេមេគង្គ។ យោងតាមការកំណត់ទីតាំងភូមិសាស្ត្រ ភូមិទ្រា មានទីតាំងស្ថិតនៅក្នុងភូមិទ្រា ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម តំបន់ ២១ ក្នុងភូមិភាគបូព៌ា។ សក្ខីកម្មនានាទាក់ទងនឹងភូមិមួយនេះ មិនអាចឱ្យគេសន្និដ្ឋានបានថា ជនជាតិចាមត្រូវបានគេកំណត់គោលដៅជាពិសេស បានឡើយ។

• **<u>ករណីរបស់លោក អ៊ីត សេន</u>**

១៧៣៩. លោក អ៊ីត សេន បានកត់សម្គាល់នៅចំពោះមុខអង្គជំនុំជម្រះថា គាត់ត្រូវបានគេបញ្ជូនទៅភូមិទ្រាជាមួយគ្រួសារចាមផ្សេងទៀត[1652]។ ពេលជិតទៅដល់ភូមិទ្រា "បងប្អូនចាម" បាននិយាយប្រាប់គាត់ថា "ឃើញគេចងភ្នែក យកទៅខាងទន្លេ"[1653]។

១៧៤០. ក្រោយមក នៅពេលលើកឡើងពីការជាប់ឃុំឃាំងរបស់ខ្លួន[1654] សាក្សី អ៊ីត សេន បានថ្លែងថា មនុស្សត្រូវបានគេធ្វើទារុណកម្ម ប្រសិនបើគេនិយាយថាខ្លួនជាខ្មែរ ព្រោះថាកងសន្តិសុខដឹងថា អ្នកទាំងអស់នោះសុទ្ធតែជាចាម[1655]។ សាក្សី អ៊ីត សេន បានដឹងថាអ្នកផ្សេងទៀតជាជនជាតិចាម តាមរយៈកិច្ចសន្ទនារបស់គាត់ជាមួយអ្នកជាប់ឃុំផ្សេងទៀត នៅក្នុងផ្ទះប្រហែល ២០ នៅជិតផ្ទះដែលគាត់នៅ។ ក្នុងអំឡុងពេលសវនាការ គាត់បានទទួលស្គាល់ថាគាត់មិនដឹងថាអ្នកទាំងនោះមកពីខាងណា នោះទេ[1656]។

---

[1652] <u>អ៊ីត សេន</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/342.1** ទំព័រ ៦០ ក្រោយម៉ោង 14.34.08។

[1653] <u>អ៊ីត សេន</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/342.1** ទំព័រ ៥៩ មុនម៉ោង 14.31.15។ មេធាវីការពារក្តីសូមបញ្ជាក់ថា ក្នុងចម្លើយជាភាសាខ្មែរ នៅក្នុងសវនាការ អ៊ីត សេន មិនបាននិយាយថា "គេចងភ្នែក<u>ចាម</u>" ដូចនៅក្នុងភាសាបារាំងនោះទេ។ អង្គជំនុំជម្រះត្រូវពិចារណាទៅលើភាសាខ្មែរ។

[1654] <u>អ៊ីត សេន</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/342.1** ទំព័រ ៥៨ ក្រោយម៉ោង 14.26.50។

[1655] <u>អ៊ីត សេន</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/342.1** ទំព័រ ៦១ មុនម៉ោង 14.39.28 ទំព័រ ៦៣ មុនម៉ោង 15.06.45, សម្រង់ចេញពីសៀវភៅរបស់ អ៊ីសា ឧស្មាន *"ការបះបោររបស់ជនជាតិចាម"* ឆ្នាំ ២០០៦ ឯកសារ **E3/9334**, ERN KH 00204436។

[1656] <u>អ៊ីត សេន</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/342.1** ទំព័រ ៦៣ មុនម៉ោង 15.03.50 ទំព័រ ៦៤ ក្រោយម៉ោង 15.08.35។

១៧៤១. ក៏ប៉ុន្តែ នៅពេលចោទសួរដោយក្រុមមេធាវីការពារក្តី សាក្សី អ៊ុត សេន បានបញ្ជាក់ថា "ក្នុងផ្ទះជាមួយគ្នា នៅក្បែរគ្នាអត់ឱ្យនិយាយគ្នា"។ គាត់បានឃើញអ្នកដែលនៅផ្ទះជិតៗនោះតាមបង្អួច ប៉ុន្តែ សក្ខី-កម្មរបស់គាត់ បង្ហាញឱ្យឃើញច្បាស់ថា គាត់បានត្រឹមតែធ្វើការសន្មត ព្រោះថា តាមស្ថានភាពជាក់ស្តែង គាត់មិនអាចនិយាយគ្នាជាមួយអ្នកនៅតាមផ្ទះទាំង ២០ នោះបានឡើយ ក្នុងពេលគាត់ជាប់ឃុំឃាំង[1657]។

១៧៤២. ទីតាំងផ្ទះឃុំឃាំងមនុស្ស ដូចដែលសាក្សី អ៊ុត សេន បានពិពណ៌នា គឺធ្វើឱ្យកិច្ចសន្ទនាបែបសន្មតទាំងនេះ រឹតតែមិនអាចជឿជាក់បានថែមទៀត។ សាក្សីបានឱ្យដឹងថា ផ្ទះនីមួយៗ នៅដាច់ពីគ្នាពីពីរ បី ឬ បួនម៉ែត្រ និងតំរៀបគ្នាជាជួរនៅជាប់ទន្លេមេគង្គ។ លើសពីនេះទៀត នៅពេលសួរទាក់ទងនឹងផ្ទះដែលគាត់ឃុំ លោក អ៊ុត សេន បានពន្យល់ថា "[...] បង្អួច ទ្វារខាងមុខ ខាងក្រោយ ប៉ុន្តែចាក់សោអស់ហើយ ពេលខ្ញុំនៅទីនោះ ចាក់សោគ្រប់បង្អួច"[1658]។ លោកស្រី ម៉ាត់ ស ដែលបានថ្លែងដូចគ្នាថា គាត់ត្រូវបានឃុំឃាំងនៅទ្រា បានពន្យល់ថា ទ្វារ និងបង្អួច ផ្ទះដែលគាត់ជាប់ឃុំ គឺបិទជិត[1659]។

១៧៤៣. ម្យ៉ាងវិញទៀត សាក្សី អ៊ុត សេន ខ្លួនឯង បានពន្យល់ប្រាប់អង្គជំនុំជម្រះថាគេមិនអាចកំណត់នរណាម្នាក់ថាជាចាមបានទេ នៅពេលដែលបុគ្គលម្នាក់នោះ មិនស្លៀកសម្លៀកបំពាក់ប្រពៃណី និងមិនថ្វាយបង្គំនៅព្រះវិហារ[1660]។ ក្នុងសម័យនោះ ដោយសារតែជនជាតិចាមស្លៀកពាក់ខ្មៅដូចមនុស្សគ្រប់គ្នា ដូច្នេះ គាត់មិនអាចកំណត់នរណាម្នាក់ថាជាជនជាតិចាម ពីចម្ងាយបានទេ[1661]។

---

[1657] <u>អ៊ុត សេន</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/343.1** ទំព័រ ៤១ មុនម៉ោង 11.23.32។

[1658] <u>អ៊ុត សេន</u>៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/343.1** ទំព័រ ៤៨ ក្រោយម៉ោង 13.44.44។

[1659] <u>ម៉ាត់ ស</u>៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/375.1** ទំព័រ ២៥ ក្រោយម៉ោង 10.12.36 ("[...] គេហ្នឹងបិទៗបង្អួច បិទទ្វារហ្នឹងទៅ [...]។ អត់ឱ្យពួកយើងខ្ញុំចុះដើរទៅណាផង ឃុំឃាំងដាក់លើផ្ទះនុំង")។

[1660] <u>អ៊ុត សេន</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/342.1** ទំព័រ ៤១ មុនម៉ោង 11.27.37។

[1661] <u>អ៊ុត សេន</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/342.1** ទំព័រ ៥០ មុនម៉ោង 13.49.33។ សូមមើលផងដែរ <u>អ៊ុសា ឧស្មាន</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/388.1** ទំព័រ ៧៣-៧៤ ក្រោយម៉ោង 16.02.22, ប្រតិចារឹក ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ឯកសារ **E1/389.1** ទំព័រ ២៤ ក្រោយម៉ោង 10.44.00។

១៧៤៤. ដូច្នេះ តាមរយៈសក្ខីកម្មរបស់គាត់ គេក៏មិនអាចបង្ហាញភស្តុតាងឱ្យហួសពីវិមតិសង្ស័យបានថា អ្នកដែលជាប់ឃុំឃាំងនៅក្នុងផ្ទះបិទជិតទាំងនោះ គឺសុទ្ធជាជនជាតិចាម ហើយថាការសម្លាប់ដែលគាត់បានឃើញពីចម្ងាយ គឺពាក់ព័ន្ធតែជនជាតិចាម បានដែរ។

• **<u>ករណីលោកស្រី នោ សាទះ និងលោកស្រី ម៉ាត់ ស</u>**

១៧៤៥. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានបញ្ជាក់ប្រាប់អង្គជំនុំជម្រះថា គាត់បានរស់ក្នុងភូមិខ្សាច់ប្រឆេះលើ ឃុំក្រូចឆ្មារ រហូតដល់ការមកដល់របស់ពួកកម្មាភិបាលភូមិភាគនិរតី ប្រហែលពេលជិតដាច់របបខ្មែរក្រហម[1662]។ ក្រោយបែកចេញពីគ្រួសារដែលគាត់មិនដឹងថាធ្វើដំណើរទៅទីណានោះ លោកស្រី នោ សាទះ និយាយថាគាត់បានចូលក្នុងកងចល័ត[1663]។ ក្នុងអំឡុងពេលសវនាការ លោកស្រី ម៉ាត់ ស ក៏បានចែករំលែកផងដែរអំពីដំណើររឿងរបស់គាត់ មុននឹងគាត់ចូលក្នុងកងចល័តជាមួយគ្នានឹងដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ក្នុងឃុំក្រូចឆ្មារ[1664]។

១៧៤៦. ប៉ុន្តែ ស្ត្រីចាមទាំងពីរនាក់នេះ ដែលត្រូវបានគេសន្មតថាបានឆ្លងកាត់ព្រឹត្តិការណ៍ដូចគ្នា គឺមានទំនាក់ទំនងនឹងអង្គហេតុផ្សេងគ្នា។ ពួកគាត់ទាំងពីរត្រូវបានចាប់ខ្លួនជាមួយគ្នា ប៉ុន្តែ បើតាមលោកស្រី ម៉ាត់ ស គាត់បានចំណាយពេលជាងមួយម៉ោង ដើម្បីដើរពីខ្សាច់ប្រឆេះកណ្តាលទៅដល់ទ្រា[1665]។ ខុសគ្នាពីលោកស្រី ម៉ាត់ ស លោកស្រី នោ សាទះ បាននិយាយថា ចម្ងាយផ្លូវដូចគ្នានេះ ត្រូវការពេលដើរ ពីប្រាំទៅប្រាំមួយម៉ោង[1666]។

---

[1662] <u>នោ សាទះ</u>៖ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/351.1** ទំព័រ ១៥ មុនម៉ោង 09.48.38 ("សង្គ្រាមដូចថាវា១ចុងបញ្ចប់ហើយណ៎ា", កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩ ឯកសារ **E3/7772**, ERN KH 00345168 (គាត់បាននិយាយអំពីការការចាប់ខ្លួនគាត់ នៅភូមិទ្រា ក្នុងខែកក្កដា ឆ្នាំ ១៩៧៨)។

[1663] <u>នោ សាទះ</u>៖ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/351.1** ទំព័រ ១៤ ក្រោយម៉ោង 09.43.13 ទំព័រ ៣០ ក្រោយម៉ោង 10.58.32។

[1664] <u>ម៉ាត់ ស</u>៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/375.1** ទំព័រ ១៨ មុនម៉ោង 09.54.30 ទំព័រ ២៣ ប្រហែលម៉ោង 10.08.49 ទំព័រ ៤១ មុនម៉ោង 11.15.53 ទំព័រ ៤៨ ប្រហែលម៉ោង 13.37.26 ទំព័រ ៧១ មុនម៉ោង 15.06.03។

[1665] <u>ម៉ាត់ ស</u>៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/375.1** ទំព័រ ៤២ ប្រហែលម៉ោង 11.18.32។

[1666] <u>នោ សាទះ</u>៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/350.1** ទំព័រ ៤៦ ក្រោយម៉ោង 14.12.45, ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/351.1** ទំព័រ ៣០ ក្រោយម៉ោង 10.59.53។

១៧៤៧. ក្នុងសៀវភៅរបស់ខ្លួនដែលមានចំណងជើងថា *Oukoubah* លោក អ៊ីសា ឧស្មាន បានលើកឡើងពីការឃុំខ្លួនចាម ១០០ នាក់ ក្នុងផ្ទះមួយ នៅទ្រា[1667]។ ក្នុងអំឡុងពេលសវនាការ គាត់បានទទួលស្គាល់ថា លោកស្រី នោ សាទះ លោកស្រី ម៉ាត់ ស និងស្ត្រីផ្សេងៗទៀតដែលគាត់បានស្រង់យកចម្លើយដើម្បីមកពិពណ៌នាព្រឹត្តិការណ៍នេះ បានផ្តល់ជូនគាត់នូវតួលេខខុសគ្នា។ ដូច្នេះហើយបានជាគាត់ជ្រើសរើសតួលេខ ១០០ ដោយចិត្តឯង ដើម្បីសរសេររឿងរ៉ាវរបស់គាត់ ដោយទាំងដឹងច្បាស់ពីការបំផ្លើសមួយចំនួនរបស់ជនរងគ្រោះខ្លះ[1668]។ ឧទាហរណ៍មួយនេះ បង្ហាញឱ្យឃើញឡើងវិញពីផលលំបាកក្នុងការជឿទុកចិត្តលើរឿងរ៉ាវមួយចំនួនដែលមិនត្រូវបានផ្ទៀងផ្ទាត់ និងសាកល្បង ក្នុងអំឡុងពេលសវនាការ។

១៧៤៨. ទោះយ៉ាងណា រឿងរ៉ាវរបស់លោកស្រី នោ សាទះ និងលោកស្រី ម៉ាត់ ស បានបង្ហាញពីចំនួនអ្នកទោសស្ត្រីប្រែប្រួលមួយ គឺប្រមាណ ៣០ នាក់ និងចន្លោះពី ២០០ ទៅ ៣០០ នាក់[1669]។ ម្យ៉ាងវិញទៀត គាត់ទាំងពីរនាក់ មិនបានលើកឡើងពីការធ្វើទារុណកម្ម ក្នុងពេលគាត់ជាប់ឃុំនៅទ្រា ដែលនៅទីនោះ ពួកគាត់ត្រូវបាន “ហៅ” សួរចង់ដឹងមើលថាពួកគាត់ជាកូនខ្មែរ ឬជាកូនចាម ពីព្រោះថាកូនចាម ឬ កូនកាត់ចាម ត្រូវគេនាំចេញទៅខាងក្រៅ[1670]។ ជាថ្មីម្តងទៀត ត្រង់ចំណុចនេះ រឿងរ៉ាវ

---

[1667] សៀវភៅរបស់ អ៊ីសា ឧស្មាន មានចំណងជើងថា *Oukoubah* ឆ្នាំ ២០០២ ឯកសារ **E3/1822**, ERN EN 00078454។

[1668] អ៊ីសា ឧស្មាន៖ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/408.1** ទំព័រ ៧ ក្រោយម៉ោង 09.23.23 ទំព័រ ៨-៩ ក្រោយម៉ោង 09.28.05, នោ សាទះ៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤៦ ក្រោយម៉ោង 14.12.45, ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៣១ ក្រោយម៉ោង 11.02.49 ទំព័រ ៣៣ ក្រោយម៉ោង 11.06.29 ទំព័រ ៥៦ ក្រោយម៉ោង 14.14.58, ម៉ាត់ ស៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/375.1** ទំព័រ ២៤ ប្រហែលម៉ោង 10.11.03 ទំព័រ ៤២ ក្រោយម៉ោង 11.18.32 ទំព័រ ៨២ មុនម៉ោង 15.42.15 ទំព័រ ៧៣ ប្រហែលម៉ោង 15.12.42, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩ ឯកសារ **E3/7772**, ERN KH 00345168។

[1669] នោ សាទះ៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤៦ ក្រោយម៉ោង 14.12.45, ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៤១ មុនម៉ោង 11.33.33, ម៉ាត់ ស៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/375.1** ទំព័រ ២៤ ប្រហែលម៉ោង 10.11.03 ទំព័រ ៤២ ក្រោយម៉ោង 11.18.32 ទំព័រ ៨២ មុនម៉ោង 15.42.15 ទំព័រ ៧៣ ប្រហែលម៉ោង 15.12.42, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩ ឯកសារ **E3/7772**, ERN KH 00345168។

[1670] ម៉ាត់ ស៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/375.1** ទំព័រ ២៧ មុនម៉ោង 10.35.36 ទំព័រ ៤៤-៤៥ ក្រោយម៉ោង 11.27.26 ទំព័រ ៤៦ ប្រហែលម៉ោង 11.32.43 ទំព័រ ៦០ ប្រហែលម៉ោង 14.14.56។ នោ សាទះ៖ ប្រតិចារឹក

របស់ស្ត្រីចាមទាំងពីរនាក់នេះ គឺមិនដូចគ្នា ព្រោះថា លោកស្រី នោ សាទះ បានអះអាងថា ទាហាន និយាយថា ហូ ជាប្រធានស្រុកថ្មី ចំណែកឯលោកស្រី ម៉ាត់ ស គ្រាន់តែបានពិពណ៌នាពី ហូ ថាជា "ប្រធាន" ម្នាក់ធម្មតា ហើយគាត់ក៏មិនដឹងថាតើ ហូ នៅមានជីវិតដល់សព្វថ្ងៃដែរឬអត់ នៅពេលគាត់កំពុងផ្តល់ចម្លើយនៅចំពោះមុខតុលាការ[1671]។

១៧៤៩. សំណួរទាក់ទងនឹងឈ្មោះរបស់ "ហូ" គឺសំខាន់ ព្រោះថា អយ្យការគាំទ្រថា "ហូ" នេះ គឺជា បាន សៀក ខណៈដែល លោក បាន សៀក បានបដិសេធឈ្មោះនេះ ក្នុងអំឡុងពេលសវនាការ។ ទាក់ទងនឹងឈ្មោះដែលគាត់ប្រើក្នុងស្រុកក្រូចឆ្មារ លោក បាន សៀក បានបដិសេធជាច្រើនលើកច្រើនសាថាគាត់មិនបានប្រើឈ្មោះហៅក្រៅ "ហូ" នេះទេ ដោយគាត់បានថ្លែងថា គេហៅគាត់ថា "ហែម ឬ ហង្ស ហែម"។ គាត់ក៏បានប្រើឈ្មោះហៅក្រៅ "ផុស" ផងដែរ ក្រោយឆ្នាំ ១៩៧៩[1672]។ នៅពេលត្រូវបានចោទសួរទាក់ទងនឹងឈ្មោះហៅក្រៅរបស់ប្រធានស្រុក ហូ ឬ ផុស នេះ សាក្សី វ៉ាន់ ម៉ាត់ មិនអាចឆ្លើយបាន[1673]។

១៧៥០. ទោះយ៉ាងណាក៏ដោយ នៅពេលត្រូវបានសួរតទល់នឹងចម្លើយរបស់ នោ សាទះ លោក បាន សៀក បានបដិសេធថាគាត់មិនបានចូលរួមក្នុងការជ្រើសរើសបែងចែករវាងចាម និងខ្មែរឡើយ[1674]។ អង្គជំនុំជម្រះត្រូវវាយតម្លៃលើអង្គហេតុទៅតាមចម្លើយតទល់គ្នារបស់សាក្សី តែគេត្រូវរំឭកថា លោក

---

ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤៨ ក្រោយម៉ោង 14.21.20 ទំព័រ ៥៩ ប្រហែលម៉ោង 15.23.00, ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/351.1** ទំព័រ ៣៧-៣៨ ក្រោយម៉ោង 11.21.29។

[1671] <u>នោ សាទះ</u>៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៥៤-៥៥ មុនម៉ោង 15.07.12។ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៨ឯកសារ **E3/5193**, ERN KH 00204445 គាត់បានឆ្លើយថា ហូ ត្រូវបានសម្លាប់ដោយអ្នកភូមិ នៅក្នុងឆ្នាំ ១៩៧៩, ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/351.1** ទំព័រ ៤៤ មុនម៉ោង 13.38.29 គាត់មិនដឹងថា ហូ ត្រូវបានអ្នកភូមិទ្រាសម្លាប់ ឬមិនសម្លាប់នោះទេ។ ការកែប្រែសក្ខីកម្មមួយរំពេចនេះនៅក្នុងសវនាការ ធ្វើឲ្យលេចឡើងនូវមន្ទិលសង្ស័យអំពីការកែតម្រូវសក្ខីកម្ម ដើម្បីធ្វើឲ្យរឿងរ៉ាវមានភាពស៊ីសង្វាក់គ្នា។ <u>ម៉ាត់ ស</u>៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/375.1** ទំព័រ ៦៤ មុនម៉ោង 14.29.05។

[1672] <u>បាន សៀក</u>៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ឯកសារ **E1/353.1** ទំព័រ ៥៥ ប្រហែលម៉ោង 14.10.04 ទំព័រ ៥៦ ប្រហែលម៉ោង 14.15.18, ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ឯកសារ **E1/354.1** ទំព័រ ៣៣ ប្រហែលម៉ោង 11.20.23 ទំព័រ ៣៤ ប្រហែលម៉ោង 11.22.42 ទំព័រ ៤៥ ប្រហែលម៉ោង 14.01.44។

[1673] <u>វ៉ាន់ ម៉ាត់</u>៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ឯកសារ **E1/398.1** ទំព័រ ៧៤ ក្រោយម៉ោង 15.42.50។

[1674] <u>បាន សៀក</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ឯកសារ **E1/354.1** ទំព័រ ៥៦ មុនម៉ោង 15.05.03។

ស្រី ម៉ាត់ ស បានអះអាងដូចដែលបានឃើញខាងលើថា ការរៀបការរបស់គាត់ត្រូវបានរៀបចំឡើងដោយលោក បាន សៀក ខណៈដែលកម្មាភិបាលទាំងអស់ដឹងថា ប្តីគាត់ និងខ្លួនគាត់ផ្ទាល់ ជាជនជាតិចាម[1675]។

### iii. រណ្តៅរកឃើញនៅទ្រា ក្រោយឆ្នាំ ១៩៧៩

១៧៥១. លោកស្រី ម៉ាត់ ស ឆ្លើយថាគាត់បានឃើញគេសម្លាប់មនុស្ស និងទម្លាក់ចូលក្នុងរណ្តៅ។ គាត់ជាមនុស្សតែម្នាក់គត់ដែលបាននិយាយរឿងនេះ[1676]។ ជាចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ទទួលស្គាល់ថាគាត់បានកុហក់លោក អ៊ីសា ឧស្មាន ទាក់ទងនឹងអ្វីដែលគាត់និយាយថាបានឃើញ[1677]។ ចំណែកលោក អ៊ីត សេន វិញ បានអះអាងថា គាត់មិនបានឃើញរណ្តៅ និងការសម្លាប់មនុស្សក្នុងរណ្តៅ នោះទេ[1678]។

១៧៥២. មិនខុសគ្នាពីអ្វីដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយលោក ស្លេះ ទ័ត ដែរ សាក្សី ស៊ុះ រំលី បានថ្លែងនៅក្នុងសវនាការថា សាកសពមនុស្សត្រូវបានរកឃើញនៅតាមរណ្តៅ។ គាត់ទាំងពីរនាក់បានឃើញរណ្តៅទាំងនោះ ក្រោយឆ្នាំ១៩៧៩ តែគាត់ពុំអាចបញ្ជាក់បានថាតើសាកសពទាំងអស់នោះ ជាជនជាតិ ឬក៏ជាជនជាតិខ្មែរ[1679]។ ម្យ៉ាងវិញទៀត លោក ស្លេះ ទ័ត បានបញ្ជាក់ប្រាប់អ្នកស៊ើបអង្កេតថា គាត់មិនដឹងថាតើមានមន្ទីរសន្តិសុខដែរឬក៏អត់ នៅក្នុងភូមិទ្រា[1680]។

---

[1675] សូមមើលខាងលើ កថាខណ្ឌ ១៦៨៧។

[1676] ម៉ាត់ ស៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/375.1** ទំព័រ ៣១ មុនម៉ោង 10.47.06 ទំព័រ ៤៥ ក្រោយម៉ោង 11.29.46 ទំព័រ ៣៥-៣៦ ក្រោយម៉ោង 10.57.37។

[1677] នោ សាទះ៖ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៨ ឯកសារ **E3/5193**, ERN KH 00204446។

[1678] អ៊ីត សេន៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៤៧ ប្រហែលម៉ោង 13.42.00។

[1679] ស៊ុះ រំលី៖ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/372.1** ទំព័រ ៥៩ មុនម៉ោង 14.28.41 ទំព័រ ៦៨ ក្រោយម៉ោង 15.15.55, កំណត់ហេតុស្តាប់ចម្លើយ ស្លេះ ទ័ត ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩ ឯកសារ **E3/7773**, ERN KH 00345176-00345177។

[1680] កំណត់ហេតុស្តាប់ចម្លើយ ស្លះ ទ័ត ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩ ឯកសារ **E3/7773**, ERN KH 00345177។

១៧៥៣. តាមរយៈសក្ខីកម្មទាំងនេះ គេមិនអាចសន្និដ្ឋានបានថា គឺមានតែជនជាតិចាមប៉ុណ្ណោះដែលត្រូវបានសម្លាប់ក្នុងរណ្ដៅទាំងនេះ។ ដូចដែលបានឃើញពីខាងលើរួចមកហើយ លោក បាន សៀក បានបញ្ជាក់ថា ជនរងគ្រោះនៃការសម្លាប់ គឺជាកម្លាំងកងចល័ត ដែលរួមមានជនជាតិចាម និងជនជាតិខ្មែរ[1681]។

### 3.ខ. ស្រុកកងមាស

#### i. ការចាប់ខ្លួនមនុស្សនៅក្នុងស្រុកកងមាស

១៧៥៤. ភស្តុតាងមួយផ្នែក អាចធ្វើឱ្យគេយល់ឃើញថា មានការចាប់ខ្លួនមនុស្សនៅស្រុកកងមាស ហើយថាវត្តអូរត្រកួន គឺជាកន្លែងដែលកើតមានការសម្លាប់មនុស្ស បើទោះជាខ្លឹមសារជាសារវន្តនៃភស្តុតាងទាក់ទងនឹងការសម្លាប់មនុស្ស គឺជាពាក្យចចាមអារ៉ាមក៏ដោយ។ ប៉ុន្តែ ភស្តុតាងទាំងឡាយដែលប្រមូលបាន ក៏ចង់បង្ហាញឱ្យឃើញផងដែរថា ពុំមែនមានតែជនជាតិចាមទេដែលត្រូវចាប់ខ្លួននៅក្នុងស្រុក ប៉ុន្តែការចាប់ខ្លួននេះ ពាក់ព័ន្ធនឹងប្រជាជនទាំងអស់គ្នា ដោយមិនប្រកាន់ថាអ្នកណាជាអ្នកណាឱ្យជាក់លាក់ឡើយ។

១៧៥៥. លោក សយ ឌឿន ក៏បានលើកឡើងដូចគ្នាពីការចាប់ខ្លួនកម្មាភិបាលមួយចំនួន នៅស្រុកកងមាស ចន្លោះចុងឆ្នាំ ១៩៧៧ និងដើមឆ្នាំ ១៩៧៨។ កម្មាភិបាលចាប់ខ្លួនត្រូវជំនួសដោយ កាន ជាគណៈ-ស្រុក និងប្រពន្ធរបស់គាត់ឈ្មោះ ភាព ជាគណៈឃុំពាមជីកង។ ការចាប់ខ្លួនជនជាតិចាម និងប្រជាជនថ្មី បានចាប់ផ្ដើមនៅពេល កាន និង ភាព ទៅដល់។ លោក សយ ឌឿន និយាយថាការចាប់ខ្លួនជនជាតិចាម កើតឡើងនៅចុងឆ្នាំ ១៩៧៨ ដោយគាត់បញ្ជាក់ថា ក្នុងរយៈពេលដែលគាត់នៅក្នុងក្រុមដាវរែង ជនជាតិចាមត្រូវបានចាប់ខ្លួនញឹកញាប់ជាងគេ ហើយ "យកទៅវត្តអូរត្រកួន"។ ប៉ុន្តែគាត់ក៏បានបញ្ជាក់ផងដែរពីភាពត្រឹមត្រូវរបស់ចម្លើយគាត់កាលពីពេលមុន ដែលបញ្ជាក់ថាគាត់ចាប់ខ្លួន "ប្រជាជនថ្មី ទាហាន លន់ នល់ និងជនជាតិចាម"[1682]។

---

[1681] សូមមើលខាងលើ កថាខណ្ឌ ១៧០៩។

[1682] សយ ឌឿន៖ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ឯកសារ E1/374.1 ទំព័រ ២៥-២៧ ប្រហែលម៉ោង 10.31.38 និង 10.38.27 ទំព័រ ២៧ មុនម៉ោង 10.42.20 ទំព័រ ៣៦ មុនម៉ោង 11.13.48 ទំព័រ ៣៧ ក្រោយម៉ោង 11.13.48 ទំព័រ ៧៣ មុន 15.29.23។

១៧៥៦. លោក តាយ គឹមហ៊ាន់ បានឮគេនិយាយពីឈ្មោះ ហាន ប្រធានវត្តអូរត្រកួន តែគាត់មិនដែលបានចូលក្នុងវត្តម្តងណាឡើយ ដោយសារតែជាបរិវេណសន្តិសុខ[1683]។ ប៉ុន្តែ គាត់បានឆ្លើយថាបានឃើញគេនាំមនុស្សទៅវត្តអូរត្រកួន "បួនប្រាំដង" ជួនកាលឃើញ "ពីរនាក់ទៅ ជួនកាលឃើញម្នាក់ទៅ"។ គាត់បានឃើញខ្មែរក្រហមចូលទៅក្នុងវត្ត[1684]។

១៧៥៧. ត្រង់ចំណុចនេះ ចម្លើយរបស់ជនជាតិចាម លោក ម៉ាត់ ទូល័ស គឺគួរឱ្យចាប់អារម្មណ៍ជាពិសេស។ ក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ម៉ាត់ ទូល័ស បានឆ្លើយថា ដោយសារតែគាត់ចេះបើក កាណូត ក្នុងនាមជាអ្នកនេសាទ គេបានឱ្យគាត់"ដឹកអ្នកទោស" ទៅវត្តអូរត្រកួន។ គាត់បានបញ្ជាក់ប្រាប់អ្នកស៊ើបអង្កេតថា ទោះខ្លួនជាជនជាតិចាមក៏ដោយ ក៏គាត់ "មិនដឹងថាជាចាម ឬខ្មែរទេ ពីព្រោះគ្មានអ្វីសម្គាល់"។ ដូចគ្នានេះដែរ គាត់បានឆ្លើយថា ថ្ងៃមួយ នៅពេលដឹកយុវជនចល័តមួយក្រុមផ្សេងទៀត គេមិនបានប្រាប់គាត់ថា "ចាម ឬខ្មែរទេ"។ ជាពិសេសទៀតនោះ សាក្សី ម៉ាត់ ទូល័ស បានបញ្ជាក់ថា ទោះជានៅក្នុងភូមិរបស់គាត់ គ្រប់គ្រួសារចាមទាំងអស់ ត្រូវបានសម្លាប់ក៏ដោយ ក៏គាត់ "មិនដឹងទេ" ទាក់ទងនឹងការបោសសម្អាតប្រជាជនចាម[1685]។

១៧៥៨. លោក ហុក ហឿន បានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា "ដំបូង ការចាប់កើតឡើងចំពោះប្រជាជនខ្មែរប៉ុណ្ណោះ" ហើយការចាប់ខ្លួនប្រជាជនចាម កើតឡើងពេលក្រោយមកទៀត[1686]។ ការចាប់ខ្លួនពាក់ព័ន្ធនឹងចាមនៅក្នុងភូមិរបស់គាត់ និងចាមរស់នៅភូមិសាច់ស្ងួរ។ គាត់បានថ្លែងថា អតីតអ្នកសាធារណរដ្ឋខ្មែររស់នៅក្នុងភូមិ ក៏ត្រូវបានចាប់ខ្លួនដូចគ្នា[1687]។

---

[1683] តាយ គឹមហ៊ាន់៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/348.1** ទំព័រ ១១ មុនម៉ោង 09.37.48 ទំព័រ ៦២-៦៣ មុនម៉ោង 15.05.44 ទំព័រ ៥៨ ប្រហែលម៉ោង 14.32.03។

[1684] តាយ គឹមហ៊ាន់៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/348.1** ទំព័រ ៨-៩ ចន្លោះម៉ោង 09.21.59 ដល់ម៉ោង 09.27.55 ទំព័រ ៤៧ មុនម៉ោង 13.58.38។

[1685] កំណត់ហេតុស្តាប់ចម្លើយ ម៉ាត់ ទូល័ស ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ឯកសារ **E3/9360** សំណួរ/ចម្លើយទី ១៦, ១៧, ១៨, ២១, ២២ និង ៣៣។

[1686] កំណត់ហេតុស្តាប់ចម្លើយ សុខ ហឿន ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ឯកសារ **E3/5256**, ERN KH 00243082។

[1687] កំណត់ហេតុស្តាប់ចម្លើយ សុខ ហឿន ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ឯកសារ **E3/5256**, ERN KH 00243080។

១៧៥៩. បើទោះជាលោក សំរិត មុយ បានឆ្លើយថា ការបាត់ខ្លួនជនជាតិចាម បានចាប់ផ្តើមកើតមានពេលពួកកម្មាភិបាលនិរតីមកដល់ក៏ដោយ ក៏គាត់បានបញ្ជាក់ផងដែរថា ចាប់ពីឆ្នាំ ១៩៧៧ មក ការចាប់ខ្លួន និងការសម្លាប់មនុស្ស បានកើនឡើងជាទូទៅ ជាមួយនឹងការបង្កើតក្រុមដាវវែង តែការចាប់ និងសម្លាប់នោះ មិនមែនពាក់ព័ន្ធ "ត្រឹមតែបងប្អូនអ៊ីស្លាមមួយទេ"[1688]។

១៧៦០. លោក សេង ឃុយ បានឱ្យដឹងថា អ្នកទទួលខុសត្រូវចាប់មនុស្ស គឺកម្លាំងសន្តិសុខ "ឃុំ" ហើយគាត់ឮគេនិយាយថា រុន គឺជាអ្នកទទួលខុសត្រូវកម្លាំងសន្តិសុខនេះ។ រុន ជាមនុស្សគួរឱ្យខ្លាចខ្លាំងណាស់ ព្រោះ "ឱ្យតែមក គឺចាប់អ្នកស្រុកតែម្តង ខ្លាចរឿងគេចាប់យកទៅសម្លាប់ចោលហ្នឹង ព្រោះអត់មានសួរនាំអី"។ លោក សេង ឃុយ បានឆ្លើយផងដែរថា "នៅក្នុងឆ្នាំ ៧៧ នេះ ខ្មែរក្រហមមានទ្រង់ទ្រាយកាប់សម្លាប់ខ្លាំង" ហើយគាត់ឮគេនិយាយពី "ការបោសសម្អាតជនជាតិចាម ទ្រង់ទ្រាយធំ" តែគាត់ក៏បានកត់សម្គាល់ដូចគ្នាថាមានការបាត់ខ្លួនគ្រួសារប្រជាជនថ្មី ក្នុងឃុំរបស់គាត់[1689]។ ដូច្នេះ យោងតាមសក្ខីកម្មរបស់គាត់ ការចាប់ខ្លួនពុំមែនសំដៅតែលើជនជាតិចាមមួយនោះទេ ក្រៅពីថ្ងៃច្បាស់លាស់មួយនេះ។

១៧៦១. លោកស្រី វៀល នាង បានឆ្លើយថា នៅពេលកម្មាភិបាលនិរតីមកដល់ "មានការចាប់ខ្លួនមនុស្សច្រើន" ហើយ "មុខសញ្ញានៃការចាប់ខ្លួនគឺកម្មាភិបាលចាស់ និងប្រជាជនថ្មី" បើទោះជាគាត់បានឃើញផ្ទាល់ត្រឹមតែគេដឹកជនជាតិចាមទៅវត្តអូរត្រកួន ក៏ដោយ[1690]។ គាត់ពុំបានបង្ហាញកាលបរិច្ឆេទណាមួយ ហើយគាត់ក៏មិនដឹងអ្វីច្រើនជាងនេះ ទាក់ទងនឹងចាមដែលគេដឹកយកទៅ។

១៧៦២. នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ លោក សុខ ម៉េងលី ជាប្រជាជននៅឃុំអង្គរបាន បានឆ្លើយថា គាត់ជាសមាជិកក្រុមដាវវែង ដឹកនាំដោយឌឿន និងស្ថិតក្រោមការទទួលខុសត្រូវរបស់ឃុំ។ គាត់បានឱ្យដឹងថា មនុស្សគ្រប់ប្រភេទត្រូវបានចាប់ខ្លួន ដោយជាដំបូង គឺ"ប្រជាជនថ្មីដែលមានកំហុស"

---

[1688] សំរិត មុយ៖ ប្រតិចារឹក ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/347.1** ទំព័រ ៣៩ មុនម៉ោង 11.30.48 ទំព័រ ៥៦ មុនម៉ោង 14.22.00 ទំព័រ ៨១ មុនម៉ោង 16.01.23។

[1689] សេង ឃុយ៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ **E1/344.1** ទំព័រ ៦៤ ក្រោយម៉ោង 14.22.15 ទំព័រ ៧៤ មុនម៉ោង 15.09.52។

[1690] កំណត់ហេតុស្តាប់ចម្លើយ វៀល នាង ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ **E3/9652** សំណួរ/ចម្លើយទី ១៧-១៨ និង ២០។

បន្ទាប់មក គឺជនជាតិចាម និងគ្រួសាររបស់ពួកគេ ប៉ុន្តែក៏មានប្រជាជនមូលដ្ឋានដែរ "នៅពេលដែលពួកគេប្រព្រឹត្តកំហុស ឬដោយសារលួចអ្វីមួយ"[1691]។

### ii. ព័ត៌មានអំពីរណ្តៅដែលបានរកឃើញក្រោយឆ្នាំ១៩៧៩

១៧៦៣. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ជាអ្នកដែលបានរួចជីវិតពីការចាប់ខ្លួនទ្រង់ទ្រាយធំ បាននិយាយថា៖ "រណ្តៅដែលកប់ជនជាតិចាមនៅវត្តអូរត្រកួនហ្នឹង [...] កាលពីមួយរឹកប៉ុល ពត [គាត់]អត់បានទៅមើលផ្ទាល់ទេ" តែគាត់បានធ្វើដំណើរទៅកាន់ដីមួយកន្លែងនៅក្បែរវត្តអូរត្រកួន ក្រោយឆ្នាំ ១៩៧៩ ជាមួយអង្គការមួយ[1692]។

១៧៦៤. នៅពេលសួរតទល់នឹងចម្លើយកាលពីមុនដែលនិយាយពីឆ្អឹងសាកសព លោក ហ៊ីម ម៉ាន បានបញ្ជាក់ថា រណ្តៅតែមួយគត់ដែលគាត់បានឃើញមុនពេលវៀតណាមចូលមកដល់ គឺទទេពុំមានអ្វីទាំងអស់ ព្រោះថា "គាត់គិតថា គេនឹងសម្លាប់ទាំងខ្មែរ ទាំងចាម"។ គាត់និយាយថា ក្រោយឆ្នាំ ១៩៧៩ "មនុស្សបានទៅ" ជីកដី ហើយបានរកឃើញ "គ្រឿងអលង្ការមួយចំនួន"។ ម្យ៉ាងទៀត គាត់បានបន្ថែមថា គាត់សន្និដ្ឋានថាឪពុកម្តាយគាត់ ត្រូវគេសម្លាប់ត្រង់កន្លែងនោះ ព្រោះថា "បើមិនស្លាប់ហ្នឹង មកវិញហើយ"[1693]។

១៧៦៥. លោក ហ៊ីម ម៉ាន បានឱ្យដឹងថា ចាមទាំងអស់ដែលត្រូវចាប់សម្លាប់ គឺស្លៀកពាក់ដូចប្រជាជនខ្មែរ ព្រោះថាសម្លៀកបំពាក់ប្រពៃណី ត្រូវបានហាមឃាត់មុននេះ[1694]។ ក្នុងកំណត់ហេតុស្តាប់ចម្លើយ លោក ម៉ាត់ ទូល័ស បានបញ្ជាក់អះអាងថា "គេមិនឱ្យ [គាត់] ស្លៀកសម្លៀកបំពាក់ចាមទេ"[1695]។

---

[1691] កំណត់ហេតុស្តាប់ចម្លើយ សុខ ម៉េងលី ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ឯកសារ **E3/9654** សំណួរ/ចម្លើយទី ១-៦ និង សំណួរ/ចម្លើយទី ១២-១៣។

[1692] <u>ហ៊ីម ម៉ាន</u>៖ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/349.1** ទំព័រ ៤៩ ក្រោយម៉ោង 14.16.35។

[1693] <u>ហ៊ីម ម៉ាន</u>៖ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/349.1** ទំព័រ ៥០ មុនម៉ោង 14.22.04។

[1694] <u>ហ៊ីម ម៉ាន</u>៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/350.1** ទំព័រ ៣២ ក្រោយម៉ោង 11.16.24។

[1695] កំណត់ហេតុស្តាប់ចម្លើយ ម៉ាត់ ទូល័ស ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ឯកសារ **E3/9360** សំណួរ/ចម្លើយទី ២៤។

១៧៦៦. លោក សេង ស្រ៊ុន បានថ្លែងក្នុងសវនាការថា ក្រោយឆ្នាំ ១៩៧៩ គាត់បានឃើញឆ្អឹងមនុស្ស ហើយខោអាវប្រពៃណីចាម ត្រូវបានរកឃើញនៅពេលប្រជាជនកាយរណ្ដៅសពដើម្បីស្វែងរករបស់មានតម្លៃ[1696]។ ត្រង់ចំណុចនេះ សក្ខីកម្មរបស់គាត់ គឺមានភាពផ្ទុយគ្នាទៅនឹងចម្លើយរបស់ខ្លួនគាត់ផ្ទាល់ និងផ្ទុយពីចម្លើយសាក្សីទាំងអស់ដែលបានបញ្ជាក់ថា នៅក្នុងកាលបរិច្ឆេទនៃការសម្លាប់មនុស្សដែលរងការចោទប្រកាន់នេះ ជនជាតិខ្មែរ និងចាម គឺស្លៀកពាក់ដូចគ្នា[1697]។ សាក្សី សេង ស្រ៊ុន នៅតែរក្សាចម្លើយគាត់ដូច្នេះដដែល ទោះជាមានភាពមិនស៊ីសង្វាក់គ្នា រហូតដល់គាត់ហ៊ានអះអាងថាគាត់អាចមើលដឹងថាជាសាកសពចាម ឬក៏ជាសាកសពខ្មែរ[1698]។

១៧៦៧. វាច្បាស់ណាស់ថា ទោះបីជាប្រជាជនស្រុកកងមាសជាច្រើននាក់ បានលើកឡើងពីការរកឃើញរណ្ដៅសព ក្រោយឆ្នាំ ១៩៧៩ នៅជិតបរិវេណវត្តអូរត្រកួន ក៏ដោយ[1699] ក៏វត្តមាននៃរណ្ដៅទាំងនោះអាចផ្ដល់បានត្រឹមតែភ័ស្តុតាងស្ដីពីការណ៍ដែលមានការសម្លាប់ប្រជាជនជាទូទៅ និងពុំមែនជនជាតិចាម ជាពិសេសនោះទេ ព្រោះថាមនុស្សគ្រប់គ្នាសុទ្ធតែបានបញ្ជាក់ថា ខោអាវដែលរកឃើញនៅតាមរណ្ដៅ គឺជាខោអាវរួមសម្រាប់មនុស្សគ្រប់គ្នា លើកលែងតែចម្លើយខុសគេរបស់លោក សេង ស្រ៊ុន។

១៧៦៨. ម្យ៉ាងវិញទៀត លោក សេង ឃុយ ដែលមានតួនាទីជាមេឃុំ នៅពេលមកផ្ដល់សក្ខីកម្ម បានថ្លែងថា "ប៉ាន់ស្មានប្រជាជនចាមរាល់ថ្ងៃនេះ [...] ស្មានប្រជាជនពីដើមហ្នឹង ប្រហែលជាមិនខុស មិន

---

[1696] សេង ស្រ៊ុន៖ ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/346.1** ទំព័រ ៣៦ មុនម៉ោង 11.23.32។

[1697] សូមមើលកថាខណ្ឌមុន (កថាខណ្ឌ ១៧៦៥) និង នោ សាទះ៖ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E1/351.1** ទំព័រ ៩ ក្រោយម៉ោង 09.27.13 ទំព័រ ៤៦ ក្រោយម៉ោង 13.42.08, ម៉ាត់ ស៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/375.1** ទំព័រ ១៦ ក្រោយម៉ោង 09.44.36។

[1698] សេង ស្រ៊ុន៖ ប្រតិចារឹក ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/347.1** ទំព័រ ៨ មុនម៉ោង 09.25.55 ទំព័រ ១០ មុនម៉ោង 09.31.16។

[1699] មុយ វ៉ាន់នី៖ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/373.1** ទំព័រ ៤៥ មុនម៉ោង 14.19.06 ទំព័រ ៥៧ ប្រហែលម៉ោង 15.12.36, សេង ឃុយ៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៧ឯកសារ **E1/344.1** ទំព័រ ៨១ ក្រោយម៉ោង 15.29.05, តាយ គឹមហ៊ាន់៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/348.1** ទំព័រ ១៧-១៨ ក្រោយម៉ោង 09.56.13 ទំព័រ ១៩ មុនម៉ោង 10.02.44, កំណត់ហេតុស្ដាប់ចម្លើយ សុខ ម៉េងលី ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ឯកសារ **E3/9654** សំណួរ/ចម្លើយទី ២៣, កំណត់ហេតុស្ដាប់ចម្លើយ ហុក ហឿន ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ឯកសារ **E3/5256** ERN KH 00243081។

ត្រូវប៉ុន្មានទេ” ដោយគាត់បញ្ជាក់ថា ក្នុងឃុំអង្គរបានរបស់គាត់ មានចាមរស់នៅប្រមាណជាបួនរយគ្រួសារ[1700]។

## ផ្នែកទី ៤. ការកំណត់បទចោទប្រកាន់

១៧៦៩. ផ្ទុយគ្នាពីសហចៅក្រមស៊ើបអង្កេតដែលចាប់ផ្តើមដោយការកំណត់បទចោទប្រកាន់លើអង្គហេតុអំពើប្រល័យពូជសាសន៍ មេធាវីការពារក្តីត្រូវកំណត់ជាបឋមថា តើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលចោទប្រកាន់ចំពោះលោក ខៀវ សំផន មានធាតុផ្សំដែរឬអត់។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងទម្រង់ជាអំពើមនុស្សឃាត ពុំអាចបំពេញបានឡើយ ប្រសិនបើគ្មានការបង្ហាញឱ្យឃើញជាមុនអំពីអំពើមនុស្សឃាត ដែលស្ថិតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នោះ។

### ១. អំពើមនុស្សឃាត (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)

### ក. និយមន័យ

១៧៧០. ធាតុផ្សំសត្យានុម័តិនៃអំពើមនុស្សឃាត រួមមានអំពើសកម្ម ឬ អកម្មរបស់ជនជាប់ចោទ ឬ របស់ជនណាម្នាក់ ឬ ច្រើននាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើសកម្ម ឬ អកម្មដែលបណ្តាលឱ្យជនរងគ្រោះស្លាប់[1701]។ ពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័តិវិញ ចារីត្រូវមានចេតនាផ្ទាល់ក្នុងការធ្វើឱ្យគេស្លាប់[1702]។

### ខ. ការកំណត់បទចោទប្រកាន់លើអង្គហេតុ

[1700] សេង ឃុយ៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ E1/344.1 ទំព័រ ៨១ ក្រោយម៉ោង 15.29.05។

[1701] សាលក្រម ០០២/០១ កថាខណ្ឌ ៤១២។

[1702] សូមមើលខាងលើ កថាខណ្ឌ ៣៩៤-៤២៩។

១៧៧១. ដូចដែលបានឃើញពីខាងលើរួចមកហើយ អង្គជំនុំជម្រះត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុដែលជាធាតុផ្សំនៃអំពើមនុស្សឃាត ដែលស្ថិតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅមន្ទីរសន្តិសុខវត្តអូរត្រកួន[1703]។

១៧៧២. នៅមន្ទីរសន្តិសុខវត្តអូរត្រកួន គ្មានសាក្សីបានឃើញផ្ទាល់ភ្នែកនូវអំពើមនុស្សឃាតឡើយ តែយោងតាមវិធីសាស្ត្របែប "សរុប" របស់អង្គជំនុំជម្រះតុលាការកំពូល ភ័ស្តុតាងមួយផ្នែកដែលត្រូវបានបង្ហាញ អាចឱ្យគេគិតបានថា ធាតុផ្សំនៃអំពើឧក្រិដ្ឋកម្មមនុស្សឃាត អាចត្រូវបានបំពេញ។ ប៉ុន្តែអង្គជំនុំជម្រះត្រូវប្រុងប្រយ័ត្នក្នុងពេលវិភាគលើភ័ស្តុតាង ព្រោះថាភ័ស្តុតាងនេះ គឺរួមផ្សំជាពិសេសដោយពាក្យចចាមអារ៉ាម និងកំណត់ហេតុស្តាប់ចម្លើយ[1704]។

១៧៧៣. ផ្ទុយទៅវិញ ភ័ស្តុតាងទាំងអស់នេះមិនអាចឱ្យគេសន្និដ្ឋានបានថា ក្នុងរយៈពេលដែលលើកយកមកពិចារណានេះ អំពើមនុស្សឃាតទាំងនោះ គឺបានកំណត់គោលដៅជាពិសេសលើជនជាតិចាម បាននោះទេ ទាំងពាក់ព័ន្ធនឹងមូលហេតុនៃការចាប់ខ្លួន ទាំងពាក់ព័ន្ធនឹងរណ្តៅសពរួមដែលបានកាយក្រោយឆ្នាំ ១៩៧៩។

## ២. ការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)

### ក. និយមន័យ

១៧៧៤. ធាតុផ្សំសត្យានុម័តិនៃបទសម្លាប់រង្គាល គឺមានអំពើសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ[1705]។ ពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័តិវិញ អ្នកធ្វើឱ្យគេស្លាប់ត្រូវមានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្សទ្រង់ទ្រាយធំ ឬក៏ដាក់ពួកគេឱ្យស្ថិតក្នុងល័ក្ខខ័ណ្ឌរៀបចំទុកជាមុន ដើម្បីធ្វើឱ្យពួកគេស្លាប់[1706]។

---

[1703] សូមមើលខាងលើ កថាខណ្ឌ ១៥៤០-១៥៤១។

[1704] សូមមើលខាងក្រោម កថាខណ្ឌ ២១៥១ ដល់កថាខណ្ឌ ២១៥៧។

[1705] សាលដីកា ០០២/០១ កថាខណ្ឌ ៥១៧។

[1706] សាលដីកា ០០២/០១ កថាខណ្ឌ ៥១៧ ដល់កថាខណ្ឌ ៥២២។

## ខ. ការកំណត់បទចោទប្រកាន់លើអង្គហេតុ

១៧៧៥. ដូចដែលបានរំឭកពីខាងលើ អង្គជំនុំជម្រះត្រូវបានស្នើឱ្យពិនិត្យលើអង្គហេតុនានាដែលជាធាតុផ្សំនៃបទសម្លាប់រង្គាលជនជាតិចាម ចាប់ពីដើមឆ្នាំ ១៩៧៧ ជាពិសេស នៅតាមមន្ទីរសន្តិសុខទ្រា ក្នុងភូមិភាគបូព៌ា និងនៅមន្ទីរសន្តិសុខវត្តអូរត្រកួន ក្នុងភូមិភាគកណ្តាល តែកម្រិតត្រឹមស្រុកក្រូចឆ្មារ និងស្រុកកងមាស[1707]។

១៧៧៦. ការវិភាគលើភស្តុតាងទាំងអស់ ទោះជាក្នុងភូមិភាគបូព៌ាក្តី ឬក៏ក្នុងភូមិភាគកណ្តាលក្តី គឺមិនអាចឱ្យគេបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យបានថា ធាតុផ្សំនៃបទឧក្រិដ្ឋសម្លាប់រង្គាលត្រូវបានបំពេញនោះទេ ទាំងពាក់ព័ន្ធនឹងស្ថានភាពរស់នៅក្នុងស្រុកក្រូចឆ្មារ និងក្នុងស្រុកកងមាស (១) ទាំងពាក់ព័ន្ធនឹងធាតុផ្សំអង្គហេតុដែលត្រូវបានជ្រើសរើសសម្រាប់មន្ទីរសន្តិសុខទ្រា និងមន្ទីរសន្តិសុខវត្តអូរត្រកួន (២)។

### 1. គ្មានភស្តុតាងបង្ហាញពីស្ថានភាពរស់នៅដែលត្រូវបានរៀបចំឡើងដើម្បីបង្កឱ្យមានការស្លាប់

១៧៧៧. ការវិភាគលើភស្តុតាងទាំងអស់ ទោះជាក្នុងភូមិភាគបូព៌ា ឬក៏ក្នុងភូមិភាគកណ្តាលក្តី មិនអាចឱ្យគេបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យបានថា ធាតុផ្សំបទឧក្រិដ្ឋសម្លាប់រង្គាល ត្រូវបានបំពេញនោះទេ។ សក្ខីកម្មទាំងឡាយទាក់ទងនឹងស្ថានភាពរស់នៅក្នុងស្រុកក្រូចឆ្មារ និងជាពិសេស ក្នុងស្រុកកងមាស គឺបានបដិសេធការណ៍ដែលប្រជាជនចាម ត្រូវដាក់ឱ្យស្ថិតក្នុងស្ថានភាពរស់នៅរៀបចំជាមុន ដើម្បីបង្កឱ្យមានការបាត់បង់ជីវិត។

១៧៧៨. ទោះបីជាសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី មានលទ្ធភាពនិយាយពីការលំបាកផ្សេងៗគ្នា ទៅតាមកន្លែងក៏ដោយ ក៏ជនជាតិចាមត្រូវបានគេដាក់ឱ្យស្ថិតនៅក្នុងស្ថានភាពរស់នៅដូចគ្នានឹងប្រជាជនដទៃទៀត ដោយពួកគេរៀបការ ធ្វើការ និងហូបចុកជាមួយនឹងប្រជាជនខ្មែរ។ ការណ៍ដែលមានការរៀបចំដើម្បីផ្តល់ជម្រកស្នាក់នៅ ផ្តល់អាហារ និងថែទាំដល់ប្រជាជន ហើយបើទោះណាជាវា

[1707] សូមមើលខាងលើ កថាខណ្ឌ ១៥៤៣ ដល់កថាខណ្ឌ ១៥៤៦។

មិនបានគ្រប់គ្រាន់ក្តី គឺមិនអាចនាំឱ្យគេសន្និដ្ឋានបានថា អ្នកទទួលខុសត្រូវតាមសហករណ៍ ឬ តាមអង្គភាពដែលមានចាមធ្វើការ មានចេតនាសម្លាប់ពួកគេ ដោយដាក់ឱ្យពួកគេស្ថិតក្នុងស្ថានភាពដូចនេះបានឡើយ។

## 2. ភស្តុតាងមិនគ្រប់គ្រាន់សម្រាប់សន្និដ្ឋានបានថាមានការសម្លាប់មនុស្សក្នុងចំនួនច្រើន

១៧៧៩. ភស្តុតាងទាក់ទងនឹងមន្ទីរសន្តិសុខទ្រា ក៏មិនគ្រប់គ្រាន់ឱ្យគេសន្និដ្ឋានបានថាមានការសម្លាប់មនុស្សក្នុងចំនួនច្រើន។ រឿងរ៉ាវរបស់សាក្សីផ្សេងៗគ្នា ទាក់ទងនឹងមន្ទីរសន្តិសុខទ្រា គឺមិនមានភាពស៊ីសង្វាក់រវាងគ្នានិងគ្នា ហើយទោះយ៉ាងណា ក៏មិនអាចឱ្យគេបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យបានថា ឧក្រិដ្ឋកម្មសំដៅលើជនជាតិចាម ត្រូវបានបំពេញ នោះទេ។

១៧៨០. លោក អ៊ុត សេន ពុំបានឃើញការសម្លាប់មនុស្សដោយផ្ទាល់ភ្នែក ហើយគាត់មិនដឹងថាមានអ្វីកើតឡើងចំពោះអ្នកទៅជាមួយគាត់ផ្សេងទៀត ក្រោយពីគាត់បានគេចខ្លួនមក។ បើទោះជាអង្គជំនុំជម្រះត្រូវចាប់ផ្តើមពិចារណាលើភស្តុតាងបានមកពីសក្ខីកម្មមិនស៊ីសង្វាក់គ្នារបស់លោកស្រី ម៉ាត់ ស ថាការសម្លាប់មនុស្សបានកើតឡើងនៅថ្ងៃដែលគាត់ជាប់ឃុំឃាំងដែលរងការចោទប្រកាន់ នៅភូមិទ្រាក៏ដោយ ក៏យោងតាមភស្តុតាងដែលមាន អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាមានការសម្លាប់មនុស្សក្នុងចំនួនច្រើន ហើយអង្គជំនុំជម្រះក៏មិនអាចសន្និដ្ឋានបានថា អ្នកទាំងអស់នោះត្រូវបានសម្លាប់ដោយសារតែពួកគេស្ថិតក្នុងក្រុមជនជាតិចាម បាននោះទេ។

១៧៨១. ដូចគ្នានេះដែរ ក្នុងករណីដែលអង្គជំនុំជម្រះត្រូវពិចារណាថា ការសម្លាប់មនុស្សមួយចំនួន អាចត្រូវបានប្រព្រឹត្តនៅស្រុកក្រូចឆ្មារ ជាពិសេស ទាក់ទងនឹងការបង្ក្រាបការបះបោរដែលសាក្សី បាន សៀក បានលើកឡើង ក៏ដោយ ក៏ករណីដាច់ឡែកទាំងនេះ ទាក់ទងនឹងជនជាតិចាម និងជនជាតិខ្មែរ គឺមិនអាចឱ្យគេសន្និដ្ឋានថាមនុស្សជាច្រើននាក់ត្រូវបានសម្លាប់ បានឡើយ ហើយរឹតតែមិនអាចសន្និដ្ឋានបានថា អ្នកទាំងអស់នោះសុទ្ធតែជាចាម បានដែរ។

១៧៨២. ក្រោយពេលពិនិត្យលើភស្តុតាងទាំងអស់ បើទោះជាអង្គជំនុំជម្រះសម្រេចសន្និដ្ឋានថា ឧក្រិដ្ឋកម្មមនុស្សឃាតអាចត្រូវបំពេញបានក៏ដោយ ក៏គេត្រូវកត់សម្គាល់ថា ភស្តុតាងគឺពុំមានគ្រប់គ្រាន់

សម្រាប់បង្ហាញឱ្យឃើញអំពីអំពើមនុស្សឃាតទ្រង់ទ្រាយធំលើជនជាតិចាម នោះទេ។ ដូចដែលបានរំឭកឡើងវិញពីខាងលើរួចមកហើយ ភ័ស្តុតាងទាក់ទងនឹងមូលហេតុចាប់ខ្លួន គឺចង់បង្ហាញថាប្រជាជនគ្រប់សមាសភាពផ្សេងៗគ្នា ត្រូវបានចាប់នាំយកទៅវត្តបឹងត្រកួន ដែលភាគច្រើន ដោយសារតែមូលហេតុដែលសាក្សីពុំបានដឹង។

### 3. ភ័ស្តុតាងពុំគ្រប់គ្រាន់សម្រាប់សន្និដ្ឋានបានថាមានផែនការកម្ទេចក្រុមជនជាតិចាម

១៧៨៣. សក្ខីកម្មតែមួយគត់ដែលអាចជឿជាក់បានតិចតួច និងគ្មានការអះអាងបញ្ជាក់បន្ថែមរបស់លោក សុះ កំរី ទាក់ទងនឹងអត្ថិភាពបែបសន្មតនៃសៀវភៅស្តើងនិយាយពីផែនការទូទៅក្នុងការសម្លាប់រង្គាលជនជាតិចាម គឺមានលក្ខណៈផ្ទុយគ្នាទៅនឹងផ្នែកមួយនៃសក្ខីកម្មផ្ទាល់របស់គាត់ ក៏ដូចជាផ្ទុយគ្នាទៅនឹងសាក្សីជាច្រើននៅភូមិភាគបូព៌ា និងភូមិភាគកណ្តាល ដែលពួកគាត់បានបញ្ជាក់ថាការចាប់ខ្លួន និងការសម្លាប់ជាយថាហេតុណាមួយនាពេលក្រោយមកទៀត គឺពាក់ព័ន្ធប្រជាជនគ្រប់សមាសភាព។

១៧៨៤. សូម្បីតែសាក្សី 2-TCW-894 និង 2-TCW-938 ដែលបានលើកឡើងពីការចាប់ខ្លួនជនជាតិចាម ក៏បានបង្ហាញថា ការចាប់ខ្លួនត្រូវបានធ្វើក្នុងចំណោមប្រជាជនផ្សេងៗទៀត ដោយសារតែមានការចោទថាពួកគេបានប្រព្រឹត្តកំហុសផ្សេងៗ ឬ ក៏ប្រឆាំង នៅក្នុងស្រុកកំពង់សៀមរបស់ពួកគេ។ ដូច្នេះ គេមិនអាចសន្និដ្ឋានបានជាដាច់ខាតថា ចារីមានឆន្ទៈវាយប្រហារលើក្រុមមួយនេះ ក្នុងនាមជាជនជាតិចាម បានឡើយ។

១៧៨៥. សក្ខីកម្មផ្សេងទៀត ទាក់ទងនឹងមូលហេតុនៃការចាប់ខ្លួនមនុស្សក្នុងភូមិភាគបូព៌ា ឬ ក្នុងភូមិភាគកណ្តាល និងប្រជាជនពាក់ព័ន្ធ គឺនិយាយដូចគ្នាដែរ។ ក្នុងស្រុកកងមាសក្តី ក្នុងស្រុកក្រូចឆ្មារក្តី បើយោងតាមសាក្សី ការចាប់ខ្លួនមនុស្ស និងការសម្លាប់ដែលរងការចោទប្រកាន់ គឺពាក់ព័ន្ធប្រជាជនគ្រប់សមាសភាព ក្នុងនោះមានចាមផងដែរ។

## ៣. ការធ្វើទារុណកម្ម )ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ(

### ក. និយមន័យ

១៧៨៦. ឧក្រិដ្ឋកម្មធ្វើទារុណកម្មដែលជាធាតុផ្សំឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានកំណត់និយមន័យដោយអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសាលដីការឿងក្តី ឌុច ក្រោយពីបានផ្ទៀងផ្ទាត់ពីអត្ថិភាពនៃឧក្រិដ្ឋកម្មមួយនេះ នៅសម័យកាលដែលអង្គហេតុបានកើតឡើង[1708]។ លិខិតុបករណ៍ និងយុត្តិ-សាស្ត្រអន្តរជាតិផ្សេងៗ ដូចជាយុត្តិសាស្ត្រតុលាការយោធាអាមេរិក ដែលត្រូវបានបង្កើតឡើងអនុលោមតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យសម្ព័ន្ធមិត្ត ចន្លោះឆ្នាំ ១៩៤៦ ដល់ ឆ្នាំ ១៩៤៩ សេចក្តីអត្ថាធិប្បាយលើសន្ធិសញ្ញាក្រុងហ្សឺណែវ ឆ្នាំ ១៩៥៨ រឿងក្តីប្រទេសក្រិក នៅចំពោះមុខគណៈកម្មាធិការសិទ្ធិមនុស្សអឺរ៉ុប ឆ្នាំ ១៩៦៩ និងដំណើរការនៃការអនុម័តលើសេចក្តីប្រកាសទាក់ទងនឹងការធ្វើទារុណកម្ម ឆ្នាំ ១៩៧៥ ត្រូវបានលើកយកមកពិចារណា[1709]។ ក្រុមមេធាវីការពារក្តីឯកភាពតាមការវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូល ត្រង់ថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទារុណកម្ម ពិតជាមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះឆ្នាំ ១៩៧៥ និង ១៩៧៩ ហើយថាសេចក្តីប្រកាសស្តីពីការធ្វើទារុណកម្ម ឆ្នាំ ១៩៧៥ បង្ហាញឱ្យឃើញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ កាលពីសម័យនោះ[1710]។ យោងតាមសេចក្តីប្រកាសនេះ ការធ្វើទារុណកម្ម ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

> "រាល់អំពើទាំងឡាយណាដែលបណ្តាលឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង លើផ្លូវកាយ ឬ ផ្លូវចិត្ត ដែលតបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ ដោយមន្ត្រីសាធារណៈ ឬ តាមការញុះញង់របស់មន្ត្រីសាធារណៈ ក្នុងគោលបំណងជាអាទិ៍ទទួលបានព័ត៌មាន ឬ ចម្លើយសារភាព ពីជននោះ ឬពីតតិយជន ឬក្នុងគោលបំណងដាក់ទណ្ឌកម្មជននោះចំពោះអំពើដែលគេបានប្រព្រឹត្ត ឬដែលសង្ស័យថាបានប្រព្រឹត្ត ឬដើម្បីបំភិត

---

1708 សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៨៥-២០៥ និងកថាខណ្ឌ ២១១-២១២។

1709 សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៩៥ ដល់កថាខណ្ឌ ២០៤។

1710 សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២០៥។

បំភ័យជននោះ ឬអ្នកផ្សេងទៀត។ [...] អំពើទារុណកម្ម ជាទម្រង់ទោសមួយដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប មួយយ៉ាងធ្ងន់ធ្ងរ និងដោយចេតនា”[1711]។

១៧៨៧. អនុលោមតាមគោលការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា និយមន័យដែលត្រូវបានជ្រើសរើសនៅក្នុងសន្ធិសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មឆ្នាំ ១៩៨៧ ដែលអង្គជំនុំជម្រះ និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា បានយកមកអនុវត្ត ទោះជាមិនមានលក្ខណៈរឹតត្បិតខ្លាំងក៏ដោយ ក៏មិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានឡើយ[1712]។

១៧៨៨. ផ្ដើមចេញពីនិយមន័យដែលមាននៅក្នុងសេចក្ដីប្រកាសស្ដីពីការធ្វើទារុណកម្មឆ្នាំ ១៩៧៥ អង្គជំនុំជម្រះតុលាការកំពូល បានញែកចេញនូវធាតុផ្សំចំនួនបួន៖

“(ក) អំពើណាមួយដែលបណ្ដាលឱ្យមានការឈឺចាប់ ឬការរងទុក្ខយ៉ាងធ្ងន់ធ្ងរ ផ្នែករាងកាយ ឬ ស្មារតី (ធាតុផ្សំសត្យានុម័តិ)

(ខ) ដែលប្រព្រឹត្តឡើងដោយចេតនាទៅលើបុគ្គលណាមួយ (ធាតុផ្សំអត្តនោម័តិ)

(គ) ដោយមន្ត្រីសាធារណៈ ឬ ដោយការញុះញង់ពីមន្ត្រីសាធារណៈ

(ឃ) ក្នុងគោលបំណងដើម្បីទទួលបាននូវព័ត៌មាន ឬចម្លើយសារភាព ឬការដាក់ទណ្ឌកម្ម ឬការបំភិតបំភ័យ”[1713]។

១៧៨៩. ធាតុផ្សំចុងក្រោយនេះ គឺពិតជាសំខាន់ខ្លាំងណាស់ ព្រោះវាបែងចែកលក្ខណៈខុសគ្នារវាងការធ្វើទារុណកម្ម និងការប្រព្រឹត្តបែបសាហាវឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។ សេចក្ដីអត្ថាធិប្បាយលើសន្ធិសញ្ញាក្រុងហ្សឺណែវស្ដីពីការធ្វើទារុណកម្ម ផ្ដោតសំខាន់លើសារៈសំខាន់នៃគោលបំណងដែលចង់បាន តាមរយៈការបង្កឱ្យមានការឈឺចាប់៖ “ចំណុចដែលសំខាន់ គឺមិនសំដៅតែលើ

[1711] មាត្រា ១ នៃសេចក្ដីថ្លែងការណ៍ស្ដីពីការប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក សេចក្ដីសម្រេចលេខ ៣៤៥២ (XXX) របស់មហាសន្និបាតអង្គការសហប្រជាជាតិ៨ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៧៥ (“សេចក្ដីថ្លែងការណ៍ស្ដីពីទារុណកម្ម”)។

[1712] សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៨៩ ដល់កថាខណ្ឌ ១៩៤។

[1713] សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៩៥។

ការឈឺចាប់ដែលជាគោលដៅនៅពីក្រោយការវាយប្រហារបង្កឱ្យមានការឈឺចាប់នោះឡើយ”[1714] ។ ដូចគ្នានេះដែរ ក្នុងរឿងក្តីប្រទេសក្រិក ឆ្នាំ ១៩៦៩ ដែលចែកការប្រព្រឹត្តិបែបអមនុស្សធម៌ ដាច់ចេញពីការធ្វើទារុណកម្ម ដោយបញ្ជាក់ថា ចំពោះការធ្វើទារុណកម្ម វាមាន “គោលដៅទទួលបាននូវព័ត៌មាន ឬចម្លើយសារភាព ឬក៏ជាការដាក់ទណ្ឌកម្ម”[1715]។

១៧៩០. ហេតុដូចនេះ ការវិភាគលើភ័ស្តុតាង ត្រូវបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យថា ការឈឺចាប់ត្រូវបានបង្កឡើងក្នុងគោលបំណងមួយច្បាស់លាស់។ ប្រសិនបើភ័ស្តុតាង មិនអាចកំណត់លក្ខណៈខុសគ្នារវាងអំពើបង្កឡើងក្នុងគោលដៅជាក់លាក់ និងភាពឃោរឃៅសុទ្ធសាធបាន ដូច្នេះ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ហើយធាតុផ្សំអំពើធ្វើទារុណកម្ម ក៏មិនអាចបំពេញបាន[1716]។

## ខ. ការកំណត់បទចោទលើអង្គហេតុ

១៧៩១. ដូចដែលបានឃើញពីខាងលើ អង្គហេតុទាំងឡាយទាក់ទងនឹងការឃុំខ្លួនជនជាតិចាម ត្រូវបានកម្រិតត្រឹមមន្ទីរសន្តិសុខទ្រា ក្នុងភូមិភាគបូព៌ា[1717]។

១៧៩២. សក្ខីកម្មតែមួយគត់ដែលគ្មានអ្វីសំអាងរបស់លោក អ៊ីត សេន មិនអាចឱ្យគេសន្និដ្ឋានបានថា ឧក្រិដ្ឋកម្មធ្វើទារុណកម្ម មានភ័ស្តុតាងបង្ហាញឱ្យហួសពីវិមតិសង្ស័យបានទេ។

---

[1714] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ មតិទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទី ៤ (Jean S. Pictet បោះពុម្ពឆ្នាំ ១៩៥៨) ពាក់ព័ន្ធនឹងមាត្រា ២ ទំព័រ ៦៤០,សាលដីកា ខុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២០០ ដល់កថាខណ្ឌ ២០១។

[1715] រឿងក្តីប្រទេសក្រិច កម្រងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស លេខ ១២ ឆ្នាំ ១៩៦៩ ទំព័រ ១៨៩, សាលដីកា ខុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២០២ ដល់កថាខណ្ឌ ២០៣។

[1716] សាលដីកា *Limaj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧ កថាខណ្ឌ ២១។

[1717] សូមមើលខាងលើ កថាខណ្ឌ ១៥៥៣-១៥៥៩។

## ៤. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា )ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ(

### ក. និយមន័យ

១៧៩៣. ធាតុផ្សំសត្យានុម័តិនៃអំពើធ្វើទុក្ខបុកម្នេញ គឺអំពើសកម្ម ឬ អកម្មដែលពិតជារើសអើង ហើយដកហូត ឬ រំលោភទៅលើសិទ្ធិជាមូលដ្ឋានដែលមានចែងក្នុងសន្ធិសញ្ញាអន្តរជាតិ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ[1718]។ ពាក់ព័ន្ធនឹងការរើសអើងជាក់ស្តែងដែលតម្រូវឱ្យមានសម្រាប់ធ្វើជាធាតុផ្សំសត្យា-នុម័តៈ

> "ការរើសអើងជាក់ស្តែង កើតមានឡើងនៅពេលដែលជនរងគ្រោះណាម្នាក់ត្រូវបានគេកំណត់ជាគោលដៅដោយសារតែជនរងគ្រោះនោះជាសមាជិកនៅក្នុងក្រុមណាមួយ ដែលចារីបានកំណត់ ដោយផ្អែកលើមូលហេតុជាក់លាក់មួយចំនួន ពោលគឺមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា ហើយជនរងគ្រោះនោះត្រូវតែស្តែងឱ្យឃើញច្បាស់លាស់គ្រប់គ្រាន់ថា គាត់បានស្ថិតក្នុងក្រុមនយោបាយ ពូជសាសន៍ ឬ សាសនាណាមួយ ដែលផលវិបាកនៃការធ្វើទុក្ខបុកម្នេញដែលជាល័ក្ខខ័ណ្ឌតម្រូវនោះ ត្រូវតែកើតមានទៅលើក្រុមនោះ"[1719]។

១៧៩៤. ធាតុផ្សំអត្តនោម័តិដែលជាល័ក្ខខ័ណ្ឌតម្រូវសម្រាប់បង្កើតបានជាឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញ តម្រូវបង្ហាញឱ្យឃើញថា អ្នកប្រព្រឹត្តិអំពើសកម្ម ឬ អកម្មដែលត្រូវបានចោទប្រកាន់ បានធ្វើសកម្មភាពតាមទំនើងចិត្ត ដោយមានចេតនារើសអើង ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា[1720]។

### ខ. ការកំណត់បទចោទលើអង្គហេតុ

១៧៩៥. ដូចបានរំឭកពីខាងលើ អង្គជំនុំជម្រះត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុទាំងឡាយដែលជាធាតុផ្សំនៃអំពើធ្វើទុក្ខបុកម្នេញសាសនា ក្នុងពេលប្រព្រឹត្តមកលើជនជាតិចាម ដូចដែលបានពិពណ៌នានៅ

---

[1718] សាលក្រម ០០២/០១ កថាខណ្ឌ ៤២៧, សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២២៦។

[1719] សាលក្រម ០០២/០១ កថាខណ្ឌ ៤២៨, សាលដីកា ០០២/០១ កថាខណ្ឌ ៦៦៧។

[1720] សាលក្រម ០០២/០១ កថាខណ្ឌ ៤២៧, សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២២៦។

ត្រង់កថាខណ្ឌ ១៤២០ នៃដីកាដំណោះស្រាយ និងជាពិសេស ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២[1721]។

១៧៩៦. ការពិនិត្យលើអង្គហេតុទាក់ទងនឹងការប្រព្រឹត្តទៅនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ មិនអាចឱ្យគេបង្ហាញឱ្យឃើញពីការរើសអើងចំពោះជនជាតិចាម បានឡើយ។ ដូចប្រជាជនដទៃទៀតដែរ ទោះជាមានដើមកំណើត ឬ សាសនា យ៉ាងណាក្តី អ្នកទាំងអស់នោះត្រូវបានផ្លាស់ទីលំនៅដែលត្រូវបានសម្រេចក្នុងក្របខ័ណ្ឌនៃការរៀបចំឡើងវិញ។

១៧៩៧. ការប្រព្រឹត្តដែលប្រជាជនចាមបានទទួលរង ក៏មិនអាចឱ្យគេសន្និដ្ឋានបានថា អ្នកទាំងនោះបានរងគ្រោះនូវការប្រព្រឹត្តបែបរើសអើង ដោយសារតែមូលហេតុសាសនារបស់ពួកគេបានឡើយ។ ដោយសារតែសាសនាទាំងអស់ត្រូវបានហាមឃាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គេពុំអាចសន្និដ្ឋានបានថា មានការប្រព្រឹត្តមួយជាពិសេសទុកសម្រាប់តែសាសនាអ៊ីស្លាមមួយបានទេ។

១៧៩៨. ម្យ៉ាងទៀត ដូចដែលបានលើកឡើងពីខាងដើម ទាក់ទងនឹងការពិនិត្យលើឧក្រិដ្ឋកម្មសម្លាប់រង្គាលស្ថានភាពរស់នៅរបស់ប្រជាជនចាម គឺដូចគ្នានឹងប្រជាជនខ្មែរដែរ។ ម្យ៉ាងវិញទៀត សាក្សីជាច្រើនបានសង្កត់ធ្ងន់លើការពិពណ៌នាស្តីពីការប្រព្រឹត្តស្មើភាពគ្នានេះ ហើយដូច្នេះ វាផ្ទុយគ្នាទៅនឹងអ្វីដែលគេអាចសន្និដ្ឋានថាមានការរើសអើង និងមានចេតនាធ្វើការរើសអើងលើជនជាតិចាម។

## ៥. អំពើមនុស្សឃាត (អំពើប្រល័យពូជសាសន៍)

## ក. និយមន័យអំពើប្រល័យពូជសាសន៍ តាមរយៈអំពើមនុស្សឃាត

### 1. សេចក្តីផ្តើម

១៧៩៩. សញ្ញាណអំពើប្រល័យពូជសាសន៍ ត្រូវបានកសាងឡើងចាប់តាំងពីឆ្នាំ ១៩៤៤ មក ដោយអ្នកច្បាប់ឈ្មោះ Raphaël LEMKIN ដើម្បីឆ្លើយតបទៅនឹងអំពើប្រព្រឹត្តដោយរបបណាហ្ស៊ី ក្នុងអំឡុងពេល

[1721] សូមមើលខាងលើ កថាខណ្ឌ ១៥៤៣ ដល់កថាខណ្ឌ ១៥៤៦។

សង្គ្រាមលោកលើកទី២[1722]។ ក្នុងពេលជំនុំជម្រះរឿងក្ដីនៅតុលាការ Nuremberg ក្នុងខែតុលា ឆ្នាំ ១៩៤៦ ដោយសារពុំមានច្បាប់ ឬ សន្ធិសញ្ញាចែងអំពីបញ្ហានេះ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ពុំបានក្លាយជាធាតុផ្សំនៃការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទឡើយ។ ក្នុងសាលដីកាក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានរំឭកថា៖

> "បទសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងយុត្តិសាស្ត្រតុលាការយោធាអន្តរជាតិIMT បានរួមបញ្ចូលនូវបទឧក្រិដ្ឋមួយដែលក្រោយមកត្រូវបានកំណត់ថាជាបទប្រល័យពូជសាសន៍ ជាពិសេសនៅក្នុងបរិបទនៃដំណោះស្រាយចុងក្រោយ [...]។ ក្នុងន័យនេះ បទសម្លាប់រង្គាល គឺជាយុត្តិសាស្ត្ររបស់បទប្រល័យពូជសាសន៍"[1723]។

១៨០០. នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦ ពីរខែក្រោយពីការជំនុំជម្រះនៅតុលាការ Nuremberg មហា- សន្និបាតអង្គការសហប្រជាជាតិបានចាត់ទុក "ការបង្ក្រាបបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ [...] ជាកិច្ចការបម្រើឱ្យផលប្រយោជន៍ជាអន្តរជាតិ"[1724]។ បន្ទាប់មក មហាសន្និបាតអង្គការសហ-ប្រជាជាតិបាន"ស្នើឱ្យប្រទេសសមាជិក ចាត់វិធានការផ្លូវច្បាប់ចាំបាច់នានាដើម្បីបង្ការ និងបង្ក្រាបឧក្រិដ្ឋកម្មនេះ"[1725]។

១៨០១. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៤៨ អនុសញ្ញាស្ដីពីការបង្ការ និងបង្ក្រាបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ("អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍") ត្រូវបានចុះហត្ថលេខា។ និយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មានចែងក្នុងមាត្រា ២ នៃអនុសញ្ញា៖

> "ក្នុងអនុសញ្ញានេះ អំពើប្រល័យពូជសាសន៍ គឺជាអំពើមួយក្នុងចំណោមអំពើដូចខាងក្រោម ហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬ មួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជា៖

---

[1722] *Axis Rule in Occupied Europe*, Raphaël LEMKIN ឆ្នាំ ១៩៤៤។

[1723] សាលដីកា ០០២/០១ កថាខណ្ឌ ៥១៧។

[1724] សេចក្ដីសម្រេច លេខ ៩៦(១) ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦ នៃមហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំពេញអង្គលើកទី ៥៥។

[1725] សេចក្ដីសម្រេច លេខ ៩៦(១) ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦ នៃមហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំពេញអង្គលើកទី ៥៥។

ក) ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម

ខ) ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬ សតិបញ្ញាសមាជិកនៃក្រុម

គ) ការធ្វើដោយចេតនាឱ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក

ឃ) ការដាក់នូវវិធានការនានា ដែលមានបំណងរាំងមិនឱ្យមានការផ្តល់កំណើតទារក

ង) ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត”[1726]។

១៨០២. នៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ សែសិបឆ្នាំក្រោយពីការចុះហត្ថលេខាលើអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា នៅក្នុងសាលក្រមរឿងក្តី *Akayesu* បានសម្រេចផ្តន្ទាទោសជាលើកដំបូងពីបទប្រល័យពូជសាសន៍ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិមួយ[1727]។ ក្រោយមកទៀត តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ក៏ដូចជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានធ្វើសេចក្តីសម្រេចជាច្រើនលើកច្រើនសា ទាក់ទងនឹងការចោទប្រកាន់ពីបទប្រល័យពូជសាសន៍[1728]។

១៨០៣. សេចក្តីផ្តើមទាំងប៉ុន្មាននេះ គឺពិតជាសំខាន់ណាស់ ដើម្បីអាចឱ្យគេយល់បានថា នៅសម័យកាលដែលអង្គហេតុស្ថិតក្រោមការពិនិត្យរបស់អង្គជំនុំជម្រះបានកើតឡើង តុលាការអន្តរជាតិនានា មិនដែលផ្តល់ការបកស្រាយលើនិយមន័យធាតុផ្សំនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ម្តងណាឡើយ។

១៨០៤. ប្រសិនបើអង្គជំនុំជម្រះត្រូវតម្រូវឱ្យប្រើប្រាស់នូវធាតុផ្សំទាំងឡាយដែលកើតមានមុនអង្គហេតុ អង្គជំនុំជម្រះត្រូវធានាជាបន្ត និងជាប្រចាំឱ្យបាននូវការគោរពគោលការណ៍នីត្យានុកូលភាព និងល័ក្ខខ័ណ្ឌតម្រូវរបស់ច្បាប់ស្តីពីភាពអាចយល់ដឹងជាមុនថាជាបទល្មើស និងមានច្បាប់ចែង[1729]។

---

[1726] មាត្រា ២ នៃអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៤៨។

[1727] សាលក្រម *Akayesu* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨។

[1728] សូមមើល អាទិ៍៖ សាលក្រម *Rutaganda* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៩, សាលក្រម *Jelisić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩, សាលដីកា *Krstić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤, សាលក្រម *Seromba* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦, សាលក្រម *Karadžić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦។

[1729] សូមមើលខាងលើ កថាខណ្ឌ ៣០០ ដល់កថាខណ្ឌ ៣៣០។

១៨០៥. ដើម្បីធ្វើកិច្ចការនេះ អង្គជំនុំជម្រះត្រូវបានជំរុញយ៉ាងខ្លាំងក្លាឱ្យយកតាមការអនុវត្តយ៉ាងហ្មត់ចត់របស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយ ដែលនៅពេលផ្តល់ការពន្យល់លើធាតុផ្សំនីមួយៗនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ សហចៅក្រមស៊ើបអង្កេតបានយោងតែទៅលើការងារត្រៀមរៀបចំអនុសញ្ញា ឆ្នាំ ១៩៤៨ ប៉ុណ្ណោះ[1730]។

## 2. ធាតុផ្សំឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

១៨០៦. និយមន័យក្នុងមាត្រា ២ នៃអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលត្រូវបានដកស្រង់យកមកគ្រប់ពាក្យគ្រប់ម៉ាត់ដោយមាត្រា ៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ធ្វើឱ្យស្តែងចេញនូវធាតុផ្សំទាំងពីរនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

១៨០៧. ធាតុផ្សំសត្យានុម័តិ គឺរួមមានការប្រព្រឹត្តសកម្មភាពមួយ ឬ ច្រើន ដូចមានរៀបរាប់ក្នុងវាក្យខណ្ឌ ក) ដល់វាក្យខណ្ឌ ង) នៃមាត្រា ២ របស់អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍។ លោក ខៀវ សំផន ត្រូវបានចោទប្រកាន់តែពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយអំពើមនុស្សឃាត (មាត្រា ២ វាក្យខណ្ឌ ក)) លើសមាជិកក្រុមជនជាតិចាម និងក្រុមជនជាតិវៀតណាម[1731]។ ហេតុដូច្នេះ ពុំចាំបាច់មានការអធិប្បាយទាក់ទងនឹងអំពើជាក់ស្តែងដទៃទៀតដែលជាធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ឡើយ។

១៨០៨. ធាតុផ្សំអត្តនោម័តិ ត្រូវបានឱ្យនិយមន័យថាជាចេតនាក្នុងការបំផ្លាញទាំងស្រុង ឬ មួយផ្នែក នូវក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ណាមួយ។

### 2.ក. ធាតុផ្សំសត្យានុម័តិ

---

[1730] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១២ និងកំណត់សម្គាល់ចុងឯកសារ ៥១៦៧-៥១៨១។

[1731] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៣៦-១៣៣៧ (ជនជាតិចាម) និងកថាខណ្ឌ ១៣៤៣-១៣៤៤ (ជនជាតិវៀតណាម)។

១៨០៩. កិច្ចការត្រៀមរៀបចំអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ បានផ្តល់ធាតុផ្សំតិចតួចបំផុត ទាក់ទងនឹងនិយមន័យអំពើមនុស្សឃាតលើសមាជិកក្រុម។ ក្នុងសាលក្រម *Akayesu* ចៅក្រមបានសម្រេចថា "អំពើមនុស្សឃាត អាចត្រូវបានបំពេញ ប្រសិនបើគេបានធ្វើឱ្យមានមនុស្សស្លាប់ ជាមួយនឹងចេតនាចង់ធ្វើដូច្នេះ"[1732]។ តុលាការយុត្តិធម៌អន្តរជាតិ ក្នុងរឿងក្តីទាក់ទងនឹងការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងបង្ក្រាបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ ២០០៧ បានបញ្ជាក់ថា អំពើមនុស្សឃាត គឺពិតជាបង្កឡើងដោយចេតនាប្រាកដណាស់[1733]។

១៨១០. ធាតុផ្សំទាំងនេះ គឺស្របគ្នានឹងធាតុផ្សំនៃនិយមន័យអំពើមនុស្សឃាត ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងនិយមន័យអំពើមនុស្សឃាតដោយចេតនា ក្នុងឋានៈជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ។ និយមន័យអំពើមនុស្សឃាត គឺ "អំពើសកម្ម ឬ អកម្មរបស់ជនជាប់ចោទ ឬ របស់ជនណាម្នាក់ ឬ ច្រើននាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើសកម្ម ឬ អកម្មដែលបណ្តាលឱ្យជនរងគ្រោះស្លាប់។ [...] ចារីត្រូវមានចេតនាផ្ទាល់ក្នុងការធ្វើឱ្យគេស្លាប់"[1734]។

## 2.២. ធាតុផ្សំអត្តនោម័តិ

១៨១១. ដើម្បីឱ្យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អាចបំពេញបាន គេត្រូវបង្ហាញឱ្យឃើញថា អំពើមនុស្សឃាតលើសមាជិកក្រុម ត្រូវបានអនុវត្តឡើង "ក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ"។ ចេតនាឧក្រិដ្ឋពិសេសមួយនេះ ដែលជាលក្ខណៈសម្គាល់នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អាចត្រូវបានវិភាគ តាមរយៈការបំបែកចេញ

---

[1732] សាលក្រម *Akayesu* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥០០។

[1733] កថាខណ្ឌ ១៨៦ នៃសាលដីកាលើរឿងក្តីស្តីពីការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (បូស្នៀ និងហឺហ្សេហ្គោវីណា ទល់នឹង ស៊ែរប៊ី និងម៉ុងតេណេហ្គ្រូ) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[1734] សូមមើលខាងលើ កថាខណ្ឌ ៣៩៤-៤២៩ កថាខណ្ឌ ១៤៥៧ និងកថាខណ្ឌ ១៧៧០។

ជាសមាសធាតុដូចតទៅ៖ គោលបំណងបំផ្លិចបំផ្លាញក្រុមណាមួយ (i) ទាំងស្រុង ឬមួយផ្នែក (ii) ជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា (iii)។

១៨១២. នៅពេលកំណត់និយមន័យពាក្យទាំងអស់នេះបានហើយ គេនៅត្រូវធ្វើបែបណាដើម្បីបង្ហាញឱ្យឃើញពីចេតនាប្រល័យពូជសាសន៍ តាមរយៈអង្គហេតុដែលរងការចោទប្រកាន់ (iv)។

### i. គោលបំណងបំផ្លិចបំផ្លាញក្រុមណាមួយ

១៨១៣. ក្នុងសេចក្ដីសម្រេចចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦ មហាសន្និបាតអង្គការសហប្រជាជាតិ បានចែកដាច់រវាងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មមនុស្សឃាត ដោយបានពិពណ៌នាអំពីប្រល័យពូជសាសន៍ថាជា"ការបដិសេធសិទ្ធរស់រានមានជីវិតរបស់ក្រុមមនុស្សទាំងមូល"[1735]។ ក្នុងអំឡុងពេលធ្វើកិច្ចការត្រៀមរៀបចំអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មានការកត់សម្គាល់ថា "ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាក្រុមមនុស្ស។ គឺពុំមែនចំនួនមនុស្សតិច ឬ ច្រើនដែលត្រូវបានកំណត់ជាគោលដៅ ដោយសារមូលហេតុជាក់លាក់ណាឡើយ [...] តែវាជាក្រុមមួយតែម្តង"[1736]។

១៨១៤. ក្នុងសេចក្តីព្រាងក្រមឧក្រិដ្ឋកម្ម ឆ្នាំ ១៩៩៦ គណៈកម្មាធិការច្បាប់អន្តរជាតិ បានអត្ថាធិប្បាយលើចេតនាក្នុងការបំផ្លាញក្រុម ដូច្នេះផងដែរ។ ក្រៅពីនេះ គណៈកម្មាធិការនេះបានគូសបញ្ជាក់ពីទំហំនៃចេតនា "បំផ្លាញក្រុមមួយ "តែម្តង" គឺមានន័យថាជាផ្នែកមួយដាច់ខុសពីគេ និងពុំមែនគ្រាន់ត្រឹមជាមនុស្សប៉ុន្មាននាក់ ដោយសារតែពួកគេស្ថិតក្នុងក្រុមនោះឡើយ"[1737]។ ក្រោយមក ធាតុផ្សំនេះត្រូវបានលើកឡើងវិញនៅក្នុងសាលក្រម *Akayesu* ដែលនៅក្នុងនោះ មានការបញ្ជាក់ថា "ដូច្នេះជនរងគ្រោះនៃអំពើនេះ គឺជាសមាជិកក្រុម ដែលត្រូវបានជ្រើសរើសក្នុងនាមជាអ្នកស្ថិតក្នុងក្រុម

---

[1735] សេចក្តីសម្រេច លេខ ៩៦(១) ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦ នៃមហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំពេញអង្គលើកទី ៥៥។

[1736] ឯកសារអង្គការសហប្រជាជាតិ លេខ E/AC.25/3 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៤៨ ទំព័រ ៧។

[1737] សេចក្តីព្រាងក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសុវត្ថិភាពមនុស្សជាតិ ព្រមទាំងមតិអត្ថាធិប្បាយពាក់ព័ន្ធ ឆ្នាំ ១៩៩៦ ទំព័រ ៤៧ របស់គណៈកម្មាធិការនីតិអន្តរជាតិ។

នោះតែម្តង ដែលជាចុងក្រោយ វាមានន័យថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាក្រុមផ្ទាល់តែម្តង និងពុំមែនត្រឹមតែបុគ្គល នោះទេ”[1738]។

១៨១៥. ចេតនាក្នុងការបំផ្លាញដែលជាធាតុផ្សំផ្ទាល់នៃអំពើប្រល័យពូជសាសន៍ បានបែងចែកផងដែរនូវលក្ខណៈខុសគ្នារវាងឧក្រិដ្ឋកម្មនេះ និងការធ្វើទុក្ខបុកម្នេញ ក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដូច្នេះ គេមិនគ្រាន់តែត្រូវបង្ហាញឱ្យឃើញថាអំពើទាំងនេះសំដៅទៅលើបុគ្គល ដោយសារតែបុគ្គលនោះស្ថិតក្នុងក្រុម (ធាតុផ្សំចេតនានៃអំពើធ្វើទុក្ខបុកម្នេញ) តែម្យ៉ាងនោះទេ[1739]។ តែគេនៅត្រូវបង្ហាញឱ្យឃើញថា អំពើទាំងនេះត្រូវបានអនុវត្តក្នុងគោលបំណងបំផ្លាញក្រុមនេះ ថែមទៀត។

១៨១៦. គេអាចនិយាយបានម្យ៉ាងទៀតថា ខុសគ្នាពីអំពើធ្វើទុក្ខបុកម្នេញ ដែលសំដៅលើបុគ្គល អាស្រ័យទៅតាមសមាជិកភាពរបស់គេនៅក្នុងសហគមន៍ណាមួយជាក់លាក់ ដោយមិនចាំបាច់សំដៅបំផ្លាញសហគមន៍[1740] តែចំពោះអំពើប្រល័យពូជសាសន៍វិញ ចេតនាក្នុងការបំផ្លាញនេះ គឺចាំបាច់ត្រូវតែមាន។

១៨១៧. ចេតនាក្នុងការបំផ្លាញនេះ បានក្លាយជាប្រធានបទក្នុងកិច្ចពិភាក្សាដេញដោល ក្នុងអំឡុងពេលធ្វើកិច្ចការត្រៀមរៀបចំសន្ធិសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍។ បញ្ហាប្រល័យពូជសាសន៍លើផ្នែកវប្បធម៌ ត្រូវបានចោទឡើងតាំងពីពេលចាប់ផ្តើមកិច្ចពិភាក្សាជាមួយគណៈប្រតិភូខ្លះ ដែលបានបញ្ចូលក្នុងនិយមន័យអំពើប្រល័យពូជសាសន៍ នូវវិធានការ និងសកម្មភាពនានាធ្វើឡើងប្រឆាំងនឹង

---

[1738] សាលក្រម *Akayesu* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥២១ យោងដល់របាយការណ៍វិភាគនៃសម័យប្រជុំលើកទី ៦ របស់គណៈកម្មាធិការនៃមហាសន្និបាត ពីថ្ងៃទី ២១ ខែ កញ្ញា ដល់ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ១៩៤៨។

[1739] សូមមើលខាងលើ កថាខណ្ឌ ១២១២ ដល់កថាខណ្ឌ ១២១៣។

[1740] សាលក្រម *Krstić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥៥៣។ ពាក់ព័ន្ធនឹងចេតនាបំផ្លាញ សូមមើលផងដែរនូវសាលក្រម *Akayesu* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥២២, សាលក្រម *Kayishema និង Ruzindana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៩៩។

ការប្រើប្រាស់ភាសាជាតិ ឬ ប្រឆាំងនឹងវប្បធម៌ជាតិ[1741]។ និយមន័យអំពើប្រល័យពូជសាសន៍ក្នុងទិដ្ឋភាពនេះ ក៏ត្រូវបានស្នើឡើងក្នុងសេចក្ដីព្រាងបញ្ជូនទៅក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ (ECOSOC)។ ប៉ុន្តែ នៅទីបញ្ចប់ និយមន័យនេះមិនត្រូវបានជ្រើសយកដាក់ក្នុងនិយមន័យដែលមហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តយកកាលពីថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៤៨ ឡើយ[1742]។ ដូច្នេះ គឺមានតែការបំផ្លាញផ្នែករូបរាងកាយ និងជីវសាស្ត្រ ប៉ុណ្ណោះ ដែលអាចធ្វើជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បាន។

១៨១៨. ក្នុងអំឡុងពេលធ្វើការងារត្រៀមរៀបចំអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ សំណើប្រទេសស៊ីរីសុំដាក់បញ្ចូលក្នុងនិយមន័យប្រល័យពូជសាសន៍ នូវសញ្ញាណនៃការបោសសម្អាតជាតិពន្ធុ ដែលរួមមានការជម្លៀស ឬ ការផ្លាស់ទីលំនៅសមាជិកក្រុមដែលទទួលបានការការពារ ក៏ត្រូវបានបដិសេធចោលដូចគ្នា[1743]។

១៨១៩. ក្នុងរឿងក្ដី *Stakic* ចៅក្រមបានបញ្ជាក់អះអាងថា គេត្រូវ "បែងចែកឱ្យដាច់រវាងការបំផ្លាញផ្នែករូបរាងកាយ និងការរម្លាយក្រុមមួយធម្មតា"[1744]។ ដូចគ្នានេះដែរ តុលាការយុត្តិធម៌អន្តរជាតិ ក៏បានទាត់ចោលគំនិតដែលថាការជម្លៀសដោយបង្ខំ អាចមានន័យស្មើនឹងការបំផ្លាញក្រុម។ បើទោះបីជាសកម្មភាពបោសសម្អាតជាតិពន្ធុខ្លះ អាចកើតឡើងស្របពេលដំណាលគ្នានឹងអំពើដែលជាធាតុផ្សំនៃបទប្រល័យពូជសាសន៍ក៏ដោយ ក៏សកម្មភាពបោសសម្អាតតែឯកឯង មិនអាចផ្សំបានជាបទល្មើសប្រល័យពូជសាសន៍ បាននោះទេ[1745]។ ក្នុងពេលពិនិត្យលើភស្តុតាង តុលាការយុត្តិធម៌អន្តរជាតិបាន

---

[1741] ឯកសារអង្គការសហប្រជាជាតិ លេខ E/AC.25/7 ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៤៨ ទំព័រ ២, ឯកសារអង្គការសហប្រជាជាតិ លេខ E/AC.25/9 ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៤៨ ទំព័រ ១។

[1742] សេចក្ដីសម្រេច លេខ ២៦០(៣) ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៤៨ នៃមហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំពេញអង្គលើកទី ១៧៩។

[1743] ឯកសារអង្គការសហប្រជាជាតិ លេខ A/C.6/234 ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៤៨។

[1744] សាលក្រម *Stakić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ៥១៩។

[1745] កថាខណ្ឌ ១៩០ នៃសាលដីកាលើរឿងក្ដីស្ដីពីការអនុវត្តអនុសញ្ញាស្ដីពីការបង្ការ និងផ្ដន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (ប៊ូស្នៀ និងហឺហ្សេហ្គោវីណា ទល់នឹង ស៊ែប៊ី និងម៉ុងតេណេហ្គ្រូ) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

សន្និដ្ឋានថា ការជម្លៀស និងការបណ្តេញអ្នកកាន់សាសនាអ៊ីស្លាមក្នុងប្រទេសបូស្នី បានកើតឡើងក្នុងប្រទេសបូស្នី-ហេហ្សេហ្គោវីន ប៉ុន្តែ ការជម្លៀស និងការបណ្តេញនេះ មិនត្រូវបានអនុវត្តជាមួយនឹងចេតនាបំផ្លាញទាំងស្រុង ឬ មួយផ្នែក នូវក្រុមដែលទទួលបានការការពារឡើយ[1746]។

ii. **ទាំងស្រុង ឬមួយផ្នែក**

១៨២០. ធាតុផ្សំ "ទាំងស្រុង ឬមួយផ្នែក" ត្រូវបានលើកយកមកពិភាក្សាក្នុងអំឡុងពេលធ្វើការងារត្រៀមរៀបចំអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ហើយត្រូវបានអនុម័តក្នុងកិច្ចពិភាក្សា ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៤៨[1747]។ គណៈប្រតិភូទាំងអស់បានឯកភាពគ្នាថា ការបញ្ចូលឃ្លា "ទាំងស្រុង ឬមួយផ្នែក" អនុញ្ញាតឱ្យបញ្ជាក់បានថា គឺពុំចាំបាច់សម្លាប់ដល់ទៅសមាជិកក្រុមទាំងអស់ ទើបហៅថាជាអំពើប្រល័យពូជសាសន៍បាននោះទេ[1748]។ ប៉ុន្តែ គណៈកម្មាធិការច្បាប់អន្តរជាតិ បានពន្យល់ថា "តាមលក្ខណៈដើមរបស់ខ្លួន ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មានបង្កប់រួចជាស្រេចនូវចេតនាបំផ្លាញយ៉ាងហោចណាស់មួយផ្នែកសំខាន់ណាមួយរបស់ក្រុមគោលដៅ"[1749]។

១៨២១. ល័ក្ខខ័ណ្ឌទាក់ទងនឹងការបំផ្លាញផ្នែកសំខាន់ណាមួយនៃក្រុមគោលដៅ ត្រូវបានលើកឡើងវិញនៅក្នុងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា[1750]។ ក្នុងសាលដីកា *Krstić* មានការបញ្ជាក់ជាអាទិ៍ថា "ល័ក្ខខ័ណ្ឌតម្រូវនេះបង្ហាញឱ្យឃើញទាំងចរិតទ្រង់ទ្រាយធំនៃអំពើប្រល័យពូជសាសន៍ ទាំងការ

---

[1746] កថាខណ្ឌ ៣២៨ ដល់កថាខណ្ឌ ៣៣៤ នៃសាលដីកាលើរឿងក្តីស្តីពីការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (ប៊ូស្នៀ និងហឺហ្សេហ្គោវីណា ទល់នឹង ស៊ែរប៊ី និងម៉ុងតេណេក្រូ) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[1747] ឯកសារអង្គការសហប្រជាជាតិ លេខ A/C.6/SR.73 ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៤៨ ទំព័រ ៩៧។

[1748] ឯកសារអង្គការសហប្រជាជាតិ លេខ A/C.6/SR.73 ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៤៨ ទំព័រ ៩៣។

[1749] សេចក្តីព្រាងក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសុវត្ថិភាពមនុស្សជាតិ ព្រមទាំងមតិអត្ថាធិប្បាយពាក់ព័ន្ធ ឆ្នាំ ១៩៩៦ ទំព័រ ៤៧ របស់គណៈកម្មាធិការនីតិអន្តរជាតិ។

[1750] សាលក្រម *Kayishema និង Ruzindana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៩៧, សាលក្រម *Bagilishema* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៦៤, សាលក្រម *Semanza* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៣១៦, សាលដីកា *Krstić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ៨ ដល់កថាខណ្ឌ ១១។

បារម្ភដែលបានលើកឡើងនៅក្នុងអនុសញ្ញា ពាក់ព័ន្ធនឹងផលវិបាកដែលអាចកើតមានមកលើការរស់មានជីវិតបន្តទៀតរបស់ក្រុមទាំងមូល ដោយសារតែការបំផ្លាញផ្នែកគោលដៅក្នុងក្រុម"[1751]។ មានការបន្ថែមថា"វាអាចមានប្រយោជន៍ដែលមិនត្រូវពិចារណាតែទៅលើទំហំតួលេខនៃការបំផ្លាញក្រុមគោលដៅមួយមុខ តែគេក៏ត្រូវពិចារណាផងដែរលើតួនាទីរបស់វានៅក្នុងក្រុមទាំងមូល"[1752]។ ជាចុងក្រោយ តុលាការយុត្តិធម៌អន្តរជាតិបានកត់សម្គាល់ថា "វាអាចសន្និដ្ឋានថាជាអំពើប្រល័យពូជសាសន៍បាន នៅពេលដែលចេតនានោះ គឺចង់បំផ្លាញក្រុម នៅក្នុងតំបន់ភូមិសាស្ត្រមួយជាក់លាក់"[1753]។

iii. <u>**ជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា**</u>

១៨២២. អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ បានរក្សាទុកបួនក្រុមជាក់លាក់ ក្នុងនោះមាន ក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា។ ក្រុមនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ត្រូវបានដកចេញជាពិសេសពីការការពារដោយអនុសញ្ញា ព្រោះថាចំណុចទាំងនេះគ្មានចរិតលក្ខណៈជាក្រុមដែល "មានស្ថិរភាព" និង "អចិន្ត្រៃយ៍"[1754]។

---

[1751] សាលដីកា *Krstić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ៨ យោងដល់សាលក្រម *Jelisić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៨២ និងសាលក្រម *Sikirica* ស្តីពីសំណើសុំដោះលែង (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០១ កថាខណ្ឌ ៧៧។

[1752] សាលដីកា *Krstić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ១២។

[1753] កថាខណ្ឌ ១៩៩ នៃសាលដីកាលើរឿងក្តីស្តីពីការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (ប៊ូស្នៀ និងហឺហ្សេហ្គោវីណា ទល់នឹង ស៊ែរប៊ី និងម៉ុងតេណេហ្ក្រូ) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[1754] សាលក្រម *Akayesu* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥១១ យោងដល់របាយការណ៍វិភាគនៃសម័យប្រជុំលើកទី ៦ របស់គណៈកម្មាធិការនៃមហាសន្និបាត ពីថ្ងៃទី ២១ ខែ កញ្ញា ដល់ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ១៩៤៨។

១៨២៣. ពុំមាននិយមន័យជាក់លាក់សម្រាប់ក្រុមទាំងបួនដែលទទួលបានការការពារ ទាំងក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ទាំងក្នុងកិច្ចការត្រៀមរៀបចំអនុសញ្ញា។

១៨២៤. សាលក្រម *Akayesu* គឺជាយុត្តិសាស្ត្រដំបូងគេ ដែលនៅក្នុងនោះ ក្រុមទាំងបួននេះ ត្រូវបានកំណត់និយមន័យដូច្នេះថា៖

> "ក្រុមជាតិ គឺសំដៅលើក្រុមមនុស្សដែលត្រូវបានចាត់ទុកថាមានទំនាក់ទំនងគតិយុត្តរួមគ្នា ផ្អែកលើភាពជាពលរដ្ឋដូចគ្នា ហើយភាពជាពលរដ្ឋនេះ បន្ថែមទៅលើភាពទៅវិញទៅមកនៃសិទ្ធ និង ករណីយកិច្ច។
>
> ក្រុមជាតិពន្ធុ សំដៅជាទូទៅលើក្រុម ដែលសមាជិកមានភាសា ឬ វប្បធម៌រួមគ្នា។
>
> និយមន័យបុរាណនៃក្រុមពូជសាសន៍ គឺផ្អែកលើលក្ខណៈរាងកាយតពូជមក ដែលជារឿយៗត្រូវកំណត់បានក្នុងតំបន់ភូមិសាស្ត្រណាមួយ ដោយមិនគិតដល់ពីកត្តាភាសា វប្បធម៌ ជាតិ ឬ សាសនា ឡើយ។
>
> ក្រុមសាសនា គឺជាក្រុមដែលសមាជិកចែករំលែករួមគ្នានូវសាសនា ជំនឿ ឬ ការប្រតិបត្តិជំនឿសាសនា"[1755]
> ។

១៨២៥. ក្រោយពីមានយុត្តិសាស្ត្រនេះ សំណួរចោទឡើងចង់ដឹងថាតើសញ្ញាណក្រុមនេះ អាចត្រូវយល់បានតាមរបៀបសត្យានុម័តិ មានន័យថាត្រូវបំពេញបាននូវលក្ខណៈវិនិច្ឆ័យសត្យានុម័តិ ដែរឬអត់ ឬមួយក៏ត្រូវយល់តាមរបៀបអត្តនោម័តិ មានន័យថា គឺអាស្រ័យទៅតាមទស្សនៈរបស់អ្នកប្រព្រឹត្ត។ នៅក្នុងសាលក្រម *Akayesu* គឺអនុម័តយកវិធីសាស្ត្របែបសត្យានុម័តិ ខណៈដែលក្នុងសាលក្រម *Jelisić* គឺជ្រើសរើសយកវិធីសាស្ត្រអត្តនោម័តិ[1756]។ ដូចដែលតុលាការយុត្តិធម៌បានកត់សម្គាល់ យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា ទាក់ទងនឹងចំណុចនេះ គឺមានភាពប្រែប្រួល[1757]។

---

[1755] សាលក្រម *Akayesu* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥១២ ដល់កថាខណ្ឌ ៥១៥។

[1756] សាលក្រម *Akayesu* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥១១, សាលក្រម *Jelisić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧០។

[1757] កថាខណ្ឌ ១៩១ នៃសាលដីកាលើរឿងក្តីស្តីពីការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (ប៊ូស្នៀ និងហឺហ្សេហ្គោវីណា ទល់នឹង ស៊ែរប៊ី និងម៉ុងតេណេហ្គ្រូ) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

១៨២៦. នៅក្នុងសាលក្រម *Akayesu* វិធីសាស្ត្ររបស់ចៅក្រម គឺមានភាពពាក់ព័ន្ធជាពិសេស ព្រោះថា ចៅក្រមផ្អែកលើមូលដ្ឋាននៃការវិភាគការងារត្រៀមរៀបចំអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ។ ក្នុងអនុសញ្ញា បញ្ជាក់ថាការងារត្រៀមរៀបចំអនុសញ្ញា "យល់បានថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អាចកំណត់គោលដៅបានតែលើក្រុមមានស្ថិរភាពដែលបង្កើតឡើងជារបៀបអចិន្ត្រៃយ៍ ហើយដែលគេស្ថិតនៅក្នុងនោះ តាមការចាប់កំណើត ផ្ទុយពីក្រុមចល័ត ដែលគេចូលជាសមាជិកតាមរយៈការស្ម័គ្រចិត្ត និងជាលក្ខណៈបុគ្គល ដូចក្រុមនយោបាយ និងសេដ្ឋកិច្ច"[1758]។ ផ្ទុយទៅវិញ ទទ្បីករណ៍របស់ចៅក្រម នៅក្នុងសាលក្រម *Jelisić* គឺពុំបានធ្វើការយោងណាមួយទៅលើចេតនារបស់អ្នកតាក់តែងអនុសញ្ញា ដើម្បីរក្សាទុកសញ្ញាណអត្តនោម័តិឡើយ[1759]។ ប្រភពយោងទៅលើឯកសារមុនៗ គឺមានតែសាលក្រម *Kayishema* ដែលនៅក្នុងនោះ គ្មានឯកសារយោងសូម្បីតែមួយក៏គ្មាន[1760] និងសេចក្តីសម្រេចក្នុងរឿងក្តី *Nikolić* ដែលនិយាយពីភាពពាក់ព័ន្ធនៃទស្សនៈយល់ឃើញរបស់អ្នកតាក់តែង ចំពោះវិធានការរើសអើងនៃអំពើធ្វើទុក្ខបុកម្នេញ ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងពុំមែនជាបទប្រល័យពូជសាសន៍[1761]។

១៨២៧. ការវិភាគផ្លូវច្បាប់ដែលត្រូវបានជ្រើសរើសយកក្នុងរឿងក្តី *Akayesu* បង្ហាញឱ្យឃើញកាន់តែច្បាស់ពីស្មារតីនៃអនុសញ្ញា ឆ្នាំ ១៩៤៨ ដែលត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មទាំងឡាយប្រព្រឹត្តដោយរបបណាហ្ស៊ី ដែលបានកំណត់គោលដៅលើក្រុមជាក់លាក់ ផ្អែកលើលក្ខណៈវិនិច្ឆ័យសត្យានុម័តិ (ជាពិសេស ជនជាតិស្វីហ្វ និងជនជាតិហ្ស៊ីហ្កាន)។ ការអនុវត្តដែលត្រូវបកស្រាយអនុសញ្ញា ផ្អែកលើឧត្តមគតិនៃការងារត្រៀមរៀបចំអនុសញ្ញាបែបនេះ គឺជាវិធីសាស្ត្រដែល

---

[1758] សាលក្រម *Akayesu* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥១១។

[1759] សាលក្រម *Jelisić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧០។

[1760] សាលក្រម *Kayishema និង Ruzindana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៩៨។

[1761] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Dragan Nikolić លេខ IT-94-2-R61 *ការពិនិត្យមើលឡើងវិញនូវការបញ្ជូនរឿងទៅជំនុំជម្រះ យោងតាមវិធាន ៦១ នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាង* ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៥ កថាខណ្ឌ ២៧។

ត្រឹមត្រូវជាងគេ និងគោរពបាននូវគោលការណ៍នីត្យានុកូលភាព។ ហេតុដូច្នេះ អង្គជំនុំជម្រះត្រូវតែជ្រើសយកវិធីសាស្ត្រមួយនេះមកអនុវត្តដូចគ្នា។

១៨២៨. បញ្ហាមួយទៀតទាក់ទងនឹងនិយមន័យក្រុម ត្រូវបានចោទឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ពោលគឺថាតើត្រូវជ្រើសរើសយកនិយមន័យក្រុម ក្នុងន័យស្រប (définitition positive) ឬ ក្នុងន័យមិនស្រប (définitition négative)។ ក្នុងរឿងក្តី *Stakić* អង្គជំនុំជម្រះបានច្រានចោលនិយមន័យក្រុម ក្នុងន័យមិនស្រប ដែលបានកំណត់ថា "មិនមែនជាជនជាតិស៊ែប" ហើយដែលនិយមន័យនេះត្រូវបានជ្រើសរើសយកនៅក្នុងរឿងក្តី *Jelisić*[1762]។ ដូចគ្នានេះដែរ តុលាការយុត្តិធម៌អន្តរជាតិបានពន្យល់ថា "អ្វីដែលសំខាន់ គឺថាអ្នកទាំងអស់នោះគឺជា[ជនជាតិអ្វី] ពុំមែនថាតើពួកគេមិនមែនជា [ជនជាតិនោះ] នោះទេ[1763]។ ក្រោយពីបានវិភាគលើប្រភពឯកសារយោងផ្សេងៗ ក្នុងនោះមានដូចជា សាលក្រមរបស់តុលាការយោធាអន្តរជាតិ កិច្ចការត្រៀមរៀបចំអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ការផ្តល់គំនិតពិគ្រោះយោបល់របស់ក្រុមការងារត្រៀមរៀបចំអនុញ្ញា លើករណីលើកលែងចំពោះអនុសញ្ញាស្តីពីការបង្ការ និងបង្ក្រាបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ ១៩៥១ ព្រមទាំងរឿងក្តី *Stakić* រួចមក តុលាការយុត្តិធម៌អន្តរជាតិបានសន្និដ្ឋានថា ក្រុមត្រូវតែកំណត់និយមន័យ តាមរបៀបស្រប[1764]។

### iv. <u>ការទាញសេចក្តីសន្និដ្ឋានពីចេតនា</u>

១៨២៩. សំណួរដែលចង់ដឹងថាតើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីបង្ហាញឱ្យឃើញពីចេតនាបំផ្លាញទាំងស្រុង ឬ មួយផ្នែក នូវក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា គឺត្រូវបានបកស្រាយដោយយុត្តិសាស្ត្រ

[1762] សាលក្រម *Stakić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ៥១២។

[1763] កថាខណ្ឌ ១៩១ នៃសាលដីកាលើរឿងក្តីស្តីពីការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (ប៊ូស្នៀ និងហឺហ្សេហ្គោវីណា ទល់នឹង ស៊ែរប៊ី និងម៉ុងតេណេហ្គ្រូ) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[1764] កថាខណ្ឌ ១៩៣ ដល់កថាខណ្ឌ ១៩៦ នៃសាលដីកាលើរឿងក្តីស្តីពីការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (ប៊ូស្នៀ និងហឺហ្សេហ្គោវីណា ទល់នឹង ស៊ែរប៊ី និងម៉ុងតេណេហ្គ្រូ) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

របស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា។ ក្នុងសាលក្រម *Akayesu* អង្គជំនុំជម្រះសាលាដំបូងបាន ផ្តល់វិធីសាស្ត្រធ្វើសេចក្តីសន្និដ្ឋានដូចខាងក្រោម៖

> "អង្គជំនុំជម្រះយល់ឃើញថា គេអាចបង្ហាញឱ្យឃើញពីចេតនាប្រល័យពូជសាសន៍ដែលកើតមាននៅពេល ប្រព្រឹត្តអំពើជាក់លាក់ណាមួយដែលរងការចោទប្រកាន់ ចេញពីសកម្មភាព ឬ សម្តីទាំងអស់របស់ជនជាប់ចោទ ឬចេញពីបរិបទទូទៅនៃការប្រព្រឹត្តអំពើល្មើសផ្សេងទៀត ដែលត្រូវបានបង្កឡើងជាប្រព័ន្ធប្រឆាំងនឹង ក្រុមតែមួយ ទោះជាអំពើផ្សេងទៀតទាំងនោះ ត្រូវបានធ្វើឡើងដោយភ្នាក់ងារតែមួយ ឬមួយក៏ដោយភ្នាក់ងារ ដទៃទៀតក៏ដោយ។ កត្តាផ្សេងទៀត ដូចជា ទំហំនៃភាពសាហាវឃោរឃៅដែលបានបង្កឡើង ចរិតលក្ខណៈ ទូទៅរបស់វា ក្នុងតំបន់ ឬ ក្នុងប្រទេសណាមួយ ឬ ការជ្រើសរើសជនរងគ្រោះ ដោយចេតនា និងជាប្រព័ន្ធ ដោយសារពួកគេជាសមាជិកក្រុមណាមួយជាក់លាក់ ដោយដកចេញនូវសមាជិកក្រុមផ្សេងៗទៀត ក៏អាច អនុញ្ញាតឱ្យអង្គជំនុំជម្រះសន្និដ្ឋានបានពីចេតនាប្រល័យពូជសាសន៍ បានដូចគ្នា"[1765]។

១៨៣០. ម្យ៉ាងវិញទៀត សំណួរបានចោទឡើងនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ ដោយចង់ដឹងថាតើ ចេតនាជាក់លាក់ដែលមានភស្តុតាងបញ្ជាក់តាមរយៈអត្ថិភាពនៃសកម្មភាពជាប្រព័ន្ធមួយចំនួន ធ្វើ ឡើងប្រឆាំងនឹងក្រុមទទួលបានការការពារ លើទឹកដីមួយ អាចស្ថិតក្នុងប្រភេទសកម្មភាពជាប្រព័ន្ធ ដូចគ្នា លើទឹកដីមួយផ្សេងទៀតដែរឬទេ។ គេអាចនិយាយបែបម្យ៉ាងទៀតថា ក្នុងអំឡុងពេលសិក្សា លើភស្តុតាងទាក់ទងនឹងការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ក្រៅប្រទេសបូស្នី-ហេហ្សេហ្គោ វីន តុលាការយុត្តិធម៌អន្តរជាតិ "សួរថាតើចេតនាជាក់លាក់ (*dolus specialis*) អាចត្រូវបានទាញ បង្ហាញចេញឱ្យឃើញពីក្នុងគំនូសសកម្មភាពទាំងឡាយដែលត្រូវបានធ្វើប្រឆាំងនឹងអ្នកកាន់សាសនា អ៊ីស្លាមទាំងអស់គ្នានៅប្រទេសបូស្នី ដូចអ្វីដែលដើមចោទក៏ បានអះអាងដែរឬអត់"[1766]។

១៨៣១. យោងតាមយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែល បានសន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អាចបំពេញបានតែសម្រាប់ព្រឹត្តិការណ៍កើតឡើង នៅ Srebrenica តុលាការយុត្តិធម៌អន្តរជាតិ គឺពុំជឿថាមានការប្រព្រឹត្តអំពើប្រល័យពូជសាសន៍

---

[1765] សាលក្រម *Akayesu* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥២៣។

[1766] កថាខណ្ឌ ៣៦៩ នៃសាលដីកាលើរឿងក្តីស្តីពីការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជ សាសន៍ (ប៊ូស្នៀ និងហឺហ្សេហ្គោវីណា ទល់នឹង ស៊ែប៊ី និងម៉ុងតេណេក្រូ) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់តុលាការ ព្រហ្មទណ្ឌអន្តរជាតិ។

នៅតាមកន្លែងផ្សេងៗទៀត ក្នុងប្រទេសបូស្នី-ហេហ្សេហ្គោវីន ដោយសារពុំមានភ័ស្តុតាងបង្ហាញឱ្យឃើញពីចេតនាប្រល័យពូជសាសន៍[1767]។ តុលាការយុត្តិធម៌អន្តរជាតិបានគូសបញ្ជាក់ថា ចេតនានេះគួរត្រូវបានបង្ហាញឱ្យឃើញ "ដោយភ្ជាប់ជាមួយឧប្បត្តិហេតុជាក់លាក់នីមួយៗ"[1768]។

១៨៣២. ដូច្នេះ តុលាការយុត្តិធម៌អន្តរជាតិ បានឆ្លើយតបទៅនឹងសំណួរចោទឡើង ដោយតុលាការបានច្រានចោលទឡ្ហីករណ៍របស់ដើមចោទក៍ ដែលលើកឡើងថាគំនូសនៃភាពសាហាវឃោរឃៅដែលត្រូវបានប្រព្រឹត្តក្នុងរយៈពេលយ៉ាងយូរ ប្រឆាំងនឹងសហគមន៍ជាច្រើន កំណត់គោលដៅលើអ្នកកាន់សាសនាអ៊ីស្លាម និងប្រជាជនក្រូអាត នៅក្នុងប្រទេសបូស្នី អាចបង្ហាញឱ្យឃើញពីចេតនាប្រល័យពូជសាសន៍[1769]។ បន្ទាប់មក តុលាការបន្ថែមថា៖

> "ចេតនាជាក់លាក់ក្នុងការបំផ្លាញក្រុមទាំងស្រុង ឬ មួយផ្នែក ត្រូវតែបង្ហាញឱ្យឃើញ ដោយយោងទៅលើកាលៈទេសៈច្បាស់លាស់មួយចំនួន លើកលែងតែអត្ថិភាពនៃផែនការទូទៅ ដៅឆ្ពោះទៅ គោលបំណងនេះ អាចត្រូវបានបង្ហាញឱ្យឃើញតាមរបៀបដែលគេអាចជឿជាក់បាន ប៉ុណ្ណោះ។ ដើម្បីឱ្យការប្រព្រឹត្តមួយអាចត្រូវបានចាត់ទុកថាជាភ័ស្តុតាងបង្ហាញឱ្យឃើញពីចេតនានេះ សេចក្តីសន្និដ្ឋានតែមួយគត់ដែលអាចយកបាន គឺការប្រព្រឹត្តនេះត្រូវបញ្ចេញឱ្យឃើញពីចេតនាជាក់លាក់មួយនេះ"[1770]។

---

[1767] កថាខណ្ឌ ២៤៥-២៧៧ កថាខណ្ឌ ៣៦៩ នៃសាលដីកាលើរឿងក្តីស្តីពីការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (បូស្នៀ និងហឺហ្សេហ្គោវីណា ទល់នឹង ស៊ែរប៊ី និងម៉ុងតេណេក្រូ) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[1768] កថាខណ្ឌ ៣៧០ នៃសាលដីកាលើរឿងក្តីស្តីពីការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (បូស្នៀ និងហឺហ្សេហ្គោវីណា ទល់នឹង ស៊ែរប៊ី និងម៉ុងតេណេក្រូ) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[1769] កថាខណ្ឌ ៣៧៣ នៃសាលដីកាលើរឿងក្តីស្តីពីការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (បូស្នៀ និងហឺហ្សេហ្គោវីណា ទល់នឹង ស៊ែរប៊ី និងម៉ុងតេណេក្រូ) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[1770] កថាខណ្ឌ ៣៧៣ នៃសាលដីកាលើរឿងក្តីស្តីពីការអនុវត្តអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (បូស្នៀ និងហឺហ្សេហ្គោវីណា ទល់នឹង ស៊ែរប៊ី និងម៉ុងតេណេក្រូ) ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

១៨៣៣. យោងតាមគន្លងដ៏មុឹងម៉ាត់របស់តុលាការយុត្តិធម៌អន្តរជាតិ គឺវាគួរឱ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ថា ក្នុងរឿងក្តី *Krstić* ដើម្បីសន្និដ្ឋានបានថាជាអំពើប្រល័យពូជសាសន៍នៅ Srebrenica អង្គជំនុំជម្រះបានផ្អែកតែលើភ័ស្តុតាងមួយចំនួន ទាក់ទងនឹងទឹកដី Srebrenica ដើម្បីសន្និដ្ឋានឱ្យឃើញពីចេតនាប្រល័យពូជសាសន៍[1771]។ សកម្មភាពទាំងឡាយធ្វើឡើងប្រឆាំងនឹងសាសនិកអ៊ី- ស្លាមមកពីប្រទេសបូស្នី នៅក្រៅដែនដីនេះ ពុំត្រូវបានបង្ហាញឡើយ។ ក្នុងរឿងក្តី *Krajišnik* អង្គ-ជំនុំជម្រះបានសិក្សាលើភ័ស្តុតាងទាក់ទងនឹងការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ នៅតាមទីតាំង ៣៥ កន្លែងផ្សេងទៀត ក្នុងប្រទេសបូស្នី-ហេហ្ស៊េហ្គោវីន តែអង្គជំនុំជម្រះពុំអាចបង្ហាញឱ្យឃើញពីចេតនាប្រល័យពូជសាសន៍បាន។ ក្នុងការពិនិត្យលើភ័ស្តុតាង អង្គជំនុំជម្រះបានបញ្ជាក់ថាខ្លួនបានផ្តោតសំខាន់លើ "សកម្មភាពផ្ទាល់ កាលៈទេសៈនានាដែលនៅជុំវិញ ជាពិសេស សម្តីរបស់អ្នកប្រព្រឹត្តឧក្រិដ្ឋកម្ម និងបុគ្គលផ្សេងទៀតនៅតាមទីកន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើង ព្រមទាំងរបាយការណ៍ផ្លូវការនានាទាក់ទងនឹងឧក្រិដ្ឋកម្ម"[1772]។

១៨៣៤. សរុបសេចក្តីមក អង្គជំនុំជម្រះត្រូវវិភាគដោយប្រុងប្រយ័ត្នខ្ពស់លើភ័ស្តុតាងទាំងឡាយដែលអាចប្រាប់ពីអត្ថិភាពនៃចេតនាប្រល័យពូជសាសន៍។ អនុលោមតាមសេចក្តីសម្រេចរបស់តុលាការយុត្តិ-ធម៌អន្តរជាតិ និងដោយគោរពតាមភាពហ្មត់ចត់របស់ចៅក្រមតុលាការឧក្រិដ្ឋកម្មសម្រាប់ប្រទេសយូហ្គោស្លាវី អង្គជំនុំជម្រះត្រូវវិភាគភ័ស្តុតាងទាំងអស់ ដោយភ្ជាប់ជាមួយតំបន់ភូមិសាស្ត្រដែលត្រូវបានកំណត់ជាគោលដៅ ដើម្បីបង្ហាញឱ្យឃើញពីចេតនាប្រល័យពូជសាសន៍។

## ២. ការកំណត់បទចោទប្រកាន់លើអង្គហេតុ

១៨៣៥. ដូចបានឃើញពីខាងលើ អង្គជំនុំជម្រះត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុដែលជាធាតុផ្សំនៃបទប្រល័យពូជសាសន៍ ដោយអំពើមនុស្សឃាត មកលើសមាជិកក្រុមជនជាតិចាម ចាប់ពីឆ្នាំ ១៩៧៧ នៅក្នុងស្រុកកងមាស (ភូមិភាគកណ្តាល) និងនៅក្នុងស្រុកក្រូចឆ្មារ (ភូមិភាគបូព៌ា) លើកលែងតែ

---

[1771] សាលក្រម *Krstić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥៩៤ ដល់កថាខណ្ឌ ៥៩៩។

[1772] សាលក្រម *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៨៦៩។

អង្គហេតុដែលបានកើតឡើងនៅមន្ទីរក្រូចឆ្មារ ដែលត្រូវបានអង្គជំនុំជម្រះដកចេញយ៉ាងច្បាស់នៅក្នុងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី[1773]។

១៨៣៦. ទោះជាក្រុមមេធាវីការពារក្តីមិនជំទាស់ថា មានភស្តុតាងមួយផ្នែក អាចឱ្យគេយល់បានថាជនជាតិចាមមួយចំនួនត្រូវបានសម្លាប់ក្នុងស្រុកដូចបានលើកឡើងក៏ដោយ ក៏ភស្តុតាងមិនអាចឱ្យគេសន្និដ្ឋានបានថាអំពើមនុស្សឃាតទាំងនេះ ត្រូវបានប្រព្រឹត្តឡើងក្នុងចេតនាបំផ្លាញក្រុមជនជាតិចាមទាំងស្រុង ឬ មួយផ្នែក បានឡើយ។

១៨៣៧. ដូចដែលបានឃើញតាមរយៈការបង្ហាញពីកាលៈទេសៈនៃអំពើមនុស្សឃាតដែលរងការចោទប្រកាន់ ភស្តុតាងទាំងឡាយមិនអាចឱ្យគេសន្និដ្ឋានបានហួសពីវិមតិសង្ស័យថាការបំផ្លាញទាំងស្រុង ឬ មួយផ្នែក នូវក្រុមជាតិពន្ធុ និង សាសនាចាម គឺជាដើមចមនៃការចាប់ខ្លួន និងការសម្លាប់ ដែលត្រូវបានចោទប្រកាន់ នោះឡើយ។

១៨៣៨. ផ្ទុយទៅវិញ ភស្តុតាងទាំងអស់ទាក់ទងនឹងអង្គហេតុក្នុងស្រុកទាំងពីរដែលបានរៀបរាប់ខាងដើម គឺចង់បង្ហាញឱ្យឃើញថា ការចាប់ខ្លួន និងការសម្លាប់ ដែលកើតមកពីទង្វើទាំងនោះ ពាក់ព័ន្ធនឹងសមាសភាគប្រជាជនខុសៗគ្នា ដោយគ្មានការបែងចែកដើមកំណើតពន្ធុ ឬ សាសនា អ្វីឡើយ។ ហេតុដូច្នេះ គេមិនអាចសន្និដ្ឋានបានថា នៅក្នុងស្រុកទាំងពីរនេះ អ្នកដែលមិនមែនជាជនជាតិចាមត្រូវបានលើកលែងជាពិសេស និងយ៉ាងច្បាស់ ពីការចាប់ និងសម្លាប់ បានឡើយ។ ការណ៍ដែលនៅក្នុងភូមិខ្លះ ប្រជាជនចាមមានចំនួនច្រើន ពុំបានធ្វើឱ្យនិន្នាការសក្ខីកម្មទូទៅ ប្រែប្រួលបានឡើយ។

១៨៣៩. ទោះជាអង្គជំនុំជម្រះត្រូវសន្និដ្ឋានថាមានការសម្លាប់ជនជាតិចាមនៅក្នុងស្រុកទាំងពីរក៏ដោយ ក៏អង្គជំនុំជម្រះពុំអាចសន្និដ្ឋានប្រកបដោយហេតុផលត្រឹមត្រូវបានថា ធាតុផ្សំអំពើប្រល័យពូជសាសន៍ត្រូវបានបំពេញ បានឡើយ។

[1773] សូមមើលខាងលើ កថាខណ្ឌ ១៥៤៣ ដល់កថាខណ្ឌ ១៥៤៦។

## ជំពូកទី ៤. ការចោទប្រកាន់ស្តីពីគោលនយោបាយពាក់ព័ន្ធនឹងវិធានការដាក់លាក់ប្រឆាំងនឹងជនជាតិចាម

១៨៤០. គោលនយោបាយបែបសន្ធរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះជនជាតិចាម គឺគ្រាន់តែជាការតាក់តែងឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលមិនស៊ីគ្នាបន្តិចណាសោះទៅនឹងតថភាពមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា។ ដូចបានលើកឡើងរួចមកហើយ នៅពេលពិនិត្យអង្គហេតុពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិចាម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចំណុចចាប់ផ្តើមនៃការស៊ើបសួរ គឺភាគច្រើនជាការងារវិភាគរបស់ អ៊ីសា ឧស្មាន នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលត្រូវបានគេបង្ហាញថា ខ្វះអព្យាក្រឹត្យភាពយ៉ាងសម្បើម[1774]។

១៨៤១. ការវិភាគភ័ស្តុតាងដោយសហចៅក្រមស៊ើបអង្កេត បន្ទាប់មក ដោយសហព្រះរាជអាជ្ញា ផ្តើមចេញពីអង្គហេតុដែលផ្តោតជាពិសេសលើភូមិភាគបូព៌ា និងភូមិភាគកណ្តាល ដើម្បីបង្ហាញថាមាន "គោលនយោបាយកម្ទេចជនជាតិចាម ក្នុងឋានៈជាក្រុមមួយ"[1775]។ ផ្ទុយទៅវិញ វិធីបែបបញ្ច្រាសស្រកីនេះ មិនអាចឈានទៅស្វែងរកដំណោះស្រាយភាពចម្រូងចម្រាស់នៃភ័ស្តុតាង ដែលនឹងមិនអាចនាំទៅដល់ការសន្និដ្ឋានថា ពិតជាមានគោលនយោបាយប្រឆាំងជនជាតិចាម ចេញមកពីបក្សកុម្មុយនីស្តកម្ពុជា ទោះផ្អែកលើឯកសារសម័យខ្មែរក្រហម (វគ្គទី ១) ឬលើសក្ខីកម្ម ក៏ដោយ (វគ្គទី ២)។

## ផ្នែកទី ១. នត្ថិភាពនៃគោលនយោបាយប្រឆាំងជនជាតិចាម ដោយផ្អែកលើឯកសារសម័យខ្មែរក្រហម

១៨៤២. ឯកសារដើមក្រមរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីពីជនជាតិចាម មិនស៊ីសង្វាក់គ្នាជាមួយនិក្ខេបបទស្តីពីគោលនយោបាយចំពោះជនជាតិចាមឡើយ បើទោះបីនិយាយពីសន្ទរកថាទូទៅស្តីពីកម្ពុជាប្រជាធិបតេយ្យ (១) ឬពីបរិបទវឹកវរនៃសន្តិសុខ ជាពិសេស នៅក្នុងការទាក់ទងគ្នារវាង កែ ពក និង មជ្ឈិម នៅក្នុងក្របខណ្ឌនៃជម្លោះប្រដាប់អាវុធ ក៏ដោយ។

---

[1774] សូមមើលខាងលើ កថាខណ្ឌ ១៥៨៨ ដល់កថាខណ្ឌ ១៦០៥។

[1775] ដីកាដំណោះស្រាយ កថាខណ្ឌ ២១២។

## ១. ឯកសារលើកឡើងពីជនជាតិចាម ថាជាសមាជិកសំខាន់មួយនៃរបបកម្ពុជាប្រជាធិបតេយ្យ

១៨៤៣. តាំងពីឆ្នាំ ១៩៧៥ ជនជាតិចាម ឬ ហៅថា "ខ្មែរអ៊ីស្លាម" នៅក្នុងរបបសម្តេច ស៊ីហានុ ត្រូវបានបង្ហាញថា ជាសមាជិកសំខាន់មួយនៃប្រជាជាតិកម្ពុជា ដែលត្រូវបានកោតសរសើរថាបានចូលរួមក្នុងចលនាបដិវត្ត[1776]។ នៅក្នុងល័ក្ខខ័ណ្ឌនេះ ដូចសមាសភាពប្រជាជនឯទៀតដែរ ជនជាតិចាមបានចូលរួមកសាងជាតិ នៅក្នុងក្របខណ្ឌនៃការរៀបចំសង្គមជាថ្មី។ អាស្រ័យហេតុនេះ មិនដែលមានឯកសារណាមួយស្តីពីការកេណ្ឌប្រជាជនដើម្បីកសាងជាតិ បានលើកឡើងពីការបែងចែកជាតិពន្ធុនោះទេ លើកលែងតែនិយាយពីវណ្ណៈ ស្របតាមទ្រឹស្តីម៉ាកនិយម[1777]។

១៨៤៤. ផ្ទុយពីអ្វីដែលបានអះអាងនៅក្នុងកថាខណ្ឌ ៧៥៣ និង ៧៥៤ នៃដីកាដំណោះស្រាយ គឺថាការផ្សព្វផ្សាយដែលនិយាយពីជនជាតិចាមជាសមាសភាពនៃប្រជាជាតិខ្មែរ មិនដែលឈប់នោះទេ។ ជាក់ស្តែង ទស្សនាវដ្តីទង់បដិវត្តន៍ ឆ្នាំ១៩៧៦ បានលើកឡើងពីប្រជាជាតិកម្ពុជាប្រជាធិបតេយ្យ "ដែលរួមមានសមាសភាពជនជាតិខ្មែរ និងជនជាតិដទៃទៀត នៅតាមមូលដ្ឋានផ្សេងៗ"[1778]។ នៅឆ្នាំ១៩៧៧ ឯកសារមួយរបស់កម្ពុជាប្រជាធិបតេយ្យ លើកឡើងពីប្រជាជនខ្មែរ និង "ជនជាតិភាគតិចក្នុងស្រុកជាច្រើនទៀត [ដែល] រស់នៅរួមគ្នា ក្នុងមហាគ្រួសារតែមួយ សាមគ្គីគ្នាស្អិតរមួតដើម្បីកសាង និងការពារជាតិ" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[1779]។

---

[1776] បងប្អូនខ្មែរអ៊ីស្លាមត្រូវបានធានានូវសេរីភាពក្នុងលទ្ធិប្រជាធិបតេយ្យ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៧៥ (FBIS) ឯកសារ **E3/272**, ERN EN 00167520។

[1777] ឧទាហរណ៍ សូមមើលឯកសារ "អំពីការក្តាប់ និងអនុវត្តមាគ៌ានយោបាយ ប្រមូលកម្លាំងរណសិរ្សប្រជាជាតិប្រជាធិបតេយ្យរបស់បក្ស" ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ ឯកសារ **E3/99**, ERN KH 00611569 "ពីមុន យើងប្រមូលកម្លាំងប្រជាជាតិប្រជាធិបតេយ្យ ដើម្បីវាយខ្មាំង រំដោះប្រទេស។ ឥឡូវ យើងប្រមូល ដើម្បីការពារប្រទេសឲ្យណែន និងកសាងប្រទេសឲ្យខ្លាំងក្លា" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1778] ទស្សនាវដ្តី "ទង់បដិវត្តន៍" លេខ ៤ ឆ្នាំ ១៩៧៦ ឯកសារ **E3/759**, ERN KH 00062749។

[1779] កម្ពុជាប្រជាធិបតេយ្យឈានទៅមុខ ឆ្នាំ ១៩៧៧ ឯកសារ **E3/1388**, ERN KH S 00679919។

១៨៤៥. ដូចគ្នានេះដែរ ជានិម្មិតរូប រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ផ្តោតសំខាន់លើ "ភាពសុខដុម" និង "មហាសាមគ្គីជាតិ" ដើម្បីការពារប្រទេស[1780]។ ចំណុចនេះទៀតសោត មិនបាននិយាយពីការចាត់ទុកជនជាតិចាមថាជាខ្មាំងឡើយ។ ម្យ៉ាងវិញទៀត នៅកថាខណ្ឌ ១១៩២ នៃ ដីកាដំណោះស្រាយ ពាក្យពេជន៍ក្រឡៃស្តីពីរដ្ឋធម្មនុញ្ញនេះ ត្រូវបានគេចោទថាជាសំដីរបស់ ខៀវ សំផន ដោយហេតុថា នៅក្នុងរដ្ឋធម្មនុញ្ញនោះ មានលើកឡើងពី "[ចេតនារបស់បក្សកុម្មុយនីស្តកម្ពុជា] ក្នុងការលុបបំបាត់គ្រប់ជនជាតិភាគតិចទាំងអស់"។ ក៏ប៉ុន្តែ ដោយគ្មានសន្ទរកថាដើមជាភាសាខ្មែរ របាយការណ៍របស់សេវាព័ត៌មានផ្សព្វផ្សាយនៅបរទេស (FBIS) គឺជាឯកសារបានការតែមួយគត់ ហើយឯកសារនេះមិនបានលើកឡើងពីការលុបបំបាត់ជនជាតិភាគតិចទាល់តែសោះ[1781]។

## ២. <u>ការទាក់ទងគ្នារវាង កែ ពក និង មជ្ឈិម</u>

### ក. <u>សារទូរលេខ ខែ មេសា ឆ្នាំ ១៩៧៦ ផ្ញើទៅ ប៉ុល ពត</u>

១៨៤៦. សារទូរលេខរបស់ កែ ពក ផ្ញើទៅ ប៉ុល ពត នាខែ មេសា ឆ្នាំ ១៩៧៦ និងខ្លឹមសារដែលត្រូវបានក្រឡៃដោយ អ៊ីសា ឧស្មាន យើងបានលើកយកមកបង្ហាញរួចហើយ[1782]។ ផ្ទុយពីការអះអាងរបស់ អ៊ីសា ឧស្មាន សារទូរលេខនេះ មិនមែនជាភ័ស្តុតាងបង្ហាញថា ខ្មែរក្រហមបានអំពាវនាវឱ្យកម្ទេច "ពូជសាសន៍ចាមទាំងមូល"[1783] នោះទេ។ សារទូរលេខនោះ គ្រាន់តែបរិយាយពី "ភាពវឹកវរ" នៅក្នុងស្រុកចម្ការលើ និងពីអង្គហេតុដែលថា ក្រុមមួយដែលមានសមាជិកជា "ទាហានចាស់ រួមផ្សំជាមួយពួកចាម និងពួកអាអតីតប្រធានក្រុមសហករណ៍" បានធ្វើសកម្មភាពប្រឆាំង។ ពួកគេ

---

[1780] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ ឯកសារ **E3/259**, ERN KH 00089844។

[1781] របាយការណ៍របស់ ខៀវ សំផន ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ (FBIS) ឯកសារ **E3/273**, ERN EN 00167810៖ "ក្រៅពីនេះទៀត ដូចបានបញ្ជាក់នៅក្នុងរដ្ឋធម្មនុញ្ញយើង <u>គោលជំហរយើង</u> គឺ<u>មិនអនុញ្ញាត</u>ឱ្យចក្រពត្តិបរទេសប្រើប្រាស់សាសនាដើម្បីធ្វើវិទ្ធង្សនាជាដាច់ខាត។ យើងប្តេជ្ញាវាយប្រយុទ្ធតទល់ពួកវា ទោះបីជាពួកវាប្រើឧបាយកលយ៉ាងណាក៏ដោយ។ ចក្រពត្តិបន្តស្វែងរកមធ្យោបាយវាយយើង ជាពិសេស ពួកវាប្រើប្រាស់សាសនា ដើម្បីជ្រៀតចូលប្រទេសយើង" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ផ្នែកនេះមិននិយាយសំដៅដល់ចលនាសាសនានៅក្នុងប្រទេសនោះទេ។

[1782] ទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ ឯកសារ **E3/511**, ERN KH 00000766។

[1783] សៀវភៅរបស់ អ៊ីសា ឧស្មាន *ការបះបោររបស់ជនជាតិចាម* ឆ្នាំ ២០០៦ ឯកសារ **E3/2653** ទំព័រ ១១៥ ERN EN 00219176។

ទំនងជាបានបង្ហាញរូបថត និងសេចក្តីថ្លែងការណ៍មួយរបស់ លន់ នល់ និងបានដុតបំផ្លាញព្រៃ និងចម្ការដំណាំ។ សកម្មភាពនេះបណ្តាលឱ្យមានការចាប់ខ្លួន "អតីតប្រធានក្រុមសហករណ៍"។ សារទូរលេខនោះ មិនបាននិយាយពីជនជាតិចាមដាច់ដោយឡែកទេ ក៏ប៉ុន្តែ បានលើកឡើងពីសកម្មភាពរបស់ក្រុមប្រឆាំងមួយ។

## ខ. ការទាក់ទងគ្នាផ្សេងទៀត

១៨៤៧. នៅកថាខណ្ឌ ៧៦៤ នៃដីកាដំណោះស្រាយ កំណើនយ៉ាងគំហុកនៃរបាយការណ៍ស្តីពីការទាក់ទងគ្នារវាង កែ ពក និងមជ្ឈិម នៅអំឡុងឆ្នាំ ១៩៧៨ ត្រូវបានយកមកប្រើប្រាស់ ដោយសហចៅក្រមស៊ើបអង្កេត ដើម្បីសំអាងថា រលកនៃការកាប់សម្លាប់ជនជាតិចាម ដែលបានចោទប្រកាន់ នៅក្នុងភូមិភាគកណ្តាល និងភូមិភាគបូព៌ា នៅឆ្នាំ ១៩៧៧ និង ១៩៧៨ ទំងនងជាត្រូវបានរៀបចំដោយមជ្ឈិម។

១៨៤៨. ក៏ប៉ុន្តែ ម្យ៉ាង នៅដើមឆ្នាំ ១៩៧៧ មានការបោសសម្អាតភូមិភាគកណ្តាល បន្ទាប់ពីការចាប់ខ្លួន កុយធួន។ ម្យ៉ាងវិញទៀត ឆ្នាំ ១៩៧៨ ជាឆ្នាំនៃការកើនឡើងខ្លាំងក្លានៃជម្លោះប្រដាប់អាវុធ។ បាន សៀក បានអះអាងថា កែ ពក ជាលេខាភូមិភាគកណ្តាល និងទទួលបន្ទុកយោធាភូមិភាគបូព៌ា ជាមួយ សុន សេន[1784]។ ចំណុចនេះត្រូវបានបញ្ជាក់អះអាងដោយសាក្សីមួយចំនួន ស្តីពីជម្លោះប្រដាប់អាវុធ។ ដូច្នេះ វាជារឿងធម្មតាទេដែលថាការទាក់ទងគ្នាជាមួយថ្នាក់លើពាក់ព័ន្ធនឹងស្ថានការណ៍នៃការប្រយុទ្ធ កាន់តែកើនឡើងសន្ធឹកសន្ធាប់ ជាពិសេស នៅចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[1785]។

១៨៤៩. មជ្ឈិមមិនអាចគ្រប់គ្រងស្ថានការណ៍ប្រយុទ្ធបាន និងពិតជាមិនអាចក្តាប់បានពីអ្វីដែលកំពុងកើតឡើងនៅសមរភូមិផ្ទាល់។ សក្ខីកម្មរបស់ មាស វឿន អំពីការណ៍ដែល ប៉ុល ពត ប្រគល់ឱ្យគាត់បំពេញបេសកម្មស៊ើបអង្កេតពីស្ថានការណ៍ជាក់ស្តែងនៅក្នុងតំបន់ព្រះវិហារ នៅចុងឆ្នាំ ១៩៧៨ គឺ

---

[1784] បាន សៀក៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ឯកសារ E1/353.1 ទំព័រ ៦៥ ក្រោយម៉ោង 15.08.46។

[1785] សូមមើលខាងលើ កថាខណ្ឌ ៧៥០។

ជាឧទាហរណ៍ជាក់ស្តែងមួយពីបញ្ហានេះ[1786]។ សក្ខីកម្មរបស់ កែ ពេជ្រវណ្ណៈ អំពីការស៊ើបអង្កេត ដែលឪពុកគេត្រូវធ្វើ គឺជាឧទាហរណ៍ល្អមួយទៀត[1787]។

## ផ្នែកទី ២. ឧត្តិភាពនៃគោលនយោបាយ ផ្តែកលើសក្ខីកម្ម

១៨៥០. វាមិនមែនជារឿងស្រាលទេ នៅពេលសាក្សីចាមម្នាក់ ដែលមិនសូវចង់មកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ បានផ្តល់សក្ខីកម្មតែមួយគត់អំពីអត្ថិភាពនៃឯកសារមួយ ដែលឯកសារនេះទំនងជាលើកឡើងពីគោលនយោបាយសម្លាប់រង្គាលជនជាតិចាម តាមការសន្មត។ សក្ខីកម្មដាច់ដោយឡែកតែឯង និងមិនទំនងជាច្រើន របស់គាត់ (១) ផ្ទុយគ្នាពីសក្ខីកម្មយ៉ាងច្រើនសន្ធឹកសន្ធាប់ស្តីពីអត្ថិភាពបែបសន្មតនៃគោលនយោបាយប្រឆាំងជនជាតិចាម ក្នុងកម្រិតបក្សកុម្មុយនីស្តកម្ពុជា (២)។

### ១. ភាពមិនទំនង និងភាពផ្ទុយគ្នា នៃសក្ខីកម្មរបស់ សុះ កំរី

១៨៥១. សក្ខីកម្មរបស់ សុះ កំរី នៅចំពោះមុខអង្គជំនុំជម្រះ ចោទបញ្ហាជាច្រើន។ ពីដំបូង អង្គជំនុំជម្រះ ក៏ដូចជាភាគីដែរ បានត្រឹមតែអាចសង្កេតឃើញថា សាក្សីមិនបានសហការល្អ ដោយអង្គជំនុំជម្រះមានការលំបាកក្នុងការកោះហៅគាត់មកចំពោះមុខខ្លួន។ ដោយមិនត្រឹមតែមិនព្រមចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ដោយអះអាងថាមានបញ្ហាសុខភាព[1788] សុះ កំរី ដែលបច្ចុប្បន្នជាមេសាសនា ថែមទាំងបានបដិសេធមិនព្រមធ្វើសម្បថ ដោយមូលហេតុមិនច្បាស់លាស់ពាក់ព័ន្ធនឹងសាសនា ដែលគាត់មិនអាចអាចផ្តល់សំអាងហេតុស្របតាមគម្ពីរកូរ៉ង់[1789]។ ការពិនិត្យមើលដោយ

---

[1786] មាស រឿន៖ ប្រតិចារឹក ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ឯកសារ **E1/130.1** ទំព័រ ៥៦ ក្រោយម៉ោង 14.08.43។

[1787] កំណត់ហេតុស្តាប់ចម្លើយ កែ ពេជ្រវណ្ណៈ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៩ ឯកសារ **E3/35**, ERN KH 00340569-00340569។ សូមមើលខាងលើ កថាខណ្ឌ ១៧១១ ដល់កថាខណ្ឌ ១៧១២។

[1788] សុះ កំរី៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ **E1/415.1** ទំព័រ ៤៥ មុនម៉ោង 11.31.41 ទំព័រ ៤៩ ក្រោយម៉ោង 13.40.18។ សូមមើលផងដែរនូវអ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ ដែលមានចំណងជើងថា "សាក្សី 2-TCW-827 និងកាលវិភាគ" ផ្ញើនៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ វេលាម៉ោង ២ និង ៤៣ នាទី រសៀល។

[1789] សុះ កំរី៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ **E1/415.1** ទំព័រ ១២ ក្រោយម៉ោង 09.35.00។

ត្រួសៗទៅលើចំណុចសំខាន់ៗនៃសក្ខីកម្មរបស់គាត់ មិនអាចឱ្យគេចាត់ទុកបានថាអាចជឿជាក់បាននោះទេ។

### ក. ជីវភាពរស់នៅរបស់ជនជាតិចាមនៅចម្ការលើ

១៨៥២. មានស្រុកកំណើតនៅភូមិស្គី ស្រុកចម្ការលើ ខេត្តកំពង់ចាម សុះ កំរី បានកែតម្រូវកំហុសទាំងឡាយនៅក្នុងបទសម្ភាសន៍របស់គាត់ជាមួយ អ៊ីសា ឧស្មាន ស្ដីពីប្រធានបទនេះ។ គាត់បានគូសបញ្ជាក់ជាពិសេសថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មិនត្រូវបានជម្លៀសចេញទៅណាទេ តែបានស្នើសុំប្ដូរទៅភូមិជយោរិញ[1790] ហើយគាត់បានប្ដូរឈ្មោះ មិនមែនដោយសារការភ័យខ្លាចទេ តែបានប្ដូរមុនពេលនោះទៅទៀត នៅពេលគាត់បាន "ចាប់ផ្ដើមបង្រៀន"[1791]។

១៨៥៣. សុះ កំរី បានថ្លែងថា ជនជាតិចាមរស់នៅភូមិស្គី ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ដែលនៅទីនោះ គាត់បានជួបជុំគ្រួសារគាត់វិញ បន្ទាប់ពីបានត្រឡប់មកពីភូមិជយោរិញ នៅឆ្នាំ ១៩៧៨[1792]។ គាត់បានយល់ស្របតាមអ្វីដែលសាក្សីទាំងអស់បាននិយាយពីបម្រាមប្រតិបត្តិសាសនា និងបម្រាមប្រើប្រាស់សម្លៀកបំពាក់ប្រពៃណី តែបានបញ្ជាក់ថាបានទទួលការអនុញ្ញាត្តិឱ្យបន្តបង្រៀន "អក្សរសាស្ត្រខ្មែរ"[1793] តទៅទៀត។ គាត់បានបញ្ជាក់ដែរថា នៅពេលមានសាច់ជ្រូក ក្នុងពេលស្រស់ស្រូបអាហាររួម ប្រជាជនហូបអ្វីដែលមាន[1794]។

១៨៥៤. សុះ កំរី បានថ្លែងផងដែរថា ប្រធានភូមិទាំងអស់សុទ្ធតែជាជនជាតិចាមដដែល។ បើទោះបីជាមានប្រធានភូមិជាជនជាតិចាមខ្លះត្រូវបានសម្លាប់ តែ *"មនុស្សចំណូលថ្មីជាជនជាតិចាម"* ដែរ[1795]។

---

[1790] <u>សុះ កំរី</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ **E1/415.1** ទំព័រ ៧៤ ក្រោយម៉ោង 15.23.17។

[1791] <u>សុះ កំរី</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ **E1/415.1** ទំព័រ ៧៦ ក្រោយម៉ោង 15.29.44។

[1792] <u>សុះ កំរី</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ **E1/415.1** ទំព័រ ៧៧ 15.31.59។

[1793] <u>សុះ កំរី</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ **E1/415.1** ទំព័រ ៨ ក្រោយម៉ោង 09.22.34 ទំព័រ ៩ មុនម៉ោង 09.25.44 ទំព័រ ៦៩ ប្រហែលម៉ោង 15.03.29 អំពីសាសនា និងប្រពៃណី ទំព័រ ២៨ ក្រោយម៉ោង 10.40.02 ទំព័រ ៣៨-៣៩ ក្រោយម៉ោង 11.09.47 ទំព័រ ៤៣ មុនម៉ោង 11.26.09 អំពីការបង្រៀននៅក្នុងភូមិរបស់គាត់។

[1794] <u>សុះ កំរី</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ **E1/415.1** ទំព័រ ៣៨ មុនម៉ោង 11.09.47។

[1795] <u>សុះ កំរី</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ **E1/415.1** ទំព័រ ៦៧ ប្រហែលម៉ោង 14.39.58។

១៨៥៥. បាន សៀក ដែលត្រូវបានបញ្ជូនទៅធ្វើការនៅចម្ការលើមួយរយៈ បានថ្លែងថា រូបគាត់មិនបានដឹងពីទីកន្លែងរស់នៅពិតប្រាកដរបស់ជនជាតិចាម នៅក្នុងស្រុកទេ ដោយគាត់បានបញ្ជាក់ថា នៅការដ្ឋានដែលគាត់ធ្វើការ "គេមិនបានប្រាប់ [គាត់] ថា នរណាជាចាម ចិន ឬ ខ្មែរ ទេ" ដោយពួកគេគិតតែពួតដៃគ្នាធ្វើការ[1796]។ គាត់បានអះអាងពីការហាមប្រាមប្រតិបត្តិសាសនា ទាំងជនជាតិចាម ក៏ដូចជាពុទ្ធសាសនិកដែរ[1797]។

## ខ. ការប្រជុំថ្នាក់ភូមិ នៅបុសខ្នុរ

១៨៥៦. សុះ កំរ៉ឺ បានថ្លែងថា នៅឆ្នាំ ១៩៧៧ នៅពេលគាត់រស់នៅភូមិជយោ គាត់បានចូលរួមប្រជុំថ្នាក់ភូមិមួយ នៅបុសខ្នុរ ដែលនៅក្នុងកិច្ចប្រជុំនោះ គេបានកំណត់ "ខ្មាំងជាច្រើនប្រភេទ" រួមមាន "ជនប្រតិកិរិយា មេសាសនា អតីតរដ្ឋការសម័យមុន និងជនជាតិចាម" ដោយលោកបានបញ្ជាក់នៅពេលក្រោយបន្តិចមកថា "មនុស្សទាំងអស់នោះមិនមែនសំដៅដោយជាក់លាក់ ទៅលើជនជាតិចាមទេ តែទៅលើពួកសាវគ្គសាសនា"[1798]។

១៨៥៧. នៅពេលសួរដេញដោយដោយសហព្រះរាជអាជ្ញាពីសៀវភៅរបស់ អ៊ីសា ឧស្មាន សាក្សី សុះ កំរ៉ឺ បានផ្លាស់ប្តូរសាច់រឿងរបស់គាត់ ដោយថ្លែងនៅចុងបញ្ចប់ថា "គឺនៅក្រោយពេលប្រជុំឯណោះទេ ដែលមានការលើកឡើងពីជនជាតិចាម"។ ទន្ទឹមនឹងនេះ គាត់ថែមទាំងមិនអាចនិយាយប្រាប់បានថា នរណាជាអ្នកនិយាយពាក្យពេជន៍ទាំងអស់នោះ សូម្បីតែអ្នកនិយាយនោះជាមនុស្សប្រុស ឬស្រី ដោយគាត់ថ្លែងថា៖ "ខ្ញុំមិនស្គាល់ជននេះទេ"[1799]។ម្យ៉ាងទៀត គាត់បានបញ្ជាក់ថា គាត់មិនធ្លាប់បានស្គាល់នរណាម្នាក់នៅថ្នាក់ស្រុក ឬភូមិភាគទេ[1800]។

---

[1796] បាន សៀក៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ឯកសារ **E1/353.1** ទំព័រ ៣១ មុនម៉ោង 10.52.57។

[1797] បាន សៀក៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ឯកសារ **E1/354.1** ទំព័រ ២៨ មុនម៉ោង 11.02.25។

[1798] សុះ កំរ៉ឺ៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ **E1/415.1** ទំព័រ ២៣ មុនម៉ោង 10.09.36។

[1799] សុះ កំរ៉ឺ៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ **E1/415.1** ទំព័រ ២៥ ក្រោយម៉ោង 10.13.27។

[1800] សុះ កំរ៉ឺ៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/415.1** ទំព័រ ២៥ ក្រោយម៉ោង 10.13.27 ទំព័រ ២៦ ប្រហែលម៉ោង 10.33.21។

១៨៥៨. ទោះបី សុះ កំរ៉ុ ចាប់យកសាច់រឿងនៃសក្ខីកម្មរបស់គាត់បែបណាក្តី វាច្បាស់ណាស់ថា សាច់រឿងនោះមាននិយាយតែពីកិច្ចប្រជុំមូលដ្ឋានថ្នាក់ស្រុកមួយ ហើយគាត់ថែមទាំងបានលើកឡើងពីសំដីរបស់បុគ្គលមិនស្គាល់អត្តសញ្ញាណម្នាក់។ ម្យ៉ាងទៀត សាក្សីទទួលស្គាល់ថាបាន "ទាញសេចក្ដីសន្និដ្ឋានផ្ទាល់ខ្លួន ពាក់ព័ន្ធនឹងការសម្លាប់ជនជាតិចាម និងខ្មែរ" ដោយសន្និដ្ឋានថា "មានជនជាតិចាមជាច្រើននាក់ ត្រូវបានសម្លាប់"[1801]។ សក្ខីកម្មរបស់ សុះ កំរ៉ុ អាចយកមកប្រើប្រាស់បានស្ដួចស្ដើង ដើម្បីបង្ហាញពីអត្ថិភាពនៃគោលនយោបាយចំពោះជនជាតិចាម ដោយនៅក្នុងសវនាការដដែលនោះ គាត់បានថ្លែងថា ប្រជាជនទាំងអស់ប្រឈមមុខនឹងការប្រហារជីវិត៖

> "គ្មាននរណាម្នាក់ដឹងពីមូលហេតុនៃការកាប់សម្លាប់ប្រជាជនមូលដ្ឋាន ឬប្រជាជនថ្មីទេ។ ហេតុដូច្នេះហើយបានជាមនុស្សគ្រប់រូបភ័យខ្លាចគេយកទៅសម្លាប់។ ពួកគេរង់ចាំឱ្យតែគេហៅឈ្មោះ ហើយសង្ឃឹមថានឹងបានរួចជីវិត។ ពួកគេរស់នៅក្នុងភាពភ័យខ្លាច"[1802]។

## គ. "ឯកសារព័ណ៌លឿង" ដ៏អាថ៌កំបាំង ស្ដីពីការសម្លាប់រង្គាលជនជាតិចាម តាមការសន្មត

១៨៥៩. ហេតុផលសំខាន់នៃការកោះហៅសាក្សី សុះ កំរ៉ុ គឺការស្មានថាគាត់បានអានឯកសារមួយ ដែលគាត់ទំនងជាបានប្រទះដោយចៃដន្យ ដោយសារគាត់បានសុំពី "នីរសាម្នាក់" យកមកអាន។ ឯកសារ "ក្របពណ៌លឿង" ដែលទំនងជាមានចំណងជើងថា "ផែនការសម្រាប់សហករណ៍ចម្រើន" ដែលទំនងជាមាន "ជំពូកមួយស្ដីពីខ្មាំង ពាក់ព័ន្ធនឹងជនជាតិចាម"។ បើតាមការថ្លែងរបស់គាត់ប្រាប់ អ៊ីសា ឧស្មាន គេបានសរសេរថា "ជនជាតិចាមជាសត្រូវធំជាងគេបង្អស់ ដែលត្រូវកម្ទេចឱ្យអស់មុនឆ្នាំ ១៩៨០"[1803]។

១៨៦០. ក្រៅពីស្ថានភាព នៃ "ភាពចៃដន្យ" ដ៏គួរឱ្យភ្ញាក់ផ្អើល ដែលថា សុះ កំរ៉ុ ស្ថិតនៅតែម្នាក់ឯងក្នុងមន្ទីរឃុំ ដើម្បីអាន "កែអផ្សុក" នូវឯកសារការងារមួយរបស់ "មេគាត់" ដែល "នីរសារម្នាក់" បាន

---

[1801] សុះ កំរ៉ុ៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ E1/415.1 ទំព័រ ៦០-៦១ ក្រោយម៉ោង 14.19.46។

[1802] សុះ កំរ៉ុ៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ E1/415.1 ទំព័រ ៦៧ មុនម៉ោង 14.39.58។

[1803] សុះ កំរ៉ុ៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ឯកសារ E1/415.1 ទំព័រ ៥៧-៥៨ ប្រហែលម៉ោង 14.11.45។

ប្រគល់មកគាត់ ហើយឯកសារនោះលើកឡើងពីការសម្លាប់រង្គាលជនជាតិរបស់គាត់[1804] សក្ខីកម្ម របស់សាក្សីរូបនេះ បង្កប់ទៅដោយភាពចម្រូងចម្រាស់ដ៏គួរឱ្យងឿងឆ្ងល់ផ្សេងទៀត។

១៨៦១. អាស្រ័យហេតុនេះ ខណៈដែលគាត់បានបញ្ជាក់ប្រាប់ អ៊ីសា ឧស្មាន ថាគាត់បានឃើញឯកសារនោះ មួយថ្ងៃក្រោយការប្រជុំនៅបុសខ្នុរ សុះ កំរ៉ី បានថ្លែងនៅចំពោះមុខអង្គសវនាការថា តាមពិតទៅ គឺរយៈមួយឆ្នាំក្រោយការប្រជុំ "ប្រហែលជានៅខែ តុលា ឆ្នាំ ១៩៧៨" ដែលគាត់ទំនងជាបានអានឯកសារនោះ[1805]។ ជាងនេះទៅទៀត នៅពេលឆ្លើយជាលើកដំបូងទៅកាន់សហព្រះរាជអាជ្ញា គាត់លែងចងចាំទាំងចំណងជើង ទាំងខ្លឹមសារ នៃឯកសារ[1806] ហើយក្រោយមកទៀត ថែមទាំងលែងចងចាំពណ៌ ឬ កាលបរិច្ឆេទឆ្នាំ ១៩៨០ ដែលទំនងជាមានបញ្ជាក់នៅក្នុងឯកសារនោះ[1807]។

១៨៦២. ម្យ៉ាងវិញទៀត បើសិនជាគេជឿលើសក្ខីកម្មរបស់គាត់មែន វាគួរណាស់តែ សុះ កំរ៉ី ធ្លាប់បាននិយាយពីសៀវភៅនេះ ឬក៏និយាយប្រាប់ ម៉ាត់ លី ដែលជាអ្នកដឹកនាំជនជាតិចាមខ្ពស់ជាងគេ នៅក្រោយឆ្នាំ ១៩៧៩ ឬក៏ប្រាប់ញាតិរបស់គាត់ណាម្នាក់ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ដើម្បីឱ្យអ្នកទាំងនោះដឹងជាមុនផងអំពីគ្រោះថ្នាក់ដ៏ធំដែលចាមគ្រប់គ្នានឹងត្រូវប្រឈមនេះ[1808]។ ដូច្នេះ យើងអាចយល់ច្បាស់ហើយអំពីមូលហេតុនៃការដែលគាត់មិនព្រមធ្វើសម្បថ ព្រមទាំងការដែលគាត់មិនព្រមចូលមកផ្តល់សក្ខីកម្មនោះ។

---

[1804] សុះ កំរ៉ី៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/415.1** ទំព័រ ៥៨ មុនម៉ោង 14.14.43 (គាត់មិនមែនឱ្យសៀវភៅទេ គឺគាត់យកទាំងសំណុំ ទាំង គេហៅថាទាំងសៀវភៅទាំងអស់ហ្នឹង យកមកឱ្យរើសមើលចង់អានអ្វី ប៉ុន្តែ ខ្ញុំចាប់ទៅគឺចំសៀវភៅហ្នឹង"។

[1805] សុះ កំរ៉ី៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/415.1** ទំព័រ ៦១ មុនម៉ោង 14.22.51 ទំព័រ ៧៩ ក្រោយម៉ោង 15.38.03។

[1806] សុះ កំរ៉ី៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/415.1** ទំព័រ ៣២ ប្រហែលម៉ោង 10.52.21។

[1807] សុះ កំរ៉ី៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/415.1** ទំព័រ ៥៧ ក្រោយម៉ោង 14.09.38 ទំព័រ ៥៨ ក្រោយម៉ោង 14.11.45។

[1808] សុះ កំរ៉ី៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/415.1** ទំព័រ ៥៩ ប្រហែលម៉ោង 14.14.43 ទំព័រ ៨១-៨២ ចាប់ពីម៉ោង 15.47.35។

១៨៦៣. ក្នុងនាមជាសមាជិកផ្ញើមនៅក្នុងសហគមរបស់គាត់ និងជាប្រភពមួយសំខាន់ជាងគេរបស់ អ៊ីសា ឧស្មាន យើងត្រូវតែទទួលស្គាល់ថា សក្ខីកម្មរបស់គាត់ដែលមិនព្រមធ្វើក្រោមសម្បថ មិនអាចឱ្យទុកចិត្ត និងជឿជាក់បានឡើយ។ អង្គជំនុំជម្រះត្រូវពិចារណាជាចាំបាច់ពីភាពមិនទំនងទាំងនេះ នៅក្នុងក្របខណ្ឌនៃការពិភាក្សាសម្រេចលើឯកសារមួយ ដែលគ្មានកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ឬសាក្សីណាម្នាក់ផ្សេងទៀត ធ្លាប់បានលើកឡើងពីអត្ថិភាពនៃឯកសារនោះឡើយ។

១៨៦៤. បើទោះបីជាលោកបានសង្កត់ធ្ងន់ថា ជនជាតិចាមទំនងជាត្រូវបានគេធ្វើទុក្ខបុកម្នេញ និងរងផលប៉ះពាល់ខ្លាំងជាងគេ នៅក្នុងរបបខ្មែរក្រហម អ៊ីសា ឧស្មាន បានបង្ខំចិត្តទទួលស្គាល់ថា ជនជាតិចាម "ក៏ដូចជាជនជាតិខ្មែរដែរ" រស់នៅជាមួយគ្នា ចាប់តាំងពីខែ វិច្ឆិកា ឆ្នាំ ១៩៧៥ មក លែងមានកម្មសិទ្ធិផ្ទាល់ខ្លួន និងជាទូទៅ ធ្វើការបែកគ្នាពីកូនៗរបស់ពួកគេ[1809]។ ដូច្នេះ បើល័ក្ខខ័ណ្ឌការងារមានសភាពធ្ងន់ធ្ងរមែន គឺសម្រាប់ជនជាតិខ្មែរ ក៏ដូចជាសម្រាប់ជនជាតិចាមដែរ។ វាគ្មានការរើសអើងនោះទេ។ ភ័ស្តុតាងក្រៅពីនេះ ក៏មិនអាចឱ្យគេសន្និដ្ឋានបានថា មានផែនការកម្ទេចជនជាតិចាម ក្នុងឋានៈជាក្រុមមួយនោះឡើយ។

## ២. <u>អនិត្ថិភាពនៃគោលនយោបាយ បើតាមសាក្សីផ្សេងទៀត</u>

### ក. <u>កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា</u>

១៨៦៥. សាក្សី 2-TCW-850 បានថ្លែងនៅចំពោះមុខអង្គសវនាការ ថាបានទទួលការតែងតាំងជាសមាជិកស្រុកបារាយណ៍ ក្នុងខេត្តកំពង់ធំ នៅឆ្នាំ ១៩៧៨[1810]។ នៅចំពោះមុខអង្គសវនាការ គាត់បានអះអាងថាបានចូលរួមក្នុងកិច្ចប្រជុំមួយ នៅចម្ការលើ ដែលនៅក្នុងកិច្ចប្រជុំនោះ គាត់ទទួលបានឯកសារមួយ ដែលគាត់គិតថាជា "ទង់បដិវត្តន៍" ណែនាំឱ្យ "ប្រព្រឹត្តដូចគ្នាចំពោះប្រជាជន១៧មេសា" និងហាមឃាត់រាល់ការបែងចែករវាងប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន[1811]។ គាត់មិនបានលើក

---

[1809] <u>អ៊ីសា ឧស្មាន</u>៖ ប្រតិចារឹក ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ឯកសារ **E1/389.1** ទំព័រ ៣៤ ក្រោយម៉ោង 11.21.04 ទំព័រ ៣៦ ក្រោយម៉ោង 11.27.05។

[1810] <u>2-TCW-850</u>៖ ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៥ឯកសារ **E1/461.1** ទំព័រ ១៥ មុនម៉ោង 09.48.32។

[1811] <u>2-TCW-850</u>៖ ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **E1/461.1** ទំព័រ ៦០-៦១ មុនម៉ោង 15.04.42, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៩ឯកសារ **E3/5293**, ERN KH 00348843។

ឡើងទាល់តែសោះ អំពីការណែនាំណាមួយឱ្យប្រឆាំងនឹងជនជាតិចាម ហើយការលើកឡើងបែបនេះផ្ទុយគ្នាស្រឡះពីសក្ខីកម្មរបស់ សុះ កំរី ដែលរស់នៅក្នុងស្រុកតែមួយ។

១៨៦៦. បទពិសោធន៍មានភាពខុសគ្នា ទៅតាមភូមិភាគ និងតំបន់។ សក្ខីកម្មរបស់កម្មាភិបាលបង្ហាញថាគ្មានគោលនយោបាយមកពីថ្នាក់កំពូលនៃបក្សកុម្មុយនីស្តចំពោះជនជាតិចាមទេ។

១៨៦៧. ពេជ្រ ជឹម អតីតប្រធានស្រុកត្រាំកក់ បន្ទាប់មក ប្រធានចម្ការកៅស៊ូភូមិភាគកណ្ដាល បានពន្យល់ថា លោកបានដោះស្រាយបញ្ហាស្បៀងអាហារសម្រាប់ជនជាតិចាម "ដោយផ្អែកលើការព្រមព្រៀង" ជំនួសសាច់ជ្រូកដោយអាហារផ្សេង សម្រាប់អាហាររួម ដោយមិនបានលើកឡើងពីការបង្ខិតបង្ខំណាមួយលើបញ្ហានេះឡើយ[1812]។ ផាន់ ឆេន អតីតកម្មាភិបាលនៅត្រាំកក់ ដែលបានតាមពេជ្រ ជឹម ទៅភូមិភាគកណ្ដាល បានថ្លែងថា ប្រជាជនចាមជាច្រើនអ្នកធ្វើការនៅភូមិភាគកណ្ដាល ហើយមានផ្ទះជាច្រើន "ត្រូវបានសាងសង់សម្រាប់ពួកគេ"[1813]។ គាត់មិនដែលបានឮគេនិយាយពីគោលនយោបាយជាក់លាក់លើជនជាតិចាមឡើយ[1814]។

១៨៦៨. ដូចបានលើកឡើងពីខាងលើ សូម្បីតែសក្ខីកម្មរបស់សាក្សី 2-TCW-938 ក៏មិនអាចឱ្យគេសន្និដ្ឋានបានថាមានគោលនយោបាយចំពោះជនជាតិចាម ដែលទំនងជាត្រូវបានដាក់ចេញពីក្រុងភ្នំពេញ។ ជាក់ស្ដែង ក្រៅពីភាពផ្ទុយគ្នានៃសក្ខីកម្មរបស់គាត់ស្ដីពីបទបញ្ជាទទួលមកពីតំបន់ គាត់បានទទួលស្គាល់ ថាមិនបានដឹងអ្វីទាំងអស់អំពីការប្រាស្រ័យទាក់ទងគ្នារវាងតំបន់ និងភូមិភាគ និងមានសិទ្ធិសម្រេចចាប់ខ្លួននរណាម្នាក់[1815]។

១៨៦៩. នៅកម្រិតខ្ពស់ជាងនេះ ទោះបីជាខ្លួនគាត់ផ្ទាល់មានទំនោរទៅរកការសន្មតលើឯកសារដែលគាត់ទើបតែបានដឹងនៅពេលជំនុំជម្រះ **ឌុច** បានថ្លែងនៅចំពោះមុខអង្គជំនុំជម្រះថា ទាំង សុន សេន

---

[1812] ពេជ្រ ជឹម៖ ប្រតិចារឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ឯកសារ **E1/292.1** ទំព័រ ១៩ មុនម៉ោង 10.08.22។

[1813] ផាន់ ឆេន៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ឯកសារ **E1/269.1** ទំព័រ ៦៣ មុនម៉ោង 14.41.27។

[1814] ផាន់ ឆេន៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ឯកសារ **E1/269.1** ទំព័រ ៧២-៧៣ មុនម៉ោង 15.33.53។

[1815] សូមមើលខាងលើ កថាខណ្ឌ ១៦៧៦ ដល់កថាខណ្ឌ ១៦៧៧។

ទាំង នួន ជា "មិនធ្លាប់បានផ្តល់ការណែនាំអំពីជនជាតិចាម" ដល់រូបគាត់ម្តងណាឡើយ[1816]។ ម៉្យាងទៀត គាត់ "មិនធ្លាប់បានសង្កេតឃើញមានការចាប់ខ្លួនសមាជិកនៃក្រុមជនជាតិចាមម្តងណាសោះ" ហើយថែមទាំងបានអះអាងថា "មិនមានគោលនយោបាយកម្ទេចជនជាតិចាមទេ"[1817]។ គាត់ថែមទាំងមិនធ្លាប់បានឃើញ "ឯកសារណាមួយនៅសម័យនោះ ដែលលើកឡើងពីមាគ៌ាបក្សបែបនេះឡើយ"។ ព័ត៌មានមកពីអ្នកទទួលខុសត្រូវមន្ទីរ ស-២១ ដែលជាមន្ទីរសន្តិសុខធំជាងគេបង្អស់របស់ប្រទេស ដែលក្នុងនោះក៏មានបុគ្គលិកជាជនជាតិចាមដែរ គឺជាព័ត៌មានដ៏សម្បើមមួយ[1818]។

១៨៧០. ក្នុងអំឡុងពេលសវនាការលើឯកសារគន្លឹះ សហព្រះរាជអាជ្ញាបានស្រង់កំណត់ហេតុនៃបទសម្ភាសន៍ លោក ជា ស៊ីម ដោយ លោក Ben KIERNAN ដែលនៅក្នុងបទសម្ភាសន៍នោះ គាត់បាននិយាយថា គ្រប់ជនជាតិភាគតិចទាំងអស់ត្រូវបានសម្លាប់ចោល[1819]។ អង្គជំនុំជម្រះមិនអាចផ្តល់ទម្ងន់ណាមួយដល់កំណត់ហេតុនៃបទសម្ភាសន៍នេះបានឡើយ ខណៈដែលអង្គជំនុំជម្រះបដិសេធការចូលមកបង្ហាញខ្លួនរបស់ ជា ស៊ីម តាមការស្នើសុំយ៉ាងទទូចរបស់ នួន ជា[1820] ហើយ Ben KIERNAN បានបដិសេធមិនចូលមកបង្ហាញខ្លួន។ ជាពិសេស សក្ខីកម្មនៅក្នុងកំណត់ហេតុនោះមិនបានបញ្ជាក់ពីមូលហេតុនៃការកាប់សម្លាប់ជនជាតិភាគតិចទាំងនោះ និងមិនបានលើកឡើងពីគោលនយោបាយឡើយ។

---

[1816] ឧទ្ធ៖ ប្រតិចារឹក ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៦ឯកសារ **E1/438.1** ទំព័រ ២០ មុនម៉ោង 10.36.20 និងអំពីសម្មតិកម្មរបស់គាត់ក្នុងបច្ចុប្បន្នកាល ទំព័រ ២១ មុនម៉ោង 10.40.17។

[1817] ឧទ្ធ៖ ប្រតិចារឹក ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ឯកសារ **E1/443.1** ទំព័រ ៧៧ ក្រោយម៉ោង 15.35.50 ទំព័រ ៨០-៨១ មុនម៉ោង 15.48.21។

[1818] ឧទ្ធ៖ ប្រតិចារឹក ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/442.1** ទំព័រ ៣៧ ប្រហែលម៉ោង 11.27.31។ ឌុច បានបញ្ជាក់ថា សឹម ម៉េល ជាបុគ្គលិក ស-២១ ត្រូវបានដាក់ទណ្ឌកម្ម ដោយសារតែគាត់បានប្រព្រឹត្តកំហុសជាច្រើនដង គឺមិនមែនដោយសារតែគាត់ជាជនជាតិចាមនោះទេ។

[1819] កំណត់ហេតុសម្ភាសន៍របស់ Ben KIERNAN ជាមួយ ជា ស៊ីម ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៨១ឯកសារ **E3/5593**, ERN KH 00713929-00713930។

[1820] បញ្ជីរបស់ នួន ជា ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ឯកសារ **E305/4.1**, ERN KH 00997120, សេចក្តីសម្រេច ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ឯកសារ **E312** កថាខណ្ឌ ៦៩។

១៨៧១. សក្ខីកម្មរបស់ ម៉ាត់ លី ដែលជាជនជាតិចាមម្នាក់ដែលស្និទ្ធនឹងមេដឹកនាំកំពូលរបស់បក្សកុម្មុយនីស្តកម្ពុជា និយាយជំទាស់ទៅនឹងទស្សនៈគោលនយោបាយជាក់លាក់ចំពោះជនជាតិចាម[1821]។ ជាក់ស្តែង គាត់បានថ្លែងថា ប៉ុល ពត "មិនស្អប់" ជនជាតិចាមទេ ហើយមូលហេតុនៃការចាប់ខ្លួន ក្នុងនោះ មានគ្រួសារលោកផងដែរ ជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ថាជាខ្មែរសេរីអា ឬ កាហ្សែបេ ឬវៀតណាម[1822]។ គាត់ថែមទាំងបង្ហាញពីការគាបសង្កត់មួយលើ "ជនជាតិខ្មែរទាំងអស់"។

១៨៧២. ដូច្នេះ គេមិនអាចនិយាយបានថា ទំនងជាមានការអនុវត្តដូចគ្នាមួយ ឬមានការណែនាំមកពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលផ្តោតជាក់លាក់លើជនជាតិចាមនោះទេ។

## ខ. សាក្សីផ្សេងទៀត

១៨៧៣. លោក Philip SHORT បានថ្លែងនៅចំពោះមុខអង្គសវនាការថា បើសិនជាមាន "ការបង្ក្រាបយ៉ាងព្រៃផ្សៃទៅលើការបះបោររបស់ពួកចាម" គេមិនអាចនិយាយបានទេពី "ការប៉ុនប៉ងដោយចេតនាក្នុងការកម្ទេចក្រុមជាក់លាក់ណាមួយ" ពាក់ព័ន្ធនឹងជនជាតិចាម[1823]។ លោក François PONCHAUD បានពិពណ៌នាបន្ថែមនៅក្នុងន័យដូចគ្នានេះដែរ ដោយលោកថ្លែងនៅក្នុងសវនាការថា មិនមាន "អំពើប្រល័យពូជសាសន៍ ដោយមូលហេតុសាសនា" ទេ។ ថ្វីបើគាត់បានគូសបញ្ជាក់ថា ស្ថានការណ៍ទំនងជាប្រែក្លាយខុសធម្មតា នៅឆ្នាំ ១៩៧៨ "ដោយសារជម្លោះជាមួយប្រទេសវៀតណាម" តែគាត់បានបញ្ជាក់ថា "សក្ខីកម្ម [ដែលគាត់បានដឹង] មិនច្បាស់គ្រប់គ្រាន់ ដើម្បីអះអាងថាមានអំពើប្រល័យពូជសាសន៍លើជនជាតិចាមឡើយ"[1824]។

---

[1821] សៀវភៅរបស់ Ben KIERNAN *"អំពើប្រល័យពូជសាសន៍នៅកម្ពុជា ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩៖ ពូជសាសន៍ មនោគមន៍វិជ្ជា និងអំណាច"* ឆ្នាំ ១៩៩៦ ឯកសារ **E3/1593** ទំព័រ 323, ERN KH 00637773។ ម៉ាត់ លី នៅក្នុងគណៈកម្មាធិការបក្សស្រុកត្បូងឃ្មុំ។ បទសម្ភាសន៍របស់ Steve HEDER ជាមួយ ម៉ាត់ លី មិនមានចុះកាលបរិច្ឆេទ ឯកសារ **E3/390**, ERN KH 00392095-00392097 និង 00392105-00392106។

[1822] បទសម្ភាសន៍របស់ ម៉ាត់ លី ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7821**, ERN KH 00229131។

[1823] Philip SHORT៖ ប្រតិចារឹក ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ឯកសារ **E1/192.1** ទំព័រ ១១-១២ មុនម៉ោង 09.41.47។

[1824] François PONCHAUD៖ ប្រតិចារឹក ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ឯកសារ **E1/179.1** ទំព័រ ៥១ មុនម៉ោង 13.45.50, ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ឯកសារ **E1/180.1** ទំព័រ ២៦ ក្រោយម៉ោង 10.24.10។

១៨៧៤. ដោយឡែក លោក Steve HEDER បានគូសបញ្ជាក់នៅចំពោះមុខអង្គសវនាការថា ការដាក់ចេញនូវគោលនយោបាយដំបូងៗ ដែលគេពិពណ៌នាថាជាគោលនយោបាយប្រឆាំងជនជាតិចាម "ត្រូវបានអនុវត្តដោយពួកកម្មាភិបាល ដែលពួកគេផ្ទាល់ក៏ជាជនជាតិចាមដែរ"[1825]។ សូម្បីតែ លោក Henri LOCARD ដែលគេមិនអាចសង្ស័យបានទេ ពីសមានចិត្តពិសេសរបស់គាត់ចំពោះជនជាប់ចោទ ក៏បានទទួលស្គាល់នៅក្នុងសវនាការផងដែរថា នៅក្នុងកិច្ចការប្រមូលចងក្រងពាក្យស្លោករបស់កម្ពុជាប្រជាធិបតេយ្យ គាត់មិនបានប្រទះឃើញ "ពាក្យស្លោកណាមួយប្រឆាំងនឹងជនជាតិចាមទេ" ដោយគាត់បានបន្ថែមថា ជនជាតិចាមមិនមែនជា "មុខសញ្ញានៃការចងអាឃាតរបស់រដ្ឋអំណាច ក្នុងឋានៈជាជនជាតិភាគតិច"[1826] នោះទេ។

១៨៧៥. ដូច្នេះ ភាពខុសប្លែកគ្នានៃសក្ខីកម្មរបស់អតីតកម្មាភិបាល និងប្រធាននៅតាមមូលដ្ឋាន និងភាពខុសៗគ្នានៃបទពិសោធន៍ ទៅតាមមូលដ្ឋាន ងាកទៅបង្ហាញថា មិនមានគោលនយោបាយចេញមកពីបក្សកុម្មុយនីស្តកម្ពុជាទេ តែចេញមកពីការគ្រប់គ្រងថ្នាក់មូលដ្ឋានលើប្រជាជន ដែលទោះបីជាជាប្រជាជនខ្មែរក្តី ឬចាមក្តី[1827]។

១៨៧៦. ដូចបានឃើញពីខាងលើ ភ័ស្តុតាងអង្គហេតុអំពីស្រុកក្រូចឆ្មារ និងស្រុកកងមាស នៅក្នុងភូមិភាគបូព៌ា និងភូមិភាគកណ្តាល មិនអាចឱ្យគេសន្និដ្ឋានបានថា ទំនងជាមានការកំណត់មុខសញ្ញាជនជាតិចាម ដោយមូលហេតុសាសនារបស់ពួកគេ ឬទំនងជាមានចេតនាកម្ទេចជនជាតិចាម ក្នុងឋានៈជា

---

1825 Steve HEDER៖ ប្រតិចារឹក ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ឯកសារ **E1/223.1** ទំព័រ ៧១-៧២ ក្រោយម៉ោង 15.13.43។

1826 Henri LOCARD៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ **E1/450.1** ទំព័រ ៧៣-៧៤ ក្រោយម៉ោង 15.22.41, ប្រតិចារឹក ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៦ឯកសារ **E1/453.1** ទំព័រ ១៤ ក្រោយម៉ោង 09.35.02។

1827 គួរកត់សម្គាល់ថា ភាពខុសគ្នាត្រូវបានសហចៅក្រមស៊ើបអង្កេតដកស្រង់ តាមព្រឹត្តិន័យ ទោះបីជាមិនបានទាញផលវិបាកសមហេតុផលក៏ដោយ។ ជាក់ស្តែង នៅកថាខណ្ឌ ៣២០ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានបង្ខំចិត្តអះអាងថា សាក្សីចងចាំថា "ជនជាតិចាមរស់នៅក្នុងស្រុកត្រាំកក់ទទួលរងនការប្រព្រឹត្តិដូចអ្នកដទៃទៀតដែរ"។ ដូចគ្នាដែរ នៅកថាខណ្ឌ ៥០០ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខក្រាំងតាចាន់៖ "ប៉ុន្តែ ក៏មានប្រជាជនមូលដ្ឋាន អតីតទាហាន នល់ នល់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ចិន វៀតណាម និងចាម ស្ថិតនៅក្នុងចំណោមអ្នកជាប់ឃុំឃាំងដែរ។ ទាក់ទិនជាមួយជនជាតិចាម សាក្សីដែលរស់នៅក្នុងស្រុកត្រាំកក់បាននិយាយថាការប្រព្រឹត្តិទៅលើជនជាតិចាមដូចគ្នានឹងប្រជាជនដទៃទៀត"។

ជនជាតិភាគតិច។ ដោយគេប្រកាន់ខ្ជាប់ណាស់នូវការវិភាគតាមលទ្ធិម៉ាក្សនិយមរបស់ខ្លួន បក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថា សាសនាជាគ្រឿងញៀនសម្រាប់ប្រជាជន ហើយសាសនាអ៊ីស្លាមត្រូវបានហាមឃាត់ដូចសាសនាឯទៀតដែរ ដែលមិនមែនជាមុខសញ្ញាពិសេសខុសគេនោះទេ។ ដូចគ្នានេះដែរ ជនជាតិចាមទទួលរងគ្រោះពីការកាប់សម្លាប់ ឬការចាប់ចង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តែភាពរងគ្រោះទាំងនេះ បណ្តាលមកពីសេចក្តីសម្រេចថ្នាក់មូលដ្ឋាន ដោយមូលហេតុស្រដៀងគ្នាទៅនឹងប្រជាជនដទៃទៀតដែរ។

១៨៧៧. ដូច្នេះ ថ្វីបើអង្គជំនុំជម្រះយល់ឃើញតាមទស្សនៈដោយឡែករបស់ខ្លួនថា ធាតុផ្សំដែលនាំទៅរកការសន្និដ្ឋានថា ការចាប់ចង ឬការកាប់សម្លាប់ ទំនងជាត្រូវបានធ្វើ នៅថ្នាក់មូលដ្ឋានដោយសារមូលហេតុជាតិពន្ធុ ឬសាសនា ក៏អង្គជំនុំជម្រះអាចត្រឹមតែកត់សម្គាល់បានថា បញ្ហាទាំងអស់នេះមិនអាចជាការអនុវត្តគោលនយោបាយមួយ ដែលបង្កើតឡើងដោយថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានទេ។ ធាតុផ្សំនៃភ័ស្តុតាង ពិតជាមិនអាចឱ្យគេទាញសេចក្តីសន្និដ្ឋានហួសពីវិមតិសង្ស័យឡើយ។

**ជំពូកទី ៥. <u>អំពីជនជាតិវៀតណាម</u>**

**ផ្នែកទី ១. <u>ការចោទប្រកាន់</u>**

**១. <u>ឧក្រិដ្ឋកម្មដែលចោទប្រកាន់</u>**

១៨៧៨. ចំពោះអង្គហេតុកើតឡើងចំពោះជនជាតិវៀតណាម ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទឃាតកម្ម បទសម្លាប់រង្គាល និងបទធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ ក្រោមរូបភាព

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[1828]។ គាត់ក៏ត្រូវបានចោទប្រកាន់ផងដែរ ពីបទប្រល័យពូជសាសន៍ តាមរយៈការកាប់សម្លាប់សមាជិកនៃក្រុមជនជាតិវៀតណាម[1829]។

១៨៧៩. ពិតមែនតែសហចៅក្រមស៊ើបអង្កេតបានបញ្ជូនខ្លួនជនជាប់ចោទ ទៅចំពោះមុខអង្គជំនុំជម្រះ ដោយសារអង្គហេតុនៃការបញ្ជូនខ្លួនជនជាតិវៀតណាមនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង[1830] តែអង្គជំនុំជម្រះមិនទទួលបានបណ្តឹងត្រឹមត្រូវតាមនីតិវិធីឡើយ ហើយអាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនអាចសម្រេចលើបញ្ហានេះបានឡើយ[1831]។

## ២. ដែនបណ្តឹងមកកាន់អង្គជំនុំជម្រះ

### ក. ការធ្វើមនុស្សឃាត

១៨៨០. តាមដីកាដំណោះស្រាយ ឃាតកម្មលើជនជាតិវៀតណាម ជំហានដំបូង សំដៅតែទៅលើអ្នកដែលជំទាស់ទៅនឹងការនិរទេសខ្លួន នៅឆ្នាំ ១៩៧៥-១៩៧៦ ហើយក្រោយមក បានក្លាយរាលដាលជាទូទៅ ចាប់ពីឆ្នាំ ១៩៧៧[1832]។ ដោយសារអង្គជំនុំជម្រះមិនទទួលបានបណ្តឹងត្រឹមត្រូវតាមនីតិវិធី ពីអង្គហេតុនៃការនិរទេសខ្លួនជនជាតិវៀតណាម អង្គជំនុំជម្រះក៏មិនអាចសម្រេចលើអង្គហេតុដែលជាធាតុផ្សំនៃបទឃាតកម្មលើជនជាតិវៀតណាម នៅក្នុងអំឡុងពេលនៃអង្គហេតុនិរទេសខ្លួនដូចគ្នានេះដែរ។ ដូច្នេះ ការពិនិត្យលើអង្គហេតុត្រូវតែកំណត់យកត្រឹមតែបទឃាតកម្មដែលទំនងជារីករាលដាលជាទូទៅ ចាប់ពីឆ្នាំ ១៩៧៧។

---

[1828] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៣ កថាខណ្ឌ ១៣៧៤ កថាខណ្ឌ ១៣៧៨ កថាខណ្ឌ ១៣៧៩ កថាខណ្ឌ ១៣៨០ (ការធ្វើមនុស្សឃាត) កថាខណ្ឌ ១៣៨១-១៣៨៦ កថាខណ្ឌ ១៣៨៨ កថាខណ្ឌ ១៣៩០ (ការសម្លាប់រង្គាល) កថាខណ្ឌ ១៤១៥ កថាខណ្ឌ ១៤២២-១៤២៣ (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍), ឧបសម្ព័ន្ធកំណត់អំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1.1 ទំព័រ ៤-៥។

[1829] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៤៣ ដល់កថាខណ្ឌ ១៣៤៩, ឧបសម្ព័ន្ធកំណត់អំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1.1 ទំព័រ ៤។

[1830] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៧ ដល់កថាខណ្ឌ ១៤០១, ឧបសម្ព័ន្ធកំណត់អំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1.1 ទំព័រ ៥។

[1831] សូមមើលខាងលើ កថាខណ្ឌ ២១៩ ដល់កថាខណ្ឌ ២៧៦។

[1832] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៨។

១៨៨១. គ្មានការបញ្ជាក់ពីការចង្អុលបង្ហាញទីតាំងភូមិសាស្ត្រណាមួយ នៅក្នុងការកំណត់បទចោទនៃអង្គហេតុនៅក្នុងដីកាដំណោះស្រាយឡើយ។ ផ្ទុយទៅវិញ បើយោងទៅលើការកំណត់អង្គហេតុនៃសហឧក្រិដ្ឋកម្មរួម សហចៅក្រមស៊ើបអង្កេតរំលឹកចំៗថា ខ្លួន "បានទទួលបណ្ដឹងពីវិធានការធ្វើឡើង [...] ប្រឆាំងនឹងជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង (ភូមិភាគបូព៌ា) និងនៅពេលវាយលុកលុយចូលប្រទេសវៀតណាម"[1833]។

១៨៨២. ជាក់ស្ដែង ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញា បង្ហាញឱ្យឃើញថា សហព្រះរាជអាជ្ញាបានសម្រេចបើកកិច្ចស៊ើបសួរមួយតាមផ្លូវតុលាការប្រឆាំងនឹង ខៀវ សំផន ដោយផ្អែកលើអង្គហេតុពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង និងក្នុងអំឡុងពេលវាយចូលលុកលុយក្នុងទឹកដីដីវៀតណាម[1834]។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតបានទទួលតែបណ្ដឹងពីអង្គហេតុទាំងនេះ ដូចបានបានចង្អុលបង្ហាញនៅក្នុងដីការបស់ខ្លួន ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០[1835]។

១៨៨៣. នៅក្នុងដីកាបំបែកសំណុំរឿង នៅពេលក្រោយមក អង្គជំនុំជម្រះបានកំណត់ដែនបណ្ដឹងមកកាន់ខ្លួនអំពីការប្រព្រឹត្តិលើជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង ដោយដកចេញពីសំណុំរឿង ០០២/០២ នូវអង្គហេតុពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជា នៅលើទឹកដីវៀតណាម[1836]។

១៨៨៤. ដោយឡែក សហព្រះរាជអាជ្ញាបានយល់ច្រឡំជ្រាបច្បាស់ពីដែនកំណត់នៃបណ្ដឹងនេះ ព្រោះថា នៅពេលស្នើសុំកោះហៅសាក្សីបន្ថែមស្ដីពីការព្រឹត្តិលើជនជាតិវៀតណាម សហព្រះរាជអាជ្ញាបានគូសបញ្ជាក់ថា៖

---

[1833] ដីកាដំណោះស្រាយ កថាខណ្ឌ ២០៦។

[1834] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៩ ដល់កថាខណ្ឌ ៧០។

[1835] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ឯកសារ **D250/3/3** កថាខណ្ឌ ៧-៩។

[1836] ឧបសម្ព័ន្ធកំណត់អំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ **E301/9/1.1** ទំព័រ ២, សូមមើលខាងលើ កថាខណ្ឌ ២០៤ ដល់កថាខណ្ឌ ២១២។

> "សហចៅក្រមស៊ើបអង្កេតបានចាត់ទុកថាខ្លួនបានទទួលបណ្ដឹងពីអង្គហេតុទាក់ទងនឹងការប្រព្រឹត្តិលើជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង ក្នុងភូមិភាគបូព៌ា និងក្នុងអំឡុងពេលវាយចូលលុកលុយទឹកដីវៀតណាម។ នៅពេលអង្គជំនុំជម្រះបំបែកការចោទប្រកាន់នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះបានដកចេញពីវិសាលភាព នៃសំណុំរឿង ០០២/០២ នូវឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងពេលវាយចូលលុកលុយទឹកដីវៀតណាម។ ដោយសារមូលហេតុនេះ ការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ដែលជនជាតិវៀតណាមទទួលរងគ្រោះ ជាប់ពាក់ព័ន្ធតែនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត ក្នុងខេត្តព្រៃវែង និងស្វាយរៀងតែប៉ុណ្ណោះ។ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលគូសបញ្ជាក់ដោយសហចៅក្រមស៊ើបអង្កេត និងដែលផ្តោតយ៉ាងជាក់លាក់លើការប្រព្រឹត្តិលើជនជាតិវៀតណាម ក៏សំដៅជាចម្បងទៅលើតំបន់ទាំងពីរនេះដែរ"[1837]។

១៨៨៥. ដូច្នេះ ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទឃាតកម្មលើជនជាតិវៀតណាម ចាប់ពីឆ្នាំ ១៩៧៧ នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង។

## ខ. ការសម្លាប់រង្គាល

១៨៨៦. ពាក់ព័ន្ធនឹងអង្គហេតុសម្លាប់រង្គាលជនជាតិវៀតណាម សហចៅក្រមស៊ើបអង្កេត បានគូសបញ្ជាក់ថា៖

> "ពាក់ព័ន្ធនឹងការប្រព្រឹត្តិលើ [ក្រុម] ជនជាតិវៀតណាម (ចាប់ពីខែ មេសា ឆ្នាំ ១៩៧៧) [...] ការកាប់សម្លាប់សមាជិក នៃ [ក្រុមនេះ] បានវិវត្តទៅមុខ រហូតមានទ្រង់ទ្រាយធំ និងទូទៅ ចំពោះបញ្ហាសម្លាប់រង្គាល"[1838]។

១៨៨៧. ដូច្នេះ អង្គជំនុំជម្រះមានសមត្ថកិច្ចពិនិត្យមើលអង្គហេតុនៃការសម្លាប់រង្គាលលើជនជាតិវៀតណាម ចាប់ពីខែ មេសា ឆ្នាំ ១៩៧៧។ ម្យ៉ាងទៀត ដូចបានបញ្ជាក់រួចហើយ ពាក់ព័ន្ធនឹងការកាប់សម្លាប់ជនជាតិវៀតណាម អង្គជំនុំជម្រះបានទទួលបណ្ដឹងតែពីបទប្រព្រឹត្តលើជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង តែប៉ុណ្ណោះ[1839]។

---

[1837] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ E381 កថាខណ្ឌ ៩។

[1838] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨៦។

[1839] សូមមើលខាងលើ កថាខណ្ឌ ១៨៨០ ដល់កថាខណ្ឌ ១៨៨៥។

១៨៨៨. អាស្រ័យហេតុនេះ ខៀវ សំផន ត្រូវតែជំនុំជ្រះពីបទសម្លាប់ផ្តាច់ពូជលើជនជាតិវៀតណាម ចាប់ពីខែ មេសា ឆ្នាំ ១៩៧៧ នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង។

## គ. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍

១៨៨៩. ពាក់ព័ន្ធនឹងអង្គហេតុនៃការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម ដោយមូលហេតុពូជសាសន៍ សហចៅក្រមស៊ើបអង្កេតបានគូសបញ្ជាក់ថា៖

> "ប្រជាជនវៀតណាមត្រូវបានធ្វើទុក្ខបុកម្នេញ ដោយសារបក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកជនជាតិវៀតណាមថាជាពូជសាសន៍មួយខុសគ្នាពីពូជសាសន៍ខ្មែរ ដោយកត្តាឬសគល់ជីវសាស្ត្រ និងសង្គម។ ការធ្វើទុក្ខបុកម្នេញពូជសាសន៍បានប្រព្រឹត្តទៅនៅខេត្តព្រៃវែង និងស្វាយរៀង នៅមន្ទីរសន្តិសុខក្រាំងតាចាន់ កោះក្ដូច អូរកន្សែង ស-២១ និងនៅតាមសហករណ៍នានាក្នុងស្រុកត្រាំកក់។ ជនជាតិវៀតណាមត្រូវបានគេកំណត់អត្តសញ្ញាណ និងមុខសញ្ញា តាមអំពើចិត្ត និងជាប្រព័ន្ធ ដោយសារពូជសាសន៍របស់ពួកគេ"[1840]។

១៨៩០. មន្ទីរសន្តិសុខកោះក្ដូច ត្រូវបានផាត់ចេញពីវិសាលភាពនៃសំណុំរឿង ០០២/០២ នៅពេលបំបែកសំណុំរឿង[1841]។ ការចោទប្រកាន់ពីការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ នៅក្នុងមន្ទីរសន្តិសុខ និងសហករណ៍ត្រាំកក់ ត្រូវបានសិក្សានៅក្នុងផ្នែកពាក់ព័ន្ធនីមួយៗ[1842]។ ដូច្នេះ នៅទីនេះ យើងគ្រាន់តែធ្វើការវិភាលើអង្គហេតុដែលជាធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញជនជាតិវៀតណាម ដោយមូលហេតុពូជសាសន៍ នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង។

១៨៩១. យើងគួរបញ្ជាក់ថា ដីកាដំណោះស្រាយលើកឡើងពីការបណ្ដេញជនជាតិវៀតណាមចេញពីទឹកដីកម្ពុជា និងបញ្ជូនទៅប្រទេសវៀតណាម ក្នុងឋានៈជាអង្គហេតុនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍[1843]។ ទន្ទឹមនឹងនេះ ដូចបានឃើញពីខាងដើម សហចៅក្រមស៊ើបអង្កេតមិនទទួល

---

[1840] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២២។

[1841] ឧបសម្ព័ន្ធកំណត់អំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ **E301/9/1.1** ទំព័រ ៣។

[1842] សូមមើលខាងលើ កថាខណ្ឌ ៨៧៩ ដល់កថាខណ្ឌ ៨៨២។

[1843] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២២។

បានបណ្តឹងពីអង្គហេតុនៃការបញ្ជូនខ្លួនជនជាតិវៀតណាមទេ[1844]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនមានសមត្ថកិច្ចវិនិច្ឆ័យអង្គហេតុទាំងនេះឡើយ។

១៨៩២. ដោយសារគ្មានការបញ្ជាក់ពីតម្រុយពេលវេលាណាមួយសោះ អង្គហេតុនៃការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម ដោយមូលហេតុពូជសាសន៍ ត្រូវតែពិនិត្យមើល ស្របតាមយុត្តាធិការពេលវេលាទាំងមូលរបស់ អ.វ.ត.ក ពោលគឺ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។

១៨៩៣. ដូច្នេះ ខៀវ សំផន ត្រូវតែជំនុំជម្រះពីបទធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម ដោយមូលហេតុពូជសាសន៍ នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង ចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និង ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។

## ឃ. <u>បទប្រល័យពូជសាសន៍ដោយឃាតកម្ម</u>

១៨៩៤. ផ្អែកតាមដីកាដំណោះស្រាយ បទប្រល័យពូជសាសន៍ដោយឃាតកម្ម ផ្តោតទៅលើបុគ្គលជាសមាជិកក្រុមជនជាតិវៀតណាម ដែលទំនងជាត្រូវបានកាប់សម្លាប់ជាលក្ខណៈប្រព័ន្ធ។ យើងគួរបញ្ជាក់ថា នេះជាក្រុមពូជពន្ធុ និងជាតិសាសន៍ពិសេសមួយ ដែលទំនងជាត្រូវបានចាត់ទុកថាជាក្រុមពូជសាសន៍មួយដែរ ដោយបក្សកុម្មុយនីស្តកម្ពុជា[1845]។

១៨៩៥. គ្មានការបញ្ជាក់ពីការចង្អុលបង្ហាញពេលវេលា ឬភូមិសាស្ត្រណាមួយឡើយ។ ដូចបានអត្ថាធិប្បាយរួចមកហើយ ពាក់ព័ន្ធនឹងបទឃាតកម្ម និងបានរំលឹករួចហើយ ក្នុងផ្នែកបទសម្លាប់រង្គាល អង្គជំនុំជម្រះបានទទួលបណ្តឹង តែពីអង្គហេតុនៃការប្រព្រឹត្តិលើជនជាតិវៀតណាម នៅខេត្តព្រៃវែង និងស្វាយរៀង[1846] និងពីអង្គហេតុនៃអំពើឃាតកម្មលើជនជាតិវៀតណាម ចាប់ពីឆ្នាំ ១៩៧៧

[1844] សូមមើលខាងលើ កថាខណ្ឌ ២១៩ ដល់កថាខណ្ឌ ២៧៦។

[1845] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៥៣។

[1846] សូមមើលខាងលើ កថាខណ្ឌ ១៨៨០-១៨៨៥ និងកថាខណ្ឌ ១៨៨៦-១៨៨៨។

ប៉ុណ្ណោះ[1847]។ ដោយសារតែបទឧក្រិដ្ឋប្រល័យពូជសាសន៍ ទំនងជាបានប្រព្រឹត្តឡើង ក្រោមទម្រង់នៃការកាប់សម្លាប់សមាជិកក្រុមជនជាតិវៀតណាមតែមួយមុខ បទឧក្រិដ្ឋនេះមិនអាចត្រូវបានយកមកធ្វើជាធាតុផ្សំ នៅមុនកាលបរិច្ឆេទនេះទេ។ ព្រមជាមួយនេះ នៅក្នុងការកំណត់អង្គហេតុនៃសហឧក្រិដ្ឋកម្មរួម នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានគូសបញ្ជាក់ថា "ចាប់ពីខែ មេសា ឆ្នាំ ១៩៧៧ ចេតនារបស់បក្សកុម្មុយនីស្តកម្ពុជា គឺរុញគោលនយោបាយនេះឱ្យកាន់តែស៊ីជម្រៅ តាមរយៈការកម្ទេចទាំងស្រុង ឬដោយផ្នែក នូវក្រុមជនជាតិវៀតណាម ក្នុងឋានៈជាក្រុមមួយ"[1848]។ ដូច្នេះ ពួកគេមានចេតនាជាក់លាក់ ដែលជាធាតុផ្សំនៃបទប្រល័យពូជសាសន៍ ចាប់ពីខែ មេសា ឆ្នាំ ១៩៧៧។

១៨៩៦. អាស្រ័យហេតុនេះ ខៀវ សំផន ត្រូវតែទទួលការជំនុំជម្រះ តែពីបទប្រល័យពូជសាសន៍ ដោយការប្រព្រឹត្តិឃាតកម្មលើសមាជិកក្រុមជនជាតិវៀតណាម នៅខេត្តព្រៃវែង និងស្វាយរៀង ចាប់ពីខែ មេសា ឆ្នាំ ១៩៧៧។

## ផ្នែកទី ២. <u>ភស្តុតាងដែលបានបង្ហាញ</u>

### ១. <u>ភស្តុតាងជាសក្ខីកម្ម</u>

១៨៩៧. ក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី ស្តីពីការប្រព្រឹត្តិលើជនជាតិវៀតណាម អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សី ១៣ នាក់[1849] ដើមបណ្តឹងរដ្ឋប្បវេណី ០៧ នាក់[1850] និងអ្នកជំនាញ ០១ រូប[1851]។ លើសពីនេះទៀត សាក្សីមួយចំនួនទៀតត្រូវបានកោះហៅពាក់ព័ន្ធនឹងផ្នែកផ្សេងទៀត បានផ្តល់សក្ខីកម្មស្តីពីអង្គហេតុនៃការប្រព្រឹត្តិលើជនជាតិវៀតណាម។

---

[1847] សូមមើលខាងលើ កថាខណ្ឌ ១៨៨០, ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៨។

[1848] ដីកាដំណោះស្រាយ កថាខណ្ឌ ២១៤។

[1849] ស៊ាន ស៊ង់, សៅ សាក់, ព្រុំ សារុន, អ៊ុំ ស៊ន់, អ៊ុង សំអ៊ាន, ស៊ិន ឆែម, អ៊ី វុន, ប៉ាក សុខ, ចេង ផល, ព្រុំ សារ៉ាត, អ៊ិន យឿង, សាន់ ឡូន, មាស វឿន។

[1850] ប្រាក់ ខឿន, ជឿង យ៉ាំងចែត, ឡាច គ្រី, ដួង អឿន។ ដើមបណ្តឹងរដ្ឋប្បវេណីបីរូបបានផ្តល់សក្ខីកម្មជាក់លាក់អំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម៖ សៀង ចាន់ធី, ខូង មួយ និង អ៊ុច ស៊ុនឡាយ។

[1851] Alexander HINTON។

១៨៩៨. ក្នុងចំណោមសក្ខីកម្មជាច្រើននេះ មានតែសាក្សី ៥ នាក់គត់ (សាវ សាក់, អ៊ុង សំអៀន, ស៊ិន ឆែម, ថាង ផល និង អ៊ិន យឿង) និងដើមបណ្ដឹងរដ្ឋប្បវេណី ២នាក់ (ឡាច គ្រី និង ដុង អឿន) បានផ្ដល់សក្ខីកម្មស្ដីពីអង្គហេតុដែលបានប្ដឹងមកអង្គជំនុំជម្រះ រួមមាន ការប្រព្រឹត្តិលើជនជាតិវៀតណាមនៅខេត្តព្រៃវែង និងស្វាយរៀង។ ដូច្នេះ មានតែសក្ខីកម្មទាំងនេះប៉ុណ្ណោះ ដែលមានភាពពាក់ព័ន្ធសម្រាប់ការពិនិត្យភ័ស្ដុតាង។

## ២. ភ័ស្ដុតាងជាឯកសារ

១៨៩៩. ពាក់ព័ន្ធនឹងភ័ស្ដុតាងជាឯកសារ សក្ខីកម្មជាលាយលក្ខណ៍អក្សរមួយចំនួនមាននៅក្នុងសំណុំរឿង ដូចជា កំណត់ហេតុស្ដាប់ចម្លើយសាក្សីចំនួន ៣៧ យកចេញពីសំណុំរឿង ០០២ កំណត់ហេតុស្ដាប់ចម្លើយសាក្សីចំនួន ៦៨ យកចេញពីសំណុំរឿង ០០៣ និង ០០៤ ប្រតិចារឹកមួយចំនួននៃសំណុំរឿង ០០២/០១ រួមទាំង បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

១៩០០. ក្រៅពីសក្ខីកម្មមុនៗរបស់សាក្សីដែលបានចូលមកបង្ហាញខ្លួន ដីកាដំណោះស្រាយបានស្រង់យ៉ាងហោចណាស់សក្ខីកម្មជាលាយលក្ខណ៍អក្សរចំនួន ១៥ ពាក់ព័ន្ធនឹងអង្គហេតុស្ដីពីជនជាតិវៀតណាមនៅខេត្តព្រៃវែង[1852] និងចំនួន ០៥ ប៉ុណ្ណោះ ពាក់ព័ន្ធនឹងអង្គហេតុស្ដីពីជនជាតិវៀតណាមនៅខេត្តស្វាយរៀង[1853]។ សក្ខីកម្មជាលាយលក្ខណ៍អក្សរផ្សេងទៀត រួមទាំងកំណត់ហេតុស្ដាប់សម្លើយសាក្សីចំនួន ៦៨ ដែលចេញមកពីសក្ខីកម្ម ក្នុងសំណុំរឿង ០០៣ និង ០០៤ លើកឡើងពីអង្គហេតុប្រព្រឹត្តទៅនៅក្រៅខេត្តទាំងពីរនេះ ដូច្នេះ មិនមានភាពពាក់ព័ន្ធ ដើម្បីដាក់បន្ទុកលើជនជាប់ចោទឡើយ។

១៩០១. អង្គជំនុំជម្រះក៏ត្រូវប្រុងប្រយ័ត្នផងដែរ ចំពោះប្រភពយោងនៃដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងការកាប់សម្លាប់ជនជាតិវៀតណាម នៅខេត្តព្រៃវែង និងស្វាយរៀង ដូចបានចោទប្រកាន់។ ជាក់ស្ដែង

---

[1852] ដីកាដំណោះស្រាយ កថាខណ្ឌ ៧៩៧ ដល់កថាខណ្ឌ ៨០០។

[1853] ដីកាដំណោះស្រាយ កថាខណ្ឌ ៧៩៧ កថាខណ្ឌ ៨០១។

កំណត់ហេតុស្លាប់ចម្លើយខ្លះលើកឡើងពីអង្គហេតុនៅក្រៅខេត្តទាំងពីរនេះ ដូច្នេះ មិនមានជាប់ពាក់ព័ន្ធទាល់តែសោះជាមួយអង្គហេតុរងការចោទប្រកាន់[1854]។

១៩០២. ពាក់ព័ន្ធនឹងភ័ស្តុតាងជាឯកសារផ្សេងទៀត គឺមានតិចតួចណាស់ដែលបានលើកឡើងពីការប្រព្រឹត្តិលើជនជាតិវៀតណាម នៅខេត្តព្រៃវែង និងស្វាយរៀង។ ចំពោះឯកសារជាទូទៅ យើងគួរងាកទៅរករបាយការណ៍ផ្សេងៗស្តីពីទិន្នន័យប្រជាសាស្ត្រ ពាក់ព័ន្ធនឹងប្រជាជនវៀតណាមនៅក្នុងប្រទេសកម្ពុជា (ក) រួមទាំងងាកទៅរកសារណាមួយ ដែលបានស្រង់ដោយសហព្រះរាជអាជ្ញា (ខ)។

## ក. ភ័ស្តុតាងអំពីទិន្នន័យប្រជាសាស្ត្រ

១៩០៣. ក្នុងចំណោមទិន្នន័យប្រជាសាស្ត្រដែលបានដាក់បញ្ចូលក្នុងសំណុំរឿង ជាបឋម យើងគួរត្រឡប់ទៅរករបាយការណ៍មួយរបស់ Ewa TABEAU ដែលបានទទួលយកជាភ័ស្តុតាង ដោយមានលេខកូដ E3/2413 (១) ជាមុនសិន មុននឹងផ្តោតទៅលើទិន្នន័យប្រជាសាស្ត្រដទៃទៀត (២)។

### 1. របាយការណ៍របស់ Ewa TABEAU

១៩០៤. នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានដកស្រង់របាយការណ៍កោសល្យវិច័យប្រជាសាស្ត្រមួយ ដែលរៀបរៀងឡើងដោយ Ewa TABEAU និង ថី ឃៀម[1855]។ ជាក់ស្តែង របាយការណ៍នេះ គ្រាន់តែជាការចងក្រងបញ្ចូលគ្នានូវទិន្នន័យស្ថិតិ និងប្រជាសាស្ត្រ របស់អ្នកនិពន្ធផ្សេងៗទៀត។ គឺដោយផ្អែកលើរបាយការណ៍នេះហើយ ដែលសហចៅក្រមស៊ើបអង្កេតបានទាញចេញនូវសេចក្តីសន្និដ្ឋានអំពីការវិវត្តប្រជាសាស្ត្រនៃប្រជាជនវៀតណាមរស់នៅប្រទេសកម្ពុជា ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ សហចៅក្រមស៊ើបអង្កេតបានដក់ស្រង់ ជាពិសេស នូវសេចក្តីសន្និដ្ឋាននៃរបាយការណ៍នោះ ដោយថ្លែងថា៖

---

[1854] ឧទាហរណ៍៖ ដីកាដំណោះស្រាយ កថាខណ្ឌ ៧៩៧ កំណត់សម្គាល់ចុងឯកសារ ៣៣៩៨ កថាខណ្ឌ ៧៩៨ កំណត់សម្គាល់ចុងឯកសារ ៣៣៩៩-៣៤០១។

[1855] ដីកាដំណោះស្រាយ កថាខណ្ឌ ៧៩២។

"អ្នកនិពន្ធរបាយណ៍បានសន្និដ្ឋានថា ប្រជាជនវៀតណាមប្រហែល ២០ ០០០ នាក់ កំពុងរស់នៅនៅឡើយលើទឹកដីខ្មែរ នៅខែ មេសា ឆ្នាំ ១៩៧៥ ហើយជាទូទៅ ត្រូវបានសម្លាប់ទាំងអស់ ដោយពួកខ្មែរក្រហម នៅចន្លោះខែ មេសា ឆ្នាំ ១៩៧៥ និងខែ មករា ឆ្នាំ ១៩៧៩"[1856]។

១៩០៥. ក្នុងអំឡុងពេលស៊ើបសួរ របាយការណ៍នេះទទួលរងនូវការរិះគន់ជាច្រើន ជាពិសេស ទៅលើវិធីសាស្ត្រ និងគុណវុឌ្ឍិ របស់ Ewa TABEAU។

១៩០៦. គឺក្រុមមេធាវីការពារក្តី នួន ជា ជាអ្នកស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឱ្យចាត់តាំងអ្នកជំនាញប្រជាសាស្ត្រ ដើម្បីកំណត់ចំនួនអ្នកស្លាប់ដោយសារឧក្រិដ្ឋកម្មប្រព្រឹត្តដោយពួកខ្មែរក្រហម[1857]។ ទន្ទឹមនឹងនោះដែរ ក្រុមមេធាវីការពារក្តីបានស្នើសុំឱ្យមានការពិគ្រោះជាមួយភាគីទាំងអស់ជាមុនសិន មុននឹងធ្វើការចាត់តាំង[1858]។ សហចៅក្រមស៊ើបអង្កេតបានយល់ព្រមចំពោះសំណើសុំធ្វើកោសល្យវិច័យនេះ និងបានចាត់តាំង Ewa TABEAU និង ថឺ យៀន ឱ្យបំពេញការងារមួយនេះដោយមិនបានពិគ្រោះយោបល់ជាមួយភាគីឡើយ[1859]។ របាយការណ៍កោសល្យវិច័យនេះ បានដាក់នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩។

១៩០៧. ក្រោយពេលដាក់របាយការណ៍នេះ ក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី បានលើកឡើងពីចំណុចខ្សោយជាច្រើនលើផ្នែកវិធីសាស្ត្រ និងជាពិសេស ពីអសមត្ថភាពរបស់ Ewa TABEAU ដោយយោងទៅលើការងារកន្លងទៅជាច្រើនរបស់គាត់ នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិប្រទេសយូហ្គោស្លាវី ព្រមទាំងពីកង្វះអនាគតិរបស់អ្នកជំនាញ និងដោយមូលហេតុទាំងនេះ បានស្នើសុំឱ្យមានការធ្វើកោសល្យវិច័យបញ្ច្រាស ដោយរិះគន់ពីការមិនបានពិគ្រោះយោបល់ភាគីទាំង

---

[1856] ដីកាដំណោះស្រាយ កថាខណ្ឌ ៧៩២។

[1857] សំណើលើកទី ៦ សុំបើកកិច្ចស៊ើបអង្កេត របស់ នួន ជា ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **D113**។

[1858] សំណើលើកទី ៦ សុំបើកកិច្ចស៊ើបអង្កេត របស់ នួន ជា ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **D113** កថាខណ្ឌ ១០។

[1859] ដីកាចាត់តាំងអ្នកជំនាញ របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ឯកសារ **D140**។

អស់ជាមុន[1860]។ សំណើសុំទាំងអស់នេះត្រូវបានបដិសេធចោល ដោយសហចៅក្រមស៊ើបអង្កេត[1861] បន្ទាប់មក ដោយអង្គបុរេជំនុំជម្រះ[1862]។

១៩០៨. ក្នុងអំឡុងពេលជំនុំជម្រះសំណុំរឿង ០០២/០១ ក្រុមមេធាវីការពារក្តី អៀង សារី បានជំទាស់នឹងសំណើសុំរបស់សហព្រះរាជអាជ្ញាឱ្យ Ewa TABEAU ចូលមកបង្ហាញខ្លួន ក្នុងឋានៈជាអ្នកជំនាញ[1863]។

១៩០៩. បន្ទាប់ពីមានការបំបែកបទចោទ សហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យ Ewa TABEAU ចូលមកបង្ហាញខ្លួន ក្នុងការជំនុំជម្រះសំណុំរឿង ០០២/០២ ដើម្បីស្តាប់សក្ខីកម្មជាអាទិ៍លើផ្នែកពាក់ព័ន្ធនឹងជនជាតិវៀតណាម[1864]។ ចំណែកឯក្រុមមេធាវីការពារក្តីបានជំទាស់ទៅនឹងការចូលមកបង្ហាញខ្លួនរបស់អ្នកជំនាញរូបនេះ ដោយមូលហេតុច្រើនយ៉ាងពាក់ព័ន្ធនឹងវិធីសាស្ត្រ អនាគតិភាព សមត្ថភាព និងចំណេះដឹងមានកម្រិត ឬស្ទើរតែគ្មាន អំពីប្រទេសកម្ពុជា របស់អ្នកជំនាញរូបនេះ[1865]។

---

[1860] សំណើលើកទី ២៦ ស្នើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០ ឯកសារ **D356**, សំណើរបស់លោក អៀង សារី សុំអ្នកជំនាញប្រជាសាស្ត្របន្ថែម ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ **D140/2** កថាខណ្ឌ ១១ ដល់កថាខណ្ឌ ២៣, សំណើរបស់លោក អៀង សារី សុំតែងតាំងអ្នកជំនាញផ្នែកប្រជាសាស្ត្របន្ថែមមួយរូប ដើម្បីធ្វើការពិនិត្យឡើងវិញទៅលើខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញ ដែលបានដាក់ជូនដោយលោកស្រី TABEAU និងលោក ថឺ ឃាម ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ ឯកសារ **D140/7** កថាខណ្ឌ ១៤ ដល់កថាខណ្ឌ ៣៨។

[1861] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១០ ឯកសារ **D356/1** ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ **D140/3** និងចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០ ឯកសារ **D140/8**។

[1862] សាលដីការបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ **D140/4/5** ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ **D140/9/4** និងចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ **D356/2/9**។

[1863] ការជំទាស់របស់លោក អៀង សារី ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ **E9/4/8**។

[1864] បញ្ជីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **E305/6.4** ទំព័រ ៥៧ (ភាសាបារាំង), បញ្ជីរបស់ នួន ជា ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **E305/4.2** ទំព័រ ៤៩។

[1865] សេចក្តីជំទាស់របស់មេធាវីការពារក្តីលោក ខៀវ សំផន ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ **E305/9** កថាខណ្ឌ ៤៥ ដល់កថាខណ្ឌ ៤៨។

១៩១០. ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានជូនដំណឹងជាលើកទីមួយ ដល់ភាគីទាំងអស់ ថាខ្លួនមានបំណងកោះហៅ Ewa TABEAU ឱ្យចូលមកបង្ហាញខ្លួន ដោយដាក់បញ្ចូលឈ្មោះអ្នកជំនាញរូបនេះ ក្នុងបញ្ជីឈ្មោះបុគ្គលដែលត្រូវចូលមកផ្តល់សក្ខីកម្មស្តីពីក្រុមជាក់លាក់[1866]។

១៩១១. រហូតដល់ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ពោលគឺប្រាំថ្ងៃក្រោយពីបានបញ្ចប់ការស្តាប់សក្ខីកម្មសាក្សីពាក់ព័ន្ធនឹងក្រុមជាក់លាក់ ទើបអង្គជំនុំជម្រះបានជូនដំណឹងដល់ភាគី អំពីការទាក់ទងរបស់ខ្លួនជាមួយ Ewa TABEAU ក្នុងគោលបំណងបញ្ជាក់ពីភាពទំនេររបស់គាត់ "ក្នុងករណីដែលអង្គជំនុំជម្រះសម្រេចកោះហៅគាត់ឱ្យចូលមកបង្ហាញខ្លួន"[1867]។ ជាការឆ្លើយតប Ewa TABEAU បានប្រាប់ថា អ្នកស្រីត្រូវការស្រាវជ្រាវបន្ថែម អស់រយៈពេលជាច្រើនខែទៀត ដោយរួមទាំងការធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ដើម្បី "ធ្វើបច្ចុប្បន្នភាពរបាយការណ៍របស់អ្នកស្រី"[1868]។

១៩១២. អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានសួរទៅគ្រប់ភាគីពាក់ព័ន្ធ ថាតើភាគីនៅតែស្នើសុំឱ្យកោះហៅ Ewa TABEAU ឱ្យចូលមកបង្ហាញខ្លួនដដែលដែរឬទេ ដោយលើកឡើងពី "ភាពមិនប្រាកដប្រជាជាក់ស្តែង នៃទិន្នន័យលេខនៅក្នុងរបាយការណ៍"[1869]។

១៩១៣. នៅក្នុងសវនាការថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញា និងក្រុមក្រុមមេធាវីការពារក្តីនួន ជា បានជំទាស់ទៅនឹងសំណើសុំកោះហៅនោះ[1870]។ ដោយអះអាងថាការធ្វើបច្ចុប្បន្នភាពរបាយការណ៍នឹងបង្កភាពយឺតយ៉ាវខ្លាំង សហព្រះរាជអាជ្ញាបានដកស្រង់សេចក្តីសង្កេតរបស់អង្គជំនុំជម្រះ ដែលថា "គ្រប់ការវិភាគប្រជាសាស្ត្រ បង្កប់ទៅដោយកត្តាមិនប្រាកដប្រជាផ្សេងៗ"។ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាបានលើកឡើងពីអ្វីដែលមនុស្សទូទៅបានដឹងរួចមកហើយ ចាប់តាំងពី

---

[1866] អ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ មានចំណងជើង "ការវិភាគបន្ថែម - ការប្រព្រឹត្តចំពោះក្រុមគោលដៅ" ផ្ញើនៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៦ វេលាម៉ោង ១០ និង ៥ នាទី ព្រឹក។

[1867] អនុស្សរណៈ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ឯកសារ **E371/2** កថាខណ្ឌ ៦។

[1868] អនុស្សរណៈ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ឯកសារ **E371/2** កថាខណ្ឌ ៦។

[1869] អនុស្សរណៈ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ឯកសារ **E371/2** កថាខណ្ឌ ៨។

[1870] ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារ **E1/468.1** ទំព័រ ១៧-២២ ចន្លោះម៉ោង 09.51.55 ដល់ម៉ោង 10.08.47។

ពេលដាក់របាយការណ៍មកម្ល៉េះ ថារបាយការណ៍នេះមិនមែនជាការងារស្ថិតិចំតែម្តងនោះទេ តែគ្រាន់តែជាការចងក្រងបញ្ចូលគ្នានូវការវិភាគផ្សេងៗរបស់អ្នកនិពន្ធដទៃទៀត[1871]។

១៩១៤. ក្រោយពីសំដែងការសោកស្តាយចំពោះពេលវេលាប្រើប្រាស់ដើម្បីទាក់ទង Ewa TABEAU[1872] ក្រុមមេធាវីការពារក្តី នួន ជា បានរំលឹកពីការរិះគន់ទៅលើរបាយការណ៍ និងលើរូបអ្នកជំនាញដែលខ្លួនមានបំណងស្នើឱ្យកោះហៅ ដើម្បីរិះគន់វិធីសាស្ត្ររបស់គាត់[1873]។ ដោយសង្កត់ធ្ងន់ទៅលើទំហំបញ្ហានៃចំនួនអ្នកស្លាប់ មុន អំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យកោះហៅ Patrick HEUVELINE ជំនួសឱ្យលោកស្រី Ewa TABEAU[1874]។

១៩១៥. ចំណែកឯក្រុមមេធាវីការពារក្តី បានរំលឹកពីការជំទាស់របស់ខ្លួន ទៅនឹងការកោះហៅលោកស្រី Ewa TABEAU[1875] ដែលតម្រូវការធ្វើបច្ចុប្បន្នភាពរបាយការណ៍របស់លោកស្រីកាន់តែបង្កើនភាពសង្ស័យចំពោះវិធីសាស្ត្ររបស់គាត់ បន្ថែមពីលើភាពមិនប្រាកដប្រជាជុំវិញទិន្នន័យប្រជាសាស្ត្រដែលបានប្រើប្រាស់ ដូចអង្គជំនុំជម្រះ និងសហព្រះរាជអាជ្ញាបានលើកឡើង[1876]។ ក្រុមមេធាវីការពារក្តីប្រកាន់យ៉ាងរឹងមាំនូវសេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្នុងសារណានេះថា ដោយគ្មានសក្ខីកម្មរបស់អ្នកជំនាញ Ewa TABEAU អង្គជំនុំជម្រះនឹងអាចត្រឹមតែផ្តល់តម្លៃជាភស្តុតាងតិចតួចបំផុតដល់ដល់របាយការណ៍ E3/2413 របស់លោកស្រី[1877]។

---

[1871] ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារ **E1/468.1** ទំព័រ ១៧-១៨ ចន្លោះម៉ោង 09.51.55 ដល់ម៉ោង 09.54.01។

[1872] ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារ **E1/468.1** ទំព័រ ១៨-២១ ចន្លោះម៉ោង 09.54.01 ដល់ម៉ោង 10.03.50, សំណើរបស់ នួន ជា ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ឯកសារ **E371**។

[1873] ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារ **E1/468.1** ទំព័រ ១៨-២០ ចន្លោះម៉ោង 09.54.01 ដល់ម៉ោង 09.59.57។

[1874] ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារ **E1/468.1** ទំព័រ ២១-២២ ចន្លោះម៉ោង 10.03.50 ដល់ម៉ោង 10.08.57។

[1875] ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារ **E1/468.1** ទំព័រ ៣២ ចន្លោះម៉ោង 10.34.23 ដល់ម៉ោង 10.36.55។

[1876] Dale LYSAK : ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារ **E1/468.1** ទំព័រ ១៧-១៨ ចន្លោះម៉ោង 09.51.55 ដល់ម៉ោង 09.54.01, អនុស្សរណៈរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ឯកសារ **E371/2** កថាខណ្ឌ ៨។

[1877] ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារ **E1/468.1** ទំព័រ ៣២ ចន្លោះម៉ោង 10.34.23 ដល់ម៉ោង 10.36.55។

១៩១៦. តាមរយៈអ៊ីមែល ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគី ថាខ្លួននឹងមិនកោះហៅ Ewa TABEAU ឱ្យចូលមកបង្ហាញខ្លួនទេ[1878]។ បើទោះបីជាសហព្រះរាជអាជ្ញាបានលើកសំអាងហេតុ ក្នុងន័យការពារការប្រើប្រាស់របាយការណ៍នេះ ដោយហេតុផលថា "ទិន្នន័យត្រូវបានប្រមូលសម្រាប់អង្គជំនុំជម្រះ ហើយទិន្នន័យទាំងនេះ ទទួលបានការពន្យល់រួចហើយ"[1879] យើងគួរកត់សម្គាល់ថា ការកោះហៅនេះមិនមែនអត់ប្រយោជន៍សោះនោះទេ។ ជាក់ស្តែង Ewa TABEAU មិនអាចត្រូវបានសួរដេញដោលដោយភាគី អំពីវិធីសាស្ត្រ ឬ ប្រភព និងកាន់តែមិនអាចសួរបានទៀត ពីមូលហេតុដែលគាត់បានអះអាងថាត្រូវធ្វើការស្រាវជ្រាវបន្ថែមអស់រយៈពេលជាច្រើនខែថែមទៀត។ ចំណុចចុងក្រោយនេះផ្ទាល់ គ្រប់គ្រាន់ល្មមអាចឱ្យយើងវាយតម្លៃបានថា ស្របតាមការសារភាពរបស់អ្នកនិពន្ធផ្ទាល់ខ្លួន របាយការណ៍របស់គាត់មានភាពខ្វះខាតច្រើន ដែលនឹងមិនអាចក្លាយជាធាតុផ្សំភ័ស្តុតាងគួរឱ្យទុកចិត្តបានឡើយ។

១៩១៧. អាស្រ័យហេតុនេះ តួលេខនៅក្នុងដីកាដំណោះស្រាយ ស្តីពីចំនួនប្រជាជនវៀតណាមរស់នៅក្នុងប្រទេសកម្ពុជា នៅឆ្នាំ ១៩៧៥ និងការណ៍ដែលថាគ្មានជនជាតិវៀតណាមណាម្នាក់សោះរស់នៅប្រទេសកម្ពុជា នៅចុងរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចបង្ហាញបានដោយអង្គជំនុំជម្រះ ដោយផ្អែកលើរបាយការណ៍នេះ។

## 2. <u>គ្មានទិន្នន័យប្រជាសាស្ត្រដែលអាចទុកចិត្តបានផ្សេងទៀត</u>

១៩១៨. បើទោះបីជាគ្មានព័ត៌មានពាក់ព័ន្ធនឹងទិន្នន័យប្រជាសាស្ត្រនៅប្រទេសកម្ពុជា មុន ក្នុងអំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ អ្នកនិពន្ធមួយចំនួនមានការចាប់អារម្មណ៍ទៅលើទិន្នន័យទាំងនេះ ដោយធ្វើការស្រាវជ្រាវអំពីខ្មែរក្រហម។ ជាក់ស្តែង លោក Patrick HEUVELINE បានតាក់តែងអត្ថបទជាច្រើនស្តីពីចំនួនសន្មតនៃអ្នកស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលអត្ថបទចុងក្រោយបានចេញផ្សាយនៅឆ្នាំ ២០១៥ (E3/10764) និងអត្ថបទពីរផ្សេងទៀត ចុះកាលបរិច្ឆេទឆ្នាំ ១៩៩៨ (E3/1798 និងE3/1799)។

---

[1878] អ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ មានចំណងជើង "កាលវិភាគសវនាការ ក្រោយពីឈប់សម្រាកបុណ្យភ្ជុំបិណ្ឌ" ផ្ញើនៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ វេលាម៉ោង ២ និង ៦ នាទី រសៀល។

[1879] ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារ **E1/468.1** ទំព័រ ៣៨ ចន្លោះម៉ោង 10.52.21 ដល់ម៉ោង 10.53.50។

១៩១៩. ដោយបដិសេធសំណើរបស់ នួន ជា សុំឱ្យកោះហៅ Patrick HEUVELINE ក្នុងឋានៈជាអ្នកជំនាញ[1880] អង្គជំនុំជម្រះបានចាត់ទុកអត្ថបទរបស់ Patrick HEUVELINE ថាមានតម្លៃជាភស្តុតាងតិចតួចខ្លាំង ដោយសារហេតុផលដូចគ្នាទៅនឹងរបាយការណ៍របស់ Ewa TABEAU។

១៩២០. ម្យ៉ាងទៀត មូលហេតុនៃសេចក្តីសម្រេច ដើរស្របនឹងន័យនេះប្រាកដណាស់ ព្រោះថា អង្គជំនុំជម្រះបានថ្លែងថា អ្នកជំនាញប្រជាសាស្ត្រម្នាក់ "មិនអាចនាំទៅរកការផ្តល់ភស្តុតាងនៃអង្គហេតុពាក់ព័ន្ធតាមផ្លូវច្បាប់បានទេ នៅក្នុងករណីនេះ និងក៏មិនអាចជួយអង្គជំនុំជម្រះធ្វើការវាយតម្លៃពីចំនួនពិតប្រាកដរបស់អ្នកស្លាប់ ដែលគេទម្លាក់ការទទួលខុសត្រូវទៅលើរបបកម្ពុជាប្រជាធិបតេយ្យបានដែរ"[1881] ដោយគូសបញ្ជាក់ថា មិនចាំបាច់វិនិច្ឆ័យពីចំនួនអ្នកស្លាប់ ដើម្បីកំណត់ទំនួលខុសត្រូវរបស់ជនជាប់ចោទឡើយ[1882]។ សេចក្តីសម្រេចនេះបានដកស្រង់ឡើករណ៍លើកឡើងដោយចៅក្រម Juge FENZ ក្នុងសវនាការ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ ស្តីពីការចូលមកបង្ហាញខ្លួនរបស់ Ewa TABEAU[1883] ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា[1884] និងរបស់ដើមបណ្តឹងរដ្ឋប្បវេណី[1885]។ បើផ្អែកលើសេចក្តីសម្រេចទាំងនេះ ជំហររបស់អង្គជំនុំជម្រះហាក់ដូចជាស្របគ្នាទៅនឹងជំហររបស់ក្រុមមេធាវីការពារក្តី ដែលប្រកាន់ជំហរថា គេអាចត្រឹមតែផ្តល់តម្លៃជាភស្តុតាងតិចតួច ដល់តួលេខដែលបានមកពីការស្រាវជ្រាវមិនពេញលេញ និងទិន្នន័យមិនអាចទុកចិត្តបាន។

១៩២១. ទន្ទឹមនឹងនេះ យើងគួរកត់សម្គាល់ថា ជំហររបស់អង្គជំនុំជម្រះមិនច្បាស់លាស់ទាល់តែសោះ។ ជាក់ស្តែង ក្នុងការឆ្លើយតបទៅនឹងសំណើដែលទំនងជាបានស្នើឡើងដោយអង្គជំនុំជម្រះ Ewa TABEAU បានគូសបញ្ជាក់ថា អង្គជំនុំជម្រះព្យាយាម "បង្ហាញពីអត្ថិភាពនៃអ្នកស្លាប់ជាជនជាតិវៀតណាម និងចាម ដែលទំនងជាមានចំនួនច្រើនជាងនេះ នៅក្នុងរបបខ្មែរក្រហម" និងចង់៖

---

[1880] សេចក្តីសម្រេច ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៦ឯកសារ **E444/1**។

[1881] សេចក្តីសម្រេច ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៦ឯកសារ **E444/1** កថាខណ្ឌ ២៤។

[1882] សេចក្តីសម្រេច ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៦ឯកសារ **E444/1** កថាខណ្ឌ ២១។

[1883] ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារ **E1/468.1** ទំព័រ ២៣ ក្រោយម៉ោង 10.08.47 ទំព័រ ២4 ក្រោយម៉ោង 10.12.44។

[1884] ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារ **E1/468.1** ទំព័រ ២៩-៣០ ចន្លោះម៉ោង 10.27.03 ដល់ម៉ោង 10.31.22។

[1885] ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ឯកសារ **E1/468.1** ទំព័រ ៣០-៣១ ចន្លោះម៉ោង 10.31.22 ដល់ម៉ោង 10.34.23។

> "ដឹងឱ្យបានជាក់លាក់ ថាតើព័ត៌មានស្ថិតិថ្មីៗទាំងនេះ នៅមានដល់សព្វថ្ងៃដែរឬទេ សម្រាប់រយៈពេលនៅចន្លោះជំរឿនឆ្នាំ១៩៦២ និងជំរឿនឆ្នាំ១៩៩៨ ដើម្បីអាចកំណត់បរិមាណនៃចំនួនអ្នកស្លាប់ច្រើនជាងជាយថាហេតុ ក្នុងចំណោមជនជាតិវៀតណាម និងចាម ប្រកបដោយភាពច្បាស់លាស់កម្រិតខ្ពស់ ដូចរបាយការណ៍ដំបូងរបស់ខ្ញុំដែរ"[1886]។

១៩២២. ដូច្នេះ ចម្លើយនេះបង្ហាញថា ផ្ទុយពីការអះអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ឯកសារ E444/1 អង្គជំនុំជម្រះបានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើទិន្នន័យតួលេខស្តីពីចំនួនជនរងគ្រោះជាជនជាតិវៀតណាម និងចាម។ ជាងនេះទៅទៀត ថ្វីបើចំនួនជនរងគ្រោះមិនអាចខ្វះបាន ដើម្បីកំណត់អត្ថិភាពនៃអំពើប្រល័យពូជសាសន៍ គេត្រូវបង្ហាញជាដាច់ខាត ពីចេតនាកម្ទេចយ៉ាងហោចណាស់មួយផ្នែកធំនៃក្រុមដែលជាមុខសញ្ញា[1887]។ អាស្រ័យហេតុនេះទិន្នន័យប្រជាសាស្ត្រអំពីចំនួនជនជាតិវៀតណាម ជាពិសេស នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង ដែលជាការដាក់បន្ទុកអំពីបទប្រល័យពូជសាសន៍ ទំនងជាមានសារៈប្រយោជន៍ដល់ការពិភាក្សា។

១៩២៣. ទន្ទឹមនឹងនេះ អង្គជំនុំជម្រះមិនមានជម្រើសផ្សេងក្រៅពីកត់សម្គាល់ពី "អនិត្តិភាពនៃទិន្នន័យស្ថិតិពាក់ព័ន្ធ និងអាចទុកចិត្តបាន សម្រាប់កំណត់តួលេខឱ្យបានច្បាស់លាស់ពីចំនួនអ្នកស្លាប់ ដែលទំនងជាបង្កឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ"[1888]។ អង្គជំនុំជម្រះត្រូវទាញសេចក្តីសន្និដ្ឋានចេញពីកំណត់សម្គាល់នេះ។ ដោយទទួលស្គាល់ថា "ទិន្នន័យប្រជាសាស្ត្រដែលមានស្រាប់ ស្តីពីក្រុមជាក់លាក់ បង្ហាញពីភាពមិនប្រាកដប្រជា ដូចទិន្នន័យប្រជាសាស្ត្រទាំងមូលដែរ"[1889] អង្គជំនុំជម្រះត្រូវបង្ខំចិត្តផ្តល់តម្លៃជាភ័ស្តុតាងតិចតួច ដល់ទិន្នន័យទាំងនេះ ដែលតម្លៃជាភ័ស្តុតាងនេះកាន់តែមានកម្រិតថែមទៀត ខណៈដែលមិនមានអ្នកនិពន្ធណាម្នាក់បានចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនោះ។

---

[1886] អនុស្សរណៈ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ឯកសារ **E371/2** កថាខណ្ឌ ៦ (សម្តីដកស្រង់របស់ Ewa TABEAU)។

[1887] សូមមើលខាងលើ កថាខណ្ឌ ១៨២០ ដល់កថាខណ្ឌ ១៨២១។

[1888] សេចក្តីសម្រេច ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៦ឯកសារ **E444/1** កថាខណ្ឌ ២២។

[1889] សេចក្តីសម្រេច ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៦ឯកសារ **E444/1** កថាខណ្ឌ ២៥។

១៩២៤. ដូច្នេះ អង្គជំនុំជម្រះនអាចទាញសេចក្តីសន្និដ្ឋានអំពីចំនួនជនរងគ្រោះជាជនជាតិវៀតណាមបាន ដោយធ្វើការសិក្សាអំពីភ័ស្តុតាងមួយករណីម្តងៗតែប៉ុណ្ណោះ។

## ខ. សារណារបស់សាកលវិទ្យាល័យ

១៩២៥. ឯកសារនេះគួរតែត្រូវលើកយកមកពិនិត្យ ដោយសារវាត្រូវបានដកស្រង់ដោយសហព្រះរាជអាជ្ញា ក្នុងអំឡុងពេលនៃសវនាការអំពីឯកសារគន្លឹះស្តីពីក្រុមជាក់លាក់[1890]។ Elizabeth DO ជាអ្នកនិពន្ធសារណាមួយអំពីសង្គមវិទ្យា ដែលមានកម្រាស់ប្រហែល ៧០ ទំព័រ ដែលលោកស្រីបានសរសេរកាលលោកស្រីនៅជានិស្សិតនៃសាកលវិទ្យាល័យ Stanford ក្នុងគោលបំណងធ្វើការសិក្សាប្រៀបធៀបរវាងការប្រព្រឹត្តិលើជនជាតិខ្មែរ និងលើជនជាតិវៀតណាម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[1891]។ ចំពោះបញ្ហាវិធីសាស្ត្រ លោកស្រីពន្យល់ថា លោកស្រីបានចុះសិក្សានៅមូលដ្ឋានផ្ទាល់ជាពិសេស នៅក្នុងភូមិភាគបូព៌ា ដោយមានជំនួយពីមជ្ឈមណ្ឌលឯកសារកម្ពុជា លោកស្រីបានស៊ើបសួរមនុស្សជាច្រើន ដែលភាគច្រើនមកពីភូមិពោធិចិន្តាំ។ លោកស្រីបានបញ្ជាក់ផងដែរ ថាបានវិភាគឯកសារសម័យនោះ និងសំណេររបស់អ្នកនិពន្ធដទៃទៀតស្តីពីរបបខ្មែរក្រហម[1892]។

១៩២៦. តម្លៃជាភ័ស្តុតាង និងភាពអាចទុកចិត្តបាននៃព័ត៌មាននានា ដែលចងក្រងដោយអ្នកនិពន្ធរូបនេះចោទជាបញ្ហាយ៉ាងខ្លាំង។ ជាក់ស្តែង ថ្វីបើឯកសារឧបសម្ព័ន្ធខ្លះបាននិយាយលម្អិតពីចំនួនមនុស្សដែលបានសម្ភាសន៍ និងសំណួរដែលបានចោទសួរ ខ្លឹមសារនៃសារណា គឺជាការសំយោគនៃបទសម្ភាសន៍ទាំងនេះ និងសៀវភៅផ្សេងៗរបស់អ្នកនិពន្ធឯទៀត[1893]។ ដូច្នេះ នៅពេលលោកស្រីលើកឡើងពីការសម្លាប់រង្គាលជនជាតិវៀតណាម តាមការសន្មត គេមិនអាចធ្វើការផ្ទៀងផ្ទាត់ពីប្រភពនៃការអះអាងនេះទេ ព្រោះថា គ្មានបទសម្ភាសន៍ជាក់លាក់ណាមួយ ឬប្រភពផ្សេងណាមួយបាន

---

[1890] ប្រតិចារឹក ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ឯកសារ **E1/390.1** ទំព័រ ៥០-៥៦ ចន្លោះម៉ោង 14.12.03 ដល់ម៉ោង 14.30.55។

[1891] Elizabeth DO៖ ការប្រព្រឹត្តិចំពោះជនជាតិភាគតិចវៀតណាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីទស្សនៈវិស័យប្រៀបធៀប **E3/4524** ("សារណារបស់ Elizabeth DO ឯកសារ **E3/4524**") ERN KH 00768920។

[1892] សារណារបស់ Elizabeth DO ឯកសារ **E3/4524**, ERN KH 00768933។

[1893] សារណារបស់ Elizabeth DO ឯកសារ **E3/4524**, ERN KH 00768978-00768984។

បញ្ជាក់ ក្រៅពីមានបញ្ជាក់ជាទូទៅថា "អ្នកផ្តល់ព័ត៌មាន"[1894]។ ដូច្នេះ ក្រៅពីឯកសារយោងជាសៀវភៅ គេមិនអាចផ្ទៀងផ្ទាត់ប្រភពដើមនៃឯកសារយោងរបស់ Elizabeth DO បានឡើយ។

១៩២៧. ម៉្យាងទៀត សារណានេះទំនងជាមិនអាចអះអាងបង្ហាញពីការរើសអើង ឬចេតនាប្រល័យពូជសាសន៍ ចំពោះជនជាតិវៀតណាមឡើយ ព្រោះថា សេចក្តីសន្និដ្ឋានផ្ទាល់របស់ Elizabeth DO ដ៏គួរឱ្យទុកចិត្តបានតិចតួច បង្ហាញឱ្យឃើញថា លោកស្រីបានបកស្រាយទិន្នន័យ បញ្ច្រាសទៅនឹងលទ្ធផលទទួលបាន។ ជាក់ស្តែង បន្ទាប់ពីបានលើកឡើងថា អ្នកផ្តល់ព័ត៌មាន ៦៧% មិនគិតថាជនជាតិខ្មែរ និងជនជាតិវៀតណាម ទទួលរងនូវការប្រព្រឹត្តិខុសគ្នានៅក្នុងភូមិរបស់គេទេ[1895] លោកស្រីកត់សម្គាល់ថា "ទិន្នន័យងាកទោរទៅចង្អុលបង្ហាញថា គ្មានភាពខុសគ្នាជាក់ស្តែង រវាងការប្រព្រឹត្តិប្រចាំថ្ងៃជាទូទៅទេ ទៅលើជនជាតិវៀតណាម និងទៅលើជនជាតិខ្មែរ"។ ក៏ប៉ុន្តែលោកស្រីបានអះអាងថា ទំនងជាមាន "តម្រុយនៃការប្រព្រឹត្តិខុសគ្នា" ជាមួយការពិពណ៌នាយ៉ាងវែងអន្លាយ ដោយគ្មានយោងប្រភពឯកសារណាឡើយ[1896]។

១៩២៨. ទោះជាយ៉ាងណាក្តី ដោយមិនបានចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ភាគីទាំងអស់មិនបានចោទសួរដោយផ្ទាល់ទៅកាន់អ្នកនិពន្ធ អំពីវិធីសាស្ត្រ និងប្រភពរបស់គាត់។ ជាពិសេស ដូចក្រុមក្រុមមេធាវីការពារក្តីបានបញ្ជាក់រួចហើយទៅកាន់អង្គសវនាការ កម្រិតស្រាវជ្រាវរបស់និស្សិតស្រីរូបនេះ ដែលមិនទាន់ដល់កម្រិតនិក្ខេបបទផងនោះ មិនអាចឱ្យអង្គជំនុំជម្រះផ្តល់តម្លៃជាភ័ស្តុតាងណាមួយ ដល់សារណានេះ និងកាន់តែលែងផ្តល់តម្លៃវិទ្យាសាស្ត្រដល់សេចក្តីសន្និដ្ឋានរបស់គាត់ទៅទៀត[1897]។

## ៣. អន្តរហេតុនៅក្រៅវិសាលភាព

---

[1894] សារណារបស់ Elizabeth DO ឯកសារ **E3/4524**, ERN KH 00768962-00768965។

[1895] សារណារបស់ Elizabeth DO ឯកសារ **E3/4524**, ERN KH 00768967-00768969។

[1896] សារណារបស់ Elizabeth DO ឯកសារ **E3/4524**, ERN KH 00768967-00768969។

[1897] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/392.1** ទំព័រ ៣១-៣២ ចន្លោះម៉ោង 10.48.04 ដល់ម៉ោង 10.51.26។

១៩២៩. មុននឹងព្យាយាមពិនិត្យអង្គហេតុឱ្យបានលម្អិត យើងគួរលើកឡើងនូវអង្គហេតុទាំងឡាយ ដែលមិនបានប្ដឹងមកអង្គជំនុំជម្រះ និងបែរជាត្រូវបានស្ដាប់ក្នុងអំឡុងពេលសវនាការលើអង្គសេចក្ដី ដូចជាអង្គហេតុនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមរូបភាពនៃការបាត់ខ្លួនដោយបង្ខំ (ក) អង្គហេតុនៅក្រៅខេត្តព្រៃវែង និងស្វាយរៀង (ខ) និងអង្គហេតុពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពសាធារណខ្មែរ នៅក្នុងទឹកដីវៀតណាម (គ)។

## ក. អង្គហេតុនៃអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមរូបភាពនៃការបាត់ខ្លួនដោយបង្ខំ)

១៩៣០. ពិតមែនតែអង្គជំនុំជម្រះបានស្ដាប់ឮសាក្សីលើកឡើងពីអង្គហេតុដែលអាចជាធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់នៃការបាត់ខ្លួនដោយបង្ខំ តែអង្គជំនុំជម្រះមិនទទួលបានបណ្ដឹងពីអង្គហេតុទាំងនេះទេ។ ជាក់ស្ដែង បើផ្អែកលើដីកាដំណោះស្រាយ ជនជាប់ចោទត្រូវបានបញ្ជូនខ្លួនទៅចំពោះមុខអង្គជំនុំជម្រះ ពីបទប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់នៃការបាត់ខ្លួនដោយបង្ខំ)[1898] ក៏ពិតមែន តែដីកាបំបែកសំណុំរឿង ដូចបានសង្ខេបនៅក្នុងឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ មិនបានកំណត់យកអង្គហេតុពាក់ព័ន្ធនឹងជនជាតិវៀតណាមទេ[1899]។

១៩៣១. អាស្រ័យហេតុនេះ អង្គជំនុំជម្រះត្រូវតែដកចេញពីកិច្ចពិភាក្សាសម្រេចរបស់ខ្លួន នូវធាតុផ្សំដែលបានទទួល និងបានស្ដាប់រួចហើយ ស្ដីពីអង្គហេតុ ដែល ខៀវ សំផន មិនត្រូវបានចោទប្រកាន់។

## ខ. អង្គហេតុនៅក្រៅខេត្តព្រៃវែង និងស្វាយរៀង

១៩៣២. អង្គជំនុំជម្រះបានសម្រេចស្ដាប់ចម្លើយសាក្សីដែលផ្ដល់សក្ខីកម្មពីអង្គហេតុពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិវៀតណាម នៅក្រៅខេត្តព្រៃវែង និងស្វាយរៀង។ សាក្សីទាំងនេះបានផ្ដល់សក្ខីកម្មអំពីព្រឹត្តិការណ៍ដែលកើតមាននៅក្នុងខេត្តនានា នៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចជាខេត្តសៀមរាប

---

[1898] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧០ ដល់កថាខណ្ឌ ១៤៧៨។

[1899] ឧបសម្ព័ន្ធកំណត់អំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1.1 ទំព័រ ៧។

កំពង់ឆ្នាំង បាត់ដំបង និងតាកែវ[1900]។ លើសពីនេះ អង្គជំនុំជម្រះបានសម្រេចកោះហៅសាក្សីមកផ្តល់សក្ខីកម្មអំពីជោគវាសនាជនជាតិវៀតណាមនៅលើផ្ទៃសមុទ្រ ដែលសក្ខីកម្មរបស់ពួកគេសុទ្ធសឹងចេញមកតែពីសំណុំរឿង ០០៣ និង ០០៤ ស្ទើរតែទាំងអស់[1901]។

១៩៣៣. ពិតមែនតែនៅក្នុងផ្នែកអង្គហេតុនៃដីកាដំណោះស្រាយមានលើកឡើងមួយផ្នែកពីការសម្លាប់រង្គាលលើជនស៊ីវីលវៀតណាមនៅក្រៅខេត្តព្រៃវែង និងស្វាយរៀង[1902] ក៏ដោយ ក៏ប៉ុន្តែ អង្គហេតុទាំងនេះគឺជាលទ្ធផលនៃការពង្រីកមិនប្រក្រតីនៃដែនបណ្តឹងមកកាន់ខ្លួនរបស់សហចៅក្រមស៊ើបអង្កេត[1903]។

១៩៣៤. អង្គជំនុំជម្រះក៏មិនទទួលបានបណ្តឹងពីអង្គហេតុពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិវៀតណាមលើផ្ទៃសមុទ្រដែរ។ ជាក់ស្តែង អង្គហេតុបែបនេះមិនមានលើកឡើងត្រង់ចំណុចណាមួយ នៃដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ឬនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឡើយ ហើយក៏មិនមែនជាកម្មវត្ថុនៃការស៊ើបសួរនៅក្នុងអំឡុងពេលស៊ើបសួរនោះដែរ។ ផ្ទុយពីគោលជំហរប្រកាន់យកដោយអង្គជំនុំជម្រះ នៅក្នុងដីកាកោះហៅសាក្សីរបស់ខ្លួនលើបញ្ហានេះ[1904] ការបញ្ជាក់បែបសាមញ្ញពីធាតុផ្សំភ័ស្តុតាងនៅចុងទំព័រនៃឯកសារ មិនគ្រប់គ្រាន់ដើម្បីពង្រីកដែនបណ្តឹងមកកាន់អង្គជំនុំជម្រះ រហូតដល់អង្គហេតុដែលមិនបានបញ្ជាក់ច្បាស់នៅក្នុងផ្នែកកំណត់បទចោទ

[1900] ខេត្តសៀមរាប៖ ស៊ាន ស៊ង់, អ៊ុំ ស៊ន់ និង អ៊ី វុន ខេត្តកំពង់ឆ្នាំង៖ ប្រាក់ ឌឿន និង ជឿង យ៉ាំងចែត ខេត្តបាត់ដំបង៖ ព្រុំ សារុន ខេត្តតាកែវ៖ សាន់ ឡូន។

[1901] 2-TCW-1000 ព្រុំ សារ៉ាត និង មាស វឿន, សំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E382** កថាខណ្ឌ ៦ ដល់កថាខណ្ឌ ១២, សំណើរបស់ នួន ជា ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E380** កថាខណ្ឌ ៨ ដល់កថាខណ្ឌ ១៥។

[1902] ដីកាដំណោះស្រាយ កថាខណ្ឌ ៨០២ ដល់កថាខណ្ឌ ៨០៥។

[1903] សូមមើលខាងលើ កថាខណ្ឌ ១៨៨១ ដល់កថាខណ្ឌ ១៨៨៥។

[1904] សេចក្តីសម្រេច ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ **E380/2** កថាខណ្ឌ ២១ យោងនៅកំណត់សម្គាល់ជើងទំព័រ ៣៧ ដល់កំណត់សម្គាល់ចុងឯកសារ ៣៤៨៧ កថាខណ្ឌ ៨១៦ នៃដីកាដំណោះស្រាយ (ទូរលេខមួយ)។

នៃដីកាដំណោះស្រាយ[1905] ហើយវាកាន់តែមិនអាចថែមទៀត នៅពេលដែលអង្គហេតុទាំងនេះមិនស្ថិតនៅក្នុងដែនបណ្តឹងមកកាន់សហចៅក្រមស៊ើបអង្កេត[1906]។

១៩៣៥. អង្គជំនុំជម្រះក៏បានសម្រេចកោះហៅផងដែរ អ្នកជំនាញខាងនរវិទ្យា Alexander HINTON ជាអ្នកនិពន្ធសៀវភៅមានចំណងជើងថា "Why Did They Kill ?"[1907]។ ប៉ុន្តែ អ្នកជំនាញរូបនេះមិនបានផ្តល់កោសល្យវិច័យណាមួយស្តីពីការប្រព្រឹត្តិលើជនជាតិវៀតណាមនៅខេត្តព្រៃវែង និងស្វាយរៀងឡើយ។ ជាក់ស្តែង "អ្នកជំនាញ" ខាងបទប្រល័យពូជសាសន៍រូបនេះ មិនបានធ្វើការសិក្សាបែបនរវិទ្យាណាមួយ នៅក្នុងខេត្តទាំងពីរនេះទេ។ គាត់បានពន្យល់នៅក្នុងសវនាការថា ពិតមែនតែគាត់បានមកកាន់ប្រទេសកម្ពុជាជាច្រើនលើក តែគាត់បានធ្វើការស្រាវជ្រាវដើម្បីសរសេរសៀវភៅរបស់គាត់ នៅក្នុងភូមិមួយក្បែរភ្នំប្រុសភ្នំស្រី ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម តែក្នុងអំឡុងពេលដប់មួយខែ រវាងឆ្នាំ ១៩៩៤ និង ឆ្នាំ ១៩៩៥ ប៉ុណ្ណោះ[1908]។ បន្ទាប់មក គាត់បានធ្វើការស្រាវជ្រាវឯកសារនៅភ្នំពេញរយៈពេលមួយខែ[1909]។

១៩៣៦. ជាមួយគ្នានេះដែរ អ្នកជំនាញរូបនេះបានពន្យល់ថា ទិសដៅសំខាន់នៃការសិក្សារបស់គាត់ គឺដើម្បីស្វែងយល់ថា ហេតុអ្វីបានជាពួកខ្មែរក្រហមសម្លាប់ជនជាតិខ្មែរ[1910]។ នៅពេលផ្តល់សក្ខីកម្ម គាត់បានត្រឹមតែនិយាយត្រួសៗពីជនជាតិចាម និងជនជាតិវៀតណាម ពីរឬបីនាក់ប៉ុណ្ណោះ ដែលពួកគេទំនងជាបានរស់នៅក្នុងតំបន់ដែលគាត់សិក្សា ពោលគឺ នៅតែខេត្តកំពង់ចាមតែមួយគត់[1911]។

---

1905 សូមមើលខាងលើ កថាខណ្ឌ ៨២ ដល់កថាខណ្ឌ ៨៥។

1906 សូមមើលខាងលើ កថាខណ្ឌ ១១០ ដល់កថាខណ្ឌ ១១៣។

1907 សៀវភៅរបស់ Alexander HINTON "ហេតុអ្វីបានជាពួកគេសម្លាប់មនុស្ស?" ឆ្នាំ ២០០៥ ឯកសារ **E3/3346**។

1908 ប្រតិចារឹក ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/401.1** ទំព័រ ៩-១០ ចន្លោះម៉ោង 09.39.38 ដល់ម៉ោង 09.42.32, ប្រតិចារឹក ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/403.1** ទំព័រ ៨៥ ចន្លោះម៉ោង 15.17.29 ដល់ម៉ោង 15.20.30 ទំព័រ ៨៨ ចន្លោះម៉ោង 15.27.09 ដល់ម៉ោង 15.30.00។

1909 ប្រតិចារឹក ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/401.1** ទំព័រ ១១ មុនម៉ោង 09.43.49។

1910 ប្រតិចារឹក ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/401.1** ទំព័រ ៦ មុនម៉ោង 09.31.21, ប្រតិចារឹក ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/403.1** ទំព័រ ៨៤ មុនម៉ោង 15.17.29។

1911 ប្រតិចារឹក ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/402.1** ទំព័រ ១៩-២៣ ចន្លោះម៉ោង 09.55.59 ដល់ម៉ោង 10.09.28។

១៩៣៧. អាស្រ័យហេតុនេះ សក្ខីកម្មរបស់គាត់មិនត្រូវបានពិនិត្យលើផ្នែកពាក់ព័ន្ធនឹងជនជាតិវៀតណាម ព្រោះថាសក្ខីកម្មនេះមិនពាក់ព័ន្ធនឹងខេត្តព្រៃវែង ឬខេត្តស្វាយរៀងឡើយ។ ការបកស្រាយសន្ទរកថាសម័យខ្មែរក្រហម និងការវិភាគពីសៀវភៅផ្សេងៗដែលមានស្រាប់អំពីកម្ពុជាប្រជាធិបតេយ្យ នៅក្នុងការផ្តល់សក្ខីកម្មរបស់គាត់ ត្រូវបានលើកឡើងរួចហើយ នៅក្នុងផ្នែកពាក់ព័ន្ធនៃសេចក្តីសន្និដ្ឋានក្នុងសារណានេះ[1912]។

## គ. អង្គហេតុពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជាលើទឹកដីវៀតណាម

១៩៣៨. ទោះបីមានការជំទាស់ជាច្រើនពីសំណាក់ក្រុមក្រុមមេធាវីការពារក្តី[1913] អង្គជំនុំជម្រះបានយល់ព្រមស្តាប់ការបង្ហាញភ័ស្តុតាងស្តីពីឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជា នៅលើទឹកដីវៀតណាម។ ក៏ប៉ុន្តែ យើងបានរំលឹកថា អង្គហេតុទាំងនេះមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសម្រេចលើអង្គហេតុទាំងនេះបានឡើយ[1914]។

## ផ្នែកទី ៣. ការពិនិត្យលើភ័ស្តុតាងពាក់ព័ន្ធ

១៩៣៩. នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតពុំបានបែងចែកភាពខុសគ្នាចំពោះអង្គហេតុដែលបានកើតឡើងក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀងនោះទេ។ ដើម្បីឱ្យមានភាពច្បាស់លាស់ជាងនេះ គេត្រូវពិនិត្យជាបន្តបន្ទាប់លើភ័ស្តុតាងក្នុងខេត្តព្រៃវែង (១) និងបន្ទាប់មក ភ័ស្តុតាងក្នុងខេត្តស្វាយរៀង (២)។

---

[1912] សូមមើលខាងក្រោម កថាខណ្ឌ ២២២៦ ដល់កថាខណ្ឌ ២២៣៣។

[1913] ប្រតិចារឹក ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/486.1** ទំព័រ ៥៦-៥៧ ចន្លោះម៉ោង 13.54.10 ដល់ម៉ោង 13.55.52 ទំព័រ ៧០ មុនម៉ោង 14.38.42, ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/490.1** ទំព័រ ៣៣ ក្រោយម៉ោង 11.05.33 ទំព័រ ៣៦ មុនម៉ោង 11.17.16 , ប្រតិចារឹក ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/491.1** ទំព័រ ២៣ ក្រោយម៉ោង 10.39.39, ប្រតិចារឹក ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/492.1** ទំព័រ ២៣ មុនម៉ោង 10.40.51, ប្រតិចារឹក ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/494.1** ទំព័រ ៩-១០ ក្រោយម៉ោង 09.30.13។

[1914] សូមមើលខាងលើ កថាខណ្ឌ ២០៤ ដល់កថាខណ្ឌ ២១២។

## ១. ការប្រព្រឹត្តលើជនជាតិវៀតណាមក្នុងខេត្តព្រៃវែង

១៩៤០. នៅក្នុងខេត្តព្រៃវែង ដីកាដំណោះស្រាយបានបង្ហាញពីព្រឹត្តិការណ៍កើតឡើងក្នុងស្រុកចំនួនបី ដោយបានយោងទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបាននិយាយពីទីកន្លែងផ្សេងៗ ក្នុងនោះមានស្រុកពាមរក៍ (ដែលមានភូមិអន្លង់ទ្រា ក្នុងឃុំព្រែកជ្រៃ និងភូមិអង្គរយស ក្នុងឃុំព្រែកអន្ទះ)[1915] ស្រុកព្រៃវែង (ដែលមានភូមិពោធិ៍ចិន្តា[1916] និងភូមិស្វាយអន្ទរ)[1917] ហើយជាចុងក្រោយ គឺស្រុកពារាំង[1918]។

### ក. ស្រុកពាមរក៍

### 1. ការចោទប្រកាន់ពីបទមនុស្សឃាតលើជនជាតិវៀតណាម

### 1.ក. ឃុំព្រែកជ្រៃ

---

[1915] កំណត់ហេតុស្តាប់ចម្លើយ សៅ សាក់ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/7780**, កំណត់ហេតុស្តាប់ចម្លើយ ឯម ប៊ុននីម ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ឯកសារ **E3/7760**, កំណត់ហេតុស្តាប់ចម្លើយ មុំ ឆឹយ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ឯកសារ **E3/7813**, កំណត់ហេតុស្តាប់ចម្លើយ នាង ណាត ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **E3/7779**, កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ៅ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/7761**, កំណត់ហេតុស្តាប់ចម្លើយ ឡង់ ហ៊ែល ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **E3/5251**, ERN KH 00233288, កំណត់ហេតុស្តាប់ចម្លើយ ប៊ុន រើន ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ឯកសារ **E3/7811**, កំណត់ហេតុស្តាប់ចម្លើយ សោម រស់ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/5246**។

[1916] កំណត់ហេតុស្តាប់ចម្លើយ អៀង អុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/9352**, កំណត់ហេតុស្តាប់ចម្លើយ ជុយ គឹមវ៉ា ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/7793**, កំណត់ហេតុស្តាប់ចម្លើយ កុល លឹម ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/5243**, កំណត់ហេតុស្តាប់ចម្លើយ ថេង ហ៊ុយ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/5244**, កំណត់ហេតុស្តាប់ចម្លើយ ស៊ិន ស៊ន់ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/9339**, កំណត់ហេតុស្តាប់ចម្លើយ ឡេង សាម៉េត ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩ឯកសារ **E3/7810**, កំណត់ហេតុស្តាប់ចម្លើយ ឡាច គ្រី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/9340**, កំណត់ហេតុស្តាប់ចម្លើយ ឈួន រី ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ឯកសារ **E3/7891**។

[1917] កំណត់ហេតុស្តាប់ចម្លើយ ឃុន ម៉ុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/7806**។

[1918] កំណត់ហេតុស្តាប់ចម្លើយ យឹម មួយ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ឯកសារ **E3/7783**។

១៩៤១. យោងតាមប្រព័ន្ធកំណត់ព្រំដែនរដ្ឋបាល អន្លង់ទ្រា គឺជាភូមិមួយស្ថិតក្នុងឃុំព្រែកជ្រៃ ស្រុកពាមរក៍ (បច្ចុប្បន្នស្ថិតក្នុងស្រុកកំពង់លាវ) ខេត្តព្រៃវែង តំបន់ ២៤ ភូមិភាគបូព៌ា[1919]។

១៩៤២. សៅ សាក់ គឺជាសាក្សីតែមួយគត់ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទងនឹងការប្រព្រឹត្តលើប្រជាជនវៀតណាម នៅក្នុងភូមិអន្លង់ទ្រា។ គាត់បានផ្តល់សក្ខីកម្មថា ក្រោយឆ្នាំ ១៩៧៥ គឺមានគ្រួសារជនជាតិវៀតណាមបីបួនគ្រួសារប៉ុណ្ណោះដែលរស់ក្នុងភូមិនេះ ក្នុងនោះមានគ្រួសាររបស់គាត់ និងមានពីរគ្រួសារទៀតឈ្មោះ នាង ណាត និង វ៉ាន់ ម៉ៅ[1920]។ ភ័ស្តុតាងផ្សេងទៀតដែលបង្ហាញពីការបាត់ខ្លួនសហព័ទ្ធជនជាតិវៀតណាម និងកូនៗដែលកើតចេញមកពីប្តីប្រពន្ធចម្រុះជាតិសាសន៍ ខ្មែរ-វៀតណាម សម្រាប់បីគ្រួសារផ្សេងទៀត ក្នុងភូមិនេះ គឺកំណត់ហេតុស្តាប់ចម្លើយសាក្សី សោម រស់, ប៊ុន រើន, មុំ ឆឹយ, ឡង់ ហ៊ៃល និង ឯម ប៊ុននីម តែចម្លើយអ្នកទាំងអស់នេះ ពុំស៊ីសង្វាក់គ្នានោះឡើយ។ ភ័ស្តុតាងទាក់ទងនឹងជោគវាសនាជនជាតិវៀតណាមក្នុងភូមិមួយនេះ ត្រូវយកមកពិនិត្យមួយករណីម្តងៗ។

### i. ករណីម្តាយរបស់ សៅ សាក់

១៩៤៣. មុនរបបកម្ពុជាប្រជាធិបតេយ្យ សៅ សាក់ រស់នៅភូមិអន្លង់ទ្រា ដែលជាទីកន្លែងដែលគាត់បានរស់នៅរហូតមកដល់សព្វថ្ងៃ[1921]។ សាក្សីរូបនេះបានពន្យល់ថា ក្នុងចន្លោះឆ្នាំ ១៩៧៥ និង ១៩៧៩ គាត់ពុំដែលបានស្តាប់វិទ្យុ និងពុំដែលបានដឹងព័ត៌មាន អ្វីទាំងអស់ ហើយគាត់បានអះអាងថា ខ្លួនមិនដឹងអ្វីសោះពីគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ ឬ បក្សកុម្មុយនីស្តកម្ពុជា ទាក់ទងនឹងជនជាតិវៀតណាម[1922]។ គាត់ពុំអាចនិយាយពីអ្វីដែលកើតឡើងក្រៅកន្លែងគាត់រស់នៅបានឡើយ[1923]។

[1919] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/362.1** ទំព័រ ៦២ ក្រោយម៉ោង 14.30.08, ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ២០ ប្រហែលម៉ោង 10.08.18។

[1920] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៦៤ ប្រហែលម៉ោង 14.36.37។

[1921] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/362.1** ទំព័រ ៦១ ក្រោយម៉ោង 14.30.08 ទំព័រ ៦៤ ក្រោយម៉ោង 14.34.36, ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ១៥ មុនម៉ោង 09.51.21។

[1922] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/363.1** ទំព័រ ១៦ ក្រោយម៉ោង 09.54.08 ទំព័រ ១៧-១៨ មុនម៉ោង 10.01.15។

[1923] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ**E1/363.1** ទំព័រ ១៥ ក្រោយម៉ោង 09.21.21។

១៩៤៤. សៅ សាក់ ថ្លែងថា ម្តាយគាត់ជាកូនកាត់វៀតណាម ហើយម្តាយគាត់មិនបានទទួលរងការធ្វើបាប ឬក៏ការប្រព្រឹត្តជាពិសេសណាមួយមកលើរូបគាត់ឡើយ នៅពេលរបបកម្ពុជាប្រជាធិបតេយ្យចូលកាន់អំណាច។ ម្តាយគាត់ធ្វើការក្នុងសហករណ៍ជាមួយប្រជាជនខ្មែរ ដើម្បីមើលថែទាំកុមារ និងទារក[1924]។ ថ្ងៃមួយ "ក្នុងពេលកើតមានព្រឹត្តិការណ៍ សោ ភឹម" ឈ្លបខ្មែរក្រហមឈ្មោះ ខន បានមកប្រាប់ សៅ សាក់ ថាម្តាយគាត់ត្រូវគេហៅឱ្យទៅប្រជុំនៅភូមិក្រសាំងផ្អើល ស្ថិតនៅខាងត្បូងឆៀងខាងកើតភូមិទ្រា ដែលនៅទីនោះ ម្តាយគាត់ត្រូវបានគេដាក់ឱ្យនៅក្នុងខ្ទមមួយ ជាមួយមនុស្សដទៃទៀត។ សាក្សីបានជួបម្តាយមួយភ្លែត ហើយគេបានឱ្យគាត់យកកូនស្រីដែលនៅជាមួយជីដូនត្រឡប់មកវិញ[1925]។ វាជាលើកចុងក្រោយដែលគាត់បានជួបម្តាយ ហើយចាប់តាំងពីពេលនោះមកគាត់ក៏លែងបានទទួលដំណឹងពីម្តាយទៀត[1926]។ ម្យ៉ាងវិញទៀត សៅ សាក់ បានបញ្ជាក់ថា គាត់មិនដែលបានឃើញការសម្លាប់មនុស្សផ្ទាល់ឡើយ[1927]។

១៩៤៥. នៅចំពោះមុខចៅក្រមស៊ើបអង្កេត នាង ណាត បានបញ្ជាក់ថា គាត់ដឹងថាម្តាយគាត់ដែលជាជនជាតិវៀតណាម ត្រូវបានគេ "យកទៅ" ដំណាលគ្នានឹងម្តាយរបស់ សៅ សាក់[1928]។ គាត់ពុំធ្លាប់បានឃើញការចាប់ខ្លួន ឬការសម្លាប់មនុស្សម្តងណាឡើយ[1929]។ ប៊ុន រើន ជានិរសាមេភូមិអន្លង់ទ្រាក្នុងសម័យខ្មែរក្រហម បានត្រឹមតែបញ្ជាក់អះអាងពីដើមកំណើតវៀតណាមរបស់ សៅ សាក់ ដែលនៅមានជីវិតរហូតដល់សព្វថ្ងៃ តែគាត់ពុំបាននិយាយអ្វីទាក់ទងនឹងជោគវាសនារបស់ម្តាយ

---

[1924] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៦៤ ប្រហែលម៉ោង 14.36.37 ទំព័រ ៦៥ ប្រហែលម៉ោង 14.38.35។

[1925] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៦៦ មុនម៉ោង 14.40.39 ទំព័រ ៦៦-៦៧ ចន្លោះម៉ោង 14.43.38 ដល់ម៉ោង 14.47.23។

[1926] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៦៩ ក្រោយម៉ោង 14.49.02។

[1927] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/363.1** ទំព័រ ២០ ក្រោយម៉ោង 10.08.18។ នៅពេលឆ្លើយទៅនឹងសំណួររបស់មេធាវីការពារក្តី នួន ជា៖ "ស៖ (...) បើខ្ញុំយល់មិនច្រឡំទេ លោកស្រីខ្លួនឯងផ្ទាល់មិនដែលធ្លាប់បានឃើញដោយផ្ទាល់ភ្នែកអំពីការសម្លាប់អ្នកណាម្នាក់ទេ។ លោកស្រីមិនដែលបានឃើញគេសម្លាប់អ្នកណាម្នាក់ផ្ទាល់ភ្នែកទេ។ តើត្រឹមត្រូវដែរទេ? ឆ៖ ចាស៎ ជាការត្រឹមត្រូវ ព្រោះមិនដែលឃើញមែន"។

[1928] កំណត់ហេតុស្តាប់ចម្លើយ នាង ណាត ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ឯកសារ **E3/7779**, ERN KH 00233292។

[1929] កំណត់ហេតុស្តាប់ចម្លើយ នាង ណាត ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ឯកសារ **E3/7779**, ERN KH 00233292។

សៅ សាក់ នោះទេ[1930]។ ពុំមានកំណត់ហេតុស្តាប់ចម្លើយណាផ្សេងទៀត បានលើកឡើងពីជោគវាសនារបស់ម្តាយ សៅ សាក់ ទេ។

១៩៤៦. សាក្សីផ្សេងទៀតដែលត្រូវបានសម្ភាសដោយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ថា មនុស្សមួយចំនួនត្រូវបានចាប់ខ្លួន និងសម្លាប់ តែសាក្សីពុំបានផ្តល់សេចក្តីលម្អិត ឬប្រភពច្បាស់លាស់ណាមួយនៃព័ត៌មានរបស់ខ្លួន ដែលបានមកតែពីពាក្យនិយាយតគ្នាប៉ុណ្ណោះ[1931]។ គ្មានសាក្សីណាមួយបានឃើញការសម្លាប់ជនជាតិវៀតណាម នៅក្នុងភូមិអន្លង់ទ្រានេះទេ។ម្យ៉ាងវិញទៀត គ្មាននរណាម្នាក់បាននិយាយពីសាកសពមនុស្សស្លាប់នោះទេ។

ii. <u>**ករណីម្តាយរបស់ នាង ណាត (ឈ្មោះ យឺន)**</u>

១៩៤៧. នៅចំពោះមុខចៅក្រមស៊ើបអង្កេត នាង ណាត បានឆ្លើយថា ម្តាយគាត់ជាជនជាតិវៀតណាម ឈ្មោះ យឺន ត្រូវបានគេនាំយកទៅ និងឃុំខ្លួន ដំណាលគ្នានឹងម្តាយរបស់ សៅ សាក់[1932]។ នាង ណាត និងបងប្រុសគាត់ ឯម ប៊ុននីម បានរួចជីវិតពីរបបខ្មែរក្រហម បើទោះជាម្តាយគាត់ជាជនជាតិវៀតណាមក៏ដោយ[1933]។ អ្នកទាំងពីរនេះ ត្រូវបានសម្ភាសដោយការិយាល័យសហចៅក្រមស៊ើបអង្កេត តែក្នុងចំណោមពួកគាត់ គ្មានអ្នកណាម្នាក់បានមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការឡើយ។ ហើយក៏គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងពីរនេះ បានឃើញផ្ទាល់នូវព្រឹត្តិការណ៍ដែលជាប់ទាក់ទងនឹងម្តាយពួកគាត់ឡើយ។

---

1930 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន រើន ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/7811**, ERN KH 00271361។

1931 កំណត់ហេតុស្តាប់ចម្លើយ សោម រស់ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/5246**, ERN KH 00225366, កំណត់ហេតុស្តាប់ចម្លើយ ឡុង ហ៊ៀល ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **E3/5251**, ERN KH 00233288, កំណត់ហេតុស្តាប់ចម្លើយ នាង ណាត ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **E3/7779**, ERN KH 00233292, កំណត់ហេតុស្តាប់ចម្លើយ មុំ នឹយ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ឯកសារ **E3/7813**, ERN KH 00271392, បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឃុន ម៉ុន ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ឯកសារ **E3/7597**, ERN KH 00034570។

1932 កំណត់ហេតុស្តាប់ចម្លើយ នាង ណាត ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/7779**, ERN KH 00233292។ សូមមើលផងដែរ <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៦៧-៦៨ ក្រោយម៉ោង 14.47.23។

1933 កំណត់ហេតុស្តាប់ចម្លើយ នាង ណាត ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/7779**, កំណត់ហេតុស្តាប់ចម្លើយ ឯម ប៊ុននីម ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ឯកសារ **E3/7760**។

• **ពាក្យចចាមអារ៉ាមមិនស៊ីសង្វាក់គ្នាទាក់ទងនឹងការប្រជុំ "ធ្វើស្ថិតិ" ជនជាតិវៀតណាម**

១៩៤៨. នាង ណាត បាននិយាយថា តាជា និង យាយហង់ ជាម្ចាស់ផ្ទះ និងបន្ទាប់មក មានជីដូនគាត់ទៀត គឺជាអ្នកប្រាប់គាត់ថា ម្តាយគាត់ឈ្មោះ យ៉ឺន ត្រូវបាន ឈុន និង សូត្រ ជាកម្មាភិបាលភូមិ នាំយកទៅជាមួយនឹងម្តាយសាក្សី សៅ សាក់ ដើម្បីប្រជុំមួយភ្លែត[1934]។

១៩៤៩. បងប្រុសគាត់ ឯម ប៊ុននីម ជាទាហានខ្មែរក្រហម ធ្វើសង្គ្រាមនៅព្រំដែនជាមួយវៀតណាម នៅសម័យនោះ បាននិយាយដូចគ្នាថា គាត់ដឹងថាម្តាយត្រូវបានចាប់ខ្លួន តាមរយៈជីដូន នៅពេលគាត់ត្រលប់មកភូមិវិញ។ ជីដូនគាត់បាននិយាយថា ម្តាយគាត់ត្រូវបានមេភូមិហៅទៅប្រជុំដើម្បីកត់ត្រាជនជាតិវៀតណាម[1935]។ ពាក្យចចាមអារ៉ាមនេះ គឺជាភស្តុតាងតែមួយគត់បង្ហាញពីការប្រជុំដើម្បីធ្វើស្ថិតិជនជាតិវៀតណាម នៅក្នុងភូមិអន្លង់ទ្រា។

១៩៥០. វាមិនត្រឹមតែគ្មានព័ត៌មានណាមួយទាក់ទងនឹងប្រភពព័ត៌មានរបស់ជីដូនគាត់ ដែលនាំឱ្យមានជាពាក្យចចាមអារ៉ាមត្រួតស៊ីគ្នាប៉ុណ្ណោះទេ តែលើសពីនេះទៀតនោះ គឺថាព័ត៌មានមួយនេះមិនត្រូវបានបញ្ជាក់អះអាងដោយ សៅ សាក់ ដែលជាសាក្សីតែម្នាក់គត់ ក្នុងសវនាការ ឬក៏ត្រូវបានបញ្ជាក់ដោយកំណត់ហេតុស្តាប់ចម្លើយណាមួយផ្សេងទៀត សូម្បីតែកំណត់ហេតុស្តាប់ចម្លើយរបស់ប្អូនស្រីគាត់ នាង ណាត ក៏ដោយ។ ផ្ទុយទៅវិញ អ្នកភូមិម្នាក់ឈ្មោះ សោម រស់ និយាយថា "មិនមានការប្រជុំប្រាប់មូលហេតុនៃការចាប់ខ្លួនគ្រួសារវៀតណាមទេ"[1936]។ ដូច្នេះ តម្លៃជាភស្តុតាងនៃចម្លើយខុសពីគេរបស់ ឯម ប៊ុននីម មួយនេះ គឺមានតិចតួចខ្លាំងណាស់។

១៩៥១. កំណត់ហេតុស្តាប់ចម្លើយរបស់ វ៉ាន់ ម៉ៅ ពុំបានផ្តល់ភស្តុតាងអ្វីដែលមានប្រយោជន៍នោះឡើយ ព្រោះថាគាត់បញ្ជាក់ប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា ប្រភពព័ត៌មានតែមួយគត់របស់គាត់ ទាក់ទងនឹងការចាប់ខ្លួនម្តាយ នាង ណាត គឺ... នាង ណាត ផ្ទាល់តែ

---

[1934] កំណត់ហេតុស្តាប់ចម្លើយ នាង ណាត ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/7779**, ERN KH 00233292។

[1935] កំណត់ហេតុស្តាប់ចម្លើយ ឯម ប៊ុននីម ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ឯកសារ **E3/7760**, ERN KH 00296236។

[1936] កំណត់ហេតុស្តាប់ចម្លើយ សោម រស់ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/5246**, ERN KH 00225366។

ម្តង[1937]។ គាត់ថែមទាំងមិនអាចបញ្ជាក់បានពីទីកន្លែងដែលគ្រួសារមួយនេះរស់នៅ ក្នុងរបបខ្មែរក្រហម[1938]។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចចាត់ទុកចម្លើយសាក្សីរូបនេះ ថាជាភ័ស្តុតាងគាំទ្របានជាដាច់ខាត។

- **<u>ភាពផ្ទុយគ្នាទាក់ទងនឹងកាលបរិច្ឆេទចាប់ខ្លួន យឺន</u>**

១៩៥២. សំណួរស្តីពីកាលបរិច្ឆេទដែល យឺន ត្រូវបានចាប់ខ្លួន ក៏ចោទជាបញ្ហាផងដែរ។ បើតាម សៅ សាក់ ការចាប់ខ្លួនម្តាយគាត់ និង យឺន គឺកើតឡើងដំណាលគ្នានឹងពេលមាន "ព្រឹត្តិការណ៍ សោ ភឹម"។ ទោះជា នាង ណាត ពុំបានផ្តល់កាលបរិច្ឆេទណាមួយក៏ដោយ ក៏ ឯម ប៊ុននីម បាននិយាយថា រឿងរ៉ាវមួយនេះបានកើតឡើងប៉ុន្មានខែមុនមានព្រឹត្តិការណ៍ សោ ភឹម[1939]។

១៩៥៣. ដូចគ្នានេះដែរ ក្នុងកំណត់ហេតុស្តាប់ចម្លើយដែល នាង ណាត លើកឡើងថា "តាម[គាត់] ឃើញ និងឮអ្នកភូមិនិយាយ គឺជនជាតិយួន ត្រូវយកទៅសម្លាប់ <u>អត់ទុកទេ</u>" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[1940] គឺពិតជាមានចំណុចសង្ស័យ ព្រោះថា គាត់បានខិតខំតអំពើដើម្បីបង្ហាញនូវអ្វីដែលគាត់បានឃើញ។ គ្រាន់តែការអានចម្លើយរបស់គាត់ ទាក់ទងនឹងអង្គហេតុ បង្ហាញឱ្យឃើញថា គាត់ពុំធ្លាប់បានឃើញការសម្លាប់មនុស្សផ្ទាល់ភ្នែកម្តងណាឡើយ។

១៩៥៤. ចំណែក សោម រស់ វិញ គាត់បានពន្យល់ពីការចោទប្រកាន់ទាក់ទងនឹងការសម្លាប់មនុស្ស ដោយភ្ជាប់ជាមួយនឹងជម្លោះប្រដាប់អាវុធ ព្រោះគាត់បាននិយាយថា ជនរងគ្រោះនៃការចាប់ខ្លួន និង

[1937] កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ៅ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/7761**, ERN KH 00225221។

[1938] កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ៅ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/7761**, ERN KH 00225221។

[1939] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/362.1** ទំព័រ ៦៥ ក្រោយម៉ោង 14.38.35 ទំព័រ ៦៦ ក្រោយម៉ោង 14.40.39, កំណត់ហេតុស្តាប់ចម្លើយ ឯម ប៊ុននីម ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ឯកសារ **E3/7760**, ERN KH 00296235 (គាត់បានកំណត់ពេលគេបញ្ជូនគាត់ទៅកងចល័ត ពីរខែមុនពេលចាប់ខ្លួន សោ ភឹម និងជួបយាយគាត់ ប្រហែលបីថ្ងៃ ក្រោយពីទៅដល់កងចល័ត)។

[1940] កំណត់ហេតុស្តាប់ចម្លើយ នាង ណាត ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/7779**, ERN KH 00233292។

សម្លាប់នេះ គឺជាអ្នកជាប់ខ្សែវៀតណាម និងខ្មែរ សោ ភឹម[1941]។ មិនខុសអ្វីពីរឿងរ៉ាវដទៃទៀតនោះទេ គឺថារឿងរ៉ាវមួយនេះ មានភាពមិនច្បាស់លាស់ ទាក់ទងនឹងការសម្លាប់មនុស្ស ហើយវាទំនងជាសក្ខីកម្មឮតាមពាក្យនិយាយតៗគ្នាតែប៉ុណ្ណោះ ព្រោះថាព័ត៌មានដែលបាននិយាយប្រាប់ ពុំដែលត្រូវបានបង្ហាញប្រភពម្តងណាឡើយ។ ដូច្នេះ រឿងរ៉ាវមួយនេះ មានតម្លៃជាភស្តុតាងតិចតួចបំផុត។

១៩៥៥. ចម្លើយទាំងនេះ ដែលជាភស្តុតាងមិនស៊ីសង្វាក់គ្នា ពុំអាចបង្ហាញឱ្យឃើញថា យ៉ឺន ដែលជាម្តាយនាង ណាត ត្រូវបានសម្លាប់នោះទេ ហើយក៏មិនអាចបង្ហាញឱ្យឃើញថាវាស្ថិតក្នុងកាលៈទេសៈបែបណានោះដែរ។ គេអាចត្រឹមតែចាត់ទុកបានថា មានភស្តុតាងធ្វើសេចក្តីសន្និដ្ឋានថា ឈ្មោះ យ៉ឺន បានបាត់ខ្លួន ក្រោយពីគាត់ត្រូវចាប់ខ្លួន។

### iii. <u>**ករណីគ្រួសាររបស់ វ៉ាន់ ម៉ៅ**</u>

១៩៥៦. ឪពុក វ៉ាន់ ម៉ៅ ឈ្មោះ សេង វ៉ាន់ ជាជនជាតិវៀតណាម[1942]។ នៅពេលចោទសួរក្នុងអំឡុងពេលសវនាការ ទាក់ទងនឹងជោគវាសនារបស់ក្រុមគ្រួសារមួយនេះ សៅ សាក់ បានអះអាងថាគាត់មិនស្គាល់ឪពុក វ៉ាន់ ម៉ៅ និងមិនដឹងពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍ទាំងឡាយដែលជាប់ទាក់ទងនឹង សេង វ៉ាន់ ទេ តែទើបតែពេល "ក្រោយមក" ទៀតប៉ុណ្ណោះដែលគាត់ដឹងថា សេង វ៉ាន់ ត្រូវបាននាំយកទៅ ជាមួយនឹងកូនៗរបស់គាត់[1943]។

១៩៥៧. ក្នុងចម្លើយនៅចំពោះមុខអ្នកស៊ើបអង្កេត វ៉ាន់ ម៉ៅ បានអះអាងថាបានឃើញគេចាប់ឪពុកគាត់ផ្ទាល់ តែគាត់មិនចាំថានៅថ្ងៃណា ហើយក៏មិនដឹងថាកម្មាភិបាលដែលមកយកឪពុកគាត់ មកពីណា និងមានប៉ុន្មាននាក់ដែរ។ ឪពុកគាត់ត្រូវបានគេដឹកតាមកាណូត ទៅរៀនសូត្របួនប្រាំថ្ងៃ ហើយចាប់ពីពេលនោះមក គាត់ក៏បាត់ខ្លួនរហូត[1944]។ ប៉ុន្តែ វ៉ាន់ ម៉ៅ បានបញ្ជាក់ថាគាត់ពុំមានវត្តមាននៅទីនោះទេ នៅពេលដែលគេនាំប្អូនប្រុស និងបងស្រីគាត់យកទៅ ពោលគឺមួយខែក្រោយពីឪពុកពួក

[1941] កំណត់ហេតុស្តាប់ចម្លើយ សោម រស់ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/5246**, ERN KH 00225366។

[1942] កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ៅ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/7761**, ERN KH 00225220។

[1943] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៧៨ មុនម៉ោង 15.35.06។

[1944] កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ៅ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/7761**, ERN KH 00225221។

គាត់ត្រូវបានចាប់ខ្លួន[1945]។ គាត់និយាយថា ក្រោយមក មានមនុស្សមករកចាប់គាត់ជាច្រើនដង តែរាល់ពេល គាត់តែងតែលាក់ខ្លួន[1946]។

១៩៥៨. កំណត់ហេតុស្តាប់ចម្លើយរបស់ សោម រស់ បានបញ្ជាក់អះអាងពីការចាប់ខ្លួនគ្រួសាររបស់ វ៉ាន់ ម៉ៅ ដោយសាក្សីបាននិយាយថារឿងនេះកើតឡើង “ប្រហែលឆ្នាំ ១៩៧៨ រដូវប្រាំង” ពោលគឺ អាចមុនខែ ឧសភា ឆ្នាំ ១៩៧៨ ឬក្រោយខែ វិច្ឆិកា ឆ្នាំ ១៩៧៨[1947]។ សាក្សីបានឱ្យដឹងថា គឺពួក “សន្តិសុខមកពីលើ” ជាអ្នកមកចាប់អ្នកទាំងនោះ នាំយកទៅតាមកាណូត ទៅទីណាក៏មិនដឹង[1948]។ ចម្លើយរបស់គាត់បង្ហាញឱ្យឃើញថា គាត់ពុំបានឃើញការសម្លាប់មនុស្ស ហើយគាត់មិនដឹងថាអ្នកទាំងនោះត្រូវបាននាំទៅទីណានោះទេ។ ម្យ៉ាងទៀត គាត់ពុំបានផ្តល់ការចង្អុលបង្ហាញណាមួយទាក់ទងនឹងប្រភពព័ត៌មានរបស់គាត់ និងពុំបានបញ្ជាក់ថាហេតុអ្វីបានជាគាត់បញ្ជាក់ថា គ្រួសារទាំងនេះត្រូវបានគេសម្លាប់។ ប៉ុន្តែ សោម រស់ បានបញ្ជាក់អះអាងថាបានជួយលាក់ វ៉ាន់ ម៉ៅ “កុំឱ្យគេចាប់”[1949]។

១៩៥៩. ប៊ុន រើន ជានិរសាមេភូមិឈ្មោះ ម៉ន បានបញ្ជាក់ថាបានទទួលបញ្ជាពី ម៉ន ឱ្យទៅហៅ វ៉ាន់ ម៉ៅ ដោយគាត់មិនដឹងពីមូលហេតុនៃការកោះហៅនេះទេ តែគាត់មិនបានធ្វើតាមបញ្ជានេះទេ ដោយសារតែកុមារនោះយំ[1950]។ ចម្លើយរបស់គាត់គឺផ្ទុយគ្នាពីចម្លើយ វ៉ាន់ ម៉ៅ ព្រោះថា បើតាម វ៉ាន់ ម៉ៅ គឺឈ្លបឈ្មោះ ហង់ សារ៉េន ទេ ដែលជាអ្នកចង់មកចាប់គាត់ ហើយគឺម្តាយធំរបស់កុមារនោះ ដែលបានលាក់កុមារនោះ[1951]។ ទាំង សោម រស់ ទាំង ប៊ុន រើន សុទ្ធតែមិនដឹង និងពុំបានបង្ហាញពីមូលហេតុនៃការកោះហៅ វ៉ាន់ ម៉ៅ។

---

[1945] កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ៅ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/7761**, ERN KH 00225221។

[1946] កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ៅ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/7761**, ERN KH 00225221។

[1947] កំណត់ហេតុស្តាប់ចម្លើយ សោម រស់ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/5246**, ERN KH 00225367។

[1948] កំណត់ហេតុស្តាប់ចម្លើយ សោម រស់ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/5246**, ERN KH 00225367។

[1949] កំណត់ហេតុស្តាប់ចម្លើយ សោម រស់ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/5246**, ERN KH 00225367។

[1950] កំណត់ហេតុស្តាប់ចម្លើយ ប៊ុន រើន ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ឯកសារ **E3/7811**, ERN KH 00271360។

[1951] កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ៅ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/7761**, ERN KH 00225221-00225222។

១៩៦០. ក្នុងកិច្ចសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ឃុន ម៉ុន ជាប្អូនថ្លៃ សេង វ៉ាន់ (ឃុន ម៉ុន ត្រូវជាប្ដីប្អូនស្រី សេង វ៉ាន់) គឺជាមនុស្សតែម្នាក់គត់ដែលបានអះអាងថា សេង វ៉ាន់ និងកូនៗ ត្រូវបានសម្លាប់ចោលគ្មានសល់ លើកលែងតែ វ៉ាន់ ម៉ៅ[1952]។ ផ្ទុយទៅវិញ ឃុន ម៉ុន មិនត្រូវបានសាកសួរទាក់ទងនឹងប្រភពព័ត៌មានរបស់គាត់ ហើយគាត់ក៏មិនបានផ្ដល់ព័ត៌មានណាមួយទាក់ទងនឹងប្រធានបទនេះដែរ។ ផ្ទុយគ្នាពី សោម រស់ ឃុន ម៉ុន និយាយថា ព្រឹត្តិការណ៍ទាំងនេះកើតឡើងនៅក្នុងឆ្នាំ ១៩៧៧[1953]។ ពាក់ព័ន្ធនឹងកិច្ចសម្ភាសក្រៅក្របខ័ណ្ឌតុលាការ តម្លៃជាភ័ស្តុតាងនៃចម្លើយមួយនេះ គឺមានតិចតួចបំផុត។ ជាពិសេសទៅទៀតនោះ គឺថាក្នុងរបបខ្មែរក្រហម ឃុន ម៉ុន រស់នៅក្នុងឃុំមួយផ្សេងទៀត គឺនៅភូមិស្វាយអន្ទរ ឃុំស្វាយអន្ទរ[1954]។ ដូច្នេះ វាសមហេតុសមផលដែលត្រូវសន្និដ្ឋានថា ចម្លើយរបស់គាត់ទាំងអស់នេះ គឺបានមកពីការនិយាយតគ្នា ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ។ ទោះយ៉ាងណាក៏ដោយ កិច្ចសម្ភាសរបស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ពុំបានផ្ដល់សេចក្ដីលម្អិតណាមួយដែលមានប្រយោជន៍ដល់ការបង្ហាញការពិតនោះឡើយ។

១៩៦១. សរុបសេចក្ដីមក ដោយហេតុថាចម្លើយខុសៗគ្នាទាំងអស់នេះ មានតម្លៃជាភ័ស្តុតាងតិចតួចខ្លាំងពេក ហើយជាពិសេសទៅទៀតនោះ ដោយសារពុំមានភ័ស្តុតាងជាក់ស្ដែង និងស៊ីសង្វាក់គ្នា គេមិនអាចបង្ហាញភ័ស្តុតាងឱ្យឃើញពីករណីសម្លាប់ក្នុងគ្រួសារ វ៉ាន់ ម៉ៅ បានឡើយ។

### iv. <u>ករណី ថាវ និងក្រុមគ្រួសាររបស់គាត់</u>

១៩៦២. ឪពុក ថាវ ជាជនជាតិចិនកាត់វៀតណាម។ នៅពេលសួរដេញដោលក្នុងអំឡុងពេលសវនាការ សៅ សាក់ បានបញ្ជាក់ថាគាត់មិនដឹងថាតើ ថាវ ត្រូវបានគេនាំទៅសម្លាប់ដែរឬអត់ តែគាត់គ្រាន់ដឹងថា

---

[1952] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឃុន ម៉ុន ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ឯកសារ **E3/7597**, ERN KH 00034570។

[1953] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឃុន ម៉ុន ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ឯកសារ **E3/7597**, ERN KH 00034571។

[1954] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឃុន ម៉ុន ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ឯកសារ **E3/7597**, ERN KH 00034582។

ថាវ ត្រូវបានបញ្ជូនទៅធ្វើការនៅកន្លែងផ្សេង ហើយក៏បាត់ខ្លួនទៅ[1955]។ វ៉ាន់ ម៉ៅ ដែលនិយាយថា បានឃើញការចាប់ខ្លួនផ្ទាល់ បានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា ថាវ ត្រូវបានគេនាំទៅ "ប្រហែលជាមួយខែមុនក្នុងពេលដែលគេចាប់ឪពុក[គាត់]" ខណៈដែល "គ្រួសាររបស់គាត់" ត្រូវបានគេនាំយកទៅប្រហែលជាមួយខែក្រោយមកទៀត[1956]។ អ្នកទាំងនោះ "ត្រូវចាប់ដាក់" កាណូត លើកលែងតែកូនប្រុសរបស់ថាវ ឈ្មោះ ណាក់ (ដែលនៅមានជីវិតដល់សព្វថ្ងៃ) ដែលត្រូវបានគេដាក់ឡើងមកលើគោកវិញ ដោយសារតែវាឃ្មំ[1957]។

១៩៦៣. ចម្លើយ វ៉ាន់ ម៉ៅ នៅពេលរឿងរ៉ាវកើតឡើង ពិតជាគួរឱ្យសង្ស័យយ៉ាងខ្លាំង ដោយសារតែគាត់នៅក្មេង នៅពេលដែលរឿងនេះកើតឡើង (អាយុប្រហែលប្រាំពីរឆ្នាំ) និងដោយសារពេលវេលាកន្លងផុតទៅ គិតតាំងពីពេលនោះមក[1958]។ វត្តមានរបស់គាត់ជាសាក្សីថាបានឃើញរឿងនេះផ្ទាល់ភ្នែក នៅពេលឆ្លើយថាខ្លួនគាត់ក៏ត្រូវបានគេស្វែងរកដូចគ្នា បង្ហាញឱ្យឃើញថាវាពិបាកនឹងជឿទុកចិត្តបានខ្លាំងណាស់។ ដោយសារគាត់មិនបានមកផ្តល់សក្ខីកម្ម រឿងរ៉ាវរបស់គាត់ មិនអាចត្រូវបានសាកល្បងមើលលើភាពផ្ទុយគ្នាមួយនេះបាន។

១៩៦៤. កំណត់ហេតុស្តាប់ចម្លើយសាក្សី សោម រស់ ទាក់ទងនឹងការចាប់ និងសម្លាប់គ្រួសារ ថាវ គឺមានភាពមិនច្បាស់លាស់ដូចគ្នានឹងគ្រួសារ វ៉ាន់ ម៉ៅ ដែរ ទាក់ទងនឹងប្រភពព័ត៌មានរបស់គាត់[1959]។ ការណ៍មិនបានមកផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការ មិនអាចឱ្យគេទទួលបានភ័ស្តុតាងអ្វីផ្សេងបានឡើយ។

១៩៦៥. វារឹតតែគ្មានភ័ស្តុតាងបង្ហាញឱ្យឃើញពីជោគវាសនាគ្រួសារ ថាវ ថែមទៀត ព្រោះថាចម្លើយ ប៊ុន រើន គឺផ្ទុយគ្នានឹងសក្ខីកម្មមុនៗ។ អតីតនិរសាមេភូមិរូបនេះ បានឆ្លើយថា ថាវ បានរត់ទៅវៀត-ណាម ក្រោយពេលរំដោះឆ្នាំ ១៩៧៥ នៅពេលមានរលកនៃការបញ្ជូនជនជាតិវៀតណាមត្រលប់

---

[1955] សៅ សាក់៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៧៩ មុនម៉ោង 15.39.38។

[1956] កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ៅ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/7761**, ERN KH 00225221។

[1957] កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ៅ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/7761**, ERN KH 00225221។

[1958] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឃុន ម៉ុន ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ឯកសារ **E3/7597**, ERN KH 00034571 គាត់បញ្ជាក់ថា វ៉ាន់ ម៉ៅ "វានៅតូចណា"។

[1959] កំណត់ហេតុស្តាប់ចម្លើយ សោម រស់ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/5246**, ERN KH 00225367។

ទៅស្រុកវិញ ហើយគឺនៅក្នុងស្ថានភាពបែបនេះហើយដែលគេលែងបានឃើញគាត់ទៀត[1960]។ ម្យ៉ាងវិញទៀត ប៊ុន រើន បានបញ្ជាក់ថា ជនជាតិវៀតណាមម្នាក់ទៀតឈ្មោះ វ៉ាត បានរត់ទៅវៀត-ណាម ដំណាលគ្នានឹង ថាវ ដែរ ហើយ វ៉ាត បានត្រលប់មកភូមិវិញក្រោយឆ្នាំ ១៩៧៩[1961]។

១៩៦៦. សៅ សាក់ បានបញ្ជាក់អះអាងក្នុងសវនាការថា រលកនៃការបញ្ជូនជនជាតិវៀតណាម ទៅប្រទេសវៀតណាមវិញ ពិតជាបានកើតមានជាច្រើនដងប្រាកដមែន ក្នុងចន្លោះឆ្នាំ ១៩៧៥ និង ឆ្នាំ ១៩៧៨[1962]។ មុំ ឆីយ ក៏បានអះអាងដូចគ្នាប្រាប់អ្នកស៊ើបអង្កេតដែរថា គាត់ឃើញគ្រួសារជនជាតិវៀតណាមត្រលប់ទៅស្រុកកំណើតវិញ ដោយផ្ទាល់ភ្នែក។ ម្យ៉ាងវិញទៀត គាត់មិនបានឃើញមានការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាមទាំងអស់នោះទេ[1963]។

១៩៦៧. ដូច្នេះ ចំណុចសង្ស័យធ្ងន់ធ្ងរ ចោទឡើងទាក់ទងនឹងជោគវាសនារបស់ ថាវ និងការពិតនៃការចាប់ខ្លួនរបស់គាត់។ ពាក់ព័ន្ធនឹងអ្នកផ្សេងទៀតក្នុងគ្រួសាររបស់គាត់ គេគួរកត់សម្គាល់ថា តាមរយៈការតទល់រវាងចម្លើយទាំងអស់ គេចងចាំបានថា អ្នកទាំងអស់នោះបានត្រឹមគេចាប់ខ្លួន និងនាំយកទៅ ប៉ុន្តែ គ្មានភស្តុតាងណាមួយអាចបង្ហាញឱ្យឃើញថាពិតជាមានការសម្លាប់បានទេ។

v. **ករណីឈ្មោះ កែម នៅ ប្រពន្ធរបស់ ឡង់ ហ៊ើល**

១៩៦៨. ឡង់ ហ៊ើល ជាសាក្សីម្នាក់ដែលត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម តែគាត់បានស្លាប់មុនពេលចូលខ្លួនមកកាន់តុលាការ[1964]។ ក្នុងចម្លើយនៅចំពោះមុខអ្នកស៊ើបអង្កេត សាក្សីរូបនេះបានបញ្ជាក់

---

[1960] កំណត់ហេតុស្តាប់ចម្លើយ ប៊ុន រើន ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ឯកសារ **E3/7811**, ERN KH 00271361។

[1961] កំណត់ហេតុស្តាប់ចម្លើយ ប៊ុន រើន ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ឯកសារ **E3/7811**, ERN KH 00271361។

[1962] សៅ សាក់៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/362.1** ទំព័រ ៧២ ក្រោយម៉ោង 15.19.31 ទំព័រ ៧៣ ក្រោយម៉ោង 15.21.05, ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ១២ ក្រោយម៉ោង 09.43.03 ទំព័រ ២៤-២៥ មុនម៉ោង 10.43.18។

[1963] កំណត់ហេតុស្តាប់ចម្លើយ មុំ ឆីយ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ឯកសារ **E3/7813**, ERN KH 00271392។

[1964] អ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ មានចំណងជើង "បញ្ជីឈ្មោះសាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់វគ្គស្តីពីការប្រព្រឹត្តិចំពោះជនជាតិវៀតណាម" ផ្ញើនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ វេលាម៉ោង ១០ និង ៣៩ នាទី ព្រឹក (ដីកាកោះ), អ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ មានចំណងជើង "កាលវិភាគ និងរហស្សនាម" ផ្ញើនៅថ្ងៃទី ០២ ខែ តុលា

ថា ប្រពន្ធគាត់ កែម នៅ ដែលមាន“ឪពុក[...]ជាជនជាតិខ្មែរសុទ្ធ ចំណែកម្តាយរបស់គាត់កាត់ វៀតណាម” និងកូនៗ ត្រូវបានគេនាំយកទៅក្នុងឆ្នាំ ១៩៧៨ មុនកងទ័ពវៀតណាមចូលមកក្នុងប្រទេសកម្ពុជា[1965]។ នៅពេលរឿងនេះកើតឡើង គាត់ពុំមានវត្តមាននៅទីនោះទេ។ ក្រោយមក ឡង់ ហៃល បានជួបប្រពន្ធ និងកូនៗ ជាលើកចុងក្រោយ នៅមុំក្រសារផ្ញើល។ ប៉ុន្មានខែក្រោយមក គាត់ត្រូវបានស្នើឱ្យរៀបការជាមួយស្ត្រីខ្មែរម្នាក់ ដោយមានការយល់ព្រមពីសាមីខ្លួន និងដោយមានការចូលរួមពីឪពុកម្តាយ[1966]។

១៩៦៩. នៅចំពោះមុខអង្គជំនុំជម្រះ សៅ សាក់ បានឆ្លើយថាគាត់ “គ្រាន់តែឮ” គេនិយាយពីជោគវាសនាគ្រួសារ ឡង់ ហៃល ហើយគាត់ឮគេនិយាយថា គ្រួសារនេះត្រូវបានគេយកទៅ។ ម្យ៉ាងវិញទៀតគាត់បានបញ្ជាក់ថា គាត់មិនដឹងថាប្រពន្ធ ឡង់ ហៃល មានជាតិសាសន៍អ្វីទេ[1967]។ គ្មានភស្តុតាងណាផ្សេងទៀតត្រូវបានបង្ហាញ ទាក់ទងនឹងជោគវាសនាក្រុមគ្រួសារមួយនេះទេ។

### vi. ករណីយាយ ឌឹក

១៩៧០. យាយឌឹក ជាឆ្មប មានដើមកំណើតជាជនជាតិវៀតណាម។ ក្នុងអំឡុងពេលសវនាការ សៅ សាក់ បានថ្លែងថា ស្ត្រីម្នាក់នេះ ត្រូវ “គេយកគាត់ទៅសម្លាប់” ប៉ុន្តែមួយរំពេចក្រោយមក សៅ សាក់ បានបញ្ជាក់ថា “[...] គេយកគាត់ទៅសម្លាប់ ដោយប្រជាជនមិនបានដឹងអី សូម្បីតែបន្តិច ស្ងាត់ៗ បាត់គាត់ពីផ្ទះ សល់តែផ្ទះទទេ”[1968]។

---

ឆ្នាំ ២០១៥ វេលាម៉ោង ៣ និង ៨ នាទី រសៀល (ការជូនដំណឹងអំពីមរណភាព), សំបុត្រមរណភាព ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ឯកសារ **E29/507**។

[1965] កំណត់ហេតុស្តាប់ចម្លើយ ឡង់ ហៃល ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **E3/5251**, ERN KH 00233287-00233288។

[1966] កំណត់ហេតុស្តាប់ចម្លើយ ឡង់ ហៃល ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/5251**, ERN KH 00233288។

[1967] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៨២ ក្រោយម៉ោង 15.45.46។

[1968] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/363.1** ទំព័រ ៧ មុនម៉ោង 09.28.08។

១៩៧១. នៅចំពោះមុខអ្នកស៊ើបអង្កេត មុំ ផឹយ បានលើកឡើងពីការបាត់ខ្លួនរបស់យាយឌឹក ដោយគាត់មិនអាចផ្តល់ការបញ្ជាក់អ្វីសូម្បីបន្តិច[1969]។ ទាំងអស់នេះគឺជាចម្លើយតែមួយគត់ទាក់ទងនឹងស្ត្រីខ្មែរ វៀតណាមម្នាក់នេះ ហើយចម្លើយទាំងអស់នេះ មិនបានផ្តល់ភស្តុតាងជាក់លាក់ណាមួយ ក្រៅតែពីការណ៍ដែលបុគ្គលនេះបានបាត់ខ្លួនពីភូមិ ក្នុងកាលៈទេសៈដូចម្តេចក៏មិនដឹង។

១៩៧២. តម្លៃជាភស្តុតាងនៃចម្លើយទាំងអស់នេះ មានតិចតួចខ្លាំងណាស់ និងពុំអាចឱ្យគេសន្និដ្ឋានបានថា យាយឌឹកត្រូវបានគេសម្លាប់ បានឡើយ។

១៩៧៣. ភស្តុតាងទាំងអស់ដែលត្រូវបានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទងនឹងភូមិអន្លង់ទ្រា មិនអាចឱ្យគេសន្និដ្ឋានហួសពីវិមតិសង្ស័យបានថា មានការសម្លាប់មនុស្សបានទេ។

### 1.២. ឃុំអន្លូរយស

១៩៧៤. ក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា អៀ ពៅ បានលើកឡើងពីករណីប្រពន្ធជនជាតិវៀតណាមរបស់គាត់។ ចម្លើយរបស់គាត់ពុំត្រូវបានលើកឡើងនៅក្នុងដីកាដំណោះស្រាយនោះទេ។ គាត់ត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ តែគាត់បានស្លាប់[1970]។ ក្នុងអំឡុងពេលសវនាការ គ្មាននរណាម្នាក់បាននិយាយពីក្រុមគ្រួសាររបស់គាត់ឡើយ គឺមានតែកំណត់ហេតុស្តាប់ចម្លើយប៉ុណ្ណោះដែលបានលើកយកបញ្ហាគ្រួសារគាត់មកនិយាយ។

១៩៧៥. អៀ ពៅ បានឱ្យដឹងថា ប្រពន្ធគាត់ត្រូវបានគេនាំយកទៅរៀនសូត្រនៅខាងកើតពាម ត្រង់ឡឥដ្ឋ ក្នុងខែ មីនា ឆ្នាំ ១៩៧៧។ កូនៗរបស់គាត់ត្រូវបាននាំទៅជាមួយម្តាយ លើកលែងតែម្នាក់ដែលបានរត់

[1969] កំណត់ហេតុស្តាប់ចម្លើយ មុំ ផឹយ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ឯកសារ **E3/7813**, ERN KH 00271392។

[1970] អ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ មានចំណងជើង "បញ្ជីឈ្មោះសាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់វគ្គស្តីពីការប្រព្រឹត្តិចំពោះជនជាតិវៀតណាម" ផ្ញើនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ វេលាម៉ោង ១០ និង ៣៩ នាទី ព្រឹក (ដីកាកោះ), អ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ មានចំណងជើង "កាលវិភាគ និងរបាយការណ៍" ផ្ញើនៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥ វេលាម៉ោង ៣ និង ៨ នាទី រសៀល (ការជូនដំណឹងអំពីមរណភាព), សំបុត្រមរណភាព ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ឯកសារ **E29/507**។

រួចខ្លួន ហើយក្រោយមក អៀ ពៅ បាននាំកូនម្នាក់នោះទៅនៅពោធិ៍ចិន្តា[1971]។ កូននោះនៅមានជីវិតមករហូត។ គ្រួសារប្រពន្ធគាត់ ត្រូវបាននាំទៅក្នុងថ្ងៃតែមួយ។ អៀ ពៅ បានសុំខ្មែរក្រហម ទៅរៀនសូត្រជាមួយក្រុមគ្រួសារគាត់ដែរ តែសំណើគាត់ត្រូវបានបដិសេធ ដោយហេតុថា "អត់ត្រូវទៅទេ ខុស"[1972]។

១៩៧៦. កូនដែលនៅមានជីវិត ឈ្មោះ ពៅ ហុង និងដែលត្រូវបានសម្ភាសដូចគ្នាដោយមជ្ឈមណ្ឌលឯកសារកម្ពុជា បានឆ្លើយថា គាត់ត្រូវបានចាប់ខ្លួនជាមួយម្តាយ និងបងប្អូន នៅពេលមួយ ដែលគាត់គិតថានៅក្នុងខែ មករា ឬខែ កុម្ភៈ ឆ្នាំ ១៩៧៧។ ពួកគាត់ត្រូវគេប្រមូលដាក់ក្នុងវត្តមួយ។ ក្រោយមកម្តាយគាត់ប្រាប់គាត់ឱ្យទៅជួបឪពុក អៀ ពៅ។ ចាប់ពីពេលនោះមក ពៅ ហុង ក៏បាត់ដំណឹងម្តាយ និងបងប្អូន រហូតមក[1973]។

### 1.គ. ករណីលើកឡើងនៅតាមកន្លែងមួយចំនួនដែលមិនត្រូវបានកំណត់ឱ្យបានច្បាស់

១៩៧៧. ក្នុងអំឡុងពេល សៅ សាក់ ផ្តល់សក្ខីកម្ម សហព្រះរាជអាជ្ញាបានសួរដេញដោលគាត់ទាក់ទងនឹងអ្នកភូមិបារាយណ៍ ដែលត្រូវបានលើកឡើងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ឡង់ ហៃល[1974]។ ក៏ប៉ុន្តែ សៅ សាក់ បានឆ្លើយថា គាត់មិនដឹងអ្វីទេ ទាក់ទងនឹងរឿងរ៉ាវកើតឡើងនៅក្នុងភូមិនេះ ដែលនៅឆ្ងាយពីភូមិរបស់គាត់ទៅទៀត[1975]។

---

[1971] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អៀ ពៅ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7954**, ERN KH 00033743-00033746។

[1972] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អៀ ពៅ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7954**, ERN KH 00033755។

[1973] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ពៅ ហុង ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០១ ឯកសារ **E3/7165a**, ERN KH 00502658។

[1974] កំណត់ហេតុស្តាប់ចម្លើយ ឡង់ ហៃល ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨14 ឯកសារ **E3/5251**, ERN KH 00233288។

[1975] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/362.1** ទំព័រ ៨៤ មុនម៉ោង 15.53.41 ទំព័រ ៨៥ ក្រោយម៉ោង 15.55.14 (នៅពេលឆ្លើយទៅនឹងការប៉ុនប៉ងលើកទីពីររបស់សហព្រះរាជអាជ្ញា អំពីអ្នកភូមិបារាយណ៍ សាក្សីនៅតែរក្សាចម្លើយដដែល "ខ្ញុំមិនបានចាំទេ។ ខ្ញុំមិនបានដឹងអ្វីទាំងអស់")។

១៩៧៨. សហព្រះរាជអាជ្ញាក៏បានសួរ សៅ សាក់ ផងដែរ ទាក់ទងនឹងគ្រួសារឈ្មោះ ឡុង (ជនជាតិវៀតណាម) និង អ៊ើល ដែលគ្រួសារមួយនេះត្រូវបានលើកឡើងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ នាង ណាត។ សាក្សីបានឆ្លើយថាគាត់មិនដឹងអ្វីទាំងអស់ទាក់ទងនឹងអ្នកទាំងពីរនេះ[1976]។ លើសពីនេះទៀត គ្មានការចង្អុលបង្ហាញណាមួយអាចឱ្យគេកំណត់បានពីទីតាំងភូមិបានថែមទៀត។ គេថែមទាំងមិនដឹងទៀតថា តើភូមិមួយនេះស្ថិតក្នុងខេត្តព្រៃវែងដែរឬអត់។

១៩៧៩. ទោះយ៉ាងណាក៏ដោយ ចម្លើយផ្ទុយពីគេ និងចម្លើយឮតាមគេនិយាយរបស់ ឡង់ ហ៊ែល និង នាង ណាត មិនអាចឱ្យគេបង្ហាញភ័ស្តុតាងធាតុផ្សំនៃបទឧក្រិដ្ឋកម្មមនុស្សឃាតបានទេ។

## 2. **បទបញ្ជា និងនីតិវិធីនៃការចាប់ខ្លួនជនជាតិវៀតណាម**

១៩៨០. នៅត្រង់កថាខណ្ឌ ៧៩៨ នៃដីកាដំណោះស្រាយ ចៅក្រមស៊ើបអង្កេតបានផ្អែកលើកំណត់ហេតុស្តាប់ចម្លើយ មុំ ធីយ និងកិច្ចសម្ភាសរបស់ ដួង អឿន ជាមួយមជ្ឈមណ្ឌលកម្ពុជា ដើម្បីសន្និដ្ឋានអំពីអត្ថិភាពនៃបញ្ជីជនជាតិវៀតណាមដែលត្រូវបានរៀបចំជាមុន សម្រាប់ធ្វើការចាប់ខ្លួន[1977]។ ចម្លើយរបស់ ដួង អឿន នឹងត្រូវលើកយកមកពិនិត្យបន្ទាប់ទៅទៀតនេះ ក្នុងក្របខ័ណ្ឌភូមិពោធិ៍ចិន្តាឃុំស្វាយអន្ទរ។

១៩៨១. មុំ ធីយ បានឮតាម “អ្នកភូមិតៗគ្នាថា កម្មាភិបាលថ្នាក់ស្រុកចុះមកកត់ឈ្មោះ”[1978]។ ហេតុដូច្នេះ “ពេលមកចាប់ កម្មាភិបាលទាំងនោះ ក៏មានបញ្ជីរួចជាស្រេច អំពីនរណាជាយួន អ្នកជាប្រពន្ធទាហាន”[1979]។ បើតាមចម្លើយមួយនេះ មនុស្សផ្សេងទៀតក្រៅពីជនជាតិវៀតណាម ហាក់ដូចជាត្រូវបានចាប់ខ្លួននាពេលនោះ។ ប៉ុន្តែ ដោយសារតែវាជាពាក្យចចាមអារ៉ាមនិយាយតៗគ្នា និងគ្មានប្រភពច្បាស់លាស់ ធ្វើឱ្យចម្លើយមួយនេះ មិនអាចជឿជាក់បានឡើយ។

---

[1976] សៅ សាក់៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៧៦ ប្រហែលម៉ោង 15.30.35, កំណត់ហេតុស្តាប់ចម្លើយ នាង ណាត ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/7779**, ERN KH 00233292។

[1977] ដីកាដំណោះស្រាយ កំណត់សម្គាល់ចុងឯកសារ ៣៤០០។

[1978] កំណត់ហេតុស្តាប់ចម្លើយ មុំ ធីយ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ឯកសារ **E3/7813**, ERN KH 00271392។

[1979] កំណត់ហេតុស្តាប់ចម្លើយ មុំ ធីយ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ឯកសារ **E3/7813**, ERN KH 00271392។

១៩៨២. ក្នុងអំឡុងពេលសវនាការ សៅ សាក់ ពុំបានឃើញអ្វីទាំងអស់ក្នុងរឿងនេះ។ ពេលដំបូង ទោះជាគាត់បាននិយាយពីបញ្ជីដែលមានកំណត់បង្ហាញពីជាតិសាសន៍របស់ឈ្មោះអ្នកនៅក្នុងនោះក៏ដោយក្ដី ក៏នេះគ្រាន់តែជាការស្មានរបស់គាត់ប៉ុណ្ណោះ[1980]។ ក្រោយមកទៀត នៅពេលសួរដេញដោលដោយក្រុមមេធាវីការពារក្ដី សៅ សាក់ បានទទួលស្គាល់ថាគាត់មិនដែលបានឃើញរបាយការណ៍ទាំងនោះទេ ហើយគាត់ក៏មិនដឹងថាតើមេភូមិឈ្មោះ ម៉ន បានផ្ញើរបាយការណ៍ទាំងនោះទៅប្រធានរបស់ខ្លួនដែរឬក៏អត់។ ជាពិសេស សាក្សីបានបញ្ជាក់ថា ក្នុងនាមជាសមាជិកភូមិធម្មតា គាត់មិនមានសមត្ថភាពទទួលបានព័ត៌មានអស់នេះនោះទេ ហើយគាត់ក៏បានបញ្ជាក់អះអាងថាខ្លួននិយាយតាមការស្មានប៉ុណ្ណោះ[1981]។

១៩៨៣. សោម រស់ ជាអ្នកភូមិអន្លង់ទ្រាម្នាក់ទៀត បានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា គ្រួសារជនជាតិវៀត-ណាម ត្រូវបានចាប់ខ្លួនដោយ "សន្តិសុខមកពីលើ" ហើយសម្លាប់។ ក៏ប៉ុន្តែ គាត់មិនអាចប្រាប់បានថាតើការចាប់ខ្លួននេះបានផ្អែកទៅតាម "[របាយការណ៍ថ្នាក់ក្រោម]" ឬអត់[1982]។ គាត់ក៏មិនបានបញ្ជាក់ពីប្រភពព័ត៌មានទទួលបាន ហើយដោយសារតែមិនបានមកផ្ដល់សក្ខីកម្ម គេក៏មិនអាចដឹងអ្វីលើសពីនេះបានដែរ។

១៩៨៤. ក្នុងចម្លើយរបស់ខ្លួន ឡង់ ហ៊ែល ក៏ធ្វើការស្មានដូចគ្នា។ គាត់បានឱ្យដឹងថា វា"ប្រាកដជាមានបញ្ជាពីថ្នាក់លើ" ឱ្យចាប់ និងសម្លាប់ជនជាតិវៀតណាម ពីព្រោះ "អ្នកថ្នាក់ក្រោម" គឺចាំតែអនុវត្តតាមប៉ុណ្ណោះ[1983]។ ផ្ទុយទៅវិញ គាត់ពុំបានពន្យល់ថាតើគាត់បានទទួលព័ត៌មានទាំងនេះតាមវិធីណា ហើយថាតើគាត់បានឃើញអ្វី បានជាគាត់ហ៊ាននិយាយបែបនេះ។ ជាមួយគ្នានេះដែរ គេត្រូវរំឭកថា បើយោងតាមចម្លើយរបស់សាក្សី គឺទោះជាយ៉ាងណាក៏ដោយ ក៏គាត់ពុំបានឃើញគេចាប់ប្រពន្ធគាត់ដោយផ្ទាល់ ឬការសម្លាប់ណាមួយនោះដែរ[1984]។

---

[1980] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ១០ ក្រោយម៉ោង 09.36.13។

[1981] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/363.1** ទំព័រ ២៤ ក្រោយម៉ោង 10.40.15។

[1982] កំណត់ហេតុស្ដាប់ចម្លើយ សោម រស់ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/5246**, ERN KH 00225367។

[1983] កំណត់ហេតុស្ដាប់ចម្លើយ ឡង់ ហ៊ែល ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/5251**, ERN KH 00233288។

[1984] កំណត់ហេតុស្ដាប់ចម្លើយ ឡង់ ហ៊ែល ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **E3/5251**, ERN KH 00233287-00233288។

## 3. ការប្រជុំស្តីពីជនជាតិវៀតណាម

១៩៨៥. សៅ សាក់ បានឱ្យដឹងថា ក្នុងពេលប្រជុំ គឺមាននិយាយតែពីបញ្ហាបង្កបង្កើនផល ពុំដែលនិយាយពីជនជាតិវៀតណាមម្តងណាឡើយ[1985]។ ចម្លើយមួយនេះត្រូវបានគាំទ្រដោយ សោម រស់ និង ឡុង ហ៊ែល នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគាត់៖ ពុំមានការប្រជុំប្រាប់ពីមូលហេតុចាប់ខ្លួនគ្រួសារវៀតណាមឡើយ[1986]។

## 4. ការប្រព្រឹត្តលើជនជាតិកម្ពុជាដែលមានសហព័ទ្ធជាជនជាតិវៀតណាម និងលើកូនៗដែលមានម្តាយ ឬ ឪពុក ជាជនជាតិវៀតណាម

### 4.ក. ការប្រព្រឹត្តលើជនជាតិខ្មែរដែលមានសហព័ទ្ធជាជនជាតិវៀតណាម

១៩៨៦. ដូចដែលបានរៀបរាប់ខាងដើម គឺថាវាគ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីសន្និដ្ឋានបានថាមានការសម្លាប់មនុស្សនៅភូមិអន្លង់ទ្រា និងនៅកន្លែងផ្សេងទៀត បានឡើយ។

១៩៨៧. យោងតាមភស្តុតាងដដែលនេះដែរ អង្គជំនុំជម្រះត្រូវកត់សម្គាល់ថា គេក៏មិនអាចបង្ហាញភស្តុតាងឱ្យឃើញថាសហព័ទ្ធរបស់ជនជាតិវៀតណាម ត្រូវបានសម្លាប់ ឬទទួលរងការធ្វើបាបបានឡើយ។

១៩៨៨. សហចៅក្រមស៊ើបអង្កេតបានផ្អែកជាអាទិ៍លើមូលដ្ឋានចម្លើយរបស់ ពៅ ហុង ដើម្បីសន្និដ្ឋានថា គឺមេភូមិដែលជាអ្នកផ្តល់ព័ត៌មានថាមានការត្រៀមទុកនូវ "ការប្រព្រឹត្តជាពិសេសទៅលើប្តី ឬ ប្រពន្ធរបស់ជនជាតិវៀតណាម និងអ្នកដែលមានឪពុក ឬម្តាយជាជនជាតិវៀតណាម"[1987]។ ក៏ប៉ុន្តែ កិច្ចសម្ភាសមួយនេះ និងកិច្ចសម្ភាសផ្សេងទៀតដែលត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ ត្រូវ

---

[1985] សៅ សាក់៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៧២ មុនម៉ោង 15.19.31។

[1986] កំណត់ហេតុស្តាប់ចម្លើយ សោម រស់ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/5246**, ERN KH 00225367, កំណត់ហេតុស្តាប់ចម្លើយ ឡុង ហ៊ែល ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/5251**, ERN KH 00233288។

[1987] ដីកាដំណោះស្រាយ កថាខណ្ឌ ៨១៣។

បានធ្វើឡើងនៅក្រៅក្របខ័ណ្ឌតុលាការ ឬមួយក៏គ្រាន់តែជាលទ្ធផលនៃការស្មានដែលខ្វះមូលដ្ឋាន និងមិនត្រូវបានបញ្ជាក់ថាពិតជាដូច្នេះមែន នៅក្នុងអំឡុងពេលសវនាការ តែប៉ុណ្ណោះ[1988]។

### 4.២. ទ្រឹស្តីទាក់ទងនឹងខ្សែស្រឡាយខាងម្តាយ

១៩៨៩. យោងតាមកថាខណ្ឌ ២១៥ និងកថាខណ្ឌ ៨០៧-៨០៨ នៃដីកាដំណោះស្រាយ ទ្រឹស្តីមួយនេះ ត្រូវបានបក្សកុម្មុយនីស្តអនុម័តសម្រេចនៅក្នុងគោលនយោបាយបំផ្លាញក្រុមជនជាតិវៀតណាម។ ការអនុវត្តទ្រឹស្តីមួយនេះ គឺថាបើម្តាយជាជនជាតិវៀតណាម កូនៗក៏ត្រូវសម្លាប់ដូចគ្នា។ ផ្ទុយទៅវិញ ប្រសិនបើឪពុកជាជនជាតិវៀតណាម កូនៗ និងប្រពន្ធ អាចមានជីវិតរស់នៅបន្តទៀត។ ពាក់ព័ន្ធករណីភូមិអន្លង់ទ្រា ចៅក្រមស៊ើបអង្កេតបានយោងទៅលើសាក្សីជាច្រើននាក់ ដើម្បីគាំទ្រទ្រឹស្តីមួយនេះ ក្នុងនោះមានសាក្សី នាង ណាត, សោម រស់, វ៉ាន់ ម៉ៅ, ឡុង ហ៊ែល និង សៅ សាក់ ដែលគាត់ជាសាក្សីតែម្នាក់គត់ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ[1989]។

១៩៩០. ប៉ុន្តែ កថាខណ្ឌ ៨០៩ នៃដីកាដំណោះស្រាយ លើកឡើងថា៖ "កូនដែលកើតពីម្តាយខ្មែរ និងឪពុកវៀតណាម ទំនងជាមិនត្រូវបានគេទុកជីវិតគ្រប់ពេលនោះទេ"។ ត្រង់ចំណុចនេះក៏ដូចគ្នា គឺថាចៅក្រមស៊ើបអង្កេតបានយោងទៅលើសាក្សីដដែលៗដែលបានបង្ហាញ លើកលែងតែសាក្សី ឡុង ហ៊ែល ចេញ។

១៩៩១. ដូចដែលទើបបានឃើញពីខាងលើ ធាតុផ្សំនៃបទឧក្រិដ្ឋនៅក្នុងរឿងរ៉ាវរបស់សាក្សីផ្សេងៗគ្នាទាំងអស់នេះ ពិតជាគ្មានភស្តុតាងគ្រប់គ្រាន់បង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យបាន នេះម្យ៉ាង ហើយម្យ៉ាងទៀត គឺថាការពិនិត្យលើទ្រឹស្តីបែបសន្មត ទាក់ទងនឹងខ្សែស្រឡាយខាងម្តាយ ក្នុងមួយករណីម្តងៗ ក៏វាគ្មានភស្តុតាងបង្ហាញឱ្យឃើញពីការអនុវត្តនូវទ្រឹស្តីមួយនេះដែរ។

---

[1988] ដីកាដំណោះស្រាយ កំណត់សម្គាល់ចុងឯកសារ ៣៤៧៧, បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ពៅ ហុង ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០១ឯកសារ **E3/7165a**, ERN KH 00502658-00502659។

[1989] ដីកាដំណោះស្រាយ កំណត់សម្គាល់ចុងឯកសារ ៣៤៦០។

១៩៩២. ប្រហែលប្រាំខែក្រោយការចាប់ខ្លួនម្តាយរបស់គាត់ សៅ សាក់ ត្រូវបានមេភូមិ ម៉ន កោះហៅប្រជុំក្នុងវត្តអន្លង់ទ្រា ជាមួយនារីចាមម្នាក់ និងបុរសពីរនាក់ទៀត ជាប្រជាជន ១៧ មេសា[1990]។ គាត់ និងបុរសទាំងពីរនាក់នេះ ត្រូវបានជាប់ឃុំឃាំងអស់ដប់ថ្ងៃ នៅអង្គរអង្គ ខណៈដែលនារីចាម ត្រូវបានដោះលែង។ ក្នុងពេលជាប់ឃុំឃាំង គេបានសួរ សៅ សាក់ ថាតើឪពុកគាត់ជាជនជាតិខ្មែរមែនដែរឬអត់ ហើយប្រកបការងារអ្វីដែរ។ ក្រោយមក គេបានឱ្យ សៅ សាក់ ធ្វើការនៅរោងបាយក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ននេះ អស់រយៈពេលបីបួនថ្ងៃ មុននឹងដោះលែងគាត់ឱ្យមានសេរីភាពឡើងវិញ[1991]។ ចម្លើយរបស់គាត់ បង្ហាញឱ្យឃើញថាគាត់មិនត្រូវបានសួរសំណួរទាក់ទងនឹងម្តាយជនជាតិវៀតណាមរបស់គាត់នោះទេ។

១៩៩៣. ក្នុងចម្លើយរបស់ខ្លួន ឯម ប៊ុននីម បានលើកឡើងដូចគ្នាថា ក្រោយ "ព្រឹត្តិការណ៍ សោ ភឹម" ប្រធានភូមិ និងកងឈ្លប បានប្រមូលកូនៗជនជាតិវៀតណាម[1992]។ ផ្ទុយទៅវិញ សាក្សីរូបនេះមិនបានពន្យល់ពីមូលហេតុនៃការប្រមូលក្មេងៗនេះ និងប្រភពនៃព័ត៌មានមួយនេះ។ ជាមួយគ្នានេះដែរ ឯម ប៊ុននីម បានប្រាប់ថាគាត់ត្រូវបានដកចេញពីកន្លែងឈរជើងកងទ័ពនៅសមរភូមិ មកធ្វើជាកង ចល័ត។ បើតាមសម្តីជីដូនរបស់គាត់ មូលហេតុនៃការផ្លាស់ប្តូរនេះ គឺបណ្តាលមកពីម្តាយគាត់ជាជនជាតិវៀតណាម តែជីដូនគាត់មិនបានផ្តល់អំណះអំណាងចំពោះសម្តីរបស់ខ្លួនគាត់ឡើយ[1993]។

១៩៩៤. ចម្លើយទាំងនេះកាន់តែចម្លែកថែមទៀត ព្រោះថា នាង ណាត ជាប្អូនស្រីរបស់ ឯម ប៊ុននីម ពុំធ្លាប់បានលើកឡើងពីរឿងនេះទេ។ ផ្ទុយទៅវិញ កំណត់ហេតុស្តាប់ចម្លើយរបស់គាត់ បង្ហាញថាគាត់មិនត្រូវបានគេធ្វើបាប គាត់អាច "នៅរៀនរហូត" ហើយពេលខ្លះ ត្រូវស្ទូងស្រូវនៅតាមស្រែ ហើយ

[1990] សៅ សាក់៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/363.1** ទំព័រ ២២ ប្រហែលម៉ោង 10.36.23, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/7780**, ERN KH 00233296។

[1991] សៅ សាក់៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៧០ មុនម៉ោង 15.15.01 ទំព័រ ៧១ ប្រហែលម៉ោង 15.15.01, ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/363.1** ទំព័រ ២២ ក្រោយម៉ោង 10.33.27។

[1992] កំណត់ហេតុស្តាប់ចម្លើយ ឯម ប៊ុននីម ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ឯកសារ **E3/7760**, ERN KH 00296236។

[1993] កំណត់ហេតុស្តាប់ចម្លើយ ឯម ប៊ុននីម ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ឯកសារ **E3/7760**, ERN KH 00296235។ អង្គជំនុំជម្រះមិនអាចផ្អែកលើចម្លើយរបស់ នាង ណាត បានទេ ពីព្រោះគាត់បានបញ្ជាក់ថា គាត់ទទួលបានព័ត៌មាននេះពី ឯម ប៊ុននីម ផ្ទាល់៖ កំណត់ហេតុស្តាប់ចម្លើយ នាង ណាត ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/7779**, ERN KH 00233292។

គាត់ឆ្លើយថា ដោយសារតែឪពុកគាត់ជាខ្មែរ បានធ្វើឱ្យគាត់អាចរួចផុតពីសេចក្ដីស្លាប់[1994]។ យ៉ាងណាមិញ ក្នុងអំឡុងពេលសវនាការ គឺពុំមានការនិយាយទាក់ទងនឹងការចាប់ខ្លួន ឬការធ្វើបាបបែបសន្ធឹតមកលើកូនៗរបស់ យឺន ទេ។ ម្យ៉ាងវិញទៀត ការប្រមូលមនុស្សដែល សៅ សាក់ បានលើកឡើងក្នុងសវនាការ គឺមានតែការប្រមូលដែលរៀបចំឡើងក្នុងក្របខ័ណ្ឌនៃការបញ្ជូនជនជាតិវៀតណាមទៅស្រុកវិញ ប៉ុណ្ណោះ[1995]។

១៩៩៥. ដោយគ្មានភស្តុតាងផ្សេងទៀត អ្វីដែលគួរឱ្យកត់សម្គាល់គឺថាសក្ខីកម្មទាំងនេះគ្មានភាពស៊ីសង្វាក់រវាងគ្នានឹងគ្នា ហើយទោះយ៉ាងណាក៏ដោយ ក៏គេពុំអាចសន្និដ្ឋានបានថាមានការប្រព្រឹត្តជាពិសេសណាមួយមកលើកូនៗ ដោយសារតែម្ដាយជាជនជាតិវៀតណាម បានឡើយ។

១៩៩៦. ក្នុងកថាខណ្ឌ ៧៩៩ នៃដីកាដំណោះស្រាយ ចៅក្រមស៊ើបអង្កេត បានបង្ហាញករណីស្ត្រីម្នាក់ទៀតដែលម្ដាយជនជាតិវៀតណាមរបស់គាត់ ត្រូវគេចាប់ខ្លួន ហើយចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា៖ "ហេតុផលតែមួយគត់ដែលគាត់អាចនៅរស់រានមានជីវិត ដោយសារអ្នកភូមិជួយយកអាសាហើយបកស្រាយប្រាប់កម្មាភិបាល ប.ក.ក ថា៖ "ខ្ញុំមានឈាមជ័រជាខ្មែរ""។ ក្នុងករណីនេះចៅក្រមស៊ើបអង្កេតនៅតែបន្តផ្អែកលើមូលដ្ឋានកំណត់ហេតុស្ដាប់ចម្លើយរបស់ ឯម ប៊ុននីម[1996]។ ក៏ប៉ុន្តែ តម្លៃជាភស្តុតាងនៃចម្លើយរបស់គាត់ ដែលផ្អែកជាសំខាន់តែលើការនិយាយតៗគ្នា មិនត្រឹមតែមានតិចតួចបំផុតប៉ុណ្ណោះទេ តែអ្វីដែលពិសេសជាងនេះទៅទៀតនោះ គឺថា ការយោងមួយនេះនៅក្នុងដីកាដំណោះស្រាយ មិនស៊ីគ្នាទៅនឹងអ្វីដែលបាននិយាយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់ថែមទៀត។ ក្នុងកំណត់ហេតុស្ដាប់ចម្លើយ សាក្សីបាននិយាយដូច្នេះថា៖ "ខ្ញុំត្រូវបានអ្នក

---

[1994] កំណត់ហេតុស្ដាប់ចម្លើយ នាង ណាត ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/7779**, ERN KH 00233292។

[1995] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/363.1** ទំព័រ ១៣ ក្រោយម៉ោង 09.44.16 (គាត់គ្រាន់តែឮពីអ្នកភូមិ គឺមិនមែនឈ្លបទេ ថា គេបញ្ជូនជនជាតិវៀតណាមទៅវៀតណាមវិញ ពីព្រោះពួកគេគ្មានសិទ្ធិរស់នៅកម្ពុជាទេ) ទំព័រ ២៤ ក្រោយម៉ោង 10.40.15 ("មានតែប្រជាជនយើងស្មានក្នុងចិត្តហ្នឹងថា ហ៊ី! បើគេជូនទៅ គេឱ្យទៅប្រទេសវៀតណាម"។ គាត់មិនអាចប្រាប់ឈ្មោះជនជាតិវៀតណាមទាំងនេះបានទេ ពីព្រោះនេះគ្រាន់តែជាពាក្យចចាមអារ៉ាម។ គឺចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៨)។

[1996] ដីកាដំណោះស្រាយ កំណត់សម្គាល់ចុងឯកសារ ៣៤០៦។

ភូមិជួយយកអាសា ហើយបកស្រាយថា ខ្ញុំមានឈាមជ័រជាខ្មែរទេ។ ឪពុកខ្ញុំ គឺជាខ្មែរសុទ្ធ"[1997]។ ចម្លើយនេះបង្ហាញឱ្យឃើញថា ដូចគ្នានឹងប្អូនស្រីគាត់ដែរ[1998] និងបើទោះជាមានការចាប់ខ្លួនម្តាយពួកគាត់ ដែលអ្នកភូមិដឹងយ៉ាងច្បាស់ថាជាជនជាតិវៀតណាមក៏ដោយ ក៏ ឯម ប៊ុននីម មិនមានភាពចាំបាច់ក្នុងការលាក់អត្តសញ្ញាណរបស់ខ្លួនឡើយ។

១៩៩៧. ចម្លើយរបស់ សោម រស់ កាន់តែគួរឱ្យសង្ស័យខ្លាំងថែមទៀត។ នៅពេលចោទសួរដោយអ្នកស៊ើបអង្កេត សាក្សីបានអះអាងថា នៅពេលដែលមានម្តាយ ឬ ឪពុក ជាជនជាតិវៀតណាម កូនៗក៏ត្រូវចាប់ខ្លួនដូចគ្នា ដោយសាក្សីបានផ្តល់ឧទាហរណ៍ករណីរបស់ យឺន (ម្តាយរបស់ នាង ណាត និង ឯម ប៊ុននីម) ដែលកូនៗរបស់គាត់ក៏ត្រូវចាប់ខ្លួនដូចគ្នា តែរត់រួច[1999]។ ក៏ប៉ុន្តែ ដូចដែលយើងទើបបានឃើញរួចហើយ ក្នុងចំណោមកូនទាំងពីរ គឺគ្មានកូនណាម្នាក់ត្រូវបានចាប់ខ្លួននោះឡើយ។ ម្យ៉ាងវិញទៀត ចម្លើយមិនត្រឹមត្រូវរបស់ សោម រស់ គឺផ្ទុយគ្នា ព្រោះថាវាក៏មិនបានជួយគាំទ្រដល់ទ្រឹស្តីទាក់ទងនឹងខ្សែស្រឡាយខាងម្តាយ ដោយសារថាវាបានលើកឡើងពីករណីរបស់ថាវ ជាឪពុកចិនកាត់វៀតណាម ហើយដែលកូនៗរបស់គាត់ស្ទើរតែគ្រប់គ្នា ត្រូវបានចាប់ខ្លួន ដូចឪពុកដែរ។

១៩៩៨. ដូចគ្នានេះដែរចំពោះគ្រួសារ វ៉ាន់ ម៉ៅ ដែលមានឪពុកជាជនជាតិវៀតណាម។ ប្រសិនបើគេនៅនិយាយថាកូនៗរបស់គាត់ ត្រូវបានចាប់ខ្លួនក្រោយគាត់ នោះទ្រឹស្តីទាក់ទងនឹងខ្សែស្រឡាយខាងម្តាយ ក៏ត្រូវរងផលប៉ះពាល់ដូចគ្នា។

១៩៩៩. ដូច្នេះ ក្រៅពីគ្រួសាររបស់ ឡុង ហ៊ែល ដែលទាក់ទងនឹងគ្រួសារមួយនេះ គឺវាគ្មានភស្តុតាងបង្ហាញឱ្យឃើញពីរឿងរ៉ាវដែលបានកើតឡើង ដូចដែលគេបានឃើញពីខាងលើ ការវិភាគលើភស្តុតាងបង្ហាញឱ្យឃើញថាទ្រឹស្តីទាក់ទងនឹងខ្សែស្រឡាយខាងម្តាយ មិនត្រូវបានអនុវត្តនៅក្នុងភូមិអន្លង់ទ្រានោះទេ។

---

[1997] កំណត់ហេតុស្តាប់ចម្លើយ ឯម ប៊ុននីម ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ឯកសារ **E3/7760**, ERN KH 00296236 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1998] កំណត់ហេតុស្តាប់ចម្លើយ នាង ណាត ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ឯកសារ **E3/7779**, ERN KH 00233292។

[1999] កំណត់ហេតុស្តាប់ចម្លើយ សោម រស់ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/5246**, ERN KH 00225367។

២០០០. ប្រសិនបើគេយកតាមភាពសមហេតុសមផលរបស់ចៅក្រមស៊ើបអង្កេតដែលបានចាត់ទុកទ្រឹស្តីនេះ ថាជាផ្នែកមួយនៃគោលនយោបាយអនុម័តដោយបក្សកុម្មុយនីស្តកម្ពុជា គេត្រូវបន្តភាពសមហេតុសមផលនេះរហូតដល់ទីបញ្ចប់ និងត្រូវកត់សម្គាល់ថា ការចាប់ខ្លួន និងសម្លាប់ដែលរងការចោទប្រកាន់ និងមិនសមស្របតាមគោលនយោបាយមួយនេះ គឺមិនអាចនិយាយទម្លាក់ទៅលើអ្នកទទួលខុសត្រូវបក្សកុម្មុយនីស្តកម្ពុជាបានឡើយ ព្រោះវាជាការរំលោភលើគោលនយោបាយសន្មតមួយនេះ។

## ខ. ស្រុកព្រៃវែង (ភូមិពោធិ៍ចិន្តាំ និងភូមិស្វាយអន្ទរ)

២០០១. យោងតាមប្រព័ន្ធកំណត់ព្រំដែនរដ្ឋបាល ពោធិ៍ចិន្តាំ និងស្វាយអន្ទរ គឺជាភូមិពីរស្ថិតនៅក្នុងឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ក្នុងតំបន់ ២០ នៃភូមិភាគបូព៌ា[2000]។

២០០២. យោងតាមសាក្សីដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ កងទ័ពខ្មែរក្រហមបានកាន់កាប់ភូមិពោធិ៍ចិន្តាំ ក្នុងអំឡុងឆ្នាំ ១៩៧២-១៩៧៣ ដោយកងទ័ពទាំងនេះមានលក្ខណៈពិសេសមួយត្រង់ថា ភាគច្រើនជាជនជាតិវៀតណាម (៧០% ជាជនជាតិវៀតណាម និង ៣០% ទៀត ជាជនជាតិខ្មែរ)។ ហេតុដូច្នេះ គឺពួកវៀតណាមដែលជាអ្នកគ្រប់គ្រងតំបន់មួយនេះ នៅមុនឆ្នាំ ១៩៧៥[2001]។ ម្យ៉ាងវិញទៀត សាក្សីផ្សេងៗទៀតបានអះអាងថា កងទ័ពវៀតណាមទាំងនោះ និង "ខ្មែររំដោះ"

---

[2000] ថេង ផល៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/370.1** ទំព័រ ៦៧ មុនម៉ោង 15.27.31, ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/371.1** ទំព័រ ៥៦ មុនម៉ោង 14.18.35, កំណត់ហេតុស្តាប់ចម្លើយ កុល លីម ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/5243**, ERN KH 00224776, កំណត់ហេតុស្តាប់ចម្លើយ អៀង អុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/9352**, ERN KH 00225355, កំណត់ហេតុស្តាប់ចម្លើយ ស៊ិន ស៊ន់ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/9339**, ERN KH 00232824។

[2001] ថេង ផល៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/370.1** ទំព័រ ៦៧ មុនម៉ោង 15.27.31, កំណត់ហេតុស្តាប់ចម្លើយ អៀង អុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/9352**, ERN KH 00225355។

បានកាន់កាប់ឃុំមួយនេះ អស់រយៈពេលប្រហែលពីរឆ្នាំ ក្រោយរបបសម្តេចនរោត្តម សីហនុ ដួលរលំ[2002]។

## 1. ការចោទប្រកាន់ពីបទមនុស្សឃាតលើជនជាតិវៀតណាម

### 1.ក. ភូមិពោធិ៍ចិន្តាំ

២០០៣. ក្រោយឆ្នាំ ១៩៧៥ នៅក្នុងភូមិពោធិ៍ចិន្តាំ គឺមានវៀតណាមតែបីគ្រួសារប៉ុណ្ណោះ ក្នុងនោះមាន វ៉ាន់ ង៉ាង (ប្តីរបស់ ឡេង សាម៉េត ហៅ តិច) ជុយ (ប្តីរបស់ ដួង អឿន) និង សាន (ប្រពន្ធរបស់ ឡាច នី)[2003]។ ដួង អឿន បានបញ្ជាក់ក្នុងសវនការថា នៅក្នុងភូមិ គាត់ស្គាល់តែបីគ្រួសារនេះទេ។ គាត់មិនដឹងអ្វីទាំងអស់ ទាក់ទងនឹងភូមិផ្សេងទៀត[2004]។

#### i. ករណី ង៉ាង (ប្តីរបស់ ឡេង សាម៉េត ហៅ តិច)

២០០៤. ង៉ាង ស្ថិតក្នុងចំណោមជនជាតិវៀតណាមដែលបានមករស់នៅក្នុងភូមិពោធិ៍ចិន្តាំ។ គាត់បានរៀបការជាមួយ ឡេង សាម៉េត នៅមុនឆ្នាំ ១៩៧៥។ ក្នុងចំណោងអាពាហ៍ពិពាហ៍នេះ គាត់បានកូនពីរនាក់ គឺ ង៉ុយ (ប្រុស) និង ង៉ាង តុប (ស្រី)[2005]។

---

[2002] កំណត់ហេតុស្តាប់ចម្លើយ កុល លឹម ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/5243**, ERN KH 00224775, បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឈួន រី ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7559**, ERN KH 00034276 (កាលជំនាន់នុំងណា ពី ៧០ វៀតណាមចូលស្រុកយើងហើយ)។

[2003] <u>ថេង ផល</u>៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/370.1** ទំព័រ ៧២ ក្រោយម៉ោង 15.46.27, <u>ដួង អឿន</u>៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៣១ ក្រោយម៉ោង 11.06.46, <u>ឡាច គ្រី</u>៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៦៦-៦៧ ក្រោយម៉ោង 15.06.14 ទំព័រ ៨២ មុនម៉ោង 15.54.12, កំណត់ហេតុស្តាប់ចម្លើយ ស៊ិន ស៊ន់ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/9339** ERN KH 00232824។

[2004] <u>ដួង អឿន</u>៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៣២ មុនម៉ោង 11.12.56។

[2005] <u>ថេង ផល</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/371.1** ទំព័រ ៣៥ ក្រោយម៉ោង 11.10.54, បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ង៉ាង តុប ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7491**, ERN KH 00033535។

២០០៥. នៅចំពោះមុខតុលាការ ថេង ផល បានឆ្លើយថា នៅឆ្នាំ ១៩៧៦-១៩៧៧ ក្រុមរបស់គាត់ដែលមាន ង៉ាងនៅក្នុងនោះផង ត្រូវបានគេឱ្យទៅកាប់រពាក់ ដោយដំបូងថាត្រូវទៅមួយខែ តែប្រាំមួយថ្ងៃក្រោយមក សេង អនុប្រធានភូមិ បានហៅមកវិញ។ ពេលធ្វើដំណើរត្រលប់មកភូមិវិញ ច្រវាក់កង់របស់ សេង បានដាច់ ហើយដូច្នេះ គាត់ក៏សុំឱ្យង៉ាងជួយតច្រវាក់ឱ្យ។ ថេង ផល និងអ្នកដទៃទៀត បានធ្វើដំណើរបន្តទៅភូមិ។ សាក្សីបានឆ្លើយថាគាត់លែងបានជួបង៉ាង តាំងពីពេលនោះមក[2006]។

២០០៦. ថេង ផល បានបញ្ជាក់ថាបានបែកពី ង៉ាង នៅមុខវត្តចាស់ ក្នុងភូមិអូរកណ្តោល ដែលវត្តមួយនេះត្រូវបានប្រើប្រាស់ធ្វើជាមន្ទីរសន្តិសុខ តែគាត់មិនដឹងថាតើ ង៉ាង ត្រូវគេនាំទៅកន្លែងនោះដែរឬអត់។ សាក្សីពុំបានឃើញរឿងរ៉ាវកើតឡើងចំពោះង៉ាង នោះទេ[2007]។ គឺនៅពេលទៅដល់ផ្ទះទៅហើយ ដែលគាត់បានឮអ្នកភូមិនិយាយថា ប្រជាជនវៀតណាមត្រូវគេ "យកទៅដាក់រទេះសេះ យកទៅកើតអស់ហើយ គេយកសម្លាប់ចោលហើយ" ដែលធ្វើឱ្យគាត់កើតក្តីបារម្ភចំពោះ ង៉ាង[2008]។

២០០៧. ក្នុងកិច្ចសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ឡេង សាម៉េត ហៅ តិច ជាប្រពន្ធរបស់ ង៉ាង បានបញ្ជាក់ថា ថេង ផល ជាអ្នកនិយាយរៀបរាប់ប្រាប់គាត់ពីរឿងរ៉ាវដែលគាត់ (ថេង ផល) បានបែកពីប្តីរបស់គាត់ (ឡេង សាម៉េត) ហើយដែលគាត់ (ឡេង សាម៉េត) លែងបានជួបតាំងពីពេលនោះមក[2009]។ ព្រឹត្តិការណ៍នេះកើតឡើងចុងឆ្នាំ ១៩៧៨ គឺមួយខែមុនការជម្លៀស ឡេង សាម៉េត

---

[2006] ថេង ផល៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/371.1** ទំព័រ ២៩-៣៣ ចន្លោះម៉ោង 10.52.47 ដល់ម៉ោង 11.07.07 ទំព័រ ៦៧ មុនម៉ោង 15.10.20។

[2007] ថេង ផល៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/371.1** ទំព័រ ២៩-៣៣ ចន្លោះម៉ោង 10.52.47 ដល់ម៉ោង 11.07.07 ទំព័រ ៦៧ ក្រោយម៉ោង 15.11.38។

[2008] ថេង ផល៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/371.1** ទំព័រ ៣២ ក្រោយម៉ោង 11.03.05។

[2009] កំណត់ហេតុស្តាប់ចម្លើយ ឡេង សាម៉េត ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩ ឯកសារ **E3/7810**, ERN KH 00271388, បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡេង សាម៉េត ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ ឯកសារ **E3/7594**, ERN KH 00033496។ គួរកត់សម្គាល់ថា ក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ឡេង សាម៉េត បានបញ្ជាក់កាលបរិច្ឆេទ គឺចុងឆ្នាំ ១៩៧៧៖ បទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ ឯកសារ **E3/7594**, ERN KH 00033516។

ទៅបាត់ដំបង និងពោធិ៍សាត់[2010]។ ង៉ាង តុប ជាកូនម្នាក់ក្នុងចំណោមកូនទាំងពីររបស់ ង៉ាង ហើយ ដែលកូនទាំងពីរបានរស់នៅក្នុងភូមិដដែល ក្រោយពីការចាកចេញរបស់ឪពុក បានឆ្លើយប្រាប់ មជ្ឈមណ្ឌលឯកសារកម្ពុជាថា គាត់ក៏ដូចគ្នា គឺគាត់បានដឹងពីការបាត់ខ្លួនឪពុក តាមរយៈម្ដាយ និង អ្នកកាប់រពាក់ និយាយតៗគ្នា[2011]។ ដូច្នេះ ចម្លើយគាត់នៅក្រៅក្របខ័ណ្ឌតុលាការ ពុំមានអ្វីលើសពី ចម្លើយម្ដាយរបស់គាត់ឡើយ។

២០០៨. រឿងរ៉ាវរបស់ ថេង ផល បានផ្ដល់ភ័ស្ដុតាងតិចតួចប៉ុណ្ណោះ ទាក់ទងនឹងជោគវាសនារបស់ ង៉ាង។ តាមការពិតទៅ គាត់បានឃើញតែឈុតឆាកមួយ ដែលក្នុងនោះ សេង សុំឱ្យង៉ាងជួយជួសជុលកង់ ឱ្យគាត់។ អ្វីផ្សេងពីនេះ គឺគ្រាន់តែជាការស្មានប៉ុណ្ណោះ។ សេណារីយ៉ូដែលក្នុងនោះ សេង ជាអ្នក ទទួលខុសត្រូវមូលដ្ឋាន ត្រូវការរៀបចំជាការសម្ដែងមួយដើម្បីបំបែក ង៉ាង យកទៅសម្លាប់ ពិតជា មិនគួរឱ្យជឿបាន ហើយជាពិសេសទៅទៀតនោះ វាគ្រាន់តែជាសេណារីយ៉ូប៉ុណ្ណោះ។ តាមរយៈ រឿងរ៉ាវមួយនេះ គេមិនអាចបង្ហាញឱ្យឃើញច្បាស់ពីធាតុផ្សំឧក្រិដ្ឋកម្ម និងចេតនាធ្វើឱ្យមនុស្ស ស្លាប់ បានឡើយ។

២០០៩. សក្ខីកម្មរបស់ ដួង អឿន ក្នុងអំឡុងពេលសវនាការ មិនបានបំភ្លឺឱ្យបានច្បាស់ជាងនេះ ទាក់ទងនឹង កាលៈទេសៈនៃការបាត់ខ្លួនរបស់ ង៉ាង។ ជាប្រពន្ធជនជាតិវៀតណាម ឈ្មោះ ជុយ និងជាអ្នករស់ នៅក្នុងភូមិនេះ គាត់បានឮគេនិយាយថា ង៉ាង ត្រូវបានឱ្យទៅកាប់រពាក់ ដោយមិនឃើញត្រលប់មក វិញ។ ក៏ប៉ុន្តែ នៅក្នុងសវនាការ គាត់មិនបានពន្យល់ថាតើគាត់ដឹងថា ង៉ាង បាត់ខ្លួនដោយរបៀប ណា។ គាត់បាននិយាយថា ង៉ាង ជាមនុស្សដំបូងគេក្នុងភូមិ ដែលត្រូវបាននាំទៅ តែគាត់មិនអាច និយាយបានថានៅពេលណានោះទេ[2012]។ គេត្រូវបញ្ជាក់ថា ដួង អឿន មានភាពមិនច្បាស់លាស់

---

[2010] កំណត់ហេតុស្ដាប់ចម្លើយ ឡេង សាម៉េត ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩ឯកសារ **E3/7810**, ERN KH 00271389។

[2011] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ង៉ាង តុប ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7491**, ERN KH 00033537-00033538។ម្យ៉ាងវិញទៀត ឡេង សាម៉េត បានបញ្ជាក់អះអាង គាត់បានប្រាប់កូនៗអំពីហេតុការណ៍ ពាក់ព័ន្ធនឹងឪពុករបស់ពួកគេ និងថាស្លាប់បាត់ហើយ៖ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡេង សាម៉េត ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ឯកសារ **E3/7594**, ERN KH 00033529។

[2012] ដួង អឿន៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/381.1** ទំព័រ ១៤ ក្រោយម៉ោង 09.44.48 ទំព័រ ២៩ មុន ម៉ោង 11.01.35 ទំព័រ ២៩ ក្រោយម៉ោង 11.01.35។

ទាក់ទងនឹងកាលបរិច្ឆេទ[2013]។ ប៉ុន្តែ ក្នុងឈុតព្រឹត្តិការណ៍របស់គាត់ គឺថា៖ "ង៉ាង យកទៅមុនគេ បង្អស់ បានតមកអ៊ីចឹងទៅ ឡាច នី ហើយប្ដីខ្ញុំក្រោយគេ"[2014]។

២០១០. ក្នុងអំឡុងពេលសវនាការ ឡាច គ្រី ប្អូនប្រុស ឡាច នី បានបញ្ជាក់អះអាងពីឈុតនៃព្រឹត្តិការណ៍នេះ ព្រោះគាត់បានឱ្យដឹងថា ប្រពន្ធបងប្រុសគាត់ ត្រូវ "ចាប់នៅៗឆ្នាំ៧៧" ង៉ាង "ចាប់ [...] ចុងឆ្នាំ ៧៥ [...] ប្រហែលជាខែ ១២ ឬមួយក៏ចូលៗខែ១២, ១១, ១២ ហ្នឹង" ហើយ ជុយ "ចាប់ខ្លួននៅ ឆ្នាំ៧៦។ រយៈពេលឃ្លាតគ្នាប្រហែលជាជិតមួយឆ្នាំ"[2015]។

២០១១. ម្យ៉ាងវិញទៀត ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរនាក់នេះ គឺផ្ទុយគ្នាពីសក្ខីកម្មរបស់ ថេង ផល ដែលមានទម្ងន់តិចតួចបំផុត។ គេត្រូវរំឭកថា ថេង ផល បានពន្យល់ក្នុងអំឡុងពេលសវនាការ ថាគាត់មានការបារម្ភចំពោះ ង៉ាង ក្រោយពីមានគេនិយាយតគ្នាពីជោគវាសនារបស់ ជុយ[2016]។ ក៏ ប៉ុន្តែ ក្រៅពីការណ៍ដែលគ្មានភ័ស្តុតាងណាមួយទាក់ទងនឹងការសម្លាប់ ជុយ ជាយថាហេតុនោះ ការ ពន្យល់របស់ ថេង ផល ពិតជាមិនអាចយល់បាន និងមានលក្ខណៈមិនសមហេតុសមផល ក្នុង

---

[2013] ចំពោះប្ដីរបស់គាត់ ដួង អឿន បានបញ្ជាក់ថា ប្ដីគាត់ត្រូវគេយកទៅបាត់ នៅឆ្នាំ ១៩៧៧ ក្នុងរដូវច្រូត គឺមួយខែ ក្រោយពេល ខ្មែរក្រហមចូលមកក្នុងភូមិរបស់គាត់ (ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381** ទំព័រ ១១ ចន្លោះម៉ោង 09.33.13 ដល់ម៉ោង 09.35.25 ទំព័រ ២៣ មុនម៉ោង 10.42.00 ទំព័រ ៣៧ ក្រោយម៉ោង 11.27.30 ទំព័រ ៣៧ ក្រោយម៉ោង 11.29.44 ទំព័រ ៤៦ មុនម៉ោង 14.02.57)។ នៅពេលសួរដេញដោលអំពីចម្លើយគួរឱ្យភ្ញាក់ផ្អើលនេះ គាត់នៅតែរក្សាចម្លើយ ដដែលពីរដងថា ឆ្នាំ ១៩៧៧ ជាឆ្នាំដែលខ្មែរក្រហមចូលមកដល់ក្នុងភូមិរបស់គាត់ (ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១៧-១៨ មុនម៉ោង 10.02.01)។ ត្រង់ចំណុចនេះ ដួង អឿន និយាយផ្ទុយគ្នាជាមួយ ថេង ហ៊ុយ និង ឡាច គ្រី ដែលថា ខ្មែរក្រហមមកដល់នៅឆ្នាំ ១៩៧០ ឬឆ្នាំ ១៩៧២ (ថេង ហ៊ុយ៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ឯក សារ **E1/370.1** ទំព័រ ៦៧ មុនម៉ោង 15.27.31 (ឆ្នាំ ១៩៧០) ទំព័រ ៧៧-៧៨ មុនម៉ោង 15.30.15 (ឆ្នាំ ១៩៧២), <u>ឡាច គ្រី</u>៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៤៩ ក្រោយម៉ោង 13.53.49 ទំព័រ ៥០ មុនម៉ោង 13.58.25)។ តាមពិត និងជាទូទៅ ដួង អឿន និយាយផ្ទុយនឹងភ័ស្តុតាងទាំងមូលនៅក្នុងសំណុំរឿង ដែលបញ្ជាក់ថា ខ្មែរក្រហម ទៅដល់ពាសពេញផ្ទៃប្រទេស យ៉ាងយូរបំផុត ត្រឹមឆ្នាំ ១៩៧៥។ ដូច្នេះ វាជាការសមហេតុផល ក្នុងការសន្និដ្ឋានថា គាត់ច្រឡំ កាលបរិច្ឆេទ។

[2014] <u>ដួង អឿន</u>៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១៤ មុនម៉ោង 09.48.11។

[2015] <u>ឡាច គ្រី</u>៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៧៦ ប្រហែលម៉ោង 15.33.35 ទំព័រ ៨១ ប្រហែលម៉ោង 15.48.50។

[2016] <u>ថេង ផល</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/371.1** ទំព័រ ៣២ ក្រោយម៉ោង 11.03.05។

ករណីបើ ង៉ាង ជាមនុស្សបាត់ខ្លួនដំបូងគេ ដូចតាមសម្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន និង ឡាច គ្រី[2017]។

២០១២. អៀង អុន ជាប្រជាជនម្នាក់ទៀត បានផ្ដល់ជូនអ្នកស៊ើបអង្កេតនូវសាច់រឿងមួយផ្សេងទៀត ដោយគាត់បានឆ្លើយថា ជនជាតិវៀតណាមនៅក្នុងភូមិពោធិ៍ចិន្ដាំ ត្រូវបានសម្លាប់ក្នុងឆ្នាំ ១៩៧៧-១៩៧៨។ ផ្ទុយគ្នាពី ដួង អឿន និង ឡាច គ្រី សាក្សីបានបញ្ជាក់នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់ថា គ្រួសារដំបូងគេដែលត្រូវបាន "សម្លាប់" គឺគ្រួសាររបស់ ជុយ និងបន្ទាប់មក គឺគ្រួសាររបស់ ង៉ាង[2018]។ នៅទីនេះ ពាក្យ "សម្លាប់" ត្រូវដាក់ក្នុងអព្ភន្តរសញ្ញា ព្រោះវាជាសញ្ញាពិសេសបង្ហាញឱ្យឃើញពីលក្ខណៈនាំមុខនៃសំណួររបស់អ្នកស៊ើបអង្កេត។ គឺអ្នកស៊ើបអង្កេតដែលបានប្រើពាក្យនេះនៅក្នុងសំណួរមួយរបស់ខ្លួន ខណៈដែលសាក្សី ពុំធ្លាប់បានលើកឡើងពីពាក្យមួយនេះម្ដងណាឡើយ នៅក្នុងចម្លើយមុនៗរបស់គាត់[2019]។

២០១៣. ក្រុមមេធាវីការពារក្ដីបានខិតខំផ្ទៀងផ្ទាត់ខ្សែអាត់សំឡេងនៃការស្ដាប់ចម្លើយរបស់សាក្សី។ ក៏ប៉ុន្តែផ្នែកចម្រូងចម្រាសទាំងអស់នេះ ដែលជាផ្នែកសំខាន់ខ្លាំង បែរជាពុំមានទៅវិញ ដូចគ្នាដែរនឹងផ្នែកពាក់ព័ន្ធមួយចំនួនធំនៃកិច្ចសម្ភាស[2020]។ ដូច្នេះ វាពិតជាមានភាពមិនប្រក្រតីនៅក្នុងនីតិវិធីស្ដាប់ចម្លើយ អៀង អុន ហើយក្រុមមេធាវីការពារក្ដីមិនមានលទ្ធភាពផ្ទៀងផ្ទាត់ខ្លឹមសារពិតប្រាកដនៃពាក្យសម្ដីរបស់គាត់បានឡើយ។ សំណួរសួរនាំមុខដែលគួរតែផ្ដន្ទាទោសរបស់អ្នកស៊ើបអង្កេត រឹតតែតម្រូវឱ្យមានភាពចាំបាច់ក្នុងការប្រើប្រាស់ប្រកបដោយការប្រុងប្រយ័ត្នខ្ពស់នូវចម្លើយមួយនេះ ដែលភាពជឿទុកចិត្តបានរបស់វា ចោទជាបញ្ហា។ ដូច្នេះ អង្គជំនុំជម្រះអាចផ្ដល់តម្លៃជាភ័ស្ដុតាងដល់ចម្លើយមួយនេះ តិចតួចបំផុត។

---

[2017] ដួង អឿន៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ២៩ មុនម៉ោង 11.01.35, ឡាច គ្រី៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/379.1** ទំព័រ ៧៦ មុនម៉ោង 15.33.35។

[2018] កំណត់ហេតុស្ដាប់ចម្លើយ អៀង អុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/9352**, ERN KH 00225355។

[2019] កំណត់ហេតុស្ដាប់ចម្លើយ អៀង អុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/9352**, ERN KH 00225355 (តើមានការចាប់យកទៅសម្លាប់ពួកគាត់នៅក្នុងឆ្នាំណា? សូមលោករៀបរាប់? [...]"។

[2020] កំណត់ហេតុស្ដាប់ចម្លើយ អៀង អុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/9352**, ERN KH 00225355 (សំណួរពីរមុន និងចម្លើយនៅទំព័រនេះ មានភាពពាក់ព័ន្ធខ្លាំងបំផុត និងមិនត្រូវបានស្ដាប់ឮទេ នៅក្នុងខ្សែអាត់)។ ខ្សែអាត់ស្ដាប់ចម្លើយ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **D166/6R** (២៣ នាទី)។

២០១៤. ចំណែកឯ ស៊ិន ស៊ន់ ដែលជាអ្នកភូមិពោធិ៍ចិន្តាម្នាក់ទៀត បានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា គាត់បានឮអ្នកភូមិនិយាយថា "ង៉ាង" និង ជុយ ត្រូវបាននាំយកទៅ ក្រោមលេសថា "ទៅកាប់រពាក់" តែតាមការពិត អ្នកទាំងពីរត្រូវបានគេនាំយកទៅសម្លាប់នៅវត្តអូរកណ្ដោល ហើយសាក្សីនិយាយថា រឿងហេតុនេះបានកើតឡើងនៅចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨[2021]។ គាត់ពុំបានផ្ដល់ការចង្អុលបង្ហាញណាមួយទាក់ទងនឹងឈ្មុតនៃព្រឹត្តិការណ៍ទេ។

២០១៥. សាក្សីរូបនេះបញ្ជាក់នៅក្នុងចម្លើយរបស់ខ្លួនថា គាត់មិនដឹងពីមូលហេតុដែលខ្មែរក្រហមសម្លាប់អ្នកទាំងពីរនោះទេ ហើយគាត់ក៏មិនដឹងថាវត្តអូរកណ្ដោលជាមន្ទីរសន្តិសុខដែរ ក្នុងសម័យខ្មែរក្រហម។ តាមរយៈការបញ្ជាក់ទាំងនេះ វាស្តែងឱ្យឃើញថា ចម្លើយរបស់ ស៊ិន ស៊ន់ ដែលមិនស៊ីគ្នាទៅនឹងការរៀបរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន និង ឡាច នី ហើយក៏មិនស៊ីគ្នានឹងការរៀបរាប់របស់ ថេង ផល គឺគ្រាន់តែជាអ្វីដែលគាត់ទទួលបានពីពាក្យចចាមអារ៉ាមរបស់អ្នកភូមិ និងការនិយាយតៗគ្នាប៉ុណ្ណោះ។ សាក្សីពុំបានឃើញការចាប់ខ្លួនជនជាតិវៀតណាមដោយផ្ទាល់ភ្នែក ហើយក៏ពុំបានឃើញការសម្លាប់ដែលបានមកពីការសន្មតលើជនជាតិវៀតណាមដែរ។ គេនៅតែមិនដឹងពីប្រភពច្បាស់លាស់នៃព័ត៌មានទាំងអស់នេះ។ ចម្លើយមួយនេះ គឺមានតម្លៃជាភ័ស្តុតាងតិចតួចខ្លាំងណាស់។

### ii. <u>ករណី ជុយ (ប្តីរបស់ ដួង អឿន)</u>

២០១៦. ជនជាតិវៀតណាមឈ្មោះ ជុយ និង ដួង អឿន ដែលសក្ខីកម្មគាត់ទាំងពីរនាក់ត្រូវបានបង្ហាញពីខាងលើរួចមកហើយ បានរៀបការជាមួយគ្នា នៅក្នុងសម័យ លន់ នល់ ហើយពួកគាត់បានកូនស្រីម្នាក់ឈ្មោះ គីមវ៉ា[2022]។ នៅចំពោះមុខអង្គជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន បានអះអាងថា គាត់ពុំមានវត្តមាននៅទីនោះទេ នៅថ្ងៃដែលគេនាំប្តីគាត់យកទៅ។ គឺម្តាយគាត់ដែលមានវត្តមាននៅ

---

[2021] កំណត់ហេតុស្តាប់ចម្លើយ ស៊ិន ស៊ន់ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/9339**, ERN KH 00232825, ERN KH 00232826.

[2022] <u>ដួង អឿន</u>៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/381.1** ទំព័រ ៥ ក្រោយម៉ោង 09.16.01 ទំព័រ ៧ ក្រោយម៉ោង 09.21.34, កំណត់ហេតុស្តាប់ចម្លើយ ជុយ គីមវ៉ា ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/7793**។

កន្លែងនោះទេដែលជាអ្នករៀបរាប់ប្រាប់គាត់ថា ប្ដីរបស់គាត់ត្រូវបានឈ្លបបណ្ដើរនាំទៅតែម្នាក់ឯង ទៅកន្លែងណាក៏មិនដឹង ដើម្បីកាប់រពាក់[2023]។ ដួង អឿន និយាយថាចាប់ពីពេលនោះមក គាត់លែងបានជួបប្ដីរហូត។ គាត់ថាការបាត់ខ្លួនប្ដីគាត់នេះ កើតឡើងក្នុងឆ្នាំ ១៩៧៧ នៅរដូវច្រូតកាត់[2024]។

២០១៧. ម្យ៉ាងវិញទៀត វាគួរឱ្យចាប់អារម្មណ៍ដែលត្រូវកត់សម្គាល់ថា ដួង អឿន បានផ្ដល់សក្ខីកម្មថា មុនបាត់ខ្លួន ប្ដីជនជាតិវៀតណាមរបស់គាត់ ពុំដែលទទួលរងការធ្វើបាប ឬ រើសអើងអ្វីឡើយ។ គាត់ពុំបានឮខ្មែរក្រហមនៅភូមិរបស់គាត់ និយាយថាជនជាតិវៀតណាមគឺជាខ្មាំង ដោយសារតែពួកគេជាជាតិសាសន៍វៀតណាម ហើយគាត់ក៏មិនបានឮការជេរប្រមាថ ឬសម្ដីមិនសមរម្យ មកលើប្ដីរបស់គាត់ឡើយ[2025]។

២០១៨. ថេង ផល បានឆ្លើយថា ពេលត្រលប់មកពីកាប់រពាក់ជាមួយង៉ាង គាត់ឮគេនិយាយថា ជុយ ត្រូវបាន "[...] យកទៅដាក់រទេះសេះ យកទៅកើតអស់ហើយ គេយកសម្លាប់ចោលហើយ"[2026]។ ការពិតទៅ សាក្សីពុំបានដឹងអ្វីច្រើនទាក់ទងនឹងកាលៈទេសៈនៃការចាប់ខ្លួននេះឡើយ ព្រោះជាចុងក្រោយ គាត់បានបញ្ជាក់ថា៖ "រឿងដែលមកយកឈ្មោះជុយ [...] ខ្ញុំ<u>មិនបានដឹង មិនបាន</u>ឮអីចឹងតែម្ដង។ [...] គឺមកដល់ក្នុងភូមិ [...] គ្រាន់តែ<u>ឮខ្សឹបខ្សៀវ</u>គ្នាថា អ្ហូ គេយកវៀតណាមទៅរៀន [...] យកជុយ [...] <u>ទៅរៀន</u>អស់ហើយ។ គ្រាន់តែប៉ុណ្ណឹងទេ ត្រង់យ៉ាងម៉េចទៀត ខ្ញុំមិនអាចដឹងបាន"[2027]។ រឿងតែមួយគត់ដែលគាត់អាចផ្ដល់សក្ខីកម្មបាន គឺថា យោងតាមការនិយាយតៗគ្នា

---

[2023] <u>ដួង អឿន</u>៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/381.1** ទំព័រ ១០-១១ ចន្លោះម៉ោង 09.33.13 ដល់ម៉ោង 09.35.52 ទំព័រ ២៣ មុនម៉ោង 10.42.00 ទំព័រ ២៤ ប្រហែលម៉ោង 10.45.08 ទំព័រ ២៦-២៧ មុនម៉ោង 10.53.30។

[2024] <u>ដួង អឿន</u>៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១០-១១ ចន្លោះម៉ោង 09.33.13 ដល់ម៉ោង 09.35.52 ទំព័រ ២៣ មុនម៉ោង 10.42.00 ទំព័រ ៣៧ ក្រោយម៉ោង 11.27.30 ទំព័រ ៣៧-៣៨ ក្រោយម៉ោង 11.29.44 ទំព័រ ៤៦-៤៧ មុនម៉ោង 14.02.57។

[2025] <u>ដួង អឿន</u>៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/381.1** ទំព័រ ២៨-២៩ ចន្លោះម៉ោង 10.56.05 ដល់ម៉ោង 11.01.35។

[2026] <u>ថេង ផល</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/371.1** ទំព័រ ៣២ ក្រោយម៉ោង 11.03.05។

[2027] <u>ថេង ផល</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/371.1** ទំព័រ ៤៤ មុនម៉ោង 13.37.40 ទំព័រ ៤៥-៤៦ ក្រោយម៉ោង 13.40.45 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

របស់អ្នកភូមិ ជុយ ត្រូវបាននាំយកទៅ ហើយរឿងក្រៅពីនេះទៀត គឺថាសាក្សីពុំដឹងអ្វីទាំងអស់ទាក់ទងនឹងកាលៈទេសៈពិតប្រាកដ។

២០១៩. ឡាច គ្រី ជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ដែរ និងជាបងប្អូនជីដូនមួយរបស់ ដួង អឿន បានថ្លែងក្នុងសវនាការថា ដួង អឿន ជាអ្នកប្រាប់គាត់ពីការបាត់ខ្លួនរបស់ ជុយ ដោយ ដួង អឿន បានពន្យល់ប្រាប់គាត់ថា ជុយ ត្រូវបានគេឱ្យទៅកាប់ឈើ។ ដូចដែលបានឃើញពីខាងលើ បើតាម ឡាច គ្រី គឺ ជុយ បានបាត់ខ្លួននៅឆ្នាំ ១៩៧៦ ពោលគឺមួយខែក្រោយពេល ង៉ាង បាត់ខ្លួន ហើយគាត់ថារឿងនេះកើតឡើង "ប្រហែលខែវិច្ឆិកា ឬ ធ្នូ ១៩៧៥"។ ក៏ប៉ុន្តែ ក្រោយមកទៀត ក្នុងសក្ខីកម្មរបស់គាត់ ឡាច គ្រី បានផ្ដល់កាលបរិច្ឆេទមួយផ្សេងទៀត ដោយគាត់និយាយថា ជុយ បាត់ខ្លួនប្រហែលជាជិតមួយឆ្នាំក្រោយ វ៉ាន់ ង៉ាង ត្រូវបានចាប់ខ្លួន ពោលគឺធ្វើស្រែបានមួយវស្សា ឬបានមួយឆ្នាំ[2028]។ ជាថ្មីម្ដងទៀត នេះគឺជាព័ត៌មាននិយាយតៗគ្នាត្រួតគ្នា ដោយសាក្សីគ្មានព័ត៌មានណាមួយទាក់ទងនឹងការសម្លាប់មនុស្សដែលរងការចោទប្រកាន់នោះឡើយ។

២០២០. ដូចដែលបានឃើញពីខាងលើនេះដែរ ថេង ផល បាននិយាយផ្ទុយមកវិញថា ការចាប់ខ្លួន ជុយ កើតឡើងប្រហែលចុងឆ្នាំ ១៩៧៦ ដើមឆ្នាំ ១៩៧៧[2029]។ ចំណែក ដួង អឿន វិញ បញ្ជាក់ថា ប្ដីគាត់ត្រូវបាននាំទៅកន្លែងណាក៏មិនដឹង នៅក្នុងឆ្នាំ ១៩៧៧[2030]។

---

[2028] ឡាច គ្រី៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៦៧ មុនម៉ោង 15.09.47 (ដួង អឿន គឺជាបងប្អូនជីដូនមួយរបស់គាត់) ទំព័រ ៥៨ ប្រហែលម៉ោង 14.26.17 ទំព័រ ៥៩ មុនម៉ោង 14.28.35 (ង៉ាង ទៅប្រហែលមួយខែក្រោយមក បានគេហៅ ជុយ) ទំព័រ ៧៦ ប្រហែលម៉ោង 15.33.35 (ក្នុងភាសាខ្មែរ ទំព័រ ៧៦ ជុយ ត្រូវបាននាំយកទៅ ក្រោយ ង៉ាង គឺរយៈពេលឃ្លាតគ្នាប្រហែលជាជិតមួយឆ្នាំក្រោយមក ធ្វើស្រែបានមួយវស្សា ឬបានមួយឆ្នាំ។ គេចាត់តាំង ជុយ ឱ្យទៅកាប់ឈើ នៅព្រៃកក្រចៅ ទៅពីផ្ទះចម្ងាយ ៣០ ទៅ ៤០ គីឡូម៉ែត្រ។ សំណើសុំការកែតម្រូវ ត្រូវបានដាក់ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧)។

[2029] ថេង ផល៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/371.1** ទំព័រ ៥១ ក្រោយម៉ោង 13.58.42, កំណត់ហេតុស្ដាប់ចម្លើយ ថេង ហ៊ុយ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/5244**, ERN KH 00224795។ សូមមើលផងដែរ កថាខណ្ឌ ២០១១ ខាងលើ។

[2030] ដួង អឿន៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១៣-១៤ ក្រោយម៉ោង 09.44.48 ទំព័រ ១៧-១៨ មុនម៉ោង 10.02.01។ សូមមើល កថាខណ្ឌ ២០០៩ ខាងលើ។

២០២១. នៅក្នុងសំណុំរឿង មានកំណត់ហេតុស្តាប់ចម្លើយចំនួនពីររបស់បុគ្គលដែលនិយាយថាខ្លួនបានឃើញការចាប់ខ្លួន ជុយ ដោយផ្ទាល់ភ្នែក។ នៅចំពោះមុខអ្នកស៊ើបអង្កេត អៀង អុន បានអះអាងថា ជុយ ត្រូវបានចាប់ខ្លួននៅឆ្នាំ ១៩៧៧-១៩៧៨។ គាត់បានឃើញគេចាប់ "ជុយ ជីដូនមួយគាត់" ដោយ "ផ្ទាល់ភ្នែក" នៅពេលល្ងាច[2031]។ "គ្រួសារជុយ ជាគ្រួសារដែលត្រូវចាប់យកទៅមុនគេ" ទៅកន្លែងណាក៏មិនដឹង "គ្រាន់តែដឹងថា យកទៅខាងកើត" តែ អៀង អុន មិនបានឃើញការសម្លាប់នេះទេ ហើយគាត់ក៏មិនបានពន្យល់ថាតើគាត់ផ្អែកលើមូលដ្ឋានអ្វីបានជាហ៊ានថ្លែងបែបនេះ[2032]។

២០២២. ដូច្នេះ តម្លៃជាភ័ស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយមួយនេះ គឺពិតជាមានតិចតួចបំផុត ដូចគ្នាដែរនឹងកំណត់ហេតុស្តាប់ចម្លើយរបស់ ឈួន រី ប្អូនជីដូនមួយរបស់ ដួង អឿន ដែលគាត់បានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា ផ្ទុយពីអ្វីដែលម្តាយ ដួង អឿន បានរៀបរាប់ប្រាប់កូនស្រីទាក់ទងនឹងការចាប់ខ្លួនជុយ គឺថា ជុយ ពុំមែនទៅតែម្នាក់ឯងជាមួយនឹងឈ្លបទេ តែគាត់ស្ថិតក្នុងក្រុមមួយដែលមានគ្នាសុទ្ធតែជនជាតិវៀតណាម[2033]។ យ៉ាងណាមិញ ចម្លើយរបស់ ឈួន រី ក៏ខុសគ្នាផងដែរពីចម្លើយសាក្សី អៀង អុន ទាក់ទងនឹងពេលចាប់ខ្លួន[2034]។

iii. <u>**ករណី សាន (ប្រពន្ធ ឡាច នី)**</u>

២០២៣. សាន ជាកូនចិនកាត់វៀតណាម កើតនៅភូមិអន្លង់ទ្រា បានមករស់នៅពោធិ៍ចិន្តាំ ជាមួយប្តីឈ្មោះ ឡាច នី និងកូនៗទាំងបីនាក់ ក្នុងឆ្នាំ ១៩៦៨[2035]។

---

[2031] កំណត់ហេតុស្តាប់ចម្លើយ អៀង អុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ **E3/9352**, ERN KH 00225355។

[2032] កំណត់ហេតុស្តាប់ចម្លើយ អៀង អុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/9352**, ERN KH 00225355។ សូមមើល កថាខណ្ឌ ២០១៣ ខាងលើ។

[2033] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឈួន រី ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7559**, ERN KH 00034285។

[2034] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឈួន រី ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7559**, ERN KH 00034285។

[2035] <u>ឡាច គ្រី</u>៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៤៧-៤៨ ប្រហែលម៉ោង 13.49.20, ប្រតិចារឹក ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/380.1** ទំព័រ ៧២ ក្រោយម៉ោង 15.39.37, បទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ឯកសារ **E3/9319**, ERN KH 00034324។

២០២៤. ថេង ផល បានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះថា ទោះជាគាត់ពុំមានវត្តមាននៅពេលចាប់ខ្លួនប្រពន្ធ ឡាច នី ក៏ដោយ ក៏គាត់និយាយថាការចាប់ខ្លួននេះកើតឡើងនៅពេលដែលគាត់នៅក្នុងព្រៃកាប់រពាក់ជាមួយង៉ាង។ ពេលត្រលប់មកដល់ភូមិវិញ គាត់ឮគេនិយាយថា សាន ត្រូវបានគេនាំយកទៅរៀនសូត្រជាមួយកូនៗ។ គាត់បានដឹងតែប៉ុណ្ណឹង ព្រោះថាព្រឹត្តិការណ៍នេះកើតឡើងមុនគាត់មកដល់ភូមិវិញ[2036]។ គាត់គ្រាន់តែឮថា ជនជាតិវៀតណាមត្រូវបានគេនាំយកទៅ ក្រោមលេសថាទៅរៀនសូត្រ ហើយចាប់ពីពេលនោះមក ពួកគេក៏បាត់ខ្លួន ហើយសាក្សីក៏មិនដឹងថាហេតុអ្វីដែរ[2037]។

២០២៥. ដួង អឿន បានឆ្លើយថាគាត់មិនបានឃើញប្រពន្ធ ឡាច នី ត្រូវគេនាំយកទៅ ហើយគាត់ក៏ពុំដឹងថា ឡាច នី និងកូនៗ ត្រូវបាននាំទៅនៅពេលណានោះដែរ ព្រោះថានៅពោធិ៍ចិន្តាំ កន្លែងដែលពួកគេរស់នៅ គឺមានចម្ងាយឆ្ងាយពីកន្លែងដែលគាត់រស់នៅ។ គាត់ក៏លែងបានជួបពួកគេទៀត[2038]។

២០២៦. ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានផ្តល់សក្ខីកម្មនៅក្នុងសវនាការថា ពុំមានអ្វីកើតឡើងចំពោះ សាន ជាបងថ្លៃ មុនពេលដែលគាត់ត្រូវបានចាប់ខ្លួនជាមួយកូនៗ ក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ឡើយ[2039]។ ក្រោយមក គាត់ក៏លែងបានជួបពួកគេ[2040]។ យោងតាមសក្ខីកម្មរបស់គាត់ក្នុងនាមជាសាក្សីបានឃើញផ្ទាល់ភ្នែក គាត់បានថ្លែងថា ពេលគាត់កំពុងធ្វើស្រែក្នុងក្រុមដែលមាន ឡាច នី ផងនោះ បងប្រុសរបស់គាត់បានដួលសន្លប់ ពេលឃើញគេចាប់ក្រុមគ្រួសាររបស់ខ្លួន[2041]។ គាត់

---

[2036] ថេង ផល៖ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/370.1 ទំព័រ ៧៥-៧៦ ប្រហែលម៉ោង 16.01.54, ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/371.1 ទំព័រ ៣៥ មុនម៉ោង 11.13.46 ទំព័រ ៦០ ក្រោយម៉ោង 14.31.53។

[2037] ថេង ផល៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/371.1 ទំព័រ ៣៦ ក្រោយម៉ោង 11.16.28 ទំព័រ ៣៦ មុនម៉ោង 11.18.18 ទំព័រ ៣៩ មុនម៉ោង 11.25.04 ទំព័រ ៤១ មុនម៉ោង 11.32.15។

[2038] ដួង អឿន៖ ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ១២ ប្រហែលម៉ោង 09.39.24 ទំព័រ ៣០ មុនម៉ោង 11.06.46 ទំព័រ ៣១ ក្រោយម៉ោង 11.06.46។

[2039] ឡាច គ្រី៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/379.1 ទំព័រ ៥០-៥១ ក្រោយម៉ោង 13.58.25។

[2040] ឡាច គ្រី៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/379.1 ទំព័រ ៥៣ ក្រោយម៉ោង 14.06.54 ទំព័រ ៥៥ មុនម៉ោង 14.16.22។

[2041] ឡាច គ្រី៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/379.1 ទំព័រ ៥១ ក្រោយម៉ោង 14.01.06 ទំព័រ ៥២ ចន្លោះម៉ោង 14.04.03 ដល់ម៉ោង 14.06.54។

និយាយបែបនេះ គឺខុសគ្នាពីចម្លើយ ឡាច នី ប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឡាច នី បាន ស្លាប់មុនពេលមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ តែគាត់ផ្ទាល់ធ្លាប់បានអះអាងថាខ្លួនមិនមាន វត្តមាននៅទីនោះទេ ពេលគេចាប់ប្រពន្ធគាត់[2042]។

២០២៧. ឡាច នី បានពន្យល់ប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា ប្រពន្ធ និងកូនៗរបស់គាត់ ត្រូវបាននាំ យកទៅនៅខែ កក្កដា ឆ្នាំ ១៩៧៧[2043]។ ពេលគេចាប់ប្រពន្ធ និងកូនៗ ឡាច នី ពុំនៅទីនោះទេ តែគឺ បងប្អូនគាត់ជាអ្នកប្រាប់គាត់ថា ប្រពន្ធ និងកូនៗគាត់ត្រូវបានដឹកតាមរទេះគោយកទៅ[2044]។ ប្រាំខែ ក្រោយមក ឡាច នី សន្និដ្ឋានថា ប្រពន្ធ និងកូនៗ ប្រហែលជាត្រូវបានគេនាំយកទៅសម្លាប់បាត់ អស់ទៅហើយ[2045]។

២០២៨. បើតាម ឡាច គ្រី ឈ្មោះ ទ្រី ដែលជាអ្នកបររទេះ បានប្រាប់គាត់ថា សន្តិសុខពីរនាក់ បានទទួល យកប្រពន្ធ និងកូនៗរបស់ ឡាច នី នៅក្នុងព្រៃត្រពាំងព្រីង ប៉ុន្តែ ទ្រី ពុំដឹងថាពួកគេទៅណាទៀត។ ទ្រី ត្រូវបានគេសម្លាប់ចោល មួយខែក្រោយព្រឹត្តិការណ៍នេះកើតឡើង[2046]។

២០២៩. ចំណែក អៀង អុន ដែលត្រូវបានសន្មតថាជាអ្នកបានឃើញព្រឹត្តិការណ៍នេះផ្ទាល់ភ្នែក បានឆ្លើយ ប្រាប់អ្នកស៊ើបអង្កេតថា ទ្រី បានយករទេះគោ មកយកគ្រួសារ ឡាច នី ដើម្បីនាំទៅទិសខាងកើត។

---

[2042] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡាច នី ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ ឯកសារ **E3/9319**, ERN KH 00034326, ERN KH 34345។

[2043] <u>ឡាច គ្រី</u>៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/379.1** ទំព័រ ៤៥ ក្រោយម៉ោង 13.41.05 (ឡាច នី បាន ស្លាប់ហើយ), បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡាច នី ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ ឯកសារ **E3/9319**, ERN KH 00034325។

[2044] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡាច នី ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ឯកសារ **E3/9319**, ERN KH 00034326-00034327 និង 00034332។

[2045] <u>ឡាច គ្រី</u>៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/379.1** ទំព័រ ៥៦ ប្រហែលម៉ោង 14.18.44។

[2046] <u>ឡាច គ្រី</u>៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥៥ ប្រហែលម៉ោង 14.14.19។ ក៏ប៉ុន្តែ ថេង ផល បានអះអាងថា ទ្រី ចាស់ហើយស្លាប់។ គាត់មិនត្រូវបានគេសម្លាប់ទេ គឺស្លាប់ដោយជរាពាធ៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ឯកសារ **E1/370.1** ទំព័រ ៧០ មុនម៉ោង 15.41.09។

គាត់និយាយថាព្រឹត្តិការណ៍នេះកើតឡើងប្រហែលឆ្នាំ ១៩៧៧-១៩៧៨ តែគាត់មិនដឹងថាពួកគេត្រូវបានសម្លាប់នៅកន្លែងណានោះទេ[2047]។

២០៣០. ទោះយ៉ាងណាក៏ដោយ គ្មាននរណាម្នាក់មានភស្តុតាងច្បាស់លាស់ ទាក់ទងនឹងរឿងរ៉ាវដែលបានកើតឡើងចំពោះគ្រួសារមួយនេះ ក្រោយពីពួកគេបានចាកចេញពីភូមិ។

### 1.ខ. ស្វាយអន្ទរ (ករណី សេង ហួរ និងក្រុមគ្រួសាររបស់គាត់)

២០៣១. ប្រពន្ធរបស់ ឃុន ម៉ុន ឈ្មោះ សេង ហួរ មានដើមកំណើតមកពីភូមិអន្លង់ទ្រា គឺជាប្អូនស្រីរបស់ សេង វ៉ាន់។ ក្រោយរៀបការរួច សេង ហួរ និងគ្រួសារ ក្នុងនោះមានម្ដាយគាត់ឈ្មោះ ហៃ បងប្អូនគាត់ឈ្មោះ ទៀង និង រ៉ុក (Rok) បានមករស់នៅក្នុងភូមិពោធិ៍ចិន្តាំ ជាមួយប្ដីគាត់[2048]។

២០៣២. សៅ សាក់ ជាមនុស្សតែម្នាក់គត់ដែលបានលើកឡើងពីគ្រួសារមួយនេះនៅចំពោះមុខអង្គជំនុំជម្រះដើម្បីប្រាប់ថាគាត់មិនដឹងថាមានរឿងអ្វីកើតឡើងចំពោះគ្រួសារនេះទេ ក្រោយពីពួកគេចាកចេញពីអន្លង់ទ្រាមក។ ក្នុងសវនាការ នៅពេលសហព្រះរាជអាជ្ញាសួរដេញដោលទាក់ទងនឹងជោគវាសនារបស់ប្រពន្ធ កូនៗ និងគ្រួសាររបស់ សេង ហួរ សៅ សាក់ ឆ្លើយថា៖ "ខ្ញុំអត់បានដឹងផង ព្រោះពេលនោះគាត់បែកគ្នា។ គាត់ទៅនៅ ខ្លះទៅនៅជ្រៃគ្រហឹម ខ្លះនៅស្វាយអន្ទរទៅ ក៏បែកគ្នារហូត"[2049]។ គាត់លែងបានជួបពួកគេ ហើយដោយសារតែមានការទទូចពីសហព្រះរាជអាជ្ញាអន្តរជាតិលើចំណុចនេះ គាត់បានពន្យល់ថា អន្លង់ទ្រា មានចម្ងាយឆ្ងាយដែរពីស្វាយអន្ទរ និងគ្រហឹម

---

[2047] កំណត់ហេតុស្ដាប់ចម្លើយ អៀង អុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/9352**, ERN KH 00225355។ សូមមើលផងដែរនូវកថាខណ្ឌ ២០១៣ ខាងលើ (បញ្ហាសំឡេង)។

[2048] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៨៦ ក្រោយម៉ោង 15.56.30, កំណត់ហេតុស្ដាប់ចម្លើយ យឹម មួយ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ **E3/7783**, ERN KH 00238897, បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឃុន ម៉ុន ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7597**, ERN KH 00034569-00034573។

[2049] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ឯកសារ **E1/362.1** ទំព័រ ៨៦ ក្រោយម៉ោង 15.56.30, ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/363.1** ទំព័រ ៣ ក្រោយម៉ោង 09.15.16។

ហើយនៅសម័យនោះ គេមិនអាចធ្វើដំណើរពីភូមិមួយទៅភូមិមួយទៀតបានទេ[2050]។ ដូច្នេះ វាមិនចម្លែកទេដែលគាត់មិនដឹងដំណឹងពួកគេនោះ។

២០៣៣. យឹម មួយ ជាបងស្រីរបស់ សេង ហួរ រស់នៅជាមួយប្តីគាត់ នៅភូមិជ្រៃគ្រហឹម ស្រុកពារាំង ខេត្តព្រៃវែង ក្នុងសម័យខ្មែរក្រហម។ គាត់ប្រាប់អ្នកស៊ើបអង្កេតថា ប្អូនស្រី និងម្តាយរបស់គាត់ រស់នៅភូមិស្វាយអន្ទរ ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង[2051]។ ប្រហែលឆ្នាំ ១៩៧៧ ឈ្មោះ អានជាអ្នកភូមិពារាំង បានប្រាប់ប្តីគាត់ថា ប្អូនប្រុសឈ្មោះ ទៀង ប្អូនស្រីគាត់ឈ្មោះ គែ ត្រូវបាននាំយកទៅសម្លាប់មុនគេ ខណៈដែលម្តាយគាត់ឈ្មោះ ហៃ ប្អូនស្រីគាត់ឈ្មោះ ហួរ និងកូនៗ ត្រូវបានសម្លាប់ពីរបីថ្ងៃក្រោយមកទៀត[2052]។ ក្នុងចម្លើយនេះ គ្មានការពន្យល់ណាមួយទាក់ទងនឹងប្រភពព័ត៌មានរបស់អាន និងថាតើគាត់បានដឹងដំណឹងនេះដោយរបៀបណា។ នៅពេលសួរតទល់នឹងចម្លើយមួយនេះ ក្នុងអំឡុងពេលផ្តល់សក្ខីកម្ម សៅ សាក់ បានត្រឹមតែឆ្លើយថា គាត់មិនអាចនិយាយអ្វីបានទាំងអស់ ព្រោះគាត់រស់នៅឆ្ងាយពី យឹម មួយ[2053]។

២០៣៤. ដើមបណ្តឹងរដ្ឋប្បវេណី ឃុន ម៉ុន ដែលត្រូវបានអង្គជំនុំជម្រះកោះហៅ បានស្លាប់មុនពេលចូលមកផ្តល់សក្ខីកម្ម[2054]។ ពេលត្រូវបានសម្ភាសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឃុន ម៉ុន បានបញ្ជាក់ថាគាត់អវត្តមាននៅពេលគេនាំគ្រួសារគាត់ទៅ។ ឪពុកគាត់និយាយថា ប្រពន្ធគាត់ត្រូវបានសន្តិសុខស្រុក មិនស្គាល់ឈ្មោះ បី ឬ បួននាក់ នាំយកទៅរៀនសូត្រ នៅក្នុងខែ តុលា ឆ្នាំ ១៩៧៧[2055]។ ជា

---

[2050] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៥-៦ ចន្លោះម៉ោង 09.22.25 ដល់ម៉ោង 09.26.50។

[2051] កំណត់ហេតុស្តាប់ចម្លើយ យឹម មួយ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ឯកសារ **E3/7783**, ERN KH 00238897។

[2052] កំណត់ហេតុស្តាប់ចម្លើយ យឹម មួយ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ឯកសារ **E3/7783**, ERN KH 0238898។

[2053] <u>សៅ សាក់</u>៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/363.1** ទំព័រ ៦ មុនម៉ោង 09.26.50។

[2054] អ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ មានចំណងជើង "បញ្ជីឈ្មោះសាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់វគ្គស្តីពីការប្រព្រឹត្តិចំពោះជនជាតិវៀតណាម" ផ្ញើនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ វេលាម៉ោង ១០ និង ៣៩ នាទី ព្រឹក (ដីកាកោះ), អ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ មានចំណងជើង "កាលវិភាគ និងរបាស្សនាម" ផ្ញើនៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥ វេលាម៉ោង ៣ និង ៨ នាទី រសៀល (ការជូនដំណឹងអំពីមរណភាព), លិខិតបញ្ជាក់មរណភាព ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ឯកសារ **E29/506**។

[2055] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឃុន ម៉ុន ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7597,** ERN KH 00034586, ERN KH 00034587-00034589។

អកុសល មិនខុសគ្នាអ្វីពីកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាច្រើនលើសលុបនោះទេ គឺថាមនុស្សពីរនាក់ទៀតបាននិយាយក្នុងពេលសម្ភាសន៍នេះ បន្ថែមពីលើ យុន ម៉ុន ក្នុងនោះមានប្អូនស្រីគាត់ សាមិត ផងដែរ[2056]។ ទោះជាយ៉ាងណា ពាក់ព័ន្ធនឹងចម្លើយធ្វើឡើងនៅក្រៅក្របខ័ណ្ឌតុលាការ គេត្រូវតែប្រយ័ត្នប្រយែងលើភាពជឿទុកចិត្តបាននៃព័ត៌មាន ប៉ុន្តែ ចម្លើយនេះជាភស្តុតាងមិនសូវរឹងមាំ នៅពេលដែលវាជិតដាមទៅដោយអន្តរាគមន៍របស់អ្នកមកពីក្រៅ[2057]។

២០៣៥. ក្នុងចម្លើយដដែលនេះ យុន ម៉ុន បានលើកឡើងពីជំនួបរបស់គាត់ជាមួយក្រុមប្រធានភូមិ ក្នុងនោះមានតាលីម និងតាឈើន។ តាមរយៈអ្នកទាំងពីរនេះ គាត់បានដឹងថាប្រពន្ធគាត់ ត្រូវបាននាំទៅរៀនសូត្រ[2058]។

២០៣៦. ដូច្នេះ វាគ្មានភាពច្បាស់លាស់ទាល់តែសោះ ទាក់ទងនឹងឈ្មោះអ្នកដែលបានចូលរួមក្នុងការចាប់ខ្លួនប្រពន្ធ និងគ្រួសារប្រពន្ធរបស់ យុន ម៉ុន។ បើតាម យុន ម៉ុន ឬបើយោងតាម សាមិត ជាប្អូនស្រីរបស់គាត់ ដែលមានវត្តមាននៅជិតគាត់ ពេលសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លីម ជាអ្នកឱ្យចាប់ប្រពន្ធ និងកូនៗរបស់ យុន ម៉ុន យកទៅសម្លាប់ តាមបញ្ជាគណៈស្រុក និងឃុំ។ យុន ម៉ុន បានបញ្ជាក់ថាគាត់មិនដែលនិយាយជាមួយ លីម ពីការចាប់ខ្លួនគ្រួសារគាត់ម្តងណាឡើយ ហើយដូច្នេះ គេមិនដឹងថាគាត់ផ្អែកលើអ្វីបានជាហ៊ានអះអាងថាមានបញ្ជាពីគណៈស្រុក[2059]។

២០៣៧. ដូច្នេះ គេត្រូវពិនិត្យលើចម្លើយរបស់ លីម ដែលមានឈ្មោះពេញហៅថា កុល លីម ហើយបើតាមសម្តីរបស់ យុន ម៉ុន និងប្អូនស្រីគាត់ លីម គឺជាមេកង នៅសម័យនោះ។ នៅពេលសម្ភាសជាមួយអ្នកស៊ើបអង្កេត កុល លីម និយាយថា គេបាននាំប្រពន្ធ យុន ម៉ុន ជាមួយកូនៗ និងក្រុមគ្រួសារ

---

[2056] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ យុន ម៉ុន ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7597**, ERN KH 00034587-00034592 (បុគ្គលទាំងនេះត្រូវបានកំណត់អត្តសញ្ញាណថាឈ្មោះ សាមិត ជាប្អូនស្រី និងម្នាក់ទៀតជាអ្នកជិតខាង។ សាមិត ជាអ្នកអះអាងថា លីម បានមកយកប្រពន្ធរបស់ យុន ម៉ុន។

[2057] សាលដីកា ០០២/០១ កថាខណ្ឌ ៩៦៥។

[2058] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ យុន ម៉ុន ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7597**, ERN KH 00034593-00034594។

[2059] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ យុន ម៉ុន ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ ឯកសារ **E3/7597**, ERN KH 00034605 (សព្វថ្ងៃ លីម នៅរស់ និងស្នាក់នៅខាងជើង នៅភូមិស្វាយអន្ទរ)។

ប្រពន្ធគាត់យកទៅនៅចុងឆ្នាំ ១៩៧៦ ដើមឆ្នាំ ១៩៧៧។ គាត់បានបញ្ជាក់ថាបានប្រទះឃើញកូនៗរបស់ម៉ុន ត្រូវបានចាប់ដាក់រទេះសេះយកទៅ "សម្លាប់" តែគាត់មិនបាននិយាយអ្វីទាំងអស់ទាក់ទងនឹងប្រពន្ធរបស់ម៉ុន និងគ្រួសារខាងប្រពន្ធគាត់[2060]។ អ្នកបររទេះប្រាប់គាត់ថា កូនៗ និងគ្រួសាររបស់ ឃុន ម៉ុន ត្រូវបានគេសម្លាប់ចោលនៅវាលតូច ឬ ព្រៃតាពៅ ស្ថិតនៅខាងត្បូងវត្តអូរកណ្ដោល ក្នុងឃុំអង្គរទ្រេត ស្រុកព្រៃវែង។ គឺពួកឈ្លបឃុំ ដែលមាន ង៉ុយ ជាប្រធាន ជាអ្នកមកចាប់អ្នកទាំងនោះ តាមបញ្ជាថ្នាក់លើ[2061]។

២០៣៨. បញ្ហានៅតែចោទមានដដែល នៅពេលដែលមិនអាចសួរដេញដោលសាក្សី ទាក់ទងនឹងភស្តុតាងដែលសំខាន់ខ្លាំងទាំងអស់នេះ ជាពិសេស នៅពេលដែលសាក្សីទាំងនោះរាយការណ៍ពី "ការទម្លាយរឿងប្រាប់" របស់អ្នកបររទេះសាមញ្ញម្នាក់ ដើម្បីបង្ហាញថាបញ្ជាគឺមកពីថ្នាក់លើ។ ប៉ុន្តែ គេអាចកត់សម្គាល់ថា កុល លីម បាននិយាយថាការពិភាក្សានេះកើតឡើងមុនការសម្លាប់ដែលរងការចោទប្រកាន់ ហើយគេក៏ត្រូវកត់សម្គាល់ដែរថា គាត់ពុំបានឃើញផ្ទាល់នូវរឿងហេតុមួយនេះ ហើយគាត់ក៏មិនបានផ្ដល់ព័ត៌មានណាមួយ ទាក់ទងនឹងអ្វីដែលបានកើតឡើង ក្រោយពេលដែលរទេះចេញបាត់ទៅដែរ។

២០៣៩. ដោយសារពុំមានលទ្ធភាពតទល់សាក្សីលើព័ត៌មានទាំងអស់នេះ ក្រុមមេធាវីការពារក្ដីត្រូវគូសបញ្ជាក់ថា ក្នុងនាមជាអ្នកជាប់ចោទថាបានអនុវត្តការចាប់ខ្លួនមួយនេះ (ប្អូនស្រីលោក ឃុន ម៉ុន បានបង្ហាញលោក កុល លីម ថាដូច្នេះ) គាត់ត្រូវនិយាយកុហក់ ដើម្បីបន្ធូរបន្ថយការទទួលខុសត្រូវរបស់គាត់។ ដូច្នេះ កំណត់ហេតុស្ដាប់ចម្លើយរបស់គាត់ គួរត្រូវបានពិនិត្យដោយភាពប្រយ័ត្នប្រយែងខ្ពស់បំផុត។

## 2. <u>**បទបញ្ជា និងនីតិវិធីចាប់ខ្លួន និងសម្លាប់ជនជាតិវៀតណាម**</u>

២០៤០. ពាក់ព័ន្ធនឹងបញ្ជីជនជាតិវៀតណាមដែលត្រូវបានរៀបចំជាមុន ហើយដែលត្រូវបានប្រើប្រាស់ក្នុងពេលចាប់ខ្លួន យោងតាមកថាខណ្ឌ ៧៩៨ នៃដីកាដំណោះស្រាយ ចៅក្រមស៊ើបអង្កេតបានផ្អែកលើ

[2060] កំណត់ហេតុស្ដាប់ចម្លើយ កុល លីម ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/5243**, ERN KH 00224776។

[2061] កំណត់ហេតុស្ដាប់ចម្លើយ កុល លីម ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ឯកសារ **E3/5243**, ERN KH 00224776។

មូលដ្ឋានចម្លើយរបស់ ដួង អឿន ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ប៉ុន្តែ នៅពេលត្រូវបានសួរដេញដោលដោយព្រះរាជអាជ្ញា គាត់បានអះអាងថា៖ "ខ្ញុំអត់បានដឹងទេ ខ្ញុំអត់បានយល់ទេ កន្លែងត្រង់ហ្នឹង ខ្ញុំមិនបានដឹងទេ។ ខ្ញុំភ្លេចអស់ហើយ [...]"[2062]។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រឹមតែគ្មានសមត្ថភាពបញ្ជាក់អះអាងពីចម្លើយមួយនេះបាននោះទេ តែគាត់ក៏បានបញ្ជាក់ថា ពុំមានការចាត់វិធានការណាមួយដើម្បីកំណត់អត្តសញ្ញាណជនជាតិវៀតណាមឡើយ។ នៅកន្លែងគាត់រស់នៅគ្មាននរណាម្នាក់បានមកសួរអ្នកភូមិថាអ្នកណាជាជនជាតិវៀតណាមនោះទេ[2063]។

២០៤១. នៅត្រង់កថាខណ្ឌ ៨០០ នៃដីកាដំណោះស្រាយ ចៅក្រមស៊ើបអង្កេតបានចាត់ទុកថា ការចាប់ខ្លួនត្រូវបានធ្វើឡើងក្រោមបញ្ជាគណៈតំបន់ ២០ ឬ ថ្នាក់លើ[2064]។ តទៅនេះ ក្រុមមេធាវីការពារក្តីនឹងពិនិត្យលើភ័ស្តុតាងដែលមាន ដោយកម្រិតនៅត្រឹមសក្ខីកម្មទាំងឡាយដែលទាក់ទងនឹងអង្គហេតុកើតឡើងក្នុងឃុំស្វាយអន្ទរ។

២០៤២. អៀង អុន បានអះអាងប្រាប់អ្នកស៊ើបអង្កេតថា ការចាប់ខ្លួនមនុស្សធ្វើឡើងតាមបញ្ជាគណៈតំបន់ ២០[2065]។ ក្រៅពីភាពជឿជាក់បានតិចតួច ជុំវិញកាលៈទេសៈនៃចម្លើយរបស់គាត់ អង្គជំនុំជម្រះមិនអាចផ្អែកលើមូលដ្ឋានចម្លើយមួយនេះបានទេ ព្រោះថា អៀង អុន បានសារភាពខ្លួនឯងថា គាត់ "[មិនស្គាល់] គណៈស្រុកព្រៃវែង និងគណៈតំបន់ ២០" ទេ ដោយសារគាត់គ្មានតួនាទីដែលអាចឱ្យគាត់ដឹងបានពីអ្វីដែលបានកើតឡើងនៅថ្នាក់លើ។ ម្យ៉ាងវិញទៀត ចម្លើយរបស់គាត់បង្ហាញឱ្យឃើញថា គាត់សន្មតថា "ជាការបញ្ជាពីលើដល់ក្រោម" ព្រោះគាត់កត់សម្គាល់ថា "ការប្រជុំពេលព្រឹក ហើយពេលល្ងាចមានការចាប់ខ្លួនតែម្តង" ដោយគាត់គូសបញ្ជាក់ថា "ប្រជាជនក្នុងភូមិទាំងអស់សុទ្ធតែដឹងដូចគ្នា"។ ក៏ប៉ុន្តែ សាក្សីដទៃទៀត និយាយខុសពីគាត់។

២០៤៣. ទោះជា ថេង ផល បានបញ្ជាក់ប្រាប់អ្នកស៊ើបអង្កេតថា អ្នកភូមិទាំងអស់សុទ្ធតែបានដឹងថា បញ្ជាឱ្យសម្លាប់មនុស្សចេញមកពីថ្នាក់លើក៏ដោយ តែគាត់ទទួលស្គាល់ថា គ្មានការប្រជុំស្តីពីផែនការ

---

2062 ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/381.1** ទំព័រ ២១-២២ ពីម៉ោង 10.36.26 ដល់ម៉ោង 10.38.02។

2063 ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/381.1** ទំព័រ ២១ មុនម៉ោង 10.36.26។

2064 ដីកាដំណោះស្រាយ កំណត់សម្គាល់ចុងឯកសារ ៣៤១២-៣៤១៣។

2065 កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ **ឯកសារ E3/9352**, ERN KH 00225355។

សម្លាប់មនុស្សឡើយ[2066]។ យ៉ាងណាមិញ ក្នុងអំឡុងពេលសវនាការ ចម្លើយរបស់គាត់ និងចម្លើយរបស់ អៀង អុន ពុំត្រូវបានបញ្ជាក់អះអាងក្នុងពេលផ្តល់សក្ខីកម្មដោយដើមបណ្តឹងរដ្ឋប្បវេណីដែលមិនបានលើកឡើងពីការប្រជុំ និងផែនការសម្លាប់ឡើយ។

២០៤៤. ចំណែកសាក្សី កុល លឹម វិញ ក្នុងនាមគាត់ជាចារីរងការចោទប្រកាន់ ក្រៅពីត្រូវកុហក់ថា ការចាប់ខ្លួនជនជាតិវៀតណាម ត្រូវបានបញ្ជាមកពីថ្នាក់លើ ប្រភពព័ត៌មានរបស់គាត់នៅតែមិនច្បាស់លាស់ថែមទៀត[2067]។

២០៤៥. ចម្លើយសាក្សី ឈួន រី ដែលអះអាងថារដ្ឋអំណាចថ្នាក់លើ "និយាយរដឺន" បានមកនៅក្នុងភូមិ ហើយបានស៊ើបសួរប្រធានភូមិថាអ្នកណាជាជនជាតិវៀតណាម ដើម្បីយកពួកគេទៅសម្លាប់ គឺគ្មានសំអាងលើប្រភពណាមួយដែលគេដឹង ឬកំណត់បាន នោះទេ[2068]។ គេកាន់តែមិនអាចសំអាងលើកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ថែមទៀត ព្រោះថាក្នុងពេលស្តាប់ចម្លើយដដែលនេះ គាត់បានថ្លែងថាគាត់មិនដឹងថាតើអាជ្ញាធរស្រុក តំបន់ ឬ មជ្ឈិម បានដឹងពីការសម្លាប់មនុស្សដែរឬ អត់។ និយាយផ្ទុយគ្នាពី អៀង អុន សាក្សី ឈួន រី បានថ្លែងផងដែរថា ពុំមានការប្រជុំមុនពេលចាប់ខ្លួនជនជាតិវៀតណាមឡើយ[2069]។

២០៤៦. ដោយហេតុថាតម្លៃជាភ័ស្តុតាងនៃចម្លើយទាំងអស់នេះមានតិចតួចខ្លាំងពេក និងភាពផ្ទុយគ្នារវាងរឿងរ៉ាវទាំងអស់នេះ អង្គជំនុំជម្រះមិនអាចសំអាងលើឯកសារទាំងនេះដើម្បីសន្និដ្ឋានថា ការចាប់ និងការសម្លាប់ បានកើតឡើង តាមបញ្ជាថ្នាក់លើ ឬ គណៈតំបន់ ២០ បានឡើយ។

### 3. ការប្រជុំទាក់ទងនឹងជនជាតិវៀតណាម និងមូលហេតុនៃការចាប់ខ្លួន

---

[2066] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ **ឯកសារ E3/5244**, ERN KH 00224795។

[2067] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ **ឯកសារ E3/5243,** ERN KH 00224775។ ចំពោះរឿង កុល លឹម និយាយកុហក សូមមើលខាងលើ កថាខណ្ឌ ២០៣៧-២០៣៩។

[2068] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ **ឯកសារ E3/7891**, ERN KH 00408518។

[2069] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ **ឯកសារ E3/7891**, ERN KH 00408518-19។

២០៤៧. ក្នុងអំឡុងពេលសវនាការ សាក្សី ចេង ផល ត្រូវបានសួរដេញដោលយ៉ាងច្បាស់លាស់ទាក់ទងនឹងការប្រជុំដែលរងការចោទប្រកាន់ ពាក់ព័ន្ធជាមួយនឹងការនាំប្រពន្ធ ឡាច នី យកទៅ។ គាត់បានអះអាងថាគាត់មិនដឹងរឿងនេះទេ ដោយសារថាគាត់ធ្វើដំណើរក្នុងព្រៃ[2070]។ គាត់បន្ថែមថា ក្នុងនាមជាប្រជាជនធម្មតាម្នាក់ គេមិនឱ្យគាត់ចូលរួមក្នុងកិច្ចប្រជុំបែបនេះទេ ហើយទោះយ៉ាងណាក៏ដោយ គាត់មិនដែលចូលរួមប្រជុំឡើយ ក្រោយការចាប់ខ្លួនជនជាតិវៀតណាម[2071]។

២០៤៨. ដួង អឿន បានបញ្ជាក់អះអាងថាគាត់មិនដែលឮកម្មាភិបាលខ្មែរក្រហមនិយាយពីវៀតណាម ក្នុងពេលប្រជុំស្ដីពីការបង្កបង្កើនផលឡើយ[2072]។ សាក្សីច្រើននាក់ផ្សេងទៀត បានបញ្ជាក់អះអាងថាពុំមានការប្រជុំនិយាយពីជនជាតិវៀតណាម នៅកន្លែងឡើយ[2073]។

២០៤៩. ឡាច គ្រី បានថ្លែងដូចគ្នាថា ពុំមានការប្រកាសពីការចាប់ខ្លួនវៀតណាម ក្នុងពេលប្រជុំទេ[2074]។ នៅពេលសួរដេញដោលដោយក្រុមមេធាវីការពារក្ដី គាត់បញ្ជាក់ថាពុំមានការប្រជុំនោះទេ មុនពេលប្រពន្ធ និងកូនៗរបស់ ឡាច នី ត្រូវគេនាំយកទៅ គឺខុសពីអ្វីដែលមានបញ្ជាក់នៅក្នុងព័ត៌មានបន្ថែមរបស់គាត់ ដែលរៀបចំដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី[2075]។ ការប្រជុំធ្វើឡើងក្រោយមកទៀត គឺនិយាយពីការបង្កបង្កើនផលស្រូវ។ ដូចគ្នានេះដែរ ឡាច គ្រី បានបដិសេធផ្នែកនៃចម្លើយរបស់គាត់ក្នុងកិច្ចសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលក្នុងនោះនិយាយថាអង្គការបានកោះ

[2070] ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/371.1** ទំព័រ ៤១ បន្ទាប់ពីម៉ោង 11.29.46។

[2071] ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/371.1** ទំព័រ ៤៧ នៅម៉ោង 13.45.41។ កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ **ឯកសារ E3/5244**, ERN KH 00224795។

[2072] ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/381.1** ទំព័រ ៣១ ប្រហែលម៉ោង 11.06.46 ទំព័រ ៣៨ បន្ទាប់ពីម៉ោង 11.29.44។

[2073] កំណត់ហេតុស្ដាប់ចម្លើយ ឡេង សាម៉េត ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩ **ឯកសារ E3/7810**។ កិច្ចសម្ភាសន៍ ឯក បាន របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ E3/7959**, ERN KH 00034002។ កិច្ចសម្ភាសន៍ ឈួន រី នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ E3/7559**, ERN FR 00426279។

[2074] ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/379.1** ទំព័រ ៥៣ នៅម៉ោង 14.06.54, ទំព័រ ៥៤ មុនម៉ោង 14.11.34, ទំព័រ ៨៤ មុនម៉ោង 16.02.17។

[2075] សេចក្ដីអះអាងបន្ថែមរបស់ Lyma NGUYEN និង បុត ម៉ៅ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១០ **ឯកសារ E3/5630**, ERN KH 00895419 (ពេលប្រជុំក្នុងភូមិ ធិម បានបញ្ជាឲ្យជ្រូយនាំយកកូនៗ និងប្រពន្ធរបស់ឡាច នី ទៅកសាង)។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/379.1** ទំព័រ ៥២-៥៣, ម៉ោង 11.19.40។

ហៅក្រុមគ្រួសាររបស់គាត់ ក្រោយពីបងថ្លៃស្រីគាត់ត្រូវបានគេនាំទៅ។ គាត់បានថ្លែងយ៉ាងដាច់ណាត់ប្រាប់តុលាការដូច្នេះថា៖ "បាទៗ អត់ៗដឹងផង អត់ដឹង ខ្ញុំបាទអត់ចូលរួមផង"[2076]។ ម្យ៉ាងវិញទៀត គាត់បានបញ្ជាក់ថាមិនបានដឹងពីផែនការ និងមូលហេតុចាប់ខ្លួនជនជាតិវៀតណាម[2077]។

២០៥០. ហេតុដូច្នេះ មនុស្សតែម្នាក់គត់ដែលលើកឡើងពីការប្រជុំបែបសន្និត ទាក់ទងនឹងជនជាតិវៀតណាម គឺសាក្សី អៀង អុន[2078]។ បន្ថែមលើបញ្ហាទាំងឡាយដែលត្រូវបានលើកឡើងរួចហើយ សក្ខីកម្មជាច្រើនដែលនិយាយបដិសេធពីអត្ថិភាពនៃការប្រជុំទាំងអស់នេះ ធ្វើឱ្យគេកាន់តែជឿជាក់ថែមទៀតថាកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ពិតជាមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។

4. <u>**កន្លែងសម្លាប់មនុស្សនៅវាលតូច**</u>

២០៥១. ត្រង់កថាខណ្ឌ ៧៩៩ នៃដីកាដំណោះស្រាយ ចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា ការសម្លាប់រង្គាលត្រូវបានប្រព្រឹត្តឡើងនៅវាលតូច ក្នុងភូមិចំការគួយ ស្រុកព្រៃវែង។ ចៅក្រមស៊ើបអង្កេតបានយោងទៅលើសាក្សីបីរូប ក្នុងនោះមាន កុល លីម, ឃុន ម៉ុន និង ឈួន រី[2079]។

២០៥២. ក្នុងអំឡុងពេលសវនាការ សាក្សី ថេង ផល បានថ្លែងថា វាលតូច ស្ថិតនៅចម្ងាយមួយគីឡូម៉ែត្រ ពីវត្តចាស់ អូរកណ្តោល។ បើតាមការនិយាយតៗគ្នាមកថា មនុស្សត្រូវបានគេនាំយកទៅវាលតូច "ដើម្បីរៀនសូត្រ" តែគាត់មិនដឹងថា "ជនជាតិវៀតណាម [យកទៅភូមិណា] [គាត់]មិនអាចដឹងទេ"[2080]។

---

[2076] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០០ **ឯកសារ E3/5640**, ERN KH 00034406។ ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/379.1** ទំព័រ ៥៤-៥៥ ពីម៉ោង 15.59.03 ដល់ម៉ោង 16.02.16។

[2077] ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/371.1** ទំព័រ ៣៩ មុនម៉ោង 11.25.04។

[2078] កំណត់ហេតុស្តាប់ចម្លើយ អៀង អុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ **ឯកសារ E3/9352**, ERN KH 00225355។

[2079] ដីកាដំណោះស្រាយ កំណត់សម្គាល់ចុងឯកសារ 3408។

[2080] <u>ថេង ផល</u>៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/371.1** ទំព័រ ៧៤-៧៦ ពីម៉ោង 13.45.21 ដល់ម៉ោង 13.48.04។

២០៥៣. ដួង អឿន ពុំបាននិយាយពីវាលតូចនោះទេ ក្នុងពេលគាត់ផ្តល់សក្ខីកម្ម តែគាត់ស្គាល់ឈ្មោះវត្តអូរកណ្តាល តែគាត់ពុំដឹងថាវត្តនេះត្រូវបានប្រើប្រាស់ជាអ្វីឡើយ ក្នុងរបបខ្មែរក្រហម ព្រោះគាត់រស់នៅឆ្ងាយពីវត្តមួយនេះ[2081]។ ណាមួយវិញទៀត នៅក្នុងដីកាដំណោះស្រាយ ពុំមានកន្លែងណាមួយនិយាយដល់ទីតាំងអូរកណ្តាលនេះទេ។

២០៥៤. ក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួន ឃុន ម៉ុន បានបញ្ជាក់ថា គាត់សន្មតថាប្រពន្ធគាត់ត្រូវបានសម្លាប់នៅវាលតូច ព្រោះក្រោយឆ្នាំ ១៩៧៩ គាត់បានដឹងតាមរយៈ "ប្រជាជនដូចគ្នា" ថាវាជាកន្លែងសម្លាប់អ្នកនៅក្នុងស្រុកដែលត្រូវបានចោទថាក្បត់ ឬជាជនជាតិវៀតណាម[2082]។ តាមរយៈចម្លើយរបស់គាត់ វាបង្ហាញឱ្យឃើញច្បាស់ថា គាត់មិនត្រឹមតែមិនបានឃើញការសម្លាប់មនុស្សប៉ុណ្ណោះទេ តែគាត់ថែមទាំងមិនស្គាល់កន្លែងនោះទៀត ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះវាគ្រាន់តែជាការស្មានរបស់គាត់ប៉ុណ្ណោះ។

២០៥៥. កុល លីម ជាសាក្សី និងជាអ្នកដែលត្រូវបានចោទប្រកាន់ថាបានចាប់ខ្លួនគ្រួសារ ឃុន ម៉ុន បានអះអាងថា អ្នកបររទេះបានប្រាប់គាត់ថា គ្រួសារ ឃុន ម៉ុន ត្រូវបានសម្លាប់នៅវាលតូច ឬ ព្រៃតាពៅ ស្ថិតនៅខាងត្បូងវត្តអូរកណ្តាល ក្នុងឃុំអង្គរទ្រេត ស្រុកព្រៃវែង[2083]។ ដូចដែលធ្លាប់បានចង្អុលបង្ហាញរួចហើយពីខាងលើ ក្រៅពីការណ៍ដែលគាត់និយាយឡើងវិញពីសម្តីអ្នកដទៃ គឺថាចម្លើយរបស់គាត់ ពុំមានធាតុផ្សំណាមួយ ទាក់ទងនឹងការពិតនៃការសម្លាប់ជនជាតិវៀតណាមនៅលើទីតាំងនោះទេ។

២០៥៦. ក្នុងពេលសម្ភាសជាមួយអ្នកស៊ើបអង្កេត ឈួន រី បានបញ្ជាក់ថាគាត់បានឮអ្នក ១៧ មេសា ដែលធ្វើការជាមួយគាត់ និយាយថាជនជាតិវៀតណាមត្រូវគេសម្លាប់នៅវាលតូច។ អ្នក ១៧ មេសា ដែលមិនស្គាល់ឈ្មោះទាំងអស់នោះ ជាអ្នកបានឃើញការសម្លាប់ផ្ទាល់។ ឈួន រី បាននិយាយថា

---

[2081] ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/381.1** ទំព័រ ៣២ ម៉ោង 11.12.56។

[2082] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ **ឯកសារ E3/7806**, ERN KH 00224676។

[2083] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ **ឯកសារ E3/5243**, ERN KH 00224776។

ក្រោយឆ្នាំ ១៩៧៩ អ្នកភូមិវាលតូចទាំងអស់សុទ្ធតែបានដឹងពីការសម្លាប់ជនជាតិវៀតណាមនេះ[2084]។

២០៥៧. ប្រភពព័ត៌មានមួយផ្សេងទៀតរបស់គាត់ គឺឈ្មោះ ទ្រី ជាអ្នកបររទេះ។ ទ្រីបានប្រាប់គាត់ថា បានដឹកជនជាតិវៀតណាមទៅកន្លែងវាលតូចនេះ តែគាត់មិនបានឃើញការសម្លាប់មនុស្សទេ[2085]។ ក៏ប៉ុន្តែ ក្នុងឆ្នាំ ២០០០ នៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា សាក្សី ឈួន រី បាននិយាយផ្សេងពីនេះថា "អ្នកធ្លាប់ស្គាល់ [...] កន្លែងហ្នឹង" បានប្រាប់គាត់ថា គេបានយកជនជាតិវៀតណាមមកសម្លាប់នៅត្រង់កន្លែងហ្នឹង[2086]។

២០៥៨. វាជាការបង្ហាញឱ្យឃើញច្បាស់ផងដែរថា ទើបតែដល់ឆ្នាំ ២០០៩ មកហើយ ពោលគឺប្រាំបួនឆ្នាំក្រោយមក ដែល ឈួន រី បញ្ជាក់ភ្លាមៗថាបានឃើញជនជាតិវៀតណាមត្រូវបានគេនាំទៅកន្លែងនោះ[2087]។ ក្រៅពីលក្ខណៈយឺតយ៉ាវរបស់ចម្លើយមួយនេះ គេមានហេតុផលត្រឹមត្រូវក្នុងការចោទសួរ ទាក់ទងនឹងវិធីដែលគាត់អាចកំណត់អត្តសញ្ញាណជនជាតិវៀតណាមដែលគាត់មិនស្គាល់ បានពីចម្ងាយ។ ជាថ្មីម្តងទៀត នៅត្រង់នេះ ដោយសារពុំមានលទ្ធភាពសួរដេញដោលក្នុងសវនាការ មន្ទិលសង្ស័យនៅតែមានដដែល។

២០៥៩. ប្រឈមនឹងកំណត់ហេតុស្តាប់ចម្លើយទាំងអស់ដែលមិនស្គាល់ប្រភព និងព័ត៌មានដែលមិនអាចផ្ទៀងផ្ទាត់បាននៅក្នុងសវនាការ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ជាប្រាកដ។ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា ជនជាតិវៀតណាមដែលត្រូវបានបង្ហាញនៅក្នុងផ្នែកមួយនេះ ត្រូវបានសម្លាប់នៅទីតាំងវាលតូចបានទេ ខណៈដែលភ័ស្តុតាងដែលមានស្រាប់ មិនអាចឱ្យគេភ្ជាប់ជនជាតិវៀតណាមទាំងនោះ ទៅនឹងទីកន្លែងសម្លាប់មនុស្សនោះបានទេ។

---

[2084] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ **ឯកសារ E3/7891**, ERN KH 00408518។

[2085] កំណត់ហេតុស្តាប់ចម្លើយ ឈួន រី ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ **ឯកសារ E3/7891**, ERN KH 00034595។

[2086] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ E3/7559**, ERN KH 00034279។

[2087] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ **ឯកសារ E3/7891**, ERN KH 00408519 (ដោយបញ្ជាក់ថា « ខ្ញុំមិនដឹងមកពីភូមិណា ឃុំណាខ្លះទេ។ » (*sic*))។

## 5. ការប្រព្រឹត្តមកលើជនជាតិខ្មែរដែលមានសហព័ន្ធជាជនជាតិវៀតណាម និងមកលើកូនៗ ដែលមានម្តាយ ឬ ឪពុកជាជនជាតិវៀតណាម

### 5.ក. ការប្រព្រឹត្តមកលើជនជាតិខ្មែរដែលមានសហព័ន្ធជាជនជាតិវៀតណាម

២០៦០. យោងតាមកថាខណ្ឌ ៨០៩ នៃដីកាដំណោះស្រាយ "[...] ហើយពេលខ្លះទៀត ប្តីខ្មែរដែលមានប្រពន្ធជនជាតិវៀតណាម ក៏ត្រូវបានគេចាប់ខ្លួន ឬ សម្លាប់ដែរ"។ ក្នុងករណីជាក់ស្តែងនេះ ចៅក្រមស៊ើបអង្កេតបានសំអាងតែទៅលើចម្លើយពីរប៉ុណ្ណោះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានបែបនេះ ដែលក្នុងនោះ ចម្លើយរបស់ ឃុន ម៉ុន បានលើកឡើងពីការចាប់ខ្លួនបែបសន្មតរបស់គាត់[2088]។

២០៦១. ឃុន ម៉ុន បានឆ្លើយថា ពីរបីថ្ងៃក្រោយការបាត់ខ្លួនគ្រួសាររបស់គាត់ គាត់ត្រូវបានគេហៅឱ្យទៅជួបឈ្មោះ ថូ ប្រធានសន្តិសុខស្រុក ហើយម្នាក់នេះបានឃុំគាត់រហូតដល់ឆ្នាំ ១៩៧៩[2089]។

២០៦២. ចម្លើយ ឃុន ម៉ុន មួយនេះ ផ្ទុយគ្នាពីចម្លើយបងប្អូនស្រីរបស់គាត់ទាំងពីរនាក់ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលពួកគាត់មិនត្រឹមតែមិនបាននិយាយពីការឃុំខ្លួនដែលរងការចោទប្រកាន់នេះទេ តែលើសពីនេះ ពួកគាត់ទាំងពីរថែមទាំងឆ្លើយថា ឃុន ម៉ុន បានរៀបការជាថ្មី ប្រហែលជាមួយឆ្នាំក្រោយមក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2090]។ ចម្លើយផ្ទុយគ្នាបែបនេះ គឺជាការបង្ហាញឱ្យឃើញម្តងទៀតពីភាពទន់ខ្សោយនៃតម្លៃជាភ័ស្តុតាងរបស់ចម្លើយប្រភេទនេះ ហើយវាត្រូវរារាំងអង្គជំនុំជម្រះមិនឱ្យសំអាងលើចម្លើយបែបនេះ នៅក្នុងពេលធ្វើសេចក្តីសម្រេចចិត្ត។

---

[2088] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ E3/7597**, ERN KH 00034595។

[2089] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ E3/7597**, ERN ERN KH 00034595 ។

[2090] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ឃុន មុត ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ E3/7585**, ERN KH 00034666-67។ កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ឃុន សាមិត ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ E3/7586**, ERN KH 00034639។

២០៦៣. ក្នុងអំឡុងពេលសវនាការ ឡាច គ្រី បានពន្យល់ដូចគ្នានឹង ឃុន ម៉ុន ដែរ ពីវិធីដែលការរៀបការមួយត្រូវបានរៀបចំសម្រាប់បងប្រុសរបស់គាត់ ក្រោយពីបងថ្លៃត្រូវគេចាប់ខ្លួន។ សាក្សីបានពន្យល់ពីការរៀបការនេះថា "មេឃុំ [...]គាត់មានការអាណិតអាសូរ [...] ឈ្មោះ ឡាច នី"[2091]។

២០៦៤. ចៅក្រមស៊ើបអង្កេតបានសំអាងជាពិសេសលើចម្លើយរបស់ ឡេង សាម៉េត ប្រជាជនស្វាយអន្ទរ ដើម្បីអះអាងថាការប្រព្រឹត្តត្រៀមសម្រាប់សហព័ទ្ធរបស់ជនជាតិវៀតណាម ព្រមទាំងកូនៗ គឺចេញមកពីសេចក្តីសម្រេចថ្នាក់លើ[2092]។ ចៅក្រមស៊ើបអង្កេតយល់ឃើញថា ឡេង សាម៉េត ដឹងដំណឹងនេះក្នុងពេល "ប្រជុំស្វ័យទិតៀន"[2093]។ ការប្រជុំនេះដឹកនាំដោយ សេង ប្រធានភូមិ នៅពោធិ៍សាត់ ប៉ុន្តែ ក្រៅពីសន្និដ្ឋានថា សេង ស្ថិតក្រោមការគ្រប់គ្រងរបស់ឃុំ ឡេង សាមិត ពុំបាននិយាយអ្វីឱ្យបានច្បាស់លាស់ ទាក់ទងនឹងអ្វីដែលប្រធានស្រុកបាននិយាយឱ្យប្រាកដនោះទេ[2094]។

២០៦៥. ជាមួយគ្នានេះដែរ គេត្រូវកត់សម្គាល់ថា ក្នុងពេលធ្វើការសម្ភាសនេះ មានមនុស្សមិនស្គាល់ម្នាក់បានចូលអន្តរាគមន៍ ហើយគឺបុគ្គលម្នាក់នេះឯងដែលបានលើកឡើងថា បទបញ្ជាគឺចេញមកពីប្រធានស្រុក តែគាត់មិនបានផ្តល់ប្រភពនៃព័ត៌មានមួយនេះទេ[2095]។ អង្គជំនុំជម្រះមិនអាចសម្រេចដោយផ្អែកលើចម្លើយមួយដែលប្រមូលបាន ក្នុងល័ក្ខខ័ណ្ឌមិនគួរឱ្យជឿទុកចិត្តបាននោះឡើយ។

២០៦៦. សរុបសេចក្តីមក យោងតាមភ័ស្តុតាងទាំងអស់ដែលមាន គេមិនអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថាមានការចាប់ ឬសម្លាប់ជនជាតិខ្មែរដែលរៀបការជាមួយនឹងជនជាតិវៀតណាម នៅក្នុងឃុំស្វាយអន្ទរ បានទេ។

---

[2091] ប្រតិចារឹក ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/380.1** ទំព័រ ៦៨-៦៩ ពីម៉ោង 15.28.32 ដល់ម៉ោង 15.32.01។

[2092] ដីកាដំណោះស្រាយ កថាខណ្ឌ ៨១៣។

[2093] ដីកាដំណោះស្រាយកំណត់សម្គាល់ចុងឯកសារ ៣៤៧៨។

[2094] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ **ឯកសារ E3/7594**, ERN KH 00033508។

[2095] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ **ឯកសារ E3/7594**, ERN KH 00033512 ក្នុងឯកសារនេះ គេឃើញមានចម្លើយ "មនុស្សម្នាក់ទៀត"។

## 5.២. ទ្រឹស្តីនាក់ទងនឹងខ្សែស្រឡាយខាងម្តាយ

២០៦៧. យោងតាមកថាខណ្ឌ ៨០៧ នៃដីកាដំណោះស្រាយ "ប្រសិនបើបុរសជាជនជាតិវៀតណាម រៀបការជាមួយស្ត្រីខ្មែរ គឺមានតែបុរសទេដែលត្រូវបានយកទៅសម្លាប់ ចំពោះប្រពន្ធ និងកូន ត្រូវបានទុកជីវិត" ដូចករណី ង៉ាង (ប្តីរបស់ ឡេង សាម៉េត) ជុយ (ប្តីរបស់ ដួង អឿន) តែបើម្តាយជាជនជាតិវៀតណាម ករណីពុំមែនដូច្នេះ នោះទេ។

២០៦៨. ក្រុមមេធាវីការពារក្តីមិនប្រកែកនោះទេពីការណ៍ដែលនៅក្នុងឃុំស្វាយអន្ទរ ភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង អាចធ្វើឱ្យគេយល់ថា កូនៗត្រូវបាននាំយកទៅក្នុងពេលតែមួយជាមួយនឹងម្តាយជនជាតិវៀតណាម ដូចជាករណីរបស់ សាន (ប្រពន្ធ ឡាច នី) សេង ហួរ (ប្រពន្ធ ឃុន ម៉ុន) និងប្រពន្ធរបស់ អៀ ពៅ។ ការពិភាក្សាផ្តោតតែលើភ័ស្តុតាងទាំងឡាយដែលពាក់ព័ន្ធដល់ការបង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មមនុស្សឃាត ប៉ុណ្ណោះ។

២០៦៩. ប៉ុន្តែ គេត្រូវគូសបញ្ជាក់ថា ភ័ស្តុតាងទាក់ទងភូមិអន្លង់ទ្រា មិនអាចឱ្យគេបញ្ជាក់អះអាងពីអត្ថិភាពនៃទ្រឹស្តីមួយដែលស្ថិតនៅក្នុងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា បានទេ។ ដូចដែលបានពិនិត្យពីខាងលើ ក្នុងករណីរបស់ សៅ សាក់ និង នាង ណាត គឺថាកូនៗដែលមានម្តាយជាជនជាតិវៀតណាម អាចមានជីវិតរស់នៅបន្តទៀត រីឯកូនៗដែលមានឪពុកជាជនជាតិវៀតណាម ត្រូវបានគេនាំយកទៅ។

២០៧០. យ៉ាងណាមិញ គេត្រូវគូសបញ្ជាក់ថា ភ័ស្តុតាងផ្សេងៗ និងផ្ទុយគ្នា ដែលមាននៅក្នុងសំណុំរឿង ពិតជាមិនអាចគាំទ្រទស្សនៈករណ៍បែបសន្មតដែលជាមូលដ្ឋាននៃគោលនយោបាយរងការចោទប្រកាន់មួយនេះ ដូចដែលបានពិពណ៌នាដោយចៅក្រមស៊ើបអង្កេត នៅក្នុងកថាខណ្ឌ ៨០៨ នៃដីកាដំណោះស្រាយ បាននោះទេ ហើយវាកាន់តែមិនអាចបង្ហាញឱ្យឃើញពីការផ្សព្វផ្សាយនូវគោលនយោបាយមួយនេះ។

២០៧១. ថេង ផល ដែលបានថ្លែងប្រាប់តុលាការថា គាត់ដឹងតិចតួចប៉ុណ្ណោះ ទាក់ទងនឹងការអនុម័តគោលនយោបាយពាក់ព័ន្ធនឹងកូនៗដែលមានឪពុក ឬ ម្ដាយជាជនជាតិវៀតណាម បានបញ្ជាក់ថា អ្វីដែលគាត់បានយល់គឺថា ប្រសិនបើម្ដាយជាជនជាតិវៀតណាម កូនៗក៏ជាវៀតណាមដូចគ្នាដែរ[2096]។

២០៧២. ទោះជាបានថ្លែងថា កូនដែលមានម្ដាយជាខ្មែរ ក៏ជាខ្មែរដូចគ្នា ដោយគាត់បានពន្យល់ថានេះជាមូលហេតុដែលកូនៗរបស់ ឡាច នី ដែលមានម្ដាយជាជនជាតិវៀតណាម ត្រូវបានគេនាំយកទៅជាមួយម្ដាយ[2097] ក៏ដោយ ក៏ ដួង អឿន ពុំមានសមត្ថភាពបញ្ជាក់បានថាវិធាននេះចេញមកពីណានោះទេ[2098]។

២០៧៣. ម្យ៉ាងវិញទៀត ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន បានរៀបរាប់ពីការបារម្ភចំពោះកូនស្រី រហូតដល់គាត់បានប្ដូរឈ្មោះនាង ខណៈដែលឪពុកនាង ជាជនជាតិវៀតណាម[2099]។ ក្នុងភូមិតូចមួយដែលគេស្គាល់ប្ដីគាត់គ្រប់គ្នា គេពិបាកនឹងយល់ពីសារៈប្រយោជន៍នៃការប្ដូរឈ្មោះនេះណាស់ តែទោះយ៉ាងណាក៏ដោយ ដួង អឿន បានសន្និដ្ឋានថាកូនស្រីរបស់គាត់ មិនត្រូវបានខ្មែរក្រហមនាំយកទៅធ្វើបាប ឬក៏រើសអើងនោះឡើយ ហើយគាត់បញ្ជាក់ថា ជីវិតរបស់នាង ពុំស្ថិតក្នុងគ្រោះថ្នាក់នោះទេ[2100]។

២០៧៤. ឡាច គ្រី បានថ្លែងថាពុំមានអ្វីគួរឱ្យកត់សម្គាល់ឡើយ មុននឹងបងថ្លៃរបស់គាត់បាត់ខ្លួន។ ប៉ុន្តែ គាត់បានដឹងថា កូនៗដែលមានម្ដាយជាជនជាតិវៀតណាម ត្រូវបាននាំយកទៅជាមួយម្ដាយ តែជាមួយគ្នានេះ គាត់បានបញ្ជាក់ដែរថា ពុំមានកម្មាភិបាលខ្មែរក្រហមណាម្នាក់និយាយរឿងនេះប្រាប់គាត់ទេ[2101]។ យ៉ាងណាមិញ វាជាការសំខាន់ដែលត្រូវគូសបញ្ជាក់ថា ឡាច គ្រី បានអះអាងប្រាប់

---

[2096] ប្រតិចារឹក ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/371.1** ទំព័រ ៤១ ម៉ោង 11.29.46។

[2097] ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/381.1** ទំព័រ ៤៣ មុនម៉ោង 11.06.23។

[2098] ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/381.1** ទំព័រ ៣៤-៣៥ ពីម៉ោង 10.49.03 ដល់ម៉ោង 10.50.05 ទំព័រ ៧០-៧១ បន្ទាប់ពីម៉ោង 14.11.42។

[2099] ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/381.1** ទំព័រ ១១ មុនម៉ោង 09.30.20 ទំព័រ ៣៥ ម៉ោង 10.47.51។

[2100] ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/381.1** ទំព័រ ២៥ ប្រហែលម៉ោង 10.48.02។ កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ **ឯកសារ E3/7793**, ERN FR KH 00225350-51។

[2101] ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/379.1** ទំព័រ ៦០ មុនម៉ោង 14.31.17។

តុលាការថា គាត់មិនដែលឮអាជ្ញាធរភូមិនិយាយពីជនជាតិវៀតណាមឡើយ[2102] ដែលនេះវាបានបដិសេធចោលថាពុំមានការផ្សព្វផ្សាយទ្រឹស្តីបែបសន្ទូតណាមួយនោះឡើយ។

២០៧៥. ម្យ៉ាងវិញទៀត ចៅក្រមស៊ើបអង្កេតបានសំអាងលើចម្លើយរបស់ ឡាច នី, ឈួន រី និង ចិន ផៃ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីគាំទ្រទឡ្ហីករណ៍បែបសន្ទូតស្តីពី"គោលនយោបាយ" មួយនេះ ដែលលើកឡើងថា កូនដែលកើតចេញពីម្តាយជនជាតិវៀតណាម ត្រូវបានគេសម្លាប់ ពីព្រោះ "ទងសុក ឬ ឈាមរបស់កូន ចេញពីម្តាយ មិនមែនចេញពីឪពុកទេ"[2103]។

២០៧៦. បើតាមចម្លើយ ឡាច នី ឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺ ផែម ប្រធានឃុំ ជាអ្នកនិយាយសម្តីនេះ តែគាត់មិនបានបញ្ជាក់ថាវាជាសេចក្តីណែនាំរបស់ថ្នាក់លើណាមួយនោះឡើយ[2104]។ រីឯសាក្សី ឈួន រី ដែលជាបងប្អូនជីដូនមួយរបស់ ឡាច នី វិញ បានថ្លែងថាគាត់សន្និដ្ឋានថា កូនដែលកើតចេញពីម្តាយជនជាតិវៀតណាម ត្រូវគេសម្លាប់ជាមួយម្តាយ ហើយបើឪពុកជាវៀតណាមវិញ គឺមានតែឪពុកម្នាក់ប៉ុណ្ណោះដែលត្រូវសម្លាប់ នេះបើតាមអ្វីដែលគាត់បានឃើញក្នុងករណីរបស់ ឡាច នី[2105]។ ចិន ផៃ ជាប្រពន្ធទីពីររបស់ អៀ ពៅ បានថ្លែងថា គាត់គិតថា ខ្មែរក្រហមគិតថា ឈាមរបស់ម្តាយ ខ្លាំងជាងឈាមឪពុក។ ដូច្នេះ វាជាការយល់ឃើញផ្ទាល់ខ្លួន និងពុំមែនជាសម្តីផ្លូវការដែលស្តាប់ឮឡើយ[2106]។ ទោះយ៉ាងណាក៏ដោយ ចម្លើយទាំងអស់នេះ ពុំអាចផ្ទៀងផ្ទាត់បាន ហើយជាទូទៅគឺបានមកពីការយល់ឃើញផ្ទាល់ខ្លួន ហើយហេតុដូច្នេះ គឺពុំអាចចាត់ទុកជាភ័ស្តុតាងបានឡើយ។

២០៧៧. ការអះអាងផ្សេងៗទៀតដែលត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ ដែលលើកឡើងថា គោលនយោបាយនេះ គឺសំដៅ "បំផ្លាញពូជ ឬខ្សែលោហិតរបស់វៀតណាម" ហើយថា "ពូជវៀតណាម

[2102] ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/379.1** ទំព័រ ៧២ មុនម៉ោង 15.21.02។

[2103] ដីកាដំណោះស្រាយ កថាខណ្ឌ ៨០៨។

[2104] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ **ឯកសារ E3/9319**, ERN KH 00034338។

[2105] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ **ឯកសារ E3/7891**, ERN KH 00408518។ កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ E3/7559**, ERN KH 0034278 (បើប្រពន្ធខ្មែរ កូនហ្មងវាខ្មែរតាមម្តាយ បើម៉ែហ្មងយួន កូនហ្មងវាខ្មែរតាមម្តាយទាំងអស់)។

[2106] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ E3/7544**, ERN KH 00033853។

មិនត្រូវមានទៀតទេ និងមិនត្រូវអនុញ្ញាតឱ្យមានការបង្កបង្កើត” គឺចេញមកដូចគ្នាពីចម្លើយមិនគួរជឿជាក់បានរបស់ ឃុន សាមិត, ឃុន មុត, ស៊ិន ឆន និង ហ៊ិន ហាន ឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា[2107]។

២០៧៨. ដូច្នេះ ផ្អែកលើកំណត់ហេតុស្តាប់ចម្លើយដែលគ្មានប្រភព និង/ឬ យោងគ្នាទៅវិញទៅមកក្នុងចំណោមគ្នាឯងទាំងអស់នេះ ដែលមិនអាចផ្ទៀងផ្ទាត់បាន និងត្រូវបានប្រមូលនៅក្រៅក្របខ័ណ្ឌតុលាការ សម្រាប់ខេត្តព្រៃវែង គេមិនអាចសន្និដ្ឋានបានពីអត្ថិភាពនៃទ្រឹស្តីទាក់ទងនឹងខ្សែស្រឡាយខាងម្តាយ ដែលទំនងត្រូវបានអនុម័តដោយបក្សកុម្មុយនីស្តកម្ពុជា ហើយក៏មិនអាចសន្និដ្ឋានបានថាទ្រឹស្តីមួយនេះត្រូវបានអនុវត្ត ស្របតាមការណែនាំជាឯកភាពមួយចំនួន ដែលចេញមកពីគោលនយោបាយជាតិបានដែរ។

**គ. ស្រុកពារាំង**

២០៧៩. នៅលើផែនទីភូមិសាស្ត្របច្ចុប្បន្នរបស់ប្រទេសកម្ពុជា ស្រុកពារាំង មានព្រំប្រទល់ជាប់ជាមួយស្រុកព្រៃវែង (ដែលមានឃុំស្វាយអន្ទរ) និងស្រុកកំពង់លាវ (ដែលមានឃុំព្រែកជ្រៃ (ភូមិអន្លង់ទ្រា) និងឃុំព្រែកអន្ទះ)។

២០៨០. យឹម មួយ ជាបងស្រីប្រពន្ធ ឃុន ម៉ុន គឺជាជនជាតិវៀតណាម និងមានដើមកំណើតនៅអន្លង់ទ្រាដូចប្អូនស្រីរបស់គាត់ដែរ។ ក្រោយរៀបការរួច គាត់បានទៅរស់នៅជាមួយប្តី ក្នុងភូមិជ្រៃគ្រហឹម ស្រុកពារាំង ក្នុងខេត្តព្រៃវែង ដូចគ្នា។ បើយោងតាមចម្លើយរបស់គាត់ ក្នុងភូមិនេះ “ពុំមានគ្រួសារវៀតណាមទេ”[2108]។

---

[2107] ដីកាដំណោះស្រាយ កំណត់សម្គាល់ចុងឯកសារ ៣៤៦៣-៣៤៦៤។

[2108] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ **ឯកសារ E3/7783**, ERN KH 00238898។

២០៨១. អៀ ពៅ បានលើកឡើងពីករណីគ្រួសារប្រពន្ធរបស់គាត់ដែលរស់នៅភូមិកំពង់ឫស្សី ឃុំកំពង់ឫស្សី ស្រុកពារាំង ដែលនៅជិតនឹងឃុំព្រែកអន្ទះរបស់គាត់។ គ្មានបញ្ហាអ្វីកើតឡើងចំពោះគ្រួសារប្រពន្ធគាត់នោះទេ នៅក្នុងសម័យខ្មែរក្រហម។ ទាំងអស់គ្នានៅមានជីវិត[2109]។

២០៨២. ចម្លើយទាំងពីរដែលលើកឡើងពីស្រុកពាមរក៍ ត្រូវនាំអង្គជំនុំជម្រះឱ្យកត់សម្គាល់ថា ខ្លួនមិនអាចសន្និដ្ឋានថាមានការប្រព្រឹត្តជាពិសេសលើជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែងទាំងមូលបានទេ។

២០៨៣. ពាក់ព័ន្ធនឹងភ័ស្តុតាងទាំងឡាយទាក់ទងនឹងព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅពោធិ៍ចិន្តាំ និងស្វាយអន្ទរ សាក្សីទាំងពីររូបដែលគ្មានវត្តមាននៅកន្លែង បានផ្តល់តែភ័ស្តុតាងដែលឮតាមគេនិយាយតគ្នាប៉ុណ្ណោះ។ ដូច្នេះ អង្គជំនុំជម្រះអាចសំអាងលើចម្លើយសាក្សីទាំងពីរ សម្រាប់តែធ្វើការបញ្ជាក់គាំទ្រជាយថាហេតុប៉ុណ្ណោះ។

## ២. ការប្រព្រឹត្តលើជនជាតិវៀតណាមនៅខេត្តស្វាយរៀង

២០៨៤. ពាក់ព័ន្ធនឹងខេត្តស្វាយរៀង ចៅក្រមស៊ើបអង្កេតបានធ្វើបទបង្ហាញពីអង្គហេតុទាក់ទងនឹងការចោទប្រកាន់ពីបទ "សម្លាប់រង្គាល" ជនស៊ីវិលវៀតណាម នៅចន្លោះឆ្នាំ ១៩៧៧ និង ឆ្នាំ ១៩៧៩ (ក)។ ចៅក្រមស៊ើបអង្កេតក៏បានរាយការណ៍ផងដែរពីភ័ស្តុតាងខ្លះៗ ទាក់ទងនឹងអ្វីដែលពួកគាត់ហៅថាជា "ទ្រឹស្តីទាក់ទងនឹងខ្សែស្រឡាយខាងម្តាយ" (ខ)។

## ក. ការចោទប្រកាន់ពីបទសម្លាប់រង្គាលជនស៊ីវិលវៀតណាមនៅក្នុងខេត្តស្វាយរៀង

២០៨៥. យោងតាមដីកាដំណោះស្រាយ "ការសម្លាប់រង្គាលលើប្រជាជនស៊ីវិលវៀតណាម ត្រូវបានប្រព្រឹត្តនៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង នាឆ្នាំ ១៩៧៧ ឆ្នាំ ១៩៧៨ និងឆ្នាំ ១៩៧៩"[2110]។ ដើម្បីគាំទ្រលើការលើកឡើងមួយនេះ មានកំណត់ហេតុស្តាប់ចម្លើយចំនួនប្រាំ និងកិច្ចសម្ភាសចំនួនបីរបស់

---

[2109] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ E3/7954**, ERN KH 00033767។

[2110] ដីកាដំណោះស្រាយ កថាខណ្ឌ ៧៩៧, ៨០១។

បុគ្គលប្រាំពីរនាក់ផ្សេងគ្នា ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា[2111]។ ក្នុងចំណោមអ្នកទាំងនោះ អង្គជំនុំជម្រះបានស្តាប់ចម្លើយបួននាក់ ក្នុងនោះមាន អ៊ុង សំអ៊ាន, ស៊ិន ឆែម, អ៊ិន យឿង និង សៀង ចាន់ធី។ គេត្រូវកត់សម្គាល់ថា អ៊ិន យឿង ពុំធ្លាប់បានផ្តល់ចម្លើយពីមុនមកទេ តែគាត់ធ្លាប់ត្រូវបានសម្ភាសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ចាន់ គា ក្នុងនាមជា "អ្នកជិតខាង"[2112]។

២០៨៦. ក្នុងសម័យខ្មែរក្រហម អ្នកទាំងបីនេះ រស់នៅក្នុងភូមិ និងឃុំផ្សេងៗគ្នា។ ដូច្នេះ គេត្រូវសិក្សាលើរឿងរ៉ាវរបស់ពួកគាត់ ដាច់ចេញពីគ្នា។ អ៊ុង សំអ៊ាន បានរៀបរាប់ពីព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅក្នុងភូមិក្របាមក ឃុំចន្ត្រី ស្រុករមាសហែក (១)។ ស៊ិន ឆែម បានរៀបរាប់ពីព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅក្នុងភូមិស្វាយយា ឃុំស្វាយយា ស្រុកស្វាយជ្រំ (២)។ ពាក់ព័ន្ធនឹង អ៊ិន យឿង គាត់ធ្លាប់រស់នៅក្នុងស្រុករមាសហែក ដូច អ៊ុង សំអ៊ាន ដែរ តែនៅក្នុងឃុំកំពង់ត្រាច (៣)។ សៀង ចាន់ធី បានផ្តល់សក្ខីកម្មទាក់ទងនឹងអង្គហេតុកើតឡើងនៅជិតភូមិឫស្សីព្រៃ ឃុំកំពង់ចំឡង ស្រុកស្វាយជ្រំ (៤)។ បន្ទាប់មកទៀត គេត្រូវវិភាគលើកំណត់ហេតុស្តាប់ចម្លើយពីរបីនេះ ដែលរឿងរ៉ាវនៅក្នុងនោះ ពុំមានជាប់ពាក់ព័ន្ធនឹងរឿងរ៉ាវសាក្សីដែលបានមកផ្តល់សក្ខីកម្មនោះទេ (៥)។

## 1. រឿងរ៉ាវរបស់ អ៊ុង សំអ៊ាន

### 1.ក. វត្តមានគ្រួសារចម្រុះខ្មែរ-វៀតណាម

២០៨៧. យោងតាមសក្ខីកម្ម អ៊ុង សំអ៊ាន គឺមានគ្រួសារចម្រុះខ្មែរ-វៀតណាម រស់នៅក្នុងភូមិមួយផ្សេងពីភូមិរបស់គាត់ មានចម្ងាយប្រហែលមួយគីឡូម៉ែត្រ[2113]។ គាត់បានពន្យល់ថាគាត់ដឹងថាអ្នកទាំង

---

[2111] ដីកាដំណោះស្រាយ កថាខណ្ឌ ៧៩៧, ៨០១ កំណត់សម្គាល់ចុងឯកសារ ៣៣៩៧ និង ៣៤១៦ ដែលយោងទៅ កំណត់ហេតុស្តាប់ចម្លើយ ខឹម សាម៉ុន, ស៊ិន ឆែម, អ៊ុង អៀន, ព្រំ យ៉ាន់, ចាន់ រឿន នៅមជ្ឈមណ្ឌលឯកសារកម្ពុជា មានចម្លើយរបស់ ប៊ូ វ៉ាន់, ចាន់ គា និង ស៊ិន ឆែម។

[2112] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ **ឯកសារ E3/7525**, ERN KH 00089630។

[2113] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៤៨ បន្ទាប់ពីម៉ោង 11.16.33។

នោះជាជនជាតិវៀតណាម ពីព្រោះពួកគេមកលក់ដូរនៅក្នុងភូមិគាត់ តែគាត់មិនស្គាល់ដល់ថ្នាក់អាចកំណត់អត្តសញ្ញាណពួកគេបានទេ[2114]។

២០៨៨. តាមរយៈចម្លើយផ្សេងៗរបស់ អ៊ុង សំអ៊ាន គេយល់បានថា មានបីគ្រួសារចម្រុះជាតិសាសន៍[2115]។ សាក្សីបានបញ្ជាក់ថា ផ្តើមចេញពីគ្រួសារទាំងបីដែលមានវត្តមានតាំងពីដំបូង វាក៏កើតបានជាកូនជាចៅ ហើយក្រោយមកទៀត ក៏មានការរៀបការផ្សេងៗទៀត ហើយដូច្នេះ ក៏មានគ្រួសារបន្ថែមទៀត[2116]។ ប៉ុន្តែ ការខ្វះការបញ្ជាក់ទាក់ទងនឹងគ្រួសារបន្ថែមសំខាន់ៗទាំងអស់នេះ មិនអាចឱ្យគេដឹងបានថា តើគ្រួសារចម្រុះជាតិសាសន៍មានចំនួនសរុបប៉ុន្មាន បើដកចេញនូវប្តីប្រពន្ធទាំងបីគូ និងកូនៗរបស់ពួកគេ។

២០៨៩. នៅពេលសហព្រះរាជអាជ្ញាសាកល្បងសុំឱ្យគាត់បង្ហាញពីភាពខុសគ្នាផ្នែករូបរាងកាយ ឬវប្បធម៌រវាងគ្រួសារទាំងនេះ ជាមួយនឹងប្រជាជនខ្មែរ អ៊ុង សំអ៊ាន បានពន្យល់ថា ពុំមានភាពខុសគ្នាអ្វីនោះទេ[2117]។ សាក្សីបានឱ្យដឹងថា ប្រជាជនខ្មែរ និងប្រជាជនវៀតណាម មានប្រភេទស្បែកដូចគ្នា។ លើសពីនេះទៀត គ្រួសារទាំងនេះនិយាយខ្មែរបានយ៉ាងល្អ គ្មានរដឹនបន្តិចសោះ។

### 1.ខ. <u>ការចាប់ខ្លួនសមាជិកមួយចំនួនរបស់គ្រួសារទាំងនេះ</u>

២០៩០. អ៊ុង សំអ៊ាន ពុំមានភាពច្បាស់លាស់ទាក់ទងនឹងជោគវាសនារបស់គ្រួសារចម្រុះជាតិសាសន៍ទាំងអស់នេះ ក្នុងរបបខ្មែរក្រហម នោះឡើយ។ ពីដំបូង គាត់បានថ្លែងថា គ្រួសារទាំងនេះត្រូវបានបាត់ខ្លួន និងបញ្ជូនត្រលប់ទៅប្រទេសពួកគេវិញ[2118]។ បន្ទាប់មក នៅពេលត្រូវបានសួរតទល់នឹងចម្លើយ

---

[2114] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៤៤-៤៦ ពីម៉ោង 11.04.50 ដល់ម៉ោង 11.10.27 ទំព័រ ៦០ បន្ទាប់ពីម៉ោង 13.44.48។

[2115] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៤៤ បន្ទាប់ពីម៉ោង 11.04.50 ទំព័រ ៥២បន្ទាប់ពីម៉ោង 11.26.37 ទំព័រ ៥៤ បន្ទាប់ពីម៉ោង 11.30.45 ទំព័រ ៦០ ពីម៉ោង 13.44.48 ដល់ម៉ោង 13.46.46។

[2116] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៦១ ពីម៉ោង 13.46.46 ដល់ម៉ោង 13.49.21។

[2117] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៥៦-៥៧ ពីម៉ោង 13.36.56 ដល់ម៉ោង 13.40.07។

[2118] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៤៥ បន្ទាប់ពីម៉ោង 11.07.53។

កាលពីមុនរបស់គាត់ ដោយសហាព្រះរាជអាជ្ញា គាត់នឹកឃើញថា “[ពួកគេត្រូវបាន]ចាប់ទៅបាត់អស់ទៅ”[2119]។

២០៩១. អ៊ុង សំអ៊ាន បានថ្លែងថាគាត់បានឃើញ “ការចាប់ខ្លួន” នេះ ដែលត្រូវបានធ្វើឡើងនៅពេលរសៀល ដោយមនុស្សពីរនាក់ គ្មានអាវុធ ហើយគាត់ឃើញពួកគេស្លៀកសម្លៀកបំពាក់ខ្មៅដូចប្រជាជនដទៃទៀតដែរ[2120]។ មនុស្សទាំងពីរនាក់នេះ បាននិយាយប្រាប់កូនៗរបស់គ្រួសារទាំងនេះថា ពួកគេត្រូវទៅតាមកងចល័ត។ សាក្សីបានបញ្ជាក់ថាក្មេងៗទាំងនោះ មានអាយុចន្លោះពី ១០ ទៅ ១៥ ឆ្នាំ ដែលជាអាយុតម្រូវសម្រាប់ចូលក្នុងកងចល័ត[2121]។

២០៩២. បន្ទាប់មកទៀត អ៊ុង សំអ៊ាន បានថ្លែងថា៖ “ទៅកងចល័តមែន លោកគ្រូ។ ទៅលើកប្រព័ន្ធភ្លឺស្រែ ជីកប្រឡាយ ជីកស្រះអីហ្នឹង លោកគ្រូ។ ខែប្រូតអ៊ីចឹងទៅ ទៅប្រូត។ ខែស្ទូង ទៅស្ទូង ទាំងអស់តែគ្នា គេយកទៅនុង”[2122]។ ផ្ទុយទៅវិញ សាក្សីពុំបានបញ្ជាក់ថាតើគាត់កំពុងនិយាយសំដៅតែទៅលើកូនៗ ឬមួយក៏ទៅលើគ្រួសារទាំងមូលតែម្តង។

២០៩៣. ពាក់ព័ន្ធនឹងឪពុកម្តាយ ដំបូង សាក្សីបានថ្លែងថាពុំមានអ្វីកើតឡើងចំពោះពួកគេនោះទេ “ព្រោះទាំងខ្មែរ ទាំងយួន ទាំងចិនអី សុទ្ធតែកងចល័ត”[2123]។ ពួកគេអាចបន្តរស់នៅតាមផ្ទះ។ បន្ទាប់មក

---

[2119] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៤៦ ពីម៉ោង 11.10.27 ដល់ម៉ោង 11.12.36, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨ **ឯកសារ E3/7796**, ERN KH 00250719។ គប្បីបញ្ជាក់ត្រង់ចំណុចនេះផងដែរថា នៅពេលផ្តល់សក្ខីកម្ម មានភាពខុសគ្នាជាច្រើនពីការអះអាងរបស់អ្នកស្រីនៅពេលមុនៗ ក្នុងការបកប្រែជាភាសាអង់គ្លេស និងបារាំង។ ក្នុងអត្ថបទជាភាសាបារាំង មានសរសេរថា : « quatre ou cinq métisses vietnamiens […] ont été arrêtés et emmenés pour de bon » ចំណែកអត្ថបទជាភាសាអង់គ្លេសវិញសរសេរថា ៖ « *four to five mixed-race Vietnamese […] were arrested and taken away.* » (ERN FR 00282908 et ERN EN 00268645)។ សក្ខីកម្មរបស់សាក្សីនៅសវនាការត្រូវគ្នានឹងអត្ថបទជាភាសាអង់គ្លេសច្រើនជាង។

[2120] អ៊ុង សំអ៊ាន ៖ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៤៦-៤៧ ពីម៉ោង 11.10.27 ដល់ម៉ោង 11.14.18។

[2121] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៤៧-៤៨ ពីម៉ោង 11.14.18 ដល់ម៉ោង 11.18.42 ទំព័រ ៦១-៦២ ពីម៉ោង 13.49.21 ដល់ម៉ោង 13.50.42។

[2122] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៦២ បន្ទាប់ពីម៉ោង 13.49.21។

[2123] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៤៩ ប្រហែលម៉ោង 11.20.51។

សាក្សីបានពន្យល់ថា តាមការពិតទៅ គាត់មិនដឹងថាមានរឿងអ្វីកើតឡើងចំពោះពួកគេនោះទេ[2124] ដោយសាក្សីបញ្ជាក់ក្រោយមកទៀតថា ដោយសារតែគាត់ត្រូវទៅជីកប្រឡាយនៅឆ្ងាយពីភូមិ[2125]។ ចំពោះកូនៗ ក៏មិនខុសគ្នាពីឪពុកម្ដាយដែរ សាក្សីគ្រាន់តែនិយាយថា គាត់លែងបានឃើញពួកគេទៀត[2126]។

២០៩៤. បន្ថែមលើការខ្វះភាពច្បាស់លាស់ និងការខ្វះព័ត៌មាន ទាក់ទងនឹងរឿងរ៉ាវដែលបានកើតឡើងចំពោះក្រុមគ្រួសារចម្រុះជាតិសាសន៍ទាំងអស់នេះ អ៊ុង សំអ៊ាន មិនមានសមត្ថភាពប្រាប់ពីកាលបរិច្ឆេទបាន។ ទោះបីជាក្នុងចម្លើយកាលពីមុនរបស់គាត់ គាត់បានឆ្លើយថា “ការចាប់ខ្លួន” ទាំងនេះ បានកើតឡើងនៅក្នុងឆ្នាំ ១៩៧៧ ក៏ដោយ[2127] តែក្នុងពេលសវនាការវិញ គាត់បានបញ្ជាក់ថាគាត់មិនចាំពីកាលបរិច្ឆេទនេះទេ[2128]។

២០៩៥. ជាចុងក្រោយ សាក្សីបានថ្លែងថាគ្មានការប្រជុំណាមួយជាមួយកម្មាភិបាលស្រុក ឬកម្មាភិបាលឃុំក្នុងភូមិរបស់គាត់នោះទេ[2129]។

## 2. <u>រឿងរ៉ាវរបស់ ស៊ិន ឆែម</u>

### 2.ក. <u>វត្តមានគ្រួសារចម្រុះជាតិសាសន៍ខ្មែរ-វៀតណាម</u>

២០៩៦. ស៊ិន ឆែម បានថ្លែងថា នៅក្នុងភូមិស្វាយយារបស់គាត់ ឃុំស្វាយយា ស្រុកស្វាយជ្រុំ មានប្រជាជនប្រហែល ១០០ គ្រួសារ រស់នៅ ក្នុងនោះគ្រួសារចម្រុះជាតិសាសន៍ខ្មែរ-វៀតណាម មានចំនួន បី ឬ

---

[2124] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៤៩ បន្ទាប់ពីម៉ោង 11.20.51 ទំព័រ ៦៥ ពីម៉ោង 13.55.08 ដល់ម៉ោង 13.56.01។

[2125] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៤៩ បន្ទាប់ពីម៉ោង 11.20.51។

[2126] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៦៥-៦៦ ពីម៉ោង 13.56.01 ដល់ម៉ោង 13.57.59។

[2127] កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨ **ឯកសារ E3/7796**, ERN KH 00250719។

[2128] <u>ស៊ិន ឆែម</u> ៖ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៤៥ បន្ទាប់ពីម៉ោង 11.07.53។

[2129] ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/366.1** ទំព័រ ៥៩ ប្រហែលម៉ោង 13.43.17។

ប្អូនគ្រួសារ[2130]។ ប៉ុន្តែ គេយល់ថា តាមពិតទៅ វាជាចំនួនគ្រួសារជនជាតិវៀតណាម នៅក្នុងឃុំស្វាយយា។ ក្នុងចម្លើយកាលពីមុនរបស់គាត់ សាក្សីបាននិយាយពីគ្រួសារទាំងអស់នេះ នៅក្នុងភូមិបីផ្សេងគ្នា មានភូមិទួលវិហារ ភូមិស៊ីការ ភូមិកៀនតាស៊ីវ ដែលភូមិទាំងអស់នេះស្ថិតនៅក្នុងឃុំស្វាយយា តែមួយ[2131]។ នេះជាអ្វីដែលត្រូវបានអះអាងបញ្ជាក់ នៅពេលគាត់ផ្តល់សក្ខីកម្ម[2132]។

២០៩៧. គាត់បានបញ្ជាក់ថាភូមិទួលវិហារនៅជិតគ្នានឹងភូមិរបស់គាត់ ឆ្លងព្រែកទៅដល់ ហើយថាគាត់ត្រូវចំណាយពេលប្រហែលមួយម៉ោងកន្លះ ដើម្បីទៅដល់ភូមិនោះ។ ទាក់ទងនឹងភូមិស៊ីការ និងភូមិកៀនតាស៊ីវវិញ ភូមិទាំងពីរនេះមានចម្ងាយប្រមាណមួយគីឡូម៉ែត្រពីភូមិរបស់សាក្សី[2133]។ សាក្សីពន្យល់ថា គាត់តែងតែទៅភូមិទាំងពីរនេះជាញឹកញាប់ ដើម្បីដូរអង្ករនឹងរបស់ហូបចុក[2134]។

២០៩៨. សាក្សីបានបញ្ជាក់ថាគាត់មិនដឹងថាតើខ្មែរក្រហមប្រើវិធីបែបណាដើម្បីបែងចែកជនជាតិខ្មែរពីជនជាតិវៀតណាមនោះទេ[2135]។ គាត់ក៏មិនស្គាល់ឈ្មោះគ្រួសារចម្រុះជាតិសាសន៍ខ្មែរ-វៀតណាម ដែលនៅក្នុងភូមិរបស់គាត់ដែរ[2136] លើកលែងតែឈ្មោះខ្មែរពីរនាក់ដែលរៀបការជាមួយស្ត្រីជនជាតិវៀតណាម ក្នុងនោះមាន តាឆោម ដែលប្រពន្ធខ្មែរទីមួយរបស់គាត់ ជាគ្រួសារខាងម្តាយរបស់សាក្សី និងម្នាក់ទៀតគឺតាឈិន[2137]។ គាត់ថ្លែងថា ជនជាតិខ្មែរ និងជនជាតិវៀតណាម ធ្វើការងារជាមួយគ្នា[2138]។

---

[2130] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ៩-១០ ពីម៉ោង 09.29.36 ដល់ម៉ោង 09.34.20។

[2131] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ **ឯកសារ E3/7794**, ERN KH 00249918។

[2132] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ២៣-២៤ ពីម៉ោង 10.52.08 ដល់ម៉ោង 10.55.53 ទំព័រ ៦៨-៦៩ ពីម៉ោង 15.47.55 ដល់ម៉ោង 15.51.25។

[2133] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ៦៩ ពីម៉ោង 15.51.25 ដល់ម៉ោង 15.53.52។

[2134] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ៦៩ បន្ទាប់ពីម៉ោង 15.53.52។

[2135] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ២៤ បន្ទាប់ពីម៉ោង 10.55.53។

[2136] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ២៤ ពីម៉ោង 10.52.08 ដល់ម៉ោង 10.55.53។

[2137] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ៥៨ ពីម៉ោង 15.11.08 ដល់ម៉ោង 15.13.51។ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ **ឯកសារ E3/7794**, ERN KH 00249918។

[2138] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ៥៤ ពីម៉ោង 14.40.23 ដល់ម៉ោង 15.00.36។

## 2.១. ការចាប់ខ្លួនសមាជិកមួយចំនួនក្នុងគ្រួសារទាំងនេះ

២០៩៩. ពាក់ព័ន្ធនឹងជោគវាសនាគ្រួសារចម្រុះជាតិសាសន៍ខ្មែរ-វៀតណាម ទាំងអស់នេះ សាក្សី ស៊ិន ឆែម (ជាប្រពន្ធអតីតកម្មាភិបាល) បានបញ្ជាក់ថា ប្រពន្ធត្រូវបានសម្លាប់ជាមួយនឹងកូនៗ ហើយថាគាត់លែងបានឃើញពួកគេទៀត[2139]។ ប៉ុន្តែ បន្ទាប់មក គាត់និយាយថា គឺត្រូវសម្លាប់ទាំងគ្រួសារតែម្តង ហើយសម្លាប់នៅពេលយប់[2140]។

២១០០. ស៊ិន ឆែម ប្រាប់ឱ្យដឹងថា កម្មាភិបាលដែលបានមកជំនួសប្តីគាត់ គឺជាអ្នកចាប់គ្រួសារទាំងនោះ បើទោះជាគាត់មិនបានចូលរួមប្រជុំណាមួយជាមួយកម្មាភិបាលទាំងនោះក៏ដោយ[2141]។ គាត់បានដឹងតាមរយៈឈ្មោះសារិន អំពីការប្រជុំទាក់ទងនឹងការប្រព្រឹត្តទៅលើប្តីប្រពន្ធចម្រុះជាតិសាសន៍ខ្មែរ-វៀតណាម និងបានដឹងពីការចូលរួមតាមការសន្ទតរបស់សារិន នៅក្នុងការសម្លាប់គ្រួសារទាំងអស់នោះ[2142]។

២១០១. ការពិតគឺថាសាក្សី ស៊ិន ឆែម មិនអាចដឹងពីរឿងរ៉ាវដែលបានកើតឡើង។ នៅពេលនោះ សាក្សីកំពុងធ្វើការ ខ្លួនគាត់ផ្ទាល់ គាត់មិនបានឃើញការចាប់ខ្លួនអ្នកទាំងអស់នោះទេ[2143] គឺគាត់បានដឹងតាមរយៈអ្នកដទៃ[2144]។ លើសពីនេះទៀត ចម្លើយរបស់ ស៊ិន ឆែម មានការប្រែប្រួល នៅក្នុងសវនាការ ទាក់ទងនឹងការណ៍ចង់ដឹងថាតើគាត់បានឮគេនិយាយពីការសម្លាប់មនុស្សទាំងអស់នោះដែរឬអត់។ នៅពេលដំបូង គាត់បានពន្យល់ថា មានគេនិយាយប្រាប់គាត់ថាគ្រួសារទាំងអស់នោះត្រូវ

---

[2139] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ២០-២១ ពីម៉ោង 10.39.17 ដល់ម៉ោង 10.41.56 ទំព័រ ៣០-៣១ ពីម៉ោង 11.15.14 ដល់ម៉ោង 11.17.44។

[2140] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ២១ បន្ទាប់ពីម៉ោង 10.41.56។

[2141] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ២២ ពីម៉ោង 10.44.45

[2142] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ២៣ ពីម៉ោង 10.49.40 ដល់ម៉ោង 10.52.08។

[2143] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ៦៧ ពីម៉ោង 15.43.37 ដល់ម៉ោង 15.45.03 ទំព័រ ៧០ ប្រហែលម៉ោង 15.56.07។

[2144] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ២៣-២៤ ពីម៉ោង 10.52.08 ដល់ម៉ោង 10.55.53 ទំព័រ ៧១-៧២ ពីម៉ោង 15.59.40 ដល់ម៉ោង 16.00.44។

បានសម្លាប់នៅម៉ឺនសាយ[2145]។ ប៉ុន្តែ នៅចុងបញ្ចប់នៃការផ្តល់សក្ខីកម្ម គាត់បាននិយាយថា អ្នកដែលបានឃើញរឿងរ៉ាវទាំងនេះ គ្រាន់តែបានប្រាប់គាត់ថា គ្រួសារចម្រុះជាតិសាសន៍ទាំងនោះ ត្រូវបានចាប់នាំយកទៅ[2146]។

២១០២. ជាមួយគ្នានេះដែរ ចម្លើយសាក្សី ស៊ិន ឆែម មានភាពប្រែប្រួល ទាក់ទងនឹងកាលបរិច្ឆេទ ចាប់តាំងពីគាត់ត្រូវបានសម្ភាសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលពេលនោះគាត់បានលើកឡើងថាការចាប់ខ្លួន កើតឡើងនៅឆ្នាំ ១៩៧៧[2147]។ ក្នុងកំណត់ហេតុស្តាប់ចម្លើយ គាត់និយាយថាការចាប់ខ្លួនកើតមាននៅឆ្នាំ ១៩៧៧ ដើមឆ្នាំ ១៩៧៨[2148] ហើយក្នុងអំឡុងពេលផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ គាត់ថ្លែងថាគ្រួសារចម្រុះជាតិសាសន៍ខ្មែរ-វៀតណាម ត្រូវបានចាប់ខ្លួន ក្រោយប្តីរបស់គាត់ត្រូវបានគេចាប់[2149] ចុងឆ្នាំ ១៩៧៧[2150]។

២១០៣. ម្យ៉ាងវិញទៀត គេត្រូវកត់សម្គាល់ថា ក្នុងអំឡុងពេលសួរដេញដោលដោយមេធាវី KOPPE សាក្សីបានច្រឡំព្រឹត្តិការណ៍មួយចំនួនដែលបានកើតឡើងចំពោះប្រជាជនខ្មែរ និងពុំមែនចំពោះគ្រួសារចម្រុះជាតិសាសន៍ខ្មែរ-វៀតណាម ទាំងនេះនោះទេ[2151]។ នៅពេលសួរទាក់ទងនឹងគ្រួសារចម្រុះជាតិសាសន៍ សាក្សីបានឆ្លើយថាគាត់មិនបានឃើញការសម្លាប់មនុស្សទេ តែគាត់បានឃើញសាកសពមនុស្ស។ អ្នកទាំងនោះត្រូវបានបង្ខំឱ្យរត់នៅពីមុខកង់ ព្រោះពួកគេត្រូវចោទថាជាជនក្បត់ ឬខុសសីលធម៌[2152]។ ក៏ប៉ុន្តែ នៅក្នុងចម្លើយកាលពីមុនរបស់សាក្សី អង្គហេតុប្រហាក់ប្រហែលគ្នា

---

[2145] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ២០-២១ ពីម៉ោង 10.39.17 ដល់ម៉ោង 10.41.56 ទំព័រ ២២ បន្ទាប់ពីម៉ោង 10.47.11 ទំព័រ ៧១ បន្ទាប់ពីម៉ោង 15.57.36។

[2146] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ៧១-៧២ ពីម៉ោង 15.59.40 ដល់ម៉ោង 16.01.34។

[2147] កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៥ **ឯកសារ E3/7526**, ERN KH 00185391។

[2148] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ **ឯកសារ E3/7794**, ERN KH 00249918។

[2149] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ២២ ពីម៉ោង 10.44.45 ដល់ម៉ោង 10.47.11។

[2150] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ១៤-១៥ ពីម៉ោង 10.00.25 ដល់ម៉ោង 10.03.19។

[2151] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ៥៩-៦០ ពីម៉ោង 15.15.30 ដល់ម៉ោង 15.18.01។

[2152] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ៦០ ពីម៉ោង 15.18.01 ដល់ម៉ោង 15.20.52។

គឺនិយាយពីប្រជាជនខ្មែរ[2153]។ នៅចុងបញ្ចប់នៃការផ្តល់សក្ខីកម្ម សាក្សីបានបញ្ជាក់អះអាងប្រាប់មេធាវី GUISSÉ ថាគាត់និយាយពីជនរងគ្រោះជនជាតិខ្មែរ[2154]។

## 3. រឿងរ៉ាវរបស់ អ៊ិន យឿង

២១០៤. តាមសំណើរបស់សហព្រះរាជអាជ្ញា អ៊ិន យឿង ត្រូវបានអង្គជំនុំជម្រះកោះហៅឱ្យមកផ្តល់សក្ខីកម្មទាក់ទងនឹងការប្រព្រឹត្តលើជនជាតិវៀតណាមក្នុងខេត្តស្វាយរៀង ដោយផ្អែកលើកិច្ចសម្ភាសរបស់ប្តីគាត់ ចាន់ គា ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា[2155]។ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើកិច្ចសម្ភាសនេះ ដោយជាដំបូងបានចាត់ទុកសាក្សីថាជា"អ្នកជិតខាង"។ ទើបតែនៅចុងបញ្ចប់នៃកិច្ចសម្ភាសប៉ុណ្ណោះដែលសាក្សីត្រូវបានប្រាប់ឈ្មោះ[2156]។ លើសពីនេះ មនុស្សទីបីបានលេចចេញមកក្នុងកិច្ចសម្ភាស ដោយត្រូវបានកំណត់អត្តសញ្ញាណថាជា"អ្នកជិតខាង"។ បើតាម អ៊ិន យឿង មនុស្សជាច្រើននាក់បានចូលរួមក្នុងកិច្ចសម្ភាសនេះ បន្ថែមពីលើ ចាន់ គា[2157]។ មនុស្សទីបីនេះគឺឈ្មោះ ព្រំ យ៉ាន[2158]។

២១០៥. ក្នុងអំឡុងពេលផ្តល់សក្ខីកម្ម សហព្រះរាជអាជ្ញាបានចោទសួរ អ៊ិន យឿង ទាក់ទងនឹងវត្តមានជនជាតិវៀតណាមនៅក្នុងភូមិ ឃុំរបស់គាត់។ ក៏ប៉ុន្តែ ចម្លើយរបស់គាត់ដែលបានឆ្លើយ មិនស៊ីគ្នានឹងចម្លើយដែលមានក្នុងកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា[2159]។ ទោះបីជាសហព្រះរាជអាជ្ញាបានសាកល្បងច្រើនលើកច្រើនសាក៏ដោយ ក៏ អ៊ិន យឿង បានបញ្ជាក់ថាគាត់នឹកមិនឃើញពី

---

[2153] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ **ឯកសារ E3/7794**, ERN KH 00249917។

[2154] ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ៦៧-៦៨ ពីម៉ោង 15.45.03 ដល់ម៉ោង 15.47.55។

[2155] កិច្ចសម្ភាសន៍ ចាន់ គា មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ **ឯកសារ E3/7525**។

[2156] កិច្ចសម្ភាសន៍ ចាន់ គា មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ **ឯកសារ E3/7525**, ERN FR 087686-87។

[2157] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៥១-៥២ ពីម៉ោង 14.00.18 ដល់ម៉ោង 14.02.02។

[2158] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៦៤ បន្ទាប់ពីម៉ោង 14.43.10។

[2159] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៤៦-៤៧ ពីម៉ោង 13.44.08 ដល់ម៉ោង 13.46.36 ទំព័រ ៥៨-៥៩ ពីម៉ោង 14.20.07 ដល់ម៉ោង 14.25.25។

វត្តមានជនជាតិវៀតណាមក្នុងភូមិកំពង់ត្រាចរបស់គាត់ឡើយ ដូចគ្នានេះដែរសម្រាប់ភូមិដែលនៅជុំវិញ ឬជាទូទៅ នៅក្នុងឃុំកំពង់ត្រាចតែម្តង (ស្រុករមាសហែក)[2160]។

២១០៦. ក្តីមន្ទិលចង់ដឹងថាតើម្នាក់នោះគឺជាសាក្សីដែលគេកំពុងចោទសួរមែនដែរឬអត់ បានកើតមានយ៉ាងប្រាកដ ហើយលោកប្រធានអង្គជំនុំជម្រះបានហាមភាគីមិនឱ្យប្រើកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមួយនេះ ក្នុងការសួរដេញដោលសាក្សីបន្តទៀត[2161]។ ដូច្នេះ ភាគីផ្សេងៗទៀតពុំមានលទ្ធភាពសួរតទល់សាក្សីនឹងចម្លើយមួយនេះបានទេ។ ស្ថានភាពបែបនេះ បង្ហាញឱ្យឃើញយ៉ាងច្បាស់ពីបញ្ហាចោទឡើងលើរបៀបរៀបចំពុំបានត្រឹមត្រូវក្នុងការធ្វើបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ការណ៍ដែលមនុស្សជាច្រើននាក់ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចសម្ភាសដោយមិនបានប្រាប់ឈ្មោះឱ្យបានច្បាស់លាស់ បានចោទជាបញ្ហាត្រង់ថាតើនរណាជាអ្នកឆ្លើយសំណួរឱ្យប្រាកដ នរណាជាអ្នកនឹកឃើញ ហើយនរណាជាអ្នកបានឃើញអ្វីឱ្យប្រាកដ។ គឺភាពជឿជាក់បានលើកិច្ចសម្ភាសទាំងអស់នោះ ដែលចោទជាបញ្ហា។

២១០៧. ត្រលប់មកនិយាយពីសក្ខីកម្មរបស់ អ៊ិន យឿង វិញម្តង។ សាក្សីបានថ្លែងថា នៅឆ្នាំ ១៩៧៥ គាត់រស់នៅក្នុងភូមិកំពង់ត្រាច ឃុំកំពង់ត្រាច ស្រុករមាសហែក[2162]។ ប្រឈមនឹងការពុំមានលទ្ធភាពប្រើប្រាស់កិច្ចសម្ភាសមជ្ឈមណ្ឌលឯកសារកម្ពុជា សហព្រះរាជអាជ្ញាបានសាកល្បងជាលើកចុងក្រោយជាមួយសាក្សី ដើម្បីធ្វើឱ្យគាត់និយាយពីការប្រព្រឹត្តលើជនជាតិវៀតណាម តែពុំបានផល។ សាក្សីនិយាយថាគាត់មិនដឹងអ្វីទេទាក់ទងនឹងរឿងនេះ[2163]។

២១០៨. ដូចគ្នានេះដែរ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសាកល្បងធ្វើឱ្យ អ៊ិន យឿង និយាយពីជនជាតិវៀតណាម ដោយឱ្យគាត់ពិនិត្យកំណត់ហេតុស្តាប់ចម្លើយរបស់ ព្រុំ យ៉ាន ជាមនុស្សទីបីដែលបានចូលរួមក្នុងកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ព្រុំ យ៉ាន រស់នៅក្នុងភូមិតែមួយ

---

[2160] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៤៦-៤៧ ពីម៉ោង 13.40.02 ដល់ម៉ោង 13.46.36 ទំព័រ ៥៧-៥៨ ពីម៉ោង 14.18.13 ដល់ម៉ោង 14.23.20។

[2161] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៦០-៦១ បន្ទាប់ពីម៉ោង 14.29.25។

[2162] ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/383.1** ទំព័រ ៦៩-៧០ ពីម៉ោង 15.59.27 ដល់ម៉ោង 16.01.55។

[2163] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៦១ ប្រហែលម៉ោង 14.31.30។

ជាមួយសាក្សី[2164]។ ក្នុងកំណត់ហេតុស្តាប់ចម្លើយនេះ ព្រំ យ៉ាន រៀបរាប់ថា នៅឆ្នាំ ១៩៧៧ គាត់បានឃើញស្ត្រីកូនកាត់វៀតណាម ដែលមានប្តីឈ្មោះ ទេព និងកូនម្នាក់ ត្រូវបានឃោធាស្រុកចាប់នាំយកទៅដោយបង្ខំ ទៅកាន់មន្ទីរស្រុករមាសហែក[2165]។ ទោះបីជា អ៊ិន យឿង នៅចាំថាបានឮ ព្រំ យ៉ាន រៀបរាប់រឿងនេះក៏ដោយ ក៏គាត់បានអះអាងថាគាត់នៅចាំថាស្ត្រីនោះជាកូនកាត់ចិន ពុំមែនកាត់វៀតណាមទេ[2166]។

២១០៩. ពាក់ព័ន្ធនឹងកូនវិញ អ៊ិន យឿង បានបញ្ជាក់ថា ព្រំ យ៉ាន បាននិយាយពីកូនកាត់វៀតណាម[2167]។ គាត់បានថ្លែងថា តាមរយៈ ព្រំ យ៉ាន ដដែលនេះ គាត់បានដឹងថាម្តាយរបស់កូននេះ ត្រូវបានសម្លាប់នៅព្រៃចក ហើយកូនត្រូវបានគេនាំយកទៅ[2168]។ ក៏ប៉ុន្តែ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ព្រំ យ៉ាន ពុំបាននិយាយពីការសម្លាប់មនុស្សទេ គឺនិយាយតែពីការចាប់ខ្លួន[2169]។

២១១០. ដូច្នេះ តាមរយៈសវនាការ វាស្តែងបង្ហាញឱ្យឃើញថា អ៊ិន យឿង ពុំបានឃើញ និងដឹងអ្វីទាំងអស់ទាក់ទងនឹងស្ត្រីកូនកាត់ម្នាក់នេះ និងកូន។ សក្ខីកម្មរបស់សាក្សីដែលមានខ្លឹមសាររៀបរាប់ពីសម្តីទាំងឡាយដែលត្រូវបានសន្មតថាជាសម្តី ព្រំ យ៉ាន តែសម្តីទាំងនេះបែរជាខុសគ្នាពីចម្លើយរបស់គាត់ (ព្រំ យ៉ាន) នាំឱ្យចោទជាបញ្ហាលើភាពជឿជាក់បាននៃសក្ខីកម្មរបស់ អ៊ិន យឿង។ បន្ថែមពីលើនេះទៀត សក្ខីកម្មមួយនេះបង្ហាញឱ្យឃើញថា ពាក្យនិយាយតគ្នាអាចកែប្រែ ឬបកស្រាយសម្តីដើមបាន។

## 4. <u>រឿងរ៉ាវរបស់ សៀង ចាន់ធី</u>

[2164] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៦២ ពីម៉ោង 14.33.39 ដល់ម៉ោង 14.35.41។

[2165] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ **ឯកសារ E3/7816**, ERN KH 00277273។

[2166] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៦៣-៦៤ ពីម៉ោង 14.38.13 ដល់ម៉ោង 14.40.14 ទំព័រ ៧៣ ពីម៉ោង 15.29.17 ដល់ម៉ោង 15.30.51។

[2167] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៩៨ បន្ទាប់ពីម៉ោង 14.40.14។

[2168] ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៦៣-៦៤ ពីម៉ោង 14.38.13 ដល់ម៉ោង 14.43.10។

[2169] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ **ឯកសារ E3/7816**, ERN KH 00277273។

២១១១. តាមរយៈចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ថី ដែលត្រូវបានស្តាប់ចម្លើយទាក់ទងនឹងទុក្ខសោកវេទនាទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ វាមានភាពពាក់ព័ន្ធដែលត្រូវពិនិត្យលើចម្លើយនានារបស់គាត់ ទាក់ទងនឹងវត្តមានជនជាតិវៀតណាម នៅកន្លែងគាត់ (៤.ក.) និងការប្រព្រឹត្តចំពោះជនជាតិវៀតណាមទាំងអស់នោះ (៤.ខ.)។ លើសពីនេះ គេត្រូវវិភាគលើចម្លើយរបស់គាត់ ទាក់ទងនឹងការចោទប្រកាន់អំពើមនុស្សឃាតលើសមាជិកមួយចំនួនក្នុងគ្រួសាររបស់គាត់ (៤.គ.) និងលើសមាជិកមួយចំនួនក្នុងគ្រួសារជនជាតិវៀតណាមដទៃទៀត ដែលគាត់បានដឹង (៤.ឃ.)។

## 4.ក. វត្តមានជនជាតិវៀតណាម

២១១២. ភាពមិនទាក់ទងគ្នា និងភាពផ្ទុយគ្នា បានលេចចេញឡើងរវាងរឿងរ៉ាវរបស់ សៀង ចាន់ថី នៅក្នុងអំឡុងពេលសវនាការ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងចម្លើយបន្ថែមរបស់គាត់។ ពាក់ព័ន្ធនឹងដើមកំណើតគ្រួសារ សៀង ចាន់ថី បានពន្យល់ប្រាប់ក្នុងសវនាការថា ជីដូនជីតាខាងឪពុកគាត់ គឺជាជនជាតិវៀតណាមសុទ្ធ ហើយថាឪពុកគាត់ជនជាតិវៀតណាម បានរៀបការជាមួយស្ត្រីខ្មែរ បានកូនកាត់ខ្មែរ-វៀតណាម ចំនួនប្រាំបីនាក់[2170]។ ប៉ុន្តែ នៅពេលសួរតទល់នឹងចម្លើយបន្ថែមក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ សៀង ចាន់ថី ពន្យល់ថា៖ “ខ្ញុំមើលដែរឯកសារហ្នឹង គឺគាត់សរសេរទៅវាខុស។ ខុស ដល់ពេលអ៊ីចឹង ពេលដែលខ្ញុំមើលហ្នឹងហួសពេលនឹងកែហើយ ដែលគាត់សរសេរថា ជីតារបស់ខ្ញុំបានវិលមកស្រុកខ្មែរ រៀបការជាមួយប្រពន្ធខ្មែរហ្នឹង មិនមែនទេ”[2171]។

២១១៣. ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា មានតែឪពុកគាត់ម្នាក់ប៉ុណ្ណោះ ដែលចេះនិយាយវៀតណាម តែគាត់ក៏អាចនិយាយខ្មែរបានយ៉ាងល្អដូចគ្នា។ លើសពីនេះ ដោយសារតែឪពុកគាត់មានស្បែកស ធ្វើ

[2170] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១៥-១៥ ពីម៉ោង 09.32.03 ដល់ម៉ោង 09.34.44 ទំព័រ ៣៦ បន្ទាប់ពីម៉ោង 10.43.55។

[2171] សេចក្តីថ្លែងការបន្ថែម ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ **ឯកសារ D409/5/1.2.1**, ERN EN 00621377។

ឱ្យគាត់ដូចជាជនជាតិវៀតណាមបេះបិទ ហើយខ្មែរក្រហមដឹងយ៉ាងច្បាស់ថា គ្រួសារដើមបណ្តឹងរដ្ឋប្បវេណី ជាកូនកាត់វៀតណាម[2172]។

២១១៤. សៀង ចាន់ថី ក៏បាននិយាយផងដែរអំពីវត្តមានគ្រួសារជនជាតិវៀតណាមពីរផ្សេងទៀត នៅក្នុងភូមិឫស្សីព្រៃ ឃុំកំពង់ចំឡង ស្រុកស្វាយជ្រំ ក្នុងនោះមានគ្រួសារស័ក្តិប្អូន ផុន ដែលមានសមាជិកប្រាំមួយនាក់ និងគ្រួសារ សាអុន[2173]។

### 4.៦. ការប្រព្រឹត្តលើជនជាតិវៀតណាម

២១១៥. មុនថ្ងៃ ១៧ មេសា ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមគ្រួសារ រស់នៅក្នុងភូមិចុងព្រែក ឃុំចេក ស្រុកស្វាយរៀង ខេត្តស្វាយរៀង[2174]។ ក្រោយថ្ងៃ ១៧ មេសា ១៩៧៥ អ្នកភូមិគាត់ ត្រូវបានជម្លៀសទៅភូមិឈូកស ឃុំឈើទាល ស្រុកស្វាយជ្រំ អស់ពីរបីថ្ងៃ បន្ទាប់មក ពួកគេត្រូវបញ្ជូនទៅធ្វើការនៅឫស្សីព្រៃ ឃុំចំឡង ស្រុកស្វាយជ្រំ[2175]។

២១១៦. សៀង ចាន់ថី បញ្ជាក់ថា នៅឈូកស ប្រជាជនមូលដ្ឋានហៅពួកអ្នកទាំងនោះថាអ្នក ១៧ មេសា ជានាយទុន សក្តិភូមិ និងកូនកាត់វៀតណាម[2176]។ ក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គាត់បានបញ្ជាក់ថា នៅស្វាយជ្រំ ក្នុងភូមិឈូកស អ្នកទាំងនោះត្រូវបង្អត់បាយ ខុសពីអ្នកភូមិដទៃទៀត ហើយថានៅឫស្សីព្រៃ របបអាហារតិចជាងរបបដែលចែកឱ្យអ្នកភូមិផ្សេងទៀត[2177]។

---

2172 ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១៤-១៦ ពីម៉ោង 09.32.03 ដល់ម៉ោង 09.36.59។

2173 ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១៥-១៦ បន្ទាប់ពីម៉ោង 09.34.44 ទំព័រ ២០ ប្រហែលម៉ោង 09.47.44។ សេចក្តីថ្លែងការបន្ថែម ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ **ឯកសារ D409/5/1.2.1**, ERN EN 00621377។

2174 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **ឯកសារ D22/366**, ERN FR 01206357។

2175 ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/393.1** ទំព័រ ១០០ បន្ទាប់ពីម៉ោង 15.37.21។ ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១៤ បន្ទាប់ពីម៉ោង 09.30.57។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **ឯកសារ D22/366**, ERN FR 01206357-58។

2176 ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/393.1** ទំព័រ ១០០-១០១ ពីម៉ោង 15.37.21 ដល់ម៉ោង 15.38.32។

2177 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **ឯកសារ D22/366**, ERN KH 00492094។

២១១៧. ប៉ុន្តែ នៅក្នុងសវនាការ សៀង ចាន់ថឺ បាននិយាយផ្ទុយពីនេះ៖ "ការហូបចុក បើប្រជាជននៅក្នុងភូមិហ្នឹង គេហូបអី យើងហូបទាំងដែរ។ គេចែកបបរ ចែកបាយប៉ុន្មានអីចឹង គេចែកដូចគ្នា"[2178]។ នៅពេលសួរតទល់នឹងព័ត៌មាននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ សៀង ចាន់ថឺ ពន្យល់ថា៖ "មុនដំបូង គេតឹងតែងណាស់ គេចែកបបរចែកអីឱ្យហូប ស្រូវអង្ករអីគេចែកឱ្យតិចតួចអីចឹងមែន។ ចាស ដល់ពេលចុងក្រោយមក ដូចថាយើងខាងសហករណ៍ គេធ្វើស្រូវបានអីចឹង ខែប្រាំងគេឱ្យយើងហូបឆ្អែត"[2179]។ ដូច្នេះ គេមិនអាចសន្និដ្ឋានបានថាមានរបបអាហារខុសគ្នានោះទេ រវាងគ្រួសារគាត់ និងអ្នកភូមិដទៃទៀត។

២១១៨. ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបញ្ជាក់ថា ក្រោយការវាយប្រហាររបស់វៀតណាមនៅឆ្នាំ ១៩៧៧ អ្នកទាំងនោះត្រូវបានចាត់តាំងឱ្យទៅនៅតាមសហករណ៍ តែពេលយប់ ពួកគេអាចត្រលប់មកដេកនៅក្នុងភូមិវិញបាន។ ឪពុកគាត់ត្រូវបានចាត់ឱ្យទៅដាំបន្លែ តែគាត់មិនអាចត្រលប់មកសម្រាន្តកន្លែងតែមួយជាមួយនឹងគ្រួសារបានទេ[2180]។ ក៏ប៉ុន្តែ ដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយផ្ទុយពីសម្តីខ្លួន នៅក្រោយមកទៀត ដោយគាត់ពន្យល់ថា៖ "ស្រាប់តែខ្ញុំមកវិញ ក៏ខ្ញុំសួរប៉ាខ្ញុំថា ប៉ាៗម៉ែ បងចាន់ថន ទៅណាហើយ? ម្តាយខ្ញុំគាត់ឆ្លើយថា៖ "បងអ្នែង គេយកទៅសែងអីវ៉ាន់ឈ្លបហើយកូន""[2181]។ ដូច្នេះ ឪពុកគាត់ហាក់ដូចជាត្រូវបានគេអនុញ្ញាតឱ្យត្រលប់មកផ្ទះវិញជាមួយគ្រួសារ។

២១១៩. ជាចុងក្រោយ សៀង ចាន់ថឺ បានបញ្ជាក់ថា៖ "គឺកាលនោះមកពីខាងវៀតណាមគេវ៉ៃចូល។ ដល់ពេលអីចឹងទៅ គេចោទប្រកាន់យើងថា យើងចូលដៃចូលជើងយួន ក្បាលយួន ខ្លួនខ្មែរ។ គេច្រើននិយាយភាសាហ្នឹង ភាសាខាងប្រធានសហករណ៍ សហករណ៍អី គេច្រើនជំនុំគ្នាអីចឹង"[2182]។

### 4.គ. <u>ការចោទប្រកាន់ពីបទមនុស្សឃាតលើជនជាតិវៀតណាម</u>

---

[2178] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១៧ ពីម៉ោង 09.38.53 ដល់ម៉ោង 09.39.31។

[2179] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១៨ ពីម៉ោង 09.41.47 ដល់ម៉ោង 09.42.47។

[2180] ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/393.1** ទំព័រ ១០២ ពីម៉ោង 15.41.32 ដល់ម៉ោង 15.44.16។

[2181] ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/393.1** ទំព័រ ១០២ មុនម៉ោង 15.44.16។

[2182] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១៩ បន្ទាប់ពីម៉ោង 09.43.44។

២១២០. សៀង ចាន់ថី បានមកផ្ដល់សក្ខីកម្មទាក់ទងនឹងព្យសនកម្មផ្លូវចិត្តដែលគាត់បានទទួលរង ដោយសារតែការសម្លាប់សមាជិកមួយចំនួនក្នុងគ្រួសាររបស់គាត់ និងដោយសារការសម្លាប់គ្រួសារជនជាតិវៀតណាមដទៃទៀត។ គេត្រូវវិភាគព្រឹត្តិការណ៍ទាំងអស់នេះ ទៅតាមលំដាប់កាលប្បវត្តិ មានន័យថា ត្រូវវិភាគលើការចោទប្រកាន់ពីការសម្លាប់បងប្រុសទាំងពីររបស់គាត់ ចាន់ថន និងចន្ថា (i) វិភាគលើការចោទប្រកាន់ពីការសម្លាប់គ្រួសារវៀតណាមទាំងពីរ (ii) និងបន្ទាប់មកទៀត វិភាគលើការធ្វើអត្តឃាតរបស់ឪពុកគាត់ (iii)។

### i. ការចោទប្រកាន់ពីការសម្លាប់បងប្រុសទាំងពីររបស់គាត់

២១២១. ដើមបណ្ដឹងរដ្ឋប្បវេណីបានឱ្យដឹងថា បងប្រុសទាំងពីររបស់គាត់ ធ្លាប់ធ្វើការឱ្យរបប លន់ នល់ ដោយបងប្រុស ចាន់ថន ធ្វើនគរបាល ហើយចន្ថា ធ្វើទាហាន[2183]។ ទោះជាដើមបណ្ដឹងរដ្ឋប្បវេណីបាននិយាយថាបងប្រុសទាំងពីររស់នៅភ្នំពេញ ក្នុងរបប លន់ នល់ ក៏ដោយ[2184] តែក្រោយមកទៀតគាត់បានពន្យល់ថា៖ "បងប្រុសទី១ ជ្រូក ចាន់ថន ហ្នឹងគាត់ធ្វើប៉ូលីសនៅភ្នំពេញ ដល់ពេលបងចន្ថាហ្នឹងគាត់ធ្វើទាហាននៅស្វាយរៀង"[2185]។

២១២២. យោងតាមពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សៀង ចាន់ថី និងចម្លើយបន្ថែមរបស់គាត់ ចាន់ថន ត្រូវបានជម្លៀសពីភ្នំពេញទៅខេត្តស្វាយរៀង ក្នុងខែមិថុនា ១៩៧៦ ជាមួយនឹងប្រពន្ធរបស់គាត់[2186]។ មានការធ្វើប្រវត្តិរូប ហើយ ចាន់ថន ត្រូវបានបញ្ជូនឱ្យទៅរៀនសូត្រ។ ចំណែកឯ

---

[2183] ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/393.1** ទំព័រ ១០១ បន្ទាប់ពីម៉ោង 15.38.32។ ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ៩ ពីម៉ោង 09.21.04 ដល់ម៉ោង 09.22.01 ទំព័រ ២១ ម៉ោង 09.50.15។

[2184] ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/393.1** ទំព័រ ១០១ បន្ទាប់ពីម៉ោង 15.38.32។ ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ២១ បន្ទាប់ពីម៉ោង 09.48.51។ សេចក្ដីថ្លែងការបន្ថែម ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ **ឯកសារ D409/5/1.2.1**, ERN KH 00621379។

[2185] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ២១ បន្ទាប់ពីម៉ោង 09.48.51។

[2186] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី **ឯកសារ D22/366**, ERN KH 00492093។ សេចក្ដីថ្លែងការបន្ថែម ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ **ឯកសារ D409/5/1.2.1**, ERN KH 00621379។

ចន្លាវិញ គាត់ត្រូវគេបញ្ជូនទៅរៀនសូត្រមួយរយៈពេលខ្លី មុននឹងគេឱ្យគាត់ទៅបាសាក់ ជួបជាមួយប្រពន្ធ[2187]។

២១២៣. ពាក់ព័ន្ធនឹងចាន់ថន ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានពន្យល់ថាគាត់ (ចាន់ថន) មានជំងឺស្ពឹក ដែលធ្វើឱ្យគាត់មិនអាចធ្វើការនៅក្នុងទឹកបាន ហើយដូច្នេះ ខែវស្សា គាត់មិនអាចធ្វើការក្នុងស្រែបានទេ[2188]។ សៀង ចាន់ថី បានបញ្ជាក់ថា៖ "ខ្ញុំនៅផ្ទះបាយ ស្រាប់តែយប់ងងឹតៗហ្នឹង ខ្ញុំកំពុងតែរៀបចាន រៀបឆ្នាំងឱ្យគេ ពួមេកងគេ គេប្រជុំគ្នា គេជំនុំគ្នា គេថាអាចាន់ថន អាហ្នឹងឱ្យតែវស្សាឡើងប្រើវា វាស្ពឹករហូត អាហ្នឹង ទុកក៏មិនចំណេញ ដកចេញក៏មិនខាតដែរ"[2189]។ ក្នុងរដូវប្រាំង ឆ្នាំ ១៩៧៧ សៀង ចាន់ថី បានកត់សម្គាល់ថាបងប្រុស ចាន់ ថន របស់គាត់ បានបាត់ខ្លួន[2190]។ ម្តាយគាត់បាននិយាយប្រាប់ថា ឈ្លបបានហៅបងប្រុសគាត់ទៅសែងអីវ៉ាន់[2191]។

២១២៤. បើតាម សៀង ចាន់ថី មនុស្សបួននាក់បានមកចាប់បងគាត់ នាំយកទៅសម្លាប់។ នៅក្នុងសវនាការគាត់បានបញ្ជាក់ថា៖

> "វាថា អាចាន់ថន មិនទាន់បានវ៉ៃផង វាសន្លប់បាត់ហើយ។ វ៉ៃតែអាដែកសោះ វាសន្លប់បាត់ហើយ។ ខ្ញុំឮផ្ទាល់ៗនឹងត្រចៀករបស់ខ្ញុំ ពីព្រោះផ្ទះខ្ញុំនៅជិតផ្ទះបាយ។ [...] វាយកខោអាវ យកកាំបិតមកសំលៀងហ្នឹងនឹងផ្ទះបាយ ឃើញខោអាវសុទ្ធតែឈាម។ វាសម្លាប់ហើយ ប្រឡាក់ឈាមទៅ វាយកត្រាំចានដែកនៅផ្ទះបាយ ទុកបោក។ ពួកវាសម្លាប់បងខ្ញុំ ហើយពួកវានិយាយគ្នា"[2192]។

២១២៥. ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ថី មិនបានឃើញបងប្រុសខ្លួនត្រូវបានចាប់ខ្លួន ហើយក៏មិនបានឃើញគាត់ស្លាប់ដែរ។ ក្រោយមក គាត់បានបញ្ជាក់ថា អ្នកផ្សេងទៀតដែលបានឃើញ បាន

---

2187 ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ២១ បន្ទាប់ពីម៉ោង 09.48.51, ទំព័រ ២៦ បន្ទាប់ពីម៉ោង 10.01.01។

2188 ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ៩ ពីម៉ោង 09.21.04 ដល់ម៉ោង 09.22.01។

2189 ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ៩-១០ ពីម៉ោង 09.22.01 ដល់ម៉ោង 09.23.08។

2190 ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១០ បន្ទាប់ពីម៉ោង 09.23.51។

2191 ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១១-១២ បន្ទាប់ពីម៉ោង 09.24.45។

2192 ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១២ បន្ទាប់ពីម៉ោង 09.26.46។

និយាយប្រាប់គាត់ពីការសម្លាប់របស់បងប្រុសគាត់[2193]។ យ៉ាងណាមិញ ក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គាត់បានបញ្ជាក់ថា៖ "មួយសប្តាហ៍ក្រោយមកទើបក្រុមគ្រួសារយើងដឹងថាគាត់ស្លាប់ គឺតាអ៊ឹម ប្រាប់ឪពុកម្តាយខ្ញុំផ្ទាល់តែម្តង"[2194]។ តាអ៊ឹមនេះ ជាមនុស្សម្នាក់ក្នុងចំណោមអ្នកផ្សេងៗទៀតដែលបាននាំបងប្រុសដើមបណ្តឹងរដ្ឋប្បវេណីយកទៅ។ ប៉ុន្តែ សៀង ចាន់ថី ពុំបានលើកឡើងពីតាអ៊ឹមនេះទេ នៅក្នុងអំឡុងពេលសវនាការ។

២១២៦. ក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ថី បាននិយាយថា ការចាប់ខ្លួននេះកើតឡើងនៅខែ ធ្នូ ឆ្នាំ ១៩៧៦។ តែក្នុងអំឡុងពេលសវនាការវិញ គាត់បានថ្លែងថា៖ "តាមខ្ញុំចាំ គឺនៅក្នុងខែច្រូត វាចុងឆ្នាំ ១៩៧៧ ហើយក្នុងខែច្រូត គេយកទៅសម្លាប់នៅទួលស្នួន។ ទួលស្នួនហ្នឹងខាងកើតវត្តតាជ័យ"[2195]។

២១២៧. ពាក់ព័ន្ធនឹងបងប្រុសគាត់ ចន្ថា ដើមបណ្តឹងរដ្ឋប្បវេណីបានថ្លែងដូច្នេះថា៖

> "[...] គេចាប់គាត់ពីឃុំបាសាក់ ភូមិៗសាលាបង្រៀន គេហៅបាយ៉ាប នៅក្នុងស្រុកស្វាយជ្រំដែរ។ គេចងគាត់ ដោយចោទគាត់ថា គាត់ហ្នឹង គាត់កាប់ដើមជ្រៃយកមកធ្វើទ្រើងនទោង ហើយគាត់ភ្ជួរ គាត់អត់ចេះភ្ជួរទេ ព្រោះគាត់ធ្លាប់តែរៀន ធ្លាប់តែធ្វើទាហាន ដល់ឱ្យគាត់ទៅភ្ជួរ គាត់អត់ចេះភ្ជួរទេ។ ពេលនុំងគោផ្អើលទៅ មុតជើងគោ ដល់ពេលមុតជើងគោ គេថាគាត់ហ្នឹងប្រឆាំងនឹងអង្គការ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់អង្គការ។ វាក៏ចាប់គាត់ចងៗ ចងហើយបណ្តើរតាមកង់រ៉ឺគាត់រហូត [...]។ ស្រាប់ខ្ញុំក្រឡេកទៅឃើញ គេរ៉ឺភឹងៗ ពីណា គេចងរ៉ឺ ស្រាប់តែក្រឡេកទៅឃើញ បងសោះ។ ឃើញបងគេចងរ៉ឺ ដូចសត្វ ដូចធាតុ។ ប្រជាជនចាស់ កាលណាគេឃើញហ្នឹង គេទាញដងរ៉ែក ទាញផាងត្នោតដាក់បងខ្ញុំភឹងៗ។ គាត់ក្រលេកមើលឃើញហៅខ្ញុំ ឱ្យប្រាប់ម៉ែផង។ [...] បងខ្ញុំបែកឈាមពេញខ្លួនទាំងអស់។ ខ្ញុំមើលអត់ចង់ស្គាល់បងទេ ពូសម្តីបងរត់ទៅមើលនឹងគេ។ រត់ទៅឃើញ បងអញសោះ [...]"[2196]។

---

[2193] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ២៦-២៧ ពីម៉ោង 10.02.17 ដល់ម៉ោង 10.03.31។

[2194] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **ឯកសារ D22/366**, ERN KH 00492094។

[2195] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ២៧ បន្ទាប់ពីម៉ោង 10.03.31។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **ឯកសារ D22/366**, ERN KH 00492094។ សេចក្តីថ្លែងការបន្ថែម ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ **ឯកសារ D409/5/1.2.1**, ERN KH 00621379។

[2196] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ៥-៦ ពីម៉ោង 09.17.37 ដល់ម៉ោង 09.21.14។

២១២៨. រឿងមួយនេះត្រូវបានលើកឡើងម្តងទៀតនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ គាត់បានបញ្ជាក់ថា គាត់ និងគ្រួសារ បានឃើញឈុតឆាកមួយនេះ[2197]។ យោងតាមចម្លើយជាលាយលក្ខណ៍អក្សរមួយនេះ សៀង ចាន់ធី បានជួបបងប្រុសគាត់កំពុងច្រូតស្រូវនៅឫស្សីព្រៃ។ គាត់បានបន្ថែមថា៖ "ខ្ញុំបានត្រឹមតែសួរសុខទុក្ខគាត់តែប៉ុណ្ណោះ ពួកវាក៏ឱ្យបងប្រុសខ្ញុំទៅច្រូត កន្លែងផ្សេងទៀតទៅ។ ប្រហែលជាមួយសប្តាហ៍ក្រោយមក មានឈ្មោះ (មិនចាំទេ) មកប្រាប់ខ្ញុំថា បងប្រុសខ្ញុំបានស្លាប់ហើយ គឺស្លាប់នៅខែច្រូត ឆ្នាំ ១៩៧៧ ដោយពួកវា ឱ្យជីករណ្តៅកប់ខ្លួនឯងនៅក្នុងភូមិតាជៃ [...]"[2198]។

២១២៩. ដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា បងប្រុសគាត់ទាំងពីរនាក់ ត្រូវបាននាំយកទៅ ដោយមូលហេតុទាក់ទងនឹងសកម្មភាពពួកគាត់ពីមុន ក្នុងរបប លន់ នល់ និងដោយសារពួកគាត់មានកំហុស។ សៀង ចាន់ធី ថ្លែងថា៖ "ចាស គឺទាក់ទង ព្រោះអីវាដឹងថាបងប្រុសខ្ញុំធ្វើប៉ូលីសហើយ ហើយវាដឹងថាបងខ្ញុំធ្វើទាហាន ទាក់ទង ព្រោះកំហុសកាលណាមានបន្តិច គឺវាផ្តួចចូលគ្នាតែម្តងសម័យហ្នឹង ព្រោះអីអ្នកដែលគេយកទៅសម្លាប់ជាមួយបងខ្ញុំ បងចាន់ថនហ្នឹង គាត់សុទ្ធតែទាហានទាំងអស់ហ្នឹង"[2199]។ ដូច្នេះ ដើមកំណើតពួកគេជាជនជាតិវៀតណាម ពុំជាប់ពាក់ព័ន្ធនោះទេ។

### ii. ការចោទប្រកាន់ពីបទមនុស្សឃាតលើសមាជិកក្រុមគ្រួសារវៀតណាមពីរផ្សេងទៀត

២១៣០. សៀង ចាន់ធី បានឱ្យដឹងថា ពីរបីថ្ងៃក្រោយការបាត់ខ្លួនរបស់បងប្រុសទីពីររបស់គាត់ គ្រួសារជនជាតិវៀតណាមទាំងពីរ ត្រូវបានគេនាំយកទៅ[2200]។ គ្រួសារថុន មានគ្នាប្រាំមួយនាក់ ហើយគ្រួសារទីពីរ មានសមាជិកបីនាក់[2201]។ វាជាការសំខាន់ដែលត្រូវកត់សម្គាល់ថា ក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី ពុំមាននិយាយអ្វីសោះពីគ្រួសារវៀតណាមទាំងពីរនេះ។ ផ្ទុយទៅវិញ ព័ត៌មានមួយនេះ មាននៅក្នុងចម្លើយបន្ថែមរបស់គាត់ ដែលមានខ្លឹមសារដូច្នេះថា៖

[2197] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **ឯកសារ D22/366**, ERN KH 00492094។

[2198] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី **ឯកសារ D22/366**, ERN KH 00492094។

[2199] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ២៨ បន្ទាប់ពីម៉ោង 10.05.15។

[2200] ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/393.1** ទំព័រ ៧៣ បន្ទាប់ពីម៉ោង 15.42.26។

[2201] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១៣ បន្ទាប់ពីម៉ោង 09.47.36។

"នៅចុងឆ្នាំ ១៩៧៧ អ្នកជិតខាងទាំងពីរគ្រួសារនោះ ត្រូវចាប់ខ្លួន និងសម្លាប់ ដោយសារពួកគេមានឈាមជ័រជាជនជាតិវៀតណាម (កាត់ជនជាតិវៀតណាម)។ ឪពុកខ្ញុំបានឃើញដោយផ្ទាល់ភ្នែក ពួកខ្មែរក្រហមបានចាប់យកកូនស្រីម្នាក់ពីក្រុមគ្រួសារមួយក្នុងចំណោមនោះ ទៅរំលោភ។ ឪពុកខ្ញុំបានប្រាប់ទៅម្ដាយខ្ញុំ និងខ្ញុំអំពីហេតុការណ៍នេះ នាយប់នោះ។ សរុបទៅ ខ្មែរក្រហមបានស្លាប់មនុស្សអស់ ៩ នាក់ ពីពីរក្រុមគ្រួសារនោះ"[2202]។

២១៣១. ក្នុងអំឡុងពេលសវនាការ ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា កូនស្រីជនជាតិវៀតណាមទាំងពីរនាក់ ធ្វើការក្នុងកងតែមួយជាមួយគ្នា ហើយ សៀង ចាន់ថី គ្រាន់តែកត់សម្គាល់ឃើញថាអ្នកទាំងពីរនាក់នោះបាត់ខ្លួនពីកន្លែងធ្វើការ។ អ្នកធ្វើការបាននិយាយប្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីថា នារីទាំងពីរនាក់នោះត្រូវបានគេនាំទៅសម្លាប់[2203]។ បន្ទាប់មក គឺឪពុកដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាអ្នកប្រាប់គាត់ថា សមាជិកគ្រួសារ ប៊ុនថុន ត្រូវបាននាំទៅសម្លាប់[2204]។ ក៏ប៉ុន្តែ ក្រោយមកបន្តិចគាត់បាននិយាយថា ឪពុកគាត់មិនស្គាល់គ្រួសារ ថុន ទេ[2205]។ ចំណែកឯដើមបណ្ដឹងរដ្ឋប្បវេណីវិញគាត់បញ្ជាក់ថាគាត់ស្គាល់តែប្រពន្ធ ថុន ម្នាក់គត់[2206]។

២១៣២. ពាក់ព័ន្ធនឹងកូនស្រីទីពីរ សៀង ចាន់ថី បានបញ្ជាក់ថា៖ "ហើយប្រពន្ធគាត់ ប្រហែលជាមួយអាទិត្យ ឬ ១០ ថ្ងៃ ខ្ញុំអត់ចាំទេណ៎ា គ្រាន់តែថាគេលួចខ្សឹបប្រាប់គ្នាថា "ហ៊ឺ! ប្រពន្ធ សាអុន គេយកទៅទៀតហើយ""[2207]។ គ្រួសារ សាអុន ត្រូវបាននាំយកទៅដំណាលគ្នានឹងបងប្រុសដើមបណ្ដឹងរដ្ឋប្បវេណី ចាន់ថន[2208]។

២១៣៣. មូលហេតុដែលរឿងរ៉ាវរៀបរាប់ដោយដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ថី ទាក់ទងនឹងជោគវាសនាគ្រួសារទាំងពីរនេះ គ្មានភាពច្បាស់លាស់ គឺព្រោះតែគាត់បានអះអាងនៅក្នុងសវនាការថា៖

---

[2202] សេចក្ដីថ្លែងការបន្ថែម ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ **ឯកសារ D409/5/1.2.1**, ERN KH 00621379។

[2203] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ៤ បន្ទាប់ពីម៉ោង 09.13.45។

[2204] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ៤ បន្ទាប់ពីម៉ោង 09.13.45។

[2205] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១២ បន្ទាប់ពីម៉ោង 09.45.00។

[2206] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ២៣ មុនម៉ោង 10.38.50។

[2207] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១២ បន្ទាប់ពីម៉ោង 09.45.00។

[2208] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ២៣ បន្ទាប់ពីម៉ោង 10.35.54។

"ខ្ញុំគ្រាន់តែឮអ្នកភូមិគេខ្សឹបប្រាប់គ្នាថា កូន និងប្រពន្ធ គេយកវ៉ៃចោលហើយ គេលួចខ្សឹបប្រាប់គ្នា អ៊ីចឹង មិនបាននិយាយកោកកាក អ៊ូ! គ្រួសារនេះគេយកទៅវ៉ៃចោលអី មិនបានទេ ខ្សឹបប្រាប់គ្នា តៗ គ្នាទៅ ក្នុងភូមិ"[2209]។ ជាមួយគ្នានេះដែរ គាត់បានបញ្ជាក់ថា៖ "ចាស ព្រោះអីនៅក្នុងភូមិ កាលណា មានគេយកអ្នកទៅសម្លាប់អ៊ីចឹង គេខ្សឹបប្រាប់គ្នាថាគ្រួសារហ្នឹង គេយកទៅហើយ គេខ្សឹបប្រាប់គ្នា អ៊ីចឹង គេមិនហ៊ាននិយាយឮទេ ខ្សឹបៗប្រាប់គ្នាតៗគ្នា"[2210]។

### iii. ការធ្វើអត្តឃាតរបស់ឪពុកដើមបណ្តឹងរដ្ឋប្បវេណី

២១៣៤. ក្រោយពីកើតមានព្រឹត្តិការណ៍ទាំងអស់នេះ សៀង ចាន់ថី បានពន្យល់ថាគាត់ភ័យតក់ស្លុត និង បារម្ភពីជីវិតខ្លួនឯង ហើយឪពុកគាត់ក៏ដូចគ្នា។ មូលហេតុនេះហើយបានជាឪពុកគាត់សម្រេចចិត្ត ធ្វើអត្តឃាត[2211] ដូចដែលអ្វីដែលគេបានប្រាប់គាត់[2212]។

## 5. ចម្លើយផ្សេងទៀត

២១៣៥. បន្ថែមលើចម្លើយមុនៗរបស់សាក្សី ដីកាដំណោះស្រាយបានយោងទៅលើកំណត់ហេតុស្តាប់ចម្លើយ មួយចំនួន ដែលលើកឡើងអំពីវត្តមានជនជាតិវៀតណាម នៅខេត្តស្វាយរៀង និងត្រូវបានចាប់នាំ យកទៅបាត់[2213]។ កំណត់ហេតុស្តាប់ចម្លើយ ព្រំ យ៉ាន់ ត្រូវបានបង្ហាញជូនសាក្សី អ៊ិន យឿង ដែល

---

[2209] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ២៣ បន្ទាប់ពីម៉ោង 10.38.50។

[2210] ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១៤ បន្ទាប់ពីម៉ោង 09.50.32។

[2211] ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/393.1** ទំព័រ ១០៣ បន្ទាប់ពីម៉ោង 15.42.26។ ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ១២ បន្ទាប់ពីម៉ោង 09.45.00។

[2212] ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/393.1** ទំព័រ ៧៣ បន្ទាប់ពីម៉ោង 15.46.07។

[2213] ដីកាដំណោះស្រាយ កថាខណ្ឌ ៧៩៧ កំណត់សម្គាល់ចុងឯកសារ ៣៣៩៦ ដែលយោងទៅកំណត់ហេតុស្តាប់ចម្លើយ ខឹម សាម៉ុន ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៨ **ឯកសារ E3/7797** ដែលយោងទៅកំណត់ហេតុស្តាប់ចម្លើយ ចាន់ រឿន ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ **ឯកសារ E3/7815** ហើយដែលយោងទៅកិច្ចសម្ភាសន៍ ប៉ូ វ៉ាន់ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ **ឯកសារ E3/7498**។

មិនត្រឹមតែមិនអាចបញ្ជាក់អះអាងអំពីខ្លឹមសារប៉ុណ្ណោះទេ ថែមទាំងបានផ្ដល់ចម្លើយផ្ទុយគ្នាអំពីដើមកំណើតរបស់ស្ត្រីកូនកាត់ទៀតផង[2214]។

២១៣៦. កំណត់ហេតុស្ដាប់ចម្លើយ ប៊ូ វ៉ាន់, ខឹម សាម៉ុន, និង ចាន់ រឿន មិនត្រូវបានបង្ហាញជូនសាក្សីណាមួយដែលបានមកផ្ដល់សក្ខីកម្មនៅក្នុងសវនាការនោះទេ។ បុគ្គលទាំងនេះរៀបរាប់អំពីហេតុការណ៍នៅតាមឃុំ-ស្រុកផ្សេងៗ ពាក់ព័ន្ធនឹងជនជាតិវៀតណាមផ្សេងទៀត។

២១៣៧. ក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ប៊ូ វ៉ាន់ និយាយអំពីប្រពន្ធជនជាតិវៀតណាមរបស់ ឡេង និង ឆង ដែលត្រូវបាននាំយកទៅជាមួយកូនៗ។ ប៊ូ វ៉ាន់ មិនដឹងថាគេនាំអ្នកទាំងនេះទៅណាទេ ពីព្រោះគាត់មិនមានវត្តមាននៅថ្ងៃកើតហេតុនោះ។ គាត់មិនចាំឆ្នាំណានោះទេ គាត់គិតថាប្រហែលជាក្នុងឆ្នាំ ១៩៧៦ ឬក្នុងឆ្នាំ ១៩៧៧។ បើតាម ប៊ូ វ៉ាន់ អ្នកជាប់ "ខ្សែយួន" ត្រូវបានកម្ទេចចោល[2215]។

២១៣៨. ក្នុងចម្លើយឆ្លើយជូនអ្នកស៊ើបអង្កេត សាក្សី ខឹម សាម៉ុន បាននិយាយថា ក្រោយមកទៀត ជនជាតិវៀតណាមណា ដែលមិនព្រមទៅស្រុកវិញ ត្រូវគេចាប់យកទៅសម្លាប់។ គាត់បញ្ជាក់ថា ជនជាតិវៀតណាមទាំងនេះភាគច្រើននៅម្ដុំផ្សារចក ក្នុងឃុំជាមួយគាត់ដែរ ប៉ុន្តែ គាត់មិនចាំឈ្មោះ[2216]។ ក្រៅពីតម្លៃជាភ័ស្តុតាងតិចតួចនៃចម្លើយជាលាយលក្ខណ៍អក្សរនេះ គ្មានអ្វីមួយអាចឱ្យសន្និដ្ឋានថា ខឹម សាម៉ុន បានឃើញការសម្លាប់ និងអាចឱ្យកំណត់ប្រភពនៃព័ត៌មានរបស់គាត់នោះទេ។

២១៣៩. ចាន់ រឿន បានឆ្លើយជូនអ្នកស៊ើបអង្កេតថា នៅភូមិតង្កៀបក្ដាម ឃុំត្រពាំងស្ដៅ ស្រុករមាសហែក គាត់បានឃើញស្ត្រីកូនកាត់វៀតណាមម្នាក់ និងកូនស្រី អាយុ ៦ ឆ្នាំ ត្រូវបានមេឃុំចាប់យកទៅបាត់។ គាត់ឮតាម "អ្នកភូមិ" ថា ម្ដាយ និងកូននេះត្រូវបានយកទៅសម្លាប់នៅព្រៃចក។ ការចាប់

---

[2214]សូមមើលខាងលើ កថាខណ្ឌ ២១០៨-២១១០។

[2215]កិច្ចសម្ភាសន៍ ប៊ូ វ៉ាន់ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ **ឯកសារ E3/7498**, ERN KH 00089577។

[2216]កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨**ឯកសារ E3/5260**, ERN KH 00250705។

ខ្លួននេះកើតឡើងប្រហែល ៣ ខែ មុនពេលជម្លៀសប្រជាជនទៅខេត្តពោធិ៍សាត់[2217]។ គ្មានភស្តុតាងជាក់លាក់ណាមួយអាចឱ្យកំណត់ប្រភពដើមនៃព័ត៌មានអំពីការសម្លាប់នេះ ឬកាលៈទេសៈនៃការសម្លាប់នេះទេ។

## ខ. ទ្រឹស្តីខ្សែស្រឡាយខាងម្តាយ

២១៤០. ដូចបានឃើញពីខាងលើ នៅកថាខណ្ឌ ៨០៧ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានលើកឡើងអំពី "ទ្រឹស្តីខ្សែស្រឡាយខាងម្តាយ"[2218]។ ចំពោះការអនុវត្តន៍នេះនៅខេត្តស្វាយរៀង ដីកាដំណោះស្រាយបានយោងទៅលើកំណត់ហេតុស្តាប់ចម្លើយ ចាន់ រឿន, ព្រំ យ៉ាន់, ប៊ូ វ៉ាន់ និង ចាន់ គា[2219] និងចម្លើយពីមុនៗរបស់ ស៊ិន ឆែម[2220]។

២១៤១. ក្នុងចម្លើយឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ស៊ិន ឆែម បានពន្យល់ជាអាទិ៍ថា កូនរបស់ម្តាយជាជនជាតិវៀតណាមត្រូវគេយកទៅ ពីព្រោះកូនបៅដោះម្តាយ ហើយគាត់បានរក្សាចម្លើយនេះដដែលនៅក្នុងសវនាការ។ ផ្ទុយទៅវិញ ពេលមកបង្ហាញខ្លួន ស៊ិន ឆែម បានបញ្ជាក់ថា គាត់ទទួលបានព័ត៌មាននេះពីអ្នកចូលរួមប្រជុំ[2221]។ ដូច្នេះ នេះគ្រាន់តែជាពាក្យចចាមអារ៉ាមប៉ុណ្ណោះ។

---

[2217]កំណត់ហេតុស្តាប់ចម្លើយ ចាន់ រឿន ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ **ឯកសារ E3/7815**, ERN KH 00277259-60។

[2218]សូមមើលខាងលើ កថាខណ្ឌ ២០៦៧។

[2219]កំណត់ហេតុស្តាប់ចម្លើយ ចាន់ រឿន ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ **ឯកសារ E3/7815**។ កំណត់ហេតុស្តាប់ចម្លើយ ព្រំ យ៉ាន ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ **ឯកសារ E3/7816**។ កិច្ចសម្ភាសន៍ ប៊ូ វ៉ាន់ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ **ឯកសារ E3/7498**។ កិច្ចសម្ភាសន៍ ចាន់ គា មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ **ឯកសារ E3/7525**។

[2220]កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ **ឯកសារ E3/7794**។ កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៥ **ឯកសារ E3/7526**។

[2221]ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/367.1** ទំព័រ ២២-២៣ ពីម៉ោង 10.47.11 ដល់ម៉ោង 10.49.40។

២១៤២. ក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រំ យ៉ាន់ គាត់គ្រាន់តែនិយាយថា ស្ត្រីកូនកាត់វៀតណាមម្នាក់ និងកូន ត្រូវគេនាំយកទៅបាត់។ ដូចបានឃើញពីខាងលើ ពេលមកបង្ហាញខ្លួន អ៊ិន យឿង បាន ឆ្លើយថាជាស្ត្រីកូនកាត់ចិនទៅវិញ[2222]។

២១៤៣. នៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា សាក្សី ប៊ូ វ៉ាន់ បាននិយាយអំពីស្ត្រីជនជាតិ វៀតណាមយកប្តីខ្មែរ ដែលត្រូវគេនាំយកទៅជាមួយកូនៗ[2223]។

២១៤៤. សាក្សី ចាន់ រឿន បានប្រាប់អ្នកស៊ើបអង្កេតថា ស្ត្រីកូនកាត់វៀតណាមម្នាក់ និងកូនស្រី ត្រូវគេនាំ យកទៅបាត់[2224]។

២១៤៥. ចំណែកឯក្នុងកិច្ចសម្ភាសន៍របស់ ចាន់ គា ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា អ្នកដែលត្រូវបាន កំណត់អត្តសញ្ញាណថាជា “អ្នកជិតខាង” ជាអ្នកឆ្លើយទៅនឹងសំណួរអំពីជនជាតិវៀតណាម[2225]។ ក៏ប៉ុន្តែ ពេលមកបង្ហាញខ្លួន អ៊ិន យឿង មិនបានបញ្ជាក់អះអាងអំពីខ្លឹមសារនៃកិច្ចសម្ភាសន៍នេះទេ ពាក់ព័ន្ធនឹងជនជាតិវៀតណាម[2226]។

២១៤៦. ទោះជាយ៉ាងនេះក្តី កំណត់ហេតុស្តាប់ចម្លើយ ឬសក្ខីកម្មផ្សេងទៀត មិនបានគាំទ្រដល់ចម្លើយរបស់ ស៊ិន ឆែម ដែលគ្រាន់តែឮគេថាកូនរបស់ម្តាយជាជនជាតិវៀតណាមត្រូវគេយកទៅផងដែរ ពីព្រោះ ថាកូនបៅដោះម្តាយ និងពីព្រោះថានេះជាទ្រឹស្តីរបស់បក្សកុម្មុយនីស្តកម្ពុជា នោះឡើយ។

## ផ្នែកទី ៤. ការកំណត់ប្រភេទបទល្មើស

---

[2222]សូមមើលខាងលើ កថាខណ្ឌ ២១០៨-២១១០។

[2223]កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ **ឯកសារ E3/7498**, ERN KH 00089577។

[2224]កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ **ឯកសារ E3/7815**, ERN KH 00277258។

[2225]កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ **ឯកសារ E3/7525**, ERN FR 00903084-87 ។

[2226]សូមមើលខាងលើ កថាខណ្ឌ ២១០៥។

២១៤៧. ខុសពីសហចៅក្រមស៊ើបអង្កេត ដែលបានចាប់ផ្ដើមកំណត់ប្រភេទបទល្មើសនៃអង្គហេតុ តាមរយៈអំពើប្រល័យពូជសាសន៍[2227] យើងត្រូវតែកំណត់ថា តើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់ទៅលើលោក ខៀវ សំផន មានធាតុផ្សំគ្រប់គ្រាន់ដែរឬទេ។ ជាការពិត ដើម្បីកំណត់ថា តើពិតជាមានការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាត នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ដែរឬទេ ដំបូងបង្អស់ យើងត្រូវរកឱ្យឃើញថាពិតជាមានការប្រព្រឹត្តិអំពើមនុស្សឃាតប្រាកដមែន។

## ១. អំពើមនុស្សឃាត (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)

### ក. និយមន័យ

២១៤៨. ធាតុផ្សំសត្យានុម័តិនៃអំពើមនុស្សឃាតរួមមានអំពើសកម្ម ឬអកម្មរបស់ជនជាប់ចោទ ឬរបស់ជនណាម្នាក់ ឬច្រើនម្នាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើសកម្ម ឬអកម្ម ដែលបណ្ដាលឱ្យជនរងគ្រោះស្លាប់[2228]។ ចំពោះធាតុផ្សំអត្តនោម័តិ ចារីត្រូវមានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្ស[2229]។

## ខ. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ

២១៤៩. យោងតាមភ័ស្តុតាងដែលបានបង្ហាញ ច្បាស់ណាស់ថា យើងស្ថិតនៅឆ្ងាយមែនទែនពីអ្វីដែលសហចៅក្រមស៊ើបអង្កេត បានហៅថាជា "ការសម្លាប់រង្គាលលើជនស៊ីវិលវៀតណាម"[2230]។ ជាក់ស្ដែង ភ័ស្តុតាងបានបង្ហាញអំពីវត្តមានជនជាតិវៀតណាមតិចតួចបំផុត នៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង ក្នុងឆ្នាំ ១៩៧៥។ ទោះបីជាក្រុមមេធាវីការពារក្ដីមិនបានជំទាស់ថា ជនជាតិវៀតណាម

---

[2227] ដីកាដំណោះស្រាយ, ជំពូក ៣. ការកំណត់ប្រភេទបទល្មើស II. បទល្មើសប្រល័យពូជសាសន៍ III. គ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

[2228] សាលក្រម ០០២/០១ កថាខណ្ឌ ៤១២។

[2229] សូមមើលខាងលើ កថាខណ្ឌ ៣៩៤-៤២៩។

[2230] ដីកាដំណោះស្រាយ កថាខណ្ឌ ៧៩៧-៧៩៨, ៨០១។

ខ្លះបានបាត់ខ្លួនក៏ដោយ ក៏គេមិនអាចបង្ហាញឱ្យហួសពីវិមតិសង្ស័យនូវអំពើមនុស្សឃាតលើករណីភាគច្រើន ដែលត្រូវបានលាតត្រដាង នៅក្នុងភស្តុតាង នោះឡើយ។

២១៥០. គួររំឭកអំពីដំណើរការនៃការបង្ហាញអង្គហេតុឱ្យហួសពីវិមតិសង្ស័យ ដើម្បីឈានដល់ការកំណត់ប្រភេទបទល្មើសនៃអំពើមនុស្សឃាត (១) មុននឹងផ្តោតលើសេចក្តីសន្និដ្ឋានដែលត្រូវប្រកាន់យកយោងតាមភស្តុតាងដែលបានវិភាគ (២)។

## 1. ការបង្ហាញនូវអំពើមនុស្សឃាតឱ្យហួសពីវិមតិសង្ស័យ

២១៥១. ដូចបានរៀបរាប់លម្អិតពីខាងលើ ដំណើរការបង្ហាញអង្គហេតុឱ្យហួសពីវិមតិសង្ស័យត្រូវបានរំឭកដោយអង្គជំនុំជម្រះតុលាការកំពូល និងយុត្តិសាស្ត្រអន្តរជាតិ[2231]។

២១៥២. ជាពិសេស ពាក់ព័ន្ធនឹងអំពើមនុស្សឃាត អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា "ដើម្បីផ្តល់មូលដ្ឋានគាំទ្រដល់ការយល់ឃើញទូទៅហួសពីវិមតិសង្ស័យចំពោះការសម្លាប់នោះ ហេតុការណ៍ជាក់លាក់នៃការសម្លាប់មនុស្សត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យ ដោយពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហាថាតើមានការសម្រេចដាក់ពិរុទ្ធភាពពីបទមនុស្សឃាតចំពោះហេតុការណ៍នីមួយៗដែរ ឬយ៉ាងណានោះទេ"[2232]។

២១៥៣. នៅពេលអង្គជំនុំជម្រះតុលាការកំពូលធ្វើការវិភាគទៅលើករណីជាក់លាក់នៃអំពើមនុស្សឃាត ក្នុងសាលដីកាលើសំណុំរឿង ០០២/០១ ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា ពុំមានវិធានទូទៅណាមួយចែងថា ប្រសិនបើពុំមានភស្តុតាងច្រើនគាំទ្រការយល់ឃើញទេនោះ ការយល់ឃើញឱ្យហួសពីវិមតិសង្ស័យមួយពុំអាចត្រូវបានធ្វើឡើង ដោយសមហេតុផលបានឡើយ[2233]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចដាក់ពិរុទ្ធភាព ដោយផ្អែកលើមូលដ្ឋានសាក្សីតែម្នាក់

---

[2231] សូមមើលខាងលើ កថាខណ្ឌ ៦៤០-៦៤៩។

[2232] សាលដីកា ០០២/០១ កថាខណ្ឌ ៤២០។

[2233] សាលដីកា ០០២/០១ កថាខណ្ឌ ៤២៤។

បាន ប៉ុន្តែ ទោះជាយ៉ាងណាក្តី ភ័ស្តុតាងនោះត្រូវតែវាយតម្លៃ ដោយមានការប្រុងប្រយ័ត្នសមស្រប ហើយត្រូវតែផ្តល់សំអាងហេតុគ្រប់គ្រាន់ចំពោះសេចក្តីសន្និដ្ឋានរបស់ខ្លួន[2234]។

២១៥៤. បន្ទាប់មកទៀត អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សេចក្តីចង្អុលបង្ហាញមួយចំនួន។ ឧទាហរណ៍ រឿងរ៉ាវមួយ នៅក្នុងសវនាការ ដែលកើតចេញពីការឮតៗគ្នា គ្មានប្រភពច្បាស់លាស់ មិនគ្រប់គ្រាន់ឱ្យទាញសេចក្តីសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យនោះឡើយ។ ប៉ុន្តែ រឿងរ៉ាវនេះអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ប្រៀបធៀបជាមួយរឿងរ៉ាវរបស់បុគ្គលម្នាក់ទៀត ប្រសិនបើការសម្លាប់បានកើតឡើង នៅក្នុងកាលៈទេសៈប្រហាក់ប្រហែលគ្នា[2235]។

២១៥៥. ម្យ៉ាងវិញទៀត ភ័ស្តុតាងក្រៅតុលាការមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត ហើយទោះបីជាមានច្រើនយ៉ាងណាក៏ដោយ ក៏ភ័ស្តុតាងទាំងនេះពុំអាចយកមកធ្វើជាមូលដ្ឋានគាំទ្រដល់ការយល់ឃើញឱ្យហួសពីវិមតិសង្ស័យឡើយ[2236]។ ជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទោះបីជាកំណត់ហេតុស្តាប់ចម្លើយចំនួន ៣ មានភ័ស្តុតាងជាក់លាក់ និងផ្ទាល់ក៏ដោយ ក៏កំណត់ហេតុទាំងនេះពុំអាចបញ្ជាក់អំពីអំពើមនុស្សឃាតបានឡើយ ដោយសារតែម្ចាស់ចម្លើយពុំបានមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ[2237]។

២១៥៦. ដូចគ្នាផងដែរចំពោះសក្ខីកម្មតាមរយៈពាក្យចចាមអារ៉ាម និងសក្ខីកម្មក្រៅតុលាការ[2238]។ ចម្លើយក្រៅតុលាការ ដែលមានប្រភពព័ត៌មានអនាមិក រួមជាមួយពាក្យចចាមអារ៉ាមតគ្នាពីរដង ពុំអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការយល់ឃើញអំពីការសម្លាប់បានឡើយ[2239]។ ករណីនៃចម្លើយដែលផ្អែកលើពាក្យចចាមអារ៉ាម និងផ្តល់ព័ត៌មានតិចតួចអំពីប្រភព មិនអាចយកធ្វើជាមូលដ្ឋានសម្រាប់បញ្ជាក់បន្ថែមបានឡើយ[2240]។ ផ្ទុយទៅវិញ ករណីនៃចម្លើយខ្លីៗអំពីការសម្លាប់ ដែលអាច

---

[2234] សាលដីកា ០០២/០១ កថាខណ្ឌ ៤៩៦។

[2235] សាលដីកា ០០២/០១ កថាខណ្ឌ ៤២៨។

[2236] សាលដីកា ០០២/០១ កថាខណ្ឌ ៤៣០-៤៣១។

[2237] សាលដីកា ០០២/០១ កថាខណ្ឌ ៤៧១។

[2238] សាលដីកា ០០២/០១ កថាខណ្ឌ ៤៤១។

[2239] សាលដីកា ០០២/០១ កថាខណ្ឌ ៤៤២។

[2240] សាលដីកា ០០២/០១ កថាខណ្ឌ ៤៣៤។

កើតចេញពីពាក្យចចាមអារ៉ាម ទោះបីជាមិនអាចជាភ័ស្តុតាងអំពីសម្លាប់ក៏ដោយ អាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការបញ្ជាក់បន្ថែមជាទូទៅបាន[2241]។

២១៥៧. ចំពោះចំនួននៃការសម្លាប់ ទោះបីជាភ័ស្តុតាងជាលាយលក្ខណ៍អក្សរបង្ហាញអំពីភវនីយភាពថា ការសម្លាប់មានចំនួនលើសពីការបង្ហាញទៅទៀតក៏ដោយ ក៏វាមិនសមហេតុផលទេ ក្នុងការសន្និដ្ឋានសរុបលឿនពេកអំពីចំនួនជនរងគ្រោះ និងចរិតលក្ខណៈនៃការសម្លាប់ជាប្រព័ន្ធ ឬក្នុងទ្រង់ទ្រាយធំ[2242]។

## 2. សេចក្តីសន្និដ្ឋានស្តីពីអំពើមនុស្សឃាតលើជនជាតិវៀតណាម

២១៥៨. ឥឡូវនេះ យើងគួរទាញសេចក្តីសន្និដ្ឋានតាមផ្លូវច្បាប់ ចេញពីការវិភាគភ័ស្តុតាង មួយករណីម្តងៗ ពីព្រោះការសន្និដ្ឋានទូទៅស្តីពីអំពើមនុស្សឃាតលើជនជាតិវៀតណាម មិនអាចធ្វើឡើងបានឡើយ ប្រសិនបើពុំមានករណីជាក់លាក់នៃអំពើមនុស្សឃាតត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យនោះ។

### 2.ក. អំពើមនុស្សឃាតនៅខេត្តព្រៃវែង

#### i. អន្លង់ទ្រា

២១៥៩. ចំពោះភូមិអន្លង់ទ្រា ទោះបីជាមានភ័ស្តុតាងនាំឱ្យគិតថាមានការចាប់ និងឃុំម្តាយរបស់ សៅ សាក់ និង យឺន ហើយគេលែងឃើញពួកគាត់ទៀតក៏ដោយ ក៏នេះអាចជាការបាត់ខ្លួនដោយបង្ខំ ដែលអង្គជំនុំជម្រះមិនត្រូវបានប្តឹងឱ្យកាត់សេចក្តីនោះឡើយ។

២១៦០. ផ្ទុយទៅវិញ ពុំមានសាក្សីណាម្នាក់បានឃើញការសម្លាប់ស្ត្រីទាំងពីរនាក់នេះ ដោយផ្ទាល់ភ្នែកនោះឡើយ។ ភ័ស្តុតាងតែមួយគត់ ដែលលើកឡើងអំពីការសម្លាប់ម្តាយរបស់ សៅ សាក់ គឺចម្លើយជាលាយលក្ខណ៍អក្សររបស់ នាង ណាត ដែលពាក្យចចាមអារ៉ាម គ្មានប្រភពច្បាស់លាស់គ្រប់គ្រាន់

---

[2241] សាលដីកា ០០២/០១ កថាខណ្ឌ ៤៣៣។

[2242] សាលដីកា ០០២/០១ កថាខណ្ឌ ៤៤៨។

និងអាចជាពាក្យចចាមអារ៉ាមតគ្នាពីរដង។ ពុំមានភស្តុតាងណាមួយបង្ហាញអំពីការសម្លាប់ យឺន ឡើយ។ ដូច្នេះ ពុំមានភស្តុតាងគ្រប់គ្រាន់បង្ហាញអំពីធាតុផ្សំនៃអំពើមនុស្សឃាតទៅលើម្តាយរបស់ សៅ សាក់ និង យឺន ឡើយ។

២១៦១. ចំពោះ សេង វ៉ាន់ (ឪពុករបស់ វ៉ាន់ ម៉ៅ) ភស្តុតាង ដែលបានបង្ហាញ មិនអាចឱ្យទាញសេចក្តីសន្និដ្ឋានលើការសម្លាប់ជាយថាហេតុបានឡើយ។ ជាក់ស្តែង ពុំមានសាក្សីណាម្នាក់បានឃើញគេសម្លាប់គាត់ដោយផ្ទាល់ភ្នែកនោះឡើយ។ ចម្លើយជាលាយលក្ខណ៍អក្សរតែមួយគត់របស់ ឃុន ម៉ុន បានលើកឡើងថា គាត់ត្រូវគេសម្លាប់ជាមួយកូនៗ លើកលែងតែ វ៉ាន់ ម៉ៅ។ តម្លៃជាភស្តុតាងតិចតួច ព្រមទាំងកង្វះភាពច្បាស់លាស់ និងប្រភពនៃចម្លើយ មិនអាចឱ្យទាញសេចក្តីសន្និដ្ឋានលើការសម្លាប់ សេង វ៉ាន់ បានឡើយ។ ភស្តុតាងនៅសេសសល់មិនគ្រប់គ្រាន់ឱ្យទាញសេចក្តីសន្និដ្ឋានលើការសម្លាប់គាត់បានឡើយ។

២១៦២. ករណីរបស់ ថាវ ក៏មិនខុសគ្នាដែរ។ ភស្តុតាង ដែលបានលើកឡើង មិនគ្រប់គ្រាន់ឱ្យទាញសេចក្តីសន្និដ្ឋានអំពីការសម្លាប់ជាយថាហេតុបានឡើយ។ សក្ខីកម្មផ្ទាល់មាត់របស់ សៅ សាក់ គ្រាន់តែលើកឡើងអំពីការបាត់ខ្លួន។ ចម្លើយជាលាយលក្ខណ៍អក្សរលើករណីរបស់ ថាវ មានភាពផ្ទុយគ្នា ហើយទោះជាក្នុងករណីណាក៏ដោយ ពុំមានចម្លើយណាមួយនិយាយអំពីការសម្លាប់ឡើយ។ ដូច្នេះ ពុំមានភស្តុតាងគ្រប់គ្រាន់បង្ហាញអំពីធាតុផ្សំនៃអំពើមនុស្សឃាតឡើយ។

២១៦៣. ចំពោះ កែម នៅ ប្រពន្ធរបស់ ឡុង ហ៊ែល ពុំមានភស្តុតាងពាក់ព័ន្ធនឹងការសម្លាប់គាត់ឡើយ។ បើតាមសក្ខីកម្មផ្ទាល់មាត់ និងកំណត់ហេតុស្តាប់ចម្លើយមួយ គាត់ត្រូវគេនាំយកទៅ ប៉ុន្តែ នេះគ្រាន់តែជាពាក្យចចាមអារ៉ាម ឬពាក្យចចាមអារ៉ាមតគ្នាពីរដង ប៉ុណ្ណោះ។ បើពុំមានភស្តុតាងគ្រប់គ្រាន់ទេ គេមិនអាចទាញសេចក្តីសន្និដ្ឋានណាមួយលើករណីនេះបានឡើយ។

២១៦៤. ពុំមានភស្តុតាងបង្ហាញអំពីការសម្លាប់យាយ ដឹក ឡើយ។ សក្ខីកម្មផ្ទាល់មាត់ និងកំណត់ហេតុស្តាប់ចម្លើយមួយ លើកឡើងអំពីការបាត់ខ្លួនគាត់ ដោយពុំបានផ្តល់សេចក្តីបញ្ជាក់ ឬព័ត៌មានលម្អិតអំពីកាលៈទេសៈនៃការបាត់ខ្លួនឡើយ។

២១៦៥. ករណីប្រពន្ធរបស់ អៀ ពៅ មិនត្រូវបានលើកឡើងនៅក្នុងសវនាការឡើយ។ កំណត់ហេតុទាំងពីរ ដែលនិយាយអំពីករណីរបស់គាត់ មិនត្រឹមតែធ្វើឡើងនៅក្រៅក្របខ័ណ្ឌតុលាការប៉ុណ្ណោះទេ ថែម ទាំងមិនអាចយកមកធ្វើជាមូលដ្ឋានគាំទ្រដល់សេចក្តីសន្និដ្ឋាន ឱ្យហួសពីវិមតិសង្ស័យទៀតផង។ ដូចគ្នាផងដែរចំពោះករណីរបស់ សេង ហួរ (ប្រពន្ធរបស់ ឃុន ម៉ុន) ដែលត្រូវបានលើកឡើងតែ ក្នុងចម្លើយជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ។

២១៦៦. ទោះបីជាមានកំណត់ហេតុពីរ ដែលបានលើកឡើងជាទូទៅពីការសម្លាប់ជនជាតិវៀតណាមឈ្មោះ នាង ណាត និង សោម រស់ ក៏ដោយ នេះគឺជាភ័ស្តុតាងក្រៅតុលាការដែលមានតម្លៃតិចតួចបំផុត។ ក្រៅពីនេះទៀត កំណត់ហេតុទាំងនេះខ្វះភាពច្បាស់លាស់អំពីហេតុការណ៍ និងមិនមែនជាព័ត៌មាន ផ្ទាល់ ដែលអាចឱ្យទាញសេចក្តីសន្និដ្ឋាន ឬប្រៀបធៀបអង្គហេតុបានឡើយ។ លើសពីនេះទៅទៀត ពុំមានភ័ស្តុតាងអំពីសាកសព ឬរណ្តៅសាកសព ត្រូវបានលើកឡើងចំពោះមុខអង្គជំនុំជម្រះឡើយ។

២១៦៧. ជាសេចក្តីសន្និដ្ឋាន ពុំមានករណីជាក់លាក់ណាមួយអាចឱ្យកំណត់ថាជាអំពើមនុស្សឃាតឡើយ ដោយសារតែភ័ស្តុតាងមិនគ្រប់គ្រាន់។ ដូច្នេះ ពុំមានសេចក្តីសន្និដ្ឋានទូទៅណាមួយលើការសម្លាប់ ជនជាតិវៀតណាមនៅអន្លង់ត្រា អាចត្រូវបានទទួលយកឡើយ។

ii. <u>**ពោធិ៍ចិន្តាំ**</u>

២១៦៨. ចំពោះករណីរបស់ ង៉ាង យោងតាមភ័ស្តុតាងដែលបានបង្ហាញ នេះអាចជាការបាត់ខ្លួនដោយបង្ខំ ដែលអង្គជំនុំជម្រះមិនត្រូវបានប្តឹងឱ្យកាត់សេចក្តី។ ផ្ទុយទៅវិញ ពុំមានសាក្សីបានឃើញការសម្លាប់ ណាមួយឡើយ។

២១៦៩. កំណត់ហេតុ ដែលបានលើកឡើងអំពីការសម្លាប់ ផ្អែកតែលើការស្មាន (ថេង ផល) ឬជាចម្លើយ មិនអាចជឿទុកចិត្តបាន (អៀង អុន)។ ចម្លើយជាលាយលក្ខណ៍អក្សរមួយទៀតរបស់ (ស៊ិន ស៊ុន) ផ្អែកតែលើពាក្យចចាមអារ៉ាម។ បន្ថែមពីភាពផ្ទុយគ្នារវាងសក្ខីកម្ម និងចម្លើយនានា ពុំមានជម្រើស ណាមួយទៀតផ្សេងក្រៅពីកត់សម្គាល់ថា ភ័ស្តុតាងមិនគ្រប់គ្រាន់ឱ្យទាញសេចក្តីសន្និដ្ឋានស្តីពីអំពើ មនុស្សឃាតឱ្យហួសពីវិមតិសង្ស័យបានឡើយ។

២១៧០. ចំពោះករណីរបស់ ជុយ នេះអាចជាការបាត់ខ្លួនដោយបង្ខំ។ ប៉ុន្តែ យោងតាមភ័ស្តុតាងដែលបានបង្ហាញ គេក៏មិនអាចបង្ហាញអំពើមនុស្សឃាតឱ្យហួសពីវិមតិសង្ស័យបានឡើយ។

២១៧១. ជាក់ស្តែង គ្មានអ្នកណាម្នាក់បានឃើញការសម្លាប់ ឬដឹងថា ជុយ ត្រូវគេនាំយកទៅណាឱ្យប្រាកដនោះទេ។ អៀង អុន និង ឈួន វី ឆ្លើយថាបានឃើញគេចាប់ខ្លួន ជុយ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគាត់។ ប៉ុន្តែពួកគាត់មិនបានឃើញការសម្លាប់ដោយផ្ទាល់នោះទេ។ មានតែកំណត់ហេតុស្តាប់ចម្លើយ អៀង អុន ប៉ុណ្ណោះ ដែលបានលើកឡើងអំពីការសម្លាប់ ជុយ ប៉ុន្តែ នេះជាការស្មាន ឬជាពាក្យចចាមអារ៉ាម។ លើសពីនេះទៅទៀត ក្រៅពីភាពផ្ទុយគ្នារវាងចម្លើយនានា យើងឃើញថាចម្លើយរបស់ អៀង អុន ខ្វះនូវភាពអាចជឿទុកចិត្តបាន។

២១៧២. ចំពោះ សាន ករណីនេះអាចជាការបាត់ខ្លួនដោយបង្ខំ។ ប៉ុន្តែ ពុំមានសាក្សីណាម្នាក់បានឃើញគេសម្លាប់គាត់ឡើយ។ ចម្លើយមួយចំនួនលើកឡើងអំពីភវនីយភាពនៃការសម្លាប់គាត់ ប៉ុន្តែ នេះជាសក្ខីកម្ម តាមពាក្យចចាមអារ៉ាម គ្មានប្រភពច្បាស់លាស់គ្រប់គ្រាន់ និងជាកំណត់ហេតុពីរដែលគេមិនស្គាល់ប្រភពដែលអាចជាពាក្យចចាមអារ៉ាមតគ្នាពីរដង ដែលមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។ ដូច្នេះ ពុំមានភ័ស្តុតាងគ្រប់គ្រាន់បង្ហាញអំពីធាតុផ្សំនៃអំពើមនុស្សឃាតឡើយ។

### iii. ស្វាយអន្ទរ

២១៧៣. ពុំមានព័ត៌មានណាមួយអំពីជោគវាសនារបស់ សេង ហួរ អាចត្រូវបានពិភាក្សាដេញដោលនៅក្នុងសវនាការឡើយ។ មានកំណត់ហេតុពីរបី ដែលមានតម្លៃជាភ័ស្តុតាងតិចតួច បានលើកឡើងអំពីការបាត់ខ្លួន សេង ហួរ។ ក្រៅពីនោះ ព័ត៌មានទទួលបានតាមរយៈពាក្យចចាមអារ៉ាម ហើយភាពផ្ទុយគ្នាជាច្រើនត្រូវបានរកឃើញ នៅក្នុងចម្លើយនានា ដែលមិនអាចឱ្យទាញសេចក្តីសន្និដ្ឋានស្តីពីជោគវាសនារបស់ សេង ហួរ បាន។ ដូច្នេះ ពុំមានភ័ស្តុតាងគ្រប់គ្រាន់បង្ហាញអំពីធាតុផ្សំនៃអំពើមនុស្សឃាតឡើយ។

2.១. អំពើមនុស្សឃាតនៅខេត្តស្វាយរៀង

២១៧៤. ចំពោះខេត្តស្វាយរៀង ភស្តុតាង ដែលបានបង្ហាញ មិនអាចឱ្យកំណត់អំពីការប្រព្រឹត្តិអំពើមនុស្សឃាតលើជនជាតិវៀតណាមបានឡើយ។

២១៧៥. ក្នុងករណីរបស់គ្រួសារជនជាតិវៀតណាម ដែលរៀបរាប់ដោយ អ៊ុង សំអ៊ាន ភស្តុតាងដែលបានបង្ហាញជូន មិនបានលើកឡើងអំពីការសម្លាប់នោះទេ គឺលើកឡើងតែអំពីការបាត់ខ្លួន ដែលអង្គជំនុំជម្រះមិនត្រូវបានប្ដឹងឱ្យកាត់សេចក្ដីនោះទេ។

២១៧៦. ចំពោះស្ត្រី និងកូនៗ ដែល ស៊ុន ឆែម បានលើកឡើង គាត់មិនបានឃើញការចាប់ខ្លួន និងសម្លាប់ដោយផ្ទាល់ភ្នែកនោះទេ។ ព័ត៌មានថាពួកគេត្រូវបាននាំយកទៅ គឺបានមកពីអ្នកភូមិ។ នេះមិនមែនជាប្រភពច្បាស់លាស់គ្រប់គ្រាន់ ដើម្បីទាញសេចក្ដីសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យនោះឡើយ។ ចំពោះការសម្លាប់ នេះគ្រាន់តែជាព័ត៌មានតាមពាក្យចចាមអារ៉ាមប៉ុណ្ណោះ។ ទោះបីជាគេដឹងប្រភពក៏ដោយ ក៏ព័ត៌មាននេះខ្វះភាពច្បាស់លាស់អំពីកាលៈទេសៈនៃការទទួលបាន។ នេះគឺជាភស្តុតាងតែមួយគត់ ពាក់ព័ន្ធនឹងការសម្លាប់ស្ត្រី និងកូនជនជាតិវៀតណាម ជាភស្តុតាងប្រយោលដែលមិនអាចឱ្យទាញសេចក្ដីសន្និដ្ឋានស្ដីពីអំពើមនុស្សឃាតឱ្យហួសពីវិមតិសង្ស័យ។

២១៧៧. អ៊ិន យឿង មិនអាចនិយាយអំពីជនជាតិវៀតណាម នៅក្នុងភូមិរបស់គាត់ បានឡើយ។ ភាពផ្ទុយគ្នាក្នុងកំណត់ហេតុស្ដាប់ចម្លើយ ព្រំ យ៉ាន់ មិនអាចឱ្យបញ្ជាក់អំពីសញ្ជាតិរបស់ជនរងគ្រោះ ឬកំណត់អំពីកាលៈទេសៈនៃការបាត់ខ្លួនគាត់ឡើយ។ ដូច្នេះ ពុំមានការសម្លាប់ណាមួយអាចត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ។

២១៧៨. ជាចុងក្រោយ សៀង ចាន់ធី ពុំមែនជាសាក្សីនៃការសម្លាប់ណាមួយឡើយ។ បងប្រុសទាំងពីររបស់គាត់ទំនងជាត្រូវបានចាប់ខ្លួន ដោយសារតែជាអតីតទាហាន លន់ នល់ និងបានប្រព្រឹត្តកំហុស។ ចំពោះគ្រួសារវៀតណាម មានតែពាក្យចចាមអារ៉ាមអំពីការសម្លាប់ពួកគេប៉ុណ្ណោះ។ សក្ខីកម្មតែមួយគត់របស់ សៀង ចាន់ធី មិនគ្រប់គ្រាន់ឱ្យកំណត់អំពីធាតុផ្សំនៃអំពើមនុស្សឃាតនោះទេ។

២១៧៩. ករណីមួយចំនួនត្រូវបានលើកឡើងក្នុងចម្លើយជាលាយលក្ខណ៍អក្សរ។ ក្រៅពីមានតម្លៃជាភ័ស្តុតាងតិចតួច ចម្លើយទាំងនេះខ្វះភាពច្បាស់លាស់ ហើយប្រភពមិនសូវលម្អិត។ ដូច្នេះ ចម្លើយទាំងនេះមិនអាចយកមកធ្វើជាមូលដ្ឋាន សម្រាប់បង្កើតជាអំពើមនុស្សឃាត ឬបញ្ជាក់បន្ថែមបានឡើយ។

## ២. ការសម្លាប់រង្គាល (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)

### ក. និយមន័យ

២១៨០. ធាតុផ្សំសត្យានុម័តិនៃការសម្លាប់រង្គាលត្រូវបានបំពេញដោយការសម្លាប់មនុស្សក្នុងចំនួនច្រើន[2243]។ ចំពោះធាតុផ្សំអត្តនោម័តិ ចារីត្រូវមានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្សច្រើន ឬធ្វើឱ្យពួកគេរស់នៅក្នុងល័ក្ខខ័ណ្ឌជីវិតដ៏លំបាកលំបិនបណ្តាលឱ្យស្លាប់[2244]។

### ខ. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ

២១៨១. យោងតាមភ័ស្តុតាងដែលមាន ពុំមានករណីជាក់លាក់ណាមួយនៃអំពើមនុស្សឃាតទៅលើជនជាតិវៀតណាមត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ។ ទោះបីជាអង្គជំនុំជម្រះអាចយល់ឃើញជាវិសាមញ្ញថា អំពើមនុស្សឃាតមួយចំនួនអាចត្រូវបានប្រព្រឹត្ត ក៏ដោយ ក៏ករណីដាច់ដោយឡែកនេះមិនអាចឱ្យសន្និដ្ឋានថាមនុស្សជាច្រើននាក់ត្រូវបានសម្លាប់នោះឡើយ។ ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល គឺជាឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតក្នុងទ្រង់ទ្រាយធំ ប្រឆាំងនឹងក្រុមណាមួយ គឺមិនមែនប្រឆាំងនឹងបុគ្គលម្នាក់ៗនោះទេ។

២១៨២. ប៉ុន្តែ ភ័ស្តុតាងដែលបានផ្តល់ជូនបង្ហាញថា ជនជាតិវៀតណាមមួយចំនួន ដែលគេលើកឡើងនៅក្នុងសវនាការ ត្រូវបាននាំយកទៅជាក្រុម ក្នុងពេលជាមួយគ្នា ប៉ុន្តែ ដាច់ដោយឡែកពីគ្នា ក្នុងចន្លោះពេលវែង ភាគច្រើនដោយមិនដឹងមូលហេតុ ឬដោយសារមូលហេតុផ្សេងបណ្តាលមកពីការប្រព្រឹត្តិកំហុស ឬជាប់និន្នាការជាមួយនឹងរបបចាស់។ ក្រៅពីនេះទៀត ពុំមានភ័ស្តុតាងណាមួយត្រូវបាន

---

[2243] សាលដីកា ០០២/០១ កថាខណ្ឌ ៥១៧។

[2244] សាលដីកា ០០២/០១ កថាខណ្ឌ ៥១៧-៥២២។

លើកឡើង ពាក់ព័ន្ធនឹងអត្ថិភាពនៃរណ្តៅសាកសព ឬការរកឃើញសាកសពជនជាតិវៀតណាម នោះឡើយ។ ដូច្នេះ យើងមិនអាចនិយាយអំពីការសម្លាប់ក្នុងទ្រង់ទ្រាយធំ ឬការកម្ទេចជនជាតិវៀតណាមក្នុងទ្រង់ទ្រាយធំបានឡើយ។ ពុំមានភ័ស្តុតាងណាមួយអាចឱ្យបង្ហាញអំពីចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្សច្រើននោះឡើយ។

២១៨៣. ដូច្នេះ ភ័ស្តុតាង ដែលមានស្រាប់ មិនអាចបង្ហាញឱ្យហួសពីវិមតិសង្ស័យអំពីការសម្លាប់រង្គាលជនជាតិវៀតណាមបានឡើយ។

## ៣. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)

### ក. និយមន័យ

២១៨៤. ធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញរួមមានអំពើសកម្ម ឬអកម្ម ដែលនាំឱ្យមានការរើសអើងតាមព្រឹត្តិន័យ និងបដិសេធ និងរំលោភសិទ្ធិជាមូលដ្ឋាន ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ឬអនុសញ្ញា[2245]។ ចំពោះការរើសអើងដែលតម្រូវឱ្យមាន ដើម្បីផ្គុំបានជាធាតុផ្សំសត្យានុម័តិ៖

> "ការរើសអើងជាក់ស្តែងកើតមានឡើង នៅពេលដែលជនរងគ្រោះណាម្នាក់ត្រូវបានគេកំណត់ជាគោលដៅដោយសារតែជនរងគ្រោះនោះជាសមាជិកនៅក្នុងក្រុមណាមួយ ដែលចារីបានកំណត់ដោយផ្អែកលើមូលហេតុជាក់លាក់មួយចំនួន ពោលគឺ មូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ហើយជនរងគ្រោះនោះត្រូវតែស្តែងឱ្យឃើញច្បាស់លាស់គ្រប់គ្រាន់ថា គាត់បានស្ថិតក្នុងក្រុមនយោបាយ ពូជសាសន៍ ឬសាសនាណាមួយ ដែលផលវិបាកនៃការធ្វើទុក្ខបុកម្នេញដែលជាល័ក្ខខ័ណ្ឌតម្រូវនោះត្រូវតែកើតមានទៅលើក្រុមនោះ"[2246]។

២១៨៥. ធាតុផ្សំអត្តនោម័តិដែលតម្រូវឱ្យមាន ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ទាមទារឱ្យបង្ហាញឱ្យឃើញអំពីការប្រព្រឹត្តអំពើសកម្ម ឬអកម្ម ដោយមានចេតនារើសអើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[2247]។

---

[2245]សាលក្រម ០០២/០១ កថាខណ្ឌ ៤២៧ៈ សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២២៦។

[2246]សាលក្រម ០០២/០១ កថាខណ្ឌ ៤២៨ៈ សាលដីកា ០០២/០១ កថាខណ្ឌ ៦៦៧។

[2247]សាលក្រម ០០២/០១ កថាខណ្ឌ ៤២៧ៈ សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២២៦។

## ខ. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ

២១៨៦. ក្រោយពីការវិភាគទៅលើភស្តុតាងរួចមក ពុំមានព័ត៌មានណាមួយអាចឱ្យសន្និដ្ឋានបានថា ជនជាតិវៀតណាមទទួលរងនូវការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង នោះឡើយ។

២១៨៧. ចំពោះធាតុផ្សំសត្យានុម័តិ ភស្តុតាងនៃអំពើសកម្ម ឬអកម្ម ដែលនាំឱ្យមានការរើសអើងតាមព្រឹត្តិន័យ មិនត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យនោះទេ។ ជាក់ស្តែង ពុំមានភស្តុតាងណាមួយអាចឱ្យគិតថា ជនជាតិវៀតណាមមួយចំនួនដែលត្រូវគេ "នាំយកទៅ" ត្រូវបានកំណត់មុខសញ្ញា ដោយហេតុថាពួកគេស្ថិតនៅក្នុងក្រុមជនជាតិវៀតណាម ក្នុងឋានៈជាពូជសាសន៍មួយ ឡើយ។

២១៨៨. នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ជនជាតិវៀតណាម ដែលមានវត្តមាននៅឡើយ មិនទទួលរងនូវការរើសអើងឡើយ។ ជាក់ស្តែង សាក្សីជាច្រើនបានអះអាងថាជនជាតិវៀតណាមធ្វើការជាមួយខ្មែរ ដូចគេឯងដែរ។ ឧទាហរណ៍ ម្តាយរបស់ សៅ សាក់ បានធ្វើការជាមួយខ្មែរនៅក្នុងសហករណ៍មួយ ដោយត្រូវគេចាត់តាំងឱ្យមើលថែកុមារ និងទារក។ អ៊ុង សំអ៊ាន និង ស៊ុន ឆែម ក៏បានឆ្លើយដូចគ្នានេះដែរ ពាក់ព័ន្ធនឹងវៀតណាមដែលមានវត្តមាននៅក្នុងភូមិរបស់ពួកគាត់ ឬនៅជិតនោះ។

២១៨៩. ជាទូទៅ ដួង អឿន បានឆ្លើយថា ប្តីគាត់ជាជនជាតិវៀតណាមមិនដែលទទួលរងនូវការធ្វើបាប ការជេរប្រទេច ឬការប្រមាថមើលងាយ នោះឡើយ។ គាត់ប្រាប់ថាមិនធ្លាប់ឮខ្មែរក្រហមនៅក្នុងភូមិរបស់គាត់ចាត់ទុកជនជាតិវៀតណាមជាខ្មាំងនោះទេ។ មានតែ សៀង ចាន់ធី ម្នាក់ប៉ុណ្ណោះ ដែលបាននិយាយអំពីការជេរប្រមាថគ្រួសារគាត់ នៅក្នុងភូមិមួយ ដែលគេជម្លៀសគាត់ទៅនៅ ប្រហែល ១៥ ថ្ងៃ ប៉ុន្តែនេះជាការជេរប្រមាថជាទូទៅរបស់ប្រជាជនមូលដ្ឋាន គឺមិនចាំបាច់តែពួកគាត់ជាជនជាតិវៀតណាមនោះទេ ពីព្រោះអ្នកទាំងនេះត្រូវគេចាត់ទុកជាពួកនាយទុន ប្រជាជន ១៧ មេសា និងពួកសក្តិភូមិ។

២១៩០. ទោះបីជាការចាប់ខ្លួនជនជាតិវៀតណាមមួយចំនួនបានកើតឡើងមែន ឬទោះបីជាអង្គជំនុំជម្រះអាចយល់ឃើញជាវិសាមញ្ញ ជនជាតិវៀតណាមខ្លះត្រូវបានសម្លាប់ ក៏ដោយ ក៏ភ័ស្តុតាងមិនអាចឱ្យបង្ហាញថា ជនជាតិវៀតណាមត្រូវបានកំណត់មុខសញ្ញា ដោយសារតែពួកគេស្ថិតនៅក្នុងក្រុមជនជាតិវៀតណាមឡើយ។ ម្ដាយរបស់ សៅ សាក់ និង យឺន ជាជនជាតិវៀតណាម ប៉ុន្តែ ពុំមានការលើកឡើងអំពីមូលហេតុនៃការចាប់ខ្លួនពួកគាត់ឡើយ។ ដូច្នេះ ស្ត្រីទាំងពីរនាក់អាចត្រូវបានចាប់ខ្លួន មិនមែនដោយសារតែដើមកំណើតរបស់ពួកគាត់ជាជនជាតិវៀតណាម។ បន្ទាប់មក សៅ សាក់ ជាកូនស្រី ត្រូវបានចាប់ខ្លួន ក្នុងពេលជាមួយគ្នានឹងស្ត្រីចាមម្នាក់ និងបុរស ១៧ មេសា ពីរនាក់ រួចត្រូវបានដោះលែងមកវិញ។

២១៩១. ករណីនេះដូចគ្នាផងដែរចំពោះ ង៉ាង, ជុយ និង សាន នៅភូមិពោធិ៍ចិនដាំ។ ភ័ស្តុតាងមិនអាចឱ្យសន្និដ្ឋានថា ពួកគេត្រូវបានចាប់ខ្លួន ដោយសារតែដើមកំណើតរបស់ពួកគាត់ជាជនជាតិវៀតណាមនោះឡើយ។ ថេង ផល និង ឡាច គ្រី បានឆ្លើយថា ខ្លួនមិនដឹងថាហេតុអ្វីបានជាគេនាំអ្នកទាំងនេះទៅនោះទេ។ ម្យ៉ាងវិញទៀត ដួង អឿន បានបញ្ជាក់អះអាងថា ប្ដីគាត់ជាអតីតទាហានវៀតណាមប្រកបរបរលក់ដូរ និងរកស៊ីរត់ពន្ធ ដែលតម្រូវឱ្យគាត់ចេញចូលវៀតណាម[2248]។ ដោយសារតែជម្លោះប្រដាប់អាវុធជាមួយវៀតណាមកាន់តែឡើងកម្ដៅខ្លាំង នៅពេលចាប់ខ្លួនគាត់ ករណីនេះអាចជាប់ពាក់ព័ន្ធនឹងមុខរបរពីមុនៗរបស់គាត់។

---

[2248] ដួង អឿន : ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/381.1** ទំព័រ ៤០-៤១ ពីម៉ោង 13.37.35 ដល់ម៉ោង 13.41.58 ទំព័រ ៤១ មុនម៉ោង 13.41.58 ទំព័រ ៤២ ប្រហែលម៉ោង 13.46.49។ កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០០ **ឯកសារ E3/7562**, ERN KH 00034084-85 (គាត់បញ្ជាក់ថាប្ដីគាត់មានមុខរបរមិនច្បាស់លាស់។ គាត់លក់អាភៀន។ លាក់ដែរ បើមិនលាក់ ជាប់គុក។)។ សូមមើលផងដែរ ៖ ឡាច គ្រី : កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ E3/7559**, ERN KH 00034271-72, ERN KH 00034274-75 (គាត់មករស់នៅប្រទេសកម្ពុជានៅឆ្នាំ១៩៧០ បន្ទាប់រដ្ឋប្រហាររបស់ លន់ នល់។ គាត់ឡើងចុះវៀតណាម-កម្ពុជាដើម្បីកិច្ចការរកស៊ី។ ស្ថានភាពជីវភាពគាត់ធូរធារគួរសម។)៖ កិច្ចសម្ភាសន៍ នៅ សំ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០០ **ឯកសារ D230/1.1.49b**, ERN KH 00451710 (ជុយ ធ្វើទាហាន មុននឹងមករស់នៅក្នុងភូមិ ក្នុងឆ្នាំ ១៩៧១។ បន្ទាប់មក គាត់លក់ដូរគ្រប់យ៉ាង។ មិនមានឯកសារលេខកូដ E3 ទេ ប៉ុន្តែគាត់បានចូលសវនាការ នៅក្នុងពេលស្ដាប់សក្ខីកម្មដើមបណ្ដឹង ឡាច គ្រី : ប្រតិចារឹក ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/380.1** ទំព័រ ១-២ ពីម៉ោង 14.42.15 ដល់ម៉ោង 14.45.03។

២១៩២. ជាចុងក្រោយ នៅខេត្តស្វាយរៀង ច្បាស់ណាស់ថា បងប្រុសទាំងពីររបស់ សៀង ចាន់ធី មិនមែនត្រូវបានចាប់ខ្លួន ដោយសារតែដើមកំណើតរបស់ពួកគាត់ជាជនជាតិវៀតណាមនោះឡើយ គឺដោយសារតែគាត់ជាអតីតនគរបាល និងទាហាន លន់ នល់ និងបានប្រព្រឹត្តកំហុសក្នុងរបបខ្មែរក្រហម។ មូលហេតុនៃការបាត់ខ្លួនគ្រួសារផ្សេងទៀត ដោយសារតែដើមកំណើតរបស់ពួកគេជាជនជាតិវៀតណាម គ្រាន់តែជាការស្មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី ប៉ុណ្ណោះ ហើយគាត់បានឆ្លើយនៅក្នុងសវនាការថា គឺឋានៈពីមុនរបស់ពួកគេជាដើមហេតុនាំឱ្យពួកគេបាត់ខ្លួន។

២១៩៣. ភ័ស្តុតាងអំពីអត្ថិភាពនៃបញ្ជី ឬមធ្យោបាយផ្សេងទៀត ដែលទំនងជាអាចឱ្យកំណត់អត្តសញ្ញាណជនជាតិវៀតណាម មុនពេលចាប់ខ្លួន មិនត្រូវបានលើកឡើងឡើយ។ សៅ សាក់ បានបញ្ជាក់អះអាងថា គាត់មិនដឹងអំពីអត្ថិភាពនៃរបាយការណ៍នៅស្វាយអន្ទរនោះទេ គឺដូចជា ដួង អឿន នៅពោធិ៍ចិនដាំដែរ។ មានតែកំណត់ហេតុស្តាប់ចម្លើយសាក្សី មុំ ឆឹយ មួយប៉ុណ្ណោះ ដែលលើកឡើងអំពីបញ្ជី ប៉ុន្តែ បញ្ជីនោះមិនមែនមានតែឈ្មោះជនជាតិវៀតណាមប៉ុណ្ណោះទេ គឺថែមទាំងមានទាំងឈ្មោះប្រពន្ធទាហានខ្មែរទៀតផង។ សូម្បីតែក្នុងករណីនេះ មូលហេតុពូជសាសន៍មិនអាចយកជាការបានទេ។

២១៩៤. ក្នុងសវនាការ សាក្សីមិនអាចបញ្ជាក់អះអាងពីអត្ថិភាពនៃកិច្ចប្រជុំណាមួយស្តីពីជនជាតិវៀតណាមបានឡើយ។ សាក្សីទាំងអស់នៅខេត្តព្រៃវែងបានឆ្លើយថា ពុំមានកិច្ចប្រជុំអំពីជនជាតិវៀតណាម ឬប្រធានបទជនជាតិវៀតណាមមិនត្រូវបានលើកឡើង ក្នុងពេលប្រជុំនោះឡើយ។ ចម្លើយនេះស៊ីសង្វាក់គ្នានឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួនទៀត។

២១៩៥. មានតែ ស៊ិន ឆែម នៅស្វាយរៀង ម្នាក់ប៉ុណ្ណោះ និយាយអំពីកិច្ចប្រជុំមួយ ដែលគេលើកឡើងអំពីប្តី-ប្រពន្ធចម្រុះជាតិសាសន៍ខ្មែរ-វៀតណាម ប៉ុន្តែ ព័ត៌មាននេះផ្អែកតែលើសម្តីរបស់ សារិន ប៉ុណ្ណោះ។ ភ័ស្តុតាងនេះគឺជាពាក្យចចាមអារ៉ាម គ្មានព័ត៌មានអំពីកាលៈទេសៈដែល សារិន ប្រាប់គាត់អំពីបញ្ហានេះទេ។ ដោយសារតែជាភ័ស្តុតាងតែមួយគត់ដែលលើកឡើងអំពីការអនុវត្តបែបនេះនៅខេត្តស្វាយរៀង ភ័ស្តុតាងនៃការធ្វើទុក្ខបុកម្នេញទៅលើជនជាតិវៀតណាម ដោយផ្អែកលើមូលហេតុខ្សែស្រឡាយខាងម្តាយ មិនអាចត្រូវបានបង្ហាញទេ នៅខេត្តស្វាយរៀង។

២១៨៦. នៅខេត្តព្រៃវែង ការរើសអើងទៅលើជនជាតិវៀតណាម ដោយផ្អែកលើមូលហេតុខ្សែស្រឡាយខាងម្តាយ ក៏មិនអាចត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យនោះដែរ។ ជាក់ស្តែង ក្រោយពីវិភាគទៅលើភ័ស្តុតាង ច្បាស់ណាស់ថា ពុំមានការអនុវត្តបែបនេះនៅក្នុងភូមិស្វាយអន្ទរនោះទេ។ ទោះបីជាចំពោះប្តីប្រពន្ធចម្រុះជាតិសាសន៍នៅពោធិ៍ចិនដាំ កូនដែលមានម្តាយវៀតណាម ទំនងជាត្រូវបានចាប់ខ្លួន ឯកូនដែលមានម្តាយខ្មែរមិនមានបញ្ហា ក៏ដោយ វាហាក់ដូចជាគ្រាន់តែជាការសង្កេតឃើញរបស់សាក្សីក្នុងសវនាការប៉ុណ្ណោះ ហើយពួកគេមិនអាចពន្យល់បានថាតើពួកគេបានព័ត៌មាននេះមកពីណានោះទេ។ ដូច្នេះ ពុំមានភ័ស្តុតាងបង្ហាញឱ្យហួសពីវិមតិសង្ស័យថា នៅខេត្តព្រៃវែង និងស្វាយរៀង ជនជាតិវៀតណាមត្រូវបានកំណត់មុខសញ្ញា ដោយផ្អែកលើមូលហេតុខ្សែស្រឡាយខាងម្តាយ នោះឡើយ។

២១៨៧. ទោះបីជានេះជាព័ត៌មាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយធម្មតាមួយក៏ដោយ ជនជាតិវៀតណាមម្នាក់ត្រូវបានសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយ។ គាត់រស់នៅភូមិជ្រៃក្រហម ស្រុកពារាំង។ គាត់បានប្រាប់ថា គាត់ និងកូនៗ មិនមានការព្រួយបារម្ភអ្វីនោះទេ។

២១៨៨. ចំពោះធាតុផ្សំអត្តនោម័តិ ភ័ស្តុតាងដែលទើបតែនឹងលើកឡើងបង្ហាញថា ពុំមានការរើសអើងជាក់ស្តែងទៅលើក្រុមជនជាតិវៀតណាមនោះឡើយ។ ដូច្នេះ ចេតនារើសអើង ដោយមូលហេតុពូជសាសន៍ មិនអាចត្រូវបានបង្ហាញនោះឡើយ។

## ៤. អំពើមនុស្សឃាត (អំពើប្រល័យពូជសាសន៍)

### ក. និយមន័យ

២១៨៩. អំពើមនុស្សឃាត ដែលបង្កើតបានជាអំពើប្រល័យពូជសាសន៍ គឺជាអំពើមនុស្សឃាតដែលត្រូវបានប្រព្រឹត្តក្នុងចេតនាបំផ្លាញទាំងស្រុង ឬដោយផ្នែកដល់ក្រុមប្រជាជាតិមួយ ក្រុមជាតិពន្ធុមួយ ក្រុមពូជសាសន៍មួយ ឬក្រុមសាសនាមួយ[2249]។

[2249] សូមមើលខាងលើ កថាខណ្ឌ ១៧៩៩-១៨៣៤។

## ខ. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ

២២០០. យោងតាមភ័ស្តុតាងដែលមានស្រាប់អំពីខេត្តព្រៃវែង និងខេត្តស្វាយរៀង អំពើមនុស្សឃាតទៅលើជនជាតិវៀតណាមមិនអាចត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យបានឡើយ។ ទោះបីជាអង្គជំនុំជម្រះយល់ឃើញជាវិសាមញ្ញថា មានករណីដាច់ដោយឡែកនៃអំពើមនុស្សឃាត ក៏ដោយ ក៏អង្គជំនុំជម្រះត្រូវបង្ហាញភ័ស្តុតាងថា អំពើមនុស្សឃាតត្រូវបានប្រព្រឹត្តក្នុងចេតនាបំផ្លាញទាំងស្រុង ឬដោយផ្នែកដល់ក្រុមប្រជាជាតិមួយ ក្រុមជាតិពន្ធុមួយ ក្រុមពូជសាសន៍មួយ ឬក្រុមសាសនាមួយ។

២២០១. ជាដំបូង យើងត្រូវកំណត់ថា តើជនជាតិវៀតណាម ដែលទំនងជាត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហម ពិតស្ថិតនៅក្នុងក្រុមណាមួយនៃក្រុមទាំងបួននេះដែរឬទេ។ យោងតាមភ័ស្តុតាងទាំងមូលក្រៅពីករណីរបស់ អ៊ិន យឿង អ្នកទាំងនោះត្រូវបានគេហៅទៅ ដោយសារតែមានដើមកំណើតជាជនជាតិវៀតណាម គឺ យ៉ាងហោចណាស់ មានឪពុក ឬម្ដាយវៀតណាម។ នៅក្នុងសក្ខីកម្មនានាលើកលែងសក្ខីកម្មរបស់ សៀង ចាន់ធី ពុំមានភ័ស្តុតាងបង្ហាញថា ជនជាតិវៀតណាមអាចខុសពីខ្មែរ អាស្រ័យលើរូបរាងកាយនោះឡើយ។ អាស្រ័យហេតុនេះ អ្នកទាំងនេះមិនអាចស្ថិតនៅក្នុងក្រុមពូជសាសន៍មួយបានទេ។ សាក្សីមានទំនោរបែងចែកបុគ្គលទាំងនេះ ដោយសារតែប្រទេសកំណើតគឺវៀតណាម ទៅវិញទេ។ ដូច្នេះ អ្នកទាំងនេះស្ថិតនៅក្នុងក្រុមប្រជាជាតិ ឬក្រុមជាតិពន្ធុមួយ។

២២០២. ភ័ស្តុតាង ដែលត្រូវបានវិភាគ មិនអាចឱ្យបង្ហាញថា អ្នកទាំងនេះ ទោះបីជាវៀតណាមក៏ដោយ ត្រូវបានកំណត់មុខសញ្ញា ក្នុងចេតនាបំផ្លាញក្រុមជនជាតិវៀតណាម នោះឡើយ។ នៅក្នុងផ្នែកកំណត់ប្រភេទបទល្មើសនៃឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ យើងបានបង្ហាញថា ពុំមានការរើសអើងជាក់ស្ដែងទៅលើជនជាតិវៀតណាមនោះឡើយ។ គ្មានភ័ស្តុតាងណាមួយអាចឱ្យដឹងបានថាអ្នកដែលត្រូវគេសម្លាប់តាមសន្ទូត ត្រូវបានកំណត់មុខសញ្ញា ដោយសារតែដើមកំណើតរបស់ពួកគេនោះឡើយ។ នៅក្នុងសវនាការ សាក្សីមិនបានឆ្លើយថា ពួកគាត់ដឹងថាហេតុអ្វីបានជាអ្នកទាំងនេះត្រូវគេសម្លាប់នោះឡើយ។

២២០៣. គួរកត់សម្គាល់ថា ក្នុងករណីខ្លះ មនុស្សមួយចំនួនទំនងជាត្រូវបានកំណត់មុខសញ្ញា ជាឯកត្តបុគ្គលឧទាហរណ៍ ជុយ។ ដូចគ្នាផងដែរចំពោះ សៅ សាក់ និង យឺន។ កូនៗរបស់ពួកគាត់មិនមានបញ្ហា

ដោយសារតែដើមកំណើតរបស់ពួកគេឡើយ នៅក្នុងរបបខ្មែរក្រហម។ បងប្រុសទាំងពីររបស់សៀង ចាន់ធី មិនមែនត្រូវបានចាប់ខ្លួន ដោយសារតែពួកគាត់ជាជនជាតិវៀតណាមនោះឡើយ គឺដោយសារតែសកម្មភាពពីអតីតកាល និងការប្រព្រឹត្តកំហុស។ បងប្អូនដទៃទៀតរបស់គាត់មិនមានបញ្ហាអ្វីនោះឡើយ។ ឧទាហរណ៍ទាំងនេះបង្ហាញថា ជនជាតិវៀតណាមមិនមែនត្រូវបានកំណត់មុខសញ្ញា ដោយសារតែដើមកំណើតរបស់ពួកគាត់នោះឡើយ។ ដូច្នេះ ភ័ស្តុតាងដែលថាអ្នកទាំងនេះត្រូវបានកំណត់មុខសញ្ញា ជាឋានៈជាក្រុមមួយ មិនត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ។

២២០៤. ចំពោះចេតនាបំផ្លាញក្រុម ជាក់ស្តែងណាស់ គឺគ្មានភ័ស្តុតាងនោះទេ។ ការធ្វើបញ្ជី ឬកិច្ចប្រជុំអំពីជនជាតិវៀតណាម មិនអាចត្រូវបានបង្ហាញនៅក្នុងសវនាការឡើយ។ ទោះបីជាសាក្សីមួយចំនួនបានឆ្លើយថា ជនជាតិវៀតណាមទាំងអស់ ដែលគេនាំទៅ គឺយកទៅសម្លាប់ចោល ក៏ដោយ ក៏នេះគ្រាន់តែជាពាក្យចចាមអារ៉ាមប៉ុណ្ណោះ។ ភ័ស្តុតាងនេះតិចតួចស្តួចស្តើងពេកមិនអាចបង្ហាញអំពីចេតនាបំផ្លាញក្រុមជនជាតិវៀតណាមបានទេ។ ក្រៅពីនេះទៀត ទ្រឹស្តីខ្សែស្រឡាយខាងម្តាយដែលសហចៅក្រមស៊ើបអង្កេតបានបរិយាយ មិនត្រូវបានពិនិត្យផ្ទៀងផ្ទាត់គ្រប់ទីកន្លែងនោះទេ។ ផ្ទុយទៅវិញ នៅភូមិស្វាយអន្ទរ ទ្រឹស្តីនេះហាក់ដូចជាមិនត្រូវបានអនុវត្តទាល់តែសោះ។

២២០៥. ជាចុងក្រោយ ទោះបីជាឧបមាថាជនជាតិវៀតណាមពីរបីនាក់ត្រូវបានសម្លាប់ក៏ដោយ ក៏លក្ខណៈវិនិច្ឆ័យនៃការបំផ្លាញក្រុមជាសារវន្តមិនត្រូវបានបំពេញនោះដែរ។ ពុំមានទិន្នន័យប្រជាសាស្ត្រគួរឱ្យទុកចិត្តបានណាមួយ អាចឱ្យប៉ាន់ប្រមាណចំនួនជនជាតិវៀតណាមរស់នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ក្នុងឆ្នាំ ១៩៧៧ បានទេ។ ប៉ុន្តែ សក្ខីកម្មនានាបានបង្ហាញថា បើមានជនជាតិវៀតណាមរស់នៅ ក៏មានតិចតួចបំផុតនៅតាមភូមិនីមួយៗ។ ដូច្នេះ យើងមិនអាចដឹងថាតើជនជាតិវៀតណាមបន្តិចបន្តួចដែលអង្គជំនុំជម្រះអាចយល់ឃើញថាត្រូវគេសម្លាប់ ដោយមើលងាយវិធាននៃការពិនិត្យភ័ស្តុតាង ជាផ្នែកដ៏សំខាន់មួយនៃក្រុមជនជាតិវៀតណាមនៅខេត្តព្រៃវែង ដែរឬទេ។ ទោះជាយ៉ាងណាក៏ដោយ ទោះបីជាសារៈសំខាន់នៃតួលេខមិនមានភាពចាំបាច់ក៏ដោយ ក៏ជនជាតិវៀតណាមប៉ុន្មាននាក់ដែលត្រូវបានលើកឡើងនេះ មិនតំណាងឱ្យទ្រង់ទ្រាយធំនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះឡើយ។

២២០៦. ដូច្នេះ ទោះបីជាអង្គជំនុំជម្រះសម្រេចយល់ឃើញថា អំពើមនុស្សឃាតលើជនជាតិវៀតណាមអាចត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យក៏ដោយ ក៏ភ័ស្តុតាងដែលមានស្រាប់មិនអាចបង្ហាញថា អំពើមនុស្សឃាតទាំងនេះត្រូវបានប្រព្រឹត្តក្នុងចេតនាបំផ្លាញក្រុមជនជាតិវៀតណាមទាំងស្រុង ឬដោយផ្នែកនោះឡើយ។

## ជំពូកទី ៦. គោលនយោបាយស្តីពីការកំណត់គោលដៅជាក់លាក់ទៅលើជនជាតិវៀតណាម

២២០៧. ក្រោយពីបានធ្វើការកត់សម្គាល់បឋមចាំបាច់ខ្លះៗ ដើម្បីកំណត់ព្រំដែននៃការពិភាក្សា (១) យើងត្រូវផ្តោតលើការប្រើប្រាស់ពាក្យ "យួន" ដែលជារឿយៗ ត្រូវបានបកស្រាយខុស បែរជាមានន័យអវិជ្ជមាន ឬរើសអើងពូជសាសន៍ទៅវិញ (២)។ បន្ទាប់មកទៀត ការអានជាសត្យានុម័តិនូវសេចក្តីថ្លែងការណ៍ជាផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យ អាចឱ្យសន្និដ្ឋានបានថា ពុំមានគោលនយោបាយពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាឱ្យវាយប្រហារទៅលើជនស៊ីវិលវៀតណាម នៅកម្ពុជាឡើយ។ គឺវៀតណាម ក្នុងឋានៈជារដ្ឋមួយមានជម្លោះប្រដាប់អាវុធជាមួយកម្ពុជា ដែលត្រូវបានមេដឹកនាំជាន់ខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកជាសត្រូវរបស់កម្ពុជាប្រជាធិបតេយ្យ (៣)។

### ផ្នែកទី ១. ការកត់សម្គាល់បឋម

២២០៨. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា គោលនយោបាយប្រឆាំងនឹងជនជាតិវៀតណាមបានចាប់ផ្តើមមុនឆ្នាំ ១៩៧៥ និងបន្តរីកធំ យ៉ាងហោចណាស់រហូតដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩[2250]។ ជាក់ស្តែង តាំងពីឆ្នាំ ១៩៧៣ មក បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមបណ្តេញជនជាតិវៀតណាមពីទឹកដីកម្ពុជា ហើយប្រតិបត្តិការនេះបន្តរហូតដល់ឆ្នាំ ១៩៧៦។ ក្រុមមេធាវីការពារក្តីបានពន្យល់រួចមកហើយថា អង្គជំនុំជម្រះមិនបានទទួលបណ្តឹងតាមផ្លូវច្បាប់អំពីអង្គហេតុនៃការជម្លៀសជនជាតិវៀតណាមនោះទេ។ ដូច្នេះ អង្គជំនុំជម្រះពុំមានយុត្តាធិការកាត់សេចក្តីអង្គហេតុទាំងនេះទេ[2251]។

[2250] ដីកាដំណោះស្រាយ កថាខណ្ឌ ២១៣។

[2251] សូមមើលខាងលើ កថាខណ្ឌ ២១៩-២៧៦។

២២០៩. គោលនយោបាយប្រឆាំងនឹងជនជាតិវៀតណាមមានទំហំធំជ្រុល ចាប់ពីខែ មេសា ឆ្នាំ ១៩៧៧។ បើតាមសហចៅក្រមស៊ើបអង្កេត "ចេតនារបស់បក្សកុម្មុយនីស្តកម្ពុជា គឺជំរុញគោលនយោបាយនេះឱ្យបានកាន់តែឆ្ងាយ តាមរយៈការកម្ទេចទាំងស្រុង ឬមួយផ្នែកនៃក្រុមជនជាតិវៀតណាម ដោយសារពួកគេជាក្រុមនេះ"[2252]។

២២១០. ដើម្បីបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយនេះ សហចៅក្រមស៊ើបអង្កេតបាននំលោភលើវិសាលភាពនៃបណ្តឹងមកកាន់ខ្លួន ជាញឹកញាប់។ ក្រុមមេធាវីការពារក្តីសូមរំឭកថា សហចៅក្រមស៊ើបអង្កេតទទួលបានបណ្តឹងអំពីអង្គហេតុពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិវៀតណាម តែនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ប៉ុណ្ណោះ[2253]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតបានផ្អែកលើភ័ស្តុតាងមួយចំនួនដែលបង្ហាញអំពីអង្គហេតុកើតឡើងនៅក្រៅខេត្តទាំងពីរនេះ។

២២១១. នេះជាករណីនៃឯកសារពីរ ដែលត្រូវបានយកធ្វើជាមូលដ្ឋាននៅក្នុងដីកាដំណោះស្រាយដើម្បីបង្ហាញអំពី "ការអនុវត្តគោលនយោបាយនេះ [...] នៅក្នុងលិខិតឆ្លើយឆ្លងរវាងភូមិភាគ និងមជ្ឈិម"[2254]។ គឺរបាយការណ៍មួយរបស់ភូមិភាគបស្ចិម ធ្វើដោយមន្ទីរ ៤០១ នៅខែ កក្កដា ឆ្នាំ ១៩៧៨[2255] និងឯកសារមួយនិយាយអំពីការសន្ទនាតាមទូរស័ព្ទ រវាង មាស មុត មកពីកងពល ១៦៤ និងមេដឹកនាំជាន់ខ្ពស់ អំពីទូកវៀតណាមប្រដាប់អាវុធ[2256]។ នេះក៏ជាករណីផងដែរនៃភ័ស្តុតាងដែលត្រូវបានដកស្រង់ ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានអំពីការសម្លាប់រង្គាលជនជាតិវៀតណាម នៅភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរ[2257]។

---

[2252]ដីកាដំណោះស្រាយ កថាខណ្ឌ ២១៤។

[2253]សូមមើលខាងលើ កថាខណ្ឌ ១៨៨០-១៨៨៥។

[2254]ដីកាដំណោះស្រាយ កថាខណ្ឌ ២១៤។

[2255]ជូនអង្គការជាទីគោរព និងជាទីស្នេហា ពីការិយាល័យ ៤០១ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៧៨**ឯកសារ E3/1094**។

[2256]កងពលតូចលេខ ១៦៤ ផ្នែកនយោបាយ ទំនាក់ទំនងតាមទូរស័ព្ទសម្ងាត់ នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨ កំណត់ហេតុ ចុះហត្ថលេខា ដោយ មុត ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៨**ឯកសារ E3/928**។

[2257]ដីកាដំណោះស្រាយ កថាខណ្ឌ ២១៤។

២២១២. ជាចុងក្រោយ ដោយផ្អែកតែទៅលើភ័ស្តុតាងជាឯកសារដែលស្ថិតក្នុងវិសាលភាពនៃបណ្តឹងទៅកាន់ខ្លួន សហចៅក្រមស៊ើបអង្កេតបានត្រឹមតែសំអាងលើទស្សនាវដ្តីទង់បដិវត្តន៍ ខែ មេសា ឆ្នាំ ១៩៧៧ ប៉ុណ្ណោះ[2258]។

២២១៣. ម្យ៉ាងវិញទៀត កំណត់ហេតុស្តាប់ចម្លើយសាក្សី ឃុន គីម ពុំមានសម្តីដែលត្រូវបានប្រើប្រាស់នៅក្នុងដីកាដំណោះស្រាយ ដើម្បីគាំទ្រដល់ការអះអាងថា "អតីតកម្មាភិបាលមួយរូបក៏បានបញ្ជាក់អំពីគោលនយោបាយនេះផងដែរ ដោយលើកឡើងថា នៅទីកន្លែងណាដែលមានជនជាតិវៀតណាមគ្រប់គ្នាត្រូវប្រុងប្រយ័ត្នដើម្បីរកឱ្យឃើញ និងកម្ចាត់ចោលសត្រូវផ្ទៃក្នុងទាំងនេះ"[2259]។ ជាក់ស្តែងសាក្សីនេះជាកម្មាភិបាលតែម្នាក់គត់ដែលត្រូវបានដកស្រង់ (ធ្វើឱ្យយើងមិនយល់អំពីការប្រើប្រាស់ពហុវចនៈ) ហើយគាត់មិនបាននិយាយអំពីជនជាតិវៀតណាមនោះទេ គឺគាត់សំដៅដល់ "វៀតកុង" ដែលចូលមកបង្កប់ខ្លួននៅគ្រប់ទីកន្លែង[2260]។

២២១៤. លើសពីនេះទៀត ទស្សនៈរបស់សហចៅក្រមស៊ើបអង្កេតដែលផ្អែកលើការប្រព្រឹត្តិចំពោះជនជាតិវៀតណាមនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ដើម្បីបង្ហាញអំពីទ្រឹស្តីខ្សែស្រឡាយខាងម្តាយ និងទាញការសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងជនជាតិវៀតណាម មិនអាចយកជាការបានទេ នៅពេលពិនិត្យ[2261]។

២២១៥. សហព្រះរាជអាជ្ញាក៏បានបង្ហាញឯកសារជាច្រើនផងដែរ ជាពិសេស នៅក្នុងសវនាការបង្ហាញឯកសារគន្លឹះអំពីក្រុមជាក់លាក់ ដែលពាក់ព័ន្ធនឹងអង្គហេតុក្រៅវិសាលភាពនៃការជំនុំជម្រះក្តី៖ ការជម្លៀសជនជាតិវៀតណាម ជនជាតិវៀតណាមនៅលើសមុទ្រ ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងទឹកដីវៀតណាម ដោយមិនគិតការប្រើប្រាស់សារទូរលេខ ឬរបាយការណ៍របស់កម្មាភិបាលស្តី

---

[2258]ទស្សនាវដ្តីទង់បដិវត្ត លេខពិសេស ខែ មេសា ឆ្នាំ ១៩៧៧ **ឯកសារ E3/742**។

[2259]ដីកាដំណោះស្រាយ កថាខណ្ឌ ២១៤ កំណត់សម្គាល់ចុងឯកសារ ៧៤៨។

[2260]កំណត់ហេតុស្តាប់ចម្លើយ ឃុន គីម ហៅ នួន ប៉ែត ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ **ឯកសារ E3/360**, ERN KH 00186345 ក្រុមមេធាវីការពារក្តីកត់សម្គាល់ឃើញថាមានបញ្ហាក្នុងការបកប្រែនៅក្នុងអត្ថបទជាភាសាអង់គ្លេស។ ពីព្រោះថាលោកបានយោងតែទៅលើពាក្យ « *Vietnamese* » តែមិនយោងទៅលើពាក្យ វៀតកុងទេ ៖ ERN EN 00268860។ ក៏ប៉ុន្តែនៅក្នុងឯកសារដើមជាភាសាខ្មែរ បញ្ជាក់ថាសាក្សីពិតជានិយាយពី វៀតកុង : ERN KH 00186345។

[2261]ដីកាដំណោះស្រាយ កថាខណ្ឌ ២១៤។ សូមមើលខាងលើ កថាខណ្ឌ ២១៩៥-២១៩៦ និងកថាខណ្ឌ ២២០៤។

ពីស្រុកត្រាំកក់ ឬតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជា ដែលមិនមែនជាខេត្តព្រៃវែង និងស្វាយរៀង។ ភស្តុតាងទាំងនេះត្រូវតែបដិសេធចោល។

២២១៦. ភស្តុតាងពាក់ព័ន្ធ អំពីគោលនយោបាយប្រឆាំងនឹងជនជាតិវៀតណាម ចាំបាច់ត្រូវវិភាគជាមួយអត្ថិភាពនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ចាប់ពីខែ ឧសភា ឆ្នាំ ១៩៧៥[2262]។

២២១៧. ដូចក្រុមមេធាវីការពារក្តីបានលើកឡើងជាច្រើនលើកច្រើនសាមកហើយ ការភាន់ច្រឡំមិនឈប់ឈររបស់សហព្រះរាជអាជ្ញារងសុន្ទរកថា សេចក្តីថ្លែងការណ៍ផ្លូវការផ្សេងទៀតរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ក្នុងក្របខ័ណ្ឌនៃស្ថានភាពសង្គ្រាម និងការអំពាវនាវឱ្យវាយប្រហារលើប្រជាជនស៊ីវិល គឺជាការបកស្រាយខុសស្រឡះចំពោះសេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាទៅលើបញ្ហានេះ។

## ផ្នែកទី ២. ការត្រឡប់មកនិយាយអំពីការបកស្រាយពាក្យ "យួន"

### ១. ការប្រើប្រាស់ពាក្យ "យួន" នៅប្រទេសកម្ពុជា

២២១៨. អ្វីៗជាច្រើនត្រូវបាននិយាយពាក់ព័ន្ធនឹងពាក្យ "យួន" ដោយអង្គជំនុំជម្រះមិនបានស្តាប់ភស្តុតាងជាច្រើនអំពីការប្រើប្រាស់ពាក្យនេះ។

២២១៩. ចំពោះអ្នកនិយាយភាសាខ្មែរ សញ្ញាណរើសអើងពូជសាសន៍ជាប់ជាមួយនឹងពាក្យ "យួន" មិនត្រូវគ្នានឹងបម្រើបម្រាស់ផ្សេងៗ នៅកម្ពុជា តាំងពីយូរយារណាស់ហើយ នោះឡើយ។ វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ដែលបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានកំណត់និយមន័យពាក្យនេះដូចខាងក្រោម៖

[2262]សូមមើលខាងលើ កថាខណ្ឌ ៦៧១-៨៤៥។

"ជាតិមនុស្សអ្នកដែនតុងកឹង ដែនអណ្ណាម ដែនកូសាំងស៊ីន៖ *យួនតុងកឹង យួនអណ្ណាម យួនកូសាំងស៊ីន*។ ពាក្យសាមញ្ញច្រើនហៅយួនតុងកឹងថា យួនហាណូយ ហៅយួនអណ្ណាមថា យួនហ្វេ ហៅយួនកូសាំងស៊ីនថា យួនព្រៃនគរ"[2263]។

២២២០. ដូច្នេះ ដំបូងឡើយ ពាក្យ "យួន" ពុំមានសញ្ញាណរើសអើង ឬមើលងាយនោះទេ គឺសំដៅដល់ការស្ថិតនៅទីតាំងភូមិសាស្ត្រផ្សេង[2264]។ ចាប់ពីឥណ្ឌូចិនបារាំងទទួលបានឯករាជ្យមក ជនបដិវត្តន៍វៀតណាមបានប្រើប្រាស់ពាក្យវៀតណាម ដែលមិនប្រើនៅក្នុងភាសាខ្មែរ។

២២២១. ភស្តុតាងខាងភាសាវិទ្យា សម្រាប់អ្នកនិយាយភាសាខ្មែរ ជាពិសេស អាចឱ្យបដិសេធចោលនូវសញ្ញាណបន្ទុះបង្អាប់ជាប់ជាមួយនឹងពាក្យ "យួន"។ ជាក់ស្តែង ពាក្យដែលគេប្រើប្រាស់ជាទូទៅក្នុងភាសាខ្មែរ សម្រាប់សមាសនាម ដែលសំដៅដល់ដើមកំណើត ឬឫសគល់វៀតណាម។ ឧទាហរណ៍មួយចំនួនអាចឱ្យឆ្លុះបញ្ចាំងនូវអះអាងអំណាងនេះ៖ ម្ជូរយួន សំដៅដល់សម្លដ៏ល្បីដែលខ្មែរចូលចិត្ត, ស្រមោចយួន សំដៅដល់ស្រមោចក្រហមកាច ពីព្រោះវាហ៊ានតទល់នឹងអ្នកដែលធំជាងវា, កូនយួន ជាពាក្យសំដៅដល់កុមារស្បែកស និងស្អាត នៅក្នុងសង្គមខ្មែរ, ស្រីយួន គ្រាន់តែសំដៅជាទូទៅដល់ស្ត្រីវៀតណាម គឺពុំមានបង្កប់ន័យបន្ទុះបង្អាប់នោះទេ។ ទោះជាយ៉ាងនេះក្តី មានពាក្យបន្ទុះបង្អាប់ពិតប្រាកដចំពោះជនជាតិវៀតណាម ដែលជាពាក្យជេរប្រមាថ ឬរើសអើងពូជសាសន៍យ៉ាងច្បាស់ក្រឡែត[2265]។

---

[2263]សម្តេចសង្ឃ ជួន ណាត *វចនានុក្រមខ្មែរ* ឆ្នាំ១៩៦៨ ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ទំព័រ ៩៥៥។ ស្នាដៃនេះទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជាថាជាឯកសារសម្រាប់ប្រើប្រាស់ជាផ្លូវការ។

[2264]ចំពោះប្រធានបទនេះ សូមមើលដែលលោក ទូច ប៊ូវ៉ា ផ្ញើជូនអ្នករៀបរៀង ដែលមានចំណងជើងថា "*Objectors to [Y]uon have been hypnotised by foreign 'Expert'*" កាសែតពេញប៊ុស្តិ៍ ចុះថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ ២០១០ http://www.phnompenhpost.com/national/objectors-yuon-have-been-hypnotised-foreign-'experts'។ នៅក្នុងវេទិកានេះ អ្នកនិពន្ធបានរៀបរាប់ពីប្រវត្តិនៃការប្រើពាក្យ "យួន" ហើយពន្យល់ថាតើន័យនៃពាក្យនេះបានប្រែប្រួលយ៉ាងដូចម្តេចនៅក្នុងប្រវត្តិសាស្ត្រ និងតាមការប្រកាន់ជំហរនយោបាយ។ គេគួរតែលើកឡើងពីសង្គ្រាមប៉ាក្កាដែលបានកើតឡើងនាពេលថ្មីៗ គឺនៅឆ្នាំ ២០១៣ ជាមួយនឹងការលើកឡើងរបស់ លោក អ៊ឹ វីរៈ និងលោក សម រង្ស៊ី។ សូមមើលផងដែរ http://www.phnompenhpost.com/national/meaning-yuon-1 et http://www.phnompenhpost.com/national/dont-impoverish-our-language។

[2265]ឧទាហរណ៍នៃការជេរប្រមាថរបៀបដូចគ្នានេះ ៖ អាស្រុកយៀ [ស្រុកីដូង], អាកន្ទប, អាសឹង។ ពាក្យទាំងនេះច្រើនតែប្រើនៅក្នុងបរិបទនៃពាក្យសម្តីស្អប់ជនបរទេស។

២២២២. សាក្សីផ្សេងៗ ដែលមកផ្ដល់សក្ខីកម្មជាបន្តបន្ទាប់នៅក្នុងសវនាការ បានប្រើប្រាស់ពាក្យ "យួន" ជាទូទៅ។ ប្រសិនបើយើងចង់បកស្រាយបម្រើបម្រាស់ពាក្យនេះ តាមបែបវិជ្ជមាន ចំពោះអតីតយុទ្ធជន ឥរិយាបថនេះទៅដល់ដែនកំណត់ នៅពេលខ្មែរសាមញ្ញនៅតាមជនបទប្រើប្រាស់ពាក្យនេះ។

២២២៣. ឧទាហរណ៍គួរឱ្យចាប់អារម្មណ៍បំផុត គឺការប្រើប្រាស់ពាក្យនេះជាភាសាខ្មែរដោយអតីតប្តី-ប្រពន្ធ ឬសមាជិកគ្រួសារវៀតណាម ឬអ្នកភូមិធម្មតាដែលរស់នៅជិតព្រំដែនវៀតណាម ដូចជា នៅខេត្តព្រៃវែង និងស្វាយរៀង ជាដើម។ ជាអកុសល ក្នុងករណីភាគច្រើន ពាក្យនេះមិនត្រូវបានបកប្រែជាភាសាបារាំងទេ នៅពេលសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី មកផ្តល់សក្ខីកម្ម។ ផ្ទុយទៅវិញ បុគ្គលទាំងនេះប្រើពាក្យ "យួន" ជារឿយៗដើម្បីនិយាយអំពីជនជាតិ ឬប្រទេសវៀតណាម ឧទាហរណ៍ "ប្រទេសយួន" សម្រាប់ប្រទេសវៀតណាម "យួន" សម្រាប់ប្រជាជនវៀតណាម និងភាសា "យួន" សម្រាប់ភាសាវៀតណាម[2266]។

២២២៤. ជាក់ស្តែង សាក្សី សៅ សាក់ ដែលមានម្តាយវៀតណាម នៅខេត្តព្រៃវែង បានប្រើប្រាស់ពាក្យ "យួន" ជាច្រើនលើច្រើនសា ដើម្បីនិយាយអំពីគ្រួសារដែលគេបញ្ជូនត្រឡប់ទៅវៀតណាមវិញ និយាយអំពី សេង ហួរ ជាប្រជាជននៅភូមិអន្លង់ទ្រា និងជាប្រពន្ធរបស់ យុន ម៉ុន ក៏ដូចជានិយាយ

---

[2266] សូមមើលឧទាហរណ៍ ៖ ជឿង យ៉ាំងថែត៖ ប្រតិចារឹក ថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៤៥ ម៉ោង 11.08.39 (បញ្ហាបកប្រែ សូមមើលប្រតិចារឹកជាភាសាខ្មែរ ទំព័រ ៣២) ទំព័រ ៦៤ ម៉ោង 13.55.04 (KH ទំព័រ ៤៥) ទំព័រ ៦៥ បន្ទាប់ពីម៉ោង 13.58.00 (KH ទំព័រ ៤៦) ទំព័រ ៧០-៧១ ប្រហែលម៉ោង 14.09.35 (KH ទំព័រ ៥០-៥១) ទំព័រ ៨៣-៨៤ មុនម៉ោង 14.39.52 (KH ទំព័រ ៦០) ទំព័រ ១០៣ នៅម៉ោង 15.42.31 (KH ទំព័រ ៧៤)។ ប្រតិចារឹក ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៥ឯកសារ **E1/364.1** ទំព័រ ៧ ប្រហែលម៉ោង 09.14.20 (KH ទំព័រ ៥) កូនដែលមានឪពុកម្តាយសញ្ជាតិវៀតណាម។ ខ្វង មួយ៖ ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ៥៩ នៅម៉ោង 13.39.47 (KH ទំព័រ ៤០) ទំព័រ ៧៩ មុនម៉ោង 14.53.51 (KH ទំព័រ ៥៣) ទំព័រ ៨០ នៅម៉ោង 14.56.19 (KH ទំព័រ ៥៤) – កូនដែលមានម្តាយសញ្ជាតិវៀតណាមដែលមានញាតិរស់នៅវៀតណាមពេលបច្ចុប្បន្ន។ ប្រាក់ ខឿន៖ ប្រតិចារឹក ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៦៨-៦៩ បន្ទាប់ពីម៉ោង 13.56.14 (KH ទំព័រ ៤៥) – ប្តីយកប្រពន្ធសញ្ជាតិវៀតណាម។ អ៊ុង សំអ៊ាន ៖ ប្រតិចារឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/366.1** ទំព័រ ៦១ នៅម៉ោង 13.46.46 (KH ទំព័រ ៤២) ទំព័រ ៩៩-១០០ បន្ទាប់ពីម៉ោង 15.26.07 (KH ទំព័រ ៦៨) ទំព័រ ១០៣-១០៤ បន្ទាប់ពីម៉ោង 15.36.33 (KH ទំព័រ ៧១)។ ស៊ិន ឆែម៖ ប្រតិចារឹក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/367.1** ទំព័រ ២៨-២៩ បន្ទាប់ពីម៉ោង 10.39.59 (KH ទំព័រ ២១)។

អំពីអ្នកភូមិផ្សេងទៀត[2267]។ ខួង អឿន ដែលមានប្ដីវៀតណាម ក៏បានប្រើប្រាស់ពាក្យ "យួន" ដើម្បីនិយាយអំពីជនជាតិវៀតណាម ជាទូទៅ[2268]។

២២២៥. ការពន្យល់របស់លោក Alexander HINTON អំពីន័យបង្កប់របស់ពាក្យដែលមានចរិតហិង្សា និងរើងអើងពូជសាសន៍ មានដែនកំណត់ជាសត្យានុម័តិ។ ក្នុងល័ក្ខខ័ណ្ឌនេះ ការប្រើប្រាស់ពាក្យ "យួន" ក្នុងសុន្ទរកថារបស់តំណាងកម្ពុជាប្រជាធិបតេយ្យ មិនអាចឱ្យសន្និដ្ឋានថាមានឆន្ទៈអំពាវនាវឱ្យប្រើអំពើហិង្សាប្រឆាំងនឹងប្រជាជនស៊ីវិលជនជាតិវៀតណាមនោះឡើយ គឺមិនដូចការអះអាងរបស់អ្នកជំនាញ ក្នុងពេលផ្ដល់សក្ខីកម្ម នោះទេ[2269]។

## ២. ដែនកំណត់នៃសក្ខីកម្មរបស់លោក Alexander HINTON

២២២៦. ចំណុចនេះតម្រូវជាចាំបាច់ឱ្យយើងត្រឡប់មកនិយាយអំពីចម្លើយ និងការបកស្រាយរបស់គាត់អំពីពាក្យ "យួន" ជាអាទិ៍ នៅក្នុងសុន្ទរកថា ថ្លែងដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងជាពិសេសសុន្ទរកថារបស់ ប៉ុល ពត នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ និងគោលជំហររបស់នរវិទូដែលមានលក្ខណៈជ្រុលហួសហេតុ[2270]។ គោលជំហរនេះដាច់ចេញពីការពិតនៃសង្គមវិទ្យាកម្ពុជា ដែលទើបនឹងរំឭកពីខាងលើ។

---

[2267] ឧទាហរណ៍សូមមើល : ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/362.1** ទំព័រ ៩៨ មុនម៉ោង 15.20.15 (« [...] ការជម្លៀសគ្រួសារដែលមានឪពុក ឬម្ដាយមានប្រភពយួនតិចឬច្រើន » KH ទំព័រ ៧០-៧១)។ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/362.1** ទំព័រ ១១៦ បន្ទាប់ពីម៉ោង 15.55.46 ("[...] ជាកូនកាត់ចិនយួន" KH ទំព័រ ៨៣-៨៤) ប្រតិចារឹក ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ១២-១៣ ប្រហែលម៉ោង 09.35.07 (KH ទំព័រ ៩) ទំព័រ ១៤ នៅម៉ោង 09.37.24 (KH ទំព័រ ១០)។

[2268] ប្រតិចារឹក ថ្ងៃទី 25.01.16 **ឯកសារ E1/381.1** ទំព័រ ៤៣ នៅម៉ោង 11.04.34 (KH ទំព័រ ៣០)។

[2269] ប្រតិចារឹក ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/402.1** ទំព័រ ៨ ពីម៉ោង 09.16.08 ដល់ម៉ោង 09.17.18៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/403.1** ទំព័រ ៣៣ មុនម៉ោង 10.03.32។

[2270] សុន្ទរកថារបស់ ប៉ុល ពត ទស្សនាវដ្ដីទង់បដិវត្ត ខែមេសា ១៩៧៨ **ឯកសារ E3/4604**, ERN KH 00064710៖ Alexander HINTON : ប្រតិចារឹក ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/402.1** ទំព័រ ៨ ពីម៉ោង 09.16.08 ដល់ម៉ោង 09.17.18 ទំព័រ ៤8 មុនម៉ោង 10.58.21 ទំព័រ ៤9 នៅម៉ោង 11.00.07 ទំព័រ ១25 បន្ទាប់ពីម៉ោង 15.54.36 ទំព័រ ១28-129 ប្រហែលម៉ោង 16.01.28៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/403.1** ទំព័រ ៣៣ មុនម៉ោង 10.03.32 ទំព័រ ៥៨ មុនម៉ោង

២២២៧. ការដាច់ចេញពីការពិតនេះ និងព្រឹសដែលនាំឱ្យមើលឃើញតែ "ប្រល័យពូជសាសន៍" ដែលសាស្ត្រាចារ្យសាកលវិទ្យាល័យ Alexander HINTON បាននិយាយអំពីភ័ស្តុតាងដែលគេបង្ហាញជូនគាត់ បានប៉ះពាល់យ៉ាងច្បាស់ដល់លទ្ធភាពរបស់គាត់ក្នុងការវិភាគជាសត្យានុម័តិ លើអត្ថន័យច្បាស់លាស់បំផុតនៃសុន្ទរកថាមួយ ដែលលើកឡើងអំពីការប្រយុទ្ធខាងយោធា។ ជាក់ស្តែង ក្នុងសុន្ទរកថារបស់ ប៉ុល ពត នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ ដែលបានថ្លែង ក្រោយពេលកងទ័ពវៀតណាមចូលលុកលុយប្រទេសកម្ពុជា នៅចុងឆ្នាំ ១៩៧៧[2271] ពុំមានសារលាក់កំបាំងនោះទេ។ អ្នកទទួលខុសត្រូវបក្សកុម្មុយនីស្តកម្ពុជានិយាយយ៉ាងច្បាស់ និងលម្អិតអំពីជម្លោះប្រដាប់អាវុធ និងកងទ័ពវៀតណាមជាសត្រូវ[2272]។

២២២៨. សក្ខីកម្មរបស់លោក Alexander HINTON អំពីប្រធានបទនេះ បង្ហាញឱ្យឃើញចំណុចសំខាន់នៃដែនកំណត់របស់អ្នកជំនាញមួយចំនួន។ ព្រឹសប្រល័យពូជសាសន៍ដែលបានលើកឡើងខាងលើ ក្នុងក្របខ័ណ្ឌនៃការសិក្សានរវិទ្យា (មិនមែនប្រវត្តិសាស្ត្រ ឬយោធា) វាជាកំហុសជាប់នឹងម្នាក់ៗដែលមិនអាចតម្រង់ទិសការពិភាក្សាសម្រេចរបស់តុលាការអនាគតិនោះទេ។ ជាក់ស្តែង ទស្សនៈរបស់គាត់ ដែលលេចឡើងនៅក្នុងការងាររបស់គាត់ដែលបង្ហាញអំពីចរិត "ព្រៃ" និងកម្រោលរបស់មនុស្សខ្មែរ អាចរំខានដោយច្រើនប្រការ[2273]។

២២២៩.ម្យ៉ាងវិញទៀត ការមិនដឹងភ័ស្តុតាងក្នុងសំណុំរឿងពីសំណាក់លោក Alexander HINTON ដែលធ្វើឱ្យគាត់បង្ខំចិត្តទទួលស្គាល់ថាបានតាមដានសវនាការតែខ្លះៗ និងបានពិនិត្យតែឯកសារខ្លះៗនៅក្នុងវែបសាយត៍របស់ អ.វ.ត.ក[2274] មិនអាចឱ្យគាត់មានសិទ្ធិធ្វើការអះអាងដាច់ណាត់បែបនេះទេ។

---

11.13.01.៖ ប្រតិចារិក ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/404.1** ទំព័រ ២៧-២៨ ប្រហែលម៉ោង 09.52.37 ទំព័រ ២៩-៣០ ប្រហែលម៉ោង 09.57.17 ទំព័រ ៣២ ប្រហែលម៉ោង 10.00.50 ទំព័រ ៣៦-៣៨ ពីម៉ោង 10.09.07 ដល់ម៉ោង 10.12.39 ទំព័រ ៦៧-៧៣ ពីម៉ោង 11.26.50 ដល់ម៉ោង 11.39.21។

[2271] សូមមើលខាងលើ កថាខណ្ឌ ៨០២-៨១១។

[2272] សូមមើលខាងលើ កថាខណ្ឌ ៧៣៤-៧៤០។

[2273] សៀវភៅរបស់លោក Alexander HINTON, *Why Did They Kill? Cambodia in the Shadow of Genocide* **ឯកសារ E3/3346**, ERN EN 00431658-59។

[2274] ប្រតិចារិក ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/403.1** ទំព័រ ៩៦ នៅម៉ោង 15.51.11។

ឧទាហរណ៍ អង្គជំនុំជម្រះគួរតែនៅចងចាំអំពីគោលជំហររបស់គាត់ទៅលើសុន្ទរកថារបស់សម្តេច សីហនុ ក្រោយឆ្នាំ ១៩៧៩ ដែលស្តែងឱ្យឃើញអំពីភាពអគតិតាមបែបប្រលោមលោកជាជាងវិទ្យាសាស្ត្រ នៅក្នុងការ "វិភាគ" នយោបាយរបស់គាត់[2275]។

២២៣០. ភាពជំនាញរបស់គាត់នៅមានកម្រិត។ គួររំឭកផងដែរថា សៀវភៅរបស់គាត់ "ហេតុអ្វីបានជាពួកគេសម្លាប់មនុស្ស" គឺជាផ្នែកផ្តានៃការងារស្រាវជ្រាវមានកម្រិតខាងភូមិសាស្ត្រ និងកាលវេលា[2276]។ ប្រភពចម្បង ដែលបានប្រើប្រាស់នៅក្នុងសៀវភៅរបស់គាត់ មិនអាចឱ្យភាគីពិនិត្យផ្ទៀងផ្ទាត់បាន ដោយសារតែកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់ តម្រូវដោយ "ពិធីសារស្រាវជ្រាវ" របស់នរវិទូ[2277]។

២២៣១. អង្គជំនុំជម្រះតុលាការកំពូលបានគូសបញ្ជាក់ថា៖ "ករណីដែលប្រភពដើមពុំអាចទទួលបាន និងផ្ទៀងផ្ទាត់ពេញលេញ ភ័ស្តុតាងរបស់អ្នកជំនាញនេះត្រូវផ្តល់ទម្ងន់ខ្សោយ ដោយសារលទ្ធភាពត្រូវបានរឹតត្បិតសម្រាប់ភាគី និងតុលាការ សួរដេញដោលលើការសន្និដ្ឋានរបស់អ្នកជំនាញនោះ"[2278]។ ទោះបីជាការងារនរវិទ្យារបស់សាស្ត្រាចារ្យសាកលវិទ្យាល័យរូបនេះ ទទួលបានការកោតសរសើរពីសំណាក់សហសេវិករបស់គាត់ក៏ដោយ ក៏នេះជារឿងមួយផ្សេង ប៉ុន្តែ ត្រូវចេះទទួលស្គាល់ដែនកំណត់ជាសត្យានុម័តិ ក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០២។ លោក Alexander HINTON ក៏បានទទួលស្គាល់ផងដែរថា លោក Ben KIERNAN គឺជាប្រភពដ៏សំខាន់ សម្រាប់សៀវភៅរបស់

---

[2275] ប្រតិចារឹក ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/402.1** ទំព័រ ៩២-៩៣ នៅម៉ោង 16.00.54។ ប្រតិចារឹក ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/403.1** ទំព័រ ២៣ ប្រហែលម៉ោង 09.59.00។

[2276] ប្រតិចារឹក ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/404.1** ទំព័រ ១៤ នៅម៉ោង 09.43.15 : « ជាថ្មីម្តងទៀត <ខ្ញុំផ្តោតការសិក្សាស្រាវជ្រាវរបស់ខ្ញុំ> គឺ <នៅត្រង់ការ> ពិភាក្សាលើបទពិសោធន៍ប្រជាជនមកពីភូមិពោធិ៍»។ សូមមើលខាងលើ កថាខណ្ឌ ១៩៣៥-១៩៣៧។

[2277] ប្រតិចារឹក ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/401.1** ទំព័រ ១៣ ប្រហែលម៉ោង 09.40.51។ ប្រតិចារឹក ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/402.1** ទំព័រ ១៦-១៧ ពីម៉ោង 09.49.59 ដល់ម៉ោង 09.51.25។ ប្រតិចារឹក ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/403.1** ទំព័រ ៦ បន្ទាប់ពីម៉ោង 09.15.54 ទំព័រ ៩៧ ប្រហែលម៉ោង 15.53.58។

[2278] សាលដីកា ០០២/០១ កថាខណ្ឌ ៣២៩។

គាត់[2279]។ ក៏ប៉ុន្តែ ដោយហេតុថាលោក Ben KIERNAN មិនបានមកផ្តល់សក្ខីកម្ម ការងារស្រាវជ្រាវរបស់គាត់មានតម្លៃជាភស្តុតាងតិចតួចបំផុត[2280]។

២២៣២. ដើម្បីត្រឡប់មកនិយាយអំពីបញ្ហាសុន្ទរកថារបស់បក្សកុម្មុយនីស្តកម្ពុជា វាជាការសំខាន់ក្នុងការពិនិត្យមើលសុន្ទរកថាទាំងនេះក្នុងបរិបទនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម ដែលជាចំណុចស្នូលនៃសេចក្តីថ្លែងការណ៍ផ្លូវការទាំងនេះ។ យើងទទួលស្គាល់ថាសម្តីនៅក្នុងសុន្ទរកថាពិតជាមានភាពធ្ងន់ធ្ងរ ប៉ុន្តែ យើងកម្រឃើញមានសុន្ទរកថារបស់មេដឹកនាំប្រទេសណាមួយក្នុងពេលសង្គ្រាមនិយាយទៅកាន់ប្រទេសជាសត្រូវក្នុងពាក្យពេចន៍រាក់ទាក់នោះណាស់។ ម្យ៉ាងវិញទៀត បើយើងមានឱកាសបែរទៅវិភាគខ្លឹមសារនៃសុន្ទរកថារបស់មន្ត្រីសាធារណរដ្ឋសង្គមនិយមវៀតណាម អំពីកម្ពុជាប្រជាធិបតេយ្យ ក្នុងពេលមានជម្លោះពេញបន្ទុកនោះ វាច្បាស់ណាស់ថា គេនឹងឃើញមានភាសាស្រដៀងគ្នានេះពីខាងវៀតណាម។

២២៣៣. ទោះបីជាសហព្រះរាជអាជ្ញាបានព្យាយាមបង្ហាញឱ្យឃើញអំពីចរិតរើសអើងពូជសាសន៍ នៃរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីផ្តល់យុត្តិកម្មដល់គោលនយោបាយប្រឆាំងនឹងជនស៊ីវិលវៀតណាមក៏ដោយ[2281] ក៏ការវិភាគជាសត្យានុម័តិទៅលើសុន្ទរកថា និងឯកសារពីសម័យនោះ ស្តែងឱ្យឃើញជាចម្បងអំពីសង្គ្រាមរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម គឺមិនមានការរើសអើងទៅលើប្រជាជនវៀតណាមនោះឡើយ។ ម្យ៉ាងវិញទៀត លោក Steve HEDER បានបដិសេធអំណះអំណាងថា របបកម្ពុជាប្រជាធិបតេយ្យអាចរើសអើងពូជសាសន៍[2282]។

---

[2279] ប្រតិចារឹក ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/402.1** ទំព័រ ៧១ បន្ទាប់ពីម៉ោង 15.04.48។

[2280] សាលដីកា ០០២/០១ កថាខណ្ឌ ៣៣៤, ១០១៥។

[2281] ប្រតិចារឹក ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/390.1** ទំព័រ ៥៨ ពីម៉ោង 14.33.20 ដល់ម៉ោង 14.36.22។

[2282] អត្ថបទសរសេរដោយលោក Steve HEDER មានចំណងជើងថា *"ជាតិសាសន៍និយម លទ្ធិម៉ាក្សនិយម ការកំណត់ក្រុមគោលដៅ និងអំពើប្រល័យពូជសាសន៍"*នៅក្នុងសៀវភៅ "របបប៉ុល ពត" របស់លោក Ben Kiernan **ឯកសារ E3/3995**។ អត្ថបទនេះត្រូវបានមេធាវីការពារក្តី បានលើកឡើងនៅក្នុងសវនាការដែលពិភាក្សាអំពីឯកសារគន្លឹះស្តីពីជនជាតិវៀតណាម ៖ « នៅក្នុងការព្យាយាមរបស់គាត់ដើម្បីលើកទឡ្ហីករណ៍ផ្សេងពីនេះ Kiernan លើកឡើងនូវអង្គហេតុដែលថាជនរងគ្រោះភូមិភាគបូព៌ាជាច្រើនត្រូវបានគេប្រើពាក្យបន្ទះបង្អាប់ថាជា "ក្បាលយួនខ្លួនខ្មែរ" [...] ដែលគាត់បកប្រែថា "ខ្លួនខ្មែរចិត្តគំនិតយួន" និងដែលគាត់សំដៅទៅលើអ្នកទាំងឡាយដែលត្រូវបានគេរើសអើងប្រកាន់ពូជសាសន៍ដែលត្រូវបានសម្លាប់។ ឃ្លានេះដែលអាចបកប្រែផងដែរថា "ក្បាលយួនខ្លួនខ្មែរ" ត្រូវបានគេយកមកប្រើតាំងពីយូរយារណាស់មកហើយដើម្បី ធ្វើឱ្យនឹកឃើញនូវរូបភាពនៃរចនាសម្ព័ន្ធ

## ផ្នែកទី ៣. សង្គ្រាមប្រឆាំងនឹងរដ្ឋមួយ គឺមិនមែនប្រឆាំងនឹងប្រជាជនស៊ីវិលនោះទេ

២២៣៤. យើងគួរត្រឡប់មកនិយាយអំពីសុន្ទរកថាមួយចំនួនរបស់បក្សកុម្មុយនីស្តកម្ពុជា ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨ ដែលត្រូវបានលើកឡើងយ៉ាងទូលំទូលាយ នៅក្នុងសវនាការ (ក) និងអំពីឯកសារផ្សេងទៀតពីសម័យនោះដែលនិយាយអំពីជនជាតិវៀតណាម ក្នុងក្របខ័ណ្ឌនៃជម្លោះប្រដាប់អាវុធ (ខ) ដើម្បីឱ្យយល់ថា ពិតជាមានការបែងចែករវាងវៀតណាមជារដ្ឋសត្រូវ និងជនស៊ីវិលវៀតណាម។ អវត្តមាននៃភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ អំពីការសម្លាប់រង្គាលជនស៊ីវិលវៀតណាម នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ជាសេចក្តីសន្និដ្ឋានសមហេតុផលថាគ្មានគោលនយោបាយប្រឆាំងនឹងជនស៊ីវិលវៀតណាម (គ)។

### ១. សុន្ទរកថាក្នុងពេលសង្គ្រាម

២២៣៥. មុននឹងវិភាគអំពីសុន្ទរកថានៅសម័យនោះ គួររំឭកថាសហចៅក្រមស៊ើបអង្កេតបានយកសុន្ទរកថាមួយចំនួនរបស់លោក ខៀវ សំផន មកធ្វើជាមូលដ្ឋានគាំទ្រដល់ការយល់ឃើញអំពីការចូលរួមក្នុងការតាក់តែង ឬអនុវត្តគោលនយោបាយប្រឆាំងនឹងជនជាតិវៀតណាម[2283]។

---

នយោបាយខ្មែរក្រោមការដឹកនាំរបស់វៀតណាម។ ការលើកឡើងរបស់ Kiernan ដែលថាឃ្លានេះត្រូវបានគេប្រើដើម្បីគាបសង្កត់ "ខ្មែរភាគច្រើន... ដោយមូលហេតុពូជសាសន៍ដែលពួកគេពិតជាមិនមែនជនជាតិខ្មែរគឺមិនពេញលេញឡើយ។ ផ្ទុយទៅវិញឃ្លានេះបង្ហាញថាការដឹកនាំនយោបាយនិងជំនឿនយោបាយ ត្រូវបានគេចាត់ទុកថាមានសារៈសំខាន់ជាលក្ខណៈនៃរាងកាយជីវសាស្ត្រមានរូបរាងកាយឬពូជសាសន៍ជាជនជាតិខ្មែរ ពុំទទួលបាននូវការការពារឡើយ ៖ អំពើក្បត់វណ្ណៈនិងបុព្វហេតុជាតិ គឺជារឿងនយោបាយ ហើយមិនអាចប្រព្រឹត្តទៅដោយនរណាម្នាក់ ដោយមិនគិតអំពីពណ៌សម្បុរ ទ្រង់ទ្រាយ ភ្នែក ឬសក់ ដែលត្រូវបានគេសង្ស័យថាបដិសេធមិនទទួលយកនិងមិនស្មោះត្រង់ចំពោះមាគ៌ានយោបាយដ៏ត្រឹមត្រូវនៃការដឹកនាំរបស់ "មេដឹកនាំចលនាអធន" ឡើយ»។ សូមមើលផងដែរ ប្រតិចារិក ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/391.1** ទំព័រ ៦៥-៦៦ ពីម៉ោង 11.25.14 ដល់ម៉ោង 11.28.17។

[2283] ដីកាដំណោះស្រាយ កថាខណ្ឌ ១១៩០-១១៩៨។

២២៣៦. ជាក់ស្តែង សហចៅក្រមស៊ើបអង្កេតយល់ឃើញថាសុន្ទរកថារបស់លោក ខៀវ សំផន អំពីជនជាតិវៀតណាម មានគោលដៅញុះញង់ឱ្យស្អប់ខ្ពើម និងភ័យខ្លាច ដែលជំរុញឱ្យប្រជាជនប្រឆាំងនឹងជនជាតិនេះ[2284]។ ក្រៅពីនេះទៀត សុន្ទរកថាទាំងនេះត្រូវបានថ្លែង ក្នុងបរិបទនៃការសម្លាប់រង្គាលលើជនជាតិវៀតណាមក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង[2285]។ ដូច្នេះ យើងត្រូវវិភាគខ្លឹមសារ និងបរិបទនៃសេចក្តីថ្លែងការណ៍ចំនួនបីរបស់លោក ខៀវ សំផន ចន្លោះពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨ ដែលត្រូវបានដកស្រង់នៅក្នុងដីកាដំណោះស្រាយ[2286]។

២២៣៧. យើងត្រូវបង្ហាញអំពីភាពមិនស៊ីសង្វាក់គ្នា ក្នុងការបកស្រាយសុន្ទរកថាទាំងនេះដោយសហចៅក្រមស៊ើបអង្កេត។ ជាក់ស្តែង នៅប៉ុន្មានទំព័រក្រោយមកក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់សេចក្តីថ្លែងការណ៍ដដែលដើម្បីបង្ហាញថា លោក ខៀវ សំផន ដឹងអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ[2287]។ នេះគឺទទួលស្គាល់ថា (ដោយមិនទាញផលវិបាកគតិយុត្ត) បរិបទនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម មានសារៈសំខាន់ដើម្បីឱ្យយល់សុន្ទរកថាទាំងនេះ។

២២៣៨. ដូចគ្នាផងដែរចំពោះសហព្រះរាជអាជ្ញា ដែលបានបង្ហាញសុន្ទរកថារបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជាច្រើនដង ដោយដកស្រង់សម្តីខុសបរិបទ ដើម្បីអះអាងថាជនស៊ីវិលវៀតណាមត្រូវបានកំណត់មុខសញ្ញា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ផ្ទុយទៅវិញ ខ្លឹមសារនៃសុន្ទរកថាពីសម័យនោះ ដែលត្រូវបានបង្ហាញក្នុងលំដាប់កាលប្បវត្តិ ស្តែងឱ្យឃើញយ៉ាងច្បាស់ថា មានតែវៀតណាមក្នុងឋានៈជារដ្ឋសត្រូវរបស់កម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ដែលត្រូវបានកំណត់គោលដៅ។

---

[2284] ដីកាដំណោះស្រាយ កថាខណ្ឌ ១១៩៦។

[2285] ដីកាដំណោះស្រាយ កថាខណ្ឌ ១១៩៧។

[2286] សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប ភ្នំពេញ វិទ្យុជាតិ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ **ឯកសារ E3/201** (មានលេខកូដ **ឯកសារ E3/200** ផងដែរ)។ ការផ្តាច់ទំនាក់ទំនងមួយរយៈរវាងប្រទេសកម្ពុជា និងវៀតណាម សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៧៧ **ឯកសារ E3/267**។ សុន្ទរកថាដោយសមមិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យនៅឯកិច្ចប្រជុំមហាជនមួយក្នុងឱកាសខួបលើកទី៣ថ្ងៃជ័យជំនះ ១៧ មេសា និងការបង្កើតកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ **ឯកសារ E3/202** (មានលេខកូដ **ឯកសារ E3/562** ផងដែរ)។

[2287] ដីកាដំណោះស្រាយ កថាខណ្ឌ ១២០០ ស្តីពីតួនាទីរបស់ ខៀវ សំផន។

## ក. សុន្ទរកថារបស់លោក ខៀវ សំផន នៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧

២២៣៩. ក្នុងមិទ្ទីងនៅទីក្រុងភ្នំពេញ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ លោក ខៀវ សំផន បានថ្លែងសុន្ទរកថាដើម្បីរំឭកខួបជ័យជម្នះ ១៧ មេសា[2288]។ សុន្ទរកថានេះមានគោលដៅជាចម្បងអបអរសាទរប្រជាជនកម្ពុជាប្រជាធិបតេយ្យ ក្នុងកិច្ចខិតខំប្រឹងប្រែងកសាងប្រទេស។ ប្រធានបទនៃការការពារជាតិត្រូវបានលើកឡើងដោយខ្លី។ លោក ខៀវ សំផន បានថ្លែងថា៖

> "ក្នុងវិស័យការពារកម្ពុជាប្រជាធិបតេយ្យ ការពាររដ្ឋបាលកម្មករ-កសិករយើង និងថែរក្សាយុទ្ធផលបដិវត្តន៍របស់យើង យើងអាចធ្វើបានទាំងស្រុង ដោយឯករាជ្យម្ចាស់ការ និងគ្មានភាពស្មុគស្មាញ ឬការបារម្ភ ដោយហេតុថាកងទ័ពរបស់យើង ដោយសហការជាមួយកម្មករនៃសហជីពយើង កសិករនៃសហករណ៍យើង និងមូលដ្ឋានផ្សេងៗ មិនអនុញ្ញាតឱ្យខ្មាំងជ្រៀតចូលដែនទឹក ឬដែនគោកយើង ឬធ្វើវិទ្ធង្សនាកម្មបដិវត្តន៍កម្ពុជាយើងជាដាច់ខាត ទោះជាមកពីខាងក្រៅ ឬមកពីខាងក្នុងក៏ដោយ។ [...] បន្ទាប់ពីរំដោះភ្លាម នៅពេលយើងទទួលរងនូវការលំបាកមិនអាចថ្លាថ្លែងបាន ដោយសារតែយើងទើបតែងើបពីសង្គ្រាមមហាវិនាសកម្មរបស់ពួកចក្រពត្តិអាមេរិក ខ្មាំងបានទទួលបរាជ័យក្នុងការធ្វើឱ្យយើងជួបភាពវឹកវរធ្ងន់ធ្ងរ។ សព្វថ្ងៃនេះ ខ្មាំងពិតជាមិនអាចធ្វើអ្វីយើងបានទេ។ នេះគឺជាជំនឿដ៏មុតមាំរបស់យើង ស្តែងចេញពីភ័ស្តុតាងដ៏ប្រត្យក្ស។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី យើងត្រូវបន្តភារកិច្ចការពារកម្ពុជាប្រជាធិបតេយ្យយើង ការពាររដ្ឋបាលកម្មករ-កសិករយើង ថែក្សាយុទ្ធផលបដិវត្តន៍កម្ពុជាយើង តាមរយៈការកម្ទេចឱ្យបានជាដាច់ខាតនូវខ្មាំងគ្រប់ប្រភេទ ទប់ស្កាត់មិនឱ្យពួកវាឈ្លានពាន ជ្រៀតជ្រែក ឬធ្វើវិទ្ធង្សនាប្រឆាំងយើង។ យើងត្រូវបោសសម្អាតខ្មាំង ដោយម្ចាស់ការតាមមាគ៌ានយោបាយក្នុងប្រទេស មាគ៌ានយោបាយក្រៅប្រទេស និងមាគ៌នយោបាយយោធារបស់អង្គការបដិវត្តន៍យើង។ យើងត្រូវធ្វើអ្វីៗគ្រប់យ៉ាងឱ្យបានល្អ និងគ្រប់ជ្រុងជ្រោយ។ យើងមិនត្រូវមានចិត្តរាយមាយធ្វេសប្រហែស ឬភ្លេចភ្លាំង ដោយសារតែជ័យជម្នះពីអតីតកាលទេ។ ផ្ទុយទៅវិញ យើងត្រូវតែក្លាហានថែមទៀត ត្រៀមលក្ខណៈជាប់ជានិច្ច រក្សាស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ឥតងាករេ និងបន្តវាយប្រយុទ្ធ និងកម្ទេចខ្មាំងគ្រប់ប្រភេទ គ្រប់ពេលវេលា។"[2289]។

២២៤០. ទោះបីជាវៀតណាមមិនត្រូវបានហៅចំៗនៅក្នុងសុន្ទរកថានេះក៏ដោយ ក៏ការថ្លែងរបស់លោក ខៀវ សំផន ពីការទប់ស្កាត់ខ្មាំងមិនឱ្យប្រព្រឹត្តអំពើឈ្លានពាន សំដៅដល់ការទាស់ទែងគ្នានៅតាមព្រំដែន

---

[2288] សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប ភ្នំពេញ វិទ្យុជាតិ ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ **ឯកសារ E3/201** ។

[2289] សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប ភ្នំពេញ វិទ្យុជាតិ ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ **ឯកសារ E3/201,** ERN KH 00287220។

វៀតណាម ដែលកាន់តែមានច្រើន និងតានតឹងឡើងៗ នៅសម័យនោះ។ សុន្ទរកថានេះឆ្លុះបញ្ចាំងអំពីសុន្ទរកថាលោក អៀង សារី ថ្លែងនៅចំពោះមុខអង្គការសហប្រជាជាតិ ដែលបានលើកឡើងពីខាងលើ[2290]។ ដូច្នេះ សម្ដីរបស់លោក ខៀវ សំផន ជំរុញឱ្យកងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យការពារប្រទេស ប្រឆាំងនឹងខ្មាំងដែលប្រព្រឹត្តអំពើឈ្លានពាន។ ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតថា គាត់អំពាវនាវឱ្យ “ប្រជាជនប្រយុទ្ធជាមួយពួកវៀតណាម” គឺជាការនិយាយព្រាវៗ[2291]។ សម្ដីទាំងនេះមិនអាចឱ្យបង្ហាញអំពីគោលនយោបាយប្រឆាំងនឹងជនជាតិវៀតណាមក្នុងឋានៈជាក្រុមមួយ ដូចដែលសហព្រះរាជអាជ្ញាបានអះអាងនោះទេ[2292] គឺគ្រាន់តែលើកឡើងអំពីការការពារទឹកដីជាតិ នៅសម័យកាលដែលបក្សកុម្មុយនីស្តកម្ពុជាមិននិយាយដោយចំហអំពីជម្លោះកំពុងកើតឡើង។

## ខ. <u>សេចក្ដីថ្លែងការណ៍របស់លោក ខៀវ សំផន ក្នុងពេលផ្ដាច់ទំនាក់ទំនងជាមួយវៀតណាមនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧</u>

២២៤១. សេចក្ដីថ្លែងការណ៍របស់លោក ខៀវ សំផន ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ នេះ ក៏ត្រូវបានសហចៅក្រមស៊ើបអង្កេតយកមកប្រើប្រាស់ផងដែរ ដើម្បីអះអាងថាគាត់បានចូលរួមក្នុងការតាក់តែង ឬអនុវត្តគោលនយោបាយមួយប្រឆាំងនឹងជនជាតិវៀតណាម ដោយអំពាវនាវឱ្យ “ប្រជាជនប្រយុទ្ធជាមួយពួកវៀតណាម”[2293]។ ជាថ្មីម្ដងទៀត ឃ្លាទូទៅនេះមិនគិតដល់បរិបទសង្គ្រាម ខណៈដែលថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ គឺជាកាលបរិច្ឆេទដ៏សំខាន់ នៅក្នុងជម្លោះ។

២២៤២. ជាក់ស្ដែង នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ក្រោយពីកងទ័ពវៀតណាមច្រើនសន្ធឹកសន្ធាប់ចូលមកក្នុងទឹកដីកម្ពុជា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានសម្រេចចិត្តផ្ដាច់ទំនាក់ទំនងការទូតជាផ្លូវការជាមួយវៀតណាម[2294]។ សេចក្ដីថ្លែងការណ៍នេះ គឺជាភាគសំខាន់នៃសុន្ទរកថា ក្នុងពេលមានជម្លោះ

[2290] សូមមើលខាងលើ កថាខណ្ឌ ៧២៨-៧២៩។

[2291] ដីកាដំណោះស្រាយ កថាខណ្ឌ ១១៩០ កំណត់សម្គាល់ចុងឯកសារ ៤៨៦៤។

[2292] ប្រតិចារឹក ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/390.1** ទំព័រ ៣២ បន្ទាប់ពីម៉ោង 11.12.33។

[2293] ដីកាដំណោះស្រាយ កថាខណ្ឌ ១១៩០។

[2294] សូមមើលខាងលើ កថាខណ្ឌ ៨១០។

ដែលចោលទោសការឈ្លានពានខាងយោធា ក៏ដូចជាលើកទឹកចិត្តកងទ័ព និងប្រជាជនកម្ពុជាឱ្យរក្សាការប្រុងប្រយ័ត្នបដិវត្តន៍ប្រឆាំងនឹងជនឈ្លានពានវៀតណាម[2295]។

២២៤៣. ច្បាស់ណាស់ សាររបស់លោក ខៀវ សំផន គឺជាការអំពាវនាវឱ្យកងទ័ពប្រយុទ្ធនឹងខ្មាំងយោធាវៀតណាម និងជាសារលើកទឹកចិត្តឱ្យគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងធ្វើសង្គ្រាម។ គ្មានអ្វីត្រូវសង្ស័យទេថា ខ្មាំងនោះសំដៅដល់រដ្ឋវៀតណាម៖ "កងទ័ពបដិវត្តន៍កម្ពុជា និងប្រជាជនសម្ពហាភាពកម្ពុជាទាំងមូល ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រាកដជានឹងបណ្តេញខ្មាំងយួនវាតទី លេបទឹកដីឱ្យចេញអស់ពីទឹកដីកម្ពុជាទាំងស្រុង"[2296]។

២២៤៤. ក្រោយពីសារ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ឯកសារមួយចេញពីកងទ័ពកម្ពុជាប្រជាធិបតេយ្យត្រូវបានសរសេរតប ដោយលើកឡើងអំពីការវាយប្រហារផ្សេងៗ និងឧប្បត្តិហេតុកើតឡើងនៅតាមព្រំដែន ជាមួយកងកម្លាំងវៀតណាម ហើយត្រូវបានរៀបរាប់នៅក្នុងសុន្ទរកថារបស់លោក ខៀវ សំផន[2297]។

## គ. សុន្ទរកថារបស់ ប៉ុល ពត នៅខែ មេសា ឆ្នាំ ១៩៧៨

២២៤៥. សុន្ទរកថារបស់ ប៉ុល ពត ចុះខែ មេសា ឆ្នាំ ១៩៧៨ ត្រូវបានសហព្រះរាជអាជ្ញាយកមកប្រើប្រាស់ជាច្រើនដង ជាពិសេស នៅក្នុងសវនាការស្តីពីឯកសារគន្លឹះ ពាក់ព័ន្ធនឹងជនជាតិវៀតណាម[2298]។ ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញា នៅក្នុងវគ្គស្តីពីជម្លោះប្រដាប់អាវុធ មានការពន្យល់ថាពុំ

---

[2295] ការផ្តាច់ទំនាក់ទំនងជាមួយវៀតណាមទាំងស្រុងជាបណ្តោះអាសន្នរបស់កម្ពុជា ថ្ងៃទី ៣១ ធ្នូ ឆ្នាំ ១៩៧៧ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៨**ឯកសារ E3/267**។

[2296] ការផ្តាច់ទំនាក់ទំនងជាមួយវៀតណាមទាំងស្រុងជាបណ្តោះអាសន្នរបស់កម្ពុជា ថ្ងៃទី ៣១ ធ្នូ ឆ្នាំ ១៩៧៧ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៨**ឯកសារ E3/267**, ERN KH 00680579។

[2297] កងទ័ពកម្ពុជាអនុម័តសេចក្តីសម្រេចស្តីពីជម្លោះជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៧៨**ឯកសារ E3/1285**, ERN KH 00244271។

[2298] ប្រតិចារឹក ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/390.1** ទំព័រ ៤៦-៤៨ ចន្លោះម៉ោង [១៣.៥៩.១២] និង [១៤.០៤.៣៦]។

អាចចាត់ទុកសុន្ទរកថានេះជាការញុះញង់ឱ្យវាយប្រហារ ទៅលើជនស៊ីវិលវៀតណាមបានទេ[2299]។ ច្បាស់ណាស់ នេះជាសុន្ទរកថាមួយ ដែលមានគោលដៅលើកទឹកចិត្តកងទ័ពកម្ពុជាប្រជាធិបតេយ្យ ក្នុងការប្រយុទ្ធនាពេលខាងមុខជាមួយវៀតណាម គឺភ្លាមៗក្រោយពីកងទ័ពសត្រូវចូលជ្រៅទៅក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ[2300]។ សុន្ទរកថានេះគ្រាន់តែសំដៅបង្ហាញការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងធ្វើសង្គ្រាម ដូចសាក្សីជាយោធាជាច្រើននាក់បានបញ្ជាក់អះអាង នៅក្នុងសវនាការ[2301]។

## ឃ. សុន្ទរកថារបស់លោក ខៀវ សំផន នៅថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨

២២៤៦. សុន្ទរកថាទីបីរបស់លោក ខៀវ សំផន ថ្លែងនៅក្នុងតួនាទីនិមិត្តរូបជាប្រធានគណៈប្រធានរដ្ឋ ត្រូវបានធ្វើឡើង នៅក្នុងបរិបទដូចគ្នានឹងបរិបទនៃសុន្ទរកថារបស់ ប៉ុល ពត ដែរ[2302]។ បើតាមសហចៅក្រមស៊ើបអង្កេត សុន្ទរកថានេះរៀបរាប់ថា "វៀតណាមជាខ្មាំងសត្រូវឈ្លានពាន ពួកវាគតទីនិយម និងពួកលេបទឹកដីនិយម ដែលមានមហិច្ឆតាលេបទឹកដីកម្ពុជា ស្របតាមផែនការសហព័ន្ធឥណ្ឌូចិនរបស់វា"[2303]។ ក្រៅពីនេះទៀត នៅក្នុងកថាខណ្ឌ ១១៩៧ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានរៀបរាប់ថា លោក ខៀវ សំផនៈ

> "បានបញ្ជាក់ថា កិច្ចការទីមួយរបស់ប្រជាជន គឺត្រូវការពារប្រទេសប្រឆាំងនឹងពួកវៀតណាម ដែលជាចារកម្ម បង្កើតក្រុម និងប៉ុនប៉ងធ្វើរដ្ឋប្រហារនៅកម្ពុជា តាមរយៈការអនុវត្តឱ្យបានត្រឹមត្រូវតាមមាគ៌ាបក្ស ទាំងកិច្ចការពារផ្នែកខាងក្រៅ និងខាងក្នុង។ ខៀវ សំផន បានលើកឡើងថា សកម្មភាពប្រចាំថ្ងៃរបស់យើង គឺត្រូវ

---

[2299] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៧៣៤-៧៤០។

[2300] ទង់បដិវត្ត "បទឧទ្ទេសនាមរបស់សមមិត្តលេខាបក្សកុម្មុយនីស្តកម្ពុជា ក្នុងឱកាសអបអរសាទរខួបទី៣ នៃមហាជ័យជម្នះ ១៧ មេសា [...]" ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ **ឯកសារ E3/4604** ERN 00064710។

[2301] ព្រុំ សារ៉ាត ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/382.1** ទំព័រ ២២-២៣ ចន្លោះម៉ោង [១៣.៣៤.៤៨] និង [១៣.៤២.២៤], ជួន ធី ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៧១ ប្រហែលម៉ោង [១៥.១៦.៣១], 2-TCW-859 ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៧៣ ប្រហែលម៉ោង [១៥.២៣.០៦]។

[2302] សុន្ទរកថាសមមិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ក្នុងឱកាសមិទ្ទីងមហាជនដើម្បីគម្រប់ខួបលើកទី៣ ថ្ងៃជ័យជម្នះ ១៧ មេសា និងការបង្កើតកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ **ឯកសារ E3/202**។ សុន្ទរកថានេះត្រូវបានរាយការណ៍ផងដែរនៅក្នុងរបាយការណ៍ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ "មិទ្ទីងនៅក្រុងភ្នំពេញ ដើម្បីរំឭកខួបថ្ងៃ ១៧ មេសា" ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ **ឯកសារ E3/562** (ភាសាអង់គ្លេស)។

[2303] ដីកាដំណោះស្រាយ កថាខណ្ឌ ១១៩៦។

លុបបំបាត់ពួកខ្មាំងសត្រូវឈ្លានពានគ្រប់ប្រភេទឱ្យបានជាស្ថាពរ និងជារៀងរហូតពីទឹកដីកម្ពុជា ជាពិសេស អំពើឧក្រិដ្ឋនៃពួកឈ្លានពានវៀតណាម ពួកវាតទីនិយម និងពួកលេបទឹកដី"។

២២៤៧. សេចក្តីដកស្រង់ទាំងនេះមិនបង្ហាញអំពីការញុះញង់ឱ្យស្អប់ខ្ពើមប្រជាជនវៀតណាមឡើយ គឺគ្រាន់តែជាការអំពាវនាវឱ្យការពារប្រទេសប្រឆាំងនឹងខ្មាំងឃោឃៅយួន ដែលកំពុងស្ថិតនៅក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យនៅឡើយ កាលពីប៉ុន្មានខែមុន។ ពាក្យ "ជនឈ្លានពាន វាតទី និងលេបទឹកដី" ត្រូវបានប្រើប្រាស់ជាញឹកញាប់ មិនត្រឹមតែដោយសារអតីតកាលពោរពេញដោយភាពជ្រួលច្របល់នៃប្រទេសទាំងពីរប៉ុណ្ណោះទេ[2304] គឺថែមទាំងដើម្បីថ្កោលទោសការឈ្លានពានទ្រង់ទ្រាយធំខាងយោធាកាលពីពេលថ្មីៗ ដោយមិនអាចប្រកែកបាន ទៀតផង។

២២៤៨. ការពិនិត្យមើលឡើងវិញនូវបរិបទនៃសេចក្តីថ្លែងការណ៍ទាំងនេះបង្ហាញឱ្យឃើញថា សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា បានបំភ្លៃខ្លឹមសារសុន្ទរកថានេះ ដោយភ្ជាប់ទំនាក់ទំនងជាមួយនឹងការសម្លាប់រង្គាលជនស៊ីវិលវៀតណាម នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង។ ក្នុងករណីអង្គជំនុំជម្រះត្រូវសន្និដ្ឋានថាមានអំពើមនុស្សឃាតខ្លះនៅខេត្តទាំងពីរនេះ បើទោះបីជាមានភស្តុតាងមិនគ្រប់គ្រាន់ក៏ដោយ ក៏អង្គជំនុំជម្រះត្រូវតែទទួលស្គាល់ថាសុន្ទរកថានេះមិនពាក់ព័ន្ធនឹងអង្គហេតុទាំងនេះទេ។

២២៤៩. សហព្រះរាជអាជ្ញាក៏បានបំភ្លៃសុន្ទរថា ដោយមិនគិតដល់បរិបទ និងបានសន្និដ្ឋានថា "មានចេតនាសម្លាប់យុទ្ធជន និងមិនមែនយុទ្ធជន ដោយមិនរើសមុខ ដោយប្រើប្រាស់ពាក្យខ្លាំងគ្រប់ប្រភេទ និងភ្នាក់ងារយួនទាំងអស់"[2305]។ ជាក់ស្តែង ច្បាស់ណាស់ នេះជាការបកស្រាយខុស ពីព្រោះឃ្លាដែលបានដកស្រង់ សំដៅតែទៅលើកងទ័ពវៀតណាម ដែលបានចូលក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យកាលពីពេលថ្មីៗនេះ[2306]។

---

[2304] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៦៧៤-៦៧៦។

[2305] ប្រតិចារឹក ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/390.1** ទំព័រ ៤៦ មុនម៉ោង [១៣.៥៩.១២]។

[2306] របាយការណ៍ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ "មិទ្ទីងនៅក្រុងភ្នំពេញ ដើម្បីរំឭកខួបថ្ងៃ ១៧ មេសា" ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ **ឯកសារ E3/562** ERN 00280375, 00280380 (ភាសាបារាំង)។

ខ. សេចក្តីថ្លែងការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៧៩

២២៥០. សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនេះ ត្រូវបានធ្វើឡើង ប៉ុន្មានថ្ងៃមុនពេលរបបខ្មែរក្រហមដួលរលំ។ សេចក្តីថ្លែងការណ៍នេះបានថ្កោលទោសយ៉ាងដាច់អហង្ការចំពោះការឈ្លានពានជាច្រើនដងរបស់វៀតណាមមកលើទឹកដីកម្ពុជា និងបានប្រកាសថា យោងតាមការវាយប្រហារចុងក្រោយនេះ ឯករាជ្យភាពរបស់កម្ពុជាកំពុងទទួលរងនូវការគំរាមកំហែង។ វាជារឿងមិនសមហេតុផលទាល់តែសោះ ដែលសហព្រះរាជអាជ្ញាអាចផ្អែកលើសេចក្តីថ្លែងការណ៍នេះដើម្បីតវ៉ាថា "ជនជាតិវៀតណាមត្រូវបានគេកំណត់គោលដៅ ដោយសារតែពូជសាសន៍ខ្លួន មិនមែនដោយសារតែពួកគេជាយុទ្ធជននោះឡើយ"[2307]។ ជាក់ស្តែង ឯកសារនេះលើកឡើងតែអំពីកម្លាំងយោធា និងនយោបាយ ដែលជាប់ពាក់ព័ន្ធ ក្នុងសេចក្តីថ្កោលទោសស្តីពីការឈ្លានពានខាងយោធាពីសំណាក់វៀតណាមប៉ុណ្ណោះ[2308]។

២២៥១. ដូច្នេះ សុន្ទរកថាទាំងនេះត្រូវបានធ្វើឡើង ក្នុងពេលមានជម្លោះប្រដាប់អាវុធទ្រង់ទ្រាយធំជាមួយវៀតណាម។ ខ្លឹមសារនៃសុន្ទរកថាទាំងនេះមិនអាចត្រូវបានបកស្រាយផ្សេងក្រៅពីការសំដៅដល់សត្រូវរបស់កម្ពុជានោះឡើយ គឺរដ្ឋវៀតណាម។ អង្គជំនុំជម្រះត្រូវចៀសវាងប្រព្រឹត្តកំហុសដដែលនៃការបកស្រាយដដែល។ ក្នុងន័យដដែលនេះ អង្គជំនុំជម្រះគួរនៅចាំថា ការប្រើប្រាស់សុន្ទរកថារបស់លោក ខៀវ សំផន នៅកូរ៉េខាងជើង ស្តីពីការវាយយកឧដុង្គ ដើម្បីគាំទ្រដល់អត្ថិភាពនៃគោលនយោបាយមួយរបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានហាមឃាត់[2309]។ ជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលបានវិនិច្ឆ័យថា សម្តីនេះអាចត្រូវបានបកស្រាយថាជាការសំដៅលើការសម្លាប់ ក្នុងពេលប្រយុទ្ធ ដោយសារជម្លោះ[2310]។

២២៥២. ក្រៅពីនេះទៀត ទាក់ទងនឹងការប្រើប្រាស់ពាក្យ "ខ្មាំង" ដែលត្រូវបានលើកឡើងយ៉ាងទូលំទូលាយនៅក្នុងសុន្ទរកថាទាំងនេះ ដើម្បីនិយាយអំពីវៀតណាម ឬកម្លាំងយោធាវៀតណាម ក្នុងករណី

---

[2307] ប្រតិចារឹក ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/390.1** ទំព័រ ៥០ មុនម៉ោង [១៤.១២.០៣]។

[2308] ប្រតិចារឹក ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/392.1** ទំព័រ ៣០ ក្រោយម៉ោង [១០.៤៥.១៩]។

[2309] សាលក្រម ០០២/០១ កថាខណ្ឌ ១២៥។

[2310] សាលដីកា ០០២/០១ កថាខណ្ឌ ៨៨៣។

អង្គជំនុំជម្រះយល់ឃើញថាមុខសញ្ញាផ្សេងទៀតក្រៅពីមុខសញ្ញាឃោជា ត្រូវបានកំណត់ដោយពាក្យនេះ អង្គជំនុំជម្រះត្រូវពន្យល់នូវទឡ្ហីករណ៍របស់ខ្លួន[2311]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានគូសបញ្ជាក់ផងដែរថា សុន្ទរកថាឃោសនាប្រភេទនេះមានទំនោរបំផ្លើស ឬបំប៉ោងតួលេខ ដែលកាត់បន្ថយភាពគួរឱ្យជឿជាក់បាន[2312]។

## ២. ឯកសារពីសម័យនោះផ្សេងទៀត ដែលលើកឡើងអំពីវៀតណាម

២២៥៣. ដូចសុន្ទរកថាដែរ ឯកសារពីសម័យនោះជាច្រើនសំដៅដល់ជម្លោះប្រដាប់អាវុធជាមួយវៀតណាម និងអស្ថិរភាពនៅជិតព្រំដែន ឧទាហរណ៍ ជាអាទិ៍ ទស្សនាវដ្ដី “ទង់បដិវត្តន៍” និង “យុវជន-យុវនារីបដិវត្តន៍” ដែលចេញផ្សាយ ចាប់ពីខែ មេសា ឆ្នាំ ១៩៧៧[2313]។ ការសំដៅដល់វៀតណាមមានភាពស្រដៀងគ្នា នៅក្នុងទស្សនាវដ្ដីទាំងនេះភាគច្រើន។ ឧទាហរណ៍ ទស្សនាវដ្ដីទង់បដិវត្តន៍ ខែ មេសា ឆ្នាំ ១៩៧៧ ដែលត្រូវបានសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា យកមកប្រើប្រាស់[2314] និយាយសំដៅដល់រដ្ឋវៀតណាម ក្នុងឋានៈជា “ខ្មាំង” និង “ភ្នាក់ងារយួន” ដែលត្រូវប្រយុទ្ធ ដើម្បីការពារទឹកដី[2315]។ គួររំឭកថាកម្មាភិបាលផ្ដាច់ខ្លួនជាច្រើនបានរត់ភៀសខ្លួនពីកម្ពុជាប្រជាធិបតេយ្យទៅវៀតណាម ហើយត្រូវបានវៀតណាមបំពាក់បំប៉នឱ្យវាយបក្សកុម្មុយនីស្តកម្ពុជា[2316]។ ដូច្នេះ “ភ្នាក់ងារយួន” អាចសំដៅដល់កម្មាភិបាលផ្ដាច់ខ្លួន ដែលត្រូវបានចាត់ទុកថាចូលដៃជើងជាមួយ

---

[2311] សាលដីកា ០០២/០១ កថាខណ្ឌ ៩៣០។

[2312] សាលដីកា ០០២/០១ កថាខណ្ឌ ៨៨៣, ៨៩០។

[2313] ទង់បដិវត្ត លេខពិសេស ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៧ **ឯកសារ E3/742**, ទង់បដិវត្ត លេខពិសេស ចេញផ្សាយខែ ធ្នូ ឆ្នាំ ១៩៧៧-មករា ១៩៧៨ **ឯកសារ E3/725**, យុវជន និងយុវនារីបដិវត្ត លេខ ១-២ ចេញផ្សាយខែ មករា និងកុម្ភៈ ឆ្នាំ ១៩៧៨ **ឯកសារ E3/726**, ទង់បដិវត្ត លេខពិសេស ចេញផ្សាយខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៨ **ឯកសារ E3/727**, ទង់បដិវត្ត លេខ ៧ ចេញផ្សាយខែ កក្កដា ឆ្នាំ ១៩៧៨ **ឯកសារ E3/746**, យុវជន និងយុវនារីបដិវត្ត លេខ ១០ ចេញផ្សាយខែ តុលា ឆ្នាំ ១៩៧៨ **ឯកសារ E3/765**។

[2314] ដីកាដំណោះស្រាយ កថាខណ្ឌ ១១៩៧, ប្រតិចារឹក ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/401.1** ទំព័រ ៦០-៦២ ចន្លោះម៉ោង [១៤.១៧.៣០] និង [១៤.២៣.៤០], ប្រតិចារឹក ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/390.1** ទំព័រ ៣៣-៣៥ ចន្លោះម៉ោង [១១.១៧.៤០] និង [១១.២៤.៤២]។

[2315] ទង់បដិវត្ត ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៧ **ឯកសារ E3/742** ERN 00062986, 00062990-92។

[2316] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨១៨-៨២៣។

វៀតណាម។ ប៉ុន្តែ ទោះជាក្នុងករណីណាក៏ដោយ ជនស៊ីវិលវៀតណាម នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង មិនត្រូវបានកំណត់គោលដៅដោយសម្តីទាំងនេះទេ។

២២៥៤. នៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ ខែ មករា-ខែ កុម្ភៈ ឆ្នាំ ១៩៧៨ រដ្ឋវៀតណាមក៏ត្រូវបានហៅថាជារដ្ឋឈ្លានពាន លេបទឹកដី[2317]។ បើតាមសហព្រះរាជអាជ្ញា ការប្រើពាក្យ "យួន" ក៏ជាការអំពាវនាវឱ្យសម្លាប់ជនស៊ីវិលវៀតណាមផងដែរ[2318]។ ក្រុមមេធាវីការពារក្តីសូមយោងទៅលើការអត្ថាធិប្បាយខាងលើ ចំពោះប្រធានបទនេះ[2319]។ ក្រៅពីនេះទៀត ទស្សនាវដ្តីទង់បដិវត្តន៍នេះមិនសំដៅដល់ជនស៊ីវិលទាល់តែសោះ ផ្ទុយទៅវិញ គឺលើកឡើងតែអំពីវិធានការទប់ទល់នឹងរដ្ឋវៀតណាម ដើម្បីការពារទឹកដីរបស់ខ្លួនប៉ុណ្ណោះ។

២២៥៥. ក្រៅពីទស្សនាវដ្តី "ទង់បដិវត្តន៍" និង "យុវជន-យុវនារីបដិវត្តន៍" ឯកសារផ្សេងទៀតបានលើកឡើងអំពីជម្លោះប្រដាប់អាវុធ ឬការឃោសនាដើម្បីលើកទឹកចិត្តកងទ័ព និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងធ្វើសង្គ្រាម[2320]។ ម្យ៉ាងវិញទៀត សារទូរលេខមួយរបស់ ផុន ចុះខែ វិច្ឆិកា ឆ្នាំ ១៩៧៧ បានរាយការណ៍អំពីឧប្បត្តិហេតុជាមួយវៀតណាម នៅជិតព្រំដែនក្នុងតំបន់ ២៣[2321]។ នៅក្នុងឯកសារទាំងនេះ ពុំមានការកំណត់គោលដៅទៅលើជនស៊ីវិលវៀតណាម នៅខេត្តព្រៃវែង និងខេត្តស្វាយរៀងឡើយ។ ឯកសារទាំងនេះមិនអាចគាំទ្រដល់អត្ថិភាពនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងជនជាតិវៀតណាមបានឡើយ។ ម្យ៉ាងវិញទៀត ភ័ស្តុតាងអំពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តលើជនស៊ីវិលវៀតណាម នៅក្នុងតំបន់ទាំងនេះ មិនត្រូវបានបង្ហាញឡើយ។

---

[2317] យុវជន និងយុវនារីបដិវត្ត លេខ ១-២ ចេញផ្សាយខែ មករា និងកុម្ភៈ ឆ្នាំ ១៩៧៨ **ឯកសារ E3/726** ERN 00063495។

[2318] ប្រតិចារឹក ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/390.1** ទំព័រ ៤៥ ចន្លោះម៉ោង [១៣.៥៣.៥៣] និង [១៣.៥៦.១០]។

[2319] សូមមើលផ្នែកខាងលើ កថាខណ្ឌ ២២១៨-២២២៥។

[2320] សេចក្តីណែនាំរបស់ ៨៧០ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៨ **ឯកសារ E3/741**, កងទ័ពកម្ពុជាអនុម័តសេចក្តីសម្រេចស្តីពីជម្លោះជាមួយសាធារណៈរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៧៨ **ឯកសារ E3/1285**, ខ្មាំងយួន ឈ្លានពានវាតទីលេបទឹកដី ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៧៩ **ឯកសារ E3/722**។

[2321] ទូរលេខ ៨២ គោរពជូន បងប៉ុល ជាទីស្នេហា និងនឹករលឹក យើងខ្ញុំសូមជម្រាបពីសភាពការណ៍នៅសមរភូមិនៅតំបន់២៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ **ឯកសារ E3/896**។

### ៣. អវត្តមាននៃភស្តុតាងអំពីការសម្លាប់រង្គាលជនស៊ីវិលវៀតណាម

២២៥៦. បើតាមសហចៅក្រមស៊ើបអង្កេត ការសម្លាប់រង្គាលជនស៊ីវិលវៀតណាម នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង គឺជាផ្នែកមួយមិនអាចកាត់ផ្តាច់បាននៃគោលនយោបាយប្រឆាំងនឹងវៀតណាម។ ក្រៅពីនេះទៀត ទ្រឹស្តីខ្សែស្រឡាយខាងម្តាយបង្ហាញអំពីគោលនយោបាយកម្មេចរបស់បក្សកុម្មុយនីស្តកម្ពុជា[2322]។ ផ្ទុយទៅវិញ សុន្ទរកថា និងឯកសារផ្សេងទៀតពីសម័យនោះ របស់បក្សកុម្មុយនីស្តកម្ពុជា មិនអាចឱ្យបង្ហាញថា ជនស៊ីវិលវៀតណាមនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ត្រូវបានកំណត់មុខសញ្ញានោះឡើយ។ ជាពិសេស ការវិភាគទៅលើភស្តុតាង នៅក្នុងសំណុំរឿង ០០២/០២ មិនអាចឱ្យសន្និដ្ឋានថាមានការសម្លាប់រង្គាលជនស៊ីវិលវៀតណាមបានឡើយ[2323]។

២២៥៧. ក្រៅពីវត្តមានជនជាតិវៀតណាមតិចតួច នៅតាមភូមិខ្លះ ក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង[2324] គ្មានការសម្លាប់ជនជាតិវៀតណាមណាមួយ ត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ[2325]។ ទ្រឹស្តីខ្សែស្រឡាយខាងម្តាយក៏មិនអាចត្រូវបានពិនិត្យផ្ទៀងផ្ទាត់បានដែរ[2326]។ អង្គជំនុំជម្រះត្រូវតែកត់សម្គាល់ជាចាំបាច់ថា អត្ថិភាពនៃគោលនយោបាយបំផ្លិចបំផ្លាញដោយផ្នែក ឬទាំងស្រុងទៅលើជនជាតិវៀតណាម មិនត្រូវបានបង្ហាញឱ្យឃើញឡើយ។

## ជំពូកទី ៧. អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

### ផ្នែកទី ១. បទចោទ

២២៥៨. ក្នុងចំណោមឧក្រិដ្ឋកម្មទាំងអស់ ដែលទទួលយកនៅក្នុងផ្នែក “ការកំណត់ប្រភេទបទល្មើស” នៃដីកាដំណោះស្រាយ មានតែឧក្រិដ្ឋកម្មនៃការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ ក្នុងឋានៈ

---

[2322] ដីកាដំណោះស្រាយ កថាខណ្ឌ ២១៤-២១៥។

[2323] សូមមើលផ្នែកខាងលើ កថាខណ្ឌ ២១៥៨-២១៧៩ និង ២១៨១-២១៨៣។

[2324] សូមមើលផ្នែកខាងលើ កថាខណ្ឌ ២២០៥។

[2325] សូមមើលផ្នែកខាងលើ. កថាខណ្ឌ ២១៥៨-២១៧៩។

[2326] សូមមើលផ្នែកខាងលើ កថាខណ្ឌ ២១៩៥-២១៩៧។

ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុណ្ណោះ មានធាតុផ្សំគ្រប់គ្រាន់ ដោយសារអង្គហេតុដែលត្រូវបានរៀបរាប់ថាបានប្រព្រឹត្តទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[2327]។

២២៥៩. យើងបានគូសបញ្ជាក់ពីខាងលើថា យោងតាមកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមជាមួយនឹងប្រជាជនថ្មី និងខ្មែរមកពីបរទេស (ក្រុមមួយនៃក្រុមទាំងបីដែលត្រូវបានកំណត់ដោយបក្សកុម្មុយនីស្តកម្ពុជា) គឺជាជនរងគ្រោះនៃការរើសអើងដែលត្រូវបានកំណត់ថាជាការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ[2328]។

២២៦០. ក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មទាំងអស់ដូចបានរៀបរាប់នៅកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយជាកថាខណ្ឌទូទៅ ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ទីតាំងដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មិនត្រូវបានបែងចែកឱ្យដាច់ពីទីតាំង ដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងក្រុមមួយនៃក្រុមផ្សេងទៀតដូចបានរៀបរាប់នៅកថាខណ្ឌ ១៤១៧ ឡើយ។

២២៦១. ការអានអង្គហេតុ ដូចបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ធ្វើឱ្យយើងដឹងថា អង្គហេតុពាក់ព័ន្ធនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បានកើតឡើងនៅសហករណ៍ត្រាំកក់ (១) ការដ្ឋានទំនប់ ១ មករា (២) ស-២១ (៣) និងក្រាំងតាចាន់ (៤)។ ទីតាំងទាំងនេះត្រូវបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ។ ដូច្នេះ យើងត្រូវយល់ថា សហចៅក្រមស៊ើបអង្កេតបានកំណត់អង្គហេតុដែលកើតឡើងនៅទីនោះថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

២២៦២. ម្យ៉ាងវិញទៀត អង្គហេតុទាំងនេះត្រូវបានអង្គជំនុំជម្រះទទួលយកថាជាការបង្ហាញអំពីការអនុវត្តគោលនយោបាយប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងឧបសម្ព័ន្ធនៃដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ហើយនឹងត្រូវសិក្សានៅជំពូកបន្ទាប់នេះ[2329]។

---

[2327] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៦-១៤១៧, សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៤៤, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ៣-៥។

[2328] សូមមើលផ្នែកខាងលើ កថាខណ្ឌ ២២០៤។

[2329] ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ២។

## ១. សហករណ៍ត្រាំកក់

២២៦៣. នៅក្នុងដីកាដំណោះស្រាយ អង្គហេតុពាក់ព័ន្ធនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសរសេរតែបីឃ្លា នៅកថាខណ្ឌ ៣១៩ (ក្រោមការពិនិត្យ "សហករណ៍ត្រាំកក់") និងអត្ថាធិប្បាយនៅកថាខណ្ឌ ៤៩៨ (ក្រោមការពិនិត្យ "មន្ទីរសន្តិសុខក្រាំងតាចាន់")។

២២៦៤. យោងតាមកថាខណ្ឌ ៣១៩៖

> "អតីតទាហាន និងប៉ូលីសរបស់របប [សាធារណរដ្ឋខ្មែរ] ជាពិសេស អ្នកដែលមានតំណែងជាមន្ត្រី ត្រូវបានគេពិនិត្យមើលយ៉ាងល្អិតល្អន់។ បញ្ជីឈ្មោះអតីតទាហាន លន់ នល់ ដែលបានមកដល់ឃុំ ត្រូវបានគេរៀបចំ និងបញ្ជូនទៅស្រុក។ ឧទាហរណ៍ ឯកសារស្រុក ១០៥ ពីឃុំញ៉ែងញ៉ង បានកត់ត្រានូវឈ្មោះអតីតទាហានចំនួន ១១ រូប ដែលត្រូវបានបញ្ជូនទៅក្នុងឃុំញ៉ែងញ៉ងនេះ"។

២២៦៥. ម្យ៉ាង ពាក្យស្រពេចស្រពិលអំពី "ការពិនិត្យមើលយ៉ាងល្អិតល្អន់" ទៅលើអតីតទាហាន និងប៉ូលីសនៃរបបសាធារណរដ្ឋខ្មែរ មិនអាចគ្រប់គ្រាន់ឱ្យសន្និដ្ឋានអំពីអត្ថិភាពនៃការរើសអើង ដោយសារតែឋានៈរបស់អ្នកទាំងនោះបានឡើយ។ ដើម្បីបង្ហាញឱ្យលើសពីការមិនទុកចិត្តជាធម្មតារបស់អ្នកឈ្នះសង្គ្រាមរវាងបងប្អូនឯង ទៅលើអ្នកចាញ់ថ្មីៗ យ៉ាងហោចណាស់ គេគួរតែពន្យល់អំពីផលវិបាកនៃការតាមដាននេះទៅលើជីវិតរបស់អ្នកដែលត្រូវគេកំណត់មុខសញ្ញា តែវាមិនដូច្នោះទេ។

២២៦៦. ម្យ៉ាងទៀត ពុំមានភស្តុតាងណាមួយ ដែលបានលើកឡើងនៅកថាខណ្ឌ ៣១៩ ត្រូវបានយកមកប្រើម្តងទៀត នៅកថាខណ្ឌ ១៤១៧ និងកថាខណ្ឌ ១៤១៨ ស្តីពីការកំណត់ប្រភេទបទល្មើស ហើយឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញផ្អែកតែលើអង្គហេតុដូចតទៅ៖ ការកំណត់អត្តសញ្ញាណ "ខ្មាំង" ជាច្រើនក្រុម ការដកចេញពី "ផែនការរួមនៃការកសាងលទ្ធិសង្គមនិយម" ការដាក់ឱ្យរស់នៅក្នុងល័ក្ខខ័ណ្ឌលំបាកខ្លាំង និងការចាប់មនុស្សជាក្រុមៗ ដើម្បីយកទៅអប់រំឡើងវិញ ឬកម្ទេចចោល។ ពុំមានចំណុចណាមួយមានទំនាក់ទំនងជាមួយសេចក្តីសន្និដ្ឋាននៃកថាខណ្ឌ ៣១៩ ទាល់តែសោះ។

២២៦៧. ផ្អែកលើកថាខណ្ឌ ៣១៩ នៃដីកាដំណោះស្រាយ គេមិនអាចនិយាយថា សហចៅក្រមស៊ើបអង្កេត បានបញ្ជូនលោក ខៀវ សំផន ទៅជំនុំជម្រះ ចំពោះអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បានឡើយ។ ក្នុងករណីអង្គជំនុំជម្រះសម្រេចផ្ទុយពីនេះ អង្គជំនុំជម្រះត្រូវតែកត់សម្គាល់ឃើញអំពីភាពខ្វះខាតនៃភស្តុតាងដាក់បន្ទុកប្រឆាំងនឹងរូបគាត់។

២២៦៨. កថាខណ្ឌ ៤៩៨ បានបង្ហាញជាសំខាន់ថា ក្រោយរំដោះទីក្រុងភ្នំពេញ ពេលមកដល់ស្រុកត្រាំកក់ ប្រជាជនជម្លៀសត្រូវបានបង្ខំឱ្យធ្វើប្រវត្តិរូប ហើយអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានបាត់ខ្លួនបន្ទាប់មក។ កថាខណ្ឌនេះក៏បានបញ្ជាក់ផងដែរថា "បញ្ជីអ្នកទោសនៅមន្ទីរសន្តិសុខក្រាំងតាចាន់ [...] បង្ហាញថា ភាគច្រើននៃអ្នកទាំងនោះ ដែលបានបាត់ខ្លួន ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់"។

២២៦៩. ដូច្នេះ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរហាក់ដូចជាត្រូវបានរើសអើង ដោយសារហេតុផលតែមួយគត់ គឺពួកគាត់ជាសមាជិកក្រុមគោលដៅ។ ផ្ទុយពីអង្គហេតុដែលបានរៀបរាប់នៅកថាខណ្ឌ ៣៩៩ នៃដីកាដំណោះស្រាយ អង្គហេតុទាំងនេះបង្កើតបានជាមូលដ្ឋាននៃការចោទប្រកាន់អំពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៃកថាខណ្ឌ ១៤១៦។ អាស្រ័យហេតុនេះ លោក ខៀវ សំផន ត្រូវតែឆ្លើយតប។

### ២. ទំនប់ ១ មករា

២២៧០. ដូចបានឃើញពីខាងលើពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅការដ្ឋានទំនប់ ១ មករា សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅកថាខណ្ឌ ១៤១៨ នៃដីកាដំណោះស្រាយ ថា នៅតាមការដ្ឋានការងារ ក្រុមដែលត្រូវបានកំណត់គោលដៅ នៅកថាខណ្ឌ ១៤១៧៖

> "ត្រូវបានគេធ្វើបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខ័ណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត។ មនុស្សទាំងនេះក៏ត្រូវបានគេចាប់ជាក្រុមៗផងដែរ ដើម្បីយកទៅអប់រំឡើងវិញ ឬទៅកម្ទេចចោល នៅតាម**មន្ទីរសន្តិសុខ** និង **កន្លែងសម្លាប់មនុស្ស**" (អក្សរដិត នៅក្នុងឯកសារដើម)[2330]។

២២៧១. ចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ការចោទប្រកាន់ផ្អែកលើកថាខណ្ឌ ៣៦៦ ដែលលើកឡើងអំពីការបាត់ខ្លួន នៅការដ្ឋាន។

២២៧២. ផ្ទុយទៅវិញ យើងបាននិយាយពីខាងលើពាក់ព័ន្ធនឹងប្រជាជនថ្មីថា សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញឱ្យឃើញអំពីការរើសអើងណាមួយនៅកថាខណ្ឌ ៣៦៦ នៃដីកាដំណោះស្រាយ នោះទេ ដោយហេតុថាអ្នកធ្វើការនៅការដ្ឋានអាចត្រូវបានចាប់ខ្លួន ដោយគ្មានការបែងចែកថាពួកគេស្ថិតនៅក្នុងក្រុមនេះ ឬក្រុមនោះឡើយ[2331]។

### ៣. <u>ស-២១</u>

២២៧៣. នៅកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងអំពីអង្គហេតុដែលបានកើតឡើងប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅ ស-២១៖

> "ចំណែកឯភ្នាក់ងារតូចតាចនៃរបបចាស់ អ្នកខ្លះត្រូវបានចាប់ខ្លួនភ្លាមៗ បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាដណ្តើមបានអំណាច ដោយសារការគាំទ្ររបស់ខ្លួនដល់រដ្ឋាភិបាលចាស់ ហើយជាញឹកញាប់ ពួកគេត្រូវបានសម្លាប់នៅតាមមន្ទីរសន្តិសុខ ដូចជា **មន្ទីរ ស-២១** [...]" (អក្សរដិត នៅក្នុងឯកសារដើម)។

២២៧៤. ការចោទប្រកាន់នេះផ្អែកលើកថាខណ្ឌ ៤៣២ នៃដីកាដំណោះស្រាយ ដែលបញ្ជាក់ថា "មានឈ្មោះចូលក្នុងបញ្ជី [អ្នកទោស នៅ ស-២១] ផងដែរ ជាពិសេស អតីតទាហាន និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ"។

---

[2330] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១០៦៣-១០៦៨។

[2331] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១០៦៣-១០៦៨។

២២៧៥. កថាខណ្ឌ ១៤១៧ លើកឡើងថាអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានកំណត់មុខសញ្ញា ដោយសារតែពួកគេស្មោះត្រង់នឹងអតីតរដ្ឋាភិបាលកម្ពុជា។ ផ្ទុយទៅវិញ នៅកថាខណ្ឌ ៤៣២ ដែលត្រូវបានសន្មតថាជាមូលដ្ឋាននៃការចោទប្រកាន់នេះ ពុំមាននិយាយសំដៅដល់មូលហេតុនៃការចាប់ខ្លួនអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាល់តែសោះ។ កថាខណ្ឌ ៤៣២ គ្រាន់តែប្រាប់ថា ក្នុងចំណោមអ្នកទោសផ្សេងទៀត អ្នកខ្លះជាអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ ករណីនេះមិនគាំទ្រដល់ការចោទប្រកាន់លើលោក ខៀវ សំផន នៅកថាខណ្ឌ ១៤១៧ នោះឡើយ។

២២៧៦. ដូច្នេះ សេចក្តីសន្និដ្ឋាន នៅកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយ គ្រាន់តែជាការអះអាងតាមទំនើងចិត្តរបស់សហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ។ សេចក្តីសន្និដ្ឋានបែបនេះមិនអាចយកជាការបានទេ នៅក្នុងការជំនុំជម្រះក្តីអន្តរជាតិ ហើយលោក ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបទៅនឹងអង្គហេតុដែលគ្មានមូលដ្ឋានគាំទ្របែបនេះឡើយ។

## ៤. ក្រាំងតាចាន់

២២៧៧. យើងបានឃើញពីខាងលើថានៅកថាខណ្ឌ ៤៩៨ នៃដីកាដំណោះស្រាយ ក្រោមការពិនិត្យអង្គហេតុពាក់ព័ន្ធនឹងក្រាំងតាចាន់ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានអំពីជោគវាសនារបស់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់[2332]។

២២៧៨. មានតែអង្គហេតុកើតឡើង នៅក្នុងបរិវេណក្រាំងតាចាន់ផ្ទាល់ប៉ុណ្ណោះ ដែលត្រូវបានអត្ថាធិប្បាយនៅទីនេះ។

២២៧៩. ក្រោមការពិនិត្យមន្ទីរសន្តិសុខនេះ មានការនិយាយសំដៅដល់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅកថាខណ្ឌ ៥០០ ដែលបញ្ជាក់ជាអាទិ៍ថា “ក៏មានប្រជាជនមូលដ្ឋាន អតីតទាហាន លន់ នល់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ចិន វៀតណាម និងចាម ស្ថិតនៅក្នុងចំណោមអ្នកជាប់ឃុំឃាំងដែរ”។

---

[2332] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២៦១-១២៦២។

២២៨០. សេចក្តីសន្និដ្ឋាននៃកថាខណ្ឌនេះត្រូវបានពិនិត្យមើលពីខាងលើរួចមកហើយ នៅក្នុងផ្នែកការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនថ្មី នៅក្រាំងតាចាន់[2333]។ ក្រុមមេធាវីការពារក្តីបានពន្យល់ថា សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញភស្តុតាងអំពីអត្ថិភាពនៃការរើសអើងទៅលើប្រជាជនថ្មី នៅក្នុងបរិវេណក្រាំងតាចាន់នោះទេ។ ទឡ្ហីករណ៍ដូចគ្នានេះអនុវត្តចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

២២៨១. អាស្រ័យហេតុនេះ លោក ខៀវ សំផន មិនអាចត្រូវបានចោទប្រកាន់ ចំពោះអង្គហេតុដែលត្រូវបានកំណត់ជាការការធ្វើទុក្ខបុកម្នេញទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្រាំងតាចាន់នោះឡើយ។ គាត់មិនចាំបាច់ត្រូវឆ្លើយតបទៅនឹងការចោទប្រកាន់ទាំងនេះទេ។

## ផ្នែកទី ២. ភស្តុតាងគាំទ្រដល់សេចក្តីសន្និដ្ឋាននៃដីកាដំណោះស្រាយ

២២៨២. ការពិនិត្យលើភស្តុតាងគាំទ្រនៃដីកាដំណោះស្រាយ ប្រាប់អំពីចរិតលក្ខណៈគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់នៃបទចោទ ដែលជនជាប់ចោទត្រូវបានបញ្ជូនទៅជំនុំជម្រះ។ ផ្ទុយពីការរំពឹងទុក ការពិនិត្យនេះបង្ហាញថា សហចៅក្រមស៊ើបអង្កេតបានរំលោភទៅលើវិធាននៃបណ្តឹងរបស់ខ្លួន យោងតាមព័ត៌មានអំពីបទចោទដែលទើបតែពិនិត្យមើល។

### ១. អំពីការតាមដានអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ដែលត្រូវបានចោទប្រកាន់ នៅកថាខណ្ឌ ៣១៩

២២៨៣. យើងបាននិយាយពីខាងលើថា សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញអំពីការរើសអើងទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនោះឡើយ។

[2333] សូមមើលផ្នែកខាងលើ កថាខណ្ឌ ១២៦៤-១២៦៥។

២២៨៤. ភស្តុតាងគាំទ្រដល់សេចក្តីសន្និដ្ឋានបីឃ្លានៃកថាខណ្ឌ ៣១៩ អំពីប្រព្រឹត្តទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[2334] ធ្វើឱ្យយើងមានការព្រួយបារម្ភជាថ្មីម្តងទៀតអំពីភាពមធ្យ័តនៃកិច្ចស៊ើបសួរដែលសហចៅក្រមស៊ើបអង្កេតបានធ្វើឡើងអស់រយៈពេលបីឆ្នាំ។

២២៨៥. ជាបឋម ការអះអាងអំពីការតាមដានអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរពុំមានភស្តុតាងគាំទ្រណាមួយឡើយ។ ការសន្និដ្ឋានអំពីការធ្វើបញ្ជីឈ្មោះអតីតនាយទាហាននៃរបប លន់ នល់ នៅតាមឃុំ រួចផ្ញើទៅស្រុក ផ្អែកលើភស្តុតាងតែមួយគត់ដែលត្រូវបានចាត់ទុកជាឧទាហរណ៍នៃការអនុវត្តបែបនេះ។ ផ្ទុយទៅវិញ ទោះបីជារបាយការណ៍ដែលយកមកសំអាងនេះ បង្ហាញយ៉ាងច្បាស់អំពីឈ្មោះនាយទាហាន និងឃុំដែលពួកគេរស់នៅក៏ដោយ ក៏ពុំមានសញ្ញាណអ្វីអំពីអ្នកត្រូវទទួលព័ត៌មានទាំងនេះឡើយ។

២២៨៦. ដូច្នេះ ប្រសិនបើមិនអាចបង្ហាញភស្តុតាងសូម្បីតែមួយ សម្រាប់គាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួន ការព្យាករណ៍របស់សហចៅក្រមស៊ើបអង្កេតមិនអាចយកជាការបានទេ។

២២៨៧. ក្នុងល័ក្ខខ័ណ្ឌបែបនេះ និងប្រសិនបើអង្គជំនុំជម្រះសម្រេចជាករណីលើកលែងថា សហចៅក្រមស៊ើបអង្កេតបានបញ្ជូនទៅជំនុំជម្រះយ៉ាងត្រឹមត្រូវ នូវអង្គហេតុដែលត្រូវបានប្រព្រឹត្តទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ លោក ខៀវ សំផន មិនអាចដឹងថាតើគាត់ត្រូវឆ្លើយតបទៅនឹងអ្វីនោះទេ។

## ២. អំពីការបាត់ខ្លួនអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ដែលត្រូវបានចោទប្រកាន់ នៅកថាខណ្ឌ ៣៩៨

២២៨៨. យើងបាននិយាយពីខាងលើថា លោក ខៀវ សំផន ត្រូវឆ្លើយតបទៅនឹងអង្គហេតុនៃការបាត់ខ្លួនដែលត្រូវបានចោទប្រកាន់ នៅកថាខណ្ឌ ៣៩៨ នៃដីកាដំណោះស្រាយ។ ភស្តុតាងគាំទ្រដល់ការចោទប្រកាន់នេះបង្ហាញអំពីភាពមិនប្រក្រតីជាច្រើន។ ភស្តុតាងនេះត្រូវបានរៀបរាប់លម្អិតដូចខាង

[2334] សូមមើលផ្នែកខាងលើ កថាខណ្ឌ ២២៦៤-២២៦៧។

ក្រោម ដើម្បីបង្ហាញជាថ្មីម្ដងទៀតអំពីការមិនយកចិត្តទុកដាក់ពីសំណាក់សហចៅក្រមស៊ើបអង្កេត ទៅលើវិធាននីតិវិធី និងសិទ្ធិរបស់ជនជាប់ចោទ។

២២៨៩. ឃ្លាពីរដំបូងនៃកថាខណ្ឌ ៣៩៨ បញ្ជាក់ថា៖

> "អ្នករស់នៅស្រុកត្រាំកក់បានបំភ្លឺថា មុនពេលដែលអ្នកត្រូវបានជម្លៀសមកពីភ្នំពេញមកដល់ក្នុងតំបន់នេះ លេខាស្រុក និងឃុំ បានចូលរួមអង្គប្រជុំ ដោយពួកគេត្រូវបានណែនាំថា នឹងមានការសម្រិតសម្រាំង ក្នុងចំណោមអ្នកដែលត្រូវបានគេជម្លៀស។ ជនណាមួយធ្លាប់ជាពលបាលទោ ឬខ្ពស់ជាងនេះ ក្នុងរបបលន់ នល់ ហើយអ្នកជាធ្លាប់បម្រើឱ្យរដ្ឋការ លន់ នល់ ក្នុងឋានៈជាអនុប្រធានទីមួយ ឬខ្ពស់ជាងនេះ នឹងត្រូវបានសម្រិតសម្រាំង"។

២២៩០. ទោះបីជាអង្គហេតុទាំងនេះមានលក្ខណៈធ្ងន់ធ្ងរក៏ដោយ ក៏ពុំមានភ័ស្តុតាងគាំទ្រណាមួយឡើយ។ យើងមិនអាចដឹងថាតើសហចៅក្រមស៊ើបអង្កេតទទួលបានព័ត៌មាននេះ ដោយរបៀបណានោះទេ។ លោក ខៀវ សំផន មិនចាំបាច់ឆ្លើយតបទៅនឹងការចោទប្រកាន់គ្មានមូលដ្ឋានបែបនេះទេ។

២២៩១. សហចៅក្រមស៊ើបអង្កេតអះអាងបន្តទៀតថា៖

> "ហេតុការណ៍នេះត្រូវបានបញ្ជាក់បន្ថែមដោយសាក្សីបីរូប រួមទាំងអតីតប្រធានយុវជនស្រុក ថា នៅពេលដែលប្រជាជនថ្មីមកដល់ត្រាំកក់ ពួកគេត្រូវបានបង្ខំឱ្យធ្វើប្រវត្តិរូប ហើយថាអ្នកដែលប្រាប់ថាខ្លួនជាទាហាននឹងត្រូវបាត់ខ្លួនបន្ទាប់មក"។

២២៩២. សេចក្ដីសន្និដ្ឋានចុងក្រោយនេះផ្អែកលើសម្ដីរបស់សាក្សី អៀប ឌុច ដែលត្រូវបានអ្នកស៊ើបអង្កេតស្ដាប់ចម្លើយក្នុងអំឡុងកិច្ចស៊ើបសួរ។ សាក្សីរូបនេះមិនធ្លាប់អះអាងថាមនុស្សបានបាត់ខ្លួននោះទេ គឺគាត់បានបញ្ជាក់ថាពួកគេ "នឹងត្រូវបាត់ខ្លួន"។ ឃ្លាទាំងពីរនេះមិនមានន័យដូចគ្នានោះទេ ពីព្រោះនៅក្នុងសម្មតិកម្មទីពីរនេះ សកម្មភាពមិនទាន់ត្រូវបានធ្វើនៅឡើយទេ[2335]។ ពាក្យនីមួយៗសុទ្ធតែមានន័យ ហើយសហចៅក្រមស៊ើបអង្កេតពិតជានៅចាំបាន។

---

[2335] កំណត់ហេតុស្ដាប់ចម្លើយ អៀប ឌុច ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៧ **ឯកសារ E3/4627** ERN 00163493។

២២៩៣. បន្តិចក្រោយមក បន្ទាប់ពីធ្វើការសន្និដ្ឋាន ដោយគ្មានការចោទប្រកាន់អំពីការរើសអើង[2336] សហចៅក្រមស៊ើបអង្កេតបានបន្តថា៖

"សមាជិកគណៈកម្មាធិការឃុំម្នាក់ក្នុងឃុំត្រាំកក់បញ្ជាក់ថា លេខាឃុំបានបញ្ជាឱ្យប្រមូលអ្នកជម្លៀសទាំងអស់ ដែលមានឋានៈពីស័ក្តិមួយឡើងទៅ។ នៅពេលប្រមូលផ្តុំរួច ថ្នាក់លើបានបញ្ជូនឡានមកដឹកចេញទៅ។ ប្រជាជនទាំងនោះបាត់ខ្លួនជារៀងរហូត"។

២២៩៤. សេចក្តីសន្និដ្ឋាននេះផ្អែកលើចម្លើយរបស់សាក្សី ប៊ុន ធៀន ដែលបានឆ្លើយជូនអ្នកស៊ើបអង្កេតក្នុងអំឡុងកិច្ចស៊ើបសួរ។ ផ្ទុយទៅវិញ យើងបានបញ្ជាក់ពីខាងលើហើយថា សាក្សីរូបនេះមិនធ្លាប់រស់នៅក្នុងស្រុកត្រាំកក់នោះឡើយ គឺគាត់រស់នៅក្នុងស្រុកទ្រាំងឯណោះទេ[2337]។ សេចក្តីសន្និដ្ឋាន ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតធ្វើឡើង ដោយរំលោភលើវិសាលភាពនៃបណ្តឹងទៅកាន់ខ្លួន មិនអាចយកមកដាក់បន្ទុកប្រឆាំងនឹងលោក ខៀវ សំផន បានឡើយ។

២២៩៥. សហចៅក្រមស៊ើបអង្កេតបន្តទៀតថា៖

"បញ្ជីអ្នកទោសនៅមន្ទីរសន្តិសុខក្រាំងតាចាន់ រួមទាំងការកើនឡើងនៃចំនួនអ្នកទោសនៅមន្ទីរសន្តិសុខនេះក្រោយខែ មេសា ឆ្នាំ ១៩៧៥ បង្ហាញថា ភាគច្រើននៃអ្នកទាំងនោះ ដែលបានបាត់ខ្លួន ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខក្រាំតាចាន់"។

២២៩៦. សេចក្តីសន្និដ្ឋាននេះគួរឱ្យចាប់អារម្មណ៍ ពីព្រោះវាមិនផ្អែកលើបញ្ជីអ្នកទោសណាមួយឡើយ គឺផ្អែកលើសម្តីរបស់សាក្សី ពេជ្រ ជឹម និង ផាន់ ឆេន ដែលមិនបាននិយាយអ្វីទាំងអស់ ដូចការអះអាងរបស់សហចៅក្រមស៊ើបអង្កេត ដែលបំភ្លេចចោលនូវគុណធម៌នៃភាពម៉ឺងម៉ាត់[2338]។

---

[2336]ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨៖ "សាក្សីម្នាក់បានរៀបរាប់ថា នៅពេលមកដល់ស្រុកត្រាំកក់ ក្នុងខែមេសា ឆ្នាំ១៩៧៥ គាត់ត្រូវបានបង្គាប់ឱ្យសរសេរប្រវត្តិរូបផ្ទាល់ខ្លួនរបស់គាត់ ដោយប្រាប់យ៉ាងជាក់លាក់អំពីថាតើគាត់ជាទាហាន ឬមន្ត្រីរដ្ឋការនៃរបប លន់ នល់"។

[2337]សូមមើលផ្នែកខាងលើ កថាខណ្ឌ ៩៣៦, កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធៀន ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ **ឯកសារ E3/5498** ERN 00368598, 00368599, 00368600 និង 00368605។

[2338]ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨ កំណត់សម្គាល់ជើងទំព័រ ២១៥៩។

២២៩៧. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានបញ្ចប់កថាខណ្ឌនេះថា៖

"មានរបាយការណ៍ជាច្រើនមកពីឃុំជូនទៅស្រុក ក្នុងឆ្នាំ ១៩៧៧ បង្ហាញថា ការសម្រិតសម្រាំងអតីតទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ នៅតែបន្តមាន ក្រោយឆ្នាំ ១៩៧៥"។

២២៩៨. មានតែសេចក្តីសន្និដ្ឋាននេះទេដែលហាក់ដូចជាគាំទ្រដោយភ័ស្តុតាងមួយចំនួន ស្របតាមការអះអាងរបស់សហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែដូចករណីជាញឹកញយដែរ ភ័ស្តុតាងផ្សេងទៀតស្ថិតនៅក្រៅវិសាលភាពទាំងស្រុង ពីព្រោះពាក់ព័ន្ធនឹងហេតុការណ៍កើតឡើងនៅឃុំនៃស្រុកត្រាំកក់ ដែលសហចៅក្រមស៊ើបអង្កេតមិនមានភារកិច្ចត្រូវស៊ើបអង្កេត[2339]។

## ផ្នែកទី ៣. ភ័ស្តុតាងបង្ហាញជូនក្នុងពេលជំនុំជម្រះក្តី

២២៩៩. ក្នុងចំណោមភ័ស្តុតាង ដែលបានបង្ហាញជូនក្នុងពេលជំនុំជម្រះក្តី (១) ភ័ស្តុតាងជាច្រើនស្ថិតនៅក្រៅយុត្តាធិការរបស់អង្គជំនុំជម្រះ (២)។ ភ័ស្តុតាងខ្លះទៀតអាចឱ្យយើងគិតថា ឧក្រិដ្ឋកម្មមួយចំនួនអាចមានធាតុផ្សំគ្រប់គ្រាន់ (៣)។

### ១. បញ្ជីភ័ស្តុតាង

២៣០០. នៅថ្ងៃទី ០១ និងថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ សាក្សីតែម្នាកគត់បានមកផ្តល់សក្ខីកម្មស្តីពីការប្រព្រឹត្តទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងឋានៈជាក្រុមគោលដៅជាក់លាក់[2340]។

---

[2339]សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៤៨-៨៥២, ដីកាដំណោះស្រាយ កថាខណ្ឌ ៩៩៨ កំណត់សម្គាល់ជើងទំព័រ ២១៦០។ ឧទាហរណ៍ សូមមើល **ឯកសារ E3/2048** (IS18.33) ERN 00079087 (របាយការណ៍ឃុំពពេល), ERN 00079089 (របាយការណ៍ឃុំជាងទង), ERN 00079090 (របាយការណ៍ឃុំពពេល)។

[2340]សៅ វ៉ន ប្រតិចារឹក ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/385.1**, ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/386.1**។

យើងនឹងពន្យល់នៅជំពូកបន្ទាប់នេះថា ហេតុអ្វីបានជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការបម្រុងទុកវគ្គមួយសម្រាប់ប្រធានបទនេះ គ្មានន័យខ្លឹមសារ[2341]។

២៣០១. ភស្តុតាងជាច្រើនត្រូវបានស្តាប់ពាក់ព័ន្ធនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងអំឡុងសវនាការលើសំណុំរឿង ០០២/០២។ ក្នុងវគ្គទាំងអស់ដែលអង្គជំនុំជម្រះបានបង្កើតឡើង សាក្សីបានឆ្លើយទៅនឹងសំណួរដែលបានចោទសួរពាក់ព័ន្ធនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

២៣០២. ម្យ៉ាងវិញទៀត ក្រៅពីកំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០២ កំណត់ហេតុស្តាប់ចម្លើយជាច្រើនមកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលត្រូវបានដាក់បញ្ចូលយ៉ាងសន្ធឹកសន្ធាប់ក្នុងពេលជំនុំជម្រះក្តីលើសំណុំរឿង ០០២ លើកឡើងអំពីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

## ២. ភស្តុតាងក្រៅវិសាលភាព

២៣០៣. យើងមិនអាចរៀបរាប់ឱ្យអស់នូវភស្តុតាងក្រៅវិសាលភាព ដែលអង្គជំនុំជម្រះបានដាក់បញ្ចូលក្នុងពេលជំនុំជម្រះក្តីនេះ ជាបន្តបន្ទាប់នោះទេ។ អង្គជំនុំជម្រះត្រូវបានប្តឹងឱ្យពិនិត្យតែទៅលើអង្គហេតុនៃការធ្វើទុក្ខបុកម្នេញទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅតាមសហករណ៍ត្រាំកក់ប៉ុណ្ណោះ។

២៣០៤. ព័ត៌មានផ្សេងទៀតដែលទទួលបាន ពាក់ព័ន្ធនឹងការប្រព្រឹត្តលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ស្ថិតនៅក្រៅវិសាលភាពរបស់អង្គជំនុំជម្រះ ពោលគឺអង្គជំនុំជម្រះមិនត្រូវបានប្តឹងដោយសហចៅក្រមស៊ើបអង្កេតតាមផ្លូវច្បាប់ ឬព័ត៌មានទាំងនេះស្ថិតនៅក្រៅនីតិវិធី តាំងពីពេលជូនដំណឹងអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា។

## ៣. ភស្តុតាងអំពីឧក្រិដ្ឋកម្មនៃការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយនៅត្រាំកក់

[2341]សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ២៣០៦-២៣១៨។

២៣០៥. ភស្តុតាងមួយផ្នែកដែលបានបង្ហាញ អាចនាំឱ្យយើងគិតថាមានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដូចបានចោទប្រកាន់ នៅកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ។ ទោះជាយ៉ាងនេះក្តី ក្រុមមេធាវីការពារក្តីសូមរំឭកថា ឧក្រិដ្ឋកម្មនេះអាចមានធាតុផ្សំគ្រប់គ្រាន់ក្នុងករណីនេះ តែប្រសិនបើវាកើតឡើងនៅក្នុងឃុំណាមួយក្នុងចំណោមឃុំទាំង ៨ ក្រោមវិសាលភាពនៃកិច្ចស៊ើបសួរ[2342]។

## ជំពូកទី ៨. ការចោទប្រកាន់អំពីគោលនយោបាយស្តីពីការចាត់វិធានការដាក់លាក់ប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

២៣០៦. លោក ខៀវ សំផនត្រូវបានចោទប្រកាន់អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១ មករា ស-២១ និងក្រាំងតាចាន់។ យើងបានឃើញនៅជំពូកមុនថា លោក ខៀវ សំផន ឆ្លើយតបតែនឹងអង្គហេតុកើតឡើងនៅសហករណ៍ត្រាំកក់ ដោយសារភស្តុតាងរបស់សហចៅក្រមស៊ើបអង្កេតមិនគ្រប់គ្រាន់ឱ្យបញ្ជូនគាត់ទៅជំនុំជម្រះចំពោះមុខអង្គជំនុំជម្រះ ពីបទឧក្រិដ្ឋផ្សេងទៀតដែលត្រូវបានចោទប្រកាន់[2343]។

២៣០៧. យោងតាមសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរគឺជាក្រុមមួយ ដែលជាកម្មវត្ថុនៃការអនុវត្តគោលនយោបាយស្តីពីការចាត់វិធានការដាក់លាក់ ដោយហេតុថាទីតាំងឧក្រិដ្ឋកម្ម ដែលទទួលយកនៅក្នុងសំណុំរឿង ០០២/០២ ឆ្លុះបញ្ចាំងអំពីគោលនយោបាយនេះ។ ជាក់ស្តែង បើតាមអង្គជំនុំជម្រះ៖

> "ការចោទប្រកាន់អំពីអង្គហេតុទាក់ទិននឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗ មានភាពពាក់ព័ន្ធនឹងគោលនយោបាយកំណត់គោលដៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ"[2344]។

២៣០៨. ដើម្បីគាំទ្រដល់អំណះអំណាងនេះ អង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងកំណត់សម្គាល់ជើងទំព័រថា៖

---

[2342] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៨៤៨។

[2343] សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ២២៨២-២៣០៥។

[2344] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1** កថាខណ្ឌ ៤៤។

"ដីកាដំណោះស្រាយបានចោទប្រកាន់ថា មានគំរូស្តីពីការកំណត់គោលដៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ ការចោទប្រកាន់លើអង្គហេតុ ដែលពាក់ព័ន្ធនឹងគំរូនេះ ត្រូវបានបញ្ចូលក្នុងផ្នែកនៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ (ដីកាដំណោះស្រាយ កថាខណ្ឌ ៣១៩) ការដ្ឋានទំនប់ ១ មករា (ដីកាដំណោះស្រាយ កថាខណ្ឌ ៣៦៦) មន្ទីរសន្តិសុខ ស-២១ (ដីកាដំណោះស្រាយ កថាខណ្ឌ ៤៣២) មន្ទីរសន្តិសុខក្រាំងតាចាន់ (ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨, ៥០០)"[2345]។

២៣០៩. ការវិភាគរបស់អង្គជំនុំជម្រះ គឺមិនត្រឹមត្រូវ និងកុហក។ នៅកថាខណ្ឌខាងលើ ពុំមាននិយាយអំពី "ប្រព័ន្ធ" ប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ទាល់តែសោះ។ ពាក្យដែលមានន័យមិនច្បាស់លាស់នេះនាំឱ្យអង្គជំនុំជម្រះធ្វើការវិភាគដោយលម្អៀង។ គ្មានអ្វីផ្សេងពីនេះទេ ពីព្រោះយើងបាននិយាយនៅជំពូកមុនថា ពុំមានកថាខណ្ឌណាមួយ ដូចបានរៀបរាប់នៅក្នុងកំណត់សម្គាល់ជើងទំព័រ (លើកលែងតែកថាខណ្ឌ ៤៩៨) លើកឡើងអំពីការប្រព្រឹត្តិជាក់លាក់ទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ទាល់តែសោះ។

២៣១០. ការវិភាគរបស់អង្គជំនុំជម្រះពឹងផ្អែកលើការអានដីកាដំណោះស្រាយ ដោយលម្អៀង។ យោងតាមកថាខណ្ឌ ២០៦ នៃដីកាដំណោះស្រាយ ក្រោមចំណងជើង "វិធានការផ្សេងៗដែលបានធ្វើឡើងប្រឆាំងនឹងក្រុមជាក់លាក់នានា"

"សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីអំពើនានា ដែលបានប្រព្រឹត្តប្រឆាំងនឹងជនជាតិចាម នៅភូមិភាគកណ្តាល ភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ ប្រឆាំងនឹងជនជាតិវៀតណាម នៅក្នុងខេត្តស្វាយរៀង និងខេត្តព្រៃវែង (ភូមិភាគបូព៌ា) និងក្នុងអំឡុងពេលនៃការចូលលុកលុយនៅប្រទេសវៀតណាម ការប្រឆាំងចំពោះពុទ្ធសាសនិក នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ និង<u>ការប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងអំឡុងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ</u>។ ព្រឹត្តិការណ៍ចុងក្រោយនេះបង្កើតបានជាឧទាហរណ៍មួយ ក្នុងចំណោមឧទាហរណ៍យ៉ាងច្រើន នៃអំពើប្រឆាំងទៅនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

---

[2345]សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E301/9/1** កំណត់សម្គាល់ជើងទំព័រ ៩៥។

២៣១១. ដូច្នេះ មិនមានការលើកឡើងអំពីគោលនយោបាយកំណត់គោលដៅទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅទូទាំងប្រទេសនោះឡើយ គឺមានតែអង្គហេតុពីរប្រភេទប៉ុណ្ណោះ៖ អង្គហេតុពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលសហចៅក្រមស៊ើបអង្កេតអះអាងថាខ្លួនទទួលបានបណ្តឹង ក្នុងផ្នែក "វិធានការផ្សេងៗដែលបានធ្វើឡើងប្រឆាំងនឹងក្រុមជាក់លាក់នានា" និងអង្គហេតុពាក់ព័ន្ធនឹងព្រឹត្តិការណ៍ផ្សេងទៀត ដែលសហចៅក្រមស៊ើបអង្កេតមិនទទួលបានបណ្តឹង ក្នុងទិដ្ឋភាពនោះឡើយ។

២៣១២. ដូច្នេះ ចំពោះទីតាំងដែលត្រូវបានពិនិត្យនៅក្នុងសំណុំរឿង ០០២/០២ សហចៅក្រមស៊ើបអង្កេតមិនត្រូវបានផ្តល់អាណត្តិឱ្យស៊ើបសួរលើគោលនយោបាយជាយថាហេតុ ដែលនាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះឡើយ។ ករណីនេះពន្យល់ថា ហេតុអ្វីបានជាអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមិនត្រូវបានកំណត់ជាក្រុមគោលដៅជាក់លាក់ ដូចពុទ្ធសាសនិក ជនជាតិចាម និងវៀតណាម នៅផ្នែកទី "៧. ការកត់សម្គាល់អំពីអង្គហេតុនៃឧក្រិដ្ឋកម្ម" ចំណុច "ឃ. ការប្រព្រឹត្តិចំពោះក្រុមមនុស្សជាក់លាក់" នៃដីកាដំណោះស្រាយ[2346]។ ចំណុចនេះអាចឱ្យយើងនិយាយបានថាអង្គជំនុំជម្រះមិនមានយុត្តាធិការ ដើម្បីកាត់សេចក្តីលើការទទួលខុសត្រូវរបស់លោក ខៀវ សំផន នោះទេ បើពិចារណាទៅលើគោលនយោបាយជាយថាហេតុរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានកំណត់គោលដៅទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

២៣១៣. អាស្រ័យហេតុនេះ លោក ខៀវ សំផន មិនចាំបាច់ឆ្លើយតបទៅនឹងការអនុវត្តគោលនយោបាយដែលត្រូវបានអង្គជំនុំជម្រះបង្កើតឡើងដោយខ្លួនឯងតាមទំនើងចិត្ត នៅក្នុងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី។

២៣១៤. ដូច្នេះ អង្គជំនុំជម្រះមិនគួរត្រូវបានអនុញ្ញាតឱ្យដាក់បញ្ចូលភស្តុតាងជាហូរហែ ពាក់ព័ន្ធនឹងការប្រព្រឹត្តិទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅតាមទីតាំងឧក្រិដ្ឋកម្មនោះឡើយ។

២៣១៥. នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ តាមសំណើរបស់ក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះបានបញ្ជាក់អំពីគោលជំហរនេះ និងបានផ្ញើអ៊ីមែលជូនភាគីនូវសំអាងហេតុនៃសេចក្តីសម្រេច ដែលបាន

[2346] ដីកាដំណោះស្រាយ មាតិកា ទំព័រ ៥ និងកថាខណ្ឌ ៧៥០-៨៥០។

ធ្វើឡើងនៅក្នុងសវនាការ ទាក់ទិននឹងការសម្រេចថាសំណួររបស់សហព្រះរាជអាជ្ញាអំពីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទំនប់ត្រពាំងថ្ម (ទីតាំងដែលអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមិនត្រូវបានកំណត់គោលដៅនៅក្នុងដីកាដំណោះស្រាយ) មានភាពពាក់ព័ន្ធ ទោះបីជាមានការជំទាស់ពីក្រុមមេធាវីការពារក្តីលោក នួន ជា ក៏ដោយ។

២៣១៦. ទោះបីជាគ្មានគោលនយោបាយប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងអង្គហេតុជាកម្មវត្ថុនៃសំណុំរឿង ០០២/០២ ក៏ដោយ ក៏អង្គជំនុំជម្រះបានផ្តល់យុត្តិកម្មទៅលើភាពមិនប្រក្រតីនៃគោលជំហររបស់ខ្លួន៖

> "អង្គជំនុំជម្រះយល់ឃើញថា សំណួររបស់សហព្រះរាជអាជ្ញាមានភាពពាក់ព័ន្ធទៅនឹងអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បន្ថែមពីលើការបោសសម្អាតផ្ទៃក្នុង"[2347]។

២៣១៧. គោលជំហរនេះមានភាពផ្ទុយស្រឡះនឹងវិសាលភាពនៃបណ្តឹងទាំងមូល និងបណ្តាលឱ្យខាតពេលយ៉ាងច្រើន ពីព្រោះថាសាក្សីត្រូវបានស្តាប់ចម្លើយអំពីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅតាមទីតាំងឧក្រិដ្ឋកម្មទាំងអស់ ក្នុងពេលជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ ដោយសហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឱ្យទទួលបានពេលវេលាបន្ថែម ដើម្បីបង្ហាញឯកសារអំពីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងសវនាការស្តីពីឯកសារគន្លឹះ ពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះក្រុមគោលដៅជាក់លាក់[2348]។

២៣១៨. គោលជំហរផ្ទុយស្រឡះរបស់អង្គជំនុំជម្រះក៏បង្ហាញផងដែរថា ភាគច្រើន ចៅក្រមមិនសូវយល់អំពីទម្លាក់ករណ៍របស់ដីកាដំណោះស្រាយ។ ការវិភាគរបស់អង្គជំនុំជម្រះលើខ្លឹមសារ "ការបោសសម្អាតផ្ទៃក្នុង" ដូចមានបង្ហាញនៅក្នុងអ៊ីមែល ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ គឺជាឧទាហរណ៍ថ្មីមួយទៀត។ លោក ខៀវ សំផន មិនត្រូវទទួលរងនូវផលវិបាកពីការអល់អែក ឬការបង្ហាញអំពីភាពអគតិរបស់អង្គជំនុំជម្រះចំពោះគាត់នោះឡើយ។

---

[2347] សារអេឡិកត្រូនិក ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E362**។

[2348] ប្រតិចារឹក ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/391.1** ទំព័រ ៥ ប្រហែលម៉ោង [០៩.១៧.៤២]។

## ភាគទី ៤. ការដាក់បទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍

### ជំពូកទី ១. ការរៀបអាពាហ៍ពិពាហ៍

### ផ្នែកទី ១. បទចោទ

២៣១៩. លោក ខៀវ សំផន ត្រូវបានចោទប្រកាន់អំពីអង្គហេតុកើតឡើងនៅទូទាំងប្រទេស ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតកំណត់ថាជា "អំពើអមនុស្សធម៌ផ្សេងទៀត" ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)[2349]។

២៣២០. ពីកថាខណ្ឌ ៨៤៣ ដល់កថាខណ្ឌ ៨៦០ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋានអំពីអង្គហេតុពាក់ព័ន្ធនឹងការដាក់បទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានជាអាទិ៍ថា បុរស និងស្ត្រីត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ ក្នុងអំឡុងរបបនោះ នៅទូទាំងប្រទេស ក្នុង "ពិធីរួមគ្នា ចាប់ពីពីរគូទៅជាងមួយរយគូ" ដែលរៀបចំដោយថ្នាក់លើ (កថាខណ្ឌ ៨៤៤)។ សហចៅក្រមស៊ើបអង្កេតក៏បានចោទប្រកាន់ទៀតថា ការរួមដំណេកត្រូវបានឃ្លាំមើលដោយកងឈ្លប (កថាខណ្ឌ ៨៥៨)។

### ផ្នែកទី ២. ការបង្ហាញភស្តុតាង

#### ១. កំណត់សម្គាល់បឋម

---

[2349] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៣០-១៤៣៣, ១៤៤២-១៤៤៧, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ** E301/9/1.1 ទំព័រ ៦ (ត្រង់កំណត់សម្គាល់ជើងទំព័រ ១៥ នៃឧបសម្ព័ន្ធនេះ អង្គជំនុំជម្រះសាលាដំបូងបានរំឭកថា អង្គបុរេជំនុំជម្រះបានលុបចោលការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត ដែលថាមានអំពើរំលោភផ្លូវភេទ ក្នុងទម្រង់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រោះថាការរំលោភផ្លូវភេទតែមួយ ពុំមាននោះទេនៅចន្លោះឆ្នាំ ១៩៧៥ និង ១៩៧៩)។

២៣២១. ការដាក់បទបញ្ហាលើការរៀបអាពាហ៍ពិពាហ៍ គឺជាបញ្ហាដែលត្រូវបានលើកឡើងច្រើនជាងគេបំផុត នៅក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ ពីព្រោះអ្នកដែលមកផ្តល់សក្ខីកម្មភាគច្រើនត្រូវបានសួរដេញដោលលើបញ្ហានេះ (ក)។ ក្រៅពីនេះទៀត កំណត់ហេតុស្តាប់ចម្លើយដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង (ខ)។

## ក. លក្ខណៈពិសេសនៃភស្តុតាងជាសក្ខីកម្ម

### 1. ភស្តុតាងជាសក្ខីកម្មយ៉ាងច្រើន

២៣២២. ក្រៅពីមនុស្សជាច្រើនដែលត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មអំពីប្រធានបទផ្សេងទៀត ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ នៅក្នុងសវនាការ បុគ្គល ១៦ រូប បានផ្តល់សក្ខីកម្មដោយឡែកក្នុងក្របខ័ណ្ឌនៃវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ គឺអ្នកជំនាញ ២ រូប សាក្សី ២ រូប និងដើមបណ្តឹងរដ្ឋប្បវេណី ១២ រូប (ដើមបណ្តឹងរដ្ឋប្បវេណី ៣ រូប ស្តីពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម)។ ក្នុងចំណោមសាក្សីទាំង ២ រូប និងដើមបណ្តឹងរដ្ឋប្បវេណីទាំង ១២ រូប បុគ្គល ៧ រូប មិនត្រូវបានសហាចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០២ នោះឡើយ[2350]។

### 2. លក្ខណៈពិសេសនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

២៣២៣. តាមនិយមន័យ ដើមបណ្តឹងរដ្ឋប្បវេណី គឺជាអ្នកដែលត្រូវបានចាត់ទុកជាជនរងគ្រោះនៃអង្គហេតុឧក្រិដ្ឋ ដែលជាកម្មវត្ថុនៃការជំនុំជម្រះក្តី។ បុគ្គលទាំង ១២ រូប ដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយមាន ឬគ្មានជំនួយពីអង្គការក្រៅរដ្ឋាភិបាល បានមកផ្តល់សក្ខីកម្ម និងបានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើកិច្ចដំណើរការនីតិវិធី។ យើងមិននិយាយថាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុទ្ធតែកុហកនោះទេ ប៉ុន្តែ យើងទទួលស្គាល់ថាមានភាពអគតិ និងទាមទារជា

---

[2350] ដើមបណ្តឹងរដ្ឋប្បវេណី៖ 2-TCCP-274, ជា ឌៀប, ផាន់ ហ៊ឹម, មុំ វុន, ប៉ែន សុចាន់, ព្រាប សុឃឿន, សាក្សី៖ 2-TCW-1002 (ព្រាប សុឃឿន និង 2-TCW-1002 ត្រូវបានកោះហៅដោយផ្អែកតែទៅលើចម្លើយពួកគាត់នៅក្នុងសំណុំរឿង ០០៣ និង ០០៤)។

ចាំបាច់ឱ្យមានការពិនិត្យផ្ទៀងផ្ទាត់ភាពអាចទុកចិត្តបាន និងភាពអាចជឿជាក់បាន នៃចម្លើយរបស់ពួកគាត់។

២៣២៤. ជាក់ស្តែង ក្រៅពីដើមបណ្តឹងរដ្ឋប្បវេណីមិនបានធ្វើសម្បថ ពួកគាត់ត្រូវបានតំណាងជាសមូហភាពដែលអាចមានផលប៉ះពាល់ទៅលើខ្លឹមសារនៃចម្លើយរបស់ពួកគាត់។ ជាការពិត ក្នុងក្របខ័ណ្ឌនៃកិច្ចប្រជុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងក្នុងពេលជួបជុំជាក្រុម ខ្លឹមសារនៃសក្ខីកម្មរបស់ពួកគាត់អាចត្រូវបានកែប្រែ ដោយចេតនា ឬដោយអចេតនា។

២៣២៥. បញ្ហានៃភាពអាចទុកចិត្តបាននៃសក្ខីកម្មរបស់ពួកគាត់បានចោទឡើងយ៉ាងខ្លាំង ពីព្រោះតែសក្ខីកម្មខ្លះរបស់អ្នកខ្លះបានប្រែប្រួលទៅតាមកាលវេលា និងអាស្រ័យទៅតាមកិច្ចដំណើរការនីតិវិធី ដោយមានការបន្ថែមព័ត៌មានដែលតែងតែជាភស្តុតាងដាក់បន្ទុក គឺមិនមែនដោយចៃដន្យនោះទេ។ ករណីចោទជាបញ្ហាបំផុត គឺករណីរបស់ ជា ឌៀប ដែលបានដាក់ពីរ ពាក់ព័ន្ធនឹងការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩ និងនៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៣ ប៉ុន្តែ គាត់ទើបតែបញ្ជាក់អំពីការជួបលោក ខៀវ សំផន ក្នុងទម្រង់បែបបទព័ត៌មានបន្ថែម ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៤។ ការពន្យល់មិនអាចទទួលយកបានអំពីហេតុផលនៃការបញ្ចេញឈ្មោះជនជាប់ចោទយឺតពេលនៅក្នុងចម្លើយរបស់គាត់ ចោទជាបញ្ហា[2351]។

---

[2351]ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា ឌៀប ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩ **ឯកសារ E319/45.4.8** ERN 01049379 (ភាសាខ្មែរ) ERN 01139644 (ភាសាអង់គ្លេស), ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់ ជា ឌៀប ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៣ **ឯកសារ E319/45.4.8** ERN 01049384 (ភាសាខ្មែរ) ERN 01139647 (ភាសាអង់គ្លេស) (ឬ**ឯកសារ E3/5010b** ERN 01049384), ទម្រង់បែបបទព័ត៌មានបន្ថែមរបស់ ជា ឌៀប ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E3/5010a** ERN 01003332, ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/467.1** ទំព័រ ៤៣-៤៥ ប្រហែលម៉ោង [១១.២០.៥០]។ ទាក់ទងនឹងការប្រែប្រួលនៃចម្លើយ សូមមើលផងដែរ៖ 2-TCCP-274 ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ៥ ប្រហែលម៉ោង [០៩.១៣.១២] ទំព័រ ១៣ ប្រហែលម៉ោង [០៩.៣៧.០៤], មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/475.1** ទំព័រ ៣៧ ប្រហែលម៉ោង [១១.១៧.០៥] ទំព័រ ៦៧-៧១ ចន្លោះម៉ោង [១៥.១៤.៤៤] និង [១៥.២៣.៥៩]។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានរៀបរាប់រឿងរ៉ាវជីវិតរៀបការរបស់គាត់ ដែលខុសគ្នាពីចម្លើយឆ្លើយកាលពីពេលមុន ដើម្បីកាត់បន្ថយជាអតិបរមានូវផលវិបាកនានានៃការរៀបការដែលបានរៀបចំឱ្យគាត់នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ។

២៣២៦. ឧទាហរណ៍នេះចោទជាបញ្ហាជាទូទៅបំផុត ពាក់ព័ន្ធនឹងភាពអាចទុកចិត្តបាននៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ យ៉ាងណាមិញ ការប្រៀបធៀបបទពិសោធន៍ទូទៅរបស់សាក្សីដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ ជាមួយនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្តែងឱ្យឃើញភាពខុសគ្នាខ្លាំងនៃបទពិសោធន៍ និងការយល់ឃើញ រវាងសាក្សីដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានកោះហៅជាពិសេស ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍។

២៣២៧. ចំណុចនេះពន្យល់យ៉ាងច្បាស់ តាមរយៈការជ្រើសរើសដើមបណ្តឹងរដ្ឋប្បវេណីឱ្យមកផ្តល់សក្ខីកម្មដោយមេធាវីរបស់ពួកគេ ដោយសហព្រះរាជអាជ្ញា ឬដោយអង្គជំនុំជម្រះ អាស្រ័យទៅតាមបទពិសោធន៍ឈឺចាប់ខ្លាំង ដែលអាចធ្វើឱ្យព័ត៌មានដាក់បន្ទុករឹតតែមានភាពរឹងមាំ។ ប៉ុន្តែ យើងត្រូវតែយល់ស្របផងដែរថាចំពោះបទពិសោធន៍របស់ប្រជាជនខ្មែរនៅទូទាំងប្រទេស រឿងរ៉ាវទាំងនេះមិនសុទ្ធតែផ្ទុះបញ្ចាំងការឆ្លងកាត់ជួបប្រទះជាទូទៅ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នោះទេ។

២៣២៨. ភ័ស្តុតាងទាំងនេះនឹងត្រូវលើកឡើងម្តងទៀត ពាក់ព័ន្ធនឹងគោលនយោបាយ ដែលត្រូវបានចោទប្រកាន់ ស្តីពីការដាក់បទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែ យើងចាំបាច់ត្រូវធ្វើការសង្កេតបឋមនេះសិន។ អង្គជំនុំជម្រះត្រូវតែគិតគូរដល់ចំណុចនេះ ក្នុងពេលពិចារណាទៅលើតម្លៃជាភ័ស្តុតាងនៃសក្ខីកម្ម។

## 3. <u>សារៈសំខាន់នៃសក្ខីកម្មរបស់អ្នកជំនាញ</u>

២៣២៩. អ្នកជំនាញពីររូបក៏បានផ្តល់សក្ខីកម្មអំពីសេចក្តីសន្និដ្ឋាននៃការស្រាវជ្រាវរបស់ពួកគាត់ ទៅលើការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ លោកស្រី Kasumi NAKAGAWA បានផ្តល់សក្ខីកម្ម ដោយផ្អែកលើការស្រាវជ្រាវជាក់លាក់របស់គាត់ទៅលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចំណែកឯលោកស្រី Peg LEVINE បានផ្តល់សក្ខីកម្មអំពីការស្រាវជ្រាវជាទូទៅរបស់គាត់ទៅលើការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទោះបីជាសក្ខីកម្មរបស់ពួកគាត់ត្រូវបានកម្រិតជាចាំបាច់ត្រឹមសំណាកនៃការស្រាវជ្រាវក៏ដោយ ក៏វាអាចផ្តល់ព័ត៌មានគួរឱ្យ

ចាប់អារម្មណ៍ ពាក់ព័ន្ធនឹងបរិបទវប្បធម៌នៅកម្ពុជា នៅមុន និងក្នុងអំឡុង និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។

### ខ. កំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានដាក់បញ្ចូលយ៉ាងច្រើនសន្ធឹកសន្ធាប់

២៣៣០. ផ្នែកនៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងការដាក់បទបញ្ញាលើការរៀបអាពាហ៍ពិពាហ៍ ប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរចំនួន ១១៩ ឬកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១៦ រូប។

២៣៣១. កថាខណ្ឌ ៨៦១ នៃដីកាដំណោះស្រាយ បង្ហាញថា "ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៦៤ នាក់ ត្រូវបានប្រកាសទទួលស្គាល់ ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ"។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ៦ រូប ដែលជាភាគីនៃសំណុំរឿង ០០២ រួចហើយ ក៏ជាភាគីនៃសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ផងដែរ ហើយបានដាក់បញ្ចូលឯកសារបន្ថែម (ឧទាហរណ៍ ទម្រង់បែបបទព័ត៌មានបន្ថែមទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី) ដែលត្រូវបានធ្វើឡើង ក្នុងក្របខ័ណ្ឌនៃកិច្ចស៊ើបសួរទាំងនោះ[2352]។

២៣៣២. បញ្ហានៃភាពអាចជឿជាក់បាននៃចម្លើយជាលាយលក្ខណ៍អក្សរជារួម របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាពិសេស កាលៈទេសៈដែលចម្លើយទាំងនោះត្រូវបានធ្វើឡើង ត្រូវបានរៀបរាប់ពីខាងលើរួចមកហើយ[2353]។ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះត្រូវមានការប្រយ័ត្នប្រយែងខ្ពស់ ក្នុងពេលពិនិត្យលើចម្លើយជាលាយលក្ខណ៍អក្សរចំនួន ៨០ មកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលត្រូវបានទទួលយកជាភ័ស្តុតាងយ៉ាងច្រើនសន្ធឹកសន្ធាប់។

### ២. ភ័ស្តុតាងក្រៅវិសាលភាព

[2352] 2-TCCP-232, សេង សឿន, ជា ឌៀប, 2-TCW-1002, ប៉ែន សុចាន់, ព្រាប សុឃឿន។

[2353] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៥២៥-៥៥១។

២៣៣៣. ទោះបីជាអង្គជំនុំជម្រះទទួលបានបណ្ដឹងអំពីអង្គហេតុទាំងមូលនៃការរៀបអាពាហ៍ពិពាហ៍ ក៏ដោយ ក៏យើងបានរំឭកពីខាងលើថា អង្គជំនុំជម្រះទទួលបានបណ្ដឹងតែអំពីអង្គហេតុនៃការរំលោភសេពសន្ថវៈក្នុងក្របខ័ណ្ឌអាពាហ៍ពិពាហ៍ប៉ុណ្ណោះ[2354]។ បើទោះជាមានសេចក្ដីសម្រេចរបស់ខ្លួនផ្ទាល់ និងមានការជំទាស់ពីសំណាក់ក្រុមមេធាវីការពារក្ដីក៏ដោយ ក៏អង្គជំនុំជម្រះបានបណ្ដោយឱ្យសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនរូប ដែលផ្ដល់សក្ខីកម្មក្នុងវគ្គស្ដីពីការដាក់បទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍ លើកឡើងអំពីអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍។

២៣៣៤. ដើមបណ្ដឹងរដ្ឋប្បវេណី ៤ រូប គឺ ហេង ឡៃហ៊ាង, ង៉ែត ចាត, 2-TCCP-274 និង មុំ វុន[2355] បានរៀបរាប់អំពីអង្គហេតុនៃការរំលោភសេពសន្ថវៈលើជនផ្សេងទៀត ក្រៅក្របខ័ណ្ឌអាពាហ៍ពិពាហ៍។ ដូច្នេះ ផ្នែកនេះនៃសក្ខីកម្មរបស់ពួកគាត់ត្រូវបដិសេធចោល ពីព្រោះវាពាក់ព័ន្ធនឹងអង្គហេតុ ដែលលោក ខៀវ សំផន មិនត្រូវបានចោទប្រកាន់។

## ៣. ភស្តុតាងដែលមិនត្រូវបានជំទាស់តវ៉ា

២៣៣៥. មុននឹងចូលទៅពិនិត្យមើលភស្តុតាង ក្រុមមេធាវីការពារក្ដីសូមបញ្ជាក់ថា ខ្លួនមិនជំទាស់ទៅនឹងអត្ថិភាពនៃការរៀបអាពាហ៍ពិពាហ៍ច្រើនគូ ក្រោមការរៀបចំរបស់កម្មាភិបាលមូលដ្ឋាន នៅថ្នាក់ឃុំ សហ-ករណ៍ និងកង ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នោះទេ។ ក្រុមមេធាវីការពារក្ដីក៏មិនជំទាស់ដែរថា ការរៀបអាពាហ៍ពិពាហ៍មិនគោរពតាមពិធី និងទំនៀមទម្លាប់បុរាណខ្មែរ។

---

[2354]សូមមើលផ្នែកខាងលើ កថាខណ្ឌ ១៧១-២០៣។

[2355]ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/476.1** ទំព័រ ៥៣-៥៤ ប្រហែលម៉ោង [១៤.១៥.២៧], ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៨ ប្រហែលម៉ោង [០៩.២៣.០៣], 2-TCCP-274 : ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ៥-៦ ប្រហែលម៉ោង [០៩.១៣.១២], 2-TCCP-274 : ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ៥-៦ ប្រហែលម៉ោង [០៩.១៣.១២] ទំព័រ ១៤ ប្រហែលម៉ោង [០៩.៣៧.០៤]៖ "ចាសហ្នឹងខ្ញុំអត់បានដាក់ហ្នឹងមែន ប៉ុន្តែខ្ញុំនឹកឃើញអាពេលហ្នឹង ខ្ញុំបំពេញបន្តិចទៅចាស" ទំព័រ ១៤ ប្រហែលម៉ោង [០៩.៣៧.០៤], មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/475.1** ទំព័រ ៣៧-៣៨ប្រហែលម៉ោង [១១.១៧.០៥] ទំព័រ ៦៧-៧១ចន្លោះម៉ោង [១៥.១៤.៤៤] និង [១៥.២៣.៥៩]។

## ផ្នែកទី ៣. ការពិនិត្យមើលភ័ស្តុតាងពាក់ព័ន្ធ

២៣៣៦. សក្ខីកម្ម កំណត់ហេតុស្តាប់ចម្លើយ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតយ៉ាងច្រើនសន្ធឹកសន្ធាប់ មិនអាចឱ្យពិនិត្យមើលសព្វជ្រុងជ្រោយ ឬពិភាក្សាឱ្យបានលម្អិតឡើយ។ អង្គជំនុំជម្រះរឹតតែមិនអាចទទួលបណ្តឹងអំពីអង្គហេតុនៅទូទាំងប្រទេសឡើយ។ ដូច្នេះ ការពិនិត្យមើលភ័ស្តុតាងអំពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នឹងត្រូវធ្វើឡើង តាមប្រធានបទ ដូចបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ និងពិនិត្យមើលនៅក្នុងសវនាការ (២)។ ដើម្បីយល់ឱ្យច្បាស់អំពីការដាក់បទបញ្ញាលើការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ យើងត្រូវពិនិត្យមើលភ័ស្តុតាងដែលបានស្តាប់ និងមានស្រាប់ អំពីការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ជាមុនសិន (១)។

### ១. ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ

### ក. ការសម្រេចចិត្តមិនអាស្រ័យនឹងឆន្ទៈរបស់អនាគតគូស្វាមី-ភរិយា

២៣៣៧. អ្នកជំនាញ ដែលបានផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ គឺលោកស្រី Kasumi NAKAGAWA និងលោកស្រី Peg LEVINE បានយល់ស្របគ្នាជាឯកច្ឆន្ទអំពីបញ្ហានៃការរៀបអាពាហ៍ពិពាហ៍ខ្មែរ តាមការផ្សំផ្គុំពីសំណាក់អាណាព្យាបាល។ លោកស្រី Kasumi NAKAGAWA បានសង្ខេបអំពីការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ថាជារឿងសមូហភាពសុទ្ធសាធ គឺមិនមែនជារឿងបុគ្គលនោះទេ។ បើតាមលោកស្រី “នេះមិនមែនជារឿងបុគ្គលនោះទេ គឺជារឿងគ្រួសារ រវាងភាគីពីរ រវាងគ្រួសារពីរ”។ លោកស្រីបានបន្ថែមទៀតថា “នេះក៏ជាកិច្ចការរបស់ឃុំផងដែរ ពីព្រោះអ្នកភូមិត្រូវបានអញ្ជើញឱ្យផ្តល់ការអនុញ្ញាតដល់ការរៀបអាពាហ៍ពិពាហ៍”[2356]។ នៅពេលសុំឱ្យបញ្ចេញមតិលើការយល់ឃើញនេះ លោកស្រី Peg LEVINE បានអះអាងថា “ពិតណាស់ នេះជាកិច្ចការគ្រួសារ ប៉ុន្តែវាជាកិច្ចការរបស់គ្រួសារច្រើន ជាកិច្ចការរបស់

[2356] ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ២៩ ប្រហែលម៉ោង [១០.៤៥.១១]។

សហគមន៍។ ដូច្នេះ វាមិនមែនពាក់ព័ន្ធតែនឹងគ្រួសារនោះទេ គឺវាពាក់ព័ន្ធនឹងគ្រួសារ និងសហគមន៍ជាទូទៅ”[2357]។

២៣៣៨. ដូច្នេះ ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ដែលជាកិច្ចសន្យារវាងគ្រួសារពីរ ដោយមិនចាំបាច់មានការព្រមព្រៀងពីសាមីខ្លួន មិនត្រូវគ្នានឹងទស្សនាទាននៃការរៀបអាពាហ៍ពិពាហ៍ចេញពីសេចក្តីស្នេហារបស់ពួកបស្ចិមប្រទេសនោះទេ។

## 1. សញ្ញាណនៃមនោសញ្ចេតនាស្នេហា ក្នុងអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ

២៣៣៩. ក្នុងវប្បធម៌ខ្មែរ ការរៀបអាពាហ៍ពិពាហ៍មិនមែនគ្រាន់ត្រឹមតែជាការរួមសុខទុក្ខរបស់មនុស្សពីរនាក់ប៉ុណ្ណោះទេ គឺជាកិច្ចព្រមព្រៀង ឬកិច្ចសន្យា រវាងគ្រួសារពីរ។ នៅមុនឆ្នាំ ១៩៧៥ និងរហូតមកទល់សព្វថ្ងៃនេះ បើតាមលោកស្រី Kasumi NAKAGAWA កិច្ចសន្យានេះគឺជាកម្មវត្ថុនៃការចរចានិងអមដោយបណ្ណាការជាប្រពៃណីដែលគ្រួសារខាងប្រុសត្រូវជូនទៅគ្រួសារខាងស្រី។ ដោយសារតែកិច្ចសន្យានេះមានផលវិបាកសំខាន់ខាងបេតិកភណ្ឌ ជារឿយៗ គ្រួសារគូដណ្តឹងស្វែងរកកិច្ចព្រមព្រៀងមួយដែលផ្តល់ប្រយោជន៍ដល់សាមីខ្លួនទាំងពីរ។ អាស្រ័យហេតុនេះ ការរៀបអាពាហ៍ពិពាហ៍ត្រូវបានរៀបចំជាទូទៅដោយគ្រួសារមកពីមជ្ឈដ្ឋានសង្គម និងមានបេតិកភណ្ឌសមមូលគ្នា[2358]។

២៣៤០. លើសពីសញ្ញាណនៃ “សេចក្តីស្នេហាអណ្តែតអណ្តូង” “ការស្រឡាញ់” សហព័ទ្ធរបស់ខ្លួន ក្នុងវប្បធម៌ខ្មែរ មានន័យខុសគ្នា។ ជាក់ស្តែង បើតាមលោកស្រី Kasumi NAKAGAWA៖

---

[2357] ប្រតិចារឹក ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/480.1** ទំព័រ ៣៨ ប្រហែលម៉ោង [១៤.២៥.០២]។

[2358] <u>កាស៊ូមិ ណាកាហ្កាវ៉ា</u> ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/473.1** ទំព័រ ២៨ ប្រហែលម៉ោង [១០.៥៥.៣៨]៖ “ចាស ខ្ញុំដឹងថាប្រព័ន្ធនេះ គឺឥឡូវនេះកំពុងតែអនុវត្តនៅក្នុងសង្គមខ្មែរនៅឡើយទេ”, ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ៣៥ ប្រហែលម៉ោង [១១.០៦.២៦]៖ “[...] ដំណើរការរៀបចំការរៀបការនេះចាប់ផ្តើមឡើងដែលថាខាងប្រុសចាប់ផ្តើម ហើយខាងស្រីយល់ព្រម គឺថាអាចប្រហែលជាចំណាយពេលរាប់ខែ បន្ទាប់មានការចរចាគ្នាជាច្រើនរវាងគ្រួសារទាំងពីរ”, ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/473.1** ទំព័រ ៥៨-៥៩ ប្រហែលម៉ោង [១០.៥៥.៣៨], ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/473.1** ទំព័រ ១៥ ប្រហែលម៉ោង [០៩.៥៣.១៧], ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ៣៦ ប្រហែលម៉ោង [១១.០៩.២២]។

"ពាក្យថាស្រឡាញ់ ឬស្នេហានេះ គឺពិបាកក្នុងការនិយាយ ឬក៏កំណត់អត្ថសញ្ញាណណាស់ តាមប្រពៃណី ឬក៏ទំនៀមទម្លាប់ខ្មែរនោះ។ ស្ត្រីគឺត្រូវយល់តាមការសន្មតថា [...] គាត់ត្រូវតែស្រឡាញ់ប្តី ប៉ុន្តែ ពាក្យថាស្នេហានេះក៏វាមានលក្ខណៈស្មុគស្មាញ។ តាមអ្វីដែលខ្ញុំយល់នោះ មុនរបបខ្មែរក្រហម បើសិនជាស្ត្រីមានស្នេហាពិតប្រាកដចំពោះប្តី គេយល់ថាសំណាងល្អក្នុងជីវិត ពីព្រោះគេយល់ថា ស្នេហាមិនកើតឡើងដោយស្វ័យប្រវត្តិចេញពីអាពាហ៍ពិពាហ៍ទេ។ ស្ត្រីត្រូវតែបង្ហាញពីមនោសញ្ចេតនារបស់ខ្លួនទៅប្តី"[2359]។

២៣៤១. លោកស្រី Peg LEVINE បានគាំទ្រយោបល់នេះ។ គាត់បានអះអាងថា "គេកម្រនិយាយពីសេចក្តីស្នេហាណាស់ ចំពោះអ្នកដែលគាត់បានសម្លាស"។ ប៉ុន្តែ គាត់បានបន្ថែមថា "ចំណងបណ្តាលមកពីកត្តាវប្បធម៌ច្រើនជាងសេចក្តីស្នេហា"។ នៅពេលប៉ុនប៉ងប្រកាន់យកទស្សនៈ "ផ្តោតលើការគិត" អ្នកជំនាញអាចកត់សម្គាល់ឃើញថា ទស្សនាទាននៃសេចក្តីស្នេហាស្ទើរតែគ្មានទាល់តែសោះនៅក្នុងអាពាហ៍ពិពាហ៍ខ្មែរ[2360]។ ដូច្នេះ ទស្សនៈប្រពៃណីត្រូវតែជាការចាប់ផ្តើមការប្រៀបធៀបរវាងការរៀបអាពាហ៍ពិពាហ៍ នៅមុន និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ យើងចាំបាច់ត្រូវផ្តាច់ចេញពីចក្ខុវិស័យ "បស្ចិមប្រទេស" ដើម្បីវាយតម្លៃអំពីភាពខុសគ្នានៃការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមិនងាយស្រួលនឹងធ្វើ សម្រាប់តួអង្គសង្គមស៊ីវិលដែលតស៊ូមតិដើម្បីផ្លាស់ប្តូរផ្នត់គំនិតដែលនៅតែមានក្រោយសម័យខ្មែរក្រហម ក៏ដូចជាសម្រាប់អ្នកស្រាវជ្រាវ។ម្យ៉ាងវិញទៀត លោកស្រី Peg LEVINE បានបង្ហាញអំពីការលំបាកដែលគាត់ជួបប្រទះ នៅពេលលទ្ធផលនៃការស្រាវជ្រាវរបស់គាត់ មិនឆ្លុះបញ្ចាំងយោបល់ភាគច្រើនអំពីការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2361]។

---

[2359] កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/473.1** ទំព័រ ២៤-២៥ ប្រហែលម៉ោង [១០.៤០.០៨]។

[2360] ផេហ្គី ឡឺវ៉ាញ ប្រតិចារឹក ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/480.1** ទំព័រ ៤៨-៤៩ ប្រហែលម៉ោង [១៥.១៤.៥៥]។

[2361] ផេហ្គី ឡឺវ៉ាញ ប្រតិចារឹក ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/480.1** ទំព័រ ៣៣ ប្រហែលម៉ោង [១៤.០៥.២២]៖ "សំណួរនេះគឺថាសំណួរមួយស្មុគស្មាញណាស់សម្រាប់ខ្ញុំ ជាពិសេសបទពិសោធន៍ពាក់ព័ន្ធជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា ក្នុងឋានៈជា*កុងស៊ុលតង់*ឯករាជ្យ។ ពាក្យថាជា "កុងស៊ុលតង់ឯករាជ្យ" នេះគឺថាជាទីប្រឹក្សាមួយសម្រាប់គម្រោងមួយដែលខ្ញុំបានធ្វើការ ប៉ុន្តែខ្ញុំមិនដែលបានឃើញរបាយការណ៍ចុងក្រោយទេ ពីព្រោះរបាយការណ៍នោះប្រហែលជាខាងអ្នកផ្តល់មូលនិធិនោះ គឺថាមិនពេញចិត្ត ឬក៏យ៉ាងណានោះ។ [...] ដើម្បីឱ្យអង្គការហ្នឹង គឺថាបំពេញបេសកកម្មរបស់ខ្លួនទៅមុខទៀត។ ជួនកាលយើងមានការឃោគយល់ទៅលើគម្រោងណានីមួយៗជាមួយនឹងថវិកា ដើម្បីសម្របសម្រួលគ្នាឱ្យទទួលបាននូវលទ្ធផល តែខ្ញុំគិតឃើញថា លទ្ធផលនោះ គឺថាមិនមែនជាលទ្ធផលមួយដែលសុទ្ធតែឯករាជ្យនោះទេ។ ដូច្នេះ ទាក់ទងនឹងបញ្ហានេះ ខ្ញុំមិនចង់មានការពាក់ព័ន្ធជាមួយនឹងខាងផ្នែក ទៅលើជាមួយអង្គការណាមួយនោះទេ [...]"។

២៣៤២. ទោះបីជាអ្នកជំនាញទាំងពីររូប បានកត់សម្គាល់អំពីកង្វះភាពពាក់ព័ន្ធនៃទស្សនាទានសេចក្តីស្នេហា នៅក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរក៏ដោយ ក៏លោកស្រី Kasumi NAKAGAWA បានបញ្ជាក់ថា បើតាមគំនិតគាត់ ស្រីដែលត្រូវបានគេរៀបការឱ្យ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ "មិនតម្រូវឱ្យស្រឡាញ់ប្តីនោះទេ ពីព្រោះមិនមានការព្រមព្រៀងពីឪពុកម្តាយឱ្យរៀបអាពាហ៍ពិពាហ៍"។ ផ្ទុយទៅវិញ ស្ត្រីមានកាតព្វកិច្ចស្រឡាញ់ប្តី ក្នុងករណីមានការព្រមព្រៀងពីឪពុកម្តាយឱ្យរៀបអាពាហ៍ពិពាហ៍។ ចំពោះអ្នកជំនាញ នៅមុនឆ្នាំ ១៩៧៥ ករណីនៃការរៀបអាពាហ៍ពិពាហ៍កើតចេញពីសេចក្តីស្នេហា "កម្រមានណាស់"[2362]។ ការស្រឡាញ់សហព័ទ្ធ គឺជារបៀបមួយនៃការផ្តល់កិត្តិយសដល់ជម្រើសរបស់ឪពុកម្តាយក្នុងការរៀបអាពាហ៍ពិពាហ៍ ដោយហេតុថាការយល់ព្រមពីសំណាក់សាមីខ្លួនមិនមែនជាមូលដ្ឋាននៃការរៀបអាពាហ៍ពិពាហ៍នោះទេ។

## 2. ប្រភេទនៃការព្រមព្រៀងក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ

២៣៤៣. ក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ កូនត្រូវបានដកចេញពីដំណើរការនៃការចរចា។ អ្នកជំនាញ Kasumi NAKAGAWA បានប្រមូលរឿងរ៉ាវស្តីពីការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ ឬពីឆ្នាំ ១៩៦០ ដល់ឆ្នាំ ១៩៧៥។ គាត់ទាញបាននូវការវិភាគមួយយ៉ាងច្បាស់៖

> "ចំពោះលទ្ធភាពរបស់ស្ត្រីក្នុងការសម្រេចចិត្ត គឺស្ទើរតែគ្មាន មានន័យថា កូនស្រីទទួលការណែនាំ ឬបញ្ជាពីឪពុកម្តាយឱ្យរៀបការជាមួយបុរសណាម្នាក់"[2363]។

២៣៤៤. អ្នកជំនាញបានបន្ថែមទៀតថា "ឪពុកម្តាយសម្រេចចិត្តជំនួសកូនស្រី" ហើយទោះបីជាកូនប្រុសមានសេរីភាពជាងក៏ដោយ ក៏ចាំបាច់ត្រូវតែមានការយល់ព្រមពីឪពុកម្តាយ[2364]។ លោកស្រី Peg

[2362] កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ** E1/473.1 ទំព័រ ២៤ ប្រហែលម៉ោង [១០.៤០.០៨]។

[2363] កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ** E1/472.1 ទំព័រ ២៨ ប្រហែលម៉ោង [១០.៤១.២០] (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

LEVINE យល់ស្របតាមយោបល់នេះ[2365]។ យោបល់នេះត្រូវបានបញ្ជាក់អះអាងក្នុងសវនាការដោយបុគ្គលជាច្រើន ដូចជា អ៊ុំ សុផានី[2366] ឬ មាស ឡៃហួរ ដែលត្រូវបានឪពុកម្តាយផ្សំផ្គុំ "តាំងពីយូរណាស់មកហើយ"[2367]។ ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-274 បានរៀបអាពាហ៍ពិពាហ៍ មុនរបបកម្ពុជាប្រជាធិបតេយ្យ នៅអាយុ ១៥ ឬ ១៦ ឆ្នាំ។ គាត់បានឆ្លើយថា គាត់មិនស្គាល់ប្ដីគាត់ មុនថ្ងៃភ្ជាប់ពាក្យទេ ហើយ "ឪពុកម្ដាយគាត់" ជាអ្នកសម្រេចចិត្តទុកដាក់ គឺ "អត់ដូចសម័យឥឡូវទេ ដែលក្មេងៗស្គាល់គ្នាមុនពេលរៀបការ"[2368]។

២៣៤៥. ដូច្នេះ ការព្រមព្រៀងពីសំណាក់អនាគតគូស្វាមី-ភរិយា មិនមែនជារឿងសំខាន់ទេ ក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ។ ចំពោះអ្នកជំនាញ "កូនស្រីរំពឹងឱ្យឪពុកម្ដាយជាអ្នកសម្រេចលើមង្គលការរបស់ខ្លួន" និងយល់ព្រម "ដោយបិទភ្នែក" ដោយសារទុកចិត្តថាឪពុកម្ដាយសម្រេចចិត្តត្រូវជាង"។ ជាក់ស្ដែង គាត់បានពន្យល់ថាតាមការវិភាគរបស់គាត់ "ការបង្ខំ" ឱ្យរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺដោយសារតែខ្មែរក្រហម "មិនទទួលបានការទុកចិត្តពីសំណាក់គូស្រករ" ដែល "មិនអាចចាត់ទុកខ្មែរក្រហមជាឪពុកម្ដាយរបស់ខ្លួន"[2369]។ ប៉ុន្តែការវិភាគ

---

[2364]កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ៣០ ប្រហែលម៉ោង [១០.៤៩.២៣] ទំព័រ ២៨ ប្រហែលម៉ោង [១០.៤៣.២០]។

[2365]ផេហ្គី ឡឺវ៉ាញ ប្រតិចារឹក ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/480.1** ទំព័រ ៣៨ ប្រហែលម៉ោង [១៤.២៥.០២]៖ "ដំបូង សូមឆ្លើយតបទៅនឹងសំណួរពាក់ព័ន្ធទៅនឹងចម្លើយរបស់កញ្ញា ណាកាហ្គាវ៉ា។ ចាស ត្រឹមត្រូវហើយ គឺជាកិច្ចការរបស់គ្រួសារជាច្រើននៅក្នុងសហគមន៍ទាំងមូលតែម្ដង មិនមែនតែគ្រួសារនេះមួយទេ"។

[2366]អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/251.1** ទំព័រ ៧៩-៨០ ប្រហែលម៉ោង [១៥.៤៩.៤០]។

[2367]មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ៦៤ ប្រហែលម៉ោង [១៥.២៣.៤២] ទំព័រ ៦៣ ប្រហែលម៉ោង [១៥.១៩.៣៤]

[2368]2-TCCP-274 : ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ២៤-២៥ ប្រហែលម៉ោង [១០.៣៤.២៦]។ ប៉ុន្តែ គំនិតនេះគួរត្រូវបានបង្ហាញឱ្យឃើញពីភាពខុសគ្នាបន្តិចជាមួយនឹងស្ថិតិបច្ចុប្បន្ន ទាក់ទងនឹងការជ្រើសរើសស្វាមី។ ទាក់ទងចំណុចនេះ សូមមើល៖ របាយការណ៍មានចំណងជើងថា "ការវាយតម្លៃពីយ៉េនឌ័រ" (*« Gender Assessment »*) អង្គការ USAID កម្ពុជា ២០១០ **ឯកសារ E3/10661b** ទំព័រ ១៤ ERN 01324462 (ភាសាអង់គ្លេស)៖ "មានស្ត្រីចំនួន ១៩ ភាគរយ ប៉ុណ្ណោះដែលជ្រើសរើសស្វាមីដោយខ្លួនឯង ឬដោយមានការឯកភាពពីសំណាក់អនាគតស្វាមីខ្លួន។ ជំនួសមកវិញ ជារឿយៗ ការសម្រេចជ្រើសរើសស្វាមីនេះ តែងធ្វើឡើងដោយមានការពិភាក្សាជាមួយ "អ្នកដទៃផ្សេង" (២៩ ភាគរយ) ហើយស្ត្រីជាងពាក់កណ្ដាល (៥២ ភាគរយ) ពុំបានចូលរួមទាល់តែសោះក្នុងការជ្រើសរើសគូស្រករ"។

[2369]ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/473.1** ទំព័រ ៨ ប្រហែលម៉ោង [០៩.២៩.៥៣]។

លើការទុកចិត្ត "ដោយបិទភ្នែក" លើការសម្រេចរបស់ឪពុកម្តាយក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ដែលខុសពី "ការបង្ខំ" ក្នុងរបបខ្មែរក្រហម បង្ហាញថាការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំបែបនេះនៅបន្តកើតមានរហូតដល់សព្វថ្ងៃ[2370]។

២៣៤៦. សំណួរដែលចោទឡើងពិតប្រាកដ ដើម្បីបិទបញ្ចប់ការប្រៀបធៀប គឺថា តើជម្រើសនៃការរៀបអាពាហ៍ពិពាហ៍ ក៏ដូចជាការជ្រើសរើសគូស្រករ គឺជាបុព្វសិទ្ធិផ្តាច់មុខរបស់ឪពុកម្តាយដែរឬទេ ហើយតើការប្រកែកត្រូវបានសង្គមទទួលយកដែរឬទេ?

### 3. ភាពមិនអាចប្រកែកបានចំពោះការផ្សំផ្គុំពីឪពុកម្តាយ

២៣៤៧. យោងតាមចម្លើយរបស់អ្នកជំនាញ ភ័ស្តុតាងផ្សេងទៀតដែលបានរៀបរាប់ខាងលើ ក៏ដូចជារឿងរ៉ាវរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី[2371] ការជំទាស់ពីសំណាក់អនាគតគូស្វាមី-ភរិយាទៅនឹងការសម្រេចចិត្តរបស់ឪពុកម្តាយ មិនអាចទទួលយកបានឡើយ។ សម្ពាធពីសង្គម និងពីគ្រួសារទាំងសងខាង មិនអាចឱ្យប្រែក្រឡាស់កិច្ចព្រមព្រៀង ដែលបានចរចា និងសម្រេចពីមុន បានឡើយ។ លោកស្រី Kasumi NAKAGAWA បានពន្យល់ថា ការជំទាស់នឹងឪពុកម្តាយលើបញ្ហាដ៏សំខាន់ គឺមិនអាចទៅរួចទេ៖

> "តាមប្រពៃណី ក្នុងវប្បធម៌ខ្មែរ ក៏ដូចជាវប្បធម៌ដទៃទៀតជាច្រើនដែរ កូនមិនត្រូវបានចាត់ទុកជាបុគ្គលមានសិទ្ធិពេញលេញនោះទេ។ កូនត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិ តែជាទ្រព្យសម្បត្តិរបស់ឪពុកម្តាយ។ ដូច្នេះ

---

[2370] សម្រាប់ជាឧទាហរណ៍ សូមមើលអត្ថបទមានចំណងជើងថា "អាពាហ៍ពិពាហ៍ដោយការរៀបចំ រងការស្តីបន្ទោសថាធ្វើឱ្យគ្រួសារបែកបាក់" រៀបរៀងដោយ MARCHER A. សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ **ឯកសារ E3/7288**។ នៅក្នុងអត្ថបទនោះ អ្នកនិពន្ធបង្ហាញពីបញ្ហាសង្គមនានាដែលកើតចេញមកពីការបែកបាក់គ្រួសារ ក្រោយពីមានការរៀបអាពាហ៍ពិពាហ៍ដែលមិនមានការយល់ព្រម។

[2371] 2-TCCP-274: ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ២៤-២៥ ប្រហែលម៉ោង [១០.៣៤.២៦], អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/252.1** ទំព័រ ១៨ ប្រហែលម៉ោង [០៩.៥៩.០៨], មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ៦២-៦៤ ចន្លោះម៉ោង [១៥.១៦.១២] និង [១៥.២៣.៤២], កង អ៊ុត ប្រតិចារឹក ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/322.1** ទំព័រ ២៥ ប្រហែលម៉ោង [១០.៥៥.១៩]។

ឪពុកម្តាយគិតថា ពួកគេត្រូវធ្វើសេចក្តីសម្រេចជំនួសកូន ទាក់ទងនឹងការអប់រំ ឬការរៀបអាពាហ៍ពិពាហ៍។ នេះជាបញ្ហាសំខាន់បំផុតសម្រាប់ប្រជាជនកម្ពុជាជាច្រើន [...]។ មិនចំពោះតែការរៀបការទេ គឺថាជីវិតអនាគតរបស់កូនៗ ពេលខ្លះ ឪពុកម្តាយជាអ្នកសម្រេចដែរ [...]។ ដូច្នេះ កូនស្រីអត់មានជម្រើសក្នុងការឆ្លើយបដិសេធទេ ពីព្រោះពួកគេពឹងផ្អែកលើឪពុកម្តាយជាអ្នកជ្រើសរើសឱ្យ"[2372]។

២៣៤៨. ការស្តាប់បង្គាប់ចាស់ទុំ ដែលរំពឹងចង់បានពីកូនប្រុស ក៏ជាចរិតលក្ខណៈនៃសង្គមបុរាណដែរ[2373]។ ក្នុងករណីបដិសេធ ដំណើរការនៃការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីបណ្តាលឱ្យមានការស្តីបន្ទោសពីសង្គម បង្កឱ្យមានផលវិបាកធ្ងន់ធ្ងរដល់យុវជនសាមី និងគ្រួសារ ជាមួយនឹងសញ្ញាណធ្ងន់ធ្ងរនៃការអប្បយស។ ពេលឆ្លើយទៅនឹងសំណួររបស់អង្គជំនុំជម្រះអំពីលទ្ធភាពក្នុងការប្រកែកមិនព្រមរៀបការ លោកស្រី Kasumi NAKAGAWA បានអះអាងថា "ការថែរក្សាកេរ្តិ៍ឈ្មោះគ្រួសារ គឺជារឿងសំខាន់បំផុត ហើយកូនស្រីត្រូវថែរក្សាកេរ្តិ៍ឈ្មោះគ្រួសារឱ្យបានល្អ"។ ទោះបីជាកូនប្រុសអាចផ្តួចផ្តើមក្នុងការរៀបអាពាហ៍ពិពាហ៍ តាមរយៈឪពុកម្តាយ ក៏ដោយ ក៏ពួកគេត្រូវគោរពតាមការជ្រើសរើសរបស់ឪពុកម្តាយ។ លោកស្រី Kasumi NAKAGAWA មិនធ្លាប់ឮស្ថានភាពដែលយុវជនម្នាក់ប្រកែកមិនព្រមតាមការជ្រើសរើសរបស់ឪពុកម្តាយនោះទេ ហើយគាត់យល់ឃើញថា កូនប្រុសក៏មិនសូវសុំឪពុកម្តាយរៀបការដែរ[2374]។ ទម្ងន់នៃប្រពៃណីទៅលើកូនស្រីទាមទារជាចាំបាច់ឱ្យចាប់អារម្មណ៍ទៅលើឋានៈរបស់ស្ត្រី មុនរបបកម្ពុជាប្រជាធិបតេយ្យ។

## 4. ឋានៈរបស់ស្ត្រី និងទំនាក់ទំនងរវាងបុរស និងស្ត្រី មុនរបបកម្ពុជាប្រជាធិបតេយ្យ

២៣៤៩. កេរ្តិ៍ឈ្មោះគ្រួសារ និងករណីយកិច្ចរបស់កូនចំពោះឪពុកម្តាយ គឺជាមូលហេតុមួយដែលពន្យល់អំពីការរីកសុះសាយនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ។ អ្នកជំនាញ Kasumi NAKAGAWA

[2372] ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ៣១ មុនម៉ោង [១០.៥១.៤០]។

[2373] ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ២៨ ប្រហែលម៉ោង [១០.៤៣.២០]។

[2374] ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ២៨ ប្រហែលម៉ោង [១០.៤៣.២០] ទំព័រ ៣០ ប្រហែលម៉ោង [១០.៤៩.២៣] ទំព័រ ៣១ ប្រហែលម៉ោង [១០.៥១.៤០], ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/473.1** ទំព័រ ១៥ ប្រហែលម៉ោង [០៩.៥៣.១៧] ទំព័រ ២៧ ប្រហែលម៉ោង [១០.៥០.០៥]។

បានរំឭកថា "នៅតែមានប្រពៃណី ដែលឪពុកម្តាយជាអ្នកផ្សំផ្គុំ ឬបង្ខំកូនឱ្យរៀបការ ជាពិសេស គឺកូនស្រី" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[2375]។

២៣៥០. ប្រការនេះក៏ត្រូវគ្នានឹងចក្ខុវិស័យប្រពៃណីនិយមស្តីពីតួនាទីរបស់ស្ត្រី ដូចមានក្នុងកំណាព្យបុរាណ "ច្បាប់ស្រី" ដែលជាក្រមសីលធម៌សម្រាប់កូនស្រី និងប្រពន្ធ។ "ច្បាប់ស្រី" សង្ខេបអំពីឋានៈរបស់ស្ត្រី មុនរបបកម្ពុជាប្រជាធិបតេយ្យ និងលើកតម្កើងការគោរពប្តី[2376] ការទទួលយកការប្រព្រឹត្តគ្រប់បែបយ៉ាងរបស់ប្តី[2377]។ ច្បាប់ស្រី ដែលទើបត្រូវបានលុបចេញពីកម្មវិធីសិក្សាកាលពីពេលថ្មីៗនេះ បានចាក់ឫសជាប់យ៉ាងជ្រៅក្នុងវប្បធម៌ខ្មែរ[2378] និងត្រូវបានរិះគន់យ៉ាងខ្លាំង ដោយសារតែបង្កផលវិបាករហូតមកដល់សព្វថ្ងៃ[2379]។ ទន្ទឹមនឹងនេះ ការរៀបពាហ៍ពិពាហ៍តាមការផ្សំផ្គុំ គឺនៅតែជា

---

[2375] ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/473.1** ទំព័រ ៣៣-៣៤ ប្រហែលម៉ោង [១១.១១.៤៦]។

[2376] ច្បាប់ស្រី និពន្ធដោយ ម៉ឺន មៃ **ឯកសារ E3/10659** ERN 01324417-19៖ "[...] ចូរនាងចាំចេះ បម្រើស្វាមី [...] មិនកោតមិនខ្លាចចិត្តប្តី ឱ្យប្រុសដទៃ មាក់ងាយប្តីណា។ ហៅស្រី ឥតលក្ខិណា ឥតមានកិរិយា មារយាទពុំសម [...] ចូររកវៀនយកច្បាប់ស្រី ឱ្យកោតខ្លាចប្តី គម្លែងក្រឡា [...] ពាក្យពេចន៍ការកិច្ចអ្វីៗ អត់ឱនកុំបី ឱ្យអាក់ចិន្តា", **ឯកសារ E3/10659** ERN 01324423៖ "មួយទោះប្តីនោះកាចក្តាត់ ខឹងយល់វាយវាត់ ជេរចោរជកទង មិនហ៊ានឆ្លើយឈ្លោះរំលង តតបទៅផង ក្រែងពុកេរ្តិ៍ឆ្ងាយ"។

[2377] ច្បាប់ស្រី និពន្ធដោយ ម៉ឺន មៃ **ឯកសារ E3/10659** ERN 01324419-20៖ "ឱ្យកូនស្រីស្ងួនខំអត់ ឱ្យបានរលត់ រលាយកំហឹង កុំកូនកាន់ខ្លួនប្រែប្រឹង តតបទៅនឹង អ្នកជាស្វាមី [...] ទោះបីបើប្តីនាងជេរ នាងចូរទៅឯ ដំណេកគិតសិន ចេញមកនាងយកពាក្យទន់ ស្រដីឱ្យអន់ ស្រាយទោសនោះទៅ [...] ព្រោះឯងមិនក្រែងមិនស្តាប់ ពាក្យគេបង្គាប់ បង្កើតតែឈ្លោះ [...] ទោះបីប្តីប្រើមាសមេ កុំកូនចំអែ ចំអៀកមិនទៅ ឆ្ងាយជិតកុំគិតរង់នៅ ក្រោកក្រេសដើរទៅ កុំឱ្យប្តីជេរ", **ឯកសារ E3/10659** ERN 01324422៖ "ទោះខឹងប្តីក្រៃប៉ុន្មាន មិនចេះហៅហាន ឆ្លើយឈ្លោះតមាត់"៖ ភាពអត់ធ្មត់នេះ ធ្វើឱ្យស្ត្រីទទួលបានបុណ្យកុសល "នឹងបានក្សេមក្សាន្តពណ្ណរាយ សេពសុខសប្បាយ និរទុក្ខកាយា"។

[2378] កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/473.1** ទំព័រ ៤២ ប្រហែលម៉ោង [១៣.៣២.១៤]។ អ្នកជំនាញបានប្រាប់ឱ្យដឹងថា ច្បាប់ស្រីត្រូវបានលុបបំបាត់ចោល ដោយយោងតាមអនុសាសន៍របស់គណៈកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី ដែលគណៈកម្មាធិការនេះយល់ឃើញថាច្បាប់ស្រីគឺជា "និមិត្តរូបនៃការគាបសង្កត់ស្ត្រីនៅក្នុងប្រទេសកម្ពុជា" តែវានៅតែត្រូវបានបន្តផ្សព្វផ្សាយនៅក្នុងក្របខណ្ឌគ្រួសារ ជាពិសេសក្នុងអំឡុងពេលកិច្ចពិធីសំខាន់ៗក្នុងវប្បធម៌ខ្មែរ ដែលនៅពេលនោះ គោលការណ៍មួយចំនួន ដូចថា "ត្រូវទន់ភ្លន់ ត្រូវស្លូតបូតល្អ [...] ទាំងអស់នេះត្រូវបានបង្រៀនដើម្បីឱ្យនារីក្លាយខ្លួនជាស្ត្រីខ្មែរគោរពប្រពៃណី"។

[2379] អត្ថបទមានចំណងជើងថា "គ្មានទេកន្លែងសម្រាប់ "ច្បាប់ស្រី" នៅក្នុងសាលារៀនក្នុងប្រទេសកម្ពុជា" និពន្ធដោយ K. GRACE សារព័ត៌មាន ខេមបូឌាដេលី ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E3/10660** ERN 01328190-93, "អំពើហិង្សាលើស្ត្រី៖ ច្បាប់កម្ពុជារើសអើងចំពោះស្ត្រី" CAMBOW ២០០៧ **ឯកសារ E3/10658a** ទំព័រ ៤-៥ ERN 01407569-70។

រឿងដែលគេខ្ពើមរអើមជួបប្រទះបំផុត ចំពោះប្រជាជនភាគច្រើន ជាពិសេស នៅតាមជនបទ[2380]។ ការស្វែងយល់អំពីទស្សនៈជាប្រពៃណីនៃការរៀបអាពាហ៍ពិពាហ៍ ជួយឱ្យយើងយល់កាន់តែច្បាស់ថាតើកម្មាភិបាលទទួលបន្ទុករៀបអាពាហ៍ពិពាហ៍ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលវប្បធម៌អ្វីខ្លះ និងផ្ដល់នូវចក្ខុវិស័យមិនមានសូវមានលក្ខណៈទូកនិយម អំពីរបៀបដែលអ្នករៀបការឱ្យគេ និងអ្នករៀបការ មើលឃើញរឿងរ៉ាវ។

## ខ. ករណីយកិច្ចជាប្ដី-ប្រពន្ធ និងការរំលោភសេពសន្ថវៈ

២៣៥១. បញ្ហា "ករណីយកិច្ចជាប្ដីប្រពន្ធ" ក៏ជាបញ្ហាវប្បធម៌ដ៏សំខាន់ផងដែរ។ អត្ថិភាពនៃការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍នៅតែពិបាកនឹងទទួលយកបាន សព្វថ្ងៃនេះ ហើយទើបតែត្រូវបានដាក់បញ្ចូលក្នុងបទប្បញ្ញត្តិច្បាប់កាលពីពេលថ្មីៗនេះ[2381]។ ដូច្នេះ ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ដែលនៅតែកើតមានស្ទើរគ្រប់ទីកន្លែង ត្រូវវិភាគជាមួយនឹងទស្សនៈជាប្រពៃណីនៃ "ករណីយកិច្ច" នេះ មុនរបបកម្ពុជាប្រជាធិបតេយ្យ។ ជាក់ស្ដែង វគ្គមួយនៃច្បាប់ស្រីបង្គាប់ឱ្យស្ត្រីគោរពតាមចំណង់ផ្លូវភេទរបស់ប្ដី ដោយឥតប្រកែក និងបិទមាត់ជិត៖

"ភ្លើងមួយគម្ដែងក្រឡា គឺប្ដីអាត្មា ថិតថេររួមរ័ក្ស។
ឱ្យនាងប្រណិប័តន៍ជឿជាក់ កុំធ្វើឱ្យអាក់ ឱ្យអន់ចិត្តប្ដី។
អត់ឱនខ្លាចខ្លួនជាស្រី កុំឱ្យស្រដី ទុកគេជាស្មើ។

---

[2380] ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ** E1/473.1 ទំព័រ ៤៣-៤៤ ចន្លោះម៉ោង [១៣.៣៤.២១] និង [១៣.៣៩.១៥], អត្ថបទមានចំណងជើងថា "អាពាហ៍ពិពាហ៍ដោយការរៀបចំ រងការស្ដីបន្ទោសថាធ្វើឱ្យគ្រួសារបែកបាក់" រៀបរៀងដោយ MARCHER A. សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩**ឯកសារ** E3/7288។

[2381] ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ប្រកាសឱ្យប្រើថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥ មាត្រា ៣ និង មាត្រា ៧។ ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនេះ ដែលរៀបរាប់ត្រង់មាត្រា ៣ ថាការឈ្លានពានខាងផ្លូវភេទ ជាសកម្មភាពមួយនៃអំពើហិង្សា (ហើយដែលមាត្រា ៧ នៃច្បាប់នេះ បានកំណត់និយមន័យជាអាទិ៍ពីអំពើហិង្សាក្នុងគ្រួសារថាជា "ការប្រើហិង្សាសេពសន្ថវៈ") ទើបតែត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ ២០០៥ ប៉ុណ្ណោះ។ នៅពេលអានច្បាប់នេះផ្ទួបគ្នាជាមួយនឹងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា ដែលកម្រិតទោសទណ្ឌចំពោះបទរំលោភសេពសន្ថវៈ ច្បាប់នេះបានបញ្ចូលយ៉ាងច្បាស់នូវការកំណត់ជាបទឧក្រិដ្ឋនូវអំពើឈ្លានពានខាងផ្លូវភេទរវាងប្ដីប្រពន្ធ។ ប៉ុន្តែ ច្បាប់នេះនៅមានខ្វះចន្លោះ ព្រោះថាបើទោះជានិយមន័យពាក្យ "ការប្រើហិង្សាសេពសន្ថវៈ" អាចរាប់បញ្ចូលនូវអវត្តមាននៃការយល់ព្រមក៏ដោយ ក៏សញ្ញាណនៃការយល់ព្រមចំពោះទំនាក់ទំនងផ្លូវភេទ មិនត្រូវបានបញ្ជាក់ឱ្យច្បាស់លាស់នោះដែរ។

ទោះកើតហេតុភេទសារពើ ពាក្យពុំប្រសើរ ជញ្ជឹងចាំស្លាប់។
ទោះប្តីស្រដីពុំគាប់ ពុំគួរឱ្យប្រាប់ បានដឹងដល់ម្តាយ"[2382]។

២៣៥២. វគ្គនេះស៊ីសង្វាក់គ្នាយ៉ាងខ្លាំងជាមួយនឹងផ្នែកផ្សេងទៀតនៃអត្ថបទច្បាប់ស្រីនេះ ដែលអនុវត្តផងដែរ ចំពោះទំនាក់ទំនងផ្លូវភេទរវាងប្តី និងប្រពន្ធ។ លោកស្រី Kasumi NAKAGAWA បានបញ្ជាក់អះអាងអំពីអត្ថិភាពនៃការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍មុនឆ្នាំ ១៩៧៥ និងក្រោយមក គឺនៅឆ្នាំ ២០១៦។ គាត់ចាំថា គេប្រាប់ឱ្យ "ស្ត្រីមួយចំនួនស្តាប់បង្គាប់ប្តី នៅរាត្រីផ្សំដំណេក" បើទោះជាមិនមានការអប់រំអំពីផ្លូវភេទក៏ដោយ[2383]។

២៣៥៣. ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ (ឥឡូវនេះ គេហៅបែបនេះ) មិនទាន់លេចឡើងទេ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏មិនមែនជាផលវិបាកដែរ។ ទោះបីជាបទប្បញ្ញត្តិច្បាប់បានការវិវត្តជាវិជ្ជមានក៏ដោយ ក៏ច្បាប់ស្រី ក្នុងចំណោមកត្តាផ្សេងទៀត ធ្លាប់ជាក្រមប្រតិបត្តិដែលមានស្រាប់នៃអាកប្បកិរិយា អស់ជាច្រើនជំនាន់ មុនរបបកម្ពុជាប្រជាធិបតេយ្យ និងនៅតែជាក្រមប្រតិបត្តិដដែល។

២៣៥៤. ទោះបីជាការសង្កេតនេះអាចមិនជាទីពេញចិត្តក៏ដោយ ក៏គំនិតដែលថាបុរសអាចប្រព្រឹត្តអំពើរំលោភសេពសន្ថវៈលើប្រពន្ធខ្លួនឯង និងគំនិតនៃការព្រមព្រៀងពីប្រពន្ធជាចាំបាច់ និងមិនជាប្រព័ន្ធមិនមានទេនៅក្នុងទំនៀមទម្លាប់ខ្មែរ នៅមុនឆ្នាំ ១៩៧៥ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និងក្រោយឆ្នាំ ១៩៧៩ គឺទើបតែមាននៅពេលថ្មីៗនេះប៉ុណ្ណោះ។

២៣៥៥. ដូច្នេះ អាកប្បកិរិយាខ្លះ គឺជាលទ្ធផលនៃទស្សនៈវប្បធម៌ ច្រើនជាងលទ្ធផលនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានសារៈសំខាន់ក្នុងការវិភាគភ័ស្តុតាង។

---

[2382] ច្បាប់ស្រី និពន្ធដោយ ម៉ីន មៃ **ឯកសារ E3/10659** ទំព័រ ៣ ERN 01324419។

[2383] ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/473.1** ទំព័រ ៣២ ប្រហែលម៉ោង [១១.០៧.៤៣], ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ៣៧-៣៨ ប្រហែលម៉ោង [១១.១៣.៥៤]។

## ២. ការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

២៣៥៦. យើងយល់ស្របជារួមថា កម្ពុជាប្រជាធិបតេយ្យបានលុបបំបាត់ប្រពៃណីចោលទាំងអស់ ដើម្បីបង្កើតវិធានថ្មីលើគ្រប់វិស័យ និងនៅគ្រប់ជាន់ថ្នាក់នៃសង្គម។ ប៉ុន្តែ ការវិភាគអំពីការរៀបអាពាហ៍ពិពាហ៍បង្ហាញឱ្យឃើញពីភាពស្រដៀងគ្នាជាមួយនឹងការអនុវត្ត មុនរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះត្រូវពិចារណាថាតើអ្វីជាយន្តការពីមុន អ្វីជាការវិវត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

### ក. វិធានស្តីពីការរៀបអាពាហ៍ពិពាហ៍

២៣៥៧. ទោះបីជាការយល់ព្រមរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរមិនមានភាពចាំបាច់ក៏ដោយ ក៏យើងចាំបាច់ត្រូវពិនិត្យមើលខ្លឹមសារនៃសក្ខីកម្មលើបញ្ហានេះ ជាពិសេស យោងទៅតាមអ្វីដែលទើបបានរំឭកអំពីប្រពៃណីខ្មែរពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា។

### 1. គោលការណ៍គ្រប់គ្រងការផ្សំផ្គុំ

២៣៥៨. បុរេវិនិច្ឆ័យដែលថា ជាគោលការណ៍ ការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើឡើង ក្រោមការបង្ខិតបង្ខំ មិនមែនជាការពិតនោះទេ។ ដូចយើងនឹងឃើញខាងក្រោមនេះ ទោះបីជាមានប្រពៃណីនៅសេសសល់ នៅក្នុងការជំនួសសិទ្ធិអំណាចរបស់ឪពុកម្តាយដោយសិទ្ធិអំណាចរបស់អង្គការក៏ដោយ ក៏យើងត្រូវទទួលស្គាល់ថា លទ្ធិកុម្មុយនីស្តនៃបក្សកុម្មុយនីស្តកម្ពុជាចង់បញ្ចូលវិធានទំនើបជាងមុននៅក្នុងស្ថាប័ននេះ ដែលគិតគូរជាអាទិ៍ដល់ការយល់ព្រមជាឯកត្តជន និងអាយុអប្បបរមានៃការរៀបអាពាហ៍ពិពាហ៍។

#### 1.ក. លក្ខខណ្ឌ "តាមផ្លូវច្បាប់"៖ សីលធម៌ ១២ ប្រការ

២៣៥៩. ជាបឋម គួរកត់សម្គាល់ថា គោលការណ៍ ដូចមានចែងនៅក្នុងឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា បញ្ជាក់យ៉ាងច្បាស់អំពីភាពចាំបាច់ ក្នុងការទទួលបានការយល់ព្រមពីសំណាក់អនាគតប្តី-ប្រពន្ធ។ ប្រការទី ៦ នៃសីលធម៌ ១២ ប្រការ ដែលដកស្រង់ដោយទស្សនាវដ្តីយុវជន-យុវនារីបដិវត្តន៍ ចេញផ្សាយខែ តុលា ឆ្នាំ ១៩៧៨ ចែងដូចខាងក្រោម៖

> "ចំពោះបញ្ហារៀបចំគ្រួសារបច្ចុប្បន្ននេះ គ្មានអ្វីជាឧបសគ្គទេ ឱ្យតែឈរលើគោលការណ៍របស់បក្សទាំងពីរយ៉ាង គឺ ទី ១ សាមីខ្លួនទាំងសងខាងយល់ព្រម ទី ២ សមូហភាពយល់ព្រម ក៏ជាការស្រេចទៅហើយ។ តើមានហេតុផលអីនាំឱ្យយើងប៉ះពាល់សីលធម៌នារី-បុរស?"[2384]។

២៣៦០. ភាពចាំបាច់ក្នុងការទទួលបានការយល់ព្រមពីសាមីខ្លួនទាំងសងខាង ត្រូវបានបញ្ជាក់អះអាងដោយសាក្សីជាច្រើន ក្នុងចំណោមនោះ មានកម្មាភិបាលមួយចំនួនរបស់បក្សកុម្មុយនីស្តកម្ពុជាផងដែរ។ សាក្សី 2-TCW-938 បានឆ្លើយថា "ការរៀបអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបានតែប្រសិនបើភាគីទាំងពីរយល់ព្រម"។ សាក្សី 2-TCW- 894, ឱ ហួ, 2-TCW-823 និង 2-TCW-850 បានបញ្ជាក់អះអាងអំពីចំណុចនេះ ហើយសាក្សី ពេជ្រ ជឹម បានបន្ថែមថា ច្បាប់ចង់ឱ្យ "សាមីខ្លួនទាំងសងខាងយល់ព្រម"[2385]។ លើសពីនេះទៅទៀត សាក្សី ពេជ្រ ជឹម បានគូសបញ្ជាក់ថា ស្រុកអនុញ្ញាតឱ្យរៀបការ អាស្រ័យទៅតាមព័ត៌មានទទួលបានពីថ្នាក់ក្រោម គឺមានន័យថាសំណើចេញមកពីថ្នាក់ក្រោម[2386]។

---

[2384] ទស្សនាវដ្តីមានចំណងជើងថា "យុវជន និងយុវនារីបដិវត្ត លេខ ១០" ចេញផ្សាយខែ តុលា ឆ្នាំ ១៩៧៨ **ឯកសារ E3/765** ERN 00376494។

[2385] 2-TCW-938 : ប្រតិចារឹក ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/378.1** (សវនាការអសាធារណៈ) ទំព័រ ៣៤-៣៥ ចន្លោះម៉ោង [១១.២៧.១៤] និង [១១.៣០.៣៣], 2-TCW-894 : ប្រតិចារឹក ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/376.1** (សវនាការអសាធារណៈ) ទំព័រ ៥៨ ប្រហែលម៉ោង [១៥.៣៥.១៥], ឱ ហួ ប្រតិចារឹក ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/301.1** ទំព័រ ៥៦ ប្រហែលម៉ោង [១៤.៣៨.៣៤], ជួន ធី ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៨៣ ប្រហែលម៉ោង [១៥.៥៧.២៩], ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ៤ ប្រហែលម៉ោង [០៩.០៩.៤៥], 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/512.1** ទំព័រ ៣៣ ប្រហែលម៉ោង [១១.១៧.៣៧], 2-TCW-850 : ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/461.1** ទំព័រ ៦២-៦៣ ប្រហែលម៉ោង [១៥.០៩.២២], ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ E1/290.1** ទំព័រ ៣១-៣២ ប្រហែលម៉ោង [១៣.៤៧.១០]។

[2386] ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/461.1** ទំព័រ ៦៤ ចន្លោះម៉ោង [១៥.១៤.៤២] និង [១៥.១៧.៥៤]។

២៣៦១. នៅក្នុងសវនាការ សាក្សី ជួន ធី បានរក្សាចម្លើយពីមុនដដែល ដែលគាត់បានប្រាប់បានស្ដាប់ឮ ប៉ុល ពត និយាយអំពីការយល់ព្រមជាចាំបាច់ពីប្ដី-ប្រពន្ធ៖ "សៈ កាលនោះ ប៉ុល ពត មាននិយាយថា ត្រូវរើសគូយ៉ាងម៉េចដែរទេ? ឆ ២៩៖ ប៉ុល ពត និយាយថាសម្រេចលើសាមីខ្លួនគេជាអ្នកសម្រេច បើគេយល់ព្រម រៀបចំឱ្យគេទៅ កុំបង្ខំគេ"[2387]។ ដូច្នេះ ចម្លើយនេះបញ្ជាក់អះអាងអំពីការពិតនៃសីលធម៌ ប្រការទី ៦។

២៣៦២. ប៉ុន្តែ សាក្សី 2-TCW-1005 បានឆ្លើយថា៖

> "ទោះបីជាទាំងអស់គ្នាចូលរួមប្រជុំដូចគ្នា ដែលនិយាយអំពីសីលធម៌ទាំងនោះ ម្នាក់ៗអនុវត្តខុសគ្នាទាំងអស់តាមការយល់ឃើញរៀងៗខ្លួន។ [...] ប្រសិនបើអនុវត្តល្អទាំងអស់គ្នា មានអី [...]។ ច្បាប់មានមែន តែដល់បុគ្គលមិនអនុវត្ត"[2388]។

២៣៦៣. សក្ខីកម្មពីរចុងក្រោយនេះបង្ហាញឱ្យឃើញជាថ្មីម្ដងទៀតអំពីគោលការណ៍ដែលមានចែង និងការអនុវត្តជាក់ស្ដែង។

២៣៦៤. ការពិនិត្យមើលសក្ខីកម្មដែលអង្គជំនុំជម្រះបានស្ដាប់ ទោះបីជាមានមតិស្របរបស់សហព្រះរាជអាជ្ញាក៏ដោយ បង្ហាញឱ្យឃើញការពិតខុសពីនេះខ្លាំង ដោយសារតែបទពិសោធន៍របស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការយល់ព្រមរៀបការ មានលក្ខណៈខុសៗគ្នា។ ប៉ុន្តែ យើងត្រូវមើលឃើញភាពខុសគ្នាទុកដូចជាការអនុវត្តវិធានមិនបានត្រឹមត្រូវ ក្នុងករណីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

### 1.២. ការសម្ដែងការយល់ព្រម

[2387] ជួន ធី ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ១២-១៣ ប្រហែលម៉ោង [០៩.៣៨.២២], កំណត់ហេតុស្ដាប់ចម្លើយ **ឯកសារ E3/10713** ស/ឆ ២៨។

[2388] ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/449.1** ទំព័រ ៣៧ ប្រហែលម៉ោង [១១.០៥.២៦]។

២៣៦៥. ទោះបីជាការយល់ព្រមពីសាមីខ្លួនមិនមានភាពចាំបាច់ ក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ក៏ដោយ ក៏សាក្សី ដែលត្រូវគេរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានលើកឡើងអំពីការប្ដេជ្ញាជាឱឡារិក ដែលជាការឆ្លុះបញ្ចាំងអំពីការយល់ព្រមរៀបការ[2389]។ ម្យ៉ាងវិញទៀត គួរកត់សម្គាល់ថា សាក្សីខ្លះបានញែកដាច់រវាងការរៀបអាពាហ៍ពិពាហ៍ មុនរបបកម្ពុជាប្រជាធិបតេយ្យ និង "ការប្ដេជ្ញា" ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[2390]។ សាក្សីខ្លះទៀតស្ម័គ្រចិត្តរៀបការ[2391] ស្របតាមការអះអាងនៅក្នុងឯកសារមួយចំនួន[2392]។

---

[2389]ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/254.1** ទំព័រ ១៦ ប្រហែលម៉ោង [០៩.៥៣.០៤], ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/255.1** ទំព័រ ១៣ ប្រហែលម៉ោង [០៩.៤៧.៣៧], ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ៧០ ប្រហែលម៉ោង [១៥.១១.២៦], 2-TCCP-232 : ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/464.1** ទំព័រ ១២ ប្រហែលម៉ោង [០៩.៤២.៣០] ទំព័រ ១៦-១៧ ប្រហែលម៉ោង [០៩.៥៧.៥៦], ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/466.1** ទំព័រ ៥៧ ប្រហែលម៉ោង [១៤.០៤.០១], 2-TCW-1002 : ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/469.1** ទំព័រ ៣១ ប្រហែលម៉ោង [១០.៤៣.៣៥] ទំព័រ ៤១ ប្រហែលម៉ោង [១១.២២.១០], មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/475.1** ទំព័រ ៤៥ ប្រហែលម៉ោង [១៣.៤២.២១], ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/476.1** ទំព័រ ១៣ ប្រហែលម៉ោង [០៩.៤៧.៣៣], ជួ គីមឡុន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/253.1** ទំព័រ ១៩ ប្រហែលម៉ោង [១០.០៦.៤៦], រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១២ **ឯកសារ E1/262.1** ទំព័រ ២២ ប្រហែលម៉ោង [១០.១៦.៤២], ខិ ហួ ប្រតិចារឹក ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/301.1** ទំព័រ ៥៦-៥៧ ប្រហែលម៉ោង [១៤.៤១.៤៧], ស៊ូ សឿន ប្រតិចារឹក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/310.1** ទំព័រ ៦១ ប្រហែលម៉ោង [១៥.១៣.៣៧], ជុំ សាមឿន ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/321.1** ទំព័រ ៥១ ប្រហែលម៉ោង [១៤.២៥.០៩], សែន សុផុន ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/323.1** ទំព័រ ៦៤ ប្រហែលម៉ោង [១៥.៤៩.៥៩], ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/361.1** ទំព័រ ៨១ ប្រហែលម៉ោង [១៥.៥៨.៥៥], នាង អ៊ួច ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ E1/274.1** ទំព័រ ២៥ ប្រហែលម៉ោង [១០.៤៩.០២], ព្រុំ សារុន ប្រតិចារឹក ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/364.1** ទំព័រ ៦៥ ប្រហែលម៉ោង [១៥.១១.០៩], អ៊ុន ឃឿង ប្រតិចារឹក ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៧១ ប្រហែលម៉ោង [១៥.២៤.៣០], ចៅ ឡាង ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/339.1** ទំព័រ ៥៩ ប្រហែលម៉ោង [១៥.១១.០៥], អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/394.1** ទំព័រ ៦៧-៦៨ ប្រហែលម៉ោង [១៥.៤១.១៣], 2-TCW-850 : ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/461.1** ទំព័រ ៦៣ ប្រហែលម៉ោង [១៥.១២.០៧]។

[2390]ព្រុំ សារុន ប្រតិចារឹក ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/364.1** ទំព័រ ៦៥ ប្រហែលម៉ោង [១៥.១១.០៩]៖ "សួររៀបអាពាហ៍ពិពាហ៍អ្វី? មិនមែនរៀបទេក្នុងជំនាន់ហ្នឹងនោះ អត់មានរៀបអាពាហ៍ពិពាហ៍ទេ មានតែប្ដេជ្ញា ចាប់ដៃគ្នា គ្មានអាពាហ៍ពិពាហ៍រៀបទេ", កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ **ឯកសារ E3/9736** ស/ឆ ១០-១១។

[2391]ម៉ម សឿម ហៅ ហេង សាមួត ប្រតិចារឹក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/325.1** ទំព័រ ១៩-២០ ប្រហែល

២៣៦៦. បញ្ហាចោទឡើង ពាក់ព័ន្ធនឹងសុពលភាពនៃការយល់ព្រមជាចាំបាច់ អនុលោមតាមបទបញ្ញារបស់កម្ពុជាប្រជាធិបតេយ្យ។ ជាក់ស្តែង សាក្សីខ្លះទទួលរងនូវការកៀបសង្កត់ពីសំណាក់ឪពុកម្តាយ ឬសាច់ញាតិ[2393] ឯសាក្សីខ្លះទៀតត្រូវបានបង្ខំឱ្យប្តេជ្ញា ក្រោយពីបានប្រកែក[2394]។ សាក្សីខ្លះទៀតបានពន្យល់ថាខ្លួនមិនហ៊ានប្រកែកទេ ដែលសំដៅដល់ការពិបាកក្នុងការប្រកែកក្នុងការរៀបការតាមប្រពៃណី[2395]។ ជាចុងក្រោយ មានឧទាហរណ៍នៃអ្នកដែលបានប្រកែកមិនព្រមរៀបការ ដោយមិន

---

ម៉ោង [១០.០៣.១៩], សុះ រំលី ប្រតិចារិក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/372.1** ទំព័រ ៣៥ ប្រហែលម៉ោង [១១.១៣.៤៩], អ៊ិន យឿង ប្រតិចារិក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៧៧ ប្រហែលម៉ោង [១៥.៤១.៣០], 2-TCCP-274 : ប្រតិចារិក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ២៦ ប្រហែលម៉ោង [១០.៣៨.១៣]។

[2392]របាយការណ៍ស្តីពីសេវាផ្សព្វផ្សាយព័ត៌មានបរទេស លេខ ០៩ ឆ្នាំ ១៩៧៨ **ឯកសារ E3/76** ERN 00170426 (ភាសាអង់គ្លេស) ERN 01327012 (ភាសាខ្មែរ)។ ទស្សនាវដ្តីមានចំណងជើងថា "យុវជន និងយុវនារីបដិវត្ត លេខ ១០" ចេញផ្សាយខែតុលា ឆ្នាំ ១៩៧៨ **ឯកសារ E3/765** ERN 00540025 (ភាសាបារាំង) ERN 00376494 (ភាសាខ្មែរ) ERN 00539994 (ភាសាអង់គ្លេស)។

[2393]សេង សឿន ប្រតិចារិក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/465.1** ទំព័រ ១៨ ប្រហែលម៉ោង [១០.០៦.០០], ជាំង ស្រីមុំ៖ ប្រតិចារិក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/252.1** ទំព័រ ១៧-១៨ ចន្លោះម៉ោង [០៩.៥៧.១៣] និង [១០.០០.២១], មាស ឡៃហួរ ប្រតិចារិក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ៦២ ប្រហែលម៉ោង [១៥.១៦.១២], សេង ស៊្រុន ប្រតិចារិក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/346.1** ទំព័រ ៤៥-៤៦ ចន្លោះម៉ោង [១១.៤៩.១៥] និង [១១.៥២.៥៤]៖ "[...] ក៏ប៉ុន្តែរឿងអ្នកដទៃទៀតគឺអត់បានស្ម័គ្រចិត្តទេ។ [...] គឺបានចាស់ទុំអីចូលស្តីដណ្តឹងអីចឹងទៅណា [...]"។

[2394]សុន វុត ប្រតិចារិក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/412.1** ទំព័រ ១១ ប្រហែលម៉ោង [០៩.៣៨.០៣], ជុំ សាមឿន ប្រតិចារិក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/321.1** ទំព័រ ៥១ ប្រហែលម៉ោង [១៤.២៥.០៩], ឃិន វ៉ាត ប្រតិចារិក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/325.1** ទំព័រ ៦៨ ប្រហែលម៉ោង [១៥.៤០.៣៥], យី ឡៃស្រួ ប្រតិចារិក ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/334.1** ទំព័រ ៤៧-៤៨ ប្រហែលម៉ោង [១៤.០៦.០៨], ចៅ ឡាង ប្រតិចារិក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/339.1** ទំព័រ ៥៤-៥៥ ប្រហែលម៉ោង [១៤.៣៦.៥០], ប៊ិត ឃឿន ប្រតិចារិក ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/502.1** ទំព័រ ៣៤ ប្រហែលម៉ោង [១១.២៧.៥១]។

[2395]ជាំង ស្រីមុំ ប្រតិចារិក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/254.1** ទំព័រ ១៩-២០ ប្រហែលម៉ោង [១០.០២.១៩], កង អ៊ុត ប្រតិចារិក ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/322.1** ទំព័រ ២៦ មុនម៉ោង [១១.០១.៥២], ម៉ម សឿម ហៅ ហេង សាមួត ប្រតិចារិក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/324.1** ទំព័រ ៧២ មុនម៉ោង [១៥.៥៣.២៣], 2-TCW-938 : ប្រតិចារិក ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/378.1** (សវនាការអសាធារណៈ) ទំព័រ ៣១-៣៣ ចន្លោះម៉ោង [១១.១៦.៥៩] និង [១១.២៤.៣១], អ៊ិន យឿង ប្រតិចារិក ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៦៨ ប្រហែល

ទទួលរងទណ្ឌកម្ម ឬជួបបញ្ហា[2396]។ ត្រង់ចំណុចចុងក្រោយនេះ គួរកត់សម្គាល់ថា អ្នកដែលដឹងច្បាស់អំពីគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា អាចមានសេរីភាពក្នុងការប្រកែក។ តួយ៉ាងដូចជាសាក្សី រស់ ស៊ុយ ដែលទោះបីជាគាត់និយាយអំពីការយល់ព្រមដោយសារតែខ្លាចការសងសឹកក៏ដោយ ក៏គាត់បានឆ្លើយជូនអ្នកស៊ើបអង្កេតថា៖

> "ស៖ លោកបាននិយាយថា មានផែនការឱ្យរៀបការមួយរយគូក្នុងមួយខែ តើផែនការនេះសម្រេចបានជោគជ័យទេ? ឆ ៨១៖ អត់បានទេ។ ស៖ ហេតុអ្វី? ឆ ៨២៖ ដោយសារមានអ្នកខ្លះព្រមរៀបការតាមការចាត់តាំង ឯអ្នកខ្លះទៀត ដែលបានយល់អំពីផែនការនេះ ឬមានមិត្តភក្តិនិយាយប្រាប់ពីគោលការណ៍បក្ស គេក៏បានប្រកែកមិនព្រមរៀបការ"[2397]។

---

ម៉ោង [១៥.១៥.៥៥], ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ **ឯកសារ E1/455.1** ទំព័រ ៤៩ ប្រហែលម៉ោង [១៤.០២.១០], យី ឡៃស្រួ ប្រតិចារឹក ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/334.1** ទំព័រ ៤៦ មុនម៉ោង [១៤.០៣.៤៤], ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/361.1** ទំព័រ ៨០ ប្រហែលម៉ោង [១៥.៥៦.៤៨], ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ៧១ ប្រហែលម៉ោង [១៥.១៥.០៦] ទំព័រ ៨១ ប្រហែលម៉ោង [១៥.៥០.០១], 2-TCCP-232 : ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/464.1** ទំព័រ ១១-១២ ចន្លោះម៉ោង [០៩.៣៧.១៦] និង [០៩.៤២.៣០] ទំព័រ ២០ ប្រហែលម៉ោង [១០.៣៧.៤៣], ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/466.1** ទំព័រ ៧៦ ប្រហែលម៉ោង [១៥.២៥.៤៨], ជាល ជឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/484.1** ទំព័រ ២០ ប្រហែលម៉ោង [១០.០៤.៥២], ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/487.1** ទំព័រ ៦៥ ប្រហែលម៉ោង [១៥.០៥.៣៤], ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/488.1** ទំព័រ ១២ ប្រហែលម៉ោង [០៩.៣៥.០០]។

[2396] 2-TCW-1002 : ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/469.1** ទំព័រ ៣១-៣២ ប្រហែលម៉ោង [១០.៥០.០២] ទំព័រ ៥៥ ប្រហែលម៉ោង [១៤.០៧.១៦], ភៅ យ៉ាវ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/264.1** ទំព័រ ២៦ ប្រហែលម៉ោង [១០.៥៣.៣០], ធុច ស៊ីថន ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/500.1** ទំព័រ ៥៤ ប្រហែលម៉ោង [១៤.៥៣.៥៤], មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ៦២ ប្រហែលម៉ោង [១៥.១៦.១២], សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/411.1** ទំព័រ ៥៩ មុនម៉ោង [១៤.៤១.៣០], ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/412.1** ទំព័រ ៣ ប្រហែលម៉ោង [០៩.០៧.៤៩], ឯម ភឿង ប្រតិចារឹក ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/263.1** ទំព័រ ៤៤ ប្រហែលម៉ោង [១៣.៤៥.០៩], ជួន ធី ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ៤ ប្រហែលម៉ោង [០៩.០៩.៤៥], ឱ ហួ ប្រតិចារឹក ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/301.1** ទំព័រ ៥៦ ប្រហែលម៉ោង [១៤.៣៨.៣៤]។

[2397] កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E3/10620** ស/ឆ ៨១-៨២។

២៣៦៧. ក្នុងល័ក្ខខ័ណ្ឌនេះ ភាពចាំបាច់ក្នុងការទទួលបានការយល់ព្រមពីសាមីខ្លួន ភាពចម្រុះនៃសក្តីកម្ម និង ការខ្លាចមិនហ៊ានប្រកែកជាមួយអាជ្ញាធរដោយមិនសម្តែងនូវការមិនយល់ព្រម មិនអាចឱ្យសន្និដ្ឋាន ថាការរៀបអាពាហ៍ពិពាហ៍មួយចំនួនមានលក្ខណៈបង្ខំបានឡើយ។

២៣៦៨. ដោយសារតែកងចល័តបម្រុងទុកសម្រាប់តែអ្នកនៅលីវ ដោយហេតុថាត្រូវផ្លាស់ទីរហូត សាក្សីខ្លះ បានចាត់ទុកការបញ្ជូនទៅធ្វើការនៅតាមការដ្ឋានជាការដាក់ទណ្ឌកម្ម ក្នុងករណីប្រកែកមិនព្រម រៀបការ។ ការពិត គឺថា ជាទូទៅ អ្នកមានគ្រួសារនៅធ្វើការតាមសហករណ៍ ដែលអាចឱ្យពួកគេ រួមរស់ជាមួយគ្រួសារបាន។ ម្យ៉ាងវិញទៀត អ្នកខ្លះស្ម័គ្រចិត្តរៀបការ ដូចករណីរបស់ អ៊ុន យឿង ដោយសារតែហេតុផលនេះ[2398]។

## 1.គ. អាយុរៀបការ

២៣៦៩. ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទទួលបានភស្តុតាងអំពីការ រៀបការមុនអាយុកំណត់ មិនទទួលបានផ្លែផ្កានោះឡើយ។ សូម្បីតែសក្តីកម្មនៅពេលចុងក្រោយ របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ខៀប ដែលលើកឡើងជាលើកដំបូងអំពីសុន្ទរកថារបស់លោក ខៀវ សំផន ស្តីពីការរៀបការ ក៏មិនអាចសម្រេចជោគជ័យបានដែរ។ លោកស្រី ជា ខៀប ជាដើម បណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ តាំងពីឆ្នាំ ២០០៩ មិនធ្លាប់និយាយអំពីលោក ខៀវ សំផន ទាល់តែសោះ នៅមុនថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៤[2399]។ នៅក្នុងសវនាការ គាត់បានឆ្លើយថា គាត់បានចូលរួមស្តាប់សុន្ទរកថារបស់លោក ខៀវ សំផន ដែលនិយាយលើកទឹកចិត្តស្ត្រីឱ្យរៀបការ នៅអាយុ ១៩ ឆ្នាំ ដើម្បីបង្កើតកូនចៅ។ គាត់មិនអាចពន្យល់អំពីការកែក្រឡាស់នេះបានទេ[2400]។

[2398]ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៥៦ ប្រហែលម៉ោង [១៤.១៥.១១] ទំព័រ ៧៧ ប្រហែល ម៉ោង [១៥.៤១.៣០]៖ "ចាស ខ្ញុំសុខចិត្តស្ម័គ្រចិត្ត រៀបការទៅនៅបានតាមសហករណ៍ មិននៅកងចល័តទេ ពិបាកណាស់"។

[2399]ជា ខៀប_ទម្រង់បែបបទព័ត៌មានបន្ថែម ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E3/5010a** ERN 01003332, បើ ទោះជាគាត់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ក៏ដោយ ដែលក្នុងឱកាសនោះ គាត់ទំនងជាបាននិយាយសម្តីដាក់ បន្ទុកខ្លាំង ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ នៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៤ ឬប្រមាណជាមិនដល់ពីរខែផង ក្រោយពីមាន ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ) ដែលដីកានេះបានរៀបចំគម្រោងពិនិត្យលើការរៀបការ នៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤។ សូមមើលផ្នែកខាងលើ កថាខណ្ឌ ២៣២៥។

[2400]ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/467.1** ទំព័រ ៤៣-៤៥ ប្រហែលម៉ោង [១១.២០.៥០]។

ចម្លើយនេះមិនស៊ីសង្វាក់គ្នានឹងសក្ខីកម្ម ឬឯកសារណាមួយឡើយ ប៉ុន្តែ ត្រូវគ្នាឥតខ្ចោះនឹងពាក្យពេចន៍របស់ដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងការបង្កើនចំនួនប្រជាជន។ ភាពយឺតយ៉ាវនៃសក្ខីកម្មនេះធ្វើឱ្យមិនសូវទុកចិត្តបាន។

២៣៧០. ទោះជាយ៉ាងនេះក្តី បើយោងតាមសក្ខីកម្មទាំងអស់ ការរៀបការត្រូវបានកំណត់នៅអាយុ ២០ ឆ្នាំ និងលើសពីនេះ ដោយសារតែខ្មែរក្រហមបានរំលាយចោលការអនុវត្តការរៀបការមុនអាយុរបស់សង្គមបុរាណ[2401]។ ចំណុចនេះត្រូវបានបញ្ជាក់អះអាងដោយសាក្សី 2-TCW-1002 និង សេង សឿន[2402]។ ករណីនេះត្រូវគ្នានឹងបទពិសោធន៍ទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ដែលបានស្តាប់ចម្លើយ៖ ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-274 មានអាយុប្រហែល ២៣ ឬ ២៤ ឆ្នាំ, ស៊ូ សុធារី មានអាយុជាង ៣០ ឆ្នាំ និងអ្នកនៅជុំវិញគាត់មានអាយុចន្លោះពី ២០ ដល់ ៣០ ឆ្នាំ, ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-232 និងអ្នកផ្សេងទៀត មានអាយុពី ២៣ ដល់ ២៥ ឆ្នាំ, ផាន់ ហ៊ីម មានអាយុប្រហែល ២២ ឆ្នាំ, មុំ វុន មានអាយុប្រហែល ២៦ ឆ្នាំ និង ហេង ឡៃហ៊ាង មានអាយុ ២៥ ឆ្នាំ នៅឆ្នាំ ១៩៧៥[2403]។ ចំពោះ ព្រាប សុឃឿន និងទោះបីជាមានការប៉ុនប៉ងពីសហ

---

[2401] 2-TCCP-274 : ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ២៤ ប្រហែលម៉ោង [១០.៣៤.២៦], ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ១៦ ប្រហែលម៉ោង [០៩.៤៥.៣៩]។ សូមមើលផងដែរករណីរៀបការនារីក្មេងៗ ដែលត្រូវបានរាយការណ៍នាសម័យបច្ចុប្បន្ននេះ៖ អត្ថបទមានចំណងជើងថា "អាពាហ៍ពិពាហ៍ដោយការរៀបចំ រងការស្តីបន្ទោសថាធ្វើឱ្យគ្រួសារបែកបាក់" និពន្ធដោយ MARCHER A. សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ **ឯកសារ E3/7288** ERN 01114232។

[2402] 2-TCW-1002 : ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/469.1** ទំព័រ ៤៥-៤៦ ប្រហែលម៉ោង [១៣.៣៦.២៦], សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/465.1** ទំព័រ ៣១ ប្រហែលម៉ោង [១១.១១.០៣]។

[2403] 2-TCCP-274 : ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/461.1** ទំព័រ ៧៦ ប្រហែលម៉ោង [១៥.៥៥.៥៨], ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ៦១ ប្រហែលម៉ោង [១៤.២២.៥១] (ព្រោះថា ស៊ូ សុធារី កើតនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៤០), ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ៧៨ ប្រហែលម៉ោង [១៥.៣៩.២៤] ("បើតាមខ្ញុំដឹងទៅ ដែលមើលទៅថាស្របាក់ស្របាលគ្នាហ្នឹង [...] ហើយក្មេងៗម៉ាស្រករគ្នាហ្នឹង [...] ហើយឱ្យក្មេងជ្រុលគឺមិនមាន [...] អាយុខ្ពង់២០ជាង ឬ៣០អី ខាងប្រុស"), 2-TCCP-232 : ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/464.1** ទំព័រ ២០ ប្រហែលម៉ោង [១០.៣៧.៤៣], ផាន់ ហ៊ីម ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/467.1** ទំព័រ ៦៧ ប្រហែលម៉ោង [១៤.១១.៥៧] និងទំព័រ ៥៨ ប្រហែលម៉ោង [១៣.៤១.៤៣] (សាក្សីរៀបការនៅខែវិច្ឆិកា ឆ្នាំ១៩៧៨ ហើយគាត់មានអាយុ ៦០ ឆ្នាំ នៅពេលគាត់មកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ ក្នុងឆ្នាំ ២០១៦)។

ព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបង្ហាញថាគាត់នៅក្មេងក៏ដោយ ក៏គាត់មានអាយុប្រហែល ២០ ឬ ២១ ឆ្នាំ នៅចុងឆ្នាំ ១៩៧៦ ឬដើមឆ្នាំ ១៩៧៧។ ជាចុងក្រោយ ង៉ែត ចាត និង សយ ណាវឿន មានអាយុប្រហែល ២០ ឆ្នាំ នៅពេលរៀបការ ហើយ កុល ណែម មានអាយុជាង ២៦ ឆ្នាំ[2404]។ ជាករណីខុសគេ សុន វុត បានឆ្លើយថា អាយុរៀបការសម្រាប់បុរស និងស្រី គឺប្រហែល ៣០ ឆ្នាំ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1040 បានឆ្លើយថា បុរសរៀបការនៅអាយុប្រហែល ២៥ ឆ្នាំ និងស្ត្រី ប្រហែល ២០ ឆ្នាំ[2405]។ ដូច្នេះ ឧទាហរណ៍ដោយឡែកនៃអាយុក្រោមចន្លោះនេះ គឺជាករណីលើកលែងផ្ទុយនឹងការបញ្ញត្តិរបស់បក្សកុម្មុយនីស្តកម្ពុជា[2406]។

---

មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/475.1** ទំព័រ ៣១ ប្រហែលម៉ោង [១១.០០.១៥]។ មុំ វុន ឆ្លើយថា គាត់មានអាយុ ៦៧ ឆ្នាំ នៅពេលគាត់មកផ្តល់សក្ខីកម្មចំពោះមុខតុលាការ នៅឆ្នាំ ២០១៦ ដែលនេះមានន័យថាគាត់មានអាយុ ២៦ ឆ្នាំ នៅឆ្នាំ ១៩៧៥ ដែលជាឆ្នាំគាត់រៀបការ។ ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/476.1** ទំព័រ ៤៦ ប្រហែលម៉ោង [១៣.៤៨.៥៤], ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/488.1** ទំព័រ ៣ ប្រហែលម៉ោង [០៩.០៨.២៣]។

[2404]ព្រាប សុឃឿន បានឆ្លើយថាអាយុពិតប្រាកដរបស់គាត់នៅពេលគាត់មកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ នៅឆ្នាំ ២០១៦ គឺ ៦២ ឆ្នាំ ហើយថាគាត់ប្រហែលជារៀបការនៅចុងឆ្នាំ ១៩៧៦ ឬ ១៩៧៧ ដែលនេះបង្ហាញថានាពេលនោះ គាត់មានអាយុប្រហែល ២០ ឬ ២១ ឆ្នាំ៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/487.1** ទំព័រ ៥៥-៥៦ ប្រហែលម៉ោង [១៤.១៦.៣៣] និង ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/488.1** ទំព័រ ៥៦-៥៧ ប្រហែលម៉ោង [១៣.៤៦.៣៣], ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/488.1** ទំព័រ ៩៥-៩៦ ប្រហែលម៉ោង [១៦.០២.០៤], សយ ណាវឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ២៥ ប្រហែលម៉ោង [១០.៣០.២១] និងទំព័រ ២៧ ប្រហែលម៉ោង [១០.៣៦.២៤], កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/488.1** ទំព័រ ៦៦ ប្រហែលម៉ោង [១៤.១៨.០៥]។

[2405]សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/411.1** ទំព័រ ៥៩ ប្រហែលម៉ោង [១៤.៤១.៣០], ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/412.1** ទំព័រ ៥-៦ ប្រហែលម៉ោង [០៩.១៧.៤០], 2-TCCP-1040 : ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/459.1** ទំព័រ ៦៤ ប្រហែលម៉ោង [១៥.២៥.៤៨]។

[2406]ពាក់ព័ន្ធនឹងករណីរំលោភខុសពីគេទាំងនេះ សូមមើល៖ ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/482.1** ទំព័រ ៥១ ប្រហែលម៉ោង [១៣.៤៣.៤៩]។ ប៉ែន សុចាន់ បានឆ្លើយថា គាត់ជានារីក្មេងជាងគេដែលត្រូវរៀបការ៖ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/483.1** ទំព័រ ៥១ ប្រហែលម៉ោង [១១.៤៧.១០], សៀង សុវិដា ប្រតិចារឹក ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/308.1** ទំព័រ ៣៤-៣៥ ប្រហែលម៉ោង [១១.០៩.៤៥]។ ពាក់ព័ន្ធនឹងអាយុបែបសន្ទុតរបស់សាក្សីម្នាក់ក្នុងសំណុំរឿង ០០៣/០០៤ សូមមើលសេចក្តីកត់សម្គាល់របស់មេធាវីការពារក្តី៖ ប្រតិចារឹក ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/470.1** ទំព័រ ៤៧ ប្រហែលម៉ោង [១៤.០២.២២], ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/471.1** ទំព័រ ២៧-២៨ ប្រហែលម៉ោង [១០.៤១.០២]។ សាក្សី យី ឡៃស្រូវ បានឆ្លើយផងដែរថា គាត់មានអាយុ ១៧ ឆ្នាំ នៅពេលរៀបការ៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/334.1** ទំព័រ ៤៩ ប្រហែលម៉ោង

## 2. តួនាទីរបស់អាជ្ញាធរក្នុងការជ្រើសរើសគូស្រករ

២៣៧១. កថាខណ្ឌ ៨៤៥ នៃដីកាដំណោះស្រាយ គូសបញ្ជាក់ថាការរៀបការត្រូវបានរៀបចំដោយអ្នកផ្សេង ឬគ្រួសាររបស់ពួកគេ។ ការពិនិត្យមើលភ័ស្តុតាងបង្ហាញឱ្យឃើញថា ស្ថានភាព នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនដូចគ្នាទេ គឺមានភាពដូចស្រដៀងគ្នាច្រើនជាមួយសម័យកាលមុនរបបកម្ពុជាប្រជាធិបតេយ្យ។

## 2.ក. ភាពស្រដៀងគ្នា និងភាពខុសគ្នានៃដំណើរការ

២៣៧២. ភាពស្រដៀងគ្នាមានច្រើន រវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំជាប្រពៃណី។ លោកស្រី Kasumi NAKAGAWA បានកត់សម្គាល់ឃើញថាក្នុងការរៀបចំសង្គមឡើងវិញរបស់កម្ពុជាប្រជាធិបតេយ្យ យុវជននៅលីវត្រូវបានចាត់តាំងទៅធ្វើការនៅកងចល័ត ក្រោមការទទួលខុសត្រូវរបស់កម្មាភិបាលមូលដ្ឋាន[2407]។ កម្មាភិបាលមូលដ្ឋានទាំងនេះជាអ្នកអនុវត្តសិទ្ធិអំណាច ដែលជាទូទៅ ត្រូវបានផ្តល់ជូនឪពុកម្តាយ ឬអាណាព្យាបាល នៅក្នុងសង្គមចាស់។ ដូច្នេះ នេះជាការផ្ទេរបុព្វសិទ្ធិរបស់ឪពុកម្តាយក្នុងការផ្សំផ្គុំជូនអង្គការ ប៉ុន្តែ មានបែបបទស្រដៀងគ្នានឹងសម័យកាលមុនរបបកម្ពុជាប្រជាធិបតេយ្យ។

២៣៧៣. លោកស្រី Kasumi NAKAGAWA បានបែងចែកយ៉ាងច្បាស់រវាងការរៀបការដោយបង្ខំ និងការរៀបការដោយមានការអនុញ្ញាត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ បើតាមគាត់ ការរៀបការ

---

[១៤.១០.០០] វាជាអ្វីដែលស៊ីសង្វាក់គ្នា ព្រោះថាបើគាត់កើតឆ្នាំ ១៩៥៨ គាត់ត្រូវមានអាយុ ១៧ ឆ្នាំ នៅឆ្នាំ ១៩៧៥៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ** E1/334.1 ទំព័រ ២០ ប្រហែលម៉ោង [១០.៣០.០០]។ ក៏ប៉ុន្តែ គាត់បានរៀបការជាមួយប្តីគាត់ មួយខែមុនវៀតណាមចូល ដែលនេះមានន័យថាគាត់រៀបការនៅឆ្នាំ ១៩៧៨ ហើយដូច្នេះ នៅពេលនោះ គាត់មានអាយុប្រហែល ២០ ឆ្នាំ៖ ប្រតិចារឹក ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ** E1/334.1 ទំព័រ ៥១ ប្រហែលម៉ោង [១៤.២០.០០]។

[2407] កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ** E1/472.1 ទំព័រ ៣០ ប្រហែលម៉ោង [១០.៤៩.២៣] ទំព័រ ៤៨ ប្រហែលម៉ោង [១៣.៤៦.៣០]៖ "ភាគច្រើននោះ គឺនារីនៅលីវដែលស្ថិតនៅក្នុងវ័យបន្តពូជនៅក្នុងកងចល័ត កងនារី"។

ដោយបង្ខំ គឺជាការរៀបការដែល យ៉ាងហោចណាស់ មានសាមីខ្លួនណាម្នាក់មិនយល់ព្រម ចំណែកឯការរៀបការដោយមានការអនុញ្ញាត គឺមានការយល់ព្រម ទោះជាជ្រើសរើសដោយឪពុកម្តាយ ឬខ្មែរក្រហមក៏ដោយ[2408]។ លោកស្រីយល់ឃើញថា ការផ្សំផ្គុំអនុវត្តដំហានដូច នៅមុនរបបកម្ពុជាប្រជាធិបតេយ្យដែរ មុននឹងសុំឱ្យអាជ្ញាធរមូលដ្ឋានផ្តល់សុពលភាព។ សាក្សីជាច្រើនបានបញ្ជាក់អះអាងអំពីអត្ថិភាពនៃការអនុញ្ញាតដោយកម្មាភិបាល តាមសំណើរបស់ឪពុកម្តាយ ឬយុវជន[2409]។ ទោះបីជាអ្នកជំនាញបានបញ្ជាក់ថា មុនឆ្នាំ ១៩៧៥ អាជ្ញាធរមូលដ្ឋានមិនបានដើរតួនាទីនេះក៏ដោយ ក៏គាត់ទទួលស្គាល់ថា អាជ្ញាធរមូលដ្ឋានចូលរួមក្នុងពិធី ដូចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ដើម្បីផ្តល់សុពលភាពដល់ការរៀបអាពាហ៍ពិពាហ៍ តាមរយៈវត្តមានរបស់ពួកគេ[2410]។

## 2.២. ភាពខុសគ្នានៃសក្ខីកម្មអំពីការចូលរួមរបស់ឪពុកម្តាយ

២៣៧៤. ក្នុងករណីផ្សេងទៀត ទោះបីជាការរៀបចំមង្គលការដោយអ្នកមានអំណាចមេបា ក្រៅពីឪពុកម្តាយ មិនស្របនឹងប្រពៃណីក៏ដោយ ក៏ការទទួលយកពីសំណាក់អនាគតប្តី-ប្រពន្ធ តាមការជ្រើសរើសរបស់អ្នកមានអំណាចមេបាថ្មីនេះ ឬអវត្តមាននៃការប្រកែក គឺជាការគោរពអ្នកមានអំណាចមេបាតាមប្រពៃណី ក្នុងរបៀបនៃការយល់ព្រមតាមការផ្សំផ្គុំ។ ទោះបីជាមានការផ្ទេរពីអ្នកមានអំណាច

---

[2408] ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ៥២ ប្រហែលម៉ោង [១៣.៥៧.៣៦] ទំព័រ ៤៤-៤៥ ចន្លោះម៉ោង [១៣.៣២.៣៣] និង [១៣.៣៥.០០]។

[2409] 2-TCW-850 : ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/461.1** ទំព័រ ៦២ ប្រហែលម៉ោង [១៥.០៦.៥៧], ពេជ្រ ជឹម, ប្រតិចារឹក ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ E1/290.1** ទំព័រ ៣១-៣២ ប្រហែលម៉ោង [១៣.៤៧.១០], ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ E1/291.1** ទំព័រ ៤-៥ ប្រហែលម៉ោង [០៩.១៤.៤២], មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ៨-៩ ប្រហែលម៉ោង [០៩.២៨.៤១], កុង អ៊ុត ប្រតិចារឹក ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/322.1** ទំព័រ ២៥ ប្រហែលម៉ោង [១០.៥៥.១៩], អ៊ុំ ជី ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/326.1** ទំព័រ ៨៧ ប្រហែលម៉ោង [១៥.៤៨.១៨], សេង ស្រ៊ុន ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/346.1** ទំព័រ ៤៦ ប្រហែលម៉ោង [១១.៥១.៤០]។

[2410] ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ២៩ ប្រហែលម៉ោង [១០.៤៥.១១] ("ហើយរបៀបដែលគេទទួលបានការអនុញ្ញាតពីអាជ្ញាធរវិញ គឺថាវាអាចនឹងត្រូវបានគេចុះបញ្ជីនៅអាជ្ញាធរមូលដ្ឋាន ប៉ុន្តែភាគច្រើន អាជ្ញាធរមូលដ្ឋានទាំងអស់នោះ ដូចជាប្រធានភូមិអីជាដើម ត្រូវបានគេអញ្ជើញឱ្យមកចូលរួមក្នុងពិធីមង្គលការនោះដែរ។ ហើយនេះហើយគឺជានីតិវិធីក្នុងការចុះអត្រានុកូលដ្ឋានការរៀបការនោះ") និងទំព័រ ៣៦-៣៧ ប្រហែលម៉ោង [១១.១១.២០]។

មេបាមួយ (ឪពុកម្ដាយ) ទៅកាន់អ្នកមានអំណាចមេបាមួយទៀត (អាជ្ញាធរមូលដ្ឋាន ឬអង្គការ) ក៏ដោយ ក៏ដំណើរការមានភាពស្រដៀងគ្នាខ្លាំងនឹងការផ្សំផ្គុំតាមប្រពៃណី[2411]។

២៣៧៥. សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើន បានលើកឡើងអំពីការចូលរួមរបស់ឪពុកម្ដាយក្នុងការរៀបអាពាហ៍ពិពាហ៍។ ឧទាហរណ៍ កង អ៊ិត, អះម៉ាត់ សហ្វីយាស់, ហេង ឡៃហ៊ាង, មាស ឡៃហួរ និង សេង ស្រ៊ុន ត្រូវបានគេរៀបការ ក្រោយពីមានការផ្សំផ្គុំ ដោយបានពិគ្រោះយោបល់ជាមួយឪពុកម្ដាយ[2412]។ យន់ ប៊ីន ក៏បានលើកឡើងអំពីវត្តមានរបស់ឪពុកម្ដាយ ក្នុងពេលរៀបការ[2413]។ សាក្សី 2-TCW-918 ក៏បានលើកឡើងអំពីការចូលរួមរបស់ឪពុកម្ដាយ ដូចសាក្សី 2-TCW-850 និង

2-TCW-1002 ដែរ។ សាក្សី ដែលមិនបានមកផ្ដល់សក្ខីកម្ម ក៏បានបញ្ជាក់អះអាងអំពីការចូលរួមរបស់ឪពុកម្ដាយ[2414] ដូចលោកស្រី Kasumi NAKAGAWA ដែរ[2415]។

---

[2411] កាន ចុល ប្រតិចារឹក ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/327.1** ទំព័រ ៥៤ ប្រហែលម៉ោង [១៥.៣៣.០៦], ឱ ហូ ប្រតិចារឹក ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/301.1** ទំព័រ ៤២-៤៣ ប្រហែលម៉ោង [១៣.៥៤.២០]។

[2412] កង អ៊ិត ប្រតិចារឹក ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/322.1** ទំព័រ ២៥ ប្រហែលម៉ោង [១០.៥៥.១៩], អះម៉ាត់ សហ្វីយ៉ាស់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/375.1** ទំព័រ ៦៧ ប្រហែលម៉ោង [១៤.៣៩.៣៩], ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/476.1** ទំព័រ ៤៣ ប្រហែលម៉ោង [១៣.៤១.៤០], មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ៨-៩ ប្រហែលម៉ោង [០៩.២៨.៤១], សេង ស្រ៊ុន ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/346.1** ទំព័រ ៤៦ ប្រហែលម៉ោង [១១.៥១.៤០]។

[2413] យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/457.1** ទំព័រ ២៩ ប្រហែលម៉ោង [១១.០៩.១០], 2-TCW-918 : ប្រតិចារឹក ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/360.1** ទំព័រ ២៨ ប្រហែលម៉ោង [១១.១២.២៦], 2-TCW-850 : ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/461.1** ទំព័រ ៦២ ប្រហែលម៉ោង [១៥.០៦.៥៧], 2-TCW-1002 : ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/469.1** ទំព័រ ៥២ ប្រហែលម៉ោង [១៤.០០.០៤]។

[2414] កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E3/9655** ស/ឆ ១៦, កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E3/9666** ស/ឆ ៧, កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ **ឯកសារ E3/9743** ស/ឆ ៣។

[2415] ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ៤៥ ប្រហែលម៉ោង [១៣.៣៥.០០]។

២៣៧៦. ដូច្នេះ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេថា ព្យសនកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី បានលើកឡើងជារឿយៗ គឺអវត្តមាននៃពិធីផ្សេងៗ ឬអវត្តមានគ្រួសារក្នុងពេលរៀបការ ជាជាងរបៀបនៃការរៀបចំផ្សំផ្គុំ[2416]។ ប៉ុន្តែ សូម្បីតែក្នុងករណីនេះ ក៏គ្រួសារបានដើរតួនាទីដែរ។

## 2.គ. **<u>ចំណងទាក់ទង និងមនោសញ្ចេតនា កើតក្រោយការរៀបអាពាហ៍ពិពាហ៍</u>**

២៣៧៧. ការរក្សាចំណងអាពាហ៍ពិពាហ៍ជាច្រើន ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ គឺជាភាពស្រដៀងគ្នាមួយទៀតជាមួយនឹងការរៀបការតាមការផ្សំផ្គុំ។ គូខ្លះបានចែកផ្លូវគ្នា ភ្លាមៗក្រោយពីចប់របបកម្ពុជាប្រជាធិបតេយ្យ ឯគូខ្លះទៀតបានបែកគ្នា យូរក្រោយមកទៀត ដោយសារតែហេតុផលមិនអាស្រ័យនឹងកាលៈទេសៈនៃការរៀបការ[2417]។ បើតាមអ្នកជំនាញ គូភាគច្រើនបន្តរស់នៅជាមួយសហព័ទ្ធដែលបានរៀបការ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[2418]។ បាតុភូតនេះត្រូវបានបញ្ជាក់អះអាងនៅក្នុងសវនាការ[2419]។ ម្យ៉ាងវិញទៀត សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានគូសបញ្ជាក់ថា ការប្តេជ្ញាតម្រូវឱ្យគូស្រករស្រឡាញ់គ្នា[2420]។

---

[2416] <u>ផេហ្គី ឡឺវ៉ាញ</u> ប្រតិចារឹក ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/481.1** ទំព័រ ៣៥-៣៨ ចន្លោះម៉ោង [១១.០២.៥៣] និង [១១.១១.០២]។ សូមមើលផងដែរផ្នែកខាងក្រោម កថាខណ្ឌ ២៣៧៩-២៣៩០។

[2417] <u>ថៅ ឡាង</u> ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/339.1** ទំព័រ ៦៤-៦៦ ចន្លោះម៉ោង [១៥.៣២.៥៦] និង [១៥.៤០.៥៦]៖ “[...] ចង់រកប្រពន្ធដែលមានផ្ទះមានសម្បែងមានដីធ្លីស្រែចម្ការ [...] ហើយក៏មិនមែនថា យើងនឹងងាយនឹងសម្រេចចិត្តថាលែងបានទេ ដោយសារថាប្តីប្រពន្ធនាងខ្ញុំពុំមានអ្វីដែលជាទំនាស់ ឬមានការឈ្លោះទាស់ទែងគ្នានោះទេ [...]។ តែដោយសារថាម្តាយរបស់គាត់មិនពេញចិត្ត [...] គឺខ្ញុំចុះចេញ លែងលះពីគាត់ហ្នឹង”, <u>មុំ វុន</u> ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/475.1** ទំព័រ ៤៧-៤៨ ប្រហែលម៉ោង [១៣.៥០.៣៧], <u>មាស ឡៃហួរ</u> ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ១៦ ប្រហែលម៉ោង [០៩.៥៣.៣៤]។

[2418] <u>កាស៊ូមិ ណាកាហ្គាវ៉ា</u> ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/473.1** ទំព័រ ១៥ ប្រហែលម៉ោង [០៩.៥៣.១៧], <u>ផេហ្គី ឡឺវ៉ាញ</u> ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/482.1** ទំព័រ ២៦ ប្រហែលម៉ោង [១០.១៨.៥៧]។ សូមមើលផងដែរ អត្ថបទមានចំណងជើងថា៖ “ស្ថិតក្រោមការបង្ខំឲ្យរៀបការ គូស្វាមីភរិយាពីសម័យខ្មែរក្រហមប្តេជ្ញាជាថ្មីដោយស្ម័គ្រចិត្ត” និពន្ធដោយ S. KHIMM និង K. CHAN ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៦ សារព័ត៌មាន ឌឹខេមបូឌា ដេលី **ឯកសារ E3/7298**។

[2419] <u>ម៉ម សឿម ហៅ ហេង សាម្លូត</u> ប្រតិចារឹក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/325.1** ទំព័រ ២៣ ប្រហែលម៉ោង [១០.១២.៥៦], <u>អ៊ុន យឿង</u> ប្រតិចារឹក ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៧១ ប្រហែលម៉ោង [១៥.២៤.៣០], <u>2-TCW-938</u> : ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/379.1** (សវនាការអសាធារណៈ) ទំព័រ

២៣៧៨. ត្រង់ចំណុចនេះ លោកស្រី Peg LEVINE បានពន្យល់ថា ចំណងទាក់ទងបានរីកលូតលាស់ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ដោយសារតែបទពិសោធន៍នៃសន្តានចិត្តល្អ និងការជម្នះការលំបាកជាមួយគ្នា។ ការរៀបការដោយគ្មានពិធីតាមប្រពៃណី មិនបានរារាំងជំនឿសាសនា ដែលហៅថា "គូព្រេង" នោះទេ គឺថាព្រះកំណត់មក។ ទៅតាមករណីនីមួយៗ ការរៀបអាពាហ៍ពិពាហ៍ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានបង្កើតឱ្យមានចំណងទាក់ទង ដូចគូស្រករដែលកើតចេញពីមង្គលការតាមប្រពៃណីដែរ[2421]។

---

២៦ ប្រហែលម៉ោង [១០.៤៣.៤០], សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/412.1** ទំព័រ ១១ ប្រហែលម៉ោង [០៩.៣៨.០៣], យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/464.1** ទំព័រ ២៤ ប្រហែលម៉ោង [១០.៥២.៣២], 2-TCW-1002 : ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/469.1** ទំព័រ ៤៨ ប្រហែលម៉ោង [១៣.៤៦.៣៦]។

[2420] ភ្លៅ យ៉ារ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/264.1** ទំព័រ ២៥ មុនម៉ោង [១០.៥០.៤៣]៖ "[...] គាត់ឡើងទៅ គាត់គ្រាន់តែថា៖ "ខ្ញុំសូមប្ដេជ្ញាស្រឡាញ់យាយអស់មួយជីវិត"។ ហើយយាយគាត់ឡើងដែរថា "សូមប្ដេជ្ញាស្រឡាញ់តាអស់មួយជីវិត"", ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/466.1** ទំព័រ ៥៦ ប្រហែលម៉ោង [១៤.០០.៣១]៖ "អង្គការគ្រាន់តែណែនាំថា [...] ឲ្យចេះស្រឡាញ់គ្នា", ផាន់ ហ៊ីម ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/467.1** ទំព័រ ៧១ ប្រហែលម៉ោង [១៤.២៥.២៧]៖ "[...] អប់រំពីរឿងយើងរស់នៅមានជាគូស្វាមីហ្នឹងទៅ [...] ចេះស្រឡាញ់គ្នា ខំប្រឹងធ្វើការងារ", មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/475.1** ទំព័រ ៤៤ ប្រហែលម៉ោង [១៣.៤០.៣៥]៖ "កម្មាភិបាល [...] ប្រកាសប្រាប់ថា គូស្រករដែលរៀបថ្មីជាប្ដីប្រពន្ធហើយនេះ ត្រូវចេះស្រឡាញ់គ្នា មើលថែរក្សាគ្នា [...]"។ ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/482.1** ទំព័រ ៥៦ ប្រហែលម៉ោង [១៤.០២.០៧] ("[...] ក៏ត្រូវពេញចិត្ត"), សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៣១ មុនម៉ោង [១០.៥១.០៦]៖ "ហើយអង្គការទាំងនោះបានហៅមួយគូឡើងប្ដេជ្ញាចិត្ត [...] ឲ្យស្រឡាញ់គ្នាចាប់ពីពេលនេះតទៅ បង្កបង្កើនផលឲ្យបានច្រើន [...]", សេង លីថេង ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/503.1** ទំព័រ ៣៤ ប្រហែលម៉ោង [១១.២៥.១៨]៖ "ពិធីមានតែហូបចុកអីបន្តិចបន្តួច ហើយមានការណែនាំ ផ្ដាំផ្ញើអី ឲ្យចេះស្រឡាញ់គ្នាយូរអង្វែង អីដូចជាយើងអ៊ីចឹងដែរហ្នឹង", 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៨០ ប្រហែលម៉ោង [១៦.០០.៥៧]៖ "បាទគាត់និយាយផ្ដាំផ្ញើរៀបចំអាពាហ៍ពិពាហ៍ ដោយមានការណែនាំកសាងខ្លួន ខំសាមគ្គីភាពរវាងគ្នានឹងគ្នា [...]"។

[2421] ផេហ្គី ឡឺវ៉ាញ ប្រតិចារឹក ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/480.1** ទំព័រ ៤៨-៥០ ចន្លោះម៉ោង [១៥.១៤.៥៥] និង [១៥.១៩.៣៥]។

### 3. ការរៀបអាពាហ៍ពិពាហ៍ និងអទត្ថមាននៃពិធីផ្សេងៗ

២៣៧៩. កថាខណ្ឌ ៨៤៣ និងកថាខណ្ឌ ៨៤៤ បានលើកឡើងអំពីពិធីរៀបការរួមគ្នា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានចាប់ពី "២ គូ ទៅជាង ១០០ គូ" និងភាគច្រើន ពី ១០ គូ ទៅ ១០០ គូ។ ដូច្នេះ គម្លាតខុសគ្នាឆ្ងាយណាស់។ តាមពិត សាក្សីខ្លះបានលើកឡើងអំពី "ពិធីប្ដេជ្ញាបដិវត្តន៍" ធំៗជាសមូហភាព ហើយសាក្សីជាច្រើនបានលើកឡើងអំពីពិធីតូចៗសម្រាប់គូតិចតួច[2422]។ លក្ខណៈសមូហភាពត្រូវបានបង្ហាញថាជាមធ្យោបាយកាត់បន្ថយចំណាយរបស់អង្គការ។

២៣៨០. ក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវ អ្នកជំនាញ Peg LEVINE បានវិភាគប្រភេទនៃការឃើចាប់ដែលរៀបរាប់ដោយប្ដី-ប្រពន្ធ ក្នុងចំណោមអាពាហ៍ពិពាហ៍របស់ពួកគេ។ គាត់បានរកឃើញថា ការបង្ខំមិនត្រូវបាននិយាយចេញមកដោយឯកឯងដោយប្ដី-ប្រពន្ធ ដែលជាសំណាកគំរូនៃការសិក្សារបស់គាត់ទេ។ ការសិក្សានរវិទ្យារបស់គាត់នាំឱ្យគាត់សន្និដ្ឋានថា ការឃើចាប់របស់គូដែលរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមែនដោយសារការបង្ខំឱ្យយល់ព្រមនោះទេ គឺដោយសារការលុបបំបាត់ពិធីផ្សេងៗតាមប្រពៃណី ក្នុងពេលរៀបអាពាហ៍ពិពាហ៍។ លោកស្រី Peg LEVINE បានលើកឡើងអំពីចរិតលក្ខណៈនៃការបាត់បង់ពិធី ដែលបណ្ដាលឱ្យបាត់បង់ការគាំពារការភ័យ

---

[2422] ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/252.1** ទំព័រ ៥៥-៥៦ ប្រហែលម៉ោង [១៣.៥១.០៨] (សាក្សីនិយាយថាមាន៣ គូ ពីរបី គូ និងប្រហែល ៣០ ៣២ គូ), ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/254.1** ទំព័រ ៦៥ ប្រហែលម៉ោង [១៥.២១.០៨] (មានបួនប្រាំគូ និងច្រើនគូ) ទំព័រ ៧៥ ប្រហែលម៉ោង [១៥.៥២.១១] (៦ គូ), រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/262.1** ទំព័រ ៤៨-៤៩ ប្រហែលម៉ោង [១៣.៤៩.៥០] (២ គូ) ទំព័រ ៥១ មុនម៉ោង [១៣.៥៨.១៥] (៣៤ គូ), នាង អ៊ួច ប្រតិចារឹក ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៥ **ឯកសារ E1/275.1** ទំព័រ ៣៣-៣៤ ប្រហែលម៉ោង [១១.២៨.៥៤] (៥ គូ), ប៊ិច សុខា ប្រតិចារឹក ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/302.1** ទំព័រ ៤៥ ប្រហែលម៉ោង [១៤.១៤.៤៥] (ច្រើនគូ), មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ៣ មុនម៉ោង [០៩.០៨.២៨] (២៥ គូ), ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/321.1** ទំព័រ ៥១ ប្រហែលម៉ោង [១៤.២៥.០៩] (៥ គូ), ឃិន វ៉ាត ប្រតិចារឹក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/325.1** ទំព័រ ៦៨ ប្រហែលម៉ោង [១៥.៤០.៣៥] (១ គូ), យី ឡៃស្រួ ប្រតិចារឹក ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/334.1** ទំព័រ ៥០ ប្រហែលម៉ោង [១៤.១២.៣៦] (៣ គូ), ឈុយ ហ៊ុយ ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/335.1** ទំព័រ ៣៦ ប្រហែលម៉ោង [១១.២៦.៣៨] (៤ គូ), សុះ រំលី ប្រតិចារឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/372.1** ទំព័រ ៣៥ ប្រហែលម៉ោង [១១.១៣.៤៩] (៤ គូ ជាង ២០ គូ), 2-TCW-894 : ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/377.1** (សវនាការអសាធារណៈ) ទំព័រ ៣០ ប្រហែលម៉ោង [១១.០១.៥០] (៨ គូ)។

ខ្លាច ជាពិសេស ដោយសារតែភាពមិនអាចកំណត់បាន និងភាពអាថ៌កំបាំងរបស់អង្គការ[2423]។ ការវិភាគនេះត្រូវបានគាំទ្រដោយឧទាហរណ៍នៃការរៀបការម្តងទៀត នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីប្រារព្ធពិធី សម្រាប់គូដែលបានរៀបការ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2424]។

## ខ. ស្ថានភាពក្រោយការរៀបអាពាហ៍ពិពាហ៍

### 1. កាលៈទេសៈបង្ខំដែលត្រូវបានចោទប្រកាន់

២៣៨១. ការវិភាគអង្គហេតុ ដែលអាចត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ រួមបញ្ចូលផ្នែកពាក់ព័ន្ធនឹងកាលៈទេសៈបង្ខំ។ កថាខណ្ឌ ៨៤៩ នៃដីកាដំណោះស្រាយ រៀបរាប់ជាអាទិ៍អំពីការភ័យខ្លាចទទួលទណ្ឌកម្ម ក្នុងករណីជំទាស់នឹងអង្គការ ដូចបានលើកឡើងពីខាងលើ[2425]។ សាក្សីខ្លះបានឆ្លើយថា ការប្រកែកមិនព្រមរួមដំណេកអាចនាំទៅដល់ការកសាង។ សក្ខីកម្មរបស់សាក្សីជាច្រើនសុទ្ធតែជាពាក្យចចាមអារ៉ាម ឬជាការស្មានដោយខ្លួនឯង[2426]។

២៣៨២. លើសពីនេះទៀត កាលៈទេសៈបង្ខំ ដែលត្រូវបានមើលឃើញយ៉ាងទូលំទូលាយ ត្រូវពិនិត្យ ដោយធៀបនឹងលក្ខណៈពិសេសនៃវប្បធម៌របស់សង្គមខ្មែរ ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០។ ជាក់ស្តែង ដូចបានឃើញពីខាងលើ ការរៀបការមិនផ្អែកលើការយល់ព្រមពីមនុស្សពីរនាក់នោះទេ ហើយការវិភាគ

---

[2423]ប្រតិចារឹក ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/481.1** ទំព័រ ៣៥-៣៨ចន្លោះម៉ោង [១១.០២.៥៣] និង [១១.១១.០២]។

[2424]ប្រតិចារឹក ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/481.1** ទំព័រ ៣៦ ប្រហែលម៉ោង [១១.០៥.១៥], ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/482.1** ទំព័រ ២-៤ ប្រហែលម៉ោង [០៩.០៣.៣២] ទំព័រ ៧-៨ ប្រហែលម៉ោង [០៩.១៩.៣៣]។ អត្ថបទមានចំណងជើងថា៖ "ស្ថិតក្រោមការបង្ខំឲ្យរៀបការ គូស្វាមីភរិយាពីសម័យខ្មែរក្រហមប្តេជ្ញាជាថ្មីដោយស្ម័គ្រចិត្ត" និពន្ធដោយ S. KHIMM និង K. CHAN ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៦ សារព័ត៌មាន ឌឺខេមបូឌា ដេលី **ឯកសារ E3/7298**។

[2425]សូមមើលផ្នែកខាងលើ កថាខណ្ឌ ២៣៦៥-២៣៦៨។

[2426]រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/262.1** ទំព័រ ៥០ មុនម៉ោង [១៣.៥៥.៥៨], 2-TCCP-232 : ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/464.1** ទំព័រ ២២ ប្រហែលម៉ោង [១០.៤៨.១២] ទំព័រ ២៩ ប្រហែលម៉ោង [១១.០៩.២៤], ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៣ ប្រហែលម៉ោង [០៩.០៨.៥១], 2-TCW-1002 ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/469.1** ទំព័រ ៥៨ ប្រហែលម៉ោង [១៤.១៨.៣០]។

តាមបែបបស្ចិមប្រទេសទៅលើការរៀបការ មិនអាចយកមកអនុវត្តបានទេ។ ដូចគ្នាផងដែរ ក្រៅពីអ្វីដែលបានអត្ថាធិប្បាយពាក់ព័ន្ធនឹងច្បាប់ស្រី គួរកត់សម្គាល់ផងដែរថា ការអប់រំខ្មែរច្រានចោលស្មារតីរឹះគន់ និងការជំទាស់តវ៉ា ដែលអាចដើរតួនាទីក្នុងការមិនប្រកែកមិនព្រមរៀបការ[2427]។

២៣៨៣. អវត្តមាននៃការមិនទុកចិត្តលើអាជ្ញាធរ ការបាត់បង់ពិធីគាំពារ និងវត្តមានអង្គការនៅគ្រប់ទិសទី ដូចជា "ចរិតលក្ខណៈបរមត្ថវិជ្ជា ឬទេវកថាវិទ្យា"[2428] អាចដើរតួនាទីនៅក្នុងការភ័យខ្លាចរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ យើងត្រូវចាត់ទុកការភ័យខ្លាចនៅក្នុងបរិបទជាក់លាក់នៃការរៀបការថាបណ្តាលមកពីចរិតលក្ខណៈវប្បធម៌ ជាជាងបណ្តាលមកពីប្រព័ន្ធកៀបសង្កត់។ គោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ គឺត្រូវមានការយល់ព្រមពីសាមីខ្លួនទាំងសងខាង គឺជាការជឿនលឿនទៅមុខ បើធៀបទៅនឹងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងត្រូវបានមើលឃើញបែបនេះ។

២៣៨៤. ជាចុងក្រោយ យើងត្រូវយោងទៅលើការវិភាគរបស់លោកស្រី Peg LEVINE ពាក់ព័ន្ធនឹងការប្រើប្រាស់ពាក្យ "បង្ខំ"។ ជាក់ស្តែង គាត់បានកត់សម្គាល់ថា ជម្រើសវាក្យស័ព្ទអាចជះឥទ្ធិពលខ្លាំងដល់ទស្សនៈដែលថាមនុស្សម្នាក់ៗមានបទពិសោធន៍ផ្ទាល់ខ្លួន។ ដូច្នេះ គាត់បានសង្កេតឃើញថា ប្តី-ប្រពន្ធភាគច្រើន ដែលជាសំណាកគំរូនៃការស្រាវជ្រាវ មិនបានចាត់ទុកការរៀបការរបស់ពួកគាត់ថាជាការបង្ខំទេ រហូតដល់ពេលដែលការផ្សំផ្គុំ នៅក្នុងរបបខ្មែរក្រហម ត្រូវបានកំណត់ថាជាការបង្ខំ[2429]។ ម្យ៉ាងវិញទៀត គាត់បានពន្យល់ថា ក្រោម ១០% នៃសំណាកគំរូរបស់គាត់ ត្រូវបានគេរៀបការ ដោយការបកស្រាយការគំរាមកំហែងអំពើ "ហិង្សា"។ តាមពិត គ្មានអំពើហិង្សាណាមួយឡើយ[2430]។

---

[2427] សៀវភៅនិពន្ធដោយ P. SHORT មានចំណងជើងថា *Anatomie d'un cauchemar* ឆ្នាំ ២០០៤ **ឯកសារ E3/9** ទំព័រ ៥២ ERN 00639491 (ភាសាបារាំង)។ សូមមើលផ្នែកខាងលើ កថាខណ្ឌ ២៣៦៥-២៣៦៨។

[2428] ផេហ្គី ឡឺវ៉ាញ ប្រតិចារឹក ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/481.1** ទំព័រ ៥-៦ ប្រហែលម៉ោង [០៩.១៦.៤១]។

[2429] ផេហ្គី ឡឺវ៉ាញ ប្រតិចារឹក ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/480.1** ទំព័រ ៣៣-៣៤ ប្រហែលម៉ោង [១៤.០៨.៥៤] ទំព័រ ៣២-៣៣ ប្រហែលម៉ោង [១៤.០៥.២២]។

[2430] ផេហ្គី ឡឺវ៉ាញ ប្រតិចារឹក ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/481.1** ទំព័រ ២៩ ប្រហែលម៉ោង [១០.៤២.៤១]។

## 2. ការរួមដំណេក

២៣៨៥. បើតាមកថាខណ្ឌ ២១៨ ដល់កថាខណ្ឌ ២២០ នៃដីកាដំណោះស្រាយ ភ័ស្តុតាងដែលសហចៅក្រមស៊ើបអង្កេតប្រមូលបាន អាចឱ្យកំណត់ថា កម្ពុជាប្រជាធិបតេយ្យបានបង្កើតគោលនយោបាយស្តីពីការដាក់បទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍ ដោយត្រូវបង្ខំយុវជនឱ្យរៀបការ ដើម្បីបង្កើនចំនួនប្រជាជន។ គោលនយោបាយបែបនេះពន្យល់អំពីការឃ្លាំមើលការរួមដំណេកដោយកងឈ្លប ដូចបានរៀបរាប់នៅកថាខណ្ឌ ៨៥៨ នៃដីកាដំណោះស្រាយ។ យើងត្រូវពិនិត្យមើលភ័ស្តុតាងសក្ខីកម្មពាក់ព័ន្ធនឹងបញ្ហានេះ ដោយទំនាក់ទំនងហេតុ និងបច្ច័យ ដែលបង្ហាញដោយសហចៅក្រមស៊ើបអង្កេត នឹងត្រូវពិនិត្យមើលខាងក្រោមនេះ[2431]។

## 2.ក. ការណែនាំឱ្យរួមដំណេក

២៣៨៦. សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បានអះអាងថា គូនីមួយៗត្រូវគេបង្ខំឱ្យរួមដំណេកជាអាទិ៍ តាមរយៈការអប់រំអ្នកដែលមិនចុះសម្រុងនឹងគ្នា នៅផ្ទះមេភូមិ ឬនៅមន្ទីររបស់អាជ្ញាធរមូលដ្ឋាន[2432]។ ការអប់រំនេះ គឺជាការនិយាយបញ្ចុះបញ្ចូលដោយមេភូមិ ឬថ្នាក់លើ ឱ្យប្តី-ប្រពន្ធ

---

[2431] សូមមើលផ្នែកខាងក្រោម កថាខណ្ឌ ២៤៣០-២៤៣៩។

[2432] <u>អ៊ិន យឿង</u> ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៦៩ ប្រហែលម៉ោង [១៥.១៨.២៥]៖ "ប្រាប់គេបានប្រាប់ថា ត្រូវតែរួមដំណេកគ្នា បើមិនរួមដំណេកគ្នា គេយកទៅដាក់កន្លែងឃុំឱ្យដេកជាមួយគ្នា [...]", <u>ភៅ យ៉ាវ</u> ប្រតិចារឹក ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ **ឯកសារ E1/264.1** ទំព័រ ២៧ មុនម៉ោង [១០.៥៨.៥៣]៖ "បាទ គេចង់ដឹងរឿងរួមដំណេកហ្នឹង លោកប្រធាន។ បាទ បើអត់ចុះសម្រុងគ្នាអ៊ីចឹង ស្អែកឡើងគេហៅមកទាំងពីរនាក់ហ្នឹង ណែនាំ ប្រាប់អ៊ីចេះ ប្រាប់អ៊ីចុះ [...]", <u>ប្រាក់ ខឿន</u> ប្រតិចារឹក ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/361.1** ទំព័រ ៨១ ប្រហែលម៉ោង [១៥.៥៨.៥៥]៖ "[...] យកចិត្តទុកដាក់ជាមួយគ្នា ដើម្បីរស់រានមានជីវិតដេកនៅជាមួយគ្នា កុំឱ្យមានពាក្យធំ ពាក្យតូច កុំឱ្យបន្ទោសទៅដល់អង្គការ [...]", <u>2-TCW-834</u>: ប្រតិចារឹក ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/376.1** (សវនាការអសាធារណៈ) ទំព័រ ៦០ មុនម៉ោង [១៥.៤២.០១], <u>2-TCW-938</u> : ប្រតិចារឹក ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/378.1** (សវនាការអសាធារណៈ) ទំព័រ ៤០ ប្រហែលម៉ោង [១៣.៤៧.២៧], <u>2-TCCP-300</u> : ប្រតិចារឹក ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/361.1** ទំព័រ ៨១ ប្រហែលម៉ោង [១៥.៥៨.៥៥]។

ថ្លោងថ្មីខំប្រឹងចុះសម្រុងនឹងគ្នា។ ការចូលរួមរបស់មេភូមិ ឬអាជ្ញាធរមូលដ្ឋាន ក្នុងការដោះស្រាយទំនាស់គ្រួសារ មិនមែនជារឿងកម្រនោះទេ ហើយការអនុវត្តនេះបន្តរហូតមកទល់សព្វថ្ងៃ[2433]។

២៣៨៧. នៅពេលឆ្លើយទៅនឹងសំណួរអំពីការរួមដំណេក នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ អ្នកជំនាញ Kasumi NAKAGAWA បានអះអាងថា ដោយសារគេកម្រនឹងនិយាយពីរឿងរួមភេទ សង្គមខ្មែរនៅមុនរបបកម្ពុជាប្រជាធិបតេយ្យ មិនស្គាល់អ្វីទៅជាការអប់រំផ្លូវភេទនោះទេ គឺមិនមានការណែនាំអំពីការរួមភេទនោះទេ។ ប៉ុន្តែ គាត់បានបញ្ជាក់ថា គេរំពឹងចង់ឱ្យប្តី-ប្រពន្ធរួមដំណេកជាមួយគ្នា។ ជាក់ស្តែង គេបានណែនាំស្ត្រីខ្លះឱ្យ "ធ្វើតាមប្តី ក្នុងរាត្រីផ្សំដំណេក"។ បើតាមអ្នកជំនាញ តាមប្រពៃណី គេរំពឹងចង់ឱ្យប្រពន្ធមានគភ៌ភ្លាមៗ បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច ដែលតម្រូវឱ្យមានការរួមភេទ បើទោះជាគ្មានការកំណត់ជាផ្លូវការក៏ដោយ[2434]។

២៣៨៨. លើសពីនេះទៅទៀត លោកស្រី Peg LEVINE បានលើកឡើងអំពីទម្រង់នៃការបង្ហាញអំពីផ្លូវភេទនៅតាមស្រុកស្រែ ក្រោមរូបភាពជារឿងកំប្លែងសើចសប្បាយ។ ត្រង់នេះទៀត ទំនាក់ទំនងផ្លូវភេទត្រូវបានលើកឡើងដោយសារបញ្ហាបន្តពូជ[2435]។ម្យ៉ាងវិញទៀត គាត់បានធ្វើការប្រៀបធៀបរវាងភាពតឹងរ៉ឹងនិយមនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលសាក្សី ឌុច ស៊ីថន បានលើកឡើងរួចមកហើយ និងភាពតឹងរ៉ឹងនិយមនៃវប្បធម៌ខ្មែរ។ ទោះបីជាក្នុងការសិក្សា គាត់បានកត់សម្គាល់ឃើញថា ប្តី-ប្រពន្ធភាគតិចបានឮគេស្នើឱ្យរួមដំណេក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដោយ ក៏គាត់អះអាងថា មានចំនួនតិចតួចប៉ុណ្ណោះដែលបានអនុវត្តតាម នាពេលក្រោយមក[2436]។

---

[2433] "អំពើហិង្សាលើស្ត្រី៖ ច្បាប់កម្ពុជារើសអើងចំពោះស្ត្រី" CAMBOW ២០០៧ **ឯកសារ E3/10658a** ទំព័រ ១-៧ ERN 01407566-72។

[2434] <u>កាស៊ូមិ ណាកាហ្គាវ៉ា</u> ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ៣៧-៣៨ ប្រហែលម៉ោង [១១.១៣.៥៤]។

[2435] <u>ផេហ្គី ឡឺវ៉ាញ</u> ប្រតិចារឹក ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/480.1** ទំព័រ ៥៨ ចន្លោះម៉ោង [១៥.៤៨.៣០] និង [១៥.៥១.២៤]។

[2436] និក្ខេបបទរបស់ <u>ផេហ្គី ឡឺវ៉ាញ "ការសិក្សាអំពីបរិបទនៃការរៀបការ និងការផ្តល់កំណើត ក្នុងសម័យខ្មែរក្រហម៖ បដិវត្តន៍ទំនៀមទម្លាប់"</u> **ឯកសារ E3/1794** ERN 00482540 (ភាសាអង់គ្លេស), ប្រតិចារឹក ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/480.1** ទំព័រ ៥៧ ប្រហែលម៉ោង [១៥.៤៤.២០]។ អ្នកជំនាញបានបញ្ជាក់នៅក្នុងសវនាការថា មនុស្ស ៤០ ភាគរយ (៧៦ នាក់ លើ ១៩២) ទំនងជាត្រូវបានណែនាំឱ្យរួមដំណេក។ គឺប្រហែលមានតែ ៩ ភាគរយ ប៉ុណ្ណោះ (១៩ នាក់ ក្នុងចំណោម ១៩២)

## 2.ខ. សក្ខីកម្មអំពីការឃ្លាំមើល

២៣៨៩. បរិបទវប្បធម៌តឹងរ៉ឹង និងសីលធម៌ផ្លូវភេទអភិរក្សនិយមរបស់ខ្មែរក្រហម ធ្វើឱ្យចម្លើយពាក់ព័ន្ធនឹងការរួមដំណេកមិនសូវមានភាពគួរឱ្យជឿជាក់បាន។ ម្យ៉ាងវិញទៀត ជារឿយៗ សក្ខីកម្មអំពីបញ្ហានេះ គឺជាលទ្ធផលនៃការស្មាន ឬពាក្យចចាមអារ៉ាម។ ជាពិសេស អ្នកដែលបានលើកឡើងអំពីការឃ្លាំមើលបែបនេះ និយាយអំពីទង្វើរបស់ឈ្លបភូមិ ដោយមិនបង្ហាញអំពីសេចក្ដីណែនាំទទួលបានពីថ្នាក់លើ។

២៣៩០. ជាក់ស្ដែង សាក្សីមួយចំនួនបានឆ្លើយថា ការរួមដំណេកដោយប្ដី-ប្រពន្ធថ្មោងថ្មីត្រូវបានឃ្លាំមើលដោយពួកឈ្លប ឬឃោធា[2437]។ ប៉ុន្តែ សាក្សីភាគច្រើនផ្អែកលើពាក្យចចាមអារ៉ាម ឬការស្មាន ដែលមិនគ្រប់គ្រាន់ឱ្យបង្ហាញអំពីអង្គហេតុដែលបានចោទប្រកាន់[2438]។ ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់បាន

---

ដែលពិតជាបានរួមដំណេកនៅថ្ងៃរៀបការ ដោយមាន ឬគ្មានការណែនាំពីអាជ្ញាធរមូលដ្ឋានរបស់ពួកគេ។

[2437]មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ១៤ មុនម៉ោង 09.48.28៖ "មានឈ្លបគេមកតាមនៅពីក្រោម ខ្លាច ដូចថាយើងមកអ៊ីចឹង យើងធ្វើមាន់ធ្វើអី យើងចិញ្ចឹមមាន់តាមផ្ទះ យើងសែនយើងអី", ប្រាក់ ឡឿន ប្រតិចារឹក ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ **ឯកសារ E1/361.1** ទំព័រ ៨០ ប្រហែលម៉ោង [១៥.៥៨.៥៥], ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ៧៤ ប្រហែលម៉ោង [១៥.២៤.១៤], 2-TCCP-232 : ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/464.1** ទំព័រ ២៣ មុនម៉ោង [១០.៥១.០៨]។

[2438]រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/262.1** ទំព័រ ៥០ ប្រហែលម៉ោង [១៣.៥៥.៥៨], ឯក ហឿន ប្រតិចារឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/298.1** ទំព័រ ៧៩ ប្រហែលម៉ោង [១៦.០២.១៩], សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ **ឯកសារ E1/412.1** ទំព័រ ៤ ប្រហែលម៉ោង [០៩.១២.៤៨], ភ្មៅ យ៉ាវ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/264.1** ទំព័រ ២៩ ប្រហែលម៉ោង [១១.០៤.៣៧] ទំព័រ ៤៩ ប្រហែលម៉ោង [១៤.១៣.៥៤]៖ "សៈ លោកសាក្សី តើត្រឹមត្រូវទេដែលថា លោករៀបរាប់ប្រហែលវាគឺជាវិធានបំភ័យឱ្យខ្លាចជាទូទៅ តែតាមការពិតថាមិនមានអ្នកណាម្នាក់ត្រូវបានគេបញ្ជូនទៅមន្ទីរអប់រំ ឬក៏ត្រូវក្រាំងតាចាន់ ដោយសារតែប្រព្រឹត្តខុស ដូចជាលួចដូង ឬក៏មិនរួមដំណេកក្រោយរៀបការនោះទេ។ តើបើខ្ញុំនិយាយថាអ៊ីចឹង វាត្រឹមត្រូវដែរឬអត់? ឆៈ បាទជាការត្រឹមត្រូវ លោកប្រធាន បាទ", 2-TCCP-274 : ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ៧ ប្រហែលម៉ោង [០៩.១៨.៤០]៖ "ចាស ចុងក្រោយហ្នឹងបានរួមដំណេក បើសិនជាយើងមិនរួម ខ្លាចគេយកយើងទៅធ្វើបាប ព្រោះគេមានមកហ្នឹងមានគ្នាប្រាំពីរ ឬប្រាំបីនាក់មកយាមកាមជុំវិញហ្នឹង។ [...] កន្លែងហ្នឹងគេមកធ្វើការនៅជុំអង្គភាពហ្នឹងផង ហើយដល់ពេលយប់ឡើង [...] មកមើល តើរួមដំណេកឬអត់ បើសិនជាអត់មានរួមដំណេកទេ គេអាចមានវិធានការផ្សេងទៀង"។ ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា

អះអាងជាលើកទីមួយនៅក្នុងសវនាការ ប្ដី-ប្រពន្ធ ដែលមិនចុះសម្រុងនឹងគ្នា ត្រូវបានឈ្លបនាំយកទៅ។ ការដាក់បញ្ចូលភ័ស្តុតាងយឺតពេលបែបនេះដោយដើមបណ្តឹងរដ្ឋប្បវេណី បង្កឱ្យមានមន្ទិលសង្ស័យទៅលើភាពស្មោះត្រង់ និងភាពឱកាសនិយមនៃសក្ខីកម្មរបស់គាត់[2439]។

២៣៩១. លើសពីនេះទៅទៀត សាក្សីភាគច្រើនមិនបែងចែកភាពខុសគ្នារវាងការឃ្លាំមើលការរួមដំណេក និងការឃាមជាទូទៅក្នុងមូលដ្ឋាននោះទេ។ យ៉ាងណាមិញ សាក្សី សយ ណារឿន បានឆ្លើយថាគាត់បានឃើញឈ្លបអង្គុយក្រោមផ្ទះជិតខាង នៅចម្ងាយប្រមាណ ៥០ ម៉ែត្រ និងបានទាញការសន្និដ្ឋានថា ប្ដី-ប្រពន្ធកំពុងត្រូវបានគេឃ្លាំមើល[2440]។ នេះគឺជាការសន្និដ្ឋានជាបុគ្គល គ្មានតម្លៃជាភ័ស្តុតាងជាពិសេស បើធៀបនឹងសក្ខីកម្មរបស់កម្មាភិបាល។

## 2.គ. <u>សក្ខីកម្មអំពីអវត្តមាននៃការឃ្លាំមើល ឬអវត្តមាននៃការណែនាំឱ្យឃ្លាំមើល</u>

២៣៩២. សក្ខីកម្ម ដូចបានបញ្ជាក់ខាងលើ ផ្ទុយនឹងសក្ខីកម្មផ្សេងទៀតដែលបង្ហាញថាគ្មានការឃ្លាំមើល និងជាពិសេស គ្មានសេចក្តីណែនាំឱ្យឃ្លាំមើល នោះឡើយ ឧទាហរណ៍ សក្ខីកម្មរបស់កម្មាភិបាលជា

---

ឆ្នាំ ២០១៦ **ឯកសារ E1/466.1** ទំព័រ ៥៧-៥៨ ប្រហែលម៉ោង [១៤.០៥.៣០]៖ "អត់មានបានរួមដំណេកជាមួយប្ដីរបស់ខ្ញុំទេ ព្រោះបានអី ខាងណាខ្លាចឈ្លប ខ្លួនខ្ញុំផ្ទាល់ ណាខ្លាចប្ដី មួយទៀតខ្លាចឈ្លបទៀត ម្លោះហើយសុខចិត្តនាំគ្នាសម្ងំ អត់ហ៊ានមាត់ ហ៊ានកអីទាំងអស់", <u>គុល ណែម</u> ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/488.1** ទំព័រ ៧៧ ប្រហែលម៉ោង [១៥.០៨.៥៦]៖ "បើមិនរួមម៉េច បើថាវា ដូចថាគេការឱ្យហើយ យើងខ្លាចគេទាំងសងខាង។ យើងមានហ៊ានជាមួយគេណាជំនាន់ហ្នឹង វានៅលើគេទាំងអស់។ ដូច្នេះយើងត្រូវគោរពគេ។ បើយើងមិនគោរព មានតែស្លាប់ ឬមួយយ៉ាងម៉េច គេធ្វើទារុណកម្មយើង"។

[2439]<u>សយ ណារឿន</u> ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៣០ ប្រហែលម៉ោង [១០.៤៨.២៥]៖ "[...] ស្រាប់តែក្រឡេកទៅឃើញ [...] កងឈ្លប [...] ជូនមួយគូហ្នឹងចេញពីរោងបាត់។ [...] បានឃើញឈ្លបត្រឡប់មកវិញ តែអត់ឃើញអ្នកដែលគូប្ដេជ្ញាកាលពីក្បាលព្រលប់ហ្នឹងទេ។ នាងខ្ញុំគិតសន្និដ្ឋានថា អ្នកគូនោះប្រហែលជាមិនចុះសម្រុងគ្នា [...]" ទំព័រ ៤៣ មុនម៉ោង [១១.៣១.២៥] "[...] ខ្ញុំមិនអាចចាំនូវភាពទាំងអស់នោះគ្រប់២៤ម៉ោងទេ។ ខ្ញុំអាចមានការភ្លេចភ្លាំង ដល់ក្រោយមកទៀត ខ្ញុំនឹកឃើញ ដល់ពេលខ្ញុំចេះតែរំឭកទៅ ខ្ញុំអាចនឹកឃើញពីគេដើរឃាមល្បាត ពីគេនាំមនុស្សទៅ"។

[2440]<u>2-TCCP-274</u> : ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ៤៩ ប្រហែលម៉ោង [១៣.៤៥.០៣], <u>សយ ណារឿន</u> ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ២៩-៣០ ប្រហែលម៉ោង [១០.៤៤.៥៧]។

ច្រើនមកពីមូលដ្ឋានផ្សេងៗ។ ជាក់ស្តែង សៅ ហ៊ាន ឆ្លើយថា គាត់ "មិនធ្លាប់ឃើញហេតុការណ៍បែបនេះទេ" ក៏ដូចជា សាក្សី ធុច ស៊ីថន, 2-TCW-1005 និង 2-TCW-1002 ដែរ[2441]។

២៣៩៣. សាក្សី ជួន ធី បានឆ្លើយថា គ្មានការឃ្លាំមើលបែបនេះទេ ហើយគាត់បានបន្ថែមថា គាត់មិនធ្លាប់ឮថ្នាក់លើចេញសេចក្តីណែនាំក្នុងន័យបែបនេះទេ[2442]។ សាក្សី ផាន់ ហ៊ីម និង ពេជ្រ ជឹម បានអះអាងថា "គ្មានការឃ្លាំមើលទេ"។ យាន លន់ និង កង អ៊ុត ក៏បានផ្តល់សក្ខីកម្មក្នុងន័យនេះដែរ[2443]។

២៣៩៤. ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង បាននិយាយស៊ីសង្វាក់គ្នា ពេលគាត់ឆ្លើយថា "អ្នកនៅអង្គភាពជាមួយគ្នាហ្នឹងជាអ្នកតាមដាន។ [...] អ្នកទទួលបន្ទុកតាមដានមកពីអង្គភាពជាមួយគ្នា"[2444]។ ទោះបីជាការឃ្លាំមើលត្រូវបានអនុវត្តក៏ដោយ ក៏មេផ្ទាល់របស់សាមីខ្លួនជាអ្នកធ្វើដោយខ្លួនឯង។

---

[2441] សៅ ហ៊ាន ប្រតិចារឹក ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/265.1** ទំព័រ ៣៤ ប្រហែលម៉ោង [១១.១៥.០៦], ធុច ស៊ីថន ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/500.1** ទំព័រ ៥៧ ប្រហែលម៉ោង [១៥.០៤.២៨]៖ "អត់មាននិយាយផងបញ្ហាហ្នឹង។ គេអត់ នៅក្នុងជំនាន់នោះគេមិនដែលនិយាយពីរឿងរបៀបអ៊ីចឹងៗ គេអត់និយាយទេ គឺជាបញ្ហា - បារាំងហៅថា "*ឡាម៉ូរ៉ាល់លីតេ*" ខ្មែរយើងដឹងថា គេអត់និយាយទេ ពីរឿងការរួមដំណេក ពីរឿងស្អីៗហ្នឹង គេអត់មាននិយាយទេ", 2-TCW-1005 : ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ **ឯកសារ E1/449.1** ទំព័រ ២៦ ប្រហែលម៉ោង [១០.១២.១៥]៖ "ព្រោះអត់មានទេ បើថារដ្ឋ -- អង្គការការឲ្យហើយ ដូចអត់មានតាមដានអីទៀតទេ [...] អាហ្នឹង បើសិនណាជានៅអង្គភាពខ្ញុំហ្នឹង អត់អីទេ"។ 2-TCW-1002 : ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/469.1** ទំព័រ ៥៨ ប្រហែលម៉ោង [១៤.១៨.៣០]។

[2442] ជួន ធី ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ៥ ប្រហែលម៉ោង [០៩.១៣.៤៦]៖ "ពេលដែលរៀបចំហើយ មិនឲ្យទៅតាមដានរឿងដំណេកអីជាមួយគ្នា គឺអត់ដែលឮ"។ "ខ្ញុំអត់ដែលឮថ្នាក់ដឹកនាំខាងលើប្រាប់ឲ្យតាមដានរឿងការរស់នៅអី ផ្សំដំណេកជាមួយគ្នា មិនផ្សំដំណេក គឺអត់ដែលមានទេ។ អានេះបើខាងមូលដ្ឋាន ខ្ញុំក្តាប់មិនបានទេ [...]"។

[2443] ផាន់ ហ៊ីម ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/467.1** ទំព័រ ៧៩ ប្រហែលម៉ោង [១៥.០៨.៤៨]៖ "ខ្ញុំអត់ដែលឮផង", ពេជ្រ ជឹម ប្រតិចារឹក ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ **ឯកសារ E1/291.1** ទំព័រ ៧ ប្រហែលម៉ោង [០៩.២៥.៤០]៖ "អត់ដែលបានដឹងច្បាស់លាស់ទេ ប៉ុន្តែក្រោយៗមក ចេះតែឮហុយៗ ដូចគាត់ថាអ៊ីចឹង ថាឈ្លបលបស្តាប់ លបស្អី។ ប៉ុន្តែអារឿងហ្នឹង តាមខ្ញុំយល់ មិនមែនមានកងឈ្លបឯណាមកពិនិត្យអ្នកការថ្មីម៉េច អត់ទេ", យាន លន់ ប្រតិចារឹក ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/317.1** ទំព័រ ៥៨ ប្រហែលម៉ោង [១៤.៤៣.០៩]៖ "បាទ គ្មានទេបាទ និយាយរឿងអ៊ីចឹងៗគឺវាគ្មាន។ គ្មានអស់លោកណាទៅតាមរឿងអ៊ីចឹងៗ បាទ វាដូចជាមិនសមនឹងលើកឡើងសោះ បាទ", កង អ៊ុត ប្រតិចារឹក ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/322.1** ទំព័រ ២៩ ប្រហែលម៉ោង [១១.១៤.២៤]៖ "ចាស ខ្ញុំអត់ដឹងទេ អត់ៗមាន ខ្ញុំអត់មានទេ"។

[2444] ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/476.1** ទំព័រ ៤៨ ប្រហែលម៉ោង [១៣.៥៤.២៥]។

២៣៩៥. ឌុច បានចាត់ទុកកម្មាភិបាលដែលតាមដានការរួមដំណេកជា "កម្មាភិបាលខូច" ដោយថែមទាំងបានផ្ដល់ឧទាហរណ៍អំពីកម្មាភិបាលម្នាក់ដែលត្រូវបានដាក់ "ទណ្ឌកម្ម ដោយសារបានធ្វើបែបនេះ" ក្រោយពីបានសុំទោសប្ដី-ប្រពន្ធនោះ"[2445]។ ជាក់ស្ដែង គាត់មិនត្រឹមតែបញ្ជាក់អះអាងអំពីចម្លើយរបស់សាក្សី ជួន ធី អំពីអវត្តមាននៃសេចក្ដីណែនាំឱ្យឃ្លាំមើលប្ដី-ប្រពន្ធ ប៉ុណ្ណោះទេ គឺថែមទាំងបាននិយាយអំពីការដាក់ទណ្ឌកម្មចំពោះអាកប្បកិរិយាណា ដែលត្រូវគេវិនិច្ឆ័យថាផ្ទុយនឹងគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា។

## 3. ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានលើកឡើងអំពីការរំលោភសេពសន្ថវៈក្នុងចំណោងអាពាហ៍ពិពាហ៍

២៣៩៦. ក្រុមមេធាវីការពារក្ដីសូមរំឭកថា មានតែការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះដែលត្រូវពិនិត្យមើលដោយអង្គជំនុំជម្រះ។ 2-TCCP-274, មុំ វុន, ព្រាប សុឃឿន និង ប៉ែន សុចាន់ ជាដើមបណ្ដឹងរដ្ឋប្បវេណីបួនរូប ដែលបានលើកឡើងអំពីអង្គហេតុនៃការរំលោភសេពសន្ថវៈ[2446]។ សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបីរូប ក្នុងចំណោមនោះ ចោទជាបញ្ហានៃភាពអាចជឿជាក់បាន ដោយសារហេតុផលមួយចំនួន។

### 3.ក. រឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-274

២៣៩៧. ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៤ ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-274 បានដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់[2447]។ នៅក្នុងឯកសារទាំងនេះ គាត់មិនធ្លាប់បានលើកឡើងអំពីការរំលោភសេពសន្ថវៈបន្តិចណាទាល់តែសោះ។ គាត់ទើបតែបង្ហាញព័ត៌មាននេះ នៅថ្ងៃមកផ្ដល់សក្ខីកម្មជាលើកដំបូង នៅចំពោះមុខអង្គជំនុំជម្រះ ដោយនិយាយអំពី

---

[2445] កំណត់ហេតុស្ដាប់ចម្លើយ កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៩ **ឯកសារ E3/5789** ERN 00410173។

[2446] ដូចបាននិយាយពីខាងលើ សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-274 និង មុំ វុន នឹងមិនត្រូវបានពិនិត្យទាក់ទងនឹងអង្គហេតុនៃការរំលោភសេពសន្ថវៈក្រៅអាពាហ៍ពិពាហ៍នោះទេ។ សូមមើលផ្នែកខាងលើ កថាខណ្ឌ ២៣៣៣-២៣៣៤។

[2447] ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៩ **ឯកសារ E3/6011**, ទម្រង់បែបបទព័ត៌មានបន្ថែម ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៤ **ឯកសារ E3/6011a**។

ការរំលោភសេពសន្ថវៈក្រៅវិសាលភាព មុននឹងអះអាងថាប្ដីគាត់ក៏បានរំលោភគាត់ផងដែរ។ គាត់ក៏បានពន្យល់ផងដែរថា គាត់មិនបានដាក់បញ្ចូលចំណុចនេះនៅក្នុងឯកសារពីមុន ពីព្រោះ "គាត់ទើបតែនឹកឃើញនៅពេលនោះ"[2448]។ នៅពេលសួរដេញដោលអំពីពេលនៃការរំលោភនេះ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់ព័ត៌មានផ្ទុយគ្នាជាច្រើន គឺគាត់មិនអាចពន្យល់បានទេ ពីព្រោះគាត់បានឆ្លើយថា គាត់បានរួមដំណេកជាមួយប្ដី ប្រហែល ១០ ថ្ងៃ ទៅ ១៥ ថ្ងៃ ក្រោយពេលរៀបការ រួច "មួយខែទៅពីរខែ ក្រោយមក" ខណៈដែលនៅក្នុងឯកសារ គាត់និយាយថាមួយឆ្នាំក្រោយពេលរៀបការទើបគាត់ព្រមរួមដំណេកជាមួយប្ដី[2449]។ ក្រៅពីភាពមិនសមទំនងនៃអង្គហេតុក្រៅវិសាលភាព នៅនាទីចុងក្រោយ ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចពន្យល់អំពីភាពមិនស៊ីសង្វាក់គ្នាខ្លាំងនៅក្នុងចម្លើយរបស់គាត់។ ភាពផ្ទុយគ្នាជាច្រើន និងភាពយឺតពេលនៃការបង្ហាញព័ត៌មាននេះ ធ្វើឱ្យសក្ខីកម្មរបស់គាត់មិនអាចជឿជាក់បានទេ។

### 3.២. រឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន

២៣៩៨. ទន្ទឹមនឹងនេះ ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បានរៀបរាប់អំពីការរំលោភក្នុងចំណងអាពាហ៍ពិពាហ៍ដែលប្ដីគាត់មកប្រព្រឹត្តមកលើគាត់ តាមបញ្ជា និងនៅចំពោះមុខឈ្លប[2450]។ ជាទូទៅ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មពោរពេញដោយភាពផ្ទុយគ្នា ធ្វើឱ្យរឿងរ៉ាវរបស់គាត់មិនសូវមានភាពអាចជឿជាក់បាន។ ជាក់ស្ដែង ក្រោយពីរៀបរាប់អំពីការរៀបការលើកទីមួយគួរឱ្យខ្លាច គាត់បែរជាមានសេចក្ដីស្នេហាផ្អែមល្ហែម ប៉ុន្មាននាទីក្រោយមក។ លើសពីនេះទៅទៀត លោកស្រី មុំ វុន បានរៀបរាប់អំពីការបាត់ខ្លួនប្ដីគាត់ នៅឆ្នាំ ១៩៧៥ ក្រោយពេលគេហៅទៅរៀនសូត្រ ខណៈដែល

---

[2448] ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ១៤ ក្រោយម៉ោង [០៩.៣៧.០៥] ទំព័រ ៥ ប្រហែលម៉ោង [០៩.១៣.១២] ទំព័រ ១៤ ប្រហែលម៉ោង [០៩.៣៧.០៥]។

[2449] ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/462.1** ទំព័រ ៣៨-៣៩ ចន្លោះម៉ោង [១១.១៩.២០] និង [១១.២៤.៣៨]។

[2450] មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/475.1** ទំព័រ ៤៥-៤៦ ប្រហែលម៉ោង [១៣.៤៣.៤៦] ទំព័រ ៨២-៨៤ ចន្លោះម៉ោង [១៥.៥៥.៣៨] និង [១៦.០១.៣៣]។

នៅក្នុងឯកសារ គាត់មិនបានលើកឡើងអំពីការបាត់ខ្លួនប្តី នៅឆ្នាំ ១៩៧៥ នោះទេ ដោយបញ្ជាក់ថា ប្តីគាត់ជាអ្នកឡើងត្នោត នៅឆ្នាំ ១៩៧៧[2451]។

### 3.គ. រឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន

២៣៩៩. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ក៏បានឆ្លើយថា គាត់ត្រូវបានប្តីរំលោភផងដែរ។ រឿងរ៉ាវរបស់គាត់មានភាពមិនស៊ីសង្វាក់គ្នា ហើយការពន្យល់អំពីបញ្ហានេះមិនគួរជាទីពេញចិត្តនោះទេ៖ គាត់មិនធ្លាប់និយាយថា គាត់ត្រូវបានប្តីរំលោភទាល់តែសោះ នៅក្នុងឯកសាររបស់គាត់។ ផ្ទុយទៅវិញ គាត់ថែមទាំងបានរៀបរាប់ថាប្តីគាត់ជាមនុស្សស្លូតទៀតផង។ ប៉ុន្តែ គាត់បានសម្រេចចិត្តយ៉ាងទាន់ហន់ក្នុងការបន្ថែមអង្គហេតុនេះនៅក្នុងទម្រង់បែបបទព័ត៌មានបន្ថែមនៅឆ្នាំ ២០១៤ និងនៅក្នុងសវនាការ។ ទោះបីជាគាត់បានពន្យល់ថា ពីមុន គាត់ខ្មាសអៀនមិនហ៊ាននិយាយអំពីការរំលោភក៏ដោយ ក៏គ្មាននរណាបង្ខំឱ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះរៀបរាប់ថាប្តីគាត់ជាមនុស្សស្លូតដែរ[2452]។ លើសពីនេះទៅទៀត គាត់បានឆ្លើយថា គាត់ត្រូវគេជំរុញឱ្យនិយាយអំពីការរំលោភនេះ កាលណាខ្មាស "គឺមិនមានភ័ស្តុតាងជាក់លាក់ទេ"[2453]។ ដូច្នេះ សក្ខីកម្មរបស់គាត់ត្រូវបានធ្វើឡើង សម្រាប់តម្រូវការនៃរឿងក្តី។ ភាពមិនស៊ីសង្វាក់គ្នានៃរឿងរ៉ាវរបស់គាត់ធ្វើឱ្យសក្ខីកម្មរបស់គាត់មានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។

## ផ្នែកទី ៤. ការកំណត់ប្រភេទបទល្មើស

### ១. "និយមន័យ" នៃអំពើអមនុស្សធម៌ផ្សេងទៀត (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)

---

[2451] ប្រតិចារិក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ** E1/475.1 ទំព័រ ៤៥-៤៦ ប្រហែលម៉ោង [១៣.៤៣.៤៦] ទំព័រ ៦២-៦៣ ប្រហែលម៉ោង [១៤.៣៨.២២] ទំព័រ ៨២-៨៤ចន្លោះម៉ោង [១៥.៥៥.៣៨] និង [១៦.០១.៣៣], ប្រតិចារិក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ** E1/477.1 ទំព័រ ៧-៩ចន្លោះម៉ោង [០៩.១៨.៥៩] និង [០៩.២៧.៥៣]។

[2452] ប្រតិចារិក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ** E1/488.1 ទំព័រ ៤២-៤៥ ចន្លោះម៉ោង [១១.២៣.១៨] និង [១១.៣៣.១២] ទំព័រ ៤៩-៥១ចន្លោះម៉ោង [១១.៤១.២៨] និង [១១.៤៧.០៦]។

[2453] ប្រតិចារិក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ** E1/488.1 ទំព័រ ៤៥ ប្រហែលម៉ោង [១១.៣១.១៧]។

២៤០០. មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានរៀបរាប់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា និងបញ្ចប់ដោយ "អំពើអមនុស្សធម៌ផ្សេងទៀត"។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា យោងតាមគោលការណ៍នីត្យានុកូលភាព ការរំលោភសេពសន្ថវៈ ដែលជាបទឧក្រិដ្ឋមួយដាច់ដោយឡែក នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់ជាតិ នៅសម័យកើតអង្គហេតុនោះទេ ហេតុដូច្នេះ មិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានទេ[2454]។ ចំពោះប្រភេទបន្ថែមនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" អង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ប្រសិនបើបកស្រាយ និងអនុវត្ត ក្នុងគោលបំណងដើម្បីរឹតត្បិតវិសាលភាពនៃប្រភេទមិនជាក់លាក់នេះ ប្រភេទបន្ថែមនេះស្របតាមគោលការណ៍នីត្យានុកូលភាព[2455]។

២៤០១. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ធាតុផ្សំជាក់លាក់ ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្មនេះ គឺ អំពើសកម្ម ឬអកម្មៈ

- ដែលមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា ទៅនឹងអំពើជាក់លាក់ដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ
- ដែលបណ្តាលឱ្យមានការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរ លើរូបកាយ ឬផ្លូវចិត្ត ឬជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ
- ដែលបានប្រព្រឹត្តឡើងដោយចេតនា ដើម្បីបង្កឱ្យមានការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរ លើរូបកាយ ឬផ្លូវចិត្ត ឬជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[2456]។

២៤០២. ទោះបីជាពុំមានល័ក្ខខ័ណ្ឌតម្រូវថា អំពើប្រព្រឹត្តជាក់លាក់ត្រូវតែជាបទល្មើសច្បាស់លាស់ ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ក៏ដោយ ក៏ចាំបាច់ត្រូវកំណត់អត្តសញ្ញាណនៃទំនាក់ទំនងពិតប្រាកដរវាងសិទ្ធិ

---

[2454] សាលដីកា ឌុច ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៧៤-១៨៣។

[2455] សាលដីកា ០០២/០១ កថាខណ្ឌ ៥៧៨។

[2456] សាលដីកា ០០២/០១ កថាខណ្ឌ ៥៨០។

និងការហាមឃាត់ ដែលមានចែងនៅក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្ស ជាធរមាននៅសម័យកើតអង្គហេតុដែលនាំឱ្យមានការចោទប្រកាន់អំពី "អំពើអមនុស្សធម៌ផ្សេងទៀត"[2457]។

២៤០៣. ការលេចឡើងបន្តបន្ទាប់នូវបទដ្ឋានថ្មីស្តីពីសិទ្ធិមនុស្សជាក់លាក់បន្ថែមទៀត រួមទាំងបទដ្ឋាននៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដូចជា បទដ្ឋានប្រឆាំងនឹងការផ្លាស់ទីលំនៅដោយបង្ខំ ឬការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ អាចៈ ១) ជាការអះអាងបន្ថែមលើអនីត្យានុកូលភាពអន្តរជាតិស្តីពីអំពើប្រព្រឹត្តដែលបានចោទប្រកាន់ ២) ត្រូវបានប្រើប្រាស់ជារង្វាស់សម្រាប់វាយតម្លៃលើបញ្ហាថាតើអំពើប្រព្រឹត្តនោះឈានដល់កម្រិតធ្ងន់ធ្ងរដែលតម្រូវ ដែរឬយ៉ាងណា។ ទោះជាយ៉ាងណាក្តី អត្ថិភាពនៃបទដ្ឋានជាក់លាក់ជាងពុំអាចកំណត់ថាតើបទចោទនោះស្របតាមគោលការណ៍នីត្យានុកូលភាព ដែរឬយ៉ាងណានោះឡើយ[2458]។

២៤០៤. ដូចការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំដែរ ពេលឧក្រិដ្ឋកម្មត្រូវបានកំណត់ជាប្រភេទដាច់ដោយឡែក នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ការពិនិត្យមើលធាតុផ្សំនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ត្រូវតែជាការពិនិត្យមើលធាតុផ្សំប្រភេទ "អំពើអមនុស្សធម៌ផ្សេងទៀត" នោះតែម្តង គឺមិនមែនជាការពិនិត្យមើលធាតុផ្សំនៃឧក្រិដ្ឋកម្មជាក់លាក់នៅពេលក្រោយនោះទេ[2459]។

២៤០៥. បើតាមអង្គជំនុំជម្រះតុលាការកំពូល គោលការណ៍នីត្យានុកូលភាពត្រូវបានគោរព ប្រសិនបើអំពើប្រព្រឹត្តជាក់លាក់ ដែលត្រូវបានរកឃើញថាជា "អំពើអមនុស្សធម៌ផ្សេងទៀត" រំលោភបំពានលើសិទ្ធិជាសារវ័ន្តរបស់ជនរងគ្រោះ និងមានភាពធ្ងន់ធ្ងរប្រហែលគ្នានឹងអំពើជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ចំណុចនេះតម្រូវឱ្យមានការពិចារណា ដោយផ្អែកតាមករណីជាក់ស្តែងនីមួយៗ អំពីផលប៉ះពាល់នៃអំពើប្រព្រឹត្តលើជនរងគ្រោះ និងថាតើអំពើនេះអាចប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរឬយ៉ាងណា[2460]។

---

[2457] សាលដីកា ០០២/០១ កថាខណ្ឌ ៥៨៤។

[2458] សាលដីកា ០០២/០១ កថាខណ្ឌ ៥៨៥។

[2459] សាលដីកា ០០២/០១ កថាខណ្ឌ ៥៨៩។

[2460] សាលដីកា ០០២/០១ កថាខណ្ឌ ៥៨៦។

២៤០៦. ដូច្នេះ ចៅក្រមត្រូវមានភាពម៉ត់ចត់ខ្លាំងក្នុងការពិនិត្យមើលប្រភេទបន្ថែមនេះ ដោយបកស្រាយ និង អនុវត្តយ៉ាងរឹតត្បិតបំផុត។ នៅសម័យកើតអង្គហេតុដែលនាំឱ្យមានការចោទប្រកាន់អំពី "អំពើអមនុស្សធម៌ផ្សេងទៀត" ក្រោយសង្គ្រាមលោកលើកទី ២ ក៏ដូចជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការបដិសេធសិទ្ធិមនុស្សមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។ នៅសម័យនោះ ការបដិសេធសិទ្ធិមនុស្សមិនមានលក្ខណៈ ឬកម្រិតធ្ងន់ធ្ងរដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នោះឡើយ។

២៤០៧. តបទៅនឹងសំណួរសួរថាតើសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសដែរឬទេ ដោយកំណត់ថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅក្នុងបរិបទនេះ ស្ថិតក្នុងនិយមន័យនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា នេះជាបញ្ហាអង្គច្បាប់ និងអង្គហេតុចម្រុះគ្នា ដែលត្រូវដោះស្រាយ ក្នុងពេលជំនុំជម្រះក្តី[2461]។

## ២. ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ

២៤០៨. យោងតាមកាលៈទេសៈអង្គហេតុ និងអង្គច្បាប់នៃរឿងក្តី នៅសម័យនោះ អំពើដែលចោទប្រកាន់ទៅលើជនជាប់ចោទ ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ មិនមែនជាអង្គហេតុស្ថិតក្នុង "និយមន័យ" នៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នោះឡើយ។ ជាក់ស្តែង អំពើនេះមិនមានលក្ខណៈ ឬកម្រិតធ្ងន់ធ្ងរដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ (ក) ដូចបានបញ្ជាក់ដោយផលប៉ះពាល់ទៅលើជនរងគ្រោះ (ខ)។ម្យ៉ាងវិញទៀត អំពើមិនត្រូវបានប្រព្រឹត្តដោយចេតនា ដើម្បីបង្កការឈឺចាប់ធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬប៉ះពាល់ធ្ងន់ធ្ងរដល់បូរណភាពរាងកាយ ឬផ្លូវចិត្ត ឬប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូរជាមនុស្សឡើយ (គ)។

---

[2461]សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ **ឯកសារ D427/1/30** កថាខណ្ឌ ៣៩៧, អនុស្សរណៈ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ **ឯកសារ E306** កថាខណ្ឌ ២។

## ក. លក្ខណៈ និងកម្រិតធ្ងន់ធ្ងរ

២៤០៩. ការរៀបអាពាហ៍ពិពាហ៍ "ដែលត្រូវបានដាក់ជាបទបញ្ជា" នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ទំនាក់ទំនងផ្លូវភេទរវាងប្ដី-ប្រពន្ធ មិនមានលក្ខណៈ និងកម្រិតធ្ងន់ធ្ងរ ដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ដែលមាននៅសម័យនោះឡើយ។

២៤១០. ក្នុងសំណុំរឿង ០០២/០១ ពេលអង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ផ្អែកលើអង្គហេតុ ដែលត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យ ការជម្លៀសប្រជាជនត្រូវចាត់ទុកជាអំពើអមនុស្សធម៌ផ្សេងទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2462] អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា ការដែលការជម្លៀសមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានឹងបទឧក្រិដ្ឋជាក់លាក់ដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញតាមរយៈអង្គហេតុដែលថា មានបុគ្គលមួយចំនួនធំបានទទួលរងនូវផលប៉ះពាល់ដោយសារការជម្លៀសនេះ និងថាអ្នកខ្លះត្រូវបានសម្លាប់ ឬបានស្លាប់ដោយសារល័ក្ខខ័ណ្ឌនៃការជម្លៀសនេះ[2463]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាផងដែរថា អំពើប្រព្រឹត្តនេះមានលក្ខណៈ "ប្រហាក់ប្រហែល" គ្នានឹងអំពើល្មើសនៃបទឧក្រិដ្ឋជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពោលគឺ ការនិរទេស[2464]។

២៤១១. ក្នុងរឿងក្ដីនេះ អំពើប្រព្រឹត្តនេះមិនមានលក្ខណៈ "ប្រហាក់ប្រហែល" គ្នានឹងអំពើល្មើសនៃបទឧក្រិដ្ឋជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នោះឡើយ។ យើងមិនអាចកំណត់អត្តសញ្ញាណនៃទំនាក់ទំនងពិតប្រាកដរវាងសិទ្ធិ និងការហាមឃាត់ ដែលមានចែងនៅក្នុងលិខិតុបករណ៍ស្ដីពីសិទ្ធិមនុស្ស ជាធរមាននៅសម័យកើតអង្គហេតុ នោះឡើយ (១)។ ក្រៅពីនេះទៀត ខុសពីការជម្លៀសដោយបង្ខំ ដែលត្រូវបានកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ

[2462]សាលដីកា ០០២/០១ កថាខណ្ឌ ៦៥៥-៦៦០។

[2463]សាលដីកា ០០២/០១ កថាខណ្ឌ ៦៥៦ និង ៦៥៩។

[2464]សាលដីកា ០០២/០១ កថាខណ្ឌ ៦៥៦។

ការចាប់ផ្តើមលេចឡើងនូវបទដ្ឋានជាក់លាក់ជាងមុននៅពេលក្រោយ បញ្ជាក់អំពីអវត្តមាននៃអនីត្យានុកូលភាពអន្តរជាតិនៃអំពើប្រព្រឹត្ត និងអាចឱ្យកំណត់ថាអំពើនេះមិនឈានដល់កម្រិតធ្ងន់ធ្ងរដែលតម្រូវឡើយ (២)។

## 1. អវត្តមាននូវចំនាក់ចំនងពិតប្រាកដរវាងសិទ្ធិ និងការហាមឃាត់ ដែលមានចែងនៅក្នុងអត្ថបទច្បាប់ជាធរមាននៅសម័យនោះ

២៤១២. នៅសម័យកើតអង្គហេតុដែលនាំឱ្យមានការចោទប្រកាន់អំពី "អំពើអមនុស្សធម៌ផ្សេងទៀត" ទោះបីជាសិទ្ធិក្នុងការយល់ព្រមដោយសេរីចំពោះការរៀបអាពាហ៍ពិពាហ៍ ត្រូវបានទទួលស្គាល់ដោយសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨ ក៏ដោយ[2465] ក៏មាត្រា ៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ហាមឃាត់ "គ្រប់ពេលវេលា និងគ្រប់ទីកន្លែង" នូវ៖ "ក) ការប៉ះពាល់ដល់ជីវិត បូរណភាពរាងកាយ ជាពិសេស អំពើមនុស្សឃាតតាមគ្រប់រូបភាព ការធ្វើឱ្យពិការ ការប្រព្រឹត្តសាហាវឃោរឃៅ ការធ្វើទារុណកម្ម និងការបង្ការឈឺចាប់លើរាងកាយ ខ) ការចាប់ជាចំណាប់ខ្មាំង គ) ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ជាពិសេស ការប្រព្រឹត្តិធ្វើឱ្យអាម៉ាស់ និងបន្ទាបបន្ថោក ឃ) ការផ្តន្ទាទោស និងការសម្លាប់ ដោយគ្មានការជំនុំជម្រះជាមុន"[2466]។

២៤១៣. ចាប់តាំងពីក្រោយសង្គ្រាមលោកលើកទី ២ រហូតដល់សម័យកើតអង្គហេតុដែលបានចោទប្រកាន់ ទោះបីជាអនុសញ្ញាអន្តរជាតិផ្សេងទៀតបានទទួលស្គាល់សិទ្ធិ ក្នុងការយល់ព្រមរៀបអាពាហ៍ពិពាហ៍

---

[2465]សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១៦-២ (អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរី និងពេញលេញពីអនាគតប្តីប្រពន្ធ)។ មាត្រា ២ នៃអនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ទាសភាព ទាសពាណិជ្ជកម្ម និងការបង្កើត និងការអនុវត្តដែលមានលក្ខណៈប្រហាក់ប្រហែលនឹងទាសភាព ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៥៦ ពុំបានចែងអំពីសិទ្ធិនេះទេ។ មាត្រា ២ នេះចែងថា ដើម្បីបញ្ឈប់ការអនុវត្តនៃការទទួលបាន ឬការប្រគល់នូវប្រពន្ធ និងការផ្ទេរបន្តនូវស្ត្រីដែលមានប្តីស្លាប់ តាមរយៈការបន្តវេន រដ្ឋភាគីទាំងអស់សន្យាថាត្រូវលើកទឹកចិត្តដល់ការស្វែងរកជំនួយតាមផ្លូវនីតិវិធីដែលអាចឱ្យអនាគតប្តី ឬ ប្រពន្ធអាចសម្តែងការព្រមព្រៀងរៀបការរបស់ពួកគេបានដោយសេរី ហើយរដ្ឋភាគីសន្យាថាត្រូវលើកទឹកចិត្តឱ្យមានការចុះបញ្ជីរៀបអាពាហ៍ពិពាហ៍។

[2466]ក្នុងបុព្វកថានៃមាត្រា ៣ ដែលជាមាត្រារួមនៃអនុសញ្ញាក្រុងហ្សឺណែវ មានការបង្ហាញ "ពីការប្រព្រឹត្តអប្បបរមាបែបលក្ខណៈជាមនុស្ស"។ មាត្រានេះអនុវត្តចំពោះ "អ្នកដែលមិនចូលរួមដោយផ្ទាល់ក្នុងជម្លោះ"។

ដោយសេរី[2467] ក៏ដោយ ក៏មាត្រា ៤ នៃពិធីសារបន្ថែមលើកទី ២ ទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ បានបំពេញបន្ថែម នៅឆ្នាំ ១៩៧៧ នូវការហាមឃាត់នៃមាត្រា ៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវ ជាមួយនឹងទណ្ឌកម្មរួម ភេរវកម្ម ការរំលោភសេពសន្ថវៈ ការបង្ខំឱ្យប្រព្រឹត្តពេស្យាចារ ទាសភាព និងការជួញដូរទាសករ ក៏ដូចជាការឆក់ប្លន់[2468]។

២៤១៤. ដូច្នេះ យើងមិនអាចចាត់ទុកថា ការបដិសេធសិទ្ធិក្នុងការយល់ព្រមរៀបអាពាហ៍ពិពាហ៍ដោយសេរី អាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានឡើយ។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានកំណត់ថាជាបទឧក្រិដ្ឋឡើយ នៅក្នុងច្បាប់កម្ពុជានៅសម័យនោះ និងបច្ចុប្បន្ន ហើយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនធ្លាប់ត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

## 2. <u>ការចាប់ផ្តើមលេចឡើងនូវបទដ្ឋានជាក់លាក់ជាងមុននៅពេលក្រោយ</u>

២៤១៥. បន្ថែមលើអវត្តមាននូវអនីត្យានុកូលភាពជាតិ អវត្តមាននូវអនីត្យានុកូលភាពអន្តរជាតិនៃអំពើប្រព្រឹត្ត និងការមិនឈានដល់កម្រិតធ្ងន់ធ្ងរដែលតម្រូវឱ្យមាន ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបញ្ជាក់ដោយអវត្តមាននៃការលេចឡើងនូវបទដ្ឋានថ្មីៗ និងជាក់លាក់ជាងមុន។

២៤១៦. ខុសពីការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ នៅក្នុងអត្ថបទច្បាប់បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិនានា។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏មិនត្រូវបានដាក់បញ្ចូលក្នុងនិយមន័យ និង

---

[2467] អនុសញ្ញាស្តីពីការព្រមព្រៀងរៀបអាពាហ៍ពិពាហ៍ អាយុតិចបំផុតដែលអាចរៀបការបាន និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៦២, មាត្រា ១ (ប្រទេសកម្ពុជាពុំបានចូលរួមក្នុងអនុសញ្ញានេះទេ) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ២៣-២ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, ១៦ ធ្នូ ១៩៦៦, មាត្រា ១០-១ (ប្រទេសកម្ពុជាទើបតែចូលរួមក្នុងកតិកាសញ្ញាទាំងពីរនេះនៅឆ្នាំ ១៩៩២)។

[2468] ពិធីសារបន្ថែមលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ស្តីពីការការពារជនរងគ្រោះដោយសារជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ (ពិធីសារបន្ថែម ២) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៧៧ មាត្រា ៤ "ការធានាជាមូលដ្ឋាន"។

បញ្ជីនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្ស ដូចមានចែងនៅក្នុងសេចក្តីព្រាងអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ឆ្នាំ ២០១៥[2469]។

២៤១៧. ទើបតែនៅឆ្នាំ ២០០៨ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានចាត់ទុកជាលើកដំបូងជា "អំពើអមនុស្សធម៌ផ្សេងទៀត" ដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសម្រាប់សេរ៉ាឡេអូន នៅក្នុងរឿងក្តី Brima ដែលបានជ្រើសយកការពិចារណាទៅលើមធ្យោបាយដែលបានលើកឡើង ដោយសារតែវាមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍនីតិព្រហ្មទណ្ឌអន្តរជាតិ[2470]។

២៤១៨. ទោះបីជាមានភាពថ្មីស្រឡាង និងមានការចោទប្រកាន់ពីតុលាការព្រហ្មទណ្ឌអន្តរជាតិទៅលើជនម្នាក់ពីបទរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងលក្ខណៈជា "អំពើអមនុស្សធម៌ផ្សេងទៀត" ជាលើកដំបូងនៅឆ្នាំ ២០១៦ ក៏ដោយ[2471] ក៏នោះគឺជាស្ថានភាពដែលស្ត្រីត្រូវបានចាប់ពង្រត់ និងធ្វើឱ្យទៅជាទាសករ ដូចបានលើកឡើងក្នុងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី តាមការអនុញ្ញាតរបស់អង្គជំនុំជម្រះ[2472]។ ម្យ៉ាងទៀត ម្ចាស់សារណានេះបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅសេរ៉ាឡេអូន និងនៅរដ្ឋអាហ្វ្រិកផ្សេងទៀត ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មធ្វើឱ្យទៅជាទាសករ ដែលមានបង្អែក ក្នុងការសិក្សាស្រាវជ្រាវចំពោះ "ស្ត្រីរស់រានមានជីវិតពីការចាប់ពង្រត់ និងទាសភាព" ក្នុងអំឡុងសង្គ្រាមនៅសេរ៉ាឡេអូន ដែលត្រូវគេចាប់ខ្លួនអស់រយៈពេលចាប់ពី ២ ខែ ដល់ ១១ ឆ្នាំ[2473]។

---

[2469] របាយការណ៍លើកទី១ ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ A/CN.4/680 កថាខណ្ឌ ១៧៧។

[2470] សាលដីកា *Brima* (តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន) ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ១៨១៖ "បើទោះជាមានរបៀបដែលអយ្យការបានចាត់ចំណាត់ថ្នាក់ "ការរៀបការដោយបង្ខំ" នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបើទោះជាអយ្យការធ្វើសេចក្តីសង្កេតលើបណ្តឹងសាទុក្ខនេះ ហើយដែលសេចក្តីសង្កេត ទាំងនោះមិនស្របគ្នានឹងការធ្វើចំណាត់ថ្នាក់បែបនេះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាលើចំណុចទាំងឡាយដែលបានលើកឡើង ដោយចាត់ទុកថាវាដូចជាបញ្ហាសារៈសំខាន់ទូទៅមួយដែលអាចជួយធ្វើឱ្យយុត្តិសាស្ត្រច្បាប់ព្រហ្មទណ្ឌអន្តរជាតិកាន់តែសម្បូរបែប"។ (យើងជាអ្នកគូសបន្ទាត់ពីក្រោម) (ភាសាអង់គ្លេស)។¶

[2471] *រដ្ឋអាជ្ញា តទល់នឹង Ongwen* ICC-02/04-01/15 សេចក្តីសម្រេចលើការបញ្ជាក់ស្តីពីការចោទប្រកាន់ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៨៧-៩៥ (ភាសាអង់គ្លេស)។

[2472] សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E418/4** កថាខណ្ឌ ២៦។

[2473] សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E418/4** កថាខណ្ឌ ២១។

២៤១៩. អង្គហេតុទាំងនេះមិនស៊ីគ្នានឹងអង្គហេតុនៃរឿងក្ដីរបស់យើងនោះទេ។ ច្បាស់ណាស់ថាការចាប់ផ្ដើម អភិវឌ្ឍផ្នែកគតិយុត្តនាពេលថ្មីៗនេះបានពង្រឹងដល់ការដែលថា អំពើប្រព្រឹត្តដែលបានចោទប្រកាន់ទៅលើជនជាប់ចោទ ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងក្របខ័ណ្ឌនេះ មិនមានលក្ខណៈ ឬកម្រិតធ្ងន់ធ្ងរដែលតម្រូវឱ្យមាននៅសម័យនោះ ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នោះឡើយ[2474]។

## ខ. ផលប៉ះពាល់

២៤២០. ការត្រឡប់មកនិយាយអំពីបែបបទនៃការរៀបអាពាហ៍ពិពាហ៍ នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ បានបង្ហាញឱ្យឃើញថា ការយល់ព្រមពីសំណាក់សាមីខ្លួនទាំងសងខាង មិនមែនជាចំណុចស្នូលនៃប្រពៃណីខ្មែរទេ។ ការផ្សំផ្គុំដោយឪពុកម្ដាយ គឺជាបទដ្ឋាន។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការផ្សំផ្គុំដោយអាជ្ញាធរមូលដ្ឋានបានជំនួសឱ្យការផ្សំផ្គុំដោយឪពុកម្ដាយ។ ដូច្នេះ គឺមានផ្លាស់ប្ដូរអំណាចមេបាពីឪពុកម្ដាយទៅអាជ្ញាធរមូលដ្ឋាន ប៉ុន្តែ មានភាពដូចគ្នាច្រើនក្នុងរបៀបជ្រើសរើសមនុស្សដែលអាចក្លាយជាសហព័ទ្ធ។

២៤២១. ទោះបីជាការប៉ះពាល់ដល់សេរីភាព និងដល់ការសម្រេចលើជោគវាសនាផ្ទាល់របស់ខ្លួន អាចបង្កព្យសនកម្មក៏ដោយ ក៏ការខូចខាតដែលបង្កឡើងមិនអាចប្រៀបផ្ទឹមនឹងការខូចខាតដែលកើតចេញពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចបានរៀបរាប់ (ឬមិនអាចប្រៀបផ្ទឹមនឹងការខូចខាតដែលកើតចេញពីការរៀបការ ក្នុងលក្ខណៈជា "អំពើអមនុស្សធម៌ផ្សេងទៀត" ដែលចាប់ផ្ដើមលេចឡើងនាពេលសព្វថ្ងៃនេះ នោះឡើយ ឧទាហរណ៍ ក្នុងបរិបទនៃជម្លោះអាហ្វ្រិក)។ ការខូចខាតរឹតតែមិនមានទៅ

---

[2474]ភាពសកម្មដើម្បីបុព្វហេតុរបស់អ្នកនិពន្ធសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី ពិតជាគួរឱ្យស្ងើចសរសើរ ហើយក្រោយពីបានធ្វើបទបង្ហាញស្ដីពីយុត្តិសាស្ត្រថ្មីៗ ពួកគេបានសន្និដ្ឋានថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះឆ្នាំ ១៩៧៥ និង ១៩៧៩ ហើយថា "ច្បាប់ព្រហ្មទណ្ឌអន្តរជាតិបានវិវត្តដោយបញ្ចូល "អំពើអមនុស្សធម៌ផ្សេងទៀត" នៃអាពាហ៍ពិពាហ៍ដោយបង្ខំ" (សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E418/4** កថាខណ្ឌ ៣៨)។ ម្យ៉ាងទៀតទាក់ទងនឹងការបែងចែកនាពេលថ្មីៗនេះរវាងករណីយកិច្ចប្ដីប្រពន្ធ និងការរំលោភក្នុងអាពាហ៍ពិពាហ៍ សូមមើលផ្នែកខាងលើ កថាខណ្ឌ ២៣៥១-២៣៥៥។

ទៀត ពីព្រោះសេរីភាពក្នុងការរៀបការមិនមាននោះទេ នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ទាំងនៅក្នុងច្បាប់ ទាំងនៅក្នុងការអនុវត្តក្នុងសង្គម។

២៤២២. ដូច្នេះ ដូចលោកស្រី Peg LEVINE បានគូសបញ្ជាក់យ៉ាងត្រឹមត្រូវ សំណាកគំរូភាគច្រើននៃការសិក្សារបស់គាត់មានការឈឺចាប់ធ្ងន់ធ្ងរនឹងអវត្តមាននៃពិធីផ្សេងៗ ក្នុងពេលរៀបអាពាហ៍ពិពាហ៍ លើសពីការរៀបអាពាហ៍ពិពាហ៍ផ្ទាល់។ នេះជាចំណុចចេញពីសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបាននិយាយអំពីការសោកស្តាយដែលមិនមានពិធីសាសនា នៅចំពោះមុខគ្រួសារ ឬគូស្រករដែលឪពុកម្តាយបានជ្រើសរើស[2475]។

២៤២៣. អវត្តមាននូវពិធី ឬកម្មវិធីជាលក្ខណៈគ្រួសារ[2476] មិនធ្វើឱ្យព្យសនកម្ម ដែលទទួលរង មានកម្រិតធ្ងន់ធ្ងរដល់ថ្នាក់អាចឱ្យចាត់ទុកការផ្សំផ្គុំឱ្យរៀបអាពាហ៍ពិពាហ៍ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

---

[2475] ស៊្វ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/463.1** ទំព័រ ៥៣ ចន្លោះម៉ោង [១៤.00.៥៥] និង [១៤.0៣.៤៣], 2-TCCP-232 : ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/464.1** ទំព័រ ១៨ មុនម៉ោង [១០.0៦.៥៤]៖ "[...] ចាប់បង្ខំឱ្យរៀបការ ចំពោះខ្ញុំវិញ ខ្លួនខ្ញុំតែម្តងគ្មានខោអាវស្លៀកទេ ខោអាវមួយកំប្លេប្រឡាក់សុទ្ធតែដីដាចទៀត ខោក៏ដាច អាវក៏ដាច កន្សែងក៏ដាច ខ្លួនក៏ស្គម ក្រឡេកទៅមើលជុំវិញ គ្មានបងប្អូនទេ [...]"។ ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/466.1** ទំព័រ ៦១ ប្រហែលម៉ោង [១៤.១៦.១៤]៖ "បានថាខ្ញុំតូចចិត្តដែរហ្នឹង ដល់ឃើញសព្វថ្ងៃ មកឃើញសម័យឥឡូវនិងសម័យពីដើម តូចចិត្តនឹងវាសនាខ្លួនឯង", 2-TCW-1002 : ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/469.1** ទំព័រ ៤២ ប្រហែលម៉ោង [១១.២៥.៤៤]៖ "គឺខ្ញុំ អត់មានអារម្មណ៍អី នឹកឃើញអារម្មណ៍ថាអន់ចិត្ត ថាគាត់ការឱ្យហ្នឹងតែម្តង អត់មានបងប្អូន អើជំនាន់ហ្នឹងយើងជ្រះស្រឡះ។ អត់មានអារម្មណ៍ថា ចង់បានម៉ែឪ បងប្អូនអីអត់ទេ គឺវាទូទៅទាំងអ៊ីចឹងហើយ ទាំងអស់គ្នាអ៊ីចឹងហើយ", មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/475.1** ទំព័រ ៥៨ ប្រហែលម៉ោង [១៤.២៤.៣៧]៖ "ហើយវាខុសគ្នា ខុសគ្នាអាកន្លែងថារៀបការហើយ តែងតែមានជប់លៀង មានសាច់ជ្រូក សាច់គោ សាច់មាន់អីទទួលភ្ញៀវ ដល់នេះអត់មានទេ ស្ងួតស្ងាត់ព្រលឹត", ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/476.1** ទំព័រ ១៣ ប្រហែលម៉ោង [០៩.៤៧.៣៣], ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/488.1** ទំព័រ ១៣-១៤ ប្រហែលម៉ោង [០៩.៤១.៥៣]៖ "ដល់អ៊ីចឹងហើយ ពេលការទៀត យើងអត់មានសេចក្តីសប្បាយចិត្ត ដោយសារការនេះ គ្មានម៉ែឪ គ្មានសាច់ញាតិ គ្មានបងប្អូន អ្នកស្រុកភូមិផងរបងជិតខាងអី គេមកអបអរសាទរមង្គលទេ គឺការនេះការតែគ្នាឯង ការនឹងអ្នកគូៗការហ្នឹង [...] អ៊ីចឹងការនេះគេគ្មានចាក់ភ្លេងខ្មែរ សែនចងដៃ កាត់សក់ បុកល័ក្ត ចាក់ចេកដេកអង្ករៀប គ្មានទេ", ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៤ ប្រហែលម៉ោង [០៩.១៣.១៩]។

[2476] ពាក់ព័ន្ធនឹងចំណុចនេះ គេត្រូវរំលឹកថាសាក្សីជាច្រើននាក់ បានលើកឡើងពីការជ្រើសសហព័ទ្ធដោយឪពុកម្តាយ ដោយមានការយល់ព្រម ឬ "អនុញ្ញាត" ពីអាជ្ញាធរមូលដ្ឋាន ដែលពាក្យចុងក្រោយនេះគឺជាពាក្យដែលប្រើដោយអ្នកជំនាញ ណាកាហ្គាវ៉ា។

ជា "អំពើអមនុស្សធម៌ផ្សេងទៀត" បានឡើយ។ គួរគូសបញ្ជាក់ផងដែរថា ជារឿយៗ ព្យសនកម្ម ដែលលើកឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការ គឺបណ្ដាលមកពីល័ក្ខខ័ណ្ឌរស់នៅជាទូទៅ គឺមិនអាស្រ័យនឹងការរៀបអាពាហ៍ពិពាហ៍ទេ[2477]។ ម្យ៉ាងវិញទៀត ដូចយើងបានលើកឡើងពីខាងលើ អ្នកខ្លះចាត់ទុកការរៀបអាពាហ៍ពិពាហ៍ជាមធ្យោបាយក្នុងការទទួលបានល័ក្ខខ័ណ្ឌរស់នៅល្អប្រសើរជាងមុន។

### គ. ចេតនា

២៤២៤. នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការរៀបអាពាហ៍ពិពាហ៍ និងការរួមភេទ មិនត្រូវបានប្រព្រឹត្តដោយចេតនា ដើម្បីបង្កការឈឺចាប់ធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬប៉ះពាល់ធ្ងន់ធ្ងរដល់បូរណភាពរាងកាយ ឬផ្លូវចិត្ត ឬប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស ឡើយ។

២៤២៥. ជាក់ស្ដែង មានការជំនួសសិទ្ធិអំណាចឪពុកម្ដាយដោយអាជ្ញាធរមូលដ្ឋាន ក្នុងគោលដៅអនុញ្ញាតឱ្យប្រជាជនអាចរៀបការ និងកសាងគ្រួសារ។ សេចក្ដីណែនាំឱ្យអនាគតប្ដី-ប្រពន្ធចេះស្រឡាញ់ និងថែរក្សាគ្នា បង្ហាញថាគោលបំណងមិនមែនចង់បង្កការឈឺចាប់នោះទេ។ ម្យ៉ាងវិញទៀត នៅសម័យនោះ នៅប្រទេសកម្ពុជា គេមិនស្គាល់សញ្ញាណនៃការរំលោភសេពសន្ថវៈរវាងប្ដី-ប្រពន្ធនោះឡើយ។ អ្នកដែលផ្សំផ្គុំឱ្យប្រជាជនរៀបអាពាហ៍ពិពាហ៍មិនមានចេតនាបែបនេះឡើយ។

---

សាក្សីផ្សេងៗទៀតបានលើកឡើងផងដែរនូវវត្តមានក្រុមគ្រួសារនៅក្នុងពិធីរៀបការ។

[2477] ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ** E1/489.1 ទំព័រ ២៣-២៤ ប្រហែលម៉ោង [១០.០៦.៤៩], គុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ** E1/488.1 ទំព័រ ៨៩ ប្រហែលម៉ោង [១៥.៤១.៥២], សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ** E1/489.1 ទំព័រ ៤៥ ប្រហែលម៉ោង [១១.៣៥.១៥], ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ** E1/488.1 ទំព័រ ៦១ ចាប់ពីម៉ោង [១៤.០១.២៩] ទំព័រ ៦៣ ប្រហែលម៉ោង [១៤.០៦.៥៨], ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ** E1/483.1 ទំព័រ ៥៥ ប្រហែលម៉ោង [១១.៥៧.២១] ទំព័រ ៥៦ ប្រហែលម៉ោង [១២.០០.២៧], មុំ វុន ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ** E1/477.1 ទំព័រ ១៩-២០ ចន្លោះម៉ោង [០៩.៤៨.២៣] និង [០៩.៥២.៣៥], សេង សឿន ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ** E1/466.1 ទំព័រ ៤៣-៤៤ ប្រហែលម៉ោង [១១.៣៧.៥៥]។

២៤២៦. ការរំលោភសេពសន្ថវៈដែលដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនបានចោទប្រកាន់ (ក្រៅពីភាពផ្ទុយគ្នា) ជាករណីដាច់ដោយឡែក ដែលមិនអាចបង្កើតបានជាចេតនាផ្ទាល់ក្នុងការរំលោភសេពសន្ថវៈឡើយ។ ម្យ៉ាងវិញទៀត ទ្រឹស្តីរបស់សហព្រះរាជអាជ្ញាមានភាពច្បាស់លាស់ត្រង់ចំណុចនេះ។ ជាក់ស្តែង នៅពេលជជែកតវ៉ាអំពីការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ សហព្រះរាជអាជ្ញាបានអះអាងថា ការរំលោភសេពសន្ថវៈ គឺជាផលវិបាកពីធម្មជាតិ និងអាចប្រមើលមើលបាន នៃការរៀបអាពាហ៍ពិពាហ៍[2478]។ ដូច្នេះ សហព្រះរាជអាជ្ញាបានទទួលស្គាល់ដោយខ្លួនឯងអំពីអលទ្ធភាពក្នុងការបង្ហាញចេតនាផ្ទាល់នៃការរំលោភសេពសន្ថវៈ។

២៤២៧. អង្គជំនុំជម្រះត្រូវពិចារណាជាចាំបាច់ដល់ភ័ស្តុតាងទាំងនេះ និងសន្និដ្ឋានថា ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ការរៀបអាពាហ៍ពិពាហ៍ និងការរួមភេទ មិនមែនជា "អំពើអមនុស្សធម៌ផ្សេងទៀត" នោះទេ។

## ជំពូកទី ២. គោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដែលចោទប្រកាន់

២៤២៨. យើងទើបនឹងបានឃើញហើយថា លើផ្នែកច្បាប់ គេពុំអាចចាត់ទុកថាអង្គហេតុទាំងឡាយដែលសហចៅក្រមស៊ើបអង្កេតកំណត់ថាជា "ការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ" ស្ថិតនៅក្នុងនិយមន័យនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។

២៤២៩. ទន្ទឹមនឹងនោះ យើងគួរគប្បីពិនិត្យមើលភ័ស្តុតាងដែលបានបង្ហាញ ដើម្បីស្វែងរកការពិតអំពីបទបញ្ញាស្តីអំពីការរៀបការ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការបង្ហាញដ៏ងាយពេកអំពី

---

[2478]ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ **ឯកសារ E1/240.1** ទំព័រ ២៤ (ប្រតិចារឹកជាភាសាបារាំងមានបញ្ហា) ក្រោយម៉ោង [១០.១២.១៧] (វាជាសវនាការបឋម ដែលនៅពេលនោះ សហព្រះរាជអាជ្ញាបានប្រកាសថា សហឧក្រិដ្ឋកម្មរួម ទម្រង់ ៣ គឺពិតជាសំខាន់ខ្លាំងណាស់សម្រាប់សំណុំរឿង ០០២/០២ ដោយសហព្រះរាជអាជ្ញាបានផ្តល់ឧទាហរណ៍ស្តីពីការរំលោភសេពសន្ថវៈ៖ "ដូចជាឧទាហរណ៍មួយ គឺបទរំលោភសេពសន្ថវៈនៅក្នុងរឿងក្តី ០០២/០២ នោះក៏ត្រូវបានចាត់ទុកថាគឺជាផលវិបាកធម្មតា ហើយអាចប្រមើលមើលបាននៃផែនការនៃការធ្វើទុក្ខបុកម្នេញ នៃការសម្លាប់ នៃការធ្វើទារុណកម្ម ហើយនិងការបង្ខំគូស្រករឱ្យរៀបការនោះ"។

បក្សកុម្មុយនីស្តកម្ពុជាដែលលើកទឹកចិត្តឱ្យមានការប្រព្រឹត្តិអំពើរំលោភសេពសន្ថវៈដើម្បីបង្កើនចំនួនប្រជាជន មិនឆ្លុះបញ្ចាំងតថភាពនៃអង្គហេតុឡើយ (ផ្នែកទី I) និងចោទជាបញ្ហានៃភាពជាតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ផ្នែកទី II) ដែលតម្រូវឱ្យមានការប្រុងប្រយ័ត្នយ៉ាងខ្លាំងក្នុងការពិនិត្យភ័ស្តុតាង។

## ផ្នែកទី ១. ការពិភាក្សាដេញដោលចាកប្រធានអំពីការបង្កើនចំនួនប្រជាជន

### ១. សុន្ទរកថាផ្លូវការ

២៤៣០. សហព្រះរាជអាជ្ញាដែលបានជ្រើសយកការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ដែលដើមបណ្តឹងរដ្ឋប្បវេណីជ្រើសយកតាមក្រោយ អះអាងថាមូលហេតុនៃបទបញ្ជាស្តីពីការរៀបការ និងការរៀបចំចាត់ចែងអាពាហ៍ពិពាហ៍រួម គឺជាការបង្កើនចំនួនប្រជាជន។ ទោះបីជា វាជាការពិតដែលបក្សកុម្មុយនីស្តកម្ពុជាបានសង្កត់ធ្ងន់ជាច្រើនដងលើការបង្កើនចំនួនប្រជាជនតាមដែលអាចធ្វើបាន និងតាមប្រាថ្នា ក៏ដោយ ក៏សុន្ទរកថានេះត្រូវបានធ្វើឡើងក្នុងចក្ខុវិស័យនៃការស្តារប្រទេសឡើងវិញជាទូទៅ។

២៤៣១. ជួន ធី បានលើកឡើងនៅក្នុងសវនាការអំពីពាក្យពេចន៍ដែល ប៉ុល ពត បាននិយាយក្នុងពេលប្រជុំមួយ ដែលក្នុងពេលនោះ គាត់បានបង្ហាញការរៀបការជាការចូលរួមចំណែកក្នុងការបង្កើតឱ្យមាន "ប្រជាសាស្ត្រល្អមួយ" នៃប្រជាជននៅកម្ពុជាសម័យក្រោយសង្គ្រាម ដែល "ជាប្រទេសដ៏ធំទូលាយមួយ" "ដែលនៅសល់ដីគ្មានប្រជាជននៅ"[2479]។ ក៏ប៉ុន្តែ ដោយសារតែការសម្លឹងមើលរឿងរ៉ាវតែមួយជ្រុងៗ ទើបគេយល់ឃើញថា ការរៀបការទំនងជាគោលនយោបាយ "រួម" ត្រូវបានគ្រោងទុកដើម្បីបង្កើនចំនួនប្រជាជន។

២៤៣២. ជួន ធី មិនត្រឹមតែបានពន្យល់នៅក្នុងសាលសវនាការយ៉ាងច្បាស់ថា ប៉ុល ពត បានបំបាត់ការបង្ខិតបង្ខំក្នុងការរៀបអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ[2480] គឺថែមទាំងបន្ថែមជាពិសេសថា សុន្ទរកថាផ្លូវការ

---

[2479] ជួន ធី ប្រតិចារឹក ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/490.1** ទំព័រ ១២ មុនម៉ោង [០៩.៣៦.០៣]។

[2480] សូមមើលផ្នែកខាងលើ កថាខណ្ឌ ២៣៦១។

ជាច្រើនរៀបរាប់អំពីវិធានការណ៍ជាក់លាក់ដែលគ្រោងទុកដើម្បីសម្រេចបាននូវការបង្កើនចំនួនប្រជាជន។

២៤៣៣. អាស្រ័យហេតុដូចនេះ ក្នុងឆ្នាំ ១៩៧៧ នៅអង្គការសហប្រជាជាតិ អៀង សារី បានបង្ហាញអំពីអ្វីដែលជាផែនការរបស់រដ្ឋាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជាដើម្បីឱ្យមាន "ប្រជាជនពី ១៥ ទៅ ២០ លាននាក់ ក្នុងរយៈពេលដប់ឆ្នាំខាងមុខ" ដោយនិយាយលម្អិតអំពីវិធានការ "ក្នុងវិស័យសង្គមកិច្ច និងសុខាភិបាល ដើម្បីធានាឱ្យបានឆាប់រហ័សដល់សុខភាពរបស់ប្រជាជនទាំងអស់" រួមមានវិធានការណ៍លើការបណ្តុះបណ្តាល "គ្រូពេទ្យបដិវត្តន៍ និងការផលិតថ្នាំ"[2481]។ ដូច្នេះ ពុំមានការលើកឡើងអំពីការរៀបការនោះទេ។

២៤៣៤. ក្នុងសុន្ទរកថាឆ្នាំ១៩៧៧មួយ ប៉ុល ពត លើកឡើងអំពីការប្រយុទ្ធប្រឆាំងនឹងជំងឺជាច្រើន "ពីសង្គមចាស់ និងការបំពុលសង្គម" និងនិយាយយ៉ាងវែងអំពីយុទ្ធនាការកំចាត់ជំងឺគ្រុនចាញ់។ គាត់សង្ខេបការជឿនលឿនទាំងនេះថាជាការចូលរួមក្នុងការធ្វើឱ្យ "ប្រសើរឡើងដល់ល័ក្ខខ័ណ្ឌជីវភាព និងសុខភាពរបស់ប្រជាជនយើង ពីព្រោះយើងសង្ឃឹមថាអាចបង្កើនចំនួនប្រជាជនយើងដល់ ១៥លាន ទៅ ២០លាននាក់ ក្នុងរយៈពេលយ៉ាងហោចណាស់ដប់ឆ្នាំខាងមុខ[2482]។ សុន្ទរកថាបែបនេះមានជាប់រហូតពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្រោយរបបនេះក៏នៅតែមានដែរ[2483]។

---

[2481] របាយការណ៍មហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៣២ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ **ឯកសារ E3/1586** កថាខណ្ឌ ៦០ ERN 00291027-28។

[2482] របាយការណ៍ស្តីពីសេវាផ្សព្វផ្សាយព័ត៌មានបរទេស ចុះខែ តុលា ឆ្នាំ ១៩៧៧ **ឯកសារ E3/290** ERN 00168651 (ភាសាអង់គ្លេស)។ សូមមើលសេចក្តីអត្ថាធិប្បាយរបស់លោក ខៀវ សំផន ទាក់ទងនឹងការវិភាគរបស់លោក លើប្រធានបទស្តីពីផែនការនានារបស់ ប៉ុល ពត តាមរយៈការសិក្សារបស់គាត់លើកំណត់ហេតុមួយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលអ្នកនិពន្ធបានលើកឡើង៖ សៀវភៅនិពន្ធដោយលោក ខៀវ សំផន មានចំណងជើងថា "ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ" ឆ្នាំ ២០០៤ **ឯកសារ E3/16** ERN 00643891 (ភាសាបារាំង) ERN 00380467 (ភាសាខ្មែរ) ERN 00498284 (ភាសាអង់គ្លេស)។

[2483] ទង់បដិវត្ត លេខពិសេស ចេញផ្សាយខែ ធ្នូ ១៩៧៦-មករា ១៩៧៧ **ឯកសារ E3/25** ERN 00063054-55៖ "ដើម្បីឱ្យប្រជាជនកើនបានឆាប់ ទាល់តែជីវភាពឡើង សុខភាពបានល្អ។ ដូច្នេះ មានតែបង្កបង្កើនផលឱ្យបានរហ័ស។ លុយដែលបានមកពីការនាំផលិតផលទៅបរទេស គឺដើម្បីពង្រីកកសិកម្ម ពង្រីកឧស្សាហកម្ម និងបម្រើជីវភាពប្រជាជន។ គ្មានធ្វើអីក្រៅពីនេះទេ"។ របាយការណ៍ស្តីពីសេវាផ្សព្វផ្សាយព័ត៌មានបរទេស មានចំណងជើងថា "មិទ្ទីងនៅក្រុងភ្នំពេញ ដើម្បីរំឭកខួបថ្ងៃ ១៧ មេសា" ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ **ឯកសារ E3/562** ERN 00280381 (ភាសាបារាំង) ERN 00249991 (ភាសាខ្មែរ) ERN

២៤៣៥. ដូច្នេះ ការរៀបការអាចចូលរួមចំណែកក្នុងការបង្កើនចំនួនប្រជាជនក៏ពិតមែន ក៏ប៉ុន្តែវាមិនមែនជាគោលនយោបាយតែឯកឯងដែលបក្សកុម្មុយនីស្តកម្ពុជាផ្តោតលើដើម្បីសម្រេចគោលដៅនៃការបង្កើនប្រជាជននេះទេ។ ដូច្នេះការជំរុញឱ្យមានការរៀបការដោយបង្ខំមិនដែលមាននៅក្នុងកាលវិភាគរបស់បក្សកុម្មុយនីស្តកម្ពុជានោះទេ។

## ២. សក្ខីកម្មផ្ទុយគ្នាក្នុងសវនាការ

២៤៣៦. នៅក្នុងវគ្គជំនុំជម្រះលើបទបញ្ហាស្តីពីការរៀបអាពាហ៍ពិពាហ៍ ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនបានផ្តល់សក្ខីកម្ម។ គួរឱ្យឆ្ងល់ដែរ ពួកគាត់បានលើកឡើងស្មើរតែគ្រប់ៗគ្នាអំពីពាក្យពេចន៍លើភាពចាំបាច់នៃការ "បង្កើនកូនជូនអង្គការ"។ ជាក់ស្តែង ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-274 បានលើកឡើងអំពីពាក្យពេចន៍បែបនេះ ដែលបាននិយាយដោយប្រធានកងរបស់គាត់ ក្នុងខណៈដែលគាត់មិនបានលើកឡើងពីពាក្យពេចន៍ទាំងអស់នេះនៅក្នុងចម្លើយជាលាយលក្ខអក្សររបស់គាត់។[2484] ដូចគ្នាដែរ កាលពីឆ្នាំ ២០១៤ ជា ដៀប បានចាំសុន្ទរកថាដែល ខៀវ សំផន បានថ្លែងយ៉ាងត្រូវកាលៈទេសៈមុនពេលគាត់រៀបការ។[2485] ស៊្វ សុធារី និង មុំ វុន បានផ្តល់សក្ខីកម្មក្នុងទិសដៅនេះដែរ ដូច ប៉ែន សុចាន់ ព្រាប សុឃឿន កុល ណែម ង៉ែត ឆាត និង សយ ណារឿន។[2486]

---

S00010565 (ភាសាអង់គ្លេស)។ ទង់បដិវត្ត លេខ ៩ ចេញផ្សាយខែ កញ្ញា ឆ្នាំ ១៩៧៨ **ឯកសារ E3/215** ERN 00064617-18។ ជារឿយៗ ទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ តែងតែលើកបង្ហាញពីស្ថានភាពរស់នៅរបស់ប្រជាជនដែលត្រូវតែធ្វើឱ្យប្រសើរឡើងថែមទៀត។ ឧទាហរណ៍ សូមមើល៖ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៧៨**ឯកសារ E3/1092** ERN 00611449-50 (ភាសាបារាំង) ERN KH 00143579 (ភាសាខ្មែរ) ERN EN 00289924 (ភាសាអង់គ្លេស), *SWB* ភាគ ៣ "បទសម្ភាសន៍ជាមួយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យស្តីពីគោលនយោបាយប្រជាជន និងការតស៊ូប្រឆាំងវៀតណាម" ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៨១ **ឯកសារ E3/686** ERN 00599792 (ភាសាបារាំង) ERN S00644682 (ភាសាខ្មែរ) ERN S00030349 (ភាសាអង់គ្លេស)។

[2484] ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦**ឯកសារ E1/462.1** ទំព័រ ៧២ ប្រហែលម៉ោង [១៥.១៧.១២]។

[2485] ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦**ឯកសារ E1/466.1** ទំព័រ ៥២ប្រហែលម៉ោង [១៣.៥០.១០]។

[2486] ស៊្វ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦**ឯកសារ E1/462.1** ទំព័រ ៧២ ប្រហែលម៉ោង [១៥.១៧.១២], មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/475.1** ទំព័រ ៤៤ ប្រហែលម៉ោង [១៣.៤០.៣៥], ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦**ឯកសារ E1/482.1** ទំព័រ ៥៦ ប្រហែលម៉ោង [១៤.០២.០៧], ព្រាប សុឃឿន ប្រតិចារឹក

២៤៣៧. ឯកសណ្ឋានភាពនៃរឿងរ៉ាវទាំងនេះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រហែលជាមិនសូវធ្វើឱ្យភ្ញាក់ផ្អើល និងហាក់ដូចជាមិនសូវសមស្របនឹងកាលៈទេសៈប៉ុន្មានទេចំពោះតម្រូវការនៃបុព្វហេតុរបស់ខ្លួន ប្រសិនបើនៅពេលដែលសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីផ្ទាល់មួយចំនួនដែលបានផ្ដល់សក្ខីកម្មលើវគ្គជំនុំជម្រះផ្សេងៗទៀត មានលើកឡើងអំពីពាក្យពេចន៍ស្រដៀងគ្នានេះដោយប្រទាក់ក្រឡាគ្នាវិញនោះ។ ក៏ប៉ុន្តែ នៅពេលដែលគេចោទសំណួរនេះទៅពួកគាត់ ពួកគាត់ភាគច្រើនបានឆ្លើយថាមិនបានទទួលការណែនាំឱ្យបង្កើត "កូនឱ្យអង្គការ" ទេ។

២៤៣៨. ជាក់ស្ដែង អ៊ិន យឿង ភ្នៅ យ៉ារ ចៅ ឡាង 2-TCCP-104, 2-TCW-1037, ធុច ស៊ីថន សេង លីថេង 2-TCW-823 មាស ឡៃហួរ និង យី ឡៃសួរ មិនបាននិយាយថាបានឮការណែនាំបែបនេះនៅក្នុងពិធីរៀបការដែលពួកគាត់បានចូលរួមទេ។[2487] សូម្បីតែសាក្សី ផាន់ ហ៊ីម និង 2-TCW-1002 ដែលបាននិយាយថាមិនចង់រៀបការ ក៏មិនបានលើកឡើងអំពីពាក្យពេចន៍ទាក់ទងនឹងការបង្កើតកូនឱ្យបក្សដែរ។[2488]

---

ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/487.1** ទំព័រ ៧៣ ប្រហែលម៉ោង [១៥.៣២.០៨], កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/488.1** ទំព័រ ៧៨ ប្រហែលម៉ោង [១៥.១២.០៣], ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ១០ ប្រហែលម៉ោង [០៩.២៨.២៧], សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៣១ មុនម៉ោង [១០.៥១.០៦]។

[2487] អ៊ិន យឿង ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៧០ ប្រហែលម៉ោង [១៥.២១.១០], ភ្នៅ យ៉ារ ប្រតិចារឹក ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/264.1** ទំព័រ ២៥ ប្រហែលម៉ោង [១០.៥០.៤៣], ចៅ ឡាង ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/339.1** ទំព័រ ៦០ ប្រហែលម៉ោង [១៥.១៤.២៥], 2-TCCP-1040 : ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/459.1** ទំព័រ ៥១ ប្រហែលម៉ោង [១៤.១៧.៥០], 2-TCW-1037 : ប្រតិចារឹក ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/485.1** ទំព័រ ២៨ ប្រហែលម៉ោង [១០.៥៧.១០], ធុច ស៊ីថន ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/500.1** ទំព័រ ៥៣ ប្រហែលម៉ោង [១៤.៥១.០៨], សេង លីថេង ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/503.1** ទំព័រ ៣៥ ប្រហែលម៉ោង [១១.២៥.១៨], 2-TCW-823 : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៨០ ប្រហែលម៉ោង [១៦.០០.៥៧], មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ១១ មុនម៉ោង [០៩.៣៧.៤៣], យី ឡៃសួរ ប្រតិចារឹក ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/334.1** ទំព័រ ៥២ ប្រហែលម៉ោង [១៤.២៣.២១]។

[2488] ផាន់ ហ៊ីម ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/467.1** ទំព័រ ៨៨ ប្រហែលម៉ោង [១៥.៤១.០៣], 2-TCW-1002 : ប្រតិចារឹក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/469.1** ទំព័រ ៣៨ ប្រហែលម៉ោង [១១.១៤.៣៦], 2-

២៤៣៩. ដូច្នេះ វាគួរឱ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ថា ដូចបញ្ហារំលោភសេពសន្ថវៈក្នុងបរិបទរៀបអាពាហ៍ពិពាហ៍ដែរ សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងក្របខណ្ឌនៃបទបញ្ហាស្ដីអំពីការរៀបការ ខុសគ្នាយ៉ាងខ្លាំងពីសក្ខីកម្មផ្សេងទៀតទាំងប៉ុន្មានពាក់ព័ន្ធនឹងភាពធ្ងន់ធ្ងរនៃអង្គហេតុចោទប្រកាន់។ សក្ខីកម្មទាំងនេះមានគោលបំណងចោទប្រកាន់ឱ្យកាន់តែធ្ងន់ធ្ងរថែមទៀតយ៉ាងជាក់ស្ពាន់។

## ផ្នែកទី ២. ភាពជាតំណាងនៃរឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

២៤៤០. ផ្អែកលើការសង្កេតខាងលើ វាជាការត្រឹមត្រូវក្នុងការចោទសំណួរអំពីភាពជាតំណាងនៃរឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងក្របខណ្ឌនៃការចេញបទបញ្ជាថ្នាក់ជាតិស្ដីពីការរៀបអាពាហ៍ពិពាហ៍។

### ១. និដ្ឋភាពទូទៅនៃសក្ខីកម្មក្នុងសវនាការនៃសំណុំរឿង ០០២/០២

២៤៤១. ដោយគ្មានការស៊ើបអង្កេតទ្រង់ទ្រាយធំ វាជាការលំបាកក្នុងការវាយតម្លៃថាតើមានការរៀបការប៉ុន្មានភាគរយ ដែលសាមីជនទទួលអារម្មណ៍ថាជាការរៀបការដោយបង្ខំដូចដែលដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លងកាត់។ ដូចដែល PEG LEVINE បានលើកឡើងក្នុងពេលផ្ដល់សក្ខីកម្ម បញ្ហាមិនមែនស្ថិតនៅត្រង់ការចោទជាបញ្ហានៃបទពិសោធន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានផ្ដល់សក្ខីកម្មទាំងនេះទេ បញ្ហាគឺត្រូវមានសមត្ថភាពក្នុងការពិចារណាអំពីបទពិសោធន៍របស់ពួកគាត់ក្នុងទស្សនវិស័យទូលាយជាងក្រុមដើមបណ្ដឹងរដ្ឋប្បវេណីដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដោយពិចារណាលើបទពិសោធន៍របស់ពួកគាត់ពីជ្រុងមួយផ្សេងទៀត។[2489]

---

TCW-1002 គ្រាន់តែបានបង្ហាញពីការចំអន់គ្នាលេង ដូចដែលបានលើកឡើងដោយអ្នកជំនាញ ផេហ្គី ឡឺវ៉ាញ ក្នុងពិធីអាពាហ៍ពិពាហ៍ ហើយដែលអ្នកជំនាញរូបនេះយល់ថា ការចំអន់គ្នាលេងបែបនេះ គឺយោងទៅលើប្រពៃណី។ សូមមើល៖ ផេហ្គី ឡឺវ៉ាញ ប្រតិចារឹក ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ** E1/480.1 ទំព័រ ៥៨ ប្រហែលម៉ោង [១៥.៤៨.៣០]។

[2489] ផេហ្គី ឡឺវ៉ាញ ប្រតិចារឹក ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ** E1/481.1 ទំព័រ ២៩ ប្រហែលម៉ោង [១០.៤២.៤១]។

២៤៤២. គ្រាន់តែពិនិត្យលើសក្ខីកម្មរបស់សាក្សីដែលបានមកផ្តល់សក្ខីកម្មលើផ្នែកនេះ អាចផ្តល់ទស្សនវិស័យមួយផ្សេងទៀតបាត់ទៅហើយ។ ក្រៅពីដើមបណ្តឹងរដ្ឋប្បវេ និងសាក្សីដែលបានផ្តល់សក្ខីកម្មលើការរៀបអាពាហ៍ពិពាហ៍ មានមនុស្ស ២២ នាក់ទៀតដែលបាននិយាយនៅក្នុងសាលសវនាការថា ខ្លួនបានរៀបការក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងចំណោមមនុស្សទាំង ២២ នាក់នេះ មាន ០៦ នាក់ និយាយយ៉ាងច្បាស់ថា ខ្លួនត្រូវបានបង្ខំឱ្យរៀបការ គឺ ជាំង ស្រីមុំ (ភូមិភាគនិរតី) ថៅ ឡាង (ភូមិភាគកណ្តាល) ឃិន វ៉ាត (ភូមិភាគបស្ចិម) យី ឡៃស្រូវ (ភូមិភាគពាយ័ព្យ) មុំ សារឿន (ភូមិភាគបូព៌ា) ធុច ស៊ីថន (ភ្នំពេញ)[2490]។

២៤៤៣. ផ្ទុយទៅវិញ មាន ១២ នាក់ បានឆ្លើយយ៉ាងច្បាស់ថាមិនត្រូវបានបង្ខំឱ្យរៀបការនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺ អ៊ុំ សុផានី (ភូមភាគនិរតី) មាស ឡៃហួរ (ភូមភាគកណ្តាល) កង អ៊ុត (ភូមភាគកណ្តាល) សេង ស្រ៊ុន (ភូមភាគកណ្តាល) អះម៉ាត់ សហ្វីយ៉ាស់ (ភូមភាគបូព៌ា) ឌុច (ភ្នំពេញ)ហួន ជួម (ភូមភាគពាយ័ព្យ) ជួន ធី (ភូមភាគបស្ចិម) ប៊ិត បឿន សេង (ភ្នំពេញ) លីថេង) ភ្នំពេញ( ម៉ាក ឈឿន (ភូមភាគនិរតី) អ៊ិន យឿង (ភូមភាគបូព៌ា)[2491]។

---

[2490] ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/254.1** ទំព័រ ១៦ ប្រហែលម៉ោង [០៩.៥៣.០៤], ថៅ ឡាង ប្រតិចារឹក ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/339.1** ទំព័រ ៥៤-៥៥ ចន្លោះម៉ោង [១៤.៣៦.៥០] និង [១៤.៤០.៣៥], ឃិន វ៉ាត ប្រតិចារឹក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ **ឯកសារ E1/325.1** ទំព័រ ៦៧-៦៨ ចន្លោះម៉ោង [១៥.៣៦.៤២] និង [១៥.៤០.៣៥], យី ឡៃស្រូវ ប្រតិចារឹក ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ **ឯកសារ E1/334.1** ទំព័រ ៤៧ ប្រហែលម៉ោង [១៤.០៦.០៨], 2-TCCP-1040 : ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ **ឯកសារ E1/459.1** ទំព័រ ២០ ប្រហែលម៉ោង [១០.១២.៥៤], ធុច ស៊ីថន ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/500.1** ទំព័រ ៥៥-៥៦ ប្រហែលម៉ោង [១៤.៥៩.០០]។

[2491] អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/251.1** ទំព័រ ៨០ ប្រហែលម៉ោង [១៥.៥១.៥៧]៖ អ៊ុំ សុផានី និយាយថាម្តាយក្មេកគាត់ បានបង្ខំឲ្យគាត់រៀបការ៖ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ **ឯកសារ E1/252.1** ទំព័រ ១៧ ប្រហែលម៉ោង [០៩.៥៧.១៣], មាស ឡៃហួរ ប្រតិចារឹក ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/305.1** ទំព័រ ៨-៩ ប្រហែលម៉ោង [០៩.២៨.៤១], កង អ៊ុត ប្រតិចារឹក ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ **ឯកសារ E1/322.1** ទំព័រ ៤១ ប្រហែលម៉ោង [១៣.៥៤.១៧], សេង ស្រ៊ុន ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ **ឯកសារ E1/346.1** ទំព័រ ៤៦ ប្រហែលម៉ោង [១១.៥១.៤០], អះម៉ាត់ សហ្វីយ៉ាស់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ **ឯកសារ E1/375.1** ទំព័រ ៦៧ ប្រហែលម៉ោង [១៤.៣៩.៣៩], កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ **ឯកសារ E1/436.1** ទំព័រ ១៣-១៤ ប្រហែលម៉ោង [០៩.៤៥.០៨], 2-TCW-1037 : ប្រតិចារឹក ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/485.1** ទំព័រ ២៩-៣០ ប្រហែលម៉ោង [១០.៥៩.៤៧] និង [១១.០៣.៤៧], ជួន ធី ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/489.1** ទំព័រ ៨២ ក្រោយ

២៤៤៤. ដូច្នេះ បទពិសោធន៍ខុសៗគ្នាទាំងនេះដែលមិនស៊ីគ្នានឹងតក្កវិជ្ជាក្នុងតំបន់ អាចឱ្យយើងមើលឃើញនូវអ្វីដែលអ្នកជំនាញបានគូសវាសបង្ហាញ ដែលថាអាចមានការរៀបការដោយបង្ខំនៅកម្រិតណាមួយទៅ តែគេមិនអាចទាញការសន្និដ្ឋានថាមានអត្ថិភាពជាគោលនយោបាយ។

## ២. <u>សេចក្តីសន្និដ្ឋាន</u>

២៤៤៥. សក្ខីកម្មរបស់អ្នកជំនាញត្រូវតែប្រើប្រាស់ដោយគិតអំពីកម្មវត្ថុនៃការស្រាវជ្រាវ និងវិធីសាស្ត្ររបស់គាត់។ កម្មវត្ថុនៃការស្រាវជ្រាវរបស់ Kasumi NAKAGAWA ផ្តោតសំខាន់ទៅលើជនរងគ្រោះដោយការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ. ចាប់តាំងពីដើមទី ជម្រើសនេះតម្រង់ទិសដៅក្នុងការជ្រើសរើសប៉ាន់គំរូនៃការស្រាវជ្រាវរបស់គាត់។ ហើយការជ្រើសរើសប៉ាន់គំរូនៃការស្រាវជ្រាវរបស់គាត់នេះក៏តម្រង់ទិសលទ្ធផលនៃការស្រាវជ្រាវរបស់គាត់ជាចាំបាច់យ៉ាងជាក់ច្បាស់។

២៤៤៦. Peg LEVINE បានជ្រើសរើសវិធីសាស្ត្រមួយខុសពីនេះ ដែលគាត់បានពន្យល់យ៉ាងលម្អិត។ គាត់បានសម្រេចចិត្តមិនប្រើប្រាស់ប៉ាន់គំរូ "ឥស្សរចិត្ត" ក្នុងការស្រាវជ្រាវលើការរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយប្រកាន់យកវិធីសាស្ត្រមួយដែលមានលក្ខណៈអព្យាក្រឹត្យតាមតែអាចធ្វើទៅបាន ដើម្បីជៀសវៀងមិនធ្វើការវាយតម្លៃ និងមានបុរេវិនិច្ឆ័យលើអារម្មណ៍ផ្ទួចត់របស់បុគ្គល

---

ម៉ោង [១៥.៥៥.០៣], <u>ប៊ិត បឿន</u> ប្រតិចារឹក ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/502.1** ទំព័រ ៣១ ចន្លោះម៉ោង [១១.១៦.៤២] និង [១១.១៨.២១], <u>សេង លីថេង</u> ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ **ឯកសារ E1/503.1** ទំព័រ ១៩ ប្រហែលម៉ោង [១០.០៦.២៣], <u>2-TCW-823</u> : ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ **ឯកសារ E1/511.1** ទំព័រ ៧៨-៧៩ ប្រហែលម៉ោង [១៥.៥៥.១៥], <u>អ៊ុន យឿង</u> ប្រតិចារឹក ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ **ឯកសារ E1/387.1** ទំព័រ ៧៧ ប្រហែលម៉ោង [១៥.៤១.៣០] (ដែលគាត់ស្ម័គ្រចិត្តរៀបការដើម្បីត្រឡប់ទៅសហករណ៍វិញ)។ គេក៏អាចបន្ថែម រី ពៅ ម្នាក់ទៀត ដោយចាត់ទុកគាត់ជាសាក្សីទី ១៤ ព្រោះថាគាត់បានលើកឡើងពីផែនការរៀប ផ្សំផ្គុំជាមួយនារីម្នាក់ក្នុងភូមិ ដែលនៅទីបញ្ចប់ទៅផែនការនេះមិនអាចសម្រេចបាន ដោយសារតែការមកដល់របស់ពួកវៀតណាម៖ <u>រី ពៅ</u> ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/262.1** ទំព័រ ២២ ប្រហែលម៉ោង [១០.១៦.៤២], ឯម ភឿង ក៏មិនត្រូវបានគេបង្ខំឱ្យរៀបការដូចគ្នា៖ <u>ឯម ភឿង</u> ប្រតិចារឹក ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ **ឯកសារ E1/263.1** ទំព័រ ៤៣ ប្រហែលម៉ោង [១៣.៤៣.១៥]៖ "[...] គេអត់ដែលថាអីទៀតទេ។ ឈប់រករឿងតែម្តង រហូតដល់រំដោះ"។

ដែលគាត់សម្ភាសន៍។ គាត់ក៏បានយកចិត្តទុកដាក់ប្រមូលទិន្នន័យអំពីកាលវេលានិងទីកន្លែងអាកាសដែលអាចឱ្យគាត់កំណត់បាននូវការប្រែប្រួលទៅតាមទីកន្លែង និងពេលវេលា និងការប្រែប្រួលទៅតាមអាជ្ញាធរមូលដ្ឋាន។[2492]

២៤៤៧. ទោះបីអ្នកជំនាញទាំងពីរមានវិធីសាស្ត្រស្រាវជ្រាវខុសគ្នាក៏ដោយ ក៏ជាលទ្ធផលពួកគាត់ទាញការសន្និដ្ឋានស្រដៀងៗគ្នាដែរ។

២៤៤៨. Kasumi NAKAGAWA និយាយអំពីអត្ថិភាពនៃគោលនយោបាយ និងការលួចស្តាប់គូស្រករ៖

> "ខ្ញុំគិតថាមានគោលនយោបាយដែលបង្កើតឡើងនៅថ្នាក់លើ វាជាគោលនយោបាយដើម្បីរៀបចំការរៀបជាសមូហភាព ប៉ុន្តែខ្ញុំមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ថាពិតជាមានគោលនយោបាយដែលបង្កើតឡើងនៅថ្នាក់លើក្នុងបំណងរៀបចំការរៀបការដោយបង្ខំ"[2493]។
> "ខ្ញុំសុំទោស ខ្ញុំមិនមានភស្តុតាងដើម្បីឆ្លើយនឹងសំណួរលោកស្រី ប៉ុន្តែខ្ញុំដឹងថាមិនមែនគូស្រករទាំងអស់ទេដែលត្រូវបានគេលបស្តាប់នោះ។ វាអាស្រ័យទៅតាមអាជ្ញាធរមូលដ្ឋានដែលសម្រេចធ្វើឱ្យប្រជាជនភ័យខ្លាចកាន់តែខ្លាំងឡើង"[2494]។

២៤៤៩. Peg LEVINE ដែលត្រូវបានចោទសំណួរអំពីអត្ថិភាពនៃគោលនយោបាយជាតិ បានរៀបរាប់ដូចតទៅនេះ៖

---

[2492] ផេហ្គី ឡឺវ៉ាញ ប្រតិចារឹក ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/480.1** ទំព័រ ២៨-២៩ ប្រហែលម៉ោង [១៣.៥២.៣៨] ទំព័រ ៤៦-៤៧ ប្រហែលម៉ោង [១៥.០៦.០១] ទំព័រ ៤៧-៥០ ប្រហែលម៉ោង [១៥.១២.៥៥] ទំព័រ ៥៣-៥៤ ប្រហែលម៉ោង [១៥.៣១.២៧], ប្រតិចារឹក ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ E1/481.1** ទំព័រ ៣០-៣១ ប្រហែលម៉ោង [១០.៤៦.៤១] ទំព័រ ៣៣ ប្រហែលម៉ោង [១០.៥៦.១១] ទំព័រ ៣៣ ប្រហែលម៉ោង [១០.៥៦.១១]។

[2493] កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/472.1** ទំព័រ ៦៦ ប្រហែលម៉ោង [១៥.០៦.០៧]។ សូមមើលផងដែរ ផ្នែកនៃសក្ខីកម្មរបស់គាត់ទាក់ទងនឹងភាពខុសគ្នាទៅតាមមូលដ្ឋាន, ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/473.1** ទំព័រ ៥០ ប្រហែលម៉ោង [១៣.៥៥.០៩] ទំព័រ ៥៣ មុនម៉ោង [១៤.០៥.៤០]៖ "ហ្នឹងត្រឹមត្រូវហើយ។ ខ្ញុំបានឆ្លើយថា ខ្ញុំមិនអាចរកឃើញភស្តុតាងណាមួយដែលថាមានគោលនយោបាយថ្នាក់កណ្តាល គោលនយោបាយថ្នាក់ជាតិ ដាក់ចេញទៅថាបង្ខំឱ្យប្រជាជនរៀបការនៅទេ ឱ្យគូស្រកររៀបការជាមួយគ្នានោះទេ"។

[2494] ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ **ឯកសារ E1/473.1** ទំព័រ ៥៦ មុនម៉ោង [១៤.១៣.២៣]។

"ខ្ញុំសូមបញ្ជាក់ វាសំខាន់ណាស់ក្នុងការធ្វើការបញ្ជាក់នេះ។ ដោយសារតែប្រជាសាស្ត្រដែលជាមូលដ្ឋាននៃសំណួររបស់លោកស្រី ខ្ញុំមិនមានរារែកទាល់តែសោះក្នុងការជឿថាអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានថ្លែងរៀបរាប់ថាជាបទពិសោធន៍របស់គាត់ជាការពិត។ ប៉ុន្តែពាក់ព័ន្ធនឹងទំនោរ និងការសន្និដ្ឋានលើសំណួរដែលសួរថាតើការរៀបការទាំងអស់សុទ្ធតែត្រូវបានបង្ខំគ្រប់ពេលវេលា និងគ្រប់ទីកន្លែងក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?។ ចម្លើយរបស់ខ្ញុំគឺ ទេ"[2495]។

២៤៥០. វិធីសាស្ត្រស្រាវជ្រាវរបស់អ្នកជំនាញទាំងពីរធ្វើឱ្យយើងយកមកពិចារណា។ ជាក់ស្តែង ប្រសិនបើដូចអ្វីដែលបានកើតឡើងនៅចំពោះមុខ អ.វ.ត.ក ដែលមានតែករណីអាក្រក់ជ្រុលហួសផុតគេទាំងអស់ប៉ុណ្ណោះដែលត្រូវបានបង្ហាញជានិយាម ធាតុផ្សំភ័ស្តុតាងសុទ្ធតែត្រូវបំភ្លៃឱ្យខុសដើម្បីសន្និដ្ឋានថាមានគោលនយោបាយថ្នាក់ជាតិ និងដើម្បីកំណត់ផងដែរអំពីខ្លឹមសារដែលសន្មតទុកជាមុននៃគោលនយោបាយនេះ។ ត្រង់នេះ យើងសូមយោងទៅលើការកត់សម្គាល់បឋមរបស់យើងអំពីភ័ស្តុតាង និងលក្ខណៈពិសេសនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាភាគីក្នុងរឿងក្តី ដែលគេត្រូវការឱ្យផ្តន្ទាទោសជនជាប់ចោទ។[2496]

២៤៥១. ក្នុងបរិបទនេះ អង្គជំនុំជម្រះត្រូវតែចោទសំណួរសួរខ្លួនឯងអំពីភាពជាតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ។ មតិអន្តរជាតិ និងសង្គមស៊ីវិលចាប់អារម្មណ៍ទៅលើឧក្រិដ្ឋកម្មលើផ្លូវភេទ និងឧក្រិដ្ឋកម្មដែលមានមូលដ្ឋានប្រភេទនេះ។ គេមានសិទ្ធិចាប់អារម្មណ៍លើរឿងនេះ។ ទោះយ៉ាងនេះក្តី ក៏ទំនោរចង់ផ្តន្ទាទោសដើម្បីធ្វើជាគំរូ និងផ្តល់ចម្លើយជានិមិត្តរូបមិនត្រូវធ្វើឱ្យយើងភ្លេចច្បាប់ និងភ្លេចភាពស្ងប់ចិត្តប្រកបដោយសត្យានុម័តិ ដែលត្រូវតែជាមគ្គុទេសរបស់តុលាការមួយ។ ទោះយ៉ាងណាក្តី ក្នុងខណៈដែលពុំមានអត្ថិភាពនៅសម័យអង្គហេតុនៃឧក្រិដ្ឋកម្មរៀបការដោយបង្ខំដែលបង្កើតបានជាអំពើអមនុស្សធម៌ដទៃទៀត អង្គជំនុំជម្រះត្រូវតែនិយាយអំពីច្បាប់។ ហើយនេះទោះបីខ្លួនធ្វើការសន្និដ្ឋានលើអត្ថិភាពជាសន្មតនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាយ៉ាងណាក៏ដោយ ក៏ខ្លួនត្រូវតែនិយាយអំពីច្បាប់ដែរ។

---

[2495] ប្រតិចារឹក ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ **ឯកសារ** E1/481.1 ទំព័រ ២៩ ប្រហែលម៉ោង [១០.៤៤.៣៤]។

[2496] សូមមើលផ្នែកខាងលើ កថាខណ្ឌ ២៣២១-២៣២២។

## មាតិកាទី ៤. ទំនួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល

### ភាគទី ១. ការចោទប្រកាន់

២៤៥២. ខៀវ សំផន ត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ តាមរយៈទម្រង់នៃការចូលរួមផ្សេងៗគ្នា។ លើកលែងតែចំពោះឧក្រិដ្ឋកម្មមួយចំនួនប្រឆាំងនឹងក្រុមជាក់លាក់[2497] គាត់ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ តាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។[2498] លើសពីនេះទៅទៀត គាត់ត្រូវបានចោទប្រកាន់ថាបានបង្កើតផែនការ ញុះញង់ ជំរុញ និងលើកទឹកចិត្ត និងបានបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នេះ ហើយត្រូវបានចោទប្រកាន់ថា ជាអ្នកទទួលខុសត្រូវនៃឧក្រិដ្ឋកម្មទាំងអស់នេះក្នុងឋានៈជាមេ។[2499]

២៤៥៣. សហចៅក្រមស៊ើបអង្កេតបានសម្រេចជាលាយលក្ខអក្សរ និងច្បាស់លាស់ថាមិនចោទប្រកាន់គាត់ពីបទសហឧក្រិដ្ឋកម្មរួមទម្រង់ទីពីរទេ ប៉ុន្តែគាត់ត្រូវបានបញ្ជូនទៅជំនុំជម្រះពីបទបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ។[2500] យោងតាមសហចៅក្រមស៊ើបអង្កេត ខៀវ សំផន ជាមនុស្សម្នាក់ក្នុងចំណោម "មនុស្សដ៏សំខាន់ៗ" ផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួម[2501] ដែលផែនការរួមរបស់សមាជិកទាំងអស់គឺ៖

---

[2497] ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ក្នុងទម្រង់ជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរផ្សេងៗលើអនុសញ្ញាក្រុងហ្សឺណែវ៖ ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

[2498] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥, ១៥៣៦-១៥៣៧, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ៨។

[2499] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤៤-១៥៤៥, ១៥៤៧-១៥៤៨, ១៥៥០-១៥៥១, ១៥៥៣-១៥៥៤, ១៥៥៧-១៥៦០, ឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ **ឯកសារ E301/9/1.1** ទំព័រ ៨។

[2500] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤១។

[2501] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤០។

> "ផែនការរួមរបស់មេដឹកនាំបក្សកម្ពុជាប្រជាធិបតេយ្យ គឺធ្វើឱ្យសម្រេចបាននូវបដិវត្តន៍សង្គមនិយមឆាប់រហ័សនៅកម្ពុជា តាម "ជំហានមហាលោតផ្លោះ" និងការការពារប្រទេសប្រឆាំងទៅនឹងសត្រូវទាំងខាងក្នុង និងខាងក្រៅ តាមគ្រប់មធ្យោបាយចាំបាច់។ ផែនការរួមនេះពុំមែនមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ ប៉ុន្តែការធ្វើឱ្យសម្រេចផែនការរួមនេះរួមមាន ជាការប្រព្រឹត្តិនូវឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឬក៏ជាការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ"។[2502]

២៤៥៤. យោងតាមសហចៅក្រមស៊ើបអង្កេត ផែនការរួម "បានកើតឡើងតាំងពីមុនថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ទៅទៀត ហើយបានបន្តមានយ៉ាងហោចណាស់រហូតដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩"[2503]។ ផែនការនេះទំនងជាត្រូវបានពង្រីក "ចាប់ពីដើមឆ្នាំ ១៩៧៧" ទៅដល់អំពើប្រល័យពូជសាសន៍លើជនជាតិចាម និង "ចាប់ពីខែ មេសា ឆ្នាំ ១៩៧៧" ពង្រីកទៅដល់អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម។ មានការចោទប្រកាន់ថាចាប់តាំងពីពេលនោះមក៖

> "សមាជិកទាំងឡាយនៃសហឧក្រិដ្ឋកម្មរួមបានដឹងអំពីការណ៍ដែលថា ការធ្វើឱ្យបានសម្រេចនូវ ផែនការរួមត្រូវបានពន្លាតផងដែរដល់ការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ទៅលើក្រុមមនុស្សដែលទទួលបានការការពារទាំងនេះ។ ការដែលថា សមាជិកទាំងឡាយនៃសហឧក្រិដ្ឋកម្មរួមទទួលយកការបង្កើនមធ្យោបាយប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមធ្យោបាយនេះត្រូវបានប្រើប្រាស់ដើម្បីធ្វើឱ្យបាន សម្រេចនូវផែនការរួម មានន័យថា សមាជិកទាំងនោះមានចេតនាក្នុងការ ធ្វើឱ្យបានសម្រេចនូវផែនការនោះតាមរយៈអំពើប្រល័យពូជសាសន៍"[2504]។

២៤៥៥. ដោយហេតុថា ខៀវ សំផន ត្រូវបានផ្តន្ទាទោសជាស្ថាពរក្នុងសំណុំរឿង ០០២/០១ ពីបទចូលរួមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មិនរើរវាយអ្វីទាល់តែសោះទេលើលទ្ធផលនៃសំណុំរឿង ០០២/០២ នោះទេ។ ទោះបីជាគាត់នឹងបន្តបដិសេធការសន្និដ្ឋានរបស់អង្គជំនុំជម្រះ និងរបស់អង្គជំនុំជម្រះតុលាការកំពូលលើតួនាទី និងការចូលរួមចំណែកក្នុងឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ជាប់រហូតក៏ដោយ ក៏គាត់មើលឃើញថាវាគ្មានប្រយោជន៍អ្វី

[2502] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៤។

[2503] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៨។

[2504] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៧។

ទាល់តែសោះ ក្នុងការនិយាយលម្អិតនៅក្នុងសំណុំរឿង ០០២/០២ អំពីទស្សនៈដែលគាត់បានលើកឡើងជារៀងរហូត និងដែល អ.វ.ត.ក គ្មានថ្ងៃនឹងយកត្រចៀកស្តាប់នោះឡើយ[2505]។

២៤៥៦. ឥឡូវនេះ វាច្បាស់ណាស់ថាតុលាការនេះកាត់ក្តីរបបមួយ គឺមិនកាត់ក្តីបុគ្គលទេ។ បើសិនអង្គជំនុំជម្រះសម្រេចចិត្តអនុវត្តវិធានច្បាប់ស្តីអំពីទំនួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល និងអនុវត្តវិធានស្តីពីការពិនិត្យភ័ស្តុតាងប្រកបដោយភាពមិនលម្អៀងវិញនោះ អង្គជំនុំជម្រះប្រហែលជាមិនអាចផ្តន្ទាទោសលោក ខៀវ សំផន ទេ។

២៤៥៧. នៅក្នុងផ្នែកស្តីពីទំនួលខុសត្រូវរបស់ ខៀវ សំផន នេះ ក្រុមមេធាវីការពារក្តីចង់ផ្តោតសំខាន់ទៅលើការរំលឹកពីកត្តាជាមូលដ្ឋានផ្នែកច្បាប់មួយចំនួនស្តីអំពីនិយមន័យនៃទម្រង់ទំនួលខុសត្រូវ (ផ្នែកទីII) និងស្តីអំពីការប្រើប្រាស់សុន្ទរកថាដើម្បីចាប់គាត់ឱ្យទទួលខុសត្រូវ (ផ្នែកទីIII)។

## ភាគទី ២. និយមន័យនៃទម្រង់នៃការទទួលខុសត្រូវ

### ជំពូកទី ១. សហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ

២៤៥៨. សហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ គឺជាទម្រង់នៃទំនួលខុសត្រូវដែលត្រូវបានកំណត់និយមន័យលើកទីមួយដោយតុលាការចំពោះកិច្ចដោយផ្អែកលើអត្ថបទគតិយុត្ត និងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២[2506]។

#### ផ្នែកទី ១. ធាតុផ្សំសត្យានុម័តិ

២៤៥៩. ធាតុផ្សំសត្យានុម័តិនៃសហឧក្រិដ្ឋកម្ម រួមមានធាតុផ្សំបី៖

---

[2505] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល នៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ **ឯកសារ** E295/6/4, សេចក្តីសន្និដ្ឋានការពារ ថ្ងៃទី ២៥, ២៨ និង ៣១ ខែ តុលា ឆ្នាំ ២០១៣ **ឯកសារ E1/234.1 ឯកសារ E1/235.1 ឯកសារ E1/237.1**,សារណាបណ្តឹងសាទុក្ខ ០០២/០១។

[2506] សូមមើលផ្នែកខាងលើ កថាខណ្ឌ ៤៣២-៤៣៧។

១. បុគ្គលច្រើននាក់ដែលមិនចាំបាច់តែរៀបចំជារចនាសម្ព័ន្ធយោធា នយោបាយ ឬរដ្ឋបាល។[2507] ដើម្បីឱ្យអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមជាប់ទំនួលខុសត្រូវនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយបុគ្គលម្នាក់ផ្សេងទៀត គេត្រូវបង្ហាញឱ្យឃើញថាឧក្រិដ្ឋកម្មនេះ ជាទំនួលខុសត្រូវរបស់សមាជិកម្នាក់ក្នុងចំណោមសមាជិកទាំងអស់នៃសហឧក្រិដ្ឋកម្មរួម ហើយបុគ្គលរូបនេះ ដែលប្រើប្រាស់ជនដៃដល់ បានធ្វើសកម្មភាពស្របតាមផែនការរួម។ អត្ថិភាពនៃទំនាក់ទំនងនេះ ត្រូវតែត្រូវបានវាយតម្លៃតាមករណីនីមួយៗ។[2508]

២. អត្ថិភាពនៃផែនការរួមដែលមានបំណងប្រព្រឹត្តឧក្រិដ្ឋកម្ម ឬតម្រូវឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម[2509] ទោះបីជាមធ្យោបាយឧក្រិដ្ឋដើម្បីអនុវត្តសហឧក្រិដ្ឋកម្មរួម អាចវិវត្តទៅតាមពេលវេលា និងរាលដាលទៅដល់ឧក្រិដ្ឋកម្មផ្សេងទៀតក្រៅពីឧក្រិដ្ឋកម្មដែលបានគ្រោងទុកពីដើមទីក៏ដោយ ក៏ភ័ស្តុតាងនៃការព្រមព្រៀងគ្នាលើការធ្វើឱ្យរាលដាល ត្រូវតែគោរពតាមល័ក្ខខ័ណ្ឌដូចគ្នា និងល័ក្ខខ័ណ្ឌស្តីអំពីការព្រមព្រៀងពីដំបូងទី។[2510] ម្យ៉ាងទៀត អង្គជំនុំជម្រះត្រូវតែបង្ហាញឱ្យឃើញថា សមាជិកនៃសហឧក្រិដ្ឋកម្មរួម ត្រូវបានជូនដំណឹងអំពីការពង្រីកមធ្យោបាយឧក្រិដ្ឋ និងបង្ហាញឱ្យឃើញថាពួក

---

[2507] សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២១២ នៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤៣០ យោងទៅលើសាលដីកា *Stakić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៦៤ និងយោងទៅលើ សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៧។

[2508] សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២១២ នៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤៣៣ និង ៤៣៤ យោងទៅលើសាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤១០ និង ៤១៣។

[2509] សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២១២ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤៣៧ យោងទៅលើសាលដីកា *Stakić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៦៤ និងយោងទៅលើ សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៧។

[2510] សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២១២ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤៤២ និង ៤៤៣ បានយោងទៅលើ សាលដីកា *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៦៣ និងយោងទៅលើ សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៧។

គេមិនបានធ្វើអ្វីទាំងអស់ដើម្បីរារាំងការពង្រីកនេះ ហើយនៅតែបន្តអនុវត្តការពង្រីកផែនការរួម។ អង្គជំនុំជម្រះក៏ត្រូវកំណត់ឱ្យបានច្បាស់លាស់ផងដែរ អំពីពេលវេលានៃការបញ្ចូលឧក្រិដ្ឋកម្មបន្ថែមទាំងនេះទៅក្នុងផែនការរួម។[2511]

៣. ការចូលរួមរបស់ជនជាប់ចោទទៅក្នុងគោលបំណងរួម ដែលតម្រូវឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម។[2512] ជនជាប់ចោទត្រូវតែចូលរួមដោយចិត្តឯង ទៅក្នុងផ្នែកណាមួយនៃផែនការរួម។[2513] ការចូលរួមចំណែកនេះ អាចជាការជួយ ឬការចូលរួមចំណែកក្នុងការសម្រេចផែនការរួម។[2514] ទោះបីជាការចូលរួមរបស់ជនជាប់ត្រូវតែជាល័ក្ខខ័ណ្ឌមួយដែលសំខាន់អត់មិនបានក៏ដោយ ក៏ការចូលរួមនេះត្រូវតែមានលក្ខណៈជាដុំកំភួន។[2515]

---

2511 សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២១២ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤៤៤ បានយោងទៅលើ សាលដីកា *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៧១, ១៧៥, ១៧៦, ១៩៣ និង ១៩៤ និងបានយោងទៅលើ សាលដីកា *Celebići* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ១៩២, ២៥២, ២៥៥ និង ២៥៦។

2512 សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២១២ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤៤៥ បានយោងទៅលើ សាលដីកា *Vasiljević* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ កថាខណ្ឌ ១០០ និងយោងទៅលើ សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៧។

2513 សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២១២ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤៤៦ បានយោងទៅលើ សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៩៦។

2514 សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២១២ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤៤៧ បានយោងទៅលើ សាលដីកា *Stakić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៦៤ និងបានយោងទៅលើ សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៧។

2515 សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២១២ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤៥០ បានយោងទៅលើ សាលដីកា *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ៦៧៥ និងបានយោងទៅលើ

## ផ្នែកទី ២. ធាតុផ្សំអត្តនោម័ត

២៤៦០. អង្គជំនុំជម្រះមួយអាចយល់ឃើញថាជនជាប់ចោទម្នាក់ពិតជាមានចេតនាចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម តែក្នុងករណីដែលគេអាចការទាញសេចក្ដីសន្និដ្ឋានតែមួយគត់ដោយសមហេតុផល ពីធាតុផ្សំនៃភ័ស្តុតាងដែលដាក់បង្ហាញចំពោះមុខអង្គជំនុំជម្រះ។[2516]

២៤៦១. ចំពោះសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ ចេតនាឧក្រិដ្ឋដែលជាល័ក្ខខ័ណ្ឌតម្រូវ គឺជាចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មជាក់លាក់មួយ ហើយអ្នកចូលរួមត្រូវតែមានចេតនានេះទាំងអស់គ្នា[2517]។ ដូច្នេះ ជនជាប់ចោទត្រូវតែមានចេតនាចូលរួមក្នុងការសម្រេចគោលបំណងរួមផង និងមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មផង។[2518]

---

សាលដីកា *Kvočka* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ៩៨។

[2516] សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ២១៤ ភាគ ១ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤៥១ បានយោងទៅលើ សាលដីកា *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ៦៨៥ និងបានយោងទៅលើ សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤២៩។

[2517] សាលដីកា *Stanišić et Simatović* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៧៧, សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២១៤, សាលដីកា *Stakić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៦៥, សាលដីកា *Vasiljević* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ កថាខណ្ឌ ១០១, សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៨។

[2518] សាលដីកា *Stanišić et Zupljanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣៧៥,សាលដីកា *Popović* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ១៣៦៩, សាលដីកា *Munyakazi* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ១៦០, សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៣៦៥។

២៤៦២. ជនជាប់ចោទត្រូវមានចេតនាប្រព្រឹត្តឧក្រិដ្ឋដូចគ្នា គឺមិនត្រឹមតែគ្រោងទុក ឬប៉ាន់ស្មានមុននោះទេ។[2519] សហឧក្រិដ្ឋកម្មទម្រង់ទីមួយ តម្រូវឱ្យមានភ័ស្តុតាងនៃចេតនាឧក្រិដ្ឋផ្ទាល់ ដោយហេតុថា ចេតនាប្រយោលមិនគ្រប់គ្រាន់ទេ។[2520]

២៤៦៣. ក្នុងក្របខណ្ឌនៃឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញដែលតម្រូវឱ្យមានចេតនាជាក់លាក់ គេត្រូវតែបង្ហាញឱ្យឃើញថា ជនជាប់ចោទមានចេតនារើសអើង ដូចគ្នានឹងសមាជិកនៃសហឧក្រិដ្ឋកម្មរួមដទៃទៀតទាំងអស់។[2521] ដូចគ្នាដែរ នៅក្នុងក្របខណ្ឌនៃអំពើប្រល័យពូជសាសន៍ គេត្រូវតែបង្ហាញឱ្យឃើញថា ជនជាប់ចោទមានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដូចសមាជិកដទៃទៀតទាំងអស់នៃសហឧក្រិដ្ឋកម្មរួម។[2522]

---

[2519] សាលដីកា *Sainović* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៤ កថាខណ្ឌ ១០១៤៖ “យោងតាមផែនការសហឧក្រិដ្ឋកម្មរួម ទម្រង់ ១ ជនជាប់ចោទត្រូវមានចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ និងមិនមែនគ្រាន់តែត្រឹមភាពអាចព្យាករណ៍បាននៃឧក្រិដ្ឋកម្មទាំងអស់នោះទេ” (ភាសាអង់គ្លេស)។ សូមមើលផងដែរ សាលដីកា *Karemera និង Ngirumpatse* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ ៥៦៤៖ “បញ្ហានៃ “ភាពព្យាករណ៍បាន” គឺពាក់ព័ន្ធនឹងទម្រង់ទូលាយនៃផែនការសហឧក្រិដ្ឋកម្មរួម និងពុំមែនពាក់ព័ន្ធនឹងទម្រង់មូលដ្ឋាននោះទេ”(ភាសាអង់គ្លេស)។

[2520] សាលក្រម *Stanišić និង Simatović* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ២ កថាខណ្ឌ ១២៥៨ និងកំណត់សម្គាល់ជើងទំព័រ ២១៩៣៖ “សហឧក្រិដ្ឋកម្មរួម ទម្រង់១ តម្រូវឲ្យមានចេតនា គឺចេតនាឧក្រិដ្ឋផ្ទាល់តែម្តង ហើយ [...] ការធ្វេសប្រហែសដោយចេតនា ឬចេតនាជាយថាហេតុណាមួយ គឺមិនគ្រប់គ្រាន់នោះទេ”។ សូមមើលផងដែរ កថាខណ្ឌ ២៣៣២៖ “ប៉ុន្តែ ដូចគ្នានឹងករណីខាងលើដែរ អង្គជំនុំជម្រះយល់ច្បាស់ថា ការបានដឹងបែបនេះ និងការយល់ព្រមទទួលយកហានិភ័យដែលថាឧក្រិដ្ឋកម្មអាចនឹងកើតមានឡើង គឺពិតជាមិនគ្រប់គ្រាន់ដើម្បីបង្ហាញឲ្យឃើញពីការទទួលខុសត្រូវ ដោយសារតែការបានចូលរួមក្នុងផែនការសហឧក្រិដ្ឋកម្មរួម ទម្រង់១ នោះឡើយ”។

[2521] សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ ភាគ ១ កថាខណ្ឌ ២១៤ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤៥៣ បានយោងទៅលើ សាលដីកា *Kvočka* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ១១០ និងបានយោងទៅលើ សាលក្រម *Krnojelac* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២ កថាខណ្ឌ ៤៨៧។

[2522] សាលក្រម *Karadžić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៤៩ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ១៧៤៥ បានយោងទៅលើ សាលដីកា ៩៨*bis Karadžić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៧៩ និង ៨៣។

## ផ្នែកទី ៣. សហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយដែលមានគោលបំណងផ្ទាល់មិនឧក្រិដ្ឋ

២៤៦៤. ទំនួលខុសត្រូវដែលត្រូវទទួលផ្អែកលើមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម ជាចម្បង តម្រូវឱ្យកំណត់អត្តសញ្ញាណនៃគោលបំណងឧក្រិដ្ឋរួម។[2523] ប្រសិនបើគោលបំណងផ្ទាល់មិនមានចរិតឧក្រិដ្ឋ យ៉ាងហោចណាស់ទាល់តែឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដើម្បីសម្រេចគោលបំណងរួម មានសារធាតុដូចនឹងសារសំខាន់នៃគោលបំណងនេះ។[2524]

២៤៦៥. ប្រសិនបើគោលបំណងផ្ទាល់ដែលត្រូវសម្រេចមិនមានចរិតឧក្រិដ្ឋ ចាំបាច់ត្រូវបែងចែករវាងអ្វីដែលឧក្រិដ្ឋ និងអ្វីដែលមិនឧក្រិដ្ឋរបស់ផែនការនេះ៖




---

[2523] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ២២៥ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ២២៥ បានយោងទៅលើ សាលដីកា *Krnojelac* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ កថាខណ្ឌ ១១៦។

[2524] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ២២៥ ដែលនៅក្នុងកំណត់សម្គាល់ជើងទំព័រ ២២៦ បានយោងទៅលើ សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២២៧ និងយោងទៅលើ សាលក្រម *Martić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៤២ និងយោងទៅលើ សាលដីកា *Martić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ១១២ ព្រមទាំងយោងទៅលើ សាលដីកា *Brima* (តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន) ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ៧៦។

២៤៦៦. ជានិច្ចកាល គេត្រូវតែបង្ហាញឱ្យឃើញជាដាច់ខាតថា "ជនជាប់ចោទមិនមែនគ្រាន់តែសេពគប់ឧក្រិដ្ឋជនទេ" ប៉ុន្តែគាត់ "មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម" "ជាប់ទំនាក់ទំនងជាមួយបុគ្គលដទៃទៀតដើម្បីសម្រេចគោលបំណងនេះ និងបានចូលរួមចំណែកយ៉ាងទូលំទូលាយក្នុងឧក្រិដ្ឋកម្ម"។[2525] ជាក់ស្តែង ក្នុងច្បាប់អន្តរជាតិ ក៏ដូចជាក្នុងច្បាប់ជាតិ គ្មាននរណាម្នាក់អាចត្រូវបានចាប់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើ ឬសកម្មភាពរួមគ្នាណាមួយ ដែលគាត់មិនបានចូលរួម ដោយផ្ទាល់ ឬមិនបានចូលរួមតាមលក្ខណៈណាមួយផ្សេងទៀត (គ្មានការផ្តន្ទាទោស បើគ្មានច្បាប់ចែង)[2526]

២៤៦៧. អាស្រ័យហេតុដូចនេះ គេត្រូវតែបង្ហាញឱ្យឃើញថា ជនជាប់ចោទមានចេតនាចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មចាំបាច់ដើម្បីសម្រេចគោលបំណងមិនឧក្រិដ្ឋរបស់ខ្លួន។ សហឧក្រិដ្ឋកម្មរួម "មិនមែនជាទស្សនទានគ្មានដែនកំណត់ ដែលអាចឱ្យទាញការសន្និដ្ឋានថា ជនជាប់ចោទមានពិរុទ្ធភាពដោយធ្វើការប្រៀបធៀបនោះទេ"។[2527] ម្យ៉ាងទៀត គ្រប់ប្រភេទនៃអាកប្បកិរិយាទាំងអស់ មិនមែនជាធាតុផ្សំនៃការចូលរួមចំណែកសំខាន់ក្នុងផែនការរួម ដែលអាចនាំឱ្យមានទំនួលខុសត្រូវសហឧក្រិដ្ឋកម្មរួមនោះទេ។[2528] អ្វីដែលសំខាន់ចំពោះច្បាប់ គឺការពិនិត្យថាតើជនជាប់ចោទមានចេតនាចង់ឱ្យមាន

[2525] សាលដីកា *Martić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ១៧២, សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៣១។

[2526] សាលដីកា *Martić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ៨២, សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៨៦។

[2527] សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤២៨។

[2528] សាលដីកា *Sainović* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៤ កថាខណ្ឌ ៩៨៨ ("អង្គជំនុំជម្រះតុលាការកំពូលសូមរំលឹកថា រាល់សកម្មភាពរបស់ជនជាប់ចោទ ពុំមែនសុទ្ធតែអាចផ្សំជាការចូលរួមក្នុងការអនុវត្តសហឧក្រិដ្ឋកម្មរួមឲ្យពេញលេញបាន ដើម្បីឲ្យជនជាប់ចោទទទួលខុសត្រូវព្រហ្មទណ្ឌបាននោះទេ") ដោយនៅក្នុង កំណត់សម្គាល់ជើងទំព័រ ៣២៤៧ បានយោងទៅលើ សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤២៧ (ជនជាប់ចោទ "ត្រូវតែបានចូលរួមក្នុងការធ្វើឱ្យសម្រេចបំណងរួម ដែលជាចំណុចស្នូលនៃផែនការនេះ" ហើយ"រាល់អំពើល្មើសរបស់ជនជាប់ចោទ ត្រូវផ្សំបានជាការចូលរួមចំណែកគ្រប់គ្រាន់ក្នុងអំពើឧក្រិដ្ឋកម្ម ដើម្បីដាក់ឱ្យគាត់ទទួលខុសត្រូវ")។

ការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងបានចូលរួមចំណែកជាដុំកំភួននៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលស្ថិតក្នុងសហឧក្រិដ្ឋកម្មរួមនេះដែរឬទេ។[2529]

២៤៦៨. ជនជាប់ចោទអាចត្រូវបានប្រកាសពិរុទ្ធភាព តែក្នុងករណីដែលលក្ខខ័ណ្ឌចាំបាច់ទាំងនេះត្រូវបានបំពេញឱ្យហួសពីវិមតិសង្ស័យ។[2530] ជាឧទាហរណ៍ វាជាការមិនសមហេតុផលទេ ក្នុងការទាញការសន្និដ្ឋានពីការដែលជនជាប់ចោទគ្រាន់តែចូលរួមក្នុងពិធីមួយ ថាគាត់មានចេតនាឧក្រិដ្ឋរួមដូចសមាជិកដទៃទៀតដែរ។[2531]

## ជំពូកទី ២. <u>ទម្រង់ទំនួលខុសត្រូវផ្សេងទៀតក្រៅពីសហឧក្រិដ្ឋកម្មរួម</u>

២៤៦៩. ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះមិនបានចាប់ឱ្យ ខៀវ សំផន ទទួលខុសត្រូវពីបទបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម និងពីឋានៈគាត់ជាមេនោះទេ។ រីឯអង្គជំនុំជម្រះតុលាការកំពូលវិញ បានចាប់ឱ្យគាត់ទទួលខុសត្រូវតែពីបទសហឧក្រិដ្ឋកម្មរួមតែប៉ុណ្ណោះ ដោយពុំបានពិនិត្យកំហុសអង្គច្បាប់ដែលលើកឡើងទាក់ទងនឹងការកំណត់និយមន័យរបស់អង្គជំនុំជម្រះស្តីអំពីការបង្កើតផែនការ ការញុះញង់ ការជួយ និងលើកទឹកចិត្ត។

២៤៧០. ផ្អែកលើមូលហេតុទាំងនេះ ក្រុមមេធាវីការពារក្តីយោងយ៉ាងច្បាស់លាស់ទៅទឡ្ហីករណ៍ ដែលមានរៀបរាប់លម្អិតនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ដែលយោងតាមទឡ្ហីករណ៍ទាំងនេះ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅសម័យនៃអង្គហេតុដែលចោទប្រកាន់ មិនមានចេតនាណាមួយដែលមានកម្រិតទាបជាងចេតនាផ្ទាល់ពាក់ព័ន្ធនឹងការ

---

[2529] សាលដីកា *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ៦៩៦ ("លើទិដ្ឋភាពច្បាប់ អ្វីដែលសំខាន់គឺជនជាប់ចោទបានចូលរួមយ៉ាងសំខាន់ក្នុងការប្រព្រឹត្ត<u>ឧក្រិដ្ឋកម្មទាំងឡាយ</u>ដែលជាធាតុផ្សំនៃផែនការសហឧក្រិដ្ឋកម្មរួម" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)) យោងទៅលើ សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៣០។

[2530] សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤២៨។

[2531] សាលដីកា *Mugenzi និង Mugiraneza* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ១៣៩ និងជាទូទៅ កថាខណ្ឌ ១៣៦-១៤១។

បង្កើតផែនការ ការញុះញង់ ការជួយ និងលើកទឹកចិត្ត។[2532] ទាក់ទងនឹងការចេញបញ្ជា ក្រុមមេធាវីការពារក្តីសុំយោងទៅទឡ្ហីករណ៍ដែលនិយាយលម្អិតក្នុងខ្លឹមសារដូចគ្នាដោយមេធាវី នួន ជា នៅក្នុងសារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១។[2533] ដោយឡែក ក្រុមមេធាវីការពារក្តីគាំទ្រនិយមន័យដែលអង្គជំនុំជម្រះបានផ្តល់ស្តីអំពីទំនួលខុសត្រូវក្នុងឋានៈជាមេ។[2534]

## ភាគទី ៣. សុន្ទរកថាបញ្ឆេះកំហឹង និងការឃោសនាសង្គ្រាម

២៤៧១. ដោយហេតុថា ខៀវ សំផន ត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ ពីបទឧក្រិដ្ឋកម្មរើសអើងប្រល័យពូជសាសន៍ និងធ្វើទុក្ខបុកម្នេញដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្របតាមសហឧក្រិដ្ឋកម្មរួម ពីបទញុះញង់ ការជួយ និងលើកទឹកចិត្ត គួរគប្បីពិនិត្យឱ្យល្អិតល្អន់បំផុតទៅលើតួនាទីនៃសុន្ទរកថាទាំងនេះ។

២៤៧២. យោងតាមយុត្តិសាស្ត្រអន្តរជាតិ វាមានសារៈសំខាន់ដោយអត់មិនបានក្នុងការធ្វើការបែងចែករវាងម្យ៉ាង សុន្ទរកថាដែលគេហៅជាទូទៅថា "សុន្ទរកថាបញ្ឆេះកំហឹង" ដែលញុះញង់ឱ្យស្អប់ប្រជាជនមួយក្រុម សហគមន៍មួយ និងជួនកាលក្នុងកម្រិតដ៏ហួសហេតុបំផុត រហូតដល់ញុះញង់ឱ្យធ្វើទុក្ខបុកម្នេញ ឬឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងម្យ៉ាងទៀត សុន្ទរកថាដែលសំដៅឃោសនាពេលធ្វើសង្គ្រាមក្នុងគោលបំណងគាំទ្រការប្រឹងប្រែងក្នុងសង្គ្រាម និងផ្តល់កម្លាំងចិត្តដល់ក្រុមកងទ័ព។

---

[2532] សារណាបណ្តឹងសាទុក្ខ ០០២/០១ កថាខណ្ឌ ៧៤-៧៩ (ការរៀបចំផែនការ) កថាខណ្ឌ ៨០-៨៦ (ការញុះញង់) កថាខណ្ឌ ៨៧-៩២ (ការជួយ និងជំរុញ) កថាខណ្ឌ ៩៣-៩៩ (ការចូលរួមតាមរយៈអំពើអកម្ម) កថាខណ្ឌ ១០៥-១០៧ (ភាពអាចយល់ដឹងបាន និងភាពអាចប្រមើលមើលបាន)។

[2533] បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ **ឯកសារ F16** កថាខណ្ឌ ៦៧៤-៦៧៩។

[2534] សាលក្រម ០០២/០១ កថាខណ្ឌ ៧១៥-៧១៦។

២៤៧៣. វាជាការចាំបាច់ណាស់ក្នុងការត្រលប់មកនិយាយអំពីសញ្ញាណដ៏សំខាន់នៃសិទ្ធិសេរីភាពបញ្ចេញមតិ និងដែនកំណត់របស់វា ក្នុងករណីញុះញង់ឱ្យរើសអើង និងស្អប់ខ្ពើម ក៏ដូចជាការទទួលយកប្រភេទឃោសនាផ្សេងៗ (១) មុននឹងពិចារណាលើយុត្តិសាស្ត្រសម័យក្រោយសង្គ្រាមលោកលើកទីពីរ (២) និងយុត្តិសាស្ត្ររបស់តុលាការចំពោះកិច្ច (៣) ដែលពាក់ព័ន្ធចំពោះអង្គហេតុនៃសំណុំរឿងនេះ។

**ជំពូកទី ១. ការសង្ខេបស្ថានភាពនៃច្បាប់អន្តរជាតិស្តីពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការញុះញង់ឱ្យប្រព្រឹត្តអំពើរើសអើង និងការឃោសនា**

២៤៧៤. សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងដែនកំណត់របស់វា ត្រូវបានពិនិត្យដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានវិភាគសុន្ទរកថា ឬសេចក្តីថ្លែងការណ៍ដទៃទៀតរបស់ជនជាប់ចោទ ដែលបានញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬញុះញង់ចារីសំខាន់ៗឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ធ្វើទុក្ខបុកម្នេញ ឬឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។[2535]

២៤៧៥. ជាក់ស្តែង លិខិតតូបករណ៍ច្បាប់អន្តរជាតិជាច្រើន បានចាត់ទុកសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិជាសិទ្ធិជាមូលដ្ឋាន។[2536] ក៏ប៉ុន្តែ សិទ្ធិនេះមិនមានលក្ខណៈដាច់ខាត ហើយលិខិតគតិយុត្តអន្តរជាតិទាំងនេះ ការពារមនុស្សគ្រប់រូបប្រឆាំងនឹងការរើសអើង ប្រឆាំងនឹងការអំពាវនាវឱ្យមានការស្អប់ខ្ពើមជាតិសាសន៍ ឬសាសនា។ ប្រភេទនៃការឃោសនាមួយចំនួនត្រូវបានហាមឃាត់ជាពិសេសដោយអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍។ មាត្រាទី ៥ នៃអនុសញ្ញានេះ ចែងថា ៖

---

[2535] ឧទាហរណ៍៖ សាលក្រម *Bikindi* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៣៧៨-៣៨៥។

[2536] ឧទាហរណ៍ សូមមើល៖ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១៩, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៩, អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ មាត្រា ៥, អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស មាត្រា ១០-១, អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស មាត្រា ១៣-១, ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងប្រជាជន មាត្រា ៩។

"រដ្ឋជាភាគីថ្កោលទោសរាល់ការឃោសនា និងការរៀបចំទាំងឡាយណាដែលមានគំនិត ឬទស្សនៈដែលផ្អែកលើឧត្តមភាពនៃពូជសាសន៍ នៃក្រុមមនុស្សណាមួយទៅតាមពណ៌សម្បុរ ឬប្រភពជាតិពន្ធុ ឬដែលមានបំណងផ្តល់ហេតុផល ឬលើកទឹកចិត្តរាល់ទម្រង់នៃការស្អប់ខ្ពើម និងការរើសអើងពូជសាសន៍ [...]"។

២៤៧៦. ទោះបីជាការញុះញង់ឱ្យមានការរើសអើង ឬការឃោសនាលើកកម្ពស់ឧត្តមភាពនៃពូជសាសន៍មួយ ត្រូវបានហាមឃាត់ក្នុងច្បាប់អន្តរជាតិក៏ដោយ ក៏ជាទូទៅក្នុងពេលសង្គ្រាម ការឃោសនាត្រូវបានអនុញ្ញាតដោយស្របច្បាប់ក្នុងច្បាប់មនុស្សធម៌អន្តរជាតិ។ ឧទាហរណ៍ មាត្រា ២១ នៃវិធានស្តីអំពីសង្គ្រាមអាកាសរបស់តុលាការក្រុងឡាអេឆ្នាំ១៩២៣ អនុញ្ញាតឱ្យប្រើប្រាស់អាកាសនាវាដើម្បីផ្សព្វផ្សាយសារឃោសនា។[2537]

២៤៧៧. នៅពេលពិភាក្សាដើម្បីតាក់តែងសន្ធិសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មានការបែងចែករវាងការឃោសនាដែលមានទិសដៅញុះញង់ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងការឃោសនាសង្គ្រាម។ អាស្រ័យហេតុដូចនេះ របាយការណ៍នៃការពិភាក្សានេះបានកត់ត្រាពាក្យពេចន៍នៃប្រតិភូរបស់ប្រទេសលីបង់ដូចតទៅនេះ៖

*"លោក AZKOUL (ប្រទេសលីបង់) បានជំរុញពីភាពចាំបាច់នៃការដាក់បញ្ចូលអំពើនៃការឃោសនាដែលមានចែងក្នុងអនុសញ្ញា ដែលបង្កើតជាការរៀបចំផ្លូវចិត្តសម្រាប់បទឧក្រិដ្ឋស្តីពីអំពើប្រល័យពូជសាសន៍។ ក៏ប៉ុន្តែ គាត់ចង់លើកឡើងនូវការលំបាកមួយ៖ នៅពេលមានសង្គ្រាម វាជារឿងធម្មតាដែលរដ្ឋត្រូវធ្វើការគាបសង្កត់ ហើយយុទ្ធនាការឃោសនាតាមវិទ្យុមានគោលបំណងបញ្ឆេះការស្អប់ខ្ពើមប្រឆាំងខ្មាំងសត្រូវ។ វាច្បាស់លាស់គឺថា យុទ្ធនាការទាំងនេះដែលជួយលើកម្ពស់ស្មារតីរបស់ពលរដ្ឋរបស់ខ្លួន មិនគួរត្រូវបានចាត់ទុកថាជាការឃោសនា ដែលញុះញង់ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទេ។"*[2538]

---

[2537] វិធានពាក់ព័ន្ធនឹងការគ្រប់គ្រងវិទ្យុទូរលេខក្នុងពេលមានសង្គ្រាម និងសង្គ្រាមតាមផ្លូវអាកាសកំណត់ដោយគណៈកម្មាធិការអ្នកច្បាប់ នៅទីក្រុងឡាអេ ធ្នូ ១៩២២-កុម្ភៈ ១៩២៣, មាត្រា ២១, សូមមើលតាមតំណភ្ជាប់៖ https://ihl-databases.icrc.org/dih-traites/WebART/275-370033?OpenDocument.។

[2538] កំណត់ហេតុ E/AC.25/SR.5 ទំព័រ ១០ អាចរកមើលបានតាមរយៈតំណភ្ជាប់៖ http://dag.un.org/bitstream/handle/11176/264904/E_AC.25_SR.5-EN.pdf?sequence=1&isAllowed=y. (ភាសាអង់គ្លេស)។

២៤៧៨. ប្រតិភូនៃប្រទេសបារាំង និងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត មានមតិយោបល់ថា ការបែងចែកនេះ និងការបកស្រាយអត្ថបទឃោសនាទាំងនេះ ជាកាតព្វកិច្ចរបស់តុលាការមានសមត្ថកិច្ច[2539]។

២៤៧៩. ចំពោះអត្ថបទច្បាប់មនុស្សធម៌អន្តរជាតិ ការឃោសនាត្រូវបានទទួលយកជាទូទៅថាជា "ឧបាយកលសង្គ្រាម គឺជាវិធីសាស្ត្រសង្គ្រាមមួយដែលមិនត្រូវបានហាមឃាត់ទេ វាផ្ទុយពីអំពើវៀចវេរមិនកាន់សច្ចធម៌។ មាត្រាទី ៣៧ នៃពិធីសាបន្ថែម I ឆ្នាំ១៩៧៧ និយាយអំពីវិធីសាស្ត្រសង្គ្រាមទាំងពីរនេះ។ ផ្ទុយទៅវិញ ច្បាប់មនុស្សធម៌អន្តរជាតិហាមឃាត់រាល់ការញុះញង់ឱ្យវាយប្រហារ ឬប្រើអំពើហិង្សាប្រឆាំងនឹងប្រជាជនស៊ីវិល។[2540] ដូច្នេះ ទោះបីជាសុន្ទរកថាមិនពាក់ព័ន្ធដោយផ្ទាល់ជានិច្ចជាកាលក៏ដោយ ក៏ច្បាប់មនុស្សធម៌អន្តរជាតិមិនហាមឃាត់ការប្រើប្រាស់ការឃោសនា ដរាបណាការឃោសនានេះគោរពតាមវិធានច្បាប់មនុស្សធម៌អន្តរជាតិ។

## ជំពូកទី ២. យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ

២៤៨០. វាគួរឱ្យចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការវិភាគ និងប្រៀបធៀបរឿងក្តីពីរដែលត្រូវបានជំនុំជម្រះដោយតុលាការយោធាអន្តរជាតិ ដូចជារឿងក្តី *Streicher* ដែលត្រូវបានផ្តន្ទាទោសពីបទញុះញង់ឱ្យប្រព្រឹត្តអំពើមនុស្សឃាត និងការសម្លាប់រង្គាល (ផ្នែកទី I) និងរឿងក្តី *Fritzsche* ដែលត្រូវបានលើកលែងការចោទប្រកាន់ពីបទចោទដូចគ្នា (ផ្នែកទី II)។ រឿងក្តីទាំងនេះមានភាពពាក់ព័ន្ធ បើយើងគិតអំពីអង្គហេតុនៃរឿងក្តីនេះ ដោយហេតុថាជនជាប់ចោទត្រូវបានចោទប្រកាន់ជាពិសេសលើសុន្ទរកថា និងការផ្សព្វផ្សាយការឃោសនារបស់ពួកគេក្នុងអំឡុងរបបណាស៊ី។

### ផ្នែកទី ១. រឿងក្តី *Streicher*

---

[2539] កំណត់ហេតុ E/AC.25/SR.5 ទំព័រ ១២ (ភាសាអង់គ្លេស)។

[2540] ពិធីសារបន្ថែម I មាត្រា ៥១(១), មាត្រា ៥៧(២)(ក)(i)។

២៤៨១. អ្នកបោះពុម្ពផ្សាយ និងនិពន្ធនាយកនៃកាសែតប្រចាំសប្តាហ៍ប្រឆាំងនឹងជនជាតិជ្វីហ្វ *Stricher* ត្រូវបានផ្តន្ទាទោសពីបទញុះញង់មនុស្សឃាត និងការសម្លាប់រង្គាលស្របតាមមាត្រា ៦-គ នៃធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ[2541]។ តុលាការនេះបានសង្កត់ធ្ងន់លើចំនួនអត្ថបទកាសែតដែលមានសេចក្តីប្រកាសឱ្យស្អប់ខ្ពើម៖ "ចាប់តាំងពីឆ្នាំ ១៩៣៨ គាត់បានចាបផ្តើមសុំឱ្យកម្ទេចពូជសាសន៍ជ្វីហ្វ។ អត្ថបទកាសែត *Der Sturmer* ចំនួន២៣ដែលត្រូវបានសរសេរចន្លោះឆ្នាំ ១៩៣៨ និងឆ្នាំ ១៩៤១ និងដែលណែនាំឱ្យ "កម្ទេច" ជនជាតិជ្វីហ្វ ត្រូវបានដាក់ឱ្យពិភាក្សាដេញដោល សម្រាប់ជាឧទាហរណ៍មានលក្ខណៈសម្គាល់នៃការបង្រៀនរបស់គាត់"។ បន្ទាប់មក តុលាការនេះបានដកស្រង់ឧទាហរណ៍មួយចំនួននៃសេចក្តីថ្លែងការណ៍ទាំងនេះ ដែលក្នុងនោះមាន៖

> "វិចារណកថាមួយដែលចេញផ្សាយនៅខែ កញ្ញា ឆ្នាំ ១៩៣៨ ចាត់ទុកជនជាតិជ្វីហ្វជា "មេរោគ" ជាមហន្តរាយ និងប្រកាសថាជនជាតិជ្វីហ្វមិនមែនជាមនុស្ស និងចោទប្រកាន់ថាជា "បញ្ញើក្អែក" ជាសភាវៈចង្រៃទុច្ចរិតជន និងជាអ្នកចម្លងជំងឺដែលត្រូវតែកម្ទេចដើម្បីជាប្រយោជន៍ដល់មនុស្សជាតិ"។ អត្ថបទដទៃទៀតប្រកាសថា បញ្ហាជនជាតិជ្វីហ្វអាចដោះស្រាយបានលុះត្រាណាតែ "សហគមន៍ជ្វីហ្វទូទាំងពិភពលោក" ត្រូវបានកម្ទេចឱ្យក្លាយជាផេះ ហើយបានទាយទុកជាមុនថា ពីពេលនេះទៅ៥ឆ្នាំខាងមុខ ផ្នូររបស់ជនជាតិជ្វីហ្វនឹង "បញ្ជាក់ថាប្រជាជនឧក្រិដ្ឋ និង ឃាតករនេះ ប្រាកដជាបានទទួលជោគវាសនាដ៏សាកសមចំពោះខ្លួន"។ [...] នៅខែ កុម្ភៈ ឆ្នាំ ១៩៤៤ គាត់បានអះអាងនៅក្នុងអត្ថបទមួយដែលគាត់ចុះហត្ថលេខាដោយផ្ទាល់ដៃថា៖ "ជនណាប្រព្រឹត្តដូចជនជាតិជ្វីហ្វ គឺជាពួកយ៉ូកូម និងឧក្រិដ្ឋជន។ ហើយអ្នកដែលនិយាយតាមជនជាតិជ្វីហ្វ ឬចង់ធ្វើតាមពួកគេ សាកសមនឹងទទួលបានជោគវាសនាដូចពួកគេ គឺទទួលបានការសម្លាប់ឱ្យផុតពូជ សេចក្តីស្លាប់"

២៤៨២. លើសពីនេះទៅទៀត *Striecher* បានបន្តសរសេរ និងបោះពុម្ពការឃោសនានេះ ក្នុងខណៈដែលគាត់ដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅអាល្លឺម៉ង់ខាងកើតប្រឆាំងនឹងជនជាតិជ្វីហ្វ។ ដូច្នេះ តុលាការយោធាអន្តរជាតិបានសន្និដ្ឋានថា៖

> "ការដែល *Striecher* ជំរុញឱ្យប្រព្រឹត្តបទមនុស្សឃាត និងសម្លាប់ឱ្យផុតពូជនៅសម័យដែលនៅភាគខាងកើត ជនជាតិជ្វីហ្វត្រូវបានសម្លាប់រង្គាលនៅក្នុងលក្ខណ្ឌគួរឱ្យរន្ធត់បំផុត សម្រេចបាននូវ "ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍" ដែលមានចែងក្នុងចំណោមឧក្រិដ្ឋកម្មសង្គ្រាម និងមានកំណត់ដោយលក្ខន្តិកៈ ហើយជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងដែរ"។

[2541] សាលក្រមតុលាការយោធាអន្តរជាតិ សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹង *Streicher*។

## ផ្នែកទី ២. រឿងក្តី *Fritzsche*

២៤៨៣. *Fritzsche* ដឹកនាំភ្នាក់ងារសារព័ត៌មានមួយរបស់រដ្ឋាភិបាលអាល្លឺម៉ង់ ដែលត្រូវបានបញ្ចូលទៅក្នុងក្រសួងណាហ្ស៊ីទទួលបន្ទុកខាងឃោសនាការ និងបន្ទាប់មក គាត់ត្រូវបានតែងតាំងជាប្រធានផ្នែកសារព័ត៌មានជាតិនៅក្នុងក្រសួងនោះ។[2542] គាត់ត្រូវបានចោទប្រកាន់ជាពិសេសពីបទបញ្ឆុះបញ្ចូលលើកទឹកចិត្ត និងជំរុញឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយផ្អែកទាំងស្រុងលើសកម្មភាពឃោសនាការរបស់គាត់។

២៤៨៤. ក្រៅពីមុខងារដ៏សំខាន់ៗរបស់គាត់នៅក្នុងការផ្សព្វផ្សាយឃោសនាមុនពេលសង្គ្រាម និងនៅពេលចាប់ផ្តើមសង្គ្រាម តុលាការយោធាអន្តរជាតិបានអះអាងថា នៅទីបញ្ចប់នៃសង្គ្រាម៖

> "*Frietsche* ក្លាយជាមនុស្សតែម្នាក់គត់ដែលប្រើអំណាចនៅក្នុងការផ្សព្វផ្សាយវិទ្យុនៅក្រសួង។ ក្នុងឋានៈនេះ គាត់តាក់តែង និងផ្សព្វផ្សាយ "ពាក្យសម្តី" ប្រចាំថ្ងៃរបស់វិទ្យុដែលផ្សព្វផ្សាយទៅដល់អង្គភាពឃោសនាការទាំងអស់នៃចក្រភពអាល្លឺម៉ង់ និងពាក្យសម្តីដែលស្របតាមគោលនយោបាយទូទៅរបស់របបណាហ្ស៊ី។ ពាក្យសម្តីទាំងនេះត្រូវតែគោរពតាមការណែនាំរបស់ការិយាល័យនយោបាយស្តីពីការផ្សព្វផ្សាយវិទ្យុរបស់ក្រសួងការបរទេស និងត្រូវតែគោរពតាមការត្រួតពិនិត្យរបស់ Goebbels"។

២៤៨៥. បន្ទាប់មកទៀត តុលាការយោធាអន្តរជាតិបានកត់សម្គាល់ថា៖

> "សម្រង់នៃសុន្ទរកថារបស់គាត់ត្រូវបានដកស្រង់នៅក្នុងសាលសវនាការ ដែលបង្ហាញឱ្យឃើញអំពីការរើសអើងផ្តាច់មុខចំពោះជនជាតិជ្វីហ្វ។ ដូច្នេះ គាត់បានប្រកាសតាមវិទ្យុថា សង្គ្រាមត្រូវបានបង្កដោយជនជាតិជ្វីហ្វ ហើយជោគវាសនារបស់ពួកនេះនឹងវេទនាតាមទំនាយរបស់អ៊ីត្លែ។ ប៉ុន្តែ សុន្ទរកថាទាំងនេះមិនបានជំរុញឱ្យធ្វើទុក្ខបុកម្នេញ ឬសម្លាប់ជនជាតិជ្វីហ្វឱ្យផុតពូជនោះទេ។ ពុំមានភ័ស្តុតាងអ្វីបង្ហាញថាគាត់បានដឹងឮអំពីការសម្លាប់ជនជាតិជ្វីហ្វឱ្យផុតពូជនៅភាគខាងកើតនៃប្រទេសអាល្លឺម៉ង់ឡើយ"។

[2542] សាលក្រមតុលាការយោធាអន្តរជាតិ សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹង *Fritzsche*។

២៤៨៦. លើសពីនេះទៅទៀត តុលាការយោធាអន្តរជាតិបានធ្វើការបែងចែកដ៏ច្បាស់លាស់មួយ រវាងការឃោសនាជំរុញឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់ និងការឃោសនាបង្កើតបរិយាកាសសង្គ្រាមទូទៅមួយ ដោយសន្និដ្ឋានថា៖

> "វាហាក់ដូចជា មួងម្កាល *Frietsche* បានធ្វើសេចក្តីប្រកាសយ៉ាងភ្លៀវភ្លាដែលគ្មានអ្វីផ្សេងក្រៅពីការឃោសនា។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏តុលាការទាញការសន្និដ្ឋានថា សេចក្តីថ្លែងការណ៍ទាំងនេះមានគោលបំណងញុះញង់ជនជាតិអាល្លឺម៉ង់ឱ្យប្រព្រឹត្តអំពើឃោរឃៅទៅលើប្រជាជនដែលទទួលរងការឈ្លានពាន។ ដូច្នេះ គេមិនអាចចោទប្រកាន់គាត់ថាបានចូលរួមក្នុងឧក្រិដ្ឋកម្មទាំងនេះនោះទេ។ តាមពិត គាត់ចង់បំផុសឱ្យមានចលនាមតិគាំទ្រអ៊ីត្លែ និងការជួយជ្រោមជ្រែងសង្គ្រាម"។ (យើងជាអ្នកគូសបន្ទាត់ពីក្រោម)

### ជំពូកទី ៣. យុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ

២៤៨៧. តុលាការចំពោះកិច្ចបានពិចារណាអំពីសុន្ទរកថារបស់ជនជាប់ចោទមួយចំនួន និងផលប៉ះពាល់របស់វាទៅលើជនដៃដល់។ ក្នុងរឿងក្តីជាច្រើនដែលយុត្តិសាស្ត្រត្រូវបានដកស្រង់ក្នុងរឿងក្តីមួយនេះ លើកឡើងជាពិសេសអំពីការញុះញង់ជាសាធារណៈ និងដោយផ្ទាល់ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែលវាជាឧក្រិដ្ឋកម្មមួយទៅហើយ ហើយមិនមែនជាទម្រង់នៃទំនួលខុសត្រូវនោះទេ។ ទោះបីជាមានភាពខុសគ្នានេះក៏ដោយ ក៏យើងអាចទាញមេរៀនជាច្រើនចំពោះធាតុផ្សំដែលត្រូវតែយកមកគិតពិចារណាដើម្បីវិភាគសុន្ទរកថា និងសេចក្តីថ្លែងការណ៍ទាំងអស់របស់ជនជាប់ចោទរួមមានគោលបំណងនៃការថ្លែងសុន្ទរកថា និងបរិបទវប្បធម៌ ប្រវត្តិសាស្ត្រ និងនយោបាយ។[2543]

[2543] សាលក្រម *Akayesu* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៥៧, សាលក្រម *Nahimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ១០១១, ១០២២, ១០២៣, សាលដីកា *Nahimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៦៩៨-៧០៣, សាលក្រម *Bikindi* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ២៤៧, សាលក្រម *Nzabonimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ១៧៥៣, សាលដីកា *Nzabonimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ ១៣៤, សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣០០។

## ផ្នែកទី ១. រឿងក្ដី Nahimmana (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា)

២៤៨៨. រឿងក្ដី *Nahimana* ឬរឿងក្ដី *សារព័ត៌មាន* អាចឱ្យយើងកត់សម្គាល់អំពីសារៈសំខាន់នៃគោលបំណងរបស់សុន្ទរកថានៅក្នុងរឿងក្ដីនេះ។ មានការកត់សម្គាល់ថា ដើម្បីកំណត់ទំហំនៃទំនួលខុសត្រូវ "យុត្តិសាស្ត្រនេះកំណត់យកចេតនា គឺបានន័យថាគោលបំណងនៃសុន្ទរកថា ដោយព្យាយាមស្វែងយល់ ថាតើគោលបំណងដែលត្រូវសម្រេចមានភាពធម្មានុរូបឬទេ (ជាឧទាហរណ៍ ការស្វែងយល់អំពីប្រវត្តិសាស្ត្រ ការផ្សព្វផ្សាយព័ត៌មាន និងដំណឹង ទំនួលខុសត្រូវរបស់រដ្ឋអំណាចសាធារណៈ)"។[2544]

២៤៨៩. ចៅក្រមបានគូសបញ្ជាក់អំពីសារៈសំខាន់នៃបរិបទនៃការតាក់តែងសុន្ទរកថា ឬសេចក្ដីថ្លែងការណ៍ដូចតទៅនេះ៖ "យុត្តិសាស្ត្រស្ដីពីការញុះញង់តម្រូវឱ្យពិចារណាអំពីបរិបទ ចំពោះការវាយតម្លៃលើផលប៉ះពាល់ជាសក្ដានុពលនៃពាក្យពេចន៍ដែលជនជាប់ចោទបានថ្លែង។ [...] គេត្រូវគិតអំពីបរិបទដើម្បីកំណត់អំពីការប៉ះពាល់ជាសក្ដានុពលទៅលើសន្តិសុខជាតិ និងសណ្ដាប់ធ្នាប់សាធារណៈ" ។[2545]

២៤៩០. ឧទាហរណ៍ ពួកគាត់យល់ឃើញថា "អត្ថបទ និងការផ្សាយវិទ្យុមួយចំនួនដែលរដ្ឋអាជ្ញាបានចោទប្រកាន់មានខ្លឹមសារជាការរំលឹកប្រវត្តិសាស្ត្រ ការវិភាគនយោបាយ ឬការការពារមនសិការជាតិពន្ធុប្រឆាំងនឹងការបែងចែកបុព្វសិទ្ធិមិនស្មើភាពគ្នានៅប្រទេសរ៉្វាន់ដា"។[2546] ចំពោះកម្មវិធីផ្សាយវិទ្យុ Barayagwisa ដែលនៅក្នុងកម្មវិធីនេះ គាត់រៀបរាប់កាលពីកុមារភាពរបស់គាត់ អំពីរបៀបដែល

---

[2544] សាលក្រម *Nahimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ១០០១។

[2545] សាលក្រម *Nahimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ១០០៤-១០០៦។

[2546] សាលក្រម *Nahimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ១០១៩។

គាត់ត្រូវធ្វើការឱ្យពួកទុត្ស៊ី និងអំពីការដែលគាត់មិនមានសិទ្ធិញុំាបាយជាមួយពួកនេះ ពីព្រោះពួកគេជាមេ[2547] ចៅក្រមបានសន្និដ្ឋានថា៖

> "អង្គជំនុំជម្រះយល់ឃើញថា វាជាការចាំបាច់បំផុតក្នុងការបែងចែករវាងការពិភាក្សាអំពីមនសិការជាតិពន្ធុ និងការគាំទ្រឱ្យមានការស្អប់ខ្ពើមជាតិពន្ធុ។ ការអន្តរាគមរបស់កម្មវិធីវិទ្យុនេះជាផ្នែកមួយនៃមនសិការជាតិពន្ធុ គឺមិនមែនជាផ្នែកនៃការគាំទ្រឱ្យមានការស្អប់ខ្ពើមជាតិពន្ធុនោះទេ ទោះបីជាពាក្យពេចន៍ដ៏ខ្លាំងៗដែលពិតជាអាចនាំឱ្យអ្នកស្តាប់ចង់អនុវត្តតាមដើម្បីដោះស្រាយបញ្ហារើសអើងដែលគាត់បានលើកឡើងក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ឥទ្ធិពលនេះបណ្តាលមកពីតថភាពដែលគាត់ពិពណ៌នា គឺមិនមែនបណ្តាលមកពីពាក្យពេចន៍ផ្ទាល់របស់គាត់នោះទេ។ ពាក្យពេចន៍បែបនេះក្នុងបទអន្តរាគមន៍នេះមិនអាចកំណត់ថាជាការញុះញង់ទេ។ តាមការពិត បទអន្តរាគមន៍នេះជាប្រភេទនៃការនិយាយស្តីដែលត្រូវបានការពារដោយសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ"។[2548]

២៤៩១. ផ្ទុយទៅវិញ ចំពោះការផ្សាយវិទ្យុដែលបង្ហាញអំពីបញ្ជីឈ្មោះរបស់ជនសង្ស័យ ដោយប្រមានថាដោយសាររដ្ឋាភិបាលមិនការពារពួកគេគ្រប់គ្រាន់ ពួកគេត្រូវរៀបចំការការពារខ្លួនដោយផ្ទាល់ដើម្បីជៀសវាងការសម្លាប់រង្គាលឱ្យផុតពូជ ចៅក្រមបានពិចារណាថា កម្មវិធីផ្សាយទាំងនេះជាការញុះញង់ឱ្យប្រព្រឹត្តអំពើហិង្សា។[2549] ទាក់ទងទៅនឹងកម្មវិធីផ្សាយមួយទៀត ចៅក្រមបានចង្អុលបង្ហាញថា "*Habimana* អំពាវនាវទៅដល់អ្នកស្តាប់របស់ខ្លួនថា៖ "ចូរអ្នកនាំគ្នាមើលតែច្រមុះតូចរបស់វាហើយបន្ទាប់មកវាយបំបាក់ច្រមុះវាទៅ"។ ការកំណត់អត្តសញ្ញាណខ្មាំងតាមរយៈច្រមុះ និងញុះញង់ឱ្យវាយបំបាក់ច្រមុះនេះ ឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីចេតនាកម្ទេចក្រុមជាតិពន្ធុនេះ"។[2550]

---

[2547] សាលក្រម *Nahimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ៣៤៥។

[2548] សាលក្រម *Nahimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ១០២០។

[2549] សាលក្រម *Nahimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ១០២៨។

[2550] សាលក្រម *Nahimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ១០៣២។

## ផ្នែកទី ២. រឿងក្តី BIKINDI (តុលាការព្រហ្មទណ្ឌសម្រាប់ប្រទេសរ៉្វាន់ដា)

២៤៩២. មានការចោទប្រកាន់ទៅលើ *BIKINDI* ថាបាន "ចូលរួមក្នុងអំពើប្រល័យពូជសាសន៍ តាមរយៈការតាក់តែងចម្រៀងដែលណែនាំឱ្យមានសាមគ្គីភាពរវាងក្រុមជាតិពន្ធុអ៊ូទូ និងដែលលើកទឹកចិត្តឱ្យចងកំហឹងពូជសាសន៍ គឺឱ្យមានការវាយប្រហារទៅលើពួកទុត្ស៊ី និងសម្លាប់ពួកទាំងនេះ។ ចម្រៀងទាំងនេះត្រូវបានប្រើប្រាស់ក្នុងពេលបន្ទាប់មក នៅក្នុងយុទ្ធនាការឃោសនាសំដៅឱ្យចាត់ទុកពួកទុត្ស៊ីជាខ្មាំង និងសំដៅដាស់សតិអារម្មណ៍ និងញុះញង់អ្នកស្តាប់ឱ្យស្អប់ខ្ពើមពួកទុត្ស៊ី ហើយប្រព្រឹត្តអំពើហិង្សាទៅលើពួកគេ"។[2551]

២៤៩៣. ដើម្បីវិភាគចម្រៀងទាំងអស់នេះ ចៅក្រមបានគិតអំពី "បរិបទវប្បធម៌ ប្រវត្តិសាស្ត្រ និងនយោបាយ ដែលចម្រៀងទាំងអស់នេះត្រូវបានតាក់តែង និងផ្សព្វផ្សាយ"។[2552] ចៅក្រមបានសន្និដ្ឋានថា៖

> "ចម្រៀងដែលមានចំណងជើង Twasezereye Nanga Abahutu និង Bene Sebahinzi បានបំភ្លៃប្រវត្តិសាស្ត្រនៃប្រទេសរ្វាន់ដាក្នុងគោលបំណងទូន្មានឱ្យមានសាមគ្គីភាពរវាងពួកអ៊ូទូ និងសន្និដ្ឋានថាបទ Nanga Abahutu និងបទ Bene Sebahinzi ត្រូវបានតាក់តែងឡើងដើម្បីផ្សព្វផ្សាយឃោសនាឱ្យប្រឆាំងពួកទុត្ស៊ី និងលើកទឹកចិត្តឱ្យស្អប់ខ្ពើមជាតិពន្ធុនេះ។ នៅក្នុងបរិបទដែលមានភាពតានតឹងរវាងក្រុមជាតិពន្ធុកើនឡើងនៅប្រទេសរ្វាន់ដា នៅដើមទស្សវត្សឆ្នាំ១៩៩០ដែលនាំឱ្យមានអំពើប្រល័យពូជសាសន៍ បទ Twasezereye Nanga Abahutu ត្រូវបានប្រើប្រាស់នៅពេលក្រោយមកទៀត ដើម្បីផ្សព្វផ្សាយការឃោសនាប្រឆាំងពួកទុត្ស៊ី។ តាមរយៈខ្លឹមសារដ៏ឆាបឆ្លួននៃការអត្ថាធិប្បាយរបស់អ្នកកាសែតនៃវិទ្យុ RTLM ដែលអមការផ្សព្វផ្សាយសាចុះសាឡើងនៃបទចម្រៀងរបស់ BIKINDI និងការផ្តល់សក្ខីកម្មរបស់សាក្សី អង្គជំនុំជម្រះសន្និដ្ឋានថាបទចម្រៀងរបស់ BIKINDI ត្រូវបានប្រើប្រាស់ដោយវិទ្យុ RTLM ក្នុងក្របខណ្ឌយុទ្ធនាការឃោសនាសំដៅបង្កការមាក់ងាយ និងការស្អប់ខ្ពើមចំពោះប្រជាជនទុត្ស៊ី សំដៅញុះញង់អ្នកស្តាប់ឱ្យខឹងសម្បារនឹងពួកទុត្ស៊ី និងឱ្យប្រព្រឹត្តអំពើហិង្សាលើពួកគេ។ អង្គជំនុំជម្រះសន្និដ្ឋានថា ក្នុងឆ្នាំ១៩៩៤ ក្នុងប្រទេសរ្វ៉ាដា ចម្រៀងបីបទរបស់ BIKINDI ត្រូវបានប្រើប្រាស់ដោយមិនអាចប្រកែកបានដើម្បីបញ្ឆេះកំហឹងឈឺ

---

[2551] សាលក្រម *Bikindi* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ១៨៦។

[2552] សាលក្រម *Bikindi* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ២៤៧។

ចាប់ អារម្មណ៍ផ្ទុះចត់ និងការភ័យខ្លាចប្រឆាំងនឹងពួកទុត្ស៊ី។ ដោយគិតអំពីប្រពៃណីភាសានិយាយរបស់ប្រទេសរ៉្វាន់ដា និងអំពីប្រជាប្រិយភាពរបស់វិទ្យុ RTLM នៅសម័យនេះ អង្គជំនុំជម្រះបានសន្និដ្ឋានថា ការផ្សព្វផ្សាយចម្រៀងរបស់ BIKINDI មានឥទ្ធិពលរីកសាយលើអំពើប្រល័យពូជសាសន៍”។[2553]

២៤៩៤. ដោយហេតុថាមិនមានការបង្ហាញឱ្យឃើញថា BIKINDI ដើរតួនាទីណាមួយក្នុងការផ្សព្វផ្សាយ និងប្រើប្រាស់ចម្រៀងទាំងនេះ គាត់មិនត្រូវបានប្រកាសពិរុទ្ធភាពដោយផ្អែកលើមូលដ្ឋាននេះទេ[2554]។

## ផ្នែកទី ៣. <u>រឿងក្តី *NZABONIMANA* (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា)</u>

២៤៩៥. *NZABONIMANA* ត្រូវបានប្រកាសថាមានពិរុទ្ធភាពពីបទញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងមានពិរុទ្ធភាពអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមរយៈការញុះញង់។

២៤៩៦. ទាក់ទងនឹងការញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ចៅក្រមបានផ្តោតសំខាន់ទៅលើបរិបទផ្នែកភាសា៖

> “ដើម្បីកំណត់ថាតើសុន្ទរកថាមួយជាការញុះញង់“ដោយផ្ទាល់”ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ការពិចារណាចម្បង គឺត្រូវផ្តោតទៅលើខ្លឹមសារនៃពាក្យពេចន៍ដែលប្រើប្រាស់ក្នុងពេលជាក់លាក់ណាមួយ។ វប្បធម៌ និងភាពខុសគ្នាតិចតួចរបស់ភាសាគិនយ៉ារវ៉ាន់ដា ត្រូវតែយកមកគិត។ អង្គជំនុំជម្រះអាចពិនិត្យថាតើអ្នកស្តាប់យល់សុន្ទរកថានេះយ៉ាងដូចម្តេច ដើម្បីកំណត់សារជាក់លាក់របស់វាឱ្យបាន។”[2555]

---

[2553] សាលក្រម *Bikindi* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ២៦៤។

[2554] សាលក្រម *Bikindi* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៤២១។

[2555] សាលក្រម *Nzabonimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ១៧៥៣។

២៤៩៧. ទាក់ទងនឹងការផ្តន្ទាទោសគាត់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមរយៈការញុះញង់ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ជាពិសេសទៅលើធាតុសំខាន់នៃការចូលរួមជាសារធាតុនៃពាក្យពេចន៍របស់គាត់ ដែលបណ្តាលឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម រីឯខ្លឹមសារនៃពាក្យពេចន៍ទាំងនេះពុំមានសង្ស័យទេដែលថាវាជាសុន្ទរកថាជំរុញឱ្យស្អប់ខ្ពើម ហើយថែមទាំងជាសុន្ទរកថាដែលអំពាវនាវដោយផ្ទាល់ឱ្យប្រព្រឹត្តមនុស្សឃាត និងការសម្លាប់រង្គាលលើពួកទុត្ស៊ីឱ្យផុតពូជ។[2556]

## ផ្នែកទី ៤. រឿងក្តី *SESELJ* (តុលាការព្រហ្មទណ្ឌសម្រាប់អតីតប្រទេសយូហ្គោស្លាវី)

២៤៩៨. នៅក្នុងរឿងក្តី *Šešelj* ជនជាប់ចោទត្រូវបានចោទប្រកាន់ជាអាទិ៍ពីបទឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញ។ ដើម្បីបញ្ជាក់ថាតើគាត់អាចត្រូវបានចាប់ឱ្យទទួលខុសត្រូវពីបទបានញុះញង់ជនដែលល់សំខាន់ៗនៃឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញដែរឬទេ ចៅក្រមបានធ្វើការវិភាគជាពិសេសលើការផ្សព្វផ្សាយមនោគមវិជ្ជាលើជនជាប់ចោទតាមរយៈបច្ចេកទេសនៃការឃោសនាជាដើម និងបានធ្វើការវិភាគយ៉ាងលម្អិតលើសុន្ទរកថារបស់គាត់។[2557]

២៤៩៩. ទាក់ទងនឹងការវិភាគទីមួយ ចៅក្រមបានចង្អុលបង្ហាញថា "ទោះបីជាអង្គជំនុំជម្រះទទួលស្គាល់ដូចជនជាប់ចោទដែលថា ការឃោសនាមនោគមវិជ្ជា "ជាតិនិយម" តែឯកឯងមិនមានចរិតឧក្រិដ្ឋក៏ដោយ ក៏ផ្ទុយពីការអះអាងរបស់ជនជាប់ចោទ គឺអង្គជំនុំជម្រះជាអ្នកវិភាគ និងកំណត់ប្រភេទបទល្មើសទៅតាមច្បាប់ដែលអាចអនុវត្តបានសម្រាប់រឿងក្តីនេះ ទៅលើពាក្យពេចន៍ដែលជនជាប់ចោទបាននិយាយ និងផលប៉ះពាល់ជាសក្តានុពលរបស់ពាក្យពេចន៍ទាំងនេះទៅលើអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានរៀបរាប់នៅក្នុងដីកាចោទប្រកាន់ ដោយគោរពតាមបរិបទវប្បធម៌ប្រវត្តិសាស្ត្រ និងនយោបាយ។[2558]

---

[2556] សាលក្រម *Nzabonimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ១៧០៦-១៧១៨។

[2557] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ២៩៧-៣៤៣។

[2558] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣០០។

២៥០០. ទាក់ទងនឹងសុន្ទរកថារបស់ជនជាប់ចោទ ចៅក្រមបានដកចេញភ្លាមៗនូវសុន្ទរកថាដែលគ្រាន់តែថ្លែងឡើងដើម្បីផ្គត់ផ្គង់សង្គ្រាម និងនូវសុន្ទរកថាទាំងឡាយណាដែលទាក់ទងនឹងទឹកដី ហើយមិនមែនស្ថិតក្នុងវិសាលភាពភូមិសាស្ត្រនៃដីកាចោទប្រកាន់។[2559]

២៥០១. ចំពោះសុន្ទរកថាទីមួយដែលត្រូវបានសិក្សាវិភាគ *Šešelj* " ទំនងជាបានប្រកាសថា "ឆាប់ៗខាងមុខនឹងលែងមានសល់ជនជាតិពុស្តាហ្ស៊ីណាម្នាក់នៅក្នុងតំបន់នេះទៀតហើយ" និងប្រហែលជាបានប្រាប់ជាមុនដល់អ្នកកាន់សាសនាកាតូលិកក្នុងតំបន់នោះថា ពួកគេពុំមានអ្វីត្រូវខ្លាចក្រែងទៀតទេ ប្រសិនបើពួកគេមិនសហការជាមួយពួកពុស្តាហ្ស៊ី និងមិនចូលបក្សពួកជាមួយពួកគេ"។[2560] ពាក្យពេចន៍ទាំងនេះ ដែលត្រូវបានយកទៅសរសេរបន្តនៅក្នុងអត្ថបទសារព័ត៌មាន ពុំបានធ្វើឱ្យចៅក្រមភាគច្រើនជឿជាក់ថាជាពាក្យពេចន៍ដែលញុះញង់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម "ដោយហេតុថាបរិបទតម្រូវឱ្យយើងយល់ថា វាជាពាក្យពេចន៍ដែលថ្លែងឡើងក្នុងគោលបំណងពង្រឹងបក្សនយោបាយទៅវិញទេ"។[2561]

២៥០២. ទាក់ទងនឹងសុន្ទរកថាផ្សេងមួយទៀត សាក្សីមួយចំនួនបានរៀបរាប់ថា *Šešelj* បាននិយាយ "នៅចំពោះមុខសមាជិកដែលមានឋានៈខ្ពង់ខ្ពស់នៃកងកម្លាំងរបស់ជនជាតិស៊ែប៊ីថា "មិនឱ្យមានជនជាតិអ៊ូស្តាស្សាណាម្នាក់ចេញពីតំបន់វ៉ុលកូវ៉ា ដោយរស់រានមានជីវិតឡើយ"។ ចៅក្រមបានកត់សម្គាល់ថាសាក្សីមួយចំនួនបានពន្យល់ថាពាក្យ "អ៊ូស្តាស្សា" សំដៅលើទាហានជនជាតិក្រូអាត និងថាម្នាក់ៗអាចធ្វើការបកស្រាយលើពាក្យនេះរៀងៗខ្លួន។ សាក្សីដទៃទៀតបានពន្យល់ថា ខ្លួនបានឮការអំពាវនាវឱ្យពួកអ៊ូស្តាស្សាចុះចាញ់។ មានការគូសបញ្ជាក់ថា នៅពេលថ្លែងសុន្ទរកថានេះ *Šešelj*

---

[2559] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣០៣។

[2560] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣០៦។

[2561] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣០៧។

បានមកកាន់សមរភូមិដើម្បីចូលរួមក្នុងការប្រយុទ្ធមុនពេលទីក្រុងនេះដួលរលំបន្តិច។[2562] អាស្រ័យហេតុដូចនេះ ចៅក្រមបានសន្និដ្ឋានថា ៖

> "អង្គជំនុំជម្រះកត់សម្គាល់អំពីភាពផ្ទុយគ្នារវាងសាក្សីនានាព្រម ទាំងការដែលសាក្សីរដែលមួយចំនួនបានផ្តល់ចម្លើយមិនទៀងទាត់។ ការផ្តល់ចម្លើយមិនទៀងទាត់នេះបង្កឱ្យមានការមន្ទិលសង្ស័យទៅលើខ្លឹមសារជាក់លាក់នៃអ្វីដែលជនជាប់ចោទបាននិយាយ។ ក្នុងពេលនេះ ទោះបីជ្រើសរើសយកចម្លើយដែលចោទប្រកាន់ថាជនជាប់ចោទបាននិយាយក្រោមទម្រង់មួយដ៏ចម្រូងចម្រាសក៏ដោយ ក៏ចៅក្រមភាគច្រើន លើកលែងតែចៅក្រម Lattanzi ម្នាក់ប៉ុណ្ណោះដែលផ្តល់មតិជំទាស់ មិនអាចបដិសេធលទ្ធភាពសមហេតុសមផលមួយដែលថា សុន្ទរកថាទាំងនេះត្រូវបានថ្លែងឡើងក្នុងបរិបទជម្លោះក្នុងគោលបំណងផ្តល់កម្លាំងចិត្តដល់កងទ័ពខាងខ្លួន ជៀសជាងការអំពាវនាវឱ្យសម្លាប់មិនឱ្យសល់ម្នាក់ដោយគ្មានអាណិតអាសូរ (ពីព្រោះថាបើពុំធ្វើដូច្នេះទេ ការប្រកាសតាមឧគ្ឃោសនស័ព្ទអំពាវនាវឱ្យពួកអ៊ូស្តាស្សាចុះចាញ់នៅតាមផ្លូវនៃក្រុងវុកូវ៉ា ប្រហែលជាគ្មានន័យនោះទេ)"[2563]។

២៥០៣. ចៅក្រមបានពិចារណាលើសុន្ទរកថាមួយទៀតដែល *Šešelj* បានថ្លែង ដែលនៅក្នុងសុន្ទរកថានេះ គាត់ទំនងជាបានប្រើពាក្យពេចន៍ពាក់ព័ន្ធនឹងពួក "balijas" ដោយសុំឱ្យពួកគេទៅទិសខាងកើតដែលកន្លែងរបស់ខ្លួននៅទីនោះ។[2564] ម្យ៉ាងទៀត ជនជាប់ចោទបានបញ្ជាក់ថា ខ្លួនបានប្រើពាក្យ "pogani" ប្រឆាំងនឹងពួកអ៊ីស្លាមអភិរក្សនិយម និងអ្នកកាន់សាសនាអ៊ីស្លាមផ្សេងទៀតទាំងអស់ដែលពាក្យនេះមានន័យថា "សំរាម" ឬ "លាមក"។[2565]

២៥០៤. ក៏ប៉ុន្តែ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះបានចេញសេចក្តីសន្និដ្ឋានដូចតទៅនេះ៖

---

[2562] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣០៤-៣០១៧។

[2563] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣១៨។

[2564] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣២២។

[2565] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣២៥។

“លើកលែងតែចៅក្រម Lattanzi ដែលមានមតិផ្ទុយ ចៅក្រមភាគច្រើនមិនអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា នៅពេលអំពាវនាវឱ្យជនជាតិស៊ែប៊ី “បោសសម្អាត” “ពួក pogani” ឬ “balijas”ចេញពីប្រទេសបូស្នី ជនជាប់ចោទកំពុងអំពាវនាវឱ្យ “បោសសម្អាតជាតិពន្ធុ” ដែលមិនមែនជនជាតិស៊ែប៊ី” ចេញពីប្រទេសបូស្នី។ ជាក់ស្តែង ចៅក្រមភាគច្រើនយល់ឃើញថា ដោយយោងតាមបរិបទ ភ័ស្តុតាងដែលព្រះរាជអាជ្ញាផ្តល់ជូនមិនមានទឡ្ហីករណ៍គាំទ្រគ្រប់គ្រាន់ ដើម្បីដកចេញនូវលទ្ធភាពដែលថាតាមរយៈការអំពាវនាវនេះ ជនជាប់ចោទកំពុងតែចូលរួមជ្រោមជ្រែងសង្គ្រាមដោយផ្តល់កម្លាំងចិត្តដល់កងទ័ពស៊ែប៊ីទៅវិញនោះទេ។ លើសពីនេះទៅទៀត ចំពោះពាក្យពេចន៍ដែលរបាយការណ៍របស់នគរបាលបានកំណត់ថាជា “ការសន្ទនាខ្លីមួយ” ដែលព្រះរាជអាជ្ញាបានដាក់ឱ្យពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ពុំមានការបង្ហាញឱ្យឃើញថាសុន្ទរកថានេះជះឥទ្ធិពលបន្តិចណាសោះ។[2566]

២៥0៥. ទាក់ទងនឹងសុន្ទរកថាអំពាវនាវឱ្យជនជាតិក្រូអាតចេញពីប្រទេសស៊ែប៊ី ចៅក្រមបានយល់ឃើញថា គាត់បានអំពាវនាវយ៉ាងច្បាស់លាស់ឱ្យបណ្តេញ ឬផ្លាស់ទីជនជាតិក្រូអាតដោយបង្ខំចេញពីភូមិដ្ឋាន ប៉ុន្តែចៅក្រមក៏យល់ឃើញផងដែរថា ភ័ស្តុតាងមិនបានបង្ហាញឱ្យឃើញថាសុន្ទរកថានេះ ជាដើមហេតុនៃការចាកចេញរបស់ជនជាតិក្រូអាត ឬជាដើមហេតុនៃឃុបឃិតនាការធ្វើទុក្ខបុកម្នេញនោះទេ [2567]។ ចៅក្រមបានចេញការសន្និដ្ឋានដូចគ្នាលើសុន្ទរកថាដទៃទៀត ដែលអំពាវនាវឱ្យបណ្តេញជនជាតិក្រូអាត[2568] និងបានសន្និដ្ឋានផងដែរថា សុន្ទរកថាដែលជនជាប់ចោទបានថ្លែង មិនអាចជាអំពើជាក់ស្តែងនៃការញុះញង់នោះទេ។[2569]

២៥0៦. ដូច្នេះ នៅក្នុងរឿងក្តីនេះ ក៏ដូចជានៅក្នុងការជម្រះសេចក្តីផ្សេងៗទៀតដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ បរិបទនៃការថ្លែងសុន្ទរកថានេះ ត្រូវតែយកមកគិតជាចាំបាច់។ ក្នុងខណៈដែលក្នុងរឿងក្តី ដែលជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា មានបរិបទអំពើ

[2566] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២0១៦ កថាខណ្ឌ ៣២៨។

[2567] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២0១៦ កថាខណ្ឌ ៣៣៣។

[2568] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២0១៦ កថាខណ្ឌ ៣៣៤-៣៤២។

[2569] សាលក្រម *Šešelj* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២0១៦ កថាខណ្ឌ ៣៤៣។

ប្រល័យពូជសាសន៍យ៉ាងច្បាស់លាស់ និងក្នុងខណៈដែលសុន្ទរកថា ឬចម្រៀងរៀបរាប់យ៉ាងច្បាស់អំពីការរើសអើងជាតិពន្ធុ រីឯក្នុងរឿងក្តី *Šešelj* វិញ សុន្ទរកថាប្រឆាំងនឹងពួកក្រូអាតត្រូវបានថ្លែងឡើង ក្នុងពេលដែលការប្រយុទ្ធកំពុងតែកើតឡើងរវាងកងកម្លាំងក្រូអាត និងកងកម្លាំងស៊ែប៊ី។

២៥០៧. អាស្រ័យហេតុដូចនេះ អង្គជំនុំជម្រះត្រូវតែវិភាគខ្លឹមសារនៃសុន្ទរកថាទាំងអស់ដោយគិតអំពីបរិបទប្រវត្តិសាស្ត្រ នយោបាយ វប្បធម៌ និងភាសា។ ក្នុងចក្ខុវិស័យនេះ ការគិតអំពីបរិបទជម្លោះប្រដាប់អាវុធជាមួយនឹងប្រទេសវៀតណាមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ជាការចាំបាច់ខានមិនបាន។[2570]

## សេចក្តីសន្និដ្ឋាន

២៥០៨. សព្វថ្ងៃនេះ ខៀវ សំផន ត្រូវបានផ្តន្ទាទោសដោយអង្គជំនុំជម្រះតុលាការកំពូលឱ្យជាប់ពន្ធនាគារមួយជីវិតក្នុងសំណុំរឿង ០០២/០១។ ដូច្នេះ បញ្ហាប្រឈមនៃការការពារក្តីគាត់មិនស្ថិតត្រង់សេចក្តីសង្ឃឹមមិនច្បាស់លាស់ ថាគាត់នឹងត្រូវបានដោះលែងនោះទេ។

២៥០៩. ក៏ប៉ុន្តែ ខៀវ សំផន ប្រាថ្នាចង់ឱ្យមានការនិយាយអំពីច្បាប់ គឺគ្រាន់តែចង់និយាយពីច្បាប់ដោយគោរពតាមគោលការណ៍ដូចដែលមានរៀបរាប់លម្អិតនៅខាងដើមនៃសារណានេះ គឺបានន័យថាត្រូវដកចេញនូវអង្គហេតុទាំងឡាយណាដែលត្រូវបានបញ្ជូនមកចំពោះមុខអង្គជំនុំជម្រះដោយខុសច្បាប់ ហើយអនុវត្តតែតាមច្បាប់ដែលមានជាធរមាននៅសម័យអង្គហេតុតែប៉ុណ្ណោះ។ ជំនឿជឿជាក់ដោយឥស្សរៈចិត្តរបស់អង្គជំនុំជម្រះមិនអាច "តទល់នឹងវិធានគ្រប់គ្រងភ័ស្តុតាងដែលអាចអនុវត្តបាន និងលក្ខខណ្ឌតម្រូវដ៏តឹងរ៉ឹងមិនផ្អែកលើអារម្មណ៍នៃវិធាននេះ"[2571]។

២៥១០. ដោយហេតុថា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចបានបង្ហាញក្នុងពេលជំនុំជម្រះសេចក្តី មិនត្រូវគ្នាទាល់តែសោះទៅនឹងឧត្តមគតិរបស់គាត់ លោក ខៀវ សំផន សូមបដិសេធពេញ

---

[2570] សូមមើលផ្នែកខាងលើ មាតិកា ២ ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ និងសូមមើលផងដែរ កថាខណ្ឌ ២២៣៥-២២៥២។

[2571] សូមមើលផ្នែកខាងលើ កំណត់សម្គាល់ជើងទំព័រ ៦០៧។

ទំហឹងថា គាត់មិនដែលមានចេតនាប្រព្រឹត្ត ឬចូលរួមក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលចោទប្រកាន់នោះទេ។

## អាស្រ័យហេតុនេះ

២៥១១. ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង មេត្តា៖

- **អនុវត្ត**វិធានច្បាប់ដោយមិនលម្អៀង
- **កត់សម្គាល់**ថា អង្គជំនុំជម្រះមិនបានទទួលត្រឹមត្រូវតាមនីតិវិធីនូវផ្នែកមួយចំនួននៃដីកាបញ្ជូនរឿងឱ្យជំនុំជម្រះ ដែលតាមរយៈនេះ ខៀវ សំផន ត្រូវបានបញ្ជូនមកជំនុំជម្រះដោយខុសច្បាប់ និង**ប្រកាស**ថាខ្លួន**ពុំមានយុត្តាធិការ**ក្នុងការជំនុំជម្រះលើផ្នែកទាំងនេះទេ
- **លើកលែង**លោក ខៀវ សំផន ឱ្យរួចផុតពីការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងរូបគាត់។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>រាជធានីភ្នំពេញ | |